ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

គម្រោងច្បាប់
និងបទប្បញ្ញត្តិអនុវត្តចំពោះ
គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ



បច្ចុប្បន្នកម្ម ឆ្នាំ២០២១



ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

ក្រមច្បាប់

និងបទប្បញ្ញត្តិអនុវត្តចំពោះ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

បច្ចុប្បន្នកម្ម ឆ្នាំ២០២១

អារម្ភកថា



វិស័យធនាគារ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចព្រោះវិស័យនេះ អាចកៀរគរធនធានហិរញ្ញវត្ថុដែលទំនេរសម្រាប់បម្រើឱ្យតម្រូវការក្នុងផលិតកម្មនិងអាជីវកម្ម។ ដើម្បីផ្សារភ្ជាប់ការសន្សំជាមួយការវិនិយោគនិងកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យធនាគារត្រូវតែដើរទន្ទឹមគ្នាជាមួយការអភិវឌ្ឍវិស័យឯកជន សម្រាប់ទ្រទ្រង់ដល់ការបង្កើនល្បឿនកំណើនសេដ្ឋកិច្ចដែលត្រូវបានចាត់ទុកថាជាមធ្យោបាយចម្បងសម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ចាប់តាំងពីទស្សវត្សរ៍ឆ្នាំ១៩៩០ ក្របខ័ណ្ឌបទប្បញ្ញត្តិចំពោះវិស័យធនាគារត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ ក្នុងរយៈពេលនោះ ប្រកាស បទបញ្ជា សារាចរណែនាំផ្សេងៗត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ដើម្បីសម្រួលឱ្យដំណើរការវិស័យនេះ ប្រព្រឹត្តទៅដោយរលូន។ ជាលទ្ធផល ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យធនាគារនិងហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងតាមរយៈអន្តរការិយកម្មធនាគារ ដែលបានកៀរគរធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រវិស័យផលិតកម្ម និងសេវាកម្ម។ នេះបញ្ជាក់ឱ្យឃើញថា ជំនឿទុកចិត្តរបស់សាធារណជនចំពោះវិស័យធនាគារនៅកម្ពុជា មានការកើនឡើងជាបន្តបន្ទាប់។

ធនាគារជាតិនៃកម្ពុជា យល់ឃើញថា ការរៀបចំចងក្រងកម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនេះឡើង មានសារៈសំខាន់ណាស់សម្រាប់ធនាគារិក សវនករ និស្សិត និងអ្នកវិនិយោគដែលមានបំណងចង់ស្វែងយល់ពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធដែលបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តកន្លងមក ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ដើម្បីឱ្យស្របតាមការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ។

ខ្ញុំសង្ឃឹមនិងជឿជាក់ថា ឯកសារនេះពិតជាផ្តល់នូវផលប្រយោជន៍ជាអតិបរមា ចំពោះធនាគារិក សវនករ និស្សិត និងវិនិយោគិន ក្នុងការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារដែលបានខិតខំរៀបចំចងក្រងឯកសារនេះឡើង។

ទេសាភិបាល

ជា.ចាន់តូ

FORWARD

The banking sector in Cambodia is playing an important role in contributing to economic development through the mobilization and allocation of previously unproductive financial resources to fulfill the financial needs of the manufacturing and services sectors.

Matching savings to investment and economic growth, the banking sector must develop in line with private sector development in order to sustain the economic growth, pace, a measure regarded by Royal Government of Cambodia as essential for poverty reduction.

Since the 1990s, a legal framwork for the banking sector has been established. At that time Prakas, directives, circulars and regulations were issued to facilitate the smooth functioning of this sector. As a result, in recent years the banking and financial sectors have developed rapidly, reflected through the banking intermediation of mobilizing financial resources to support the manufacturing and services sectors. This is clear evidence of the subsequent increase of public confidence in Cambodia's banking and financial sectors.

We at the National Bank of Cambodia understand that a compilation of laws and regulations applicable to banks and financial institutions is essential for bankers, auditors, students and investors who are willing to get a better understanding of the comprehensive and centralized legal framework and regulations for Cambodia's banking sector. As for the evolution of the banking sector, all laws and regulations have been issued and updated by the National Bank of Cambodia into the compilation of laws and regulations applicable to banks and financial institutions.

I hope and believe that this document truly provides considerable benefits to bankers, auditors, students, and investors in their research studies aimed at a better understanding of legal framework and regulations of the banking sector in Cambodia.

I would like to thank the team for their hard work in compiling this document.

The Governor
Chea Chanto

សេចក្តីថ្លែងអំណរគុណ

"កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ត្រូវបានរៀបចំឡើងតាមគំនិតផ្តួចផ្តើមរបស់លោក Michel DABADIE អតីតជំនាញការប្រចាំនៅធនាគារជាតិនៃកម្ពុជា ដោយមានការគាំទ្រដោយ លោកជំទាវ **ជា សិរី** អគ្គនាយកបច្ចេកទេស នៃធនាគារជាតិនៃកម្ពុជា។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងមន្ត្រី-បុគ្គលិកនៃនាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការរៀបចំឯកសារនេះសម្រេចបានជាស្តាពរ។

អគ្គនាយកដ្ឋានត្រួតពិនិត្យ

កំណត់សម្គាល់សម្រាប់ការប្រើប្រាស់
កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាឯកសារសម្រាប់សាធារណជន ជាពិសេសចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការស្វែងយល់និងអនុវត្តច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងវិស័យធនាគារនៅកម្ពុជា។ ឯកសារនេះត្រូវបានចងក្រងដំបូងនៅក្នុងឆ្នាំ២០០៨ បន្ទាប់មកក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០១១ និងឆ្នាំ២០១៦ ហើយការចងក្រងឡើងវិញក្នុងឆ្នាំ២០២១នេះ គឺជាការធ្វើបច្ចុប្បន្នកម្មលើកទី៣។ ការធ្វើបច្ចុប្បន្នលើកនេះបានដាក់បញ្ចូលនូវបទប្បញ្ញត្តិថ្មីៗដែលបានដាក់ចេញឱ្យប្រើប្រាស់ចាប់ពីឆ្នាំ២០១៧ រហូតដល់ពាក់កណ្តាលឆ្នាំ២០២១ និងដកចេញនូវបទប្បញ្ញត្តិមួយចំនួនដែលត្រូវបាននិរាករណ៍ ព្រមទាំងដាក់បញ្ចូលបទប្បញ្ញត្តិដែលបានកែសម្រួល សំដៅផ្តល់ជូនអ្នកអាននូវព័ត៌មានគ្រប់ជ្រុងជ្រោយនិងមានបច្ចុប្បន្នភាព។

កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បច្ចុប្បន្នកម្មឆ្នាំ២០២១ ត្រូវបានបែងចែកជា ៣ ផ្នែកធំៗគឺ ១/- សេចក្តីផ្តើម ២/- ខ្លឹមសារច្បាប់និងបទប្បញ្ញត្តិ និង ៣/- ឧបសម្ព័ន្ធ។

<u>ការណែនាំលើផ្នែកទី១៖ សេចក្តីផ្តើម</u>

សេចក្តីផ្តើម រួមបញ្ចូលនូវខ្លឹមសារមួយចំនួន ដូចជា ១/- អារម្ភកថា ២/- សេចក្តីថ្លែងអំណរគុណ ៣/- កំណត់សម្គាល់សម្រាប់ការប្រើប្រាស់កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ៤/- មាតិកា។

<u>ការណែនាំលើផ្នែកទី២៖ ខ្លឹមសារច្បាប់និងបទប្បញ្ញត្តិ</u>

ច្បាប់និងបទប្បញ្ញត្តិដែលមាននៅក្នុងឯកសារនេះ ត្រូវបានបែងចែកជា ៨ ផ្នែកធំៗ ដូចខាងក្រោម៖

ក. **ច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖** ផ្នែកនេះបង្ហាញពីច្បាប់សំខាន់ៗដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ខ. **បទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនានារបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ការស្នើសុំប្រកបអាជីវកម្មជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

គ. **បទប្បញ្ញត្តិអនុវត្តចំពោះធនាគារពាណិជ្ជ និង ធនាគារឯកទេស៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិប្រុងប្រយ័ត្ន វិធានគណនេយ្យនិងរបាយការណ៍ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត សម្រាប់ធនាគារពាណិជ្ជនិងធនាគារឯកទេស។

ឃ. **បទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិប្រុងប្រយ័ត្ននិងវិធានគណនេយ្យនិងរបាយការណ៍ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ង. **បទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ និងគ្រឹះស្ថានផ្សេងទៀត។

ច. **ហ្វាស៊ីលីធីរបស់ធនាគារជាតិនៃកម្ពុជា៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងហ្វាស៊ីលីធីដែលធនាគារជាតិនៃកម្ពុជាផ្តល់ឱ្យចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ឆ. **ប្រព័ន្ធទូទាត់ ជាត់ទាត់ និង ផ្ទេរប្រាក់ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖** ផ្នែកនេះបង្ហាញពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ ជាត់ទាត់ និងផ្ទេរប្រាក់ មូលប្បទានបត្រ និងកម្រៃសេវាចំពោះការប្រើប្រាស់សេវាទាំងនោះ។

ជ. **ការគ្រប់គ្រងក្រដាសប្រាក់៖** ផ្នែកនេះបង្ហាញពីព័ត៌មានផ្សេងៗដូចជា សេចក្តីជូនដំណឹងពាក់ព័ន្ធនឹងក្រដាសប្រាក់។

កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ភាគច្រើនត្រូវបានចងក្រងទៅតាមលំដាប់លំដោយនៃកាលបរិច្ឆេទនៃការដាក់ឱ្យអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនេះ ប៉ុន្តែ ក្នុងករណីដែលប្រកាស ឬសារាចរណែនាំ ឬសេចក្តីជូនដំណឹងផ្សេងៗដែលមានការពាក់ព័ន្ធគ្នាបទប្បញ្ញត្តិទាំងនេះត្រូវបានរៀបចំបន្តបន្ទាប់គ្នាដោយមិនស្ថិតតាមលំដាប់លំដោយនៃកាលបរិច្ឆេទឡើយ ដើម្បីសម្រួលដល់ការស្វែងរកព័ត៌មានដែលពាក់ព័ន្ធគ្នា។

សម្រាប់គោលបំណងនៃការរៀបចំឯកសារនេះ ឃ្លាមួយចំនួនត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការស្វែងយល់បទប្បញ្ញត្តិទាំងនោះ។ ឃ្លាទាំងនោះ រួមមាន៖

- **"ត្រូវបានជំនួសដោយប្រកាស.....”** មានន័យថា ខ្លឹមសារនៃចំណុច ឬប្រការនេះ ត្រូវបានជំនួសដោយខ្លឹមសារនៃប្រកាសផ្សេងទៀត ដូច្នេះ សូមរកមើលខ្លឹមសារដែលពាក់ព័ន្ធនៅក្នុងប្រកាសផ្សេងនោះ។
- **"ប្រការ...ថ្មី ចែងដូចខាងក្រោម៖”** មានន័យថា ចំពោះប្រការមួយចំនួនដែលត្រូវបានជំនួសទាំងស្រុងដោយប្រការថ្មីនៃប្រកាសណាមួយ នោះខ្លឹមសារថ្មីត្រូវបានដកស្រង់ចេញពីប្រកាសថ្មីនិងត្រូវបានដាក់ពីខាងក្រោមឃ្លានេះ ចំណែកឯខ្លឹមសារដើមត្រូវបានដកចេញ។
- **"(ផុតរយៈពេលអនុវត្ត)”** មានន័យថា ខ្លឹមសារនៃប្រការ ឬឃ្លានេះ មិនតម្រូវឱ្យអនុវត្តទៀតទេ ដោយសារខ្លឹមសារដើមមានកំណត់រយៈពេលឬកាលបរិច្ឆេទច្បាស់លាស់ឱ្យគ្រឹះស្ថានអនុវត្ត ប៉ុន្តែកាលបរិច្ឆេទនោះបានកន្លងផុតហើយ។

<u>ការណែនាំលើផ្នែកទី៣៖ ឧបសម្ព័ន្ធ</u>

ឧបសម្ព័ន្ធនៃកម្រងច្បាប់និងបទប្បញ្ញត្តិនេះ ត្រូវបានបែងចែកជា ៣ តារាង ហើយតារាងនីមួយៗបង្ហាញពីព័ត៌មានផ្សេងៗគ្នា ដូចខាងក្រោម៖

១. **តារាងបទប្បញ្ញត្តិពីឆ្នាំ២០១៧ ដល់ ពាក់កណ្តាលឆ្នាំ២០២១៖** តារាងនេះបង្ហាញពីបទប្បញ្ញត្តិទាំងឡាយដែលត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៧ ដល់ពាក់កណ្តាលឆ្នាំ២០២១។

២. **តារាងបទប្បញ្ញត្តិដែលកែសម្រួលលើបទប្បញ្ញត្តិផ្សេងៗ៖** តារាងនេះបង្ហាញពីបទប្បញ្ញត្តិទាំងឡាយណាដែលកែសម្រួលប្រការមួយចំនួននៃបទប្បញ្ញត្តិដើម។ បទប្បញ្ញត្តិទាំងនេះមិនត្រូវបានដាក់ចូលទៅក្នុងកម្រងច្បាប់និងបទប្បញ្ញត្តិនេះទេ ដោយសារខ្លឹមសារសំខាន់នៃបទប្បញ្ញត្តិទាំងនេះត្រូវបានដកស្រង់យកទៅដាក់ក្នុងបទប្បញ្ញត្តិពាក់ព័ន្ធរួចហើយ។

៣. **តារាងបទប្បញ្ញត្តិត្រូវបាននិរាករណ៍ និងបទប្បញ្ញត្តិនៅមានប្រសិទ្ធភាពអនុវត្ត៖** តារាងនេះត្រូវបានបែងចែកជា ២ ជួរឈរ សម្រាប់ចងក្រងបទប្បញ្ញត្តិដែលធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តកន្លងមក ប៉ុន្តែត្រូវបាននិរាករណ៍ដោយបទប្បញ្ញត្តិថ្មី។ ឧទាហរណ៍ បទប្បញ្ញត្តិពាក់ព័ន្ធនឹងអត្រាប្រាក់បម្រុងកាតព្វកិច្ច ត្រូវបានដាក់ឱ្យអនុវត្តដោយបទប្បញ្ញត្តិថ្មីៗជាបន្តបន្ទាប់ ហើយបទប្បញ្ញត្តិចុងក្រោយ ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០២០ ដូច្នេះ បទប្បញ្ញត្តិចាស់ៗទាំងនោះត្រូវបានដាក់បញ្ចូលគ្នាក្នុងជួរឈរខាងឆ្វេងនៃតារាង ចំណែកបទប្បញ្ញត្តិពាក់ព័ន្ធនឹងអត្រាប្រាក់បម្រុងកាតព្វកិច្ចដែលនៅមានសុពលភាពអនុវត្ត ត្រូវបានដាក់នៅក្នុងជួរឈរខាងស្តាំ។

ក្នុងករណីមានភាពមិនស្របគ្នាណាមួយដែលអាចកើតឡើងរវាងខ្លឹមសារនៃអត្ថបទដើមនិងខ្លឹមសារនៅក្នុងឯកសារនេះ ខ្លឹមសារនៅក្នុងអត្ថបទដើមមានអាទិភាព។ ខ្លឹមសារជាភាសាអង់គ្លេសត្រូវបានបកប្រែដោយមន្ត្រី-បុគ្គលិករបស់ធនាគារជាតិនៃកម្ពុជាយោងលើខ្លឹមសារច្បាប់ដើមជាភាសាខ្មែរ។ ក្នុងករណីដែលការបកប្រែនៅក្នុងកម្រងនេះជាភាសាអង់គ្លេសមិនស្របគ្នាទៅនឹងច្បាប់ដើមជាភាសាខ្មែរ សូមប្រើប្រាស់ខ្លឹមសារភាសាខ្មែរជាគោល។

ប្រសិនបើ លោក-លោកស្រី ប្រទះឃើញកំហុសណាមួយនៅក្នុងឯកសារនេះ សូម លោក-លោកស្រី ទំនាក់ទំនងមកក្រុមការងាររបស់យើងខ្ញុំ តាមរយៈសារអេឡិចត្រូនិក prrt@nbc.org.kh។

មាតិកា

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

កំណត់សម្គាល់សម្រាប់ការប្រើប្រាស់កម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ក. ច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ១
- ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ២៧
- ព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ ៣១
- ព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៣៩
- ព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ៧៣
- ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ១៩៩
- ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ ៣១៣

ខ. បទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- **ធ៧-៩៧-១៩៧ ប្រ.ក** ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ — ប្រកាសស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៣២៨
- **ធ៧-០៨-១៩៣ ប្រ.ក** ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ — ប្រកាសស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារ ...៣៣៣
- **ធ៧-០១៦-១១៧ ប្រ.ក** ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ — ប្រកាសស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៣៣៦
- **ធ៧-០១៦-០០៣ ស.រ.ច.ណ.ន** ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ — សារាចរណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ... ៣៣៨
- **ធ៧-០១-១៣៦ ប្រ.ក** ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ — ប្រកាសស្តីពី ប្រាក់តម្កល់ធានាលើដើមទុន ៣៤១
- **ធ៧-០០-០៤ ប្រ.ក** ថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ ៣៤៣
- **ធ៧-០០-០៥ ប្រ.ក** ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ..... ៣៦៣
- **ធ៧-០៧-១៦៣ ប្រ.ក** ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣៨០
- **ធ៧-០០-០៦ ប្រ.ក** ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣៨៣
- **ធ៧-០១៧-៣២៦ ប្រ.ក** ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ — ប្រកាសស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ៤០០
- **ធ៩-០៩-២៣០ ប្រ.ក** ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់ ៤០៩
- **ធ៩-០២១-០៥២ ប្រ.ក** ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ — ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ៤២០
- **ធ៧-០១១-២៤១ ប្រ.ក** ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ — ប្រកាសស្តីពី អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ៤២៥

- **ធ៧-០១១-២៤២ ប្រ.ក** ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុន
  ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ភតិសន្យាហិរញ្ញវត្ថុ ៤២៨
- **ធ៩-០១០-១៥១ ប្រ.ក** ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី ៤៤៣
  ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០
- **ធ១៤-០១៧-១៦១ ប្រ.ក** ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់
  ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ សងប្រាក់ ៤៥៤

គ. បទប្បញ្ញត្តិអនុវត្តចំពោះធនាគារពាណិជ្ជ និង ធនាគារឯកទេស

គ.១. បទប្បញ្ញត្តិប្រុងប្រយ័ត្ន

- **ធ៩-៩៨-៤១៤ ប្រ.ក** ប្រកាសស្តីពី ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់
  ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨ ក្នុងស្រុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៦៩
- **ធ៧-០០-៤៦ ប្រ.ក** ប្រកាសស្តីពី អនុបាតសាធនភាពរបស់ធនាគារ ៤៧១
  ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០
- **ធ៧-០១-១៣៧ ប្រ.ក** ប្រកាសស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ ៤៧៥
  ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១
- **ធ៧-០២០-៤១៧ ឆ.ត** សេចក្តីណែនាំស្តីពីការគណនាព័ត៌មានហិរញ្ញវត្ថុបន្ថែម
  ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ និងនិយមន័យ "សម្ព័ន្ធញាតិ"..... ៤៧៧
- **ធ៧-០១-១៨៦ ប្រ.ក** ប្រកាសស្តីពី អចលនទ្រព្យរបស់ធនាគារ ៤៨១
  ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១
- **ធ៧-០៦-២២៦ ប្រ.ក** ប្រកាសស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់
  ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៨៣
- **ធ៧-០៩-២១៦ ប្រ.ក** ប្រកាសស្តីពី ការផ្តល់របាយការណ៍ឥណទានធំ និងពិនិត្យ
  ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ តាមដានហានិភ័យឥណទានប្រមូលផ្តុំ ៤៨៧
- **ធ៧-០៩-០៧៥ ប្រ.ក** ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់
  ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៩១
- **ធ៧-០១៥-១៧៧ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ច
  ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ លើ (១) ប្រាក់បញ្ញើអតិថិជន (២) ប្រាក់បញ្ញើធនាគារអនិវាសជន
  និង (៣) ប្រាក់កម្ចីអនិវាសជន ៥០៨

- **ធ៧-០២០-២៣០ ប្រ.ក** ប្រកាសស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់
  ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥១០
- **ធ៧-០១០-១៨២ ប្រ.ក** ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ៥១២
  ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០
- **ធ៧-០១១-០០១ ស.រ.ច** សារាចរស្តីពី ការអនុវត្តប្រកាសស្តីពីការគណនាមូលនិធិ
  ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ផ្ទាល់សុទ្ធរបស់ធនាគារ ៥១៦

គ.២. ទិដ្ឋានគណនេយ្យ និង របាយការណ៍

- **ធ៧-០៤-២០៤ ប្រ.ក** ប្រកាសស្តីពី ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
  ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥២០
- **ធ៧-០៦-២១១ ប្រ.ក** ប្រកាសស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍របស់ធនាគារ
  ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ពាណិជ្ជ និងធនាគារឯកទេស ៥៣៨
- **ធ៧-០១២-០០៤ ស.ក.ណ.ន** សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេល សម្រាប់
  ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានធនាគារ ៥៤០
- **ធ៦-០២១-១៨៤ ប្រ.ក** ប្រកាសស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ.. ៥៤១
  ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១

គ.៣. បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

- **ធ៧-០១-១៨៧ ប្រ.ក** ប្រកាសស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ ៥៤៣
  ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១
- **ធ៥-០១-២០១ ប្រ.ក** ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់ជាគោលសម្រាប់
  ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១ បុនហិរញ្ញប្បទាន ៥៤៥
- **ធ៧-០៣-០០២ ស.រ.ណ.ន** សារាចរណែនាំស្តីពី ការផ្តល់និងការថតចម្លងឯកសារ
  ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ នៅពេលត្រួតពិនិត្យដល់ទីកន្លែង ៥៤៦
- **ធ៧-០៤-០៣៧ ប្រ.ក** ប្រកាសស្តីពី ការទូទាត់សងជាមុននូវប្រាក់ថ្លៃជួលនិង
  ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ ភតិសន្យា ៥៤៧
- **ធ៧-០៤-០០៦ ប្រ.ក** ប្រកាសស្តីពី ការទូទាត់ភាគលាភជាមុន ៥៤៩
  ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤

ឃ. បទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឃ.១. បទប្បញ្ញត្តិប្រុងប្រយ័ត្ន

- **ធ៧-០១-១១៥ ប្រ.ក** ប្រកាសស្តីពី ការគណនាការប្រាក់ចំពោះឥណទាន
  ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១ មីក្រូហិរញ្ញវត្ថុ ៥៥០
- **ធ៧-០២-៤៥ ប្រ.ក** ប្រកាសស្តីពី ការរក្សាប្រាក់បម្រុងកាតព្វកិច្ចចំពោះគ្រឹះស្ថាន
  ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ មីក្រូហិរញ្ញវត្ថុ ៥៥១
- **ធ៧-០២-៤៨ ប្រ.ក** ប្រកាសស្តីពី អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន
  ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ មីក្រូហិរញ្ញវត្ថុ ៥៥៣
- **ធ៧-០៧-១៣២ ប្រ.ក** ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន
  ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ មីក្រូហិរញ្ញវត្ថុ ៥៥៤
- **ធ៧-០៧-១៣៣ ប្រ.ក** ប្រកាសស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូ
  ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ហិរញ្ញវត្ថុ ៥៥៧

ឃ.២. វិធានគណនេយ្យ និង របាយការណ៍

- **ធ៧-០២-៤៧ ប្រ.ក** ប្រកាសស្តីពី តម្រូវការរបាយការណ៍សម្រាប់ប្រតិបត្តិករ
  ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីនិងគ្រឹះស្ថាន
  មីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ៥៥៩
- **ធ៧-០៦-២១២ ប្រ.ក** ប្រកាសស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍របស់គ្រឹះស្ថាន
  ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ មីក្រូហិរញ្ញវត្ថុ ៥៦១

ង. បទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ង.១. បទប្បញ្ញត្តិប្រុងប្រយ័ត្ន

- **ធ៧-០២-២០៣ ប្រ.ក** ប្រកាសស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវ
  ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២ បន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ..... ៥៦៣
- **ធ៧-០៧-១៣៤ ប្រ.ក** ប្រកាសស្តីពី ការត្រួតពិនិត្យស្ថានភាពចំហាសុទ្ធនៃរូបិយប័ណ្ណ
  ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៦៧
- **ធ៧-០២០-៨៦៨ ធ.ត** សេចក្តីជូនដំណឹងស្តីពី ករណីលើកលែងកម្រិតកំណត់លើ
  ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពចំហាសុទ្ធចំពោះរូបិយវត្ថុជាតិ..... ៥៦៩

- **ធ៧-០១១-២៤៣ ប្រ.ក** ប្រកាសស្តីពី តម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់
  ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៧១
- **ធ៧-០១២-១៨៤ ប្រ.ក** ប្រកាសស្តីពី កម្រិតកំណត់នៃការកាន់កាប់ និងជួញដូរ
  ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ មូលបត្ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៧៤
- **ធ៧-០១២-១៨៥ ប្រ.ក** ប្រកាសស្តីពី វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យ
  ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើជា
  ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ៥៧៧
- **ធ៧-០១៥-៣៤៩ ប្រ.ក** ប្រកាសស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព ៥៨០
  ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥
- **ធ៧-០២០-០០៣ ស.រ.ណ.ន** សារាចរណែនាំស្តីពី សេចក្តីពន្យល់បន្ថែមទៅលើឧបសម្ព័ន្ធ ២
  ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ នៃប្រកាសស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព ៦០៣
- **ធ៧-០១៧-៣០១ ប្រ.ក** ប្រកាសស្តីពី ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពរបស់
  ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦១១
- **ធ៧-០១៧-៣៥៤ ប្រ.ក** ប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និង
  ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ សំវិធានធនលើអ៊ីមែរមិន ៦២២
- **ធ៧-០១៨-០០១ ស.រ.ច.ណ** សារាចរណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់
  ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន ៦៥២
- **ធ៧-០២០-១៣៤ ធ.ត** សេចក្តីជូនដំណឹងស្តីពី សេចក្តីបញ្ជាក់បន្ថែមលើការធ្វើ
  ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ សំវិធានធនចំពោះហ្វាស៊ីលីធីរបស់គ្រឹះស្ថានធនាគារ
  និងហិរញ្ញវត្ថុដែលរក្សានៅធនាគារជាតិនៃកម្ពុជា ៦៥៦
- **ធ៧-០១៨-០៦៨ ប្រ.ក** ប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថាន
  ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារនិងហិរញ្ញវត្ថុ ៦៥៧
- **ធ៧-០១៨-០០១ ស.ក.ណ** សារាចរណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការកំណត់
  ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦៧០
- **ធ៧-០២០-០០២ ស.រ.ណ.ន** សារាចរណែនាំបន្ថែមស្តីពី ការអនុវត្តប្រកាសស្តីពីការកំណត់
  ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦៧១

១.២. អតិបាលកិច្ច

- **ធ៧-០៨-២១១ ប្រ.ក** ប្រកាសស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិង
  ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ហិរញ្ញវត្ថុ ៦៧៨
- **ធ៧-០៨-២១២ ប្រ.ក** ប្រកាសស្តីពី លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់
  ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
  ដែលមានអាជ្ញាបណ្ណ ៦៨៨
- **ធ៧-០១០-១៧២ ប្រ.ក** ប្រកាសស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ
  ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ និងហិរញ្ញវត្ថុ ៦៩៦

១.៣. ព័ត៌មានឥណទាន វិធានគណនេយ្យ និង របាយការណ៍

- **ធ៧-០០-៥០ ប្រ.ក** ប្រកាសស្តីពី ដំណើរការគណនេយ្យកម្មសម្រាប់ប្រតិបត្តិការ
  ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ រូបិយប័ណ្ណ ៧២០
- **ធ៧-០៥-០៣ ស.រ.ណ.ន** សារាចរណែនាំស្តីពី ការអនុវត្តគណនេយ្យរូបិយវត្ថុចម្រុះ
  ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥ តាមប្លង់គណនីឯកភាព ៧២៤
- **ធ៧-០៧-១៦៤ ប្រ.ក** ប្រកាសស្តីពី ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រា
  ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ .. ៧២៧
- **ធ៧-០១៩-១២២ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី កាតព្វកិច្ចរៀបចំរបាយការណ៍
  ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ហិរញ្ញវត្ថុប្រចាំគ្រារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ .. ៧២៨
- **ធ៧-០២០-៣៥២ ប្រ.ក** ប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន ៧៣០
  ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

១.៤. អត្រាការប្រាក់

- **ធ៥-០៣-០០៧ ប្រ.ក** ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ... ៧៦០
  ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣
- **ធ៥-០៩-០១១ ប្រ.ក** ប្រកាសស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមាន
  ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ កាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់
  ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក ៧៦១
- **ធ៥-០១៤-០០២ ប្រ.ក** ប្រកាសស្តីពី ការប្រើប្រាស់អត្រា LIBOR ជំនួសអត្រា SIBOR ... ៧៦២
  ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤

- **ធ៧-០៩-២១៣ ប្រ.ក** ប្រកាសស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ... ៧៦៣
  ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩
- **ធ៧-០១៧-១០៩ ប្រ.ក** ប្រកាសស្តីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន... ៧៦៤
  ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

១.៥. បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

- **ធ៧-០២-២២០ ប្រ.ក** ប្រកាសស្តីពី ប្រតិបត្តិការលើមូលបត្ររបស់ធនាគារដែលមាន
  ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២ អាជ្ញាបណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ៧៦៦
- **ធ៧-០៤-០៣៨ ប្រ.ក** ប្រកាសស្តីពី កាតព្វកិច្ចអនុវត្តតាមខ្លឹមសារនិងការពិត... ៧៦៨
  ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤
- **ធ៧-០៥-០២ ស.រ.ណ.ន** សារាចរណែនាំស្តីពី ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាព
  ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥ នៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៧៧០
- **ធ៧-០៥-០៥៤ ប្រ.ក** ប្រកាសស្តីពី គោលនយោបាយឥណទាន នីតិវិធី និង
  ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ សិទ្ធិអំណាចផ្តល់ឥណទាន ៧៧៣
- **ធ៧-០១១-០៨២ ប្រ.ក** ប្រកាសស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ
  ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ និងទស្សនៈអនាគត ៧៧៦
- **ធ៧-០១៣-១២២ ប្រ.ក** ប្រកាសស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារ
  ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ និងហិរញ្ញវត្ថុ ៧៧៩
- **ធ៧-០១៣-០០១ ស.រ.ច.ណ** សារាចរណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការកំណត់
  ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៧៨៤
- **ធ៧-០១៤-០០១ ស.រ.ច** សារាចរណែនាំស្តីពី ការផ្តល់សេវាសាធារណៈរបស់
  ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា ៧៨៦
- **ធ៧-០១៤-២២៦ ប្រ.ក** ប្រកាសស្តីពី កិច្ចការពារផ្នែកគតិយុត្តសម្រាប់មន្ត្រីទទួលបន្ទុក
  ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៧៩៣
- **ធ៧-០១៥-១៥៤ ប្រ.ក** ប្រកាសស្តីពី ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរ
  ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ត្រួតពិនិត្យនិងបញ្ញត្តិករក្នុងនិងក្រៅប្រទេស ៧៩៥

- **ធ៧-០១៦-២១០ ស.ជ.ណ** ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ — សេចក្តីជូនដំណឹងស្តីពី ការហាមឃាត់ទទួលយក អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្តល់ឥណទាន ៧៩៧
- **ធ៧-០១៦-៣៣៤ ប្រ.ក** ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ — ប្រកាសស្តីពី ការផ្តល់ឥណទានជារូបិយវត្ថុជាតិរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៧៩៨
- **ធ៧-០១៧-២៩៩ ប្រ.ក** ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ — ប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ៧៩៩
- **ធ៧-០១៧-៣០០ ប្រ.ក** ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ — ប្រកាសស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា ៨០៩
- **ធ៧-០១៧-៣៣៥ ប្រ.ក** ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ — ប្រកាសស្តីពី សវនកម្ម ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.. ៨១១
- **ធ៧-០២០-១៥៤៩ ឆ.ត** ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ — សេចក្តីជូនដំណឹងស្តីពី បញ្ជីរាយនាមឯកសារ ដែលគ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ត្រូវភ្ជាប់ឯកសារជូនជាមួយសំណើសុំ ផ្សេងៗ មកធនាគារជាតិនៃកម្ពុជា ៨២២
- **ធ៧-០២១-១០៥ ប្រ.ក** ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ — ប្រកាសស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការធ្វើអាជីវកម្មបេឹងកាសូរេន ៨៣៨

ច. ហ្វាស៊ីលីធីរបស់ធនាគារជាតិនៃកម្ពុជា

- **ធ៥-០៩-២២៩ ប្រ.ក** ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ — ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ ប្រតិបត្តិការទទួលទិញវិញដើម្បីធានាដល់ប្រតិបត្តិការ អន្តរធនាគារនៅក្នុងទីផ្សារូបិយវត្ថុ ៨៤៥
- **ធ៥-០១០-១៨៣ ប្រ.ក** ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ — ប្រកាសស្តីពី ការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា ៨៥៩
- **ធ៥-០១៤-២៣០ ប្រ.ក** ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ — ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះសមាជិក សភាជាត់ទាត់ជាតិ ៨៦៥
- **ធ៥-០១៤-០០៤ ស.ក.ណ.ន** ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ — សេចក្តីណែនាំអនុវត្តប្រកាសស្តីពីការផ្តល់សន្ទនីយភាព ចំពោះសមាជិកសភាជាត់ទាត់ជាតិ ៨៦៧
- **ធ៧-០១៥-១៥៣ ប្រ.ក** ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ — ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៨៦៨

- **ធ១-០១៦-០៥៤ ពិសេស** ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ — សេចក្តីជូនដំណឹងស្តីពី ការដាក់ឱ្យអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានារបស់ធនាគារជាតិនៃកម្ពុជា .. ៨៧១
- **ធ៥-០១៧-៤១៥ ស.ជ.ណ** ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ — សេចក្តីជូនដំណឹងស្តីពី ការបង្កើនឥណប្រតិទានប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ៨៧៣
- **ធ៥-០១៨-២៣០ ស.ជ.ណ** ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ — សេចក្តីជូនដំណឹងស្តីពី ការបន្ថែមឥណប្រតិទានប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ៨៧៤
- **ធ៥-០១៨-០០២ ស.ក.ណ.ន** ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ — សេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ៨៧៥
- **ធ៥-០១៧-៧០០ ស.ជ.ណ** ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ — សេចក្តីជូនដំណឹងស្តីពី ការដាក់ឱ្យប្រើប្រាស់ផ្លែតហ្វូមរបស់ធនាគារជាតិនៃកម្ពុជា (NBCP) ៨៧៧

ឆ. ប្រព័ន្ធទូទាត់ ជាត់ទាត់ និង ផ្ទេរប្រាក់ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ឆ.១. ប្រព័ន្ធទូទាត់ ជាត់ទាត់ និង ផ្ទេរប្រាក់

- **ធ៩-០៦-២៣៤ ប្រ.ក** ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦ — ប្រកាសស្តីពី ប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ៨៧៨
- **ធ៩-០៦-២៣៥ ប្រ.ក** ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០០៦ — ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ ៨៨៦
- **ធ៩-០៦-២៤០ ប្រ.ក** ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ — ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ ៨៩៧
- **ធ៩-០១០-១៥០ ប្រ.ក** ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ — ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ៩០៣
- **ធ៥-០១៤-០៦៨ ប្រ.ក** ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ — ប្រកាសស្តីពី ការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈធនាគារជាតិនៃកម្ពុជា ៩០៧
- **ធ៥-០១៦-០១៥ ស.ជ.ណ** ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ — សេចក្តីជូនដំណឹងស្តីពី ការដាក់ឱ្យប្រើប្រាស់សេវា Online Banking System របស់ធនាគារជាតិនៃកម្ពុជា ៩១២
- **ធ៥-០១៦-០០២ ស.រ.ច.ណ.ន** ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ — សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ៩១៣

- **ធ១៤-០១៦-១៣៥ ប្រ.ក** ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ — ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ... ៩១៤
- **ធ១៤-០១៦-១៤៧ ប្រ.ក** ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ — ប្រកាសស្តីពី សមាជិកភាពប្រព័ន្ធ Fast និង ប្រព័ន្ធ Central Shared Switch ៩១៥
- **ធ១៤-០១៧-៣០៧ ប្រ.ក** ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ — ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Cambodian Shared Switch ៩១៧
- **ធ១៤-០១៨-១៩៤ ប្រ.ក** ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ — ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ៩១៨
- **ធ១៤-០១៩-៤២៥ ប្រ.ក** ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ — ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay .. ៩២៣
- **ធ១៤-០២០-០៤៦ ប្រ.ក** ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ — ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay ៩២៤
- **ធ១៤-០២០-៣៤៩ ប្រ.ក** ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ — ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ វិធាននិងនីតិវិធី ប្រព័ន្ធបាគង ៩២៦
- **ធ១៤-០២០-៣៥០ ប្រ.ក** ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ — ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង ... ៩២៧
- **ធ១៤-០២០-៣៥១ ប្រ.ក** ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ — ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ .. ៩៣០

ឆ.២. មូលប្បទានបត្រ

- **ធ៥-០០-១៥០ ប្រ.ក** ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ — ប្រកាសស្តីពី សភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក ៩៤៦
- **ធ៥-០០-១៧០ ប្រ.ក** ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ — ប្រកាសស្តីពី សភាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ៩៦៥
- **ធ៩-០៨-១៨៦ ប្រ.ក** ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ — ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ..... ៩៨៣

- **ធ៩-០៨-១៨៧ ប្រ.ក** ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ... ៩៩៦
  ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨
- **ធ៥-០៩-២២៨ ប្រ.ក** ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់មូលបត្រស្តង់ដាររបស់
  ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជា ១០០០
- **ធ៥-០១៨-៣០២ ប្រ.ក** ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មីរបស់
  ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា ១០០២
- **ធ៥-០១៨-៧៤២ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី មូលប្បទានបត្រគំរូថ្មីរបស់
  ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា ១០០៥

ឆ.៣. អត្រាសេវា

- **ធ៥-០៣-០១៦ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការផ្ទេរទៅ-មក ខេត្ត-ក្រុង និង
  ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៣ ការកំណត់អត្រាសេវា ១០០៦
- **ធ៥-០៩-៦៣៨ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការកំណត់អត្រាសេវាផ្ទេរប្រាក់
  ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ ទៅ-មកក្នុងប្រទេស តាមរយៈធនាគារជាតិនៃកម្ពុជា... ១០០៩
- **ធ៥-០៩-៨៦០ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការបង់អត្រាសេវាជាត់ទាត់ប្រចាំឆ្នាំ
  ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ របស់សមាជិកសភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា ... ១០១០
- **ធ៥-០១០-៤៨៦ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការយកកម្រៃសេវាជាត់ទាត់ប្រចាំឆ្នាំ
  ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ និងប្រាក់ជាកពិន័យមូលប្បទានបត្របញ្ជូនត្រឡប់នៅសាខា
  ធនាគារជាតិនៃកម្ពុជាខេត្ត ១០១១
- **ធ៥-០១១-១៣៦ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការយកកម្រៃសេវាសភាជាត់ទាត់
  ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១ ប្រចាំឆ្នាំនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត ១០១២
- **ធ៥-០១៨-៧៥៩ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី កម្រៃសេវាគណនី និងសេវាសម្រាប់
  ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ការផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធនៅធនាគារជាតិនៃកម្ពុជា ១០១៣
- **ធ៥-០១៩-១០៤៩ ស.ជ.ណ** សេចក្តីជូនដំណឹងស្តីពី ការបង់កម្រៃពីការប្រើប្រាស់សេវា
  ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ NBC Online Banking System (OBS) ១០១៤

៩. ការគ្រប់គ្រងក្រដាសប្រាក់

- **ធ៣-៩៧-៥៧៦ ស.ជ.ណ** ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៧ — សេចក្តីជូនដំណឹងស្តីពី ការដកហូតទុកដោយគ្មានថ្នូរនូវក្រដាសប្រាក់រៀលគំរូគ្រប់ប្រភេទ ១០១៥
- **ធ១-០៩-៥៣៥ ស.ជ.ណ** ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ — សេចក្តីជូនដំណឹងស្តីពី ការដកហូតយកក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ ១០១៦
- **០៥០-១៦ អ.ប** ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ — សេចក្តីជូនដំណឹងស្តីពី ការទទួលរាប់ក្រដាសប្រាក់ជារូបិយវត្ថុជាតិនិងរូបិយប័ណ្ណ ១០១៧
- **ធ៥-០១៧-២៩២ ស.ជ.ណ** ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ — សេចក្តីជូនដំណឹងស្តីពី នីតិវិធីនៃការបើកប្រាក់នៅធនាគារជាតិនៃកម្ពុជា ១០១៨
- **០៩៩-២០ អ.ប** ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ — សេចក្តីជូនដំណឹងស្តីពី ការបើកសាច់ប្រាក់ជារូបិយប័ណ្ណពីធនាគារជាតិនៃកម្ពុជា ១០១៩
- **១០០-២០ អ.ប** ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ — សេចក្តីជូនដំណឹងស្តីពី ការដកហូតយកក្រដាសប្រាក់រៀលក្លែងក្លាយ ១០២០

ឧបសម្ព័ន្ធ

- តារាងបទប្បញ្ញត្តិពីឆ្នាំ២០១៧ ដល់ ពាក់កណ្តាលឆ្នាំ២០២១
- តារាងបទប្បញ្ញត្តិដែលកែសម្រួលលើបទប្បញ្ញត្តិផ្សេងៗ
- តារាងបទប្បញ្ញត្តិត្រូវបាននិរាករណ៍ និងបទប្បញ្ញត្តិមានប្រសិទ្ធភាពអនុវត្ត

ក. ច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

ការអៀបចំនិងការប្រព្រឹត្តទៅ

នៃ

ធនាគារជាតិនៃកម្ពុជា

ព្រះរាជក្រម

នស/រកម/០១៩៦/២៧ លេខ

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឪ្ញុំន

កេតុមាលិនីឥន្ទ្រតនោសុជាត ឥសុន្ធរិលក្ស រង្គឧបាទុះសេនង់ ឯកវោត្តម

ធម្មិកឧបាសកជាធិក ទេវនាថ ទេវទេពតិគ្ត

ព្រះចៅក្រុងកម្ពុជាធិបតី

. . . . . .

- បានឈើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឈើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឈើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- បានឈើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប្យបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិ
- បានឈើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង ឯកឧត្តម ថៅ ប៉ោងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឈើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការអប្យបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបាន អនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ជំពូកទី ១
បទបញ្ញត្តិទូទៅ

មាត្រា ១.-

ធនាគារជាតិនៃកម្ពុជាហៅថា "ធនាគារកណ្តាល" គឺជាស្ថាប័នស្វយ័តសាធារណៈមានលក្ខណៈជាពាណិជ្ជកម្មនិងឧស្សាហកម្ម ។

មាត្រា ២.-

ធនាគារកណ្តាលជានីតិបុគ្គលមានសមត្ថភាពគតិយុត្តិពេញលេញនិងជាអាទិ៍មានសមត្ថភាពក្នុងការ :

១-ឱ្យប្រាក់គេខ្ចី ខ្ចីប្រាក់ពីគេនិងចុះកិច្ចសន្យាផ្សេងៗទៀត ។

២-ប្តឹងនិងការពារនៅមុខតុលាការ ។

៣-ធ្វើលទ្ធកម្ម កាន់កាប់និងផ្ទេរចេញនូវចលនទ្រព្យនិងអចលនទ្រព្យ ក្នុងគោលដៅនៃការប្រកបអាជីវកម្មរបស់ខ្លួន ។

មាត្រា ៣.-

ធនាគារកណ្តាលមានបេសកកម្មចំបងគឺកំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថេរភាពសំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន ។

មាត្រា ៤.-

ធនាគារកណ្តាលមានសិទ្ធិចេញប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទៀតដើម្បីបំពេញបេសកកម្មរបស់ខ្លួននិងដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ។

មាត្រា ៥.-

ធនាគារកណ្តាលត្រូវចេញផ្សាយជាប្រក្រតីនូវគោលដៅនយោបាយរូបិយវត្ថុ (រូបិយវត្ថុ ឥណទាន ការប្តូរប្រាក់ អត្រាតារប្រាក់)និងស្ថិតិទាក់ទងជាអាទិ៍ដល់បរិមាណរូបិយវត្ថុ ថ្លៃ ឥណទាន ជញ្ជីងទូទាត់និងការប្តូរប្រាក់ ។

មាត្រា ៦.-

ទីស្នាក់ការដើមធនាគារកណ្តាលត្រូវតាំងនៅរាជធានីភ្នំពេញ ។ ធនាគារកណ្តាលអាចបើក សាខា ទីភ្នាក់ងារក្នុងប្រទេសនិងការិយាល័យតំណាងនៅឯបរទេស ក្រោយពីមានការយល់ព្រមពីក្រុម ប្រឹក្សាភិបាលនៃធនាគារកណ្តាល ។

ជំពូកទី ២

មុខងារនិងភារកិច្ចទូទៅ

មាត្រា ៧.-

ធនាគារកណ្តាលមានមុខងារនិងភារកិច្ចដូចតទៅ :

១-កំណត់គោលដៅនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។

២-ត្រិះរិះរក អនុវត្តនិងត្រួតពិនិត្យនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ឱ្យសំរេចទៅតាមគោលដៅដែល បានកំណត់ ។

៣-ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផលហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាល ។

៤-ផ្តល់ឫជកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀត ដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ ។

៥-ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជានិងកែលំអប្រសិទ្ធិភាពនៃការទូទាត់អន្តរ-ធនាគារ ។

៦-ទទួលភារៈផ្តាច់មុខជាអ្នកចោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ទទួលខុសត្រូវនិងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈ ក្នុងកិច្ចការធនាគារ ឥណទានរូបិយវត្ថុ ។

៨-តម្លើងតារាងជញ្ជីងទូទាត់ ។

៩-ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទេយ្យជាមួយប្រទេសក្រៅ ។

១០-ចូលរួមក្នុងការបង្កើតនិងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុ ។

១១-ផ្តល់ឫជកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ឃារីមប័ណ្ណក្សងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ។

១២-កំណត់អត្រាការប្រាក់ ។

មាត្រា ៨.-

ធនាគារកណ្តាលអាចបើកគណនីឱ្យ :

-ស្ថាប័នរដ្ឋឬអង្គភាពរដ្ឋបាលកណ្តាល ដូចជារតនាគារជាតិជាដើម

-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារកណ្តាលឱ្យធ្វើអាជីវកម្ម

-ធនាគារកណ្តាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ។

ធនាគារកណ្តាលមិនអាចបើកគណនីឱ្យសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មបានទេ លុះជារបស់រដ្ឋកំដោយ ។

ជំពូកទី ៣

ស្វ័យភាពនៃធនាគារកណ្តាល

មាត្រា ៩.-

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន ធនាគារកណ្តាលក្នុងឋានៈជាអ្នកទទួលនូវសិទ្ធិអចិន្ត្រៃយ៍ពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការគ្រប់គ្រង តែត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តភារកិច្ចនិងលទ្ធផលដែលសំរេចបាន ជូនរដ្ឋសភានិងរាជរដ្ឋាភិបាល ។

ទេសាភិបាលនៃធនាគារកណ្តាលអាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី តាមការអញ្ជើញរបស់រាជរដ្ឋាភិបាល ។ រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលនៃធនាគារកណ្តាល តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលនេះ។

តាមសំណើរបស់រដ្ឋសភា ទេសាភិបាលឬសមាជិកក្រុមប្រឹក្សាភិបាលត្រូវបំភ្លឺអំពីនយោបាយនៃធនាគារកណ្តាលឬអត្ថាធិប្បាយសេចក្តីព្រាងច្បាប់ជូនរដ្ឋសភា ឬគណៈកម្មការជំនាញនៃរដ្ឋសភា ។

មាត្រា ១០.-

នៅដំណាច់ឆមាសនីមួយៗ ធនាគារកណ្តាលត្រូវដាក់ជូនរដ្ឋសភានិងរាជរដ្ឋាភិបាលនូវរបាយការណ៍ដោយ :

-វាយតម្លៃនូវគោលចំៗនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងរៀបរាប់អំពីនយោបាយរូបិយវត្ថុនិងនយោបាយប្តូរប្រាក់ដែលធនាគារកណ្តាលត្រូវអនុវត្តក្នុងឆមាសបន្ទាប់ឬក្នុងរយៈពេលវែងជាងនេះ ។

-ពិនិត្យឡើងវិញនិងវាយតម្លៃការអនុវត្តនយោបាយរូបិយវត្ថុនិងនយោបាយប្តូរប្រាក់ដែលមានចែងក្នុងរបាយការណ៍ឆមាសមុន ។

មាត្រា ១១.-

ក្រៅពីរបាយការណ៍ខាងលើ ធនាគារកណ្តាលត្រូវធ្វើរបាយការណ៍តាមការចាំបាច់របស់រដ្ឋសភានិងរាជរដ្ឋាភិបាល ។

ជំពូកទី ៤

ការគ្រប់គ្រងធនាគារកណ្តាល

មាត្រា ១២.-

១-អង្គការគ្រប់គ្រងរបស់ធនាគារកណ្តាលគឺក្រុមប្រឹក្សាភិបាល ដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវបានដឹកនាំដោយទេសាភិបាល ។ ក្រុមប្រឹក្សានេះមានសមាជិក ៧រូប គឺ ទេសាភិបាល ទេសាភិបាលរង និងសមាជិក ៥រូបទៀត ដែល ១រូបតំណាងប្រមុខរដ្ឋាភិបាល ១រូប តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូបតំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឱ្យ មជ្ឈដ្ឋានឧត្តមសិក្សា និង ១រូបទៀតតំណាងឱ្យបុគ្គលិកធនាគារកណ្តាល ។

ក្នុងតំណែងរបស់ខ្លួន ទេសាភិបាលនិងទេសាភិបាលរង មិនអាចជាមន្ត្រីរាជការ មិនអាចជាទីប្រឹក្សាអង្គភាពសាធារណៈ មិនអាចជាសមាជិករាជរដ្ឋាភិបាលនិងមិនអាចជាសមាជិករដ្ឋសភាទេ ។

លក្ខខ័ណ្ឌខាងលើនេះក៏ត្រូវអនុវត្តចំពោះសមាជិកដទៃទៀតដែរលើកលែងតែតំណាងឱ្យ ប្រមុខរាជរដ្ឋាភិបាលនិងតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងតំណាងមជ្ឈដ្ឋានឧត្តមសិក្សាដែលម្នាក់ៗអាចរក្សាលក្ខណៈជាមន្ត្រីរាជការបាន ។

២-ក្រុមប្រឹក្សាមានភារកិច្ចជាអាទិ៍ :

-រៀបចំនយោបាយសំរាប់កិច្ចប្រតិបត្តិការរបស់ធនាគារកណ្តាល

-ចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការធនាគារកណ្តាល

-ចងក្រងបទបញ្ជាផ្ទៃក្នុង

-តាក់តែងលក្ខន្តិកៈបុគ្គលិក

-បង្កើតនាយកដ្ឋានសាខារបស់ធនាគារកណ្តាល

-បង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យ

-បង្កើតគណៈកម្មការសំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈនៃបុគ្គលិក ។

៣-ទេសាភិបាលមានតួនាទីជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាលនិងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា លើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន ។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការរបស់ធនាគារកណ្តាល និងមានសិទ្ធិអំណាចធ្វើកិច្ចការទាំងឡាយណាដែលមិនបានកំណត់សំរាប់ក្រុមប្រឹក្សានៅក្នុងច្បាប់នេះឬបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ទេសាភិបាលត្រូវតែងតាំងមន្ត្រី បុគ្គលិកនៃធនាគារកណ្តាលនិងលើកសំណើជូនក្រុមប្រឹក្សាក្នុងការកម្រិតប្រាក់បៀវត្ស ព្រមទាំងប្រាក់បំណាច់ផ្សេងៗចំពោះក្របខ័ណ្ឌជាន់ខ្ពស់ ។

៤-ទេសាភិបាលរងមានសិទ្ធិអំណាច និងបំពេញការកិច្ចទាំងឡាយដែលទេសាភិបាលកំណត់ឱ្យ ។ ក្នុងករណីអវត្តមានរបស់ទេសាភិបាល ទេសាភិបាលរងជំនួសទេសាភិបាល ។

មាត្រា ១៣.-

ទេសាភិបាលនិងទេសាភិបាលរងត្រូវបានតែងតាំង ផ្ទាស់ប្តូរ បញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

សមាជិកដទៃទៀតនៃក្រុមប្រឹក្សាត្រូវបានតែងតាំង ផ្ទាស់ប្តូរ បញ្ឈប់ពីតំណែងដោយអនុក្រឹត្យ ។ សមាជិកទាំងនេះត្រូវបានជ្រើសរើសតាមបញ្ជីរៀបចំដោយទេសាភិបាលដែលមានឈ្មោះពីនាក់ក្នុងប្រភេទតំណាងនីមួយៗ ។

មាត្រា ១៤.-

១-សមាជិកនៃក្រុមប្រឹក្សាត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងមានអាយុមិនលើសពី ៦៥ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសំរាប់រយៈពេល ៤ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបានតែ ១ដងគត់ ។ ចំពោះក្រុមប្រឹក្សាលើកទី១ ដែលបង្កើតតាមច្បាប់នេះលើកលែងតែទេសាភិបាល ទេសាភិបាលរងនិងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២រូប ត្រូវចប់ក្នុងរយៈ ២ឆ្នាំក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២-សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក-ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាលឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬផ្នែកពាណិជ្ជកម្ម ។

ខ-មានសេចក្តីសំរេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ដែលចែងក្នុងមាត្រា ១៥និង១៦នៃច្បាប់នេះ ។

គ-អវត្តមានក្នុងការប្រជុំជាប់ៗគ្នា៤ដង លើកលែងតែមានជម្ងឺនិងក្នុងករណីប្រធានសិក្ខីដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ-លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង-មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានដោយបាត់បង់សមត្ថភាពពលកម្មនិងវិបត្តិស្មារតី ។

ច-ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣-ការប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើយ៉ាងហោចណាស់ ២ខែម្តង ។

៤-សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមានដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥-ទេសាភិបាលនិងទេសាភិបាលរងទទួលប្រាក់កម្រៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនិងសមាជិកនៃរាជរដ្ឋាភិបាល ។

ជាត្រា ១៥.-

១-មិនអនុញ្ញាតឱ្យអ្នកដឹកនាំ បុគ្គលិកឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សារបស់ធនាគារកណ្តាល:

-ទាញយកតាមរយៈធនាគារកណ្តាលនូវផលប្រយោជន៍ទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬផ្នែកផ្សេងៗទៀត

-ទទួលយក ដើម្បីផលប្រយោជន៍ទាំងនេះនូវការណែនាំដែលពាក់ព័ន្ធដល់ភារកិច្ចដែលខ្លួនត្រូវបំពេញដូចមានចែងក្នុងច្បាប់នេះ

-ទទួលធ្វើការងារណាដែលផ្ទុយពីភារកិច្ចរបស់ខ្លួន

-ទទួលអំណោយឬឋានៈសំរាប់ខ្លួនឯងផ្ទាល់ឬសំរាប់បុគ្គលជិតស្និទ្ធិជាមួយខ្លួនដែលជាគ្រួសារផ្ទាល់ក្តី ការកាន់កាប់ពាណិជ្ជកម្មឬហិរញ្ញវត្ថុក្តីដោយលំអៀងនូវភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ច។

២-សមាជិកទាំងអស់នៃក្រុមប្រឹក្សាត្រូវរាយការណ៍ឱ្យបានសព្វគ្រប់ជូនទៅក្រុមប្រឹក្សាអំពី ផលប្រយោជន៍សំខាន់ៗផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬរបរអាជីវកម្មផ្សេងទៀតដែលខ្លួនឬគ្រួសារផ្ទាល់មានដោយចំពោះឬដោយប្រយោល ហើយពុំមានសិទ្ធិបោះឆ្នោតលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ខ្លួនឡើយ ។ ប៉ុន្តែអាចចូលរួមដើម្បីបំពេញចំនួនកូរ៉ុមក្នុងអង្គប្រជុំ ដែលត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ។

មាត្រា ១៦.-

អ្នកដឹកនាំ បុគ្គលិកនិងសមាជិកនៃក្រុមប្រឹក្សារបស់ធនាគារកណ្តាលមិនត្រូវផ្តល់ឱ្យអ្នកដទៃនូវពត៌មានដែលទាក់ទងនឹងការសម្ងាត់វិជ្ជាជីវៈដែលខ្លួនបានទទួលក្នុងពេលបំពេញភារកិច្ចឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលច្បាប់អនុញ្ញាតឬមានការបង្គាប់ពីតុលាការ ។

ជំពូកទី ៥
ដើមទុន ការប្រើប្រាស់ទ្រព្យសកម្ម

មាត្រា ១៧.-

១-ធនាគារកណ្តាលត្រូវបានអនុញ្ញាតឱ្យមានដើមទុនដែលកម្រិតដោយអនុក្រឹត្យ ។ ដើមទុននេះអាចកែប្រែបានតាមពេលវេលាចាំបាច់ ។ ដើមទុនទាំងមូលត្រូវបានចុះបញ្ជីនិងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាលនិងមិនអាចផ្ទេរឬដាក់ឱ្យជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

២-នៅពេលដែលទ្រព្យសកម្មពិតក្នុងតារាងតុល្យការរបស់ធនាគារកណ្តាលថយចុះក្រោមចំនួនទ្រព្យអកម្ម រាជរដ្ឋាភិបាលត្រូវប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដើម្បីបំពេញឱនភាពនោះក្នុងកំឡុង ៦០ថ្ងៃ ក្រោយពីពេលចេញផ្សាយតារាងតុល្យការរបស់ធនាគារកណ្តាល ។ មូលប័ត្ររដ្ឋជាប័ណ្ណអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន ។

មាត្រា ១៨.-

លទ្ធផលជាមូលដ្ឋាននៃការិយបរិច្ឆេទនីមួយៗរបស់ធនាគារកណ្តាលត្រូវបានគណនា ក្រោយពីបានដកចំណាយប្រតិបត្តិការប្រចាំការិយបរិច្ឆេទនោះនិងក្រោយពីបានដកទុកសំរាប់ .

១-ទាយជ្ឈទានដល់គណនីសវិធានធនសំរាប់ហានិភ័យនិងការស្រុតចុះតម្លៃនិងដល់គណនីរំលស់ទ្រព្យសកម្ម ។

២-សវិធានធនដល់មូលនីធិសោធនដែលកំណត់ដោយក្រុមប្រឹក្សា ។

៣-ប្រាក់បំរុងទូទៅស្មើនឹង ២០% (ម្ភៃភាគរយ) លើលទ្ធផលក្រោយពីដកក្នុងចំណុច ១និង២នៃមាត្រានេះ ។

៤-ប្រាក់បំរុងសំរាប់សងថ្លៃមូលប័ត្រទាំងឡាយដែលធនាគារកណ្តាលបានទទួល ។

៥-មូលនិធិសំរាប់វិនិយោគសមូហភាពរបស់ធនាគារកណ្តាលដែលកំណត់ដោយក្រុមប្រឹក្សា។

មាត្រា ១៩.-

ប្រាក់ចំណេញសុទ្ធត្រូវបង់ចូលថវិកាជាតិក្រោយពីបានដកចេញ :

- ៥% (ប្រាំភាគរយ) សំរាប់រង្វាន់បុគ្គលិកដោយមិនគិតក្រុមប្រឹក្សា ។
- ០.៥% (សូន្យក្បៀសប្រាំភាគរយ) សំរាប់សមាជិកក្រុមប្រឹក្សា ។

មាត្រា ២០.-

គម្រោងចំណាយទាំងអស់របស់ធនាគារកណ្តាលត្រូវចងក្រងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាហើយផ្ញើជូនរាជដ្ឋាភិបាលនិងរដ្ឋសភាដើម្បីជាពត៌មាន ។

ជំពូកទី ៦

សម្ព័ន្ធភាពផ្ទៃក្នុងរវាងភ្នាក់ងារសាធារណៈ

មាត្រា ២១.-

១-ធនាគារកណ្តាលទទួលប្រាក់បញ្ញើជាចំមុខជារូបិយវត្ថុជាតិពីរតនាគារជាតិ ។ ធនាគារកណ្តាលទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជូនសន្លឹកប្រាក់ដែលរតនាគារជាតិត្រូវចំណាយ ។

ធនាគារកណ្តាលត្រូវកំណត់ជាមួយនឹងរតនាគារជាតិនូវកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលត្រូវអនុវត្ត ។

២-ចំណូលជារូបិយប័ណ្ណរបស់រតនាគារជាតិត្រូវលក់ឱ្យធនាគារកណ្តាល ហើយធនាគារកណ្តាលត្រូវបញ្ចូលទឹកប្រាក់ជារៀលក្នុងគណនីតែមួយរបស់រតនាគារជាតិដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ ។

មាត្រា ២២.-

ធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ ។

ធនាគារកណ្តាលមានភារកិច្ចក្នុងការផ្តល់ពត៌មាននិងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយដែលមានអានុភាពក្នុងការធ្វើឱ្យសំរេចគោលដៅនយោបាយនៃហិរញ្ញវត្ថុ ។

មាត្រា ២៣.-

១-ធនាគារកណ្តាលត្រូវជួយត្រប់ត្រងក្នុងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាលឬអង្គភាពសាធារណៈដោយធ្វើប្រតិបត្តិការលើមូលប័ត្រជាអាទិ៍ ជូនយោបល់លើកាលបរិច្ឆេទនៃការចេញផ្សាយមូលប័ត្រនិងជំរុញទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុឱ្យរីកចំរើន ។

២-ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិតំណាងរបស់រាជរដ្ឋាភិបាលឬរបស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការដូចខាងក្រោមនេះ :

-ការទិញ លក់មូលប័ត្រដែលចេញផ្សាយដោយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈព្រមទាំងកិច្ចការជាភ្នាក់ងារគណនេយ្យដើម្បីចុះបញ្ជីនិងផ្ទេរនូវមូលប័ត្រនោះ

-ការទូទាត់សងដើមនិងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលប័ត្រទាំងនោះ ។

៣-ធនាគារកណ្តាលត្រូវកំណត់ជាមួយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈ អំពីកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

មាត្រា ២៤.-

ធនាគារកណ្តាលមិនត្រូវផ្តល់ឥណទានដោយផ្ទាល់ឬដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលប័ត្រដែលចេញផ្សាយដំបូងឬមូលប័ត្រដែលធានាដោយរាជរដ្ឋាភិបាលឬដោយអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ ។

មាត្រា ២៥.-

ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវិសាខមិនហួសពី ៣ខែជូនទៅរកនាគារជាតិ ដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន :

១-រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាលនិងអ្នកទទួលដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវិសាខនិងអត្រាការប្រាក់ ។

២-ប្រតិបត្តិការឥណទានត្រូវធ្វើឱ្យមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដែលអាចធ្វើអន្តរការបាន ។

៣-ចំនួនទឹកប្រាក់សរុបនៃឥណទាននិងមូលប័ត្រដែលមានស្របតាមមាត្រា ២៤នៃច្បាប់នេះក្នុងការិយបរិច្ឆេទនីមួយៗមិនត្រូវឱ្យលើសពី ១០% (ដប់ភាគរយ) នៃចំណូលធម្មតានៃថវិកាជាតិក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយ ដោយមិនគិតជំនួយនិងចំណូលពីការលក់ទ្រព្យសម្បត្តិ ។

មាត្រា ២៦.-

នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការផ្សារចំហឬកិច្ចប្រតិបត្តិការអប្បហារឬឥណទានជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារកណ្តាលអាចលក់ ទិញ ទទួលឬដាក់បង់ស្បុងនៃមូលប័ត្ររដ្ឋដែលត្រូវបានគេចោះផ្សាយជាសាធារណៈពីមុនមក ហើយដែលត្រូវផុតកំណត់សងក្នុងកំឡុង ៩០ថ្ងៃ ។

មាត្រា ២៧.-

ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលត្រូវពិគ្រោះជាមួយធនាគារកណ្តាលសិន មុននឹងសំរេចថវិកាជាតិជាស្តាពរដើម្បីកំណត់នូវចំនួនទឹកប្រាក់ឥណទានសរុបដែលរាជរដ្ឋាភិបាលនិងអង្គភាពសាធារណៈនានាអាចត្រូវការពីធនាគារកណ្តាលក្នុងកម្រិតដូចមានចែងក្នុងមាត្រា ២៥នៃច្បាប់នេះ ។

មាត្រា ២៨.-

ធនាគារកណ្តាលចូលរួមក្នុងការគ្រប់គ្រងបំណុលសាធារណៈក្នុងនិងក្រៅប្រទេសដោយរាប់បញ្ចូលទាំងលិខិតធានារ៉ាប់រងចេញជូនឥណទាយកផង ។

ជំពូកទី ៧

របបនិទនយោបាយប្តូរប្រាក់

មាត្រា ២៩.-

ធនាគារកណ្តាលត្រូវកំណត់និងអនុវត្តរបបនិងនយោបាយប្តូរប្រាក់នៃព្រះរាជាណាចក្រកម្ពុជា ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣០.-

១-ធនាគារកណ្តាលត្រូវរក្សានិងគ្រប់គ្រងទុនបំរុងផ្លូវការក្រៅប្រទេសដែលរួមមាន :

-មាសរូបិយវត្ថុ

-រូបិយប័ណ្ណដែលមានទ្រង់ទ្រាយជាក្រដាសឬជាកាសនិងសមតុល្យធនាគារនៅបរទេស

-ធនធានជាទុនបំរុងដែលអន្តរជាតិទទួលស្គាល់ជាអាទិ៍មាន :

.រូបិយប័ណ្ណដែលទិញពីមូលនិធិរូបិយវត្ថុអន្តរជាតិយកក្នុងផ្នែកបំរុង

.ធនធានជាសិទ្ធិដកតំសេស អេស.ឌី.អរ (S.D.R) របស់ព្រះរាជាណាចក្រកម្ពុជា

-រូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលមានកំណត់ជារូបិយប័ណ្ណហើយត្រូវសងនៅក្រៅប្រទេស

-ប័ណ្ណរតនាគារដែលចោះផ្សាយដោយរដ្ឋាភិបាលបរទេស

-មូលប័ត្រដែលចោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។

២-ធនាគារកណ្តាលត្រូវរក្សាទុនបំរុងក្រៅប្រទេសឱ្យនៅកម្រិតគ្រប់គ្រាន់ដើម្បីធានាដល់ប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

៣-កាលណាទុនបំរុងផ្លូវការក្រៅប្រទេសមានការថយចុះឬមានភាពដែលអាចថយចុះដលកម្រិតខ្វះខាត ធនាគារកណ្តាលត្រូវជាក់ជូនដល់រាជរដ្ឋាភិបាលនូវរបាយការណ៍ស្តីពីមូលហេតុនៃបញ្ហានិងវិធានការដើម្បីកែសម្រួល ។ របាយការណ៍នេះត្រូវធ្វើជាប្រចាំរហូតដល់ស្ថានភាពថយចុះខាងលើត្រូវបានដោះស្រាយរួចជារសេច ។

៤-ធនាគារកណ្តាលជាអ្នកទទួលបន្ទុកថែរក្សាធនធានផ្លូវការក្រៅប្រទេសរបស់ព្រះរាជ-
ណាចក្រកម្ពុជា ហើយមានសិទ្ធិជ្រើសរើសអាណត្តិគាហកដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារ
កណ្តាលឬធនាគារពាណិជ្ជកម្មបរទេសដើម្បីកាន់កាប់ជំនួស ។

មាត្រា ៣១.-

១-ធនាគារកណ្តាលត្រូវកំណត់អត្រាប្តូរប្រាក់នៃរូបិយវត្ថុជាតិឱ្យមានស្ថិរភាព ។ ដូច្នេះ
ធនាគារកណ្តាលមានសិទ្ធិជាអាទិ៍ :

-ធ្វើអាជីវកម្មលើមាសជាកាសឬជាដុំនិងលើលោហៈធាតុឬត្បូងថ្មមានតម្លៃផ្សេងទៀត

-ធ្វើអាជីវកម្មលើរូបិយប័ណ្ណដោយប្រើឧបករណ៍នានាដែលធនាគារិកធ្លាប់ប្រើជាទូទៅ

-ធ្វើអាជីវកម្មលើប័ណ្ណរតនាគារឬលើមូលប័ត្រផ្សេងទៀត ដែលចេញផ្សាយឬធានាដោយ
រដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ

-បើកនិងកាន់កាប់គណនីធនាគារពាណិជ្ជឬស្ថាប័នហិរញ្ញវត្ថុ ឬធារណៈអន្តរជាតិនៅ
ឯបរៈទស

-បើកនិងកាន់កាប់គណនី និងធ្វើសកម្មភាពជាភ្នាក់ងារឬជាអ្នកទាក់ទងជំនួសមុខធនាគារ
កណ្តាលបរទេស រដ្ឋាភិបាលបរទេស ទីភ្នាក់ងាររដ្ឋាភិបាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈ
អន្តរជាតិនានា

-កំណត់អត្រាទិញ លក់រូបិយប័ណ្ណនានា

-កម្រិតស្ថានភាពរូបិយប័ណ្ណនៃធនាគារពាណិជ្ជនិងទីកន្លែងប្តូរប្រាក់ដែលមិនមែនជា
ធនាគារ

-ចេញបទបញ្ជាដែលពាក់ព័ន្ធលើការប្តូរប្រាក់និងអាជីវកម្មលើមាស លោហៈធាតុនិងត្បូងថ្ម
មានតម្លៃ

-ប្រកាសអត្រាប្តូរវ៉ាងប្រាក់រៀលនិងរូបិយប័ណ្ណផ្សេងៗ

-ចូលរួមក្នុងកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិជំនួសមុខឱ្យរដ្ឋ

២-ធនាគារកណ្តាលមិនអាចផ្តល់ឱ្យអ្នកដទៃនូវលិខិតធានាអត្រាប្តូរប្រាក់ទៅអនាគត ហើយ
មិនអាចអនុញ្ញាតឬមិនត្រូវប្រើពាក្យអត្រាទ្វើរ្យ ។

មាត្រា ៣២.-

១-ប្រាក់កម្ចៃលើសសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលតម្លៃទ្រព្យសកម្មនិងទ្រព្យអកម្មនៃធនាគារកណ្តាលដែលកត់ត្រាជារូបបិយប័ណ្ណឬឯកតាគណនីឯទៀតក្រៅពីរូបិយវត្ថុជាតិ ត្រូវចុះជាឥណទាននៅក្នុងគណនីទុនបំរុងពិសេស ។

២-ប្រាក់កម្ចៃខ្វះសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលដូចខាងលើនេះ ត្រូវកត់ត្រាបញ្ចេញពីសមតុល្យឥណទាយីនៃគណនីទុនបំរុងពិសេស ហើយបើសមតុល្យនោះមានបរិមាណមិនគ្រប់គ្រាន់ដើម្បីទូទាត់ប្រាក់ខ្វះទាំងនោះទេ រតនាគារជាតិត្រូវចេញមូលប័ត្រដែលអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានទៅឱ្យធនាគារកណ្តាលដើម្បីបង្ក្រប់ឱនភាព ។

៣-ទាំងប្រាក់កម្ចៃលើសសុទ្ធ ទាំងប្រាក់កម្ចៃខ្វះសុទ្ធដែលចែងក្នុងមាត្រានេះមិនត្រូវគិតចូលក្នុងតារាងប្រតិបត្តិការប្រចាំឆ្នាំរបស់ធនាគារកណ្តាលឡើយ ។

៤-រាល់សមតុល្យឥណទាយីក្នុងគណនីទុនបំរុងពិសេស នៅចុងការិយបរិច្ឆេទនៃធនាគារកណ្តាល ត្រូវប្រើសំរាប់សងមូលប័ត្រដែលត្រូវបានបោះផ្សាយដូចមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

៥-សមតុល្យគណនីទុនបំរុងពិសេសនេះមិនត្រូវមានការរម្រើមតម្រង់ឡើយ លើកលែងតែអនុលោមតាមមាត្រានេះ ។

ជំពូកទី ៨

សម្ព័ន្ធភាពជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

មាត្រា ៣៣.-

ធនាគារកណ្តាលត្រូវទទួលខុសត្រូវផ្តាច់មុខក្នុងការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀតដូចមានចែងក្នុងមាត្រា ៧នៃច្បាប់នេះដោយ :

១-ចេញប្រកាស បទបញ្ជានិងការណែនាំផ្សេងៗព្រមទាំងចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យសំរេចមុខងារដែលមានចែងក្នុងជំពូកទី២នៃច្បាប់នេះដោយអនុវត្តបទដ្ឋាននៃការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងត្រួតពិនិត្យព្រមទាំងមធ្យោបាយសមស្រប ។

២-ចាត់តាំងបុគ្គលិករបស់ខ្លួនឬបុគ្គលដទៃទៀតដែលមានសមត្ថភាពឱ្យត្រួតពិនិត្យជានិច្ច
កាលលើលិខិតស្នាមនិងចុះធ្វើអធិការកិច្ចដលកន្លែង ព្រមទាំងពិនិត្យបញ្ជី ការចុះបញ្ជីនិងឯកសារផ្សេងៗ
របស់គ្រឹះស្ថានទាំងនេះ ។

៣-តម្រូវឱ្យអភិបាលឬបុគ្គលិកគ្រឹះស្ថានទាំងនោះផ្តល់ដល់ធនាគារកណ្តាលនូវពត៌មាននានា
សំរាប់ធ្វើការត្រួតពិនិត្យនិងកែតំរូវ ។

៤-ប្តឹងទៅតុលាការឬដាក់កម្មវិធីតាមច្បាប់ជាធរមាន ប្រសិនបើមានការប្រព្រឹត្តល្មើស
ដោយគ្រឹះស្ថាន ឬដោយអភិបាលបុគ្គលិករបស់គ្រឹះស្ថាននោះ :

-បំពានបទបញ្ញត្តិនៃច្បាប់ជាធរមាន ឬបទបញ្ជារបស់ធនាគារកណ្តាល

-ការខ្វះខាតក្នុងការបំពេញភារកិច្ចផ្សេងៗ

-មិនគោរពវិធានការនយោបាយរូបិយវត្ថុឬវិធានការប្រុងប្រយ័ត្ននានាដែល
បានកំណត់ ។

មាត្រា ៣៤.-

ធនាគារកណ្តាលមានសិទ្ធិបើកគណនីនិងទទួលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
ដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្តល់ការប្រាក់និងយកកម្រៃដែលធនាគារកណ្តាល
ជាអ្នកកំណត់ ។

មាត្រា ៣៥.-

១-ធនាគារកណ្តាលចេញបទបញ្ជាដោយផ្សព្វផ្សាយឬជូនដំណឹងជាលាយលក្ខណ៍អក្សរដល់
ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីតម្រូវឱ្យគ្រឹះស្ថានទាំងនោះ
តំកល់ទុនបំរុងកាតព្វកិច្ច ។ ទុនបំរុងនេះត្រូវរក្សាជាសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនឬជាប្រាក់បញ្ញើពិសេស
ក្នុងគណនីចរន្តនៅធនាគារកណ្តាល ។

២-ធនាគារកណ្តាលតម្រូវរមេគុណទុនបំរុងដូចគ្នាចំពោះកិច្ចសន្យាសទិស ។ ចំនួនទឹកប្រាក់
ទុនបំរុងតម្កល់ទុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយយោលទៅតាមប្រាក់បញ្ញើនិង
កិច្ចសន្យាសទិសផ្សេងៗទៀតដែលគ្រឹះស្ថានធ្វើជាមួយអតិថិជន ។

រាល់ការកំណត់ឫការបង្កើនមេគុណទុនបំរុងកាតព្វកិច្ចនឹងចូលជាធរមាន១ខែចាប់ពីពេលដែលគ្រឹះស្ថាននោះបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ។

ធនាគារកណ្តាលអាចលើកលែងការតម្រូវទុនបំរុងជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រភេទខ្លះ

៣-ធនាគារកណ្តាលជាក់ពិន័យដោយយកកម្រៃជើងសាក្នុងមួយថ្ងៃដែលល្មើសស្មើនឹង ១/១០ (មួយភាគដប់) នៃអត្រាបុនហិរញ្ញប្បទានចុងក្រោយរបស់ធនាគារកណ្តាលលើគ្រឹះស្ថានទាំងឡាយណាដែលមិនគោរពទុនបំរុងកាតព្វកិច្ច ។ កម្រៃជើងសាទាំងនេះអាចដកយកពីសមតុល្យនៃគណនីរបស់គ្រឹះស្ថាននោះដែលមានបើកនៅធនាគារកណ្តាល ។

មាត្រា ៣៦.-

១-ធនាគារកណ្តាលត្រូវកំណត់បែបបទហើយទិញ លក់ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើអប្បហារ បុនប្បហារ កំដូចជាធ្វើកិច្ចប្រតិបត្តិការប៉ង់ស្យុងនូវ :

ក-រូបិយាណត្តិឬប័ណ្ណសងតាមបញ្ជាដែលចោះផ្សាយ ឬធ្វើឡើងសំរាប់ផ្តែកពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្មជាយថាភូតដោយមានហត្ថលេខាសាធនីយពីរយ៉ាងតិច ក្នុងនោះយ៉ាងហោចណាស់ត្រូវមានហត្ថលេខាមួយជារបស់ធនាគារពាណិជ្ជដែលមានកាលវសាន ៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលកំប៉ុន្តែរូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលចេញឬធ្វើឡើងសំរាប់ហិរញ្ញប្បទាន ផលិតកម្មឬពាណិជ្ជកម្មធញ្ជាតិ តាមរដូវកាលអាចមានកាលវសាន ២១០ថ្ងៃ គិតពីថ្ងៃចេញផ្សាយ ។

ខ-មូលប័ត្ររដ្ឋដែលបានចេញផ្សាយជាសាធារណៈនិងមានកាលវសាន ៩០ថ្ងៃ គិតគិតពីថ្ងៃដែលបានធ្វើលទ្ធកម្ម ។

គ-មូលប័ត្រឥណទេយ្យឯកជនដែលអាចជួញដូរបានលើទីផ្សាររូបិយវត្ថុព្រមទាំងឥណទេយ្យឯកជនរបស់ធនាគារ ដែលមានហត្ថលេខាសាធនីយនិងដែលមានចុះនៅក្នុងបញ្ជីដោយទទួលស្គាល់ដោយក្រុមប្រឹក្សា ។

ឃ-មូលប័ត្ររបស់ធនាគារកណ្តាលផ្ទាល់ ។

២-ធនាគារកណ្តាលត្រូវកំណត់និងចេញផ្សាយនូវអត្រាអប្បបរមាសំរាប់ធ្វើបុនអប្បហារ បុរេប្រទាន ទទួលប៊ីង់ស្យុង ឬឱ្យខ្ចី ។ ធនាគារកណ្តាលអាចកំណត់អត្រានិងពិដានអតិបរមាខុសៗគ្នាសំរាប់ប្រតិបត្តិការ ឬកាលវិសានផ្សេងៗគ្នា ។

មាត្រា ៣៧.-

ធនាគារកណ្តាលអាចផ្តល់បុរេប្រទានលើគណនីចរន្តដល់ធនាគារពាណិជ្ជដែលធានាដោយមូលប័ត្ររដ្ឋឬមូលប័ត្រធានាដោយរដ្ឋ ។

មាត្រា ៣៨.-

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ធនាគារកណ្តាលដែលប្រកាសជារួមឬដោយឡែក ស្តីពីតារាងកុលសម្ព័ន្ធ ការសន្យាក្រៅតារាងកុលសម្ព័ន្ធនិងគណនីអាជីវកម្មដែលទាក់ទងទៅនឹង :

-ដើមទុនអប្បបរមា

-ចំនួនទឹកប្រាក់អប្បបរមានៃមូលនិធិសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តាល់

-ការហាមឃាត់ ការដាក់កម្រិត លក្ខខ័ណ្ឌ បញ្ហត្តិផ្សេងៗ

២-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើសកម្មភាពដូចគ្នានិងមានស្ថានភាពហិរញ្ញវត្ថុដូចគ្នាត្រូវស្ថិតនៅក្រោមបទបញ្ជាដូចគ្នា ។

មាត្រា ៣៩.-

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនទៅធនាគារកណ្តាលនូវពត៌មានឬមិនន័យដែលធនាគារកណ្តាលសុំស្នើដើម្បីបំពេញមុខងាររបស់ខ្លួន ។

២-ក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់វិជ្ជាជីវៈ ធនាគារកណ្តាលអាចបោះពុម្ពផ្សាយទាំងស្រុងឬមួយផ្នែកនូវពត៌មានទាំងនោះឬមិនន័យរួមតាមប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬតាមប្រភេទសកម្មភាពរបស់គេ ។

៣-ធនាគារកណ្តាលទទួលរ៉ាប់រងលើកកំពស់សេវាអន្តរធនាគារដូចជាធ្វើមជ្ឈការនៃហានិភ័យ និងការមិនសងបំណុលជាដើម ។

មាត្រា ៤០.-

ក្នុងកិច្ចសហប្រតិបត្តិការជាមួយធនាគារពាណិជ្ជ ធនាគារកណ្តាលត្រូវបង្កើតសភាផាត់ទាត់មួយសំរាប់បំរើការទូទាត់អន្តរធនាគារឱ្យឆាប់រហ័សនិងមានប្រសិទ្ធិភាព ។

ជំពូកទី ៩
រូបិយវត្ថុ

មាត្រា ៤១.-

ឯកតារូបិយវត្ថុរបស់កម្ពុជាគឺរៀល។ មួយរៀលស្មើនឹងដប់កាក់ មួយកាក់ស្មើនឹងដប់សេន។ សញ្ញាសំគាល់ប្រាក់រៀលគឺអក្សរ (រ) ។

មាត្រា ៤២.-

ធនាគារកណ្តាលមានសិទ្ធិផ្តាច់មុខក្នុងការចេញផ្សាយក្រដាសប្រាក់និងកាសជារៀល កាក់និងសេន ។

មាត្រា ៤៣.-

១-ក្នុងពេលដែលមិនបានដកចេញពីចរាចរទេនោះ ក្រដាសប្រាក់និងកាសដែលចេញផ្សាយដោយធនាគារកណ្តាលគឺជារូបិយវត្ថុមានតម្លៃនិស្សន្ទកូលក្នុងព្រះរាជាណាចក្រកម្ពុជានិងមានតេជានុភាពធ្វើសេវីកាគ្មានព្រំដែនចំពោះក្រដាសប្រាក់ និងមានព្រំដែនចំពោះកាសក្នុងលំក្នុងំណួកំណត់ដោយធនាគារកណ្តាល ។

២-ការទូទាត់ណាដែលមានចំនួនទឹកប្រាក់លើសពីការកំណត់របស់ធនាគារកណ្តាលអាចឬត្រូវតែធ្វើតាមលេខនា ។

មាត្រា ៤៤.-

១-ធនាគារកណ្តាលជាអ្នកទទួលបន្ទុកក្នុងការចាត់ពុម្ពក្រដាសប្រាក់ ចាត់ពុម្ពកាសនិងការងារពាក់ព័ន្ធឯទៀតដូចជាការធានាសន្តិសុខក្នុងការថែរក្សានិងចរនាក្រដាសប្រាក់និងកាសដែលមិនទាន់

បញ្ចេញផ្សាយ ការធានាថែរក្សានិងការបំផ្លាញចោលនៅពេលចាំបាច់នូវបណ្តាពុម្ពក្រដាសប្រាក់និងកាស ដែលដកចេញពីចរាចរ ។

២-ធនាគារកណ្តាលត្រូវកំណត់ដោយបទបញ្ជានូវលក្ខណៈផ្សេងៗ តម្លៃ ទំហំ ទម្ងន់ គំរូ និងលក្ខណៈរូបភាពផ្សេងៗទៀតរបស់ក្រដាសប្រាក់ដែលត្រូវបោះពុម្ពនិងកាសដែលត្រូវចាក់ពុម្ព ។

មាត្រា ៤៥.-

ធនាគារកណ្តាលមានសិទ្ធិសំរេចប្រកាសប្តូរ ក្រោយពីមានការយល់ព្រមពីរាជរដ្ឋាភិបាលដើម្បី ដកចេញពីចរាចរនូវក្រដាសប្រាក់និងកាសដែលបានបោះផ្សាយរួចហើយ ។ ធនាគារកណ្តាលចំណាយសង តាមតម្លៃនៃក្រដាសប្រាក់ឬកាសទាំងនោះ ដោយប្តូរនឹងក្រដាសប្រាក់ឬកាសផ្សេងទៀតដែលខ្លួនបានបោះ ផ្សាយ ។ សេចក្តីសំរេចនេះត្រូវមានទម្រង់ជាបទបញ្ជារបស់ធនាគារកណ្តាលហើយត្រូវបញ្ជាក់ច្បាស់អំពី រយៈពេលនិងទីតាំងដែលត្រូវប្តូរក្រដាសប្រាក់និងកាសទាំងនោះ ។

មាត្រា ៤៦.-

នៅពេលចប់រយៈកាលប្តូរក្រដាសប្រាក់និងកាសដែលបានចែងក្នុងមាត្រា ៤៥ :

១-ក្រដាសប្រាក់និងកាសប្រមូលចូលដែលបានមកពីការប្តូរត្រូវតែលែងមានតម្លៃ និត្យានុកូល ។

២-ចំនួនទឹកប្រាក់ជាក្រដាសនិងជាកាសសរុបដែលបានប្រកាសឱ្យមកប្តូរតែមិនបាន យកមកប្តូរ ត្រូវគិតដកចេញពីបរិមាណរូបិយវត្ថុនៅក្នុងចរាចរដែលចុះក្នុងបញ្ជីធនាគារកណ្តាលហើយត្រូវ ចាត់ទុកជាប្រាក់ចំណូលរបស់ធនាគារកណ្តាល ។

មាត្រា ៤៧.-

បើមានជនណាស្នើសុំប្តូរក្រដាសប្រាក់ឬកាសដែលធនាគារកណ្តាលបោះផ្សាយនោះ ធនាគារ កណ្តាលត្រូវតែប្តូរឱ្យតាមតម្លៃស្មើដោយគ្មានគិតសោហ៊ុយអ្វីទាំងអស់ ។

មាត្រា ៤៨.-

ហាមមិនឱ្យផលិតជាថ្មីឡើងវិញនូវក្រដាសប្រាក់ កាស មូលប្បទានប័ត្រ មូលប័ត្រឬប័ណ្ណ ទូទាត់ផ្សេងៗទោះជារៀល ជាកាក់ ជាសេនក្តីឬជារូបិយវត្ថុបរទេសក្តីនិងមិនឱ្យបង្កើតវត្ថុទាំងឡាយណា

ដែលត្រាប់តាមក្រដាសប្រាក់ ការស មូលប្បទានប័ត្រ ប័ណ្ណទូទាត់ផ្សេងៗដោយពុំបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីធនាគារកណ្តាលជាមុនឡើយ ។

មាត្រា ៤៩.-

ធនាគារកណ្តាលត្រូវតែត្រួតត្រងដោយផ្ទាល់នូវសន្តិចិរូបិយវត្ថុបំរុងច្វើផែនការចោះផ្សាយនិងធានាការផ្តល់ជាទៀងទាត់នូវក្រដាសប្រាក់និងកាស ដើម្បីបំពេញតម្រូវការរូបិយវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាទាំងបរិមាណនិងគុណភាព ។

មាត្រា ៥០.-

ធនាគារកណ្តាលត្រូវដកចេញពីចរាចរនូវរូបិយវត្ថុមិនគ្រប់លក្ខណៈប្រើប្រាស់ដើម្បីបំផ្លាញចោលហើយប្តូរថ្មីជំនួសវិញ ។

មាត្រា ៥១.-

ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និងកាស បើសិនជារូបភាពវាលែងមានភាពច្បាស់លាស់ បាត់បង់រូបភាពដើមឬឆ្នុះឆ្លាយឬដែលបាត់បង់ទំហំ ៣០% (សាមសិបភាគរយ) ឬលើសពីនេះ ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរហើយបំផ្លាញចោលដោយគ្មានសំណងចំពោះម្ចាស់ទេលើកលែងតែករណីពិសេសដែលធនាគារកណ្តាលអាចយល់ព្រមសងមួយចំណែកឬទាំងអស់ ។

មាត្រា ៥២.-

ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនពត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា ៥៣.-

ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលឱ្យសង ចំពោះក្រដាសប្រាក់ឬកាសណាដែលខ្ជូនច្វើឱ្យបាត់បង់ឬច្វើឱ្យអន្តរាយឡើយ ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្លៃនូវក្រដាសប្រាក់ដែលមានការខូចខាតរូបភាពក្រៅ ជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ ចោះពុម្ព ចោះត្រាឬបិទវត្ថុស្អិតពីលើឬឆ្នុះឆ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ ។

មាត្រា ៥៤.-

បរិមាណក្រដាសប្រាក់និងកាសកំពុងធ្វើចរាចរ ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យអកម្មរបស់ធនាគារកណ្តាលដោយមិនគិតបញ្ចូលនូវបរិមាណក្រដាសប្រាក់និងកាសនៅក្នុងសន្និធិរូបិយវត្ថុបំរុងទេ ។

ជំពូកទី ១០
គណនីនិងការពិនិត្យគណនី

មាត្រា ៥៥.-

ការិយបរិច្ឆេទគណនេយ្យនៃធនាគារកណ្តាល ចាប់ផ្តើមពីថ្ងៃទី០១ខែមករាដល់ថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ ។

មាត្រា ៥៦.-

ធនាគារកណ្តាលត្រូវ :

១-កាន់កាប់បញ្ជីគណនេយ្យនិងបញ្ជីផ្សេងៗទៀតហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែលឆ្លុះបញ្ចាំងដោយច្រាកដប្រជានូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ស្របទៅតាមគោលការណ៍និងបែបបទគណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅសំរាប់ធនាគារកណ្តាល ។

២-រៀបចំនិងចេញផ្សាយរបាយការណ៍សង្ខេបប្រចាំខែស្តីពីស្ថានភាពនៃសកម្មភាពរបស់ខ្លួន។

៣-ជាក់ជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាក្នុងអំឡុង ៦ខែ បន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនីមួយៗនូវច្បាប់ចម្លងនៃគណនីប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍ដែលអាចចេញផ្សាយបាន ស្តីពីប្រតិបត្តិការរបស់ខ្លួននិងស្តីពីស្ថានភាពសេដ្ឋកិច្ចរូបិយវត្ថុក្នុងការិយបរិច្ឆេទកន្លងមក ។

មាត្រា ៥៧.-

ការពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាលត្រូវធ្វើឡើងដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល ។

ជំពូកទី ១១

បទបញ្ញត្តិផ្សេងៗ

មាត្រា ៥៨.-

ធនធាន ទ្រព្យសម្បត្តិ ប្រភពលាភ ប្រតិបត្តិការនិងអាជីវកម្មរបស់ធនាគារកណ្តាលត្រូវបានលើកលែងមិនយកពន្ធនិងអាករឡើយ ។

មាត្រា ៥៩.-

ធនាគារកណ្តាលមិនត្រូវចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងសហគ្រាសដែលមានលក្ខណៈឧស្សាហកម្មឬពាណិជ្ជកម្មឡើយ លើកលែងតែគ្រឹះស្ថានដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយសកម្មភាពរបស់ធនាគារកណ្តាល ដូចជាការវាយតម្លៃនិងការពិនិត្យកិច្ចសន្យាធានា ប្រព្រឹត្តកម្មនិងការបញ្ជូនមិនន័យ ការចោះពុម្ពឯកសារហិរញ្ញវត្ថុ ការជាត់ទាត់សងគ្នា ការបញ្ជូនសារលិខិតឬការជម្រះបញ្ជីទ្រព្យសម្បត្តិក្នុងលក្ខខ័ណ្ឌដែលទឹកប្រាក់ចូលហ៊ុនទាំងអស់នោះមិនលើសពី ៥% (ប្រាំភាគរយ) នៃមូលនិធិរបស់ខ្លួនផ្ទាល់ ។

មាត្រា ៦០.-

ធនាគារកណ្តាលមិនត្រូវធ្វើលទ្ធកម្មដោយទិញឬដោយកតិសន្យានូវសិទ្ធិពិតប្រាកដលើអចលនទ្រព្យ លើកលែងតែទ្រព្យសម្បត្តិណាដែលចាំបាច់សំរាប់ធ្វើសកម្មភាពនិងមុខងាររបស់ខ្លួនឬសំរាប់ការងារសង្គមកិច្ចចំពោះបុគ្គលិករបស់ខ្លួន ។

បទបញ្ញត្តិនៃមាត្រានេះពុំឃាត់ធនាគារកណ្តាលមិនឱ្យធ្វើលទ្ធកម្មក្នុងក្របខ័ណ្ឌនៃការទូទាត់សងឥណទេយ្យរបស់ខ្លួននូវសិទ្ធិដែលមានចែងក្នុងមាត្រា ៥៩ឬមាត្រានេះទេ ។

មាត្រា ៦១.-

រាល់ប្រកាស បទបញ្ជា សារាចរនិងបណ្តាសេចក្តីណែនាំផ្សេងៗដែលចេញដោយធនាគារកណ្តាលសំរាប់អនុវត្តជាទូទៅចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការផ្សព្វផ្សាយក្នុងរាជកិច្ចហើយចូលជាធរមានបញ្ជាក់ចាប់តាំងពីថ្ងៃចេញផ្សាយនោះឬតាមកាលកំណត់ដែលមានចែងក្នុង ប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទាំងនោះ ។

មាត្រា ៦២.-

ដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ធនាគារកណ្តាលអាចធ្វើបណ្តឹងខាងផ្នែករដ្ឋប្បវេណីភ្ជាប់ជាមួយផ្នែកព្រហ្មទណ្ឌនូវគ្រប់ដំណាក់កាលនៃនីតិវិធី ។

មាត្រា ៦៣.-

ការកម្រិតឥណទាននៅក្នុងចំណុច ៣ មាត្រា ២៥ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះឥណទានណាដែលត្រូវផ្តល់ឱ្យក្រោយថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

ជំពូកទី ១២
ទោសប្បញ្ញត្តិ

មាត្រា ៦៤.-

ជនណាពុំព្រមទូទាត់រូបិយវត្ថុដែលមានតម្លៃនីតិានុកូលនិងមានតេជានុភាពធ្វើសេវីកាលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់ដែលពុំព្រមទូទាត់នោះ ។

មាត្រា ៦៥.-

អ្នកក្លែងក្រជាសប្រាក់ឬកាសដែលជារូបិយវត្ថុមានតម្លៃនីតិានុកូលនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើដែនដីនៃរដ្ឋដទៃទៀតនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់អស់មួយជីវិត ។

វត្ថុតាងដែលរឹបអូសបានត្រូវទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

មាត្រា ៦៦.-

ជនណាប្រព្រឹត្តដោយចេតនាដោយបញ្ចូលក្នុងចរាចរឬរក្សាទុកសំរាប់ចរាចរនូវក្រជាសប្រាក់ឬកាសក្លែងក្លាយ ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

មាត្រា ៦៧.-

ជនណាប្រើប្រាស់ឬរក្សាទុកដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលនូវបណ្តាសម្ភារៈ ឧបករណ៍ គ្រឿងយន្តនិងប្រដាប់សំរាប់ផលិតក្រដាសប្រាក់ឬកាស ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ឯវត្ថុតាងនឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

មាត្រា ៦៨.-

ជនណាទទួលក្រដាសប្រាក់ឬកាសដែលក្រោយមកបានដឹងថាជាក្រដាសប្រាក់ឬកាសក្លែងក្លាយហើយនៅតែយកទៅដាក់ឱ្យធ្វើចរាចរវិញ ជននោះត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដង នៃទឹកប្រាក់នោះ ។

មាត្រា ៦៩.-

ដើម្បីអនុវត្តនិងបំពេញមុខងារឱ្យបានល្អតាមច្បាប់នេះ ធនាគារកណ្តាលអាចស្នើសុំពត៌មានដែលខ្លួនត្រូវការពីរូបវន្តបុគ្គលឬនីតិបុគ្គលដែលពាក់ព័ន្ធ រួមទាំងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអង្គភាពក្រោមឱវាទទៀតផង ។

ជនណាដែលមិនព្រមផ្តល់ពត៌មានដែលធនាគារកណ្តាលបានស្នើសុំស្របតាមមាត្រានេះឬដែលមានចេតនាផ្តល់ពត៌មានខុសឬបំភាន់ ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000 រ (មួយលានរៀល) ដល់ ១0.000.000 រ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧0.-

ជនណាគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើសកម្មភាពមានលក្ខណៈជាធនាគារដូចជាឥណទាន ជំនួញជើងសារូបិយប័ណ្ណ ការប្តូររូបិយប័ណ្ណ ការទទួលប្រាក់ពីសាធារណជន ការគ្រប់គ្រងមធ្យោបាយទូទាត់ ប្រតិបត្តិការលើមូលប័ត្រ អាជីវកម្មមាស លោហធាតុនិងត្បូងថ្មមានតម្លៃដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលត្រូវបញ្ឈប់សកម្មភាពភ្លាមតាមអធិបញ្ជារបស់ធនាគារកណ្តាល ។ ជនដែលប្រព្រឹត្តល្មើសនឹងអធិបញ្ជានេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000រ (មួយលានរៀល)ដល់ ១0.000.000 រ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧១.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៥ ចំណុច ១ និងមាត្រា ១៦ និងត្រូវបានផ្តន្ទាទោសកំន៍យជាប្រាក់ពី ១.០០០.០០០ រ (មួយលានរៀល)ដល់ ១០.០០០.០០០ រ (ដប់លានរៀល) និង/ឬជាកំនួនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

ជំពូកទី ១៣

អវសានប្បញ្ញត្តិ

មាត្រា ៧២.-

បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ ១៩៩៦

ព្រះបាទសម្តេច

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ៖

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

លេខ : ៣៦ ប.ល.

ចម្លងត្រឹមត្រូវ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ចៅ ចៃយណាត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧

នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

នៃធនាគារជាតិ នៃ កម្ពុជា



ព្រះរាជក្រម

ណស/រកម/១២០៦ /០៣៦ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិថាតិសាសនា រក្ខគខត្តិយា ខេមរារដ្ឋារស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាថនា សម្ភូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណាសន្តិ សុភមង្គលា សិរីនិបុណា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រ កត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងពាក្យនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧
នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

មាត្រាមួយ.-

មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា ១៤ .- ថ្មី

១-សមាជិកនៃក្រុមប្រឹក្សា ត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍ និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានអាយុមិនលើសពី ៦៥ ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសម្រាប់រយៈពេល ៤ ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបាន ។ ចំពោះក្រុមប្រឹក្សាលើកទី ១ ដែលបង្កើតតាមច្បាប់នេះ លើកលែងតែទេសាភិបាលទេសាភិបាលរង និងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២ រូប ត្រូវចប់ក្នុងរយៈពេល ២ ឆ្នាំ ក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងត្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២_ សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក_ ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាល ឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬ ផ្នែកពាណិជ្ជកម្ម ។

ខ_ មានសេចក្តីសម្រេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ ដែលចែងក្នុងមាត្រា ១៥ និង១៦ នៃច្បាប់នេះ ។

គ_ អវត្តមានក្នុងការប្រជុំជាប់ៗគ្នា ៤ ដង លើកលែងតែមានហេតុផលសមរម្យ និងក្នុងករណីប្រធានសម្តី ដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ_ លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង_ មិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន ដោយចាត់បង់សមត្ថភាពពលកម្ម និងវិបត្តិស្មារតី ។

ច_ ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣_ ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើយ៉ាងហោចណាស់ ២ ខែ ម្តង ។

៤_ សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្សាចំវត្តមាន ដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥_ ទេសាភិបាល និងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមួលដ្ឋានពីធនាគារកណ្តាលស្មើនឹងសមាជិកនៃរាជរដ្ឋាភិបាល ។

មាត្រា ៥៧ .– ថ្មី

ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា-
ភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ ។

មាត្រា ៥៨.–

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ក្នុង ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ជកររ
ជា ស៊ីម

៣រស.០៦១២.៥៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមព្រះរាជទានព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
ហត្ថលេខា
ជា ចាន់តូ

លេខ : ១៧. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ម.ស.ា ឆ្នាំ ២០០៧
អគ្គលេខាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ
ឃុន ជិនភេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

ការគ្រប់គ្រងការប្តូរប្រាក់

ជស/រកម/០៨៩៧/០៣

ព្រះរាជក្រម

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ខ្ចតគោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង ឯកឧត្តម ថោ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និង អំពី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីតាំងស្រុងដូចតទៅ :

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.

ច្បាប់នេះអនុវត្តចំពោះរាល់ប្រតិបត្តិការរូបិយប័ណ្ណនិងជាទូទៅគឺ រាល់ប្រតិបត្តិការដែលប្រព្រឹត្តឡើងរវាងនិវេសជននិងអនិវេសជនទាក់ទងទៅនឹង :

- ការទូទាត់ពាណិជ្ជកម្ម
- ការផ្ទេរប្រាក់ ឬ
- ចលនានៃដើមទុន ដោយរាប់បញ្ចូលទាំងការវិនិយោគផង ។

មាត្រា ២.

ត្រូវចាត់ទុកជារូបិយប័ណ្ណ សំរាប់ការអនុវត្តច្បាប់នេះ :

- មធ្យោបាយទូទាត់ឬមូលប័ត្រ ជារូបិយវត្ថុបរទេស
- មាសមិនទាន់កែឆ្នៃឬលោហធាតុមានតំលៃផងទៀតមិនទាន់កែច្នៃនិងត្បូងថ្មមានតំលៃមិនទាន់កែច្នៃ ។

មាត្រា ៣.

ត្រូវចាត់ទុកជានិវេសជន :

- រូបវន្តបុគ្គលទាំងឡាយដោយពុំគិតពីសញ្ជាតិ ដែលមានសកម្មភាពចំបងឬមានលំនៅឋានចំបងនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ) ឡើងទៅ រៀរលែងតែមន្ត្រីបរទេស ដែលបំពេញបេសកកម្មការទូតឬបេសកជនប្រហាក់ប្រហែល
- នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសនិងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នីតិបុគ្គលនៃច្បាប់ក្រៅប្រទេស
- គ្រប់មន្ត្រីរាជការខ្មែរបំពេញភារកិច្ចនៅបរទេស ដោយឥតគិតពីរយៈពេលនៃការស្នាក់នៅ ។

មាត្រា ៤.

ត្រូវចាត់ទុកជាអនិវេសជន :

- រូបវន្តបុគ្គលសញ្ជាតិខ្មែរ ដែលមានសកម្មភាពចំបងឬលំនៅឋានចំបង

នៅបរទេសចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ) ឡើងទៅ

- រូបវន្តបុគ្គលបរទេសដែលមានសកម្មភាពចំបងឬលំនៅឋានចំបងនៅព្រះរាជាណាចក្រកម្ពុជា តិចជាងមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ)
- នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសដែលមានទីតាំងនៅបរទេសនិងសាខានៅបរទេសរបស់នីតិបុគ្គលនៃច្បាប់ក្នុងប្រទេស
- មន្ត្រីបរទេសដែលបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ឬបេសកជនប្រហាក់ប្រហែល ។

ជំពូកទី ២

អន្តរការិយកម្មធនាគារ

មាត្រា ៥.

១- រាល់ប្រតិបត្តិការប្តូរប្រាក់តាមរបៀបលេខនាដោយមានរាប់បញ្ចូលការទិញនិងការលក់រូបិយប័ណ្ណលើផ្សារប្តូរប្រាក់ផង ការផ្ទេរប្រាក់ ការទូទាត់ក្រៅប្រទេសគ្រប់ប្រភេទក៏ដូចជាចលនានៃដើមទុនជារូបិយប័ណ្ណ ឬជារូបិយវត្ថុជាតិរវាងកម្ពុជានិងប្រទេសក្រៅ ឬរវាងនិវេសជននិងអនិវេសជន អាចប្រព្រឹត្តទៅដោយសេរី ប៉ុន្តែប្រតិបត្តិការទាំងនោះ ត្រូវតែអនុវត្តដោយឆ្លងតាមអន្តរការីប្រតិស្រុតិ ។

២- មានតែធនាគារដែលមានទីតាំងជាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេដែលត្រូវបានចាត់ទុកជាអន្តរការីប្រតិស្រុតិ ។

៣- អន្តរការីប្រតិស្រុតិ ក្រោមល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងបទបញ្ជា ត្រូវបង្ខំឲ្យផ្តល់ជូនធនាគារកណ្តាលជាទៀងទាត់ នូវរបាយការណ៍តាមកាលកំណត់តាមប្រភេទនៃប្រតិបត្តិការផ្ទេរប្រាក់ឬការទូទាត់និងចលនានៃដើមទុនចេញ និងចូលដែលបានអនុវត្តរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសក្រៅទៅតាមរយៈពេលដែលនឹងកំណត់ដោយធនាគារកណ្តាល ។

៤- អន្តរការីប្រតិស្រុតិដែលធ្វើការនាំចេញសាច់ប្រាក់ជារូបិយប័ណ្ណ ត្រូវធ្វើប្រតិវេទន៍ជាមុនជូនធនាគារកណ្តាល ។

៥- អាជីវករប្តូរប្រាក់ដល់ដៃដែលមានទីតាំងអចល័តឬចល័តអាចធ្វើសកម្មភាពប្តូរប្រាក់បានលុះត្រាតែបានទទួលការអនុញ្ញាតជាមុនពីធនាគារកណ្តាល ។

មាត្រា៦.

ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសំរាប់រយៈពេលយ៉ាងយូរ៣ខែ ដើម្បីកំណត់ល័ក្ខខ័ណ្ឌបណ្តោះអាសន្នខ្លះចំពោះសកម្មភាពរបស់អន្តរការីប្រតិស្រុតិ ជាអាទិ៍ចំពោះប្រតិបត្តិការដែលមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ ឬស្ថានភាពរូបិយប័ណ្ណរបស់ខ្លួនឬការឱ្យខ្ចីជារូបិយវត្ថុជាតិទៅអនិវេសជន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

មាត្រា ៧.

និវេសជនអាចកាន់រក្សាទុកនូវរូបិយប័ណ្ណដោយសេរីទាំងទម្រង់ ទាំងទីកន្លែងនៅក្នុងប្រទេស ។ ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសម្រាប់រយៈពេលយ៉ាងយូរ ៣ខែ ដើម្បីផ្អាកមិនឱ្យអនុវត្តបទប្បញ្ញត្តិនេះជាបណ្តោះអាសន្ន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

ជំពូកទី ៣
ប្រតិបត្តិការចរន្ត

មាត្រា ៨.

អ្នកនាំចេញឬអ្នកនាំចូលទំនិញឬសេវា ត្រូវធ្វើការទូទាត់តាមរយៈអន្តរការីប្រតិស្រុតិនូវប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនជាមួយប្រទេសក្រៅ ។

មាត្រា ៩.

ធនាគារកណ្តាលអាចទាមទារឱ្យអន្តរការីប្រតិស្រុតិបង្ហាញនូវសក្តីប័ត្រធនាគារវិកប្ប នៅពេលដែលដាក់ពាក្យសុំទិញរូបិយប័ណ្ណដើម្បីទូទាត់ការនាំចូល និងនៅពេលក្រោយមកទៀតនូវសក្តីប័ត្ររដ្ឋបាលផ្សេង។ទៀតដែលបញ្ជាក់ថា ទំនិញបាននាំចូលមកក្នុងប្រទេសរួចហើយ ។

មាត្រា ១០.

ចាប់តាំងពីពេលធ្វើបេឡានិច័យ ប្រាក់ចំណូលដែលបានមកពីការនាំចេញទំនិញឬសេវា ត្រូវបញ្ចូលក្នុងខ្នង់ឥណទានៃគណនីរបស់អ្នកនាំចេញ ដែលមានបើកនៅធនាគារវិកប្បស្របតាមមាត្រា៨ នៃច្បាប់នេះ ។

មាត្រា ១១.

មូលនិធិបរិភាគជារូបិយវត្ថុជាតិ ដែលបានមកពីការធ្វើពាណិជ្ជកម្មក្នុងប្រទេសនូវទំនិញនាំចូលក្នុងក្របខ័ណ្ឌការខ្ចីប្រាក់ពីក្រៅឬជាអំណោយ ត្រូវបង់ចូលខ្នង់ឥណទាននៃគណនីរបស់រតនាគារជាតិ ដែលបើកនៅធនាគារកណ្តាល នៅតាមបែបបទដែលនឹងត្រូវកំណត់តាមកិច្ចព្រមព្រៀងរួមរវាងរតនាគារជាតិនិងធនាគារកណ្តាល ។

មាត្រា ១២.

រាល់ការនាំចេញឬការនាំចូលមាសមិនទាន់កែច្នៃ ត្បូងថ្មមានតំលៃមិនទាន់កែច្នៃឬលោហធាតុមានតំលៃមិនទាន់កែច្នៃផងទៀត អាចដំណើរការដោយសេរី ស្របតាមចំណុច ១ មាត្រា ៥ នៃច្បាប់នេះ ប៉ុន្តែត្រូវធ្វើប្រតិវេទន៍ជាមុននៅធនាគារកណ្តាល បើចំនួនទំនិញនៃប្រតិបត្តិការនីមួយៗមានតំលៃស្មើឬលើសពីមួយម៉ឺន (១០.០០០) ដុល្លារអាមេរិក ។

មាត្រា ១៣.

ការនាំចេញឬការនាំចូលដោយអ្នកដំណើរនូវមធ្យោបាយទូទាត់ជារូបិយប័ណ្ណដែលមានទឹកប្រាក់ស្មើឬលើសពីមួយម៉ឺន (១០.០០០) ដុល្លារអាមេរិក ឬជារូបិយវត្ថុជាតិដែលមានតំលៃសមមូលនឹងមួយម៉ឺន (១០.០០០) ដុល្លារអាមេរិកឬច្រើនជាងនេះ ត្រូវតែធ្វើប្រតិវេទន៍ចំពោះមន្ត្រីគយនៅពេលឆ្លងកាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ។

សាច់ប្រាក់ចាប់តាំងពីកិរិតមួយដែលកំណត់ដោយបទបញ្ជារបស់ធនាគារកណ្តាល អ្នកនាំចេញត្រូវដាក់ជូនធនាគារកណ្តាលពិនិត្យជាមុន មុននឹងធ្វើការនាំចេញ ។

ជារៀងរាល់ខែ ទីចាត់ការគយនិងរដ្ឋាករត្រូវបញ្ជូនបញ្ជីនៃប្រតិវេទន៍ដូចបានកំណត់ខាងលើទៅធនាគារកណ្តាល ។

ជំពូកទី៤

ការវិនិយោគ ចលនានៃដើមទុន

មាត្រា ១៤.

ចលនានៃដើមទុនទាក់ទងនឹងការវិនិយោគបរទេសនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥

ក្នុងករណីដែលការជំរះបញ្ជីនៃការវិនិយោគបរទេសបានប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ផលដែលបានមកពីការជំរះបញ្ជីនោះនឹងត្រូវផ្ទេរបានដោយសេរី ។

មាត្រា ១៦

ការធ្វើវិនិយោគនៃនិវេសជននៅបរទេស ត្រូវធ្វើប្រតិវេទន៍ជាមុនដល់ធនាគារកណ្តាល បើទឹកប្រាក់មានចំនួនស្មើឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

មាត្រា ១៧

ការផ្ទេរប្រាក់ទាក់ទងនឹងការធ្វើវិនិយោគឬការជំរះបញ្ជីនៃការធ្វើវិនិយោគ ត្រូវធ្វើតាមរយៈអន្តរការីប្រតិស្រុតិដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។ អន្តរការីប្រតិស្រុតិត្រូវធ្វើរបាយការណ៍ជូនធនាគារកណ្តាលជាក្រោយលើទឹកប្រាក់ធ្វើប្រតិបត្តិការម្តងៗមានចំនួនស្មើ ឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

ជំពូកទី ៥
ចលនានៃដើមទុនផ្សេងៗ

មាត្រា ១៨

ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ ដោយរាប់បញ្ចូលទាំងឥណទានពាណិជ្ជកម្មផងរវាងនិវេសជននិងអនិវេសជនអាចប្រព្រឹត្តទៅដោយសេរី ឲ្យតែការខ្ចីនិងការសងវិញ ធ្វើតាមរយៈអន្តរការីប្រតិស្រុតិ ។

មាត្រា ១៩

ចលនានៃដើមទុនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ (ការទូទាត់ថ្លៃទំនិញឬសេវានាំចូលនិងនាំចេញ ការផ្ទេរប្រាក់ ការវិនិយោគ ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ) ត្រូវបញ្ចូលក្នុងរបាយការណ៍ធនាគារជាប្រចាំតាមការកំណត់ដែលមានចែងក្នុងចំណុច ៣ មាត្រា ៥ នៃច្បាប់នេះ ។ ចលនានៃដើមទុនទាំងនោះត្រូវកត់ត្រាតាមប្រភេទប្រតិបត្តិការនិមួយៗ ហើយត្រូវគោរពដល់ការសម្ងាត់វិជ្ជាជីវៈ ។

ជំពូកទី៦
ទោសប្បញ្ញត្តិ

មាត្រា ២០

អន្តរការីប្រតិស្រុតិមានភារៈ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយប្រុងប្រយ័ត្នន្វាការគោរពបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ឬដែលមានចែងក្នុបទបញ្ជាទាំងឡាយនៃធនាគារកណ្តាលដើម្បីអនុវត្តប្រតិបត្តិការដែលខ្លួនបានធ្វើដោយផ្ទាល់ឬដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

អន្តរការីប្រតិស្រុតិណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ២១

ជនណាប្រព្រឹត្តល្មើសនឹងចំណុច៣ ឬ ចំណុច៤ ឬ ចំណុច៥ នៃមាត្រា៥ ឬប្រព្រឹត្តល្មើសនឹងមាត្រា១៧ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ ដប់លានរៀល(១០.០០០.០០០រៀល) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

មាត្រា ២២

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា១១ឬវាក្យខ័ណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ស្មើនឹងដប់ភាគរយ(១០ភាគរយ) នៃទឹកប្រាក់ល្មើស ។

មាត្រា ២៣

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១២ ឬមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងម្ភៃភាគរយ(២០ភាគរយ)នៃទឹកប្រាក់ល្មើស ។

មាត្រា ២៤

ជនណាប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ដប់លានរៀល(១០.០០០.០០០រៀល) ។ រីឯវត្ថុតាងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

មាត្រា ២៥

ជនណាប្រព្រឹត្តល្មើសនឹងចំណុច ១ មាត្រា ៥ ឬមាត្រា ៨ ឬមាត្រា ១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងហាសិបភាគរយ (៥០ភាគរយ) នៃទឹក ប្រាក់ល្មើស ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ២៦

បទប្បញ្ញតិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ សីហា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ហត្ថលេខា	**ហត្ថលេខា**
ង៉ឹច ហួត	**ហ៊ុន សែន**

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ថោ ប៊ែនណាត

លេខ: ១៨៧ ធ.ល

ដើម្បីចម្លងចែក

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ១៩៩៧

អគ្គលេខាធិការរដ្ឋបាលធនាគារ

ជា ឆាន់

រាជកិច្ចឆ្នាំទី ៥ លេខ៣១ ស្ងួន ថ្ងៃទី២៣ ខែសីហា ឆ្នាំ ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

គ្រឹះស្ថានធនាគារ

និង

ហិរញ្ញវត្ថុ

ព្រះរាជក្រម

នស/រកម/១១៩៩/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ខ្ញុកតោសុជាត ឥសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- ចាន់ទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ចាន់ទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៥១ ៥៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ចាន់ទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកស/១១៩៧/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ចាន់ទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ចាន់ទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសអោយប្រើ

ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះ ឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ស្របតាមរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ជំពូកទី ១

អន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុ

មាត្រា ១.-

ធនាគារគឺជានីតិបុគ្គល ដែលមាននីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី ។

មាត្រា ២.-

ប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន :

១- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកំរៃ រាប់បញ្ចូលទាំងឥណទានកិតិសន្យានិងការសន្យាតាមហត្ថលេខា ។

២- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន ។

៣- ប្រព្រឹត្តិកម្មនិងការដាក់អោយអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយប័ណ្ណ ។

អង្គភាពណាក៏ដោយ អោយតែអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំងពាប្រភេទខាងលើនេះ ត្រូវបានចាត់ទុកជាបានធ្វើអាជីវកម្មធនាគារ តាមការដាក់ស្តែង ។

អង្គភាពណា ដែលអនុវត្តតែសកម្មភាពមួយក្នុងចំណោមសកម្មភាពជាមូលដ្ឋានទាំងពានេះ ឬអនុវត្តតែផ្នែកមួយនៃសកម្មភាពនីមួយៗនោះ ត្រូវបានអោយឈ្មោះថាជាធនាគារឯកទេស ។

មាត្រា ៣.-

ចំពោះសាធារណជនឬសំរាប់ខ្លួនឯងផ្ទាល់ ធនាគារអាចធ្វើបាននូវ :

១- រាល់ប្រតិបត្តិការហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ វៀរលែងតែ ប្រតិបត្តិការធានារ៉ាប់រងដែលត្រូវកំណត់ដោយច្បាប់ធានារ៉ាប់រងដោយឡែក ។

២- រាល់ប្រតិបត្តិការប្តូរប្រាក់ ។

៣- អន្តរការិយកម្មនិងការអនុវត្តន៍រាល់ប្រតិបត្តិការលើមូលប័ត្រឥណទេយ្យជួញដូរបាននៅ

លើទីផ្សារ ។

៤- វាល់ប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ។

៥- សេដ្ឋពាណិជ្ជកម្មដល់ដៃឬមានកាលកំណត់ លើលោហធាតុនិងត្បូងថ្មមានតម្លៃ និងវត្ថុធាតុដើមឬទំនិញ ។

៦- ប្រតិបត្តិការលើសេវាកម្មដទៃទៀត ដែលផ្សារភ្ជាប់នឹងសកម្មភាពចំបងរបស់ខ្លួន ដោយមានការយល់ព្រមពីអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារ ។

មាត្រា ៤.-

ធនាគារ ដូចដែលបានកំណត់និយមន័យមកហើយ អាចអនុវត្ត សំរាប់ខ្លួនឯងផ្ទាល់ឬសំរាប់អតិថិជនរបស់ខ្លួន ដោយផ្ទាល់ឬតាមរយៈការចូលហ៊ុនទៅក្នុងក្រុមហ៊ុនឯកទេសណាមួយឬច្រើន នូវប្រតិបត្តិការផ្សេងៗលើមូលប័ត្រ ដែលបង្កបង្កើតនូវអន្តរការិយកម្មហិរញ្ញវត្ថុ ជាអាទិ៍រួមមាន :

១- ការប្រមូលមូលនិធិសំរាប់បរិវិសកម្ម ឬសំរាប់ទិញមូលប័ត្រ តាមបញ្ជារបស់អតិថិជនជាឯកត្តជនឬជាក្រុមប្រមូលផ្តុំជាអង្គភាពបណ្តាក់ទុនសមូហភាព ។

២- បរិវិសកម្មនិងការជួញដូរមូលប័ត្រ ។

៣- ការរក្សាទុកមូលប័ត្រ ។

៤- ការគ្រប់គ្រងមូលប័ត្រ ជាឯកត្តជនឬជាសមូហភាព ។

៥- ការទិញផ្តាច់មូលប័ត្រនៅពេលផ្សាយចេញ ។

៦- វិស្វកម្មហិរញ្ញវត្ថុ ។

៧- ការជួញដូរឧបករណ៍និស្សន្ទទាក់ទងនឹងសកម្មភាពរបស់ខ្លួន ។

៨- ប្រតិបត្តិការគ្រប់ប្រភេទលើមូលប័ត្រធ្វើឡើងសំរាប់ខ្លួនផ្ទាល់ក្នុងនាទីជាក្រុមហ៊ុនពាណិជ្ជកម្មចំណុះច្បាប់ទូទៅនិងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៥.-

សំរាប់តតិយជន ក្រុមហ៊ុនហិរញ្ញវត្ថុឯកទេសឯទៀតក៏អាចធ្វើប្រតិបត្តិការលើមូលប័ត្រដូចធនាគារដែរ ។

មាត្រា ៦.-

ពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ក្រុមហ៊ុនហិរញ្ញវត្ថុត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជាស្របតាមបទប្បញ្ញត្តិនៃមាត្រា ៧ ចំណុច ៤ និងចំណុច ១១ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ។

ប៉ុន្តែរាល់ប្រតិបត្តិការលើមូលប័ត្រដែលអនុវត្តដោយធនាគារនិងដោយក្រុមហ៊ុនហិរញ្ញវត្ថុក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើលរបស់គណៈកម្មការពិសេសមួយដោយឡែក ចំពោះការចេញផ្សាយ តម្លាភាពនៃការជូញដូរ និងកិច្ចការពារប្រាក់សន្សំវិនិយោគក្នុងសង្គារីមប័ណ្ណ ។

សមាសភាពនិងតួនាទីរបស់គណៈកម្មការនេះត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ជាដែលគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ ។

មាត្រា ៧.-

អាជ្ញាធរអាណាព្យាបាលនៃប្រពន្ធ័ធនាគារនិងអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធហិរញ្ញវត្ថុត្រូវសហការក្នុងការកំណត់បែបបទ លើសកម្មភាពមូលប័ត្រ ឬ ក្នុងឱកាសដែលចេញអាជ្ញាប័ណ្ណ ឬ តាមការចេញបទបញ្ជា ដើម្បីជៀសវាងការភ័ន្តច្រឡំ ដែលអាចកើតមានឡើងពីសកម្មភាពជាន់គ្នាមួយចំនួន នៅក្នុងរង្វង់ធនាគារ ឬ នៅក្នុងរង្វង់ក្រុមហ៊ុនហិរញ្ញវត្ថុឯកទេស ដូចជាការប្រមូលប្រាក់បញ្ញើមានមុខសញ្ញា ការរក្សាទុកឬការគ្រប់គ្រងមូលប័ត្រ ។

មាត្រា ៨.-

រាល់ប្រតិបត្តិការដែលប្រទាក់ក្ងានឹងសកម្មភាពធនាគារ ដូចមានចែងនៅក្នុងមាត្រា ៣ កថាខ័ណ្ឌ ២-៣-៤-និង ៥ នៃច្បាប់នេះ អាចធ្វើឡើងបានដោយអង្គភាពមិនមែនធនាគារតែក្នុងលក្ខខណ្ឌដែលមានកំណត់ដោយអាជ្ញាធរអាណាព្យាបាល ប្រសិនបើប្រតិបត្តិការទាំងនោះធ្វើសំរាប់សាធារណជន ។

ជំពូកទី ២

ដែននៃការអនុវត្តន៍

មាត្រា ៩.-

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចដែលបានកំណត់ន័យក្នុងជំពូកទី១ខាងលើ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ និងត្រូវបានហៅថា "គ្រឹះស្ថានចំណុះច្បាប់នេះ" ក្នុងមាត្រាបន្តបន្ទាប់ទៅនេះ ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយត្រូវបានហាមឃាត់មិនអោយយកប្រតិបត្តិការធនាគារធ្វើជាអាជីវកម្មប្រក្រតី ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយ មិនត្រូវប្រើប្រាស់នូវនាមករណ៍ឬយីហោ ឬពាណិជ្ជសញ្ញា ឬសេវាសញ្ញា ការផ្សាយដំណឹងពាណិជ្ជកម្មឬរាល់សំនួនពាក្យដទៃទៀត ដែលនាំអោយមានការយល់ច្រឡំថាខ្លួនត្រូវបានប្រតិស្រុតអោយធ្វើសកម្មភាពណាមួយក្រោមការអនុញ្ញាតនៃច្បាប់នេះ ។

មាត្រា ១០.-

បណ្តាគ្រឹះស្ថានចំណុះច្បាប់នេះ ក្រៅពីត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្មឬក្រោមលក្ខន្តិកៈនីត្យានុកូលពិសេសនៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះថែមទៀត ។

ក្នុងករណីមានខ្វិមសារខ្វែងគ្នារវាងអត្ថបទច្បាប់ទាំងនេះ គឺបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវយកជាបានការ ។

ជំពូកទី ៣

រូបភាពគតិយុត្តរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

មាត្រា ១១.-

គ្រឹះស្ថានចំណុះច្បាប់នេះត្រូវតែបានបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនភាគហ៊ុននៃច្បាប់

ពាណិជ្ជកម្មឬក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គហសមាគមឬសហករណ៍ដែលស្ថិតនៅក្រោម លក្ខន្តិកៈនីត្យានុកូលដោយឡែក ។

ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គហសមាគមឬសហករណ៍ ត្រូវតែបានប្រមូលផ្តុំគ្នាជាសហពន្ធ ដែលហៅថាអង្គការកណ្តាល ។

អង្គការកណ្តាលទាំងនេះ ត្រូវទទួលបន្ទុកក្នុងការជម្រុញអោយមានសិទ្ធិពលរវាងបណ្តាញនៃ ត្រីះស្ថានដែលចូលជាសមាជិក ហើយធានាដំណើរការអោយបានត្រឹមត្រូវ ។

ដើម្បីសំរេចតាមបំណងខាងលើ អង្គការកណ្តាលទាំងនេះត្រូវចាត់វិធានការចាំបាច់ជាអាទិ៍ ដើម្បី ធានាអោយមានសាច់ប្រាក់ងាយស្រួលនិងសាធនភាពនៃត្រីះស្ថានទីមួយៗនៃបណ្តាញទាំងមូល ។

អង្គការកណ្តាលខ្លួនឯងទាំងនេះក៍ត្រូវបានចាត់ទុកជាត្រីះស្ថានចំណុះច្បាប់នេះដែរ ។

មាត្រា ១២.-

ត្រីះស្ថានចំណុះច្បាប់នេះ ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចជាក្រុមហ៊ុនក្រោម ច្បាប់ក្នុងស្រុកឬជាសាខារបស់ធនាគារបរទេស ។

មាត្រា ១៣.-

ធនាគារបរទេសអាចបើក នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន នូវការិយាល័យដែលមាន សក្តានុភាព ខាងពត៌មាន សម្ព័ន្ធការ ឬជាតំណាង បន្ទាប់ពីបានទទួលការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែ ការិយាល័យទាំងនេះមិនអាចធ្វើប្រតិបត្តិការអន្តរការិយកម្មធនាគារឬហិរញ្ញវត្ថុនិងការស្វែងរកអតិថិជនបាន ឡើយ ។

ការបោះទីតាំងទាំងនោះ អាចប្រកាន់យកទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុកឬជាត្រីះស្ថានសាមញ្ញ ឬជាអ្នកទទួលសិទ្ធិប្រទានសាមញ្ញ ហើយត្រូវតែមានការចុះក្នុងបញ្ជីពាណិជ្ជកម្មតាមរូបភាពដែលប្រកាន់យក ។

ការិយាល័យតំណាងទាំងនេះអាចរក្សាទុកនូវនាមករណ៍ឬយីហោនៃធនាគារបរទេសដែលខ្លួន តំណាងអោយ ។

ការអនុញ្ញាតអោយបើកការិយាល័យតំណាងមានថេរវេលាពីរឆ្នាំ (២ឆ្នាំ) ហើយអាចត្រូវបន្ត អោយបានតែមួយដងគត់ ។

ជំពូកទី ៤

អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

មាត្រា ១៤.-

មុននឹងចេ្ញសកម្មភាព គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរអាណាព្យាបាលសិន ។ មុននឹងផ្តល់អាជ្ញាប័ណ្ណអោយ អាជ្ញាធរអាណាព្យាបាលត្រូវពិនិត្យអោយបានច្បាស់លាស់ ជាពិសេសនូវ :

១- គុណភាពនៃអ្នកចូលហ៊ុននិងស្ថានភាពពិតប្រាកដខាងហិរញ្ញវត្ថុរបស់អ្នកទាំងនោះ ។

២- សម្បទានៃអ្នកចូលហ៊ុនសំខាន់ៗ ដើម្បីគោរពរួមគ្នានូវកាតព្វកិច្ចដែលតម្រូវដល់អ្នកទាំងនោះក្នុងករណីចាំបាច់ត្រូវបង្កើនបង្គ្រប់ តាមវិធីណាមួយ នូវមូលនិធិថ្នាល់របស់ធនាគារតាមស្មារតីមាត្រា ២៧ នៃច្បាប់នេះ ។

៣- ភាពសមស្របនៃមធ្យោបាយធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដោយមានកម្មវិធីសកម្មភាពភ្ជាប់ជាមួយ ។

អាជ្ញាធរអាណាព្យាបាលត្រូវស្វែងយល់ពីពត៌មានលើលក្ខខណ្ឌបដិការដែលប្រទេសក្រៅផ្តល់អោយកាលបើភាគទុនិករបស់ក្រុមហ៊ុនក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឬទីស្នាក់ការនៃសាខាជាអាណិកជននៃប្រទេសទាំងនោះ ។

មាត្រា ១៥.-

អាជ្ញាធរអាណាព្យាបាលនឹងសំរេចផ្តល់អាជ្ញាប័ណ្ណក្នុងរយៈពេលប្រាំមួយខែ (៦ខែ) គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់ ។ រាល់ការបដិសេធមិនផ្តល់អាជ្ញាប័ណ្ណត្រូវតែមានធ្វើប្រសែន៍ដល់ម្ចាស់សំណើ ។ បញ្ជីសមាជិកនៃគ្រឹះស្ថានប្រតិស្រុតត្រូវចុះផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជា និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជានិងក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរអាណាព្យាបាល ។

ជំពូកទី ៥

ដើមទុនអប្បបរមា សាធនភាព

មាត្រា ១៦.-

គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមរូបភាពក្រុមហ៊ុនពាណិជ្ជកម្មឬមិនមែនពាណិជ្ជកម្ម នៃច្បាប់ក្នុងស្រុក ទោះក្រោមរូបភាពតតិយុត្តបែបណាក៏ដោយ មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានដើមទុនដំបូងដែលត្រូវបង់គ្រប់ចំនួនទាំងស្រុង យ៉ាងតិចស្មើនឹងចំនួនដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាល ។

សាខាទាំងឡាយនៃធនាគារបរទេស មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានទាយជ្ជទានដើមទុនដែលត្រូវបង់គ្រប់ចំនួនទាំងស្រុងស្មើនឹងដើមទុនអប្បបរមារបស់គ្រឹះស្ថានចំណុះច្បាប់នេះ បង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ។

ដើមទុនអប្បបរមានិងប្រាក់ដកស្តុកធានាជាអចិន្ត្រៃយ៍នៅក្នុងបញ្ជីធនាគារជាតិនៃកម្ពុជា របស់គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់អាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែចំពោះធនាគារពាណិជ្ជ ចំនួនទឹកប្រាក់នៃដើមទុនអប្បបរមា មិនត្រូវស្ថិតនៅក្រោមកំរិតហាសិបពាន់លានរៀល (៥០.០០០.០០០.០០០រ) ទេ ។

ចំនួនទឹកប្រាក់ខាងលើនេះ ត្រូវគិតតាមអត្រាអន្តរជាតិ មួយ អេស.ឌ្រ.អរ៍ (SDR) ស្មើនឹងប្រាំពាន់ប្រាំមួយរយដប់ប្រាំមួយរៀល (៥.៦១៦រ) ។

ចំពោះប្រាក់ដែលត្រូវតំកល់នៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់យ៉ាងតិចចំនួនប្រាំភាគរយ (៥%) នៃចំនួនដើមទុនអប្បបរមាខាងលើ ។

គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុកនិងក្រោមទំរង់ជាសាខាធនាគារបរទេស ត្រូវបង្ហាញជាអចិន្ត្រៃយ៍ថា បន្ទាប់ពីការដកចេញនូវទ្រព្យសកម្មគ្មានកម្ម ទ្រព្យសកម្មរបស់ខ្លួនមានតំលៃលើសពីទ្រព្យអកម្មដែលខ្លួនជំពាក់តតិយជនក្នុងទឹកប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមាឬទាយជ្ជទានដើមទុនអប្បបរមា ។

មាត្រា ១៧.-

ត្រឹះស្ថានចំណុះច្បាប់នេះត្រូវគោរពអនុបាតនៃសាធនភាពដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាលតាមវិបរិណាមនៃបទដ្ឋានអន្តរជាតិ ។ ឃោលទៅតាមទំហំហានិភ័យ ត្រឹះស្ថានចំណុះច្បាប់នេះត្រូវកែតំរូវបរិមាណមូលនិធិផ្ទាល់សុទ្ធអោយបានសមស្របតាមសមាមាត្រ ។

ជំពូកទី ៦

សមត្ថភាពនៃអ្នកដឹកនាំ

មាត្រា ១៨.-

ត្មានជនណាម្នាក់អាច :

- ធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៃត្រឹះស្ថានប្រតិស្រុត
- គ្រប់គ្រង កាន់កាប់ ឬ ដឹកនាំ ដោយផ្ទាល់ឬតាមរយៈសន្ធានការី ទោះជាក្នុងតួនាទីណាក៏ដោយ
- ចុះហត្ថលេខាក្នុងនាមត្រឹះស្ថាននោះ ។

ប្រសិនបើជននោះ :

១- ត្រូវបានផ្តន្ទាទោសជាស្ថាពរ ពីបទ :

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬ រំលោភលើការទុកចិត្ត
- លួចដកហូតយកទ្រព្យសាធារណៈ ក្នុងតួនាទីខ្លួនជាអ្នកទទួលរក្សាបញ្ជើ
- ជិរឥយកមូលនិធិ ឬ វត្ថុមានតម្លៃ ធ្វើនិទ្ទនភាព អោយខូចកេរ្តិ៍ឈ្មោះប្រទេសជាតិ ឬ ល្មើសនឹងច្បាប់ប្តូរប្រាក់
- ធ្វើព្រ៊ីទ្វិកម្ម
- ការសំអាតប្រាក់
- ក្លែង ឬ/ និងប្រើលិខិតក្លែងក្លាយ ឯកជនឬសាធារណៈ ។

២- ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញផ្សាយមូលប្បទានប័ត្រគ្មានសវិធានវត្ថុ ។

៣- ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេស ពីបទឧក្រិដ្ឋឬមជ្ឈិម ដែលចែងនៅចំណុច ១ និង ២ នៃមាត្រានេះ ។

៤- ត្រូវបានផ្តន្ទាទោស នៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ពីបទធនអ្ប័យផ្ទាល់ខ្លួន ឬការជំរះបំណុលតាមផ្លូវតុលាការ ឬការជំរះទ្រព្យសម្បត្តិ ។

៥- ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្កោះយសពីមុខងារសាធារណៈ ។

៦- ត្រូវបានជាប់រឿងជាឯកត្តជន ក្នុងការគ្រប់គ្រងនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាប័ណ្ណត្រូវបានដកហូតវិញដោយមូលហេតុរងទណ្ឌកម្មខាងវិន័យ ។

ជំពូកទី ៧

សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគីរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម

មាត្រា ១៩.-

លក្ខខណ្ឌទាំងឡាយនៃការផ្សំបង្កើតដើមទុន ទោះជាប្រែប្រួលក្តីមិនប្រែប្រួលក្តី នៃគ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមរូបភាពក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម រួមទាំងអត្តសញ្ញាណកម្មអចិន្ត្រៃយ៍នៃសង្គមិកៈឬអ្នកកាន់ភាគហ៊ុននៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្មទាំងនេះ ត្រូវបានកំណត់តាក់តែងនៅក្នុងលក្ខន្តិកៈនិត្យានុកូលពិសេសមួយ សំរាប់អនុវត្តលើក្រុមហ៊ុនដែលមានលក្ខណៈសហការណ៍ឬសង្គហាសមាគម ។

អនុលោមតាមមាត្រា ១១ និងចំណុច ២ នៃមាត្រា ១៤ នៃច្បាប់នេះ អង្គការកណ្តាលនៃបណ្តាញនីមួយៗគឺជាអ្នកទទួលបានសាធនភាពនិងសាច់ប្រាក់ងាយស្រួលនៃបណ្តាញនេះ ចំពោះតតិយជន អ្នកផ្ញើប្រាក់ឬឥណទាយក ។

ជំពូកទី ៨

សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគទុនិកភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្ម

មាត្រា ២០.-

ភាគទុនិកៈនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្ម អាចជារូបវន្តបុគ្គល ឬតាមលក្ខខណ្ឌកំណត់ដោយអាជ្ញាធរអាណាព្យាបាល អាចជានីតិបុគ្គលដែលភាគទុនិកៈត្រូវមានអត្តសញ្ញាណច្បាស់លាស់ ។

អាជ្ញាធរអាណាព្យាបាលត្រូវច្បេសវាងជាអាទិ៍ នូវក្រុមហ៊ុនដែលជាភាគទុនិកៈបណ្តាក់បន្តគ្នាពីមួយទៅមួយ ។

មាត្រា ២១.-

ក្រុមហ៊ុនហ្វូលឱ្យដែលមានគ្រឹះស្ថានចំណុះច្បាប់នេះជាបុត្តសម្ព័ន្ធ ដោយផ្តាច់មុខឬជាចំបង ចំនួនតិចឬច្រើនក៏ដោយ ក៏ត្រូវចាត់ទុកជាគ្រឹះស្ថានចំណុះច្បាប់នេះដែរ ជាអាទិ៍ចំពោះការទាក់ទងទៅនឹងអាជ្ញាប័ណ្ណ និងភាពចំណុះក្រោមអាជ្ញាធរអាណាព្យាបាល ។

មាត្រា ២២.-

គ្រឹះស្ថានចំណុះច្បាប់នេះត្រូវបញ្ជូនអោយអាជ្ញាធរអាណាព្យាបាល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ នូវអត្តសញ្ញាណនៃភាគទុនិកៈរបស់ខ្លួន ដែលមានភាគទុនស្មើឬលើសចំនួនប្រាំភាគរយ (៥%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោតដោយផ្ទាល់ឬដោយប្រយោល ។

មាត្រា ២៣.-

រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវធ្វើប្រតិវេទន៍ ជូនទៅអាជ្ញាធរអាណាព្យាបាលដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានចំណុះច្បាប់នេះ ដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មឬអនុប្បទានភាគទុន ដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលអោយភាគទុនិកៈឬក្រុមភាគទុនិកៈនេះទទួលបានឬបាត់បង់ទៅវិញចំនួនប្រាំភាគរយ (៥%) នៃដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះឬចំនួនប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោត ។

មាត្រា ២៤.-

១- រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវទទួល ដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានពាក់ព័ន្ធចំណុះច្បាប់នេះ នូវការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាលដើម្បីធ្វើលទ្ធកម្មឬអនុប្បទានភាគទុនដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលអោយភាគទុនិកៈឬក្រុមភាគទុនិកៈនេះ :

ក- ទទួលបានឬបាត់បង់ទៅវិញ ពាក់កណ្តាល មួយភាគបី មួយភាគប្រាំ ឬ មួយភាគដប់ នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត

ខ- ទទួលបានឬបាត់បង់ទៅវិញ នូវសិទ្ធិអំណាចនៃការត្រួតពិនិត្យលើការគ្រប់គ្រងរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលខុសត្រូវក្នុងការបំពេញទំរង់បែបបទនៃប្រតិវេទន៍ឬនៃការអនុញ្ញាត ។

ក្នុងករណីដែលទំរង់បែបបទទាំងនេះបំពេញមិនបានត្រឹមត្រូវ ការបោះឆ្នោតរបស់ភាគទុនិកៈពាក់ព័ន្ធនៅក្នុងមហាសន្និបាតនឹងត្រូវចាត់ទុកជាមោឃៈជាស្ងួយប្រវត្តិដោយមិនទាន់និយាយដល់ទណ្ឌកម្មនីត្យានុកូលឯទៀតដែលត្រូវអនុវត្តផង ។

មាត្រា ២៥.-

ក្រោមបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្មស្តីពីចំនួនអប្បបរមានៃភាគទុនិកៈរបស់ក្រុមហ៊ុនមូលធនទំហំបរិមាណនៃការដាក់ទុនធីមួយៗចូលក្នុងដើមទុននៃគ្រឹះស្ថានចំណុះច្បាប់នេះមិនត្រូវមានកំរិតទេ ។ ប៉ុន្តែនៅក្នុងពេលពិនិត្យពាក្យសុំអាជ្ញាប័ណ្ណ ហើយក្រោយមក នៅពេលធ្វើប្រតិវេទន៍ឬសុំការអនុញ្ញាតឆ្លងកំរិតភាគរយដែលបានចែងខាងលើ អាជ្ញាធរអាណាព្យាបាលត្រូវ :

- យកចិត្តទុកដាក់អោយមានវត្តមាននៃភាគទុនិក:ដែលមានឥទ្ធិពល

- ចៀសវាងនូវការប្រមូលផ្តុំ ក៏ដូចជាការបំបែកហួសប្រមាណនៃដើមទុន ។

ប៉ុន្តែការប្រមូលផ្តុំធំធេងអាចត្រូវទទួលយកបានក្នុងករណីដែលភាគទុនិក:ពាក់ព័ន្ធគឺជាធនាគារបរទេសដែលមានស្តង់ឌីងខ្ពស់ ។

មាត្រា ២៦.-

នៅក្នុងន័យនៃច្បាប់នេះ ភាគទុនិក:ត្រូវបានចាត់ទុកថាមានឥទ្ធិពល ចាប់តាំងពីពេលដែលខ្លួនគេមាន ដោយផ្ទាល់ឬដោយប្រយោល នូវភាគទុនយ៉ាងតិចស្មើនឹងម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ឬចាប់តាំងពីពេលដែលខ្លួនគេមាននូវសិទ្ធិអំណាចក្នុងការសំរេចពិតប្រាកដ ដោយមូលហេតុជាអាទិ៍នៃការបំបែកហួសប្រមាណនៃដើមទុន ។

មាត្រា ២៧.-

កាលបើស្ថានភាពហិរញ្ញវត្ថុនៃគ្រឹះស្ថានចំណុះច្បាប់នេះមានបញ្ហាខ្វះខាត អាជ្ញាធរអាណាព្យាបាលត្រូវបង្ការប៉ាន់ដោយដាច់ខាតដល់ភាគទុនិក:មានឥទ្ធិពលអោយពួតដៃគ្នាក្នុងការបង្កើនមូលនិធិថ្មាល់ ធ្វើយ៉ាងណាអោយបទដ្ឋានបទបញ្ជានៃសាធនភាពត្រូវបានគោរព ។

ក្នុងករណីមិនព្រមអនុវត្តតាម ភាគទុនិក:មានឥទ្ធិពលទាំងនោះត្រូវទទួលទណ្ឌកម្មនានាដែលបានគ្រោងទុកក្នុងចំណុច ២ នៃមាត្រា ៥៥ នៃច្បាប់នេះ ។ បើមានការដកស៊ីតារាងតុល្យការ ឥណទាយកឬអ្នកធ្វើប្រាក់អាចប្តឹងទៅតុលាការទាមទារអោយភាគទុនិក:មានឥទ្ធិពលបំពេញទ្រព្យអកម្ម ។

ជំពូកទី ៩

សមាសភាព អត្ថសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ
នៃភាគទុនិកភាគរបស់ទីស្នាក់ការគ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើង
ក្រោមរូបភាពជាសាខាធនាគារបរទេស

មាត្រា ២៨.-

សាខានៃគ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុបរទេស ដែលត្រូវបានប្រតិស្រុតអោយធ្វើសកម្មភាពធនាគារ ឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងជាបន្ទាន់ដល់អាជ្ញាធរអាណាព្យាបាល ក្រោមការទទួលខុសត្រូវរបស់ខ្លួន នូវពត៌មានអំពីការកែប្រែសមាសភាពនៃភាគទុនិកៈមានឥទ្ធិពលនៃទីស្នាក់ការរបស់ខ្លួន ។

មាត្រា ២៩.-

អាជ្ញាធរអាណាព្យាបាលអាចពិនិត្យឡើងវិញ នូវអាជ្ញាប័ណ្ណដែលបានចេញអោយសាខា បើសិនជាការផ្លាស់ប្តូរដែលលើកឡើងនៅមាត្រា ២៨ នៃច្បាប់នេះ មានលក្ខណៈបន្ថយការធានាខាងហិរញ្ញវត្ថុឬការទទួលខុសត្រូវរបស់ទីស្នាក់ការនៅបរទេស ។

មាត្រា ៣០.-

កាលបើស្ថានភាពហិរញ្ញវត្ថុតម្រូវអោយធ្វើ សាខាធនាគារមានកាតព្វកិច្ចស្នើទៅទីស្នាក់ការនៅបរទេសអោយបង្កើនឡើងវិញនូវទាយជ្ជទានដើមទុនដែលមានបញ្ជាក់នៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ១៦ នៃច្បាប់នេះឬកែប្រែការប្រើប្រាស់ទ្រព្យសកម្មឡើងវិញ ។

មាត្រា ៣១.-

ក្នុងករណីដកល់តារាងតុល្យការនៅបរទេសនៃទីស្នាក់ការរបស់សាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ទ្រព្យសកម្មទាំងអស់នៃសាខានេះត្រូវបានឃាត់ទុក ជាអាទិភាពសំរាប់សងអោយអតិថិជនជានិវែសជនដែលបានយកមកធ្វើទុកនូវមូលប័ត្រ មាស ឬប្រាក់ និងសំរាប់សងអោយឥណទាយក ក្នុងករណីអ្នកជំរះបញ្ជីរបស់សាខាទទួលស្គាល់ថាជាសិទ្ធិរបស់ពួកគេនៅក្នុងទ្រព្យសកម្ម នៅពេលដកល់តារាងតុល្យការនៃទីស្នាក់ការ ។

ជំពូកទី ១០

ភាគកម្មរបស់គ្រឹះស្ថានចំណុះច្បាប់នេះក្នុងដើមទុន
នៃក្រុមហ៊ុនពាណិជ្ជកម្មដទៃទៀត

មាត្រា ៣២.-

ត្រូវបានចាត់ទុកជាភាគកម្ម ក្នុងការអនុវត្តន៍ច្បាប់នេះ គឺភាគកម្ម ដែលអនុញ្ញាតអោយគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់ ដោយផ្ទាល់ឬដោយប្រយោល នូវចំនួនដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនដែលគ្រឹះស្ថាននោះបានចូលរួម ។

មាត្រា ៣៣.-

គ្រឹះស្ថានចំណុះច្បាប់នេះមិនអាចមានភាគកម្មលើសពីដប់ប្រាំភាគរយ (១៥%) នៅក្នុងក្រុមហ៊ុនមួយ ហើយសរុបភាគកម្មក្នុងក្រុមហ៊ុននានាមិនអាចលើសពីហុកសិបភាគរយ (៦០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ ។

មាត្រា ៣៤.-

ភាគកម្មនៅក្នុងដើមទុននៃសហគ្រាសនិងក្រុមហ៊ុនដូចខាងក្រោមនេះ មិនត្រូវរងកិរិតភាគរយនីមួយ១ ឬរួមគ្នាដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះឡើយ :

១- សហគ្រាសមានចរិតឧស្សាហកម្ម អចលនទ្រព្យ ឬ ពាណិជ្ជកម្មដែលជាសកម្មភាពផ្សារភ្ជាប់ជាមួយអាជីវកម្មនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ ក្រោយពីមានប្រតិវេទន៍ឬការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល តាមបទប្បញ្ញត្តិនៃជំពូកទី ៨ នៃច្បាប់នេះ ។

៣- ក្រុមហ៊ុនអាជីវកម្មកសិកម្ម ។

មាត្រា ៣៥.-

ត្រូវបានចាត់ទុកថាជាក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ សំរាប់ការអនុវត្តន៍ក្នុងចំណុច ២ នៃមាត្រា ៣៤ នៃច្បាប់នេះគឺ :

១- គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនហិរញ្ញវត្ថុ រួមបញ្ចូលទាំងក្រុមហ៊ុនដែលធ្វើសកម្មភាពដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

៣- សហគ្រាសដែលប្រកបរបរជាប្រក្រតី នូវប្រតិបត្តិការធនាគារនិងប្រតិបត្តិការហិរញ្ញវត្ថុនៅបរទេស ។

៤- ក្រុមហ៊ុនធានារ៉ាប់រង ។

មាត្រា ៣៦.-

កាលបើភាគទុនិក:គ្រឹះស្ថានចំណុះច្បាប់នេះជាក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ ឬកាលបើគ្រឹះស្ថានចំណុះច្បាប់នេះខ្លួនឯងកាន់កាប់នូវភាគកម្មក្នុងក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ អាជ្ញាធរអាណាព្យាបាលត្រូវទាមទារ សំរាប់ការគណនាមូលនិធិផ្ទាល់សុទ្ធដើម្បីជាមូលដ្ឋានអោយអនុបាតប្រុងប្រយ័ត្ននៃគ្រឹះស្ថានចំណុះច្បាប់នេះ នូវ :

- ការដកចេញនៃភាគកម្មដែលគ្រឹះស្ថានក្រោយនេះកាន់កាប់ក្នុងក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ

- ការច្របាច់បញ្ចូលគ្នាជាមុននៃតារាងតុល្យការរបស់ចង្កោមក្រុមហ៊ុន នៅពេលដែលភាគកម្មទៅវិញទៅមកនេះមានចំនួនស្មើឬលើសពីម្ភៃភាគរយ (២០%) នៃដើមទុនក្រុមហ៊ុនពាក់ព័ន្ធ ។

មាត្រា ៣៧.-

ការចូលភាគកម្មដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុននីតិបុគ្គលមានចរិតឧស្សាហកម្មឬពាណិជ្ជកម្មដែលមានទីស្នាក់ការនៅបរទេស ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

ជំពូកទី ១១

ការចោះទីតាំងនៃគ្រឹះស្ថានចំណុះច្បាប់នេះ នៅបរទេសឬនៅក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣៨.-

ការចូលភាគកម្មនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុនធនាគារឬក្រុមហ៊ុនហិរញ្ញវត្ថុ ព្រមទាំងការបើកសាខាឬការិយាល័យតំណាងនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

មាត្រា ៣៩.-

ការបើកសាខាដោយគ្រឹះស្ថានចំណុះច្បាប់នេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

ការចូលភាគកម្មដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះមួយទៀត ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ ដល់មាត្រា ២៧ ព្រមទាំងមាត្រា ៣៣ ដល់មាត្រា ៣៥ នៃច្បាប់នេះ ។

ជំពូកទី ១២

អាជ្ញាធរអាណាព្យាបាលនិងអំណាចចេញបទបញ្ជា

មាត្រា ៤០.-

ធនាគារកណ្តាលបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារនិងលើសកម្មភាពប្រមាក់គ្នាដូចជាផ្សារប្តូរប្រាក់វត្ត ប្រព័ន្ធទូទាត់អន្តរធនាគារនិងអន្តរការិយកម្មហិរញ្ញវត្ថុ ។

ក្នុងតួនាទីនេះ ធនាគារកណ្តាល :

១- ចេញអាជ្ញាប័ណ្ណនិងកំណត់បែបបទនានាអំពីការចេញអាជ្ញាប័ណ្ណនេះ ។

២- រៀបចំ កាន់កាប់យ៉ាងទៀងទាត់ជាប្រចាំនិងចាត់ចែងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជានិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបញ្ជីរាយនាមធនាគារ ។

៣- ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតអោយកំណត់អោយច្បាស់ជាអាទិ៍នូវ :

ក- កំពស់ដើមទុនអប្បបរមានិងការយកទៅប្រើក្នុងប្រភេទទ្រព្យសកម្ម ។

ខ- អនុបាតឬមេគុណប្រុងប្រយ័ត្នផ្សេងៗ ដែលពាក់ព័ន្ធជាពិសេសដល់សាច់ប្រាក់ងាយស្រួល សាធនភាព ការប៉ះពែងហានិភ័យ និងការប្រឈមមុខខល់នឹងហានិភ័យនៃការប្តូរប្រាក់ឬនៃទីផ្សារ ។

គ- វិធីវាយតម្លៃសមតុល្យនៃគណនី ។

ឃ- លក្ខខណ្ឌនានាដែលគេអាចចូលភាគកម្មក្នុងដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះឬក្រុមហ៊ុនហិរញ្ញវត្ថុ ។

ង- លក្ខខណ្ឌនានាដែលគ្រឹះស្ថានចំណុះច្បាប់នេះអាចចូលភាគកម្មក្នុងដើមទុននៃក្រុមហ៊ុនដទៃទៀតដែលមានចរិតធនាគារឬហិរញ្ញវត្ថុ ។

ច- ចំណាត់ថ្នាក់ប្រភេទឥណទានិងការធ្វើសវិធានធនចំពោះបំណុលពិបាកទារ ។

ឆ- ប្រព័ន្ធគណនេយ្យធនាគារនិងបទដ្ឋានដែលពាក់ព័ន្ធ ។

ជ- លក្ខខណ្ឌនានា ដែលប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុត្រូវបានអនុវត្តចំពោះអតិថិជន ។

ឈ- ការរៀបចំសេវាកម្មអន្តរធនាគារជាអាទិ៍ ការបង្កើតមជ្ឈការនៃពត៌មាន នៃហានិភ័យ ឬនៃបំណុលពិបាកទារ ។

ញ- លក្ខខណ្ឌនៃការផ្តល់បដិប្បញ្ញត្តិ តាមករណីនីមួយៗ ក្នុងលក្ខណៈពិសេសនិងបណ្តោះអាសន្ន ។

ដ- លក្ខខណ្ឌនានា ដែលត្រូវធ្វើប្រតិវេទន៍ជូនឬសុំការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល អំពីការប្រែប្រួលឬការផ្ទាស់ប្តូរដែលពាក់ពន្ធ័ជាមួយ នាមករណ៍ ទំរង់ទីក្បាទុកូល ដើមទុន ការដឹកនាំ ការបោះចីតាំង និងសកម្មភាពនៃគ្រឹះស្ថានចំណុះច្បាប់នេះឬនៃទីស្នាក់ការ ប្រសិនបើជាករណីសាខាធនាគារបរទេស ។

ឋ- ការប្រកបមុខរបរស្វែងរកអតិថិជនក្នុងវិស័យធនាគារឬហិរញ្ញវត្ថុ ។

ឌ- ការកំណត់ដោយពិគ្រោះជាមួយសមាគមវិជ្ជាជីវៈនៃគ្រឹះស្ថានចំណុះច្បាប់នេះនូវវិធាននៃការប្រព្រឹត្តិទៅនៃប្រព័ន្ធធានាប្រាក់បញ្ញើ ។

ឈ- បែបបទអនុវត្តនៃច្បាប់នេះ ដែលទាក់ទងដល់ភាពខុសគ្នាស្តីពី លក្ខន្តិកៈគតិយុត្ត វិសាលភាពនៃបណ្តាញ ឬ ប្រភេទនៃសកម្មភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

៤- ចាត់ចែងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបទបញ្ជាដែលតាក់តែងឡើងដោយសំអាងលើសិទ្ធិអំណាចរបស់ខ្លួន ។

៥- រាប់រង តាមដាន ត្រួតពិនិត្យប្រព័ន្ធធនាគារ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ជាអចិន្ត្រៃយ៍លើឯកសារនិងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ដល់ទីកន្លែងនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។ បើយល់ឃើញថាចាំបាច់ អាចពង្វាតការត្រួតពិនិត្យដល់ទីកន្លែង នៅក្នុងក្រុមហ៊ុនជាបុត្តសម្ព័ន្ធរាល់អង្គភាពដែលជាសម្ព័ន្ធញាតិដទៃទៀតជាអាទិ៍ ក្រុមហ៊ុនដែលជាភាគទុនិកៈ ។

៦- រៀបចំឬត្រួតពិនិត្យគ្រប់ប្រព័ន្ធទូទាត់អន្តរធនាគារ ។

៧- អាចទាមទារការផ្តល់ពត៌មានដែលខ្លួនវិនិច្ឆ័យថាមានប្រយោជន៍ដល់បេសកកម្មរបស់ខ្លួន ពីគ្រឹះស្ថានចំណុះច្បាប់នេះ ពីរដ្ឋបាលនានា ពីស្នងការគណនី ឬ ពីគ្រប់នីតិបុគ្គលឬរូបវន្តបុគ្គលដទៃទៀត ។

៨- អាចសំរេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៥៤ នៃច្បាប់នេះ ។

មាត្រា ៥១.-

បេសកកម្មរបស់អាជ្ញាធរអាណាព្យាបាល គឺ :

១- ចេញអោយគ្រឹះស្ថានចំណុះច្បាប់នេះនូវអាជ្ញាប័ណ្ណសំរាប់ធ្វើសកម្មភាពធនាគារឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានពិនិត្យគ្រប់ជ្រុងជ្រោយនូវហេតុផលគ្រប់យ៉ាង ។

២- ប្រកាសអោយប្រើនិងចាត់អនុវត្តវិធានប្រុងប្រយ័ត្ននៃរចនាសម្ព័ន្ធនៃការគ្រប់គ្រង ដែលគ្រឹះស្ថានចំណុះច្បាប់នេះត្រូវប្រតិបត្តិតាម ។

៣- ត្រួតពិនិត្យជាអចិន្ត្រៃយ៍ជាក្រោយ នូវស្ថានភាពនិងដំណើរការរបស់គ្រឹះស្ថានចំណុះច្បាប់នេះ នៅលើឯកសារនិងទៅដល់ទីកន្លែង ។

៤- សំរេចដាក់ទណ្ឌកម្មដល់គ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងករណីមិនប្រតិបត្តិតាមច្បាប់ ។

៥- ប្តឹងទៅតុលាការ ប្រសិនបើគ្រឹះស្ថានចំណុះច្បាប់នេះមិនប្រតិបត្តិតាមច្បាប់និងបទបញ្ជា ធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់សាធារណជន ។

អ្នកដឹកនាំនិងភាគទុនិកៈនៃគ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលខុសត្រូវក្នុងការកន្ត្រៃចម្បាំងខាងយុទ្ធ-សាស្ត្រ កំហុសឬការព័ន្ធច្រឡំក្នុងកិច្ចគ្រប់គ្រង កង្វះការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១៨. ១៩. ២៧ និងមាត្រា ៣០ នៃច្បាប់នេះ ។

ជំពូកទី ១៣

វិធានការប្រុងប្រយ័ត្ន ការត្រួតពិនិត្យផ្ទៃក្នុង

មាត្រា ៤២.-

នៅក្នុងលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល គ្រឹះស្ថានចំណុះច្បាប់នេះមានកាតព្វ-កិច្ចគោរព មិនត្រឹមតែវិធានការនយោបាយរូបិយវត្ថុ ដែលមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគោរពបទដ្ឋានគ្រប់គ្រងទាំងឡាយ សំរាប់ធានាសាច់ប្រាក់ងាយស្រួលនិងសាធនភាព ចំពោះអ្នកផ្ញើប្រាក់ និងជាទូទៅ ចំពោះតតិយជន ក៏ដូចចំពោះសមតានៃវិធានសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឡើតផង ។

ដើម្បីគណនាមូលនិធិផ្ទាល់សុទ្ធ ដែលជាមូលដ្ឋានក្នុងការកំណត់បទដ្ឋានប្រុងប្រយ័ត្នរបស់គ្រឹះស្ថានចំណុះច្បាប់នេះនីមួយៗ អាជ្ញាធរអាណាព្យាបាលត្រូវដកចេញនូវ :

១- ទ្រព្យគ្មានតម្លៃខាងទ្រព្យសកម្ម នៃតារាងតុល្យការរបស់គ្រឹះស្ថាននេះ ។

២- ភាគកម្មទាំងឡាយដែលមានចូលក្នុងក្រុមហ៊ុនមានចរិតជាធនាគារឬហិរញ្ញវត្ថុ ព្រមទាំងក្នុងលក្ខខណ្ឌដែលកំណត់តាមបទបញ្ជា នូវការអោយខ្ចីគ្រប់ប្រភេទនិងគ្រប់រយៈកាលដល់ភាគទុនិកៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ឬមូលប័ត្រដែលគេបានចុះហត្ថលេខា ។

មាត្រា ៤៣.-

នៅក្នុងលក្ខខណ្ឌកំណត់ដោយអាជ្ញាធរអាណាព្យាបាល គ្រឹះស្ថានចំណុះច្បាប់នេះត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលមានវត្ថុបំណងជាអាទិ៍ :

១- ពិនិត្យបញ្ជាក់ថាប្រតិបត្តិការ ដែលអនុវត្តដោយគ្រឹះស្ថានចំណុះច្បាប់នេះនិងការរៀបចំនីតិវិធីមានលក្ខណៈត្រឹមត្រូវតាមបទប្បញ្ញត្តិនិងបទបញ្ជា តាមបទដ្ឋាននិងរបៀបប្រើប្រាស់ជាជីវៈ និងការណែនាំកិច្ចសាស្ត្រ ក៍ដូចតាមការតម្រង់ទិសនៃការដឹកនាំទូទៅរបស់គ្រឹះស្ថាន ។

២- ពិនិត្យបញ្ជាក់ថា ភិរិតកំណត់អំពីហានិភ័យជាអាទិ៍ នៃបដិភាគ ការប្តូរប្រាក់ អត្រាការប្រាក់ និងទីផ្សារ ត្រូវបានគោរពតាមយ៉ាងហ្មត់ចត់ ។

៣- ប្រុងប្រយ័ត្នចំពោះសច្ចភាពនៃពត៌មានគណនេយ្យ ថវិកា និងហិរញ្ញវត្ថុ ដែលផ្សព្វផ្សាយទៅផ្ទៃក្នុងនិងទៅខាងក្រៅ ជាពិសេស ចំពោះលក្ខខណ្ឌនៃកិច្ចបញ្ជិកា នៃការរក្សាទុក និងលទ្ធភាពប្រើប្រាស់នូវពត៌មាននេះ ។

ជំពូកទី ១៤

កាតព្វកិច្ចគណនេយ្យ ការត្រួតពិនិត្យពីខាងក្រៅ ដោយស្នងការគណនី

មាត្រា ៤៤.-

បទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្មឬនៃលក្ខន្តិកៈនីស្សានុកូលរបស់ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ដែលពាក់ព័ន្ធនិងការបញ្ឈប់បញ្ជី ការត្រួតពិនិត្យគណនី ព្រមទាំងការបញ្ជាក់អះអាងលើគណនី ដោយស្នងការគណនីត្រូវអនុវត្តលើគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

មាត្រា ៤៥.-

គ្រឹះស្ថានចំណុះច្បាប់នេះមានកាតព្វកិច្ចតាក់តែងនិងផ្សព្វផ្សាយ ហើយក្នុងករណីចាំបាច់ ច្រៀបចំចូលគ្នានូវគណនីរបស់ក្រុមខ្លួន តាមលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

ទន្ទឹមនេះ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវបង្ហាញជូន អាជ្ញាធរអាណាព្យាបាលដោយឡែងពេលនូវស្ថានភាពគណនេយ្យ អំពីការអនុវត្តនីវិធានការប្រុងប្រយ័ត្នធីស្សានុកូលឬនៃបទបញ្ជា ។

មាត្រា ៤៦.-

ស្នងការគណនីអាចធ្វើប្រតិបត្តិការនៅក្នុងគ្រឹះស្ថានចំណុះច្បាប់នេះបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

មុននឹងធ្វើការបញ្ជាក់អះអាងលើគណនី ស្នងការគណនីពិនិត្យសច្ចភាពនៃពត៌មានគណនេយ្យដែលមាននៅដំណាច់ការិយបរិច្ឆេទ ក្នុងតារាងតុល្យការ ក្រៅតារាងតុល្យការ ក្នុងគណនីអាជីវកម្ម និងក្នុងតារាងឧបសម្ព័ន្ធ ដែលសំរាប់ផ្សព្វផ្សាយឬផ្ញើជូនអាជ្ញាធរអាណាព្យាបាល ។

ស្នងការគណនីត្រូវប្តឹងទៅតុលាការ បើសំគាល់ឃើញថាគ្រឹះស្ថានចំណុះច្បាប់នេះបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ឬនៃបទបញ្ជា ធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍សាធារណជន ។

បន្ទាប់ពីការពិនិត្យ ស្នងការគណនីត្រូវតាក់តែងនិងផ្ញើជូនអាជ្ញាធរអាណាព្យាបាលនូវរបាយការណ៍ដែលបរិយាយពីការកត់សំគាល់របស់ខ្លួន ជាអាទិ៍អំពី :

១- ការបង់ដើមទុន ។

២- វិធីវាយតម្លៃសមតុល្យ ។

៣- វិធីច្រចាច់ចូលគ្នានូវតុល្យការ ។

៤- ស្ថានភាពហិរញ្ញវត្ថុនៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

៥- កិច្ចព្រមព្រៀងដែលអាចមានដោយផ្ទាល់ឬដោយប្រយោល ក្នុងការិយបរិច្ឆេទនីមួយៗ រវាងគ្រឹះស្ថានចំណុះច្បាប់នេះជាភាគីម្ខាងនិងភាគទុនិកៈឬអ្នកដឹកនាំរបស់ខ្លួនជាភាគីម្ខាងទៀត ។

អាជ្ញាធរអាណាព្យាបាលអាចស្នើសុំពីស្នងការគណនីនូវគ្រប់ពត៌មានលើសកម្មភាពនិងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចបញ្ជូនអោយស្នងការគណនី នូវសេចក្តីកត់សំគាល់របស់ខ្លួនឬនូវសំណើសុំអោយពន្យល់ ដែលស្នងការគណនីត្រូវតែឆ្លើយតបជាលាយលក្ខណអក្សរ ។

ជំពូកទី ១៥

ការសម្ងាត់វិជ្ជាជីវៈ

មាត្រា ៤៧.-

ចំពោះបុគ្គលដែលចូលរួម ទោះក្នុងឋានៈណាក៏ដោយ នៅក្នុងការអភិបាល ការដឹកនាំ ការគាន់ ការត្រួតពិនិត្យផ្ទៃក្នុងឬពីខាងក្រៅនៃគ្រឹះស្ថានចំណុះច្បាប់នេះ ឬ ចំពោះបុគ្គលឯទៀតដែលធ្វើការងារអោយគ្រឹះស្ថានចំណុះច្បាប់នេះ មិនត្រូវបរិហារបញ្ចេញប្រាប់ដល់ជនណាក៏ដោយ នូវពត៌មានដែលមានចរិតសម្ងាត់លើសេចក្តីប្រកាស ហេតុការណ៍ សារលិខិត តួលេខ ឬ អត្ថន័យនៃឯកសារគណនេយ្យឬរដ្ឋបាលដែលខ្លួនបានដឹងតាមរយៈមុខងាររបស់ខ្លួន ។

បុគ្គលទាំងឡាយណាដែលមិនគោរពតាមកាតព្វកិច្ចទាក់ទងនឹងការរក្សាការសម្ងាត់វិជ្ជាជីវៈនេះត្រូវទទួលទោសដែលចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះ ។

ប៉ុន្តែកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈនេះ មិនអាចជំទាស់នឹងអាជ្ញាធរអាណាព្យាបាល ស្នងការ-គណនី អភិបាលបណ្តោះអាសន្ន អ្នកជំរះបញ្ជី ក៏ដូចជាអាជ្ញាធរតុលាការដែលចាត់ការក្នុងក្របខ័ណ្ឌនៃនីតិព្រហ្មទណ្ឌ ។

ជំពូកទី ១៦

សម័ន្ធញាតិរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

មាត្រា ៤៨.-

បន្ថែមលើបទប្បញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់នេះ ស្តីពីការគណនាមូលនិធិថ្នាល់សុទ្ធ ការសហការខាងហិរញ្ញវត្ថុគ្រប់ប្រភេទ ដែលផ្តល់ដោយគ្រឹះស្ថានចំណុះច្បាប់នេះ ទោះតាមរូបភាពណាក៏ដោយ ត្រូវតែស្ថិតនៅក្រោមបទបញ្ជារបស់អាជ្ញាធរអាណាព្យាបាលដែលសំដៅ ម្យ៉ាងត្រូវតែដឹងជាអថិច្ចន្លែយអំពីការសហការនេះ និងម្យ៉ាងទៀតត្រូវស្ថិតនៅក្នុងកិរិតកំណត់ កាលបើហត្ថគាហកៈត្រូវបានចាត់ទុកជាភាគីក្នុងសម័ន្ធញាតិ ។

មាត្រា ៤៩.-

ក្នុងន័យនៃច្បាប់នេះ ត្រូវបានចាត់ទុកជាភាគីក្នុងសម្ព័ន្ធញាតិជាមួយគ្រឹះស្ថានចំណុះច្បាប់នេះ គឺ :

១- បុគ្គលទាំងឡាយដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ។

២- ក្រុមហ៊ុនណាដែលគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ឬដោយប្រយោល នូវភាគកម្មយ៉ាងតិចស្មើនឹងដប់ភាគរយ (១០%) នៃដើមទុនឬតំណាងយ៉ាងតិចដប់ភាគរយ (១០%) នៃសិទ្ធិបោះឆ្នោត ។

៣- បុគ្គលណាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ឬ ការត្រួតពិនិត្យផ្ទៃក្នុង ។

៤- រាល់ស្នងការគណនី ។

មាត្រា ៥០.-

អាជ្ញាធរអាណាព្យាបាលមានសិទ្ធិសុំអោយគ្រឹះស្ថានចំណុះច្បាប់នេះអនុវត្តការសហការខាងហិរញ្ញវត្ថុ តាមនីតិវិធីដូចគ្នា ចំពោះហត្ថគាហកៈ ដែលអាជ្ញាធរអាណាព្យាបាលចាត់ទុកជាភាគីសម្ព័ន្ធជិតស្និទ្ធ ជាអាទិ៍ ខាងពង្សឬហិរញ្ញវត្ថុជាមួយបុគ្គលទាំងឡាយដែលមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ឬចំពោះហត្ថគាហកៈមានភាគកម្មតិចជាងភាគដែលមានចែងកំណត់ក្នុងមាត្រា ៤៩ នៃច្បាប់នេះក៏ពិតមែន តែមានឥទ្ធិពលក្នុងការគ្រប់គ្រងដោយហេតុមានការបំបែកដើមទុនហួសប្រមាណ ។

ជំពូកទី ១៧
ការសំអាតប្រាក់

មាត្រា ៥១.-

យោងតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០១៩៧-០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៧ គ្រឹះស្ថានចំណុះច្បាប់នេះត្រូវតែអនុវត្តក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយត្រូវចាត់ត្រឹមវិធានការសំដៅ ម្យ៉ាងកត់អត្តសញ្ញាណច្បាស់លាស់របស់អតិថិជនទាំងអស់និង

របស់ប្រតិបត្តិការទាំងឡាយដែលធ្វើតាមរយៈខ្លួន បើសិនជាលើសពីកិរិតមួយដែលអាជ្ញាធរអាណាព្យាបាលបានកំណត់ ហើយសំដៅម៉្យាងទៀត រក្សាទុកឯកសារពាក់ព័ន្ធទាំងអស់យ៉ាងតិចអោយបានដប់ឆ្នាំ (១០ឆ្នាំ) ។

ជំពូកទី ១៨

ទណ្ឌកម្មខាងវិន័យ

មាត្រា ៥២.-

ប្រសិនបើត្រីះស្ថានប្រតិស្រុតបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ឬនៃបទបញ្ជាស្តីពីសកម្ម-ភាពរបស់ខ្លួន ឬប្រសិនមិនបានធ្វើតាមការដាស់តឿន ឬប្រសិនមិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាលអាចសំរេចដាក់ តាមនីតិវិធីដែលធ្វើចំពោះមុខសាមីខ្លួន នូវទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមធ្វើប្រតិបត្តិការមួយចំនួននិងការកំណត់ព្រំដែនដទៃទៀត ក្នុងការធ្វើសកម្មភាព
- ការព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ឬច្រើននាក់ ដោយមានឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការអោយលាឈប់ពីការងារជាស្ម័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ឬច្រើននាក់ ដោយមានឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការដាក់អោយស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់
- ការដកហូតអាជ្ញាប័ណ្ណជាស្ថាពរនិងការដាក់អោយជំរះបញ្ជីជាបន្ទាប់ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចសំរេច ឬ ដោយជំនួស ឬ ដោយបន្ថែមលើទណ្ឌកម្មទាំងនេះ នូវការពិន័យជាប្រាក់យ៉ាងច្រើនបំផុតត្រឹមស្មើនឹងដើមទុនអប្បបរមាដែលតំរូវអោយត្រីះស្ថាននោះអនុវត្ត ។

មាត្រា ៥៣.-

ការតែងតាំងអភិបាលបណ្តោះអាសន្នឬអ្នកជំនះបញ្ជីគឺជាវិធានការប្រញាប់បន្ទាន់ ដែលមានចរិតអភិបាលនិងអភិរក្ស ។ ការតែងតាំងនេះត្រូវបានជូនដំណឹងជាផ្លូវការដល់ក្រឹះស្ថានសាមី ហើយមានប្រសិទ្ធិភាពអនុវត្តជាបន្ទាន់ ។

មាត្រា ៥៤.-

ទណ្ឌកម្មឯទៀតខាងវិន័យ ដែលមានចរិតជាសីលធម៌ឬជាប្រាក់កាស គឺជាការសំរេចយុត្តាធិការធ្វើឡើងដោយអាជ្ញាធរអាណាព្យាបាលដែលជាអ្នកមានសិទ្ធិសំរេចចុងក្រោយបំផុតជាស្ថាពរ ។ ទណ្ឌកម្មទាំងនេះត្រូវបានអនុវត្តជាបន្ទាន់ ប៉ុន្តែអាចជាកម្មវត្ថុប្តឹងសាទុក្ខបានដើម្បីវិនិច្ឆ័យដោយមូលហេតុខុសខាងទំរង់ឬខាងនីតិវិធីចំពោះមុខយុត្តាធិការរដ្ឋបាលខ្ពស់បំផុត ។

ជំពូកទី ១៩
ទណ្ឌកម្មខាងព្រហ្មទណ្ឌ

មាត្រា ៥៥.-

ក្រៅពីទណ្ឌកម្មដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នានា ឬលើលក្ខន្តិកៈនីត្យានុកូលនៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ទណ្ឌកម្មខាងក្រោមនេះអាចត្រូវបានអនុវត្តនៅក្នុងន័យនៃច្បាប់នេះគឺ :

១- បុគ្គលណា ជាឯកត្តជនក្តីឬក្នុងនាមអង្គភាពក្តី ដែលយកប្រតិបត្តិការធនាគារជាវិជ្ជាជីវៈជាប្រក្រតីនិងសំរាប់សាធារណជនដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ដល់ប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០៛) ដល់ពីរយហាសិបលានរៀល (២៥០.០០០.០០០៛) ឬទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ដោយមិនទាន់គិតដល់ការបិទក្រឹះស្ថានផង ។

២- បុគ្គលណាឬអង្គភាពណា ដែលប៉ះពាល់លើបទប្បញ្ញត្តិនៃមាត្រា ៩, ១១, ១៨, ១៩, ២៧, ៣០ និងមាត្រា ៤៧ នៃច្បាប់នេះ ត្រូវរងទណ្ឌកម្មខាងព្រហ្មទណ្ឌដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៥ នៃច្បាប់នេះ ។

៣- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០រ) ដល់ដប់លានរៀល (១០.០០០.០០០រ) ឬមួយក៏ទទួលទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ចំពោះបុគ្គលណា ទោះជាឯកត្តជនក្តីឬក្នុងនាមអង្គភាពក្តីដែល :

- បំពានលើបទប្បញ្ញត្តិនៃមាត្រា ៨, ១៣, ២៣, ២៤, ២៨, ៣៨, ៣៩, ៤៤, ៤៥, ៤៦ និងមាត្រា ៥១ នៃច្បាប់នេះ

- ឬ មិនឆ្លើយតបនឹងការសុំពត៌មានដូចមានចែងក្នុងចំណុច ៧ នៃមាត្រា ៤០នៃច្បាប់នេះ ពីសំណាក់អាជ្ញាធរអាណាព្យាបាល បន្ទាប់ពីការដាក់កំហិត

- ឬ ជូនដំណឹងដោយចេតនា នូវពត៌មានខុសដល់អាជ្ញាធរអាណាព្យាបាល

- ឬ បង្កឧបសគ្គ ដល់ការត្រួតពិនិត្យដោយអាជ្ញាធរអាណាព្យាបាលឬដោយស្នងការគណនីរបស់ត្រឹះស្ថានចំណុះច្បាប់នេះ ព្រមទាំងដល់ការបំពេញបេសកកម្មរបស់អភិបាលបណ្តោះអាសន្នឬអ្នកជំនះបញ្ជីដែលតែងតាំងឡើងដោយអាជ្ញាធរអាណាព្យាបាល ។

មាត្រា ៥៦.-

ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះត្រូវសំរេចដោយតុលាការ ផ្អែកលើពាក្យបណ្តឹងឬការប្តឹងទាវជម្ងឺចិត្តពីបទអាជ្ញា ពីសំណាក់អាជ្ញាធរអាណាព្យាបាលឬពីសំណាក់សមាគមវិជ្ជាជីវៈរបស់ត្រឹះស្ថានចំណុះច្បាប់នេះ ដែលចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ ។

ជំពូកទី ២០

ការអភិបាលបណ្តោះអាសន្ន ការជំនះបញ្ជី

មាត្រា ៥៧.-

ប្រសិនបើមានគ្រោះភ័យធ្ងន់ធ្ងរនិងជាក់ស្តែងលើសាធនភាពរបស់ត្រឹះស្ថានចំណុះច្បាប់នេះ និងប្រសិនបើការបំពេញបង្គ្រប់មូលនិធិផ្ទាល់ដែលចែងក្នុងចំណុច ២ នៃមាត្រា ១៤, មាត្រា ១៥, ២៧ និង មាត្រា ៣០ នៃច្បាប់នេះនៅតែគ្មានប្រសិទ្ធភាព អាជ្ញាធរអាណាព្យាបាលអាច ជាស្ម័យប្រវត្តិ ឬតាមសំណើរបស់អ្នកដឹកនាំ

ឬរបស់ភាគទុនិក: តែងតាំងអភិបាលបណ្តោះអាសន្ន សំរាប់រយៈពេលដប្លែងដែលមិនអាចលើសពីបីខែ (៣ខែ) ។ ប្រសិនបើកាលៈទេសៈតម្រូវ បេសកកម្មរបស់អភិបាលបណ្តោះអាសន្នអាចត្រូវបានពន្យារពេលបីខែ (៣ខែ) ទៀត ។ ត្រីះស្ថានចំណុះច្បាប់នេះត្រូវទទួលបន្ទុកក្នុងការចេញសោហ៊ុយទាំងអស់ ។

មាត្រា ៥៨.-

ក្រោយពេលតែងតាំង អភិបាលបណ្តោះអាសន្នមានសិទ្ធិអំណាចផ្តាច់មុខក្នុងការដឹកនាំ ការគ្រប់គ្រង និងជាតំណាងអោយត្រីះស្ថានចំណុះច្បាប់នេះ ។

មាត្រា ៥៩.-

បេសកកម្មចំបងរបស់អភិបាលបណ្តោះអាសន្ន គឺ :

- រៀបចំជាបន្ទាន់នូវការវាយតម្លៃថា ត្រីះស្ថានចំណុះច្បាប់នេះអាចឬមិនអាចមានសាធនភាព
- គ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ដោយការពារអោយបានជាអតិបរមានូវសាធនភាពរបស់ត្រីះស្ថាន និងសមភាពរវាងអ្នកផ្ញើប្រាក់ឬតណាទាយក ។

មាត្រា ៦០.-

អភិបាលបណ្តោះអាសន្នត្រូវធ្វើរបាយការណ៍ពីបេសកកម្មរបស់ខ្លួនទៅអាជ្ញាធរអាណាព្យាបាល ដើម្បីដកចេញនូវវិធានការអភិរក្ស បន្ទាប់ពីការវាយតម្លៃ ត្រីះស្ថានត្រូវបានចាត់ទុកថាមានសាធនភាព ហើយត្រីះស្ថាននេះអាចគោរពតាមរាល់វិធានការប្រុងប្រយ័ត្នតាមច្បាប់និងតាមបទបញ្ជា ។

មាត្រា ៦១.-

ប្រសិនបើបន្ទាប់ពីការវាយតម្លៃ ត្រីះស្ថានអាចមានសាធនភាព ប៉ុន្តែប្រសិនបើត្រីះស្ថាននេះ ក្នុងរយៈពេលបីខែ (៣ខែ) ក្នានលទ្ធភាពអនុវត្តវិធានការតាមបទដ្ឋានប្រុងប្រយ័ត្នទាក់ទងដល់មូលនិធិផ្តាល់សុទ្ធ និងទាក់ទងដល់សាច់ប្រាក់ងាយស្រួល អាជ្ញាប័ណ្ណអាចត្រូវដកហូតវិញ ហើយការអភិបាលបណ្តោះអាសន្នត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីក្រៅផ្លូវតុលាការ ដោយត្រីះស្ថានចំណុះច្បាប់នេះជាអ្នកទទួលចេញសោហ៊ុយ ។

អ្នកជំរះបញ្ជី ដែលអាចជាអភិបាលបណ្តោះអាសន្ន ត្រូវជំរះទ្រព្យសកម្មនិងសងបំណុលនៃគ្រឹះស្ថាន ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរអាណាព្យាបាល ។

មាត្រា ៦២.-

ប្រសិនបើបន្ទាប់ពីការវាយតម្លៃ គ្រឹះស្ថានគ្មានសាធនភាព អាជ្ញាប័ណ្ណត្រូវបានដកហូតភ្លាម ហើយការអភិបាលបណ្តោះអាសន្នត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីតាមផ្លូវតុលាការ ហើយសោហ៊ុយចំណាយជាបន្ទុករបស់គ្រឹះស្ថាន ។

អភិបាលបណ្តោះអាសន្នត្រូវធ្វើប្រតិវេទន៍ទូវការឈប់សងប្រាក់ហើយប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីតែងតាំងអ្នកជំរះបញ្ជីតាមផ្លូវតុលាការ ។ អភិបាលបណ្តោះអាសន្នអាចបំពេញតួនាទីជាអ្នកជំរះបញ្ជីបានដែរ ។

អ្នកជំរះបញ្ជីតាមផ្លូវតុលាការ ជំរះទ្រព្យសកម្ម ហើយដោះស្រាយរាល់កិច្ចសន្យា ក្រោមការត្រួតពិនិត្យរបស់តុលាការនិងតាមនីតិវិធីនៃច្បាប់ទូទៅ ។ ប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុដែលប្រព្រឹត្តឡើងនៅពេលជំរះបញ្ជី ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៦៣.-

ការជំរះបញ្ជី តាមផ្លូវតុលាការឬមិនតាមផ្លូវតុលាការ អាស្រ័យដោយគ្រឹះស្ថានចំណុះច្បាប់នេះ គ្មានឬមានសាធនភាព និងត្រូវធ្វើឡើងបន្ទាប់ពីការប្រកាសដកអាជ្ញាប័ណ្ណ ដោយការដាក់ទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

មាត្រា ៦៤.-

ផ្អែកលើលក្ខណៈពិសេសនៃសកម្មភាពធនាគារឬហិរញ្ញវត្ថុ កិច្ចសន្យាក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ បន្ទាប់ពីបានប្រកាសទុកជាបានការ ត្រូវជំរះស្រឡះតាមលំដាប់ដូចខាងក្រោម :

១- សោហ៊ុយនិងតម្លៃការដែលពាក់ព័ន្ធដល់ការអភិបាលបណ្តោះអាសន្ននិងការជំរះបញ្ជីតាមផ្លូវតុលាការឬមិនតាមផ្លូវតុលាការ ។

២- ពន្ធនិងអាករ ដែលត្រូវបង់ជូនរតនាគារជាតិ ។

៣- ប្បវ័ត្តិបុគ្គលិករបស់គ្រឹះស្ថានចំណុះច្បាប់នេះសំរាប់រយៈពេលបីខែ (៣ខែ) មុនថ្ងៃកំណត់តែងតាំងអ្នកជំរះបញ្ជី ។

៤- ឥណទេយ្យធានាដោយឯកសិទ្ធិដទៃទៀតឬដោយប្រាតិភោគ ក្នុងករណីដែលការធានាទាំងនេះត្រូវបានព្រមព្រៀងនៅក្រៅរយៈពេលមន្ទិលសង្ស័យ ។

៥- ប្រាក់បញ្ញើជាសាច់ប្រាក់ ជាមាស និងជាមូលបត្រ ឬ ឥណទេយ្យគ្រប់ប្រភេទដែលកាន់កាប់ដោយសាមីជន ក្រៅពីស្ថាបន័ធនាគារឬហិរញ្ញវត្ថុ ដោយចាប់ផ្តើមសងអតិថិជនម្នាក់ៗ ដែលជាម្ចាស់គណនីប្រាក់បញ្ញើជារៀលទូវិកប្រាក់ដូចគ្នាខ្ពស់បំផុតចំនួនពីរលានរៀល (២.000.000៛) ។

៦- ប្រាក់បញ្ញើដទៃទៀតជាសាច់ប្រាក់ ជាមាស និងជាមូលបត្រ ឬ ឥណទេយ្យផ្សេងទៀតដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុ ។

៧- ឥណទេយ្យជាប់លក្ខខណ្ឌនិងការអោយខ្ចីជាប់ភាគភាព ។

មាត្រា ៦៥.-

អាជ្ញាធរអាណាព្យាបាល អភិបាលបណ្តោះអាសន្ន ឬអ្នកជំរះបញ្ជី ត្រូវតែប្តឹងទៅតុលាការប្រសិនបើសំគាល់ឃើញមានបទល្មើសចូនដូរខាងព្រហ្មទណ្ឌដែលជំទាស់នឹងបទប្បញ្ញត្តិច្បាប់ឬបទបញ្ជា ។

មាត្រា ៦៦.-

អភិបាលបណ្តោះអាសន្នឬអ្នកជំរះបញ្ជី ត្រូវបានជ្រើសរើសដោយអាជ្ញាធរអាណាព្យាបាលនៅក្នុងបញ្ជីអ្នកមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិ ដែលអាជ្ញាធរអាណាព្យាបាលបានរៀបចំជាមួយក្រសួងយុត្តិធម៌ ។

មាត្រា ៦៧.-

ប្រសិនបើបេសកកម្មខាងលើត្រូវរាំងស្ទះតាមបែបណាក្តីដោយគ្រឹះស្ថានចំណុះច្បាប់នេះ អភិបាលបណ្តោះអាសន្នឬអ្នកជំរះបញ្ជី ត្រូវប្រើប្រាស់សិទ្ធិប្តឹងតវ៉ាចំពោះមុខតុលាការពីបទល្មើសមិនអោយបំពេញមុខងារ ។

មាត្រា ៦៨.-

ភាគទុនិកៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលមានសាធនភាព អាចសំរេចក្នុងមហាសន្និបាតវិសាមញ្ញ នូវការជំរះបញ្ជីគ្រឹះស្ថានរបស់ខ្លួនបានតាមនីតិវិធីនៃច្បាប់ទូទៅ ។

ផ្តើមចេញពីសេចក្តីសំរេចនេះ អាជ្ញាធរអាណាព្យាបាលតែងតាំងអ្នកជំរះបញ្ជីដើម្បីអោយធ្វើប្រតិបត្តិការជំរះបញ្ជី ក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

មាត្រា ៦៩.-

តម្លៃការនិងសោហ៊ុយផ្សេងៗទៀត ដែលកើតមកពីការអភិបាលបណ្តោះអាសន្នឬដោយការជំរះបញ្ជីត្រូវគិតគូរលើមូលដ្ឋាននៃអត្រាគំលៀវជ្វាជីវៈប្រចាំតំបន់ជាធរមាននិងជាបន្ទុកស្ថាប័នប្រវត្តិរូបរបស់គ្រឹះស្ថានចំណុះច្បាប់នេះ តាមការអនុវត្តន៍មាត្រា ៥៧, ៦១, ៦២, ៦៣ និងមាត្រា ៦៤ នៃច្បាប់នេះ ។

ជំពូកទី ២១
កិច្ចការពារអតិថិជន

មាត្រា ៧០.-

អាជ្ញាធរអាណាព្យាបាលមានបន្ទុកកំណត់នូវកំរិតវិធានៃការដឹកនាំល្អ ក្រោយពីការពិគ្រោះយោបល់ពីវិជ្ជាជីវៈ សំដៅការពារអតិថិជន ជាអាទិ៍ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹង :

១- តម្លាភាព និងការកំរិតលក្ខណៈនៃបរិយាយានិងតម្លៃការនៃប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុ ។

២- ការអនុវត្តន៍ឬការបញ្ឈប់ឥណទាន ។

៣- ការចរចាឡើងវិញលើការអោយខ្ចី ។

មាត្រា ៧១.-

សមតុល្យឥណទាយី នៃគណនីរបស់អតិថិជន ឬរបស់គ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុ ដែលនៅសល់

គ្មានចលនាពីសំណាក់ម្ចាស់គណនី ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ជាប់គ្នា ត្រូវតែផ្ទេរ ក្រោយពីរយៈពេលនេះ ជូនទៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងប្រាក់បញ្ញើធនាគារ ដែលត្រូវងអាជ្ញាយុកាលលទ្ធកម្ម ។

ជំពូកទី ២២
ការរៀបចំវិជ្ជាជីវៈ

មាត្រា ៧២.-

នៅក្រោមរូបភាពគតិយុត្តឬឯកទេសកម្មណាក៏ដោយ គ្រឹះស្ថានចំណុះច្បាប់នេះទាំងអស់មានភាពកិច្ចចូលជាសមាជិកដោយផ្ទាល់ទៅក្នុងសមាគមវិជ្ជាជីវៈតែមួយគត់ ដែលលក្ខន្តិកៈត្រូវតែដាក់ស៊ុមិដ្ឋាការជាមុនពីសំណាក់អាជ្ញាធរអាណាព្យាបាល ។ ដោយឡែកចំពោះក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ការចូលជាសមាជិកក្នុងសមាគមវិជ្ជាជីវៈត្រូវធ្វើតាមរយៈអង្គការសហពន្ធ័រួមដូចមានកំណត់ក្នុងមាត្រា ១១ នៃច្បាប់នេះ ។

សមាគមនេះត្រូវស្ថិតនៅក្រោមអំណាចប្រធានតែម្នាក់ ដែលសមាជិកទាំងអស់ត្រូវបោះឆ្នោតជ្រើសរើសតាមនីតិវិធីច្បាស់លាស់ក្នុងលក្ខន្តិកៈរបស់សមាគម ។ ប៉ុន្តែនៅក្នុងផ្ទៃក្នុងនៃសមាគម សមាជិកអាចប្រមូលផ្តុំគ្នា ជាផ្ទៃករងដាច់ៗគ្នាទៅតាមឯកទេសកម្មវិជ្ជាជីវៈរបស់ខ្លួន ។

មាត្រា ៧៣.-

សមាគមវិជ្ជាជីវៈនេះមានកម្មវត្ថុដូចតទៅ :

១- តំណាងផលប្រយោជន៍សមូហភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ជាពិសេសចំពោះអំណាចសាធារណៈនិងអាជ្ញាធរអាណាព្យាបាល ។

២- ផ្តល់ពត៌មានដល់សមាជិកនិងសាធារណជន ស្តីពីទិដ្ឋភាពនៃប្រតិបត្តិការធនាគារនិងហិរញ្ញវត្ថុ ។

៣- សិក្សារាល់បញ្ហាដែលជាប្រយោជន៍រួម ។

៤- លើកកំពស់ការបណ្តុះបណ្តាលអន្តរធនាគារខាងវិជ្ជាជីវៈ ។

៥- រៀបចំនិងគ្រប់គ្រងរាល់សេវាអន្តរធនាគារ ដោយមានការយល់ព្រមឬក្រោមការត្រួតពិនិត្យពីអាជ្ញាធរអាណាព្យាបាល ។

៦- ប្តឹងទៅតុលាការ យោងតាមមាត្រា ៥៦ នៃច្បាប់នេះ ។

ជំពូកទី ២៣

អន្តរប្បញ្ញត្តិ

មាត្រា ៧៤.-

១- ត្រឹះស្ថានដែលបានទទួលប្រតិស្រុតពីមុនមក ត្រូវកែតំរូវលក្ខន្តិកៈសកម្មភាពនិងរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនអោយបានសមស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ក្រោយពីច្បាប់នេះចូលជាធរមាន និងត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មីទៅក្នុងរយៈពេលដូចគ្នានេះ ។

ក្រោយពីការពិនិត្យពាក្យសុំ ធនាគារជាតិនៃកម្ពុជានឹងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិនិងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវឈ្មោះត្រឹះស្ថានដែលបានទទួលប្រតិស្រុតតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្រោយរយៈពេលប្រាំមួយខែ (៦ខែ) ត្រឹះស្ថានណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទដ្ឋានទាំងឡាយសំរាប់អនុវត្ត ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួននិងត្រូវធ្វើការជំរះបញ្ជី ។

២- ត្រឹះស្ថានណាយកប្រតិបត្តិការមានចរិតជាធនាគារឬហិរញ្ញវត្ថុធ្វើអាជីវកម្មដែលចែងក្នុងមាត្រា ២ មាត្រា៣ និងមាត្រា ៤ នៃច្បាប់នេះ ដោយគ្មានទីតិសម្បទា ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់ខ្លួន ហើយត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទៅអាជ្ញាធរអាណាព្យាបាលពាក់ព័ន្ធក្នុងរយៈពេលបីខែ (៣ខែ) ចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។

៣- អង្គភាពទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងអនុវត្តប្រតិបត្តិការធនាគារសំដៅជំរុញអន្តរការិយកម្មធនាគារ នៅក្នុងវិស័យកសិកម្ម សិប្បកម្ម ជនឱ្យតូចតាចនិងសេវាចំពោះឯកត្តជន អាចបន្តសកម្មភាពរបស់ខ្លួននៅក្នុងលក្ខខណ្ឌបដិប្បញ្ញត្តិនៃច្បាប់នេះ ដែលត្រូវបានកំណត់ដោយបទបញ្ជាពិសេសរបស់ធនាគារជាតិនៃកម្ពុជា ជាអាទិ៍អំពី :

- ដើមទុនអប្បបរមា

- អាជ្ញាប័ណ្ណនិងបែបបទអនុវត្ត
- វិធានការប្រុងប្រយ័ត្នដែលត្រូវប្រតិបត្តិតាម
- លក្ខខណ្ឌនៃការចោះទីតាំង ។

ជំពូកទី ២៤

អវសានប្បញ្ញត្តិ

មាត្រា ៧៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧៦.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ស្តេចព្រះករុណាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ២១៨ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩

អគ្គលេខាធិការរដ្ឋសភាជាតិ

ហត្ថលេខា

ជា ចាន់តូ

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិកម្ពុជា

ហត្ថលេខា

ជា ចាន់តូ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

ឧបករណ៍អាចដួញដួរបាន

និង

ប្រតិបត្តិការទូទាត់សងប្រាក់

ព្រះរាជក្រម

នស/រកម/១០០៥/០៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតារស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកស/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់អគ្គទេសាភិបាលធានាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ចិ ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើចម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកចិ ១០ នីតិកាលចិ ១ ដែលមានសេចក្តីចាំងស្រុងដូចតទៅនេះ :

/ւշ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះគ្រប់គ្រងលើឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ រួមបញ្ចូលទាំងគណនីធនាគារ និងប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់ ។

១-ឧបករណ៍អាចជួញដូរបានសំដៅដល់បញ្ជា ឬ ការសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីទូទាត់សងចំនួនប្រាក់ជាកំណត់មួយ ដែលអាចផ្ទេរបានតាមរយៈការប្រគល់ ហើយកាលបើចាំបាច់ក៏មានបិទ្ទិលេខផងដែរ ។ ឧបករណ៍អាចជួញដូរបានដែលគ្រប់គ្រងដោយច្បាប់នេះ រួមមានមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា ។

២-ប្រតិបត្តិការទូទាត់សងប្រាក់ ដែលគ្រប់គ្រងនិងកំណត់ដោយច្បាប់នេះ ជាការផ្ទេរមូលនិធិរវាង ឬ ពីគណនីធនាគារ ។ ប្រតិបត្តិការទូទាត់សងប្រាក់អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ ។ ប្រតិបត្តិការនេះ ត្រូវបានផ្តួចផ្តើមឡើងតាមរយៈបញ្ជាទូទាត់ ដែលអាចត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ តាមអេឡិចត្រូនិក និងដោយផ្ទាល់មាត់នៅក្រោមល័ក្ខខ័ណ្ឌខ្លះ ។

៣-ប្រព័ន្ធទូទាត់សងប្រាក់ រួមមានស្ថាប័ន ឬ យន្តការ ដែលសម្រួលដល់ការទូទាត់សងប្រាក់ជារូបិយវត្ថុ និងជាការផ្ទេរតម្លៃជារូបិយវត្ថុតាមរយៈប្រតិបត្តិការទូទាត់សងប្រាក់ ។

មាត្រា ២.-

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មានន័យមន័យដូចតទៅ :

១-ភរណីយ្រឆានសំគ្គិ សំដៅដល់ព្រឹត្តិការណ៍ ដែលជាឧបសគ្គមិនអាចចៀសផុតបាន មិនអាចគ្រប់គ្រងបាន និងហួសពីលទ្ធភាពត្រួតត្រារបស់បុគ្គល ដែលត្រូវអនុវត្តកាតព្វកិច្ច ។

២-ភារចេញផ្សាយ សំដៅដល់ការសរសេរ ចុះហត្ថលេខា និងប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជាឱ្យទៅអ្នកកាន់ទីមួយ ។

៣-ការចញ្ញាមូលប្បទានប័ត្រ ឬរូបិយាណត្តិ សំដៅដល់ការសរសេរ និងចុះហត្ថលេខាលើមូលប្បទានប័ត្រ ឬរូបិយាណត្តិ ។

៤-ការទូទាត់ សំដៅដល់ការសងប្រាក់ ដើម្បីជម្រះកាតព្វកិច្ចលើបញ្ជាទូទាត់អន្តរធនាគារ ។

៥-ការបន្ហាញ សំដៅដល់ការប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬប័ណ្ណសងតាមបញ្ជា ដើម្បីសុំឱ្យធ្វើស្នីការចំពោះរូបិយាណត្តិ ឬទូទាត់សងប្រាក់ពីបហារិក ឬអ្នកចេញប័ណ្ណ ។

៦-ការប្រតិបត្តិ នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់ការអនុវត្តបញ្ជាដែលមាននៅក្នុងបញ្ជាទូទាត់ តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ។

៧-ការផ្ទាត់ទាត់ សំដៅដល់ការប្តូរគ្នា និងជំណើរការជាអន្តរធនាគារលើបញ្ជាទូទាត់ក្នុងគោលដៅគណនាចំនួនប្រាក់សុទ្ធ ជាទ្វេភាគីឬពហុភាគី ដែលធនាគារនីមួយៗជំពាក់គ្នាទៅវិញទៅមកក្នុងការទូទាត់រាល់បញ្ជាទូទាត់ដែលត្រូវបានបញ្ចូលមកក្នុងគ្រាផ្ទាត់ទាត់នីមួយៗ ។

៨-ការផ្ទេរផ្ទៃក្នុង សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងធនាគារជាមួយគ្នា ដោយមានបញ្ជាទូទាត់តែមួយ ។ អ្នកចូលរួមនៅក្នុងការផ្ទេរផ្ទៃក្នុង រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារដែលជើរតួជាអ្នកផ្តើមប្រតិបត្តិការផង និងជាធនាគារគោលដៅផង ហើយនិងអ្នកទទួល ។

៩-ការផ្ទេរអន្តរធនាគារ សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់នៅធនាគារពីរផ្សេងគ្នា ដោយមានបញ្ជាទូទាត់យ៉ាងតិចចំនួនពីរ ។ នៅក្នុងការផ្ទេរអន្តរធនាគារ :

ក-ធនាគារទទួលនីមួយៗ ដែលពុំមែនជាធនាគារគោលដៅប្រតិបត្តិតាមបញ្ជាទូទាត់នៃអ្នកផ្ទេរបស់ខ្លួន តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ហើយបញ្ជាទូទាត់ចុងក្រោយត្រូវបានផ្ញើទៅធនាគារគោលដៅ

ខ-អ្នកចូលរួមនៅក្នុងការផ្ទេរអន្តរធនាគារ រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារផ្តើមប្រតិបត្តិការ ធនាគារគោលដៅ និងអ្នកទទួល ព្រមទាំងអាចមាន

ធនាគារអន្តរការីមួយ ឬ ច្រើនផងដែរ

គ-នៅពេលណាដែលធនាគារផ្តើមប្រតិបត្តិការ ពុំបានទទួទាត់ដោយផ្ទាល់ជាមួយធនាគារគោលដៅទេ យ៉ាងហោចណាស់ក៏ចាំបាច់ត្រូវមានធនាគារអន្តរការីមួយ ឬ ច្រើនផងដែរ

ឃ-សម្រាប់បញ្ជាទូទាត់អន្តរធនាគារនីមួយៗ ធនាគារផ្ញើទូទាត់ជាមួយធនាគារទទួល ដូចមានចែងក្នុងមាត្រា ២០២ នៃច្បាប់នេះ ។

១០-**ការផ្តេរឥណទាន** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅធនាគាររបស់ខ្លួន ដោយផ្អែកលើការអនុញ្ញាតពីអ្នកសងប្រាក់ឱ្យធ្វើការទារប្រាក់ពីគណនីអ្នកសងប្រាក់ ។

១១-**ការផ្តេរឥណទាន** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកសងប្រាក់ដែលបានចេញបញ្ជាទូទាត់ឱ្យធនាគារផ្តេរមូលនិធិចេញពីគណនីរបស់ខ្លួនឱ្យទៅអ្នកទទួលប្រាក់ ឬទៅក្នុងគណនីអ្នកទទួលប្រាក់ ។

១២-**កិច្ចព្រមព្រៀង** ក្នុងផ្នែកទី ៧ ជំពូកទី ៥ នៃច្បាប់នេះសំដៅដល់កិច្ចសន្យារវាងធនាគារ និងអតិថិជន ដែលអនុវត្តចំពោះប្រតិបត្តិការគណនី រួមទាំងបញ្ជាទានោ ដូចជារយៈពេលនៃប្រតិបត្តិការនោះ ការកែប្រែ និងបញ្ឈប់ជាដើម ។

១៣-**គណនី** សំដៅដល់គណនីទាំងឡាយ ដែលបានបើកនៅក្រោមកិច្ចសន្យារវាងអតិថិជន និងធនាគារ ទោះបីជាគណនីចរន្ត គណនីផ្តេរប្រាក់ ឬ គណនីផ្សេងទៀតក្តី និងរួមទាំងគណនីនៅក្រោមទំនាក់ទំនងពិសេស ដែលបង្កើតឡើងក្នុងគោលបំណងអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់តែមួយប៉ុណ្ណោះ ។

១៤-**គណនីទូទាត់** សំដៅដល់គណនីដែលធនាគារមួយ បានបើកនៅក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ចូលនិងចេញ ។

១៥-**គណនីច្រកចំបណ្តើមានសៀវភៅ** សំដៅដល់គណនីដែលត្រូវបានចុះឥណពន្ធ និងឥណទានដោយធនាគារ ដើម្បីកត់ត្រាប្រតិបត្តិការក្នុងសៀវភៅច្រកចំបណ្តើដែលធនាគារបានចេញឱ្យអតិថិជនតាំងពីដំបូង ហើយត្រូវបានយកមកឱ្យធនាគារកត់ត្រារាល់ប្រតិបត្តិការ ។

១៦-**តារាងការប្រគល់សិទ្ធិ** សំដៅដល់ការប្រគល់សិទ្ធិ ដែលមានកម្រិត

ដើម្បីទារប្រាក់ក្នុងនាមអ្នកផ្ទេរ ។

១៧-តាមអេឡិចត្រូនិក សំដៅដល់មធ្យោបាយទូរគមនាគមន៍ភ្ជាប់ដោយប្រព័ន្ធកុំព្យូទ័រ ឬការបញ្ជូនជាវូបវ័ន្ត ពុំមានការភ្ជាប់ប្រព័ន្ធកុំព្យូទ័រ មានខ្សែអាត់ ហ្វូណូក្រាម ឬឧបករណ៍ប្រហាក់ប្រហែលនេះ ។

១៨-តម្លៃសម្រាប់ទារបំណុល សំដៅដល់តម្លៃដែលត្រូវបានទទួលដោយអ្នកផ្ទេរនៅពេលធ្វើបេឡានិច័យ ឬតម្លៃដែលទារមកវិញដោយអ្នកទទួលការផ្ទេរ នៅលើឧបករណ៍អាចជួញដូរបាន ។

១៩-តម្លៃសម្រាប់ធានា ឬតម្លៃសម្រាប់ដាក់បញ្ចាំ សំដៅដល់ការផ្ទេរដោយមានការធានា ឬ ការផ្ទេរក្នុងគោលបំណងបង្កើតអត្ថប្រយោជន៍នៃការធានា និងដែលមិនមែនជាការផ្ទេរកម្មសិទ្ធិ ។

២០-ថ្ងៃធ្វើការរបស់ធនាគារ សំដៅដល់ពេលវេលាមួយផ្នែកនៃថ្ងៃដែលក្នុងអំឡុងពេលនោះ ធនាគារបានបើកទ្វារដើម្បីទទួលដំណើរការបញ្ជូនបញ្ជាទូទាត់ និងសារផ្សេងៗដែលទាក់ទងទៅនឹងប្រតិបត្តិការទូទាត់សងប្រាក់ ។

២១-ថ្ងៃប្រសិទ្ធភាព សំដៅដល់ថ្ងៃធ្វើការរបស់ធនាគារ ដែលនៅក្នុងថ្ងៃនោះ បញ្ជាទូទាត់ត្រូវបានអនុវត្តតាមបញ្ជារបស់អ្នកធ្វើ ។

២២-ធនាគារ សំដៅដល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការធនាគារក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថាន ឬអង្គភាពណាមួយដែលច្បាប់អនុញ្ញាតឱ្យទទួលប្រាក់បញ្ញើ ឬ ចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់លើគណនីរបស់អតិថិជន ។

សាខា ឬ ការិយាល័យដោយឡែករបស់ធនាគារ ត្រូវបានចាត់ទុកជាធនាគារដាច់ដោយឡែក សម្រាប់គោលបំណងនៃ (ក) ភារកិច្ចក្នុងការអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់ និង (ខ) ការគណនាពេលវេលាដែលក្នុងពេលនោះ ឬ កំណត់កន្លែងដែលនៅទីនោះសកម្មភាព ឬ សេចក្តីជូនដំណឹង ឬ បញ្ជាត្រូវបានធ្វើ ។

២៣-ធនាគារគោលដៅ សំដៅដល់ធនាគារ ដែលត្រូវបានបញ្ជាក់នៅក្នុងបញ្ជាទូទាត់ ដែលក្នុងនេះ ការទូទាត់ឱ្យទៅអ្នកទទួលប្រាក់ក្នុងការផ្ទេរឥណទាន ត្រូវ

ចានធ្វើឡើង ឬ ដែលមានគណនីរបស់អ្នកសងប្រាក់ក្នុងការផ្ទេរឥណពន្ធ ។ ធនាគារគោលដៅ ជាធនាគារដែលទទួលបញ្ជាទូទាត់ក្រោយគេបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារគោលដៅ ជាធនាគាររបស់អ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារគោលដៅ ជាធនាគាររបស់អ្នកសងប្រាក់ ។

២៤-ធនាគារផ្តើមប្រតិបត្តិការ សំដៅដល់ធនាគារដែលទទួលបញ្ជាទូទាត់ដែលផ្តើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារផ្តើមប្រតិបត្តិការជាធនាគាររបស់អ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្តើមប្រតិបត្តិការជាធនាគាររបស់អ្នកទទួលប្រាក់ ។

២៥-ធនាគារទទួល សំដៅដល់ធនាគារ ដែលបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវបានបញ្ជូនឱ្យទៅ ។

២៦-ធនាគារអន្តរការី សំដៅដល់ធនាគារទទួល ដែលស្ថិតនៅកណ្តាលធនាគារផ្តើមប្រតិបត្តិការ និងធនាគារគោលដៅ ។

២៧-នីតិវិធីសុវត្ថិភាព សំដៅដល់នីតិវិធីបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអតិថិជន និងធនាគារទទួល ក្នុងគោលបំណង :

-ផ្ទៀងផ្ទាត់ថា បញ្ជាទូទាត់ ឬ ការបញ្ជាបញ្ឈប់ពិតជាបញ្ជារបស់អតិថិជន ឬ

-រាវរកការភ័ន្តច្រឡំក្នុងការបញ្ជូន ឬ ក្នុងខ្លឹមសារនៃបញ្ជាសងប្រាក់ឬបញ្ជាបញ្ឈប់ ។

នីតិវិធីសុវត្ថិភាព អាចទាមទារឱ្យមានការប្រើប្រាស់វិធាន លេខកូដ ឬ លេខសម្ងាត់ដែលបញ្ជាក់ពាក្យ ឬ ចំនួនប្រាក់ពាក្យមានន័យសម្ងាត់ នីតិវិធីសួរបញ្ជាក់ទៅវិញ ឬ វិធីប្រហាក់ប្រហែលផ្សេងទៀត ។ ការប្រៀបធៀបហត្ថលេខានៅលើបញ្ជាទូទាត់ ឬ ទំនាក់ទំនងជាមួយអតិថិជន ដែលមានគំរូហត្ថលេខាប្រតិស្រុតពុំមែនជានីតិវិធីសុវត្ថិភាពឡើយ ។

២៨-បច្ចិលទិញដោយគ្មានសោហ៊ុយ សំដៅដល់ការសន្យា ដែលអនុញ្ញាតឱ្យធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធ ដោយមិនតម្រូវឱ្យអ្នកកាន់ធ្វើវិវុទ្ធវាទ ។

២៩-បញ្ជាទូទាត់ សំដៅដល់បញ្ជាទៅធនាគារឱ្យធ្វើការសងប្រាក់ ឬទារប្រាក់មួយចំនួនចេញពីគណនី ដែលបានចង្អុលបង្ហាញឱ្យទៅ ឬ សម្រាប់អ្នកទទួលប្រាក់ ឬ ឱ្យទៅ ឬ សម្រាប់គណនីរបស់អ្នកទទួលប្រាក់ និងរួមទាំងការកែប្រែណាមួយ នៅលើបញ្ជាទូទាត់ផងដែរ ។ បញ្ជានោះអាចមានកំណត់ថ្ងៃប្រសិទ្ធភាព ប៉ុន្តែមិនត្រូវស្ថិតនៅក្រោមលក្ខខណ្ឌណាមួយ ក្រៅពីអ្វីដែលធនាគារផ្តើមប្រតិបត្តិការបានព្រមព្រៀងអនុវត្តឡើយ ។ ភាគីនៃបញ្ជាទូទាត់ រួមមានអ្នកធ្វើ និងធនាគារទទួល ។ នៅពេលណាដែលអ្នកធ្វើជាធនាគារ នៅពេលនោះបញ្ជាទូទាត់ គឺជាបញ្ជាទូទាត់អន្តរធនាគារ ។

៣០-បហារីត សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ ។

៣១-បហារិត សំដៅដល់បុគ្គលដែលទទួលបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ ។

៣២-ប្រតិបត្តិការទូទាត់សងប្រាក់ សំដៅដល់ការផ្ទេរមូលនិធិពីគណនីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ ឬ ឱ្យទៅគណនីអ្នកទទួលប្រាក់ ។ ប្រតិបត្តិការទូទាត់សងប្រាក់ :

(ក)អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ

(ខ)ត្រូវបានផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទៅកាន់ធនាគារផ្តើមប្រតិបត្តិការ ឱ្យអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់នោះ

(គ)ត្រូវបានអនុវត្តដោយធនាគារអ្នកសងប្រាក់ ដោយការកត់ត្រាឥណពន្ធលើគណនីរបស់អ្នកសងប្រាក់ ចំពោះធនាគាររបស់អ្នកទទួលប្រាក់វិញ ធ្វើការកត់ត្រាឥណទានលើគណនីរបស់អ្នកទទួលប្រាក់ ឬ ដាក់មូលនិធិឱ្យស្ថិតនៅក្នុងការគ្រប់គ្រង និងសម្រាប់តម្រូវការប្រើប្រាស់របស់អ្នកទទួលប្រាក់ ដូចដែលបានបញ្ជាដោយអ្នកផ្តើមប្រតិបត្តិការ

(ឃ)អាចជាការផ្ទេរមូលនិធិពីអ្នកសងប្រាក់ទៅអ្នកទទួលប្រាក់ដែលអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬ ពីរផ្សេងគ្នា និង

(ង)អាចជាការផ្ទេរមូលនិធិ ដែលនៅក្នុងនោះអ្នកសងប្រាក់ត្រូវតែមានគណនី ហើយការទូទាត់ឱ្យទៅអ្នកទទួលប្រាក់អាចនឹងធ្វើឡើងនៅក្នុងធនាគារតែមួយជាមួយគ្នា ឬ ពីរផ្សេងគ្នា ។

៣៣-**បិដ្ឋិលេខ** សំដៅដល់ហត្ថលេខាលើខ្នងនៃឧបករណ៍អាចផ្ទេរបានដោយមាន ឬ គ្មានពាក្យបញ្ជាក់ ។ ដើម្បីមានប្រសិទ្ធភាព បិដ្ឋិលេខត្រូវតែបានបំពេញបង្គ្រប់ដោយការប្រគល់ ។

៣៤-**បុគ្គល** សំដៅដល់នីតិបុគ្គល និងរូបវ័ន្តបុគ្គល ។

៣៥-**តារាងគ្រប់គ្រាន់នៃសមតុល្យ** ចំពោះបញ្ជាទូទាត់ សំដៅដល់ការមានមូលនិធិគ្រប់គ្រាន់ពោលគឺ អត្ថិភាពនៃសមតុល្យគណនី ដែលមិនតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់ រួមមានសមតុល្យនៅពេលបិទបញ្ជីនាថ្ងៃធ្វើការរបស់ធនាគារថ្ងៃមុន**បូក** ខ្នង់ឥណទាននៃការផ្ទេរប្រាក់ចូលក្នុងគណនីអ្នកសងប្រាក់នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ ប្រាក់បញ្ញើនិងប្រាក់ផ្ទេរចូល **ដក** ការសងប្រាក់ចេញ ការដកប្រាក់ដែលកើតមានរួចហើយ នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ និង សោហ៊ុយទាំងឡាយរបស់ធនាគារ ដែលអាចមាន ។ មូលនិធិដែលឆ្លុះបញ្ចាំងជាខ្នង់ឥណទានបណ្តោះអាសន្ន នៅក្នុងគណនីរបស់អ្នកសងប្រាក់មិនត្រូវបានបូកបញ្ចូលជាផ្នែកមួយនៃចំនួនប្រាក់ ដែលតម្រូវសម្រាប់ការទូទាត់នោះទេ ។

៣៦-**មូលនិធិ** សំដៅដល់សាច់ប្រាក់ និងប្រាក់បញ្ញើ ដែលបានដាក់ធ្វើនៅក្នុងគណនីធនាគារ ។

៣៧-**រូបិយបដិភោគ** សំដៅដល់ការជានាទូទាត់សងប្រាក់លើមូលប្បទានប័ត្ររូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ។

៣៨-**រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុណាមួយ ក្រៅពីរូបិយវត្ថុក្នុងស្រុក ។

៣៩-**រូបិយវត្ថុក្នុងស្រុក** សំដៅដល់ប្រាក់រៀល ដែលជារូបិយវត្ថុផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ។

៤០-**ទិរុទ្ធភាព** សំដៅដល់ប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងជាផ្លូវការនៅក្នុងកាលៈទេសៈទាំងឡាយដូចជា ការខកខាន ឬ ការបដិសេធមិនធ្វើស្ថិការ ការមិនទូទាត់សងប្រាក់ ឬ មិនផ្តល់ទិដ្ឋាការ ដែលផ្តល់សិទ្ធិដល់អ្នកកាន់ឱ្យធ្វើឧបាស្រ័យលើ

ឧបករណ៍អាចជួញដូរបាន ។ វិរុទ្ធវាទត្រូវតែបានធ្វើដូច និងនៅពេលដែលតម្រូវដោយបទប្បញ្ញត្តិដោយឡែកនៃច្បាប់នេះ ។

៤១-**ស្វ័ការ** សំដៅដល់ការយល់ព្រមរបស់បហារិតនៃរូបិយាណត្តិដើម្បីអនុវត្តតាមបញ្ជារបស់បហារិក ។ ដើម្បីមានប្រសិទ្ធភាព ស្វ័ការត្រូវតែបានបំពេញបង្គ្រប់ ដោយការប្រគល់និងការជូនដំណឹង ។

៤២-**សម្រាប់មេឡានិច័យ** សំដៅដល់បិដ្ឋិលេខមួយដែលបង្ហាញថាបិដ្ឋិ-លេខនោះមិនមែនជាការផ្ទេរកម្មសិទ្ធិ ប៉ុន្តែសម្រាប់គោលបំណងសម្រួលបេឡានិច័យ ឬ ទារមកវិញនូវចំនួនប្រាក់លើឧបករណ៍អាចជួញដូរបាន ដោយអ្នកទទួលការផ្ទេរក្នុងនាមអ្នកផ្ទេរ ។

៤៣-**អត្តគាហក** នៅក្នុងជំពូកទី ២ ទី ៣ និងទី ៤ នៃច្បាប់នេះ សំដៅដល់បុគ្គលដែលទទួលផលពីការទូទាត់សងមូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា នៅពេលត្រូវបានចេញផ្សាយ ។

៤៤-**អតិថិជន** សំដៅដល់ឯកត្តជន ទោះបីជាមានប្រកបមុខរបរក្តី ឬ ពុំមានក្តី ឬនីតិបុគ្គលរួមទាំងធនាគារផង ដែលមានគណនីនៅធនាគារមួយ ។

៤៥-**អន្តរាគមន៍ជើម្បីទូទាត់សងច្រាក់** សំដៅដល់នីតិវិធីដែលភាគីមិនពាក់ព័ន្ធនឹងឧបករណ៍អាចជួញដូរបានចូលធ្វើអន្តរាគមន៍ ដើម្បីធ្វើស្វ័ការ ឬ ទូទាត់សងប្រាក់ជូនភាគីដែលពាក់ព័ន្ធ ។

៤៦-**អ្នកចេញប័ណ្ណសងតាមបញ្ជា ឬ អ្នកចេញប័ណ្ណ** សំដៅដល់បុគ្គលដែលធ្វើការសន្យាទូទាត់សងប្រាក់ នៅលើប័ណ្ណសងតាមបញ្ជា ។

៤៧-**អ្នកឆ្នើ** សំដៅដល់បុគ្គលដែលបញ្ជូនបញ្ជាទូទាត់ទៅធនាគារទទួល ។

៤៨-**អ្នកផ្តើមប្រតិបត្តិការ** សំដៅដល់អ្នកធ្វើបញ្ជាទូទាត់ដំបូង ដែលផ្តើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកផ្តើមប្រតិបត្តិការជាអ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកផ្តើមប្រតិបត្តិការ ជាអ្នកទទួលប្រាក់ ។

៤៩-**អ្នកឧទ្ធរណ៍** សំដៅដល់អ្នកចូលរួម ដែលធនាគាររបស់ខ្លួន ជាអ្នកទទួលបញ្ជាទូទាត់ចុងក្រោយបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលជាអ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលជាអ្នក

សងច្រាក់ ។

៥០-អ្នកទទួលច្រាក់ នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់អ្នកចូលរួម ដែលនឹងត្រូវទទួលច្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងច្រាក់ និងនៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលច្រាក់រាប់បញ្ចូលផងដែរ នូវអ្នកដែលត្រូវទទួលច្រាក់ដោយការផ្ទេរដែលមានការប្រគល់សិទ្ធិ បើសិនជាមាន ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលច្រាក់ជាអ្នកទទួល ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលច្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។

៥១-អ្នកសងច្រាក់ សំដៅដល់អ្នកចូលរួម ដែលត្រូវសងច្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងច្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកសងច្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកសងច្រាក់ជាអ្នកទទួល ។

៥២-ឥណទានតិចរូបន៍ សំដៅដល់ពិតានឥណទាន ដែលអនុញ្ញាតឱ្យខ្ចីមូលនិធិ ហើយការដក ឬ ការផ្ទេរមូលនិធិនោះត្រូវប្រើមូលប្បទានប័ត្រ ឬ បញ្ជាទូទាត់ ។

៥៣-ឥណប្រតិទាន សំដៅដល់កាលបរិច្ឆេទ ដែលរូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ត្រូវដល់កាលកំណត់សង ។

៥៤-ឱឍស្ថ័យ សំដៅដល់សិទ្ធិប្តឹងទារសំណងមកវិញនូវការខូចប្រយោជន៍ពីបុគ្គលដែលពាក់ព័ន្ធ លើឧបករណ៍អាចជួញដូរបាន ។

ជំពូកទី ២

មូលប្បទានប័ត្រ

ផ្នែកទី ១

ការចេញនិងទម្រង់នៃមូលប្បទានប័ត្រ

មាត្រា ៣.-

មូលប្បទានប័ត្រ ជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតលក្ខខ័ណ្ឌឱ្យទៅធនាគារនិងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ មូលប្បទានប័ត្រ

ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងជំពូកនេះ ។

មាត្រា ៤.-

មូលប្បទានប័ត្រ អាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ ជាអក្សរបរទេស និងត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **មូលប្បទានប័ត្រ** ដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតលក្ខខ័ណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែង ដែលមូលប្បទានប័ត្រត្រូវបានចេញ

-ហត្ថលេខារបស់បហារក ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានប័ត្រ ។

មាត្រា ៥.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ពុំមានសុពលភាពជាមូលប្បទានប័ត្រឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌខាងក្រោម :

១-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថា ជាកន្លែងត្រូវទូទាត់សងប្រាក់ ។ បើមានកន្លែងច្រើនបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិត មូលប្បទានប័ត្រនោះអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបញ្ជាក់មុនបង្អស់ ។

២-បើគ្មានសេចក្តីបញ្ជាក់ទាំងនេះ និងសេចក្តីបញ្ជាក់ណាមួយផ្សេងទៀតទេ មូលប្បទានប័ត្រអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបហារិតមានទីស្នាក់ការកណ្តាលរបស់ខ្លួន ។

៣-មូលប្បទានប័ត្រដែលមិនបានបញ្ជាក់ច្បាស់លាស់ទូវកន្លែងនៃការចេញ ត្រូវបានចាត់ទុកថាចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារក ។

មាត្រា ៦.-

មូលប្បទានប័ត្រត្រូវតែបានចេញឱ្យទូទាត់សងប្រាក់ដោយធនាគារ ដែលបានទទួលរក្សាប្រាក់សម្រាប់ទុកសងក្នុងនាមបហារ័ក និងដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ដែលមានចែង ឬ បញ្ជាក់ឱ្យបហារ័កមានសិទ្ធិប្រើប្រាស់ប្រាក់នោះ តាមមូលប្បទានប័ត្រ ។ ទោះបីបដិញ្ញាខាងលើនេះ មិនបានប្រតិបត្តិតាមក្តី ក៏ឧបករណ៍នេះនៅតែមានសុពលភាពជាមូលប្បទានប័ត្រដដែល ។

មាត្រា ៧.-

មូលប្បទានប័ត្រ មិនត្រូវបានធ្វើស្ទីការទេ ។ សេចក្តីបញ្ជាក់ពីស្ទីការនៅលើមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ មិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិ ក្នុងដែរបស់បហារិតដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហារិតនៃមូលប្បទានប័ត្រក៏មិនទទួលខុសត្រូវចំពោះអ្នកកាន់ឡើយ ។

មាត្រា ៨.-

មូលប្បទានប័ត្រអាចត្រូវបានចេញផ្សាយ ដើម្បីទូទាត់សងប្រាក់ឱ្យទៅ :

-បុគ្គលដែលមានការបញ្ជាក់ដោយមាន ឬ ដោយគ្មានពាក្យថា **សងតាមបញ្ជា**

-បុគ្គលដែលមានការបញ្ជាក់ដោយពាក្យថា **មិនសងតាមបញ្ជា** ឬ ដោយពាក្យផ្សេងៗទៀតដែលមានន័យដូចគ្នា ឬ

-អ្នកកាន់ ។

មូលប្បទានប័ត្រ ដែលអាចទូទាត់សងប្រាក់ឱ្យទៅបុគ្គល ដែលមានបញ្ជាក់ដោយពាក្យថា ឬ **អ្នកកាន់** ឬ ពាក្យទាំងឡាយដែលមានន័យដូចគ្នានេះ ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រ ដែលចេញឱ្យទៅអ្នកកាន់ ។

មូលប្បទានប័ត្រ ដែលមិនបានបញ្ជាក់ឈ្មោះរបស់អត្ថគាហក ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ ។

មាត្រា ៩.-

មូលប្បទានប័ត្រ អាចត្រូវចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារ័កខ្លួនឯងផ្ទាល់ ។

មូលប្បទានប័ត្រ អាចត្រូវចេញជាប្រយោជន៍ឱ្យតតិយជន ។

មូលប្បទានប័ត្រ មិនអាចចេញដើម្បីទូទាត់សងប្រាក់ ដោយបហារ័កខ្លួនឯងបានឡើយ លើកលែងតែការចេញនេះ ធ្វើឡើងដោយគ្រឹះស្ថានមួយទៅលើគ្រឹះស្ថានមួយទៀត ដែលជាកម្មសិទ្ធិរបស់បហារ័កផងដែលនេះ ។

មាត្រា ១០.-

បដិញ្ញាណាមួយពាក់ព័ន្ធទៅនឹងការតម្រូវឱ្យសងការប្រាក់ ដែលកំណត់ទៅលើមូលប្បទានប័ត្រមិនត្រូវយកជាបានការឡើយ ។

មាត្រា ១១.-

មូលប្បទានប័ត្រ អាចត្រូវបានទូទាត់សងប្រាក់ នៅទីស្នាក់ការរបស់តតិយបុគ្គលនៅកន្លែងដែលបហារិតមានទីស្នាក់ការ ឬ នៅកន្លែងផ្សេងមួយទៀតឱ្យតែជានិច្ចកាលតតិយបុគ្គលនេះជាធនាគារ ។

មាត្រា ១២.-

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាង ជាចំនួនត្រូវយកជាបានការ ។

មាត្រា ១៣.-

រាល់កាតព្វកិច្ចនៃបុគ្គលផងទៅៗទៀត ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រនៅតែមានតម្លៃផងដែល ទោះបីមូលប្បទានប័ត្រនោះ មានហត្ថលេខារបស់បុគ្គលអសម-

ត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខា ដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬបានចុះ ហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ១៤.-

បុគ្គលណាដែលបានចុះហត្ថលេខានៅលើមូលប្បទានប័ត្រក្នុងនាមបុគ្គលមួយ ទៀត ដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគី មួយលើមូលប្បទានប័ត្រនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នា នឹងបុគ្គលដែលខ្លួនបានទទួលភ៉ាប់រងជូនឱ្យ ។ វិធានដូចគ្នានេះ ក៏អនុវត្តទៅលើអាណា-ត្តិជនដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ១៥.-

បហារ័កទទួលខុសត្រូវក្នុងការទូទាត់សងប្រាក់ ។ បដិញ្ញាណាមួយ ដែលធ្វើឱ្យ បហារ័ករួចផុតពីការទទួលខុសត្រូវនេះ មិនត្រូវយកជាបានការឡើយ ។

មាត្រា ១៦.-

បើមូលប្បទានប័ត្រ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយ ត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិន គោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើក លែងតែអ្នកកាន់នេះ បានទទួលមូលប្បទានប័ត្រមកដោយទុច្ចរិត ឬ មានកំហុសដោយ ការធ្វេសប្រហែសធ្ងន់ធ្ងរ ។

ផ្នែកទី ២

បិដ្ឋលេខមូលប្បទានប័ត្រ

មាត្រា ១៧.-

មូលប្បទានប័ត្រ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមាន ឬ ដោយគ្មានពាក្យថា **សងតាមបញ្ជា** អាចត្រូវផ្ទេរបាន ដោយបិដ្ឋិលេខ ។

មូលប្បទានប័ត្រដែលចេញឱ្យទូទាត់សងច្រាក់ ចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមានពាក្យថា **មិនសុខតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នាអាចត្រូវបានផ្ទេរ ស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

មូលប្បទានប័ត្រ អាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបហារ័កក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃមូលប្បទានប័ត្រនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខមូលប្បទានប័ត្រនោះ បន្តទៀតបាន ។

មាត្រា ១៨.-

បិដ្ឋិលេខ ត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយ ដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងមូលប្បទានប័ត្រ ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឡើងដោយបហារិក ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ **ស្លឹកការ៉ង់** មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

បិដ្ឋិលេខដែលធ្វើឱ្យបហារិក មានតម្លៃត្រឹមតែជាបង្គាន់ដៃទទួលប្រាក់ លើកលែងតែក្នុងករណីដែលបហារិកមានគ្រឹះស្ថានច្រើនកន្លែង ហើយបិដ្ឋិលេខនេះត្រូវបានធ្វើជាប្រយោជន៍ឱ្យគ្រឹះស្ថានមួយទៀត ក្រៅពីគ្រឹះស្ថានដែលមូលប្បទានប័ត្រនោះ ត្រូវបានចេញ ។

មាត្រា ១៩.-

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរនៅលើខ្នងមូលប្បទានប័ត្រ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុបំត្រែ** និងត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខអាចមិនបញ្ជាក់ពីអត្តសាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

មាត្រា ២០.-

បិដ្ឋិលេខផ្ទេរសិទ្ធិទាំងអស់ នៃមូលប្បទានប័ត្រឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តមូលប្បទានប័ត្រជាចំហ ឬ ឱ្យ បុគ្គលដទៃទៀត

-ផ្ទេរមូលប្បទានប័ត្រឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

មាត្រា ២១.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណាដែលមូលប្បទានប័ត្រត្រូវបានធ្វើបិដ្ឋិលេខបន្តឡើយ ។

មាត្រា ២២.-

ម្ចាស់មូលប្បទានប័ត្រ ដែលអាចធ្វើបិដ្ឋិលេខបានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់មូលប្បទានប័ត្រតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវចាត់ទុកថាបានទទួលមូលប្បទានប័ត្រ តាមរយៈបិដ្ឋិលេខចំហ ។

មាត្រា ២៣.-

បិដ្ឋិលេខនៅលើមូលប្បទានប័ត្រ ដែលចេញឱ្យទៅអ្នកកាន់នាំឱ្យអ្នកធ្វើបិដ្ឋិលេខនោះមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែបិដ្ឋិលេខ

នេះ មិនប្រែក្លាយឧបករណ៍នោះទៅជាមូលប្បទានប័ត្រ**សងតាមបញ្ជា** ឡើយ ។

មាត្រា ២៤.-

នៅពេលដែលបុគ្គលណាមួយបានបាត់បង់សិទ្ធិកាន់កាប់មូលប្បទានប័ត្រដោយមូលហេតុណាក៏ដោយ ទោះបីជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិ-ដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងមាត្រា ២២ នៃច្បាប់នេះ អ្នកកាន់ដែលទទួលបានមូលប្បទានប័ត្រមកជាកម្មសិទ្ធិមិនត្រូវបានបង្ខំឱ្យចោះបង់ចោលមូលប្បទានប័ត្រឡើយ លើកលែងតែមូលប្បទានប័ត្រនោះបានមកដោយទុច្ច-រិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

មាត្រា ២៥.-

បុគ្គលទាំងឡាយដែលប្តឹងអំពីមូលប្បទានប័ត្រ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបហារ័ក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលមូលប្បទានប័ត្រ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់ក្រុមបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះមិនអនុវត្តចំពោះមូលប្បទានប័ត្រ ដែលចេញដើម្បីទូទាត់សងច្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសងតាមបញ្ជា** ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

មាត្រា ២៦.-

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ទារបំណុល** ឬ **សម្រាប់បេឡានិចំយ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃមូលប្បទានប័ត្រនោះ ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់ ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខដងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគី ដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះ បានក្លាយជាអសមត្ថភាពនីស្សាឧក្ខលឡើយ ។

មាត្រា ២៧.-

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីវិវុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសម-មូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់បង្ហាញឱ្យទូទាត់សងច្រាក់ អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ២២ មាត្រា ២៤ និង មាត្រា ២៥ នៃច្បាប់នេះឡើយ ។

បើគ្មានភស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទត្រូវចាត់ទុកថាបានធ្វើនៅលើមូលប្បទានប័ត្រ មុនពេលធ្វើវិវុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នា ឬ នៅមុនផុតរយៈពេលកំណត់យោងតាមកថាខណ្ឌខាងលើនៃមាត្រានេះ ។

ផ្នែកទី ៣
រូបិយបដិភោគមូលប្បទានប័ត្រ

មាត្រា ២៨.-

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនច្រាក់ទាំងអស់ ឬ មួយផ្នែកនៃមូលប្បទានប័ត្រ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គលក្រៅពីបហារិត ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។

មាត្រា ២៩.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើមូលប្បទានប័ត្រផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់

រូបិយបដិភោគហៅថា រូបិយបដិភោគី ។

ហត្ថលេខាធ្វើរូបិយបដិភោគ ត្រូវបានចុះនៅខាងមុខមូលប្បទានប័ត្រ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យ បានច្បាស់លាស់នូវបុគ្គលណាមួយ ដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ រូបិយបដិភោគ ត្រូវបានចាត់ទុកថាធ្វើឱ្យបហារ័ក ។

មាត្រា ៣០.-

រូបិយបដិភោគីមានកាតព្វកិច្ច ផ្ទេរបុគ្គលដែលបានទទួលការធានាវិញ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះ មិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេង។ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងមូលប្បទានប័ត្រ រូបិយបដិភោគីមានសិទ្ធិទាំងឡាយ ដែលផ្តើមចេញពីមូលប្បទានប័ត្រនោះ ទល់នឹងបុគ្គលដែលត្រូវបានធានា និង បុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះ នៅលើមូលប្បទានប័ត្រ ។

ផ្នែកទី ៤
ការបង្ហាញមូលប្បទានប័ត្រនិងការទូទាត់សងច្រាក់

មាត្រា ៣១.-

មូលប្បទានប័ត្រ ត្រូវបានទូទាត់សងច្រាក់នៅពេលបង្ហាញ ។ បដិញ្ញាណាមួយដែលមានន័យផ្ទុយពីនេះ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ ដែលបានបង្ហាញឱ្យទូទាត់សងច្រាក់នៅមុនកាលបរិច្ឆេទដែលជាថ្ងៃចេញផ្សាយត្រូវតែទូទាត់សងច្រាក់នៅថ្ងៃបង្ហាញ ។

មាត្រា ៣២.-

មូលប្បទានប័ត្រ ត្រូវតែបានបង្ហាញដើម្បីឱ្យទូទាត់សងច្រាក់ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតពីថ្ងៃចេញផ្សាយ ។

មាត្រា ៣៣.-

នៅពេលដែលមូលប្បទានប័ត្រត្រូវបានចេញនៅកន្លែងមួយហើយ នឹងត្រូវទូទាត់សងប្រាក់នៅកន្លែងមួយផ្សេងទៀត ដែលមានប្រតិទិនខុសគ្នាថ្ងៃចេញផ្សាយនឹងត្រូវបានប្រកាន់យកតាមថ្ងៃដែលត្រូវគ្នាក្នុងប្រតិទិនប្រចាំកន្លែងដែលត្រូវទូទាត់សងប្រាក់ ។

មាត្រា ៣៤.-

ការបង្ហាញមូលប្បទានប័ត្រនៅ ឬ តាមរយៈសភាផាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកផ្សេងដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជា ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

មាត្រា ៣៥.-

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវជំទាស់ ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិអ្នកកាន់ ។

បើការទូទាត់សងមូលប្បទានប័ត្រមិនត្រូវបានជំទាស់ទេ បហារិកនៅតែអាចទូទាត់សងប្រាក់បាន ទោះបីផុតរយៈពេលកំណត់ត្រូវបង្ហាញក៏ដោយ ។

មាត្រា ៣៦.-

មរណភាព ឬ អសមត្ថភាពរបស់បហារ័ក ដែលកើតឡើងក្រោយការចេញផ្សាយមូលប្បទានប័ត្រ ពុំមានផលប៉ះពាល់ដល់មូលប្បទានប័ត្រឡើយ ។

មាត្រា ៣៧.-

បហារិកដែលទូទាត់សងមូលប្បទានប័ត្រអាចតម្រូវឱ្យប្រគល់មូលប្បទានប័ត្រនោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

បើមិនមានចំនួនប្រាក់គ្រប់គ្រាន់ ក្នុងគណនីរបស់បហារ័កទេ អ្នកកាន់អាចមិនបដិសេធការទូទាត់សងចំនួនប្រាក់មួយផ្នែកនៃមូលប្បទានប័ត្រ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បហារិកអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើមូលប្បទានប័ត្រ និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ៣៨.-

បហារិកដែលទូទាត់សងមូលប្បទានប័ត្រមានបិដ្ឋិលេខ ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ៣៩.-

រូបិយប័ណ្ណដែលត្រូវប្រើប្រាស់ សម្រាប់ទូទាត់សងប្រាក់លើមូលប្បទានប័ត្រត្រូវបានកំណត់ដូចខាងក្រោម :

១-មូលប្បទានប័ត្រ ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យបហារិកដើម្បីទូទាត់សងជារូបិយប័ណ្ណនៃគណនី ដែលមូលប្បទានប័ត្រត្រូវបានចេញ ។

២-នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃគណនី ចំនួនប្រាក់អាចត្រូវសងជារូបិយប័ណ្ណនៃគណនីដោយបហារិកតាមតម្លៃនៃរូបិយប័ណ្ណនោះ នៅថ្ងៃទូទាត់សងប្រាក់ ។

៣-បើមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយមូលប្បទានប័ត្រនេះមិនត្រូវបានទូទាត់សងប្រាក់នៅពេលបង្ហាញ អ្នកកាន់អាចតម្រូវឱ្យភាគីពាក់ព័ន្ធធ្វើការទូទាត់សងចំនួនប្រាក់នៃមូលប្បទានប័ត្រជារូបិយប័ណ្ណនៃកន្លែងទូទាត់សងប្រាក់តាមអត្រាប្តូរប្រាក់ នៅថ្ងៃបង្ហាញ ឬនៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

៤-ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់ ត្រូវអនុវត្តក្នុងការកំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារិកអាចកំណត់ថាចំនួនប្រាក់ទូទាត់សង ត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ដែលបញ្ជាក់នៅលើមូលប្បទានប័ត្រ ។

៥-ទោះបីមានកថាខណ្ឌទី ៣ នៃមាត្រានេះក៏ដោយ មូលប្បទានប័ត្រចេញឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលត្រូវបានប្រើនៅព្រះរាជាណាចក្រកម្ពុជា ឬ បើនៅលើមូលប្បទានប័ត្រ បហារិកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើជារូបិយប័ណ្ណមួយច្បាស់លាស់ អ្នកកាន់អាចទាមទារពីភាគីពាក់ព័ន្ធណាមួយឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់នោះ ។

៦-បើចំនួនប្រាក់នៃមូលប្បទានប័ត្រ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែល

មាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់និងប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះនៅពេលដែលរូបិយប័ណ្ណ ដែលបានបញ្ជាក់មិនមែនជារូបិយប័ណ្ណនៃគណនីដែលត្រូវទូទាត់សងប្រាក់ ការទូទាត់សងមូលប្បទានប័ត្រត្រូវធ្វើឡើងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ពុំមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់នៃមូលប្បទានប័ត្រត្រូវបានធ្វើឡើងជារូបិយប័ណ្ណដែលត្រូវបានប្រើយ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

ផ្នែកទី ៥

មូលប្បទានប័ត្រឆូតបន្ទាត់និងមូលប្បទានប័ត្រទូទាត់សងចូលក្នុងគណនី

មាត្រា ៥០.-

បហារ័ក ឬ អ្នកកាន់អាចឆូតបន្ទាត់លើមូលប្បទានប័ត្រ ។

ការឆូតបន្ទាត់មានរូបភាពជាបន្ទាត់ស្របគ្នាពីរដែលគូសនៅខាងមុខមូលប្បទានប័ត្រ ។ បន្ទាត់ឆូតអាចមានពីរបែប គឺបន្ទាត់ឆូតទូទៅ ឬ បន្ទាត់ឆូតពិសេស ។

បន្ទាត់ឆូតទូទៅមានបន្ទាត់គូសតែពីរ ឬ នៅចន្លោះបន្ទាត់ទាំងពីរមានពាក្យថាធនាគារ ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ។ បន្ទាត់ឆូតពិសេសមានឈ្មោះរបស់ធនាគារនៅចន្លោះបន្ទាត់ទាំងពីរ ។

បន្ទាត់ឆូតទូទៅ អាចត្រូវប្តូរបានទៅជាបន្ទាត់ឆូតពិសេស ប៉ុន្តែបន្ទាត់ឆូតពិសេសមិនអាចត្រូវប្តូរមកជាបន្ទាត់ឆូតទូទៅវិញបានឡើយ ។

ការកោសលុបកែបន្ទាត់ឆូត ឬ ឈ្មោះរបស់ធនាគារ មិនអាចធ្វើបានឡើយ ។

មាត្រា ៥១.-

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតទូទៅ បហារិកអាចទូទាត់សងឱ្យទៅធនាគារ ឬ ទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះ ។

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតពិសេស បហារិកអាចទូទាត់សងឱ្យទៅធនាគារដែលមានឈ្មោះនៅលើមូលប្បទានប័ត្រតែប៉ុណ្ណោះ ឬ បើធនាគារនេះជាបហា-

រិតអាចទូទាត់សងឱ្យទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះដែរ ។ ប៉ុន្តែធនាគារដែលមានឈ្មោះលើមូលប្បទានប័ត្រ អាចធ្វើបេឡានិច័យតាមរយៈធនាគារមួយទៀត ។

ធនាគារអាចទទួលយកមូលប្បទានប័ត្រឆ្លងបន្ទាត់ពីអតិថិជនរបស់ខ្លួន ឬពីធនាគារមួយផ្សេងទៀតតែប៉ុណ្ណោះ ។ ធនាគារមិនអាចធ្វើបេឡានិច័យមូលប្បទានប័ត្រឆ្លងបន្ទាត់ជាប្រយោជន៍ឱ្យបុគ្គលផ្សេងទៀត ក្រៅពីបុគ្គលដែលបានពោលខាងលើនេះឡើយ ។

ចំពោះមូលប្បទានប័ត្រដែលមានបន្ទាត់ឆ្លងពិសេសច្រើន បហារិតមិនអាចទូទាត់សងប្រាក់បានឡើយ លើកលែងតែក្នុងករណីដែលមានបន្ទាត់ឆ្លងតែពីរកន្លែងដែលក្នុងនោះបន្ទាត់ឆ្លងមួយកន្លែងសម្រាប់ធ្វើបេឡានិច័យតាមរយៈសភាជាត់ទាត់ ។

បហារិត ឬ ធនាគារ ដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាត ដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

មាត្រា ៤២.-

បហារ័ក ឬ អ្នកកាន់មូលប្បទានប័ត្រអាចហាមឃាត់ការទូទាត់សងជាសាច់ប្រាក់ដោយសរសេរអក្សរកាត់ទទឹងផ្ទៃមុខមូលប្បទានប័ត្រនោះថា **សម្រាប់ទូទាត់សងចូលក្នុងគណនី** ឬ តាមសំនួនសេចក្តីដែលមានន័យដូចគ្នា ។

ក្នុងករណីនេះ មូលប្បទានប័ត្រអាចត្រូវបានទូទាត់ដោយបហារិតតាមរយៈកិច្ចបញ្ជីកាគណនេយ្យតែប៉ុណ្ណោះ ដោយការចុះឥណទានចូលគណនី ការផ្ទេរប្រាក់ពីគណនីមួយចូលទៅគណនីមួយទៀត ការកាត់កង ឬ ការទូទាត់តាមរយៈសភាជាត់ទាត់ ។ ការទូទាត់តាមកិច្ចបញ្ជីកាគណនេយ្យមានន័យថា ជាការទូទាត់សងប្រាក់ ។

ការកោសលុបកែណាមួយចំពោះពាក្យថា **សម្រាប់ទូទាត់សងចូលក្នុងគណនី** មិនអាចធ្វើបានឡើយ ។

បហារិតដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាតដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

ផ្នែកទី ៦

ទ្វេជាស្រេយចំពោះការមិនទូទាត់សងប្រាក់

មាត្រា ៤៣.-

អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧ ចាស្រេយទល់នឹងអ្នកធ្វើបិដ្ឋិលេខបហារ័ក និងភាគី ជាប់ពាក់ព័ន្ធដទៃទៀត បើមូលប្បទានប័ត្រដែលត្រូវបានបង្ហាញនៅក្នុងរយៈពេលកំណត់ត្រឹមត្រូវនោះមិនត្រូវបានទូទាត់សងប្រាក់ ហើយបើមានភស្តុតាងយ៉ាងហោចណាស់មួយ ដែលបង្ហាញពីការបដិសេធមិនទូទាត់សងប្រាក់ដូចខាងក្រោម :

-វិរុទ្ធវាទ ឬ ឧបករណ៍ផ្ទៃវការផ្សេងណាមួយ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទនិងបញ្ជាក់ដោយបហារិតអំពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទធ្វើឡើងដោយសភាជាត់ទាត់ដែលបញ្ជាក់ថាមូលប្បទានប័ត្រ ត្រូវបានប្រគល់នៅក្នុងរយៈពេលកំណត់ និងមិនត្រូវបានទូទាត់សងប្រាក់ ។

មាត្រា ៤៤.-

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃមូលប្បទានប័ត្រភ្ជាប់ជាមួយ ហើយត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញបហារិត ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ មិនទទួលយក ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនទទួលយក ។

វិវុទ្ធវាទឬប្រតិវេទនីដែលសមមូលគ្នា ត្រូវតែបានធ្វើឡើងនៅមុនពេលផុតកំណត់បង្ហាញឱ្យទូទាត់សងច្រាក់ ។

បើមូលប្បទានប័ត្រត្រូវបានបង្ហាញឱ្យទូទាត់សង នៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់វិវុទ្ធវាទ ឬ ប្រតិវេទនីដែលសមមូលគ្នាអាចត្រូវបានធ្វើឡើងនៅថ្ងៃធ្វើការទីមួយបន្ទាប់ពីរយៈពេលផុតកំណត់ ។

ក្រោយផុតរយៈពេលកំណត់សម្រាប់ធ្វើវិវុទ្ធវាទស្តីពីការមិនទូទាត់សងច្រាក់ អ្នកកាន់ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធលើមូលប្បទានប័ត្រនោះ ប៉ុន្តែអាចប្តឹងបហារ័កក្រោមបទប្បញ្ញត្តិដោយឡែកស្តីពីកិច្ចសន្យា ហើយសំណងដែលបានមកវិញ ត្រូវកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារ័កដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

មាត្រា ៤៥.-

អ្នកកាន់ ត្រូវជូនដំណឹងពីការមិនទូទាត់សងច្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងទៅបហារ័កនៅក្នុងរយៈពេលប្រាំបួន(០៩)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលវិវុទ្ធវាទ ឬ ប្រតិ-វេទនីដែលសមមូលគ្នាត្រូវបានធ្វើ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងច្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **មធ្យិមវិញ្ញាដោយគ្មានសោហ៊ុយ** ឬ **មធ្យិមវិញ្ញាដោយគ្មានវិវុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិ-លេខរបស់ខ្លួនអំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះនិងអាសយ-ដ្ឋានរបស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់បហារ័កបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ សេចក្តីជូនដំណឹងដូចគ្នានេះក៏ត្រូវបានផ្តល់ទៅរៀបិយបដិភោគីនៅក្នុងរយៈពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិទ្ធិលេខមិនបានបញ្ជាក់អំពីអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិទ្ធិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង អាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនមូលប្បទានប័ត្រត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹងត្រូវបង្ហាញភស្តុតាងថា ខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះ នឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានធ្វើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួនបើមាន ប៉ុន្តែចំនួនច្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនច្រាក់នៃមូលប្បទានប័ត្រឡើយ ។

មាត្រា ៤៦.–

តាមរយៈបដិញ្ញាថា **បទិ្ធលវិញ្ញាដោយគ្មានសោហ៊ុយ** ឬ **បទិ្ធលវិញ្ញាដោយគ្មានវិរុទ្ធភាព** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើមូលប្បទានប័ត្រ បហារ័ក អ្នកធ្វើបិទ្ធិលេខ ឬរូបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធភាពឬប្រតិវេទន៍ដែលសមមូលគ្នា ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះ មិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញមូលប្បទានប័ត្រនៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងបានឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ជាបន្ទុករបស់បុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់នោះ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហារ័ក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិទ្ធិលេខឬរូបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែ

អ្នកធ្វើបិទ្ធិលេខ ឬ រូបិយបងិភោគីនោះតែប៉ុណ្ណោះ ។ ទោះបីជាបងិឈ្លាសវសេរដោយ បហារ័កក្តី បើអ្នកកាន់ធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា អ្នកកាន់នេះត្រូវទទួលភ័ប់រងលើសោហុយទាំងអស់ដែលកើតមាន ។ កាលបើបងិឈ្លាកើតចេញអំពីអ្នកធ្វើបិទ្ធិលេខ ឬ រូបិយបងិភោគី សោហុយនៃវិរុទ្ធវាទ ឬ នៃប្រតិវេទន៍ ដែលសមមូលគ្នា បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើមូលប្បទានបំត្រ ។

មាត្រា ៥៧.-

រាល់បុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានបំត្រមានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះមុខអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្តឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានបំត្រជាឯកត្តជន ឬ រួមគ្នាដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើមូលប្ប-ទានបំត្រ ហើយបានទទួលយកមូលប្បទានបំត្ររក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្តឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្តឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្តឹងទីមួយនោះក៏ដោយ ។

មាត្រា ៥៨.-

អ្នកកាន់អាចទាមទារពីភាគីដែលខ្លួនបានអនុវត្តសិទ្ធិធ្វើឧបាស្រ័យនូវចំនួនប្រាក់ដែលមិនត្រូវបានទូទាត់សង ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ និងសោហុយទាំងឡាយដែលកើតមាន ។

មាត្រា ៥៩.-

ភាគីដែលទទួលនិងទូទាត់សងមូលប្បទានបំត្រ អាចទាមទារមកវិញពីភាគីទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សង ការប្រាក់លើ

ចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃដែលបានទូទាត់សងប្រាក់ និងសោហុយទាំងឡាយដែលកើតមាន ។

មាត្រា ៥០.-

ភាគីពាក់ព័ន្ធនីមួយៗដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ឱ្យប្រគល់មកខ្លួនវិញនូវមូលប្បទានប័ត្ររួមជាមួយវិរុទ្ធ-ភាព ឬ ប្រតិវេទន៍ដែលសមមូលគ្នា និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលនិងបានទូទាត់សងមូលប្បទានប័ត្រអាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយបាន ។

មាត្រា ៥១.-

កាលបើការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬវិរុទ្ធភាព ឬ ប្រតិវេទន៍ដែលសមមូលគ្នាក្នុងរយៈពេលកំណត់ត្រូវបានភាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវធ្វើប្រតិវេទន៍អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើមូលប្បទានប័ត្រ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ៤៥ នៃច្បាប់នេះ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញមូលប្បទានប័ត្រភ្លាមដើម្បីឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធភាព ឬ ធ្វើប្រតិវេទន៍ដែលសមមូលគ្នា ។

បើករណីប្រធានស័ក្តិនៅតែបន្តកើតមានលើសពីដប់ប្រាំ(១៥)ថ្ងៃ ក្រោយកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងអំពីករណីប្រធានស័ក្តិនោះទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ក្តី ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធភាព ឬ ប្រតិវេទន៍ដែលសមមូលគ្នាមិនចាំបាច់ធ្វើឡើយ ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញមូលប្បទានប័ត្រ ឬ ធ្វើវិរុទ្ធវាទ ឬ ធ្វើប្រតិវេទន៍ដែលសមមូលគ្នា មិនត្រូវបានចាត់ទុកជាករណីប្រជានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើមូលប្បទានប័ត្រដែលត្រូវបានចាត់បង់ ឬ បំផ្លាញ អាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តមូលប្បទានប័ត្រដែលសងការខូចខាតទៅភាគីពាក់ព័ន្ធចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើមូលប្បទានប័ត្រតាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលមូលប្បទានប័ត្រមកដោយសុចរិត ។

ផ្នែកទី ៧
បេឡានិចំយមូលប្បទានប័ត្រ

មាត្រា ៥២.-

បេឡានិចំយមូលប្បទានប័ត្រ ត្រូវបានប្រព្រឹត្តទៅដូចខាងក្រោមនេះ :

១-កាលបើមូលប្បទានប័ត្រ ត្រូវបានប្រគល់ឱ្យធនាគារដើម្បីចុះឥណទានគណនីអតិថិជនតាមចំនួនប្រាក់នៃមូលប្បទានប័ត្រ ធនាគារទទួលបានសិទ្ធិនិងអំណាចទាំងអស់របស់អ្នកកាន់មូលប្បទានប័ត្រ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការចុះឥណទានគណនីនេះមានលក្ខណៈបណ្តោះអាសន្ន ហើយធនាគារអាចចុះឥណពន្ធគណនី ឬ ម៉្យាងទៀតអាចធ្វើឧបាស្រ័យទាមទារពីអតិថិជនវិញបាន បើមូលប្បទានប័ត្រមិនត្រូវបានទូទាត់សងប្រាក់ទេនោះ ។ លើកលែងតែបានព្រមព្រៀងផ្សេងពីនេះ ការដកប្រាក់ចេញពីគណនីឥណទានបណ្តោះអាសន្នអាចធ្វើបាន លុះណាតែមានការសម្រេចរបស់ធនាគារតែប៉ុណ្ណោះ និងជាកម្មវត្ថុនៃការសងវិញ ឬ ការធ្វើឧបាស្រ័យពីអតិថិជន បើមូលប្បទានប័ត្រមិនត្រូវបានទូទាត់សងប្រាក់ទេ ។

៣-ដោយមិនគិតដល់ការខ្វះខាត ការខុសឆ្គង ការរឹតត្បិតឬការកម្រិត ឬ ទម្រង់ ឬ ប្រភេទនៃបិដ្ឋិលេខរបស់អតិថិជន សិទ្ធិរបស់ធនាគារក្រោមកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាម្ចាស់នៃមូលប្បទានប័ត្រដែលអាចធ្វើបិដ្ឋិលេខបានអនុលោមតាមមាត្រា ២២ ទោះបីមានមាត្រា ២៦ នៃច្បាប់នេះ ដែលអនុវត្តផ្សេងពីនេះក៏ដោយ ។

មាត្រា ៥៣.-

នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានបង្ហាញឱ្យធនាគារថ្វើបេឡានិច័យ មូល-ប្បទានប័ត្រនោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្តីពីប្រតិបត្តិការទូទាត់សងច្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីមូលប្បទានប័ត្ររវាងបទ-ប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាចាន ការ ។

ផ្នែកទី ៨
ការកែលើមូលប្បទានប័ត្រ

មាត្រា ៥៤.-

ក្នុងករណីមានការកែលើខ្លឹមសារនៃមូលប្បទានប័ត្រ រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែនោះ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃមូលប្បទានប័ត្រ ។

ផ្នែកទី ៩
រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

មាត្រា ៥៥.-

រាល់ការធ្វើឧបាស្រ័យ ដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហាវ័ក និងភាគីពាក់ព័ន្ធផ្ទៃាទៀត មានរយៈពេលប្រាំមួយ(០៦)ខែ បន្ទាប់ពីការផុតកំណត់រយៈពេលបង្ហាញឱ្យទូទាត់សងច្រាក់ ។

រាល់ការធ្វើឧបាស្រ័យដោយភាគីពាក់ព័ន្ធផ្ទៃាទៀតអំពីការទូទាត់សងមូលប្ប-ទានប័ត្រទល់នឹងភាគីជាប់ពាក់ព័ន្ធផងគ្នា មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលភាគីពាក់ព័ន្ធបានទូទាត់សងមូលប្បទានប័ត្រ ឬ បានទទួលរងការប្តឹង ។

មាត្រា ៥៦.-

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

ផ្នែកទី ១០
ការគណនារយៈពេលកំណត់

មាត្រា ៥៧.-

ការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធភាទអាចប្រព្រឹត្តទៅបាននៅក្នុងថ្ងៃធ្វើការតែប៉ុណ្ណោះ ។

កាលបើថ្ងៃចុងក្រោយនៃរយៈពេលដែលបានកំណត់ ដើម្បីអនុវត្តសកម្មភាពណាមួយទាក់ទងទៅនឹងមូលប្បទានប័ត្រ ជាពិសេសចំពោះការបង្ហាញឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធភាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាត្រូវចំថ្ងៃឈប់សម្រាកជាផ្លូវការ រយៈពេលកំណត់នេះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ពីផុតរយៈពេលកំណត់ ។ ថ្ងៃឈប់សម្រាកក៏ត្រូវបានរាប់បញ្ចូលទៅក្នុងការគណនារយៈពេលកំណត់ទាំងនោះផងដែរ ។

មាត្រា ៥៨.-

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលផងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

មាត្រា ៥៩.-

ទោះបីតាមផ្លូវច្បាប់ក្តី ឬ តាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

ជំពូកទី ៣

រូបិយាណត្តិ

ផ្នែកទី ១

ការចេញផ្សាយនិងទម្រង់នៃរូបិយាណត្តិ

មាត្រា ៦០.-

រូបិយាណត្តិជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតលក្ខខ័ណ្ឌ ចេញដោយបុគ្គលមួយឱ្យទៅបុគ្គលដទៃ ចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យបុគ្គលជាអ្នកទទួលបញ្ជាទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ រូបិយាណត្តិត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងក្នុងជំពូកនេះ ។

មាត្រា ៦១.-

រូបិយាណត្តិជាឧបករណ៍ឥណទាន ។ រូបិយាណត្តិអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ អក្សរបរទេស ហើយត្រូវតែមានឱទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **រូបិយាណត្តិ** ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតលក្ខខ័ណ្ឌឱ្យទូទាត់សងនូវចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិកដែលជាបុគ្គលត្រូវទូទាត់សងប្រាក់

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន

-កាលបរិច្ឆេទ និងកន្លែង ដែលរូបិយាណត្តិត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់បហារិកដែលជាបុគ្គលចេញបញ្ជាលើរូបិយាណត្តិ ។

មាត្រា ៦២.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយឬច្រើនមានចែងនៅក្នុងមាត្រា ៦១ នៃច្បាប់នេះ ពុំមានសុពលភាពជារូបិយាណត្តិឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌមួយខាងក្រោម :

១-រូបិយាណត្តិ ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិកត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់បហារិកផងដែរ ។

៣-រូបិយាណត្តិ ដែលមិនបានបញ្ជាក់ច្បាស់នូវកន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថាចេញ នៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារក ។

៤-រូបិយាណត្តិ អាចត្រូវចេញឱ្យទូទាត់សងប្រាក់ទៅអ្នកកាន់បាន ។ រូបិយាណត្តិដែលគ្មានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន ត្រូវបានចាត់ទុកថាជារូបិយាណត្តិទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

មាត្រា ៦៣.-

រូបិយាណត្តិ អាចត្រូវបានចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារក ។ រូបិយាណត្តិ អាចត្រូវបានចេញទៅលើបហារកខ្លួនឯងផ្ទាល់ ឬ ជាប្រយោជន៍ដល់តតិយបុគ្គល ។

មាត្រា ៦៤.-

រូបិយាណត្តិ អាចត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់បហារិត ឬ នៅកន្លែងផ្សេងទៀត ។

មាត្រា ៦៥.-

ចំពោះប្រភេទរូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ បហារកអាចចែងលក្ខ-

ខ័ណ្ឌថាចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃរូបិយាណត្តិផ្សេងពីខាងលើ បដិញ្ញានេះមិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ ត្រូវតែបានបញ្ជាក់នៅលើរូបិយាណត្តិ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញផ្សាយរូបិយាណត្តិ លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

មាត្រា ៦៦.-

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរ ជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នាចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

មាត្រា ៦៧.-

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើរូបិយាណត្តិនៅតែមានតម្លៃដដែល ទោះបីរូបិយាណត្តិនោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬ បានចុះហត្ថ-លេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ៦៨.-

បុគ្គលណា ដែលបានចុះហត្ថលេខានៅលើរូបិយាណត្តិក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើរូបិយាណត្តិនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលភ៉ាប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជនដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ៦៩.-

បហារ័កចានាលើស្វ័ការនិងការទូទាត់សងប្រាក់ ។

បហារ័កអាចរួចផុតពីការទទួលខុសត្រូវលើស្វ័ការ ប៉ុន្តែមិនអាចរួចផុតពីការទទួលខុសត្រូវលើការទូទាត់សងប្រាក់ឡើយ ។

មាត្រា ៧០.-

បើរូបិយាណត្តិ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផែងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលរូបិយាណត្តិមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

ផ្នែកទី ២
បិដ្ឋិលេខរូបិយាណត្តិ

មាត្រា ៧១.-

រូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា **សងតាមបញ្ជា** អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលបហារ័កបានបញ្ចូលក្នុងរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នា រូបិយាណត្តិនោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

រូបិយាណត្តិអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបហារិតក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃរូបិយាណត្តិនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខរូបិយាណត្តិនោះបន្តទៀតបាន ។

មាត្រា ៧២.-

បិដ្ឋិលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខរូបិយាណត្តិ មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនច្រាក់ក្នុងរូបិយាណត្តិ ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យអ្នកកាន់ មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

មាត្រា ៧៣.-

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងរូបិយាណត្តិ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុប័ត្រ** ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខអាចមិនបញ្ជាក់ពីអត្តគាហក ឬអាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិ-លេខប៉ុណ្ណោះ ហៅថា **បិដ្ឋិលេខចំហ** ។

មាត្រា ៧៤.-

បិដ្ឋិលេខផ្ទេរសិទ្ធិទាំងអស់នៃរូបិយាណត្តិឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តរូបិយាណត្តិជាចំហ ឬ ឱ្យ បុគ្គលដទៃទៀត

-ផ្ទេររូបិយាណត្តិឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

មាត្រា ៧៥.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខ អាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀតបាន ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលរូបិយាណត្តិត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើរូបិយាណត្តិចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែរូបិយាណត្តិនោះមិនអាចប្រែក្លាយទៅជារូបិយាណត្តិ **សខតាមបញ្ជា** បានឡើយ ។

មាត្រា ៧៦.-

ម្ចាស់រូបិយាណត្តិដែលអាចធ្វើបិដ្ឋិលេខបានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់រូបិយាណត្តិតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលរូបិយាណត្តិតាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយ បានចាត់បង់សិទ្ធិកាន់កាប់រូបិយាណត្តិដោយមូលហេតុណាក៏ដោយ ទោះបីជារូបិយាណត្តិចេញផ្សាយឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ល្អចមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានរូបិយាណត្តិមកជាកម្មសិទ្ធិ មិនត្រូវបានបង្ខំឱ្យបោះបង់ចោលរូបិយាណត្តិឡើយ លើកលែងតែរូបិយាណត្តិនោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

មាត្រា ៧៧.-

បុគ្គលទាំងឡាយដែលប្តឹងអំពីរូបិយាណត្តិ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបហារ័ក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់ក្ងនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះរូបិយាណត្តិដែលចេញផ្សាយ ដើម្បីទូទាត់សងច្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសងតាមបញ្ជា** ឬ ប្រយោគណាមួយ ដែលមានន័យដូចគ្នាបានឡើយ ។

មាត្រា ៧៨.-

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ទារបំណុល** ឬ **សម្រាប់បេឡានិច័យ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តបានក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់បាន ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខបានផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីស្សានុកូលឡើយ ។

នៅពេលដែលរូបិយាណត្តិត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ រូបិយាណត្តិនោះជាបញ្ហាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្តីពីប្រតិបត្តិការទូទាត់សងច្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីរូបិយាណត្តិរវាងបទប្បញ្ញត្តិនៃជំពូកនេះនិងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាចានការ ។

មាត្រា ៧៩.-

កាលបើបិដ្ឋិលេខមួយមានសេចក្តីបញ្ជាក់ថា **តម្លៃសម្រាប់ធានា** ឬ **តម្លៃសម្រាប់ជាកំបញ្ចាំ** ឬ សេចក្តីបញ្ជាក់ណាផ្សេងទៀត ដែលមានន័យថាសម្រាប់ជាកំបញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្តាភាគីដែលពាក់ព័ន្ធមិនអាចប្តឹងអ្នកកាន់ ដោយសំអាងលើទំនាក់ទំនងផ្ទាល់ជាមួយអ្នកធ្វើបិដ្ឋិលេខបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់ក្រុមបំណុល ។

មាត្រា ៨០.-

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីវិនិច្ឆ័យ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសម-មូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងច្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់នេះឡើយ ។

បើគ្មានកស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបានធ្វើនៅលើរូបិយាណត្តិមុនពេលធ្វើវិនិច្ឆ័យឬប្រតិវេទន៍ដែលសមមូលគ្នា ឬ មុនផុតរយៈពេលកំណត់ដែលបានយោងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។

ផ្នែកទី ៣
ស្វ័ការរូបិយាណត្តិ

មាត្រា ៨១.-

រហូតដល់ពេលឥណប្រតិទាន អ្នកកាន់ ឬ បុគ្គលដែលមានរូបិយាណត្តិ អាចបង្ហាញរូបិយាណត្តិបាននៅលំនៅរបស់បហារិតដើម្បីឱ្យធ្វើស្វ័ការ ។

មាត្រា ៨២.-

ចំពោះប្រភេទរូបិយាណត្តិណាក៏ដោយ បហារ័កអាចចែងលក្ខខ័ណ្ឌថា រូបិយា-ណត្តិនោះ ត្រូវបានបង្ហាញឱ្យធ្វើស្វ័ការដោយមាន ឬ ដោយគ្មានកំណត់ពេល ។

បហារ័កអាចហាមឃាត់ការបង្ហាញឱ្យធ្វើស្វ័ការបាន លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវទូទាត់សងច្រាក់ នៅអាសយដ្ឋានរបស់តតិយភាគី ឬ នៅកន្លែងផ្សេងទៀត ក្រៅពីលំនៅរបស់បហារិត ឬ លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវបានចេញឱ្យទូទាត់សងច្រាក់នៅពេលកំណត់មួយក្រោយការបង្ហាញ ។

បហារ័កក៏អាចចែងលក្ខខ័ណ្ឌថា ការបង្ហាញឱ្យធ្វើស្វ័ការនេះមិនប្រព្រឹត្តទៅនៅមុនកាលបរិច្ឆេទដែលបានកំណត់នោះឡើយ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗអាចចែងលក្ខខ័ណ្ឌថា រូបិយាណត្តិត្រូវបានបង្ហាញឱ្យធ្វើស្វ័ការដោយមាន ឬ ដោយគ្មានរយៈពេលកំណត់ លើកលែងតែបហារ័កបានហាមឃាត់ការធ្វើស្វ័ការនោះរួចហើយ ។

មាត្រា ៨៣.-

រូបិយាណត្តិទាំងឡាយដែលត្រូវទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើស្វ័ការនៅក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។

បហារ័កអាចបង្រួញ ឬ ពន្យាររយៈពេលកំណត់នេះ ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខទាំងឡាយផងដែរ ។

មាត្រា ៨៤.-

បហារិតអាចស្នើសុំឱ្យធ្វើការបង្ហាញរូបិយាណត្តិបានជាលើកទីពីរនៅថ្ងៃបន្ទាប់ពីការបង្ហាញលើកទីមួយ ។ ភាគីទាំងឡាយដែលពាក់ព័ន្ធមិនអាចតវ៉ាថា ការស្នើសុំនេះមិនត្រូវអនុវត្តតាមនោះបានឡើយ លើកលែងតែការស្នើសុំនេះត្រូវបានចែងនៅក្នុងវិបុច្ឆាទ ។

អ្នកកាន់មិនត្រូវប្រគល់ឱ្យទៅបហារិតនូវរូបិយាណត្តិដែលបង្ហាញឱ្យធ្វើស្វ័ការឡើយ ។

មាត្រា ៨៥.-

ស្វ័ការត្រូវបានសរសេរនៅលើរូបិយាណត្តិដោយប្រើពាក្យថា **ចាននេះធ្វើស្វ័ការ** ឬពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយបហារិត ។ ហត្ថលេខាសាមញ្ញរបស់បហារិតនៅខាងមុខនៃរូបិយាណត្តិបង្កើតបានជាស្វ័ការ ។

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងច្រាក់ក្នុងរយៈពេលណាមួយក្រោយការបង្ហាញ ឬ ត្រូវតែបានបង្ហាញឱ្យធ្វើស្វ័ការនៅក្នុងរយៈពេលកំណត់ណាមួយដោយអនុលោមតាមបដិញ្ញាពិសេស ស្វ័ការនោះត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃបង្ហាញឱ្យទូទាត់សងច្រាក់ ។ បើស្វ័ការនោះគ្មាន

ចុះកាលបរិច្ឆេទទេ អ្នកកាន់ ដើម្បីរក្សាសិទ្ធិឧបាស្រ័យទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងទល់នឹងបហារ័កត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្ញេចភ្ញាំងនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

មាត្រា ៨៦.-

ស្វ័ការពុំមានលំក្ខខ័ណ្ឌទេ ប៉ុន្តែបហាវិតអាចទាមទារការធ្វើស្វ័ការទៅលើតែមួយផ្នែកនៃចំនួនប្រាក់ដែលត្រូវទូទាត់សង ។

រាល់ការកែប្រែផ្សេងទៀត ដែលអ្នកធ្វើស្វ័ការបានធ្វើលើខ្ឹមសារនៃរូបិយាណត្តិ គឺជាការបដិសេធមិនធ្វើស្វ័ការ ។ ប៉ុន្តែអ្នកធ្វើស្វ័ការត្រូវទទួលខុសត្រូវស្របតាមខ្ឹមសារនៃស្វ័ការដែលខ្លួនបានកែប្រែ ។

មាត្រា ៨៧.-

កាលបើបហារ័កនៃរូបិយាណត្តិបានបញ្ជាក់កន្លែងទូទាត់សងប្រាក់ក្រៅពីលំនៅរបស់បហាវិត ដោយគ្មានបញ្ជាក់ពីអាសយដ្ឋានរបស់តតិយភាគីដែលជាកន្លែងត្រូវទូទាត់សងប្រាក់ បហាវិតអាចបញ្ជាក់ឈ្មោះតតិយភាគីនេះនៅក្នុងពេលធ្វើស្វ័ការតែម្តង ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ អ្នកធ្វើស្វ័ការត្រូវបានចាត់ទុកថាបានយល់ព្រមទូទាត់សងរូបិយាណត្តិនោះដោយខ្លួនឯងនៅកន្លែងទូទាត់សងប្រាក់ ។

បើរូបិយាណត្តិត្រូវបានទូទាត់សងនៅលំនៅរបស់បហាវិត អាសយដ្ឋានដែលជាកន្លែងជាមួយគ្នានឹងកន្លែងដែលធ្វើការទូទាត់សងប្រាក់ ត្រូវបានបញ្ជាក់នៅពេលបហាវិតធ្វើស្វ័ការ ។

មាត្រា ៨៨.-

រូបិយាណត្តិមិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិក្នុងដៃរបស់បហាវិតដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហាវិតនៃរូបិយាណត្តិដែលមិនព្រមធ្វើស្វ័ការមិនទទួលខុសត្រូវលើរូបិយាណត្តិឡើយ ។

តាមរយៈស្វ័ការ បហាវិតទទួលទូទាត់សងរូបិយាណត្តិនៅពេលដល់ឥណប្រតិទាន ។

បើពុំមានការទូទាត់សងច្រាក់ទេ អ្នកកាន់ ទោះបីខ្លួនជាបហាវ័កក្តី មានសិទ្ធិធ្វើឧបាស្រ័យផ្ទាល់អំពីរូបិយាណត្តិទល់នឹងអ្នកធ្វើស្វ័ការ ចំពោះអ្វីៗដែលអាចត្រូវបានទាមទារអនុលោមតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃច្បាប់នេះ ។

មាត្រា ៨៩.-

កាលបើបហាវិតដែលបានធ្វើស្វ័ការនៅលើរូបិយាណត្តិបានលុបស្វ័ការនោះនៅមុនពេលមានបដិទានរូបិយាណត្តិមកវិញ ស្វ័ការនេះត្រូវបានចាត់ទុកថាបានបដិ-សេធចោល ។ ក្នុងករណីដែលគ្មានកស្តុតាងផ្ទុយពីនេះ ការលុបចោលត្រូវបានចាត់ទុកថាធ្វើឡើងនៅមុនពេលរូបិយាណត្តិត្រូវបានធ្វើបដិទាន ។

បើបហាវិតបានជូនដំណឹងពីស្វ័ការរបស់ខ្លួនជាលាយលក្ខណ៍អក្សរឱ្យទៅអ្នកកាន់ ឬ ឱ្យទៅភាគីណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ទោះបីយ៉ាងណាក៏ដោយ ក៏បហាវិតត្រូវទទួលខុសត្រូវចំពោះភាគីទាំងនេះ ស្របតាមខ្លឹមសារនៃស្វ័ការរបស់ខ្លួន ។

ផ្នែកទី ៤
រូបិយបដិភោគរូបិយាណត្តិ

មាត្រា ៩០.-

ការទូទាត់សងរូបិយាណត្តិ អាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនច្រាក់ទាំងអស់ ឬ មួយផ្នែកនៃរូបិយាណត្តិ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។

មាត្រា ៩១.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើង នៅលើរូបិយាណត្តិផ្ទាល់ ឬ នៅលើអនុ-ប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថា **រូបិយបដិភោគី** ។

រាល់ហត្ថលេខា ដែលបានចុះនៅខាងមុខរូបិយាណត្តិក្រៅពីហត្ថលេខារបស់បហារិក ឬ របស់បហារ័ក ត្រូវបានចាត់ទុកថាជាហត្ថលេខាធ្វើរូបិយបដិភោគ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវបុគ្គលណាមួយដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថា ធ្វើឱ្យបហារ័ក ។

មាត្រា ៩២.-

រូបិយបដិភោគីមានកាតព្វកិច្ចជូនបុគ្គល ដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងរូបិយាណត្តិ រូបិយបដិភោគីមានសិទ្ធិទាំងឡាយនៃរូបិយាណត្តិនោះទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះនៅលើរូបិយាណត្តិ ។

ផ្នែកទី ៥
ឥណទានរូបិយាណត្តិ

មាត្រា ៩៣.-

រូបិយាណត្តិអាចត្រូវបានចេញដើម្បី :

-ទូទាត់សងច្រាក់នៅពេលបង្ហាញ

-ទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ

-ទូទាត់សងច្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

រូបិយាណត្តិអាចត្រូវបានចេញឱ្យទូទាត់សងច្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមានល័ក្ខខ័ណ្ឌថាក្នុងករណីខកខានទូទាត់សងច្រាក់នៅដំណាក់កាលណាមួយ ចំនួនច្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

រូបិយាណត្តិទាំងឡាយដែលមានឥណប្រតិទានផ្សេងពីនេះ ត្រូវបានចាត់ទុកជាមោយៈ ។

មាត្រា ៩៤.-

រូបិយាណត្តិទូទាត់សងច្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងច្រាក់នៅពេលបង្ហាញ ។ រូបិយាណត្តិនេះត្រូវតែបានបង្ហាញនៅពេលណាមួយ ក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។ បហារ័កអាចបង្រួញ ឬ ពន្យារយៈពេលនេះ ។ រយៈពេលកំណត់នេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខជងដែរ ។

បហារ័កអាចបញ្ជាក់ថា រូបិយាណត្តិទូទាត់សងច្រាក់នៅពេលបង្ហាញមិនត្រូវបានបង្ហាញឱ្យទូទាត់សងច្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញ ត្រូវចាប់ផ្តើមពីថ្ងៃកំណត់នោះ ។

មាត្រា ៩៥.-

ឥណប្រតិទាននៃរូបិយាណត្តិទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើស្វីការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធ-វាទ ។

បើគ្មានវិរុទ្ធវាទទេ ស្វីការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកធ្វើស្វីការ ត្រូវបានចាត់ទុកថា បានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើស្វីការ ។

មាត្រា ៩៦.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងច្រាក់ក្នុងរយៈពេលមួយខែ ឬច្រើនខែ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬក្រោយការបង្ហាញរូបិយាណត្តិ

មានឥណប្រតិទានទៅកាលបរិច្ឆេទ ដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ រូបិយាណត្តិមានឥណប្រតិទានទៅថ្ងៃចុងក្រោយនៃខែនោះ ។

កាលបើរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញរយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្តាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា **ប្រាំបីថ្ងៃ** ឬ**ដប់ប្រាំថ្ងៃ** មិនមានន័យថា មួយសប្តាហ៍ ឬ ពីរសប្តាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថា **កន្លះខែ** មានន័យថាដប់ប្រាំថ្ងៃ ។

មាត្រា ៩៧.-

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

កាលបើរូបិយាណត្តិចេញរវាងកន្លែងពីរ ដែលមានប្រតិទិនខុសគ្នាត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ថ្ងៃចេញផ្សាយត្រូវបានគិតតាមថ្ងៃដែលត្រូវគ្នានឹងប្រតិទិននៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយឥណប្រតិទានក៏ត្រូវកំណត់ស្របទៅតាមនោះដែរ ។ រយៈពេលសម្រាប់បង្ហាញរូបិយាណត្តិត្រូវបានគណនាទៅតាមវិធាននេះ ។

វិធានទាំងនេះមិនត្រូវបានអនុវត្តទេ បើមានបដិញ្ញា ឬ ខ្ចីមសារចែងអំពីវិធានផ្សេងពីនេះ ។

ផ្នែកទី ៦

ការទូទាត់សងប្រាក់

មាត្រា ៩៨.-

អ្នកកាន់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២)ថ្ងៃ ធ្វើការបន្ទាប់ ។

ការបង្ហាញរូបិយាណត្តិតាមរយៈសភាជាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

មាត្រា ៩៩.-

បហារិតដែលទូទាត់សងរូបិយាណត្តិ អាចតម្រូវឱ្យប្រគល់រូបិយាណត្តិនោះឱ្យខ្លួនក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់រូបិយាណត្តិ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បហារិតអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើរូបិយាណត្តិ និងទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ១០០.-

នៅពេលដែលរូបិយាណត្តិមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ៩៨ នៃច្បាប់នេះ ភូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

មាត្រា ១០១.-

អ្នកកាន់រូបិយាណត្តិ មិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់នៅមុនពេលដល់ឥណប្រតិទានឡើយ ។

បហារិតដែលទូទាត់សងប្រាក់មុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិ-ភ័យ ដោយខ្លួនឯងផ្ទាល់ ។

បហារិតដែលទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ បហារិត ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលិខាប់បិទ្ធ-លេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិទ្ធិលេខឡើយ ។

មាត្រា ១០២.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញជារូបិយប័ណ្ណដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើរូបិយាណត្តិនោះធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារិកអាចចែងលុះក្នុងខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើរូបិយាណត្តិ ។

វិធានទាំងឡាយខាងលើនេះមិនត្រូវបានអនុវត្តចំពោះរូបិយាណត្តិ :

-ដែលចេញជារូបិយប័ណ្ណដែលមានការទទួលយក នៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ បហារិកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ រូបិយាណត្តិនឹងត្រូវទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃរូបិយាណត្តិ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែលមានឈ្មោះដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និងប្រទេសចេញផ្សាយ ឬប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុង

រូបិយាណត្តិត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងច្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងច្រាក់ មិនមាននាមចារឹកដូចគ្នា ការទូទាត់សងច្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើច្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងច្រាក់ ។

នៅពេលដែលរូបិយាណត្តិត្រូវបានទូទាត់សងនៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវចុះឥណពន្ធតាមចំនួនច្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

ផ្នែកទី ៧
ឧបាស្រ័យចំពោះការមិនធ្វើស្វ័ការឬការមិនទូទាត់សងច្រាក់

មាត្រា ១០៣.-

អ្នកកាន់រូបិយាណត្តិ អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារ័ក និងភាគីពាក់ព័ន្ធដទៃៗទៀត :

១-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងច្រាក់មិនត្រូវបានធ្វើ ឬ

២-ទោះបីនៅមុនពេលដល់ឥណប្រតិទានក្តី :

-បើមានករណីមិនព្រមធ្វើស្វ័ការចំពោះចំនួនច្រាក់ទាំងស្រុង ឬមួយផ្នែកនៃរូបិយាណត្តិ

-ក្នុងករណីធនក្ស័យរបស់បហារិត ទោះបីជាមាន ឬគ្មានធ្វើស្វ័ការក្តី ឬក្នុងករណីបញ្ឈប់បហារិតមិនឱ្យទូទាត់សងច្រាក់ដោយគ្មានសេចក្តីសម្រេចពីតុលាការ ឬនៅពេលណាដែលការអនុវត្តរឹបអូសទ្រព្យសម្បត្តិរបស់បហារិតពុំបានសម្រេច

-ក្នុងករណីធនក្ស័យរបស់បហារ័កនៃរូបិយាណត្តិ ដែលមិនធ្វើស្វ័ការ ។

មាត្រា ១០៤.-

វិរុទ្ធវាទអាចត្រូវបានធ្វើឡើងក្រោមលក្ខខ័ណ្ឌដូចតទៅ :

១-ការខកខានមិនបានធ្វើស្វ័ការ ឬ មិនបានទូទាត់សងច្រាក់ត្រូវតែបានបង្ហាញភស្តុតាងដោយវិរុទ្ធវាទតាមច្បាប់ ។

២-វិវុទ្ធវាទចំពោះការមិនធ្វើស្វ័ការ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់បង្គាញឱ្យធ្វើស្វ័ការ ។ ដូចមានចែងនៅក្នុងមាត្រា ៨៤ នៃច្បាប់នេះ បើការបង្គាញលើកទីមួយ ត្រូវបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់នោះ វិវុទ្ធវាទអាចធ្វើឡើងនៅថ្ងៃបន្ទាប់ ។

៣-វិវុទ្ធវាទចំពោះការមិនទូទាត់សងរូបិយាណត្តិ ដែលត្រូវទូទាត់សងច្រាក់ នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្គាញត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលរូបិយាណត្តិនោះត្រូវទូទាត់សងច្រាក់ ។ នៅក្នុងករណីនៃរូបិយាណត្តិ ដែលត្រូវទូទាត់សងច្រាក់នៅពេលបង្គាញវិវុទ្ធវាទត្រូវតែបានធ្វើក្រោមល័ក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើស្តីពីវិវុទ្ធវាទចំពោះការមិនធ្វើស្វ័ការ ។

៤-វិវុទ្ធវាទចំពោះការមិនធ្វើស្វ័ការ អាចធ្វើបានដោយមិនចាច់បង្គាញរូបិយាណត្តិឱ្យទូទាត់សងច្រាក់ និងបង្គាញវិវុទ្ធវាទចំពោះការមិនទូទាត់សងច្រាក់ ។

៥-បើបហារិតត្រូវបានបញ្ឈប់មិនឱ្យទូទាត់សងច្រាក់ ទោះបីមាន ឬ គ្មានស្វ័ការក្តី ឬ បើការអនុវត្តរឹបអូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧចាស្រ័យបាន តែនៅក្រោយការបង្គាញរូបិយាណត្តិឱ្យទៅបហារិតធ្វើការទូទាត់សងច្រាក់ និងនៅក្រោយពេលដែលវិវុទ្ធវាទត្រូវបានធ្វើ ។

៦-បើបហារិតត្រូវបានប្រកាសថាធនក្សីយ ទោះបីបាន ឬ មិនបានធ្វើស្វ័-ការក្តី ឬ បើបហារ័កនៃរូបិយាណត្តិ ដែលមិនធ្វើស្វ័ការត្រូវបានប្រកាសថាធនក្សីយការបង្គាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្សីយនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧចាស្រ័យបាន ។

៧-វិវុទ្ធវាទត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រី ដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិវុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃរូបិយាណត្តិភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិវុទ្ធវាទនោះ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិវុទ្ធវាទ

សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរក
មិនឃើញបហារិត ឬ អ្នកធ្វើស្ងីការ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិ-
សេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស្ងីការ ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណា-
ចក្រកម្ពុជាដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ
និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស្ងីការ ។

៨-វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ
និងមានចុះហត្ថលេខារបស់បហារិតបញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបាន
កំណត់នៅក្នុងកថាខណ្ឌទី ៧ នៃមាត្រានេះ ។

មាត្រា ១០៥.-

អ្នកកាន់ត្រូវជូនដំណឹងពីការមិនធ្វើស្ងីការ ឬ មិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋ-
លេខរបស់ខ្លួន បហារិក និងរូបិយបដិភោគីណាមួយនៃអ្នកធ្វើស្ងីការនៅក្នុងរយៈពេល
ប្លន(០៤)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណី
ដែលមានបដិញ្ញាថា **បទ្ធិលទិញដោយគ្មានសោហ៊ុយ** ឬ **បទ្ធិលទិញដោយគ្មានទិរុទ្ធវាទ**
ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ(០២)ថ្ងៃធ្វើការ
បន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋលេខនីមួយៗត្រូវជូនដំណឹងដល់
អ្នកធ្វើបិដ្ឋលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួល ដោយបញ្ជាក់ពីឈ្មោះ
និងអាសយដ្ឋានរបស់អ្នកធ្វើបិដ្ឋលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់
លំដោយរហូតដល់បហារិកបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវ
គិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូន
ដំណឹង ត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើរូបិយាណត្តិ សេចក្តីជូនដំ-
ណឹងដូចគ្នានេះ ក៏ត្រូវបានផ្តល់ទៅរូបិយបដិភោគីនៅក្នុងពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋលេខ មិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បាន
បញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋលេខមុនបន្ទាប់
គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹងអាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនរូបិយាណត្តិត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួន បើមាន ប៉ុន្តែចំនួនច្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនច្រាក់នៃរូបិយាណត្តិឡើយ ។

មាត្រា ១០៦.-

តាមរយៈបដិញ្ញាថា **បទ្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បទ្វិលទិញដោយគ្មានទិរុទ្ធភាព** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរ និងមានចុះហត្ថលេខានៅលើរូបិយាណត្តិ បហាវ័ក អ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគី អាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធភាព ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញរូបិយាណត្តិ នៅក្នុងរយៈពេលកំណត់ ឬពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ជាបន្ទុករបស់បុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហាវ័ក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែអ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីប៉ុណ្ណោះ ។ ទោះបីបដិញ្ញាសរសេរដោយបហាវ័កក៏ដោយ បើអ្នកកាន់ធ្វើវិរុទ្ធភាព អ្នកកាន់នេះត្រូវទទួលភ័ប់រងលើសោហ៊ុយទាំងអស់ដែលកើតមាន ។ កាលបើបដិញ្ញាកើតចេញអំពីអ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគី សោហ៊ុយនៃ

វិរុទ្ធវាទ បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើរូបិ-
យាណត្តិ ។

មាត្រា ១០៧.-

ភាល់បហាវ័ក អ្នកធ្វើស្វីការ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលជានាដោយការធ្វើរូបិ-
យបដិភោគនៃរូបិយាណត្តិ មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្តឹងទល់នឹងបុគ្គលជាប់ពាក់ព័ន្ធទៅនឹងរូបិយាណត្តិជាឯកត្តជន
ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះ ចូលមកជាប់ពាក់
ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះ ត្រូវមានចំពោះបុគ្គលណាដែលបានចុះហត្ថលេខាលើរូបិយា-
ណត្តិ ហើយបានទទួលយករូបិយាណត្តិរក្សាទុក និងបានទូទាត់សងប្រាក់ ។

ភាល់ការប្តឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនភាំងការប្តឹងទល់
នឹងបុគ្គលផ្សេងទៀតឡើយ ទោះបីបុគ្គលផ្សេងទាំងនេះទាក់ទិនបន្តបន្ទាប់ ពីបុគ្គលដែល
បានទទួលរងការប្តឹងទីមួយនោះក៏ដោយ ។

មាត្រា ១០៨.-

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្ជិនអនុវត្តសិទ្ធិឧបាស្រ័យនូវចំនួនប្រាក់នៃ
រូបិយាណត្តិដែលមិនបានធ្វើស្វីការ ឬ មិនបានទូទាត់សងដោយមានការប្រាក់ បើការ
ប្រាក់នោះមានចែងលើរូបិយាណត្តិ ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយ
ធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហ៊ុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃ
រូបិយាណត្តិត្រូវជាកម្មវត្ថុនៃការធ្វើអប្បហារ ។ អប្បហារនេះត្រូវបានគណនាទៅតាម
អត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបាស្រ័យ នៅកន្លែងស្នាក់នៅរបស់
អ្នកកាន់ ។

មាត្រា ១០៩.-

ភាគីដែលបានទទួលយក និងទូទាត់សងរូបិយាណត្តិ អាចទាមទារមកវិញពីភាគី
ទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សងការប្រាក់

លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហុយទាំងឡាយដែលកើតមាន ។

មាត្រា ១១០.-

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តឹងទាមទារឱ្យប្រគល់មកខ្លួន នូវរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធភាព និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយក និងបានទូទាត់សងរូបិយាណត្តិ អាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយ ។

មាត្រា ១១១.-

នៅក្នុងករណីដែលការអនុវត្តសិទ្ធិធ្វើឧបាស្រ័យ បន្ទាប់ពីការធ្វើស្ទីការតែលើមួយផ្នែកនៃចំនួនប្រាក់ ភាគីដែលទូទាត់សងចំនួនប្រាក់លើរូបិយាណត្តិដែលមិនត្រូវបានធ្វើស្ទីការនោះ អាចទាមទារឱ្យបញ្ចាក់ការទូទាត់សងប្រាក់មួយផ្នែកនេះនៅលើរូបិយាណត្តិ និងទាមទារយកបង្កាន់ដៃក្នុងការទូទាត់សងប្រាក់នេះផង ។ អ្នកកាន់ក៏ត្រូវតែប្រគល់ឱ្យអ្នកទូទាត់សងប្រាក់នេះ នូវច្បាប់ចម្លងមានវិញ្ញាបនកម្មនៃរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធភាព ដើម្បីអាចអនុវត្តសិទ្ធិឧបាស្រ័យជាបន្តទៀត ។

មាត្រា ១១២.-

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើឧបាស្រ័យអាចទូទាត់សងប្រាក់ដោយខ្លួនឯង តាមមធ្យោបាយនៃរូបិយាណត្តិថ្មីមួយទៀតដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញឱ្យទៅភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់សងនៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានា ដែលចែងនៅក្នុងមាត្រា ១០៨ និង មាត្រា ១០៩ នៃច្បាប់នេះ រូបិយាណត្តិថ្មីមានបញ្ជាលនូវកម្រៃជើងសា និងថ្លៃតែមប្រើផងដែរ ។

បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សង ត្រូវបានកំណត់ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញនៅកន្លែងដែលរូបិយាណត្តិដំបូង ត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់ភាគីពាក់

ព័ន្ធ ។ បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិទូទាត់សងនៅពេលបង្ហាញ នៅកន្លែងដែលបហារ័កនៃរូបិយាណត្តិថ្មីនោះ មានលំនៅនៅកន្លែងជាមួយភាគីមួយដែលពាក់ព័ន្ធ ។

មាត្រា ១១៣.-

អ្នកកាន់ចាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយបហារ័ក និងភាគីពាក់ព័ន្ធផ្សេងទៀត លើកលែងតែសិទ្ធិធ្វើឧបាស្រ័យទល់នឹងអ្នកធ្វើស្វីការ ក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ការធ្វើវិរុទ្ធវាទចំពោះការមិនធ្វើស្វីការ ឬ ការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បច្ចិលខិញ្ញដោយគ្មានសោហ៊ុយ** ឬ **បច្ចិលខិញ្ញដោយគ្មានវិរុឆ្ឆាឆ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

បើគ្មានការបង្ហាញឱ្យធ្វើស្វីការក្នុងរយៈពេលដែលកំណត់ដោយបហារ័កទេ អ្នកកាន់ចាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនចំពោះការមិនទូទាត់សងប្រាក់ក៏ដូចជាការមិនធ្វើស្វីការ លើកលែងតែខ្វីមសារនៃបដិញ្ញាបានបង្ហាញថា បហារ័កមានចេតនាធ្វើឱ្យខ្លួនរួចផុតពីការធានាលើស្វីការតែប៉ុណ្ណោះ ។

បើបដិញ្ញាស្តីពីរយៈពេលកំណត់ឱ្យបង្ហាញ មានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខនោះតែប៉ុណ្ណោះ ។

អ្នកកាន់ដែលចាត់បង់សិទ្ធិធ្វើឧបាស្រ័យក្រោមមាត្រានេះ អាចប្តឹងបហារ័កក្រោមបទប្បញ្ញត្តិដោយឡែកស្តីពីកិច្ចសន្យា ។ សំណងបានមកវិញដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវបានកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារ័កដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

មាត្រា ១១៤.-

កាលបើការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិវុទ្ធវាទក្នុងរយៈពេលកំណត់ត្រូវបានភាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបានដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើរូបិយាណត្តិ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១០៥ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិភ្លាមដើម្បីឱ្យធ្វើស្ថិការ ឬឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិវុទ្ធវាទ ។

បើករណីប្រធានស័ក្តិ នៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលដល់ឥណប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិវុទ្ធវាទមិនចាំបាច់ធ្វើឡើយ ។

ចំពោះរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬនៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះ ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះរូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញដែលមានបញ្ជាក់ច្បាស់នៅលើរូបិយាណត្តិ ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិវុទ្ធវាទ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើរូបិយាណត្តិដែលត្រូវបានចាត់បង់ ឬ ត្រូវបំផ្លាញអាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តរូបិយាណត្តិដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើរូបិយាណត្តិតាមសេចក្តី

សម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលរូបិយាណត្តិមកដោយសុចរិត ឬ ដោយ គ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

ផ្នែកទី ៨
ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

មាត្រា ១១៥.-

បហារ័ក អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវធ្វើស្វ័ការ ឬ ទូទាត់សងប្រាក់បានក្នុងករណីចាំបាច់ ។

រូបិយាណត្តិអាចត្រូវបានធ្វើស្វ័ការ ឬ ទូទាត់សងដោយបុគ្គលដែលធ្វើអន្តរាគមន៍ ដើម្បីទូទាត់សងប្រាក់ជូនកូនបំណុលណាមួយ ដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីបហារិត ឬ ភាគីដែលបានពាក់ព័ន្ធលើរូបិយាណត្តិរួចហើយ លើកលែងតែអ្នកធ្វើស្វ័ការ ។

នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគី ដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនប្រាក់នៃរូបិយាណត្តិឡើយ ។

មាត្រា ១១៦.-

ស្វ័ការដោយអន្តរាគមន៍អាចកើតមាននៅក្នុងគ្រប់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់ឥណប្រតិទានលើរូបិយាណត្តិដែលមិនទាន់ត្រូវបានធ្វើស្វ័ការ ។

កាលបើរូបិយាណត្តិមានបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវបានចាត់តាំងឱ្យធ្វើស្វ័-ការ ឬ ឱ្យទូទាត់សងប្រាក់ ក្នុងករណីចាំបាច់នៅកន្លែងដែលទូទាត់សងប្រាក់ អ្នកកាន់មិនអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួន នៅមុនពេលដល់ឥណប្រតិទានទល់នឹងបុគ្គលដែលត្រូវបានចាត់តាំង និងហត្ថលេខីបន្តបន្ទាប់ឡើយ លើកលែងតែអ្នកកាន់បានបង្ហាញ

រូបិយាណត្តិឱ្យទៅបុគ្គលនោះ និងមានសំអាងដោយវិរុទ្ធវាទអំពីការបដិសេធមិនព្រមធ្វើស្វ័ការរបស់បុគ្គលដដែលនេះ ។

ក្នុងករណីអន្តរាគមន៍ផ្សេងៗទៀត អ្នកកាន់អាចបដិសេធការធ្វើស្វ័ការដោយអន្តរាគមន៍ ។ ផ្ទុយទៅវិញ បើព្រមទទួលយកស្វ័ការបែបនេះ អ្នកកាន់ចាត់បង់សិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់ឥណប្រតិទានទល់នឹងបុគ្គលដែលបានធ្វើស្វ័ការនេះនិងហត្ថលេខីបន្តបន្ទាប់ ។

មាត្រា ១១៧.-

ស្វ័ការដោយអន្តរាគមន៍ត្រូវធ្វើនៅលើរូបិយាណត្តិ និងចុះហត្ថលេខាដោយបុគ្គលដែលធ្វើអន្តរាគមន៍ ។ ស្វ័ការនេះបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវទទួលការទូទាត់សងប្រាក់ ហើយក្នុងករណីគ្មានការបញ្ជាក់នេះទេ ស្វ័ការត្រូវបានចាត់ទុកថាបានធ្វើឱ្យបហារ័ក ។

មាត្រា ១១៨.-

អ្នកធ្វើស្វ័ការដោយអន្តរាគមន៍ មានការទទួលខុសត្រូវដូចគ្នានឹងភាគីទទួលអន្តរាគមន៍ចំពោះអ្នកកាន់ និងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បន្ទាប់ក្រោយភាគីដែលបានទទួលអន្តរាគមន៍នោះ ។

ថ្វីបើមានការធ្វើស្វ័ការដោយអន្តរាគមន៍ក្តី ក៏ភាគីទទួលអន្តរាគមន៍ និងភាគីទាំងឡាយដែលពាក់ព័ន្ធអាចទាមទារឱ្យអ្នកកាន់ប្រគល់រូបិយាណត្តិវិរុទ្ធវាទ និង ទាមទារបង្គាន់ដៃទទួលប្រាក់បានបើមាន ដើម្បីប្លូរនឹងការទូទាត់សងចំនួនប្រាក់ដូចមានចែងក្នុងមាត្រា ១០៨ នៃច្បាប់នេះ ។

មាត្រា ១១៩.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ អាចធ្វើបាននៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះរូបិយាណត្តិ នៅពេលដល់ឥណប្រតិទាន ឬ នៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងប្រាក់ ត្រូវរាប់បញ្ចូលនូវចំនួនប្រាក់ទាំងអស់ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងប្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ ។

មាត្រា ១២០.-

បើរូបិយាណត្តិត្រូវបានធ្វើស្វ័ការដោយអន្តរាគមន៍ពីបុគ្គលដែលមានលំនៅនៅកន្លែងត្រូវទូទាត់សងប្រាក់ ឬ បើបុគ្គលទាំងឡាយដែលមានលំនៅនៅទីនោះដែរត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ ត្រូវធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់យ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ ឬ ភាគីដែលរូបិយាណត្តិត្រូវបានធ្វើស្វ័ការជាប្រយោជន៍ឱ្យ និងអ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

មាត្រា ១២១.-

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍ចាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

មាត្រា ១២២.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាព អំពីការទទួលប្រាក់នៅលើរូបិយាណត្តិដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជួស ។ ក្នុងករណីគ្មានសេចក្តីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យបហារ័ក ។

រូបិយាណត្តិ និងវិរុទ្ធវាទ បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

មាត្រា ១២៣.-

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃរូបិយាណត្តិទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជួស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើរូបិយាណត្តិ ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខរូបិយាណត្តិបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគី ដែលទទួលការទូទាត់សងប្រាក់ជួសត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ ការទូទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេ ត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ផ្នែកទី ៩
ផ្នែកទាំងឡាយនៃរូបិយាណត្តិមួយច្បាប់និងច្បាប់ចម្លង

មាត្រា ១២៤.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញមួយច្បាប់មានពីរ ឬច្រើនផ្នែកផ្ទួចគ្នា ផ្នែកនីមួយៗត្រូវចុះលេខ និងមានសេចក្តីយោងនៅផ្នែកផ្សេងទៀត ផ្នែកទាំងអស់បង្កើតបានជារូបិយាណត្តិមួយច្បាប់ ។

ស្វីការ និងបិដ្ឋិលេខនីមួយៗ នៅលើរូបិយាណត្តិដែលបានចេញក្នុងមួយច្បាប់អាចត្រូវបានសរសេរនៅលើផ្នែកណាមួយ ប៉ុន្តែត្រូវបានពាក់ព័ន្ធទៅលើរូបិយាណត្តិទាំងមូល ហើយមិនមែនទៅលើតែផ្នែកណាមួយដាច់គ្នានោះទេ ។ ស្វីការ ឬ បិដ្ឋិលេខនីមួយៗទាំងនោះ ត្រូវបានសរសេរនៅលើតែផ្នែកមួយប៉ុណ្ណោះ ។

បហារ័កដែលចុះហត្ថលេខាលើផ្នែកនីមួយៗ មានការទទួលខុសត្រូវនៅលើរូបិយាណត្តិទាំងមូល ហើយមិនមែនលើផ្នែកនីមួយៗនោះទេ ។

ភាគីដែលបានធ្វើផ្ដែកមួយដើម្បីធ្វើស្វ័ការ ត្រូវតែចង្អុលបង្ហាញនៅលើផ្ដែកផ្សេងទៀត នូវឈ្មោះរបស់បុគ្គលដែលមានផ្ដែកនោះនៅក្នុងដៃ ។ បុគ្គលនោះត្រូវតែប្រគល់ផ្ដែកនោះឱ្យទៅអ្នកកាន់ស្របច្បាប់នៃផ្ដែកមួយទៀត ។ បើបុគ្គលនោះបដិសេធ អ្នកកាន់អាចអនុវត្តសិទ្ធិឧបាស្រ័យបាន លុះត្រាតែខ្លួនបានធ្វើវិរុទ្ធវាទដោយបញ្ជាក់អំពី :

-ផ្ដែកដែលបានធ្វើដើម្បីធ្វើស្វ័ការ មិនត្រូវបានប្រគល់ឱ្យខ្លួនតាមការស្នើសុំ

-ស្វ័ការ ឬការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅលើផ្ដែកផ្សេងទៀត ។

មាត្រា ១២៥.-

នៅពេលដែលអ្នកកាន់រូបិយាណត្តិមួយច្បាប់ធ្វើបិដ្ឋិលេខលើផ្ដែកពីរ ឬ ច្រើនឱ្យទៅបុគ្គលផ្សេងគ្នា :

-អ្នកកាន់ត្រូវទទួលខុសត្រូវ នៅលើរាល់ផ្ដែកទាំងនោះ ហើយអ្នកធ្វើបិដ្ឋិលេខនីមួយៗបន្ទាប់ពីអ្នកកាន់ ត្រូវទទួលខុសត្រូវលើផ្ដែកដែលខ្លួនបានធ្វើបិដ្ឋិលេខដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា

-អ្នកកាន់ស្របច្បាប់នៃផ្ដែកដែលមានកម្មសិទ្ធិទីមួយ មានសិទ្ធិទាមទារប្រាក់ដែលបហារ័កបានសងឱ្យទៅបុគ្គលណាមួយ ឬ បហារិត ដែលមិនបានធ្វើស្វ័ការលើរូបិយាណត្តិ ។

នៅពេលដែលបហារិតធ្វើស្វ័ការច្រើនជាងមួយផ្ដែក ហើយផ្ដែកដែលបានធ្វើស្វ័ការនោះធ្លាក់ទៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ផ្សេងគ្នា បហារិតត្រូវទទួលខុសត្រូវលើរាល់ផ្ដែកទាំងនោះ ដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា ។

មាត្រា ១២៦.-

នៅពេលដែលអ្នកធ្វើស្វ័ការលើរូបិយាណត្តិ ដែលបានចេញមួយច្បាប់ ធ្វើការទូទាត់សងប្រាក់ ដោយពុំបានទាមទារឱ្យប្រគល់មកវិញនូវផ្ដែកដែលមានស្វ័ការរបស់ខ្លួន ហើយផ្ដែកនោះនៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ នៅពេលដល់ឥណប្រតិទាន អ្នកធ្វើស្វ័ការនោះ ត្រូវទទួលខុសត្រូវចំពោះអ្នកកាន់នេះ ។

បហារ័កនៃរូបិយាណត្តិមួយច្បាប់ ត្រូវរួចផុតពីការទទួលខុសត្រូវ នៅពេលដែលខ្លួនបានសងប្រាក់ នៅលើផ្ដែកណាមួយដែលបានយកមកបង្ហាញ ។

ក្រោមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១២៥ និងមាត្រា ១២៦ នៃច្បាប់នេះ នៅពេលដែលផ្នែកណាមួយនៃរូបិយាណត្តិ ត្រូវបានរួចបំណុលដោយការទូទាត់សងច្រាក់ ឬ តាមរបៀបផ្សេងទៀត រូបិយាណត្តិទាំងមូលត្រូវបានរួចបំណុល ។

មាត្រា ១២៧.-

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងរូបិយាណត្តិ ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យ បានត្រឹមត្រូវតាមច្បាប់ដើមជាមួយនិងបិដ្ឋិលេខ និងសេចក្តីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់លាស់នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខ និងធ្វើរូបិយបដិភោគនៅក្នុងលក្ខណៈដូចគ្នា ហើយមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

មាត្រា ១២៨.-

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើមត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើមដែលមានចែងខាងលើ ឱ្យទៅអ្នកកាន់ស្របច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើរូបិយបដិភោគច្បាប់ចម្លង លុះត្រាតែបានបញ្ជាក់នៅលើវិរុទ្ធភាទថា ច្បាប់ដើមមិនទាន់ត្រូវប្រគល់មកវិញតាមសំណើរបស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ដើមមានបដិញ្ញាថា **ចាប់ផ្តើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិលេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ** ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខបន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

ផ្នែកទី ១០
ការកែលើរូបិយាណត្តិ

មាត្រា ១២៩.-

ក្នុងករណីមានការកែលើខ្លឹមសារនៃរូបិយាណត្តិ រាល់ភាគីដែលបានចុះហត្ថ-លេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃរូបិយា-ណត្តិ ។

ផ្នែកទី ១១
រយៈពេលកំណត់នៃការធ្វើឱ្យបាត់ស្រម៉ៃ

មាត្រា ១៣០.-

រាល់ឧបាស្រ័យដែលកើតឡើងពីរូបិយាណត្តិ ទល់នឹងអ្នកធ្វើស្ងីការ មានរយៈពេលបី(០៣)ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រ័យដែលធ្វើឡើងដោយអ្នកកាន់ ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងបហារ័ក មានរយៈពេលមួយឆ្នាំ គិតពីថ្ងៃធ្វើវិនុទ្ធវាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទាន កាលបើមានបដិញ្ញាថា **បច្ចិលខិញ្ញដោយគ្មានសោហ៊ុយ** ឬ **បច្ចិលខិញ្ញដោយគ្មានខិរុច្ឆទាន** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រ័យរបស់អ្នកធ្វើបិដ្ឋិលេខ ទល់នឹងអ្នកធ្វើបិដ្ឋិលេខជងគ្នា និងបហា-រ័ក មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និង បានទូទាត់សងរូបិយាណត្តិ ឬ គិតពីថ្ងៃដែលបានទទួលរងការប្តឹង ។

មាត្រា ១៣១.-

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះមាន សុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

ផ្នែកទី ១២

ការគណនារយៈពេលកំណត់

មាត្រា ១៣២.-

រូបិយាណត្តិដែលដល់រយៈពេលកំណត់ទូទាត់សងប្រាក់ នៅថ្ងៃឈប់សម្រាកផ្លូវការ នឹងត្រូវទូទាត់សងនៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងរូបិយាណត្តិ ជាពិសេសការបង្ហាញឱ្យធ្វើស្ទីការ និងវិរុទ្ធភាទអាចត្រូវធ្វើឡើងបានតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយ ដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

មាត្រា ១៣៣.-

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះ នឹងមិនរាប់បញ្ចូលជាមួយជងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

មាត្រា ១៣៤.-

ទោះបីតាមផ្លូវច្បាប់ក្តីឬតាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

ជំពូកទី ៤

បំណុលសងតាមបញ្ជា

ផ្នែកទី ១

ការចេញផ្សាយនិងទម្រង់នៃបំណុលសងតាមបញ្ជា

មាត្រា ១៣៥.-

បំណុលសងតាមបញ្ជា ជាការសន្យាលាយលក្ខណ៍អក្សរដោយឥតលក្ខខ័ណ្ឌដែលធ្វើឡើងនិងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបំណុលដែលសន្យាសងចំនួនប្រាក់

ជាកំណត់មួយ ឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជា ត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ច ដែលមានចែងនៅក្នុងជំពូកនេះ ។

មាត្រា ១៣៦.-

ប័ណ្ណសងតាមបញ្ជាជាឧបករណ៍ឥណទាន ។ ប័ណ្ណសងតាមបញ្ជាអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ អក្សរបរទេស ហើយត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **ប័ណ្ណសងតាមបញ្ជា** ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញប័ណ្ណ

-ការសន្យាទូទាត់សងដោយឥតល័ក្ខខ័ណ្ឌនូវចំនួនប្រាក់ជាកំណត់មួយ

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែងដែលប័ណ្ណសងតាមបញ្ជានោះត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់អ្នកចេញប័ណ្ណ ដែលជាបុគ្គលធ្វើការសន្យាលើប័ណ្ណសងតាមបញ្ជា ។

មាត្រា ១៣៧.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ១៣៦ នៃច្បាប់នេះពុំមានសុពលភាពជាប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌដូចខាងក្រោម :

១-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់អ្នកចេញប័ណ្ណផងដែរ ។

៣-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់កន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថា ចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ។

៤-ប័ណ្ណសងតាមបញ្ជា អាចត្រូវចេញដើម្បីទូទាត់សងប្រាក់ទៅអ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជាដែលគ្មានឈ្មោះបុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាជាប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

មាត្រា ១៣៨.-

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងប្រាក់ នៅកន្លែងក្រៅពីលំនៅរបស់អ្នកចេញប័ណ្ណ រួមទាំងនៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់អ្នកចេញប័ណ្ណ ឬ នៅកន្លែងផ្សេងទៀត ។

មាត្រា ១៣៩.-

ចំពោះប្រភេទប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ អ្នកចេញប័ណ្ណអាចចែងលក្ខខ័ណ្ឌថា ចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃប័ណ្ណសងតាមបញ្ជាផ្សេងពីខាងលើ បដិញ្ញានេះ មិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ត្រូវតែបានបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញប័ណ្ណសងតាមបញ្ជា លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

មាត្រា ១៤០.-

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរជាពួកអក្សរផង និងជាពួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជា

តួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬជាតួលេខ និងកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

មាត្រា ១៤១.-

រាល់កាតព្វកិច្ចនៃបុគ្គលផងទៅៗទៀត ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា នៅតែមានតម្លៃផងដែល ទោះបីប័ណ្ណសងតាមបញ្ជានោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថ-លេខា ឬ បានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ១៤២.-

បុគ្គលណាដែលបានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា ក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើប័ណ្ណសងតាមបញ្ជានោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលភ័ប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជន ដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ១៤៣.-

បើប័ណ្ណសងតាមបញ្ជាមានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលប័ណ្ណសងតាមបញ្ជាមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

ផ្នែកទី ២

បិដ្ឋិលេខប័ណ្ណសងតាមបញ្ជា

មាត្រា ១៤៤.-

ប័ណ្ណសងតាមបញ្ជា ដែលចេញឱ្យទូទាត់សងចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា **សងតាមបញ្ជា** អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលអ្នកចេញប័ណ្ណបានបញ្ចូលក្នុងប័ណ្ណសងតាមបញ្ជា ដែលចេញដើម្បីទូទាត់សងច្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នា ប័ណ្ណសងតាមបញ្ជានោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាព ជាការផ្ទេរជាធម្មតាតែប៉ុណ្ណោះ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅអ្នកចេញប័ណ្ណក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃប័ណ្ណសងតាមបញ្ជានោះក្តី ។ បុគ្គលទាំងនេះអាចធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជានោះបន្តទៀតបាន ។

ឧបករណ៍ដែលមានទម្រង់ជាប័ណ្ណសងតាមបញ្ជា ដែលអាចទូទាត់សងបានតាមបញ្ជាអ្នកចេញប័ណ្ណ មិនមែនជាប័ណ្ណសងតាមបញ្ជាក្រោមជំពូកនេះឡើយ លើកលែងតែប័ណ្ណនេះត្រូវបានធ្វើបិដ្ឋិលេខដោយអ្នកចេញប័ណ្ណ។

មាត្រា ១៤៥.-

បិដ្ឋិលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជា មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនច្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ **អ្នកកាន់** មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

មាត្រា ១៤៦.-

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងប័ណ្ណសងតាមបញ្ជា ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុប័ត្រ** ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខ អាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

មាត្រា ១៤៧.-

បិដ្ឋិលេខ ផ្ទេរសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលផ្សេងទៀត

-ធ្វើបិដ្ឋិលេខបន្តប័ណ្ណសងតាមបញ្ជាជាចំហ ឬ ឱ្យបុគ្គលផ្សេងទៀត

-ផ្ទេរប័ណ្ណសងតាមបញ្ជាឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

មាត្រា ១៤៨.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើប័ណ្ណសងតាមបញ្ជាចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែប័ណ្ណសងតាមបញ្ជានោះមិនអាចប្រែក្លាយទៅជាប័ណ្ណសងតាមបញ្ជា ដើម្បី**សងតាមបញ្ជា**ឡើយ ។

មាត្រា ១៤៩.-

ម្ចាស់ប័ណ្ណសងតាមបញ្ជាដែលអាចធ្វើបិដ្ឋិលេខបាន ជាអ្នកកាន់ស្របច្បាប់

បើបុគ្គលនេះបានក្លាយជាម្ចាស់ប័ណ្ណសងតាមបញ្ជា តាមរយៈការធ្វើបិដ្ឋិលេខជាបន្ត បន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខ ដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្ត ដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលប័ណ្ណសងតាមបញ្ជា តាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយបានចាត់បង់សិទ្ធិកាន់កាប់ប័ណ្ណសងតាមបញ្ជា ដោយមូលហេតុណាក៏ដោយ ទោះបីជាប័ណ្ណសងតាមបញ្ជាចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់អួចមានចែងនៅក្នុងកថាខណ្ឌ ខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានប័ណ្ណសងតាមបញ្ជាមកជាកម្មសិទ្ធិ មិន ត្រូវបានបង្ខំឱ្យចោះបង់ចោលប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែប័ណ្ណសងតាម បញ្ជានោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

មាត្រា ១៥០.-

បុគ្គលទាំងឡាយដែលប្តឹងអំពីប័ណ្ណសងតាមបញ្ជា មិនអាចប្តឹងអ្នកកាន់ដោយ សំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកចេញប័ណ្ណ ឬ ជាមួយអ្នកកាន់មុនៗបាន ឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹង នាំឱ្យខូចប្រយោជន៍ដល់ក្ងនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះប័ណ្ណសងតាមបញ្ជាដែលចេញ ដើម្បីទូទាត់សងទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា **មិនសង តាមបញ្ជា** ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

មាត្រា ១៥១.-

កាលបើបិដ្ឋិលេខមានពាក្យថា **តម្លៃសម្រាប់ទារបំណុល** ឬ **សម្រាប់បេឡានិចំយ** ឬ **តាមការប្រគល់សិទ្ធិ** ឬ ប្រយោគណាមួយផ្សេងទៀតដែលបញ្ជាក់ពីការប្រគល់សិទ្ធិ សាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជា ប៉ុន្តែអ្នកកាន់នេះអាច ធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់បាន ហើយអ្នកកាន់នេះ ក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខបានផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីតិសាស្ត្រឡើយ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជា ត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ ប័ណ្ណសងតាមបញ្ជានោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្តីពីប្រតិបត្តិ-ការទូទាត់សងច្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីប័ណ្ណសងតាមបញ្ជារវាងបទប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាចានការ ។

មាត្រា ១៥២.-

កាលបើបិដ្ឋិលេខមួយមានសេចក្តីបញ្ជាក់ថា **តម្លៃសម្រាប់ឆានា** ឬ **តម្លៃសម្រាប់ជាក់បញ្ជរ** ឬ សេចក្តីបញ្ជាក់ណាផ្សេងទៀតដែលមានន័យថាសម្រាប់ដាក់បញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជានោះ ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្តាភាគីដែលពាក់ព័ន្ធមិនអាចប្តឹងអ្នកកាន់បាន ដោយសំអាងលើទំនាក់ទំនងផ្ទាល់របស់ខ្លួនជាមួយអ្នកធ្វើបិដ្ឋិលេខឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់ភ្នែនបំណុល ។

មាត្រា ១៥៣.-

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីការធ្វើវិបុទ្ធភាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមមូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងច្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ១៤៩ និងមាត្រា ១៥០ នៃច្បាប់នេះ ។

បើគ្មានភស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបានធ្វើនៅលើប័ណ្ណសងតាមបញ្ជាមុនធ្វើវិនុទ្ធភាទ ឬ ប្រតិវេទនីដែលសមមូលគ្នា ឬ មុនជុតរយៈពេលកំណត់ ដែលបានយោងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥៣ នេះ ។

ផ្នែកទី ៣

ការទទួលខុសត្រូវរបស់អ្នកចេញប័ណ្ណសងតាមបញ្ជា

មាត្រា ១៥៤.-

ក្នុងការចេញប័ណ្ណសងតាមបញ្ជា អ្នកចេញប័ណ្ណសន្យាទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ។

បើមិនបានទូទាត់សងប្រាក់ អ្នកកាន់អាចធ្វើឧបាស្រ័យដោយផ្ទាល់លើប័ណ្ណសងតាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណ ដើម្បីទាមទារនូវអ្វីដែលអាចធ្វើបានស្របតាមមាត្រា ១៧៥ និងមាត្រា ១៧៦ នៃច្បាប់នេះ ។

មាត្រា ១៥៥.-

ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើទិដ្ឋាការនៅក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទចេញប័ណ្ណ ។

អ្នកចេញប័ណ្ណអាចបង្រៀញ ឬ ពន្យាររយៈពេលកំណត់នេះបាន ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រៀញដោយអ្នកធ្វើបិដ្ឋិលេខទាំងឡាយផងដែរ ។

មាត្រា ១៥៦.-

ទិដ្ឋាការត្រូវបានសរសេរនៅលើប័ណ្ណសងតាមបញ្ជា ដោយប្រើពាក្យថា **បានធ្វើទិដ្ឋាការ** ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយអ្នកចេញប័ណ្ណ ។

ទិដ្ឋាការត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃដែលបង្ហាញឱ្យទូទាត់សងប្រាក់ ។ បើទិដ្ឋាការនោះគ្មានចុះកាលបរិច្ឆេទទេ អ្នកកាន់ដើម្បីរក្សាសិទ្ធិឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងអ្នកចេញប័ណ្ណ ត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្ញាក់ផ្អើលនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

រយៈពេលកំណត់ក្រោយការបង្ហាញដែលប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់ ត្រូវគិតពីថ្ងៃធ្វើទិដ្ឋាការដែលបានចុះហត្ថលេខាដោយអ្នកចេញប័ណ្ណ នៅលើប័ណ្ណសងតាមបញ្ជា ។ ការបដិសេធរបស់អ្នកចេញប័ណ្ណក្នុងការផ្តល់ទិដ្ឋាការដោយមានចុះកាលបរិច្ឆេទ ត្រូវតែបញ្ជាក់ដោយការធ្វើវិរុទ្ធវាទ ដែលជាកាលបរិច្ឆេទកំណត់ថ្ងៃចាប់ផ្តើមនៃរយៈពេលកំណត់ បន្ទាប់ពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ។

ផ្នែកទី ៤
រូបិយបដិភោគប័ណ្ណសងតាមបញ្ជា

មាត្រា ១៥៧.-

ការទូទាត់សងប័ណ្ណសងតាមបញ្ជាអាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃប័ណ្ណសងតាមបញ្ជា ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

មាត្រា ១៥៨.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើប័ណ្ណសងតាមបញ្ជាផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀត ដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថារូបិយបដិភោគី ។

រាល់ហត្ថលេខាដែលបានចុះនៅខាងមុខប័ណ្ណសងតាមបញ្ជា ក្រៅពីហត្ថលេខារបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាហត្ថលេខាធ្វើរូបិយបដិភោគ ។

រូបិយបដិភោគត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ នូវបុគ្គលណាមួយដែលជាបុគ្គលទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថាធ្វើឱ្យអ្នកចេញប័ណ្ណ ។

មាត្រា ១៥៩.-

រូបិយបដិភោគីមានកាតព្វកិច្ចផ្ទេរបុគ្គលដែលបានទទួលការធានាវិញ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេង។ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងប័ណ្ណសងតាមបញ្ជា រូបិយបដិភោគីមានសិទ្ធិទាំងឡាយនៃប័ណ្ណសងតាមបញ្ជានេះ ទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានោះ នៅលើប័ណ្ណសងតាមបញ្ជា ។

ផ្នែកទី ៥
ឥណទានប័ណ្ណសងតាមបញ្ជា

មាត្រា ១៦០.-

ប័ណ្ណសងតាមបញ្ជា អាចត្រូវបានចេញដើម្បី :

-ទូទាត់សងច្រាក់នៅពេលបង្ហាញ

-ទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងច្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញប័ណ្ណ

-ទូទាត់សងច្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានចេញដើម្បីឱ្យទូទាត់សងច្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមាន

លើកខ្ពស់ណាថា ក្នុងករណីខកខានទូទាត់សងប្រាក់នៅដំណាក់កាលណាមួយ ចំនួនប្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

បំណុលសងតាមបញ្ជាទាំងឡាយ ដែលមានឥណប្រតិទានផ្សេងពីនេះត្រូវបានចាត់ទុកជាមោយៈ ។

មាត្រា ១៦១.-

បំណុលសងតាមបញ្ជាទូទាត់សងប្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយត្រូវតែបានបង្ហាញនៅពេលណាមួយក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញផ្សាយ ។ អ្នកចេញប័ណ្ណអាចបង្រួញ ឬ ពន្យារយៈពេលនេះបាន ។ រយៈពេលកំណត់នេះក៏អាចត្រូវបានបង្រួញ ដោយអ្នកធ្វើបិដ្ឋិលេខផងដែរ ។

អ្នកចេញប័ណ្ណអាចបញ្ជាក់ថា ប័ណ្ណសងតាមបញ្ជាដែលអាចទូទាត់សងប្រាក់នៅពេលបង្ហាញ មិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករ-ណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញត្រូវចាប់ផ្តើមពីថ្ងៃកំណត់នោះ ។

មាត្រា ១៦២.-

ឥណប្រតិទាននៃប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើទិដ្ឋាការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទទេ ទិដ្ឋាការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើទិដ្ឋាការ ។

មាត្រា ១៦៣.-

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានចេញ ដើម្បីឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែ ឬ ច្រើនខែក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាន នៅកាលបរិច្ឆេទដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាននៅថ្ងៃចុងក្រោយនៃខែនោះ ។

កាលបើប័ណ្ណសងតាមបញ្ជាត្រូវបានចេញដើម្បីឱ្យទូទាត់សងប្រាក់ ក្នុងរយៈពេលមួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ រយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្តាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា **ប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃ** មិនមានន័យថាមួយសប្តាហ៍ ឬ ពីរសប្តាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថា **កន្លះខែ** មានន័យថាដប់ប្រាំថ្ងៃ ។

មាត្រា ១៦៤.-

កាលបើប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់នៅថ្ងៃកំណត់មួយ ឬ នៅរយៈពេលកំណត់មួយ បន្ទាប់ពីថ្ងៃកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ លើកលែងតែមានបដិញ្ញានៅក្នុងប័ណ្ណសងតាមបញ្ជា ឬ មានល័ក្ខ-ខ័ណ្ឌសាមញ្ញ ដែលប័ណ្ណសងតាមបញ្ជាចង្អុលបង្ហាញអំពីបំណងក្នុងការជ្រើសរើសយកវិធានផ្សេងពីនេះ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

ផ្នែកទី ៦
ការទូទាត់សងប្រាក់

មាត្រា ១៦៥.-

អ្នកកាន់ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២) ថ្ងៃធ្វើការបន្ទាប់ ។

ការបង្ហាញប័ណ្ណសងតាមបញ្ជាតាមរយៈសភាជាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកមួយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជា គឺជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

មាត្រា ១៦៦.-

អ្នកចេញប័ណ្ណដែលទូទាត់សងប័ណ្ណសងតាមបញ្ជា អាចតម្រូវឱ្យប្រគល់ប័ណ្ណសងតាមបញ្ជានោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់ប្រាក់មួយផ្នែកនៃចំនួនប្រាក់ប័ណ្ណសងតាមបញ្ជា ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ អ្នកចេញប័ណ្ណអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះនៅលើប័ណ្ណសងតាមបញ្ជា និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ១៦៧.-

នៅពេលដែលប័ណ្ណសងតាមបញ្ជាមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ១៦៥ នៃច្បាប់នេះ ក្រុមប័ណ្ឌលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

មាត្រា ១៦៨.-

អ្នកកាន់ប័ណ្ណសងតាមបញ្ជាមិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទានឡើយ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិភ័យដោយខ្លួនឯងផ្ទាល់ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ អ្នកចេញប័ណ្ណត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ១៦៩.-

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើជារូបិយប័ណ្ណ ដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេស

ជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើប័ណ្ណសងតាមបញ្ជានោះ ធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃដែលទូទាត់សងប្រាក់ តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែអ្នកចេញប័ណ្ណអាចចែងលក្ខខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។

វិធានទាំងឡាយខាងលើនេះ មិនត្រូវបានអនុវត្តចំពោះប័ណ្ណសងតាមបញ្ជា :

-ដែលធ្វើជារូបិយប័ណ្ណដែលមានការទទួលយកនៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ អ្នកចេញប័ណ្ណបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ ប័ណ្ណសងតាមបញ្ជានឹងត្រូវទូទាត់សងជារូបិយប័ណ្ណដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវបានបញ្ជាក់ជារូបិយប័ណ្ណ ដែលមានឈ្មោះដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និង ប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់មិនមានឈ្មោះដូចគ្នា ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានទូទាត់សងប្រាក់នៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវចុះឥណពន្ធតាមចំនួនប្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

ផ្នែកទី ៧

ខ្ចាស្រ័យចំពោះការមិនទូទាត់សងប្រាក់

មាត្រា ១៧០.-

អ្នកកាន់ប័ណ្ណសងតាមបញ្ជា អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ អ្នកចេញប័ណ្ណ និងភាគីពាក់ព័ន្ធដទៃៗទៀត :

-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើ

-នៅមុនពេលដល់ឥណប្រតិទាន ក្នុងករណីធនក្រ័យរបស់អ្នកចេញប័ណ្ណ ឬ ក្នុងករណីអ្នកចេញប័ណ្ណបញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ទោះបីគ្មានសេចក្តីសម្រេចពីតុលាការក្តី ឬ នៅពេលណាដែលការអនុវត្តវិបអ្វូសទ្រព្យសម្បត្តិរបស់អ្នកចេញប័ណ្ណពុំបានសម្រេចក្តី ។

មាត្រា ១៧១.-

ការខកខានមិនបានទូទាត់សងប្រាក់ ត្រូវតែបានបង្ហាញភស្តុតាងដោយវិរុទ្ធភាពតាមច្បាប់ ។

វិរុទ្ធភាពចំពោះការមិនទូទាត់សងប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណឬក្រោយការបង្ហាញ ត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលប័ណ្ណសងតាមបញ្ជានោះត្រូវទូទាត់សងប្រាក់ ។ នៅក្នុងករ-ណីនៃប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ វិរុទ្ធភាពត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។ វិរុទ្ធភាពចំពោះការបដិសេធមិនផ្តល់ទិដ្ឋាការ អាចធ្វើបានដោយមិនចាំបង្ហាញឱ្យទូទាត់សងប្រាក់ហើយត្រូវតែធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។

បើអ្នកចេញប័ណ្ណ បញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ឬ បើការអនុវត្តវិបអ្វូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន តែនៅក្រោយការ

បង្ហាញប័ណ្ណសងតាមបញ្ជា ឱ្យទៅអ្នកចេញប័ណ្ណធ្វើការទូទាត់សងប្រាក់ និងនៅក្រោយពេលដែលវិរុទ្ធវាទត្រូវបានធ្វើ ។

បើអ្នកចេញប័ណ្ណត្រូវបានប្រកាសថាធនក្សីយ ការបង្ហាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្សីយនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន ។

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ឱ្យបញ្ជាក់យថាភាពនៃឯកសារ ។ ជរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃប័ណ្ណសងតាមបញ្ជាភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់ឈ្មោះបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញអ្នកចេញប័ណ្ណ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសពីដប់ (១០) គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ។

វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់អ្នកចេញប័ណ្ណ បញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

មាត្រា ១៧២.-

អ្នកកាន់ត្រូវជូនដំណឹងពីការមិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងរូបិយបដិភោគីណាមួយនៃអ្នកចេញប័ណ្ណ នៅក្នុងរយៈពេលបួន (០៤) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បច្ចិលខិញ្ញដោយគ្មានសោហ៊ុយ** ឬ **បច្ចិលខិញ្ញដោយគ្មានវិរុទ្ធភាព** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋាន

របស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់អ្នកចេញប័ណ្ណបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា សេចក្តីជូនដំណឹងជូចគ្នានេះក៏ត្រូវបានផ្តល់ទៅរៀបិយបដិភោគី នៅក្នុងពេលកំណត់ជូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខមិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង អាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនប័ណ្ណសងតាមបញ្ជាត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវបានចាត់ទុកថា បានគោរពតាមបើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើង ដោយការធ្វេសប្រហែសរបស់ខ្លួនបើមាន ប៉ុន្តែចំនួនច្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនច្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

មាត្រា ១៧៣.-

តាមរយៈបដិញ្ញាថា **បដិសេធដោយគ្មានសោហ៊ុយ** ឬ **បដិសេធដោយគ្មានទំរុឡាង** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា អ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធភាព ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញប័ណ្ណសងតាមបញ្ជានៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹងឡើយ ។ សោហ៊ុយ

ដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ត្រូវធ្លាក់ទៅលើបុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់ ។

បដិញ្ញាដែលត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីត្រូវអនុវត្តបានចំពោះអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីតែប៉ុណ្ណោះ ។ ទោះបីជាមាន ឬ គ្មានបដិញ្ញាក្តី បើអ្នកកាន់ធ្វើវិរុទ្ធវាទ សោហុយនៃការធ្វើវិរុទ្ធវាទអាចត្រូវបានទាវពីបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

មាត្រា ១៧៤.-

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលធានា ដោយការធ្វើរូបិយបដិភោគនៃប័ណ្ណសងតាមបញ្ជា មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្តឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងប័ណ្ណសងតាមបញ្ជាជាឯកត្តជន ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិបួចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ហើយបានទទួលយកប័ណ្ណសងតាមបញ្ជារក្សាទុក និងបានបូទាត់សងប្រាក់ ។

រាល់ការប្តឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្តឹងទល់នឹងបុគ្គលផ្សេងទៀតឡើយ ទោះបីបុគ្គលផ្សេងទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្តឹងទីមួយនោះក៏ដោយ ។

មាត្រា ១៧៥.-

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្ជិនអនុវត្តសិទ្ធិធ្វើឧបាស្រ័យ នូវចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជា ដែលមិនបានបូទាត់សងដោយមានការប្រាក់ បើការប្រាក់នោះមានចែងលើប័ណ្ណសងតាមបញ្ជា ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវជាកម្មវត្ថុនៃការធ្វើអប្បហារ ។ អប្បហារនេះត្រូវបានគណនា

ទៅតាមអត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបាស្រ័យនៅកន្លែងស្នាក់នៅ
របស់អ្នកកាន់ ។

មាត្រា ១៧៦.-

ភាគីដែលបានទទួលយកនិងទូទាត់សងប័ណ្ណសងតាមបញ្ជា អាចទាមទារមកវិញ
ពីភាគីទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់
សង ការប្រាក់លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ ដោយធនា-
គារជាតិនៃកម្ពុជាគិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

មាត្រា ១៧៧.-

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារ
ដោយប្លែរនឹងការទូទាត់សងប្រាក់ ឱ្យប្រគល់មកខ្លួននូវប័ណ្ណសងតាមបញ្ជារួមជាមួយ
នឹងវិរុទ្ធភាព និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយកនិងបានទូទាត់សងប័ណ្ណសងតាម
បញ្ជា អាចលុបចោលបិដ្ឋិលេខរបស់ខ្លួនផ្ទាល់ និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់បាន
តាមក្រោយ ។

មាត្រា ១៧៨.-

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើ
ឧបាស្រ័យអាចទូទាត់សងខ្លួនឯង តាមមធ្យោបាយនៃការចេញរូបិយាណត្តិដែលត្រូវទូ
ទាត់សងប្រាក់នៅពេលបង្ហាញទៅលើភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់
សងបាននៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានាដែលចែងនៅក្នុងមាត្រា ១៧៥ និងមាត្រា ១៧៦
នៃច្បាប់នេះ រូបិយាណត្តិមានបញ្ជាលនូវកម្រៃជើងសានិងថ្លៃតែមប្រើផងដែរ ។

បើរូបិយាណត្តិត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់
ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ
នៅពេលដែលប័ណ្ណសងតាមបញ្ជាចំបូងត្រូវបានទូទាត់សងនៅលំនៅរបស់ភាគីពាក់
ព័ន្ធ ។ បើរូបិយាណត្តិត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវ

ចានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ នៅពេលដែលអ្នកចេញរូបិយាណត្តិនោះ មានលំនៅនៅកន្លែងជាមួយភាគីដែលពាក់ព័ន្ធ ។

មាត្រា ១៧៩.-

អ្នកកាន់ចាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងភាគីពាក់ព័ន្ធដទៃៗទៀត លើកលែងតែអ្នកចេញប័ណ្ណក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញប័ណ្ណសងតាមបញ្ជា ដែលចេញដើម្បីឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ធ្វើវិនិច្ឆ័យចំពោះការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បដិលេខិញ្ញដោយគ្មានសោហ៊ុយ** ឬ **បដិលេខិញ្ញដោយគ្មានវិនិច្ឆ័យ** ឬ សេចក្តីផ្សេងណាមួយ ដែលមានន័យដូចគ្នា ។

បើបដិញ្ញាស្តីពីរយៈពេលកំណត់ឱ្យបង្ហាញមានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខតែប៉ុណ្ណោះ ។

មាត្រា ១៨០.-

កាលបើការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិនិច្ឆ័យក្នុងរយៈពេលកំណត់ ត្រូវបានភាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នឹងត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១៧២ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាភ្លាម ដើម្បីឱ្យធ្វើការទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិនិច្ឆ័យ ។

បើករណីប្រធានស័ក្តិនៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលដល់ឥណប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិនិច្ឆ័យ មិនចាំបាច់ធ្វើឡើយ ។

ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះ ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញ ដែលមានបញ្ជាក់ច្បាស់នៅលើប័ណ្ណសងតាមបញ្ជា ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិនិច្ឆ័យ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើប័ណ្ណសងតាមបញ្ជាដែលត្រូវបានចាត់បង់ ឬ ត្រូវបំផ្លាញ អាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តប័ណ្ណសងតាមបញ្ជាដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើប័ណ្ណសងតាមបញ្ជាតាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលប័ណ្ណសងតាមបញ្ជាមកដោយសុចរិត ឬ ដោយគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

ផ្នែកទី ៨

ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

មាត្រា ១៨១.-

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវទូទាត់សងប្រាក់ ក្នុងករណីចាំបាច់ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងច្រាក់ ដោយបុគ្គលដែលធ្វើអន្តរាគមន៍ដើម្បីទូទាត់សងច្រាក់ជូសកូនបំណុលណាមួយដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីដែលបានពាក់ព័ន្ធលើប័ណ្ណសងតាមបញ្ជា ។

នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគីដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងច្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនច្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

មាត្រា ១៨២.-

ការទូទាត់សងច្រាក់ដោយអន្តរាគមន៍អាចធ្វើបាន នៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះប័ណ្ណសងតាមបញ្ជានៅពេលដល់ឥណប្រតិទាន ឬនៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងច្រាក់ត្រូវរាប់បញ្ចូលទាំងចំនួនច្រាក់ទាំងអស់ ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងច្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិនុទ្ធវាទចំពោះការមិនទូទាត់សងច្រាក់ ។

មាត្រា ១៨៣.-

បើបុគ្គលទាំងឡាយដែលមានលិនៅនៅកន្លែងទូទាត់សងច្រាក់ ត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ត្រូវធ្វើវិនុទ្ធវាទចំពោះការមិនទូទាត់សងច្រាក់ យ៉ាងយឺតបំផុតនៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិនុទ្ធវាទ ។

បើគ្មានវិនុទ្ធវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ និងអ្នកធ្វើបិន្ទិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

មាត្រា ១៨៤.-

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍ចាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

មាត្រា ១៨៥.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាពអំពីការទទួលប្រាក់នៅលើប័ណ្ណសងតាមបញ្ជា ដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជួស ។ ក្នុងករណីគ្មានសេចក្តីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យអ្នកចេញប័ណ្ណ ។

ប័ណ្ណសងតាមបញ្ជា និងវិរុទ្ធវាទ បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

មាត្រា ១៨៦.-

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជួស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើប័ណ្ណសងតាមបញ្ជា ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជាបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគីដែលទទួលការទូទាត់សងប្រាក់ជួស ត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ការទូទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ត្រូវចាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ផ្នែកទី ៩

ច្បាប់ចម្លង

មាត្រា ១៨៧.-

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងប័ណ្ណសងតាមបញ្ជា ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យ បានត្រឹមត្រូវតាមច្បាប់ដើមជាមួយនឹងបិដ្ឋិលេខ និងសេច-ក្តីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់លាស់ នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខនិងធ្វើរូបិយបដិភោគ នៅក្នុងលក្ខណៈដូចគ្នា និងមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

មាត្រា ១៨៨.-

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើមត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើម ដែលមានចែងខាងលើឱ្យទៅអ្នកកាន់ស្របច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើរូបិយបដិភោគច្បាប់ចម្លង លុះត្រាតែបានបញ្ជាក់នៅលើវិបុទ្ធវាទថា ច្បាប់ដើមមិនទាន់ត្រូវបានប្រគល់មកវិញតាមសំណើរបស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ដើមមានបដិញ្ញាថា **ចាប់ផ្តើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិលេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ** ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខបន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

ផ្នែកទី ១០
ការកែលើបំណ្ណសងតាមបញ្ជា

មាត្រា ១៨៩.-

ក្នុងករណីមានការកែលើខ្លឹមសារនៃប័ណ្ណសងតាមបញ្ជា រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃប័ណ្ណសងតាមបញ្ជា ។

ផ្នែកទី ១១
រយៈពេលកំណត់នៃការធ្វើឱ្យបាស្រាំយ

មាត្រា ១៩០.-

រាល់ឧបាស្រាំយដែលកើតឡើងពីប័ណ្ណសងតាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណមានរយៈពេលបី (០៣) ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រាំយដែលធ្វើឡើងដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយមានរយៈពេលមួយ (០១) ឆ្នាំ គិតពីថ្ងៃធ្វើវិរុទ្ធភាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទានកាលបើមានបដិញ្ញាថា **បង្វិលចំញដោយគ្មានសោហ៊ុយ** ឬ **បង្វិលចំញដោយគ្មានវិរុទ្ធភាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រាំយរបស់អ្នកធ្វើបិដ្ឋិលេខទល់នឹងអ្នកធ្វើបិដ្ឋិលេខផងគ្នាមានរយៈពេលប្រាំមួយ (០៦) ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និងបានទូទាត់សងប័ណ្ណសងតាមបញ្ជា ឬ គិតពីថ្ងៃដែលបានទទួលរងការប្តឹង ។

មាត្រា ១៩១.-

ការកំណត់រយៈពេលធ្វើឧបាស្រាំយដូចមានចែងក្នុងមាត្រា ១៩០ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

ផ្នែកទី ១២

ការគណនារយៈពេលកំណត់

មាត្រា ១៩២.-

ប័ណ្ណសងតាមបញ្ជាដែលផុតរយៈពេលកំណត់ទូទាត់សងប្រាក់នៅថ្ងៃឈប់សម្រាកផ្លូវការនឹងត្រូវទូទាត់សងប្រាក់នៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងប័ណ្ណសងតាមបញ្ជា ជាពិសេសការបង្ហាញឱ្យទូទាត់សងប្រាក់ និងវិវុទ្ធ-វាទអាចត្រូវធ្វើឡើងតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

មាត្រា ១៩៣.-

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលជាមួយផងទេ នូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

មាត្រា ១៩៤.-

ទោះបីតាមផ្លូវច្បាប់ក្តី ឬ តាមផ្លូវតុលាការក្តីពុំអនុញ្ញាតឱ្យមានរយៈពេលអនុ-គ្រោះឡើយ ។

ជំពូកទី ៥

ប្រតិបត្តិការទូទាត់សងប្រាក់

ផ្នែកទី ១

កម្មវត្ថុនៃការអនុវត្ត

មាត្រា ១៩៥.-

ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ជារូបិយវត្ថុក្នុងស្រុក ឬ រូ-បិយប័ណ្ណណាមួយ ។ ជំពូកនេះកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកចូលរួមនិងអនុវត្ត

ចំពោះការរៀបចំប្រតិបត្តិការ ការត្រួតពិនិត្យ និងការគ្រប់គ្រងប្រព័ន្ធទូទាត់សងច្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៩៦.-

រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចបើកគណនីជារូបិយវត្ថុក្នុងស្រុក និងជារូបិយ-ប័ណ្ណ និងអាចធ្វើប្រតិបត្តិការទូទាត់សងច្រាក់តាមរយៈគណនីទាំងនេះ នៅក្រោមលក្ខខ័ណ្ឌដែលបានព្រមព្រៀងទៅតាមបទប្បញ្ញត្តិទាំងឡាយក្នុងផ្នែកទី ៧ នៃជំពូកនេះ ។ រូបវន្តបុគ្គលឬនីតិបុគ្គលអាចមានគណនីមួយ ឬ ច្រើនក្នុងធនាគារមួយ ឬ ច្រើនបាន ។

កថាខណ្ឌខាងលើនៃមាត្រានេះពុំបានបដិសេធចោល និងត្រូវអនុលោមតាមកាតព្វកិច្ចណាមួយដែលតម្រូវដោយច្បាប់ទាក់ទងទៅនឹងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកក៏ដូចជាការរឹតត្បិត ឬ ការផាក់កំហិតដោយច្បាប់ដែលពាក់ពន្ធ័ទៅនឹងប្រភេទ ឬ ផ្តាក់ជាក់លាក់របស់គណនី ឬរូបិយប័ណ្ណ ។

មាត្រា ១៩៧.-

បញ្ជាទូទាត់អាចត្រូវផ្តើដោយអតិថិជនណាមួយពីក្នុង ឬ ពីក្រៅព្រះរាជាណាចក្រកម្ពុជា និងទទួលដោយធនាគារណាមួយដែលមានទីតាំងនៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃជំពូកនេះ ហើយបទប្បញ្ញត្តិណាដែលពុំមានចែងទេ ត្រូវស្ថិតនៅក្រោមច្បាប់ដទៃទៀតដែលអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ។ កថាខណ្ឌនេះត្រូវអនុវត្តចំពោះការផ្តើពីក្នុង ឬ ពីក្រៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកផ្តើ និងធនាគារទទួល ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារដែលមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលសាខា ឬ ការិយាល័យដោយឡែកនោះបានចោះទីតាំង លើកលែងតែមាន

កិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកធ្វើ និងធនាគារទទួល ។

សិទ្ធិនិងកាតព្វកិច្ចរវាងធនាគារនិងអតិថិជនរបស់ខ្លួន ដែលទាក់ទងនឹងគណនី និងបញ្ជាទូទាត់ចូល ឬ ចេញ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែកដែលបានរក្សាគណនីទាំងនោះ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងធនាគារនិងអតិថិជនរបស់ខ្លួន ។

បញ្ជាពេលវេលានៃការទូទាត់សងប្រាក់ធ្វើឡើងដោយអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់មួយ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែករបស់ធនាគារគោលដៅ ។

បញ្ជាទូទាត់អាចត្រូវបញ្ជូនទៅធនាគារជាតិនៃកម្ពុជាឱ្យអនុវត្តការសងប្រាក់ចេញពី ឬ ចូលទៅក្នុងគណនីដែលបានបើកនៅទីនោះ ។ ក្នុងករណីនេះ ជំពូកនេះនឹងត្រូវអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាក្នុងនាមជាធនាគារមួយដែរ ។

នៅពេលណាដែលធនាគារទទួលយល់ព្រមអនុវត្តបញ្ជាដែលពុំមែនជាបញ្ជាទូទាត់ ដោយហេតុថាបញ្ជានោះជាកម្មវត្ថុនៃលិខិតឥណ្ណាមួយ បញ្ជាបែបនេះក៏ត្រូវបានចាត់ទុកថាជាបញ្ជាទូទាត់ដែរ ។ ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនត្រូវអនុវត្តចំពោះភារកិច្ច :

-របស់ធនាគារទទួលក្នុងការបញ្ជូនបន្តនូវលិខិតឥណ្ណាមួយទៅកាន់ធនាគារគោលដៅ និង

-របស់ធនាគារគោលដៅ ដើម្បីអនុវត្តលិខិតឥណ្ណនោះឡើយ ។

មាត្រា ១៩៨.-

សិទ្ធិអំណាចរបស់អ្នកទទួលក្នុងការផ្ទេរឥណពន្ធ មានដូចខាងក្រោម :

១-នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលអាចដកហូតសិទ្ធិអំណាចដែលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការដោយធ្វើសេចក្តីជូនដំណឹងដល់ធនាគារគោលដៅអំពីការដកហូតសិទ្ធិអំណាចនោះជាលាយលក្ខណ៍អក្សរ តាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់ក៏បាន បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនឱ្យធ្វើបែបនេះ ។ សេចក្តីជូនដំណឹងត្រូវតែធ្វើឡើងមុនពេលដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ និងក្នុងរយៈពេលនិងតាមវិធីត្រប់គ្រាន់ ដែលអាចឱ្យធនាគារគោលដៅមានឱកាស

សមស្របក្នុងការអនុវត្តតាម ។ ធនាគារគោលដៅត្រូវបង់សេចបញ្ជាទូទាត់ទាំងឡាយ ណារបស់អ្នកផ្តើ ដែលមានសេចក្តីជូនដំណឹងឱ្យដកហូតសិទ្ធិអំណាច ។

២-នៅក្នុងការផ្ទេរឥណពន្ធ សេចក្តីជូនដំណឹងបញ្ជាក់ពីមរណភាព ឬ សេចក្តីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីស្វាធុក្ខលនៃអ្នកទទួលដែលធនាគារ គោលដៅទទួលបាន មានប្រសិទ្ធភាពដូចគ្នានឹងសេចក្តីជូនដំណឹងរបស់អ្នកទទួលអំពី ការដកហូតសិទ្ធិអំណាច ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះដែរ ។

៣-អតិថិជនដែល :

-គណនីត្រូវបានកត់ត្រាឥណពន្ធតាមចំនួនប្រាក់ក្នុងបញ្ជាទូទាត់ នៃការផ្ទេរឥណពន្ធ

-តវ៉ាពីសិទ្ធិអំណាចរបស់អ្នកផ្តើមប្រតិបត្តិការ និង

-ជំទាស់ជាលាយលក្ខណ៍អក្សរនឹងការចុះឥណពន្ធក្នុងរយៈពេល ប្លន (០៤) ថ្ងៃបន្ទាប់ពីបានដឹងដំណឹងអំពីការចុះឥណពន្ធនេះ នៅក្នុងគណនីរបស់ខ្លួន អាចមានសិទ្ធិចុះបញ្ជាសការចុះឥណពន្ធនោះវិញ លើកលែងតែធនាគារគោលដៅ បានផ្តល់កស្តុតាងអំពីសិទ្ធិអំណាចដែលផ្តល់ដោយអតិថិជនទៅកាន់អ្នកផ្តើមប្រតិបត្តិ-ការនោះ ។

៤-តាមរយៈការអនុញ្ញាតឱ្យធ្វើការផ្ទេរឥណពន្ធ អ្នកទទួលធានាការទូទាត់សងប្រាក់ទៅអ្នកផ្តើមប្រតិបត្តិការ ។

៥-មាត្រានេះមិនអនុវត្តចំពោះសិទ្ធិអំណាចដែលអ្នកទទួលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការ តាមការចេញផ្សាយមូលប្បទានប័ត្រនោះទេ ។

ផ្នែកទី ២

បញ្ជាទូទាត់

មាត្រា ១៩៩.-

បញ្ជាទូទាត់ជាបញ្ជារបស់អ្នកផ្តើទៅធនាគារទទួល និងមិនប្រើជាការផ្ទេរមូល និធិឱ្យអ្នកចូលរួមណាមួយ ក្នុងប្រតិបត្តិការទូទាត់សងប្រាក់ឡើយ ។

បញ្ជាទូទាត់អាចធ្វើឡើងជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ អាចធ្វើ

ឡើងដោយផ្ទាល់មាត់ បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរវាងភាគី នៃបញ្ជាទូទាត់ ។ បើមានការព្រមព្រៀងដូច្នេះពីមុន និងជាកម្មវត្ថុនៃលក្ខខ័ណ្ឌក្នុងកិច្ច ព្រមព្រៀង ទំនាក់ទំនងជាបន្តបន្ទាប់មកទៀតរួមទាំងបញ្ជាបញ្ឈប់ផង ក៏អាចត្រូវធ្វើ ឡើងដោយផ្ទាល់មាត់បានដែរ ។

បញ្ជាទូទាត់ត្រូវកំណត់អត្តសញ្ញាណ អ្នកទទួលនិងធនាគារគោលដៅឱ្យ បានត្រឹមត្រូវ ។ នៅពេលណាដែលបញ្ជាទូទាត់កំណត់អត្តសញ្ញាណអ្នកចូលរួមណាមួយ នៅក្នុងប្រតិបត្តិការទូទាត់សងច្រាក់តាមប្រព័ន្ធស្វ័យប្រវត្តិដោយបញ្ជាក់ឈ្មោះ និង លេខកូដ ធនាគារទទួលពុំចាំបាច់បញ្ជាក់នូវសង្គតិភាពរវាងឈ្មោះ និង លេខកូដនោះ ឡើយ ហើយអាចសងច្រាក់ដោយផ្អែកតែលើលេខកូដប៉ុណ្ណោះ ។ នៅពេលណាដែល និយោជិតណាម្នាក់ជាអ្នកអនុវត្តបញ្ជាទូទាត់កត់សម្គាល់ឃើញថាឈ្មោះ និងលេខកូដ ពុំមានសង្គតិភាព ធនាគារទទួលត្រូវបដិសេធបញ្ជាទូទាត់នោះ ។

ធនាគារជាតិនៃកម្ពុជាអាចចេញបទបញ្ជាចែងអំពីលក្ខខ័ណ្ឌនានា ដែលនៅក្នុង នោះបញ្ជាទូទាត់ និងទំនាក់ទំនងផ្សេងៗទៀតរួមទាំងបញ្ជាបញ្ឈប់ផងដែរ អាចត្រូវបាន ធ្វើឡើងដោយផ្ទាល់មាត់ ។

មាត្រា ២០០.-

នៅក្នុងការផ្ទេរឥណទាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ធនា-គារទទួលមានកាតព្វកិច្ចអនុវត្តបញ្ជាទូទាត់របស់អ្នកធ្វើ តែក្នុងករណីដែលគណនីអ្នក ធ្វើមានសមតុល្យគ្រប់គ្រាន់ប៉ុណ្ណោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្តើមប្រតិបត្តិការត្រូវអនុវត្តបញ្ជាទូទាត់របស់ អ្នកផ្តើមប្រតិបត្តិការ បន្ទាប់ពីមានភស្តុតាងសមស្របអំពីសិទ្ធិអំណាចដែលអ្នកទទួល ប្រគល់ឱ្យ និងមានការជានាសងការខូចខាតវិញពីអ្នកផ្តើមប្រតិបត្តិការ ។ លើកលែង តែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារផ្តើមប្រតិបត្តិការពុំមានកាតព្វកិច្ចផ្តល់មូល-និធិដល់អ្នកផ្តើមប្រតិបត្តិការ ឬ សូម្បីធ្វើការចុះឥណទានបណ្តោះអាសន្នក្តី នៅមុន ពេលបញ្ចប់ការផ្ទេរឥណពន្ធ ។ បើគណនីរបស់អ្នកផ្តើមប្រតិបត្តិការត្រូវបានចុះឥណ-ទានដោយធនាគារផ្តើមប្រតិបត្តិការ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ការចុះ

ឥណទាននោះត្រូវមានលក្ខណៈបណ្តោះអាសន្ន ហើយគណនីអ្នកផ្តើមប្រតិបត្តិការអាច
នឹងត្រូវចុះឥណពន្ធវិញក្នុងចំនួនច្រាក់ស្មើនឹងការចុះឥណទាន បើការផ្ទេរឥណពន្ធពុំត្រូវ
បានបញ្ចប់ដូចដែលបានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះទេ ។

ធនាគារទទួល ត្រូវអនុវត្តតែបញ្ជាទូទាត់ណាដែល :

- បានបំពេញសេចក្តីត្រឹមត្រូវ និងបានការអនុញ្ញាត ឬ មានយថាភាព
- បានកំណត់អត្តសញ្ញាណធនាគារគោលដៅត្រឹមត្រូវ
- បានពណ៌នាអំពីអ្នកទទួលដោយច្រាកដប្រជា ។

ធនាគារទទួលដែលមិនអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវជូនដំណឹងដល់អ្នក
ផ្ញើជាបន្ទាន់អំពីការបដិសេធ ឬ ការមិនទទួលរបស់ខ្លួន ។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ និងមិនគិតដល់ការយកសោហ៊ុយ
ដូចដែលបានព្រមព្រៀង ឬ ដែលជាទម្លាប់ក្តី ធនាគារទទួលត្រូវអនុវត្តបញ្ជាទូទាត់
តាមចំនួនច្រាក់ដែលបានបញ្ជាដោយអ្នកផ្ញើ ។

ធនាគារទទួលត្រូវអនុវត្តបញ្ជាទាំងឡាយ ដែលមាននៅក្នុងបញ្ជាទូទាត់នៅថ្ងៃធ្វើ
ការដែលធនាគារទទួលបានបញ្ជានោះ ឬ នៅថ្ងៃប្រសិទ្ធភាពរបស់បញ្ជាទូទាត់នោះ
បើមាន ដែលជាទូទៅគឺនៅពេលក្រោយមកទៀត ។ ធនាគារទទួលអាចកំណត់ពេល
ម៉ោងកំណត់សម្រាប់អនុវត្តបញ្ជាទូទាត់ ។ រាល់បញ្ជាទូទាត់ណាដែលបានទទួលក្រោយ
ពេលកំណត់នេះ ត្រូវបានចាត់ទុកថាបានទទួលនៅថ្ងៃធ្វើការបន្ទាប់របស់ធនាគារ ។

ធនាគារផ្តើមប្រតិបត្តិការនៅក្នុងការផ្ទេរឥណទាន នឹងធនាគារគោលដៅ នៅ
ក្នុងការផ្ទេរឥណពន្ធដែលបានទទួលបញ្ជាទូទាត់លើសពីមួយក្នុងអំឡុងថ្ងៃធ្វើការរបស់
ធនាគារ ឬ បញ្ជាស្របច្បាប់ដទៃទៀត ដើម្បីដកមូលនិធិចេញពីគណនី អាចនឹងអនុ-
វត្តបញ្ជាទាំងនោះតាមលំដាប់លំដោយណាក៏បាន លើកលែងតែមានការចែងផ្សេងពី
នេះ នៅក្នុងច្បាប់ផ្សេងទៀត ។

ធនាគារទទួលត្រូវមានការប្រុងប្រយ័ត្នជានិច្ចក្នុងការអនុវត្តបញ្ជាទូទាត់ ។ ធនា-
គារទទួលត្រូវប្រុងប្រយ័ត្នក្នុងការបកស្រាយបញ្ជាទូទាត់ដែលមិនច្បាស់លាស់ ហើយ
ធ្វើសកម្មភាពដោយស្មោះត្រង់ និងត្រូវអនុវត្តបញ្ជាទូទាត់ទៅតាមអត្ថន័យសមស្រប
ដោយមិនចាំច់ស្វែងយល់ថាការបកស្រាយនោះជាការផ្ទុយពីបំណងរបស់អ្នកផ្ញើឡើយ ។

ក្នុងការទទួលបញ្ជាទូទាត់ និងធ្វើសកម្មភាពនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ និងទោះបីជាមានកិច្ចព្រមព្រៀងផ្ទុយពីនេះក៏ដោយ ធនាគារទទួលត្រូវតែគោរពតាមច្បាប់នេះ ព្រមទាំងបទបញ្ជា ឬ សេចក្តីណែនាំទាំងឡាយដែលពាក់ព័ន្ធក៏ដូចជាច្បាប់ដទៃទៀតដែរ ។ ធនាគារត្រូវធ្វើសកម្មភាពដោយយកចិត្តទុកដាក់ និងសុចរិតស្របតាមស្តង់ដារួមរបស់ធនាគារ និងត្រូវជួយដល់អ្នកចូលរួមនានាក្នុងការបញ្ចប់ប្រតិ-បត្តិការទូទាត់សងប្រាក់ដោយត្រឹមត្រូវ ។ នៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ធនាគារត្រូវរក្សាការសម្ងាត់ និងធ្វើសកម្មភាពជាប្រយោជន៍ខ្ពស់បំផុតរបស់អ្នកធ្វើ ។

ជាកម្មវត្ថុនៃកាតព្វកិច្ចរក្សាការសម្ងាត់ នៅក្រោមច្បាប់នានាដែលកំពុងអនុវត្ត ធនាគារទទួល ដែលបានបញ្ជាឱ្យបញ្ឈប់ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈធនាគារអន្តរការី ឬ ទៅកាន់ធនាគារគោលដៅដែលខ្លួនវិនិច្ឆ័យថាពុំអាចទុកចិត្តបានក្នុងកាលៈទេសៈនោះ ត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកធ្វើអំពីការបារម្ភរបស់ខ្លួន ។ ប៉ុន្តែនៅពេលណាដែលធនាគារទទួលនៅតែបានទទួលបញ្ជាឱ្យបញ្ឈប់ប្រតិបត្តិការផ្ទុយពីការជូនដំណឹងរបស់ខ្លួន ធនាគារទទួលអាចបដិសេធមិនទទួលបញ្ជាទូទាត់នោះ ឬ ដោយមិនគិតដល់បទប្បញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់នេះ អាចប្រតិបត្តិបញ្ជានោះដោយអ្នកធ្វើត្រូវទទួលភ៌ប់រងហានិភ័យ ។

មាត្រា ២០១.-

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ រវាងអ្នកធ្វើ និង ធនាគារទទួល បញ្ជាទូទាត់អាចត្រូវបដិសេធឬបញ្ឈប់បាន ។ បញ្ជាទូទាត់នឹងត្រូវបានបញ្ឈប់ដោយអ្នកធ្វើ នៅពេលណាដែលបញ្ជាបញ្ឈប់មានការអនុញ្ញាត ឬ មានការបញ្ជាក់ត្រឹមត្រូវដោយអ្នកធ្វើឬក្នុងនាមអ្នកធ្វើ ត្រូវបានទទួលដោយធនាគារទទួលនៅក្នុងពេល និងតាមវិធីដែលធនាគារអាចធ្វើការបញ្ឈប់បញ្ជាទូទាត់នៅមុនពេលអនុវត្ត ។

ទោះបីជាបន្ទាប់ពីបានប្រតិបត្តិបញ្ជាទូទាត់របស់អ្នកធ្វើរួចហើយក្តី តាមការស្នើសុំរបស់អ្នកធ្វើ ធនាគារដែលបានទទួលនិងប្រតិបត្តិបញ្ជានេះអាចចេញបញ្ជាបញ្ឈប់ឱ្យទៅធនាគារទទួលរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។ បញ្ជា

បញ្ឈប់ដែលចេញដោយអ្នកធ្វើទៅកាន់ធនាគារគោលដៅនៅក្នុងប្រតិបត្តិការទូទាត់សងច្រាក់នឹងមានប្រសិទ្ធភាពតែនៅពេលណាដែលបញ្ជាបញ្ឈប់នោះបានទៅដល់ធនាគារគោលដៅ នៅមុនពេលដែលប្រតិបត្តិការទូទាត់សងច្រាក់ត្រូវបានបញ្ចប់ប៉ុណ្ណោះ ។

បញ្ជាបញ្ឈប់ត្រូវតែកត់សម្គាល់បញ្ជាទូទាត់ ដែលត្រូវបញ្ឈប់នោះឱ្យបានច្បាស់លាស់ និងត្រូវបានបញ្ជូនទៅធនាគារទទួលជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីមុនរវាងភាគីនៃបញ្ជាទូទាត់ ។

បញ្ជាទូទាត់ដែលពុំទាន់បានអនុវត្តដោយធនាគារទទួលត្រូវបានដកមកវិញនៅក្នុងករណីដូចតទៅ :

-នៅពេលបញ្ចប់ថ្ងៃធ្វើការទីប្រាំរបស់ធនាគារទទួល ឬ ក្នុងរយៈពេលខ្លីជាងនេះតាមការព្រមព្រៀងគ្នា បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ឬ នៅថ្ងៃប្រសិទ្ធភាពនៃបញ្ជាទូទាត់ ដែលជាទូទៅនៅពេលក្រោយមកទៀត

-នៅពេលណាដែលធនាគារទទួលបានដឹងអំពីមរណភាព ឬ សេចក្តីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីត្យានុកូលនៃអ្នកធ្វើ ឬ

-នៅពេលណាដែលធនាគារទទួលត្រូវបានបិទដោយអាជ្ញាធរត្រួតពិនិត្យ ។

ការបញ្ឈប់ឬការដកមកវិញនូវបញ្ជាទូទាត់នឹងមិនមានប្រសិទ្ធភាពទេ បន្ទាប់ពីប្រតិបត្តិការទូទាត់សងច្រាក់នោះ ត្រូវបានបញ្ចប់ជាស្ថាពរ ។

មាត្រា ២០២.-

ការទូទាត់បញ្ជាទូទាត់អន្តរធនាគារ និងពេលវេលាសម្រាប់ការទូទាត់ត្រូវបានកំណត់ដូចតទៅ :

១-ការទូទាត់ចំពោះបញ្ជាទូទាត់អន្តរធនាគារ អាចធ្វើឡើង :

ក-នៅលើគណនីទូទាត់របស់បណ្តាធនាគារនៅធនាគារជាតិនៃកម្ពុជា ដែលនៅក្នុងករណីនេះ ត្រូវស្ថិតក្រោមបទបញ្ជាទាក់ទងនឹងសកាដាត់ទាត់ដែល

ចេញដោយធនាគារជាតិនៃកម្ពុជា

ខ-តាមរយៈការកត់ត្រាឥណពន្ធ ឬ ឥណទានទៅក្នុងគណនីផ្សេងពីគណនីទូទាត់ ដែលធនាគារមួយមាននៅធនាគារមួយទៀត ឬ នៅធនាគារទីបី ។ ការចុះឥណពន្ធ ឬ ឥណទានបែបនេះអាចធ្វើឡើងសម្រាប់បញ្ជាទូទាត់នីមួយៗដោយឡែកពីគ្នា ឬ សម្រាប់បញ្ជាទូទាត់ជាសំណុំ ដែលក្នុងករណីណាក៏ដោយ ក៏ត្រូវធ្វើឡើងនៅចុងគ្រានៃការជាត់ទាត់ដែរ

គ-តាមមធ្យោបាយផ្សេងទៀត ដែលអាចសម្រេចកាតព្វកិច្ចបាន ។

២-ពេលវេលាសម្រាប់ការទូទាត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះមានដូចតទៅ :

ក-នៅក្រោមកថាខណ្ឌទី ១-ក នៅពេលណាដែលការទូទាត់ត្រូវបានបញ្ចប់ក្រោមបទបញ្ជាទាក់ទងនឹងសភាជាត់ទាត់ដែលចេញដោយធនាគារជាតិនៃកម្ពុជា

ខ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណពន្ធគណនីមួយ នៅពេលណាដែលខ្នង់ឥណពន្ធត្រូវបានកត់ត្រាទៅក្នុងគណនី

គ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណទានគណនីមួយ នៅពេលណាខ្នង់ឥណទានដែលបានកត់ត្រាក្នុងគណនីត្រូវបានប្រើប្រាស់ ឬ បើមិនបានប្រើប្រាស់ គឺនៅពេលចាប់ផ្តើមថ្ងៃធ្វើការបន្ទាប់ដែលមានខ្នង់ឥណទានសម្រាប់ប្រើប្រាស់ ហើយធនាគារបានដឹងអំពីការចុះឥណទានក្នុងគណនីរបស់ខ្លួន

ឃ-នៅក្នុងកថាខណ្ឌទី ១-គ អនុលោមតាមច្បាប់ដែលបានកំណត់អំពីពេលសម្រេចកាតព្វកិច្ច ។

៣-កថាខណ្ឌនេះត្រូវអនុវត្តកាលបើការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ នៃមាត្រានេះកើតមានឡើងដោយអនុលោមតាមកិច្ចព្រមព្រៀង ឬ វិធានដែលអនុវត្តចំពោះការបញ្ចប់ការទូទាត់អន្តរធនាគារក្រៅធនាគារជាតិនៃកម្ពុជា និង សម្រាប់បញ្ជាទូទាត់សងច្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគី ។ ទោះបីជាមានកថាខណ្ឌទី ២-ខ នៃមាត្រានេះក៏ដោយ ការទូទាត់បែបនេះកើតមានឡើងនៅពេលដែលការទូទាត់សងនេះ ត្រូវបានបញ្ចប់តាមកិច្ចព្រមព្រៀង ឬ វិធាន ។

៤-បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាអាចរឹតត្បិត ឬ គ្រប់គ្រងលើកាលៈទេសៈ ដែលក្នុងនេះការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ ឬ គ នៃមាត្រានេះអាចកើតមានឡើង ក៏អាចជាអាចកែប្រែពេលវេលាសម្រាប់ការទូទាត់ ។

៥-ដោយមិនគិតដល់អ្វីដែលមានចែងនៅក្នុងច្បាប់ណាមួយ ដែលទោះជាទាក់ទងឬមិនទាក់ទងដល់បណ្តឹងអំពីអសាធនភាពទល់នឹងធនាគារ មិនត្រូវ :

-មានឥទ្ធិពលប្រតិសកម្មលើសិទ្ធិ និងកាតព្វកិច្ចដែលកើតឡើងពី ឬ ដែលពាក់ព័ន្ធជាមួយការជាត់ទាត់ និងការទូទាត់បញ្ជាទូទាត់ឡើយ ក្រៅពីនៅពេលវេលាដែលបណ្តឹងអំពីអសាធនភាពនោះ ត្រូវបានធ្វើ ឬ

-មានផលប៉ះពាល់ទៅលើប្រសិទ្ធភាព និងការអនុវត្តបាននៃបញ្ជាទូទាត់ដែលទទួលបានដោយធនាគារទទួល នៅមុនពេលមានបណ្តឹងអំពីអសាធនភាពនេះ និងមុនពេលការទូទាត់សងប្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគីព្រមទាំងមុនពេលមានការផ្តល់ការជានាណាមួយ ។

៦-ដើម្បីគោលបំណងនៃកថាខណ្ឌទី ៥ នៃមាត្រានេះ និងកថាខណ្ឌទី ២ នៃមាត្រាទី ២២៧ នៃច្បាប់នេះ **បណ្តឹងអំពីអសាធនភាព** គឺជាវិធានការរួមដែលកំណត់ដោយច្បាប់ដើម្បីជំរះបញ្ហី បញ្ចប់សកម្មភាព ឬ ដើម្បីរៀបចំធនាគារឡើងវិញ ទោះដោយស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្តក្តី ហើយពេលវេលានៃការបើកបណ្តឹងអំពីអសាធនភាព ជាពេលវេលាដែលអាជ្ញាធរតុលាការ ឬ រដ្ឋបាលពាក់ព័ន្ធប្រកាសអំពីសេចក្តីសម្រេចរបស់ខ្លួន ។

ផ្នែកទី ៣
អ្នកដំណើរការតតិយភាគី

មាត្រា ២០៣.-

ក្នុងការអនុវត្តផ្នែកណាមួយនៃប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារអាចប្រើប្រាស់អ្នកដំណើរការតតិយភាគី ។ ដូចដែលបានអនុញ្ញាតដោយធនាគារ អ្នកដំណើរការតតិយភាគីអាចធ្វើការក្នុងនាមធនាគារដែលបានផ្តល់សិទ្ធិជា :

-អ្នកទំនាក់ទំនង

-អ្នកជាត់ទាត់អន្តរធនាគារ ដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅកាន់ធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

-ភ្នាក់ងារគ្រប់គ្រងនិងប្រតិបត្តិការ សម្រាប់ធនាគារដែលមានគណនីអតិថិជន និង/ឬ

-កន្លែងធ្វើនិងទទួលបញ្ជាទូទាត់ដែលត្រូវបានធ្វើឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការធ្វើ និងទទួលបញ្ជាទូទាត់ ។

មាត្រា ២០៤.-

អ្នកជំណើរការតតិយភាគីត្រូវគោរពតាមរាល់កាតព្វកិច្ច ល័ក្ខខ័ណ្ឌ និងការរឹត-ត្បិតទាំងឡាយដែលកំណត់ដោយបទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ។ បទបញ្ជាទាំងនោះអាចចែងអំពីការផ្តល់អាជ្ញាប័ណ្ណ បញ្ជីកម្ម ការត្រួតពិនិត្យ និងអាចអនុវត្តចំពោះអ្នកជំណើរការតតិយភាគីគ្រប់ប្រភេទទាំងអស់ ។ ប្រភេទផ្សេងគ្នានៃអ្នកជំណើរការតតិយភាគី តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា អាចស្ថិតក្រោមកាតព្វកិច្ចខុសៗគ្នា ។

ធនាគារមួយអាចធ្វើជាអ្នកជំណើរការតតិយភាគីក្នុងនាមធនាគារមួយទៀត ។

មាត្រា ២០៥.-

ក្រៅពីការទទួលខុសត្រូវរវាងធនាគារនិងអ្នកជំណើរការតតិយភាគី ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកជំណើរការតតិយភាគីធ្វើសកម្មភាពជួសមុខឱ្យ ត្រូវទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬ កំហុសរបស់អ្នកជំណើរការតតិយភាគីនោះ ។

ដើម្បីធានាការគោរពតាមច្បាប់នេះនិងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀត ធនា-គារត្រូវធានាថា អ្នកជំណើរការតតិយភាគីត្រូវធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួន ចំពោះហេតុការណ៍ទាំងឡាយដែលបុគ្គលនេះបានធ្វើសកម្មភាពជួសមុខឱ្យ ហើយធនាគារមិនអាចបដិសេធការគ្រប់គ្រង និងការ

ត្រួតពិនិត្យនេះទេ ។

មាត្រា ២០៦.-

អ្នកជំណើរការតតិយភាគីត្រូវបដិសេធបញ្ជាទូទាត់ដែលអតិថិជនរបស់ធនាគារ ធ្វើមកខ្លួនដោយផ្ទាល់ លើកលែងតែ :

ក-បញ្ជាទូទាត់នោះត្រូវបានធ្វើមក ដោយការប្រគល់សិទ្ធិរបស់ធនាគារ

ខ-នៅក្នុងករណីនៃការផ្ទេរឥណទាន

-អ្នកជំណើរការតតិយភាគីធ្វើសកម្មភាពក្នុងនាមធនាគារ ជាភ្នាក់ងារគ្រប់គ្រង ឬ ប្រតិបត្តិការលើគណនីអតិថិជន ហើយគណនីអតិថិជននោះមានសមតុល្យគ្រប់គ្រាន់

-អ្នកជំណើរការតតិយភាគី បានទទួលការអនុញ្ញាតពីធនាគារ ។

បញ្ជាទូទាត់របស់អតិថិជនដែលអនុវត្តដោយអ្នកជំណើរការតតិយភាគី ត្រូវបានចាត់ទុកថា ជាបញ្ជាពីអតិថិជនទៅកាន់ធនាគាររបស់ខ្លួន អនុវត្តតាមបញ្ជាទូទាត់នេះ ធនាគារធ្វើបញ្ជាទូទាត់ធ្វើទៅអ្នកជំណើរការតតិយភាគី ដើម្បីបញ្ជូនបន្តទៅកាន់ធនាគារទទួល ។

នៅពេលណាដែលធនាគារមួយផ្តល់សិទ្ធិដល់អ្នកជំណើរការតតិយភាគីឱ្យធ្វើជាកន្លែងទទួលបញ្ជាទូទាត់ទាំងឡាយដែលធ្វើមកធនាគារ បញ្ជាទូទាត់ដែលបានទទួលដោយអ្នកជំណើរការតតិយភាគី ត្រូវបានចាត់ទុកថាបានទទួលដោយធនាគារទទួល ។

ផ្នែកទី ៤

ការបញ្ចប់ការផ្ទេរឥណទានចិនការសងចំណុល

មាត្រា ២០៧.-

ការផ្ទេរឥណទានត្រូវបានបញ្ចប់ក្នុងករណីដូចខាងក្រោម :

១-ការផ្ទេរឥណទានឹងត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅបានទទួលប្រាក់ ។ ចំពោះការផ្ទេរផ្ទៃក្នុង ធនាគារបានទទួលការសងប្រាក់នៅពេលណាដែលខ្លួនបានកត់ត្រាឥណពន្ធក្នុងគណនីរបស់អ្នកផ្តើមប្រតិបត្តិការនូវចំនួនប្រាក់

នៃបញ្ជាទូទាត់ ។ ចំពោះការផ្ទេរឥណទានអន្តរធនាគារ ធនាគារគោលដៅបានទទួលប្រាក់នៅពេលណាដែលការទូទាត់អន្តរធនាគាររួមទាំងបញ្ជាទូទាត់របស់ធនាគារថ្មីផងនោះ ត្រូវបានបញ្ចប់ ។

២-ការផ្ទេរឥណទានត្រូវបានបញ្ចប់ នៅពេលចាប់ផ្តើមថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃដែលធនាគារគោលដៅបានទទួលបញ្ជាទូទាត់ ឬ បន្ទាប់ពីថ្ងៃប្រសិទ្ធភាពដែលជាថ្ងៃក្រោយមកទៀត បើនៅពេលនោះ អ្នកផ្ញើមានចំនួនប្រាក់គ្រប់គ្រាន់សម្រាប់ចុះឥណទាននៅធនាគារគោលដៅ និងលើកលែងតែធនាគារគោលដៅបដិសេធបញ្ជាទូទាត់មិនយឺតជាងមួយម៉ោងក្រោយមក ។

៣-នៅពេលណាដែលអ្នកទទួលពុំមានគណនីជាមួយនិងធនាគារគោលដៅពីមុនមកទេ ឬ នៅពេលណាដែលគណនីនោះ ត្រូវបិទ ឬ ភាំងខ្ទប់ចំពោះការសងប្រាក់ចូល ការផ្ទេរឥណទានត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅសងប្រាក់ឱ្យទៅអ្នកទទួល ។

មាត្រា ២០៨.-

នៅពេលបញ្ចប់ការផ្ទេរឥណទាន ធនាគារគោលដៅនឹងក្លាយទៅជាអ្នកជំពាក់បំណុលចំពោះអ្នកទទួលតាម ចំនួនប្រាក់នៃបញ្ជាទូទាត់ដែលខ្លួនបានទទួល ហើយក្រោយពីការដកចេញកម្រៃសេវាសមស្រប ធនាគារនោះត្រូវសងប្រាក់ឱ្យទៅអ្នកទទួលភ្លាម ។

ការសងប្រាក់ឱ្យទៅអ្នកទទួលដោយធនាគារគោលដៅ ត្រូវធ្វើឡើងតាមរយៈការចុះឥណទានគណនីអ្នកទទួលមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីការផ្ទេរឥណទានត្រូវបានបញ្ចប់ ។ នៅពេលណាដែលពុំមានគណនីរបស់អ្នកទទួលប្រាក់ ឬ ពុំអាចសម្គាល់គណនីឱ្យបានច្បាស់លាស់គ្រប់គ្រាន់ទេ ឬ នៅពេលណាដែលមានការបញ្ជាបែបនេះ ធនាគារគោលដៅត្រូវផ្តល់ដំណឹងភ្លាមដល់អ្នកទទួលអំពីការដែលខ្លួនមានមូលនិធិនៅក្នុងដៃ និងត្រូវសងឱ្យទៅអ្នកទទួល ។

នៅពេលណាដែលអ្នកទទួល ឬ គណនីអ្នកទទួលពុំត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ដែលធនាគារគោលដៅបានទទួល ជាហេតុនាំឱ្យមានការសង្ស័យ

អំពីអត្តសញ្ញាណអ្នកទទួល ធនាគារគោលដៅមិនត្រូវទទួលបញ្ជាទូទាត់នោះឡើយ ហើយត្រូវផ្តល់ដំណឹងដល់អ្នកផ្ញើពីការមិនទទួលនេះ ។

នៅពេលណាដែលធនាគារគោលដៅបានសងប្រាក់ឱ្យទៅអ្នកទទួល ឬ បានសន្យាថាសងប្រាក់ឱ្យទៅអ្នកទទួលជាមុន ការសងប្រាក់ ឬ ការសន្យានេះត្រូវមានលក្ខណៈស្ថាពរនិងមិនអាចកែប្រែបាន ហើយការផ្ទេរឥណទានត្រូវចាត់ទុកថាបានបញ្ចប់ ប៉ុន្តែអ្នកផ្ញើអាចនៅជំពាក់ធនាគារទទួលរបស់ខ្លួន ។ ការសន្យាសងប្រាក់របស់ធនាគារគោលដៅអាចត្រូវធ្វើដោយផ្ទាល់ជាមួយអ្នកទទួល ឬ តាមកិច្ចព្រមព្រៀងអន្តរធនាគារ ។

មាត្រា ២០៩.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានធ្វើឡើងដើម្បីសងបំណុល ដែលអ្នកផ្តើមប្រតិបត្តិការបានជំពាក់អ្នកទទួល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ ។ ការទូទាត់សងមានកម្រិតត្រឹមចំនួនប្រាក់ដែលបានសងនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់តែប៉ុណ្ណោះ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ បន្ទាប់ពីអ្នកទទួលយល់ព្រមធ្វើការជានាលើការទូទាត់សងប្រាក់ ឬ ការជានាលើការទូទាត់សងប្រាក់នោះ ត្រូវបានបញ្ជាក់ដោយធនាគារគោលដៅទៅអ្នកទទួល លើកលែងតែក្នុងកាលៈទេសៈមួចមានចែងក្នុងកថាខណ្ឌទី ៣ មាត្រា ២០៧ នៃច្បាប់នេះ ។

អ្នកជានាឬធនាគារគោលដៅដែលបានជានាឬបញ្ជាក់អំពីការទូទាត់សងប្រាក់ក្រោមកថាខណ្ឌខាងលើត្រូវទទួលរ៉ាប់រងទូទាត់សងប្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកទទួលនូវចំនួនប្រាក់ដែលបានជានាឬបញ្ជាក់នោះ ។

ផ្នែកទី ៥

ការបញ្ចប់ការផ្ទេរឥណទានឆ្លងនិងការសងបំណុល

មាត្រា ២១០.-

ការផ្ទេរឥណទានត្រូវបានបញ្ចប់ក្នុងករណីមួចខាងក្រោម :

១-ការផ្ទេរឥណពន្ធនឹងត្រូវបានបញ្ចប់ នៅពេលណាដែលធនាគារគោលដៅកត់ត្រាឥណពន្ធគណនីរបស់អ្នកទទួល ដូចដែលបានបញ្ជាក់នៅក្នុងបញ្ជាទូទាត់ដែលខ្លួនបានទទួលហើយពុំបានចុះបញ្ជាសឥណពន្ធ និងពុំបានបដិសេធបញ្ជាទូទាត់រហូតដល់ចុងថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។ នៅពេលណាដែលបញ្ជាទូទាត់បញ្ជាទៅធនាគារគោលដៅ ឱ្យចុះឥណពន្ធលើគណនីណាមួយដែលបើកនៅធនាគារនោះ ការផ្ទេរឥណពន្ធនឹងត្រូវបញ្ចប់នៅពេលចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ទោះបីជាមុនការកត់ត្រាឥណពន្ធលើគណនីអ្នកទទួលក៏ដោយ និងបើរហូតមកទល់ពេលនោះពុំមានការបដិសេធសមស្របចំពោះបញ្ជាទូទាត់នោះទេ ។

២-រហូតដល់ពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ធនាគារគោលដៅអាចបដិសេធបញ្ជាទូទាត់នោះបាន ។ ធនាគារគោលដៅមានសិទ្ធិដែលទទួលបានពីអ្នកផ្ញើរបស់ខ្លួន ដើម្បីទូទាត់ចំនួនប្រាក់ឱ្យទៅអ្នកផ្ញើនោះវិញដោយជូនដំណឹងអំពីការបដិសេធរបស់ខ្លួនដល់អ្នកផ្ញើ និងធនាគារផ្តើមប្រតិបត្តិការ បើអ្នកទាំងពីរនេះជាធនាគារពីរផ្សេងគ្នា ។ ការបដិសេធ និង ការទទួលសិទ្ធិពីអ្នកផ្ញើមានលក្ខណៈស្ម័យប្រវត្តិតាមច្បាប់ នៅពេលណាដែលធនាគារទទួលត្រូវបានបិទទ្វារដោយអាជ្ញាធរត្រួតពិនិត្យមុនពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។

៣-នៅពេលបានទទួលសេចក្តីជូនដំណឹងពីការបដិសេធ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្តើមប្រតិបត្តិការត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួន និងមានសិទ្ធិដូចគ្នានេះ ក្នុងការទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើនោះ ។ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្តើមប្រតិបត្តិការ ត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួនអំពីការបដិសេធនោះមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីការបដិសេធ ។

៤-នៅពេលបានទទួលដំណឹងពីការបដិសេធ ធនាគារផ្តើមប្រតិបត្តិការត្រូវផ្តល់ដំណឹងភ្លាមដល់អ្នកផ្តើមប្រតិបត្តិការអំពីការបដិសេធនោះ ដោយមិនឱ្យហួសពីមួយថ្ងៃធ្វើការបន្ទាប់របស់ធនាគារ និងអាចចុះបញ្ជាសឥណទានដែលបានកត់ត្រា

ជាបណ្តោះអាសន្ននៅគ្រាមុនទៅក្នុងគណនីអ្នកផ្តើមប្រតិបត្តិការ ឬ ម៉្យាងទៀតអាចប្រមូលពីអ្នកផ្តើមប្រតិបត្តិការមកវិញនូវការទូទាត់សងច្រាក់ដែលបានធ្វើនៅពេលមុន ចំពោះបញ្ជាទូទាត់នោះ ។

៥-ថ្វីបើមានកថាខណ្ឌទី២នៃមាត្រានេះក្តី ធនាគារគោលដៅត្រូវទទួលខុសត្រូវចំពោះមុខអ្នកទទួល ក្នុងការមិនទូទាត់សងច្រាក់ដោយខុសឆ្គង នៅពេលណាដែលខ្លួនបានបដិសេធបញ្ជាទូទាត់នោះ ដោយមិនត្រឹមត្រូវតាមច្បាប់ ឬ ដោយគ្មានមូលហេតុស្របច្បាប់ :

-ទោះបីជាមានការយល់ឃើងអំពីសិទ្ធិរបស់អ្នកទទួលចំពោះការផ្ទេរឥណពន្ធក្តី

-ទោះបីជាមានអត្តសញ្ញាណច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ទទួលដោយធនាគារ ដែលមានគណនីអ្នកទទួលហើយក្តី និង

-ទោះបីមានសមតុល្យគ្រប់គ្រាន់ក្នុងគណនីក្តី ។

៦-រយៈពេលដែលបានកំណត់តាមមាត្រា ២១០ និងមាត្រា ២១១ នៃច្បាប់នេះអាចត្រូវបានបង្រួញដោយកិច្ចព្រមព្រៀង ឬ បទបញ្ជា ។

មាត្រា ២១១.-

នៅពេលបញ្ចប់ការផ្ទេរឥណពន្ធ ធនាគារគោលដៅ និង ធនាគារទទួលនីមួយៗ ដែលបានទទួលការសងច្រាក់ពីធនាគារទទួលរបស់ខ្លួន ត្រូវទទួលខុសត្រូវចំពោះអ្នកផ្ទេរបស់ខ្លួននូវចំនួនច្រាក់ដែលខ្លួនបានទទួលនោះ ។ ការសងច្រាក់ដោយធនាគារគោលដៅឱ្យទៅអ្នកផ្ទេរបស់ខ្លួនត្រូវមានចំនួនស្មើនឹងខ្នង់ឥណពន្ធដែលបានចុះនៅលើគណនីអ្នកទទួល និងត្រូវធ្វើឡើងមិនហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានបញ្ចប់ការផ្ទេរឥណពន្ធនោះ ។ ការសងច្រាក់ដោយធនាគារទទួលផងទៀតត្រូវធ្វើឡើងមិនហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលការទូទាត់សងរបស់ខ្លួន ។

នៅពេលបានទទួលច្រាក់រួច និងជាកម្មវត្ថុនៃការចុះបញ្ជាលនៅក្នុងកថាខណ្ឌទី ៣ មាត្រា ១៩៨ នៃច្បាប់នេះ ធនាគារផ្តើមប្រតិបត្តិការត្រូវជំពាក់អ្នកផ្តើមប្រតិ-បត្តិការនូវចំនួនច្រាក់ដែលខ្លួនបានទទួល ។ ក្នុងករណីនេះ ខ្នង់ឥណទានបណ្តោះអា-

សន្ធទាំងឡាយ ដែលបានផ្តល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការត្រូវចូលជាស្ថាពរ ។ មុនពេលដែលឥណទានចូលជាស្ថាពរ ពុំត្រូវមានការទាមទារឱ្យធនាគារផ្តើមប្រតិបត្តិការផ្តល់មូលនិធិឱ្យទៅអ្នកផ្តើមប្រតិបត្តិការទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការផ្តល់មូលនិធិណាមួយ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ត្រូវមានលក្ខណៈបណ្តោះអាសន្នរហូតដល់ពេលបញ្ចប់តែម្តង ។

មាត្រា ២១២.-

នៅពេលណាដែលការផ្ទេរឥណពន្ធតាមការប្រគល់សិទ្ធិត្រូវបានធ្វើឡើង ដើម្បីសងបំណុលដែលអ្នកទទួលបានជំពាក់អ្នកផ្តើមប្រតិបត្តិការ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងច្រាក់ត្រូវបានបញ្ចប់ ។ ការរួចផុតពីបំណុលមានកម្រិតត្រឹមចំនួនច្រាក់ដែលបានទូទាត់សងនៅពេលបញ្ចប់ប្រតិបត្តិការ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងច្រាក់ ប្រសិនបើ និងនៅពេលណាដែលការជានាលើការទូទាត់សងច្រាក់ត្រូវបានយល់ព្រមដោយអ្នកផ្តើមប្រតិបត្តិការ ឬ ត្រូវបានបញ្ជាក់ដោយធនាគារផ្តើមប្រតិបត្តិការទៅអ្នកផ្តើមប្រតិបត្តិការ ។

អ្នកជានា ឬ ធនាគារផ្តើមប្រតិបត្តិការដែលបានជានាឬបញ្ជាក់អំពីការទូទាត់សងច្រាក់ក្រោមកថាខណ្ឌខាងលើ ត្រូវទទួលរ៉ាប់រងទូទាត់សងច្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកផ្តើមប្រតិបត្តិការនូវចំនួនច្រាក់ដែលបានជានា ឬ បញ្ជាក់នោះ ។

ផ្នែកទី ៦

ការទទួលខុសត្រូវ ការខូចខាត និងសំណង

មាត្រា ២១៣.-

ការទទួលខុសត្រូវរបស់អ្នកធ្វើ ត្រូវបានកំណត់ដូចខាងក្រោម :

១-បុគ្គលជាអ្នកធ្វើត្រូវទទួលខុសត្រូវលើបញ្ជាសងច្រាក់ ឬលើបញ្ជាបញ្ឈប់ដែលយល់ព្រមដោយធនាគារទទួល នៅពេលណាដែលបញ្ជាសងច្រាក់ ឬបញ្ជា

បញ្ឈប់នោះត្រូវបាន :

ក-ចេញដោយបុគ្គលនោះឱ្យទៅធនាគារទទួល

ខ-ចេញដោយអ្នកទទួលសិទ្ធិពីបុគ្គលនោះ ឱ្យទៅធនាគារទទួល

គ-យល់ព្រមដោយធនាគារទទួល អនុលោមតាមនីតិវិធីសុវត្ថិភាព សមស្របដែលមានលក្ខណៈពាណិជ្ជកម្ម ដែលបានព្រមព្រៀងរវាងធនាគារនិងបុគ្គលនោះ ដើម្បីពិនិត្យបញ្ជាក់ពីយថាភាពនៃបញ្ជាទូទាត់ដែលបញ្ជាដោយបុគ្គលនោះទៅកាន់ធនាគារ ឬ

ឃ-បញ្ជាក់យល់ព្រមដោយបុគ្គលនោះ ។

២-កថាខណ្ឌទី ១-គ នៃមាត្រានេះពុំត្រូវបានអនុវត្តទេ ហើយបុគ្គលជាអ្នកធ្វើបញ្ជាទូទាត់ក៏ពុំត្រូវទទួលខុសត្រូវដែរ នៅពេលណាដែលបុគ្គលនោះបង្ហាញភស្តុតាងថាខ្លួនមិនបានទទួលផលប្រយោជន៍ពីបញ្ជាសងច្រាក់ ឬ ពីបញ្ជាបញ្ឈប់ ហើយការចេញបញ្ជាសងច្រាក់ឬបញ្ជាបញ្ឈប់ដោយគ្មានការអនុញ្ញាតនោះ ពុំត្រូវបានបង្កឡើងដោយ :

-បុគ្គលជាអ្នកធ្វើ ឬ ជនដទៃទៀតជាអ្នកទទួលសេចក្តីទុកចិត្តគ្រប់ពេលវេលាឱ្យធ្វើការងារសម្រាប់បុគ្គលនេះ ពាក់ព័ន្ធទៅនឹងប្រតិបត្តិការទូទាត់សងច្រាក់ ឬ នីតិវិធីសុវត្ថិភាព ឬ

-ជនណាដែលបានទទួលពីបុគ្គលជាអ្នកធ្វើ ឬ ពីប្រភពនៅក្រោមការគ្រប់គ្រងរបស់បុគ្គលនេះនូវលទ្ធភាពប្រើប្រាស់មធ្យោបាយបញ្ជូនសារ ឬព័ត៌មាន ព្រមទាំងមធ្យោបាយប្រើប្រាស់កម្មវិធី សូហ្វវែរ កុំព្យូទ័រ ឬ មធ្យោបាយដូចគ្នានេះ ដែលងាយស្រួលក្នុងការល្មើសនឹងនីតិវិធីសុវត្ថិភាព ។

៣-សម្រាប់គោលបំណងនៃកថាខណ្ឌទី ១-គ នៃមាត្រានេះ នីតិវិធីសុវ-ត្ថិភាពនឹងត្រូវបានចាត់ទុកថាសមស្របតាមលក្ខណៈពាណិជ្ជកម្ម បើនីតិវិធីនេះត្រូវបានជ្រើសរើសដោយអតិថិជនផ្ទុយពីការណែនាំរបស់ធនាគារដែលបានស្នើឡើងនូវនីតិវិធីសមស្រប ហើយត្រូវបានអតិថិជនបដិសេធ ។

168/128

មាត្រា ២១៤.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ អ្នកធ្វើមិនត្រូវធ្វើឱ្យមានការខូចប្រយោជន៍ដល់ធនាគារទទួលទេ និងត្រូវសងទៅធនាគារនោះវិញចំពោះការខាតបង់ផ្សេងៗ រហូតដល់ចំនួនប្រាក់នៃបញ្ជាទូទាត់ចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហុយព្រមទាំងការប្រាក់ ។

នៅក្នុងការផ្ទេរឥណទាន ទោះបីជាធនាគារទទួលបានអនុវត្ត និងមានការបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់រួចហើយក្តី អ្នកធ្វើពុំមានការទទួលខុសត្រូវឡើយ ចំពោះធនាគារទទួលលើបញ្ជាទូទាត់ដែលត្រូវបានបញ្ជូនទៅកាន់ធនាគារទទួល ដោយអនុលោមតាមនីតិវិធីសុវត្ថិភាពសម្រាប់រាវរកនូវការខុសឆ្គង ហើយផ្អែកលើកម្រិតអនុញ្ញាតដោយច្បាប់រដ្ឋប្បវេណី ធនាគារទទួលត្រូវមានសិទ្ធិទារពីអ្នកទទួលមកវិញនូវចំនួនប្រាក់ដែលអ្នកធ្វើសងដោយភ័ន្តច្រឡំ ក្នុងករណី :

-អ្នកធ្វើគ្មានបំណងធ្វើបញ្ជាទូទាត់ អ្នកធ្វើមានបំណងបញ្ជាឱ្យសងប្រាក់ទៅអ្នកទទួលផ្សេងក្រៅពីអ្នកដែលមាននៅក្នុងបញ្ជាទូទាត់ ឬ បញ្ជាទូទាត់មានចំនួនប្រាក់ធំជាងចំនួនដែលអ្នកធ្វើមានបំណងសង និង

-អ្នកធ្វើបង្ហាញភស្តុតាងថាខ្លួនបានគោរពតាមនីតិវិធីសុវត្ថិភាព ហើយការភ័ន្តច្រឡំអាចនឹងត្រូវបានរាវរកឃើញ បើធនាគារទទួលបានគោរពតាមនីតិវិធីសុវត្ថិភាពផងដែរ ។

នៅក្នុងការផ្ទេរឥណពន្ធ អ្នកធ្វើនីមួយៗជានាចំពោះធនាគារទទួលថាបញ្ជាទូទាត់របស់ខ្លួនមានការអនុញ្ញាតត្រឹមត្រូវ និងស្របតាមការប្រគល់សិទ្ធិដែលមានប្រសិទ្ធភាព និងសុពលភាពរបស់អ្នកផ្តើមប្រតិបត្តិការនិងអ្នកទទួល ។

អ្នកធ្វើបញ្ជាទូទាត់ និង អ្នកទទួលដែលអនុញ្ញាតឱ្យអ្នកផ្តើមប្រតិបត្តិការធ្វើការផ្ទេរឥណពន្ធរួមទាំងការចេញផ្សាយមូលប្បទានប័ត្រ ត្រូវមានការប្រុងប្រយ័ត្នជានិច្ចដើម្បីទប់ស្កាត់ការក្លែងបន្លំ និងការចេញផ្សាយ ឬ ការកែប្រែបញ្ជាទូទាត់ ដោយគ្មានការអនុញ្ញាតឬដោយគ្មានសិទ្ធិចេញផ្សាយ និងដើម្បីធានាថាបញ្ជាទូទាត់នោះមានលក្ខណៈច្បាស់លាស់និងមានអត្ថន័យច្រកដប្រជា ។

មាត្រា ២១៥.-

នៅពេលណាដែលការផ្ទេរឥណទានមិនត្រូវបានបញ្ចប់ទេ ដោយមិនគិតដល់កំហុសដែលបណ្តាលមកពីផ្នែកណាមួយនៃអ្នកចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់ :

១-អ្នកផ្តើមប្រតិបត្តិការពុំមានការទទួលខុសត្រូវចំពោះមុខធនាគារផ្តើមប្រតិបត្តិការទេ និងមានសិទ្ធិឱ្យចុះឥណទានឡើងវិញលើគណនីរបស់ខ្លួនតាមចំនួនប្រាក់ដែលបានចុះឥណពន្ធ ដើម្បីសងចំនួនប្រាក់ក្នុងបញ្ជាទូទាត់ ។ លើសពីនេះទៀត អ្នកផ្តើមប្រតិបត្តិការត្រូវមានសិទ្ធិទាមទារពីធនាគារផ្តើមប្រតិបត្តិការនូវចំណាយដែលសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយព្រមទាំងការប្រាក់លើចំនួនប្រាក់ដែលបានចុះឥណទានឡើងវិញនោះ ។

២-ធនាគារផ្តើមប្រតិបត្តិការនិងធនាគារអន្តរការីណាមួយ ដែលអនុវត្តបញ្ជាពីអ្នកផ្ញើរបស់ខ្លួន ត្រូវបានរួចផុតជួចគ្នានេះដែរពីការទទួលខុសត្រូវចំពោះមុខធនាគារទទួលរបស់ខ្លួន និងមានសិទ្ធិទទួលសំណងរៀងៗខ្លួនពីធនាគារនោះ លើកលែងតែចំណាយ និងសោហ៊ុយផ្សេងៗ ។

មាត្រា ២១៦.-

ធនាគារទទួល ត្រូវទទួលខុសត្រូវចំពោះចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយ ការប្រាក់ ការខូចប្រយោជន៍នានារួមទាំងការខាតបង់ពីអត្រាប្តូរប្រាក់ផងដែរបើមាន ដែលបណ្តាលមកពីការយឺតយ៉ាវ ឬ កំហុសរបស់ខ្លួន ក្នុងការអនុវត្តបញ្ជាទូទាត់ ។ អ្នកផ្តើមប្រតិបត្តិការអាចទាមទារការខាតបង់នេះ ឬ មួយពីធនាគារផ្តើមប្រតិបត្តិការ ឬ ពីធនាគារទទួល ដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ អ្នកទទួលប្រាក់អាចទាមទារការខាតបង់ ឬ មួយពីធនាគារគោលដៅ ឬ ពីធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ ធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ត្រូវទទួលខុសត្រូវសងឱ្យធនាគារផ្តើមប្រតិបត្តិការ ឬ ធនាគារគោលដៅ នូវចំនួនប្រាក់ដែលពួកគេសងការខូចខាត ។

លើសពីនេះទៀត ធនាគារទទួលដែល :

-ពុំបានផ្តល់ដំណឹងភ្លាមដល់អ្នកផ្ញើ អំពីការបដិសេធរបស់ខ្លួនចំពោះបញ្ជាទូទាត់ ឬ

មានការធ្វេសប្រហែសធ្ងន់ធ្ងរក្នុងការអនុវត្ត ឬ ពុំបានអនុវត្តនូវបញ្ជា
ទូទាត់

ត្រូវទទួលខុសត្រូវចំពោះអ្នកផ្តើមប្រតិបត្តិការលើការខូចខាតជាក់ស្តែងដែលអាចឌឹង
មុន ដែលពុំលើសពីចំនួនច្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ទោះបីអ្នក
ផ្តើមប្រតិបត្តិការជាអ្នកធ្វើ ឬ មិនមែនអ្នកធ្វើរបស់ខ្លួនក្តី ប៉ុន្តែអាស្រ័យដោយអ្នកផ្តើម
ប្រតិបត្តិការពុំមានការធ្វេសប្រហែសដែរ ។ នៅពេលដែលអាចអនុវត្តបាន អ្នកធ្វើក៏
អាចមានសិទ្ធិទទួលចំនួនច្រាក់នៃបញ្ជាទូទាត់ដែលបានសងមកវិញ អនុលោមតាមមាត្រា
២១៥ នៃច្បាប់នេះ ។

អ្នកផ្តើមប្រតិបត្តិការមានសិទ្ធិទទួលមកវិញ នៅក្រោមកថាខណ្ឌទី ១ នៃមាត្រា
នេះ នូវចំនួនច្រាក់ទាំងស្រុងពីធនាគារផ្តើមប្រតិបត្តិការ ឬ ពីធនាគារដែលមានការ
ធ្វេសប្រហែសធ្ងន់ធ្ងរ ។ អាស្រ័យដោយកិច្ចព្រមព្រៀងអន្តរធនាគារ ធនាគារដែល
ទទួលខុសត្រូវនៅក្រោមមាត្រានេះ មានសិទ្ធិទាមទារការចូលរួមចំណែកទទួលខុស
ត្រូវពីភាគីផ្សេងទៀត យោងតាមកម្រិតនៃការបង្កឱ្យមានការខូចខាតរបស់ភាគីទាំង
នោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ការទទួលខុសត្រូវនៅក្រោមមាត្រានេះ និងកំរិតកំណត់
ណាមួយដែលពាក់ព័ន្ធ មិនគិតដល់ការទទួលខុសត្រូវរបស់ធនាគារគោលដៅលើការ
ខុសឆ្គងក្នុងការមិនព្រមទូទាត់សងច្រាក់នៅក្រោមមាត្រា ២១០(៥) ទេ ។

មាត្រា ២១៧.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ ដោយមានការភ័ន្តច្រឡំ
របស់ធនាគារទទួល ដែលជាធនាគារមានកំហុស ដូចជាការសងច្រាក់ទៅអ្នកទទួលពុំ
បានធ្វើឡើង ដូចដែលបានបញ្ជាក់ក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ជា
បន្ថែមទៅលើសំណងមកវិញនៅក្រោមមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវ
អនុវត្តវិធានដូចតទៅ :

១-នៅពេលណាដែលចំនួនច្រាក់សងឱ្យទៅអ្នកទទួលច្រើនហួស ឬ តិច
ជាងចំនួនច្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ការផ្ទេរឥណទានត្រូវចាត់

ទុកថាបានបញ្ចប់ក្នុងចំនួនប្រាក់ដែលបានសងឱ្យទៅអ្នកទទួល ។ នៅលើបញ្ជាទូទាត់នីមួយ។ អ្នកផ្ញើនីមួយៗត្រូវទទួលខុសត្រូវចំពោះមុខធនាគារទទួលក្នុងចំនួនប្រាក់នៃបញ្ជាទូទាត់របស់ខ្លួន ដែលនាំឱ្យ :

ក-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលច្រើនលើសពីចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសមានសិទ្ធិទទួលបានមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលសងលើសនោះ តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៅកន្លែងជាទីតាំងរបស់ធនាគារគោលដៅ និង

ខ-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសត្រូវសងប្រាក់ដែលខ្វះឱ្យទៅអ្នកទទួល និងមានសិទ្ធិរក្សាទុក ឬ ទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើរបស់ខ្លួននូវចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការសងប្រាក់ត្រូវបានផ្ញើឱ្យទៅអ្នកទទួល ដែលពុំមែនជាអ្នកមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ហើយធនាគារមានកំហុសពុំមែនជាធនាគារគោលដៅនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទេនោះ អ្នកផ្តើមប្រតិបត្តិការនិងអ្នកផ្ញើឯទៀតមុនធនាគារមានកំហុស និងអ្នកទទួលបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ អាចចាត់ទុកថាការផ្ទេរឥណទានពុំទាន់បានបញ្ចប់ទេ ។ ធនាគារមានកំហុសមានសិទ្ធិប្រមូលមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលបានទូទាត់សង តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៃកន្លែងជាទីតាំងរបស់ធនាគារគោលដៅ ។

៣-ធនាគារមានកំហុសត្រូវទទួលខុសត្រូវ ចំពោះអ្នកចូលរួមលើប្រាក់ដើម ការប្រាក់ ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហ៊ុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មាន ដែលកើតឡើងអំពីការភ័ន្តច្រឡំនោះ ។

៤-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

មាត្រា ២១៨.-

នៅពេលដែលការផ្ទេរឥណពន្ធត្រូវបានបញ្ចប់ ដោយពុំស្របតាមការបញ្ជា នៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ដោយសារតែការភ័ន្តច្រឡំរបស់ធនាគារទទួល ដែលជាធនាគារមានកំហុស ជាបន្ថែមទៅលើសំណងមកវិញ នៅក្រោមកថាខណ្ឌទី ៥ នៃមាត្រា ២១០ និងមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវអនុវត្តវិធាន ដូចតទៅ :

១-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់តិចជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារមានកំហុសត្រូវទាមទារចំនួនប្រាក់ដែលខ្វះពីអ្នកទទួល ហើយប្រគល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់ច្រើនជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនូវចំនួនប្រាក់ដែលលើសនោះ ។ ធនាគារមានកំហុសត្រូវសងចំនួនប្រាក់ដែលលើស ឱ្យទៅធនាគារគោលដៅ និងទារចំនួនប្រាក់លើសពីអ្នកផ្តើមប្រតិបត្តិការ ឬ អ្នកចូលរួមដទៃទៀត ទៅតាមចំនួនប្រាក់លើសដែលបានរក្សាទុក ។

៣-នៅពេលណាមានការកត់ត្រាឥណពន្ធ នៅលើគណនីអ្នកទទួលមួយផ្សេង ក្រៅពីអ្នកដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនេះនូវចំនួនប្រាក់ដែលបានចុះឥណពន្ធ និងត្រូវចុះឥណពន្ធគណនីអ្នកទទួលដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការតាមចំនួនប្រាក់នៃបញ្ជាទូទាត់ ។

៤-នៅពេលណាដែលមានការកត់ត្រាឥណពន្ធ គណនីអ្នកទទួលនៅក្នុងធនាគារគោលដៅមួយផ្សេង ក្រៅពីធនាគារនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅនោះត្រូវចុះឥណទានគណនីអ្នកទទួលនោះវិញតាមចំនួនប្រាក់ដដែល និងទារប្រាក់នេះពីធនាគារមានកំហុស ។ ធនាគារមានកំហុសត្រូវទារចំនួនប្រាក់ក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការពីអ្នកទទួលបញ្ជាទូទាត់របស់អ្នក

ផ្តើមប្រតិបត្តិការ ។

៥-នៅក្រោមមាត្រានេះ ការទារប្រាក់ត្រូវធ្វើតាមរយៈការផ្ទេរឥណពន្ធ ហើយការសងប្រាក់តាមរយៈការផ្ទេរឥណទាន ។

៦-ធនាគារមានកំហុសត្រូវទទួលខុសត្រូវចំពោះអ្នកចូលរួមណាមួយលើប្រាក់ដើម ការប្រាក់ ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មានដែលកើតឡើងពីការភ័ន្តច្រឡំនោះ ។

៧-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

ផ្នែកទី ៧
គណនីធនាគារ

មាត្រា ២១៩.-

យោងតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង និងលើកលែងតែក្នុងកាលៈទេសៈដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ សមតុល្យឥណទាយីដែលមានគ្រប់គ្រាន់អាចនឹងត្រូវអតិថិជនដកប្រាក់ចេញ ឬ ធនាគារធ្វើការសងប្រាក់តាមបញ្ជាទូទាត់ ។ ធនាគារពុំត្រូវបានបង្ខំឱ្យយល់ព្រម លើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើលើសកម្រិតសមតុល្យឥណទាយីឱ្យអតិថិជនឡើយ ។

កថាខណ្ឌខាងលើនៃមាត្រានេះ នឹងពុំត្រូវអនុវត្តឡើយ នៅពេលណាដែល :

-សមតុល្យឥណទាយីនៅក្នុងគណនី គឺជាកម្មវត្ថុនៃបណ្តឹងតវ៉ា ការរឹបអូស ឬ នីតិវិធីប្រហាក់ប្រហែលនេះរបស់ឥណទាយក

-គណនីត្រូវបានបិទ ល្បុកទុក ភាំងខ្ទប់ ឬ បង្កក និង

-ក្នុងការអនុវត្តបញ្ជាទូទាត់ ឬ បញ្ជាឱ្យដកប្រាក់នោះ ធនាគារត្រូវល្មើសនឹងច្បាប់ណាមួយ ។

អតិថិជននិងធនាគារអាចព្រមព្រៀងថា មូលនិធិដែលបានបញ្ជូនមក និងបានទទួលជាប្រាក់បញ្ញើ នៅធនាគារសម្រាប់អតិថិជន ត្រូវតែបានបែងចែកតាមការបញ្ជារបស់អតិថិជន ទៅកាន់គណនីមួយឬច្រើនរបស់អតិថិជននោះ ។ គណនីនីមួយៗត្រូវ

ជាកម្មវត្ថុនៃការចុះបញ្ជីគណនេយ្យដោយឡែកពីគ្នា ពាក់ព័ន្ធទៅនឹងចលនានៃមូលនិធិ ដែលបានទទួលនិងបានសងដោយធនាគារ សម្រាប់អតិថិជន ។

មាត្រា ២២០.-

ការបើកចំហព័ត៌មាននៅក្រោមមាត្រានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ តាមអេឡិកត្រូនិក អាស្រ័យលើការព្រមព្រៀងគ្នា ។

ធនាគារត្រូវបើកចំហព័ត៌មានចំពោះអតិថិជនបច្ចុប្បន្ន និងអនាគត តាមទម្រង់រៀបចំជាស្រេចដែលងាយយល់អំពីបែបបទ និង លក្ខខ័ណ្ឌសម្រាប់អនុវត្តប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងសោហ៊ុយរបស់ធនាគារ និងបើមាន អំពីពេលវេលាចាំបាច់ស្មានចាំបាច់សម្រាប់បញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់នោះ ។

ចំពោះប្រតិបត្តិការទូទាត់សងប្រាក់ណាមួយ ឬ ខ្ទង់ឥណពន្ធ ឬ ឥណទានផ្សេងទៀត ដែលបានកត់ត្រាចូលគណនី ធនាគារត្រូវផ្តល់ជូនអតិថិជនទូវព័ត៌មានច្បាស់លាស់ ដែលអាចឱ្យអតិថិជនសម្គាល់បានការដកប្រាក់ ការដាក់ធ្វើប្រាក់ ឬ ប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងលេខយោង កាលបរិច្ឆេទ សោហ៊ុយ និង អត្រាប្តូរប្រាក់ផងដែរ បើមាន ។

លើកលែងតែចំពោះគណនីដែលមានសៀវភៅប្រាក់បញ្ញើ ធនាគារត្រូវផ្តល់ឱ្យអតិថិជនជាប្រចាំ ក្នុងរយៈពេលមិនលើសពីមួយខែ នូវរបាយការណ៍គណនីដែលបង្ហាញពីការកត់ត្រាចូលខ្ទង់ឥណទាន និងឥណពន្ធ ចាប់ពីកាលបរិច្ឆេទធ្វើរបាយការណ៍ចុងក្រោយ និងដែលផ្តល់សមតុល្យចុងគ្រាផងដែរ ។

ចំពោះគណនីដែលមានសៀវភៅប្រាក់បញ្ញើ ធនាគារត្រូវសម្រួលឱ្យមានការកត់ត្រានូវចលនាថ្មីៗ ទៅក្នុងគណនីជាបន្តបន្ទាប់ក្នុងសៀវភៅប្រាក់បញ្ញើនេះ ។ ការកត់ត្រានេះត្រូវបង្ហាញពីខ្ទង់ឥណទាន ឬ ឥណពន្ធនីមួយៗ ដែលបានធ្វើទៅលើគណនីចាប់តាំងពីពេលកត់ត្រាគ្រាមុន និងបង្ហាញពីសមតុល្យចុងគ្រាផងដែរ ។ អតិថិជនត្រូវយកសៀវភៅប្រាក់បញ្ញើមកឱ្យធនាគារកត់ត្រាដោយទៀងទាត់ ។

អតិថិជនត្រូវមានការប្រុងប្រយ័ត្នជាទូទៅ និងការរួសរាន់ក្នុងការពិនិត្យលើរបាយការណ៍ប្រចាំគ្រាទាំងនោះ ព្រមទាំងលើការកត់ត្រាចលនាថ្មីៗលើសៀវភៅប្រាក់បញ្ញើ ហើយផ្តល់ព័ត៌មានដល់ធនាគារអំពីភាពមិនប្រក្រតីឬមានការតវ៉ាលើការកត់

ត្រាឥណពន្ធ ឬ ឥណទាន ។ ធនាគារត្រូវជួយដល់អតិថិជនក្នុងការតាមដានអង្កេតលើភាពមិនប្រក្រតី ឬ លើខ្ជង់ឥណពន្ធ ឬ ឥណទានដែលមានការតវ៉ានោះ ដោយផ្តល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដែលមាន និងបើអាចធ្វើទៅបាន ធ្វើការកែសម្រួល និងកែតម្រូវចាំបាច់លើគណនីនោះ ។

មាត្រា ២២១.-

ការបើកចំហព័ត៌មានត្រូវបានកំណត់តាមវិធីមួចខាងក្រោមនេះ :

១-ធនាគារត្រូវរក្សាការសម្ងាត់ និងពុំត្រូវបើកចំហព័ត៌មានណាមួយអំពីគណនីឱ្យទៅជនណាមួយ ក្រៅពីអតិថិជនជាម្ចាស់គណនី លើកលែងតែ :

ក-នៅពេលដែលការបើកចំហ ត្រូវបានតម្រូវដោយច្បាប់

ខ-នៅពេលដែលផលប្រយោជន៍របស់ធនាគារ តម្រូវឱ្យមានការបើកចំហ

គ-នៅពេលដែលការបើកចំហ ត្រូវបានធ្វើឡើងដោយមានការយល់ព្រមពីអតិថិជន

ឃ-នៅពេលដែលការបើកចំហ ត្រូវបានធ្វើឡើងតាមការស្នើសុំជាពិសេសពីធនាគារផ្សេងទៀត ក្រោមការផ្តល់មតិលើអតិថិជនក្នុងជំណើរអាជីវកម្មធម្មតា ឬ

ង-នៅពេលដែលអតិថិជន មិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួនចំពោះធនាគារ ។

២-ការបើកចំហក្រោមកថាខណ្ឌទី ១-ខ នៃមាត្រានេះនឹងត្រូវបានធ្វើឡើងតែ :

-នៅពេលណាដែលមានការប្តឹងផ្តល់តាមផ្លូវតុលាការ ដែលក្នុងនេះធនាគារជាភាគីមួយ

-រវាងធនាគារដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកតាមរយៈរចនាសម្ព័ន្ធនៃកម្មសិទ្ធិរួម ប៉ុន្តែនៅត្រឹមតែកម្រិតការចាំបាច់សមស្រប ដើម្បីការពារធនាគារ និងសម្ព័ន្ធញាតិរបស់ខ្លួនទល់នឹងការខាតបង់តែប៉ុណ្ណោះ ក្នុងការផ្តល់នូវសេវាធនាគារ ឬ

-ជ្រាវភ្ជាប់ជាមួយនេះ និងក្នុងការចាំបាច់ ការស្នើលក់ធនាគារខ្លួនឯង ឬ មួយផ្នែកធំនៃទ្រព្យសម្បត្តិរបស់ខ្លួន ។

៣-មិនមានការបើកចំហណាមួយ ត្រូវបានធ្វើឡើងក្រោមកថាខណ្ឌទី ១-ឃ នៃមាត្រានេះឡើយ បើអតិថិជនបញ្ឈប់ការយល់ព្រមឱ្យបើកចំហនេះ និងលើកលែងតែធនាគារបានពន្យល់ឱ្យអតិថិជនយល់អំពីសិទ្ធិរបស់ខ្លួន ក្នុងការបញ្ឈប់នូវការយល់ព្រមនោះ ។ ការពន្យល់នេះ អាចត្រូវបានផ្តល់ឱ្យអតិថិជនក្នុងពេលបើកគណនីជាមួយធនាគារ ។

៤-ការបើកចំហក្រោមកថាខណ្ឌទី ១-ង នៃមាត្រានេះ ត្រូវកម្រិតចំពោះការផ្តល់ព័ត៌មានដល់ធនាគារ ឬ ភ្នាក់ងារឥណទានណាមួយ ដោយមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា នៅពេលមានកំហុស និងនៅពេលខកខានរបស់អតិថិជនដើម្បីទូទាត់សង ផ្តល់សុវត្ថិភាពគ្រប់គ្រាន់ ឬ ម៉្យាងទៀត បំពេញសំណូមពររបស់ធនាគារក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ដោយសំណើជាលាយលក្ខណ៍អក្សរឱ្យទូទាត់សងកាតព្វកិច្ចដែលនៅជាប់ជំពាក់ ។

៥-សំណងការខូចខាតដែលកើតមានដល់អតិថិជន ចំពោះការប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចក្រោមមាត្រានេះ មិនត្រូវបានកម្រិតត្រឹមតែការខាតបង់ចំនួនប្រាក់នោះទេ និងអាចរួមបញ្ចូលសំណងលើការខូចប្រយោជន៍ ការរំខាន ឬ ការប៉ះពាល់ដែលត្រូវបានបង្កឡើង ។

មាត្រា ២២២.-

ធនាគារមិនត្រូវកែប្រែជាឯកតោភាគី នូវលក្ខខ័ណ្ឌនៃការព្រមព្រៀងទេ លើកលែងតែបានជូនដំណឹងដល់អតិថិជនយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនពេលដែលការកែប្រែនោះមានសុពលភាព ។ ការកែប្រែដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ពុំមានសុពលភាពឡើយ ។

មាត្រា ២២៣.-

ដើម្បីជាចំណងនីស្សានុភូលទៅលើអតិថិជន កិច្ចព្រមព្រៀងត្រូវតែមានលក្ខណៈត្រឹមត្រូវព្រមទាំងមានចែងពីសិទ្ធិ និងការទទួលខុសត្រូវច្បាស់លាស់ និងជាភាសា

សាមញ្ញ ដោយប្រើប្រាស់ភាសាច្បាប់និងបច្ចេកទេសតែនៅពេលណាដែលចាំបាច់ប៉ុណ្ណោះ ។

ធនាគារត្រូវមានការប្រុងប្រយ័ត្នជាប្រចាំក្នុងការអនុវត្តបញ្ជាទូទាត់ និងរាល់បញ្ជាផ្សេងៗទៀតរបស់អតិថិជន ។

អតិថិជនត្រូវមានការប្រុងប្រយ័ត្ន ដើម្បីការពារការក្លែងបន្លំ និងការចេញផ្សាយ ឬ ការកែប្រែគ្មានអនុញ្ញាតលើបញ្ជាទូទាត់ និងលើបញ្ជាផ្សេងៗទៀតទៅធនាគារ និង ដើម្បីធានាថា បញ្ជាទាំងនោះមានខ្លឹមសារច្បាស់លាស់និងច្រាកដប្រជា ។

ធនាគារ និងអតិថិជន ត្រូវប្រតិបត្តិភារកិច្ចដែលនៅក្រោមច្បាប់នេះ រួមទាំងបទប្បញ្ញត្តិនានា និងកិច្ចព្រមព្រៀងរបស់ខ្លួនដោយសុចរិត ។

ជាកម្មវត្ថុនៃកម្រិតកំណត់ ឬ ការកំហិតពិសេសណាមួយដែលកំណត់ដោយច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ធនាគារត្រូវទទួលខុសត្រូវចំពោះអតិថិជន ហើយអតិថិ-ជនត្រូវទទួលខុសត្រូវចំពោះធនាគារ សម្រាប់ការខាតបង់ ឬ ការខូចខាតណាមួយដែលបង្កឡើងពីការប្រព្រឹត្តល្មើសនឹងភារកិច្ចក្រោមច្បាប់នេះ ។

មាត្រា ២២៤.-

ធនាគារអាចដកកម្រៃពីមូលនិធិឬមូលប័ត្រដែលបានដាក់ធ្វើ ក្នុងការផ្តល់សេវាចំពោះអតិថិជន ដូចជាការរក្សាសុវត្ថិភាព ការបញ្ជូននិងការផ្ទេរមូលនិធិជាប្រាក់បញ្ញើនៅធនាគារជាដើម ។

ធនាគារអាចប្រមូលផ្តុំគណនីនានារបស់អតិថិជនតែមួយ និងដកប្រាក់ដែលមានសមតុល្យឥណទាយើ នៅក្នុងគណនីមួយដើម្បី :

-សងតាមបញ្ជាទូទាត់របស់អតិថិជន បើគណនីដែលត្រូវដកប្រាក់សម្រាប់បញ្ជាទូទាត់នោះ ពុំមានសមតុល្យគ្រប់គ្រាន់

-សងបំណុលដែលអតិថិជនជំពាក់ និងត្រូវសងឱ្យទៅធនាគារនេះ

បើក្នុងករណីនីមួយៗខាងលើ ធនាគារពុំបានដឹងថាមូលនិធិនៅក្នុងសមតុល្យឥណទាយីដែលបានដកនោះ ត្រូវបានរក្សាទុកសម្រាប់បុគ្គលផ្សេងទៀតនោះទេ ។

លុះត្រាតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារអាចប្រើប្រាស់មូលនិធិ មូល-ប័ត្រ ឬ សមតុល្យឥណទាយីក្រោមមាត្រានេះ តែនៅពេលណាដែលមូលនិធិ មូលប័ត្រ ឬសមតុល្យឥណទាយីនោះ មានទំនេរសម្រាប់ឱ្យអតិថិជនដកយកភ្លាមៗប៉ុណ្ណោះ ។

ផ្នែកទី ៨
ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងគ្រាក់

មាត្រា ២២៥.-

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិបើកគណនីឱ្យអតិថិជននៅក្នុងបញ្ជីរបស់ខ្លួន រួមទាំងគណនីទូទាត់ និងទទួលប្រាក់បញ្ញើ ពីធនាគារជារូបិយវត្ថុក្នុងស្រុក និងរូបិយ-ប័ណ្ណ ទៅតាមបែបបទនិងលក្ខខ័ណ្ឌ ដូចដែលមានចែងដោយបទបញ្ជា ឬ ដូចដែលបានព្រមព្រៀងគ្នា ។

មាត្រា ២២៦.-

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ រៀបចំ សម្រេច ផ្សព្វផ្សាយជាសាធារណៈ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់ សំដៅបម្រើផល-ប្រយោជន៍សាធារណជនជាអតិបរមា ។ គោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់ត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដារអន្តរជាតិ ។ គោលនយោបាយនេះត្រូវលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់ ត្រួតពិនិត្យហានិភ័យ និងលើកកម្ពស់ការប្រកួតប្រជែងនៅក្នុងទីផ្សារសេវាកម្មទូទាត់ដែលមានសង្គតិភាពជាមួយនឹងស្ថេរ-ភាពជាទូទៅនៃប្រព័ន្ធហិរញ្ញវត្ថុ ។

មាត្រា ២២៧.-

ធនាគារជាតិនៃកម្ពុជាអាច :

-បង្កើតនិងរក្សាព័ត៌មានសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុ នៅព្រះរាជាណា-ចក្រកម្ពុជា

-ដំណើរការ ត្រួតពិនិត្យ តាមដានការអនុវត្ត និងដាក់បញ្ញត្តិកម្មប្រព័ន្ធទូទាត់សងប្រាក់ជាតិ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ និងការផកសាច់ប្រាក់រួមទាំងប្រព័ន្ធជាត់ទាត់ និង ទូទាត់សម្រាប់ការសងប្រាក់ជារូបិយវត្ថុក្នុងស្រុក និងជារូបិ-យប័ណ្ណនៅព្រះរាជាណាចក្រកម្ពុជា

-រក្សាបញ្ជីសម្រាប់មូលប័ត្រដែលបានចេញផ្សាយ បង្កើតមជ្ឈមណ្ឌល

ជាក់ផ្ទៃមូលប័ត្រ រក្សាគណនីសម្រាប់មូលប័ត្រដែលបានជាក់ផ្ទៃ ព្រមទាំងដំណើរការ ត្រួតពិនិត្យ និងជាក់បញ្ជូត្តិកម្មប្រព័ន្ធជាត់ទាត់ និងទូទាត់សម្រាប់មូលប័ត្រ

-លើកកម្ពស់ រៀបចំ និងចូលរួមនៅក្នុងប្រព័ន្ធទូទាត់សងច្រាក់ ជាត់ទាត់ និងទូទាត់ជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

-ជួយដល់បណ្តាធនាគារក្នុងការរៀបចំ និង ប្រើប្រាស់ឧបករណ៍សម្រាប់ការផ្ទៃ ដំណើរការ និងការទទួលបញ្ជាទូទាត់សម្រាប់អតិថិជនរបស់ធនាគារទាំងនោះ ក៏អួចជាសម្រាប់ការជាត់ទាត់ និងទូទាត់នៃការសងច្រាក់អន្តរធនាគារ រួមទាំងការសងច្រាក់ដោយមូលប្បទានប័ត្រ និងឧបករណ៍ទូទាត់ផទៃទៀតជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

-ជាក់បញ្ជូត្តិកម្ម ត្រួតពិនិត្យ និងតាមដានការអនុវត្ត ក៏អួចជាកំណត់លក្ខខ័ណ្ឌ និងកាតព្វកិច្ចនានាសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ ឬ ការចុះបញ្ជី ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងច្រាក់ និងសេវារូបិយវត្ថុរួមទាំងសម្រាប់ការផ្ទេរច្រាក់ ការដកសាច់ច្រាក់ ការដកច្រាក់ដោយមូលប្បទានប័ត្រ ការរក្សាសុវត្ថិភាពរូបិយវត្ថុ ការប្តូរច្រាក់ និងការចេញផ្សាយប័ណ្ណទូទាត់សងច្រាក់ និង ឧបករណ៍ទូទាត់សងច្រាក់ផងដែរ និង

-បង្កើតនីតិវិធី និងជាក់ចេញបទបញ្ជាពាក់ព័ន្ធនឹងបញ្ជាទាំងនោះ និងការអនុវត្តគោលនយោបាយប្រព័ន្ធទូទាត់សងច្រាក់របស់ខ្លួន នៅក្រោមមាត្រា ២២៦ នៃច្បាប់នេះ ។

បទបញ្ជាដែលបានជាក់ចេញដោយអនុលោមតាមមាត្រានេះ អាចផ្តល់សុពលភាពដល់កិច្ចព្រមព្រៀងជាត់ទាត់អន្តរធនាគារជាទ្វេ និង ពហុភាគី ព្រមទាំងវិធានទូទាត់អន្តរធនាគារ និងអាចកំណត់ជាពិសេសថាកិច្ចព្រមព្រៀង ឬវិធានទាំងនេះ អាចជំនួសឱ្យច្បាប់ផ្សេងទៀតដែលមានខ្លឹមសារមិនស្របគ្នាដែរ ទោះជាទាក់ទង ឬ មិនទាក់ទងដល់បណ្តឹងអំពីអសាធនភាព ។ បទបញ្ជាទាំងនោះក៏អាចផ្តល់កិច្ចការពារទុកជាមុន ឬ ការកាត់បន្ថយហានិភ័យដែលផ្សារភ្ជាប់ជាមួយការខកខាន ពុំបានបញ្ចប់ការទូទាត់ រាល់កាតព្វកិច្ច ដែលជាលទ្ធផលនៃការជាត់ទាត់អន្តរធនាគារជាពហុភាគីផងដែរ ។

ដោយពុំមានប៉ះពាល់ដល់ខ្លឹមសារទូទៅនៃមាត្រានេះ សំរាប់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងច្រាក់សេវារូបិយវត្ថុ និងរាល់ប្រព័ន្ធជាត់ទាត់និងទូទាត់នៅក្រោមមាត្រានេះ

ធនាគារជាតិនៃកម្ពុជាត្រូវមានអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងប្រតិបត្តិការទាំងនោះ ដូចមានចែងនៅក្នុងកថាខណ្ឌទី ១១ មាត្រាទី ៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

មាត្រា ២២៨.-

ធនាគារត្រូវមានលទ្ធភាពផ្ញើ ទទួល និងដំណើរការបញ្ជាទូទាត់ និង បញ្ជារបស់អតិថិជនដែលពាក់ព័ន្ធ រួមទាំងការផកសាច់ប្រាក់ និងម៉្យាងទៀតអាចចូលរួមនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ផងដែរ ។ ធនាគារអាចធ្វើកិច្ចការនេះ តាមរយៈអ្នកដំណើរការតតិយភាគីមួយ ឬ ច្រើន ដូចដែលបានព្រមព្រៀងរវាងធនាគារ និងអ្នកដំណើរការតតិយភាគី និងជាកម្មវត្ថុនៃកាតព្វកិច្ច លំហូរខ្ណ និងការរឹតត្បិត ដែលអាចមានចែងនៅក្នុងបទបញ្ជាចេញដោយធនាគារជាតិនៃកម្ពុជា ។

មាត្រា ២២៩.-

លើកលែងតែមានការអនុញ្ញាតដោយឡែកនៅក្នុងមាត្រាណាមួយ បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ មិនអាចប្រែប្រួល ឬ បដិសេធដោយកិច្ចព្រមព្រៀងជាទ្វេ ឬ ពហុភាគីឡើយ លើកលែងតែកិច្ចព្រមព្រៀងនោះអាច :

១-បង្កើនសិទ្ធិរបស់អតិថិជន ដរាបណាការបង្កើននោះ មិនប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃ

២-ផ្តល់ឱ្យមានស្តង់ដារសមស្រប ដែលបញ្ជាក់ទ្វារការប្រុងប្រយ័ត្នជាធម្មតារបស់ភាគីនីមួយៗ ក៏ដូចជាវិធីសាស្ត្រសមស្រប សម្រាប់ផ្តល់ការណែនាំ និងបទបញ្ជាណាមួយនៅក្រោមច្បាប់នេះ ព្រមទាំងកិច្ចព្រមព្រៀង

៣-ធ្វើឱ្យប្រែប្រួលសិទ្ធិ និងកាតព្វកិច្ចរវាងនិងក្នុងចំណោមធនាគារដរាបណាការប្រែប្រួលនោះ មិនប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលណាមួយ ដែលពុំមែនជាភាគីនៃកិច្ចព្រមព្រៀង រួមទាំងអតិថិជនមិនមែនធនាគារផងដែរ ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ២៣០.-

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិផ្តន្ទាទោសខាងវិន័យ ដែលតម្រូវ និង អនុវត្ត ចំពោះបុគ្គលទាំងឡាយក្នុងការមិនទូទាត់សងបំណុលរបស់ខ្លួន ពាក់ព័ន្ធជាមួយឧបករណ៍អាចជួញដូរបានឌីជីថល ។

ការប្រព្រឹត្តល្មើសនឹងបទបញ្ជា ដែលមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម :

-ការព្រមាន

-ការស្តីបន្ទោស

-ការហាមឃាត់ឬការដាក់កំហិត ក្នុងការចេញផ្សាយឧបករណ៍អាចជួញដូរបានណាមួយ ឬ គ្រប់ប្រភេទ ឬ ក្នុងការផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធសម្រាប់រយៈពេលមិនលើសពីដប់ពីរ (១២) ខែ

-ការបង់ប្រាក់ពិន័យ ពីប្រាំភាគរយ (៥%) ទៅមួយរយភាគរយ (១០០%) នៃតម្លៃចារឹករបស់ឧបករណ៍ ឬ បញ្ជាទូទាត់ដែលមិនបានទូទាត់សងប្រាក់ ឬ ឧបករណ៍ ឬ សិទ្ធិអំណាចចេញផ្សាយ ដោយរំលោភលើការហាមឃាត់ឬការដាក់កំហិត ។

នៅពេលដែលពុំមានចំនួនប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់មូលប្បទានប័ត្រដែលមានសុពលភាព ធនាគារ បហារិកដែលមិនទូទាត់មូលប្បទានប័ត្រនេះ ត្រូវកត់ត្រាហេតុការណ៍មិនទូទាត់និងរាយការណ៍ក្នុងរយៈពេលពីរ (០២) ថ្ងៃ ស្តីពីការមិនទូទាត់សងប្រាក់ទៅធនាគារជាតិនៃកម្ពុជា ។ បហារ័កនៃមូលប្បទានប័ត្រមិនត្រូវបានអនុញ្ញាតឱ្យចេញផ្សាយមូលប្បទានប័ត្រ ឬ មិនត្រូវបានផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធក្នុងរយៈពេលដប់ពីរ (១២) ខែ ។ ចំនួនប្រាក់គ្រប់គ្រាន់ក្នុងគណនីរួមមានមូលនិធិជាក់ស្តែងដែលបង្កើតបានជាសមតុល្យវិជ្ជមាននៅក្នុងគណនី ឬ ត្រូវបានផ្តល់ដោយឥណទានវិចារណ៍ ដែលបហារ័កបានទទួលពីធនាគារបហារិក ។

ធនាគារជាតិនៃកម្ពុជា ត្រូវដំណើរការចុះបញ្ជីកត់ត្រារាល់គណនីធនាគារ ដែល

តាមរយៈនោះមូលប្បទានប័ត្រត្រូវបានចេញផ្សាយ និងការផ្ទេរឥណពន្ធត្រូវបានធ្វើក៏ដូចជាការរាយការណ៍អំពីហេតុការណ៍ទាំងអស់ ហើយចេញនូវការព្រមាន ការស្តីបន្ទោស ការហាមឃាត់ និង ការដាក់កំហិតក្រោមមាត្រានេះ ។ នៅពេលចេញការព្រមាន ការស្តីបន្ទោស ការហាមឃាត់ ឬ ការដាក់កំហិត ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងដល់ធនាគារនីមួយៗ ដែលនៅក្នុងនោះ បុគ្គលដែលទទួលទណ្ឌកម្មទាំងនោះមានគណនី និងត្រូវផ្តល់ព័ត៌មានទាំងនេះដល់ធនាគារ បើមានការស្នើសុំ ។

ធនាគារ ដោយដឹងពីការហាមឃាត់ ឬ ការដាក់កំហិត ដែលបានដាក់ចេញក្រោមកថាខណ្ឌទី ៣ នៃមាត្រានេះ ត្រូវតម្រូវឱ្យបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត ប្រគល់ត្រឡប់មកវិញជាបន្ទាន់ នូវមូលប្បទានប័ត្រមិនទាន់សរសេរ និងមិនទាន់ប្រើប្រាស់ ព្រមទាំងការអនុញ្ញាតឱ្យធ្វើបេឡានិច័យតាមការផ្ទេរឥណពន្ធដែលធនាគារបានប្រគល់ឱ្យខ្លួន ។ ធនាគារ ដោយដឹងពីការហាមឃាត់ ឬ ការដាក់កំហិត ត្រូវតែទទួលខុសត្រូវចំពោះអ្នកកាន់មូលប្បទានប័ត្រ និងអ្នកផ្តើមប្រតិបត្តិការនៃការផ្ទេរឥណពន្ធ ដែលត្រូវបានចេញផ្សាយ ឬ ត្រូវបានអនុញ្ញាត ដោយបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត តាមចំនួនប្រាក់ទាំងអស់នៃមូលប្បទាន-ប័ត្រ ឬនៃការផ្ទេរឥណពន្ធ កាលបើមូលប្បទានប័ត្រមិនទាន់សរសេរ ឬ ការអនុញ្ញាតឱ្យធ្វើបេឡានិច័យ តាមការផ្ទេរឥណពន្ធត្រូវបានប្រគល់ឱ្យទៅបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត នៅមុនពេលដែលធនាគារបានដឹងអំពីការហាមឃាត់ ឬ ការដាក់កំហិតនោះ បានចូលជាធរមាន ។

ការហាមឃាត់ឬការដាក់កំហិត ក្នុងការចេញផ្សាយមូលប្បទានប័ត្រ ឬ ក្នុងការផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធ ត្រូវបានដកចេញវិញ នៅពេលណាដែលធនាគារជាតិនៃកម្ពុជាបានទទួលដំណឹងថា ការទូទាត់ត្រូវបានធ្វើឡើងតាមសំណូមពរអ្នកកាន់ ។ ការទូទាត់នោះត្រូវរួមបញ្ចូលសោហ៊ុយចំណាយរបស់ធនាគារ ដែលត្រូវទូទាត់ឱ្យទៅធនាគារបហារិក ការប្រាក់ និង ការខូចខាត តាមកម្រិតអប្បបរមាប្រាំភាគរយ (៥%) នៃចំនួនប្រាក់ដើម ដែលត្រូវទូទាត់ឱ្យអ្នកកាន់ និងប្រាក់ពិន័យចំនួនមួយលាន (១.០០០.០០០)រៀល ដែលត្រូវទូទាត់ឱ្យធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា ត្រូវចេញបទបញ្ជាស្តីពីការធ្វើឱ្យពេញលេញនូវកាតព្វកិច្ចនេះ ។

មាត្រា ២៣១.-

បុគ្គលណាដែលប្រព្រឹត្តល្មើស :

-បទប្បញ្ញត្តិណាមួយនៃច្បាប់នេះ

-បទបញ្ជា សេចក្តីណែនាំ ឬវិធានណាមួយដែលចេញដោយ ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនិងបញ្ហាណាមួយដែលមានចែងនៅក្នុងបទបញ្ជា សេចក្តីណែនាំ ឬវិធានទាំងនោះ

-ដោយមិនព្រមផ្តល់ព័ត៌មានតាមការស្នើសុំដោយស្របច្បាប់ ដែលអនុញ្ញាតដោយច្បាប់នេះ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំ (០៥) លានរៀល ដល់ដប់ (១០) លានរៀល ឬត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីពីរ (២) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ ឬទទួលទោសទាំងពីរ ។

បុគ្គលណាដែល :

-ប្រព្រឹត្តល្មើសនឹងការហាមឃាត់ ឬការដាក់កំហិត ដែលបានដាក់ចេញនៅក្រោមមាត្រា ២៣០ នៃច្បាប់នេះ

-ផ្តល់សិទ្ធិអំណាចឱ្យធ្វើការផ្ទេរប្រាក់ចេញពីគណនីរបស់ខ្លួន ដោយមានបំណងឱ្យបញ្ជាទូទាត់នោះ មិនត្រូវបានទូទាត់សង ឬ

-កែបន្លំ ក្លែងក្លាយឧបករណ៍អាចជួញដូរបាន ការអនុញ្ញាតធ្វើបេឡានិច័យដោយការផ្ទេរឥណពន្ធឬបញ្ជាទូទាត់ និងកាន់ឬប្រើប្រាស់ដោយដឹងថាឧបករណ៍អាចជួញដូរបាន ការអនុញ្ញាតឬបញ្ជាទូទាត់ទាំងនោះ ជាឧបករណ៍កែបន្លំឬក្លែងក្លាយ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំ (០៥)លាន ដល់ហាសិប (៥០)លានរៀល និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីពីរ (២)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ ។

បុគ្គលណាដែល :

-មានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកផ្ទះ ដោយការជំទាស់ ឬការដកប្រាក់ពីគណនីសម្រាប់ទូទាត់មួលប្បទានប័ត្រ

-ជាប់បំណុលលើឧបករណ៍អាចជួញដូរបាន ដោយមានចេតនាមិនទូទាត់សងឧបករណ៍នោះនៅពេលដល់ឥណប្រតិទាន

-មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់ឥណប្រតិទាន ដោយមានបំណង និងដោយមានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកផ្ទះ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីពីរ (០២)លាន ដល់ប្រាំមួយ (០៦)លានរៀល និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣)ឆ្នាំ ដោយមិនទាន់គិតដល់កាតព្វកិច្ចទូទាត់សងចំនួនប្រាក់ នៃឧបករណ៍អាចជួញដូរបាននោះទៅអ្នកកាន់ ។

គ្មានការប្តឹងណាមួយអាចត្រូវធ្វើប្រឆាំងនឹងធនាគារជាតិនៃកម្ពុជា មន្ត្រី បុគ្គលិក ឬ ថ្នាក់ដឹកនាំណាមួយរបស់ធនាគារជាតិនៃកម្ពុជា ឬ បុគ្គលណាមួយដែលធ្វើសកម្ម-ភាពក្រោមការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជាឡើយ ចំពោះការងារណាមួយដែលបានធ្វើ ឬ ខកខានមិនបានធ្វើដោយសុចរិត នៅក្នុងការប្រតិបត្តិអំណាច ឬ កាតព្វកិច្ចណាមួយដែលបំរុងដាក់ឱ្យ ឬ ត្រូវបានដាក់ឱ្យអនុវត្តនៅក្រោមច្បាប់នេះ ។

មាត្រា ២៣២.-

ក្នុងជំពូកនេះ ឧបករណ៍អាចជួញដូរបានមួចជា មូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា មានរួមទាំងឧបករណ៍ទាំងឡាយណា ដែលត្រូវបានប្រើប្រាស់ ឬ ត្រូវបានចាត់ទុកថាមានមុខងារដូចគ្នា ។

សម្រាប់ការរំលោភដោយនីតិបុគ្គល ការផ្តន្ទាទោសណាមួយក្នុងជំពូកនេះ អាចត្រូវអនុវត្តចំពោះនាយកណាម្នាក់ និងមន្ត្រីតាមឋានានុក្រមនៃនីតិបុគ្គលនោះ ។

កាលបើការរំលោភត្រូវបានធ្វើឡើងដោយភ្នាក់ងារណាម្នាក់ ការផ្តន្ទាទោសក្រោមជំពូកនេះអាចតម្រូវទៅលើ ឬ អនុវត្តចំពោះប្រធាន ភ្នាក់ងារ ឬ ទាំងពីរព្រមគ្នា ។

ទោសក្រោមជំពូកនេះ អាចធ្វើឡើងត្រួតថែមលើគ្នា និងមិនទាន់គិតដល់ទោសក្រោមច្បាប់ផ្សេងទៀតឡើយ ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

មាត្រា ២៣៣.-

ធនាគារជាតិនៃកម្ពុជា ត្រូវដាក់ចេញនូវបទប្បញ្ញត្តិវិធាន បទបញ្ជា និងសេចក្តីណែនាំ ក៏មួចជានីតិវិធីប្រតិបត្តិការសម្រាប់ការអនុវត្តច្បាប់នេះ ជាពិសេសចំពោះ :

-រចនាសម្ព័ន្ធជាឯកសមោធានសម្រាប់ការសម្គាល់និងការធ្វើចំណាត់ថ្នាក់គណនី

-គំរូនៃបញ្ជាទូទាត់

-ស្តង់ដារសម្រាប់បញ្ជូនបញ្ជាទូទាត់

-ទម្រង់នៃមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជាក៏ដូចជាទម្រង់នៃឯកសារផ្សេងទៀត ដែលត្រូវចេញផ្សាយក្រោមច្បាប់នេះ ឬ មួយដោយភាគី ឬ មន្ត្រីមានសមត្ថកិច្ច ដូចជាសេចក្តីជូនដំណឹង ឬវិរុទ្ធវាទ និងនីតិវិធីដែលពាក់ព័ន្ធ

-ភារកិច្ច នីតិវិធី និងការអនុវត្តរបស់ធនាគារក្នុងការទទួលបញ្ជាទូទាត់ និងបញ្ជាផ្សេងទៀតរបស់អតិថិជន និងដំណើរការប្រតិបត្តិការទូទាត់សងប្រាក់

-កិច្ចព្រមព្រៀងគណនីរបស់ធនាគារ និងព័ត៌មានដែលធនាគារត្រូវផ្តល់ឱ្យអតិថិជន

-ព័ត៌មានស្ថិតដែលចាំបាច់សម្រាប់ការអនុវត្តនយោបាយរូបិយវត្ថុឱ្យ បានសមស្រប និងមានប្រសិទ្ធភាពដែលធនាគារត្រូវផ្តល់ឱ្យ ធនាគារជាតិនៃកម្ពុជា និង

-ប្រការផ្សេងទៀតដែលមានចែងនៅក្នុងបទប្បញ្ញត្តិដោយឡែកនៃច្បាប់នេះ ។

បទបញ្ជានេះអាចត្រូវបានធ្វើសម្រាប់ការពារអតិថិជន ភាពសុចរិត និង ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងការប្រើប្រាស់ឧបករណ៍អាចជួញដូរបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីគោលបំណងនេះ បទបញ្ជាអាចរឹតត្បិត ដាក់កំហិត ឬ ហាមឃាត់ការប្រើប្រាស់មូលប្បទានប័ត្រ ឬ បញ្ជាទូទាត់ផ្សេងទៀត ចំពោះប្រភេទគណនី និងបុគ្គលដែលត្រូវបានកំណត់ ឬ ដាក់លក្ខខ័ណ្ឌសម្រាប់ការប្រើប្រាស់នេះ ។ បទបញ្ជាដែលចេញក្រោមច្បាប់នេះ ក៏អាចដាក់កំហិតការទទួលខុសត្រូវរបស់ឯកត្តជន ឬ ដាក់កំហិតនិងដាក់លក្ខខ័ណ្ឌដំបូងសម្រាប់ការទទួលខុសត្រូវនោះ នៅក្នុងទំនាក់ទំនងជាមួយឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ពី ឬ ទៅគណ-

124/128

នីដែលប្រើប្រាស់ជាបឋម ដើម្បីមូលហេតុបុគ្គល ឬ គ្រួសារ និងមិនមែនសម្រាប់គោលដៅអាជីវកម្ម ។

បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ អាចកំណត់ស្តង់ដារដែលប្រើសម្រាប់វាស់វែងការអនុវត្តកាតព្វកិច្ចនៅក្រោមច្បាប់នេះ និងកែប្រែក្នុងអំឡុងពេល ឬ កាលកំណត់ចុងក្រោយណាមួយសម្រាប់ការធ្វើ ឬ មិនធ្វើសកម្មភាពដែលកំណត់ឡើងដោយច្បាប់នេះ ចំពោះប្រភេទទាំងអស់ ឬ ប្រភេទដោយឡែកនៃភាគីអ្នកចូលរួមឧបករណ៍អាចជួញដូរបាន ឬ ប្រតិបត្តិការទូទាត់សងប្រាក់ ។

បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ ជាចំណងនីតិ-ស្ថានុកូលលើគ្រប់ភាគីទាំងអស់ដែលជំណើរការបញ្ជាទូទាត់ និងបដិសេធចោលកិច្ចព្រមព្រៀង ដែលគ្មានសង្គតិភាពរួមទាំងវិធានជាត់ទាត់អន្តរធនាគារទៅតាមកម្រិតមិនមានសង្គតិភាពនោះ ។

បទប្បញ្ញត្តិ វិធាន បទបញ្ជា និងសេចក្តីណែនាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ អាចគ្រប់គ្រងលើនីតិវិធី និងផ្តល់សំរាប់កំរិតកំណត់ពេលវេលា សិទ្ធិ និងដំណោះស្រាយ ក្នុងករណីដែលមានហេតុការណ៍បន្ទាន់ផ្សេងៗដូចជាកុំព្យូទ័រខូច ឬ ប្រព័ន្ធមិនដំណើរការ ដែលនាំឱ្យរាំងស្ទះដល់ប្រតិបត្តិការទូទាត់សងប្រាក់ ឬ ការអនុវត្តន៍បញ្ជាទូទាត់ ។ បទប្បញ្ញត្តិ វិធាន បទបញ្ជា និងសេចក្តីណែនាំទាំងនោះអាចលួរទុកនូវរាល់កាតព្វកិច្ច និងកំរិតកំណត់ពេលវេលាសំរាប់រយៈពេលនៃហេតុការណ៍បន្ទាន់នោះ ។

បទបញ្ជា និងសេចក្តីប្រកាសទាំងអស់ សម្រាប់ការអនុវត្តទូទៅ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច ។ បទបញ្ជា និងសេចក្តីប្រកាសនោះនឹងចូលជាធរមាននៅថ្ងៃផ្សព្វផ្សាយ ឬ នៅថ្ងៃក្រោយមកទៀត តាមការកំណត់ជាក់លាក់ ។

មាត្រា ២៣៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។ ក្នុងករណីមានទំនាស់រវាងច្បាប់នេះ និងច្បាប់ដទៃទៀត ក្រៅពីករណីដែលមានចែងជាពិសេសនៅក្នុងច្បាប់នេះ បទប្បញ្ញត្តិនៃច្បាប់នេះត្រូវមានអានុភាព ។

ថ្វែនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ជការ
នរោត្តម សីហមុនី

តាមយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
ហត្ថលេខា
ជា ចាន់តូ

លេខ ៤២៣ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាវី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

សហគ្រាសពាណិជ្ជកម្ម

ព្រះរាជក្រម

នស/រកម/០៦០៤/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ភានគុបិជាតិសាសនា អគ្គមហាឧបត្ថម្ភ ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជ្ជូបរណសន្តិ សុគបច្ចលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកស/០៧០៤/១២៤ ចុះថ្ងៃចិ ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រហលេខ ០២នស/៩៤ ចុះថ្ងៃចិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃចិ ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់លេខក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃចិ ១៧ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកចិ ២ និតិកាលចិ ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើចម្រង់ និងតតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃចិ ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកចិ ៩ និតិកាលចិ ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះកំណត់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

មាត្រា ២.-

នៅក្នុងច្បាប់នេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-បុគ្គលមានន័យថារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២-មន្ត្រីចុះបញ្ជីមានន័យថាអ្នកចុះបញ្ជី ដែលបានតែងតាំងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៣-ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមានន័យថាការិយាល័យដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

៤-បុត្រសម្ព័ន្ធមានន័យថាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនផ្សេងទៀត ដែលជា “ក្រុមហ៊ុនមេ” ។

ក-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺក្រុមហ៊ុនសហកម្ម-សិទ្ធិមេនោះកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ ។

ខ-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនគឺក្រុមហ៊ុនមូលធនមេនោះត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ។

មាត្រា ៣.-

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជី និងភ្នាក់ងារចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដ និងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់ភ្នាក់ងារចុះបញ្ជី ហើយភ្នាក់ងារចុះបញ្ជីនោះ ត្រូវតែជារូបវន្តបុគ្គល ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ ។ ភ្នាក់ងារចុះបញ្ជីមានសិទ្ធិទទួលលិខិតផ្លូវការ និងឯកសារទាំងឡាយ ព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី និងការផ្លាស់ប្តូរភ្នាក់ងារចុះបញ្ជីក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរ ។

ក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះ ត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

ឯកសារទាំងឡាយនៃព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រគល់ឱ្យទៅភ្នាក់ងារចុះបញ្ជីនៅឯទីស្នាក់ការចុះបញ្ជី នៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់ ។

ឯកសារទាំងឡាយអាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករទូទៅបានក្នុង

ករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ឬ អាចប្រគល់ឱ្យទៅអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន ។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះ ត្រូវធ្វើឱ្យទៅក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្មស្រាប់ ។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីត្រូវបានចាត់ទុកថាជាការបញ្ជូនទៅក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធននោះ ។

មាត្រា ៥.-

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ។ នាមករណ៍ជាភាសាខ្មែរ ត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀតប្រសិនបើមាន ។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់ ។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរ នៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បៃបបទឯកសារ ឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់ និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ។

មាត្រា ៦.-

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ដែលខកខានមិនបានបង់សោហ៊ុយប្រចាំពិន័យ ការប្រាក់ដែលជំពាក់ក្រសួងពាណិជ្ជកម្ម ត្រូវហាមឃាត់ក្នុងការប្តឹងផ្តល់

ឬ ប្តឹងតវ៉ាក្នុងរឿងក្តីរដ្ឋប្បវេណីរហូតដល់បានសងគ្រប់ទ្វរសោហ៊ុយ ប្រាក់ពិន័យ និង ការប្រាក់នោះ ។

វាក្យខ័ណ្ឌនេះ មិនហាមឃាត់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនធ្វើការ ប្តឹងតវ៉ាចំពោះការកំណត់សោហ៊ុយ ប្រាក់ពិន័យ ឬការប្រាក់ដែលខ្លួនត្រូវជំពាក់ឡើយ ។

ប្រសិនបើភាគីមួយប្តឹងជំទាស់ថា ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ជំពាក់ក្រសួងពាណិជ្ជកម្មទ្វរសោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ត្រូវដាក់បង្កាន់ដៃទទួលប្រាក់របស់ ក្រសួងពាណិជ្ជកម្មទៅឱ្យតុលាការពិនិត្យ ។ តុលាការត្រូវទទួលយកបង្កាន់ដៃនោះជា ភស្តុតាង រហូតដល់មានតឹកតាងផ្សេងៗទៀត ។

មាត្រា ៧.-

ក្រុមហ៊ុនដែលគ្រប់គ្រងដោយច្បាប់នេះ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

ជំពូកទី ២
ក្រុមហ៊ុនសហកម្មសិទ្ធិ
ផ្នែកទី ១
ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ
ក.-ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

មាត្រា ៨.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬ ច្រើន ដែលជាក់រួម គ្នាទ្វរទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជ-កិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ ។

មាត្រា ៩.-

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ប្រសិនបើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

មាត្រា ១០.-

ក្នុងករណីដែលកិច្ចសន្យានោះមិនច្បាស់លាស់ តុលាការត្រូវពិចារណាទ្ធរាល់វិធានដូចខាងក្រោម ដើម្បីកំណត់ថាតើភាគីទាំងអស់មានគោលបំណងរួមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឬទេ :

ក-ក្នុងករណីដែលបុគ្គលពីរ ឬច្រើន កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលទាំងនោះចែករំលែកប្រាក់ចំណេញដែលបានមកដោយទ្រព្យទាំងនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ កើតឡើងដោយទ្រព្យសម្បត្តិរួមឬទេ ។

ខ-ក្នុងករណីដែលបុគ្គលពីរ ឬច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ច ថាតើបុគ្គលទាំងនោះ មានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិណាមួយដែលបង្កើតប្រាក់ចំណូលនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួមនោះឬទេ ។

មាត្រា ១១.-

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះ ត្រូវបានធ្វើឡើងចប់សព្វគ្រប់លើកលែងតែកិច្ចសន្យាមានចែងផ្សេងពីនេះ ។

មាត្រា ១២.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហ-កម្មសិទ្ធិករទូទៅម្នាក់ៗ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ពី

ពេលដែលបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចតទៅ :

ក-ជាម្ចាស់លើចលនទ្រព្យនិងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ។

ខ-ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ។

គ-ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន ។

ឃ-ប្តឹង ឬ ត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន ។

មាត្រា ១៣.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរលុះត្រាតែ :

ក-ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (ហាសិបមួយ)ភាគរយត្រូវបានកាន់កាប់ដោយអ្នកបរិវត្តបុគ្គល ឬ នីតិបុគ្គលមានសញ្ជាតិខ្មែរ ។

មាត្រា ១៤.-

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហ-កម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ហើយនៅខាងក្រោយ ឬ ខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា “ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ” ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច ។

មាត្រា ១៥.-

សហកម្មសិទ្ធិករទូទៅម្នាក់។ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ។

ខ_ ទំនាក់ទំនងពីសហកម្មសិទ្ធិករទូទៅម្នាក់ទៅសហកម្មសិទ្ធិករទូទៅម្នាក់ទៀត

មាត្រា ១៦._

សហកម្មសិទ្ធិករទូទៅម្នាក់ៗអាច :

ក-បង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬ ជាការសន្យាថានឹងផ្តល់នូវសេវានាពេលអនាគត ។

ខ-ជាក់ភាគទុនជាសេវាដែលជាចំណេះដឹង ឬ សកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ ។

មាត្រា ១៧._

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាភ្នូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចំពោះរាល់អ្វីៗដែលខ្លួនបានសន្យាចូលរួមទៅក្នុងក្រុមហ៊ុន ។

មាត្រា ១៨._

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិជាភាគទុន សហកម្មសិទ្ធិករទូទៅនោះត្រូវធ្វើការផ្ទេរសិទ្ធិពីម្ចាស់ ឬ ពីសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

មាត្រា ១៩._

នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមបង់ភាគទុនទ្រង់ចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួល

ខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ ។

មាត្រា ២០.-

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ភាគទុនជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ ។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្ម-សិទ្ធិករទូទៅជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព ។

មាត្រា ២១.-

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានទាំងភាគទុនជាសាច់ប្រាក់ និងជាវត្ថុ ។ ភាគទុនជាវត្ថុត្រូវរាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការរាយតម្លៃនោះ ។

ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលទ្វេភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពទេ ។

មាត្រា ២២.-

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ ។

មាត្រា ២៣.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីការជាប់កាតព្វ-កិច្ចក្នុងការរួមចំណែកការខាតបង់ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាពចំពោះតតិយជនឡើយ ។

មាត្រា ២៤.-

សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា ។

ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះ ត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងបីនោះ ។

មាត្រា ២៥.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនទូរាល់ផលកម្រៃនិងប្រាក់ចំណេញទាំងឡាយដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវ-កម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហ-កម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ ។

មាត្រា ២៦.-

គ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជ-កិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

មាត្រា ២៧.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ទូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ ។

មាត្រា ២៨.-

សហកម្មសិទ្ធិករទូទៅដែលប្រកបកិច្ចការពាណិជ្ជកម្មដោយស្មោះត្រង់ចំពោះក្រុមហ៊ុន មានសិទ្ធិទទួលទូវសំណងនៃការខូចខាតដែលខ្លួនបានធ្វើក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិទទួលទូវសំណងនៃការខូចខាតចំពោះកិច្ចសន្យាដែលខ្លួនបានធ្វើ និងការខាតបង់ទាំងឡាយដែលខ្លួនទទួលរងនៅក្នុងការប្រតិបត្តិពាណិជ្ជកិច្ចសម្រាប់ក្រុមហ៊ុននោះ ។

មាត្រា ២៩.-

មាត្រា ២៨ នៃច្បាប់នេះអនុវត្តនៅពេលដែល :

ក-សហកម្មសិទ្ធិករទូទៅ ក្នុងនាមខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមគ្នា ជាម្ចាស់បំណុលនៃកូនបំណុលតែមួយ ។

ខ-បំណុលទាំងពីរនឹងត្រូវសង ។

គ-កូនបំណុលត្រូវសងទៅសហកម្មសិទ្ធិករទូទៅ ប៉ុន្តែមិនសងទៅក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។ ក្នុងករណីនេះ ចំនួននៃប្រាក់សំណងដែលសហកម្មសិទ្ធិករទូទៅទទួល ត្រូវបែងចែកទៅតាមសមាមាត្រទៅនឹងបំណុលផ្ទាល់ខ្លួន និងបំណុលចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

មាត្រា ៣០.-

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅបាន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះ ប្រើប្រាស់ក្នុងប្រយោជន៍របស់ក្រុមហ៊ុន ។

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម
សិទ្ធិទូទៅបានក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន លុះត្រាតែសហកម្មសិទ្ធិករទូទៅ
នោះមានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ។

រាល់សហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-
សិទ្ធិទូទៅ នៅក្នុងករណីមិនប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើ
ប្រាស់ទ្រព្យសម្បត្តិនោះ ។

មាត្រា ៣១.-

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅដោយ
គ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូ
ទៅបានឡើយ ។

សហកម្មសិទ្ធិករទូទៅម្នាក់ អាចប្រគល់សិទ្ធិឱ្យទៅបុគ្គលផ្សេង ដើម្បីទទួលប្រាក់
កាសជំនួសខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករទូទៅដទៃ
ទៀតឡើយ ។ ការប្រគល់សិទ្ធិបែបនេះ មិនធ្វើឱ្យអ្នកទទួលសិទ្ធិនោះក្លាយទៅជាសហ-
កម្មសិទ្ធិករទូទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។

មាត្រា ៣២.-

សហកម្មសិទ្ធិករទូទៅម្នាក់ អាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុន
សហកម្មសិទ្ធិទូទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំង
អស់ ។

មាត្រា ៣៣.-

ភាគទុនជាទ្រព្យ ឬ ប្រាក់ចំណេញរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់នៃក្រុម
ហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានប្រើប្រាស់ជាទ្រព្យធានាទ្រព្យកាតព្វកិច្ចផ្ទាល់ខ្លួន
របស់សហកម្មសិទ្ធិករទូទៅនោះ ។ ទ្រព្យធានានោះ ត្រូវមានការយល់ព្រមជាឯកច្ឆន្ទ
ពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

មាត្រា ៣៤.-

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចធ្វើសេចក្តីសម្រេចអំពីសិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

មាត្រា ៣៥.-

សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬ បុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន ។

អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដរាបណាអ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែងដោយសំឡេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

មាត្រា ៣៦.-

នៅពេលដែលបុគ្គលច្រើនរូបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ៗ អាចអនុវត្តសកម្មភាពដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

មាត្រា ៣៧.-

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហ-កម្មសិទ្ធិករទូទៅផ្សេងទៀតដែរ ។

មាត្រា ៣៨.-

រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ ។

មាត្រា ៣៩.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ ។

នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬ មិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្ម-សិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ ។

គ_ ទំនាក់ទំនងនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាមួយតតិយជន

មាត្រា ៤០._

សហកម្មសិទ្ធិករទូទៅម្នាក់ៗគឺជាភ្នាក់ងារបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ហើយសហកម្មសិទ្ធិករទូទៅទាំងនោះត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុនទ្វរាល់អំពើដែលខ្លួនបានអនុវត្ត ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធភាព ។

មាត្រា ៤១._

សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវបានជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិតក្នុងរង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬនៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

មាត្រា ៤២._

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាទ្វរាកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

តតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬទ្រព្យសម្បត្តិពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ ។

មាត្រា ៤៣._

បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ ។ ប៉ុន្តែបំណុលទាំងឡាយ

ណាដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ បំណុលនោះអាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែបុគ្គលនោះមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ ។

មាត្រា ៤៤.-

ការជូនដំណឹងទៅសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬ ការដឹងឮរបស់សហកម្មសិទ្ធិ-ករទូទៅណាម្នាក់ដែលពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមហ៊ុន ត្រូវចាត់ទុកថាជាសេចក្តីជូនដំណឹង និងការដឹងឮដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះដែរ លើកលែងតែមានការក្លែងបន្លំ ដែលប្រព្រឹត្តឡើងដោយការឃុបឃិតពីសហកម្មសិទ្ធិករទូទៅនោះចំពោះក្រុមហ៊ុន ។

មាត្រា ៤៥.-

បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ ឬ ដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្ម-សិទ្ធិករទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ ។

ក្នុងករណីមានបុគ្គលក្លែងបន្លំ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវចំពោះតតិយជនណាឡើយ លើកលែងតែក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះមិនបានចាត់វិធានការដើម្បីការពារតតិយជននោះ ក្រោយពេលដែលក្រុមហ៊ុនបានដឹងថាមានការក្លែងបន្លំហើយ ។

មាត្រា ៤៦.-

សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលមិនបានប្រកាសចេញមុខដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលស្គាល់ថាជាសហកម្ម-សិទ្ធិករទូទៅកំពាំងមុខ ។ សហកម្មសិទ្ធិករទូទៅនោះ ត្រូវទទួលខុសត្រូវចំពោះតតិយ

ជនទាំងឡាយនូវរាល់កាតព្វកិច្ច ដូចសហកម្មសិទ្ធិករទូទៅទាំងឡាយដែលបានប្រកាសចេញមុខដែរ ។

មាត្រា ៤៧.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចបោះចេញ ឬបែងចែកមូលបត្រ ឬប័ណ្ណដែលអាចលក់ដូរបានទៅឱ្យសាធារណជនឡើយ ។

កិច្ចសន្យាដែលចូលជាធរមានទៅក្នុងការបោះចេញមូលបត្រ ឬប័ណ្ណដែលធ្វើឡើងផ្ទុយពីមាត្រានេះត្រូវចាត់ទុកជាមោឃៈ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសងនូវការខូចខាតទាំងឡាយដែលបង្កឡើងពីមោឃភាពនៃកិច្ចសន្យាមូលបត្រ ឬប័ណ្ណទៅឱ្យតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ។

ឃ- ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ

មាត្រា ៤៨.-

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនៅពេលដែលបុគ្គលនោះ :

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្សីយធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬបញ្ជាឱ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ ។

មាត្រា ៤៩.-

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឱ្យមានការរំលាយជាស្ងួយប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជី ដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ កិច្ចសន្យានោះត្រូវធ្វើការកែប្រែឱ្យស្របតាមនោះដែរ ។

មាត្រា ៥០.-

បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រៅពីដោយសារការផ្ទេរ ឬដោយសារការរឹបអូស អត្ថប្រយោជន៍របស់ខ្លួនបុគ្គលនោះអាចទទួលនូវតម្លៃណាមួយនៃអត្ថប្រយោជន៍របស់ខ្លួន អំពីការអស់សិទ្ធិជាសហ-កម្មសិទ្ធិករទូទៅនេះបាន ។ សហកម្មសិទ្ធិករទូទៅដទៃទៀត ត្រូវបង់ការចំណាយជាចាំបាច់ដល់បុគ្គលនោះ នូវតម្លៃណាមួយដែលអាចធ្វើទៅបានដោយឆាប់រហ័សជាមួយនិងការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ។

តម្លៃនៃអត្ថប្រយោជន៍ត្រូវបានកំណត់ ដូចដែលមានចែងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬកិច្ចសន្យាក្នុងចំណោមសហកម្មសិទ្ធិករទូទៅទាំងឡាយ ។

បើមិនដូច្នោះទេ តម្លៃនោះត្រូវកំណត់ដោយអ្នកឯកទេសដែលបានជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយ ឬដោយតុលាការ ។

មាត្រា ៥១.-

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលមាន

ចែងអំពីការបម្រុងទុកទ្រព្យសិទ្ធិដកខ្លួន សហកម្មសិទ្ធិករទូទៅនោះអាចដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន តាមការជូនដំណឹងអំពីការដកខ្លួនដោយសុទ្ធចិត្ត ។

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលកំណត់ អាចដកខ្លួនចេញបាន តែក្នុងករណីមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយ បើមិនដូច្នោះទេលុះត្រាតែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចែងផ្សេងពីនេះ ។

មាត្រា ៥២.-

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលមានការជំទាស់ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះបាន លុះត្រាតែតុលាការពិចារណាឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុសរបស់សហកម្មសិទ្ធិករទូទៅ ។

១- ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

មាត្រា ៥៣.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម :

ក-មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

-គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

-គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត

-តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ

ខ- តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់ ។ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន ។

មាត្រា ៥៤.-

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានកាលកំណត់មួយនៃកិច្ចសន្យា អាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯក-ច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

មាត្រា ៥៥.-

ការទទួលជាកំរួមន្ទរអត្ថប្រយោជន៍ទាំងអស់ទៅក្នុងដៃសហកម្មសិទ្ធិករទូទៅតែម្នាក់ មិនមែនជាមូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ដរាបណាមានបុគ្គលណាមួយផ្សេងទៀតក្លាយជាសហកម្មសិទ្ធិករទូទៅ ក្នុងអំឡុង ១២០ (មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលអត្ថប្រយោជន៍នោះដាក់បញ្ចូលគ្នា ។

មាត្រា ៥៦.-

សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់ ។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងជាមុនអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ ។

មាត្រា ៥៧.-

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់ទៅនឹងសិទ្ធិតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬ មិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

មាត្រា ៥៨.-

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បន្តរហូតដល់ចប់ទ្វារការជម្រះបញ្ជីរបស់ក្រុមហ៊ុននោះ ។

មាត្រា ៥៩.-

សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬ ផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬ នៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ៦០.-

នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សិទ្ធិក្នុងការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី ។

អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ អ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងអស់ ។

អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

មាត្រា ៦១.-

អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន ។

អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិដែលនៅសេសសល់ ឱ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។

ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ ។

មាត្រា ៦២.-

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឱ្យទុកជាភស្តុតាង ។

មាត្រា ៦៣.-

ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក ។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ផ្នែកទី ២

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

មាត្រា ៦៤.-

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬ ច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ។

មាត្រា ៦៥.-

បុគ្គលម្នាក់អាចជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។

បុគ្គលម្នាក់ដែលជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផងក្នុងពេលតែមួយ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ ។

មាត្រា ៦៦.-

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ។ ក្នុងករណីកិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅ

ទាំងអស់ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចម្នាក់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

រយៈពេលនៃកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនត្រូវលើសកំណត់ ៩៩(កៅសិបប្រាំបួន)ឆ្នាំឡើយ ប៉ុន្តែអាចពន្យារពេលបន្តបាន ។

មាត្រា ៦៧.-

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានបង្កើតតាមកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

ក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេ ក្រុមហ៊ុននោះ ត្រូវបានចាត់ទុកថា ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ក្នុងករណីនេះ ក្រុមហ៊ុនប្រភេទនេះមិនមាននីតិបុគ្គលិកលក្ខណៈទេ ។

មាត្រា ៦៨.-

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហ-កម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ។ នៅខាងក្រោយ ឬ ក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា “ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត” ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម ។

មាត្រា ៦៩.-

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះអាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជី ការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត ។

មាត្រា ៧០.-

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬ ជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា ។

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវា ពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត ។

មាត្រា ៧១.-

សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ មានសិទ្ធិទទួលចំណែកនៃប្រាក់ចំណេញរបស់ខ្លួន ។ ប៉ុន្តែប្រសិនបើការទទួលប្រាក់ចំណេញនោះ នៅតែធ្វើឱ្យមានឱនភាពដល់ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតដែលបានទទួលចំណែកនៃប្រាក់ចំណេញនោះ ត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទល់ទៅនឹងឱនភាពភាគទុនរបស់ខ្លួន ។

មាត្រា ៧២.-

សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវទៅលើតែចំនួនទឹកប្រាក់ ឬ តម្លៃនៃទ្រព្យសម្បត្តិដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនប៉ុណ្ណោះ ។

មាត្រា ៧៣.-

សហកម្មសិទ្ធិករមានកម្រិត ដែលមានឈ្មោះនៅក្នុងនាមករណ៍ក្រុមហ៊ុនសហ-កម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដូចជាសហកម្មសិទ្ធិករទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានបញ្ជាក់ច្បាស់លាស់ ។

មាត្រា ៧៤.-

សហកម្មសិទ្ធិករទូទៅមានសិទ្ធិនិងកាតព្វកិច្ចដូចជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។ សហកម្មសិទ្ធិករទូទៅ ត្រូវរាយការណ៍ពីការគ្រប់គ្រងដល់សហកម្មសិទ្ធិករមានកម្រិតទាំងឡាយ ។

សហកម្មសិទ្ធិករទូទៅមានកាតព្វកិច្ចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិសហកម្ម-សិទ្ធិករមានកម្រិតដទៃទៀត ដែលមាននៅក្នុងដើមទុនរបស់ក្រុមហ៊ុន ។

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអាចជៀសវាងកាតព្វកិច្ចនេះបានទេ ។

មាត្រា ៧៥.-

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាទូរបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតចំពោះតតិយជន ។

មាត្រា ៧៦.-

សហកម្មសិទ្ធិករមានកម្រិត អាចទទួលប្រាក់បៀវត្សពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន ។

មាត្រា ៧៧.-

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងនៅក្នុងករណីណាក៏ដោយ សហកម្មសិទ្ធិករមានកម្រិតមិនអាចដកចំណែកណាមួយនៃភាគទុនរបស់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ និងក្រោយពីការដកនោះ ទ្រព្យសម្បត្តិដែលនៅសល់ក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ដើម្បីដោះបំណុលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបាន ។

មាត្រា ៧៨.-

សហកម្មសិទ្ធិករមានកម្រិតម្នាក់ អាចធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ ។

ក្នុងទំនាក់ទំនងទៅនឹងតតិយជន សហកម្មសិទ្ធិករមានកម្រិតដែលបានផ្ទេរអត្ត-ប្រយោជន៍របស់ខ្លួនរួចមកហើយនោះ នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត ។

មាត្រា ៧៩.-

សហកម្មសិទ្ធិករមានកម្រិតមិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ ។

សហកម្មសិទ្ធិករមានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការឹកចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់ជាគំនិតក្នុងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ជំណាក់កាល ។

សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចាក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬ មិនអនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុននោះឡើយ ។

សហកម្មសិទ្ធិករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលកើតឡើងដោយសារការប្រព្រឹត្តទាំងនោះ ។

សហកម្មសិទ្ធិករមានកម្រិត អាចអនុញ្ញាតឱ្យទទួលខុសត្រូវដូចសហកម្មសិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបានរៀបរាប់រួចហើយ ឬ សារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមជំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយមានភស្តុតាងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅពិតប្រាកដមែន ។

មាត្រា ៨០.-

នៅពេលសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបានទេ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងជំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០(មួយរយម្ភៃ)ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវបានរំលាយ ។

មាត្រា ៨១.-

តតិយជនដែលជាម្ចាស់បំណុលអាចប្តឹងទាមទារបំណុលពីក្រុមហ៊ុនសហកម្ម-សិទ្ធិមានកម្រិតនិងពីសហកម្មសិទ្ធិករទូទៅបានដូចគ្នា ដូចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។

មាត្រា ៨២.-

នៅពេលណាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនគ្រប់គ្រាន់ទេ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះតតិយជនទូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ សហ-កម្មសិទ្ធិករមានកម្រិត ត្រូវទទួលខុសត្រូវទូវបំណុលត្រឹមតែចំនួនភាគទុន ដែលខ្លួនបានព្រមព្រៀងដាក់ជាមួយគ្នា ដោយមិនគិតការផ្ទេរអត្ថប្រយោជន៍ណាមួយរបស់ខ្លួនឡើយ ។

មាត្រា ៨៣.-

ក្នុងករណីបំណុលកើនលើសពីដើមទុន ឬ ក្នុងករណីកំរ៉ៃយធននៃក្រុមហ៊ុនសហ-កម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗដែលជាម្ចាស់បំណុល មិនអាចទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ រហូតដល់ម្ចាស់បំណុលដទៃទៀតនៃក្រុមហ៊ុនមានកម្រិតនេះ ត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

មាត្រា ៨៤.-

វិធាននៃការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ ។

ជំពូកទី ៣

ក្រុមហ៊ុនមូលធន

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៨៥.-

ច្បាប់នេះអនុញ្ញាតឱ្យបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើម្បីប្រកបពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបង្កើតឡើងក្រោមច្បាប់នេះក្នុងគោលបំណងធ្វើអាជីវកម្ម ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានបានឡើយ ។

មាត្រា ៨៦.-

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនហើយត្រូវមានលក្ខណៈសម្គាល់ដូចតទៅ :

ក-ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី ០២(ពីរ)នាក់ រហូតដល់៣០(សាមសិប)នាក់ ។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ ដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្តីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន ។

ខ-ក្រុមហ៊ុននោះមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬ មូលបត្រដទៃទៀតជាសាធារណៈបានឡើយ ។ ប៉ុន្តែអាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុន

សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន ។ ក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន ។

គ-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬ ច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់ ។

ឃ-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ៨៧.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីចោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន ។

មាត្រា ៨៨.-

នៅក្នុងជំពូកនេះ ពាក្យបច្ចេកទេសទាំងឡាយមានន័យដូចតទៅ :

១-លក្ខន្តិកៈ មានន័យថាលក្ខន្តិកៈដើម ឬ លក្ខន្តិកៈធ្វើការកែប្រែ ។

២-សវនករ មានន័យថាគណនេយ្យករជំនាញម្នាក់ដែលធ្វើកិច្ចការក្នុងលក្ខណៈជាបុគ្គល ឬ ធ្វើកិច្ចការក្នុងក្រុមហ៊ុនគណនេយ្យណាមួយ ។

៣-កាតព្វកិច្ចបំណុលគឺជាសញ្ញាប័ណ្ណ ឬ ជាលិខិតបញ្ជាក់បំណុលផ្សេងៗ ឬ លិខិតស្នាមរបស់ក្រុមហ៊ុនដែលអាចធានា ឬ មិនអាចធានាបាន ។

៤-មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមានន័យថាមន្ត្រីដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីអនុវត្តការងារនៃច្បាប់នេះ ។

៥-អភិបាលមានន័យថាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

៦-ស្ថាបនិកក្រុមហ៊ុនមានន័យថារួមបន្តបុគ្គលដែលចុះហត្ថលេខាលើ

លក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៧-សេចក្តីសម្រេចសាមញ្ញមានន័យថាជាសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើនដាច់ខាត ដែលបានចូលរួមក្នុងការបោះឆ្នោត ។

៨-ភាគហ៊ុនអាចរំលោះបានមានន័យថាជាភាគហ៊ុនដែលត្រូវបានចេញដោយក្រុមហ៊ុនណាមួយ :

-ក្រុមហ៊ុននោះអាចទិញ ឬ រំលោះបានទៅតាមតម្រូវការរបស់ក្រុមហ៊ុន

-ក្រុមហ៊ុននោះត្រូវបានតម្រូវឱ្យដោយលក្ខន្តិកៈរបស់ខ្លួនដើម្បីទិញ ឬរំលោះនៅពេលកំណត់ណាមួយ ឬ ក៏ទៅតាមតម្រូវការរបស់ម្ចាស់ហ៊ុនណាម្នាក់ ។

៩-សើរីនៅក្នុងទំនាក់ទំនងទៅនឹងភាគហ៊ុនមានន័យថាជាការបែងចែកចំណាត់ថ្នាក់ភាគហ៊ុនឱ្យទៅជាប្រភេទភាគហ៊ុននីមួយៗ ។

១០-សេចក្តីសម្រេចពិសេសមានន័យថាជាសេចក្តីសម្រេចមួយត្រូវធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើន ២/៣(ពីរភាគបី) ដែលបានចូលរួមក្នុងការបោះឆ្នោត ឬ ពីការចុះហត្ថលេខារបស់សមាជិកភាគហ៊ុនទាំងឡាយ ដែលមានសិទ្ធិក្នុងការបោះឆ្នោតធ្វើសេចក្តីសម្រេចនោះ ។

១១-មូលបត្រមានន័យថា :

ក-ជាភាគហ៊ុននៅក្នុងសើរីនៃភាគហ៊ុនណាមួយ ឬ ជាភាគហ៊ុននៅក្នុងប្រភេទនៃភាគហ៊ុនណាមួយ ។

ខ-សញ្ញាប័ណ្ណ ។

គ-រួមបញ្ចូលទាំងវិញ្ញាបនបត្របញ្ជាក់ដែលផ្តល់ភស្តុតាងអំពីមូលបត្រទាំងឡាយ ។

មាត្រា ៨៩.-

ក្រុមហ៊ុនពាណិជ្ជកម្មមួយអាចធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយទៀតបាន ប្រសិនបើក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននោះ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សេង ឬ ក្រុមហ៊ុនទាំងពីរជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនតែមួយជួចគ្នា ឬ ក្រុមហ៊ុននីមួយៗត្រូវគ្រប់គ្រងដោយបុគ្គលតែមួយរូបជួចគ្នា ។

ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មពីរ ធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនមួយជួចគ្នានៅក្នុងពេលតែមួយ ក្រុមហ៊ុនទាំងនោះត្រូវចាត់ទុកថាជាក្រុមហ៊ុនដែលមានទំនាក់ទំនងធ្វើសម្ព័ន្ធភាពជាមួយគ្នា ។

មាត្រា ៩០.-

ស្ថាបនិក ឬ អភិបាលម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តន្វការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងការផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់ ។

ផ្នែកទី ២

ក.- ការបង្កើតក្រុមហ៊ុនមូលធន

មាត្រា ៩១.-

នីតិបុគ្គល ឬ រូបវន្តបុគ្គលមួយ ឬ ច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទេឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

មាត្រា ៩២.-

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ន្វវាក្យថា “ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត” ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម ។

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ឃ្លាវាក្យ ថា “ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត” ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬ ខាងក្រោម ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យឃ្លានាម-ករណ៍ ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធឃ្លានាមករណ៍ណា ដែលប្រហាក់ប្រហែលគ្នាធ្វើឱ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុន ផ្សេងទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬ នាមករណ៍មួយដែលផ្ទុយទៅ នឹងសណ្តាប់ធ្នាប់សាធារណៈដែលមានឈ្មោះអាស្រូវ ឬ ដែលមិនសមរម្យ ។ សេចក្តី សម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដែលពាក់ព័ន្ធ ទៅនឹងនាមករណ៍របស់ក្រុមហ៊ុនគឺជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ៩៣.-

លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងឱ្យលម្អិតខណ្ឌដូចខាងក្រោម :

ក-នាមករណ៍របស់ក្រុមហ៊ុន ។

ខ-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ-កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់ឱ្យអាជីវកម្មដែលក្រុមហ៊ុន នោះធ្វើពាណិជ្ជកិច្ច ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬ ច្រើនប្រភេទ ដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់ ។

ឃ-ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ ។

ង-ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើ បំណុលភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យចេញដោយក្រុមហ៊ុននោះ ។

ច-ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឱ្យចេញបំណុលភាគហ៊ុនលើសពីមួយ ប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃ ចារឹកលើបំណុលភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំង ឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបំណុលភាគហ៊ុននោះ ។

ឆ-ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុននោះ ត្រូវអនុញ្ញាតឱ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊េរីនីមួយៗ ដើម្បីកំណត់ឆ្លងបែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ ។

ជ-ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់បំណុភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងមានរបាយការណ៍ពីការកម្រិតនោះ ។

ឈ-ឈ្មោះនិងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ ។

ញ- ចំនួនអភិបាល ឬ ចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

មាត្រា ៩៤.-

លក្ខន្តិកៈត្រូវរួមបញ្ចូលផងដែរ នូវរាល់ចំណុចផ្សេងទៀតតាមការចាំបាច់ ។

មាត្រា ៩៥.-

លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬជាលិខិតសារការី ។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬ ហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ ។

មាត្រា ៩៦.-

ស្ថាបនិកក្រុមហ៊ុន ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការតម្កល់លក្ខន្តិកៈនោះជាមួយឯកសារសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត ។

មាត្រា ៩៧.-

ក្រោយពីការយល់ព្រមតម្កល់ទ្វរលក្ខន្តិក:របស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញទ្វរលិខិតបញ្ជាក់មួយជាសម្គាល់ ។

មាត្រា ៩៨.-

ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

ខ- សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន

មាត្រា ៩៩.-

ក្រុមហ៊ុនដែលបានបង្កើតឡើងតាមច្បាប់នេះមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិជួចរូបវន្តបុគ្គលដែរ ។

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជាបាន ។

មាត្រា ១០០.-

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចរបស់ខ្លួនធ្វើកិច្ចការរបស់ខ្លួន និងអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងដែនសមត្ថកិច្ចនៃប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែច្បាប់នៃប្រទេសនោះបានអនុញ្ញាត ។

មាត្រា ១០១.-

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរ លុះត្រាតែ :

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ។

មាត្រា ១០២.-

ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវ-កម្មរបស់ក្រុមហ៊ុន ។

មិនចាំបាច់មានបទបញ្ជាផ្ទៃក្នុងមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន ។

មាត្រា ១០៣.-

ក្រុមហ៊ុនមិនត្រូវប្រកបពាណិជ្ជកិច្ចណាមួយ ឬ អនុវត្តសិទ្ធិណាមួយ ដែលលក្ខន្តិក:របស់ខ្លួនបានហាមឃាត់ ឬ មិនត្រូវអនុវត្តសិទ្ធិណាមួយដែលផ្ទុយពីលក្ខន្តិក:របស់ខ្លួនឡើយ ។

មាត្រា ១០៤.-

ប្រការដែលក្រុមហ៊ុនបានប្រព្រឹត្តរំលោភលើលក្ខន្តិក:របស់ខ្លួន មិននាំឱ្យមានមោឃភាពដល់ការប្រព្រឹត្តនោះឡើយ ។ វិធាននេះអនុវត្តចំពោះគ្រប់ការប្រព្រឹត្ត រួមមានការផ្ទេរទ្រព្យសម្បត្តិទៅឱ្យក្រុមហ៊ុន ឬ ការផ្ទេរទ្រព្យសម្បត្តិពីក្រុមហ៊ុន ។

មាត្រា ១០៥.-

ប្រការដែលមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតម្កល់ទុកឯកសាររបស់ក្រុមហ៊ុន ឬ ប្រការដែលឯកសារសម្រាប់ធ្វើអធិការកិច្ច ដែលថតចម្លងទុកនៅក្នុងការិយាល័យក្រុមហ៊ុនមិនត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ទៅលើបុគ្គលណាមួយ ឬ ជាការជូនដំណឹងដល់បុគ្គលណាមួយឡើយ ។

មាត្រា ១០៦.-

ក្រុមហ៊ុន ឬ បុគ្គលម្នាក់ដែលធានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោមជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជនដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះ ឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបាន

ឡើយ ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ ឬ បានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួន ឬ ដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ :

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម ។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ ។

គ- ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬ ភ្នាក់ងារបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំង ឬ មិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្ត និងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬ ភ្នាក់ងារណាម្នាក់របស់ក្រុមហ៊ុនមិនមានសុពលភាព ឬ មិនយកជាការបានឡើយ ។

ច-ប្រាក់ខ្ចី និង ការធានា ឬ ការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ ។

គ_ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និង កំណត់ហេតុ

មាត្រា ១០៧._

នៅគ្រប់ពេលវេលា ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

មាត្រា ១០៨.-

ក្រុមហ៊ុនត្រូវផ្តល់ឱ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជ-កម្មនូវសេចក្តីជូនដំណឹងអំពីទីតាំង ទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិក:ដែលស្តីពីទីតាំង ឬ ពីការផ្លាស់ប្តូរទីតាំងស្នាក់ការចុះបញ្ជីនោះ ។

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជី ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ ។

មាត្រា ១០៩.-

ក្រុមហ៊ុនត្រូវរៀបចំនិងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួនន្ទូវ :

ក-លក្ខន្តិក: និងគ្រប់ការកែប្រែទាំងអស់ ។

ខ-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ហ៊ុន ។

គ-ឯកសារនៃសេចក្តីជូនដំណឹងតម្រូវឱ្យផ្ញើ ឬ តម្កល់ទុកជាឯកសារ ។

ឃ-បញ្ជីមូលបត្រ ។

មាត្រា ១១០.-

ម្ចាស់ហ៊ុន និងម្ចាស់បំណុលរបស់ក្រុមហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចពិនិត្យគ្រប់ឯកសារដូចដែលបានចែង នៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើសម្រង់បានដោយមិនគិតកម្រៃ ។

ប្រសិនបើក្រុមហ៊ុន ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាចធ្វើសម្រង់លើគ្រប់ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប ។

មាត្រា ១១១.-

រាល់បញ្ជីឈ្មោះម្ចាស់ហ៊ុន មិនត្រូវបានប្រើដោយបុគ្គលណាម្នាក់ឡើយ លើកលែងតែបុគ្គលនោះមានការពាក់ព័ន្ធជាមួយ :

ក-ការខិតខំប្រឹងប្រែងដើម្បីរកសំឡេងគាំទ្រក្នុងការបោះឆ្នោតពីម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

ខ-ការផ្តល់សំណើទិញភាគហ៊ុនរបស់ក្រុមហ៊ុន ។

គ-អ្វីផ្សេងៗទៀត ដែលទាក់ទងទៅនឹងការងាររបស់ក្រុមហ៊ុន ។

មាត្រា ១១២.-

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិបាលឱ្យបានសព្វគ្រប់ ។

កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬ នៅកន្លែងផ្សេងទៀត ដែលអភិបាលយល់ឃើញថាសមស្របហើយ ឯកសារទាំងនោះត្រូវបានបើកចំហ ដើម្បីឱ្យអភិបាលធ្វើការពិនិត្យបានគ្រប់ពេល ។

មាត្រា ១១៣.-

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់សម្រាប់រយៈពេល ១០(ដប់)ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ។

ប្រសិនបើបញ្ជីគណនេយ្យត្រូវរក្សាទុកនៅក្រៅព្រះរាជាណាចក្រកម្ពុជា ឯកសារច្បាប់ចម្លងនៃបញ្ជីគណនេយ្យនោះ ក៏ត្រូវបានរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីផងដែរ ។

មាត្រា ១១៤.-

ក្រុមហ៊ុន និងភ្នាក់ងាររបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកសៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ ។

មាត្រា ១១៥.-

លិខិតស្នាម ឬ កិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់ ឬ ភ្នាក់ងារម្នាក់របស់ក្រុមហ៊ុនមានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ ។

ឃ- អភិបាល និង អ្នកគ្រប់គ្រងក្រុមហ៊ុន

មាត្រា ១១៦.-

នៅពេលតម្កល់ទុកឯកសារ និងលក្ខន្តិកៈការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ស្ថាបនិកទាំងឡាយត្រូវផ្តល់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងរបស់អភិបាល ទៅតាមបែបបទដែលបានកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ស្ថាបនិកម្នាក់ ឬ អភិបាលម្នាក់អាចកោះប្រជុំក្រុមប្រឹក្សាភិបាលបានដោយផ្តល់ការជូនដំណឹងយ៉ាងតិច ០៥ (ប្រាំ)ថ្ងៃ តាមរយៈលិខិតទៅគ្រប់អភិបាល ។ លិខិតជូនដំណឹងនោះ មានបញ្ជាក់ពីពេលវេលា និងទីកន្លែងប្រជុំផង ។

អភិបាលដំបូងត្រូវកាន់តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកទីមួយ ។

មាត្រា ១១៧.-

ក្រុមប្រឹក្សាភិបាលដំបូងទាំងឡាយ ត្រូវចាត់ចែងមហាសន្និបាតលើកទី ១ របស់ម្ចាស់ហ៊ុនក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីក្រុមហ៊ុនបានបង្កើតឡើង ។ លិខិតជូនដំណឹងពីមហាសន្និបាតនោះ ត្រូវចែកយ៉ាងហោចណាស់ ២០ (ម្ភៃ)ថ្ងៃ មុនទៅបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាតនោះ ។ លិខិតជូនដំណឹងត្រូវបញ្ជាក់អំពីកាលបរិច្ឆេទទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតនោះ ។

មាត្រា ១១៨.-

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់ ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិច ០៣(បី) នាក់ ។

ម្ចាស់ហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេចសាមញ្ញ នៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ។

មាត្រា ១១៩.-

ក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។ លក្ខន្តិកៈក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

១-តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់ទ្រង់វសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២-កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣-កម្រិតប្រាក់បៀវត្ស ឬ ប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំសេចក្តីសម្រេច ។

៤-ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់ទ្រង់វលក្ខណៈជាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ ។

៥-ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬ លុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦-ស្នើសុំម្ចាស់ហ៊ុនទ្រង់វកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧-ស្នើសុំម្ចាស់ហ៊ុនដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ឬមួយភាគ ។

៨-ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

៩-ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌ នៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ ។

១០-ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១-ខ្ចីប្រាក់ ។

១២- បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣-ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤-ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥-រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

មាត្រា ១២០.-

រាល់រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី)ឆ្នាំ អាចបម្រើការងារជាអភិបាល ឬ ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ អភិបាលមិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬ មិនចាំបាច់តម្រូវឱ្យមានលក្ខណសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវ ។

មាត្រា ១២១.-

ក្នុងករណីលក្ខន្តិកៈក្រុមហ៊ុនមិនចែងអំពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ០២(ពីរ)ឆ្នាំ ហើយអាចត្រូវបោះឆ្នោតឱ្យសាជាថ្មីទៀតបាន ។

មាត្រា ១២២.-

អាណត្តិរបស់អភិបាល អាចត្រូវកំណត់ជាតំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ ។

មាត្រា ១២៣.-

លក្ខន្តិក:របស់ក្រុមហ៊ុនអាចចែងបានផងដែរពីសិទ្ធិរបស់អ្នកកាន់ប័ណ្ណភាគហ៊ុន នៃប្រភេទនីមួយៗ ដើម្បីបោះឆ្នោតជ្រើសរើសអភិបាលមួយ ឬ ច្រើន ដែលអភិបាលនោះបម្រើអាណត្តិ និងមានសិទ្ធិចាត់ចែងការងារផ្សេងៗ ដែលបានចែងក្នុងលក្ខន្តិក: ។ អាណត្តិនៃមុខតំណែង និង សិទ្ធិនៃការបោះឆ្នោតរបស់អភិបាលប្រភេទមួយអាចច្រើនជាង ឬ តិចជាងអភិបាលប្រភេទមួយផ្សេងទៀតបាន ។

មាត្រា ១២៤.-

អភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបានដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។

មាត្រា ១២៥.-

អភិបាលអាចលាលែងពីមុខតំណែងនៅពេលណាក៏បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន ។ ការលាលែងពីមុខតំណែងនេះ ត្រូវមានសុពលភាពភ្លាមឬ មានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិតជូនដំណឹងនោះ ។

អភិបាលម្នាក់ ដែលជាអភិបាលនៅសល់ចុងក្រោយក្នុងក្រុមហ៊ុន ហើយអភិបាលនោះធ្វើការលាលែងមុនពេលអភិបាលផ្សេងត្រូវបានតែងតាំង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានបង្កឡើងដល់ក្រុមហ៊ុនដោយសារការលាលែងរបស់ខ្លួន ។

មាត្រា ១២៦.-

បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងាររបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងជំនួសជាថ្មី ។

មាត្រា ១២៧.-

ក្រុមប្រឹក្សាភិបាលត្រូវបោះឆ្នោតជ្រើសតាំងប្រធានពីក្នុងចំណោមសមាជិករបស់ខ្លួន ។ ប្រធានក្រុមប្រឹក្សាភិបាលអាចត្រូវដកហូតពីមុខតំណែងដោយសំឡេងភាគច្រើនដាច់ខាតរបស់អភិបាលទាំងឡាយ ប៉ុន្តែមិនត្រូវបានដកហូតពីឋានៈអភិបាលឡើយ ។

មាត្រា ១២៨.-

ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិអញ្ជើញអភិបាលប្រជុំ ។ មួយភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការងារក៏អាចអញ្ជើញក្រុមប្រឹក្សាភិបាលប្រជុំបានដែរ ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់បីខែ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលយកជាបានការ លុះត្រាតែមានសំឡេងភាគច្រើនដោយប្រៀបរបស់សមាជិក ឬ តំណាងដែលមានវត្តមាន ។

មាត្រា ១២៩.-

ក្រុមប្រឹក្សាភិបាលអាចជួបប្រជុំនៅកន្លែងណាមួយទៅតាមលិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវបញ្ជាក់ផងដែរពីកាលបរិច្ឆេទ និងរបៀបវារៈពិស្តារ ។

អភិបាលអាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែនៅពេលចូលរួមប្រជុំ អភិបាលនោះអាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ចណាមួយបាន ដោយសំអាងថាការប្រជុំនោះមិនបានកោះហៅត្រឹមត្រូវតាមច្បាប់កំណត់ ។

មាត្រា ១៣០.-

អភិបាលអាចធ្វើសកម្មភាពបានតាមរយៈការទាក់ទងគ្នាជាលិខិត លើកលែងតែលក្ខន្តិកៈចែងផ្សេង ។

រាល់អភិបាលត្រូវទទួលសំណុំរឿងនៃសេចក្តីសម្រេចដែលត្រូវស្នើសុំការពិនិត្យ និងការសម្រេចគាំទ្រ ឬមិនគាំទ្រ ព្រមទាំងសន្លឹកឆ្នោតសម្រាប់បោះ “ព្រម” ឬ “មិនព្រម” ចំពោះប្រធានបទនោះ ។

ក្នុងករណីដែលអភិបាលទាំងអស់ បោះឆ្នោតអនុម័តលើប្រធានបទមួយ ប្រធានបទនោះត្រូវចាត់ទុកថាមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ការឆ្លើយតបជាលិខិតត្រូវចូលជាផ្នែកមួយនៃកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាល ។ លេខាធិការរបស់ក្រុមហ៊ុន ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពីការប្រាស្រ័យទាក់ទងគ្នាជាលិខិតនោះ និងត្រូវចែករបាយការណ៍នេះទៅអភិបាលទាំងអស់ ។

មាត្រា ១៣១.-

ដើម្បីសម្រួលការងាររបស់ខ្លួនក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗបានតាមការចាំបាច់ ។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបង្កើតឡើងដោយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការនីមួយៗត្រូវមានអភិបាលមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងដោយសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការត្រូវអនុវត្តកិច្ចប្រជុំរបស់ខ្លួនតាមវិធីដូចគ្នានឹងក្រុមប្រឹក្សាភិបាលដែរ ។ គណៈកម្មាធិការនីមួយៗ ត្រូវមានសិទ្ធិដែលបានផ្តល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរដែលបានបង្កើតគណៈកម្មាធិការនោះ ។ ប៉ុន្តែគណៈកម្មាធិការមួយមិនអាចត្រូវបានគេផ្ទេរអំណាចណាមួយដើម្បីធ្វើសកម្មភាពដូចតទៅនេះទេ :

ក-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ខ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលណាមួយផ្សេង ។

គ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយភាគ ឬទាំងអស់ ។

ឃ-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

ង-ប្រកាសភាគលាភ ។

ច-បោះចេញនូវប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុន ។

មាត្រា ១៣២.-

ចំនួនភាគច្រើននៃអភិបាលទាំងអស់ ដែលមានវត្តមាននៅក្នុងពេលប្រជុំបង្កើតបានជាកូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល ឬរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនោះ ប៉ុន្តែលក្ខន្តិកៈរបស់ក្រុមហ៊ុនអាចតម្រូវឱ្យកូរ៉ុមមានចំនួនច្រើនជាងនេះបាន ។

អភិបាលម្នាក់ ត្រូវមានសំឡេងឆ្នោតតែមួយ ។ អភិបាលអាចធ្វើជាអាណត្តិគាហកៈឱ្យអភិបាលមួយរូបផ្សេងទៀតបាន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឱ្យ ។

លេខាធិការត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាភិបាល ហើយត្រូវធ្វើឯកសារថតចម្លងនៃកំណត់ហេតុនេះ ទៅឱ្យអភិបាលទាំងអស់ ។

មាត្រា ១៣៣.-

ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុន អ្នកគ្រប់គ្រង ឬ បុគ្គលិករបស់ក្រុមហ៊ុនក្នុងការបំពេញភារកិច្ចដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល ។

ការចេញសងត្រូវធ្វើឡើងនៅពេលដែលអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកបានសំអាងក្នុងឆន្ទៈល្អនៅលើកំណត់ហេតុ ឬ សៀវភៅបញ្ជី ដែលមានភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ឬនៅលើព័ត៌មានមតិយោបល់ របាយការណ៍ផ្សេងៗ ឬរបាយការណ៍ ដែលបង្ហាញដោយអ្នកគ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬជនណាម្នាក់ផ្សេងអំពីបុគ្គលទាំងនោះ ។

ការចេញសងត្រូវបានអនុវត្តចំពោះតែការចំណាយ ឬ ការខ្ចីចខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកនៅពេលបម្រើការងារឱ្យក្រុមហ៊ុនប៉ុណ្ណោះ ។

មាត្រា ១៣៤.-

អភិបាល ឬ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវបង្ហាញនូវទំហំផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅឱ្យក្រុមហ៊ុន ឬ ស្នើឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងករណី :

ក-ដែលខ្លួនជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

ខ-ដែលខ្លួនមានអត្ថប្រយោជន៍ជាមួយបុគ្គលណាម្នាក់ ដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

មាត្រា ១៣៥.-

ក្នុងករណីជាអភិបាល ការបង្ហាញត្រូវធ្វើឡើង :

ក-នៅពេលប្រជុំ កិច្ចសន្យាដែលបានស្នើឡើងត្រូវពិចារណាជាលើកទីមួយ ។

ខ-នៅពេលប្រជុំលើកិច្ចសន្យា អភិបាលនោះមិនបានបង្ហាញថាមានការពាក់ព័ន្ធផលប្រយោជន៍ទេ ប៉ុន្តែក្រោយមកគាត់បានបញ្ជាក់ថាមានការពាក់ព័ន្ធ ។

គ-នៅក្រោយពេលកិច្ចសន្យាត្រូវបានធ្វើឡើង ហើយក្រោយមកអភិបាលនោះ បានបង្ហាញច្រាប់ថាមានការពាក់ព័ន្ធដល់ផលប្រយោជន៍របស់ខ្លួន ។

ឃ- ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអភិបាល ។

មាត្រា ១៣៦.-

ក្នុងករណីជាអ្នកគ្រប់គ្រងក្រុមហ៊ុន ការបង្ហាញត្រូវធ្វើឡើង :

ក-ក្រោយពីអ្នកគ្រប់គ្រងនោះ ដឹងភ្លាមថាកិច្ចសន្យា ឬកិច្ចសន្យាដែលបានដាក់ស្នើសុំនោះត្រូវសម្រេច ឬ ត្រូវបានសម្រេចរួចហើយ នៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ។

ខ-ប្រសិនបើអ្នកគ្រប់គ្រងនោះ បានបកស្រាយបង្ហាញមុនពេលដែលកិច្ចសន្យានោះបានធ្វើរួចរាល់ ។

គ-ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ ។

មាត្រា ១៣៧.-

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា :

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចី ឬកាតព្វកិច្ចទាំងឡាយ ដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន ឬ ដល់សាខាមួយរបស់ក្រុមហ៊ុន ។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង បុគ្គលិកភ្នាក់ងាររបស់ក្រុមហ៊ុន ឬ សាខាមួយរបស់ក្រុមហ៊ុន ។

គ-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាត ឬជាការធានា ។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ ។

មាត្រា ១៣៨.-

លក្ខន្តិក: ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនអាចមានចែង :

ក-ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានសិទ្ធិចាត់ចែងការិយាល័យរបស់ក្រុម

ហ៊ុន តែងតាំងអ្នកគ្រប់គ្រងក្រុមហ៊ុន កំណត់តួនាទីភារកិច្ចនិងសិទ្ធិរបស់អ្នកទាំងនោះ ឱ្យ បានច្បាស់លាស់ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។

ខ-អភិបាលអាចត្រូវបានតែងតាំងឱ្យ គ្រប់គ្រងការិយាល័យណាមួយ របស់ក្រុមហ៊ុន ។

គ-បុគ្គលម្នាក់អាចរៀបចំគ្រប់គ្រងការិយាល័យមួយ ឬ ច្រើនរបស់ក្រុម ហ៊ុនបាន ។

មាត្រា ១៣៩.-

បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឱ្យ ក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព ឬ បុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយ ផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ ។

ក្រោយពីកិច្ចសន្យាមួយ បានបង្កើតឡើងក្នុងពេលវេលាមួយសមស្រប ក្រុមហ៊ុន អាចទទួលយកបានន្ទូវកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះ ដែលបានធ្វើឡើងមុនពេល ក្រុមហ៊ុនមានអត្ថិភាព និងមុនការទទួលយល់ព្រមនៅក្នុងក្រុមហ៊ុន ។ ការទទួលនេះ ផ្អែកលើសកម្មភាព ឬ ការប្រព្រឹត្តដែលផ្តោតទៅលើគោលបំណងដ៏សំខាន់នៃកិច្ចសន្យា ដែលបានជាប់កាតព្វកិច្ចរួចមកហើយនោះ ។

ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចដោយកិច្ចសន្យា ហើយមានសិទ្ធិក្នុងការទទួលផល ប្រយោជន៍ជូចពេលដែលក្រុមហ៊ុនមានអត្ថិភាព ចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា និង ជូចពេលដែលក្រុមហ៊ុននោះជាចំណែកមួយនៃកិច្ចសន្យា ។

បុគ្គលម្នាក់ដែលប្តឹងទាមទារថាបានអនុវត្តក្នុងនាម ឬ តំណាងឱ្យក្រុមហ៊ុនមាន កាតព្វកិច្ច ឬ មានសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យាបាន លុះត្រាតែមានជីកា សម្រេចរបស់តុលាការ ។

មាត្រា ១៤០.-

អភិបាលដែលបោះឆ្នោតឱ្យ ឬ យល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុ-ញ្ញាតឱ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេត្រូវ

ទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសម-មូលដែលបានទទួល ដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួលប្រសិនបើប័ណ្ណភាគហ៊ុនដែលបានចោះចេញនោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច ។

អភិបាលមិនទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលចោះចេញសម្រាប់តម្លៃសមមូល ដែលតិចជាងសាច់ប្រាក់ ដែលក្រុមហ៊ុនអាចនឹងទទួលប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបានចោះចេញសម្រាប់លក់យកជាប្រាក់ ។

សកម្មភាពក្នុងការអនុវត្តន្វការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់នេះមិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ)ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

មាត្រា ១៤១.-

អភិបាលដែលបានចោះឆ្នោតឱ្យ ឬ យល់ព្រមចំពោះសេចក្តីសម្រេចដែលអនុ-ញ្ញាតឱ្យមានការទិញមកវិញន្វភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬ ធ្វើការចែកភាគលាភដែលផ្នុំយពីបទប្បញ្ញត្តិនៃជំពូកនេះត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាន្វរាល់ចំនួនដែលបានបែងចែក ឬ បានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ ។

សកម្មភាពដើម្បីអនុវត្តការទទួលខុសត្រូវដែលតម្រូវដោយមាត្រានេះ មិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

មាត្រា ១៤២.-

អភិបាលម្នាក់ ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកថាបានយល់ព្រមន្វរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬ សកម្មភាពដែលបានធ្វើឡើងនៅក្នុងមហាសន្និបាតលើកលែងតែ :

១-អភិបាលនោះមានការជំទាស់ ដែលស្នើដាក់ចូលក្នុងកំណត់ហេតុអង្គប្រជុំនៃមហាសន្និបាតនោះ ។

២-អភិបាលនោះ ធ្វើគំនិតជំទាស់ជាលាយលក្ខណ៍អក្សរបស់ខ្លួនទៅលេខាធិការរបស់មហាសន្និបាត មុនពេលបិទមហាសន្និបាតនោះ ។

អភិបាលដែលអវត្តមាននៅក្នុងមហាសន្និបាត នៅពេលសេចក្តីសម្រេចដែលត្រូវអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងរួចមកហើយគឺចាត់ទុកថាបានយល់ព្រមលើកលែងតែក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ក្រោយពីបានជឹងសេចក្តីសម្រេចនោះ អភិបាលនោះបាន :

១-បង្ហាញមូលហេតុនៃការជំទាស់របស់គាត់ ដែលបានបញ្ចូលទៅក្នុងកំណត់ហេតុនៃមហាសន្និបាត ។

២-ធ្វើគំនិតជំទាស់របស់ខ្លួនតាមរយៈលិខិតអនុសិដ្ឋ ឬ យកទៅប្រគល់ផ្ទាល់នៅឯការិយាល័យរបស់ក្រុមហ៊ុន ។

ជ_ ភាគហ៊ុន និង ភាគលាភ

មាត្រា ១៤៣._

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់ ។ ភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

មាត្រា ១៤៤._

ក្នុងករណីលក្ខន្តិកៈមិនបានចែងន្យូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុន។ ។

ក្នុងករណីលក្ខន្តិក:របស់ក្រុមហ៊ុន មិនបានបញ្ជាក់ន្ទវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលន្ទវសិទ្ធិ :

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

២-ក្នុងការទទួលន្ទវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន ។

៣- ក្នុងការទទួលន្ទវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុននៅពេលមានការរំលាយ ។

មាត្រា ១៤៥.-

លក្ខន្តិក:របស់ក្រុមហ៊ុន អាចចែងឱ្យមានប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ក្នុងករណីនេះ សិទ្ធិនៃប្រភេទរបស់ប័ណ្ណភាគហ៊ុននីមួយៗអាចមានលក្ខណៈដាច់ខាត ឬលក្ខណៈធៀប ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទភាគហ៊ុននីមួយៗ ត្រូវកំណត់នៅក្នុងលក្ខន្តិក:របស់ក្រុមហ៊ុននោះ ។ សិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៤៤ ត្រូវភ្ជាប់ដោយឡែក ឬ ទាំងស្រុងទៅនឹងភាគហ៊ុនមួយប្រភេទណាមួយ ។ សិទ្ធិទាំងនោះរួមមាន :

ក-ភាពដែលអាចផ្ទេរបាន ឬភាពដែលអាចផ្លាស់ប្តូរបាននៅក្នុងប្រភេទភាគហ៊ុនមួយផ្សេងទៀត ឬ មូលបត្រផ្សេងទៀតនៃក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនផ្សេងទៀតអាស្រ័យទៅលើជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ អាស្រ័យទៅលើជម្រើសរបស់ម្ចាស់ហ៊ុន ឬអាស្រ័យទៅលើការកើតឡើងនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ ។

ខ-អាទិភាពនៃការទទួលយកទ្រព្យសម្បត្តិ ដែលសល់ពីការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុនមូលធន ។

គ-ការលោះមកវិញ ការទិញឡើងវិញទៅតាមជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ ទៅតាមជម្រើសរបស់អ្នកកាន់កាប់ភាគហ៊ុន ។

ឃ-ការរឹតត្បិតទៅលើភាពដែលអាចផ្ទេរបាន ។

មាត្រា ១៤៦.-

ផ្អែកទៅតាមលក្ខន្តិក: បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាចទិញមុនគេរបស់ម្ចាស់ហ៊ុនភាគហ៊ុន និងមូលបត្រអាចអនុញ្ញាតឱ្យបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់ឱ្យ ។

អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់ចេញ ។

តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេរហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវបានបំពេញចប់សព្វគ្រប់ជាសាច់ប្រាក់ ជាវត្ថុ ឬជាសេវាពីមុនទៅក្នុងក្រុមហ៊ុន ។

ការបង់ភាគហ៊ុនជាវត្ថុ អាចរួមបញ្ចូលពាណិជ្ជសញ្ញា សិទ្ធិនិពន្ធ ប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិប្រើប្រាស់ទ្រព្យអរូបិយ ឬ សិទ្ធិប្រើប្រាស់លិខិតអនុញ្ញាតពាណិជ្ជសញ្ញា ។

អភិបាលទាំងឡាយកំណត់តម្លៃនៃការជាក់ភាគទុនជាវត្ថុ ឬ ជាសេវាកម្មពីមុននោះ ហើយសេចក្តីសម្រេចរបស់អភិបាលទាំងនេះចាត់ទុកជាបានការប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ។

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនអនុញ្ញាតឱ្យមានភាគទុនជាសេវាទេ ។

មាត្រា ១៤៧.-

ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនទាំងឡាយចំពោះបំណុលនៅក្នុងក្រុមហ៊ុនគឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ ។

មាត្រា ១៤៨.-

លក្ខន្តិក:របស់ក្រុមហ៊ុនអាចអនុញ្ញាតឱ្យបោះចេញលើគ្រប់ប្រភេទនៃប័ណ្ណភាគហ៊ុនតាមស៊េរីមួយ ឬច្រើន ។ លក្ខន្តិក:នេះអាចអនុញ្ញាតឱ្យអភិបាលទាំងឡាយកំណត់ចំនួនប័ណ្ណ និងកំណត់ការបែងចែកសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់

ទៅនឹងប័ណ្ណភាគហ៊ុនក្នុងស៊េរីនីមួយៗ ដោយអនុលោមទៅតាមការកំណត់ដែលបានធ្វើឡើងនៅក្នុងលក្ខន្តិក:របស់ក្រុមហ៊ុននោះ ។ បើពុំដូច្នេះទេ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត ឬ លក្ខខណ្ឌដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុន ប្រភេទនិងស៊េរីដូចគ្នា ត្រូវតែមានលក្ខណៈដូចគ្នា ។

មាត្រា ១៤៩.-

ក្រុមហ៊ុនត្រូវរក្សាទុកគណនីដើមទុន ដែលបានចុះបញ្ជីប្រកាសដោយឡែកពីគ្នាសម្រាប់ប្រភេទនិងស៊េរីភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនបានចោះចេញ ។

ក្រុមហ៊ុនត្រូវបន្ថែមទៅក្នុងគណនីដើមទុន ដែលបានប្រកាសទ្វរការបង់ពេញលេញណាមួយជាសាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនដែលក្រុមហ៊ុនបានទទួលចំពោះប័ណ្ណភាគហ៊ុនដែលបានចោះចេញ ។

មាត្រា ១៥០.-

ពេលណាក្រុមហ៊ុនស្នើសុំបន្ថែមទ្វរចំនួនណាមួយទៅក្នុងគណនីដើមទុន ដែលបានប្រកាសលើរាល់ប្រភេទ ឬ ស៊េរីនៃភាគហ៊ុន ប្រសិនបើចំនួនដែលត្រូវបន្ថែមនោះក្រុមហ៊ុនមិនបានទទួលគ្រប់ចំនួនទេ ពេលនោះការបន្ថែមចំនួនចូលទៅក្នុងគណនីដើមទុន ត្រូវតែមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ក្រុមប្រឹក្សាភិបាល ។

ក្រុមហ៊ុនមិនអាចបន្ថយគណនីដើមទុនដែលបានប្រកាស ឬគណនីដើមទុនណាមួយបានឡើយ ។ ក្រុមហ៊ុនអាចបន្ថយគណនីដើមទុនរបស់ខ្លួនបានសម្រាប់គោលបំណងណាមួយតាមរយៈសេចក្តីសម្រេចពិសេស ។ សេចក្តីសម្រេចពិសេស ត្រូវបញ្ជាក់គណនីដើមទុនដែលនឹងត្រូវបន្ថយ ។

ក្រុមហ៊ុនមិនត្រូវបន្ថយគណនីដើមទុនរបស់ខ្លួនទេ ប្រសិនបើមានមូលហេតុដូចខាងក្រោម :

១-ក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលរបស់ខ្លួនបានទេ តាមកាលបរិច្ឆេទដែលបានកំណត់បន្ទាប់ពីការចំណាយ ។

២-តម្លៃទ្រព្យដែលអាចប៉ាន់ស្មានបានរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល ។

វិធាននេះមិនយកមកអនុវត្តទេ ប្រសិនបើក្រុមហ៊ុនកាត់បន្ថយគណនីដើមទុនរបស់ខ្លួន ទ្វេចំនួនណាមួយដែលមិនពាក់ព័ន្ធដល់ទ្រព្យសម្បត្តិ ដែលអាចទទួលផលបាននៅពេលក្រោយ ។

ម្ចាស់បំណុលរបស់ក្រុមហ៊ុន អាចធ្វើបណ្តឹងទៅតុលាការសុំឱ្យក្រុមហ៊ុនសងមកវិញទ្វេរសាច់ប្រាក់ ឬ ទ្រព្យសម្បត្តិ បន្ទាប់ពីការកាត់បន្ថយគណនីដើមទុនដែលបានធ្វើឡើងផ្ទុយពីមាត្រានេះ ។

បណ្តឹងទាមទារការសងបំណុលដែលបានចែងដោយមាត្រានេះ មិនត្រូវធ្វើឡើងក្រោយរយៈពេលពីរ (០២)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

មាត្រា ១៥១.-

បើសិនជាលក្ខន្តិកៈក្រុមហ៊ុនផ្តល់ទ្វេរសិទ្ធិអាចទិញបានចំពោះប្រភេទណាមួយនៃប័ណ្ណភាគហ៊ុន គ្មានប័ណ្ណភាគហ៊ុនណាផ្សេងទៀតនៃប្រភេទនោះត្រូវបោះចេញទៀតឡើយលើកលែងតែម្ចាស់ហ៊ុនដែលមានសិទ្ធិទិញមុនគេត្រូវបានផ្តល់សិទ្ធិជំទូងគេបង្អស់ ។

ម្ចាស់ហ៊ុនមានសិទ្ធិទិញបានមុនទ្វេរភាគហ៊ុន ដែលបានដាក់សំណើលក់ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនប្រភេទនោះតាមតម្លៃ និងលក្ខខណ្ឌផ្សេងៗដូចដែលប័ណ្ណភាគហ៊ុនទាំងនោះ ត្រូវបានដាក់សំណើលក់ដល់តតិយជនផងដែរ ។

មាត្រា ១៥២.-

ក្រុមហ៊ុនអាចបោះចេញវិញ្ញាបនបត្របញ្ជាក់ពីឯកសិទ្ធិនៃការផ្លាស់ប្តូរ ជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទទួលម្ចូលបត្ររបស់ក្រុមហ៊ុន ។ នៅក្នុងករណីនេះ វិញ្ញាបនបត្របញ្ជាក់ ឬ ក៏ម្ចូលបត្រទាំងឡាយត្រូវកំណត់ចេញទ្វេរលក្ខខណ្ឌ

ដែលអាចអនុវត្តបាននៅក្នុងឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរ ។

ឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទិញមូលបត្ររបស់ក្រុមហ៊ុនអាចធ្វើឡើងឱ្យមានភាពដែលអាចផ្ទេរបាន ឬ មិនអាចផ្ទេរបាន ហើយជម្រើសនិងសិទ្ធិក្នុងការទិញអាចធ្វើដោយដាច់ពីគ្នា ឬ មិនដាច់ពីគ្នាពីរាល់មូលបត្រ ។

មាត្រា ១៥៣.-

ម្ចាស់ហ៊ុនម្នាក់មានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុន ។ នៅលើវិញ្ញាបនបត្រហ៊ុននីមួយៗ ដែលត្រូវបានចេញដោយក្រុមហ៊ុនត្រូវមាននាមករណ៍ក្រុមហ៊ុន ឈ្មោះរបស់បុគ្គលដែលត្រូវចេញឱ្យ ហើយនិងចំនួន និងប្រភេទរបស់ប័ណ្ណភាគហ៊ុន និងការកំណត់ទ្រព្យរាល់សើរីដែលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុននោះតំណាង ។

មាត្រា ១៥៤.-

យោងទៅតាមការរឹតត្បិតនៅក្នុងច្បាប់នេះ និងដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ភាគហ៊ុនទាំងឡាយអាចធ្វើការផ្ទេរបាន ។ ក្រុមហ៊ុនអាចផ្ទេរបានទ្រព្យភាគហ៊ុននោះនឹងធ្វើការកត់បញ្ជីទៅក្នុងសៀវភៅ និងបញ្ជីរបស់ក្រុមហ៊ុនទៅតាមសំណើរបស់ភាគីផ្ទេរ និងភាគីទទួល ។

មាត្រា ១៥៥.-

ផ្អែកទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រុមហ៊ុនអាចជាវ ឬ ទិញមកវិញនូវភាគហ៊ុនទាំងឡាយដែលបានចេញ ។

ក្រុមហ៊ុនត្រូវមានប័ណ្ណភាគហ៊ុនដែលចេញ យ៉ាងហោចណាស់ក៏មួយប្រភេទនៃប័ណ្ណភាគហ៊ុនដែលមានសិទ្ធិពេញលេញក្នុងសិទ្ធិបោះឆ្នោត និងដែលមិនស្ថិតក្រោមភាពចាំបាច់នៃការទិញមកវិញ ឬការលោះមកវិញនោះទេ ។

បើសិនជាបំណុលភាគហ៊ុនត្រូវលោះយកមកវិញ ម្ចាស់ភាគហ៊ុនមានភារកិច្ចប្រគល់បំណុលភាគហ៊ុនទៅក្រុមហ៊ុនវិញ ដោយទទួលយកមកវិញនូវតម្លៃនៃការលោះនោះ ។ បើសិនជាម្ចាស់ហ៊ុនមិនព្រមប្រគល់ឱ្យវិញ ក្រុមហ៊ុនអាចកក់នូវតម្លៃនៃភាគហ៊ុន ដែលត្រូវលោះទៅក្នុងគណនីដាច់ដោយឡែកនៅក្នុងធនាគារមួយដែលទទួលស្គាល់ដោយក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវផ្ដន់ផំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ហ៊ុននោះ ។ ក្រុមហ៊ុនត្រូវលុបចោលភ្លាមពីសៀវភៅបញ្ជីនូវបំណុលភាគហ៊ុនដែលបានលោះនៅពេលដែលលុយកក់ត្រូវបានទទួល ។ ប៉ុន្តែក្រុមហ៊ុនមិនត្រូវធ្វើការទូទាត់ណាមួយទៅលើការទិញ ឬ ការលោះបំណុលភាគហ៊ុនទេ ដែលបានបោះចេញ ប្រសិនបើមានហេតុផលថា :

១-ក្រោយពេលទិញ ក្រុមហ៊ុនគ្មានលទ្ធភាពក្នុងការសងបំណុលឱ្យទាន់ពេលវេលាទេ ។

២-ក្រោយពេលទិញតម្លៃពិតប្រាកដនៃទ្រព្យរបស់ក្រុមហ៊ុននៅតិចជាងតម្លៃសរុបរបស់បំណុល ។

បំណុលភាគហ៊ុនដែលបានទិញ និងបានលោះរួចមកហើយ ឬ បានទទួលដោយក្រុមហ៊ុនត្រូវបានលុបចេញ ឬ ប្រសិនបើលក្ខន្តិក:របស់ក្រុមហ៊ុនកម្រិតនូវចំនួននៃបំណុលភាគហ៊ុនដែលអនុញ្ញាតឱ្យបោះចេញ ក្រុមហ៊ុនអាចដាក់បំណុលភាគហ៊ុនក្នុងលក្ខ-ណៈអនុញ្ញាត ប៉ុន្តែពុំទាន់លក់ចេញ ។

មាត្រា ១៥៦.-

នៅពេលក្រុមហ៊ុនទិញ លោះមកវិញ ឬ ទទួលភាគហ៊ុនចូលក្រុមហ៊ុនត្រូវធ្វើការកែតម្រូវដោយភ្ជាប់ទៅនឹងគណនីដើមទុនដែលរក្សាទុកសម្រាប់ប្រភេទ ឬ សៀរីនៃបំណុលភាគហ៊ុនដែលបានទិញលោះមកវិញ ឬ បានទទួល ។

មាត្រា ១៥៧.-

ក្នុងករណីដែលមានការរឹតត្បិតនៅក្នុងលក្ខន្តិក: អភិបាលអាចប្រកាសចេញនូវភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ។

អភិបាលអាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ ។

មាត្រា ១៥៨.-

ក្រុមហ៊ុនមិនអាចប្រកាស ឬ បែងចែកភាគលាភបានទេ ប្រសិនបើក្រុមហ៊ុនមានមូលហេតុសមហេតុសមផលដើម្បីធ្វើឱ្យជឿថា :

ក-ក្រោយពីការបែងចែកភាគលាភនោះ ក្រុមហ៊ុនគ្មានលទ្ធភាពសងបំណុលដូចដែលបានកំណត់ឱ្យសងនោះទេ ។

ខ-តម្លៃដែលអាចប៉ាន់ស្មានបាននៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល និងដើមទុន ប្រកាសរបស់ភាគហ៊ុនគ្រប់ប្រភេទ ។

មាត្រា ១៥៩.-

ក្រុមហ៊ុនអាចបែងចែកភាគលាភ ដោយធ្វើការបោះចេញបំណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន ។ ផ្អែកតាមការរឹតត្បិតនៅក្នុងផ្នែកនេះ ក្រុមហ៊ុនអាចបែងចែកភាគលាភជាសាច់ប្រាក់ ឬជាទ្រព្យសម្បត្តិបាន ។

មាត្រា ១៦០.-

ប្រសិនបើបំណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានបោះចេញដើម្បីទូទាត់ភាគ-លាភ ចំនួនភាគលាភដែលបានប្រកាសបញ្ឈាក់ចំនួនសាច់ប្រាក់ត្រូវបន្ថែមទៅក្នុងគណនីដើមទុន ឬ ត្រូវបានរក្សាទុកសម្រាប់ប្រភេទ ឬ សើរីនៃបំណ្ណភាគហ៊ុនដែលបានបោះចេញដើម្បីទូទាត់ភាគលាភនោះ ។

ច- មូលបត្រ ការចុះបញ្ជី និងការផ្ទេរ

មាត្រា ១៦១.-

នៅក្នុងផ្នែកនេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-គាហក: មានន័យថាបុគ្គលដែលកាន់កាប់មូលបត្រដែលអាចទូទាត់ឱ្យទៅគាហក:ផ្សេងបាន ឬដែលបានធ្វើបិដ្ឋិលេខដោយចំហទុក ។

២-អ្នកទិញដោយសុទ្ធចិត្ត មានន័យថាអ្នកទិញដែលបង់តម្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានការបណ្តឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានចោះចេញឱ្យ ឬ ដែលបានធ្វើបិដ្ឋិ-លេខឱ្យ ឬ ដែលបានធ្វើបិដ្ឋិលេខចំហ ។

៣-អ្នកជើងសា មានន័យថាជាបុគ្គលជាប់កាតព្វកិច្ចទាំងស្រុង ឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជំនួញ ទិញ និងលក់មូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ ។

៤-ការប្រគល់ មានន័យថាជាការផ្ទេរការកាន់កាប់ដោយឆន្ទៈ ។

៥-សុទ្ធ មានន័យថាពិតប្រាកដមិនក្លែងក្លាយ ឬក្លែងបន្លំ ។

៦-ម្ចាស់មូលបត្រ មានន័យថាបុគ្គលមានមូលបត្រដែលបានចេញឱ្យ ឬដែលបានធ្វើបិដ្ឋិលេខឱ្យ ឬ ដែលមានធ្វើបិដ្ឋិលេខចំហ ។

៧-ចេញបន្ថែម មានន័យថាការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្តល់សិទ្ធិតាមលក្ខន្តិក:របស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ ។

៨-អ្នកជាវ មានន័យថាជាបុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់បញ្ចាំ ធ្វើអ៊ីប៉ូតែកចេញប័ណ្ណចេញសាជាថ្មី ធ្វើអំណោយទូវមូលបត្រនោះឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ ។

៩- មូលបត្រ មានន័យថាជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល :

ក-ស្ថិតក្នុងទ្រង់ទ្រាយគាហក: ទ្រង់ទ្រាយចុះបញ្ជី ឬ ទ្រង់ទ្រាយបញ្ជា

ខ-ជាគំរូបំណុលមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬ លើទីផ្សារមូល-បត្រ ឬ បានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញ ឬ ត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ ។

គ-ជាប្រភេទមួយ ឬ សើរីមួយមូលបត្រ ដែលចែកនៅក្នុងប្រភេទ ឬ សើរីនៃលិខិតស្នាម ។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន ។

១០- ការផ្ទេរ មានន័យថាគឺជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់ ។

១១-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា ឬ ក្នុងការធ្វើបិដ្ឋិលេខ មានន័យថាមនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផង ។

មាត្រា ១៦២.-

មូលបត្រគឺជាប្រភេទបំណុលដែលអាចលក់ដូរបាន ។

មាត្រា ១៦៣.-

ក្រុមហ៊ុនណាដែលតម្កល់ទុក ឬ ចែកចាយនូវផែនការអាជីវកម្ម សេចក្តីប្រកាសពីព័ត៌មានសំខាន់ ការប្រកាសពីការចុះបញ្ជី សារាចរណែនាំពីការដោះដូរ មូលបត្រ ឬ ក៏ឯកសារប្រហាក់ប្រហែលដែលទាក់ទងទៅនឹងការចែកចាយមូលបត្ររបស់ក្រុមហ៊ុនដល់សាធារណជន ត្រូវធ្វើជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវច្បាប់ចម្លងនៃឯកសារទាំងអស់នោះ ។

មាត្រា ១៦៤.-

មូលបត្រស្ថិតក្នុងទម្រង់ចុះបញ្ជី ប្រសិនបើមូលបត្រនោះ :

ក-បញ្ជាក់ច្បាស់លាស់នូវបុគ្គលដែលមានសិទ្ធិលើមូលបត្រនិងបញ្ជាក់ថាការផ្ទេរនោះ អាចកត់ចូលទៅក្នុងបញ្ជីមូលបត្របាន ។

ខ-មានភ្ជាប់ប្រកាសថា វាស្ថិតក្នុងបញ្ជីមូលបត្រ ។

មាត្រា ១៦៥.-

កាតព្វកិច្ចបំណុលស្ថិតក្នុងទម្រង់បញ្ជាដែលចែងថា កាតព្វកិច្ចបំណុលគឺអាចទូទាត់បានទៅតាមបំណង ឬ ចែងថាកាតព្វកិច្ចបំណុល ត្រូវចាត់ចែងទៅឱ្យបុគ្គលម្នាក់ដែលសម្គាល់បាន ។

មាត្រា ១៦៦.-

មូលបត្រស្ថិតក្នុងទម្រង់ "គាហក:" ប្រសិនបើមូលបត្រនោះ អាចទូទាត់ទៅឱ្យបុគ្គលណាម្នាក់ក៏បាន ។ មូលបត្រនៅក្នុងទម្រង់គាហក:មិនមានបញ្ជាក់ឈ្មោះរបស់អ្នកកាន់កាប់ទេ ។

មាត្រា ១៦៧.-

រាល់អ្នកកាន់កាប់មូលបត្រមានសិទ្ធិជ្រើសរើសមូលបត្រស្របតាមច្បាប់នេះ ឬតាមលិខិតទទួលស្គាល់ថាមិនផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលមូលបត្រពីក្រុមហ៊ុន ។

ក្រុមហ៊ុនមិនត្រូវចោះចេញនូវមូលបត្រលើសពីមួយ ដែលបានកាន់កាប់រួមគ្នាដោយបុគ្គលច្រើននាក់ ។ ការប្រគល់នូវមូលបត្រមួយទៅឱ្យបុគ្គលម្នាក់គឺជាការគ្រប់គ្រាន់ ។

មាត្រា ១៦៨.-

មូលបត្រត្រូវចុះហត្ថលេខាផ្ទាល់ដៃដោយអភិបាលម្នាក់យ៉ាងតិច ហើយហត្ថលេខាបន្ថែមផ្សេងទៀត ដែលតម្រូវឱ្យមាននៅលើមូលបត្រ អាចត្រូវបានចុះហត្ថលេខាដោយត្រាឈ្មោះ ។

មាត្រា ១៦៩.-

នៅលើមូលបត្រដែលចោះចេញដោយក្រុមហ៊ុនត្រូវមាន :

១-នាមករណ៍របស់ក្រុមហ៊ុន ។

២- ពាក្យថា“ បានធ្វើអាជីវកម្មក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា” ។

៣-ឈ្មោះរបស់បុគ្គលដែលត្រូវចេញឱ្យ ។

៤-លេខនិងប្រភេទរបស់ប័ណ្ណភាគហ៊ុននិងស៊េរីរបស់ប័ណ្ណភាគហ៊ុននោះ ។

៥-ដាក់ការរឹតត្បិតទៅលើការផ្ទេរ ។

នៅលើមូលបត្រចេញដោយក្រុមហ៊ុន ដែលត្រូវបានផ្តល់សិទ្ធិឱ្យចោះចេញច្រើនជាងមួយប្រភេទ ឬ មួយស៊េរី ត្រូវចែងឱ្យច្បាស់នូវ :

ក-សិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទស៊េរីរបស់ប័ណ្ណភាគហ៊ុននីមួយៗ ដែលបានចោះចេញ ។

ខ-ប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនដែលបង្ហាញពីសិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិត ឬលក្ខខណ្ឌភ្ជាប់ ។ ក្រុមហ៊ុននឹងផ្តល់ឱ្យម្ចាស់ហ៊ុននូវរាល់តម្រូវការ និងដោយឥតគិតថ្លៃនូវឯកសារទាំងអស់ស្តីពីសិទ្ធិអាទិភាព ការរឹតត្បិត និងលក្ខខណ្ឌភ្ជាប់ទៅនឹងប្រភេទ និងស៊េរីនីមួយៗ ។

មាត្រា ១៧០.-

ក្រុមហ៊ុនត្រូវរក្សាទុកនូវបញ្ជីមូលបត្រ ដែលនៅក្នុងនោះមានកត់ត្រានូវមូលបត្រដែលក្រុមហ៊ុនចោះចេញដោយបញ្ជាក់ប្រភេទ និងស៊េរីរបស់មូលបត្រទាំងនោះជាអាទិ៍ :

ក-ឈ្មោះដែលរៀបតាមលំដាប់អក្សរ និងអាសយដ្ឋានក្រោយបង្អស់របស់បុគ្គលម្នាក់ៗដែលជាម្ចាស់មូលបត្រ ។

ខ-លេខមូលបត្រ ដែលកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ ។

គ-កាលបរិច្ឆេទ និងលក្ខណៈពិសេសនៃការចេញ និងការផ្ទេរមូលបត្រនីមួយៗ ។

មាត្រា ១៧១.-

ក្រុមហ៊ុនត្រូវទទួលស្គាល់ម្ចាស់មូលបត្រ ដែលបានទទួលការចុះបញ្ជីថាជាបុគ្គលដែលមានសិទ្ធិបោះឆ្នោត ទទួលលិខិតជូនដំណឹង ទទួលផលប្រយោជន៍ ទទួលភាគលាភ ឬការទូទាត់សងស្របតាមមូលបត្រ និងអនុវត្តរាល់សិទ្ធិរបស់ម្ចាស់មូលបត្រនោះ ។

ក្នុងករណីដែលមានការដាក់ការរឹតត្បិតទៅលើការផ្ទេរមូលបត្រ និងមូលបត្រដែលត្រូវបានផ្ទេរចេញ ឬបញ្ជូនទៅបុគ្គលម្នាក់ដែលមិនមែនជាម្ចាស់មូលបត្រ បុគ្គលនោះត្រូវផ្តល់ភស្តុតាងអំពីការអនុញ្ញាតឱ្យខ្លួនអនុវត្តសិទ្ធិ ឬបុព្វសិទ្ធិស្របតាមមូលបត្រ ។ ក្រុមហ៊ុនត្រូវទទួលស្គាល់បុគ្គលនោះថាជាអ្នកត្រូវបានផ្តល់សិទ្ធិក្នុងការអនុវត្តសិទ្ធិ ឬបុព្វសិទ្ធិទាំងឡាយនោះ ។

មាត្រា ១៧២.-

ប្រសិនបើមានអនីតិជនម្នាក់ ដែលស្ថិតក្រោមអាណាព្យាបាលអនុវត្តសិទ្ធិជាម្ចាស់មូលបត្ររបស់ក្រុមហ៊ុនអនីតិជន ឬ តំណាងរបស់អនីតិជននោះមិនអាចបដិសេធសកម្មភាពរបស់ខ្លួនបានឡើយ ។

មាត្រា ១៧៣.-

កាលណាមូលបត្រមួយត្រូវផ្ទេរចេញ ឬ បញ្ជូនទៅបុគ្គលម្នាក់ដែលមិនមែនជាអ្នកមានឈ្មោះក្នុងបញ្ជីភាគហ៊ុន បុគ្គលនោះត្រូវមានសិទ្ធិក្លាយជា ឬ ចាត់ទុកជាអ្នកកាន់កាប់ដូចដែលបានចុះក្នុងបញ្ជីភាគហ៊ុនដែរ ប្រសិនបើបុគ្គលនោះបានតម្កល់ទុកនូវមូលបត្រដែលខ្លួនមានសិទ្ធិកាន់កាប់បានធ្វើជាម្ចាស់នោះ ។

ឯកសារតម្កល់ទុកនោះមាន :

ក-ឯកសារច្បាប់ដើមរបស់សារការី ឬ ឯកសារដើម ឬ ឯកសារដែលបញ្ជាក់ពីតុលាការ ឬ លិខិតស្នាមរដ្ឋបាលទាំងឡាយ ។

ខ-លិខិតបញ្ជាក់ភស្តុតាងអំពីការផ្ទេរមូលបត្រក្នុងនាមជាអ្នកកាន់កាប់ម្នាក់ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម :

-ដោយតំណាងស្របច្បាប់របស់អនីតិជន បុគ្គលអសមត្ថភាព ឬ បុគ្គលដែលបាត់ខ្លួន

-ដោយអ្នកជម្រះបញ្ជី ឬ

-ដោយអ្នកដែលបានទទួលទំនុកចិត្តក្នុងការគ្រប់គ្រងក្រុមហ៊ុន ក្សីយធន

មាត្រា ១៧៤.-

នៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ :

ក-រាល់ការចុះហត្ថលេខាលើមូលបត្រ ឬ ជាបិដ្ឋិលេខក្នុងករណីចាំបាច់ គឺត្រូវបានទទួលស្គាល់ លើកលែងតែមានការតវ៉ាបដិសេធន៍ជាក់លាក់ ។

ខ-ហត្ថលេខានៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវ និងមានការអនុញ្ញាត ។ ប៉ុន្តែប្រសិនបើប្រសិទ្ធភាពនៃហត្ថលេខា ត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា ។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬ ត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចោទបង្ហាញភស្តុតាងផ្ទុយ ឬ កង្វះខាតលើសុពលភាពមូលបត្រ ។

ឃ-បើភាគីចុងចោទលើកឡើងនូវភស្តុតាងផ្ទុយ ឬ ភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយ ឬ ភាពមិនពេញលក្ខណៈនោះទៅវិញ ។

មាត្រា ១៧៥.-

លើកលែងតែមានការព្រមព្រៀងផ្សេង និងអនុលោមទៅតាមច្បាប់ដោយឡែក ឬបញ្ញត្តិពាក់ព័ន្ធណាផ្សេងទៀត បុគ្គលដែលច្បាប់អនុញ្ញាតឱ្យចេញលក់មូលបត្រដែល

ចោះចេញក្នុងទម្រង់គាហក: ឬដែលបានចុះឈ្មោះអ្នកទទួល ឬដែលបានធ្វើបិដ្ឋិលេខ ទៅឱ្យអ្នកទទួល ឬបិដ្ឋិលេខចំហ ។

មាត្រា ១៧៦.-

លក្ខខណ្ឌនៃមូលបត្រដែលមានចែងនៅលើមូលបត្រ និងលក្ខខណ្ឌនៃមូលបត្រ ដោយយោងតាមឯកសារផ្សេងត្រូវឱ្យស្របគ្នា ។ ក្នុងករណីដែលលក្ខខណ្ឌទាំងពីរមិន ស្របគ្នា លក្ខខណ្ឌដែលមានចែងលើមូលបត្រ ត្រូវបានចាត់ទុកថា ជាបានការ ។

ចំពោះអ្នកទិញដោយសុទ្ធចិត្ត ទោះជាមូលបត្រនោះមានលក្ខណៈមិនប្រក្រតី ក៏ដោយ ក៏ក្រុមហ៊ុនត្រូវតែទទួលស្គាល់សិទ្ធិជាម្ចាស់មូលបត្រដែរ ។

មូលបត្រមានសុពលភាពចំពោះអ្នកទិញដោយសុទ្ធចិត្ត បើអ្នកទិញនោះមិនបាន ដឹងពីភាពមិនប្រក្រតីនៃមូលបត្រនោះ ។

មាត្រា ១៧៧.-

ហត្ថលេខាដែលគ្មានការអនុញ្ញាតនៅលើមូលបត្រនៅពេលមុន ឬ នៅក្នុងពេល ចេញមូលបត្រគឺគ្មានប្រសិទ្ធភាពទេ ។ លើកលែងតែហត្ថលេខានោះមានប្រសិទ្ធភាព សម្រាប់អ្នកទិញ និងមិនចាំបាច់មានលិខិតជូនដំណឹងអំពីការខ្វះខាតការអនុញ្ញាតនោះ ទេ ប្រសិនបើការចុះហត្ថលេខានោះ ត្រូវបានធ្វើឡើងដោយបុគ្គលម្នាក់ដែលបានអនុ-ញ្ញាតដោយអ្នកចេញបណ្ណ ដើម្បីចុះហត្ថលេខាលើមូលបត្រ ឬ មូលបត្រប្រហាក់ ប្រហែល ។

មាត្រា ១៧៨.-

នៅពេលមូលបត្រមានចុះហត្ថលេខាចាំបាច់សម្រាប់ចោះចេញ ឬ សម្រាប់ផ្ទេរ ប៉ុន្តែពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ដោយប្រការណាមួយ:

ក- បុគ្គលណាក៏អាចបំពេញន្ធរចន្លោះទំនេរនោះបានដែរ ដោយ ស្របទៅតាមសិទ្ធិរបស់បុគ្គលនោះ ។

ខ- ទោះជាការបំពេញនោះមិនគ្រប់គ្រាន់ក៏ដោយ ក៏មូលបត្រនោះចាត់ទុកជាមានលក្ខណៈពេញលេញអាចប្រើប្រាស់បាន ចំពោះអ្នកទិញដែលបានទិញពេញថ្លៃដោយមិនបានដឹងអំពីភាពមិនសុក្រឹតនោះឡើយ ។

គ-មូលបត្រដែលបានធ្វើចប់សព្វគ្រប់ហើយដែលមានការកែទោះបីជាកែដោយក្លែងបន្លំក៏ដោយ ក៏មូលបត្រនោះនៅតែមានតម្លៃអាចអនុវត្តបាន ប៉ុន្តែការអនុវត្តនេះ ត្រូវយោងលើលក្ខខណ្ឌដើម ។

មាត្រា ១៧៩.-

អ្នកទទួលចុះបញ្ជីលក់ភាគហ៊ុន ឬ ផ្ទេរភាគហ៊ុនមិនទទួលខុសត្រូវចំពោះការក្លែងបន្លំមូលបត្រទេ ប្រសិនបើ :

ក-សកម្មភាពក្នុងការបោះចេញមូលបត្រស្ថិតក្នុងវង្វង់ការងារដែលបានអនុញ្ញាត ។

ខ-មានមូលហេតុត្រឹមត្រូវថាមូលបត្រនោះចិតនៅក្នុងទម្រង់បែបបទនិងចំនួនដែលបានអនុញ្ញាតឱ្យបោះចេញ ។

មាត្រា ១៨០.-

នៅពេលប្រគល់មូលបត្រ អ្នកជាវទទួលសិទ្ធិពីមូលបត្រដូចអ្នកផ្ទេរមានដែរ ឬអ្នកដែលមានការអនុញ្ញាតដើម្បីផ្ទេរ លើកលែងតែអ្នកជាវជាភាគីក្លែងបន្លំ ឬប្រព្រឹត្តអំពើល្មើសដែលប៉ះពាល់ដល់មូលបត្រមិនបានបង្ហាញអំពីសិទ្ធិកាន់កាប់ពីម្ចាស់ពិតប្រាកដ ។

មាត្រា ១៨១.-

បុគ្គលដែលធ្វើការផ្ទេរមូលបត្រទៅអ្នកជាវដោយសុចរិតធ្វើការធានាចំពោះតែ :

១-ការផ្ទេរនោះមានសុពលភាព និងត្រឹមត្រូវតាមច្បាប់ ។

២-មូលបត្រនោះត្រឹមត្រូវមិនក្លែងបន្លំ និងមិនមានការកែសំណៅដើមឡើយ ។

៣-ក្នុងករណីដែលខ្លួនមិនដឹងថាមានអ្វី ដែលអាចបង្កឱ្យខូចខាតដល់សុពលភាពរបស់មូលបត្រនោះទេ ។

អ្នកជើងសាផ្តល់ទៅអតិថិជនរបស់ខ្លួន ទៅអ្នកចេញមូលបត្រ និងអ្នកជាវប័ណ្ណនូវការធានាដែលបានចែងក្នុងមាត្រានេះ ហើយមានសិទ្ធិ និងបុព្វសិទ្ធិជាអ្នកជាវស្ថិតក្រោមមាត្រានេះ ។ ការធានាទាំងនោះដែលសំដៅផ្តល់ប្រយោជន៍ដល់អ្នកជើងសាដែលធ្វើសកម្មភាពក្នុងឋានៈជាភ្នាក់ងារម្នាក់គឺបន្ថែមទៅលើការធានាដែលបានទទួលពីអតិថិជន និងការធានាដែលសំដៅផ្តល់ប្រយោជន៍ដល់អតិថិជន ។

មាត្រា ១៨២.-

នៅពេលមូលបត្រមួយស្ថិតក្នុងទម្រង់ចុះបញ្ជី ដែលត្រូវផ្ទេរកម្មសិទ្ធិទៅអ្នកទិញម្នាក់ដោយពុំទាន់មានបិដ្ឋិលេខ អ្នកទិញនោះនឹងក្លាយជាអ្នកទិញពិតប្រាកដដរាបណាបិដ្ឋិលេខត្រូវបានផ្តល់ឱ្យ ។

ទោះជាការផ្ទេរកម្មសិទ្ធិបានបំពេញសព្វគ្រប់ នៅពេលបញ្ចេញមូលបត្រក៏ដោយ ក៏អ្នកទិញមានសិទ្ធិទាមទារចំពោះអ្នកផ្ទេរកម្មសិទ្ធិនោះ ឱ្យផ្តល់ជូននូវបិដ្ឋិលេខជាចាំបាច់ ។

មាត្រា ១៨៣.-

បិដ្ឋិលេខមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីកើតឡើងនៅពេលដែលបុគ្គលមានសិទ្ធិចុះហត្ថលេខាលើមូលបត្រ ឬលើឯកសារដោយឡែកលើការផ្តល់សិទ្ធិ ឬការផ្ទេរកម្មសិទ្ធិមូលបត្រនោះ ឬចុះហត្ថលេខាផ្តល់សិទ្ធិដើម្បីចាត់ចែង ឬផ្ទេរកម្មសិទ្ធិមូលបត្រនោះ ។ បិដ្ឋិលេខមូលបត្រមានលក្ខណៈដូចតទៅ :

-បិដ្ឋិលេខអាចជាលក្ខណៈពិសេស ឬ បិដ្ឋិលេខចំហ

-បិដ្ឋិលេខចំហរួមមានទាំងបដ្ឋិលេខអ្នកកាន់កាប់ផង

-បិដ្ឋិលេខពិសេសបញ្ជាក់ពីបុគ្គលដែលមូលបត្រត្រូវផ្ទេរទៅឱ្យ ឬបញ្ជាក់ពីសិទ្ធិរបស់បុគ្គលដែលមានសិទ្ធិក្នុងការផ្ទេរមូលបត្រនោះ ។

ម្ចាស់មូលបត្រអាចប្តូរបិដ្ឋិលេខចំហមួយទៅជាបិដ្ឋិលេខពិសេសមួយបាន ។

នៅក្នុងផ្នែកនេះបុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខគឺ :

១-ជាបុគ្គលដែលបានបញ្ជាក់តាមរយៈមូលបត្រ ឬតាមរយៈបិដ្ឋិលេខពិសេស ដែលមានសិទ្ធិលើមូលបត្រ ។

២-ជាអ្នកតំណាងស្របច្បាប់ ប្រសិនបើបុគ្គលដែលបានចែងនៅក្នុងចំណុច ១ គឺជាបុគ្គលម្នាក់គ្មានលទ្ធភាពអនុវត្តពាណិជ្ជកិច្ចបានដោយមូលហេតុណាមួយ ។

៣-ជាបុគ្គលដែលមានសិទ្ធិចុះហត្ថលេខាតាមច្បាប់ជាធរមាន ឬ តាមលិខិតប្រគល់សិទ្ធិ ។

៤-ជាភ្នាក់ងារដែលបានទទួលការអនុញ្ញាតក្នុងន័យថាបុគ្គលដែលបានរៀបរាប់នៅក្នុងចំណុច (១) ដល់ចំណុច (៣) អាចធ្វើសកម្មភាពតាមរយៈភ្នាក់ងារបាន ។

មាត្រា ១៨៤.-

តាមរយៈបិដ្ឋិលេខរបស់ខ្លួន អ្នកធ្វើបិដ្ឋិលេខត្រូវបានសន្មតថាគ្មានកាតព្វកិច្ចធានាថាមូលបត្រនោះនឹងត្រូវបានទទួលស្គាល់ដោយអ្នកចេញមូលបត្រនោះទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។

បិដ្ឋិលេខតែមួយផ្នែកនៃឯកតានៅលើមូលបត្រ ដែលអ្នកចេញបានបញ្ជាក់ថាអាចឱ្យមានការផ្ទេរដាច់ដោយឡែកពីគ្នាបានគឺមានប្រសិទ្ធភាពក្នុងការធ្វើបិដ្ឋិលេខបន្តទៅលើផ្នែកដទៃទៀតបាន ។

មាត្រា ១៨៥.-

បិដ្ឋិលេខពិសេស ឬបិដ្ឋិលេខចំហលើមូលបត្រមួយមិនអាចចាត់ទុកជាការផ្ទេរបានទេ បើសិនជាគ្មានការប្រគល់មូលបត្រដែលមានបិដ្ឋិលេខនោះទេ ។ បិដ្ឋិលេខចុះនៅលើឯកសារដោយឡែកអាចចាត់ទុកជាការផ្ទេរបានលុះត្រាតែមានការប្រគល់មូលបត្រផង និងឯកសារដោយឡែកនោះផង ។

មាត្រា ១៨៦.-

បិដ្ឋិលេខនៃមូលបត្រនៅក្នុងទម្រង់គាហក: មិនប៉ះពាល់ដល់សិទ្ធិនៃការចុះបញ្ជី របស់អ្នកកាន់កាប់ភាគហ៊ុនឡើយ ។

មាត្រា ១៨៧.-

ម្ចាស់មូលបត្រអាចតវ៉ាពីសុពលភាពនៃបិដ្ឋិលេខទៅនឹងអ្នកចេញមូលបត្រ ឬ ទៅអ្នកទិញផ្សេងទៀតដែលមានឆន្ទៈល្អក្នុងការទទួលមូលបត្រថ្មី ដែលត្រូវបោះចេញ ឬ ចុះបញ្ជីផ្ទេរជាថ្មី ។

មាត្រា ១៨៨.-

អ្នកចេញមូលបត្រណា ដែលចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រ ដែលមាន បិដ្ឋិលេខមិនត្រឹមត្រូវ អ្នកចេញមូលបត្រនោះត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីដែល មិនត្រឹមត្រូវនោះ ។

មាត្រា ១៨៩.-

បុគ្គលដែលធានាលើហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខលើមូលបត្រធានាថាការ ចុះហត្ថលេខានៅពេលនោះជា :

១-ហត្ថលេខាត្រឹមត្រូវ ។

២-អ្នកចុះហត្ថលេខាគឺជាបុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ ។

៣-អ្នកចុះហត្ថលេខាមានសិទ្ធិស្របច្បាប់ក្នុងការចុះហត្ថលេខា ។

ប៉ុន្តែបុគ្គលដែលធានាលើហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខមិនធានាអះអាងនូវ សិទ្ធិស្របច្បាប់នៃការផ្ទេរដោយឡែកណាមួយឡើយ ។

អ្នកចេញមូលបត្រ មិនត្រូវតម្រូវយកការធានាលើបិដ្ឋិលេខជាលក្ខខណ្ឌសម្រាប់ ការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិឡើយ ។

មាត្រា ១៩០.-

ការប្រគល់មូលបត្រទៅឱ្យអ្នកជាវកើតឡើងនៅពេលដែល :

ក-អ្នកជាវម្នាក់ ឬ បុគ្គលម្នាក់ ដែលបានចាត់តាំងដោយអ្នកជាវនោះទទួលកាន់កាប់មូលបត្រ ។

ខ-អ្នកជើងសារបស់អ្នកជាវទទួលកាន់កាប់មូលបត្រដែលមានបិដ្ឋិលេខទៅឱ្យអ្នកជាវ ឬ ដែលចេញក្នុងនាមរបស់អ្នកជាវ ។

គ-អ្នកជើងសារបស់អ្នកជាវ ធ្វើការអះអាងបញ្ជាក់អំពីការទិញទៅឱ្យអ្នកជាវ ហើយនៅក្នុងកំណត់ហេតុរបស់អ្នកជើងសាបញ្ជាក់លើអត្តសញ្ញាណរបស់មូល-បត្រជាក់លាក់មួយជារបស់អ្នកជាវនោះ ។

ឃ-យោងទៅតាមមូលបត្រ ដែលមានបញ្ជាក់អត្តសញ្ញាណ ដែលត្រូវផ្ទេរកម្មសិទ្ធិក្នុងពេលតតិយជននៅមានភាពជាម្ចាស់នៅឡើយ តតិយជននោះត្រូវបានទទួលស្គាល់ខ្លួនជាអ្នកកាន់កាប់បំណុលឱ្យអ្នកជាវ ។

មាត្រា ១៩១.-

បើគ្មានការព្រមព្រៀងផ្សេងទេ ការលក់មូលបត្រមួយធ្វើឡើងដោយការផ្លាស់ប្តូរ ឬ តាមរយៈអ្នកជើងសា :

១-អតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្ទេរនៅពេលខ្លួនត្រូវផ្ទេរកម្មសិទ្ធិភាពជាម្ចាស់ទៅឱ្យអ្នកជើងសារបស់អ្នកលក់ ឬ ទៅឱ្យបុគ្គលដែលបានចាត់តាំងដោយអ្នកជើងសារបស់អ្នកលក់នោះឱ្យកាន់កាប់ជំនួសខ្លួន ។

២- អ្នកជើងសារបស់អ្នកលក់រួមមានអ្នកជើងសាជាប់ទាក់ទងដែលធ្វើសកម្មភាពឱ្យអតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធ្វើការផ្ទេរភាពជាម្ចាស់នៃមូលបត្រទៅឱ្យអ្នកជើងសារបស់អ្នកទិញ ឬ ឱ្យទៅបុគ្គលដែលបានចាត់តាំងដោយអ្នកជើងសារបស់អ្នកទិញ ឬ ដោយឥទ្ធិពលនៃភាពជាក់ស្តែងនៃការលក់ស្របតាមបទប្បញ្ញត្តិនៃការដោះដូរ ដែលបទប្បញ្ញត្តិនោះធ្វើឱ្យមានពាណិជ្ជកម្មកើតឡើង ។

ប្រសិនបើគ្មានការព្រមព្រៀងផ្សេងទេ ភារកិច្ចរបស់អ្នកផ្ទេរកម្មសិទ្ធិក្នុងការប្រគល់មូលបត្រទៅឱ្យអ្នកជាវក្រោមកិច្ចសន្យានៃការទិញគឺមិនទាន់គ្រប់គ្រាន់ទេលុះត្រាតែបុគ្គលនោះ ផ្ទេរមូលបត្រក្នុងបែបបទអាចដោះដូរបានទៅឱ្យអ្នកជាវ ឬ ឱ្យទៅបុគ្គលដែលបានប្រគល់សិទ្ធិដោយអ្នកជាវ ឬ ដោយសំអាងនូវការទទួលជឹងឮដែលត្រូវធ្វើឡើងទៅអ្នកជាវថាមូលបត្រនោះត្រូវខ្ជួនកាន់កាប់ជំនួស ។

មាត្រា ១៩២.-

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិ ដោយមិនត្រឹមត្រូវពីបុគ្គលណាមួយ ក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុច-រិតដើម្បី :

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ ឬ មួយផ្នែក ។

៣-ទាមទារការខូចខាតទាំងឡាយ ។

ប្រសិនបើមូលបត្រ ដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវដោយមូលហេតុធ្វើបិដ្ឋិលេខមិនមានការអនុញ្ញាតត្រឹមត្រូវ នៅពេលនោះម្ចាស់មូលបត្រអាចទាមទារមកវិញបាននូវភាពជាម្ចាស់នៃមូលបត្រនោះ ឬ ទាមទារឱ្យចេញមូលបត្រថ្មីមួយទៀត ទោះបីចំពោះអ្នកទិញដោយសុចរិតក៏ដោយ ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថាបិដ្ឋិលេខនោះគ្មានប្រសិទ្ធភាពមែន ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្តឹងតវ៉ា ។

មាត្រា ១៩៣.-

បើគ្មានការព្រមព្រៀងផ្សេងទេ អ្នកផ្ទេរកម្មសិទ្ធិត្រូវផ្តល់ឱ្យអ្នកជាវនូវភស្តុតាងអំពីសិទ្ធិក្នុងការផ្ទេររបស់ខ្លួន ឬផ្តល់នូវតម្រូវការណាមួយផ្សេងដែលចាំបាច់ដើម្បីទទួលបានការចុះបញ្ជីនូវការផ្ទេរមូលបត្រនោះ ។ ប៉ុន្តែប្រសិនបើការផ្ទេរកម្មសិទ្ធិនោះមិនមែនជាការផ្ទេរដែលមានបង់តម្លៃនោះ អ្នកផ្ទេរកម្មសិទ្ធិមិនចាំបាច់បង្ហាញភស្តុតាងដូចមានចែងខាងលើនេះទេ លុះត្រាតែអ្នកជាវបានបង់តម្លៃសមស្រប និង សោហ៊ុយចាំបាច់ផ្សេងៗទៀត ។

ប្រសិនបើអ្នកផ្ទេរកម្មសិទ្ធិខកខានក្នុងការអនុវត្ត ការទាមទារចាំបាច់របស់អ្នកជាវក្នុងរយៈពេលសមស្របមួយ ពេលនោះអ្នកទិញអាចប្រកែក ឬ បដិសេធការផ្ទេរកម្មសិទ្ធិនោះបាន ។

មាត្រា ១៩៤.-

មូលបត្រ ឬភាគលាភនៃផលប្រយោជន៍ផ្សេងៗមិនអាចរឹបអូសបានទេ លុះត្រាតែបុគ្គលដែលធ្វើការរឹបអូសនោះ បានទទួលសិទ្ធិជាម្ចាស់លើមូលបត្រដែលត្រូវរឹបអូសនោះ ។

មាត្រា ១៩៥.-

ពេលណាដែលមូលបត្រ នៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រ ត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ :

១-មូលបត្រមានបិដ្ឋិលេខរបស់បុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ ។

២-មានការធានាសមហេតុផលថា បិដ្ឋិលេខនោះមិនក្លែងបន្លំ ហើយមានសុពលភាព ។

៣-ច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រមូលពន្ធដារត្រូវបានអនុវត្ត ។

៤-ការផ្ទេរកម្មសិទ្ធិនោះ គឺស្របតាមច្បាប់ឬផ្ទេរទៅឱ្យអ្នកជាវពិតប្រាកដ ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជីការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខាន ឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ ។

មាត្រា ១៩៦.-

អ្នកចេញមូលបត្រមិនទទួលខុសត្រូវចំពោះម្ចាស់មូលបត្រ ឬបុគ្គលផ្សេងៗដែលទទួលការខាតបង់បណ្តាលមកពីការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រឡើយ ប្រសិនបើបិដ្ឋិលេខចាំបាច់មានចារលើមូលបត្រហើយ អ្នកចេញមូលបត្រនោះបានធ្វើការយកចិត្តទុកដាក់ក្នុងការកំណត់នូវភាពគ្រប់ជ្រុងជ្រោយនៃបិដ្ឋិលេខនោះ ។

មាត្រា ១៩៧.-

នៅពេលមូលបត្រត្រូវបានបាត់បង់ ឬត្រូវបានបំផ្លាញ ហើយម្ចាស់មិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរពីមូលហេតុទៅអ្នកចេញមូលបត្រនៅក្នុងពេលសមស្របទេ ក្រោយពីខ្លួនបានដឹងពីការបាត់បង់ ការបំផ្លាញនោះ ហើយពេលនោះអ្នកចេញមូលបត្របានចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិមូលបត្រនោះមុនការទទួលសេចក្តីជូនដំណឹងពីម្ចាស់មូលបត្រ ម្ចាស់មូលបត្រនោះត្រូវអស់សិទ្ធិក្នុងការទាមទារមូលបត្រថ្មីពីអ្នកចេញមូលបត្រ ។

មាត្រា ១៩៨.-

នៅពេលម្ចាស់មូលបត្រជូនដំណឹងថាមូលបត្រត្រូវបានបាត់បង់ ឬត្រូវបានបំផ្លាញ ពេលនោះអ្នកចេញមូលបត្រ ត្រូវចេញមូលបត្រថ្មីជំនួសមូលបត្រដើម ប្រសិនបើម្ចាស់មូលបត្រនោះ :

១-ស្នើសុំមុនពេលអ្នកចេញមូលបត្របានជូនដំណឹងថាមូលបត្រនោះត្រូវបានទទួលសិទ្ធិដោយអ្នកទិញពិតប្រាកដរួចទៅហើយ ។

២-យកមូលបត្រសងការខូចខាតមកបង្ហាញអ្នកចេញមូលបត្រ ។

៣-យល់ព្រមទទួលនូវរាល់លក្ខខណ្ឌតម្រូវ ដែលបានបង្គាប់ដោយអ្នកចេញមូលបត្រ ។

ក្រោយពីការចេញឱ្យនូវមូលបត្រថ្មី ក្រោមកថាខណ្ឌខាងលើ ប្រសិនបើអ្នកទិញមូលបត្រដើមពិតប្រាកដបង្ហាញមូលបត្រដើមនោះដើម្បីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិនោះ ។

ក្នុងការបន្ថែមសិទ្ធិណាមួយទៅលើមូលបត្រសងការខ្វះខាត អ្នកចេញមូលបត្រអាចត្រួតពិនិត្យឡើងវិញបាននូវមូលបត្រថ្មី ដែលបានចេញឱ្យពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ។

ឆ_ អ្នកទទួលរក្សាទ្រព្យសម្បត្តិ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

មាត្រា ១៩៩._

លើកលែងតែមានការអនុញ្ញាតពីតុលាការ អ្នកទទួលរក្សាទ្រព្យសម្បត្តិមិនអាចអនុញ្ញាតឱ្យប្រកបពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនបានឡើយ ។ អនុលោមតាមសិទ្ធិរបស់ឥណទាយក អ្នកទទួលរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអាចទទួលចំណូលអំពីទ្រព្យសម្បត្តិ និងអាចធ្វើការសងបំណុលដែលពាក់ព័ន្ធជាមួយទ្រព្យសម្បត្តិនោះ ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិក៏អាចដឹងផងដែរពីអត្ថប្រយោជន៍នៃមូលបត្ររបស់ម្ចាស់មូលបត្រដែលបានតែងតាំងខ្លួន ។

មាត្រា ២០០._

តុលាការអាចអនុញ្ញាតឱ្យអ្នកទទួលរក្សាទ្រព្យសម្បត្តិ ប្រកបពាណិជ្ជកិច្ចក្រុមហ៊ុនបានក្នុងគោលបំណងការពារមូលបត្រទាំងឡាយរបស់បុគ្គលដែលបានតែងតាំងខ្លួន ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិនោះគឺជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

មាត្រា ២០១.-

ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវបានតែងតាំងដោយតុលាការ ឬ ដោយលិខិតណាមួយរបស់ក្រុមហ៊ុន សិទ្ធិរបស់អភិបាលទាំងឡាយត្រូវអស់តម្លៃរហូតដល់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះត្រូវបានបញ្ចប់ ។

មាត្រា ២០២.-

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងដោយតុលាការត្រូវអនុវត្តទៅតាមការណែនាំរបស់តុលាការ ។

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងតាមសេចក្តីសម្រេចណាមួយផ្សេង ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចនេះនិងតាមការណែនាំរបស់តុលាការ ។

មាត្រា ២០៣.-

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិត្រូវ :

១-ប្រតិបត្តិដោយស្មោះត្រង់ និងដោយបំណងល្អហើយរក្សាទុកដាក់ទ្រព្យសម្បត្តិដែលស្ថិតក្នុងការកាន់កាប់របស់ខ្លួន ឬធ្វើការត្រួតពិនិត្យត្រឹមត្រូវតាមរបៀបពាណិជ្ជកម្ម ។

២-ជូនដំណឹងជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអំពីការតែងតាំង និងការបំពេញសិទ្ធិរបស់ខ្លួន ។

៣-ថែរក្សា និងត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្របទៅតាមបញ្ជារបស់តុលាការ ឬ តាមលិខិតស្នាមដែលខ្លួនត្រូវបានតែងតាំង ។

៤-បើក និងរក្សាទុកគណនីធនាគារក្នុងនាមរបស់ខ្លួនជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសម្រាប់ទឹកប្រាក់ក្រុមហ៊ុនដែលបានមកដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

៥-រក្សាទុកគណនីពិស្តារពីកិច្ចការជំនួញទាំងអស់ដែលបានសំរេចឡើងដោយខ្លួនឯងដែលជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៦-រក្សាទុកគណនីទាំងឡាយនៃការគ្រប់គ្រង និងសម្រាប់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រួតពិនិត្យក្នុងពេលម៉ោងធ្វើអាជីវកម្ម ។

៧-រៀបចំយ៉ាងហោចណាស់ម្តងក្នុងមួយឆមាសនូវរបាយការណ៍ហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនត្រូវបានតែងតាំង ។

៨-ផ្តល់នូវគណនីចុងក្រោយនៃការគ្រប់គ្រង ដើម្បីបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួន ។

មាត្រា ២០៤.-

តាមការស្នើសុំដោយអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ការស្នើសុំដោយបុគ្គលដែលមានផលប្រយោជន៍ តុលាការត្រូវចេញបញ្ជាដោយយល់ថាគួរបញ្ចូលបន្ថែមដោយគ្មានកម្រិតនូវ :

ក-ជីកាតែងតាំង ជីកាតែងតាំងជំនួស ឬ ជីកាបញ្ចប់សិទ្ធិអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ និងជីកាដែលឱ្យសច្ចានុម័តលើគណនីរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

ខ-ជីកាកំណត់សេចក្តីជូនដំណឹងដែលត្រូវផ្តល់ដល់បុគ្គលណាម្នាក់ ឬជី-កាបញ្ជូនសេចក្តីជូនដំណឹងដល់បុគ្គលណាម្នាក់ ។

គ-ជីកាកំណត់ប្រាក់ឧបត្ថម្ភដល់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

ឃ-ជីកាកំណត់ទិសដៅដល់រាល់បញ្ហាទាក់ទងទៅនឹងភារកិច្ចរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

៩_ អ្នកសវនកម្ម

មាត្រា ២០៥._

មហាសន្និបាតម្ចាស់ហ៊ុន ត្រូវធ្វើឡើងនៅទីកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងលក្ខន្តិក: ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ។

មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបានប្រសិនបើមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ។

មាត្រា ២០៦._

អភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំមិនឱ្យលើសពី ១២ (ដប់ពីរ)ខែ ក្រោយពីក្រុមហ៊ុននោះបានបង្កើតឡើងជាផ្លូវការ ។

អភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញរបស់ម្ចាស់ហ៊ុននៅពេលណាមួយក៏បានតាមការចាំបាច់ ។

មាត្រា ២០៧._

ម្ចាស់ហ៊ុនទាំងឡាយអាចធ្វើសំណូមពរទៅអភិបាលឱ្យកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនតាមគោលបំណង ដែលបានបញ្ជាក់នៅក្នុងសំណើនោះ ។

លិខិតស្នើសុំនោះត្រូវធ្វើឡើងដោយម្ចាស់មូលបត្រដែលកាន់កាប់ប័ណ្ណភាគហ៊ុនមិនតិចជាង ៥១ (ហាសិបមួយ)ភាគរយនៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានបោះចេញ ហើយដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាត ។

លិខិតស្នើសុំនោះ អាចធ្វើតាមបែបបទផ្សេងៗ ដែលបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនម្នាក់ ឬ ច្រើននាក់ ។

លិខិតសំណើនៅក្នុងកិច្ចប្រជុំ ត្រូវបញ្ជាក់នូវពាណិជ្ជកិច្ចដែលត្រូវធ្វើ ហើយត្រូវធ្វើទៅអភិបាលម្នាក់ៗ និងទៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ។

នៅពេលទទួលសំណើ អភិបាលទាំងឡាយត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីពិភាក្សាកិច្ចការពាណិជ្ជកម្មដែលបានចែងនៅក្នុងលិខិតស្នើសុំនោះ ។

ប្រសិនបើអភិបាលទាំងឡាយ មិនបានកោះប្រជុំក្នុងអំឡុងពេល ២១ (ម្ភៃមួយ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំនោះទេ ម្ចាស់ហ៊ុនណាមួយដែលបានចុះហត្ថលេខាលើលិខិតស្នើសុំនោះ អាចកោះប្រជុំមហាសន្និបាតបាន ។

លុះត្រាតែម្ចាស់ហ៊ុនទាំងឡាយបានធ្វើសេចក្តីសម្រេចនៅឯមហាសន្និបាតដែលម្ចាស់ហ៊ុនបានកោះប្រជុំ ក្នុងករណីនេះក្រុមហ៊ុនត្រូវចេញសងម្ចាស់ហ៊ុនវិញនូវការចំណាយលើកលែងតែម្ចាស់ហ៊ុនទាំងឡាយដែលបានសម្រេចផ្សេងពីនេះ ដែលបានធ្វើឡើងដោយម្ចាស់ហ៊ុនដ៏សមហេតុសមផលក្នុងការស្នើសុំការកោះប្រជុំ និងការរៀបចំមហាសន្និបាតនោះ ។

មាត្រា ២០៨.-

ក្នុងករណីមិនអាចកោះប្រជុំ ឬ មិនអាចប្រព្រឹត្តទៅបាន ចំពោះកិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុនទៅតាមបែបទ ដែលបានចែងក្នុងលក្ខន្តិក: ឬច្បាប់នេះ ឬដោយមូលហេតុណាមួយផ្សេងទៀត អភិបាល ម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំ ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចស្នើសុំតុលាការឱ្យចាត់ចែងមហាសន្និបាតបាន ទៅតាមវិធីណាមួយ ដែលតុលាការពិចារណាឃើញថាសមស្រប ។

តុលាការអាចកំណត់ក្បួរុំផ្សេងពីក្បួរុំដែលបានតម្រូវដោយលក្ខន្តិក: ឬច្បាប់នេះចំពោះកិច្ចប្រជុំដែលបានកោះប្រជុំ ដែលបានរៀបចំនិងដែលបានប្រព្រឹត្តទៅដោយផ្អែកតាមមាត្រានេះ ។

មាត្រា ២០៩.-

ម្ចាស់ហ៊ុនដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុន គឺជាអ្នកកាន់កាប់ប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ សេរី ដែលមានឈ្មោះក្នុងបញ្ជីមូលបត្រ នៅពេលបិទអាជីវកម្ម តាមកាលបរិច្ឆេទដែលកំណត់ទុកជាមុន ។

អភិបាលសម្រេចកាលបរិច្ឆេទដែលកំណត់ទុកមុនមិនច្រើនជាង ៥០ (ហា-សិប)ថ្ងៃ ឬតិចជាង ២០(ម្ភៃ)ថ្ងៃ មុនថ្ងៃធ្វើមហាសន្និបាតឡើយ ។

ប្រសិនបើអភិបាលមិនបានសម្រេចកាលបរិច្ឆេទកំណត់ទុកជាមុនទេ កាលបរិច្ឆេទកំណត់ទុកត្រូវធ្វើឡើង :

១- នៅពេលបិទអាជីវកម្ម មុនថ្ងៃជូនដំណឹងពីមហាសន្និបាត ។

២- នៅថ្ងៃមហាសន្និបាតត្រូវបានរៀបចំឡើង ប្រសិនបើគ្មានការជូនដំណឹងមុនទេ ។

ចំពោះកាលបរិច្ឆេទកំណត់ទុកមុនដើម្បីកំណត់ថា តើម្ចាស់ហ៊ុនមានសិទ្ធិផ្សេងទៀតឬទេ ក្រៅពីសិទ្ធិក្នុងការទទួលលិខិតជូនដំណឹងពីមហាសន្និបាត និងសិទ្ធិក្នុងការបោះឆ្នោត ។ សិទ្ធិនោះត្រូវកំណត់នៅថ្ងៃបិទអាជីវកម្ម ហើយដែលអភិបាលបានអនុម័តលើសេចក្តីសម្រេចដែលពាក់ព័ន្ធដល់សិទ្ធិនោះ ។

មាត្រា ២១០.-

ប្រសិនបើអភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកជាមុន អភិបាលត្រូវបោះផ្សាយលិខិតជូនដំណឹង ពីកាលបរិច្ឆេទកំណត់ទុកនោះនៅក្នុងសារព័ត៌មានដែលធ្វើចរាចរជាទូទៅដល់ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ។

អភិបាលត្រូវផ្តល់ផងដែរនូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅគ្រប់ទីផ្សារភាគហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅទីនោះបំណុភាគហ៊ុនរបស់ក្រុមហ៊ុនមានចុះក្នុងបញ្ជីសម្រាប់លក់ដូរ ។

លិខិតជូនដំណឹងនេះត្រូវផ្តល់ក្នុងអំឡុងពេល ០៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីអភិ-បាលបានបង្កើតកាលបរិច្ឆេទកំណត់ទុកនោះ ។

លិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ទុកមិនតម្រូវឱ្យមានទេ ប្រសិនបើគ្រប់អ្នកកាន់កាប់បំណុភាគហ៊ុនតាមប្រភេទ ឬ សៀរីដែលមានឈ្មោះក្នុងបញ្ជីមូលបត្រនៅពេលបិទអាជីវកម្មនាថ្ងៃអភិបាលបង្កើតកាលបរិច្ឆេទកំណត់ទុក បានធ្វើលិខិត

ជំរាបក្រុមហ៊ុនបញ្ជាក់ពីការអនុគ្រោះរបស់ខ្លួនក្នុងការទទួលលិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ទុក ។

មាត្រា ២១.

ក្រុមហ៊ុនត្រូវរៀបចំបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីការប្រជុំ ។ បញ្ជីឈ្មោះនោះ ត្រូវចាត់ថែងតាមលំដាប់អក្សរ និងបញ្ជាក់ចំនួនភាគហ៊ុនដែលបានកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ ។

ប្រសិនបើអភិបាលទាំងឡាយបានកំណត់កាលបរិច្ឆេទបញ្ជីត្រូវរៀបចំយ៉ាងយូរ ១០ (ដប់)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនោះ ។

ប្រសិនបើអភិបាលមិនបានកំណត់កាលបរិច្ឆេទ បញ្ជីត្រូវរៀបចំ :

១- នៅពេលបិទអាជីវកម្មនាថ្ងៃបន្ទាប់ ដែលលិខិតជូនដំណឹងត្រូវបានផ្តល់ឱ្យជាបន្ទាន់ ។

២- នៅពេលដែលគ្មានការជូនដំណឹង បញ្ជីត្រូវរៀបចំនៅថ្ងៃបើកមហាសន្និបាត ។

មាត្រា ២១២.

បុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន មានសិទ្ធិបោះឆ្នោតសម្តែងនៅត្រង់ប្រអប់ដែលមានឈ្មោះរបស់ខ្លួន ក្នុងអង្គប្រជុំដែលជាប់ទាក់ទងទៅនឹងបញ្ជីឈ្មោះនោះ ។

ប្រសិនបើបុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលបានផ្ទេរកម្មសិទ្ធិភាគហ៊ុនណាមួយ ក្រោយពីកាលបរិច្ឆេទកំណត់ទុក បុគ្គលទទួលកម្មសិទ្ធិនោះត្រូវមានសិទ្ធិបោះឆ្នោតនៅក្នុងអង្គប្រជុំបាន ក្រោយពីបានបំពេញលក្ខខណ្ឌពីរ :

១- មានភាគហ៊ុនដែលមានបិដ្ឋិលេខត្រឹមត្រូវ ឬ បង្ហាញភស្តុតាងដែលបញ្ជាក់ថាខ្លួនជាម្ចាស់ភាគហ៊ុន ។

២- ទាមទារបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជី ឱ្យបានមុនការប្រជុំយ៉ាង

យ៉ូរ១០(ដប់)ថ្ងៃ ឬ ផ្ទុចមានចែងនៅលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

មាត្រា ២១៣.-

ម្ចាស់ហ៊ុនម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ម្ចាស់ហ៊ុនទាំងឡាយបាន :

ក- នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការធម្មតា ។

ខ- នៅពេលប្រជុំមហាសន្និបាតម្ចាស់ហ៊ុន បញ្ជីឈ្មោះត្រូវបានរៀបចំ ។

មាត្រា ២១៤.-

លិខិតផ្ញើនដំណឹងជាលាយលក្ខណ៍អក្សរ លើរាល់ការប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវផ្តល់ទៅឱ្យម្ចាស់ហ៊ុនទាំងអស់ អភិបាលទាំងអស់ និងសវនករផង ក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ ទៅ ៥០(ហាសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃមហាសន្និបាតនោះ ។

លិខិតផ្ញើនដំណឹងពីការប្រជុំមហាសន្និបាត ម្ចាស់ហ៊ុនត្រូវបញ្ជាក់ពីកាលបរិច្ឆេទរបៀបវារៈ និងទីកន្លែងនៃមហាសន្និបាតនោះ ។

នៅពេលដែលមានពាណិជ្ជកិច្ចសំខាន់ ត្រូវលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំ :

-ឯកសារពិស្តារដែលចែងអំពីខ្លឹមសារនៃពាណិជ្ជកិច្ច ដើម្បីឱ្យម្ចាស់ហ៊ុនធ្វើការវិនិច្ឆ័យដោយសមហេតុផល និង

-អត្ថបទស្តីពីសេចក្តីសម្រេចពិសេស ត្រូវដាក់ស្នើសុំការពិនិត្យនៅក្នុងកិច្ចប្រជុំនោះ ។

ការខកខានក្នុងការទទួលលិខិតផ្ញើនដំណឹងគឺមិនដកសិទ្ធិម្ចាស់ហ៊ុនក្នុងការបោះឆ្នោតនៅឯមហាសន្និបាតនោះឡើយ ។

ប្រសិនបើកិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវលើករារៈប្រជុំទៅពេលក្រោយមានរយៈពេលតិចជាង ៣០ (សាមសិប)ថ្ងៃ គឺមិនចាំបាច់ផ្តល់លិខិតផ្ញើនដំណឹងអំពី

កិច្ចប្រជុំដែលបានលើកវារៈប្រជុំនោះឡើយ ។ ម៉្យាងទៀតអាច ធ្វើការជូនដំណឹងដោយការប្រកាសនៅឯអង្គប្រជុំ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

មាត្រា ២១៥.-

ម្ចាស់ហ៊ុន និងបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាត អាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុននេះបាន។

ប៉ុន្តែម្ចាស់ហ៊ុន ឬ បុគ្គលនោះ នៅពេលចូលរួមប្រជុំ អាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ច ដោយសំអាងថា មហាសន្និបាតនោះមិនបានកោះប្រជុំត្រឹមត្រូវតាមច្បាប់កំណត់ ។

មាត្រា ២១៦.-

ម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតប្រចាំឆ្នាំអាច :

ក- ស្នើសុំឱ្យក្រុមហ៊ុនពិនិត្យន្ធរសេចក្តីជូនដំណឹងពីប្រធានបទមួយដែលខ្លួនស្នើសុំ ដើម្បីលើកឡើងនៅក្នុងអង្គប្រជុំ ។

ខ- ពិភាក្សាវែកញែក ពីប្រធានបទមួយ ដែលសមស្របទៅនឹងសំណូមពររបស់ខ្លួន ។

មាត្រា ២១៧.-

ក្វ័រុំមនៃម្ចាស់ហ៊ុនសម្រាប់មហាសន្និបាត គឺវត្តមាននៃអ្នកកាន់កាប់ភាគហ៊ុនភាគច្រើន ដែលមានសិទ្ធិបោះឆ្នោត មានវត្តមានដោយផ្ទាល់ ឬដោយតំណាងជាអាណត្តិគាហក: លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ប្រសិនបើក្វ័រុំមានគ្រប់ចំនួននៅពេលបើកមហាសន្និបាតម្ចាស់ហ៊ុនទាំងឡាយដែលមានវត្តមាន អាចពិភាក្សានៅក្នុងអង្គប្រជុំបាន ។

ប្រសិនបើក្វ័រុំមិនមានគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាតទេ ម្ចាស់ហ៊ុនដែលមានវត្តមានអាចលើកវារកាលប្រជុំនោះទៅពេលក្រោយ និងទីកន្លែងកំណត់មួយ

ប៉ុន្តែមហាសន្និបាតដែលបានលើកវារៈប្រជុំនោះ មិនត្រូវបានអនុញ្ញាតឱ្យពិភាក្សាលើកិច្ចការជំនួញណាមួយបានឡើយ ។

មាត្រា ២១៨.-

រាល់សមាជិកហ៊ុនជាម្ចាស់ប័ណ្ណភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ឬ អាណត្តិគាហកៈរបស់ខ្លួន មានសិទ្ធិចូលរួម និងបោះឆ្នោត នៅក្នុងកិច្ចប្រជុំទៅតាមសិទ្ធិបោះឆ្នោត ដែលមានសម្រាប់ភាគហ៊ុនរបស់ខ្លួន ។

ក្នុងករណីបុគ្គលពីរនាក់ ឬច្រើននាក់កាន់កាប់ភាគហ៊ុនរួមគ្នា ហើយបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងនោះ មានវត្តមានក្នុងមហាសន្និបាតម្ចាស់ហ៊ុន អ្នកនោះអាចបោះឆ្នោតបាន ទោះជាអវត្តមានអ្នកឯទៀតក៏ដោយ ។

ប្រសិនបើមានបុគ្គលពីរនាក់ ឬ ច្រើននាក់ក្នុងចំណោមគាហកៈទាំងនោះ មានវត្តមានដោយផ្ទាល់ ឬ ដោយអាណត្តិគាហកៈរបស់ខ្លួន ពួកគេអាចបោះឆ្នោតសម្រាប់មួយសំឡេងលើភាគហ៊ុនដែលបានកាន់កាប់រួមគ្នានោះ ។

មាត្រា ២១៩.-

រាល់ម្ចាស់ហ៊ុនអាចផ្តល់សិទ្ធិ ឱ្យរូបវន្តបុគ្គលណាមួយផ្សេងដើម្បីធ្វើជាតំណាង និងដើម្បីបោះឆ្នោតក្នុងនាមជាអាណត្តិគាហកៈ ជំនួសខ្លួនបាននៅក្នុងកិច្ចប្រជុំ ។ ការប្រគល់សិទ្ធិត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានចុះហត្ថលេខាដោយម្ចាស់ហ៊ុន ហើយត្រូវមានកាលបរិច្ឆេទ ។

ឯកសារប្រគល់សិទ្ធិ មិនត្រូវមានសុពលភាពលើសពី ០១ (មួយ)ឆ្នាំឡើយ បន្ទាប់ពីកាលបរិច្ឆេទនៃហត្ថលេខាលើលិខិតប្រគល់សិទ្ធិនោះ ឬ សម្រាប់រយៈពេលខ្លីជាងនេះ ដែលឯកសារប្រគល់សិទ្ធិនោះបានបញ្ជាក់ ។

ម្ចាស់ហ៊ុនមួយចំនួន អាចព្រមព្រៀងក្នុងចំណោមពួកគេជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ចេញសំឡេងឆ្នោតនៃភាគហ៊ុនតាមវិធីណាមួយ ។

មាត្រា ២២០.-

ការបោះឆ្នោតជ្រើសរើសអភិបាល និងសេចក្តីសម្រេចលើប្រធានបទផ្សេងៗ ដែលបានផ្តល់សំឡេងឆ្នោត ដោយម្ចាស់ហ៊ុនត្រូវធ្វើតាមសន្លឹកឆ្នោតសម្ងាត់ លុះត្រាតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

មាត្រា ២២១.-

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់ម្ចាស់ហ៊ុនទាំងអស់ ដែលមានសិទ្ធិបោះឆ្នោត មានសុពលភាពដូចគ្នានឹងសេចក្តីសម្រេច ដែលបានអនុម័តនៅឯមហាសន្និបាតម្ចាស់ហ៊ុនដែរ ។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងប្រធានបទទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងមហាសន្និបាតម្ចាស់ហ៊ុន ដែលបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់ គឺរួចផុតអំពីលក្ខខណ្ឌតម្រូវនៃច្បាប់នេះ ដែលទាក់ទងទៅនឹងមហាសន្និបាតម្ចាស់ហ៊ុន ។

ឯកសារនៃជាសេចក្តីសម្រេចត្រូវរក្សាទុក ដោយមានភ្ជាប់ជាមួយកំណត់ហេតុមហាសន្និបាតម្ចាស់ហ៊ុននោះ ។

មាត្រា ២២២.-

ម្ចាស់ហ៊ុនណាដែលមិនបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពីកិច្ចប្រជុំ ហើយមានពីកតាងសមហេតុសមផលផង ម្ចាស់ហ៊ុននោះមានសិទ្ធិប្តឹងសុំទៅតុលាការ ដើម្បីទាត់ចោលសេចក្តីសម្រេចណាមួយ ដែលធ្វើឡើងនៅឯកិច្ចប្រជុំនោះ ។

ក្រុមហ៊ុន ម្ចាស់ហ៊ុន ឬ អភិបាល អាចស្នើសុំតុលាការឱ្យដោះស្រាយការខ្វែងគំនិតគ្នា ដែលពាក់ព័ន្ធដល់ការបោះឆ្នោត ឬ ការតែងតាំងអភិបាល ឬ សវនករនៃក្រុមហ៊ុននោះ ។

មាត្រា ២២៣.-

កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្រេបច្បាប់មួយ រវាងម្ចាស់ហ៊ុនទាំងអស់របស់ក្រុមហ៊ុន ដែលដាក់កម្រិតអំណាចទាំងស្រុង ឬ មួយផ្នែករបស់អភិបាលក្នុងការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់ក្រុមហ៊ុន គឺមានសុពលភាព ។

អ្នកទទួលការផ្ទេរភាគហ៊ុនដែលផ្អែកតាមការព្រមព្រៀងនោះជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកជាភាគីនៃកិច្ចព្រមព្រៀងនោះ ។

ម្ចាស់ហ៊ុនដែលជាភាគីនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទបានទទួលនូវសិទ្ធិ ភារកិច្ចទាំងអស់របស់អភិបាលក្រុមហ៊ុន ដើម្បីគ្រប់គ្រងជំនួញ និងកិច្ចការក្រុមហ៊ុន ដែលមានទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងនោះ ។ អភិបាលត្រូវបំពេញភារកិច្ច និង ការទទួលខុសត្រូវរបស់ខ្លួនតាមកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវធ្វើឡើងដោយសមាជិកហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវរក្សាទុកក្នុងកំណត់ហេតុរបស់ក្រុមហ៊ុនដូចដែលបានចែងក្នុងមាត្រា ១០៩ ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនៅលើបំណុលភាគហ៊ុន ។

ឈ_ របាយការណ៍ហិរញ្ញវត្ថុ

មាត្រា ២២៤.-

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ។ របាយការណ៍នោះត្រូវមានទាំង :

ក- របាយការណ៍ហិរញ្ញវត្ថុ ដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន ។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព និងបញ្ចប់នៅកាលបរិច្ឆេទមិនលើសពី ៦ (ប្រាំមួយ)ខែ មុនមហាសន្និបាតប្រចាំឆ្នាំ ។

ខ- របាយការណ៍របស់សវនករ ។

គ- ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬ កិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន ។

មាត្រា ២២៥.-

យោងតាមសំណើរបស់ខ្លួន ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបាន ដោយមិនគិតថ្លៃ ។

មាត្រា ២២៦.-

អភិបាលទទួលយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការយល់ព្រមនោះត្រូវមានហត្ថលេខារបស់អភិបាលម្នាក់ ឬ ច្រើននាក់ ។

ក្រុមហ៊ុនមិនត្រូវចេញឱ្យបោះផ្សាយ ឬ ធ្វើចរាចរឯកសារនៃរបាយការណ៍ហិរ-ញ្ញវត្ថុប្រចាំឆ្នាំបានឡើយ ។ ក្រុមហ៊ុនអាចធ្វើកិច្ចការខាងលើបាន លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ត្រូវអមដោយរបាយការណ៍របស់សវនករផង ។

មាត្រា ២២៧.-

ក្រុមហ៊ុនត្រូវបញ្ជូនឯកសាររបាយការណ៍ហិរញ្ញវត្ថុនិងឯកសារស្វែងយល់ទាំងឡាយទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬមុនការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ លើកលែងតែម្ចាស់ហ៊ុនណាដែលបានជូនដំណឹងទៅក្រុមហ៊ុនជាលាយលក្ខណ៍អក្សរថាខ្លួនមិនត្រូវការឯកសារទាំងនោះទេ ។

មាត្រា ២២៨.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបោះចេញមូលបត្រប្រភេទណាមួយទៅសាធារណជន ដែលត្រូវបានកាន់កាប់ដោយបុគ្គលលើសពីម្នាក់ ត្រូវធ្វើ

ឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

របាយការណ៍ និងឯកសារទាំងឡាយ ត្រូវធ្វើទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬ ធ្វើជាបន្ទាន់ បន្ទាប់ពីការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ ។

មាត្រា ២២៩.-

ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូប ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ ។

សវនករ ត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃឆ្នាំបន្ទាប់ ។

ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់តំណែង ត្រូវបន្តរហូតដល់សវនករថ្មីត្រូវបានតែងតាំង ។

មាត្រា ២៣០.-

ម្ចាស់ហ៊ុននៃក្រុមហ៊ុនដែលមិនបានចេញមូលបត្រប្រភេទណាមួយទៅឱ្យសាធារណជន ឬ ដោយគ្មានមូលបត្រដែលកាន់ដោយបុគ្គលលើសពីម្នាក់ អាចធ្វើសេចក្តីសម្រេចមិនតែងតាំងសវនករបាន ។

មាត្រា ២៣១.-

សោហ៊ុយចំណាយសម្រាប់សវនករ អាចត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចសាមញ្ញរបស់ម្ចាស់ហ៊ុន ឬ បើមិនដូច្នេះទេ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ។

មាត្រា ២៣២.-

ម្ចាស់ហ៊ុនទាំងឡាយអាចដកហូតសវនករពីមុខតំណែងបាន លើកលែងតែសវនករត្រូវបានតែងតាំងដោយតុលាការ ឬ ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុង

មហាសន្និបាតពិសេស ។ នៅក្នុងអង្គប្រជុំដូចគ្នានោះ ម្ចាស់ហ៊ុនអាចតែងតាំងសវនករជំនួសបាន ។

នៅពេលណា ដែលមានភាពទំនេរនៃតំណែងសវនករ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំមហាសន្និបាតពិសេសនៃម្ចាស់ហ៊ុន ដើម្បីបំពេញភាពទៅទំនេរនោះ ដោយត្រូវធ្វើឡើងក្នុងរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីមានភាពទំនេរនោះ ។

សវនករដែលត្រូវតែងតាំងដើម្បីបំពេញភាពទំនេរនោះ ត្រូវកាន់កាប់តំណែងបន្តជំនួសអាណត្តិដែលមិនទាន់ផុតកំណត់របស់សវនករមុន ។

មាត្រា ២៣៣.-

ប្រសិនបើក្រុមហ៊ុនមិនទាន់មានសវនករ តាមការស្នើសុំរបស់ម្ចាស់ហ៊ុន ឬ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម តុលាការអាចតែងតាំង និងដាក់កំណត់ដោះស្រាយចំណាយសម្រាប់សវនករ ដែលបានកាន់តំណែងរហូតដល់សវនករថ្មីត្រូវបានតែងតាំងដោយម្ចាស់ហ៊ុនទាំងឡាយ ។

មាត្រា ២៣៤.-

សវនករត្រូវធ្វើការត្រួតពិនិត្យ លើចំណុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុនទាំងឡាយ លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុន ឬ អភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានការបកស្រាយបំភ្លឺ និងសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ ។

សវនកររបស់ក្រុមហ៊ុន មានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាត ម្ចាស់ហ៊ុន និងចូលរួមដើម្បីជឹងឮនូវកម្មវត្ថុ ដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន ។

ប្រសិនបើអភិបាល ឬ ម្ចាស់ហ៊ុន ទោះបីជាម្ចាស់ហ៊ុននោះគ្មានសិទ្ធិបោះឆ្នោត ក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្ន ឬ ពីមុនក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ មុនមហាសន្និបាត សវនករបច្ចុប្បន្ន ឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ ។

ញ_ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

មាត្រា ២៣៥._

ក្រុមហ៊ុនមូលធន អាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន ។

មាត្រា ២៣៦._

ក្រុមហ៊ុនមូលធនត្រូវធ្វើការកែប្រែលក្ខន្តិកៈតាមសេចក្តីសម្រេចពិសេស។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬ ជាសៀរីដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្តីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង :

១- បន្ថែម កែប្រែ ឬ ដកហូតនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុន ។

២- បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុននោះ ។

៣- បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន ដែលមានសិទ្ធិចំពោះប្រភេទ ឬ សៀរីដែលមានសិទ្ធិ ឬ ឯកសិទ្ធិស្មើ ឬ ក៏លើសពីប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៤- បង្កើតប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬ លើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬ សៀរីរបស់អ្នកកាន់កាប់នោះ ។

៥- បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬ ឯកសិទ្ធិតូចជាង ឬ ស្មើ ឬ លើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៦- បន្ថយគណនីដើមទុនចុះបញ្ជីនៃប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថាប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុនជាក់លាក់មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទ ឬសៀរីនៃប័ណ្ណភាគហ៊ុន នោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រភេទ ឬ សៀរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬ ដោយប្រយោល ឬ ប៉ះពាល់ទៅនឹង សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬ សៀរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

សិទ្ធិក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងមាត្រានេះ មិនត្រូវបានលុបចោល បន្ថយ ឬ ដាក់កម្រិតដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬ តាមរបៀបណាមួយផ្សេងទៀតឡើយ ។

មាត្រា ២៣៧.-

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវធ្វើជូនទៅម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត យ៉ាងតិច ២០(ម្ភៃ) ថ្ងៃ មុនពេលបើកមហាសន្និបាត ។ លិខិតជូនដំណឹងនេះត្រូវធ្វើភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ ។

មាត្រា ២៣៨.-

ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ :

ក- ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ។

ខ- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬ សកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

គ- ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និង លក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ ។

ឃ- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ ។

ង- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ ។

ច- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ឈប់តម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត ។ ដើមទុនចុះបញ្ជីមិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម ។ បើក្នុងរយៈពេលនេះមានការតវ៉ាជំទាស់ពីម្ចាស់បំណុល ដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុង មុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន ។

ឆ- ការកែប្រែចិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន ។

ជ- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី ។

ឈ- ការកែប្រែចំនួនក្តារ៉ុម ។

ញ- បន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់នេះអនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

មាត្រា ២៣៩.-

គ្រប់ឯកសារស្តីពីការធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬ ចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេច ព្រមទាំងមានចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ អភិបាលណាម្នាក់ដែលទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល ។

ឯកសារទាំងនេះត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥(ដប់ប្រាំ) ថ្ងៃ ក្រោយពីមហាសន្និបាតបានសម្រេច ។

មាត្រា ២៤០.-

ពេលបានទទួលឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ ។

ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀត កាលបរិច្ឆេទនោះមិនឱ្យលើសពី ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ ។

ជ- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

មាត្រា ២៤១.-

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនជើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនជើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

មាត្រា ២៤២.-

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

មាត្រា ២៤៣.-

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

ក- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លក្ខន្តិក:របស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម ។

គ- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនជើមឱ្យទៅជាភាគហ៊ុន ឬមូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

ឃ- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬ កម្មសិទ្ធិផ្សេងៗទៀតដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួល ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនជើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ ។

ង- ព័ត៌មានមានផ្ទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹងជើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ច- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ជើម្បីធ្វើឱ្យប្រសើរឡើងនិងជើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម ។

មាត្រា ២៤៤.-

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនជើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតទ្ធវព័ត៌មានដូចតទៅ :

ក- នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនជើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ជើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

គ- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន ។

មាត្រា ២៤៥.-

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។

មាត្រា ២៤៦.-

ទោះបីលក្ខន្តិក:របស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬ សើរីនៃភាគហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធឬកែប្រែដោយលក្ខន្តិក:របស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ ។

មាត្រា ២៤៧.-

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមានជាអាទិ៍ :

ក- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ ។

គ- លក្ខន្តិក:របស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

ឃ- សេចក្តីប្រកាសរបស់អភិបាលឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

១- ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ។

២- ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ។

៣- គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។

៤- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើមហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។

មាត្រា ២៤៨.-

នៅពេលទទួលលក្ខន្តិក:ស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

ក- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន ។

ខ- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

គ- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ ។

ឃ- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធ ដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុន ថ្មីដែលបន្តធ្វើអាជីវកម្ម ។

ង- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈ សម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុម ហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុន ថ្មីដែលបន្តធ្វើអាជីវកម្ម ។

មាត្រា ២៤៩.-

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មាន សិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃ ម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌ ដូចតទៅ :

ក- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ ។

ខ- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការ រំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ ។

គ- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុម ហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូល គ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ឃ- នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ បំណុលភាគហ៊ុនរបស់ខ្លួន ទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

មាត្រា ២៥០.-

នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួល ធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុនដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួល

រកតម្លៃសមរម្យមួយក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ដើម្បីឱ្យមានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។

តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយ នៅក្នុងកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្តកម្ម។ មុននឹងមជ្ឈត្តករចេញសេចក្តីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្តឹងទាមទាររបស់ខ្លួន ក្នុងការវាយតម្លៃនៅពេលណាមួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តនូវតម្លៃសមមូល ដែលក្រុមហ៊ុនបានកំណត់ពីមុន ។

ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេ ភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយ ហើយម្ចាស់ហ៊ុនដែលទាមទារត្រូវទទួលទៅតាមចំនួននោះ ។

៥_ ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី

មាត្រា ២៥១._

ក្រុមហ៊ុនដែលគ្មានចេញបំណុលភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់ ។

ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្តីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញបំណុលភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។

ក្រុមហ៊ុនត្រូវបញ្ជូនសេចក្តីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

នៅពេលបានទទួលសេចក្តីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបានចាត់ទុកថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន ។

មាត្រា ២៥២.-

អភិបាលឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

លិខិតជូនដំណឹងស្តីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬ រំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុននោះ ។

ក្រុមហ៊ុនដែលមានព្រទ្យសម្បត្តិ និង/ឬ មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ។ ក្នុងករណីដែលក្រុមហ៊ុនមានចេញបំណុលភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតទេ ប្រសិនបើ :

១- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុន តាមសេចក្តីសម្រេចពិសេសឬ សេចក្តីសម្រេចសាមញ្ញ ។

២- ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុន ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៥៣.-

ក្រោយពីមានការយល់ព្រមលើសេចក្តីសម្រេចជម្រះបញ្ឈៃ និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីបំណងរំលាយជាទម្រង់លម្អិតទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីប្រកាសពីបំណងរំលាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ ។

នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយក្រុមហ៊ុនក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្ម លើកលែងតែចំពោះការពន្យារចាំបាច់សម្រាប់ការជម្រះបញ្ឈៃ ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន នៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ ។

មាត្រា ២៥៤.-

ក្រោយពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ :

ក- ធ្វើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន ។

ខ- ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល ២(ពីរ)សប្តាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀតដូចបានកំណត់ក្នុងបទបបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៥៥.-

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវ :

-ប្រមូលទ្រព្យសម្បត្តិ

-រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន

-បំពេញកាតព្វកិច្ចទាំងឡាយ

-ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬ ជាវត្ថុទៅឱ្យម្ចាស់ហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ ។

មាត្រា ២៥៦.-

នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬជនដែលមានការពាក់ព័ន្ធផលប្រយោជន៍អាចស្នើទៅតុលាការ ដើម្បីឱ្យការជម្រះបញ្ជីក្រោមការត្រួតពិនិត្យរបស់តុលាការ ។

អ្នកដាក់ពាក្យសុំត្រូវផ្តល់ឱ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ឬតាមរយៈតំណាង ។

មាត្រា ២៥៧.-

នៅពេលជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន ។

សេចក្តីសម្រេចស្តីពីការរំលាយត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបន-បត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

មាត្រា ២៥៨.-

បទប្បញ្ញត្តិស្តីពីការរំលាយ និងការជម្រះបញ្ជីខាងលើ មិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ ។

ខ- មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

មាត្រា ២៥៩.-

ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មម្នាក់ ឬច្រើននាក់តាមការចាំបាច់ ដើម្បីឱ្យបំពេញតួនាទីស្របតាមច្បាប់នេះ ។

មាត្រា ២៦០.-

ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្រ ឬ បញ្ជាក់អំពីសកម្មភាពណាមួយរបស់ក្រុមហ៊ុន ។ វិញ្ញាបនបត្រនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦១.-

លិខិតជូនដំណឹង ឬឯកសារផ្សេងៗ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងក្រុមហ៊ុនត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទទួលយកឯកសារថតចម្លងផ្សេងៗទាំងនោះបាន ។

មាត្រា ២៦២.-

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ហេតុការណ៍ពិត ដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ ។

មាត្រា ២៦៣.-

ក្រសួងពាណិជ្ជកម្មអាចធ្វើសេចក្តីណែនាំដែលមានចំណុចដូចខាងក្រោម :

ក- ការតម្រូវឱ្យរៀបរាប់ហេតុផលសំខាន់ៗដោយលម្អិត តាមការអនុញ្ញាតនៃច្បាប់នេះ ។

ខ- ការតម្រូវឱ្យមានការបង់ថ្លៃឈ្នួលចំពោះការតម្កល់ទុក ការត្រួតពិនិត្យ ឬ ការថតចម្លងឯកសារណាមួយ ឬ ចំពោះសកម្មភាពណាមួយ ។

គ- ការរៀបរាប់ពីមាតិកាតាមប្រព័ន្ធអេឡិចត្រូនិច ឬ ទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវផ្ញើជូន ឬ ចេញដោយក្រសួងពាណិជ្ជកម្ម ។

ឃ- ការប្រតិបត្តិដែលទាក់ទងដល់ការបញ្ជូន ឬ ការចេញនូវលិខិតជូនដំណឹងនិងឯកសារផ្សេងៗ ។

ង- ការរៀបរាប់ពីវិធាននានា ដែលទាក់ទងដល់ការលើកលែងមួយចំនួនដែលអនុញ្ញាតដោយច្បាប់នេះ ។

មាត្រា ២៦៤.-

លក្ខន្តិក: និងផែនការរំលាយក្រុមហ៊ុន ត្រូវផ្ញើទៅឱ្យក្រសួងពាណិជ្ជកម្ម ត្រូវមានហត្ថលេខាដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់របស់ក្រុមហ៊ុន ឬ ដោយស្ថាបនិកម្នាក់ក្នុងករណីដែលតម្រូវដោយលក្ខន្តិក: ។

ក្រោយពីបានទទួលនូវឯកសារ ឬ ផែនការតាមទម្រង់កំណត់ហើយនោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវ :

១- កត់ត្រាទុកកាលបរិច្ឆេទនៃការតម្កល់ទុក ។

២- ចេញវិញ្ញាបនបត្រ ។

៣- តម្កល់ទុកនូវវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាសរួបថត ព័ត៌មានអេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាស ។

៤- ធ្វើវិញ្ញាបនបត្រនិងឯកសារ ឬសេចក្តីប្រកាសរួបថត ព័ត៌មាន អេឡិចត្រូ-និច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាសទៅឱ្យក្រុមហ៊ុន ឬ តំណាងរបស់ក្រុមហ៊ុន ។

៥- ចុះផ្សាយនូវលិខិតជូនដំណឹងនៃការចេញវិញ្ញាបនបត្រនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦៥.-

វិញ្ញាបនបត្រដែលបានចេញដោយក្រសួងពាណិជ្ជកម្ម អាចចុះកាលបរិច្ឆេទនៅថ្ងៃដែលទទួលឯកសារ ឬផែនការ ឬដីការបស់តុលាការដែលបញ្ជាឱ្យចេញវិញ្ញាបនបត្រ ឬ នៅថ្ងៃបន្ទាប់ទៀត ដែលបានបញ្ជាក់ដោយតុលាការ ឬ បុគ្គល ដែលបានចុះហត្ថលេខាលើឯកសារ ឬ ផែនការនោះ ។

មាត្រា ២៦៦.-

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវវិញ្ញាបនបត្រ និងឯកសារចាំបាច់ដែលក្រុមហ៊ុនបានធ្វើមកឱ្យក្រសួងពាណិជ្ជកម្មស្របតាមច្បាប់នេះ ។

មាត្រា ២៦៧.-

ប្រសិនបើវិញ្ញាបនបត្រដែលចេញឱ្យក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានកំហុសឆ្គងដោយអចេតនាណាមួយនោះ អភិបាល ឬម្ចាស់ហ៊ុនត្រូវបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

ដើម្បីកែតម្រូវឡើងវិញតាមច្បាប់នេះ ។ បើមានហេតុផលត្រឹមត្រូវ ក្រសួងពាណិជ្ជកម្ម អាចបដិសេធវិញ្ញាបនបត្រដែលខុស និងចេញវិញ្ញាបនបត្រដែលត្រឹមត្រូវជំនួសវិញ ។

វិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ ត្រូវមានកាលបរិច្ឆេទតែមួយ ដូចវិញ្ញាបនបត្រចាស់ដែរ ។

ប្រសិនបើវិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ មានការកែប្រែលក្ខខណ្ឌផ្សេងពីវិញ្ញាបន-បត្រដើមនោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវផ្តល់លិខិតជូនដំណឹងជាបន្ទាន់ចំពោះការកែប្រែនោះ នៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦៨.-

បុគ្គលណាមួយដែលបានបង់ថ្លៃឈ្នួលរួចហើយ បុគ្គលនោះមានសិទ្ធិត្រួតពិនិត្យឯកសារនានា ដែលបានធ្វើទៅក្រសួងពាណិជ្ជកម្មនៅគ្រប់ម៉ោងធ្វើការ ហើយអាចធ្វើការថតចម្លង ឬ ដកស្រង់របាយការណ៍ផ្សេងៗបាន ។ ការផ្តល់ឯកសារ ឬ ថតចម្លងឯកសារដល់បុគ្គលណាម្នាក់ មិនត្រូវបានអនុវត្តចំពោះរបាយការណ៍ស៊ើបអង្កេតរបស់តុលាការទេ ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវច្បាប់ចម្លង ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់របស់ឯកសារនានា ស្របតាមលក្ខខណ្ឌនៃមាត្រានេះ ។

នៅពេលដែលឯកសារត្រូវបានរក្សាទុកដោយក្រសួងពាណិជ្ជកម្ម ហើយឯកសារនោះមានទម្រង់ជាលាយលក្ខណ៍អក្សរ ត្រូវមានលក្ខខណ្ឌដូចតទៅនេះ :

ក- ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ឯកសារចម្លងដែលតម្រូវឱ្យផ្តល់ ស្របតាមមាត្រានេះ ជាទម្រង់ឯកសារដែលអាចអានបាន ។

ខ- របាយការណ៍ដែលស្រង់ចេញពីឯកសារតម្កល់ទាំងនេះ ប្រសិនបើមានការបញ្ជាក់ពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មជាភស្តុតាងដែលមានតម្លៃដូចឯកសារដើមដែរ ។

មាត្រា ២៦៩.-

ក្រសួងពាណិជ្ជកម្មមិនមានកាតព្វកិច្ចផ្តល់ឯកសារនានា ក្រៅពីវិញ្ញាបនបត្រ និងផែនការរំលាយក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយ ក្រោយរយៈពេល ១០ (ដប់)ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួល ។

ជំពូកទី ៤
ក្រុមហ៊ុនពាណិជ្ជកម្មបរទេស
បទប្បញ្ញត្តិទូទៅ

មាត្រា ២៧០.-

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសគឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៧១.-

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះ-រាជាណាចក្រកម្ពុជាបាន តាមបែបបទផ្សេងៗដូចតទៅ :

ក- ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជ-កម្ម ។

ខ- សាខាក្រុមហ៊ុនពាណិជ្ជកម្ម ។

គ- បុត្រសម្ព័ន្ធ ។

ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមានឋានៈបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ ។

មាត្រា ២៧២.-

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវចាត់ទុកថាកំពុងធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ បានធ្វើសកម្ម-ភាពនានាដូចខាងក្រោម :

ក- ជួលការិយាល័យ ជួលកន្លែងផលិត ឬកែច្នៃ ឬ សេវាដែលមានរយៈពេលចាប់ពី ០១ (មួយ)ខែឡើងទៅ ។

ខ- ជួលបុគ្គលិកសម្រាប់បម្រើការងារឱ្យក្រុមហ៊ុន ដែលមានរយៈពេលចាប់ពីមួយខែឡើងទៅ ។

គ- ធ្វើសកម្មភាពផ្សេងទៀតណាមួយទៀត ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេស ។

មាត្រា ២៧៣.-

គ្រប់ក្រុមហ៊ុនបរទេសនានាធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាក្នុងរូបភាពណាមួយក៏ដោយ ក៏ត្រូវស្ថិតនៅក្រោមច្បាប់ និងយុត្តាធិការរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនបរទេសទាំងនោះត្រូវបំពេញទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

ក- ការិយាល័យតំណាងពាណិជ្ជកម្ម

មាត្រា ២៧៤.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ជាអាទិ៍ :

ក- ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឱ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ។

ខ- ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស ។

គ- ស្រាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ- ឃោសនាផលិតផល តាំងពិព័រណ៌ពាណិជ្ជកម្ម បង្ហាញផលិតផលនៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៌ដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៌ពាណិជ្ជកម្ម ។

ច- ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ។

ឆ- ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម ។

ប៉ុន្តែការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនអាចធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រតិបត្តិការផលិតកែច្នៃ និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

មាត្រា ២៧៥.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម ។

មាត្រា ២៧៦.-

នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស ។ នៅខាងលើឬ នៅពីមុខនាមករណ៍នេះត្រូវសរសេរដាក់ថា ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ។

មាត្រា ២៧៧.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ។

ខ- សាខាក្រុមហ៊ុន

មាត្រា ២៧៨.-

សាខាក្រុមហ៊ុនអាចធ្វើសកម្មភាពបានដូចការិយាល័យតំណាងពាណិជ្ជកម្មដែរ ។

លើសពីនេះទៀត សាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបានទ្រព្យទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គលនិង/ឬនីតិបុគ្គលបរទេស ។

មាត្រា ២៧៩.-

ទ្រព្យសកម្មរបស់សាខា គឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើកាតព្វកិច្ចរបស់សាខា ។

មាត្រា ២៨០.-

សាខាក្រុមហ៊ុន ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងម្នាក់ ឬច្រើននាក់ ដែលត្រូវតែងតាំង និងដកហូតដោយក្រុមហ៊ុនដើម ។

មាត្រា ២៨១.-

នាមករណ៍របស់សាខាគឺជានាមករណ៍របស់ក្រុមហ៊ុនដើម ។ នៅពីលើ ឬ នៅពីមុខនាមករណ៍នោះត្រូវសរសេរពាក្យ “សាខាក្រុមហ៊ុន” ។

មាត្រា ២៨២.-

"សាខាក្រុមហ៊ុន" អាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ។

គ- បុត្រសម្ព័ន្ធ

មាត្រា ២៨៣.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១ (ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ ។

មាត្រា ២៨៤.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម តាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ២៨៥.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេសអាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ជាក្រុមហ៊ុនមូលធន ។

មាត្រា ២៨៦.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរជាប្រចាំរបស់ខ្លួន ដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្ម-ភាពណា ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហាមឃាត់ចំពោះអ្នកបរទេសបុគ្គល និងនីតិ-បុគ្គលបរទេស ។

ជំពូកទី ៥
បណ្តឹងជំនួសមុខ

មាត្រា ២៨៧.-

ម្ចាស់ហ៊ុនអាចប្តឹង ឬ ធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន ។ ម្ចាស់ហ៊ុនត្រូវបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

ក- ជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន ឬអ្នកស្នងមរតករបស់ម្ចាស់ហ៊ុន នៅក្នុងអំឡុងពេលដែលការប្តឹងតវ៉ានោះ កំពុងកើតមានឡើងដោយសារពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ខ- មិនបានចោះឆ្គោតគាំទ្រ ឬមិនបានឱ្យសច្ចានុម័តតាមរបៀបណាផ្សេងទៀតឡើយ ។

គ- បានតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការដោះស្រាយជម្លោះហើយដែលក្រុមប្រឹក្សាភិបាលដោះស្រាយមិនបាន ។

ឃ- ផ្តល់លិខិតជូនដំណឹងទៅឱ្យក្រុមប្រឹក្សាភិបាល មុនពេលដាក់បណ្តឹងទៅតុលាការ ។

បណ្តឹងជំនួសមុខ បន្ទាប់ពីបាននៅតុលាការ មិនត្រូវបានដោះស្រាយដោយគ្មានការព្រមព្រៀងពីតុលាការឡើយ ។

មាត្រា ២៨៨.-

រាល់ប្រាក់សំណងដែលបានមកពីបណ្តឹងនេះ ត្រូវជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ប្រសិនបើបណ្តឹងបានផ្តល់ផលដល់ក្រុមហ៊ុន ម្ចាស់ហ៊ុនដែលបានធ្វើបណ្តឹងជំនួសមុខអាចស្នើសុំទៅតុលាការ ដើម្បីឱ្យខ្លួនបានទទួលសំណងសមស្រប ។

មាត្រា ២៨៩.-

រាល់អភិបាលនិងអ្នកគ្រប់គ្រងក្រុមហ៊ុនដែលកំពុងអនុវត្តតួនាទីរបស់ខ្លួនត្រូវ :

ក- ធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីឱ្យមានផលប្រយោជន៍

ខ្ពស់ដល់ក្រុមហ៊ុន ។

ខ- អនុវត្តដោយយកចិត្តទុកដាក់ ព្យាយាម និងជំនាញ ដូចបុគ្គលដែលមានមធ្យ័ត អនុវត្តក្នុងកាលៈទេសៈមួយដូចគ្នាដែរ ។

លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាចចែងថាគ្រប់ជម្លោះដែលកើតមានឡើងរវាងអភិបាល និងរវាងម្ចាស់ហ៊ុនត្រូវបញ្ជូនទៅមជ្ឈមណ្ឌលមជ្ឈត្តកម្ម ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ២៩០.-

អ្នកប្រព្រឹត្តបទល្មើស ឬអ្នកចូលរួមក្នុងការប្រព្រឹត្តបទល្មើស ឬអ្នកនាំឱ្យមានការប្រព្រឹត្តបទល្មើស ក្នុងការធ្វើរបាយការណ៍ បញ្ជីប្រាក់ចំណូល កំណត់ហេតុ ឬឯកសារផ្សេងៗទៀត ដែលត្រូវធ្វើទៅក្រសួងពាណិជ្ជកម្ម ឬទៅបុគ្គលផ្សេងទៀត ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល និង/ឬ ជាប់ពន្ធនាគារពី ១(មួយ) ខែ ដល់ ៦(ប្រាំមួយ) ខែ ដោយមិនទាន់គិតពីសំណងរដ្ឋប្បវេណី ឬ ទោសទណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

មាត្រា ២៩១.-

នៅពេលក្រុមហ៊ុនប្រព្រឹត្តបទល្មើស អភិបាល ឬ បុគ្គលិករបស់ក្រុមហ៊ុនណាដែលបានប្រគល់សិទ្ធិឱ្យប្រព្រឹត្តបទល្មើស ឬអនុញ្ញាត ឬបានយល់ព្រមឱ្យប្រព្រឹត្តបទល្មើស ជាអ្នកទទួលខុសត្រូវមួយនៃបទល្មើសនោះ នឹងត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា ២៩១ នៃច្បាប់នេះ ។

មាត្រា ២៩២.-

បណ្តឹងចំពោះបទល្មើសដែលបានប្រព្រឹត្តក្រោមច្បាប់នេះ ត្រូវធ្វើឡើងរយៈពេល ៣(បី)ឆ្នាំយ៉ាងយូរ ចាប់តាំងពីថ្ងៃដែលកម្មវត្ថុនៃបណ្តឹងនោះបានកើតឡើង ។

មាត្រា ២៩៣.-

ការខកខានមិនបានអនុវត្តតាមច្បាប់នេះ ដំណោះស្រាយដោយសំណងរដ្ឋប្បវេណីមិនមានឥទ្ធិពលលើបទល្មើសនោះឡើយ ។

មាត្រា ២៩៤.-

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលមិនបានអនុវត្តដោយគ្មានមូលហេតុត្រឹមត្រូវតាមបញ្ញត្តិស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ឯកសារទុក ការផ្សព្វផ្សាយ តាមតម្រូវការនៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៤៣ និង ៤៤ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ២៩៥.-

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិនៅក្នុងចំណុច គ ផ្នែកទី ២ នៃជំពូកទី ៣ ដែលពាក់ព័ន្ធនឹងសៀវភៅបញ្ជី និងកំណត់ហេតុ ត្រូវផ្តន្ទាទោសតាមមាត្រា ៤៣ និង ៤៤ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីណិជ្ជកម្ម ។

មាត្រា ២៩៦.-

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវក្នុងការធ្វើឯកសាររបាយការណ៍ហិរញ្ញវត្ថុទៅម្ចាស់ហ៊ុន និងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុទៅឱ្យម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២២៧ ត្រូវផ្តន្ទាទោសពិន័យជាទឹកប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

មាត្រា ២៩៧.-

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុ ឱ្យទៅមន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដូចបានចែងក្នុងមាត្រា ២២៨ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

មាត្រា ២៩៨.-

សវនករបច្ចុប្បន្ន ឬ សវនករពីមុនរបស់ក្រុមហ៊ុនដែលខកខានដោយគ្មានមូល-ហេតុត្រឹមត្រូវ ក្នុងការបំពេញកាតព្វកិច្ច ការចូលរួមក្នុងមហាសន្និបាតម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២៣៤ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល និង/ឬ ជាប់ពន្ធនាគារពី ១(មួយ) ខែ ដល់ ៦(ប្រាំមួយ)ខែ ។

មាត្រា ២៩៩.-

មន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល និង/ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ ។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

មាត្រា ៣០០.-

ច្បាប់នេះមិនធ្វើឱ្យប៉ះពាល់ដល់សុពលភាព និង ដល់កិច្ចដំណើរការនៃក្រុមហ៊ុនទាំងអស់ ដែលបានធ្វើការចុះបញ្ជីត្រឹមត្រូវរួចស្រេចហើយនៅក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣០១.-

ច្បាប់នេះត្រូវអនុវត្តចំពោះរាល់ដំណើរការរបស់ក្រុមហ៊ុនទាំងអស់ ក្នុងទំនាក់ទំនងផ្តល់ឯកសារ និងព័ត៌មានផ្សេងៗជូនក្រសួងពាណិជ្ជកម្ម ។

មាត្រា ៣០២.-

ក្រសួងពាណិជ្ជកម្មត្រូវរៀបចំគំរូលក្ខន្តិកៈនិងបែបបទកែលក្ខន្តិកៈស្របតាមច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនដល់ក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ ហើយដែលមានបំណងធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួន ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ៣០៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣០៤.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ភទ្របទ ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ជីករ

នរោត្តម សីហមុនី

៣រស.០៥០៦.២៩៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមទ្រង់ព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ស្តីពី

អតីសន្យាហិរញ្ញវត្ថុ



3/17

ព្រះរាជក្រម

នស/រកម/០៦០៩/០០៩ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខគខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោភាស កម្ពុជឯករាជ្ជបូរណាសន្តិ សុភមង្គលា សិរីតិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹស្សលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំ រដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ បានសម្រេចឱ្យប្រកាសឱ្យប្រើជាច្បាប់ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់សិទ្ធិ និងកាតព្វកិច្ចដល់ភាគីពាក់ព័ន្ធនឹងប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និងដាក់ចេញនូវវិធានការ ដើម្បីការពារសិទ្ធិទាំងនោះ ។

មាត្រា ២.-

ច្បាប់នេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។

មាត្រា ៤.-

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មានន័យមន័យដូចតទៅ :

- **តតិបតី** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្តេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិក: ។

- **តតិក:** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។

- **ចលនវត្ថុ** : សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដី និងអគារ ។

- **រយៈពេល** : សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះភតិក:ត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។

- **ភតិសន្យា** : សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយ ដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬតាមតម្លៃសមមូល ។ ភតិសន្យា ត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។

- **ភតិសន្យាបន្ត** : សំដៅដល់ប្រតិបត្តិការដែលចលនវត្ថុ ត្រូវបានផ្ទេរដោយភតិកៈដំបូង ត្រូវបានផ្ទេរបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងភ្នាក់ងារភាគីដំបូង នៅមានសុពលភាពដដែល ។

- **ភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :

ក-ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ-ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីផ្ទេរឱ្យភតិកៈ ។

ក៏ប៉ុន្តែ បើមានការផ្ទេរបន្តនូវចលនវត្ថុដែលបានផ្ទេរពីមុនពីភតិបតីផដែល ការផ្ទេរបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :

ក-ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬមិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

ខ-ភតិកៈមាន ឬពុំមានជម្រើស ឬក្រោយមកទទួលយកជម្រើសថាទិញ ឬបន្តជួលចលនវត្ថុ មួយរយៈពេលបន្ថែមទៀត ។

- **ការបង់ថ្លៃឈ្នួលជាមុន** : សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិកៈ នៅពេល ឬមុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។

- **ប្រាក់ប្រាតិភោគ** : សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិកៈនិងត្រូវបានកាន់កាប់ដោយភតិបតី ដើម្បីធានាការពង្រឹងកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិសន្យាបើសិនជាវត្ថុ ដោយពេញលេញ និងទៀងទាត់ ។

- **អ្នកផ្គត់ផ្គង់** : សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលភតិបតីទទួលចលន-

វត្ថុដែលត្រូវជួលឱ្យភតិកៈ ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬឱ្យជួលរួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្តត់ផ្តង់ ។

- **កិច្ចព្រមព្រៀងផ្តត់ផ្តង់** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ ។

- **កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្តត់ផ្តង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់ ។

ជំពូកទី ២

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

មាត្រា ៥.-

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតីនិងភតិកៈ ហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសាក្សីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ ។

មាត្រា ៦.-

កិច្ចព្រមព្រៀងមួយដែលពេញលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែកិច្ចព្រមព្រៀងនោះ មានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម :

ក-ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ-ចំនួនប្រាក់ ការកំណត់ត្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ-កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ-ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

មាត្រា ៧.-

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចមានចែងអំពីប្រាក់ប្រាតិភោគ ឬការបង់ថ្លៃឈ្នួលជាមុន ឬទាំងពីរ ។ សម្រាប់ភតិកៈ ប្រាក់ប្រាតិភោគ អាច ឬ មិនអាចទទួលបានឡើយ

ចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬ អាចប្រើប្រាស់ ដោយភតិបតី ឬចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ក្នុងករណីដែលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនមានចែងអំពីការប្រើប្រាក់ប្រាតិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញនិងតាមពេលកំណត់ហើយ ។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលបានការប្រាក់ទេ ។ ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

មាត្រា ៨.-

បើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងថា ចលនវត្ថុត្រូវបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតី ឬ ជាកម្មវត្ថុនៃភតិសន្យាពីភតិបតី ស្លាកសម្គាល់ទាំងនោះមិនត្រូវដកចេញ ឬ ធ្វើឱ្យមើលមិនស្គាល់ ដោយជនណាម្នាក់ ក្រៅពីភតិបតី ឬ អ្នកតំណាងរបស់ភតិបតីនោះឡើយ ។

នៅពេលបានរកឃើញការខូចខាតណាមួយនៃស្លាកសម្គាល់ដែលបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬ បើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដូចដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត ។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រានេះឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្ទាស់ប្តូរស្លាកសម្គាល់នោះ ក្រោយពីភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ ។

មាត្រា ៩.-

បើភតិបតី និងភតិកៈព្រមព្រៀងគ្នាសងតាមវិធីមិនមែនសុបិយវត្ថុ ដូចជាផលិតផលសេវាកម្ម ការដោះដូរជាវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទម្រង់មិនមែនសុបិយវត្ថុនោះ ត្រូវ[illegible]ថ្លៃទីផ្សារ លើកលែងតែភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុរបស់ពួកគាត់ណាមួយផ្សេងពីនេះ ។

មាត្រា ១០.-

នៅក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិក:ទទួលយកការប្រើប្រាស់ចលនវត្ថុ ក្នុងរយៈពេលយ៉ាងតិចបំផុត ០១ (មួយ) ឆ្នាំ ។ នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងនោះ ភតិក:អាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុនោះ ។ ភតិបតីផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យភតិក:ប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ ។

ជំពូកទី ៣
សិទ្ធិ និងភាពកិច្ចរបស់ភតិបតី

មាត្រា ១១.-

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានជួល លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិក: ឬ ទៅឱ្យភាគីផ្សេងទៀត ។

មាត្រា ១២.-

ភតិបតីត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងភាពកិច្ចសារពើពន្ធផ្សេងៗទៀត តាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

មាត្រា ១៣.-

ភតិបតីត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិក:បានយល់ព្រមទទួលចលនវត្ថុនោះ ដោយគ្មានលក្ខខណ្ឌ ។

មាត្រា ១៤.-

ភតិបតីត្រូវធានាយ៉ាងណាឱ្យភតិក:បានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុ ដែលបានជួលដោយគ្មានការរំខាន នៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណាភតិក:អនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

មាត្រា ១៥.-

ភតិបតីមិនទទួលខុសត្រូវចំពោះភតិក:លើចលនវត្ថុឡើយ លើកលែងតែក្នុងករណីដែលភតិក:បាននទទួលរងការខាតបង់ ដោយសារការធ្វើអន្តរាគមន៍របស់ភតិបតី ក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ ។

មាត្រា ១៦.-

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីមិនទទួលខុសត្រូវសងការខូចខាត ដែលបង្កដល់តតិយជន ដោយសារចលនវត្ថុដែលខ្លួនបានជួលឡើយ ។

មាត្រា ១៧.-

ក្នុងករណីដែលភតិក:មិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីត្រូវមានសិទ្ធិបន្ថែមពីលើសិទ្ធិ ដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដូចតទៅ :

ក-ភតិបតីអាចទាមទារឱ្យភតិក:បង់ថ្លៃឈ្នួលដែលមិនទាន់បានសង រួមទាំងការប្រាក់ និងការខូចខាត

ខ-ភតិបតីក៏អាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលនាអនាគតបាន អាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងអាចទាមទារយកចលនវត្ថុដែលបានជួលមកវិញ បើមានករណីណាមួយ ដូចខាងក្រោម :

-ភតិក:មិនបានបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ក្នុងរយៈពេលពីរគ្រាជាបន្តបន្ទាប់

-ភតិក:បំពានខណាមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញ-វត្ថុ និងខកខានមិនបានដោះស្រាយបញ្ហា ក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីភតិបតី

-ភតិក:មានអ្នកធានាដែលគ្មានសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយភតិក:មិនបានរកអ្នកធានាជំនួសណាម្នាក់ ដែលភតិបតីអាចទទួលយកបាន ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ តាមការស្នើសុំឱ្យរកអ្នកធានាជំនួសជាលាយលក្ខណ៍អក្សរពី

-ភតិក:គ្មានសាធនភាព ក្សីយធន ត្រូវបានរំលាយ ឬទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

គ-ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបាន ឬ មិនត្រូវបានរំលាយ នៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច :

-ទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញ ដោយមិនចាំបាច់ប្តឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើង ដោយគ្មានអំពើហិង្សា និង

-ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបានរាប់ទាំងចំណាយបន្ថែម បណ្តាលមកពីកំហុសរបស់ភតិក:ផង ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះ អាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះ បណ្តាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាតដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិក:អនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរ-ញ្ញវត្ថុ ។

ឃ-បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំពីកាសម្រេចពីតុលាការឱ្យភតិក: ប្រគល់ចលនវត្ថុជួលនោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្តុតាងដែលបង្ហាញថា ភតិក:មិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែ ភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិក: បើនៅពេលក្រោយមកមានភស្តុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានជួលមកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

មាត្រា ១៨.-

ភតិបតីមានសិទ្ធិតម្រូវឱ្យភតិក:សងការខាតបង់ បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិក:លើចលនវត្ថុដែលបានជួល ។

មាត្រា ១៩.-

ភតិបតីអាចទាមទារឱ្យភតិក:ទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានជួលក្នុងអំឡុងពេលដែលភតិក:កាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈ

ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរំលាយមុនពេលកំណើយ រហូតដល់ពេលដែលចលនវត្ថុនោះ ត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។

ប្រសិនបើភតិក:ត្រូវទិញ និងបង់ថ្លៃធានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញធានារ៉ាប់រងនេះទេ ហើយភតិក:ត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ ។

មាត្រា ២០.-

ចលនវត្ថុដែលបានជួល មិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិក:ទេ ក្នុងន័យនេះ នៅពេលដែលភតិក:ក្ស័យធន ម្ចាស់បំណុលទាំងឡាយរបស់ភតិក: រួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិក: តាមសេចក្តីសម្រេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ ។

មាត្រា ២១.-

ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម្យ៉ាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិក: ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្ទាស់ប្តូរភាពជើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិក:យល់ព្រមមិនទាមទារកាត់កងការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ ។

មាត្រា ២២.-

ក្នុងករណី ភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀត មិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមាន តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះ

ជំពូកទី ៤

សិទ្ធិ និងកាតព្វកិច្ចរបស់ភតិក:

មាត្រា ២៣.-

ភតិក:មានកាតព្វកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានជួល បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្តត់ផ្តង់ ។ បើចលនវត្ថុដែលបានជួលមិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្តត់ផ្តង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ ភតិក:មានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារភ្នាមឱ្យអ្នកផ្តត់ផ្តង់ជួសជុលវិការៈនោះ ឬ វិលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិវិលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្តត់ផ្តង់ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្តត់ផ្តង់ប្រគល់ចលនវត្ថុ ស្របតាមកិច្ចព្រមព្រៀងផ្តត់ផ្តង់ តែមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខ្វះខាត ដោយសារការខកខានរបស់អ្នកផ្តត់ផ្តង់ឡើយ ។

មាត្រា ២៤.-

ការយល់ព្រមទទួលចលនវត្ថុ អាចជាឯកសារឬអាចតាមរយៈមធ្យោបាយផ្សេង។ ទៀត ផ្ទួចខាងក្រោម :

ក-ក្រោយពេលដែលភតិក:បានពិនិត្យចលនវត្ថុ ដែលត្រូវជួលនោះរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្រប តាមកិច្ចព្រមព្រៀងផ្តត់ផ្តង់ក៏ដោយ

ខ-ភតិក:មិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្តត់ផ្តង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្តត់ផ្តង់ទៅភតិបតី និងអ្នកផ្តត់ផ្តង់ ដើម្បីឱ្យអ្នកផ្តត់ផ្តង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលា ក្រោយពេលបានទទួលដំណឹងនោះ

ក-កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិក:ត្រូវបានចាត់ទុកថា

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈ ដែលមានរាយលម្អិតពីមូលហេតុច្បាស់លាស់ក្នុងរយៈពេលកំណត់ដប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីភតិកៈបានទទួលចលនវត្ថុនោះ ។

មាត្រា ២៥.-

តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិកៈ បានយល់ព្រមទទួលចលនវត្ថុជាផ្លូវការហើយ ។

មាត្រា ២៦.-

ភតិកៈ ត្រូវប្រើប្រាស់ចលនវត្ថុឱ្យ បានត្រឹមត្រូវ តាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់វិធាន និងបទបញ្ជាជាធរមាន និងតាមលក្ខណៈបច្ចេកទេស ។ ភតិកៈក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

មាត្រា ២៧.-

នៅជិណាក់កាលផុតរយៈពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិកៈត្រូវប្រគល់ចលនវត្ថុដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណៈអ្នចនើម លើកលែងតែការសឹករេចរឹលធម្មតា ។

មាត្រា ២៨.-

ភតិកៈ ត្រូវទទួលខុសត្រូវចំពោះការចាត់បង់ចលនវត្ថុ ដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ ។

មាត្រា ២៩.-

ភតិកៈមិនត្រូវដាក់ជាហ៊ីប៊ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុក ចលនវត្ថុដែលបានជួល ឬបង្កើតឱ្យមានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ ។

មាត្រា ៣០.-

ភតិក: មានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិ-សន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

មាត្រា ៣១.-

កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិក: ផងដែរ ប្រៀបដូចជាភតិក:ជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួល ហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិក: ។ ប៉ុន្តែអ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការៈមួយចំពោះភតិក:ផង និងភតិបតីផងនោះទេ ។

សិទ្ធិរបស់ភតិក: នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិក:បានយល់ព្រម ហើយមិនត្រូវបានប៉ះពាល់ ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិក:បានយល់ព្រមលើការកែប្រែនោះ ។

មាត្រា ៣២.-

ភតិក:មិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុ ដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី ត្រូវចាត់ទុកជាមោឃៈ និងត្រូវបានចាត់ទុកថា លើសច្បាប់នេះ និងច្បាប់ផ្សេងទៀត ។

ជំពូកទី ៥

អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ជា

មាត្រា ៣៣.-

ធនាគារជាតិនៃកម្ពុជា បំពេញតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថាន ភតិ-សន្យាហិរញ្ញវត្ថុ ដែលក្នុងតួនាទីនេះ ធនាគារជាតិនៃកម្ពុជា :

១-ចេញ លួរ ឬ ដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និង កំណត់នីតិវិធីនិងបែបបទនានាអំពីការចេញអាជ្ញាបណ្ណនេះ ។

២-ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់ច្បាស់ជា អាទិ៍ន្យវ :

ក-កម្រិតដើមទុនអប្បបរមា

ខ-អនុបាតប្រុងប្រយ័ត្នផ្សេង។

គ-ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសវិធានធន

ឃ-ប្រព័ន្ធគណនេយ្យ និងបទដ្ឋានដែលពាក់ព័ន្ធ ។

៣-ត្រួតពិនិត្យ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ ជាអចិន្ត្រៃយ៍លើឯកសារ និងតាម វិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ ដល់ទីកន្លែងនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

៤-អាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុង មាត្រា ៣៥ នៃច្បាប់នេះ ។

មាត្រា ៣៥.-

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការទាំងនេះក៏អាចអនុវត្តបានផងដែរ ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកប អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ ធនាគារ ក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ ។

ជំពូកទី ៦

ឧណ្ឌកម្ម

មាត្រា ៣៥.-

ប្រសិនបើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬ មិនបានធ្វើតាមការដាស់តឿន ឬ មិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចដាក់ទណ្ឌកម្មខាងវិន័យណាមួយអ្វីខាងក្រោមនេះ :

-ព្រមាន

-ស្តីបន្ទោស

-ហាមធ្វើប្រតិបត្តិការមួយចំនួន និងកំណត់ព្រំដែនសកម្មភាព

-ល្បួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកជឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-តម្រូវឱ្យលាឈប់ពីការងារជាស្ថាយប្រវត្តិចំពោះអ្នកជឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-ដាក់ឱ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់

-ដកហូតអាជ្ញាបណ្ណជាស្ថាពរ និងការដាក់ឱ្យជម្រះបញ្ជីជាបន្ទាន់ ។

ជំពូកទី ៧

អន្តរប្បញ្ញត្តិ

មាត្រា ៣៦.-

គ្រឹះស្ថានណាដែលកំពុងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានឥតិសម្បទា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ទៅអាជ្ញាធរអាណាព្យាបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ៣៧.-

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៣៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ជកររ

នរោត្តម សីហមុនី

៣រស.០៩០៦.៤៩០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ចាង ចាន់តូ

លេខ :៥៦៥ ច.ល

ថតចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ ២០០៩

នាយកនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនគេន

17/12

ខ. បទប្បញ្ញត្តិទាក់ទងនឹង
លក្ខខណ្ឌផ្តល់អាជ្ញាបណ្ណចំពោះ
គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធ៧-៩៧-១៤៧ ប្រ.ក

ប្រកាស
ស្តីពី
លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូក ១
អំពីដើមទុន

ប្រការ ១.-

ដើមទុនរបស់គ្រឹះស្ថានត្រូវបានកម្រិតដូចខាងក្រោម៖

១.១ *(ផុតរយៈពេលអនុវត្ត)*

១.២ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារ ជាពិសេស ប្រការ ៧ និង ប្រការ ៨។)*

១.៣ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)*

១.៤ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)*

១.៥ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)*

ប្រការ ២.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តម្កល់ធានាលើដើមទុន។)

ប្រការ ៣.-

ដើមទុនក្នុងលក្ខន្តិក:របស់គ្រឹះស្ថានអាចត្រូវសុំបង្កើន ឬបន្តយបាននៅក្រោមលក្ខខណ្ឌដែលត្រូវ៖

៣.១ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០*

ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

៣.២ ករណីបង្កើន៖ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២១០ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីសោហ៊ុយបង្កើនដើមទុនសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

រាល់ការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។

ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួន សូន្យក្បៀសសូន្យបីភាគរយ (0,0៣%) លើចំនួនប្រាក់ដែលសុំបង្កើន។

៣.៣ ករណីបន្ថយ៖ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារ។)*

ប្រការ ៤.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៧ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ។)

ប្រការ ៥.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

ជំពូក ២
អំពីអាជ្ញាបណ្ណប្រកបអាជីវកម្ម

ប្រការ ៦.-

(ឃ្លាទីមួយបានផុតរយៈពេលអនុវត្ត)។ អ្នកបង្កើតគ្រឹះស្ថានត្រូវបំពេញបែបបទជា ៣ ដំណាក់កាល៖

៦.១ ដំណាក់កាលទី១៖ ការផ្តល់ព័ត៌មាន និងណែនាំលក្ខខណ្ឌនៃសំណុំបែបបទ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណ*

ចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

៦.២ ដំណាក់កាលទី២៖ ការចេញលិខិតអនុញ្ញាតជាគោលការណ៍

៦.២.១ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវបានធនាគារជាតិនៃកម្ពុជាចេញឱ្យបន្ទាប់ពីការសិក្សាសំណុំបែបបទឃើញមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីបង្កលក្ខណៈឱ្យផ្ទេរដើមទុនមកធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំទីស្នាក់ការ និងរៀបចំដំណើរការដោយអនុលោមទៅតាមរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងនោះ។

៦.២.២ ក្នុងករណីដែលសាមីគ្រឹះស្ថានកំពុងផ្តើមបង្កើតមិនអាចដំណើរការបាននៅក្នុងកាលកំណត់នៃលិខិតអនុញ្ញាតជាគោលការណ៍នោះទេ ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ៥.០០០.០០០,០០ (ប្រាំលាន) រៀលក្នុងមួយថ្ងៃដែលយឺតយ៉ាវនៅក្នុងរយៈពេល ៣០ថ្ងៃ ហើយបើនៅតែអនុវត្តមិនបាន លិខិតអនុញ្ញាតជាគោលការណ៍នោះត្រូវទុកជាមោឃៈ។

៦.៣ ដំណាក់កាលទី៣៖ ការចេញអាជ្ញាបណ្ណប្រកបអាជីវកម្ម៖

៦.៣.១ អាជ្ញាបណ្ណនេះត្រូវបានចេញជាផ្លូវការឱ្យសាមីគ្រឹះស្ថាន បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថារាល់លក្ខខណ្ឌក្នុងលិខិតអនុញ្ញាតជាគោលការណ៍ និងសំណុំបែបបទត្រូវបានបំពេញសព្វគ្រប់ហើយ។

៦.៣.២ និង ៦.៣.៣ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)*

៦.៣.៤ អាជ្ញាបណ្ណប្រកបអាជីវកម្មអាចត្រូវបន្តឡើងវិញបានលុះណាតែសាមីគ្រឹះស្ថានបានដាក់មកនូវសំណុំបែបបទដែលនៅខ្វះ ឬដែលអស់តម្លៃប្រើការបាន ឬ/និងបានធ្វើនិយ័តកម្មលើភាពមិនប្រក្រតីទាំងអស់របស់ខ្លួន។ ក្នុងករណីបំពេញលក្ខខណ្ឌទាំងនេះមិនបាន ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០,០០ (មួយលាន) រៀលក្នុងមួយថ្ងៃ ដែលយឺតយ៉ាវដោយគិតបន្ទាប់ពីថ្ងៃសុពលភាពចុងក្រោយនៃអាជ្ញាបណ្ណប្រកបអាជីវកម្មដែលពាក់ព័ន្ធរហូតដល់ពេលណាអាចបន្តឱ្យបាន។

ប្រការ ៧.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ, ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ, ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ជំពូក ៣
អំពីប្រតិបត្តិការឥណទានិងភាគកម្ម

ប្រការ ៨.-

៨.១ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២២៦ ប្រ.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

៨.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនអាចផ្តល់ឥណទាន (រាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខាគ្រប់ប្រភេទ) ឱ្យទៅ៖

៨.២.១ ភាគទុនិក-សមាជិកក្រុមប្រឹក្សាភិបាល និងនាយកចាត់ការរបស់ខ្លួន *(ត្រូវបានជំនួសដោយ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងដោយប្រកាសលេខ ធ៧-០១-១៣៧ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។)*

៨.២.២ មុខសញ្ញាប្រើប្រាស់ ដើម្បីបង់ជម្រះភាគកម្មក្នុងការបង្កើតគ្រឹះស្ថានមួយ ឬច្រើនទៀត

៨.២.៣ មុខសញ្ញាប្រើប្រាស់ក្រៅប្រទេស

៨.២.៤ មុខសញ្ញាប្រើប្រាស់ក្នុងប្រទេស ប៉ុន្តែសំអាងលើទ្រព្យដាក់បញ្ចាំដែលនៅក្រៅប្រទេសឡើយ។

៨.៣ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៥-០៥៤ ប្រ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ស្តីពី គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន។)*

៨.៤ *(ត្រូវបានជំនួសដោយច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ត្រង់ជំពូកទី ១០ ភាគកម្មរបស់គ្រឹះស្ថានចំណុះច្បាប់នេះក្នុងដើមទុននៃក្រុមហ៊ុនពាណិជ្ជកម្ម ដទៃទៀត។)*

ជំពូក ៤
អំពីការកាន់កាប់អចលនទ្រព្យ

ប្រការ ៩ និង ១០.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៦ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី អចលនទ្រព្យរបស់ធនាគារ។)

ប្រការ ១១.-

រាល់បទប្បញ្ញត្តិ ឬបទបញ្ជាទាំងឡាយណាដែលផ្ទុយនឹងស្មារតីប្រកាសនេះ ជាពិសេសបទប្បញ្ញត្តិលេខ ធ៧-៩៤-០០១ បប៣ ចុះថ្ងៃទី០១-០១-១៩៩៤ ស្តីពី លក្ខខណ្ឌសម្រាប់ធនាគារពាណិជ្ជ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១២.-

អគ្គនាយកដ្ឋាន អធិការដ្ឋានផ្ទៃក្នុង ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា មានភារកិច្ចរៀងៗខ្លួនអនុវត្តយ៉ាងម៉ឺងម៉ាត់តាមប្រកាសនេះ។

ប្រការ ១៣.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧

ឧទ្ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជោ ម៉ែងឈាត**

ធ៧-០៨-១៩៣ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាបណ្ណ
ចំពោះគ្រឹះស្ថានធនាគារ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីអប្បបរមា និងលក្ខខណ្ឌសុំអាជ្ញាបណ្ណចំពោះគ្រឹស្ថានធនាគារ។ ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីសមត្ថភាពធ្វើប្រតិបត្តិការរបស់បុគ្គលស្នើសុំ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យបានស្របតាមការងារដ៏រលូននៃប្រព័ន្ធធនាគារ ដើម្បីផ្តល់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់សាធារណជន។ ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើប្រតិបត្តិការធនាគារ ដែលមិនត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះនឹងត្រូវបដិសេធជាលាយលក្ខណ៍អក្សរ។

ប្រការ ២.-

គ្រឹះស្ថានធនាគារត្រូវគ្រប់គ្រងដោយបុគ្គលយ៉ាងតិចចំនួនពីររូប ដែលមានភាពសុចរិត និងគុណវុឌ្ឍិ និងមានបទពិសោធន៍សមស្របលើប្រតិបត្តិការធនាគារ។

ប្រការ ៣.-

ភាគទុនិកមួយ ឬច្រើន ត្រូវមានភស្តុតាងបង្ហាញថាមានបទពិសោធន៍ក្នុងសកម្មភាពដែលគ្រឹះស្ថានធនាគារមានបំណងធ្វើប្រតិបត្តិការ។

ប្រការ ៤.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវមានបុគ្គលិកគ្រប់គ្រាន់ និងមានជំនាញសមស្រប។ ធនធានបច្ចេកទេសរួមទាំងប្រព័ន្ធព័ត៌មានត្រូវមានប្រសិទ្ធភាព និងអាចជឿជាក់បានជាពិសេសប្រព័ន្ធសុវត្ថិភាពនៃប្រតិបត្តិការជាមួយសាធារណជន។

ប្រការ ៥.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអាចឱ្យគ្រឹះស្ថានធនាគារ៖

- ធានាបានថា ប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំង នីតិវិធី ប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងការអនុវត្តធុរកិច្ច និងស្តង់ដារជាទូទៅ
- ធានាការប្រតិបត្តិតាមកម្រិតកំណត់ដែលបានដាក់ចេញចំពោះហានិភ័យ ជាពិសេសហានិភ័យសមភាគី ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់
- ធានាគុណភាពរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

ភាពបិតថេរផ្នែកហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារក្នុងរយៈពេលច្រើនឆ្នាំខាងមុខ ត្រូវបង្កើតឱ្យបានគ្រប់គ្រាន់តាមរយៈផែនការអាជីវកម្ម ការសិក្សាទីផ្សារ និងការសាកល្បងហិរញ្ញវត្ថុ (financial simulations) រួមទាំង ការធ្វើសេណារីយ៉ូសាកល្បង (stress scenarios) បើចាំបាច់។ ការសាកល្បងហិរញ្ញវត្ថុ ត្រូវមានសូចនាករ ដែលទទួលស្គាល់ជាទូទៅប្រើប្រាស់ក្នុងការវិភាគហិរញ្ញវត្ថុ និងបទដ្ឋានប្រុងប្រយ័ត្ន។

ប្រការ ៧.-

(ត្រូវបានជំនួសដោយ ប្រការ ៣ និង ប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៣ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេ មានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល)។

ក្នុងករណីធនាគារមេនៅបរទេសធ្លាក់ចំណាត់ថ្នាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា។

ចំពោះធនាគារពាណិជ្ជជាសាខាធនាគារបរទេសដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ដូចធនាគារដែលមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក។

ប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុត្តសម្ព័ន្ធធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល)។

ប្រការ ៨.-

(ត្រូវបានជំនួសដោយប្រការ ៥ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៥ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៦០.០០០.០០០.០០០ រៀល (ហុកសិបប៊ីលានរៀល)។

ប្រការ ៩.-

នីតិវិធីនិងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

ប្រការ ១០.-

(ត្រូវបានជំនួសដោយប្រការ ៨ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៨ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមា ដូចមានចែងក្នុងប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ៦ និងប្រការ ៧ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ក្នុងរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ ១១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៦-១១៧ ប្រ.ក

ប្រកាស
ស្តីពី
ដើមទុនចុះបញ្ជីអប្បបរមា
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ឡើងវិញនូវដើមទុនចុះបញ្ជីអប្បបរមា ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅពង្រឹងមូលដ្ឋានដើមទុនឱ្យកាន់តែរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៣.-

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេ មានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល)។

ក្នុងករណីធនាគារមេនៅបរទេសធ្លាក់ចំណាត់ថ្នាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា។

ចំពោះធនាគារពាណិជ្ជជាសាខាធនាគារបរទេសដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ដូចធនាគារដែលមានចែងក្នុងប្រការ ៤។

ប្រការ ៤.-

ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុត្តសម្ព័ន្ធធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល) ។

ប្រការ ៥.-

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៦០.០០០.០០០.០០០ រៀល (ហុកសិបប៊ីលានរៀល)។

ប្រការ ៦.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ១២០.០០០.០០០.០០០ រៀល (មួយរយម្ភៃប៊ីលានរៀល)។

ប្រការ ៧.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវមានដើមទុនអប្បបរមាស្មើនឹង ៦.០០០.០០០.០០០ រៀល (ប្រាំមួយ ប៊ីលានរៀល)។

ប្រការ ៨.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមា ដូចមានចែងក្នុងប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ៦ និងប្រការ ៧ នៃប្រកាសនេះ ក្នុងរយៈពេល ពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ ៩.-

ត្រូវបានចាត់ទុកជានិរាករណ៍៖

- ប្រការ ៤ នៃប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រការ ២ ចំណុច ៣ នៃប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង
- ប្រការ ៧ ប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាបណ្ណ ចំពោះគ្រឹះស្ថានធនាគារ។

ប្រការ ១០.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងអគ្គនាយកគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១១.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៦-០០៣ ស.រ.ច.ណ.ន

សារាចរណែនាំ
ស្តីពី
ការអនុវត្តប្រកាសស្តីពី
ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាកំណត់នីតិវិធីបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

១. ដើមទុនចុះបញ្ជីអប្បបរមា

១.១ ធនាគារពាណិជ្ជជាសាខាធនាគារបរទេស

ធនាគារពាណិជ្ជដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេសត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីរយប៊ីលានរៀល) ប្រសិនបើធនាគារមេមាន "ចំណាត់ថ្នាក់វិនិយោគ"។ សាខាធនាគារបរទេសផ្សេងទៀតដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល)។

"ចំណាត់ថ្នាក់វិនិយោគ" របស់ធនាគារមេត្រូវបានផ្តល់ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិយ៉ាងតិចចំនួនមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់ដូចជា៖ Moody's Investor Services, Standard & Poor's, Fitch ឬភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិផ្សេងទៀតដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។ "ចំណាត់ថ្នាក់វិនិយោគ" សំដៅលើចំណាត់ថ្នាក់ដែលស្មើ ឬខ្ពស់ជាង៖

- Baa3 របស់ Moody's Investor Services
- BBB- របស់ Standard & Poor's និង
- BBB- របស់ Fitch។

លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់ត្រូវមានសុពលភាព ១ ឆ្នាំ គិតមកដល់កាលបរិច្ឆេទរាយការណ៍មកធនាគារជាតិនៃកម្ពុជា។

១.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត

ចំពោះធនាគារពាណិជ្ជដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាបុត្តសម្ព័ន្ធធនាគារបរទេស ទោះបីធនាគារមេទទួលបានចំណាត់ថ្នាក់វិនិយោគ និង/ឬ កាន់កាប់ភាគហ៊ុន ១០០% ក៏ដោយ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល)។

ចំពោះធនាគារពាណិជ្ជ និងធនាគារឯកទេស ដែលត្រូវបានបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាដូចមានចែងក្នុងខ្លឹមសារនៃប្រកាសស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយមិនគិតពីចំណាត់ថ្នាក់វិនិយោគ។

២. រយៈពេលបង្កើនដើមទុន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមាតាមការកំណត់ ដូចខាងក្រោម៖

- ត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមា ឱ្យបានយ៉ាងតិចពាក់កណ្តាលនៃដើមទុន ដែលត្រូវបំពេញបន្ថែម យ៉ាងយូរបំផុតត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៧ និង
- ត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមាឱ្យបានគ្រប់ចំនួន យ៉ាងយូរបំផុតត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

៣. ឯកសារដែលត្រូវផ្តល់

សាខាធនាគារបរទេស និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត ត្រូវផ្តល់ឯកសារជូនធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេលមិនលើសពី៦ខែ បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើសារាចរណែនាំនេះ។

៣.១ សាខាធនាគារបរទេស ត្រូវផ្តល់ឯកសារដូចខាងក្រោម៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចអំពីការបង្កើនដើមទុនចុះបញ្ជីរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារមេ ឬបុគ្គលដែលបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលនៃធនាគារមេ
- លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់របស់ធនាគារមេ
- លិខិតធានារបស់ធនាគារមេក្នុងការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- លិខិតធានាអំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់ធនាគារមេ ក្នុងករណីចំណាត់ថ្នាក់របស់ធនាគារមេធ្លាក់ចុះក្រោមចំណាត់ថ្នាក់វិនិយោគ
- លិខិតបញ្ជាក់របស់ធនាគារមេដែលបញ្ជាក់អំពីការបញ្ជូនលិខិតធានាជូនអាជ្ញាធរត្រួតពិនិត្យរបស់ធនាគារមេ និង
- ផែនការនិងយុទ្ធសាស្ត្របង្កើនដើមទុនតាមដំណាក់កាលដែលអនុម័តដោយក្រុមប្រឹក្សាភិបាលនៃធនាគារមេ ឬដោយអ្នកដែលបានទទួលសិទ្ធិពីក្រុមប្រឹក្សាភិបាលនៃធនាគារមេ ដើម្បីបង្កើនដើមទុនស្របតាមការកំណត់នៃប្រកាសស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

សាខាធនាគារបរទេស ត្រូវផ្ញើលិខិតបញ្ជាក់អំពីចំណាត់ថ្នាក់វិនិយោគរបស់ធនាគារមេ ដែលនៅមានសុពលភាព និងមានការបញ្ជាក់ភាពត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់ក្នុងសប្តាហ៍ទីមួយនៃខែមករា និងខែកក្កដា រៀងរាល់ឆ្នាំ ឬតាមការចាំបាច់។ លើសពីនេះទៀត សាខាធនាគារបរទេសត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ប្រសិនបើភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិបន្ថយចំណាត់ថ្នាក់របស់ធនាគារមេ។

ធនាគារមេត្រូវមានលិខិតធានាអំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមាក្នុងករណីចំណាត់ថ្នាក់របស់ធនាគារមេធ្លាក់ចុះក្រោមចំណាត់ថ្នាក់វិនិយោគ។ លិខិតធានាបង្កើនដើមទុននេះ ត្រូវមានចែងពីការផ្តល់ដើមទុនបន្ថែមនៅក្នុងរយៈពេល ១០ (ដប់) ថ្ងៃធ្វើការ និងត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើនដើមទុនរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារមេ។ សំណុំឯកសារបង្កើនដើមទុនត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃផ្ទេរដើមទុន។ ធនាគារមេត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីកាតព្វកិច្ចធានាបង្កើនដើមទុនខាងលើ ទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម។

៣.២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត ត្រូវផ្តល់ឯកសារដូចខាងក្រោម៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ភាគទុនិក អំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា
- លិខិតធានាពីភាគទុនិកមានឥទ្ធិពល អំពីការបង្កើនដើមទុនចុះបញ្ជីអប្បបរមា និង
- ផែនការនិងយុទ្ធសាស្ត្របង្កើនដើមទុនតាមដំណាក់កាល ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីបង្កើនដើមទុនចុះបញ្ជីអប្បបរមា ស្របតាមការកំណត់នៃប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៤. វិធានការផ្សេងទៀត

ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនមានលទ្ធភាពបំពេញតាមខ្លឹមសារនៃប្រកាសស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានត្រូវជ្រើសរើសយកដំណោះស្រាយណាមួយ ដូចខាងក្រោម៖

- ការស្វែងរកវិនិយោគិនថ្មីដែលមានសក្តានុពល
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាមួយគ្រឹះស្ថានដទៃទៀត
- ការផ្លាស់ប្តូររូបភាពគតិយុត្តរបស់គ្រឹះស្ថាន
- ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបំពេញសំណុំឯកសារពាក់ព័ន្ធនឹងដំណោះស្រាយដែលបានជ្រើសរើស ជូនធនាគារជាតិនៃកម្ពុជា។

៥. ប្រសិទ្ធភាពអនុវត្ត

សារាចរណែនាំលេខ ធ៧-០១០-០០១ ស.រ.ណ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ ស្តីពី ការកំណត់ចំណាត់ថ្នាក់វិនិយោគ ត្រូវចាត់ទុកជានិរាករណ៍។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១-១៣៦ ប្រ.ក

ប្រកាស
ស្តីពី
ប្រាក់តម្កល់ធានាលើដើមទុន

ប្រការ ១.-

កំណត់ប្រាក់តម្កល់ធានាលើដើមទុនដែលត្រូវដាក់ផ្ញើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន ១០ ភាគរយ នៃដើមទុន។

ប្រការ ២.- *(ផុតរយៈពេលអនុវត្ត)*

ប្រការ ៣.-

(ដើមទុនចុះបញ្ជីអប្បបរមារបស់ធនាគារពាណិជ្ជត្រូវបានជំនួសដោយប្រការ ៣ និង ប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៤.-

ប្រាក់តម្កល់ធានាលើដើមទុនអាចអនុវត្តជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក។ បន្ទាប់ពីបានបង់ប្រាក់តម្កល់ធានាលើដើមទុន ធនាគារសាមីមិនអាចផ្លាស់ប្តូរការជ្រើសរើសនេះបានទេ។ អត្រាប្តូរប្រាក់ប្រើប្រាស់សម្រាប់ការគណនាប្រាក់តម្កល់ធានាលើដើមទុននេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដែលមូលនិធិត្រូវបានចុះឥណទានគណនីតម្កល់ធានានៅធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

ប្រាក់តម្កល់ធានាលើដើមទុនជាប្រាក់រៀល ទទួលបានកម្រៃការប្រាក់មួយភាគពីរនៃអត្រាការប្រាក់បុនហិរញ្ញប្បទានក្នុងរយៈពេល ៦ ខែម្តងជាធរមាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកម្រៃការប្រាក់តាមអត្រា ៣/៨ នៃ SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយៈពេល ៦ ខែម្តង។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងទៅធនាគារទាំងអស់ពីអត្រាការប្រាក់ដែលបានអនុវត្តសម្រាប់កាលកំណត់នីមួយៗ។ *(អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណ ត្រូវបានជំនួសដោយប្រការ ៣ នៃប្រកាសលេខ ធ៥-០៩-០១១ ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក។)*

ប្រការ ៦.-

ប្រាក់តម្កល់ធានាលើដើមទុនត្រូវបានសងត្រឡប់ទៅវិញតែក្នុងករណីមានការជម្រះបញ្ជីធនាគារ និងស្របតាមលំដាប់អាទិភាពដែលមានចែងនៅមាត្រា ៦៥ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ប្រការ ៧.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០០-០៥ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ធនាគារពាណិជ្ជ តទៅនេះហៅថាធនាគារ ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ។

ប្រការ ២.-

អ្នកដាក់ពាក្យសុំអាជ្ញាបណ្ណធនាគារត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយ ក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៣.-

(ត្រូវបានជំនួសដោយប្រការ ៣ និងប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៣ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេមានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល)។

ក្នុងករណីធនាគារមេនៅបរទេសធ្លាក់ចំណាត់ថ្នាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា។

ចំពោះធនាគារពាណិជ្ជជាសាខាធនាគារបរទេសដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ដូចធនាគារដែលមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក។

ប្រការ ៤ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុគ្គលសម្ព័ន្ធធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល)។

ជំពូកទី ២
នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

ប្រការ ៤.-

ពាក្យសុំអាជ្ញាបណ្ណ[9] ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបទប្បញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ៖

ក. នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ. អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាក្នុងករណីជាក្រុមហ៊ុនបរទេស

គ. រូបភាពគតិយុត្តនិងលក្ខន្តិក: ឬឯកសារបង្កើតផ្សេងៗទៀត

ឃ. ប្រភេទមូលបត្រតំណាងឱ្យដើមទុន និងចំណាងទាក់ទងរវាងការកាន់កាប់មូលបត្រទាំងនោះ និងការអនុវត្តសិទ្ធិបោះឆ្នោត

ង. ចំនួនដើមទុនដែលមានស្រាប់ ឬដើមទុនដែលបានគ្រោង ឬចំនួនដើមទុនដែលត្រូវបង់ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស។ ចំនួននេះយ៉ាងតិចបំផុតត្រូវស្មើនឹងចំនួនដើមទុនដែលមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ

ច. ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ. ភាគទុនិកដែលកាន់កាប់ ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះ ត្រូវផ្តល់ព័ត៌មាន ដូចមានរៀបរាប់ក្នុងប្រការ ៥ នៃប្រកាសនេះ

ជ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារ។ អ្នកចាត់ការដែលបានទទួលការតែងតាំងហើយខាងលើនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់នៅប្រការ ៦ នៃប្រកាសនេះ ហើយផ្តល់នូវលិខិតថ្កោលទោសមួយច្បាប់។ ចំពោះអ្នកចាត់ការជាជនបរទេសដែលមានលំនៅដ្ឋាននៅកម្ពុជាតិចជាងបីឆ្នាំ (៣ឆ្នាំ) លិខិតថ្កោលទោសនេះត្រូវជំនួសដោយឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមរបស់ខ្លួនដោយមានបញ្ជាក់ថាជនដែលមានពាក់ព័ន្ធមិនត្រូវបានហាមឃាត់មិនឱ្យចាត់ចែងការងារក្នុងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយតាមខ្លឹមសារនៃបទប្បញ្ញត្តិរបស់ប្រទេសនោះទេ។ អ្នកចាត់ការសាខាធនាគារបរទេសនៅកម្ពុជា ត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចនៅទីស្នាក់ការកណ្តាល។

កំណត់សម្គាល់៖

[9] ត្រូវធ្វើជូននូវលិខិតស្នើសម្រាប់សុំអាជ្ញាបណ្ណ (មាត្រា ១៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) សម្រាប់ប្រតិវេទន៍ (មាត្រា ២៣) ឬសម្រាប់អនុញ្ញាត (មាត្រា ២៤) ស្របតាមគំរូលិខិតដែលមានក្នុងឧបសម្ព័ន្ធទី១។

ឈ. អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើ ត្រូវមានជីវប្រវត្តិ និងត្រូវឆ្លើយសំណួរដូចមានក្នុងឧបសម្ព័ន្ធទី៤ ព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថាគ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ) ហើយមានបញ្ជាក់ក្នុងជីវប្រវត្តិរបស់សមាជិកនោះ។

ញ. ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ។

ដ. ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ៖

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និងលក្ខខណ្ឌចម្បងៗ ផលកម្រៃដែលទទួលបានប្រចាំឆ្នាំ និងទឹកប្រាក់មិនទាន់សង)
- ប្រភេទនិងទំហំនៃសេវាផ្សេងទៀតដែលផ្តល់ឱ្យអតិថិជន (គណនីសន្សំ ការផ្តល់មធ្យោបាយទូទាត់ ការគ្រប់គ្រងទ្រព្យសកម្មជាដើម)
- ប្រភេទអតិថិជន (ឯកជន ឯកត្តជន ក្រុមហ៊ុន អង្គការអន្តរជាតិ វិនិយោគិនជាស្ថាប័ន) ដែលធនាគារមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក៖ មូលនិធិផ្ទាល់ បុរេប្រទានរបស់ភាគទុនិក មូលបត្រឥណទេយ្យដែលអាចជួញដូរបាន ប្រាក់បញ្ញើពីសាធារណជនទូទៅ ប្រាក់កម្ចីលើទីផ្សារអន្តរធនាគារជាដើម
- ចំនួនប៉ាន់ស្មាននៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្សដោយរាយលម្អិតតាមប្រភេទបុគ្គលិក
- ការចាត់តាំងនិងធនធានដែលបានគ្រោងទុក ពិសេសចំពោះការទាក់ទងអតិថិជន (ការបង្កើតសាខា) និងចំពោះទម្រង់ការគណនេយ្យនិងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីចំណេញ-ខាតសម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ។ ត្រូវព្យាករណ៍កម្រិតអនុបាតប្រុងប្រយ័ត្នចម្បងៗ (ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យ បីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឋ. ការត្រួតពិនិត្យផ្ទៃក្នុង៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- របៀបកំណត់កម្រិតផ្ទៃក្នុងទៅលើប្រភេទហានិភ័យ និងទម្រង់ការផ្សេងៗសម្រាប់ធានាការអនុវត្តឱ្យបានត្រឹមត្រូវ
- នីតិវិធីដែលបានគ្រោងទុកសម្រាប់ធានាការអនុវត្តឱ្យបានត្រឹមត្រូវតាមសីលធម៌វិជ្ជាជីវៈពិសេសចំពោះប្រតិបត្តិការហិរញ្ញវត្ថុជាមួយអតិថិជន និងសម្រាប់រួមចំណែកក្នុងការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់
- សមាសភាពនិងភារកិច្ចរបស់គណៈកម្មការត្រួតពិនិត្យបញ្ជី

ឧ. ការត្រួតពិនិត្យពីខាងក្រៅ

- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលត្រូវបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ

ឈ. ការត្រួតពិនិត្យរបស់ទីស្នាក់ការកណ្តាលឬក្រុមហ៊ុនដើម (សម្រាប់សាខាធនាគារបរទេស ឬ បុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស)

- ពិពណ៌នាពីទម្រង់ការសម្រាប់ការត្រួតពិនិត្យសាខាឬបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនដើម
- ពិពណ៌នាពីការត្រួតពិនិត្យសាខាឬបុត្តសម្ព័ន្ធបរទេសរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម។

ប្រការ ៥.-

ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យសុំត្រូវផ្តល់ព័ត៌មានដូចតទៅ៖

ក. អត្តសញ្ញាណរបស់ភាគទុនិក៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិក:។ ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវធានាថាសមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ។ សម្រាប់គោលបំណងទាំងអស់នេះ បុគ្គលពាក់ព័ន្ធម្នាក់ៗត្រូវបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី៥

ខ. បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លម្អិតពីការសម្របសម្រួលខាងគតិយុត្តិនិងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលបត្រ។ បើភាគទុនិកជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់ពីប្រភពដើមនៃដើមទុនវិនិយោគ។ បង្ហាញថាតើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែក ដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ. បញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ភាគទុនិក។ បើចាំបាច់ ត្រូវរៀបរាប់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនដើមនិងរបស់ក្រុមហ៊ុនហូលឌីងជាកណ្តាល (Intermediation holding companies) បង្ហាញនូវសមាមាត្រភាគហ៊ុននិងសិទ្ធិបោះឆ្នោត។ ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចាត់ការធំៗនៃអ្នកចូលហ៊ុន

ឃ. រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះ រួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគទុនិកមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថាតើក្រុមណាដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ។ បើមានត្រូវរៀបរាប់ឱ្យអស់

ង. ប្រាប់ថាតើភាគទុនិកនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ។បើមានត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណាឬអាជ្ញាធរណា

ច. បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិក

ឆ. បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកបានទទួលរងនូវការស៊ើបអង្កេត ឬទទួលរងនូវការពិន័យជាសម្ភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬតុលាការនៅកម្ពុជា ឬនៅបរទេសឬទេ។ ត្រូវរៀបរាប់ថា តើមានបានទទួលទណ្ឌកម្មណាមួយ ដោយសារការស៊ើបអង្កេត ឬទម្រង់ការឬទេ។ បញ្ជាក់ដែរថា តើភាគទុនិកជាកម្មវត្ថុ ឬអាចជាកម្មវត្ថុនៃទម្រង់ការរដ្ឋបាលយុត្តិធម៌ ឬជាមិត្តភាព នៅកម្ពុជាឬនៅបរទេសដែលអាចមានឥទ្ធិពលខាងសម្ភារៈទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកនេះឬទេ

ជ. ប្រាប់ពីគោលដៅរបស់ភាគទុនិក ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែលបានដាក់ពាក្យសុំអាជ្ញាបណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ឈ. បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកនិងអ្នកដាក់ពាក្យសុំឬទេ ហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ញ. បញ្ជាក់ថាតើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត

ដ. ផ្តល់គណនីនានារបស់ភាគទុនិកឬក្រុមហ៊ុនដើមរបស់ខ្លួន សម្រាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ ព្រមទាំងធ្វើការព្យាករណ៍សម្រាប់ឆ្នាំនេះ (រួមមានទាំងព័ត៌មានច្របាច់បញ្ចូលគ្នាផង បើចាំបាច់)។ បើភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

ប្រការ ៦.-

បុគ្គលម្នាក់ក្នុងចំណោមពីររូប (២រូប) ដែលត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រង ដូចជាការទទួលខុសត្រូវក្នុងការដឹកនាំអាជីវកម្មធនាគារឱ្យមានប្រសិទ្ធភាព ត្រូវផ្តល់ព័ត៌មានដូចខាងក្រោម

នេះ[២] ដោយបំពេញជីវប្រវត្តិ និងសំណួរដូចមានក្នុងឧបសម្ព័ន្ធទី៤

ក. អត្តសញ្ញាណរបស់នាយកចាត់ការ៖

- នាម និងគោត្តនាម
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ
- អាសយដ្ឋានផ្ទាល់ខ្លួន (ត្រូវមានទីកន្លែងស្នាក់នៅក្រោយពេលបានទទួលការតែងតាំង បើមានការផ្លាស់ប្តូរ។ នាយកចាត់ការត្រូវមានកន្លែងស្នាក់នៅជិតកន្លែងសំខាន់សម្រាប់ធ្វើអាជីវកម្ម ដូចជានៅក្នុងប្រទេសកម្ពុជា)

ខ. គុណវុឌ្ឍិ និងបទពិសោធន៍៖

- សញ្ញាបត្រ ក៏ដូចជាថ្ងៃខែឆ្នាំនិងកន្លែងទទួលសញ្ញាបត្រ
- មុខតំណែងដែលបានកាន់កាប់ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ចុងក្រោយ ដោយមានឈ្មោះ ទីកន្លែង និងសកម្មភាពរបស់និយោជក ប្រភេទបទពិសោធន៍ទទួលបាន និងកម្រិតទទួលខុសត្រូវ។

គ. បញ្ជាក់ថា តើក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន នាយកចាត់ការនឹងចូលរួមសហការ ឬមានការព្រមព្រៀងជាមួយគ្រឹះស្ថានជាឯកត្តជនឬជានីតិបុគ្គលមួយផ្សេងទៀតក្រៅពីអ្នកដាក់ពាក្យសុំឬទេ។ ក្នុងករណីណាមួយ ក៏ត្រូវផ្តល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ។

ឃ. រៀបរាប់ពីភារកិច្ចគ្រប់គ្រង ដែលនាយកចាត់ការទទួលខុសត្រូវដោយផ្ទាល់។

ង. បញ្ជាក់ថា តើនាយកចាត់ការនៅជាឬធ្លាប់បានធ្វើជាភាគទុនិកសំខាន់ (ដូចជាបានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតដប់ភាគរយ (១០%) នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត) នៃក្រុមហ៊ុនណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំឬទេ។ ប្រសិនបើមានត្រូវប្រាប់ឈ្មោះនិងសកម្មភាពរបស់ក្រុមហ៊ុនចំនួនប្រាក់ និងភាគហ៊ុនរបស់ខ្លួន ឬផលប្រយោជន៍ក្នុងក្រុមហ៊ុននោះ។

ច. ប្រាប់តាមការយល់ដឹងរបស់ខ្លួនថា តើក្រុមហ៊ុនណាខ្លះដែលខ្លួនបានកាន់កាប់តំណែងជាអ្នកទទួលខុសត្រូវឬក្នុងក្រុមហ៊ុនណាដែលខ្លួនជាភាគទុនិកសំខាន់ ឬដែលខ្លួនមានទំនាក់ទំនងអាជីវកម្មសំខាន់ជាមួយអ្នកស្នើសុំ។

ឆ. បញ្ជាក់ថា តើនៅកម្ពុជា ឬនៅបរទេស ខ្លួនធ្លាប់បានទទួលរងនូវទណ្ឌកម្មតាមនីតិវិធីវិជ្ជាជីវៈរដ្ឋបាល ឬតុលាការឬទេ។ ត្រូវរាយលម្អិតនូវព័ត៌មានទាំងអស់ឱ្យបានសមស្រប។

[២] ចំពោះការតែងតាំងនាយកចាត់ការ ធនាគារជាតិនៃកម្ពុជាត្រូវមានរាល់ព័ត៌មានទាំងអស់ដើម្បីអាចវាយតម្លៃពីកិត្តិនាម ភាពត្រឹមត្រូវ និងភាពថ្លៃថ្នូររបស់បុគ្គលដែលពាក់ព័ន្ធ។

ជ. បញ្ជាក់ថា តើខ្លួនធ្លាប់បានទទួលរងនូវវិន័យ ឬការបណ្តេញពីនិយោជកណាមួយដែរឬទេ។ បើមាន ត្រូវរាយលម្អិតនូវព័ត៌មានដែលពាក់ព័ន្ធទាំងអស់។

ឈ. បញ្ជាក់ថា តើខ្លួនជាអ្នកផ្តល់ដើមទុនទៅឱ្យអ្នកស្នើសុំឬទេ ហើយតើខ្លួនមានបំណងអនុវត្តដោយផ្ទាល់ឬតាមរយៈអន្តរការី នូវសកម្មភាពប្រតិបត្តិការឯកត្តជនឬវិជ្ជាជីវៈជាមួយអ្នកស្នើសុំឬទេ។

ញ. ផ្តល់ព័ត៌មានបន្ថែមទាំងអស់ដែលអាចជួយបំភ្លឺដល់ធនាគារជាតិនៃកម្ពុជា។

ដ. រាល់ចម្លើយទាំងអស់ដែលទាក់ទងទៅនឹងសំណួរខាងលើ ត្រូវធ្វើជូនតាមរយៈជីវប្រវត្តិ និងសំណួរក្នុងឧបសម្ព័ន្ធទី៤ និងលិខិតស្របតាមគំរូលិខិតដូចមានក្នុងឧបសម្ព័ន្ធទី២។

ប្រការ ៧.-

ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬប្រយោល យ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកមានឥទ្ធិពល ស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវធ្វើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា។

បទបញ្ជានេះអាចត្រូវដកចេញវិញបានតែនៅពេលមានការបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា។

ជំពូកទី ៣
ការអនុម័តផ្តល់អាជ្ញាបណ្ណ និង ការយកកម្រៃ

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួន ក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាបណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោយៈលើកលែងតែមានការស្នើសុំពន្យារពេល និងការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៩.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២០៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ។)

ប្រការ ៩ ថ្មី ចែងដូចខាងក្រោម៖

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាបណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារពាណិជ្ជដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១០.-

(ត្រូវបានជំនួសដោយប្រការ ៦ ចំណុច ១-ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ១១.-

គ្រឹះស្ថានត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន មួយលានរៀល (១.០០០.០០០ រៀល) នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ចំពោះគ្រឹះស្ថានដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាបណ្ណ គ្រឹះស្ថានដែលពាក់ព័ន្ធត្រូវទទួលរងនូវការជាកពិន័យដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់ សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាបណ្ណនេះបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀតរហូតដល់ត្រូវដកហូតអាជ្ញាបណ្ណ។

(សោហ៊ុយអាជ្ញាបណ្ណត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ជំពូកទី ៤
បទប្បញ្ញត្តិផ្សេងៗ

ប្រការ ១២.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តម្កល់ធានាលើដើមទុន។)

ប្រការ ១៣ និង ១៤.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៧ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ។)

ប្រការ ១៥.-

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីរូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឱ្យមានប្រសិទ្ធភាព) ត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះ ទៅធនាគារជាតិនៃកម្ពុជា៖

- អ្នកចាត់ការថ្មីត្រូវធ្វើលិខិតស្របតាមគំរូដូចមានក្នុងឧបសម្ព័ន្ធទី២ ផ្តល់ព័ត៌មានជូនទេសាភិបាលធនាគារជាតិនៃកម្ពុជាពីការតែងតាំងខ្លួនជាអ្នកចាត់ការ ហើយដោយមានបញ្ជាក់ពីមុខដំណែងរបស់ខ្លួនផង
- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)
- ព័ត៌មានដូចមានចែងនៅក្នុងប្រការ ៦ នៃប្រកាសនេះ
- ឯកសារទាំងអស់នេះត្រូវតែផ្តល់ឱ្យយ៉ាងហោចណាស់មួយខែ មុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង។

ប្រការ ១៦.-

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្ត ឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនីមួយៗត្រូវមានភ្ជាប់នូវព័ត៌មានដូចតទៅ៖

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព៖ ត្រូវផ្តល់ព័ត៌មានដែលមានកំណត់ក្នុងកថាខណ្ឌ ដ ប្រការ ៤ នៃប្រកាសនេះ
- ការបន្ថយដើមទុន៖ ពិពណ៌នាពីខ្លឹមសារនិងលក្ខខណ្ឌដូចជាការសម្របសម្រួលខាងគតិយុត្តិ និងខាងគណនេយ្យ ព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្មទៅអនាគត និងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិក:និងព័ត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីវកម្ម៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិក:
- រាល់ការផ្លាស់ប្តូរទាំងអស់ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងតិចបំផុតបីខែ (៣ខែ) មុនពេលអនុវត្តដើម្បីសុំការយល់ព្រម

ធនាគារត្រូវបង់សោហ៊ុយចំនួន មួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិក: ដែលរងវិសោធនកម្ម។ *(ការបង់សោហ៊ុយចំពោះការធ្វើវិសោធនកម្មលក្ខន្តិក:ត្រូវបានជំនួសដោយ ប្រការ ៨ ចំណុច ក នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួន មួយភាគរយ (១%) លើចំនួនដែលបន្ថយ។

ប្រការ ១៧.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធទី១

គំរូលិខិតស្នើសុំអាជ្ញាបណ្ណ (១) ធ្វើប្រតិវេទន៍ (២) សុំការអនុញ្ញាត (៣) ដែលត្រូវផ្ញើជូន ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ឯកឧត្តមជាទីគោរព

ក្នុងនាមជា ..... (៤)

ខ្ញុំសូមដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បី៖

- ទទួលបន្តអាជ្ញាបណ្ណរបស់ (ឈ្មោះក្រុមហ៊ុន) ដូចមាននៅក្នុងជំពូកទី IV នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ធ្វើប្រតិវេទន៍ពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មអនុប្បទានភាគទុនដូចមានក្នុងមាត្រាទី ២៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- សុំការអនុញ្ញាតធ្វើលទ្ធកម្ម ឬអនុប្បទានភាគទុន ដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជាទីបញ្ចប់ ខ្ញុំសូមភ្ជាប់មកជាមួយនូវពាក្យសុំស្របតាមបញ្ញត្តិនៃប្រកាសលេខ .....

សូមឯកឧត្តមទេសាភិបាលទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ហត្ថលេខា

---

(១) ក្នុងករណីស្នើសុំអាជ្ញាបណ្ណ ឬសុំបន្តអាជ្ញាបណ្ណ

(២) ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

(៣) ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្តីពី គ្រឹស្ថានធនាគារនិងហិរញ្ញវត្ថុ

(៤) ផ្តល់គំរូហត្ថលេខារបស់ប្រធាន (Chairman) នាយកចាត់ការ មន្ត្រីដទៃទៀតដែលជាភ្នាក់ងារបានទទួលសិទ្ធិអំណាច (ភ្ជាប់ឯកសារភស្តុតាងមកជាមួយផង)។

គំរូលិខិត
ផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ឯកឧត្តមជាទីគោរព

យោងតាមការតែងតាំងនាយកធនាគារ (ឈ្មោះធនាគារ) ដែលខ្ញុំនឹងចូលកាន់តំណែង ជា (.....) ខ្ញុំសូមភ្ជាប់មកជាមួយនូវព័ត៌មាន (រួមមានប្រវត្តិសង្ខេបនិងសំណួរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ៤) តាមប្រការទី៦ នៃ ប្រកាសលេខ ..... តម្រូវឱ្យមាន។

ខ្ញុំសូមធានាថាព័ត៌មានទាំងនេះពិតជាត្រឹមត្រូវ និងពេញលេញឆ្លើយតបទៅនឹងតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេស ខ្ញុំសូមធានាអះអាងថា ខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងមាត្រា ១៨ នៃច្បាប់ស្តីអំពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ្ញុំសូមសន្យាថានឹងផ្តល់ព័ត៌មានស្តីពីការប្រែប្រួលណាមួយដែលទាក់ទងទៅនឹងព័ត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកគ្រឹះស្ថានធនាគារ ខ្ញុំសូមធានាថានឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មាន ដែលទាក់ទងទៅនឹងការចាត់តាំងរដ្ឋបាល និងគណនេយ្យស្ថានភាពហិរញ្ញវត្ថុ ជាពិសេស ចំពោះគុណភាពនៃឥណទាន និងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់។

សូមឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ហត្ថលេខា

ឧបសម្ព័ន្ធទី៣

គំរូលិខិត
របស់ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលលើស
ចំនួន ២0% ច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ
ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ឯកឧត្តមទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីហាន:) ខ្ញុំសូមភ្ជាប់មកជាមួយនូវព័ត៌មានទាំងឡាយតាមសំណើរបស់ធនាគារជាតិនៃកម្ពុជាសុំ (តាមប្រកាសលេខ.....) ទាក់ទងទៅនឹងការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិក) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ)។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មានទាំងនេះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ហើយថាតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ព័ត៌មានយ៉ាងឆាប់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលខុសប្លែកយ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនហើយ។

ខ្ញុំបានកត់សម្គាល់ទៅលើបទប្បញ្ញត្តិប្រការ ៧ នៃប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះធនាគារជាតិនៃកម្ពុជាអាចបង្គាប់ឱ្យភាគទុនិកមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

សូមឯកឧត្តមទេសាភិបាលមេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ហត្ថលេខា

ឧបសម្ព័ន្ធទី៤

Photo 4×6

ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី ឯកត្តជន ឬ ជនដែលបម្រុងក្លាយទៅជា គណៈនាយក តាគទុនិក នាយកចាត់ការ របស់ធនាគារពាណិជ្ជ

CURRICULUM VITAE

and

Questionnaire for individual who are or are proposing to become

Directors, Shareholders, Managers of a Commercial Bank

1. គោត្តនាម

   Family name

---

2. នាមខ្លួន

   Given name (s)

---

3. ឈ្មោះហៅក្រៅ

   Other name (s) by which you are or have been known.

4-1. សូមរៀបរាប់បំពេញលើគំរូនេះនូវនីតិសម្បទារបស់លោក ឧទាហរណ៍ដូចជា គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក ភាគទុនិក ឬនាយកចាត់ការ ឬបុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

Please state in what capacity you are completing this form, i.e. as a current or prospective director, shareholder or manager or any combination of these.

4-2. សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងហាន: តួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

4-3. ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្ហាត់បង្ហាញរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

4-4. សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការរិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---

5. អាសយដ្ឋានផ្ទាល់ខ្លួន

Your private address

---

6. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីអំឡុង ៥ឆ្នាំមុន

Your previous private address(es) during the last 5 years.

---

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date (day/month/year) and place of birth (including district, town or city)

---

8. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ សញ្ជាតូបនីយកម្ម ការរៀបអាពាហ៍ពិពាហ៍)?

Your nationality and how it was acquired (birth, naturalization, marriage).

---

9. ឈ្មោះ និងអាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល ៥ឆ្នាំ កន្លងមក

Name(s) and address(es) of your bankers within the last 5 years.

---

10. ចូរបញ្ជាក់ពី កម្រិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years**, including the name and address of the employer in each case, the nature of the business, the position held and relevant dates.

11-2. សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

11-3. សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

---

12. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

---

13. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយ ព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

---

14. តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

---

15. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

---

16. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើសនៅប្រទេសណា តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

---

17. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

---

18. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលម្អិតស្តីពី ទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

---

19. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

---

20. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ 4-1. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិតឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

ចូរកត់សម្គាល់ឱ្យបានច្បាស់ថា៖ រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4-1.? The omission of material facts may represent the provision of misleading information (see declaration below).

N.B. (note well) the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។

ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពីរឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

DECLARATION

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ

Name: _____

មុខងារនិងឋានៈដែលទទួលបន្ទុក

Position held: _____

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

Signed: _____ Date: ..... /..... /.....

ធ៧-០០-០៥ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ធនាគារឯកទេសឥណទានជនបទ តទៅនេះហៅថាធនាគារឯកទេស ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ អនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ។

ប្រការ ២.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាបណ្ណ ត្រូវធ្វើតែប្រតិបត្តិការណាដែលមានបញ្ជាក់ច្បាស់តាមខ្លឹមសារនៃលិខិតអនុញ្ញាត។

ប្រការ ៣.-

អ្នកដាក់ពាក្យសុំអាជ្ញាបណ្ណសម្រាប់ធនាគារឯកទេស ត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៤.-

(ដើមទុនចុះបញ្ជីអប្បបរមារបស់ធនាគារឯកទេស ត្រូវបានកែសម្រួលដោយប្រការ ៥ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៥ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះ បានចែងដូចខាងក្រោម៖

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ស្មើនឹង ៦០.០០០.០០០.០០០ រៀល (ហុកសិបប៊ីលានរៀល) ។

នីតិវិធីនិងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

គ្រឹះស្ថានធនាគារដែលមានអាជ្ញាបណ្ណ ឬទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

(ការបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមា ត្រូវគោរពតាមប្រការ ៨ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៨ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានមានចែងដូចខាងក្រោម៖

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ៦ និងប្រការ ៧ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ក្នុងរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជំពូកទី ២
នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

ប្រការ ៥.-

ពាក្យសុំអាជ្ញាបណ្ណ ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ៖

ក- នាម ឬនាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិក: ឬឯកសារបង្កើតផ្សេងៗទៀត

ឃ- ប្រភេទមូលបត្រតំណាងឱ្យដើមទុន។ ចំណាងទាក់ទងរវាងការកាន់កាប់មូលបត្រទាំងនោះនិងការអនុវត្តសិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនផ្ទាល់ដែលបានអនុញ្ញាតនិងដែលបានបង់

ច- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ- ភាគទុនិកដែលកាន់កាប់ ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ព័ត៌មាន ដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារឯកទេស។ អ្នកចាត់ការដែលត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចត្រូវបំពេញជីវប្រវត្តិ និងសំណួរដូចមានក្នុងឧបសម្ព័ន្ធទី២ ហើយត្រូវផ្តល់នូវលិខិតថ្កោលទោស

ឈ- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល និងដោយបន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ)

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណគឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ

ដ- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ៖

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការ និងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និងលក្ខខណ្ឌចម្បងៗ ផលកម្រៃដែលទទួលបានប្រចាំឆ្នាំ និងទឹកប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលធនាគារឯកទេសមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក៖ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុលបន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចី ជាដើម ហើយបើចាំបាច់ ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើត និងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ (បំណុលបន្ទាប់បន្សំជាដើម)
- ចំនួនប្រហាក់ប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្ស ដោយរាយលម្អិតតាមប្រភេទបុគ្គលិក
- ទីតាំងសាខាដែលមានស្រាប់ឬដែលគ្រោងឱ្យមាន
- ការចាត់តាំងនិងធនធានដែលបានគ្រោងទុក ពិសេស ចំពោះទម្រង់ការគណនេយ្យ និងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញសម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ។ ត្រូវព្យាករណ៍កម្រិតអនុបាតប្រុងប្រយ័ត្នចម្បងៗ (ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ប- ការត្រួតពិនិត្យផ្ទៃក្នុង៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ។

ប្រការ ៦.-

ភាគទុនិកដែលកាន់កាប់ ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកស្នើសុំ ត្រូវផ្តល់ព័ត៌មានដូចតទៅ៖

ក- អត្តសញ្ញាណរបស់ភាគទុនិក៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិក:។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លម្អិតពីការសម្របសម្រួលខាងគតិយុត្តនិងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលបត្រ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថាតើភាគទុនិកមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថាតើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ។ បើមានត្រូវរៀបរាប់ឱ្យអស់

ឃ- ប្រាប់ថា តើភាគទុនិកនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ។ បើមានត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណាឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិក

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសម្ភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬតុលាការឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិក ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែលបានដាក់ពាក្យសុំអាជ្ញាបណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកនិងអ្នកស្នើសុំឬទេ ហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ- បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត។

ប្រការ ៧.-

ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវផ្ញើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា។

បទបញ្ជានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា អាចលើកលែងជាលាយលក្ខណ៍អក្សរ អនុញ្ញាតឱ្យរួចផុតពីការអនុវត្តមាត្រា ៧ នៅពេលអនុម័តលើអាជ្ញាបណ្ណ។

ជំពូកទី ៣
ការអនុម័តផ្តល់អាជ្ញាបណ្ណ និង ការយកកម្រៃ

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាបណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌនិងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតនេះត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេលនិងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៩.-

(ត្រូវបានកែសម្រួលដោយប្រកាស ធ៧-០៦-២០៨ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេស។)

ប្រការ ៩ ថ្មី ចែងដូចខាងក្រោម៖

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាបណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារឯកទេសដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១០.-

(ត្រូវបានជំនួសដោយប្រការ ៦ ចំណុច ១-ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ១១.-

ធនាគារឯកទេសត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួនដប់លានរៀល (១០.០០០.០០០ រៀល) ចំពោះទីស្នាក់ការកណ្តាល និងប្រាំបីលានរៀល (៨.០០០.០០០ រៀល) ចំពោះសាខានីមួយៗរបស់ធនាគារឯកទេសនៅមុន ថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ចំពោះធនាគារដែលបានបង្កើតឡើងក្នុងឆ្នាំសោហ៊ុយអាជ្ញាបណ្ណត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាបណ្ណ ធនាគារដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យ ដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់ តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាបណ្ណបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀត រហូតដល់ត្រូវដកហូតអាជ្ញាបណ្ណ។

(សោហ៊ុយអាជ្ញាបណ្ណត្រូវបានជំនួសដោយ ប្រការ ៤ ចំណុច ៣ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

ជំពូកទី ៤
បទបញ្ជាប្រុងប្រយ័ត្ន

ប្រការ ១២.-

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណដែលពុំធ្លាប់ធ្វើប្រតិបត្តិការ ត្រូវបង់បង្គ្រប់ឱ្យពេញមួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ។

ប្រការ ១៣.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២០៨ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេស។)

ប្រការ ១៣ ថ្មី ចែងដូចខាងក្រោម៖

ធនាគារឯកទេស ដែលបានទទួលអាជ្ញាបណ្ណហើយ ត្រូវរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ (៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកម្រៃការប្រាក់ ដូចខាងក្រោម៖

ក. ប្រាក់តម្កល់ធានាលើដើមទុនជាប្រាក់រៀល ទទួលបានកម្រៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២) នៃអត្រាការប្រាក់បុនហិរញ្ញប្បទាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយៈពេល ៦ ខែម្តង។

ខ. ប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកម្រៃការប្រាក់បីភាគប្រាំបី (៣/៨) នៃអត្រា SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយៈពេល ៦ ខែម្តង។ ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងទៅធនាគារទាំងអស់ពីអត្រាការប្រាក់ ដែលបានអនុវត្តសម្រាប់កាលកំណត់នីមួយៗ។

(អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណ ត្រូវបានជំនួសដោយ ប្រការ ៣ នៃប្រកាសលេខ ធ៥-០៩-០១១ ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុន ជារូបិយប័ណ្ណដុល្លារអាមេរិក។)

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តម្កល់ធានាលើដើមទុននេះ នៅពេលធនាគារឯកទេសនោះត្រូវបានជម្រះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម។

ប្រការ ១៤.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាបណ្ណហើយត្រូវតម្កល់ទុនបម្រុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ ទុនបម្រុងកាតព្វកិច្ចនេះ ត្រូវបានរក្សាទុកតាមលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ជាដោយឡែកស្តីពីទុនបម្រុងកាតព្វកិច្ច។

ប្រការ ១៥.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាបណ្ណរួចហើយត្រូវអនុវត្តឱ្យបានសមស្របតាមបញ្ញត្តិទាំងអស់ដែលធនាគារត្រូវអនុវត្ត ពិសេសតម្រូវការនៃការធ្វើរបាយការណ៍។

ជំពូកទី ៥

បទប្បញ្ញត្តិផ្សេងៗ

ប្រការ ១៦ និង ១៧.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៧ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ។)

ប្រការ ១៨.-

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឱ្យមានប្រសិទ្ធភាព) ត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះទៅធនាគារជាតិនៃកម្ពុជា៖

- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)
- ជីវប្រវត្តិនិងការបំពេញសំណួរក្នុងឧបសម្ព័ន្ធទី២

ឯកសារទាំងអស់នេះ ត្រូវតែផ្តល់ឱ្យយ៉ាងហោចណាស់មួយខែមុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង។

ប្រការ ១៩.-

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវ

ការរៀបរាប់ពីមូលហេតុនៃផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនីមួយៗ ត្រូវមានភ្ជាប់នូវព័ត៌មានដូចតទៅ៖

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព៖ ត្រូវផ្តល់ព័ត៌មានដែលមានកំណត់ក្នុងកថាខណ្ឌ ដ ប្រការ ៥ នៃប្រកាសនេះ
- ការបន្តយដើមទុន៖ ការពិពណ៌នាពីខ្លឹមសារនិងលក្ខខណ្ឌ ដូចជា ការសម្របសម្រួលខាងគតិយុត្ត និងខាងគណនេយ្យ ព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្មទៅអនាគតនិងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិក:និងព័ត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីវកម្ម៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិក:

រាល់ការផ្លាស់ប្តូរទាំងអស់ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលអនុវត្ត ដើម្បីសុំការយល់ព្រម។

ធនាគារត្រូវបង់សោហ៊ុយចំនួន មួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិក:ដែលរងវិសោធនកម្ម។ *(ការបង់សោហ៊ុយចំពោះការធ្វើវិសោធនកម្មលក្ខន្តិក:ត្រូវបានកែសម្រួលដោយប្រការ ៨ ចំណុច ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)*

ធនាគារត្រូវបង់សោហ៊ុយបន្តយដើមទុនចំនួនមួយភាគរយ (១%) លើចំនួនដែលបន្តយ។

ប្រការ ២០.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារឯកទេសនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២២.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ង៉ា ចាន់តូ**

គំរូលិខិត
របស់ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលទាំង ចំនួន ២0% ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ឯកឧត្តមអគ្គទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវព័ត៌មានទាំងឡាយតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា (តាមលិខិតលេខ.....) ទាក់ទងដល់ការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិក) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ)។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មាននេះគ្រប់គ្រាន់និងត្រឹមត្រូវ ហើយតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាផ្តល់ព័ត៌មានយ៉ាងឆាប់រហ័សជូនធនាគារជាតិនៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលធ្វើឱ្យប្លែកយ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនរួចមកហើយ។

ខ្ញុំបានធ្វើការកត់សម្គាល់ទៅលើបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចស្នើឱ្យភាគទុនិកដែលមានឥទ្ធិពលរបស់គ្រឹះស្ថាន ផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

ដោយសេចក្តីគោរព

ហត្ថលេខា

ឧបសម្ព័ន្ធទី២

Photo

4×6

ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី
ឯកត្តជន ឬជនដែលបម្រុងក្លាយទៅជា
គណៈនាយក ភាគទុនិក នាយកចាត់ការ របស់ធនាគារឯកទេស

CURRICULUM VITAE

and

Questionnaire for individual who are, or are proposing to become

Directors, Shareholders, Managers of a Specialized Bank

1. គោត្តនាម

Family name

---

2. នាមខ្លួន

Given name (s)

---

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

4-1. សូមរៀបរាប់បំពេញលើគំរូនេះនូវនីតិសម្បទារបស់លោក ឧទាហរណ៍ដូចជា គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក ភាគទុនិក ឬ នាយកចាត់ការ ឬ បុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

Please state in what capacity you are completing this form, i.e. as a current or prospective director, shareholder or manager or any combination of these.

4-2. សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងហាន: តួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

4-3. ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្ហាត់បង្ហាញរបស់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយ សូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

4-4. សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការរិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---

5. អាសយដ្ឋានផ្ទាល់ខ្លួន

Your private address

---

6. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីអំឡុង ៥ឆ្នាំមុន

Your previous private address(es) during the last 5 years.

---

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

---

8. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ សញ្ជាតូបនីយកម្ម ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

---

9. ឈ្មោះ និងអាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

Name(s) and address(es) of your bankers within the last 5 years.

---

10. ចូរបញ្ជាក់ពី កម្រិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years**, including the name and address of the employer in each case, the nature of the business, the position held and relevant dates.

11-2.សូមរៀបរាប់កាលពី១០ឆ្នាំមុនបើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមាន សូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះនិងចំនួនភាគហ៊ុនព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

11-3. សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

---

12. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងហាន:ជានាយក ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

---

13. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

---

14. តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

---

15. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណាតើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

---

16. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើសនៅប្រទេសណា តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយឬសមាជិកណាម្នាក់ដែរឬទេ បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

---

17. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

---

18. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលម្អិតស្តីពី ទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

---

19. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

---

20. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ 4-1. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យ ពិចារណា ឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិត ឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

ចូរកត់សម្គាល់ឱ្យបានច្បាស់ថា៖ រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4-1.? The omission of material facts may represent the provision of misleading information (see declaration below).

N.B. (note well) the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។

ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវនិងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពីរឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

DECLARATION

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ

Name: _____

មុខងារនិងឋានៈដែលទទួលបន្ទុក

Position held: _____

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

Signed: _____ Date: ..... /..... /.....

ធ៧-០៧-១៦៣ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

ផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

គ្រឹះស្ថានដែលមានបំណងសុំអាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជន ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

១- មានអាជ្ញាបណ្ណប្រកបអាជីវកម្មមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជាយ៉ាងតិចចំនួនបីឆ្នាំ

២- មានស្ថានភាពហិរញ្ញវត្ថុល្អនិងការដឹកនាំរឹងមាំតាមរយៈការធ្វើចំណាត់ថ្នាក់ផ្ទៃក្នុងដោយធនាគារជាតិនៃកម្ពុជា ត្រឹមកម្រិតសុវត្ថិភាព ចាប់ពី ២ ឆ្នាំឡើងទៅ មុនថ្ងៃដាក់ពាក្យស្នើសុំ

៣- មានដើមទុនបង់ជម្រះអប្បបរមាស្មើនឹង ១០ ពាន់លានរៀល *(ត្រូវបានជំនួសដោយប្រការ ៦ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

ប្រការ ៦ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ១២០.០០០.០០០.០០០ រៀល (មួយរយម្ភៃប៊ីលានរៀល) ។

៤- មានប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ប្រកបដោយប្រសិទ្ធភាព

៥- អនុវត្តតាមប្លង់គណនីឯកភាពរបស់ធនាគារជាតិនៃកម្ពុជា

៦- មានចំណេញដោយស្ថិរភាពយ៉ាងតិចពីរឆ្នាំជាបន្តបន្ទាប់ពីសកម្មភាពប្រតិបត្តិការចម្បងរបស់ខ្លួន។

ប្រការ ៣.-

បន្ទាប់ពីបានទទួលអាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានត្រូវតែគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១- គ្រឹះស្ថានអាចទទួលប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់តែប៉ុណ្ណោះ ហើយចំនួនប្រាក់បញ្ញើពីអតិថិជនម្នាក់មិនឱ្យលើសពី ៣% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ

២- គ្រឹះស្ថានមិនអាចផ្តល់ឥណទានទៅអតិថិជនម្នាក់លើសពី ២% និងទៅក្រុមអតិថិជនជាសម្ព័ន្ធញាតិ លើសពី ៣% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ

៣- គ្រឹះស្ថានត្រូវរក្សាគ្រប់ពេលនូវអនុបាតសាធនភាពមិនឱ្យទាបជាង ១៥% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន

៤- គ្រឹះស្ថានត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត ៥០% *(ត្រូវបានជំនួសដោយប្រការ ៥ នៃប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព។)*

៥- គ្រឹះស្ថានត្រូវរក្សាជាអចិន្ត្រៃយ៍ប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង ១០% នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា

៦- គ្រឹះស្ថានត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន ៨% នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានដែលមានបំណងទទួលប្រាក់បញ្ញើពីអតិថិជន ត្រូវដាក់ពាក្យសុំមកធនាគារជាតិនៃកម្ពុជាដើម្បីទទួលបានអាជ្ញាបណ្ណដោយឡែកមួយទៀតបន្ថែមពីលើអាជ្ញាបណ្ណដែលមានស្រាប់សម្រាប់ទទួលប្រាក់បញ្ញើពីសាធារណជន។ ធនាគារជាតិនៃកម្ពុជានឹងផ្អែកលើលក្ខណៈសម្បត្តិដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះដើម្បីវិនិច្ឆ័យផ្តល់អាជ្ញាបណ្ណសម្រាប់ទទួលប្រាក់បញ្ញើពីសាធារណជន។ អាជ្ញាបណ្ណទទួលប្រាក់បញ្ញើត្រូវព្យួរបង្ហាញសាធារណជនគ្រប់ពេលជាមួយអាជ្ញាបណ្ណដែលមានស្រាប់។

ប្រការ ៥.-

គ្រឹះស្ថានណាដែលគ្មានអាជ្ញាបណ្ណទទួលប្រាក់បញ្ញើ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុផ្សេងទៀតមិនអាចទទួលប្រាក់បញ្ញើពីសាធារណជនបានទេ។

ប្រការ ៦.-

គ្រឹះស្ថាននិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

ប្រការ ២ នៃប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឃ្លាទី២ដែលមានខ្លឹមសារអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់សេវាសញ្ច័យ ត្រូវចាត់ទុកជានិរាករណ៍ ចំពោះខ្លឹមសារផ្សេងទៀតក្នុងប្រការ ២ នេះនៅមានសុពលភាពដដែល។

ប្រការ ៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០០-០៦ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ធនាគារជាតិនៃកម្ពុជាផ្តល់អាជ្ញាបណ្ណសម្រាប់ធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តទៅនេះហៅថាគ្រឹះស្ថាន ដែលបំពេញបានតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះ។ អង្គការក្រៅរដ្ឋាភិបាល សមាគម អង្គភាពឬគ្រឹះស្ថានទាំងឡាយណាដែលមិនអាចបំពេញបានតាមលក្ខខណ្ឌសម្រាប់ការផ្តល់អាជ្ញាបណ្ណ ហើយនៅតែចូលរួមផ្តល់សេវាឥណទានជាឯកត្តជនឬជាក្រុមសាមគ្គី ត្រូវចុះឈ្មោះក្នុងបញ្ជីនៅធនាគារជាតិនៃកម្ពុជា។ *(ខ្លឹមសារឃ្លាទី២ ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ។)*

ប្រការ ២.-

គ្រឹះស្ថានដែលបានទទួលអាជ្ញាបណ្ណត្រូវធ្វើតែប្រតិបត្តិការធនាគារ ដូចមានកំណត់ក្នុងមាត្រា ២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សេវាឥណទាននិងសញ្ញ័យត្រូវបានអនុញ្ញាតឱ្យធ្វើប្រសិនបើមិនមានការហាមឃាត់ដោយប្រកាសនេះ ឬដោយខ្លឹមសារនៃលិខិតអនុញ្ញាតឱ្យបង្កើតគ្រឹះស្ថាន។ *(ឃ្លាទី២ដែលមានខ្លឹមសារអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់សេវាសញ្ញ័យ ត្រូវបានវិភាករណ៍ដោយប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)*

រាល់គ្រឹះស្ថាន អង្គការក្រៅរដ្ឋាភិបាល សមាគម ទោះបានទទួលអាជ្ញាបណ្ណ ឬបានចុះបញ្ជីហើយក្តី មិនត្រូវបានអនុញ្ញាតឱ្យ៖

ក- ផ្តល់ឥណទានភតិសន្យា ធ្វើប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivatives) និងសេដ្ឋពាណិជ្ជដល់ដៃ ឬមានកាលកំណត់លើលោហធាតុមានតម្លៃ ទំនិញត្បូងថ្មមានតម្លៃ វត្ថុធាតុដើម។

ខ- ផ្តល់សេវាទូទាត់តាមរយៈគណនីមូលប្បទានបត្រ (Checking accounts) ឬធ្វើប្រតិបត្តិការ swap ឬ មានកាលកំណត់ជារូបិយប័ណ្ណបរទេស។

ប្រការ ៣.-

អ្នកដាក់ពាក្យសុំអាជ្ញាបណ្ណសម្រាប់គ្រឹះស្ថានត្រូវចុះបញ្ជីជាក្រុមហ៊ុនភាគហ៊ុនឬជាសហករណ៍។

ប្រការ ៤.-

(ត្រូវបានជំនួសដោយប្រការ ៧ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ស្តីពី ដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៧ នៃប្រកាសលេខ ធ៧-០១៦-១១៧ ប្រ.ក នេះបានចែងដូចខាងក្រោម៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវមានដើមទុនអប្បបរមាស្មើនឹង ៦.០០០.០០០.០០០ រៀល (ប្រាំមួយ ប៊ីលានរៀល)។

ជំពូកទី ២
នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

ប្រការ ៥.-

ពាក្យសុំអាជ្ញាបណ្ណត្រូវស្នើដោយបុគ្គលដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬ ជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ៖

ក- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិក: ឬឯកសារបង្កើតផ្សេងៗទៀត

ឃ- ប្រភេទមូលបត្រតំណាងឱ្យដើមទុន និងចំណាងទាក់ទងរវាងការកាន់កាប់មូលបត្រទាំងនោះ និងការអនុវត្តសិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនដែលបានអនុញ្ញាត ឬចំនួនដើមទុនដែលបានបង់

ច- ការបែងចែកភាគហ៊ុននិងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់គ្រឹះស្ថាន

ឆ- ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ព័ត៌មាន ដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថាន

ឈ- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិនិងរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណគឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនី សម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ

ដ- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ៖

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុង ឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀត ដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់ គោលបំណង ខ្លឹមសារ និងលក្ខខណ្ឌចម្បងៗ ផលកម្រៃដែលទទួលបានប្រចាំឆ្នាំ និងទឹកប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលគ្រឹះស្ថានមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក៖ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុលបន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីជាដើម ហើយបើចាំបាច់ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើតនិងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ (បំណុលបន្ទាប់បន្សំជាដើម)
- ចំនួនប្រហាក់ប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្សដោយរាយលម្អិតតាមប្រភេទបុគ្គលិក
- ទីតាំងនៃសាខាដែលមានហើយឬក៏សាខាដែលបម្រុងបង្កើត
- ការចាត់តាំងនិងធនធានដែលបានគ្រោងទុក ពិសេសចំពោះទម្រង់ការគណនេយ្យនិងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញ សម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ។ ត្រូវព្យាករណ៍កម្រិតអនុបាតប្រុងប្រយ័ត្នចម្បងៗ (ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ប- ទម្រង់ការនៃការត្រួតពិនិត្យ៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៥៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ។

ប្រការ ៦.-

ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យសុំត្រូវផ្តល់ព័ត៌មានដូចតទៅ៖

ក- អត្តសញ្ញាណរបស់ភាគទុនិក៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិក:។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លម្អិតពីការសម្របសម្រួលខាងគតិយុត្តិនិងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលបត្រ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិក មានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ។ បើមាន ត្រូវរៀបរាប់ឱ្យអស់

ឃ- ប្រាប់ថា តើភាគទុនិកនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ។ បើមានត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណាឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងខាងក្រៅរបស់ភាគទុនិក

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកបានទទួលរងនូវការស៊ើបអង្កេត ឬទទួលរងនូវការពិន័យជាសម្ភារៈតាមទម្រង់ការវិជ្ជាជីវៈរដ្ឋបាលឬ តុលាការឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងគ្រឹះស្ថាន ដែលបានដាក់ពាក្យសុំអាជ្ញាបណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកនិងអ្នកដាក់ពាក្យសុំឬទេ ហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ- បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត។

ប្រការ ៧.-

ភាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ភាគទុនិកមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនោះ ត្រូវផ្ញើលិខិត ដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី១ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា។

បទបញ្ជានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា ។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចលើកលែងជាលាយលក្ខណ៍អក្សរអនុញ្ញាតឱ្យរួចផុតពីការអនុវត្តមាត្រា ៧ នៅពេលអនុម័តលើអាជ្ញាបណ្ណ។

ជំពូកទី ៣
ការអនុម័តផ្តល់អាជ្ញាបណ្ណ និង ការយកកម្រៃ

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការសម្រេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាបណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌនិងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេលនិងមានការយល់ព្រមពីធនាគារគារជាតិនៃកម្ពុជា។

ប្រការ ៩.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

ប្រការ ៩ ថ្មី ចែងដូចខាងក្រោម៖

ធនាគារជាតិនៃកម្ពុជាផ្តល់អាជ្ញាបណ្ណមិនមានកំណត់រយៈពេលសុពលភាព ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១០.-

(ត្រូវបានជំនួសដោយប្រការ ៦ ចំណុច ២-ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ១១.-

គ្រឹះស្ថានត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន មួយលានរៀល (១.០០០.០០០ រៀល) នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ចំពោះគ្រឹះស្ថានដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាបណ្ណ គ្រឹះស្ថានដែលពាក់ព័ន្ធត្រូវទទួលរងនូវការដាកពិន័យ ដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់ សាមសិបថ្ងៃ (៣០ថ្ងៃ)។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាបណ្ណបាន គ្រឹះស្ថានសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀតរហូតដល់ត្រូវដកហូតអាជ្ញាបណ្ណ។

(សោហ៊ុយអាជ្ញាបណ្ណត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ជំពូកទី ៤
បទបញ្ជាប្រុងប្រយ័ត្ន

ប្រការ ១២.-

ចំពោះគ្រឹះស្ថានបង្កើតថ្មី អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបង់មួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិក:ក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ។

ប្រការ ១៣.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

ប្រការ ១៣ ថ្មី ចែងដូចខាងក្រោម៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាបណ្ណហើយត្រូវរក្សាប្រាក់តម្កល់ធានាលើដើមទុន ស្មើនឹង ប្រាំភាគរយ (៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកម្រៃការប្រាក់ ដូចខាងក្រោម៖

ក. ប្រាក់តម្កល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកម្រៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២) នៃអត្រាការប្រាក់បុនហិរញ្ញប្បទានដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ ក្នុងរយៈពេល៦ខែម្តង។

ខ. ប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេសទទួលបានកម្រៃការប្រាក់ បីភាគប្រាំបី (៣/៨) នៃអត្រា SIBOR (Sigapore Inter-Bank Offered Rate) ក្នុងរយៈពេល៦ខែម្តង។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងទៅគ្រឹះស្ថានទាំងអស់ពីអត្រាការប្រាក់ ដែលបានអនុវត្តសម្រាប់កាលកំណត់នីមួយៗ។

(អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណ ត្រូវបានជំនួសដោយប្រការ ៣ នៃប្រកាសលេខ ធ៥-០៩-០១១ ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុន ជារូបិយប័ណ្ណដុល្លារអាមេរិក។)

ធនាគារជាតិនៃកម្ពុជានឹងទូទាត់សងប្រាក់តម្កល់ធានាលើដើមទុននេះនៅពេលគ្រឹះស្ថាននោះត្រូវបានជម្រះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម។

ប្រការ ១៤.-

គ្រឹះស្ថានដែលបានទទួលអាជ្ញាបណ្ណហើយ ត្រូវតម្កល់ទុនបម្រុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើ ដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ ទុនបម្រុងកាតព្វកិច្ចនេះត្រូវបានរក្សាទុកតាមលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ជាដោយឡែកស្តីពីទុនបម្រុងកាតព្វកិច្ច។

ប្រការ ១៥.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៧-១៣៣ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។)

ប្រការ ១៦.-

គ្រឹះស្ថានត្រូវរក្សាអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចត្រឹមស្មើមួយរយភាគរយ (១០០%)។ អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចតទៅ៖

ភាគយក៖ សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ចំនួនទឹកប្រាក់ជំពាក់នៅធនាគារជាតិនិងធនាគារផ្សេង (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ចំណែកទឹកប្រាក់ឱ្យខ្ចីដែលមិនលើសពីប្រតិបត្តិការមួយខែ (លើកលែងតែឥណទានចំពោះអតិថិជនដោយគ្មានកំណត់កាលវិសាន)

ភាគបែង៖ អត្រាភាគរយនៃប្រាក់បញ្ញើមានកាលកំណត់ដែលត្រូវសងក្នុងខែបន្ទាប់ + អត្រាភាគរយនៃគណនីចរន្តនិងអត្រាភាគរយនៃគណនីប្រាក់សន្សំ។ អត្រាភាគរយទាំងនេះត្រូវបានកំណត់តាមប្រកាសដោយឡែក។

ប្រការ ១៧.-

គ្រឹះស្ថានដែលបានទទួលអាជ្ញាបណ្ណហើយត្រូវអនុវត្តឱ្យសមស្របតាមបញ្ញត្តិទាក់ទងជាមួយចំណាត់ថ្នាក់ប្រភេទឥណទាន និងកម្រិតសំវិធានធនសម្រាប់ការបាត់បង់។

ប្រការ ១៨.-

កម្រិតឥណទានចំពោះអ្នកខ្ចីឯកត្តជនម្នាក់ឬអ្នកខ្ចីមួយក្រុមដែលរួមបង្កើតជាអ្នកទទួលផលតែមួយ ដោយសារមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ត្រូវកំណត់មិនឱ្យលើសពីដប់ភាគរយ (១០%) នៃមូលនិធិផ្ទាល់របស់គ្រឹះស្ថានឡើយ។

ជំពូកទី ៥
បទប្បញ្ញត្តិផ្សេងៗ

ប្រការ ១៩.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២០.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថាននៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២១.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

គំរូលិខិត
របស់តាគទុនិកដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលលើស
ចំនួន២0% ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ
ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ឯកឧត្តមអគ្គទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋាន:) ខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវព័ត៌មានទាំងឡាយ តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា (តាមលិខិតលេខ.....) ទាក់ទងដល់ការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិក) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ)។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មាននេះគ្រប់គ្រាន់និងត្រឹមត្រូវហើយតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាទៀតទេ។

ខ្ញុំសូមសន្យាផ្តល់ព័ត៌មានយ៉ាងឆាប់រហ័សជូនធនាគារជាតិនៃកម្ពុជា នូវរាល់ការប្រែប្រួលណាដែលធ្វើឱ្យប្លែកយ៉ាងខ្លាំងពីព័ត៌មានដែលបានផ្តល់ជូនរួចមកហើយ។

ខ្ញុំបានធ្វើការកត់សម្គាល់ទៅលើបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចស្នើឱ្យភាគទុនិកដែលមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ។

ដោយសេចក្តីគោរព

ហត្ថលេខា

ឧបសម្ព័ន្ធទី២

Photo

4×6

ជីវប្រវត្តិ និង ការសាកសួរទុកជាព័ត៌មាន អំពី ឯកត្តជន ឬជនដែលបម្រុងក្លាយទៅជា នាយកចាត់ការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

CURRICULUM VITAE

and

Questionnaire for individual who are, or are proposing to become

Managers of a Microfinance Institution

1. គោត្តនាម

Family name

---

2. នាមខ្លួន

Given name(s)

---

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

4-1. សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈតួនាទីទាំងនេះ។

Please describe the particular duties and responsibilities attaching to the position(s).

4-2. សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យអ្នកដាក់ពាក្យសុំអាជ្ញាបណ្ណ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការរិជ្ជាជីវៈជាមួយអ្នកដាក់ពាក្យសុំនោះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

4-3. ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្ហាត់បង្ហាញរបស់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយ សូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

4-4. សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការរិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---

5. អាសយដ្ឋានផ្ទាល់ខ្លួន

Your private address

---

6. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីអំឡុង ៥ឆ្នាំមុន

Your previous private address(es) during the last 5 years.

---

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

---

8. សញ្ជាតិ ហើយតើស្មារតីនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ សញ្ជាតូបនីយកម្ម ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

---

9. ឈ្មោះនិងអាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

Name(s) and address(es) of your bankers within the last 5 years.

---

10. ចូរបញ្ជាក់ពី កម្រិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years**, including the name and address of the employer in each case, the nature of the business, the position held and relevant dates.

11-2. សូមរៀបរាប់កាលពី១០ឆ្នាំមុនបើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

11-3. សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

---

12. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

---

13. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួនធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

---

14. តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

---

15. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

---

16. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើសនៅប្រទេសណា តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

---

17. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

---

18. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលម្អិតស្តីពី ទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

---

19. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

---

20. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ 4-1. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធដោយបង្វែរព័ត៌មានពិត ឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

ចូរកត់សម្គាល់ឱ្យបានច្បាស់ថា៖ រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4-1.? The omission of material facts may represent the provision of misleading information (see declaration below).

N.B. (note well) the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។

ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវនិងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

DECLARATION

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ

Name: _____

មុខងារនិងឋានៈដែលទទួលបន្ទុក

Position held: _____

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

Signed: Date: ..... /..... /.....

ធ៧-០១៧-៣២៦ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការត្រួតពិនិត្យគ្រឹះស្ថានដែលផ្តល់ឥណទានខ្នាតតូច។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ជំពូកទី ២
លក្ខខណ្ឌនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ

ប្រការ ៤.-

បុគ្គលណា ដែលមានបំណងផ្តល់ឥណទានខ្នាតតូច ត្រូវមានការអនុញ្ញាតជាមុន ពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានមិនអាចធ្វើអាជីវកម្មផ្តល់សេវាហិរញ្ញវត្ថុផ្សេងក្រៅពីឥណទានខ្នាតតូចបានឡើយ លើកលែងតែមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

បុគ្គលណា ដែលមានបំណងដាក់ពាក្យស្នើសុំវិញ្ញាបនបត្រធ្វើប្រតិបត្តិការឥណទានជនបទពីធនាគារជាតិនៃកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅក្រសួងពាណិជ្ជកម្ម

២. លក្ខន្តិក:របស់គ្រឹះស្ថាន

៣. រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន

៤. កិច្ចព្រមព្រៀងចូលហ៊ុនរបស់ភាគទុនិក ការកាន់កាប់ភាគហ៊ុន និងការអនុវត្តសិទ្ធិបោះឆ្នោត

៥. ឯកសារបញ្ជាក់ដើមទុន

៦. ប្រវត្តិរូបសង្ខេបរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

៧. គោលនយោបាយឥណទាន

៨. ផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ និង

៩. ឯកសារផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

គ្រឹះស្ថានត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយមុនពេលចាប់ផ្តើមប្រតិបត្តិការ គ្រឹះស្ថានត្រូវបង់ដើមទុនចុះបញ្ជីនេះ ១០០% (មួយរយភាគរយ) នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង ៥% (ប្រាំភាគរយ) នៃដើមទុនដែលបានចុះបញ្ជី នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

ប្រការ ៧.-

គ្រឹះស្ថានត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ប្រសិនបើមានករណី ដូចខាងក្រោម៖

១. ការបើកសាខា

២. ការផ្លាស់ប្តូរនាមករណ៍

៣. ការបង្កើន ឬបន្ថយដើមទុនចុះបញ្ជី

៤. ការកែប្រែលក្ខន្តិក:

៥. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

៦. ការផ្លាស់ប្តូរអភិបាល ឬគណៈគ្រប់គ្រង

៧. ការរួមបញ្ចូល ការផ្ទេរ ឬការលក់ផ្នែកខ្លះ ឬទាំងស្រុងនៃភាគហ៊ុន ឬ

៨. ការកែប្រែ ការផ្លាស់ប្តូរ និងបញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៣
ការផ្តល់ទិញ្ញាបនបត្រ

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រ ក្នុងរយៈពេល ០៣ (បី) ខែ ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។

ក្នុងករណីធនាគារជាតិនៃកម្ពុជាសម្រេចផ្តល់វិញ្ញាបនបត្រ ធនាគារជាតិនៃកម្ពុជានឹងចេញលិខិតយល់ព្រមជាគោលការណ៍ដោយមានលក្ខខណ្ឌ ដែលមានសុពលភាព ០៦ (ប្រាំមួយ) ខែ។ បន្ទាប់ពីបំពេញកាតព្វកិច្ចតាមលក្ខខណ្ឌនៃលិខិតយល់ព្រមជាគោលការណ៍ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា។

ក្នុងករណីមិនបានបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងលិខិតយល់ព្រមជាគោលការណ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោយ:។

ប្រការ ៩.-

វិញ្ញាបនបត្រមានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ និងអាចស្នើសុំបន្តជាថ្មីទៀតបាន។ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រ ក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ខែ មុនវិញ្ញាបនបត្រផុតសុពលភាព។

ប្រការ ១០.-

សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ ដូចខាងក្រោម៖

- សម្រាប់ទីស្នាក់ការកណ្តាល ៖ ២.000.000 រៀល (ពីរលានរៀល)
- សម្រាប់មួយសាខា ៖ ១.000.000 រៀល (មួយលានរៀល)

គ្រឹះស្ថានដែលទទួលវិញ្ញាបនបត្រក្នុងឆ្នាំ ត្រូវបង់សោហ៊ុយវិញ្ញាបនបត្រ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី ១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី ២ ៖ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី ៣ ៖ ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី ៤ ៖ ត្រូវបង់មួយត្រីមាស។

ប្រការ ១១.-

គ្រឹះស្ថានត្រូវបង់សោហ៊ុយផ្សេងៗ ដូចខាងក្រោម៖

- ការសិក្សាសំណុំឯកសារ ៖ ៥00.000 រៀល (ប្រាំរយពាន់រៀល)
- ការកែប្រែលក្ខន្តិក: ៖ ៥00.000 រៀល (ប្រាំរយពាន់រៀល) ក្នុងមួយទំព័រ
- ការប្តូរវិញ្ញាបនបត្រ ៖ ២.000.000 រៀល (ពីរលានរៀល)
- ការផ្ទេរភាគហ៊ុន ឬការបង្កើនដើមទុន ឬការបន្ថយដើមទុន៖ អប្បបរមា ៤00.000 រៀល (បួនរយពាន់រៀល) ឬ ០,៥%(សូន្យក្បៀសប្រាំភាគរយ) នៃតម្លៃចារឹកភាគហ៊ុនដែលប្រែប្រួល។

ប្រការ ១២.-

គ្រឹះស្ថានដែលត្រូវបានធនាគារជាតិនៃកម្ពុជាមិនផ្តល់វិញ្ញាបនបត្រ ឬដកហូតវិញ្ញាបនបត្រ ត្រូវបញ្ឈប់រាល់សកម្មភាពរបស់ខ្លួនទាំងស្រុងក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៤
កាតព្វកិច្ចរាយការណ៍ និងការត្រួតពិនិត្យ

ប្រការ ១៣.-

គ្រឹះស្ថានត្រូវអនុវត្តកាតព្វកិច្ចបង្ហាញព័ត៌មាននិងរាយការណ៍ ដូចខាងក្រោម៖

១. បង្ហាញព័ត៌មានស្របតាមស្តង់ដារគណនេយ្យនៃប្រទេសកម្ពុជា និងបទប្បញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ត្រូវផ្ញើរបាយការណ៍ត្រីមាស និងតាមការចាំបាច់ មកធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

- របាយការណ៍ទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណូល-ចំណាយ
- របាយការណ៍ឥណទានតាមប្រភេទជំនួញ
- របាយការណ៍ឥណទានចំណាត់ថ្នាក់តាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ចំណាត់ថ្នាក់ឥណទាន
- របាយការណ៍ស្តីពីព័ត៌មានបណ្តាញប្រតិបត្តិការ
- របាយការណ៍អត្រាការប្រាក់ និង
- របាយការណ៍ផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែទី១ នៃត្រីមាសបន្ទាប់។ គ្រឹះស្ថានត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

គ្រឹះស្ថានត្រូវតែងតាំងក្រុមហ៊ុនសវនកម្ម ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន។

ការត្រួតពិនិត្យដល់ទីកន្លែងអាចនឹងត្រូវបានអនុវត្ត ដោយមាន ឬគ្មានការជូនដំណឹងជាមុន។

ប្រការ ១៤.-

គ្រឹះស្ថានត្រូវគណនាការប្រាក់ តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានជាមុនឱ្យបានច្បាស់លាស់ដល់អតិថិជនអំពី អត្រាការប្រាក់ ការគណនាការប្រាក់ កម្រៃពាក់ព័ន្ធ និងលក្ខខណ្ឌផ្សេងៗនៃការផ្តល់ឥណទាន។ ការប្រាក់ត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនទឹកប្រាក់ឥណទានដែលបានផ្តល់ ដកចេញប្រាក់ដើមដែលបានសង។

គ្រឹះស្ថានត្រូវបង្ហាញអត្រាការប្រាក់ប្រចាំគ្រា និងអត្រាការប្រាក់សមមូលប្រចាំឆ្នាំនៅក្នុងកិច្ចសន្យាឥណទាន និងតារាងស្តីពីការសងរំលស់ឥណទាន។

គ្រឹះស្ថានត្រូវផ្តល់ឥណទានប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ និងត្រូវធានាថា ការផ្សព្វផ្សាយ ឬការផ្តល់ព័ត៌មានទៅអតិថិជនមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ និងមិនធ្វើឱ្យមានការភាន់ច្រឡំ។

ប្រការ ១៥.-

គ្រឹះស្ថានត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន លើកលែងតែមានបញ្ញត្តិដោយឡែក។

ជំពូកទី ៥
រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

ប្រការ ១៦.-

ភាគទុនិកត្រូវផ្តល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក៖

ក. ក្នុងករណីជានីតិបុគ្គល៖ នាមករណ៍ក្រុមហ៊ុន រូបភាពគតិយុត្ត អាសយដ្ឋាននៃទីស្នាក់ការកណ្តាល លក្ខន្តិក: និងរបាយការណ៍សវនកម្មហិរញ្ញវត្ថុ ជាដើម

ខ. ក្នុងករណីជារូបវន្តបុគ្គល៖ គោត្តនាមនិងនាម ទីកន្លែងនិងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋានបច្ចុប្បន្ន លិខិតជ្រោលទោស និងឯកសារពាក់ព័ន្ធផ្សេងទៀត។

២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត។ ភាគទុនិកត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមទុន

៣. ចំណងទាក់ទងរវាងភាគទុនិកនិងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និង

៤. ព័ត៌មានផ្សេងទៀត ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ១៧.-

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬនាយក ឬគណៈគ្រប់គ្រងរបស់គ្រឹះស្ថានដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមគ្រឹះស្ថាន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទ៖

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- លួចដកហូតយកទ្រព្យសាធារណៈក្នុងតួនាទីខ្លួនជាអ្នកគ្រប់គ្រង
- គៃបន្លំមូលនិធិ ឬមូលបត្រ ឬក្ស័យធន
- ធ្វើព្រឺទ្ធិកម្ម
- ការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ឬ
- ក្លែង និង/ឬ ប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់

៣. ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈឹម ដែលមានចែងនៅក្នុងចំណុច ១ និង ២ នៃប្រការនេះ

៤. ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្បៀងធន ឬការជម្រះបំណុល តាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ ឬ

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលអាជ្ញាបណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល នាយក និងគណៈគ្រប់គ្រងដែលត្រូវបានតែងតាំង ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា និងផ្តល់ព័ត៌មានតាមការតម្រូវ ដូចក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី ៦
ការពិន័យ

ប្រការ ១៨.-

ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្នុងការផ្តល់របាយការណ៍ លិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ គ្រឹះស្ថានត្រូវរងការពិន័យចំពោះការយឺតយ៉ាវនីមួយៗចាប់ពី ១ ថ្ងៃ ទៅ ១៥ ថ្ងៃ ជាទឹកប្រាក់ចំនួន ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ និងចាប់ពី ១៦ ថ្ងៃ ឡើងទៅ ចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃ។

២. គ្រឹះស្ថានត្រូវរងការពិន័យចំពោះការយឺតយ៉ាវក្នុងការបង់សោហ៊ុយវិញ្ញាបនបត្រ ចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃ ក្នុងរយៈពេលរហូតដល់ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីមិនអាចបង់សោហ៊ុយនេះ គ្រឹះស្ថានត្រូវរងទណ្ឌកម្មធ្ងន់ធ្ងរជាងនេះទៅទៀត រហូតដល់ត្រូវដកហូតវិញ្ញាបនបត្រ។

៣. គ្រឹះស្ថានដែលមិនគោរពតាមអធិបញ្ញា និង/ឬ ល្មើសបទប្បញ្ញត្តិជាធរមាននឹងត្រូវរងពិន័យជាទឹកប្រាក់ចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ១៩.-

ធនាគារជាតិនៃកម្ពុជា អាចព្យួរ ឬដកហូតវិញ្ញាបនបត្រ ដោយផ្អែកលើមូលហេតុមួយឬច្រើនដូចខាងក្រោម៖

- គ្រឹះស្ថានមិនបានចាប់ផ្តើមអាជីវកម្មរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានវិញ្ញាបនបត្រ
- គ្រឹះស្ថានបំពានធ្ងន់ធ្ងរលើច្បាប់ ឬបទប្បញ្ញត្តិជាធរមាន
- គ្រឹះស្ថានស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា

- គ្រឹះស្ថានអសាធនភាព ឬក្ស័យធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬ
- គ្រឹះស្ថានផ្តល់របាយការណ៍ ឬបង្ហាញព័ត៌មានមិនត្រឹមត្រូវដល់ធនាគារជាតិនៃកម្ពុជា ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ការវិភាគ និងការវាយតម្លៃស្ថានភាពរបស់គ្រឹះស្ថាន ជាដើម។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

ប្រការ ២០.-

គ្រឹះស្ថានដែលបានទទួលវិញ្ញាបនបត្រធ្វើប្រតិបត្តិការ ត្រូវបំពេញដើមទុនចុះបញ្ជីអប្បបរមាស្របតាមការកំណត់ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ០៦ (ប្រាំមួយ) ខែ គិតចាប់ពីប្រកាសនេះចូលជាធរមាន។

ប្រការ ២១.-

គ្រឹះស្ថានអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លុះត្រាតែគ្រឹះស្ថាន៖

- បានធ្វើប្រតិបត្តិការឥណទានជនបទ យ៉ាងតិចរយៈពេល ០៣ (បី) ឆ្នាំ
- មានដើមទុនបង់ជម្រះអប្បបរមា ស្របតាមប្រកាសដែលពាក់ព័ន្ធនឹងដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អ
- មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ
- មានប្រាក់ចំណេញប្រតិបត្តិការប្រកបដោយស្ថិរភាពយ៉ាងតិច ០៣ (បី) ឆ្នាំជាប់គ្នា
- មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ និងសមស្របទៅតាមសកម្មភាពប្រតិបត្តិការ និង
- បានបំពេញលក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ២២.-

គ្រឹះស្ថានណា ដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

ប្រការ ២៣.-

ប្រកាសលេខ ធ៧-០២-៤៩ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពី កាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ២៤.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

ធ្វើនៅ.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

សូមគោរពជូន

ឯកឧត្តម ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

កម្មវត្ថុ ៖ សំណើសុំវិញ្ញាបនបត្រជាគ្រឹះស្ថានឥណទានជនបទ។

យោង ៖ ប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូន ឯកឧត្តម ទេសាភិបាល មេត្តាជ្រាបថា ក្រុមហ៊ុន.....បានចុះបញ្ជីពាណិជ្ជកម្ម កាលពីថ្ងៃទី.....។ ទន្ទឹមនឹងនោះ ក្រុមហ៊ុនមានដើមទុនបង់ជម្រះចំនួន..... និងបានបំពេញគ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រកាសខាងលើ ក្នុងគោលបំណងផ្តល់សេវាឥណទានខ្នាតតូច។

ខ្ញុំបាទ/នាងខ្ញុំ សូមភ្ជាប់មកជាមួយនូវសំណុំឯកសារ ដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅក្រសួងពាណិជ្ជកម្ម
២. លក្ខន្តិក:របស់គ្រឹះស្ថាន
៣. រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន
៤. កិច្ចព្រមព្រៀងចូលហ៊ុនរបស់ភាគទុនិក ការកាន់កាប់ភាគហ៊ុន និងការអនុវត្តសិទ្ធិបោះឆ្នោត
៥. ឯកសារបញ្ជាក់ដើមទុន
៦. គោលនយោបាយឥណទាន
៧. ផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ
៨. ប្រវត្តិរូបសង្ខេបរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ដោយភ្ជាប់មកជាមួយនូវសញ្ញាបត្រជំនាញ និងបទពិសោធន៍ការងារ ជាដើម
៩. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន និងលិខិតថ្កោលទោសរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង និង
១០. លិខិតអនុញ្ញាតធ្វើការងារក្នុងព្រះរាជាណាចក្រកម្ពុជា (Work Permit) របស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ក្នុងករណីជាជនបរទេស។

ខ្ញុំបាទ/នាងខ្ញុំ សូមធានាថា រាល់ព័ត៌មាននិងឯកសារដែលបានផ្តល់ ពិតជាត្រឹមត្រូវ និងសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ ជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម ទេសាភិបាល មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម ឯកឧត្តម ទេសាភិបាល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ/នាងខ្ញុំ។

ហត្ថលេខានិងត្រា
(តំណាងក្រុមហ៊ុន)

ធ៩-០៩-២៣០ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

ប្រការ ១.-

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ ដែលកំពុងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២.-

និយមន័យ៖

១- **រូបិយវត្ថុ** សំដៅដល់ប្រាក់រៀលដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

២- **រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុបរទេសឬមធ្យោបាយទូទាត់ជារូបិយវត្ថុបរទេស។

៣- **អាជីវកម្មប្តូរប្រាក់** សំដៅដល់ការ ទិញ-លក់ ប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណនានា ឬការទិញ-លក់រូបិយប័ណ្ណមួយជាមួយនឹងរូបិយប័ណ្ណផ្សេងៗទៀត។

ប្រការ ៣.-

ប្រតិបត្តិការដែលជាសកម្មភាពប្តូរប្រាក់ រួមមាន៖

- ទិញនិងលក់ក្រដាសប្រាក់ជារូបិយប័ណ្ណ
- ទិញមូលប្បទានបត្រទេសចរណ៍។

ប្រការ ៤.-

១- បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្តូរប្រាក់ត្រូវតែសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

២- បុគ្គលដែលដាក់ពាក្យសុំអាជ្ញាបណ្ណធ្វើអាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ច និងសិទ្ធិដូចតទៅ៖

ក- ត្រូវមានដើមទុនអប្បបរមាចំនួន ៨0.000.000 រៀល (ប៉ែតសិបលានរៀល) តម្កល់នៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ដោយទទួលកម្រៃការប្រាក់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា

ខ- មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា

គ- មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយប័ណ្ណក្លែងក្លាយ។

ប្រការ ៥.-

១- ពាក្យសុំអាជ្ញាបណ្ណត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- នាមករណ៍យីហោ និងអាសយដ្ឋានធ្វើអាជីវកម្ម

ខ- លិខិតបង់ប្រាក់តម្កល់ដើមទុន

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២- ពាក្យសុំលិខិតអនុញ្ញាតត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- ឈ្មោះ និងទីលំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យសុំ

ខ- ទីតាំងធ្វើអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរខណ្ឌ ឬស្រុក និង

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

១- ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យលើពាក្យស្នើសុំក្នុងរយៈពេល ៤៥ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញហើយអាចចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាតឬបដិសេធពាក្យស្នើសុំនោះ។

២- អាជ្ញាបណ្ណឬលិខិតអនុញ្ញាតមិនអាចផ្ទេរឬប្តូរឈ្មោះបានឡើយ។

៣- អាជ្ញាបណ្ណមានសុពលភាពរយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

៤- លិខិតអនុញ្ញាតមានសុពលភាពរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។

ប្រការ ៧.-

១- អ្នកដាក់ពាក្យសុំអាជ្ញាបណ្ណប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំអាជ្ញាបណ្ណចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល)។

(ត្រូវបានជំនួសដោយ ប្រការ ៦ ចំណុច ៣ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ខ- សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន ១.២០០.០០០ រៀល (មួយលានពីររយពាន់រៀល) ដែលត្រូវបង់នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

(ត្រូវបានជំនួសដោយប្រការ ៤ ចំណុច ៨ និងប្រការ ៥ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

គ- ក្នុងរយៈពេល៣០ថ្ងៃមុនអាជ្ញាបណ្ណអស់សុពលភាព អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណជាថ្មី។

ឃ- ក្នុងករណីមិនបានដាក់ពាក្យសុំបន្តអាជ្ញាបណ្ណទាន់ពេលវេលា អ្នកកាន់អាជ្ញាបណ្ណនឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន ២០.០០០ រៀល (ម្ភៃពាន់រៀល) ក្នុងមួយថ្ងៃ។ ប្រសិនបើអាជ្ញាបណ្ណអស់សុពលភាពរយៈពេល៣០ថ្ងៃ អ្នកកាន់អាជ្ញាបណ្ណមិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំជាថ្មីឡើយ។

២- អ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំលិខិតអនុញ្ញាតចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល)

ខ- សោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំចំនួន ២០០.០០០ រៀល (ពីររយពាន់រៀល)

គ- ក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព អ្នកកាន់លិខិតអនុញ្ញាតត្រូវដាក់ពាក្យសុំបន្តជាថ្មី។

៣- ចំពោះបុគ្គលដែលដាក់ពាក្យសុំអាជ្ញាបណ្ណ សោហ៊ុយនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដំណាច់ឆ្នាំ។

៤- អាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់។

៥- ក្នុងករណីមានទីតាំង ឬអាសយដ្ឋានធ្វើប្រតិបត្តិការច្រើនកន្លែង ទីតាំងធ្វើប្រតិបត្តិការនីមួយៗត្រូវតែមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ហើយមិនត្រូវប្រកបអាជីវកម្មប្តូរប្រាក់នៅទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋាន ឬទីតាំងដែលបានអនុញ្ញាតឡើយ។

៦- រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ទីតាំងធ្វើប្រតិបត្តិការ កម្មសិទ្ធិធ្វើអាជីវកម្ម ការបិទអាជីវកម្ម និងបើកទីតាំងថ្មី អាជីវករប្តូរប្រាក់ត្រូវតែជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃកម្ពុជា។ រាល់ការកែប្រែទាំងនេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការមុនពេលបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជាឡើយ។

ប្រការ ៨.-

១- អ្នកកាន់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត៖

ក- ត្រូវលើកយីហោនៅកន្លែងអាជីវកម្មរបស់ខ្លួនដោយដាក់អក្សរ "ប្តូរប្រាក់" និងអាចដាក់បន្ថែមជាភាសាអង់គ្លេស "Authorized Money Changer"

ខ- ត្រូវដាក់បង្ហាញអាជ្ញាបណ្ណគ្រប់ពេលវេលាទាំងអស់នៅកន្លែងដែលងាយមើលឃើញនៅក្នុងបរិវេណដែលបានអនុញ្ញាត

គ- ត្រូវដាក់បង្ហាញឱ្យសាធារណជនឃើញច្បាស់ជាប្រចាំនូវតារាងអត្រា ទិញ-លក់ ប្រចាំថ្ងៃរវាងប្រាក់រៀលជាមួយប្រាក់ដុល្លារនិងរវាងប្រាក់ដុល្លារជាមួយនឹងរូបិយប័ណ្ណផ្សេងៗ

ឃ- ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាមុនពេលចាប់ផ្តើមធ្វើអាជីវកម្មប្តូរប្រាក់នៅទីតាំងថ្មី។

២- អ្នកកាន់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតត្រូវគោរពតាមក្រមប្រតិបត្តិដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៩.-

ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត បើអ្នកកាន់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត៖

ក- ល្មើសនឹងខ្លឹមសារនៃប្រកាសនិងឧបសម្ព័ន្ធនៃប្រកាសនេះ

ខ- មិនសហការជាមួយធនាគារជាតិនៃកម្ពុជាឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ឬ អង្កេត

គ- បានប្រព្រឹត្តការក្លែងបន្លំនិងធ្វើការបំភាន់ដោយចេតនា

ឃ- ធ្វើវិច្ឆេទកម្មកេងយកចំណេញដោយការបំប៉ោងអត្រាប្តូរ

ង- ផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យសាធារណជនមានការយល់ច្រឡំ ឬបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល

ច- ល្មើសនឹងបទបញ្ជាពាក់ព័ន្ធនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ប្រការ ១០.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះត្រូវទទួលរងទណ្ឌកម្មយោងតាមមាត្រា ៧០ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

ប្រការ ១១.-

ប្រកាសលេខ ធ៩-៩៨-៣៩៣ ប្រ.ក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវកម្មប្តូរប្រាក់ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១២.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងខ្លួន។

ប្រការ ១៣.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០៩-២៣០ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

ក្រមប្រតិបត្តិសម្រាប់អាជីវករប្តូរប្រាក់

១. ដែនអនុវត្ត

ក្រមប្រតិបត្តិនេះអនុវត្តចំពោះអាជីវករប្តូរប្រាក់ទាំងអស់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជីវករប្តូរប្រាក់ត្រូវគោរពតាមក្រមប្រតិបត្តិនេះជាអចិន្ត្រៃយ៍។

ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធរគ្រប់គ្រង និងត្រួតពិនិត្យដែលនៅក្រោមយុត្តាធិការនេះ អាជីវករប្តូរប្រាក់ត្រូវបានត្រួតពិនិត្យ និងត្រូវបានដាកពិន័យ ឬទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ បទប្បញ្ញត្តិនានា និងការមិនគោរពតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

បុគ្គលដែលធ្វើសកម្មភាពជាអាជីវករប្តូរប្រាក់ ត្រូវតែស្នើសុំការអនុញ្ញាត (អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត) ពីធនាគារជាតិនៃកម្ពុជាមុននឹងចាប់ផ្តើមធ្វើប្រតិបត្តិការប្តូររូបិយប័ណ្ណ។

២. ភាតព្វកិច្ចរបស់អាជីវករប្តូរប្រាក់

១- អាជីវករប្តូរប្រាក់ដែលបានទទួលអាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ៖

ក- បោះពុម្ពសៀវភៅវិក្កយបត្រឱ្យហើយជាស្រេច ដែលនៅលើវិក្កយបត្រនោះត្រូវមានលេខរៀងឈ្មោះ នាមករណ៍ យីហោ អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង។ លេខរៀងនីមួយៗនៃវិក្កយបត្រនេះត្រូវធ្វើជាពីរច្បាប់ដែលច្បាប់ដើមសម្រាប់អតិថិជន និងច្បាប់ចម្លងសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់។ អាជីវករប្តូរប្រាក់ត្រូវផ្តល់វិក្កយបត្រឱ្យអតិថិជននូវរាល់ពេលធ្វើប្រតិបត្តិការ។

ខ- បោះពុម្ពសៀវភៅវិក្កយបត្រពិសេសមួយទៀតសម្រាប់ការដកហូតប្រាក់ ឬមូលប្បទានបត្រទេសចរណ៍ក្លែងក្លាយ។ លេខរៀងនីមួយៗនៃវិក្កយបត្រនេះត្រូវធ្វើជាបីច្បាប់ ដែលច្បាប់ដើមសម្រាប់អតិថិជន ច្បាប់ចម្លងមួយសម្រាប់ផ្តល់ឱ្យធនាគារជាតិនៃកម្ពុជា ដោយត្រូវភ្ជាប់ជាមួយក្រដាសប្រាក់ ឬមូលប្បទានបត្រទេសចរណ៍ក្លែងក្លាយ និងច្បាប់ចម្លងមួយទៀតសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់។

គ- មានបុគ្គលិកដែលមានសមត្ថភាពក្នុងការធ្វើវិក្កយបត្រ ការកត់ត្រា និងធ្វើរបាយការណ៍ជូនធនាគារជាតិនៃកម្ពុជា។

២- ជាទូទៅ អាជីវករប្តូរប្រាក់ត្រូវតែប្រកាន់ខ្ជាប់នូវភាពសុចរិតផ្នែកវិជ្ជាជីវៈដោយមិនក្លែងបន្លំ ឬឆ្លៀតឱកាសពីការមិនយល់ដឹងរបស់អតិថិជនដើម្បីផ្តល់ប្រាក់ក្លែងក្លាយ ឬបន្លំក្នុងការគណនាចំនួនប្រាក់ ដែលអតិថិជនត្រូវបានទទួលជាដើម។

៣. សកម្មភាពហាមឃាត់

ក្រៅពីសកម្មភាពប្តូរប្រាក់រូបិយប័ណ្ណ និងទិញមូលប្បទានបត្រទេសចរណ៍ អាជីវករប្តូរប្រាក់មិនត្រូវធ្វើប្រតិបត្តិការដូចខាងក្រោម៖

- ផ្តល់សេវាផ្ទេរប្រាក់
- ជួញដូររូបិយប័ណ្ណដោយការទូទាត់មិនផ្ទាល់ដៃនៅក្នុងរយៈពេលជាក់លាក់នៅពេលអនាគត
- ជួញដូរមូលបត្រភាគហ៊ុន និងធ្វើជាជើងសាករដោយខ្លួនឯង ឬធ្វើក្នុងនាមអតិថិជន
- ទទួលប្រាក់បញ្ញើពីសាធារណជន
- ផ្តល់ឥណទានដល់សាធារណជន
- ផ្តល់មធ្យោបាយទូទាត់សងប្រាក់ដល់សាធារណជន
- ផ្សាយពាណិជ្ជកម្មណាមួយដែលធ្វើឱ្យសាធារណជនយល់ច្រឡំថាខ្លួនផ្តល់សេវាប្រតិបត្តិការខាងលើ
- ជួញដូរក្រដាសប្រាក់ក្លែងក្លាយ

រាល់សកម្មភាពដែលអនុវត្តដោយខុសច្បាប់ គឺជាបទឧក្រិដ្ឋ និងត្រូវបានហាមឃាត់មិនឱ្យធ្វើប្រតិបត្តិការហើយអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតជាផ្លូវការរបស់អាជីវករប្តូរប្រាក់នឹងត្រូវបានដកហូត។

៤. ការស្គាល់អតិថិជន

នៅពេលដំណើរការប្តូររូបិយប័ណ្ណ អាជីវករប្តូរប្រាក់ត្រូវស្គាល់អតិថិជនឱ្យបានច្បាស់លាស់។ ការស្គាល់អតិថិជននេះត្រូវបានធ្វើឡើងតាមរយៈការតម្រូវឱ្យអតិថិជនផ្តល់លិខិតសម្គាល់ខ្លួនជាផ្លូវការដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅប្រទេស។ លិខិតសម្គាល់ខ្លួនទាំងនោះរួមមាន អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងលិខិតសម្គាល់ខ្លួនជាផ្លូវការផ្សេងទៀតដែលមានបិទរូបថត។

ការសម្គាល់អត្តសញ្ញាណនេះនឹងត្រូវអនុវត្តចំពោះ៖

- អតិថិជនដែលប្តូរប្រាក់លើសពី ១០.០០០ ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក)
- អតិថិជនដែលប្តូរប្រាក់មួយលើកៗមានចំនួនតិច ប៉ុន្តែញឹកញាប់ដោយគ្មានមូលហេតុច្បាស់លាស់។

ចំពោះអតិថិជនដែលធ្លាប់ធ្វើប្រតិបត្តិការជាធម្មតា និងមានកម្មវត្ថុប្តូរប្រាក់ច្បាស់លាស់ ដូចជាសម្រាប់បង់ពន្ធ បើកប្រាក់បៀវត្ស ឬទិញកសិផល។ល។ ការសម្គាល់អត្តសញ្ញាណនេះអាចមានលក្ខណៈធូរស្រាលជាង។

ប្រសិនបើអតិថិជនបដិសេធក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណណាមួយ អាជីវករប្តូរប្រាក់មានសិទ្ធិបដិសេធមិនធ្វើប្រតិបត្តិការបាន។

៥. ក្រដាសប្រាក់ក្លែងក្លាយ

ក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្មប្តូរប្រាក់ត្រូវពិនិត្យមើលក្រដាសប្រាក់ និងមូលប្បទានបត្រទេសចរណ៍ដែលបានបង្ហាញសម្រាប់ទិញដើម្បីកំណត់នូវអត្តសញ្ញាណក្លែងក្លាយ។ ប្រសិនបើអាជីវករប្តូរប្រាក់ពិនិត្យឃើញថាក្លែងក្លាយអាជីវកររនោះត្រូវរក្សាទុករូបិយប័ណ្ណក្លែងក្លាយនោះ ហើយ

ចេញជាវិក្កយបត្រមួយឱ្យទៅអតិថិជនដោយបញ្ជាក់ប្រាប់អតិថិជនថាខ្លួននឹងបញ្ជូនក្រដាសប្រាក់/មូលប្បទានបត្រទេសចរណ៍មកធនាគារជាតិនៃកម្ពុជា។

អាជីវកម្មប្តូរប្រាក់ត្រូវពិនិត្យក្រដាសប្រាក់ដែលខ្លួនប្រគល់ទៅឱ្យអតិថិជនដើម្បីកំណត់អត្តសញ្ញាណ និងដកហូតក្រដាសប្រាក់ក្លែងក្លាយចេញពីក្នុងចរាចរណ៍។

ក្រដាសប្រាក់ក្លែងក្លាយត្រូវតែបញ្ជូនមកធនាគារជាតិនៃកម្ពុជាភ្លាមៗ ដោយភ្ជាប់ជាមួយវិក្កយបត្រចម្លងមួយច្បាប់។ ច្បាប់ដើមត្រូវប្រគល់ឱ្យអតិថិជន ច្បាប់ទីពីរត្រូវរក្សាទុកនៅក្នុងបញ្ជី និងច្បាប់ទី៣ត្រូវរក្សាទុកជាឯកសាររបស់អាជីវកម្មប្តូរប្រាក់។ វិក្កយបត្រនេះត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់អតិថិជន អាសយដ្ឋាន ប្រទេសកំពុងស្នាក់នៅ ប្រភេទអត្តសញ្ញាណប័ណ្ណ និងលេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទ និងទីកន្លែងដែលផ្តល់អត្តសញ្ញាណប័ណ្ណនោះ។

ប្រសិនបើអតិថិជនព្យាយាមលក់ក្រដាសប្រាក់ក្លែងក្លាយជាច្រើន ឬបរិមាណតិចតួចតែច្រើនដង អាជីវកម្មប្តូរប្រាក់ត្រូវរាយការណ៍ជាបន្ទាន់អំពីបុគ្គលនោះទៅអាជ្ញាធរមានសមត្ថកិច្ច និងទីស្នាក់ការកណ្តាល ឬសាខាធនាគារជាតិនៃកម្ពុជាដែលនៅជិតបំផុត។

ការបោះផ្សាយ ឬបោះផ្សាយឡើងវិញនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា និងការរួមគំនិតជួយសម្រួលការធ្វើចរាចរក្រដាសប្រាក់ក្លែងក្លាយគឺជាបទឧក្រិដ្ឋដែលនឹងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ និងត្រូវបានដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មប្តូរប្រាក់។ ដូច្នេះ អាជីវកម្មប្តូរប្រាក់ទាំងអស់ត្រូវធ្វើអាជីវកម្មរបស់ខ្លួនដោយប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវការពារការធ្វើចរាចរក្រដាសប្រាក់ និងមូលប្បទានបត្រទេសចរណ៍ក្លែងក្លាយ។

៦. ការប្រុងប្រយ័ត្ន និងភាតព្វកិច្ចរាយការណ៍៖ ការប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អាជីវកម្មប្តូរប្រាក់ជាអ្នកចូលរួមយ៉ាងសកម្មក្នុងទីផ្សារប្តូរប្រាក់។ ដូច្នេះ អាជីវកម្មប្តូរប្រាក់ត្រូវបានចាត់ទុកជាបុគ្គលរាយការណ៍នៅក្រោមច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងន័យនេះ អាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តតាមបទប្បញ្ញត្តិ ដែលបានកំណត់នៅក្រោមច្បាប់នេះរួមមានកាតព្វកិច្ចសម្គាល់អត្តសញ្ញាណរបស់អតិថិជន រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការប្តូរប្រាក់ ដែលលើសពីកម្រិតដែលកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

គោលបំណងនៃការតម្រូវឱ្យបំពេញកាតព្វកិច្ចទាំងនេះ គឺដើម្បីជួយឱ្យអាជីវកម្មប្តូរប្រាក់ចៀសផុតពីការចូលរួមទាំងដោយចេតនា និងដោយអចេតនាក្នុងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលជាសកម្មភាពឧក្រិដ្ឋដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ។ ដូច្នេះ ដើម្បីប្រកបមុខរបរសុចរិតជាពលរដ្ឋល្អ និងការពារខ្លួនផុតពីសកម្មភាពខុសច្បាប់ទាំងនេះ អាជីវកម្មប្តូរប្រាក់ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមបញ្ញត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់។

នីតិវិធីក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនឹងត្រូវបានណែនាំបន្ថែមទៀតដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

អាជីវករប្តូរប្រាក់ត្រូវផ្តល់របាយការណ៍ជារៀងរាល់ខែអំពីប្រតិបត្តិការ ទិញ-លក់ រូបិយប័ណ្ណ តាមការកំណត់ដូចតទៅ៖

ក- ត្រូវធ្វើកំណត់ត្រាដោយបំពេញតាមតារាង១ នៃឧបសម្ព័ន្ធនេះនូវរាល់ប្រតិបត្តិការប្តូរប្រាក់

ខ- ត្រូវបំពេញតាមតារាង២ នៃឧបសម្ព័ន្ធនេះនូវរាល់ការប្តូរប្រាក់ដោយអតិថិជនណាម្នាក់ដែលមានទឹកប្រាក់លើសពី ១០.០០០ ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក) ឬការប្តូរប្រាក់ញឹកញាប់ដោយអតិថិជនណាម្នាក់ដែលមានទឹកប្រាក់សរុបលើសពី ១០.០០០ ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក)។

របាយការណ៍អំពីប្រតិបត្តិការប្រចាំថ្ងៃរបស់អាជីវកម្មប្តូរប្រាក់ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ) នៅក្នុងសប្តាហ៍ទីពីរ រៀងរាល់ខែបន្ទាប់។

៧. ការរក្សាទុកបញ្ជី និងកំណត់ត្រា

១- អាជីវកម្មប្តូរប្រាក់ត្រូវរក្សាទុកសៀវភៅចុះបញ្ជី និងកំណត់ត្រាឱ្យបានត្រឹមត្រូវស្របតាមកាតព្វកិច្ចគ្រប់គ្រងស្តង់ដារវិជ្ជាជីវៈ និងកាតព្វកិច្ចបទប្បញ្ញត្តិ និងគតិយុត្តិផ្សេងៗទៀត។

២- ការចុះបញ្ជី និងកំណត់ត្រាអំពីសកម្មភាពប្តូររូបិយប័ណ្ណគឺជាកាតព្វកិច្ច។

៣- អាជីវករប្តូរប្រាក់ដែលកាន់អាជ្ញាបណ្ណត្រូវមានសៀវភៅធំ (General Ledger) ដើម្បីកត់ត្រានូវរាល់សកម្មភាព ទិញ-លក់ រូបិយប័ណ្ណ។ សៀវភៅនេះត្រូវរក្សាទុកនៅកន្លែងប្រកបអាជីវកម្ម និងត្រូវអាចទៅរកបានដោយងាយក្នុងករណីមានការចុះត្រួតពិនិត្យដល់ទីកន្លែង។ កំណត់ត្រាដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជានៅពេលធ្វើការត្រួតពិនិត្យដល់ទីកន្លែងត្រូវមានដូចខាងក្រោម៖

- ច្បាប់ចម្លងឯកសារជូញដូរប្រចាំថ្ងៃដែលរៀបតាមលំដាប់លេខរៀង និងកាលបរិច្ឆេទ
- ច្បាប់ចម្លងវិក្កយបត្រដែលបានចេញឱ្យសម្រាប់ការដកហូតក្រដាសប្រាក់ និងមូលប្បទានបត្រទេសចរណ៍ក្លែងក្លាយ
- ច្បាប់ចម្លងរបាយការណ៍ប្រតិបត្តិការសង្ស័យដែលបានផ្ញើជូនធនាគារជាតិនៃកម្ពុជា។

កំណត់ត្រាទាំងអស់ត្រូវរក្សាទុកជាឯកសារ សម្រាប់រយៈពេល ៥ឆ្នាំ។

៨. ការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

ក្រុមការងារត្រួតពិនិត្យធនាគារជាតិនៃកម្ពុជា អាចចុះទៅត្រួតពិនិត្យដល់ទីកន្លែងរបស់អាជីវករប្តូរប្រាក់ដោយពុំចាំបាច់ជូនដំណឹងជាមុន។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវសហការដើម្បីសម្រួលដល់ដំណើរការនៃការត្រួតពិនិត្យ និងផ្តល់សៀវភៅចុះបញ្ជីកំណត់ត្រា និងឯកសារជាភស្តុតាងនៃប្រតិបត្តិការផ្សេងៗតាមការស្នើសុំរបស់ក្រុមត្រួតពិនិត្យ។

ប្រសិនបើអាជីវកម្មប្តូរប្រាក់បង្អាក់ដំណើរការត្រួតពិនិត្យ ឬបដិសេធមិនសហការ ឥរិយាបថបែបនេះនឹងត្រូវទទួលរងការពិន័យពីធនាគារជាតិនៃកម្ពុជា។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

៩. ការបញ្ជាក់អំពីការទទួលយកក្រមប្រតិបត្តិ និងការសន្យាគោរពតាម

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

ទម្រង់នៃការចុះបញ្ជី
រាល់ប្រតិបត្តិការប្តូរប្រាក់

ឈ្មោះអាជីវកម្មប្តូរប្រាក់៖ .....

ថ្ងៃខែប្រតិបត្តិការ	ប្រភេទនិងចំនួននៃរូបិយប័ណ្ណ		អត្រាប្តូរប្រាក់
	ទិញ	លក់	

តារាង២

ទម្រង់នៃការចុះបញ្ជី
រាល់ប្រតិបត្តិការរូបិយប័ណ្ណ
ដែលមានចំនួន ១០.០០០ ដុល្លារអាមេរិក ឬលើស

ឈ្មោះអាជីវកម្មប្តូរប្រាក់៖ .....

ថ្ងៃខែប្រតិបត្តិការ	ឈ្មោះអតិថិជន	សញ្ជាតិ	លេខអត្តសញ្ញាណប័ណ្ណ[1]	ចំនួនប្រតិបត្តិការ (បញ្ជាក់ថាតើចំនួនទិញ ឬលក់រូបិយប័ណ្ណ)		អត្រាប្តូរប្រាក់
				ជារូបិយវត្ថុ	ជារូបិយប័ណ្ណ	

[1] ក្នុងករណីជាអង្គភាពអាជីវកម្ម ត្រូវកត់ត្រានូវឈ្មោះអង្គភាពអាជីវកម្មនោះ និងឈ្មោះ សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់បុគ្គលដែលធ្វើប្រតិបត្តិការសម្រាប់ឬក្នុងនាមជាអង្គភាពអាជីវកម្ម

ធ៩-០២១-០៥២ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃដែលត្រូវចាត់ទុកជារូបិយប័ណ្ណ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនទាំងឡាយណា ដែលមានបំណងធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាដើម្បីនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ។

ប្រការ ២.-

លោហធាតុ និងត្បូងថ្មមានតម្លៃដែលត្រូវចាត់ទុកជារូបិយប័ណ្ណនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចតទៅ៖

១/- លោហធាតុមានតម្លៃ សំដៅដល់ មាស ប្រាក់ ប្លាទីន ដែលមិនទាន់ច្នៃជាគ្រឿងអលង្ការ។

២/- ត្បូងថ្មមានតម្លៃ សំដៅដល់ ត្បូងថ្មដែលមិនទាន់ច្នៃជាគ្រឿងអលង្ការ។

ប្រការ ៣.-

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃត្រូវតែជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឬក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវភ្ជាប់ជាមួយនូវ៖

ក. លក្ខន្តិក:គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ប្រសិនបើអ្នកដាក់ពាក្យសុំជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

ខ. លក្ខន្តិក:ក្រុមហ៊ុនដែលមានកម្មវត្ថុចម្បងធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

គ. លិខិតបញ្ជាក់ពីការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដែលចេញដោយក្រសួងពាណិជ្ជកម្ម

ឃ. លិខិតបញ្ជាក់អាសយដ្ឋានប្រកបអាជីវកម្មពីអាជ្ញាធរមូលដ្ឋាន

ង. អត្តសញ្ញាណប័ណ្ណរបស់អ្នកគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុននិងអាសយដ្ឋានរស់នៅបច្ចុប្បន្ន

ច. រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុន

ឆ. ដើមទុន និងផែនការអាជីវកម្មរបស់ក្រុមហ៊ុនស្តីពីអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

ជ. ឯកសារផ្សេងៗទៀតតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវមានប្រព័ន្ធចុះកិច្ចបញ្ជិកាគណនេយ្យ សមស្រប។

ប្រការ ៤.-

នៅក្នុងការពិនិត្យលើពាក្យស្នើសុំអាជ្ញាបណ្ណ ធនាគារជាតិនៃកម្ពុជានឹងពិចារណាលើលក្ខខណ្ឌ វិនិច្ឆ័យត្រឹមត្រូវ និងសមស្របក្នុងការផ្តល់អាជ្ញាបណ្ណ។ ធនាគារជាតិនៃកម្ពុជានឹងបដិសេធពាក្យស្នើសុំ អាជ្ញាបណ្ណណាដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.000.000 រៀល (ពីរលានរៀល)។

ប្រការ ៥.-

អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃមានសុពលភាព ៣ឆ្នាំ (បីឆ្នាំ)។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនដែលមានបំណងចង់បន្តអាជីវកម្មត្រូវដាក់ ពាក្យស្នើសុំអាជ្ញាបណ្ណថ្មីឱ្យបាន ៣០ថ្ងៃ មុនអាជ្ញាបណ្ណចាស់អស់សុពលភាព។

អាជ្ញាបណ្ណនេះមានតម្លៃប្រើប្រាស់សម្រាប់តែគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលមានឈ្មោះក្នុងអាជ្ញាបណ្ណប៉ុណ្ណោះ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន ៥.000.000 រៀល (ប្រាំលានរៀល) នៅពេលបានទទួលអាជ្ញាបណ្ណ និងត្រូវបង់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់ឆ្នាំបន្ទាប់។

ក្នុងករណីប្តូរអាជ្ញាបណ្ណថ្មី ដោយមូលហេតុណាមួយសមស្រប គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយចំនួន ១.000.000 រៀល (មួយលានរៀល)។

ក្នុងករណីប្តូរនាមករណ៍ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំ អាជ្ញាបណ្ណជាថ្មី ដោយភ្ជាប់ជាមួយនូវសំណុំឯកសារ និងបង់សោហ៊ុយពាក់ព័ន្ធចំនួន ១.000.000 រៀល (មួយលានរៀល)។

ប្រការ ៦.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណត្រូវប្រកបអាជីវកម្មនៅលើ ទីតាំងដែលបានដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា។

រាល់ការប្តូរទីតាំង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំមកធនាគារ ជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ទីតាំងថ្មីដែលចេញដោយអាជ្ញាធរ និងត្រូវបង់ សោហ៊ុយចំនួន ១.000.000 រៀល (មួយលានរៀល)។

ប្រការ ៧.-

រាល់ការនាំចេញ ឬនាំចូលលោហធាតុមានតម្លៃ និង/ឬ ត្បូងថ្មមានតម្លៃ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវស្នើសុំប្រតិវេទន៍ជាមុនពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងអំពីការសម្រេចអនុញ្ញាតផ្តល់ប្រតិវេទន៍ក្នុងរយៈពេល ៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបង់សោហ៊ុយប្រតិវេទន៍ចំនួន ២.000.000 រៀល (ពីរលានរៀល)។

ពាក្យស្នើសុំប្រតិវេទន៍ត្រូវភ្ជាប់ជាមួយនូវ៖

ក. ឯកសារដែលបានព្រមព្រៀងគ្នាជាមួយដៃគូក្នុងការនាំចេញ-នាំចូលលោហធាតុឬត្បូងថ្មមានតម្លៃដោយមានបញ្ជាក់ច្បាស់នូវ ប្រភេទទំនិញ តម្លៃក្នុងឯកតា តម្លៃសរុប និងបរិមាណ លក្ខខណ្ឌទូទាត់ លក្ខខណ្ឌប្រគល់ទទួល កាលបរិច្ឆេទប្រគល់ទទួលថ្ងៃប្រសិទ្ធភាពទូទាត់

ខ. ឯកសារដែលបញ្ជាក់នូវ ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងអ៊ីម៉ែល របស់ដៃគូនាំចេញ-នាំចូលឱ្យបានច្បាស់លាស់ និងឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងអ៊ីម៉ែលរបស់អាជ្ញាធរដែលផ្តល់អាជ្ញាបណ្ណដល់ដៃគូនោះ។

ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យ សម្រេច អនុញ្ញាតលើពាក្យស្នើសុំនីមួយៗ មិនឱ្យលើសពី ១.000 គីឡូក្រាម (មួយពាន់គីឡូក្រាម)។

ប្រតិវេទន៍នាំចេញ ឬនាំចូលនូវលោហធាតុ ឬត្បូងថ្មមានតម្លៃមានសុពលភាព ៣០ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខា និងអាចប្រើប្រាស់បាន ២ដង។

ប្រការ ៨.-

បន្ទាប់ពីបាននាំចេញ ឬនាំចូលលោហធាតុ និង/ឬ ត្បូងថ្មមានតម្លៃរួច គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបញ្ជូនប្រតិវេទន៍ (សន្លឹកពណ៌លឿង) ដែលត្រូវបានមន្ត្រីគយនិងរដ្ឋាករចុះទិដ្ឋាការនៅផ្នែកខាងខ្នង ព្រមទាំងសក្ខីបត្របញ្ជាក់ពីការទូទាត់តាមរយៈធនាគារ មកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការដើម្បីជាសេចក្តីរាយការណ៍។

ប្រការ ៩.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តតាមគោលការណ៍កំណត់ដូចខាងក្រោមក្នុងការធ្វើអាជីវកម្មរបស់ខ្លួន៖

ក. តាំងឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុន នៅលើទីតាំងដែលបានទទួលការអនុញ្ញាត។

ខ. តាំងបង្ហាញជាសាធារណៈនូវអាជ្ញាបណ្ណដែលបានទទួលពីធនាគារជាតិនៃកម្ពុជា។

គ. ប្រកបអាជីវកម្មនៅលើទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុញ្ញាត ដូចមានចែងនៅក្នុងឯកសារពាក្យស្នើសុំអាជ្ញាបណ្ណ។

ប្រការ ១០.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណត្រូវផ្តល់របាយការណ៍ប្រចាំឆមាសស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃរបស់ខ្លួនមកធនាគារជាតិនៃកម្ពុជាឱ្យបានមុនថ្ងៃទី១៥ នៃខែដែលត្រូវរាយការណ៍។

ធនាគារជាតិនៃកម្ពុជានឹងចុះត្រួតពិនិត្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលធ្វើអាជីវកម្មនេះតាមការចាំបាច់។

ប្រការ ១១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលស្ថិតនៅក្រោមប្រកាសនេះ ត្រូវចូលរួមសហការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដើម្បីធានាបាននូវប្រសិទ្ធភាព ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រទេសកម្ពុជា។

ប្រការ ១២.-

ក្នុងករណីបញ្ឈប់សកម្មភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុន ត្រូវដាក់ពាក្យស្នើសុំបញ្ឈប់អាជីវកម្មរបស់ខ្លួនដោយបញ្ជាក់ពីមូលហេតុ និងភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណច្បាប់ដើមមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃមុនបញ្ឈប់អាជីវកម្ម។

ប្រការ ១៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលមានអាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលមិនបានធ្វើរបាយការណ៍តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជានឹងត្រូវរងការពិន័យដូចមានចែងក្នុងប្រការ ១៤ ខាងក្រោម។

ប្រការ ១៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃជូនធនាគារជាតិនៃកម្ពុជាលើសពីរយៈពេលកំណត់ ដូចមានចែងក្នុងប្រការ ១០ នឹងត្រូវរងការពិន័យជាប្រាក់ចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃ រយៈពេល ១៥ថ្ងៃ។

ករណីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនមិនបានធ្វើរបាយការណ៍ស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ និងមិនបង់ប្រាក់ពិន័យខាងលើទាន់ពេលវេលា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះនឹងត្រូវរងការព្យួរអាជ្ញាបណ្ណមិនឱ្យធ្វើប្រតិបត្តិការរយៈពេល ១ខែ។ នៅក្នុងរយៈពេលព្យួរនេះ ប្រសិនបើមានបំណងធ្វើប្រតិបត្តិការឡើងវិញ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះត្រូវដាក់ពាក្យសុំធ្វើអាជីវកម្មជាថ្មី និងបង់ប្រាក់ពិន័យពាក់ព័ន្ធ។ ប្រសិនបើមិនបានដាក់ពាក្យសុំធ្វើអាជីវកម្មឡើងវិញនៅក្នុងរយៈពេលព្យួរទេ នៅពេលផុតរយៈពេលព្យួរអាជ្ញាបណ្ណ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះនឹងត្រូវរងការដកហូតអាជ្ញាបណ្ណ។

ព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនស្តីពីការទទួលបានអាជ្ញាបណ្ណ រងការព្យួរអាជ្ញាបណ្ណ ឬដកហូតអាជ្ញាបណ្ណ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ប្រការ ១៥.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលបាននាំចេញ-នាំចូលលោហធាតុ និងត្បូងថ្ម មានតម្លៃ ដោយមិនបានសុំប្រតិវេទន៍ពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ក្រុមហ៊ុននោះនឹងត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលផ្តល់ព័ត៌មានខុស ឬបំភាន់នឹងត្រូវពិន័យ ជាប្រាក់ ១០.០០០.០០០ រៀល (ដប់លានរៀល) និង/ឬ ដកហូតអាជ្ញាបណ្ណ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ បទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬមិនបានធ្វើតាមការដាស់តឿន ឬមិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចរងទណ្ឌកម្មខាងវិន័យណាមួយ ដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមធ្វើប្រតិបត្តិការក្នុងរយៈពេលណាមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា
- ព្យួរអាជ្ញាបណ្ណក្នុងរយៈពេលណាមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា
- ដកហូតអាជ្ញាបណ្ណជាស្ថាពរ

ប្រការ ១៦.-

ប្រកាសលេខ ធ៩-០៩-២៦២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការផ្តល់អាជ្ញាបណ្ណ ប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៧.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ អគ្គបេឡា ប្រធាន នាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាម ភារកិច្ចរៀងៗខ្លួន។

ប្រការ ១៨.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១១-២៤១ ប្រ.ក

ប្រកាស
ស្តីពី
អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុ សំដៅផ្តល់គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២.-

គ្រឹះស្ថានធនាគារ អាចធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ធនាគារដូចមានចែងក្នុងមាត្រា ២ ចំណុចទី១ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមាត្រា ៣៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគាររួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

គ្រឹះស្ថានផ្សេងទៀតដែលមានបំណងផ្តល់ឬកំពុងផ្តល់ផលិតផលភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌសម្រាប់ស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ដោយប្រកាសដោយឡែក។

ប្រការ ៣.-

ភតិសន្យាហិរញ្ញវត្ថុ សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ៖

១. ភតិក:បញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ។

២. ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដើម្បីជួលឱ្យភតិក:។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់៖

១. ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបានឬមិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូលឬការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

២. ភតិក:មានឬពុំមានជម្រើសឬក្រោយមកទទួលយកជម្រើសថាទិញឬបន្តជួលចលនវត្ថុមួយរយៈពេលបន្តែមទៀត។

ប្រការ ៤.-

ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានបំណងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុត្រូវ៖

១. មានស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការរឹងមាំ អនុបាតសាធនភាព និងអនុបាតផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

២. មានធនធានមនុស្ស និងសម្ភារៈគ្រប់គ្រាន់សម្រាប់ដំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។

៣. មានផែនការអាជីវកម្មច្បាស់លាស់ជាលាយលក្ខណ៍អក្សរសម្រាប់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាននោះ។ ផែនការនេះរួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

ក. គោលនយោបាយ និងនីតិវិធីសម្រាប់ប្រតិបត្តិការអាជីវកម្ម

ខ. សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរាយការណ៍សមស្រប។ សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងហោចណាស់ត្រូវមាន៖

- ការវាយតម្លៃពីលំហូរសាច់ប្រាក់
- ប្រព័ន្ធវិភាគឥណទាន នីតិវិធីកំណត់កម្រិតឥណទានអតិថិជន និងនីតិវិធីកំណត់ប្រាក់កក់ និងកម្រៃផ្សេងៗ
- នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជា ការទិញចលនវត្ថុ អ្នកផ្គត់ផ្គង់ ការគ្រប់គ្រងចលនវត្ថុដែលរឹបអូស ការតាមដាន និងត្រួតពិនិត្យចលនវត្ថុ ការវាយតម្លៃនៃតម្លៃសេសសល់របស់ចលនវត្ថុ និង
- ឯកទេសកម្ម និងការប្រមូលផ្តុំសមស្រប។

ប្រការ ៥.-

ចលនវត្ថុសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុសំដៅដល់ទ្រព្យសម្បត្តិគ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែ ដី និងអគារ។

លុះត្រាតែមានច្បាប់ ឬកិច្ចព្រមព្រៀងចែងផ្សេងពីនេះ ចលនវត្ថុដែលត្រូវបានភ្ជាប់ ឬត្រូវបានតម្លើងនៅក្នុងអគារ ឬលើដី ឬចលនវត្ថុដទៃទៀត ត្រូវរក្សាអត្តសញ្ញាណដាច់ដោយឡែករបស់ខ្លួន និងមិនក្លាយទៅជាចំណែកនៃដី ឬអគារ ឬចលនវត្ថុដទៃទៀតដែលត្រូវបានភ្ជាប់ជាមួយនោះទេ។

ប្រការ ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា គ្រប់គ្រឹះស្ថានធនាគារ

និងហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១១-២៤២ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

សម្រេច
ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដោយកំណត់លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណនិងដាក់បទប្បញ្ញត្តិចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

ប្រការ ២.- វិសាលភាព

ប្រកាសនេះ គ្របដណ្តប់លើប្រតិបត្តិការរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាគ្រឹះស្ថានដែលធ្វើតែអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប៉ុណ្ណោះ។

ប្រការ ៣.- ដើមទុនចុះបញ្ជី

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយដើមទុនចុះបញ្ជីនេះត្រូវតែជាដើមទុនបង់ជម្រះ។

ជំពូកទី ២
នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

ប្រការ ៤.- ការដាក់ពាក្យសុំអាជ្ញាបណ្ណ

១. គ្មានបុគ្គលណាម្នាក់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

២. ពាក្យសុំអាជ្ញាបណ្ណត្រូវធ្វើឡើងដោយបុគ្គល ដែលមានសិទ្ធិអំណាចនៅក្នុងក្រុមហ៊ុន (នាយក គ្រប់គ្រង ឬបុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាច) និងបង្ហាញព័ត៌មានដូចខាងក្រោម៖

ក. កិច្ចព្រមព្រៀងចូលភាគហ៊ុន ឬកិច្ចព្រមព្រៀងរបស់ភាគទុនិក

ខ. នាម ឬនាមករណ៍របស់ក្រុមហ៊ុន

គ. អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស

ឃ. រូបភាពគតិយុត្ត និងលក្ខន្តិក:របស់ក្រុមហ៊ុន ឬឯកសារផ្សេងទៀត

ង. ប្រភេទមូលបត្រតំណាងឱ្យដើមទុន និងទំនាក់ទំនងរវាងការកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិបោះឆ្នោត

ច. ចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបោះផ្សាយ និងដើមទុនបង់ជម្រះ

ឆ. ការបែងចែងភាគហ៊ុន សិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀង ដែលអាចមានរវាងភាគទុនិកដែលធ្វើសកម្មភាពក្នុងការដឹកនាំគោលនយោបាយរបស់ក្រុមហ៊ុន

ជ. ភាគទុនិកដែលកាន់កាប់ ៥% (ប្រាំភាគរយ) នៃសិទ្ធិបោះឆ្នោត ឬលើស ត្រូវផ្តល់ព័ត៌មាន ដូចមាន រៀបរាប់នៅក្នុងប្រការ ១៣ នៃប្រកាសនេះ

ឈ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច១រូប (មួយរូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានតាម ឧបសម្ព័ន្ធ២ ព្រមទាំងមានបញ្ជាក់លិខិតផ្តោលទោសមួយច្បាប់ផង

ញ. អត្តសញ្ញាណរបស់បុគ្គលទទួលខុសត្រូវក្នុងការចេញសេចក្តីសម្រេច។ បុគ្គលនោះត្រូវបំពេញប្រវត្តិរូប និងបញ្ជាក់ថាខ្លួនមិនត្រូវបានហាមឃាត់នៅក្នុងប្រការ ១៤ នៃប្រកាសនេះទេ។ បុគ្គលនោះត្រូវមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មភតិសន្យា និងឥណទានយ៉ាងតិច៣ឆ្នាំ (បីឆ្នាំ)

ដ. ប្រសិនបើនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនេះ ជាក្រុមហ៊ុនដែលបានបង្កើតរួចហើយ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីអាជីវកម្ម ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុបញ្ជាក់ដោយស្នងការគណនី សម្រាប់ប្រតិបត្តិការរយៈពេល៣ឆ្នាំ (បីឆ្នាំ)

ឋ. ភស្តុតាងសមស្របផ្សេងទៀត ដូចជា៖

- ដំណើរការគ្រប់គ្រងហានិភ័យ ដូចជា ការកំណត់អត្តសញ្ញាណ ការវាស់វែង ការតាមដាននិងត្រួតពិនិត្យហានិភ័យ
- ផែនការគ្រប់គ្រង៖
  - ហានិភ័យសន្ទនីយភាព អត្រាការប្រាក់ និងកាលវិសាន (ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម)
  - ហានិភ័យឥណទាន
  - ហានិភ័យប្រតិបត្តិការ
  - ហានិភ័យទីផ្សារ
  - ហានិភ័យទ្រព្យសកម្ម
  - ហានិភ័យឯកសារ (Documentation Risk)
  - ហានិភ័យប្រមូលផ្តុំ (Concentration Risk)
  - ហានិភ័យដទៃទៀត ដែលអាចកើតមានចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅពេលធ្វើប្រតិបត្តិការភតិសន្យាតាមផែនការអាជីវកម្ម។

ប្រការ ៥.- សំណើសុំផ្លាស់ប្តូរព័ត៌មាន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា ដូចជា៖

ក. ការផ្លាស់ប្តូរនាមករណ៍

ខ. ការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុន

គ. ការកែប្រែវិសាលភាពអាជីវកម្ម

ឃ. ការផ្លាស់ប្តូរដើមទុនចុះបញ្ជី

ង. ការកែប្រែលក្ខន្តិក:

ច. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

ឆ. ការផ្លាស់ប្តូរអភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់

ជ. ការរួមបញ្ចូល ឬការបែងចែកឬ

ឈ. បញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៣
អនុម័តផ្តល់អាជ្ញាបណ្ណ និង ការយកកម្រៃ

ប្រការ ៦.- ការផ្តល់លិខិតអនុញ្ញាតជាគោលការណ៍

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល៣ខែ (បីខែ) ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។ ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់លក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើពុំបានអនុវត្តតាមពេលវេលាកំណត់ ឬពុំបានសុំពន្យារពេល លិខិតអនុញ្ញាតនោះត្រូវចាត់ទុកជាមោឃៈ។

ប្រការ ៧.- អនុម័តផ្តល់អាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ជាមុនសិន មុននឹងទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៨.- សុពលភាពនៃអាជ្ញាបណ្ណ

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានសុពលភាពរយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) ហើយអាចសុំបន្តជាថ្មីទៀតបាន។

ប្រការ ៩.- សោហ៊ុយសិក្សាឯកសារ និងសោហ៊ុយអាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់សោហ៊ុយសិក្សាឯកសារចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។ *(ត្រូវបានជំនួសដោយប្រការ ៦ ចំណុច ២-ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំដូចខាងក្រោម៖

- ៤.000.000 រៀល (បួនលានរៀល) សម្រាប់ស្នាក់ការកណ្តាល *(ត្រូវបានជំនួសដោយប្រការ ៤ ចំណុច ៦-ក នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*
- ២.000.000រៀល (ពីរលានរៀល) សម្រាប់មួយសាខា *(ត្រូវបានជំនួសដោយប្រការ ៤ ចំណុច ៦-ខ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

សម្រាប់ក្រុមហ៊ុនដែលបង្កើតនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបង់តាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

ជំពូកទី ៤
វិធានប្រុងប្រយ័ត្ន

ប្រការ ១០.- ការបង់ដើមទុន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់ជម្រះ ១០០% (មួយរយភាគរយ) នៃដើមទុនចុះបញ្ជីទៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមប្រតិបត្តិការ។

ក្រុមហ៊ុនត្រូវតម្កល់ប្រាក់ចំនួន ៥% (ប្រាំភាគរយ) នៃដើមទុនចុះបញ្ជី ដោយគ្មានការប្រាក់នៅក្នុងគណនីអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជានឹងប្រគល់ប្រាក់តម្កល់ឱ្យក្រុមហ៊ុនវិញ តែក្នុងករណីជម្រះបញ្ជី និងគ្មានបំណុល។

ប្រការ ១១.- កាតព្វកិច្ចរាយការណ៍

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមកាតព្វកិច្ចរាយការណ៍ ដូចខាងក្រោម៖

១. ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ស្របតាមស្តង់ដារគណនេយ្យសម្រាប់អាជីវកម្មសហគ្រាស និងបញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍តុល្យការ របាយការណ៍ចំណូលនិងចំណាយ និងរបាយការណ៍ដទៃទៀតតាមតម្រូវការរបស់អាជ្ញាធរត្រួតពិនិត្យ។ តំណាងស្របច្បាប់ និងអ្នកទទួលខុសត្រូវដទៃទៀតនៃក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

៣. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) ដំបូងនៃខែបន្ទាប់។

៤. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍សវនកម្មប្រចាំឆ្នាំ បញ្ជាក់ដោយសវនករដែលបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល៤ខែ (បួនខែ) ដំបូងនៃឆ្នាំបន្ទាប់។

ប្រការ ១២.- បទប្បញ្ញត្តិប្រុងប្រយ័ត្ន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៥
រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

ប្រការ ១៣.- ភាគទុនិក

ភាគទុនិកត្រូវផ្តល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក៖

ក. ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាននៃស្នាក់ការកណ្តាល របាយការណ៍សវនកម្មហិរញ្ញវត្ថុ លក្ខន្តិក: និងព័ត៌មានផ្សេងទៀតដែលតម្រូវដោយអាជ្ញាធរត្រួតពិនិត្យ

ខ. ក្នុងករណីជារូបវន្តបុគ្គល ត្រូវរៀបរាប់ គោត្តនាម នាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត ដោយរៀបរាប់លម្អិតអំពីនីតិវិធីនៃការទិញភាគហ៊ុន។ ប្រសិនបើភាគទុនិកជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមនៃទុនវិនិយោគ។

៣. ការបញ្ជាក់ពីចំនួនភាគរយនៃភាគហ៊ុនដែលកាន់កាប់ដោយភាគទុនិកម្នាក់ៗ ក្នុងករណីចាំបាច់ ភាគទុនិកត្រូវ៖

ក. រៀបរាប់អំពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនហូលឌីង (Intermediate Holding Companies) ដោយផ្តល់ជាភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត

ខ. ធ្វើបញ្ជីអ្នកគ្រប់គ្រងសំខាន់ៗដែលជាភាគទុនិក។

៤. ប្រសិនបើភាគទុនិកនោះជាផ្នែកនៃសម្ព័ន្ធមួយ ភាគទុនិកត្រូវ៖

ក. រៀបរាប់អំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ រួមជាមួយអង្គការលេខផង

ខ. បញ្ជាក់អំពីចំនួនភាគហ៊ុននៅក្នុងគ្រឹះស្ថានឥណទានផ្សេងទៀត ទាំងនៅក្នុងប្រទេស និងនៅបរទេស។

៥. ចំណងទាក់ទងរវាងភាគទុនិក និងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៦. នីតិវិធីសវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅរបស់ភាគទុនិក។

៧. សារតារនៃអំពើល្មើសរបស់ភាគទុនិកក្នុងរយៈពេល១០ឆ្នាំ (ដប់ឆ្នាំ) កន្លងមក ប្រសិនបើមាន។

៨. គោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងក្រុមហ៊ុន ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ។

៩. ទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិក និងអ្នកដាក់ពាក្យស្នើសុំ។

១០. ទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងភតិសន្យាហិរញ្ញវត្ថុរបស់ភាគទុនិកនៅព្រះរាជាណាចក្រកម្ពុជា។

១១. គណនីរបស់ភាគទុនិក ឬក្រុមហ៊ុនមេរបស់ខ្លួន សំរាប់រយៈពេល៣ឆ្នាំ (បីឆ្នាំ) ចុងក្រោយ ព្រមទាំងព្យាករណ៍សម្រាប់ឆ្នាំនេះ (រួមមានព័ត៌មានគួបសរុបផង ប្រសិនបើមាន)។ ក្នុងករណីភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

១២. អភិបាលកិច្ចក្រុមហ៊ុន (រចនាសម្ព័ន្ធចាត់តាំង សន្និបាតប្រចាំឆ្នាំរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាត្រួតពិនិត្យ និងនាយកជាន់ខ្ពស់) ដោយបែងចែកភារកិច្ចឱ្យបានច្បាស់លាស់ ធានាប្រតិបត្តិការដោយឯករាជ្យ និងប្រព័ន្ធត្រួតពិនិត្យមានតម្លាភាព ព្រមទាំងបង្កើតយន្តការគោលនយោបាយប្រកបដោយប្រសិទ្ធភាព យន្តការលើកទឹកចិត្ត និងរក្សាបុគ្គលិក។

១៣. គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ប្រការ ១៤.- សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល និងនាយក

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាត្រួតពិនិត្យ ឬនាយករបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬដឹកនាំ គ្រប់គ្រង ឬដំណើរការក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទ៖

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- គ្រប់គ្រងមិនបានត្រឹមត្រូវក្នុងតួនាទីខ្លួនជាអ្នករក្សាប្រាក់បញ្ញើ
- គៃបន្លំមូលនិធិ ឬមូលបត្រ ឬក្ស័យធន
- ធ្វើព្រឺទ្ធិកម្ម
- ការសម្អាតប្រាក់
- ក្លែង ឬ/និង ប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់។

៣. ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈឹម ដែលមានចែងនៅក្នុងចំណុច ១ និង ២ ខាងលើ។

៤. ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្ស័យធន ឬការជម្រះបំណុលតាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ។

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ។

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាបណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល និងនាយកដែលត្រូវបានតែងតាំង ត្រូវផ្តល់ព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ។

ជំពូកទី ៦
វិធានការ និង ការពិន័យ

ប្រការ ១៥.- សិទ្ធិអំណាចរបស់អាជ្ញាធរត្រួតពិនិត្យ

១. ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការផ្តល់ ព្យួរ ដកហូតអាជ្ញាបណ្ណ ដាក់បទប្បញ្ញត្តិ បទបញ្ជា និងការណែនាំសម្រាប់ត្រួតពិនិត្យអាជីវកម្មរបស់ក្រុមហ៊ុន តាមការចាំបាច់។

២. ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាបណ្ណ ដោយផ្អែកលើមូលហេតុមួយ ឬច្រើន ដូចខាងក្រោម៖

ក. ក្រុមហ៊ុនមិនបានចាប់ផ្តើមអាជីវកម្មក្នុងអំឡុងពេលបីខែ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណ

ខ. ក្រុមហ៊ុនបំពានច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្រប់គ្រងលើប្រតិបត្តិការក្រុមហ៊ុន

គ. ក្រុមហ៊ុនមិនអាចប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ឃ. ក្រុមហ៊ុនផ្អាកអាជីវកម្មភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា

ង. ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីអាជ្ញាធរត្រួតពិនិត្យ

ច. ក្រុមហ៊ុនអសាធនភាព ឬក្សីយធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬក្នុងដំណាក់កាលតែងតាំងអភិបាលបណ្តោះអាសន្នតាមផ្លូវតុលាការ។

ប្រការ ១៦.- វិធានការចំពោះក្រុមហ៊ុន

១. ក្នុងករណីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានប្រព្រឹត្តល្មើសនឹងច្បាប់ភតិសន្យាហិរញ្ញវត្ថុ ឬបទប្បញ្ញត្តិជាធរមាន ធនាគារជាតិនៃកម្ពុជានឹងដាក់ទណ្ឌកម្មខាងវិន័យចំពោះក្រុមហ៊ុននោះយោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ។

២. ប្រសិនបើក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជាអាចចាត់វិធានការកែតម្រូវក្នុងរយៈពេលកំណត់មួយ។ ក្នុងករណីក្រុមហ៊ុនមិនអាចអនុវត្តបានតាមពេលកំណត់ ឬសកម្មភាពរបស់ក្រុមហ៊ុនអាចប៉ះពាល់ដល់ស្ថិរភាពប្រតិបត្តិការ ឬប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់អតិថិជន ធនាគារជាតិនៃកម្ពុជានឹងចាត់វិធានការ ដូចជា ផ្អាកដំណើរការអាជីវកម្ម និងកំណត់សិទ្ធិរបស់ភាគទុនិក ជាដើម ផ្អែកទៅលើស្ថានភាពជាក់ស្តែង និងស្របតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ ១៧.- ពិន័យអន្តរការណ៍

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលមិនបានគោរពតាមកាលកំណត់នៃការបញ្ជូនរបាយការណ៍នឹងត្រូវពិន័យដូចខាងក្រោម៖

ក. ចំពោះរបាយការណ៍៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់
▪ ពី ១ ទៅ ៥ ថ្ងៃ	៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ
▪ ពី ៦ ទៅ ១០ ថ្ងៃ	៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ
▪ ពី ១១ ទៅ ១៥ ថ្ងៃ	៧០០.០០០ រៀល (ប្រាំពីររយពាន់រៀល) ក្នុងមួយថ្ងៃ។

លើសពី១៦ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

ខ. ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់
▪ ពី ១ ទៅ ៥ ថ្ងៃ	៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ
▪ ពី ៦ ទៅ ១០ ថ្ងៃ	៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ។

លើសពី១១ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

២. ការល្មើសនឹងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យទឹកប្រាក់ ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

ប្រការ ១៨.-

បុគ្គល ឬក្រុមហ៊ុនដែលបាន និងកំពុងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុដោយមិនមានអាជ្ញាបណ្ណ ត្រូវស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល៦ខែ (ប្រាំមួយខែ) គិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

ប្រការ ១៩.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២០.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធទី ១

គំរូលិខិត
សូមគោរពជូន ឯកឧត្តមទេសាភិបាល ធនាគារជាតិនៃកម្ពុជា

ឯកឧត្តមជាទីគោរព

យោងតាមការតែងតាំងនាយកក្រុមហ៊ុន (ឈ្មោះក្រុមហ៊ុន) ដែលខ្ញុំនឹងចូលកាន់តំណែងជា ..... ខ្ញុំសូមជូនភ្ជាប់មកជាមួយនូវព័ត៌មាន (រួមមានប្រវត្តិសង្ខេប និងសំណួរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២) តាមប្រការ ១៣ នៃប្រកាសនេះ។

ខ្ញុំសូមធានាថាព័ត៌មាននេះពិតជាត្រឹមត្រូវ និងពេញលេញ ឆ្លើយតបទៅនឹងតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេស ខ្ញុំសូមធានាអះអាងថា ខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងប្រការ ១៤ នៃប្រកាសនេះទេ។

ខ្ញុំសូមសន្យាថានឹងផ្តល់ព័ត៌មានស្តីពីការផ្លាស់ប្តូរណាមួយ ដែលទាក់ទងទៅនឹងព័ត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកក្រុមហ៊ុន ខ្ញុំសូមធានាថា នឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មានដែលទាក់ទងនឹងការចាត់តាំងរដ្ឋបាលនិងគណនេយ្យ ស្ថានភាពហិរញ្ញវត្ថុជាពិសេសចំពោះគុណភាពនៃទ្រព្យសម្បត្តិភតិសន្យា និងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់។

សូម ឯកឧត្តម ទេសាភិបាល មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីខ្ញុំ៕

ហត្ថលេខា

ឧបសម្ព័ន្ធទី ២

ជីវប្រវត្តិ និង ការសាកសួរទៅវិញ៖ ព័ត៌មាន អំពីឯកត្តជន ឬ ជនដែលបម្រុងក្លាយ ទៅជា គណៈនាយក ភាគទុនិក នាយកចាត់ការ របស់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

១. គោត្តនាម

.....

២. នាមខ្លួន

.....

៣. ឈ្មោះហៅក្រៅ

.....

៤.១ សូមរៀបរាប់បំពេញលើគំរូនេះនូវនីតិសម្បទារបស់លោក ឧទាហរណ៍ដូចជា គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក ភាគទុនិក ឬ នាយកចាត់ការ ឬ បុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

.....

.....

.....

.....

៤.២ សូមរៀបរាប់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈតួនាទីទាំងនេះ

.....

.....

.....

.....

៤.៣ ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្ហាត់បង្ហាញរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

.....

.....

.....

.....

៤.៤ សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យអ្នកដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនសុំនោះ។

.....

.....

.....

.....

៥. អាសយដ្ឋានផ្ទាល់ខ្លួន

.....

.....

.....

.....

៦. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីអំឡុង ៥ឆ្នាំមុន

.....

.....

.....

.....

៧. កាលបរិច្ឆេទ (ថ្ងៃ/ ខែ/ ឆ្នាំ) និងទីកន្លែងកំណើត (គិតទាំងស្រុកនិងក្រុង)

.....

.....

៨. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ សញ្ជាតូបនីយកម្ម ការរៀបអាពាហ៍ពិពាហ៍)

.....

.....

.....

.....

៩. ឈ្មោះ និង អាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

.....

.....

.....

.....

១០. ចូរបញ្ជាក់ពី កម្រិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

.....

.....

.....

.....

១១.១ ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពី ឈ្មោះ អាសយដ្ឋាន របស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

.....

.....

.....

.....

១១.២ សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុនព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

.....

.....

.....

.....

១១.៣ សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នក ចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយឬជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

.....

.....

.....

.....

១២. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋាន: ជានាយក ជាភាគទុនិក ឬជាអ្នកចាត់ការ ធ្លាប់ទទួលឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ បើមាន សូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

.....

.....

.....

.....

១៣. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

.....

.....

.....

.....

១៤. តើខ្លួនលោក-លោកស្រី ធ្លាប់ត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

.....

.....

.....

.....

១៥. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តដែរឬទេ នៅប្រទេសណាតើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

.....

.....

.....

.....

១៦. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើសនៅប្រទេសណា តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ តើធ្លាប់ត្រូវបានគេចោទប្រកាន់ ឬរកឃើញនូវកំហុសនៃការសម្អាតប្រាក់ដែរឬទេ បើសិនជាមាន សូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

.....

.....

.....

.....

១៧. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយទេ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

.....

.....

.....

.....

១៨. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលម្អិតស្តីពី ទ្រព្យសកម្មនិងទ្រព្យអកម្ម។

.....

.....

.....

.....

១៩. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទី ឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

.....

.....

.....

.....

២០. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួន ដូចមានបញ្ជាក់ក្នុងសំណួរ ៥.១ សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្ត។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធដោយបង្វែរព័ត៌មានពិត ឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

ចូរកត់សម្គាល់ឱ្យបានច្បាស់ថា៖ រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្ត។

សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយ ឬខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណប្រកបអាជីវកម្ម។

ខ្ញុំសូមបញ្ជាក់ជូនជាឧទ្ធារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៌ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេងឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពីរឿងរ៉ាវ ឬហេតុការណ៍ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាន នៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

ឈ្មោះ

.....

មុខងារ និងឋានៈដែលទទួលបន្ទុក

.....

ហត្ថលេខា.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ធ៩-០១០-១៥១ ប្រ.ក

ប្រកាស
ស្តីពី
អ្នកដំណើរការតតិយភាគី

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

គោលបំណងរបស់ប្រកាសនេះគឺដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារ ដែលបានកំណត់ដោយច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "ធនាគារ" ដើម្បីប្រគល់មួយផ្នែក ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ ឱ្យអ្នកដំណើរការតតិយភាគីមួយឬច្រើន ដូចដែលបានព្រមព្រៀងគ្នារវាងធនាគារ និងអ្នកដំណើរការតតិយភាគីទាំងនោះ និងដែលត្រូវមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាស្របតាមមាត្រា ២០៤ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

ប្រការ ២.-

អ្នកដំណើរការតតិយភាគី (Third-Party Processor) សំដៅដល់បុគ្គលដែលធនាគារបានប្រគល់សិទ្ធិឱ្យធ្វើប្រតិបត្តិការលើមួយផ្នែក ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ធនាគារនោះ។

ការផ្តល់សេវាពីខាងក្រៅ (Outsourcing) សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែកដែលធនាគារបានព្រមព្រៀងជាមួយបុគ្គល ឬធនាគារមួយផ្សេងទៀតដើម្បីធ្វើសេវានោះជំនួសខ្លួន។

ជំពូក ២
សេវាប្រតិបត្តិការទូទាត់សងប្រាក់

ប្រការ ៣.-

១. បុគ្គលដែលមិនមែនជាធនាគារមិនអាចធ្វើអាជីវកម្មពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សងប្រាក់ ឬតាំងខ្លួនឯងជាអ្នកផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់បានឡើយ លុះត្រាតែបុគ្គលនោះ៖

ក. ត្រូវបានធនាគារអនុញ្ញាតឱ្យធ្វើជាអ្នកដំណើរការតតិយភាគីរបស់ខ្លួនតាមការព្រមព្រៀងគ្នា និង

ខ. បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា

២. នៅពេលទទួលបានការអនុញ្ញាតពីធនាគារ និងទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា អ្នកដំណើរការតតិយភាគីអាចផ្តល់សេវាមួយផ្នែក ឬច្រើនផ្នែកជំនួសឱ្យធនាគារ ដូចមានចែងនៅក្នុងមាត្រា ២០៣ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដូចខាងក្រោម៖

ក. ជាអ្នកទំនាក់ទំនង

ខ. ជាអ្នកជាត់ទាត់អន្តរធនាគារដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

គ. ជាអ្នកគ្រប់គ្រង ឬជាអ្នកធ្វើប្រតិបត្តិការលើគណនីអតិថិជនរបស់ធនាគារ និង/ឬ

ឃ. ដើរតួជាកន្លែងផ្ញើ និងទទួលបញ្ជាទូទាត់ដែលត្រូវបានផ្ញើ ឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការផ្ញើ និងទទួលបញ្ជាទូទាត់។ បន្ថែមលើនេះ៖

ង. ជាអ្នកផ្តល់សេវាផ្ទេរប្រាក់តាមទូរស័ព្ទចល័ត ឬតាមមធ្យោបាយផ្សេងទៀត

ច. ជាអ្នកផ្តល់សេវាជាត់ទាត់ និងទូទាត់ ការទូទាត់សងប្រាក់ដោយប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ

ប្រការ ៤.-

១. អ្នកដំណើរការតតិយភាគីអាចគ្រប់គ្រង និងធ្វើប្រតិបត្តិការជំនួសឱ្យធនាគារមួយ ឬច្រើននូវប្រព័ន្ធទូទាត់សងប្រាក់សម្រាប់៖

ក. ប្រតិបត្តិការទូទាត់សងប្រាក់ និងការដកសាច់ប្រាក់

ខ. ការជាត់ទាត់ និងទូទាត់ នៅក្នុងប្រទេសកម្ពុជាសម្រាប់ឧបករណ៍ទូទាត់សងប្រាក់ជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

២. ក្នុងករណីនេះ អ្នកដំណើរការតតិយភាគីត្រូវតែបានទទួលការអនុញ្ញាតឱ្យធ្វើសេវាបែបនេះដោយធនាគារមួយ និងធនាគារទាំងអស់ដែលចូលរួមនៅក្នុងប្រព័ន្ធទូទាត់ ហើយការទទួលខុសត្រូវរបស់ធនាគារនីមួយៗ ត្រូវតែបានបែងចែកឱ្យបានត្រឹមត្រូវ។

ប្រការ ៥.-

អ្នកដំណើរការតតិយភាគីដែលគ្រប់គ្រងប្រព័ន្ធទូទាត់នឹងត្រូវស្ថិតនៅក្រោមប្រកាសស្តីពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ប្រកាសស្តីពីការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ និងប្រកាសស្តីពីប្រតិបត្តិការនៃគណនីទូទាត់ដែលមានស្រាប់របស់ធនាគារជាតិនៃកម្ពុជា និងវិធានការពាក់ព័ន្ធផ្សេងៗទៀតប្រសិនបើមាន។

ជំពូក ៣
ការស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកដំណើរការតតិយភាគីរបស់ធនាគារ

ប្រការ ៦.-

១. មុនពេលអនុញ្ញាតឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាជំនួសឱ្យអ្នកដំណើរការតតិយភាគី។ ពាក្យស្នើសុំនេះត្រូវតែបញ្ជាក់ ឬមានព័ត៌មានដូចតទៅ៖

ក. ឈ្មោះផ្លូវការ អាសយដ្ឋានរស់នៅ និងអាសយដ្ឋានធ្វើអាជីវកម្មរបស់អ្នកដំណើរការតតិយភាគី និងសម្មតិនាមឬឈ្មោះពាណិជ្ជកម្មដែលអ្នកដំណើរការតតិយភាគីបានប្រើប្រាស់ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនជំនួសឱ្យធនាគារ និងការពិពណ៌នាអំពីស្ថានភាពស្របច្បាប់របស់ខ្លួន។

ខ. ការពិពណ៌នាអំពីសេវាប្រតិបត្តិការទូទាត់សងប្រាក់ដែលពីមុនអ្នកដំណើរការតតិយភាគីធ្លាប់បានផ្តល់នៅក្នុងនិងក្រៅប្រទេសកម្ពុជាប្រសិនបើមាន និងសេវាប្រតិបត្តិការទូទាត់សងប្រាក់ ដែលអ្នកដំណើរការតតិយភាគីមានបំណងផ្តល់នៅក្នុងប្រទេសកម្ពុជាជំនួសឱ្យធនាគារ។

គ. ការពិពណ៌នាអំពីមធ្យោបាយស្របច្បាប់ដែលត្រូវអនុវត្ត ដើម្បីការពារមូលនិធិរបស់អតិថិជនពីហានិភ័យណាមួយដែលបណ្តាលមកពីការផ្តល់សេវាពីខាងក្រៅនេះ ការប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងកាតព្វកិច្ចស្គាល់អតិថិជនរបស់ខ្លួន ព្រមទាំងវិធានការនានាដើម្បីឱ្យអតិថិជនបានដឹងអំពីតួនាទីរបស់អ្នកដំណើរការតតិយភាគីនៅក្នុងសេវាប្រតិបត្តិការទូទាត់សងប្រាក់។ ក្នុងករណីប្រើប្រាស់ភ្នាក់ងារ ចាំបាច់ត្រូវពណ៌នាអំពីមុខងារ និងស្ថានភាពស្របច្បាប់របស់ភ្នាក់ងារទាំងនោះ។

២. ពាក្យស្នើសុំត្រូវតែភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

- សេចក្តីសម្រេចរបស់គណៈគ្រប់គ្រងធនាគារសាមីដែលអនុញ្ញាតឱ្យធនាគារប្រគល់សេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ខ្លួនមួយផ្នែក ឬច្រើនផ្នែកទៅឱ្យអ្នកដំណើរការតតិយភាគី
- កិច្ចព្រមព្រៀងរវាងធនាគារ និងអ្នកដំណើរការតតិយភាគី ដើម្បីប្រគល់និងទទួលសេវានេះ
- ការអនុញ្ញាតពីក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាល ប្រសិនបើមាន ដើម្បីអនុញ្ញាតឱ្យសាខា ឬបុត្តសម្ព័ន្ធរបស់ខ្លួនធ្វើជាអ្នកដំណើរការតតិយភាគី
- លិខិតធានារបស់ធនាគារដែលសន្យាទទួលខុសត្រូវទាំងស្រុងលើសកម្មភាពរបស់អ្នកដំណើរការតតិយភាគី

៣. ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយ ចំនួន ២.០០០.០០០រៀល (ពីរលានរៀល)។ *(ត្រូវបានជំនួសដោយប្រការ ៦ ចំណុច ៥ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

៤. ធនាគារត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន ១០.០០០.០០០ រៀល (ដប់លានរៀល) ជំនួសឱ្យអ្នកដំណើរការតតិយភាគីឱ្យបានត្រឹមថ្ងៃទី១៥ ខែមករា។ *(ត្រូវបានជំនួសដោយប្រការ ៤ ចំណុច ១១ និង ប្រការ ៥ នៃប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*

៥. ចំពោះធនាគារដែលស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកដំណើរការតតិយភាគីនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

៦. ក្នុងករណីការបង់សោហ៊ុយអាជ្ញាបណ្ណមានការយឺតយ៉ាវ ធនាគារពាក់ព័ន្ធត្រូវទទួលរងនូវការជាកពិន័យដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់ ៣០ ថ្ងៃ (សាមសិបថ្ងៃ)។

ប្រការ ៧.-

១. អាជ្ញាបណ្ណមានសុពលភាពសម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីពេលបានចេញឱ្យ។ អាជ្ញាបណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែអ្នកដំណើរការតតិយភាគីធ្វើសកម្មភាពស្របតាមច្បាប់និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមានត្រូវបានដោះស្រាយ។

២. ពាក្យស្នើសុំអាជ្ញាបណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាបណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព។ ក្នុងករណីដែលការស្នើសុំនោះមានបញ្ចូលសេវាថ្មី ឬមានវិធីខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ធនាគារជាតិនៃកម្ពុជាត្រូវពិចារណាលើបញ្ហានេះដោយចាត់ទុកថាជាការស្នើសុំអាជ្ញាបណ្ណថ្មី។

៣. ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើនេះទេ ធនាគារត្រូវទទួលរងការជាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ។

៤. ធនាគារដែលនៅតែមិនអាចគោរពតាមកាលបរិច្ឆេទកំណត់ ឬតាមពេលវេលាដែលធនាគារជាតិនៃកម្ពុជាបានពន្យារឱ្យនោះទេ នឹងត្រូវទទួលរងនូវការព្យួរអាជ្ញាបណ្ណរបស់អ្នកដំណើរការតតិយភាគី។ ការព្យួរអាជ្ញាបណ្ណនឹងត្រូវបានលុបចោលវិញ ប្រសិនបើក្នុងរយៈពេល ២០ ថ្ងៃ បន្ទាប់ពីអាជ្ញាបណ្ណត្រូវបានព្យួរធនាគារបាន៖

ក. ដាក់ពាក្យស្នើសុំ និងបង់សោហ៊ុយអាជ្ញាបណ្ណជាថ្មីឱ្យអ្នកដំណើរការតតិយភាគី និង

ខ. បង់ប្រាក់ពិន័យចំនួន ២០០.០០០ រៀល (ម្ភៃម៉ឺនរៀល) ក្នុងមួយថ្ងៃ ក្រោយពេលព្យួរអាជ្ញាបណ្ណ

៥. ប្រសិនបើធនាគារនៅតែមិនអាចបំពេញបាននូវចំណុច ៤ ខាងលើ ធនាគារនោះនឹងត្រូវទទួលរងការជាកពិន័យកាន់តែធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានទៅដល់ការដកអាជ្ញាបណ្ណអ្នកដំណើរការតតិយភាគីតែម្តង។

ប្រការ ៨.-

១. ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការយល់ព្រម ឬបដិសេធពាក្យស្នើសុំនេះក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) ក្រោយពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំពេញលេញ។

២. ធនាគារជាតិនៃកម្ពុជាអាចពន្យាររយៈពេលនៃការដាក់ពាក្យស្នើសុំ ប្រសិនបើមានមូលហេតុសមស្រប។

៣. អាជ្ញាបណ្ណត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេវា ឬសកម្មភាពទាំងឡាយដែលត្រូវបានអនុញ្ញាត និង/ឬ ត្រូវបានរឹតត្បិតចំពោះវិសាលភាព ឬមធ្យោបាយក្នុងការផ្តល់សេវាបែបនេះ។

៤. ធនាគារជាតិនៃកម្ពុជាអាចស្នើទៅគ្រឹះស្ថានធនាគារ និងអ្នកដំណើរការតតិយភាគី ដើម្បីកែប្រែផ្នែកខ្លះនៃកិច្ចព្រមព្រៀងដែលបានចុះហើយ ប្រសិនបើពិនិត្យឃើញថាកិច្ចព្រមព្រៀងទាំងនេះអាចនាំឱ្យមានហានិភ័យហួសប្រមាណចំពោះប្រព័ន្ធជាតិទូទាត់សងប្រាក់ ឬទីផ្សារ។

ប្រការ ៩.-

១. ធនាគារដែលប្រគល់សិទ្ធិក្នុងការធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់មួយផ្នែក ឬច្រើនផ្នែកទៅឱ្យអ្នកដំណើរការតតិយភាគី ត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណឡើងវិញក្នុងរយៈពេលមិនឱ្យលើស ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាបណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព។ ធនាគារត្រូវបំពេញកាតព្វកិច្ចផ្តល់ព័ត៌មាន និងបង់សោហ៊ុយបន្តអាជ្ញាបណ្ណជាថ្មីជូនសមុខឱ្យអ្នកដំណើរការតតិយភាគី។

២. ពាក្យស្នើសុំអាជ្ញាបណ្ណជាថ្មី ត្រូវមានភ្ជាប់ជាមួយនូវ៖

ក. ច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មនាពេលថ្មីៗបំផុតរបស់ធនាគារ។

ខ. ការពិពណ៌នាអំពីការកែប្រែព័ត៌មានសំខាន់ៗរបស់អ្នកដំណើរការតតិយភាគីនៅក្នុងពាក្យស្នើសុំអាជ្ញាបណ្ណដំបូងរបស់ខ្លួន ដែលមិនបានរាយការណ៍ជូនធនាគារជាតិនៃកម្ពុជានៅក្នុងរបាយការណ៍ដែលបានតម្រូវ។

គ. បញ្ជីទីតាំងនៅក្នុងប្រទេសកម្ពុជាដែលអ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ឬផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ផ្សេងៗទៀត។

ឃ. ការបង្ហាញឱ្យដឹងពីការតវ៉ាធ្ងន់ធ្ងរណាមួយ ឬសកម្មភាពស្របច្បាប់ដែលទទួលធ្វើដោយអតិថិជន ឬភាគីទីបីដែលទាក់ទងនឹងសេវាកម្មផ្តល់អាជ្ញាបណ្ណ។

ជំពូក ៤
តារាកិច្ច និងការធានារ៉ាប់រងខុសត្រូវរបស់ធនាគារ

ប្រការ ១០.-

ធនាគារដែលបានទទួលអាជ្ញាបណ្ណសម្រាប់អ្នកដំណើរការតតិយភាគីត្រូវ៖

១. ទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬកំហុសឆ្គងនានារបស់អ្នកដំណើរការតតិយភាគី និងភ្នាក់ងារដែលធ្វើសកម្មភាពក្រោមការប្រគល់សិទ្ធិរបស់ខ្លួន និងជំនួសឱ្យខ្លួន។

២. ត្រូវធានាថា អ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាព ដែលក្នុងនោះអ្នកដំណើរការតតិយភាគីបានធ្វើសកម្មភាពជំនួសឱ្យខ្លួន ដើម្បីធានានូវការគោរពតាមប្រកាសនេះ និងកាតព្វកិច្ចខាងផ្នែកគតិយុត្តផ្សេងៗទៀត។ ធនាគារមិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ។

៣. ត្រូវធានាថា អ្នកដំណើរការតតិយភាគីដែលធ្វើសកម្មភាពជំនួសឱ្យខ្លួន និងភ្នាក់ងារប្រតិស្រុតិ បានជម្រាបជូនអតិថិជនអំពីការទទួលខុសត្រូវនេះ។

៤. ត្រូវធានាថា សេវាផ្តល់ដោយអ្នកដំណើរការតតិយភាគី មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេស និងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវ៖

ក. ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ. ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗ និងការផ្តល់សេវាម្តងៗ

គ. ការបដិសេធ និងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ. ការថែរក្សាទុកកំណត់ត្រាឱ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព។

ប្រការ ១១.-

ទំនាក់ទំនង និងកាតព្វកិច្ចរបស់ធនាគារចំពោះអតិថិជនរបស់ខ្លួនមិនត្រូវបានប៉ះពាល់ដោយសារតែការប្រើប្រាស់សេវាពីខាងក្រៅនៃសកម្មភាពណាមួយដែលស្ថិតនៅក្រោមប្រកាសនេះទេ។

ជំពូក ៥
តួនាទី និងការទទួលខុសត្រូវរបស់អ្នកដំណើរការតតិយភាគី

ប្រការ ១២.-

អ្នកដំណើរការតតិយភាគី ដែលធ្វើសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឱ្យធនាគារ មានភារកិច្ចដូចតទៅ៖

១. អាចជ្រើសរើសភ្នាក់ងារមួយឬច្រើន ដើម្បីជួយដល់ប្រតិបត្តិការដាក់និងដកសាច់ប្រាក់។

២. ត្រូវមានកិច្ចសន្យាតាមផ្លូវច្បាប់ជាមួយភ្នាក់ងារដែលបានជ្រើសរើស និងត្រូវកំណត់គោលការណ៍ និងនីតិវិធីឱ្យបានច្បាស់លាស់ដើម្បីឱ្យភ្នាក់ងារនេះគោរពតាមទាំងស្រុង។

៣. ត្រូវធានាថាភ្នាក់ងារដែលបានជ្រើសរើសមិនផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់នៅក្រៅដែនសកម្មភាពអនុញ្ញាតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងភ្នាក់ងារ និងអ្នកដំណើរការតតិយភាគីឡើយ។

៤. ត្រូវធានាថា សេវាផ្តល់ដោយខ្លួនឯងផ្ទាល់ ឬភ្នាក់ងារណាមួយដែលខ្លួនតែងតាំង មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេសនិងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវ៖

ក. ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ. ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗនិងការផ្តល់សេវាម្តងៗ

គ. ការបដិសេធនិងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ. ការថែរក្សាទុកកំណត់ត្រាឱ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព។

ប្រការ ១៣.-

អ្នកដំណើរការតតិយភាគីមានកាតព្វកិច្ចទទួលខុសត្រូវទាំងស្រុងលើរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន រួមទាំងសកម្មភាពរបស់ភ្នាក់ងារដែលខ្លួនបានជ្រើសរើស ដូចតទៅ៖

១. ទទួលខុសត្រូវលើរាល់សកម្មភាព ឬរាល់កំហុសរបស់ភ្នាក់ងារប្រតិស្រុតិដែលផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឱ្យខ្លួនទាំងចំពោះតតិយភាគីផង និងចំពោះធនាគារផង។

២. ត្រូវធានាថា ភ្នាក់ងាររបស់ខ្លួនធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាពដែលក្នុងនោះភ្នាក់ងារបានធ្វើជំនួសឱ្យខ្លួន។ អ្នកដំណើរការតតិយភាគីមិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ។

៣. ត្រូវផ្តល់បញ្ជីឈ្មោះភ្នាក់ងាររបស់ខ្លួន រួមទាំងឈ្មោះ និងអាសយដ្ឋាននៃទីតាំងដែលភ្នាក់ងារទាំងនោះធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធមកធនាគារជាតិនៃកម្ពុជា ជារៀងរាល់ខែ។

ជំពូក ៦
ការគ្រប់គ្រងគណនី

ប្រការ ១៤.-

ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការផ្ទេរប្រាក់ ត្រូវតម្រូវឱ្យអ្នកដំណើរការតតិយភាគីបើកគណនីនៅធនាគាររបស់ខ្លួន ដើម្បីតម្កល់ប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់ធ្វើការផ្ទេរ ដូចជាការផ្ទេរតាមទូរស័ព្ទជាដើម។

គណនីរបស់អ្នកដំណើរការតតិយភាគីនេះ មានរូបភាពជាគណនីអាណាត្តិព្យាបាលសម្រាប់តម្កល់ប្រាក់ជាបណ្តោះអាសន្ន ដែលនឹងត្រូវបានប្រើសម្រាប់តែការផ្ទេររបស់អតិថិជនប៉ុណ្ណោះ និងមិនត្រូវបានប្រើប្រាស់ក្នុងគោលដៅផ្សេងឡើយ។

ធនាគារសាមីមានតួនាទី តាមដានត្រួតពិនិត្យគណនីនេះជាប្រចាំ ហើយក្នុងករណីមានការបញ្ឈប់សកម្មភាពរបស់អ្នកដំណើរការតតិយភាគី ឬអ្នកដំណើរការតតិយភាគីក្ស័យធន ធនាគារត្រូវតែឃាត់ទុកគណនីនេះ ដើម្បីជាផលប្រយោជន៍របស់អតិថិជន។ សមតុល្យនៃគណនីនេះ មិនមែនជាទ្រព្យសម្បត្តិរបស់អ្នកដំណើរការតតិយភាគីឡើយ។

ជំពូក ៧
ការត្រួតពិនិត្យរបាយការណ៍ និងកំណត់ត្រា

ប្រការ ១៥.-

១. ធនាគារជាតិនៃកម្ពុជា អាចត្រួតពិនិត្យប្រចាំឆ្នាំចំពោះអ្នកដំណើរការតតិយភាគី ឬប្រសិនបើចាំបាច់ចំពោះធនាគារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនចំនួន ៣០ ថ្ងៃ (សាមសិបថ្ងៃ)។

២. ធនាគារជាតិនៃកម្ពុជា អាចត្រួតពិនិត្យអ្នកដំណើរការតតិយភាគីនៅពេលណាមួយក៏បានដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជា មានហេតុផលជឿថាអ្នកដំណើរការតតិយភាគីកំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ ឬគ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងរំលោភប្រកាសនេះ ឬបទបញ្ជា ដែលចេញផ្សាយក្រោមប្រកាសនេះ។

៣. ប្រសិនបើធនាគារជាតិនៃកម្ពុជាសម្រេចថា ការត្រួតពិនិត្យដល់ទីកន្លែងដូចមានចែងក្នុងចំណុច ១ និង ២ ខាងលើជាការចាំបាច់ អ្នកដំណើរការតតិយភាគី ឬធនាគារ ត្រូវទទួលបន្ទុកលើចំណាយសមស្របនៃការត្រួតពិនិត្យនោះ។

៤. ព័ត៌មានដែលទទួលបានក្នុងអំឡុងពេលត្រួតពិនិត្យដែលមានចែងក្នុងប្រកាសនេះ អាចនឹងត្រូវបានបើកចំហាដោយអនុលោមតាមប្រការ ១៧ តែប៉ុណ្ណោះ។

ប្រការ ១៦.-

១. អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១៥ ថ្ងៃ (ដប់ប្រាំថ្ងៃ) នៃថ្ងៃធ្វើការ នូវរាល់ការកែប្រែព័ត៌មានសំខាន់ៗដែលបានផ្តល់ឱ្យនៅក្នុងពាក្យស្នើសុំអាជ្ញាបណ្ណ ដូចដែលបានតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២. ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធ អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីចុងត្រីមាសនីមួយៗនូវ៖

ក. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃប្រតិបត្តិការទូទាត់សងប្រាក់រួមទាំងតារាងតុល្យការ និង របាយការណ៍ចំណូល-ចំណាយ។

ខ. សកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងរបាយការណ៍សរុបអំពីសកម្មភាពនានាប្រចាំខែដោយបែងចែកទៅតាមប្រភេទផ្សេងៗ តាមការណែនាំរបស់ធនាគារពាក់ព័ន្ធ។

គ. បញ្ជីសេវានានាដែលអ្នកដំណើរការតតិយភាគីកំពុងធ្វើនាពេលបច្ចុប្បន្ន និងថ្ងៃ និងពេលវេលា នៃការផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់។

ឃ. ព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ១៧.-

១. អ្នកដំណើរការតតិយភាគីត្រូវរក្សាទុកនូវកំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ) និងជាពិសេសត្រូវរក្សាទុកកំណត់ត្រាសម្រាប់បញ្ជាក់នូវការគោរពតាមរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះដូចខាងក្រោម៖

ក. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗ

ខ. សៀវភៅធំដែលបានចុះបញ្ជីយ៉ាងហោចណាស់ប្រចាំខែ អំពីគណនីទ្រព្យសកម្ម ទ្រព្យអកម្ម ដើមទុន ចំណូល និងចំណាយ

គ. របាយការណ៍គណនី និងកំណត់ត្រាផ្ទៀងផ្ទាត់របស់ធនាគារ

ឃ. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗដែលបានទូទាត់សង

ង. កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗដែលបានទូទាត់សងក្នុងរយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ)

ច. បញ្ជីឈ្មោះ និងអាសយដ្ឋានចុងក្រោយបង្អស់របស់ភ្នាក់ងារខ្លួនទាំងអស់ និង

ឆ. កំណត់ត្រាផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

២. ឯកសារដែលបានរៀបរាប់ក្នុងចំណុច ១ អាចត្រូវបានរក្សាទុកក្នុងទម្រង់កំណត់ត្រាណាមួយក៏បាន។

៣. កំណត់ត្រាទាំងអស់ដែលបានរក្សាទុកដោយអ្នកដំណើរការតតិយភាគី ដូចបានចែងក្នុងចំណុច ១ និង ២ ត្រូវបានបើកចំហសម្រាប់ការធ្វើអធិការកិច្ចដោយធនាគារជាតិនៃកម្ពុជា អនុលោមតាមប្រការ ១៣។

៤. អ្នកដំណើរការតតិយភាគីត្រូវបំពេញកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ឬបទបញ្ជាផ្សេងៗទៀត។

ប្រការ ១៨.-

១. អ្នកដំណើរការតតិយភាគីត្រូវកំណត់ទុកជាមួយនឹងអាជ្ញាធរដែលត្រូវបានតែងតាំងដោយច្បាប់នូវកំណត់ត្រាទាំងអស់ដែលបានតម្រូវតាមរយៈការរាយការណ៍អំពីរូបិយវត្ថុ ការរក្សាកំណត់ត្រា និងការរាយការណ៍អំពីប្រតិបត្តិការសង្ស័យ ដូចមានចែងក្នុងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ អ្នកដំណើរការតតិយភាគីត្រូវដាក់កំណត់ចំពោះភ្នាក់ងារប្រតិស្រុតិរបស់ខ្លួនអំពីការប្រមូលព័ត៌មានដែលគួរឱ្យជឿបានទាំងអស់ ដែលអាជ្ញាធរបានកំណត់សម្រាប់គោលបំណងនេះ។

២. ការតម្កល់ទុកទាន់ពេលនូវរបាយការណ៍ពេញលេញ និងត្រឹមត្រូវជាមួយអាជ្ញាធរសមស្របគឺជាការគោរពតាមកាតព្វកិច្ចនៅក្នុងចំណុច ១។

ប្រការ ១៩.-

១. លើកលែងតែមានចែងខុសពីក្នុងចំណុច ២ ព័ត៌មាន ឬរបាយការណ៍ទាំងអស់ដែលធនាគារជាតិនៃកម្ពុជា បានទទួលពីអ្នកដំណើរការតតិយភាគី និងព័ត៌មានទាំងអស់ដែលមាននៅក្នុងឬទាក់ទងនឹងរបាយការណ៍ត្រួតពិនិត្យ ស៊ើបអង្កេត ប្រតិបត្តិការ ឬស្ថានភាពដែលរៀបចំដោយ ឬសម្រាប់ការប្រើប្រាស់របស់ធនាគារជាតិនៃកម្ពុជា ឬរបាយការណ៍ហិរញ្ញវត្ថុ តារាងតុល្យការ គឺជាការសម្ងាត់ និងមិនត្រូវបានបើកចំហជាសាធារណៈឡើយ។

២. ធនាគារជាតិនៃកម្ពុជាអាចបើកចំហព័ត៌មានដែលមិនមែនជាកម្មវត្ថុនៃការបើកចំហក្រោមចំណុច ១ ទៅឱ្យតំណាងភ្នាក់ងាររបស់រដ្ឋាភិបាល ដែលសន្យាជាលាយលក្ខណ៍អក្សរថានឹងរក្សាការសម្ងាត់នៃព័ត៌មានទាំងនោះ ឬធនាគារជាតិនៃកម្ពុជាយល់ឃើញថា ការផ្សព្វផ្សាយព័ត៌មានទាំងនោះគឺជាការចាំបាច់សមស្របសម្រាប់ការពារសាធារណជន និងដើម្បីភាពយុត្តិធម៌ ហើយធនាគារជាតិនៃកម្ពុជាក៏បានជូនដំណឹងជាមុនដល់អ្នកដំណើរការតតិយភាគីអំពីគោលបំណងផ្សព្វផ្សាយព័ត៌មានទាំងនោះ។

៣. ប្រការនេះមិនហាមឃាត់ធនាគារជាតិនៃកម្ពុជាចំពោះការបើកចំហដល់សាធារណជនអំពីបញ្ជីរាយនាមបុគ្គលដែលបានទទួលអាជ្ញាបណ្ណក្រោមប្រកាសនេះ ឬទិន្នន័យហិរញ្ញវត្ថុសរុបដែលពាក់ព័ន្ធនឹងអ្នកដំណើរការតតិយភាគី និងភ្នាក់ងារប្រតិស្រុតិរបស់អ្នកដំណើរការតតិយភាគីឡើយ។

ជំពូក ៣
និតិវិធីរដ្ឋបាល

ប្រការ ២០.-

១. ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាបណ្ណរបស់អ្នកដំណើរការតតិយភាគី ឬចេញបញ្ជាដល់អ្នកដំណើរការតតិយភាគីឱ្យដកហូតការតែងតាំងភ្នាក់ងារ ប្រសិនបើ៖

ក. អ្នកដំណើរការតតិយភាគីល្មើសនឹងប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលបានចេញផ្សាយក្រោមប្រកាសនេះ

ខ. អ្នកដំណើរការតតិយភាគីមិនសហការជាមួយធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យ ឬការអង្កេត

គ. អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តការក្លែងបន្លំ ធ្វើការបំភាន់ដោយចេតនា ឬមានការធ្វេសប្រហែសធ្ងន់ធ្ងរ

ឃ. ភ្នាក់ងារត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬល្មើសនឹងវិធានដែលបានអនុម័ត ឬបញ្ជាដែលបានចេញក្រោមប្រកាសនេះ

ង. អ្នកដំណើរការតតិយភាគីប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវ

ច. អ្នកដំណើរការតតិយភាគីមានអសាធនភាព ផ្អាកការទូទាត់សងបំណុលរបស់ខ្លួន ឬធ្វើការផ្ទេរសិទ្ធិទូទៅសម្រាប់ផលប្រយោជន៍ឥណទាយករបស់ខ្លួន ឬ

ឆ. អ្នកដំណើរការតតិយភាគីមិនដកភ្នាក់ងារចេញតាមបញ្ជាជាចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជា រួមទាំងការឃើញថាភ្នាក់ងារបានប្រព្រឹត្តល្មើសនឹងប្រកាសនេះផង។

២. ដើម្បីកំណត់ថា អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវ ធនាគារជាតិនៃកម្ពុជាអាចពិចារណាទៅលើទំហំ និងលក្ខខណ្ឌនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ ទំហំនៃការខាតបង់ភាពធ្ងន់ធ្ងរនៃបទល្មើស និងការប្រព្រឹត្តពីមុនរបស់បុគ្គលពាក់ព័ន្ធ។

ប្រការ ២១.-

ប្រសិនបើ ធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ការប្រព្រឹត្តល្មើសរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំដែលបានចេញផ្សាយក្រោមប្រកាសនេះអាចនឹងធ្វើឱ្យអ្នកដំណើរការតតិយភាគី អតិថិជនរបស់អ្នកដំណើរការតតិយភាគី ឬសាធារណជនទទួលមហន្តរាយភ្លាមៗ និងមិនអាចស្តារឡើងវិញបាន ឬបណ្តាលឱ្យមានអសាធនភាព ឬធ្វើឱ្យបាត់បង់ទ្រព្យសកម្មរបស់អ្នកដំណើរការតតិយភាគី ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាតម្រូវឱ្យអ្នកដំណើរការតតិយភាគីបញ្ឈប់សកម្មភាពល្មើសនោះភ្លាម។

ប្រការ ២២.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៩-៤២០ ប្រ.ក ចុះថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការកែសម្រួលប្រការ ២២ នៃប្រកាសស្តីពី អ្នកដំណើរការតតិយភាគី។)

ប្រការ ២២ ថ្មី ចែងដូចខាងក្រោម៖

ធនាគារជាតិនៃកម្ពុជាអាចដាក់ពិន័យចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបទបញ្ជាដែលបានចេញក្រោមប្រកាសនេះ ជាទឹកប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃទៅតាមចំនួនថ្ងៃនៃការប្រព្រឹត្តល្មើស ដោយមិនគិតពីទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២៣.-

១. គ្មានបុគ្គលណាមួយអាចធ្វើរបាយការណ៍ក្លែងបន្លំ បំភាន់ ឬធ្វើលិខិតបញ្ជាក់ក្លែងក្លាយដោយចេតនា នៅក្នុងកំណត់ត្រាដែលបានដាក់ជូន ឬដែលបានតម្រូវឱ្យរក្សាទុកក្រោមប្រកាសនេះ ឬមានចេតនាធ្វើកំណត់ត្រាក្លែងក្លាយ ឬលប់ចោលការកត់ត្រាសំខាន់ៗនៅក្នុងរបាយការណ៍នោះឡើយ។

២. គ្មានបុគ្គលណាមួយ អាចធ្វើសកម្មភាពដោយចេតនានៅក្នុងសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ដោយពុំទាន់បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

៣. ប្រសិនបើ ធនាគារជាតិនៃកម្ពុជាមានមូលហេតុច្បាស់ថា បុគ្គលណាបាន ឬកំពុងប្រព្រឹត្តល្មើសនឹងប្រការ ៣ នៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាដើម្បីបញ្ឈប់បុគ្គលនោះភ្លាម។

ជំពូក ៩
អវសានប្បញ្ញត្តិ

ប្រការ ២៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ១៥-០១៧-១៦១ ប្រ.ក

ប្រកាស
ស្តីពី
ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងនិងកំណត់នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២.-

ប្រកាសនេះ រៀបចំឡើងសម្រាប់គោលដៅដូចខាងក្រោម៖

១- ធានាសុវត្ថិភាពនិងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់

២- ជំរុញការប្រកួតប្រជែងដោយស្មោះត្រង់ និងលើកកម្ពស់គំនិតច្នៃប្រឌិត និង

៣- ផ្តល់ជំនឿទុកចិត្តដល់សាធារណៈជនលើសេវាទូទាត់សងប្រាក់។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

ការផ្តល់សេវាក្នុងករណីដូចខាងក្រោមមិនស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះទេ៖

១- ការផ្តល់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទ្រទ្រង់សេវាកម្មទូទាត់សងប្រាក់ដោយមិនពាក់ព័ន្ធក្នុងការរក្សាទុកមូលនិធិ ការរក្សាទុកនិងដំណើរការទិន្នន័យ បរធនបាលកិច្ច និងការរក្សាការសម្ងាត់ ការបញ្ជាក់អត្តសញ្ញាណនិងទិន្នន័យ ប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ការថែរក្សាទីតាំង និងឧបករណ៍សម្រាប់សេវាទូទាត់សងប្រាក់។ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់ដែលប្រើទីតាំងគ្រឹះស្ថានធនាគារសម្រាប់តែប្រតិបត្តិការផ្ទេរប្រាក់ និងទទួលបញ្ជាផ្ទេរប្រាក់ ត្រូវស្ថិតក្រោមវិសាលភាពប្រកាសស្តីពី "អ្នកដំណើរការតតិយភាគី"។

២- សេវាផ្អែកលើឧបករណ៍ទូទាត់ជាក់លាក់ ដែលអាចប្រើប្រាស់បាននៅក្នុងកម្រិតកំណត់ណាមួយ និងឧបករណ៍ដែលអាចទូទាត់ទំនិញ ឬសេវាកម្មតែនៅក្នុងទីតាំងរបស់គ្រឹះស្ថានចេញផ្សាយ ឬនៅក្នុងតែបណ្តាញទីតាំងរបស់គ្រឹះស្ថានដែលចេញផ្សាយ។

ប្រការ ៥.-

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម៖

- **អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់សេវាទូទាត់សងប្រាក់ដូចជាអ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ឬទាំងពីរ។
- **ប្រតិបត្តិការទូទាត់សងប្រាក់** សំដៅលើសកម្មភាពដែលធ្វើឡើងដោយអ្នកសងប្រាក់ អ្នកតំណាងអ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ដើម្បីធ្វើប្រតិបត្តិការដាក់ប្រាក់ផ្ទេរប្រាក់ឬដកប្រាក់។
- **មូលនិធិ** សំដៅលើធនបត្រ កាស និងរូបិយវត្ថុអេឡិចត្រូនិក។
- **ឧបករណ៍ទូទាត់សងប្រាក់** សំដៅលើឧបករណ៍ដែលអាចឱ្យអ្នកកាន់ ឬអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការទូទាត់សងប្រាក់បានតាមរយៈឧបករណ៍នោះ។
- **រូបិយវត្ថុអេឡិចត្រូនិក** សំដៅលើតម្លៃជារូបិយវត្ថុតំណាងឱ្យបំណុលចំពោះអ្នកចេញផ្សាយ រូបិយវត្ថុអេឡិចត្រូនិកចេញផ្សាយនៅពេលទទួលបានមូលនិធិផ្ទុកតម្លៃជាអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងគោលបំណងទូទាត់សងប្រាក់ និងទទួលស្គាល់ជាឧបករណ៍ទូទាត់សងប្រាក់ដោយរូបវន្តបុគ្គលនិងនីតិបុគ្គលក្រៅពីអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក។
- **អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក** សំដៅដល់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាបណ្ណក្នុងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកនៅក្រោមប្រកាសនេះ។
- **ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់** សំដៅដល់សេវាទូទាត់សងប្រាក់ដែលផ្តើមប្រតិបត្តិការឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួន ឬទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់អ្នកសងប្រាក់ ឱ្យផ្ទេរប្រាក់ចេញពីគណនីរបស់អ្នកសងប្រាក់មកគណនីរបស់អ្នកទទួលប្រាក់ ដោយមានការព្រមព្រៀងគ្នាជាមុនរវាងអ្នកសងប្រាក់និងអ្នកទទួលប្រាក់។
- **ប្រតិបត្តិការផ្ទេរឥណទាន** សំដៅដល់សេវាទូទាត់សងប្រាក់លើប្រតិបត្តិការទូទាត់សងប្រាក់មួយ ឬច្រើនដែលអ្នកសងប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួនឱ្យផ្ទេរប្រាក់ចេញពីគណនីរបស់ខ្លួនទៅគណនីរបស់អ្នកទទួលប្រាក់។
- **គណនីទូទាត់សងប្រាក់** សំដៅដល់គណនីដែលបើកដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងប្រើសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់។
- **សេវាផ្តើមការទូទាត់សងប្រាក់** សំដៅដល់សេវាដែលផ្តើមបញ្ជាទូទាត់តាមសំណើអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់តាមរយៈគណនីធនាគារ ឬគណនីទូទាត់សងប្រាក់ដែលរក្សាទុកជាមួយនឹងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មួយទៀត។

- **គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** សំដៅលើគ្រឹះស្ថានទាំងឡាយណាដែលទទួលបានអាជ្ញាបណ្ណក្នុងការផ្តល់សេវាទូទាត់សងប្រាក់អនុលោមតាមប្រកាសនេះ។
- **បញ្ជាផ្ទេរប្រាក់ជាប្រចាំ** សំដៅដល់បញ្ជាផ្ទេរប្រាក់ធ្វើឡើងដោយអ្នកទូទាត់សងប្រាក់ផ្តល់ឱ្យធនាគាររបស់ខ្លួនធ្វើការទូទាត់សងប្រាក់ជាប្រចាំនូវចំនួនទឹកប្រាក់កំណត់ទៅគណនីអ្នកទទួលប្រាក់។
- **គណនីអាណត្តិព្យាបាល** សំដៅដល់គណនីដែលបើកដោយអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក នៅពេលទទួលសាច់ប្រាក់ពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ រក្សាទុកនៅក្នុងធនាគារអាណត្តិព្យាបាលមួយ ឬច្រើន ក្នុងគោលបំណងធ្វើប្រតិបត្តិការទូទាត់សងប្រាក់តែមួយគត់ដែលបញ្ជាដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងមិនត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកឡើយ។
- **ភ្នាក់ងារ** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្តល់សេវាទូទាត់សងប្រាក់ក្នុងនាមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។
- **ការផ្តល់សេវាជំនួស** សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែកដែលបានព្រមព្រៀងគ្នាជាមួយបុគ្គល ឬគ្រឹះស្ថានមួយផ្សេងទៀតដើម្បីធ្វើសេវានោះជំនួសខ្លួន។
- **ការផ្ទេរប្រាក់** សំដៅដល់សកម្មភាពផ្ទេប្រាក់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត (ដោយពុំចាំបាច់មានគណនីនៅធនាគារ) តាមរយៈគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

ជំពូកទី ២
នីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

ប្រការ ៦.-

សេវាទូទាត់សងប្រាក់ត្រូវបានកំណត់ដូចខាងក្រោម៖

១- សេវាដែលផ្តល់លទ្ធភាពឱ្យមានការដកប្រាក់ និងដាក់ប្រាក់ក្នុងគណនីទូទាត់សងប្រាក់ និងប្រតិបត្តិការទាំងឡាយណាដែលដំណើរការតាមរយៈគណនីទូទាត់សងប្រាក់នោះ។

២- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងការផ្ទេរប្រាក់ពីគណនីទូទាត់សងប្រាក់មួយទៅគណនីទូទាត់សងប្រាក់មួយទៀត ដែលមាននៅជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មួយ ឬជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ផ្សេងទៀត៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ។

៣- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ដែលមូលនិធិត្រូវបានផ្តល់ជាឥណទានទៅឱ្យអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ។

៤- ចេញផ្សាយឧបករណ៍ទូទាត់រួមទាំងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និង/ឬ ទទួលយកប្រតិបត្តិការទូទាត់

៥- ការផ្ទេរប្រាក់នៅក្នុងប្រទេសនិងក្រៅប្រទេស

៦- សេវាផ្តើមការទូទាត់សងប្រាក់

៧- សេវាទូទាត់សងប្រាក់ផ្សេងៗទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៧.-

១- បន្ថែមលើប្រតិបត្តិការដែលមានចែងក្នុងប្រការ ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចធ្វើសកម្មភាពដូចខាងក្រោម បន្ទាប់ពីមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា៖

ក) ប្រតិបត្តិការដែលមានជាប់ពាក់ព័ន្ធជាមួយសេវាកម្មស្នូល ដូចជា ដំណើរការប្រតិបត្តិការទូទាត់សងប្រាក់ សេវាប្តូរប្រាក់ សេវារក្សាទុកនិងបំលែងទិន្នន័យ

ខ) បើកគណនីជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ) ការចូលរួមជាសមាជិកនៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់

ឃ) សកម្មភាពអាជីវកម្មផ្សេងទៀត ដែលស្ថិតនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

២- ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀត ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បង្កើតអង្គភាពដោយឡែក សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ប្រសិនបើសកម្មភាពអាជីវកម្មផ្សេងទៀតបានប៉ះពាល់ ឬអាចធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ឬការអនុលោមតាមច្បាប់ និងបទប្បញ្ញតិរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

៣- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចបើកគណនីទូទាត់សងប្រាក់ ប្រើប្រាស់សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ប៉ុណ្ណោះ។ មូលនិធិដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ទទួលបាន មិនចាត់ទុកថាជាប្រាក់បញ្ញើនោះទេ ។

៤- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អាចផ្តល់ឥណទានពាក់ព័ន្ធសេវាទូទាត់សងប្រាក់បានក្នុងករណីដូចខាងក្រោម៖

ក) ឥណទានជាសេវាកម្មបន្ថែម និងផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ប៉ុណ្ណោះ

ខ) ឥណទានផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់ ត្រូវទូទាត់សងក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ ថ្ងៃ (មួយរយប៉ែតសិបថ្ងៃ)

គ) មូលនិធិដែលទទួលពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ មិនត្រូវយកមកប្រើប្រាស់សម្រាប់ផ្តល់ឥណទានទេ

ឃ) មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវមានកម្រិតសមស្របជាមួយទំហំឥណទានដែលបានផ្តល់។

ប្រការ ៨.-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវស្នើសុំអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់រួមទាំងការចេញផ្សាយឧបករណ៍ទូទាត់សងប្រាក់ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៩.-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ការពិពណ៌នាជាលាយលក្ខណ៍អក្សរអំពីប្រភេទនៃសេវាទូទាត់សងប្រាក់ ដែលនឹងត្រូវធ្វើប្រតិបត្តិការ

២- ផែនការអាជីវកម្មដែលរួមបញ្ចូលទាំងការប៉ាន់ស្មានអំពីគម្រោងថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (បីឆ្នាំ) ដំបូង ដែលបង្ហាញអំពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធ ធនធាន និងនីតិវិធីសមស្រប ដើម្បីធានាភាពរឹងមាំនៃដំណើរការអាជីវកម្ម

៣- ភស្តុតាងអំពីភាពគ្រប់គ្រាន់នៃដើមទុន

៤- ការពិពណ៌នាអំពីនីតិវិធីក្នុងការរក្សាសុវត្ថិភាពមូលនិធិ

៥- ការពិពណ៌នាអំពីការរៀបចំអភិបាលកិច្ច និងយន្តការត្រួតពិនិត្យផ្ទៃក្នុង រួមមានទម្រង់បែបបទរដ្ឋបាល ការគ្រប់គ្រងហានិភ័យ និងនីតិវិធីគណនេយ្យ ដែលមានភាពសមស្របរឹងមាំ និងគ្រប់គ្រាន់

៦- ការពិពណ៌នាអំពីនីតិវិធីក្នុងការដោះស្រាយវិវាទរបស់អតិថិជន ព្រមទាំងយន្តការក្នុងការត្រួតពិនិត្យ និងតាមដានឧបទ្វវហេតុដែលកើតឡើង

៧- ការពិពណ៌នាអំពីនីតិវិធីសម្រាប់ចងក្រងឯកសារ ពិនិត្យ តាមដាន និងដាក់កម្រិតចំពោះការប្រើប្រាស់ទិន្នន័យសំខាន់ៗ

៨- ការពិពណ៌នាអំពីផែនការនិរន្តភាពអាជីវកម្ម រួមមានការកំណត់អត្តសញ្ញាណប្រតិបត្តិការ ស្នូល ផែនការយថាភាព និងនីតិវិធីសម្រាប់ធ្វើការសាកល្បងជាប្រចាំ

៩- ការពិពណ៌នាអំពីគោលការណ៍ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការ និងការក្លែងបន្លំ

១០- គោលនយោបាយសុវត្ថិភាព ដែលរួមមានការវាយតម្លៃលម្អិតអំពីហានិភ័យពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់រួមទាំងការក្លែងបន្លំ ការប្រើប្រាស់ខុសច្បាប់នៃទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យសំខាន់ៗ ព្រមជាមួយការពិពណ៌នាអំពីវិធានការគ្រប់គ្រងសុវត្ថិភាព និងការកាត់បន្ថយហានិភ័យទាំងនោះ

១១- ការពិពណ៌នាអំពីការរៀបចំយន្តការ និងកាតព្វកិច្ចដើម្បីអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

១២- ការពិពណ៌នាអំពីរចនាសម្ព័ន្ធចាត់តាំង រួមទាំងការប្រើប្រាស់ភ្នាក់ងារនិងសាខា ការត្រួតពិនិត្យភ្នាក់ងារ ការផ្តល់សេវាជំនួស និងការចូលរួមជាមួយប្រព័ន្ធជាត់ទាត់និងទូទាត់សងប្រាក់

១៣- ការពិពណ៌នាអំពីអត្តសញ្ញាណនិងគុណវុឌ្ឍិរបស់ភាគទុនិក ទំហំនៃការកាន់កាប់ភាគហ៊ុន និងភស្តុតាងបញ្ជាក់អំពីភាពសមស្រប ដើម្បីធានានូវភាពរឹងមាំនិងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន

១៤- ការពិពណ៌នាអំពីអត្តសញ្ញាណក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ព្រមទាំងភស្តុតាងបញ្ជាក់អំពីកេរ្តិ៍ឈ្មោះ ចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការផ្តល់សេវាទូទាត់សងប្រាក់

១៥- ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណនៃសវនករ និងស្នងការគណនេយ្យឯករាជ្យប្រតិស្រុតិ

១៦- ឯកសារគតិយុត្ត លក្ខន្តិក: និងឯកសារបង្កើតផ្សេងៗទៀត

១៧- កំណត់ពីអាសយដ្ឋាននៃស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន។

ប្រការ ១០.-

១- ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយសាកសួរព័ត៌មានចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) និងសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)។

២- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ឱ្យបានត្រឹមថ្ងៃទី១៥ នៃខែមករា។

៣- ចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលស្នើសុំអាជ្ញាបណ្ណនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណ នឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

ប្រការ ១១.-

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួនក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) ចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំអាជ្ញាបណ្ណ រួមទាំងឯកសារពាក់ព័ន្ធផ្សេងៗពេញលេញ។ ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យារយៈពេលនៃការសិក្សាពាក្យស្នើសុំ។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាតជាគោលការណ៍។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំពុំបានអនុវត្តតាមលក្ខខណ្ឌ និងរយៈពេលកំណត់ខាងលើ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេល និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា នឹងផ្តល់អាជ្ញាបណ្ណជាផ្លូវការដល់អ្នកដាក់ពាក្យស្នើសុំ បន្ទាប់ពីពិនិត្យឃើញថា រាល់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ និងសំណុំបែបបទត្រូវបានបំពេញសព្វគ្រប់។

ប្រការ ១២.-

អាជ្ញាបណ្ណមានសុពលភាពសម្រាប់រយៈពេល ៦ ឆ្នាំ (ប្រាំមួយឆ្នាំ)។ អាជ្ញាបណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពស្របតាមច្បាប់និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមានត្រូវបានដោះស្រាយ។

ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាបណ្ណផុតសុពលភាព។ ក្នុងករណីដែលការស្នើសុំនេះមានបញ្ចូលសេវាថ្មី ឬមានវិធីសាស្ត្រខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ត្រូវចាត់ទុកថាជាការស្នើសុំអាជ្ញាបណ្ណថ្មី។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំ។

ក្នុងករណីមិនព្រមមកដាក់ពាក្យស្នើសុំបន្តទៀត គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណតែម្តង។

ជំពូកទី ៣
ដើមទុនអប្បរមា និងវិធានការប្រុងប្រយ័ត្ន

ប្រការ ១៣.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាសម្រាប់ធ្វើប្រតិបត្តិការចំនួន ៨.០០០.០០០.០០០ រៀល (ប្រាំបីពាន់លានរៀល) ជាសាច់ប្រាក់។

ធនាគារជាតិនៃកម្ពុជាអាចកែប្រែកម្រិតដើមទុនចុះបញ្ជីអប្បបរមាក្នុងករណីចាំបាច់។

ប្រការ ១៤.-

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មិនត្រូវធ្លាក់ចុះទាបជាងកម្រិតដើមទុនចុះបញ្ជីអប្បបរមា។ ការគណនាមូលនិធិផ្ទាល់សុទ្ធនឹងត្រូវកំណត់ដោយបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក។

ប្រការ ១៥.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាបណ្ណ ត្រូវរក្សាប្រាក់តម្កល់ធានាដើមទុនស្មើនឹងប្រាំភាគរយ (៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ ការកំណត់ការប្រាក់នឹងមានចែងក្នុងបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក។

ប្រការ ១៦.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាមូលនិធិដែលទទួលបានពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់សម្រាប់ការផ្ទេរ និងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកទៅតាមនីតិវិធីដូចខាងក្រោម៖

១- ត្រូវដាក់តម្កល់ក្នុងគណនីដោយឡែកនៅក្នុងគ្រឹះស្ថានធនាគារពាណិជ្ជ ដែលមានរូបភាពជាគណនីអាណត្តិព្យាបាល ឬវិនិយោគលើទ្រព្យសកម្មមានសុវត្ថិភាព មានហានិភ័យទាប និងមានសន្ទនីយភាពខ្ពស់ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា

២- មូលនិធិនេះមិនមែនជាទ្រព្យសម្បត្តិរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នោះទេ។ អត្ថប្រយោជន៍ដែលទទួលបានពីការតម្កល់មូលនិធិត្រូវរក្សាទុក និងប្រើប្រាស់ជាប្រយោជន៍សម្រាប់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់

៣- ក្នុងករណីគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បញ្ឈប់សកម្មភាពអាជីវកម្ម ឬក្ស័យធន មូលនិធិត្រូវឃាត់ទុកដើម្បីទូទាត់សងទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់វិញ

៤- គ្រឹះស្ថានធនាគារដែលរក្សាមូលនិធិ ត្រូវមានតួនាទីត្រួតពិនិត្យ និងផ្សៀងផ្ទាត់សមតុល្យគណនីអាណត្តិព្យាបាលជាមួយសមតុល្យមូលនិធិដែលបានទទួលពីការផ្ទេរប្រាក់ និងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក។

ប្រការ ១៧.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមានបំណងប្រើប្រាស់ភ្នាក់ងារ ដែលធ្វើសកម្មភាពជំនួសខ្លួន ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

១- រាយការណ៍មកធនាគារជាតិនៃកម្ពុជាអំពីព័ត៌មានពាក់ព័ន្ធភ្នាក់ងារ ដូចជា នាមករណ៍ និងអាសយដ្ឋាន ប្រភេទប្រតិបត្តិការ និងទំហំសកម្មភាពប្រតិបត្តិការ

២- ត្រូវមានលក្ខខណ្ឌសមស្របក្នុងការជ្រើសរើសភ្នាក់ងារ និងខចែងអំពីមុខងារ និងការទទួលខុសត្រូវស្របតាមច្បាប់ជាធរមាន

៣- ធានាថាគ្រប់ភ្នាក់ងារប្រតិបត្តិដោយមានការត្រួតពិនិត្យពេញលេញ និងគោរពតាមគោលការណ៍និងនីតិវិធីទាំងឡាយដែលបានដាក់ចេញ។

ប្រការ ១៨.-

ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានបំណងផ្តល់មុខងារប្រតិបត្តិការទូទាត់សងប្រាក់ទៅឱ្យអ្នកផ្តល់សេវាជំនួស គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវធានាថាអ្នកផ្តល់សេវាជំនួសស្ថិតនៅក្រោមវិសាលភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ១៩.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន បូករួមទាំងសកម្មភាពប្រតិបត្តិការរបស់ និយោជិត ភ្នាក់ងារ ឬអ្នកផ្តល់សេវាជំនួសដែលខ្លួនបានជ្រើសរើស។

ប្រការ ២០.-

១- នីតិបុគ្គលទាំងឡាយណាក្រៅពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានហាមឃាត់ក្នុងការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិក។ ការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិកត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

ក) មូលនិធិទទួលបានពីការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក មិនត្រូវចាត់ទុកថាជាប្រាក់បញ្ញើនោះទេ

ខ) ត្រូវចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកតាមតម្លៃចារឹកស្មើនឹងមូលនិធិដែលទទួលបាន

គ) ត្រូវបំលែងមូលនិធិដែលទទួលបានពីអតិថិជនទៅជារូបិយវត្ថុអេឡិចត្រូនិកដោយមិនមានការពន្យារពេល និងអាចប្រើប្រាស់បានភ្លាមៗ

ឃ) ត្រូវផ្ទេរមូលនិធិ ដែលទទួលបានពីអតិថិជនទៅក្នុងគណនីអាណត្តិព្យាបាល ដែលបានបើកនៅគ្រឹះស្ថានធនាគារពាណិជ្ជ ហើយរក្សាទុកនៅក្នុងគណនីនោះក្នុងអំឡុងពេលប្រើប្រាស់

ង) មិនត្រូវផ្តល់ការប្រាក់ ឬផលប្រយោជន៍ផ្សេងទៀតទៅកាន់អ្នកប្រើប្រាស់ក្នុងអំឡុងពេលនៃការកាន់កាប់រូបិយវត្ថុអេឡិចត្រូនិក

ច) ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌក្នុងការផ្ទេររូបិយវត្ថុអេឡិចត្រូនិកជាសាច់ប្រាក់

ឆ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

២- ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកក្នុងករណីដូចខាងក្រោម មិនតម្រូវឱ្យមានការស្នើសុំអាជ្ញាបណ្ណ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន មកធនាគារជាតិនៃកម្ពុជា៖

ក) កម្រិតអតិបរមានៃសមតុល្យគណនីនីមួយៗមិនលើសពី ២០០.០០០រៀល (ពីរយពាន់រៀល) ឬសមមូល

ខ) សមតុល្យគណនីសរុបមិនលើសពី ៨០០.០០០.០០០ រៀល (ប្រាំបីរយលានរៀល) ឬសមមូល

គ) រូបិយវត្ថុអេឡិចត្រូនិកប្រើប្រាស់សម្រាប់ទូទាត់លើផលិតផល ឬសេវាកម្មដែលផ្តល់ដោយរូបវន្តបុគ្គលតែមួយ

ឃ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ២១.-

ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាទូទាត់ដល់សាធារណជន គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវអនុវត្តដូចខាងក្រោម៖

១- រៀបចំប្រព័ន្ធប្រតិបត្តិការសុវត្ថិភាពឱ្យមានភាពរឹងមាំ ដើម្បីរក្សានូវជំនឿទុកចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់សេវារបស់ខ្លួន

២- មានធនធានមនុស្សនិងសមត្ថភាព រួមទាំងផ្នែកឧបករណ៍បច្ចេកទេសគ្រប់គ្រាន់សម្រាប់ដំណើរការប្រព័ន្ធឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព

៣- រៀបចំចងក្រងនីតិវិធីប្រតិបត្តិការ និងបច្ចេកទេសឱ្យបានច្បាស់លាស់

៤- រៀបចំយន្តការត្រួតពិនិត្យប្រព័ន្ធផ្ទៃក្នុងឱ្យមានភាពរឹងមាំ

៥- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ និងដំណើរការសាកល្បងប្រព័ន្ធជាប្រចាំ

៦- រៀបចំផែនការសង្គ្រោះបន្ទាន់ រួមទាំងបង្កើតនូវប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យ

៧- រៀបចំប្រព័ន្ធសម្រាប់តាមដានប្រតិបត្តិការបន្លំឆបោក ព្រមទាំងយុទ្ធសាស្ត្រក្នុងការកំណត់អត្តសញ្ញាណហានិភ័យ។

ប្រការ ២២.-

ដើម្បីការពារអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវ៖

១- ផ្តល់នូវព័ត៌មានចាំបាច់មួយចំនួន ដល់អតិថិជនមុននឹងអតិថិជនសម្រេចប្រើសេវាទូទាត់សងប្រាក់របស់ខ្លួនដូចជា៖

ក) កម្រៃសេវាអ្នកផ្ញើ និងអ្នកទទួល

ខ) ប្រភេទសេវាដែលផ្តល់

គ) អត្រាប្តូរប្រាក់

ឃ) ថ្លៃផ្សេងៗទៀត

ង) មធ្យោបាយនិងទីតាំងដែលអតិថិជនអាចប្រើប្រាស់សេវា

ច) ពេលវេលាដែលអ្នកទទួលអាចដកប្រាក់បាន

ឆ) ពេលវេលាក្នុងការដោះស្រាយវិវាទ។

២- រៀបចំលក្ខខណ្ឌនិងខចែងអំពីការប្រើប្រាស់សេវា រួមទាំងការទទួលខុសត្រូវរបស់គ្រប់ភាគីពាក់ព័ន្ធ

៣- ផ្តល់ព័ត៌មាននិងលក្ខខណ្ឌពាក់ព័ន្ធទៅនឹងសេវារបស់ខ្លួន ដូចបានរៀបរាប់ខាងលើទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់មានលក្ខណៈងាយយល់ ច្បាស់លាស់ និងភាពងាយស្រួលក្នុងការទទួលបាន

៤- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអតិថិជនរបស់ខ្លួនយ៉ាងយូរបំផុត ២១ថ្ងៃមុននឹងមានការកែប្រែចំណុចសំខាន់ៗរបស់លក្ខខណ្ឌ និងខចែងនៃគណនីរបស់អតិថិជនដែលតម្រូវឱ្យផ្សព្វផ្សាយ លើកលែងតែការកែប្រែទាំងនោះចាំបាច់ត្រូវតែធ្វើភ្លាមៗដើម្បីរក្សានិងរៀបចំឡើងវិញនូវស្ថេរភាពប្រព័ន្ធ ឬគណនីរបស់អតិថិជន

៥- ផ្តល់វិក្កយបត្រ ឬភស្តុតាងសម្គាល់ជូនអ្នកផ្ញើ និងអ្នកទទួល នៅពេលធ្វើប្រតិបត្តិការបានជោគជ័យ

៦- រក្សាទុកវិក្កយបត្រ ឬឯកសារផ្សេងៗ ដែលអតិថិជនធ្វើប្រតិបត្តិការសម្រាប់ធ្វើការត្រួតពិនិត្យ

៧- រៀបចំនីតិវិធីក្នុងការដោះស្រាយវិវាទជាមុនជូនអតិថិជន និងផ្តល់ក្នុងករណីមានវិបត្តិឬមានការតវ៉ាកើតឡើងក្នុងការទូទាត់ ដើម្បីឱ្យអតិថិជនអាចទំនាក់ទំនងរកជំនួយបានភ្លាមៗ។

ប្រការ ២៣.-

ដើម្បីរួមចំណែកអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវបំពេញកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម៖

១- រៀបចំបង្កើតនូវប្រព័ន្ធផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យ និងតាមដានប្រតិបត្តិការសាច់ប្រាក់និងប្រតិបត្តិការសង្ស័យ

២- កំណត់ឱ្យបានច្បាស់លាស់អំពីនីតិវិធីក្នុងការស្គាល់អត្តសញ្ញាណអតិថិជន និងវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

៣- រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ទៅកាន់អាជ្ញាធរពាក់ព័ន្ធ

៤- តែងតាំងមន្ត្រីប្រតិបត្តិទទួលបន្ទុកការងារពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៥- ធានាថាតតិយភាគីណាមួយដែលធ្វើសកម្មភាពជំនួសខ្លួនគោរពតាមច្បាប់ ដូចមានចែងនៅក្នុងប្រការនេះ។

ប្រការ ២៤.-

១- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមានបំណងធ្វើសកម្មភាពណាមួយដូចខាងក្រោម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា៖

ក) ការរួមបញ្ចូលជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ឬអង្គភាពផ្សេងទៀត

ខ) ការរំសាយ ឬការបញ្ឈប់អាជីវកម្ម

គ) ផ្ទេរនិងធ្វើលទ្ធកម្មនូវអាជីវកម្មមួយផ្នែកឬទាំងមូល។

២- អាជ្ញាបណ្ណរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវបញ្ឈប់ដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌដូចខាងក្រោម៖

ក) នៅកាលបរិច្ឆេទដែលរូបភាពគតិយុត្តត្រូវបានបញ្ឈប់ដោយច្បាប់

ខ) នៅកាលបរិច្ឆេទបញ្ឈប់សកម្មភាពអាជីវកម្ម

គ) អាជ្ញាបណ្ណអស់សុពលភាព។

ប្រការ ២៥.-

រាល់ការផ្លាស់ប្តូរចនាសម្ព័ន្ធភាគទុនិក គណៈគ្រប់គ្រង នីតិវិធីប្រតិបត្តិការ និងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

ប្រការ ២៦.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវគោរពតាមការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូកទី ៤
ការត្រួតពិនិត្យ

ប្រការ ២៧.-

ធនាគារជាតិនៃកម្ពុជា នឹងចុះត្រួតពិនិត្យប្រចាំឆ្នាំចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងភ្នាក់ងារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនចំនួន ១៥ ថ្ងៃ (ដប់ប្រាំថ្ងៃ) ធ្វើការ។ ធនាគារជាតិនៃកម្ពុជា អាចចុះត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងភ្នាក់ងារនៅពេលណាមួយក៏បាន ដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជា

មានហេតុផលជឿថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងភ្នាក់ងារ កំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ គ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងបំពានប្រកាសនេះ ឬបទបញ្ជាដែលចេញផ្សាយក្រោមប្រកាសនេះ។

ប្រការ ២៨.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់ព័ត៌មានតាមការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវរៀបចំសៀវភៅកត់ត្រា កំណត់ហេតុ គណនី ឧបករណ៍ ឬឯកសារពាក់ព័ន្ធអាជីវកម្មរបស់ខ្លួន ឬអាជីវកម្មពាក់ព័ន្ធ សម្រាប់គោលបំណងត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យដែលតែងតាំងដោយធនាគារជាតិនៃកម្ពុជា ទៅតាមពេលវេលានិងការរៀបចំដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ២៩.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់របាយការណ៍ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់ តាមគំរូតារាងរបាយការណ៍ដែលបានរៀបចំ និងទៅតាមកាលបរិច្ឆេទជាក់លាក់ចំពោះព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៣០.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាទុកនូវរាល់កំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ)។

កំណត់ត្រាទាំងអស់ដែលបានរក្សាទុក ត្រូវបើកចំហសម្រាប់ធ្វើការត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា។

ជំពូកទី៥
ទោសប្បញ្ញត្តិ

ប្រការ ៣១.-

បុគ្គលណាដែលរំលោភលើបញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវទទួលរងការដាក់ទណ្ឌកម្មវិន័យ ឬពិន័យ ដូចមានចែងក្នុងមាត្រា ៥២ និង ៥៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៣២.-

ធនាគារជាតិនៃកម្ពុជា អាចព្យួរឬដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នៅក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- ខកខានធ្វើប្រតិបត្តិការក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) គិតចាប់ពីកាលបរិច្ឆេទទទួលបានអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ឬផ្អាកសកម្មភាពប្រតិបត្តិការរយៈពេល ៦ ខែ (ប្រាំមួយខែ)

២- ជូនដំណឹងមកធនាគារជាតិនៃកម្ពុជាបញ្ជាក់អំពីការលះបង់សិទ្ធិធ្វើប្រតិបត្តិការ ឬផ្អាកប្រតិបត្តិការរបស់ខ្លួន

៣- បានប្រព្រឹត្តការក្លែងបន្លំព័ត៌មាន និងឯកសារដោយចេតនា ឬមានការធ្វេសប្រហែសធ្ងន់ធ្ងរ

៤- មិនអាចបំពេញបានតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

៥- មិនគោរពតាមសេចក្តីណែនាំ ឬសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា

៦- ធ្វើប្រតិបត្តិការដែលពុំមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

៧- បង្កឱ្យមានការគំរាមកំហែងដល់សុវត្ថិភាព ប្រសិទ្ធភាព និងភាពរឹងមាំ របស់ប្រព័ន្ធទូទាត់សងប្រាក់ជាតិទាំងមូល។

ប្រការ ៣៣.-

ក្នុងករណីមានការយឺតយ៉ាវចំពោះ៖

១) ក្នុងការផ្តល់របាយការណ៍និងព័ត៌មានផ្សេងៗ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យចំនួន ១.000.000 រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យធ្ងន់ធ្ងរឡើង ប្រសិនបើនៅតែបន្តការយឺតយ៉ាវ។

២) ការបង់សោហ៊ុយអាជ្ញាបណ្ណមានការយឺតយ៉ាវ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងនូវការផាកពិន័យ ដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់ ៣០ថ្ងៃ (សាមសិបថ្ងៃ)។

ជំពូកទី ៦
អន្តរប្បញ្ញត្តិ

ប្រការ ៣៤.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលនៅមានសុពលភាពអាជ្ញាបណ្ណស្ថិតនៅក្រោមប្រកាសស្តីពី "អ្នកដំណើរការតតិយភាគី" ត្រូវបំពេញបែបបទស្នើសុំអាជ្ញាបណ្ណឡើងវិញក្នុងរយៈពេលយ៉ាងយូរបំផុត ៦ខែ (ប្រាំមួយខែ) ដោយអនុលោមតាមខ្លឹមសារប្រកាសនេះ លើកលែងចំពោះគ្រឹះស្ថានដែលមានប្រតិបត្តិការដូចចែងក្នុងប្រការ ៤ (ចំណុច ១)។

ជំពូកទី ៧
អនុសាសនប្បញ្ញត្តិ

ប្រការ ៣៥.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៣៦.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

គ. បទប្បញ្ញត្តិអនុវត្តចំពោះ ធនាគារពាណិជ្ជ និង ធនាគារឯកទេស

ក.១. បទប្បញ្ញត្តិប្រឆងប្រយ័ត្ន

ធ៩-៩៨-៥១៥ ប្រ.ក

ប្រកាស
ស្តីពី
ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់ក្នុងស្រុក
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ដាក់ចេញនូវវិធានការទប់ស្កាត់ការបញ្ចេញទៅក្រៅប្រទេសនូវប្រភពទុនជាប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានក្នុងស្រុករបស់គ្រឹះស្ថានធនាគារ (ធនាគារពាណិជ្ជ) និងគ្រឹះស្ថានហិរញ្ញវត្ថុក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យសព្វ័យក្នុងស្រុកអាចបម្រើផ្នែកវិនិយោគក្នុងប្រទេសបានទាំងស្រុង។

ប្រការ ២.-

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាទុកទាំងអស់ (១០០ ភាគរយ) នូវប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើអន្តរធនាគារ សម្រាប់ការប្រើប្រាស់របស់ខ្លួននៅក្នុងប្រទេស។

សក្តីកម្មនៃការរក្សាទុកនេះ ត្រូវបានឆ្លុះបញ្ចាំងដោយចំនួនសរុបនៃខ្នង់ប្រាក់មួយចំនួននៅខាងទ្រព្យសកម្មនៃតារាងតុល្យការដូចខាងក្រោម៖

- សាច់ប្រាក់នៅក្នុងដៃ
- ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក
- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (ដកចេញនូវប្រាក់តម្កល់ធានាចំនួន ១០ ភាគរយនៃដើមទុន)
- និងប្រាក់ឱ្យខ្ចីចងការ និងបុរេប្រទាន

ជានិច្চកាល ចំនួនសរុបនេះយ៉ាងហោចណាស់ត្រូវតែស្មើនឹងប្រាក់បញ្ញើសរុបដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើជាអន្តរធនាគារ។

ប្រការ ៣.-

នៅរៀងរាល់ខែ រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានត្រួតពិនិត្យ) នូវតារាងគណនាដែលបានចែងនៅប្រការ ២ ដោយភ្ជាប់ជាមួយរបាយការណ៍ប្រចាំខែស្តីពី ទ្រព្យសកម្មនិងទ្រព្យអកម្ម (តារាងតុល្យការ) ដែលធ្លាប់ផ្ញើមកជាប្រក្រតី។

ក្នុងករណីត្រួតពិនិត្យឃើញតារាងគណនានេះមិនឆ្លើយតបតាមលក្ខខណ្ឌដែលកំណត់នៅប្រការ ២ សាមីគ្រឹះស្ថានត្រូវរងការផាកពិន័យចំនួន ១ ភាគរយ ក្នុងមួយខែលើចំនួនដែលខ្វះ ទុកជា

ការព្រមានលើកដំបូង សម្រាប់រយៈពេលមួយខែ ហួសពីនេះត្រូវរងវិធានការធ្ងន់ធ្ងរថែមទៀតតាមករណីជាក់ស្តែង។

ប្រការ ៤.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០០-៥៦ ប្រ.ក

ប្រកាស
ស្តីពី
អនុបាតសាធនភាពរបស់ធនាគារ

ប្រការ ១.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៤-២០៦ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាព។)

ប្រការ ១ ថ្មី ចែងដូចខាងក្រោម៖

ធនាគារទាំងអស់ត្រូវពិនិត្យជាអចិន្ត្រៃយ៍នូវអនុបាតសាធនភាពរបស់ខ្លួនឱ្យបានស្របតាមបញ្ញត្តិនៃប្រកាសនេះ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យឥណទានសរុបមិនត្រូវតិចជាងដប់ប្រាំភាគរយ (១៥%) ឡើយ។

ប្រការ ២.-

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ប្រការ ៣.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៧-១៣៥ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ។)

ប្រការ ៣ ថ្មី ចែងដូចខាងក្រោម៖

ក- ភាគបែងនៃអនុបាត គឺជាតម្លៃទ្រព្យសកម្មសរុប (តម្លៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធន និងការរំលស់តម្លៃ) និងខ្នង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកម្រិតហានិភ័យ។ ភាគបែងនេះមិនរាប់បញ្ចូលនូវខ្នង់ដែលបានដកចេញនៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ខ- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម

ខ.១- ការថ្លឹងសូន្យភាគរយ (zero weighting) ចំពោះ៖

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលមានវត្ថុបញ្ចាំជាប្រាក់បញ្ញើ នៅធនាគារ

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ (Claims on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្រ របស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.២- ការថ្លឹង ២០% ចំពោះ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៣- ការថ្លឹង ៥០% ចំពោះ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុនដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.៤- ការថ្លឹង ១០០% ចំពោះ៖

- ទ្រព្យសកម្មដទៃទៀតទាំងអស់។

គ- បញ្ញត្តិដូចតទៅនេះ នឹងត្រូវអនុវត្តចំពោះខ្នង់ក្រៅតារាងតុល្យការ

គ.១- ខ្នង់ក្រៅតារាងតុល្យការត្រូវបានចាត់ថ្នាក់ជា ៤ ប្រភេទ ស្របតាមតារាងដែលមានក្នុងឧបសម្ព័ន្ធ។ ខ្នង់ក្រៅតារាងតុល្យការទាំងនេះត្រូវបានយកមកគិត៖

- តាមតម្លៃទាំងស្រុងរបស់វានៅពេលបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង
- តាមតម្លៃ ៥០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យកម្រិតមធ្យម
- តាមតម្លៃ ២០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យធុនល្មម (moderate risk)
- ខ្នង់ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាបមិនត្រូវបានយកមកគិតទេ។

គ.២- ចំនួនប្រាក់ដែលបានកំណត់ខាងលើ ត្រូវគុណជាមួយនឹងប្រភេទថ្លឹងដែលមានចែងនៅក្នុងកថាខណ្ឌ ខ ដែលត្រូវអនុវត្តចំពោះប្រភេទនៃការថ្លឹងរបស់អតិថិជន ឬ ប្រភេទទ្រព្យសកម្មពាក់ព័ន្ធនោះ។ ប៉ុន្តែ៖

- ក្នុងករណីនៃការសន្យាដែលមានការធានាពីតតិយជន ការថ្លឹងគឺជាការថ្លឹងដែលអនុវត្តចំពោះអ្នកធានា ឬចំពោះអ្នកដែលត្រូវបានគេធានា

- ក្នុងករណីនៃការធានាចំពោះធនាគារមួយផ្សេងទៀត ទាក់ទងដល់ការសងបំណុលដែលរក្សាទុកនៅធនាគារផ្សេងទៀតនោះ ការថ្លឹងជាការថ្លឹងដែលអនុវត្តចំពោះឥណទេយ្យទាំងនេះ។

ប្រការ ៤.-

ធនាគារត្រូវប្រតិវេទអនុបាតសាធនភាពរបស់ខ្លួននៅ ថ្ងៃទី៣០ ខែមិថុនា និង ថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងអាចតម្រូវឱ្យធនាគារណាមួយគណនាអនុបាតសាធនភាពរបស់ខ្លួន នៅកាលបរិច្ឆេទផ្សេងទៀត ស្របតាមការចាំបាច់នៃការត្រួតពិនិត្យ។

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ក្នុងសារាចរពីគំរូសម្រាប់គណនាអនុបាតដោយត្រូវប្រកាសពីខ្ងង់ទាំងឡាយក្នុងគំរូនេះ។

ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ច្បាស់អំពីលក្ខណៈពិសេសរបស់ខ្ងង់ដែលត្រូវអនុវត្តការថ្លឹង ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ។

ធនាគារជាតិនៃកម្ពុជា អាចបដិសេធចំពោះការថ្លឹងដែលកំពុងអនុវត្តចំពោះទ្រព្យសកម្ម ឬខ្ងង់ក្រៅតារាងតុល្យការ ប្រសិនបើគិតថាខ្ងង់នោះមិនអាចបំពេញតាមលក្ខខណ្ឌជាធរមានបានដោយពេញចិត្តនោះទេ។

ប្រការ ៥.-

ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យមានការយកចិត្តទុកដាក់ថា គោលនយោបាយគណនេយ្យខ្សោយ ឬមិនគ្រប់គ្រាន់ធ្វើឱ្យអន្តរាយដល់សារៈប្រយោជន៍នៃកម្រិតដើមទុន ដោយបង្កឱ្យមានអនុបាតសាធនភាពមិនត្រឹមត្រូវ ឬមិនអាចជឿបាន។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកថា ការអនុវត្តគណនេយ្យរឹងមាំ និងការវាយតម្លៃត្រឹមត្រូវជាការសំខាន់ ជាពិសេសចំពោះការចាត់ថ្នាក់ត្រឹមត្រូវ និងការធ្វើសំវិធានធនទ្រព្យសកម្មតាមបញ្ញត្តិនៃប្រកាស ស្តីពី ចំណាត់ថ្នាក់និងការធ្វើសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានពួរ។

ប្រការ ៦.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធនៃប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ
ចំណាត់ថ្នាក់ខ្ពង់ក្រៅតារាងតុល្យការ ដែលមានចែង
ក្នុងកថាខណ្ឌ ៣-៣.១

ប្រតិបត្តិការទាំងឡាយណាដែលមិនមានចែងក្នុងតារាងខាងក្រោមនេះ ធនាគារត្រូវចាត់ថ្នាក់ខ្នង់ទាំងនេះក្នុងប្រភេទប្រតិបត្តិការ ដែលមានលក្ខណៈស្រដៀងគ្នា បន្ទាប់ពីបានស្នើសុំធនាគារជាតិនៃកម្ពុជា ប្រសិនបើចាំបាច់។

១- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង
- ការធានាលើឥណទាន (ដកចេញហានិភ័យចំពោះអត្តគាហក)
- ការទទួលព្រម (acceptance)
- រូបិយបដិភោគ (endorsement) លើផលបត្រដែលមិនមានឈ្មោះរបស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុមួយផ្សេងទៀត
- សកម្មភាពប្រតិបត្តិការដោយមានឧបាស្រ័យ (recourse)
- កម្រិតឥណទានមិនអាចបដិសេធបាន (irrevocable credit line) ឬការធានាដែលមានលក្ខណៈជំនួសឥណទាន
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យខ្ពស់

២- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម
- ការសន្យាសងប្រាក់តាមឯកសារឥណទាន ដែលបានចេញផ្សាយឬបញ្ជាក់ហើយនៅពេលដែលទំនិញមិនត្រូវបានប្រើជាវត្ថុបញ្ចាំ
- ការធានានិងសញ្ញាបណ្ណឧបត្ថម្ភ (warranties and indemnity bonds) (រួមទាំង tender, performance, customs and tax bonds) និងការធានាដែលមិនមានលក្ខណៈជំនួសឥណទាន
- កិច្ចសន្យាផ្តល់ឥណទានមិនទាន់ប្រើ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាឱ្យខ្ចីដែលមានកាលកំណត់លើសពីមួយឆ្នាំ
- ប្រតិបត្តិផ្សេងទៀតដែលមានហានិភ័យមធ្យម

៣- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យធុនល្មម
- ឯកសារឥណទានដែលត្រូវបានចេញផ្សាយឬបញ្ជាក់ហើយ ទំនិញត្រូវបានប្រើជាវត្ថុបញ្ចាំ និងប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀត
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យធន់ល្មម

៤- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាប
- ឥណទានមិនទាន់ប្រើប្រាស់ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាឱ្យខ្ចីដែលមានកាលកំណត់រហូតពេញមួយឆ្នាំ ឬដែលអាចលុបចោលដោយគ្មានលក្ខខណ្ឌនៅពេលណាក៏បានដោយគ្មានការជូនដំណឹង
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យទាប។

ធ៧-០១-១៣៧ ប្រ.ក

ប្រកាស
ស្តីពី
ឥណទានចំពោះសម្ព័ន្ធញាតិ

ប្រការ ១.-

សម្ព័ន្ធញាតិដូចមានចែងនៅមាត្រាទី៤៩ និង ៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

ប្រការ ២.-

ឥណទាននិងឥណទានលើសសមតុល្យចំពោះសម្ព័ន្ធញាតិត្រូវអនុវត្តតាមលក្ខខណ្ឌធម្មតានៃថេរៈវេលា អត្រាការប្រាក់ រត្តបញ្ចាំ និងកាលវិភាគត្រូវទូទាត់សងវិញ។

លក្ខខណ្ឌធម្មតាក្នុងន័យនេះ គឺជាលក្ខខណ្ឌដែលត្រូវអនុវត្តចំពោះអតិថិជនមិនមែនសម្ព័ន្ធញាតិក្នុងកាលៈទេសៈដូចគ្នា។

ប្រការ ៣.-

បញ្ញត្តិដែលមានចែងក្នុងមាត្រា ២ មិនអនុវត្តចំពោះបំណុលបំពេញលើដើមទុន (Subordinated debts) ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងកាន់កាប់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា ដែលជាក្រុមហ៊ុនមេរបស់ពួកគេឡើយ។

ប្រការ ៤.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០២-១៤៦ ប្រ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០១-១៣៧ ប្រ.ក ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។)

ប្រការ ៤ ថ្មី ចែងដូចខាងក្រោម៖

សរុបឥណទានដក់សល់ថ្លឹងចំពោះសម្ព័ន្ធញាតិ មិនត្រូវឱ្យលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធទេ ទោះជាក្នុងករណីណាក៏ដោយ។ ការគណនាឥណទានសម្ព័ន្ធញាតិមិនត្រូវរួមបញ្ចូលការតម្កល់ប្រាក់នៅទីស្នាក់ការកណ្តាល ឬនៅក្រុមហ៊ុនមេ ក្រោមលក្ខខណ្ឌពីរដូចខាងក្រោម៖

- ទីស្នាក់ការកណ្តាល ឬក្រុមហ៊ុនមេជាធនាគារ
- ត្រូវមានភស្តុតាងបង្ហាញថាធនាគារមានចំណាត់ថ្នាក់ស្មើ ឬខ្ពស់ជាង A- តាមវិធីសាស្ត្រ Standard & Poor ឬតាមវិធីសាស្ត្រសមមូលដោយភ្នាក់ងារចាត់ថ្នាក់ដែលអន្តរជាតិទទួលស្គាល់។

ឥណទានដក់សល់ត្រូវគណនាទៅតាមប្រកាសស្តីពី អនុបាតសាធនភាព (ប្រកាសបច្ចុប្បន្នលេខ ធ៧-០០-៤៦ ប្រ.ក)។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ត្រូវគណនាស្របតាមប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ (ប្រកាសបច្ចុប្បន្នលេខ ធ៧-០១០-១៨២ ប្រ.ក)។

ប្រការ ៥.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ ត្រូវធ្វើប្រតិវេទន៍ប្រចាំត្រីមាសលើឥណទានដែលពាក់ព័ន្ធជូនធនាគារជាតិនៃកម្ពុជាស្របតាមគំរូដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

អត្ថបទចម្លងនៃប្រតិវេទន៍នេះ ត្រូវចម្លងជូនក្រុមប្រឹក្សាភិបាលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២០-៤១៧ ឆ.ត

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០

ជម្រាបមក
លោកបណ្ឌិត ប្រធានសមាគមធនាគារនៅកម្ពុជា

កម្មវត្ថុ ៖ ករណីសមាគមធនាគារនៅកម្ពុជាស្នើសុំគោលការណ៍ណែនាំទៅលើការគណនាព័ត៌មានហិរញ្ញវត្ថុបន្ថែមសម្រាប់កាលបរិច្ឆេទឆ្នាំ២០១៩ និងការស្រាយបំភ្លឺលើនិយមន័យ "សម្ព័ន្ធញាតិ"។

យោង ៖ - លិខិតលេខ ០០៧/២០/ស.ធ.ក ចុះថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សមាគមធនាគារនៅកម្ពុជា
- លិខិតលេខ ០០៦/២០/ស.ធ.ក ចុះថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សមាគមធនាគារនៅកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោកបណ្ឌិត ប្រធានសមាគម ឱ្យបានជ្រាបថា បន្ទាប់ពីបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់លើសំណើរបស់សមាគមធនាគារនៅកម្ពុជា រួចមក ធនាគារជាតិនៃកម្ពុជា សូមធ្វើការណែនាំបន្ថែម ដូចខាងក្រោម៖

ក. គ្រឹះស្ថានត្រូវតែរក្សាការអនុវត្តការគណនាសំវិធានធនទូទៅ ១% តាមប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ដោយសារការអនុវត្តនេះ គឺសម្រាប់គោលបំណងបទប្បញ្ញត្តិប្រុងប្រយ័ត្នតែប៉ុណ្ណោះ។ ចំពោះការបូកបញ្ចូលបំណុលបន្ទាប់បន្សំក្នុងដើមទុនថ្នាក់ទី២ គ្រឹះស្ថានត្រូវអនុវត្តតាមប្រការ ៦ និង ប្រការ ៧ នៃប្រកាសនេះ។

ខ. ដើម្បីទុកពេលឱ្យគ្រឹះស្ថានរៀបចំខ្លួនអនុវត្តស្តង់ដារ CIFRS ឱ្យបានពេញលេញ និងកែសម្រួលយុទ្ធសាស្ត្ររបស់ខ្លួនទាក់ទងនឹងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម (ROUs) ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគ្រឹះស្ថានបន្តអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ និងប្រកាសលេខ ធ៧-០១-១៨៦ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី អចលនទ្រព្យរបស់ធនាគារ ដោយមិនរាប់បញ្ចូលសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម (ROUs) ទៅក្នុងការគណនាអនុបាតសាធនភាព និងអនុបាតអចលនទ្រព្យឡើយ រហូតដល់មានការជូនដំណឹងជាថ្មី។

គ. ដើម្បីគណនាសូចនាករហិរញ្ញវត្ថុសំខាន់ៗនៃព័ត៌មានហិរញ្ញវត្ថុបន្ថែម (Supplementary Information) គ្រឹះស្ថានត្រូវប្រើទិន្នន័យតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ចំពោះទិន្នន័យណាដែលអាចប្រើប្រាស់តាមស្តង់ដារបាន។ ក្នុងករណីទិន្នន័យណាដែលមិនអាចគណនាតាមស្តង់ដារបាន គ្រឹះស្ថានត្រូវប្រើប្រាស់ទិន្នន័យតាមបទប្បញ្ញត្តិវិញ។ ធនាគារជាតិនៃកម្ពុជាបានរៀបចំជាតារាងបញ្ជាក់ពីការគណនាសូចនាករហិរញ្ញវត្ថុសំខាន់ៗទាំង ៤៣ ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។

ឃ. យោងតាមប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព ខ្នង់ ២.៨១ បញ្ជាក់ថា លំហូរចេញដែលទាក់ទងនឹងចំណាយប្រតិបត្តិការរបស់គ្រឹះស្ថាន មិនត្រូវបានរាប់បញ្ចូលនៅក្នុងការគណនាអនុបាតនេះទេ ដូច្នេះ គ្រឹះស្ថានមិនត្រូវបូកបញ្ចូលសិទ្ធិនៃប្រើប្រាស់ទ្រព្យសកម្ម និងភតិសន្យាអកម្ម ក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាពឡើយ។

ង. គ្រឹះស្ថានអាចគណនានិងប្រើប្រាស់ទិន្នន័យទុនបម្រុងតាមបទប្បញ្ញត្តិ សម្រាប់កាលបរិច្ឆេទថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ក្នុងគោលបំណងនៃការប្រៀបធៀបទិន្នន័យស្របតាមស្តង់ដារ CIFRS ១ - ការប្រើលើកដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (First Time Adoption of CIFRS) និង

ច. យោងតាមខ្លឹមសារនិយមន័យ "សម្ព័ន្ធញាតិ" នៅក្នុងចំណុចទី៣ មាត្រា ៤៩ ជំពូកទី១៦ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បុគ្គលណាដែលចូលរួមក្នុងការអភិបាលការដឹកនាំ ការកាន់កាប់ ឬ ការត្រួតពិនិត្យផ្ទៃក្នុង សំដៅដល់៖

១. សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាលទាំងអស់

២. គណៈគ្រប់គ្រងជាន់ខ្ពស់ រួមមានដូចជា៖

- ប្រធាននាយកប្រតិបត្តិ ឬ អគ្គនាយក ឬតំណែងដែលមានកម្រិតស្មើ
- អនុប្រធាននាយកប្រតិបត្តិ ឬ អគ្គនាយករង ឬតំណែងដែលមានកម្រិតស្មើ
- ថ្នាក់ប្រធាននាយកដ្ឋាន ឬតំណែងដែលមានកម្រិតស្មើ
- អនុប្រធាននាយកដ្ឋាន ឬតំណែងដែលមានកម្រិតស្មើ
- សមាជិករបស់គណៈកម្មការកម្រិតគណៈគ្រប់គ្រងទាំងអស់
- ប្រធានសវនករផ្ទៃក្នុង និង
- ប្រធានមុខងារប្រតិបត្តិតាម។

៣. បុគ្គលទាំងឡាយណាដែលស្ថិតក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ (de facto management) ឬបុគ្គលដែលទទួលសិទ្ធិប្រទាន ឬស្តីទី ដែលកាន់តំណែងណាមួយនៃចំណុចទី១ និងទី២ ខាងលើ ក្នុងអំឡុងពេលកាន់តំណែង

៤. ឪពុកម្តាយ ប្តីប្រពន្ធ បងប្អូនបង្កើត កូនបង្កើត របស់បុគ្គលក្នុងតំណែងណាមួយនៃចំណុចទី១ ទី២ និងទី៣ ខាងលើ ក្នុងអំឡុងពេលកាន់តំណែង

៥. បុគ្គលដែលត្រូវបានចាត់ទុកថាជាអត្ថគាហក:តែមួយ (single beneficiary) របស់បុគ្គលក្នុងតំណែងណាមួយនៃចំណុចទី១ ទី២ និងទី៣ ខាងលើ (ក្នុងអំឡុងពេលកាន់តំណែង) និងភាគទុនិក ដែលមានទំនាក់ទំនងទទួលផលពីពាណិជ្ជកម្ម ឬអាជីវកម្ម ដោយផ្ទាល់ ឬដោយប្រយោល និង

៦. បុគ្គលផ្សេងទៀត ដែលធនាគារជាតិនៃកម្ពុជា អាចមានមូលដ្ឋានច្បាស់លាស់កំណត់បានថាមានឥទ្ធិពលក្នុងការសម្រេចចិត្តលើការអនុមតិប្រតិបត្តិការធនាគារ។

ធនាគារជាតិនៃកម្ពុជានៅតែគាំទ្រ និងបន្តដោះស្រាយបញ្ហាពាក់ព័ន្ធនានាចំពោះការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសង្ឃឹមយ៉ាងមុតមាំថាសមាគមធនាគារនៅកម្ពុជានៅតែបន្តការសហការនិងផ្តល់ធាតុចូលសំខាន់ៗដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពខ្ពស់ និងសម្រេចបានលទ្ធផលល្អប្រសើរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោកបណ្ឌិត ប្រធានសមាគម ចូលរួមសហការ និងផ្សព្វផ្សាយដល់សមាជិកសមាគមធនាគារនៅកម្ពុជាឱ្យបានជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោកបណ្ឌិត ប្រធានសមាគម ទទួលនូវការរាប់អាន អំពីខ្ញុំ។

ត.ប. ឧេសានិបាល
អគ្គនាយកត្រួតពិនិត្យ
ហត្ថលេខានិងត្រា៖ **វ៉ែត សុវណ្ណនរៈ**

សូចនាករហិរញ្ញវត្ថុសំខាន់ៗ

Financial Soundness Indicators

Capital

1 Equity to Total Asset (A/B)
- A Equity
- B Total Assets

2 Capital Tier I to Total Assets (A/B)
- A Capital tier I*
- B Total Assets

3 Capital Tier I to Risk Weighted Asset (A/B)
- A Capital Tier I *
- B RWA*

4 Capital Tier I + Tier II to Risk Weighted Asset (A/B)
- A Capital Tier I + Tier II *
- B RWA*

5 Net Worth to Total Assets (A/B)
- A Net Worth*
- B Total Assets

6 Solvency Ratio (A/B)
- A Net Worth*
- B RWA*

7 Debt to Total Asset (A/B)
- A Total Liabilities
- B Total Assets

8 Debt to Equity (A/B)
- A Debt
- B Equity

9 Dividend to Net Profit (A/B)
- A Dividend
- B Net Profit

Asset Quality

10 Banking Reserve to Total Loans (A/B)
- A Banking reserves
- B Total loans (gross)

11 Banking Reserve to Total Assets (A/B)
- A Banking reserves
- B Total Assets

12 NPL to Total Loan (A/B)
- A NPL*
- B Total loans (gross)

13 NPL to Total Asset (A/B)
- A NPL*
- B Total Assets

14 Classified Asset to Total Loan (A/B)
- A Classified Assets*
- B Total loans (gross)

15 Classified Asset to Total Asset (A/B)
- A Classified Assets*
- B Total Assets

16 Classified Asset to Equity (A/B)
- A Classified Assets*
- B Equity

17 Loan to Related Parties to Total Loan (A/B)
- A Loan to Related Parties*
- B Total loans (gross)

18 Large Exposure to Total Loan (A/B)
- A Large Exposure*
- B Total loans (gross)

19 Loan to Related Parties to Net Worth (A/B)
- A Loan to Related Parties*
- B Net Worth*

20 Large Exposure to Total Loan (A/B)
- A Large Exposure*
- B Net Worth*

21 General Provision to Total Loan (A/B)
- A General Provision*
- B Total loans (gross)

22 Specific Provision to Total Loan (A/B)
- A Specific Provision*
- B Total loans (gross)

23 Specific Provision to NPL (A/B)
- A Specific Provision*
- B NPL*

24 All Allowances to Total Assets (A/B)
- A Total All Allowances*
- B Total Assets

25 Loans to Deposits (A/B)
- A Total loans to non-banks customers (gross)
- B Customer's deposits

Earnings

26 ROA (A/B)
- A Net Profit
- B Total assets

27 ROE (A/B)
- A Net Profit
- B Equity

28 Gross Yield (A/B)
- A Interest income
- B Total assets

29 Net Interest Margin (NIM) to Total Asset ((A-B)/C)
- A Interest Income
- B Interest Expense
- C Total assets

30 Other Income (OTINC) (A/B)
- A Other Incomes
- B Total Assets

31 Provision to Total Assets (A/B)
- A Provision*
- B Total assets

32 Overhead (A/B)
- A Non-interest expense
- B Total assets

33 Net Income Before Tax (NIBT) (A/B)
- A Net Income before Tax
- B Total assets

34 Tax to Total Assets (A/B)
- A Tax
- B Total assets

35 Interest Margin to Gross Income ((A-B)/C)
- A Interest income
- B Interest expense
- C Gross Income

36 Non-interest Income to Gross Income (A/B)
- A Non-interest income
- B Gross Income

37 Non-interest Expense to Gross Income (A/B)
- A Non-interest expense
- B Gross Income

38 Times Interest Earned ((A+B)/C)
- A Income before tax
- B Interest Expense
- C Interest Income

Liquidity

39 Liquid Asset (A/B)
- A Liquid Asset
- B Total Assets

40 Short-term Liabilities (A/B)
- A Short-term liabilities (<one year)
- B Total Assets

41 Net Liquit Assets ((A-B)/C)
- A Liquid Asset
- B Short-term liabilities (<one year)
- C Total Liabilities

42 Quick Ratio (A/B)
- A Quick Assets
- B Current Liabilities

43 Deposits to Total Loans (A/B)
- A Total customers' deposits
- B Total loans to non-bank customers (gross)

កំណត់សម្គាល់ ៖ សញ្ញា « * » សំដៅដល់ទិន្នន័យតាមបទប្បញ្ញត្តិ ហើយក្រៅពីនេះ ជាទិន្នន័យតាមស្តង់ដា CIFRS ។

Note: "" refers to regulatory figures while the rest are based on CIFRS figures.*

ធ៧-០១-១៨៦ ប្រ.ក

ប្រកាស
ស្តីពី
អចលនទ្រព្យរបស់ធនាគារ

ប្រការ ១.-

កម្មសិទ្ធិលើអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារត្រូវបញ្ជត្តិតាមខ្លឹមសារនៃប្រកាសនេះ។

ប្រការ ២.-

គ្រឹះស្ថានធនាគារអាចទទួលយកអចលនទ្រព្យបានតែក្នុងករណីពីរ៖

- អចលនទ្រព្យទាំងនោះត្រូវបានប្រើប្រាស់ដោយផ្ទាល់សម្រាប់ប្រតិបត្តិការធនាគារ
- ឬបើអចលនទ្រព្យមិនត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការធនាគារនោះទេ ក៏អចលនទ្រព្យទាំងនោះបានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ ដោយការរឹបអូសតាមច្បាប់នូវរបស់ធានា និងជួយកាត់បន្ថយហានិភ័យលើបំណុលអាក្រក់។

ប្រការ ៣.-

អចលនទ្រព្យដែលធ្វើលទ្ធកម្មដោយធនាគារសម្រាប់គោលដៅប្រតិបត្តិការ ត្រូវតែរក្សាមិនឱ្យលើសពី ៣០% នៃមូលនិធិផ្ទាល់សុទ្ធសរុប ដូចមានកំណត់ក្នុងប្រកាសលេខ ធ៧-០០-៥៧ ប្រ.ក។ *(ប្រកាសលេខ ធ៧-០០-៥៧ ប្រ.ក ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)*

ប្រការ ៤.-

អចលនទ្រព្យដែលគ្មានទំនាក់ទំនងផ្ទាល់ជាមួយប្រតិបត្តិការធនាគារ ត្រូវលក់ចេញមិនឱ្យលើសពីមួយឆ្នាំ ក្រោយកាលបរិច្ឆេទដែលអចលនទ្រព្យបានក្លាយជាទ្រព្យសម្បត្តិរបស់ធនាគារ។ អចលនទ្រព្យនឹងត្រូវបានកត់ត្រាក្នុងបញ្ជីគណនីរបស់ធនាគារតាមតម្លៃជាក់ស្តែងសមស្រប។

ប្រការ ៥.-

ការរំលោភលើបញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលរងការពិន័យ និងទណ្ឌកម្មដូចដែលមានចែងនៅត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

ធនាគារត្រូវរាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ពីការអនុវត្តស្របតាមខ្លឹមសារនៃប្រកាសនេះ តាមគំរូដែលកំណត់ដោយសារាចរណែនាំ។

ប្រការ ៧.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៦-២២៦ ប្រ.ក

ប្រកាស
ស្តីពី
ការគ្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ឥណទានធំ (Large Exposure) គឺជាចំនួនសរុបនៃឥណទាន ឬការសន្យាតាមហត្ថលេខា ដែលកើតចេញពីប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយជាមួយអត្តគាហកតែមួយ ដែលមានចំនួនប្រាក់លើសពីដប់ភាគរយ (១០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ។ ឥណទានដែលមានចំនួនប្រាក់ធំសំដៅដល់ឥណទាន ដែលមានចំនួនប្រាក់ខ្ពស់បំផុតនៃប្រភេទឥណទានណាមួយ ដូចខាងក្រោម ដែលតទៅនេះហៅថា "ឥណទាន"៖

ក- សមតុល្យនៃឥណទាន ឬនៃការសន្យាតាមហត្ថលេខា

ខ- ចំនួនប្រាក់នៃឥណទាន ឬនៃការសន្យាតាមហត្ថលេខា ដែលបានអនុញ្ញាត។

ប្រការ ២.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាជានិច្ចនូវអនុបាតនៃឥណទានធំសរុប ដែលកើតចេញពីប្រតិបត្តិការជាមួយអត្តគាហកតែមួយ មិនឱ្យលើសពីម្ភៃភាគរយ (២០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ។

ប្រការ ៣.-

សម្រាប់ប្រកាសនេះ មូលនិធិផ្ទាល់សុទ្ធត្រូវបានគណនាស្របតាមខ្លឹមសារនៃប្រកាសលេខ ធ៧-០០-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ *(ប្រកាសលេខ ធ៧-០០-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)*

សម្រាប់ប្រកាសនេះ ឥណទានដែលជាប់ទាក់ទងទៅនឹងហានិភ័យនៃការខកខានមិនបានសងរបស់បដិភាគី ត្រូវតែបានថ្លឹង (Risk Weighted) ដូចមានកំណត់នៅក្នុងប្រការ ៣ នៃប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ លេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០។ ខ្ទង់ទាំងឡាយដែលបានដកចេញនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ មិនត្រូវបានចាត់ទុកថាជាហានិភ័យឥណទានទេ។

ប្រការ ៤.-

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមកតាមបែបមួយ ដែលថានៅពេលដែលបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះដាច់ខាតនឹងនាំឱ្យបុគ្គលផ្សេងទៀតមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬ ច្រើននៅពេលណាដែល៖

ក- បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ- បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ- បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ (de facto management)

ឃ- បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពីដប់ភាគរយ (១០%) ហើយពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នា ដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (Franchise)។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ។

ប្រការ ៥.-

ចំពោះឥណទានធំ (Large Exposure) ដែលមានការធានាពីធនាគារផ្សេងទៀត ឬពីគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ការថ្លឹង (Risk Weighted) ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះត្រូវបានកាត់បន្ថយពាក់កណ្តាល និងដោយត្រូវមានការអនុញ្ញាតជាមុនពី ធនាគារជាតិនៃកម្ពុជា ហើយស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម៖

ក- លិខិតដែលផ្តល់ដោយធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិជាអ្នកធានាត្រូវបញ្ជាក់អំពីការសន្យាជាផ្លូវការក្នុងការទូទាត់សងវិញភ្លាមនូវសមតុល្យនៃឥណទាន នៅពេលដែលករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម បានកើតឡើង៖

- ការសងរំលស់មួយគ្រា ត្រូវបានខកខានមិនបានទូទាត់សងនៅថ្ងៃកំណត់ ឬ
- ឥណទានបានក្លាយទៅជាឥណទានមិនដំណើរការ

ខ- លិខិតធានាត្រូវចុះហត្ថលេខា និងទទួលដឹងឮពីអាជ្ញាធរត្រួតពិនិត្យរបស់គ្រឹះស្ថានធនាគារឬពីទីស្នាក់ការកណ្តាលនៃគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញលិខិតធានានោះ។

ប្រការ ៦.-

យោងទៅតាមការស្នើសុំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចបង្កើនអនុបាតអតិបរមា ដែលមានចែងនៅក្នុងប្រការ ២ នៃប្រកាសនេះទៅដល់កម្រិតអតិបរមាមិនឱ្យលើសពីសាមសិបប្រាំភាគរយ (៣៥%) នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន ដែលផ្តល់ឥណទាននៅក្រោមលក្ខខណ្ឌដូចខាងក្រោម៖

ក- ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់យ៉ាងហោចណាស់ថា "ល្អ" ដោយផ្អែកលើចំណាត់ថ្នាក់ផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ឬទទួលបានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ពីភ្នាក់ងារចាត់ថ្នាក់អន្តរជាតិ។

ខ- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីមានភាពរឹងមាំ ដែលរួមមានផែនការអាជីវកម្ម សាធនភាព លទ្ធភាពរកប្រាក់ចំណេញ និងការគ្រប់គ្រងមានលក្ខណៈល្អប្រសើរ។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវផ្តល់ឱ្យធនាគារជាតិនៃកម្ពុជា នូវរបាយការណ៍សវនកម្មហិរញ្ញវត្ថុ របាយការណ៍វិភាគឥណទាន និងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត នៅពេលដាក់ពាក្យស្នើសុំផ្តល់ឥណទានលើសពីសមាមាត្រដែលមានចែងក្នុងប្រការ ២ នៃប្រកាសនេះ។

ប្រការ ៧.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរក្សាជានិច្ចនូវអនុបាតឥណទានធំ ដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ដែលមានចំនួនសរុបអតិបរមាមិនឱ្យលើសពីបីរយភាគរយ (៣០០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ។

ប្រការ ៨.-

ឥណទានធំដូចដែលមានចែងនៅក្នុងប្រការ ១ ត្រូវស្ថិតនៅក្រោមនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យផ្ទៃក្នុងជាពិសេសដោយកម្រិតកំណត់នៃការប្រគល់សិទ្ធិក្នុងការសម្រេចឥណទាន ឬដោយការធ្វើយ៉ាងណាឱ្យចំនួនអតិបរមា នៃអនុបាតដែលមានចែងនៅក្នុងប្រការ ២ ដល់ប្រការ ៧ នៃប្រកាសនេះ ត្រូវបានគោរពគ្រប់ពេលវេលា។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវប្រកាន់យកនូវរាល់ជំហានចាំបាច់ដើម្បីរក្សាទុកនូវការកត់ត្រាមជ្ឈការពេញលេញចំពោះឥណទានរបស់ខ្លួន ជាពិសេសឥណទានទាំងឡាយណាដែលផ្តល់ចំពោះអត្តគាហក ដែលមានចំណងទាក់ទងគ្នាទៅវិញទៅមកតាមខ្លឹមសារនៃប្រការ ៥ នៃប្រកាសនេះ។

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យផ្តល់នូវរបាយការណ៍ ស្តីពី ជំហានទាំងឡាយដែលបានអនុវត្ត។

ប្រការ ៩.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើប្រតិវេទន៍ប្រចាំខែជូនធនាគារជាតិនៃកម្ពុជាស្តីពីឥណទានធំរបស់ខ្លួន តាមគំរូឧបសម្ព័ន្ធដែលមានភ្ជាប់ជាមួយប្រកាសនេះ។

ប្រការ ១០.-

ប្រកាសនេះមិនត្រូវបានអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ។

ប្រការ ១១.-

ប្រកាសលេខ ធ៧-០០-៥២ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១២.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជានិងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៩-២១៦ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់របាយការណ៍ឥណទានធំ និង
ពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា គ្រឹះស្ថាន ត្រូវពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ប្រចាំត្រីមាស នូវឥណទានធំបំផុតចំនួន ៥០។ គ្រឹះស្ថានត្រូវសម្រប និងលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ខ្លួន ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

ប្រការ ២.-

ហានិភ័យឥណទានប្រមូលផ្តុំអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ដូច្នេះ តម្រូវឱ្យមានការពិនិត្យតាមដានជាពិសេស ដើម្បីវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃការធ្លាក់ចុះស្ថានភាពអ្នកខ្ចីធំៗ ក្នុងកាល:ទេស:ដែលសេដ្ឋកិច្ចមិនអំណោយផល។

លើសពីនេះ ទោះបីមានបទប្បញ្ញត្តិទាក់ទងនឹងហានិភ័យឥណទានធំក្តី ក៏ហានិភ័យឥណទានប្រមូលផ្តុំ ត្រូវតែសមស្របទៅនឹងហានិភ័យដែលអាចទទួលយកបាន និងភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។ ហានិភ័យឥណទានដែលត្រូវបានចាត់ទុកថាប្រមូលផ្តុំខ្លាំងពេក តម្រូវឱ្យមានការវាយតម្លៃឡើងវិញនូវគោលនយោបាយ និងកម្រិតកំណត់ឥណទានជាបន្តបន្ទាប់ និងប្រចាំគ្រា។

ប្រការ ៣.-

រាល់ត្រីមាស គ្រឹះស្ថានត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិនូវបញ្ជីអ្នកខ្ចីធំបំផុត ជាឯកត្តជន ឬជាក្រុម ចំនួនហាសិប (៥០)។ របាយការណ៍នេះ ត្រូវមានជាអប្បបរមានូវទិន្នន័យនិងព័ត៌មានទាំងអស់ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ នូវការវាយតម្លៃសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុជារួមរបស់អ្នកខ្ចី ជាពិសេស បើឥណទានត្រូវបានធ្វើចំណាត់ថ្នាក់មិនល្អ រាល់ឯកសារ ភស្តុតាង ដែលមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ ត្រូវបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ ដើម្បីវាយតម្លៃអំពីសក្តានុពលនៃការខាតបង់ និងផលប៉ះពាល់ផ្សេងទៀត ជាពិសេស អំពីស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាពរបស់គ្រឹះស្ថាន។

របាយការណ៍ប្រចាំត្រីមាសទាំងនេះ ត្រូវមានបញ្ជាក់អំពីវិធានការទាំងអស់ដែលគ្រឹះស្ថានបាននិងត្រូវអនុវត្តដើម្បីការពារផលប្រយោជន៍របស់គ្រឹះស្ថាន។

ជំពូក ២
ការរួមបញ្ចូលគ្នាទ្រព្យហានិភ័យ

ប្រការ ៤.-

នៅពេលដែលឯកត្តជន ឬនីតិបុគ្គលពីរ ឬច្រើនត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ដោយសារតែមានទំនាក់ទំនងទៅវិញទៅមក គ្រឹះស្ថានត្រូវបូកសរុបហានិភ័យទាំងអស់ឱ្យបានត្រឹមត្រូវ និងរាយលម្អិតអ្នកខ្ចីនីមួយៗ និងកម្រិតអនុម័តឥណទានដែលបង្កើតបានជាហានិភ័យរួមបញ្ចូលគ្នា។

ប្រការ ៥.-

ត្រូវបានចាត់ទុកថាជាអត្តគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមក ដែលប្រសិនបើបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះ នឹងនាំឱ្យបុគ្គលផ្សេងទៀតត្រូវតែមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬច្រើននៅពេលណាដែល៖

ក- បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ- បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ- បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ (de facto management)

ឃ- បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពី ដប់ភាគរយ (១០%) ហើយពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នាដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (franchise)។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្តគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ។

ប្រការ ៦.-

លើសពីនេះ គ្រឹះស្ថានអាចកំណត់នូវកត្តាពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ឬទំនាក់ទំនងទៅវិញទៅមកផ្សេងទៀត ជាពិសេសដោយផ្អែកលើការវិភាគប្រភពដើម និងការប្រមូលផ្តុំនៃលំហូរសាច់ប្រាក់។

ប្រការ ៧.-

គ្រឹះស្ថានត្រូវរួមបញ្ចូលគ្នានូវហានិភ័យទាំងអស់ឱ្យបានសមស្រប ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពហានិភ័យទាំងមូលទៅលើសំណុំកូនបំណុលដែលមានទំនាក់ទំនងជាមួយគ្នាជាអ្នកខ្ចីតែមួយ។

ជំពូក ៣
ទម្រង់ និងខ្លឹមសារនៃរបាយការណ៍

ប្រការ ៨.-

គ្រឹះស្ថានត្រូវរាយការណ៍តាមគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ របាយការណ៍នេះត្រូវតែមានខ្លឹមសារគ្រប់គ្រាន់អាចទទួលយកបាន។ ហានិភ័យឥណទានធំបំផុតចំនួន ៥០ ត្រូវតែបានបង្ហាញតាមលំដាប់ចំនួនប្រាក់ថយចុះ។

ប្រការ ៩.-

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ត្រូវតែសម្គាល់អត្តសញ្ញាណ ឱ្យបានច្បាស់លាស់ និងត្រូវតែបញ្ជាក់អំពីប្រភេទនៃទំនាក់ទំនងទៅវិញទៅមក។ ព័ត៌មានលម្អិតអំពីទំនាក់ទំនង ក្នុងចំណោមសមាសភាពទាំងឡាយនៃក្រុមអ្នកខ្ចី ត្រូវមានឧបសម្ព័ន្ធភ្ជាប់មកជាមួយរបាយការណ៍។

ព័ត៌មានអំពីអត្តសញ្ញាណទាំងនោះត្រូវមានជាអប្បបរមា ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ នាមនិងគោត្តនាមទាំងអស់ដែលប្រើជាផ្លូវការ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានមុខរបរ/វិជ្ជាជីវៈ និង វិស័យសេដ្ឋកិច្ច
- នីតិបុគ្គល៖ នាមករណ៍ យីហោ លេខចុះបញ្ជីពាណិជ្ជកម្ម ថ្ងៃបង្កើតក្រុមហ៊ុន អាសយដ្ឋានក្រុមហ៊ុន មុខរបរ វិស័យសេដ្ឋកិច្ច និងព័ត៌មានផ្សេងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃអត្តសញ្ញាណ។

មុនពេលរួមបញ្ចូលហានិភ័យរបស់នីតិបុគ្គល និង/ឬ រូបវន្តបុគ្គលដែលត្រូវបានចាត់ថាជាអ្នកខ្ចីតែមួយ គ្រឹះស្ថានត្រូវរាយលម្អិតបុគ្គលនីមួយៗតាមកម្រិតអនុម័តឥណទានទាំងអស់។

ការរួមបញ្ចូលគ្នាត្រូវអនុវត្តដោយបូកសរុបដោយឡែកពីគ្នារវាងសមតុល្យដក់សល់ដុលក្នុងតារាងតុល្យការ និងសមតុល្យជាប់កិច្ចសន្យានៃខ្ទង់ក្រៅតារាងតុល្យការ។

ប្រការ ១០.-

ចំនួនហានិភ័យឥណទានក្នុងតារាងតុល្យការត្រូវតែរាយការណ៍ដោយប្រើចំនួនដុល ដែលជាចំនួនប្រាក់ដើមដក់សល់ ដោយមិនបញ្ចូលសំវិធានធនជាក់លាក់ និងការប្រាក់លើកលែងតែការប្រាក់នោះត្រូវបានបូកបញ្ចូលជាប្រាក់ដើមដូចមានចែងក្នុងកិច្ចសន្យា។

ហានិភ័យឥណទានធំត្រូវបានរាយលម្អិតតាមកម្រិតអនុម័តឥណទាននិងតាមអ្នកខ្ចីនីមួយៗ។ ព័ត៌មានអប្បបរមាដែលត្រូវមានគឺ ប្រភេទហានិភ័យ (ឥណទានវិបាកបន៍ ឬឥណទាន) ប្រាក់ដើមដក់សល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង ប្រភេទនៃការរំលស់ និងកាលវិសាន។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

ប្រការ ១១.-

ហានិភ័យក្រៅតារាងតុល្យការត្រូវតែបានរាយការណ៍ ដោយបូកបញ្ចូលនូវចំនួនសមតុល្យជាប់កិច្ចសន្យា ដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍។

កម្រិតអនុម័តឥណទាននោះ ត្រូវតែបានរាយលម្អិតតាមអត្តគាហកនីមួយៗ ហើយឆ្លុះបញ្ចាំងពីចំនួនសមតុល្យជាប់កិច្ចសន្យាដែលនៅសល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង និងពីកាលវិសានបើមាន ហើយត្រូវតែមានបញ្ជាក់ច្បាស់អំពីប្រភេទប្រតិបត្តិការ (ឥណទានវិបាកបន៍ដែលមិនបានប្រើការសន្យាឥណទានដែលមិនទាន់បានប្រើប្រាស់ ការធានានិងប្រភេទនៃការធានា)។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្នង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

ជំពូក ៤
កាលបរិច្ឆេទនៃរបាយការណ៍

ប្រការ ១២.-

គ្រឹះស្ថានទាំងអស់ ត្រូវផ្ញើរបាយការណ៍អំពីហានិភ័យឥណទានធំបំផុតចំនួន ៥០ ប្រចាំត្រីមាសគិតត្រឹមចុងខែមីនា មិថុនា កញ្ញា និងធ្នូ មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់។

ជំពូក ៥
ទណ្ឌកម្ម

ប្រការ ១៣.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូក ៦
អវសានប្បញ្ញត្តិ

ប្រការ ១៤.-

ប្រកាសនេះមិនអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ។

ប្រការ ១៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានអង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៩-០៧៥ ប្រ.ក

ប្រកាស
ស្តីពី
ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ច ឱ្យបានគ្រប់គ្រាន់ ក្នុងរយៈពេលតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងប្រតិបត្តិការសាច់ប្រាក់ងាយស្រួលប្រកបដោយសុវត្ថិភាព និងភាពរឹងមាំ។

ប្រការ ២.-

ពាក្យបច្ចេកទេសដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ៖

រយៈពេលមូលដ្ឋាន ៖ ជារយៈពេល១៤ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវយកប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ មកកំណត់ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា

រយៈពេលតម្កល់ ៖ ជារយៈពេល១៤ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្ម បម្រុងដើម្បីអនុលោមតាមប្រកាសនេះ

មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ៖ ជាចំនួនសរុបនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ក្នុងរយៈពេលមូលដ្ឋានចែកនឹង១៤។ ផលចែកដែលជាមធ្យមភាគប្រចាំថ្ងៃ ត្រូវប្រើសម្រាប់កំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់។ មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ត្រូវគណនាដោយឡែកពីគ្នា សម្រាប់ប្រាក់រៀល និងរូបិយប័ណ្ណ ស្របទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

អត្រាប្រាក់បម្រុងកាតព្វកិច្ច ៖ ជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកជាមធ្យមក្នុងរយៈពេលតម្កល់។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់សម្រាប់ប្រាក់រៀល និងសម្រាប់រូបិយប័ណ្ណ តាមរយៈបទប្បញ្ញត្តិដោយឡែក។

មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់ ៖ ជាប្រាក់បម្រុងកាតព្វកិច្ចដែលបានតម្កល់បូកនឹងចំនួនទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១៤ថ្ងៃ ចែកនឹង ១៤។ មធ្យមភាគនៃការរក្សាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ត្រូវបានគណនាដោយឡែកពីគ្នា ចំពោះប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ ស្របទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ៖ ជាផលគុណរវាងអត្រាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ជាមួយមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ។ ចំនួននេះត្រូវបានគណនានៅមុនរយៈពេលត្រូវតម្កល់ ហើយត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាទៅតាមកាលកំណត់។ ប្រាក់បម្រុងកាតព្វកិច្ច

អប្បបរមាត្រូវបានគណនាសារជាថ្មី និងដោយឡែកពីគ្នារៀងរាល់១៤ថ្ងៃ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ជារៀល និងជារូបិយប័ណ្ណ។

កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៖ ជាចំនួន ៨០% នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវតម្កល់ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលតម្កល់នៅក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាននីមួយៗដែលមាននៅធនាគារជាតិនៃកម្ពុជា។ កម្រិតអប្បបរមានេះ ត្រូវអនុវត្តទាំងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងរូបិយប័ណ្ណផ្សេងៗ។

ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់ ៖ ជាចំនួនទ្រព្យសកម្មបម្រុងដែលត្រូវរក្សាក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់រកមធ្យមភាគនៃទ្រព្យសកម្មអប្បបរមា និងដើម្បីឱ្យស្របទៅតាមការកំណត់របស់បទប្បញ្ញត្តិជាធរមាន។

ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់ រួមមានដូចជា៖

- ប្រាក់រៀល ៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ជារៀល ក្នុងរយៈពេលតម្កល់ ១៤ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា
- រូបិយប័ណ្ណ ៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា។

របាយការណ៍ប្រាក់បម្រុងកាតព្វកិច្ច មានពីរប្រភេទ៖

- របាយការណ៍រយៈពេលមូលដ្ឋាន ៖ ជាតារាងដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ជាមួយនេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងពេល៣ថ្ងៃ បន្ទាប់ពីចប់រយៈពេលមូលដ្ឋាន។ របាយការណ៍នេះត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០% និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀលនិងរូបិយប័ណ្ណ។
- របាយការណ៍រយៈពេលតម្កល់ ៖ ជាតារាងដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ជាមួយនេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងពេល៣ថ្ងៃ បន្ទាប់ពីចប់រយៈពេលតម្កល់។ របាយការណ៍នេះ ត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀលនិងរូបិយប័ណ្ណ ហើយត្រូវបង្ហាញភស្តុតាងថាបានប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ៨០%។

ជំពូក ២
ប្រាក់បម្រុងកាតព្វកិច្ច

ប្រការ ៣.-

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍អនុវត្តគោលនយោបាយរូបិយវត្ថុផង និងជាកាតព្វកិច្ចត្រួតពិនិត្យគ្រឹះស្ថានផង។ អត្រាប្រាក់បម្រុងកាតព្វកិច្ចអាចមានការផ្លាស់ប្តូរទៅតាមគោលដៅអនុវត្តគោលនយោបាយរូបិយវត្ថុ និងកាលៈទេសៈសេដ្ឋកិច្ចសកល។ ដូច្នេះ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថាន ត្រូវបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលប្រុងប្រយ័ត្ន និងសមស្របដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

ជំពូក ៣
ទ្រព្យសកម្មអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

ប្រការ ៥.-

គ្រឹះស្ថាន ត្រូវរក្សាទុកជាមធ្យមនូវសមតុល្យគ្រប់គ្រាន់នៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា។

ប្រការ ៦.-

សាច់ប្រាក់ក្នុងដៃ មិនត្រូវចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន ដើម្បីតម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាឡើយ។

ទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម៖

- សមតុល្យប្រចាំថ្ងៃក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ជារៀល របស់គ្រឹះស្ថាន ដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា
- សមតុល្យប្រចាំថ្ងៃក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណរបស់គ្រឹះស្ថានដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា។

ជំពូក ៤
រយៈពេលមូលដ្ឋាន និងរយៈពេលតម្កល់

ប្រការ ៧.-

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្អែកលើរយៈពេលពីរផ្សេងគ្នា ដែលមានរយៈពេល ១៤ ថ្ងៃប្រតិទិនជាបន្តបន្ទាប់ គឺ "រយៈពេលមូលដ្ឋាន" និង "រយៈពេលតម្កល់"។

ប្រការ ៨.-

រយៈពេលមូលដ្ឋាន ជារយៈពេល១៤ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានគណនាមធ្យមភាគប្រចាំថ្ងៃនៃប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ដើម្បីកំណត់ប្រាក់បម្រុងកាតព្វកិច្ចមធ្យមប្រចាំថ្ងៃ និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ សម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា។ ចំនួនប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមដែលត្រូវរក្សាទុកក្នុងរយៈពេលតម្កល់ ត្រូវគណនាដោយយកមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗក្នុងរយៈពេលមូលដ្ឋាន គុណជាមួយអត្រាប្រាក់បម្រុងកាតព្វកិច្ចជាធរមាន។

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលមូលដ្ឋាន ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

ប្រការ ៩.-

រយៈពេលតម្កល់ចាប់ផ្តើមនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

រយៈពេលតម្កល់មានរយៈពេល១៤ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មដែលអាចទទួលយកបានស្របតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមនៅគ្រប់១៤ថ្ងៃនៃរយៈពេលមូលដ្ឋាន។

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលតម្កល់ ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលតម្កល់។

ជំពូក ៥
មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់

ប្រការ ១០.-

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្តល់នូវភាពទន់ភ្លន់ខ្លះ ដោយសារទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ត្រូវបានគិតជាមធ្យមក្នុងរយៈពេលតម្កល់។ ប៉ុន្តែ គ្រឹះស្ថានត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីធានាប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់អប្បបរមា ដូចមានចែងនៅក្នុងប្រការ ១៣ នៃ ប្រកាសនេះ។

មធ្យមភាគទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់លើកលែងតែសមតុល្យគណនីជាត់ទាត់ត្រូវកំណត់តាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា នៅទូទាំងរយៈពេលត្រូវតម្កល់។ គ្រឹះស្ថានបានប្រតិបត្តិតាមប្រកាសនេះ ប្រសិនបើចំនួនមធ្យមភាគទ្រព្យសកម្មដែលអាចទទួលយកបានត្រូវបានរក្សានៅគ្រប់រយៈពេលតម្កល់យ៉ាងតិចបំផុតស្មើ ឬលើសពី ១០០% (មួយរយភាគរយ) នៃចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលបានគណនាដោយផ្អែកលើតួលេខនៅក្នុងរបាយការណ៍រយៈពេលមូលដ្ឋានពីមុនមក។

ប្រការ ១១.-

គណនីជាត់ទាត់ជាប្រាក់រៀលរបស់គ្រឹះស្ថានមានសមតុល្យវិជ្ជមាន ជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល។ សមតុល្យនេះនឹងត្រូវបានយកមកបូកបញ្ចូលគ្នារាល់ថ្ងៃ ហើយសមតុល្យសរុបនេះត្រូវបូកជាមួយសមតុល្យសរុបគណនីប្រាក់បម្រុងកាតព្វកិច្ចនៅចុងគ្រានៃរយៈពេលតម្កល់។ ផលចែករវាងចំនួនសរុបខាងលើជាមួយ ១៤ ត្រូវបានយកមកប្រៀបធៀបជាមួយចំនួនប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវប្រតិបត្តិតាម។

ប្រការ ១២.-

សមតុល្យគណនីជាត់ទាត់ជារូបិយប័ណ្ណ មិនមែនជាទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណទេ។

ជំពូក ៦
កម្រិតកំណត់អប្បបរមានៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ និងឱនភាពប្រាក់បម្រុងកាតព្វកិច្ច

ប្រការ ១៣.-

ទោះបីជាការគិតមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចក្នុងរយៈពេល ១៤ ថ្ងៃ អនុញ្ញាតឱ្យមានភាពទន់ភ្លន់ខ្លះ ក៏គ្រឹះស្ថានត្រូវរក្សាទុកជាអចិន្ត្រៃយ៍ក្នុងរយៈពេលតម្កល់១៤ថ្ងៃ នូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង ៨០% នៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចដែលបានកំណត់ក្នុងរយៈពេលមូលដ្ឋាន ជារៀល និងជារូបិយប័ណ្ណ។

គ្រឹះស្ថានត្រូវប្រតិបត្តិតាមប្រចាំថ្ងៃនូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០% នៅទូទាំងរយៈពេលតម្កល់ ដោយរក្សាឱ្យបានយ៉ាងតិចបំផុតនូវចំនួនសមតុល្យក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារៀលនៅធនាគារជាតិនៃកម្ពុជា។ ទោះបីជាសមតុល្យគណនីជាត់ទាត់ជាទ្រព្យសកម្មដែលអាចទទួលយកបានជាប្រាក់រៀល ក៏គ្រឹះស្ថានមិនត្រូវបញ្ចូលសមតុល្យគណនីជាត់ទាត់នេះ ជាមួយសមតុល្យគណនីទ្រព្យសកម្មបម្រុង ដើម្បីឱ្យប្រតិបត្តិតាមកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០%។

ប្រការ ១៤.-

ការល្មើសនឹងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង ៨០% និងការរក្សាទុកមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាមិនគ្រប់គ្រាន់ក្នុងរយៈពេលតម្កល់ ត្រូវចាត់ទុកថាមានឱនភាពប្រាក់បម្រុងកាតព្វកិច្ចនឹងរងការជាកពិន័យ និងវិធានការត្រួតពិនិត្យគ្រឹះស្ថានដោយធនាគារជាតិនៃកម្ពុជា។

ជំពូក ៧
ការពិន័យនិងវិធានការត្រួតពិនិត្យ

ប្រការ ១៥.-

ករណីមានឱនភាពកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង ៨០% នៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ ត្រូវរងការជាកពិន័យស្មើនឹងពីរភាគរយ (២%) នៃចំនួនឱនភាពនោះ (៨០% នៃប្រាក់បម្រុងកាតព្វកិច្ច ដកប្រាក់តម្កល់ក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច) ចំពោះឱនភាពលើកទី ១ នៃរយៈពេលតម្កល់។ ក្នុងករណីដែលមានឱនភាពដដែលកើតឡើងនៅរយៈពេលតម្កល់តែមួយនោះការជាកពិន័យនឹងកើនដល់បួនភាគរយ (៤%)។

ប្រការ ១៦.-

ឱនភាពប្រាក់បម្រុងកាតព្វកិច្ច ដោយសារការតម្កល់មិនគ្រប់គ្រាន់នូវមធ្យមភាគនៃទ្រព្យសកម្មបម្រុងក្នុងរយៈពេលតម្កល់ ត្រូវទទួលរងការជាកពិន័យស្មើនឹងពីរភាគរយ (២%) នៃចំនួនប្រាក់ឱនភាពដែលបានមកពីភាពខុសគ្នារវាងចំនួននៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់ និងមធ្យមភាគទ្រព្យសកម្មបម្រុងដែលបានតម្កល់។ ក្នុងករណីមានឱនភាពជាបន្តបន្ទាប់ នោះការជាកពិន័យនឹងត្រូវកើនឡើងដល់បួនភាគរយ (៤%)។

ប្រការ ១៧.-

ការល្មើសកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ និងឱនភាពនៃប្រាក់បម្រុងកាតព្វកិច្ចអាចបង្ហាញថាមានបញ្ហាក្នុងការគ្រប់គ្រងជាក់ស្តែង និង/ឬ បញ្ហាជាសក្តានុពលលើសាច់ប្រាក់ងាយស្រួល។ ធនាគារជាតិនៃកម្ពុជា នឹងចាត់វិធានការត្រួតពិនិត្យដ៏សមស្របដើម្បីកែតម្រូវស្ថានភាពនេះ និងប្រើសិទ្ធិអំណាចដាក់ពិន័យ ដូចដែលមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូក ៨
វិធានការអន្តរកាល

ប្រការ ១៨.-

នីតិវិធីនៃការប្តូរពីប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចចាស់ មកប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចថ្មីដូចមានចែងនៅក្នុងប្រកាសនេះ នឹងត្រូវបានណែនាំក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

ជំពូក ៩
អវសានប្បញ្ញត្តិ

ប្រការ ១៩.-

ប្រកាស និងសារាចរណែនាំ ត្រូវចាត់ទុកជានិរាករណ៍៖

- បទប្បញ្ញត្តិ ធ៧-៩៣-២៨២ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ដោយស្ថាប័នរូបិយវត្ថុ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣
- សារាចរណែនាំ ធ៧-៩៣-២៨៧ សរណេន ស្តីពី របៀបតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ព្រមទាំងការរាយការណ៍ស្តីពីប្រាក់បម្រុងកាតព្វកិច្ចនេះ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣
- សារាចរណែនាំ ធ៧-០៨-០២ ស្តីពីរយៈពេលមូលដ្ឋាន និងរយៈពេលដែលត្រូវតម្កល់ និងថ្ងៃរាយការណ៍ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨។

ប្រការ ២០.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គលេខ្លា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២១.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

របាយការណ៍ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

១.- របាយការណ៍រយៈពេលមូលដ្ឋាន

របាយការណ៍នេះត្រូវលម្អិតអំពីសមតុល្យប្រាក់បញ្ញើ និងប្រាក់កម្ចីប្រចាំថ្ងៃទៅតាមប្រភេទរូបិយប័ណ្ណ នៅក្នុងរយៈពេលមូលដ្ឋាន ដែលបង្ហាញអំពីចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាសម្រាប់រក្សាទុកនៅក្នុងរយៈពេលតម្កល់ ព្រមទាំងបង្ហាញពីកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០%។

របាយការណ៍រយៈពេលមូលដ្ឋាននេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣ (បី) ថ្ងៃ ចាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន៖

- តារាង 1A ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារៀល
- តារាង 1B ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗ គិតជាដុល្លារអាមេរិក។ តារាងនេះប្រើសម្រាប់គណនាសង្ខេបតួលេខសរុបបញ្ចូលគ្នាតាមថ្ងៃ តាមប្រភេទរូបិយប័ណ្ណ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ច។ របាយការណ៍សង្ខេបនេះនឹងត្រូវបានភ្ជាប់បន្ថែមដោយតារាងលម្អិតជាច្រើនទៀតតាមប្រភេទរូបិយប័ណ្ណដែលគ្រឹះស្ថានបានធ្វើប្រតិបត្តិការជាក់ស្តែង
  - តារាង 1B-01 ៖ របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក
  - តារាង 1B-02 ៖ របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង 1B-03 ៖ របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង 1B-04 ៖ របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណផ្សេងៗទៀត គិតជាដុល្លារអាមេរិក ជាតារាងបន្ថែមចំពោះរូបិយប័ណ្ណផ្សេងៗ ដែលខុសពីរូបិយប័ណ្ណខាងលើទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

២.- របាយការណ៍រយៈពេលតម្កល់

របាយការណ៍នេះបង្ហាញពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មបម្រុង ដែលរក្សានៅធនាគារជាតិនៃកម្ពុជា និងឱនភាពកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃតាមរយៈការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមប្រចាំថ្ងៃ។

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ រយៈពេលតម្កល់ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលតម្កល់។

- តារាង 2A ៖ របាយការណ៍រយៈពេលតម្កល់ ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារៀល។ របាយការណ៍នេះ ប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៨០% ដែលទទួលបានពីតារាង 1A។
- តារាង 2B ៖ របាយការណ៍រយៈពេលតម្កល់ ស្តីពីប្រាក់បម្រុងកាតព្វកិច្ចគិតជាដុល្លារអាមេរិក។

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជារៀល

Report of Base Period on Reserve Requirement in Riel

ឈ្មោះធនាគារ/Name of Bank: តារាង ១ ក

រយៈពេលមូលដ្ឋាន/Base Period: Table: 1 A

រយៈពេលតម្កល់/Maintenance Period: (ឯកតាគិតជាលានរៀល)

រយៈពេលត្រូវរាយការណ៍/Reporting Period: (Riel in Millions)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗជារៀល Deposits and other borrowings base in Riel					
	ប្រាក់បញ្ញើចរន្ត Demand Deposit	ប្រាក់បញ្ញើសំចៃ Saving Deposit	ប្រាក់បញ្ញើមានកាលកំណត់ Term Deposit	ប្រាក់បញ្ញើផ្សេងៗ Other Deposits	បំណុលផ្សេងទៀត Other Liabilities	**សរុប Total**
	1	2	3	4	5	**6=1+2+3+4+5**
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
					-	-
សរុប Total	-	-	-	-	-	-
មធ្យមប្រចាំថ្ងៃ Daily Average	-	-	-	-	-	-

ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period:	
អត្រាប្រាក់បម្រុងកាតព្វកិច្ច (**៨**%) Reserve Requirement Rate (8%)	0.08
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារៀល Minimum reserve requirements In riel	-
កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (**៨0**%) Daily compulsory threshold (80%)	-

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

នាយក	**អ្នកពិនិត្យ**	**អ្នកធ្វើតារាង**
Manager	Checked By	Prepared By

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗគិតជាដុល្លារអាមេរិក
Report of Base Period on Reserve Requirement in USD and Other Currencies Converted into USD

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period:
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង ១ ខ
Table: 1 B
(ជាដុល្លារអាមេរិក)
(In USD)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ជាដុល្លារអាមេរិក Deposits and other borrowings base in USD	ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗ ជាអឺរ៉ូ គិតជាដុល្លារអាមេរិក Deposits and other borrowings in EUR Converted in USD	ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ជា បាតថៃ គិតជាដុល្លារអាមេរិក Deposits and other borrowings in THB Converted in USD	ប្រាក់បញ្ញើនិងប្រាក់ កម្ចី ផ្សេងៗ ជា...គិត ជាដុល្លារអាមេរិក Deposits and other borrowings in … Converted in USD*	**សរុបប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ គិតជាដុល្លារអាមេរិក Total Deposits and other Borrowings Base Conveted into USD**
	1	2	3	4	5=1+2+3+4
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
				-	-
សរុប Total	-	-	-	-	-
មធ្យមប្រចាំថ្ងៃ Daily Average	-	-	-	-	-
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា (មជ្ឈមប្រចាំថ្ងៃ x ១២%) Minimum Reserve Requirement (Daily Average x12%)	-	-	-	-	-
ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period:					
ប្រាក់បម្រុងកាតព្វកិច្ចរូបិយប័ណ្ណអាមេរិក (ទំរង់: ១B០១ +១B០២ +១B០៣ + ១B០៤+ .....) Minimum reserve requirements in USD (Form: 1B01+1B02+1B03+1B04+ ……)					
កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Daily compulsory threshold (80%)					

* កំណត់សម្គាល់/Note:

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

កូឡោនច្រើនអាចត្រូវបន្ថែមសម្រាប់រូបិយប័ណ្ណផ្សេងៗទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន Reporting Date:
There will be additional collumns as needed for each of the Foreign Currencies the Institutions transact in

នាយក	**អ្នកពិនិត្យ**	**អ្នករៀបចំតារាង**
Manager	Checked By	Prepared By

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក

Report of Base Period on Reserve Requirement in USD

ឈ្មោះធនាគារ/Name of Bank: តារាង: ១ខ-០១

រយៈពេលមូលដ្ឋាន/Base Period: Table: 1 B-01

រយៈពេលតម្កល់/Maintenance Period: (ជាដុល្លារអាមេរិក)

រយៈពេលត្រូវរាយការណ៍/Reporting Period : (In USD)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើ និង ប្រាក់កម្ចីផ្សេងៗជាដុល្លារអាមេរិក Deposits and other borrowings base in USD					
	ប្រាក់បញ្ញើចរន្ត Demand Deposit	ប្រាក់បញ្ញើសំចៃ Saving Deposit	ប្រាក់បញ្ញើមានកាលកំណត់ Term Deposit	ប្រាក់បញ្ញើផ្សេងៗ Other Deposits	បំណុលផ្សេងទៀត Other Liabilities	**សរុប Total**
	1	2	3	4	5	6=1+2+3+4+5
សរុប Total	-	-	-	-	-	-
មធ្យមប្រចាំថ្ងៃ Daily Average	-	-	-	-	-	-

ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រួតតម្កល់ Reserve Requirement for maintainance period:	
អត្រាប្រាក់បម្រុងកាតព្វកិច្ច (**១២**%) Reserve Requirement Rate (12%)	0.12
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាដុល្លារអាមេរិក Minimum reserve requirements In USD	-
កម្រិតអប្បបរមានៃការតម្កល់ប្រាក់បម្រុង (**៨0**%) Daily compulsory threshold (80%)	-

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

នាយក	**អ្នកពិនិត្យ**	**អ្នកធ្វើតារាង**
Manager	Checked By	Prepared By

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក

Report of Base Period on Reserve Requirement in EUR Converted into USD

ឈ្មោះធនាគារ/Name of Bank:

រយៈពេលមូលដ្ឋាន/Base Period :

រយៈពេលតម្កល់/Maintenance Period :

រយៈពេលត្រួរាយការណ៍/Reporting Period :

តារាង : ១ខ-០២

Table: 1 B-02

(ឯកតាជាអឺរ៉ូ)

(In EUR)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាអឺរ៉ូ Deposits and other borrowings base in EUR							
	ប្រាក់បញ្ញើចរន្ត Demand Deposit	ប្រាក់បញ្ញើសំចៃ Saving Deposit	ប្រាក់បញ្ញើមានកាលកំណត់ Term Deposit	ប្រាក់បញ្ញើផ្សេងៗ Other Deposits	បំណុលផ្សេងទៀត Other Liabilities	សរុប Total	អត្រាប្តូរប្រចាំថ្ងៃ អឺរ៉ូ/ដុល្លារអ.រ Daily Ex. Rate EUR/USD	សរុបគិតជាដុល្លារអ.រ Total Converted into UDS
	1	2	3	4	5	6=1+2+3+4+5	7	**8=6/7**
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
						-		-
សរុប Total	-	-	-	-	-	-		$0.00
មធ្យមប្រចាំថ្ងៃ Daily Average	**-**	**-**	**-**	**-**	**-**	**-**		**$0.00**

ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period:	
អត្រាប្រាក់បម្រុងកាតព្វកិច្ច (១២%) Reserve Requirement Rate (12%)	0.12
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាអឺរ៉ូ គិតជាដុល្លារអាមេរិក Minimum reserve requirements Converted into USD	**$0.00**
កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Daily compulsory threshold (80%)	**$0.00**

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting Date:

នាយក Manager	**អ្នកពិនិត្យ** Checked By	**អ្នកធ្វើតារាង** Prepared By

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក
Report of Base Period on Reserve Requirement in THB Converted into USD

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period:
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង: ១ខ-០៣
Table: 1 B-03
(ឯកតាជាថៃបាត)
(In THB)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាថៃបាត Deposits and other borrowings base in THB							
	ប្រាក់បញ្ញើចរន្ត Demand Deposit	ប្រាក់បញ្ញើសំចៃ Saving Deposit	ប្រាក់បញ្ញើមានកាលកំណត់ Term Deposit	ប្រាក់បញ្ញើផ្សេងៗ Other Deposits	បំណុលផ្សេងទៀត Other Liabilities	សរុប Total	អត្រាប្តូរប្រាក់ប្រចាំថ្ងៃ ថៃបាត/ដុល្លារអ.រ Daily Ex. Rate EUR/USD	សរុបគិតជាដុល្លារអ.រ Total Converted into UDS
	1	2	3	4	5	6=1+2+3+4+5	7	**8=6/7**
សរុប Total	-	-	-	-	-	-		$0.00
មធ្យមប្រចាំថ្ងៃ Daily Average	**-**	**-**	**-**	**-**	**-**	**-**		**$0.00**

ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period:	
អត្រាប្រាក់បម្រុងកាតព្វកិច្ច (១២%) Reserve Requirement Rate (12%)	0.12
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា ថៃបាតគិតជាដុល្លារអាមេរិក Minimum reserve requirements Converted into USD	**$0.00**
កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨0%) Daily compulsory threshold (80%)	**$0.00**

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២00៩
Reporting Date:

នាយក	**អ្នកពិនិត្យ**	**អ្នកធ្វើតារាង**
Manager	Checked By	Prepared By

របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជា... គិតជាដុល្លារអាមេរិក
Report of Base Period on Reserve Requirement in …… Converted into USD*

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period:
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង៖ ១៨-០៣
Table: 1 B-03
(ឯកតាជា...)
(In ...)

កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period	ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា... Deposits and other borrowings base in ...							
	ប្រាក់បញ្ញើចរន្ត Demand Deposit	ប្រាក់បញ្ញើសំចៃ Saving Deposit	ប្រាក់បញ្ញើមានកាលកំណត់ Term Deposit	ប្រាក់បញ្ញើផ្សេងៗ Other Deposits	បំណុលផ្សេងទៀត Other Liabilities	សរុប Total	អត្រាប្តូរប្រាក់ប្រចាំថ្ងៃ ថៃបាត/ដុល្លារអ.រ Daily Ex. Rate EUR/USD	សរុបគិតជាដុល្លារអ.រ Total Converted into UDS
	1	2	3	4	5	6=1+2+3+4+5	7	**8=6/7**
សរុប Total	-	-	-	-	-	-		$0.00
មធ្យមប្រចាំថ្ងៃ Daily Average	**-**	**-**	**-**	**-**	**-**	**-**		**$0.00**
ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintainance period:								
អត្រាប្រាក់បម្រុងកាតព្វកិច្ច (១២%) Reserve Requirement Rate (12%)								0.12
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា... គិតជាដុល្លារអាមេរិក Minimum reserve requirements Converted into USD								**$0.00**
កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Daily compulsory threshold (80%)								**$0.00**

*** កំណត់សម្គាល់/Note:**

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន
There will be additional table as needed for each of the foreign currencies the institutions transact in

Reporting Date:

នាយក Manage	**អ្នកពិនិត្យ** Checked By	**អ្នកធ្វើតារាង** Prepared By

របាយការណ៍រយៈពេលតម្កល់ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជារៀល
Report of Maintenance Period on Reserve Requirement in KHR

ឈ្មោះធនាគារ/Name of Bank:

រយៈពេលមូលដ្ឋាន/Base Period:

រយៈពេលតម្កល់/Maintenance Period:

រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង៖ ២ ក
Table: 2 A
(ឯកតាគិតជាលានរៀល)
(In Million Riel)

កាលបរិច្ឆេទនៃរយៈពេលត្រូវតម្កល់ Date of Maintenance period	សមតុល្យប្រាក់បម្រុងកាតព្វកិច្ចជារៀល នៅធនាគារជាតិនៃកម្ពុជា Reserve Requirement Account Balance in KHR at NBC	កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Minimum threshold of reserve maintenance (80%)	**អតិរេក/(ខ្វះខាត) ប្រាក់បម្រុងកាតព្វកិច្ច ប្រចាំថ្ងៃ Daily Compulsory Threshold Surplus/(Deficit):**	សមតុល្យគណនីជាត់ទាត់ ជារៀលនៅធនាគារជាតិនៃកម្ពុជា Clearing Account Balance in KHR at NBC	សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីជាត់ទាត់ប្រចាំថ្ងៃ នៅធនាគារជាតិ នៃកម្ពុជា Daily Reserve Requirement and Clearing Account balance at NBC
	1	2	3=1-2	4	5=1+4
សរុប Total	0.00			0.00	0.00
មធ្យមប្រចាំថ្ងៃ Daily Average	0.00			0.00	0.00
ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា (ទម្រង់: ១ក) Minimum Reserve Requirement (Form: 1A):					0.00
- អតិរេកប្រាក់បម្រុងកាតព្វកិច្ច Reserve Requirement Surplus:					-
- ខ្វះខាតប្រាក់បម្រុងកាតព្វកិច្ច Reserve Requirement Deficit:					-

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

Reporting date:

នាយក/Manager

អ្នកពិនិត្យ/Checked By

អ្នករៀបតារាង/Prepared By

របាយការណ៍រយៈពេលតម្កល់ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក
Report of Maintenance Period on Reserve Requirement in USD

ឈ្មោះធនាគារ/Name of Bank:
រយៈពេលមូលដ្ឋាន/Base Period:
រយៈពេលតម្កល់/Maintenance Period:
រយៈពេលត្រូវរាយការណ៍/Reporting Period:

តារាង ៖ ២ ខ
Table: 2 B
(ឯកតាគិតជាដុល្លារអាមេរិក)
(In USD)

កាលបរិច្ឆេទនៃរយៈពេលត្រូវតម្កល់ Date of Maintenance Period	សមតុល្យគណនី ប្រាក់បម្រុងកាតព្វកិច្ច ជាដុល្លារនៅធនាគារជាតិ នៃកម្ពុជា Reserve Requirement Account Balance in USD at NBC	កំរិតកំណត់កាតព្វកិច្ច ប្រចាំថ្ងៃ (៨0%) Minimum threshold of reserve maintenance (80%)	**អតិរេក/(ខ្វះខាត) ប្រាក់បម្រុងកាតព្វកិច្ច ប្រចាំថ្ងៃ** **Daily compulsory threshold Surplus/(Deficit):**
	1	2	3=1-2
			-
			-
			-
			-
			-
			-
			-
			-
			-
			-
			-
			-
			-
			-

សរុប Total	**0.00**
មធ្យមប្រចាំថ្ងៃ Daily Average	**0.00**
- ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា (ទំរង់: ១ខ): Minimum Reserve Requirements (Form: 1B):	-
- អតិរេកប្រាក់បម្រុងកាតព្វកិច្ច: Reserve Requirement Surplus:	-
- ខ្វះខាតប្រាក់បម្រុងកាតព្វកិច្ច: Reserve Requirement Deficit:	-

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២00៩
Reporting date:

នាយក/Manager **អ្នកពិនិត្យ**/Checked By **អ្នកធ្វើតារាង**/Prepared By

សេចក្តីណែនាំ
អនុវត្តប្រកាសស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

១.- របាយការណ៍រយៈពេលមូលដ្ឋាន

របាយការណ៍រយៈពេលមូលដ្ឋានលើកទី១ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃអង្គារ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃចន្ទ ទី០២ ខែមីនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលមូលដ្ឋានលើកទី១នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបានត្រឹមថ្ងៃព្រហស្បតិ៍ ទី០៥ ខែមីនា ឆ្នាំ២០០៩ អនុវត្តចំពោះប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចថ្មី។

របាយការណ៍រយៈពេលមូលដ្ឋានលើកទី២ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃអង្គារ ទី០៣ ខែមីនា ឆ្នាំ២០០៩ ដល់ថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលមូលដ្ឋានលើកទី២នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបានត្រឹមថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលមូលដ្ឋានបន្ទាប់មកទៀតត្រូវអនុវត្តដោយស្វ័យប្រវត្តិ ក្នុងរយៈពេល ១៤ ថ្ងៃ ប្រតិទិន ដោយរាប់ចាប់ពីរយៈពេលមូលដ្ឋានមុន។

២.- របាយការណ៍រយៈពេលតម្កល់

របាយការណ៍រយៈពេលតម្កល់លើកទី១ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃសុក្រ ទី០៦ ខែមីនា ឆ្នាំ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលតម្កល់លើកទី១នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ ព្រោះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៩ ជាថ្ងៃអាទិត្យ ដូចនេះ ថ្ងៃផុតកំណត់នៃរបាយការណ៍ត្រូវលើកទៅ ថ្ងៃចន្ទ ទី២៣ ខែមីនា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលតម្កល់លើកទី២ មានរយៈពេល១៤ថ្ងៃប្រតិទិន ចាប់ពីថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី០២ ខែមេសា ឆ្នាំ២០០៩។ របាយការណ៍រយៈពេលតម្កល់លើកទី២នេះ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបាននៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ព្រោះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ជាថ្ងៃអាទិត្យ ដូចនេះ ថ្ងៃផុតកំណត់នៃរបាយការណ៍ត្រូវលើកទៅ ថ្ងៃចន្ទ ទី០៦ ខែមេសា ឆ្នាំ២០០៩។

របាយការណ៍រយៈពេលតម្កល់បន្ទាប់មកទៀតត្រូវអនុវត្តដោយស្វ័យប្រវត្តិ ក្នុងរយៈពេល ១៤ ថ្ងៃ ប្រតិទិន ដោយរាប់ចាប់ពីរយៈពេលតម្កល់មុន។

៣.- អន្តរកាលចំពោះការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

គ្រឹះស្ថានត្រូវរក្សាជាមធ្យមនូវប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់ខ្លួន ដោយផ្អែកទៅលើតួលេខ ដែលបានរាយការណ៍សម្រាប់រយៈពេលមូលដ្ឋានចាស់ចាប់ពីថ្ងៃសុក្រ ទី០៩ ខែមករា ឆ្នាំ២០០៩

ដល់ថ្ងៃព្រហស្បតិ៍ ទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់រហូតដល់ ថ្ងៃព្រហស្បតិ៍ ទី០៥ ខែមីនា ឆ្នាំ២០០៩ ដែលជារយៈពេលតម្កល់ចាស់។

ចាប់ពីថ្ងៃសុក្រ ទី០៦ ខែមីនា ឆ្នាំ២០០៩ គ្រឹះស្ថានទាំងអស់ត្រូវអនុវត្តកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើ ៨០% និងប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមសម្រាប់រយៈពេលតម្កល់។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាតាមប្រព័ន្ធថ្មីសម្រាប់រយៈពេលមូលដ្ឋានលើកទីមួយ ត្រូវអនុវត្តចាប់ពីថ្ងៃអង្គារ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃច័ន្ទ ទី០២ ខែមីនា ឆ្នាំ២០០៩ ដោយរាប់ចាប់ពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ថយក្រោយចំនួន១៧ថ្ងៃ។

៤.- ថ្ងៃឈប់សម្រាកជាសាធារណៈ

ប្រសិនបើថ្ងៃរាយការណ៍ត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកជាសាធារណៈ គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជា នៅថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់សម្រាក។

ធ៧-០១៥-១៧៧ ស.ជ.ណ

ជម្រាបមក

លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្មវត្ថុ ៖ ការអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើ (១) ប្រាក់បញ្ញើអតិថិជន (២) ប្រាក់បញ្ញើធនាគារអនិវាសជន និង (៣) ប្រាក់កម្ចីអនិវាសជន។

យោង ៖
- ប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ធ៧-០១២-១៤០ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ
- សេចក្តីជូនដំណឹងលេខ ធ៧-០៩-២៤២ ស.ជ.ណ ស្តីពី ការអនុវត្តប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា ជ្រាបថា អនុលោមតាមប្រកាសខាងលើ ប្រាក់បញ្ញើធនាគារ និងប្រាក់កម្ចីផ្សេងៗនៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ជាទ្រព្យអកម្ម ដែលរងនូវការដាក់ប្រាក់បម្រុងកាតព្វកិច្ច។ កន្លងមក ដើម្បីពង្រឹងស្ថានភាពសន្ទនីយភាពនៅកម្ពុជា ការដាក់ប្រាក់បម្រុងកាតព្វកិច្ចនេះ ត្រូវបានលើកលែងចំពោះប្រាក់កម្ចី និងប្រាក់បញ្ញើធនាគារ ដោយសារប្រព័ន្ធធនាគារនៅកម្ពុជាមានតម្រូវការខ្ពស់នូវប្រភពទុនបរទេស និងស្ថិតក្នុងកាលៈទេសៈដែលកម្ពុជាបានប្រឈមនឹងវិបត្តិហិរញ្ញវត្ថុតំបន់ និងសកលជាបន្តបន្ទាប់។

បច្ចុប្បន្ន ស្ថានភាពសេដ្ឋកិច្ចតំបន់ និងសកលបានបន្តងើបឡើងជាលំដាប់ ហើយស្ថានភាពសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារមានកម្រិតខ្ពស់ល្អប្រសើរ។ ទន្ទឹមនេះ កំណើនឥណទានទាំងក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុបានកើនឡើងយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ជាពិសេសនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ថ្វីត្បិតតែ កំណើនឥណទាន និងប្រភពទុនបរទេសបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែ កំណើននេះ ក៏បានភ្ជាប់មកជាមួយនូវហានិភ័យចំពោះវិស័យធនាគារ ក៏ដូចជាវិស័យហិរញ្ញវត្ថុទាំងមូលផងដែរ។ ស្ថិតក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារ បាននិងកំពុងពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិឱ្យកាន់តែប្រសើរឡើង ដើម្បីលើកកម្ពស់ការគ្រប់គ្រងហានិភ័យដែលអាចកើតឡើងជាយថាហេតុចំពោះប្រព័ន្ធធនាគារ។

ដោយឈរលើស្មារតីប្រុងប្រយ័ត្ន និងទស្សនៈអនាគត ធនាគារជាតិនៃកម្ពុជា សម្រេចអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើ (១) ប្រាក់បញ្ញើអតិថិជន (២) ប្រាក់បញ្ញើធនាគារអនិវាសជន និង (៣) ប្រាក់កម្ចីអនិវាសជន ដើម្បីលើកកម្ពស់ការប្រកួតប្រជែងស្មើភាពគ្នា និងរួមចំណែករក្សា

ស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ចខាងលើនេះ នឹងចូលជាធរមានសម្រាប់រយៈពេលតម្កល់ប្រាក់បម្រុងកាតព្វកិច្ច ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មេត្តាអនុវត្តតាមស្មារតីនៃសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥

ជ. ឧសាតិបាល

ឧសាតិបាលរង

ហត្ថលេខានិងត្រា៖ **ឆាវ ច័ន្ទថាណា**

ធ៧-០២០-២៣០ ប្រ.ក

ប្រកាស
ស្តីពី
ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើ
និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណ។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅប្រើប្រាស់ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់ជាឧបករណ៍ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សំដៅរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ១៩ មកលើសេដ្ឋកិច្ចកម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងអត្រា ៧% (ប្រាំពីរភាគរយ) ចំពោះរូបិយវត្ថុជាតិ និងរូបិយប័ណ្ណ។ ធនាគារជាតិនៃកម្ពុជាអាចកែសម្រួលអត្រាប្រាក់បម្រុងកាតព្វកិច្ចនេះជាថ្មី ក្នុងករណីចាំបាច់។

ប្រការ ៥.-

ប្រកាសលេខ ធ៧-០១៨-២៨២ ប្រ.ក ចុះថ្ងៃពុធ ៣រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១០-១៨២ ប្រ.ក

ប្រកាស
ស្តីពី
ការគណនាមូលនិធិថ្នាល់សុទ្ធរបស់ធនាគារ

ប្រការ ១.-

គ្រឹះស្ថានធនាគារត្រូវគណនាមូលនិធិថ្នាល់សុទ្ធឱ្យស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។ រាល់អនុបាត និងកម្រិតកំណត់ប្រុងប្រយ័ត្នដែលទាក់ទងនឹងមូលនិធិថ្នាល់សុទ្ធ ត្រូវគណនាឱ្យស្របតាមវិធាននៃការគណនានេះ។ លើសពីនេះ ដើមទុនឬទាយជ្ជទានដែលបានបង់ និងមូលនិធិថ្នាល់សុទ្ធត្រូវតែស្មើ ឬលើសពីដើមទុនអប្បបរមាដែលត្រូវបានអនុវត្តចំពោះគ្រឹះស្ថាននោះ។

ប្រការ ២.-

គ្រឹះស្ថានធនាគារត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុង សំដៅធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកាតព្វកិច្ចជាបទបញ្ជាទាំងអស់ ទាក់ទងនឹងអនុបាតសាធនភាពអប្បបរមា និងកម្រិតកំណត់ដែលទាក់ទងនឹងមូលនិធិថ្នាល់សុទ្ធ។

ប្រការ ៣.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានធនាគារអនុវត្តនីតិវិធីពិសេស ក្រោមរូបភាពជាការដកចេញនូវខ្នង់មួយចំនួនថែមទៀតពីការគណនាមូលនិធិថ្នាល់សុទ្ធ ដោយមិនគិតដល់វិធានទូទៅនៃការគណនាដូចមានចែងនៅក្នុងប្រកាសនេះ។ ការអនុវត្តនីតិវិធីពិសេសនេះគឺ ដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមបទបញ្ជា និងដើម្បីឆ្លុះបញ្ចាំងឱ្យឃើញហានិភ័យជាក់ស្តែងនិងហានិភ័យជាសក្តានុពល ក្នុងគោលបំណងប្រុងប្រយ័ត្ន។

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការអនុវត្តនីតិវិធីពិសេសនេះ ហើយគ្រឹះស្ថានធនាគារត្រូវអនុវត្តតាមភ្លាម រហូតដល់មានការណែនាំផ្សេងជាលាយលក្ខណ៍អក្សរ។

ប្រការ ៤.-

មូលនិធិថ្នាល់សុទ្ធសរុបមានសមាសធាតុ ២ ដាច់ដោយឡែកពីគ្នាគឺ៖

- ដើមទុនថ្នាក់ទីមួយ (ដើមទុនស្នូល) និង
- ដើមទុនថ្នាក់ទីពីរ (ដើមទុនបំពេញបន្ថែម)

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយទេ ឬ មិនត្រូវលើសពី ៥០% នៃមូលនិធិថ្នាល់សុទ្ធសរុបឡើយ។

មុននឹងចេញរបាយការណ៍ពាក់ព័ន្ធ ធនាគារត្រូវពិនិត្យ ផ្ទៀងផ្ទាត់ ដើម្បីធានាការប្រតិបត្តិតាមកម្រិតកំណត់នេះ។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការសមស្រប។

ប្រការ ៥.-

ដើមទុនថ្នាក់ទីមួយ ត្រូវគណនាដូចខាងក្រោម៖

I- សរុបរង A ៖ (ខ្នង់ត្រូវបូក)

- ដើមទុន ឬទាយជ្ជទាន ដែលបានបង់
- ទុនបម្រុងដែលមិនមែនជាទុនបម្រុងដែលត្រូវបានវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- ប្រាក់ចំណេញរក្សាទុកត្រឹមកម្រិត ២០% នៃសរុបរង A ។ ចំនួនលើសពី ២០% នៃសរុបរង A ធនាគារអាចសម្រេចរក្សាទុកជាទុនបម្រុង
- ប្រាក់ចំណេញសុទ្ធដែលត្រូវបានធ្វើសវនកម្មរួចហើយ សម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ
- លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏អាចអនុម័តខ្នង់ផ្សេងទៀត ដែលត្រូវបញ្ចូលទៅក្នុងសរុបរង A ដូចជាប្រាក់ចំណេញដែលបានកត់ត្រានៅក្នុងការិយបរិច្ឆេទ លុះត្រាតែ៖ ១-ប្រាក់ចំណេញនោះត្រូវបានកំណត់បន្ទាប់ពីដកចេញបន្ទុកចំណាយទាំងអស់នៅក្នុងរយៈពេលដូចគ្នា (ការរំលស់ សំវិធានធន និងការកែតម្រូវតម្លៃសុទ្ធ) ២-ប្រាក់ចំណេញនោះត្រូវបានគណនាជាចំនួនសុទ្ធដោយដកចេញនូវចំនួនប្រាក់ពន្ធនិងភាគលាភដែលត្រូវសង ៣-ប្រាក់ចំណេញសុទ្ធនេះត្រូវបានបញ្ជាក់ពីសវនករឯករាជ្យ។

II- សរុបរង B ៖ (ខ្នង់ត្រូវដក)

- ភាគហ៊ុនផ្ទាល់ដែលកាន់កាប់ដោយធនាគារ តាមតម្លៃសុទ្ធចុះបញ្ជី
- ការខាតបង្គរ
- ទ្រព្យសកម្មអរូបិយ (ដូចជា តម្លៃកេរ្តិ៍ឈ្មោះ ... ជាដើម)
- ចំពោះភាគទុនិក គណៈនាយក និងភាគីសម្ព័ន្ធញាតិដូចមាននិយមន័យនៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖
  - ចំណែកដើមទុន ឬទាយជ្ជទាន ដែលមិនទាន់បានបង់
  - ប្រាក់កម្ចី ឥណទានវិបាកបន្ត និងបុរេប្រទាន
  - ឧបករណ៍បំណុលដែលកាន់កាប់ដោយធនាគារតាមតម្លៃសុទ្ធចុះបញ្ជី (Net Book Value) ហើយមានហត្ថលេខារបស់បុគ្គលពាក់ព័ន្ធទាំងនោះ
- ការខាតក្នុងគ្រាប្រតិបត្តិការ ក្រៅពីការខាតនាចុងការិយបរិច្ឆេទប្រចាំឆ្នាំដែលរួមទាំងរាល់សំវិធានធនលើបំណុល និងមូលបត្រមិនដំណើរការ ក៏ដូចជាការកែតម្រូវដទៃទៀតសម្រាប់ការរំលស់នៅក្នុងរយៈពេលដូចគ្នា។ សំវិធានធននិងការរំលស់ត្រូវស្របតាមបទបញ្ជាជាធរមាន ដោយផ្អែកលើការវាយតម្លៃដោយប្រុងប្រយ័ត្នលើហានិភ័យដែលពាក់ព័ន្ធ។

ដើមទុនថ្នាក់ទីមួយ = សរុបរង A - សរុបរង B ។

ប្រការ ៦.-

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយសម្រាប់គណនាមូលនិធិផ្ទាល់សុទ្ធសរុប។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ដូចបានគណនាក្នុងប្រការ ៥ នៃប្រកាសនេះ ធនាគារមិនត្រូវយកចំនួនដែលលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយនោះមកគណនាបញ្ចូលឡើយ។

III- សរុបរង C ៖ (ខ្នង់ត្រូវបូក)

- ការវាយតម្លៃទុនបម្រុងឡើងវិញដោយមានការយល់ព្រមជាមុន ជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនសម្រាប់ហានិភ័យទូទៅរបស់ធនាគារ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនទូទៅ ១% ដែលបានកំណត់នៅក្នុងប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

  (សំវិធានធនទូទៅ ត្រូវបានជំនួសដោយខ្លឹមសារទាក់ទងនឹងសំវិធានធនទូទៅ ដូចមានចែងក្នុងប្រការ ៧២ នៃប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។)
- ឧបករណ៍បំណុលបន្ទាប់បន្សំមិនអាចលើសពី ៥០% នៃដើមទុនថ្នាក់ទីមួយ ហើយត្រូវបំពេញឱ្យបានគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៧ ខាងក្រោម
- ខ្នង់ដទៃទៀតដែលមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា។

IV- សរុបរង D ៖ (ខ្នង់ត្រូវដក)

- ការចូលភាគកម្មតាមតម្លៃសុទ្ធចុះបញ្ជីនៅក្នុងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ រួមទាំង ក្រុមហ៊ុនមូលបត្រ
- ខ្នង់ផ្សេងទៀត ដូចជាបន្ទុកចំណាយដែលត្រូវបង់។

ដើមទុនថ្នាក់ទីពីរ = សរុបរង C - សរុបរង D ។

ប្រការ ៧.-

៧.១ បំណុលបន្ទាប់បន្សំត្រូវមានឯកសារទ្រទ្រង់ រួមទាំងកិច្ចសន្យាផងដែរ។ កិច្ចសន្យានោះត្រូវមានបញ្ជាក់ច្បាស់ពីលំដាប់នៃម្ចាស់បំណុល (Subscriber) ដែលនៅខ្ពស់បន្ទាប់ពីភាគទុនិកធម្មតាកាលវិសាន និងលក្ខខណ្ឌផ្សេងទៀត។

៧.២ បំណុលបន្ទាប់បន្សំនេះអាចបញ្ចូលក្នុងដើមទុនថ្នាក់ទីពីរបាន លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា។

៧.៣ ធនាគារមិនត្រូវសងបំណុលបន្ទាប់បន្សំឱ្យវិនិយោគិនវិញដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជាឡើយ។ ប្រសិនបើធនាគារសម្រេចចិត្តសងបំណុលបន្ទាប់បន្សំដោយគ្មានការអនុញ្ញាតជាមុន ឥណទាយកមិនមែនជាម្ចាស់បំណុលបន្ទាប់បន្សំរបស់ធនាគារ ឬអាជ្ញាធរត្រួតពិនិត្យ ធនាគារអាចជំទាស់នឹងសំណងបែបនេះ។ ក្នុងករណីនេះ ម្ចាស់បំណុលដែលទទួលសំណងបំណុលបន្ទាប់បន្សំ មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងចំនួននោះត្រឡប់មកធនាគារវិញឡើយ នៅពេលមានការតម្រូវ។

៧.៤ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលមានកំណត់កាលវសាននៅពេលចុះកិច្ចសន្យា ធនាគារត្រូវអនុវត្តការសងរំលស់ថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលវសាននៃកិច្ចសន្យា។ ការសងរំលស់បែបនេះត្រូវធ្វើឡើងតាមដំណាក់កាលដើម្បីឱ្យចំនួននៅក្នុងសរុបរង C ស្មើនឹងសូន្យនៅកាលវសាននៃកិច្ចសន្យា។

៧.៥ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលពុំមានកំណត់កាលវសាននៅពេលចុះកិច្ចសន្យា ធនាគារត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា យ៉ាងហោចណាស់មុនប្រាំឆ្នាំ អំពីបំណងរបស់ខ្លួនក្នុងការសងបំណុលបន្ទាប់បន្សំទាំងនោះ។ ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនជំទាស់ចំពោះការសងរំលស់នេះទេ ធនាគារត្រូវអនុវត្តការសងរំលស់ថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលបរិច្ឆេទដែលត្រូវបានកំណត់ដើម្បីសងរំលស់បំណុលទាំងស្រុង។

៧.៦ ធនាគារជាតិនៃកម្ពុជាអាចនឹងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធការសងរំលស់ទាំងស្រុងនូវបំណុលបន្ទាប់បន្សំ ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុជាទូទៅរបស់ធនាគារ។

ប្រការ ៨.-

ប្រកាសស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ លេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ និង ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ លេខ ធ៧-០០-៤៧ ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១១-០០១ ស.រ.ច

សារាចរស្តីពីការអនុវត្តប្រកាស
ស្តីពី
ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ

សារាចរនេះ ដាក់ចេញនូវវិធាននិងគោលការណ៍សម្រាប់អនុវត្តប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តទៅនេះហៅថា ប្រកាស ដែលចែងអំពីរចនាសម្ពន្ធ័ដើមទុនថ្នាក់ទី១ និងថ្នាក់ទី២ ស្របតាមបទដ្ឋានអន្តរជាតិ។ យោងតាមប្រកាសនេះ ដើមទុនថ្នាក់ទី២ ត្រូវបានកម្រិតត្រឹមតែ ១០០% នៃដើមទុនថ្នាក់ទី១ ហើយប្រាក់ចំណេញរក្សាទុក ដែលជាសមាសភាគមួយនៃដើមទុនថ្នាក់ទី១ ត្រូវបានកំណត់ត្រឹមតែ ២០% នៃសរុបដើមទុនថ្នាក់ទី១ (ដើមទុនស្នូល ឬ ដើមទុនរឹង) ប៉ុណ្ណោះ ដើម្បីទប់ស្កាត់ភាពងាយប្រែប្រួល (Volatility) នៃដើមទុន។ ប្រកាសនេះ ក៏បានអនុញ្ញាតឱ្យគណនាបញ្ចូលសំវិធានធនទូទៅ ១% ជាសមាសភាគមួយនៃដើមទុនថ្នាក់ទី២ដែរ ពីព្រោះសំវិធានធនទូទៅនេះ ជាក់ស្តែងជាទុនបម្រុងទូទៅដែលពុំបានត្រៀមសម្រាប់ទប់ទល់ហានិភ័យជាក់លាក់ ឬហានិភ័យដែលបានកំណត់អត្តសញ្ញាណនោះឡើយ ប៉ុន្តែគឺដើម្បីជាខែលសម្រាប់ការពារសាធនភាពទូទៅ។

គ្រប់គ្រឹះស្ថានធនាគារ មានកាតព្វកិច្ចប្រតិបត្តិតាមរាល់វិធាន គោលការណ៍ ដែលមានចែងក្នុងប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

១.- ការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមជាអចិន្ត្រៃយ៍

គ្រឹះស្ថានធនាគារ ត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការសំដៅធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍ នូវរាល់កាតព្វកិច្ចសាធនភាព និងកម្រិតកំណត់ចំពោះដើមទុន។ ពិសេសជាងនេះទៀត គ្រឹះស្ថានធនាគារត្រូវតែងតាំងបុគ្គលទទួលបន្ទុកតាមដាន និងត្រួតពិនិត្យការប្រតិបត្តិតាមហើយត្រូវរក្សាទុកជាឯកសារនូវរាល់គោលនយោបាយ នីតិវិធី និងដំណើរការទាំងនោះ។ ជាទស្សនៈអនាគត គ្រឹះស្ថានធនាគារត្រូវវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃផែនការអភិវឌ្ឍអាជីវកម្មជាយុទ្ធសាស្ត្រ និងបើចាំបាច់ត្រូវកែតម្រូវ ដើម្បីទប់ស្កាត់បញ្ហាសាធនភាព ឬការមិនគោរពតាមកម្រិតកំណត់នៃដើមទុន។ គណៈកម្មការសវនកម្មត្រូវវាយតម្លៃឡើងវិញប្រចាំគ្រានូវប្រសិទ្ធភាពនៃគោលនយោបាយ នីតិវិធី និងដំណើរការទាំងនោះ។

២.- កាតព្វកិច្ចរាយការណ៍

គ្រឹះស្ថានធនាគារ ត្រូវផ្តល់របាយការណ៍ប្រចាំខែអំពី មូលនិធិផ្ទាល់សុទ្ធ អនុបាតសាធនភាព ព្រមទាំងរបាយការណ៍ ដែលពាក់ព័ន្ធនឹងមូលនិធិផ្ទាល់សុទ្ធ មិនយឺតជាងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

គ្រឹះស្ថានធនាគារ ត្រូវប្រើគំរូរបាយការណ៍ ដូចមានភ្ជាប់មកជាមួយនៃសេចក្តីណែនាំនេះ។

៣.- កម្រិតកំណត់ប្រុងប្រយ័ត្ននៃប្រាក់ចំណេញរក្សាទុក និងខ្នង់ត្រូវដកផ្សេងៗ

សេចក្តីសម្រេចណាមួយរបស់ភាគទុនិកអំពីប្រាក់ចំណេញរក្សាទុក ដែលអាចបែងចែកជាភាគលាភចំពោះភាគទុនិក អាចបង្កឱ្យមានភាពងាយប្រែប្រួលនៃដើមទុន។ ប្រាក់ចំណេញរក្សាទុកត្រូវបានកំណត់ត្រឹម ២០% នៃដើមទុនថ្នាក់ទី ១ (សរុបរង A នៅក្នុងប្រការ ៥ នៃប្រកាស) មុនពេលដកចេញសមាសភាគដូចមានរៀបរាប់នៅចំណុច ॥ សរុបរង B (ខ្នង់ត្រូវដកពីដើមទុនស្នូល)។ និយាយម៉្យាងទៀត ប្រាក់ចំណេញរក្សាទុកមិនត្រូវលើសពី ២៥% (មួយភាគបួន) នៃសរុបសមាសភាគផ្សេងទៀតនៃដើមទុនថ្នាក់ទី១ ទេ។

លើសពីនេះ យោងប្រការ ៣ នៃប្រកាស ធនាគារជាតិនៃកម្ពុជាអាចជូនដំណឹងអំពីការដកចេញបន្ថែមទៀតពីដើមទុនថ្នាក់ទី១ ក្នុងគោលបំណងជាពិសេសដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមការគណនាដូចមានចែងក្នុងប្រកាស។ បន្ថែមលើនេះ ផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យបង្កើនសំវិធានធនចំពោះការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មមិនត្រឹមត្រូវ ដោយដកចេញពីមូលនិធិភាគទុនិក។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីនីតិវិធីខាងលើនេះ ហើយគ្រឹះស្ថានធនាគារត្រូវប្រតិបត្តិតាមភ្លាមរហូតដល់មានការលើកលែងជាលាយលក្ខណ៍អក្សរ។

រាល់ការដកចេញដែលពាក់ព័ន្ធ ត្រូវមានបង្ហាញច្បាស់នៅលើតារាងគណនាដោយមានយោងអធិបញ្ជា ឬសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជាចំពោះគ្រឹះស្ថានធនាគារ។ ក្នុងករណី មិនគោរពតាមប្រព្រឹត្តិកម្មប្រុងប្រយ័ត្ននិងរាល់ការដកចេញទេនោះ ធនាគារជាតិនៃកម្ពុជានឹងពិចារណាដាក់ពិន័យ និងមានវិធានការចំពោះគ្រឹះស្ថានធនាគារដែលល្មើស និងបើចាំបាច់ចំពោះគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនោះ។ នៅពេលដែលទទួលបានប្រព្រឹត្តិកម្មប្រុងប្រយ័ត្ន និងការដកចេញពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារ ក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងភ្លាមទៅសវនករឯករាជ្យ សមាជិកគណៈកម្មការសវនកម្ម និងបុគ្គលទទួលបន្ទុកប្រតិបត្តិតាមដូចមានចែងក្នុងចំណុច ១ ខាងលើ។

៤.- វិធានការអន្តរកាល

ដើម្បីអនុវត្តប្រកាសប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានធនាគារត្រូវកោះប្រជុំមហាសន្និបាតភាគទុនិក នៅមុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ដើម្បីសម្រេចអំពីការបែងចែកប្រាក់ចំណេញរក្សាទុកដែលបានបង្គរទុក និងដែលបានធ្វើសវនកម្ម ហើយស្របតាមកម្រិតកំណត់អំពីប្រាក់ចំណេញរក្សាទុកជាផ្នែកនៃដើមទុនថ្នាក់ទី១។

ផ្អែកលើស្ថានភាពហិរញ្ញវត្ថុ ផែនការអភិវឌ្ឍអាជីវកម្ម និងផលប៉ះពាល់ដែលបានព្យាករណ៍ទុកទៅលើស្ថានភាព និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ មហាសន្និបាតភាគទុនិកត្រូវសម្រេចអំពីការបែងចែកប្រាក់ចំណេញរក្សាទុកតាមទម្រង់ជា៖

- ការបង្វែរទៅគណនីទុនបម្រុងដែលមិនត្រូវបែងចែក
- ការបញ្ចូលទៅក្នុងដើមទុនដែលបានបង់

- ការបែងចែកភាគលាភ ឬ
- ការគូបបញ្ចូល ៣ ចំណុចខាងលើ។

៥.- សំណើសុំបែងចែកប្រាក់ចំណេញរក្សាទុក

គណៈគ្រប់គ្រងគ្រឹះស្ថានធនាគារ ត្រូវផ្តល់របៀបវារៈនៃមហាសន្និបាតទៅធនាគារជាតិនៃកម្ពុជាឱ្យបាន ១០ ថ្ងៃធ្វើការ មុនកាលបរិច្ឆេទមហាសន្និបាត។ របៀបវារៈមហាសន្និបាតត្រូវមានរាយលម្អិតជាពិសេសដំណោះស្រាយដែលត្រូវដាក់ជូនភាគទុនិកអនុម័ត និងសំណើសុំបែងចែកប្រាក់ចំណេញរក្សាទុក។ ប្រសិនបើសំណើដំណោះស្រាយនោះជាបញ្ហាកង្វល់ប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំពោះគណៈគ្រប់គ្រង អំពីកង្វល់ផ្អែកត្រួតពិនិត្យ ឬការបដិសេធដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុ និងជាពិសេស ស្ថានភាពសាធនភាពរបស់គ្រឹះស្ថានធនាគារ ក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលរបៀបវារៈ និងសំណើដំណោះស្រាយនោះ។ គណៈគ្រប់គ្រងត្រូវជូនព័ត៌មានទៅភាគទុនិកអំពីការបដិសេធ ឬអធិបញ្ហាប្រុងប្រយ័ត្ន បើមាន។

៦.- ប្រសិទ្ធភាពអនុវត្តវិធីសាស្ត្រគណនាថ្មី

នៅថ្ងៃទីមួយបន្ទាប់ពីមហាសន្និបាតភាគទុនិកដែលនឹងប្រព្រឹត្តិទៅមិនយឺតជាងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដើម្បីសម្រេចអំពីរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ចំណេញខាត សម្រាប់ឆ្នាំ២០១០ គ្រឹះស្ថានធនាគារត្រូវអនុវត្តប្រើវិធីសាស្ត្រគណនាថ្មី និងប្រើទម្រង់របាយការណ៍ដូចមានជូនភ្ជាប់។

នៅក្រោយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ គ្រឹះស្ថានធនាគារដែលមានប្រាក់ចំណេញរក្សាទុកលើសពី ២០% នៃដើមទុនថ្នាក់ទី១ មិនត្រូវបានអនុញ្ញាតឱ្យបញ្ចូលចំណែកលើសនោះ ទៅក្នុងការគណនាមូលនិធិផ្នាល់សុទ្ធទេ។ ប្រសិនបើគ្រឹះស្ថានធនាគារនៅតែបន្តរាយការណ៍អំពីប្រាក់ចំណេញរក្សាទុកដែលលើសនោះ ធនាគារជាតិនៃកម្ពុជានឹងកែតម្រូវការគណនា និងដកចេញនូវចំណែកលើសព្រមទាំងពិចារណាដាក់ពិន័យនិងមានវិធានការចំពោះគ្រឹះស្ថានធនាគារ និងគណៈគ្រប់គ្រង។

៧.- កាតព្វកិច្ចរាយការណ៍

ដើម្បីគាំទ្ររបាយការណ៍ដំបូងទាក់ទងនឹងការគណនាមូលនិធិផ្នាល់សុទ្ធ ដែលត្រូវអនុវត្តមិនយឺតជាងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ គណៈគ្រប់គ្រងមានកាតព្វកិច្ចផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវកំណត់ហេតុផ្លូវការនៃមហាសន្និបាតភាគទុនិក ដែលបង្ហាញច្បាស់ពីការអនុមតិបែងចែកប្រាក់ចំណេញរក្សាទុកដែលបានបង្គរ និងដែលបានធ្វើសវនកម្មស្របតាមចំណុច ៤ នៃសារាចរនេះ។

បន្ទាប់ពីមហាសន្និបាតភាគទុនិកសម្រេច របាយការណ៍ហិរញ្ញវត្ថុ ការបែងចែកភាគលាភ និងការបែងចែកប្រាក់ចំណេញរក្សាទុកនៃឆ្នាំមុនៗ គណៈគ្រប់គ្រងត្រូវចេញកំណត់ហេតុផ្លូវការដែលបង្ហាញច្បាស់ពីការសម្រេចអំពីការបែងចែកផលចំណេញនិងប្រាក់ចំណេញរក្សាទុក ឬការបញ្ចូលទៅក្នុងដើមទុនដែលបានបង់ក៏ដូចជាដំណោះស្រាយផ្សេងៗដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលទៅលើស្ថានភាពសាធនភាព រចនាសម្ព័ន្ធដើមទុន និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ។

របាយការណ៍ពាក់ព័ន្ធត្រូវបានផ្តល់ជូន ធនាគារជាតិនៃកម្ពុជាមិនយឺតជាងថ្ងៃទី៣១ ខែឧសភា រៀងរាល់ឆ្នាំ។

ផ.- សារាចរនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

គ.២. វិធានគណនេយ្យ និង ទោយការណ៍

ធ៧-០៤-២០៤ ប្រ.ក

ប្រកាស
ស្តីពី
ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើនិងបញ្ជាក់ដោយសវនកម្មប្រចាំឆ្នាំ ហើយផ្ញើមកធនាគារជាតិនៃកម្ពុជាឱ្យបានមុន ថ្ងៃទី៣១ ខែមីនា នៃឆ្នាំប្រតិទិននីមួយៗ។ ស្នងការគណនីឯករាជ្យប្រតិស្រុតិត្រូវធ្វើសវនកម្ម និងផ្តល់មតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានបញ្ជាក់ដោយសវនកម្មស្របតាមខ្លឹមសារដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ។

ប្រការ ៣.-

របាយការណ៍និងគណនី ដែលត្រូវចេញផ្សាយដូចមានក្នុងគោលការណ៍ណែនាំត្រូវចាប់ផ្តើមពីឆ្នាំ២០០៥ នេះតទៅ ហើយមិនត្រូវយឺតជាងថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រតិទិននីមួយៗ។ របាយការណ៍និងគណនីដែលបានចេញផ្សាយ ត្រូវផ្តល់ជូនអតិថិជននិងសាធារណជន។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាដែលមិនបានអនុវត្តតាមបទបញ្ជានេះត្រូវទទួលរងការដាកពិន័យស្របតាមមាត្រា៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ង៉ា ចាន់តូ**

ឧបសម្ព័ន្ធទី១

ប្រកាសលេខ ធ៧-០៤-២០៤ ប្រ.ក

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំស្របតាមបទដ្ឋានគណនេយ្យកម្ពុជា (CAS) និងការណែនាំធនាគារជាតិនៃកម្ពុជា។ នៅក្នុងករណីដែលបទដ្ឋានគណនេយ្យកម្ពុជាមិនបានបញ្ជាក់អំពីប្រព្រឹត្តកម្មគណនេយ្យ ឬតម្រូវការបើកចំហព័ត៌មាន បទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ត្រូវបានប្រើជំនួស។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងរាល់ស្ថានភាពដែលមានទំនាស់កើតឡើងរវាងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង CAS ឬ IFRS ការណែនាំរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានទទួលស្គាល់ជាផ្លូវការ។

១. តារាងតុល្យការ

១.១ ធនាគារត្រូវតែបង្ហាញនូវព័ត៌មានអប្បបរមានៅក្នុងតារាងតុល្យការ ឬក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

ទ្រព្យសកម្ម

សាច់ប្រាក់

សមតុល្យជាមួយធនាគារកណ្តាល

សមតុល្យជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត

ការដាក់ប្រាក់បញ្ញើ និងការផ្តល់ឥណទានទៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត

មូលបត្រ និង ប័ណ្ណរតនាគាររបស់រដ្ឋាភិបាល

មូលបត្រ និង ប័ណ្ណរតនាគាររបស់រដ្ឋាភិបាលផ្សេងទៀត

ផលបត្រពាណិជ្ជកម្ម

ប័ណ្ណត្រូវទទួល

ការឱ្យខ្ចីចងការ និងបុរេប្រទានចំពោះអតិថិជន (កំណត់សម្គាល់ ១.៥)

សំវិធានធនលើបំណុលអាក្រក់ និងសង្ស័យ

- សំវិធានធនជាក់លាក់
- សំវិធានធនទូទៅ

ការវិនិយោគលើមូលបត្រដែលមានជាកម្មសិទ្ធិ (ធ្វើការវិភាគថាតើជាមូលនិធិ ឬបំណុល)

ទ្រព្យសកម្មផ្សេងទៀត (ផ្តល់ព័ត៌មានលម្អិតនៃខ្លង់សំខាន់ៗ)

ប្រាក់ជំពាក់របស់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់របស់ក្រុមហ៊ុនបុត្តសម្ព័ន្ធ (ធ្វើការវិភាគថាតើជាមូលធន ឬបំណុល)

ការវិនិយោគនៅក្នុងក្រុមហ៊ុនដែលជាសម្ព័ន្ធញាតិ (ធ្វើការវិភាគថាតើជាមូលបត្របំណុល ឬ មូលបត្រភាគហ៊ុន)

អចលនទ្រព្យ (កំណត់សម្គាល់ ១.៥)

ទ្រព្យសម្បត្តិដែលរឹបអូសពីកូនបំណុល (កំណត់សម្គាល់ ១.៥)

ទ្រព្យអកម្ម

ប្រាក់បញ្ញើ និងសមតុល្យរបស់ធនាគារផ្សេងៗ

ប្រាក់បញ្ញើរបស់អតិថិជនមិនមែនជាធនាគារ

សំវិធានធនលើពន្ធ

ប័ណ្ណ និងរូបិយាណត្តិត្រូវសង

ប្រាក់កម្ចីផ្សេងៗ (ដើម្បីផ្តល់នូវការបំបែកនៃខ្នង់សំខាន់ៗ)

ភាគលាភដែលត្រូវសង

ប្រាក់ជំពាក់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់ក្រុមហ៊ុនបុត្តសម្ព័ន្ធ

មូលបត្របំណុលដែលបានចេញផ្សាយ (កំណត់សម្គាល់ ១.៣)

ប្រាក់ជំពាក់ភាគទុនិក

ដើមទុន និងប្រាក់បម្រុង

ដើមទុនរួមចំណែក (សាខាបរទេស)

ភាគហ៊ុន (ដែលបានចុះបញ្ជី ចេញផ្សាយ និងទទួលស្គាល់)

ប្រាក់ខ្ចីបំពេញដើមទុន

ប្រាក់បម្រុង (ធ្វើការវិភាគទៅតាមប្រភេទនីមួយៗនៃទុនបម្រុង) ដោយរួមបញ្ចូលទាំងការវាយតម្លៃឡើងវិញទុនបម្រុង (កំណត់សម្គាល់ ១.២)

ប្រាក់ចំណេញរក្សាទុក/ការបង្គរខាត

១.២ ធនាគារត្រូវតែបង្ហាញចំនួននៃប្រាក់បម្រុងទៅតាមប្រភេទនីមួយៗនៅដើមឆ្នាំនិងចុងឆ្នាំ នៃការិយបរិច្ឆេទគណនេយ្យ ព្រមទាំងចំនួននៃការផ្ទេរទៅ ឬ ផ្ទេរមកពីប្រភេទនីមួយៗនៃទុនបម្រុងនៅកំឡុងឆ្នាំ។

	ភាគហ៊ុនធម្មតា	ទុនបម្រុងធនាគារទូទៅ	ទុនបម្រុង	ការវាយតម្លៃឡើងវិញនៃមូលបត្រភាគហ៊ុនរយៈពេលវែងដែលអាចលក់បាន	ប្រាក់ចំណេញរក្សាទុក
សមតុល្យដើមគ្រា +ការផ្ទេរចូលទុនបម្រុង -ការដកចេញពីទុនបម្រុង សមតុល្យចុងក្រោយ					

១.៣ ចំពោះមូលបត្របំណុលចេញផ្សាយដោយធនាគារដែលមានឥណប្រតិទានដំបូងច្រើនជាង ១ឆ្នាំ ធនាគារត្រូវបង្ហាញអត្រាការប្រាក់ (ចំពោះមូលបត្រដែលអត្រាការប្រាក់ថេរ) ឬ វិធីសាស្ត្រកំណត់អត្រាការប្រាក់ (ចំពោះមូលបត្រដែលមានអត្រាការប្រាក់អណ្តែត) និងកាលបរិច្ឆេទទូទាត់សង។

១.៤ ធនាគារត្រូវបង្ហាញពីតម្លៃទីផ្សារនៃការវិនិយោគ ទ្រព្យសម្បត្តិរបស់ធនាគារ និងទ្រព្យសម្បត្តិដែលរឹបអូសពីកូនបំណុល។ (ស្របនឹងតម្រូវការនៃប្រកាសលេខ ធ៧-០១-១៨៦ ប្រ.ក ស្តីពី អចលនទ្រព្យរបស់ធនាគារ)

១.៥ ឱ្យខ្ចីចងការ និងបុរេប្រទានទៅអតិថិជន

	សមតុល្យដើមគ្រា	សមតុល្យចុងគ្រា
ឥណទានទៅរដ្ឋាភិបាល - រាជរដ្ឋាភិបាល - ផ្សេងៗ		
ឥណទានពាណិជ្ជកម្ម - ឥណទានវិបារូបន៍ - ឥណទានរយៈកាលខ្លី - ឥណទានរយៈកាលវែង - ឥណទានភតិសន្យា - ឥណទានសម្ព័ន្ធញាតិ - ឥណទានពាណិជ្ជកម្មផ្សេងៗ		
ឥណទានចំពោះអ្នកប្រើប្រាស់ - អចលនទ្រព្យ - ឥណទានវិបារូបន៍ - ឥណទានចំពោះអ្នកប្រើប្រាស់ - ផ្សេងៗ		
ឥណទានសរុប		

ចំពោះខ្លឹមសារនៃ "ឥណទានសម្ព័ន្ធញាតិ" ដែលមានចែងក្នុងមាត្រាទី៤៩ និង ៥០ ក្នុងជំពូក ១៦ នៃច្បាប់ស្តីពី **គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**។

១.៦ ធនាគារត្រូវបង្ហាញចំនួនសរុបដុលនៃឥណទានដំណើរការ និងឥណទានមិនដំណើរការ (បំណុលដែលមានការធានា និងបំណុលមិនមានការធានា) ដែលបានកំណត់ជា បំណុលជាស្តង់ដារ បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ស្របតាមប្រកាសលេខ ធ៧-០០-៥១ ស្តីពី ចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ និង ប្រកាសលេខ ធ៧-០២-១៤៥ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១ *(ប្រកាសលេខ ធ៧-០០-៥១ ស្តីពី*

ចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ និង ប្រកាសលេខ ធ៧-០២-១៤៥ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១ ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។)

	សមតុល្យចុងគ្រា	សមតុល្យដើមគ្រា
បំណុលស្តង់ដារ - មានការធានា - មិនមានការធានា បំណុលក្រោមស្តង់ដារ - មានការធានា - មិនមានការធានា បំណុលសង្ស័យ - មានការធានា - មិនមានការធានា បំណុលបាត់បង់ - មានការធានា - មិនការធានា		

១.៧ ធនាគារត្រូវផ្តល់នូវតារាងដែលបង្ហាញពីបម្រែបម្រួលសមតុល្យនៃសំវិធានធននៅដើមគ្រា ដកចេញ ឬបូកបញ្ចូលក្នុងគណនីចំណេញ-ខាតនៅក្នុងឆ្នាំ ចំនួនទឹកប្រាក់ប្រើប្រាស់សម្រាប់លុបចោលបំណុលអាក្រក់ប្រចាំឆ្នាំ និងសមតុល្យចុងគ្រា ដែលអនុវត្តតាម៖

- សំវិធានធនជាក់លាក់សម្រាប់បំណុលបាត់បង់
- សំវិធានធនជាក់លាក់សម្រាប់ការថយចុះតម្លៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត
- សំវិធានធនទូទៅ សម្រាប់បំណុលបាត់បង់ដែលអាចកើតឡើង និងហានិភ័យធនាគារផ្សេងទៀត។

តារាងស្រដៀងគ្នាដែលបង្ហាញពីបម្រែបម្រួលនៃការប្រាក់ព្យួរទុក ធនាគារត្រូវផ្តល់ឱ្យផងដែរ។

១.៨ ទ្រព្យសកម្មដែលបានសន្យាជាវត្ថុធានាជាមួយភាគីទីបី រួមទាំងចំនួនសរុបនៃបំណុលដែលមានការធានាត្រូវធ្វើការបង្ហាញផងដែរ។

២. របាយការណ៍ចំណេញ-ខាត

ធនាគារត្រូវតែបង្ហាញនូវព័ត៌មានអប្បបរមានៅក្នុងរបាយការណ៍ចំណេញ-ខាត ឬក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម៖

ចំណូលពីការប្រាក់

ចំណាយការប្រាក់

ចំណូលពីការប្រាក់សុទ្ធ

ចំណូលពីប្រតិបត្តិការផ្សេងៗ

- ចំណេញ (ខាត) ពីសកម្មភាពជួញដូរ (ធ្វើការវិភាគលើចំណូលដែលបានមកពីការជួញដូររូបិយប័ណ្ណ មូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដោយឡែកពីគ្នា។
- ថ្លៃឈ្នួល និងកម្រៃជើងសា
- ភាគលាភ (ធ្វើការវិភាគលើចំណូលភាគលាភដែលបានមកពីបុគ្គលសម្ព័ន្ធ មកពីក្រុមហ៊ុនដែលជាសម្ព័ន្ធញាតិ និងមកពីការវិនិយោគផ្សេងទៀតដោយឡែកពីគ្នា)។
- ថ្លៃជួល
- ចំណេញ (ខាត) ពីការលក់មូលបត្រវិនិយោគ
- ចំណូលផ្សេងៗ

ចំណាយលើប្រតិបត្តិការផ្សេងៗ

- ការចំណាយលើបុគ្គលិក (រួមបញ្ចូលទាំងប្រាក់លើកទឹកចិត្ត)
- ការចំណាយលើអគ្គនាយក និងអត្ថប្រយោជន៍បន្ថែម
- ប្រាក់កម្រៃរបស់សវនករ
- រំលស់លើទ្រព្យសកម្មរូបិយ
- រំលស់លើទ្រព្យសកម្មអរូបិយ
- ការថែរក្សា និងការជួលនៃអចលនទ្រព្យ
- ការចំណាយលើអាគារ (ការថែរក្សានិងការធានារ៉ាប់រង)
- ការចំណាយផ្សេងៗ
- ចំណាយលើសន្តិសុខ (ធានារ៉ាប់រងលើការដឹកជញ្ជូនសាច់ប្រាក់ ការថែរក្សាអាគារ និងអតិថិជន)។

ប្រាក់ចំណេញពីប្រតិបត្តិការ

សំវិធានធនសម្រាប់ឥណទានបាត់បង់ដែលអាចកើតមាននិងការថយចុះតម្លៃនៃទ្រព្យសកម្មដទៃទៀត

- សំវិធានធនជាក់លាក់សម្រាប់បំណុលបាត់បង់
- សំវិធានធនជាក់លាក់សម្រាប់ការថយចុះតម្លៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត

- សំវិធានធនទូទៅ រួមបញ្ចូលទាំងសំវិធានធនសម្រាប់បំណុលបាត់បង់ដែលអាចកើតមាន និងហានិភ័យធនាគារដទៃទៀត
- ការប្រមូលបានមកវិញនូវសំវិធានធន និងចំណាយដែលបានលុបចោលពីគ្រាមុន
- ចំនួនដែលបានលុបចោល

ការបែងចែកប្រាក់ចំណេញ (ខាត) នៃក្រុមហ៊ុនសម្ព័ន្ធញាតិ

ចំណាយបង់ពន្ធ

ជំពូកវិសាមញ្ញ

ប្រាក់ចំណេញមិនសមស្របផ្ទេរមកពីឆ្នាំមុន

ភាគលាភ

- ភាគលាភបណ្តោះអាសន្ន
- ភាគលាភចុងក្រោយដែលបានស្នើ

ផ្ទេរទៅទុនបម្រុងទូទៅ

ប្រាក់ចំណេញមិនសមស្របផ្ទេរទៅគ្រាខាងមុខ

៣. រចនាសម្ព័ន្ធរបាយការណ៍លំហូរសាច់ប្រាក់

ធនាគារត្រូវតែរៀបចំរបាយការណ៍លំហូរសាច់ប្រាក់។

៤. ជំពូកក្រៅតារាងតុល្យការ

ធនាគារគួរតែបង្ហាញពីការបែងចែកខ្លង់ក្រៅតារាងតុល្យការជាបីផ្នែកដូចតទៅ៖

- កិច្ចសន្យាយថាភាព ត្រូវបង្ហាញចំនួនទឹកប្រាក់នៃកិច្ចសន្យាសម្រាប់ធាតុនីមួយៗខាងក្រោម ឬធាតុណាដែលមានចំណាត់ថ្នាក់ប្រហាក់ប្រហែលនឹងធាតុខាងក្រោម៖
  - ជំនួយឥណទានផ្ទាល់
  - យថាភាពពាក់ព័ន្ធនឹងប្រតិបត្តិការ
  - យថាភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម
  - កិច្ចសន្យាយថាភាពផ្សេងៗ
- ការសន្យាត្រូវបង្ហាញពីចំនួនទឹកប្រាក់នៃខ្លង់នីមួយៗដែលបានសន្យាដូចខាងក្រោម៖
  - កម្រិតឥណទានមិនបានដក និងការសន្យាពន្យារពេលឥណទានផ្សេងៗ
  - កិច្ចសន្យាផ្តល់ឥណទានដែលមិនបានដកប្រើ និងការបន្តលើកិច្ចសន្យាផ្តល់ឥណទាន
  - ការទិញ ឬលក់ទ្រព្យសកម្ម និងការដាក់ប្រាក់បញ្ញើនៅពេលអនាគត
  - ការសន្យាផ្សេងៗ

- ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទដែលមានជារូបិយប័ណ្ណបរទេស អត្រាការប្រាក់និងដើមទុន ដុំ មាស ឬ ប្រាក់ និងទំនិញប្រើប្រាស់ផ្សេងៗ រួមទាំងកិច្ចសន្យាផ្សេងៗដែលពាក់ព័ន្ធ។ កិច្ចសន្យាទាំងនោះមានការទិញ-លក់រូបិយប័ណ្ណ និងផលបត្រនាពេលអនាគត ការដោះដូររូបិយប័ណ្ណ និងអត្រាការប្រាក់ ការយល់ព្រមកំណត់អត្រាការប្រាក់នាពេលអនាគត សិទ្ធិទិញ ឬលក់ដែលកំណត់តម្លៃជាក់លាក់សម្រាប់ពេលខាងមុខ។ ក្នុងករណីចាំបាច់ ធនាគារត្រូវបង្ហាញនូវចំនួនទឹកប្រាក់នៃកិច្ចសន្យា តម្លៃទីផ្សារដុលវិជ្ជមាន ឬអវិជ្ជមាន និងមានឥទ្ធិពលនៃកិច្ចព្រមព្រៀងសរុបដែលអាចអនុវត្តបានតាមផ្លូវច្បាប់ចំពោះខ្នង់នីមួយៗ។ ក្នុងករណីចាំបាច់ ព័ត៌មានដូចគ្នានេះត្រូវបានឱ្យសម្រាប់ទំនិញប្រើប្រាស់ និងឥណទាននិស្សន្ទ។ ត្រូវញែកឱ្យដាច់នៃប្រតិបត្តិការទៅលើឧបករណ៍និស្សន្ទរវាងប្រតិបត្តិការបញ្ចៀសហានិភ័យ និងប្រតិបត្តិការពាណិជ្ជ។

៥. គោលការណ៍គណនេយ្យ

ធនាគារត្រូវតែបង្ហាញឱ្យឃើញនូវគោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុម័តក្នុងការរៀបចំ និងការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ។ ចំណុចខាងក្រោមត្រូវបង្ហាញក្នុងគោលការណ៍គណនេយ្យ ប៉ុន្តែមិនកំណត់ត្រឹមតែចំណុចទាំងអស់នេះទេ៖

- មូលដ្ឋាននៃការទទួលស្គាល់នូវប្រភពប្រាក់ចំណូលសំខាន់ៗ
- ការផ្លាស់ប្តូរវិធីសាស្ត្រគណនេយ្យក្នុងអំឡុងនៃឆ្នាំ ដែលក្នុងករណីនេះ គណនីហិរញ្ញវត្ថុនៃឆ្នាំមុនត្រូវបានបង្ហាញជាមួយវិធីសាស្ត្រថ្មី
- មូលដ្ឋានសម្រាប់ធ្វើសំវិធានធនជាក់លាក់ទៅលើឥណទានបាត់បង់ និងធ្វើសំវិធានធនទូទៅសម្រាប់ហានិភ័យឥណទាន ឬសម្រាប់ហានិភ័យធនាគារដទៃទៀត
- វិធីសាស្ត្រនៃការវាយតម្លៃទៅលើមូលបត្រវិនិយោគ ការជួញដូរមូលបត្រនិងឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ
- ការធ្វើរំលស់ទៅលើអចលនទ្រព្យ
- មូលដ្ឋាននៃការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ
- ការផ្ទេរតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយប័ណ្ណបរទេសមកជារូបិយប័ណ្ណក្នុងស្រុក។

៦. ការកាត់ចំណែកនៃព័ត៌មាន

៦.១ ធនាគារត្រូវរិភាគឥណទាន និងបុរេប្រទានទៅតាមជំពូកនៃវិស័យដូចខាងក្រោម (ការប្រមូលផ្តុំនូវការផ្តល់ទុនទៅតាមវិស័យ)

- កសិកម្ម
- ឧស្សាហកម្ម
- សំណង់ និងការស្ថាបនា
- ផ្ទះ (ទិញ)
- ដឹកជញ្ជូន និងគមនាគមន៍
- សេវាកម្ម
- វិជ្ជាជីវៈ និងការប្រើប្រាស់ជាឯកជន (លើកលែងការឱ្យខ្ចីសម្រាប់ទិញផ្ទះ)

- លក់ដុំ និង លក់រាយ - ផ្សេងៗ
- នាំចេញ
- នាំចូល

៦.២ ធនាគារត្រូវផ្តល់នូវការវិភាគឥណប្រតិទានសម្រាប់ការឱ្យខ្ចី (ទាំងធនាគារនិងមិនមែនធនាគារ) និងការដាក់ប្រាក់បញ្ញើ (ធនាគារ និងមិនមែនធនាគារ) ទៅតាមប្រភេទនៃកាលវសាន ដូចខាងក្រោម៖

- កាលវសានរយៈពេល ១ឆ្នាំ
- ច្រើនជាង ១ឆ្នាំ តែតិចជាង ៣ឆ្នាំ
- ច្រើនជាង ៣ឆ្នាំ តែតិចជាង ៥ឆ្នាំ
- ច្រើនជាង ៥ឆ្នាំ

ការវិភាគទៅតាមប្រភេទនៃឥណប្រតិទាននីមួយៗត្រូវផ្អែកទៅលើពេលវេលាដែលនៅសល់រហូតដល់កាលវសានតាមកិច្ចសន្យានៅក្នុងកាលបរិច្ឆេទតារាងតុល្យការ។

៧. **ការត្រួតពិនិត្យ**

ធនាគារត្រូវបង្ហាញព័ត៌មានដូចខាងក្រោមសម្រាប់គោលបំណងនៃការត្រួតពិនិត្យ ហើយព័ត៌មានទាំងនោះមិនចាំបាច់បោះផ្សាយសម្រាប់សាធារណជននោះទេ។

៧.១ បទប្បញ្ញត្តិប្រុងប្រយ័ត្ន

- ប្រកាសស្តីពីអនុបាតសាច់ប្រាក់ងាយស្រួលរបស់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ លេខ ធ៧-០០-៣៨ និងប្រកាសស្តីពីវិសោធនកម្ម លេខ ធ៧-០២-១៨៧ ប្រ.ក

  ក. សាច់ប្រាក់ងាយស្រួល (Liquidity Management)

  ខ. ចំណាត់ថ្នាក់សាច់ប្រាក់ងាយស្រួល (Liquidity Position)

  (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព។)

- ប្រកាសស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ លេខ ធ៧-០០-៤៧ ប្រ.ក

  (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។)

- ប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ លេខ ធ៧-០០-៥៦ ប្រ.ក
- ប្រកាសស្តីពីសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ លេខ ធ៧-០០-៥១
  (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត

ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។)

៧.២ ព័ត៌មានបន្ថែម (ឧបសម្ព័ន្ធ ២)

៧.៣ សូចនាករហិរញ្ញវត្ថុសំខាន់ៗ

- ដើមទុន
- ទ្រព្យសកម្ម
- ប្រាក់ចំណេញ
- សាច់ប្រាក់ងាយស្រួល

៧.៤ របាយការណ៍របស់អ្នកគ្រប់គ្រង

អនុសាសន៍របស់ស្នងការគណនេយ្យ កត់សម្គាល់ពីចំណុចខ្សោយដែលរកឃើញនៅក្នុងពេលធ្វើសវនកម្ម ប៉ុន្តែមិនកំណត់តែចំណុចដូចមានចែងខាងក្រោមទេ៖

១- រាល់កិច្ចសន្យា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារវាងធនាគារ និងម្ចាស់ភាគហ៊ុន នាយកគ្រប់គ្រង និងភាគីដែលពាក់ព័ន្ធដទៃទៀត។

២- ការផ្លាស់ប្តូរអ្នកគ្រប់គ្រង (បុគ្គលិកជាន់ខ្ពស់ ភាពញឹកញាប់ មូលហេតុ និងជម្លោះផលប្រយោជន៍ជាសក្តានុពល ការតែងតាំងក្រុមប្រឹក្សាភិបាល)

៣- ការឧទ្ទេសនាមផលិតផលថ្មី (ការលក់មូលបត្រទេសចរណ៍ និងកិច្ចសន្យាដោះដូរ)

៤- កិច្ចសន្យាថ្មី (ភតិសន្យាថ្មី កិច្ចព្រមព្រៀងរវាងភ្នាក់ងារនិងធនាគារ)

៥- ការបើកសាខាថ្មី (មូលហេតុ គោលបំណង និងការចាត់តាំងបុគ្គលិក)

៦- គុណភាពនៃសំពៀតឥណទាន (ការប្រមូលផ្តុំឥណទាន តំបន់ឧស្សាហកម្ម និងបុគ្គល)

៧- ការវិនិយោគក្នុងឆ្នាំ (មូលហេតុ ការអនុមតិ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)

៨- ភាពគ្រប់គ្រាន់នៃសំវិធានធន

៩- ប្រតិបត្តិការកុំព្យូទ័រ (សុវត្ថិភាព ការរក្សាទុក បុគ្គលិក ប្រសិទ្ធភាព និងហានិភ័យ)

១០- ផែនការប្រមូលការខូចខាតមកវិញក្នុងពេលអាសន្ន

១១- គោលនយោបាយសម្រាប់ការគ្រប់គ្រង់ការប្រឈមមុខនឹងហានិភ័យរូបិយវត្ថុ (ព័ត៌មានបែបបរិមាណ)

១២- ចំណុចខ្សោយដទៃទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ

ឧបសម្ព័ន្ធទី២
ប្រកាសលេខ ធ៧-០៤-២០៤ ប្រ.ក
ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

ឈ្មោះធនាគារ.....

(I). ធាតុនីមួយៗនៃតារាងតុល្យការ

(ក).(១) សរុបឥណទានតាមចំណាត់ថ្នាក់ដែលបានផ្តល់ឱ្យអតិថិជន ចំនួនទឹកប្រាក់

- ក្រោមស្តង់ដារ _____
- សង្ស័យ _____
- បាត់បង់ _____

ដក៖ ទឹកប្រាក់ប៉ាន់ស្មានដែលអាចទាញមកវិញបាន _____

ទឹកប្រាក់ប៉ាន់ស្មានដែលមិនអាចទាញមកវិញបាន _____

(២) សំវិធានធនជាក់លាក់សម្រាប់ឥណទានបាត់បង់និងសង្ស័យ

- ឱ្យខ្ចីចងការ និងបុរេប្រទាន _____
- ប័ណ្ណឥណទេយ្យ _____

(៣) សំវិធានធនទូទៅសម្រាប់ឥណទាន _____

(ខ). មូលបត្រវិនិយោគរយៈពេលខ្លីនិងរយៈពេលវែង

ការពិពណ៌នា	ថ្លៃដើម	តម្លៃចារឹកសន្លឹកប័ណ្ណ	បុព្វលាភដែលចូលក្នុងខ្នង់ចំណាយ	អប្បហារបង្គរទុកជាចំណូល	ការធ្លាក់ចុះនៃតម្លៃ		តម្លៃក្នុងបញ្ជី	តម្លៃទីផ្សារ (ចំណាយការប្រាក់ក្នុងករណីមូលបត្របំណុល)
(១) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាល					សំវិធានធនដែលបានធ្វើ	ចំនួនដែលបានលុបចោល		
(២) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាលដទៃទៀត								
(៣)ការវិនិយោគលើក្រុមហ៊ុនដែលជាសាខា								
(៤) ការវិនិយោគលើក្រុមហ៊ុនដែលពាក់ព័ន្ធ								
(៥) ការវិនិយោគដទៃទៀត								
- ការវិនិយោគជាដើមទុន								
- ក្រដាសដទៃទៀត								

• មិនរួមបញ្ចូលប័ណ្ណអប្បហារ

(គ). អគារធនាគារ និងទ្រព្យសម្បត្តិដទៃទៀតដែលមិនអាចធ្វើចលនាបាន ចំនួន

(១) ថ្លៃដើមរបស់ទ្រព្យសម្បត្តិ _____

(២) ចំនួនដែលបានលុបចោល _____

(៣) សំវិធានធនសម្រាប់រំលស់ ឬការបាត់បង់ _____

(៤) តម្លៃទីផ្សារ ឬតម្លៃទីផ្សារដែលបានប៉ាន់ស្មាន (បង្ហាញកាលបរិច្ឆេទ និងការវាយតម្លៃចុងក្រោយបំផុតរបស់អ្នកវាយតម្លៃដែលមានវិជ្ជាជីវៈ)។ បង្ហាញបញ្ជីទ្រព្យសម្បត្តិ អាសយដ្ឋាន និងសេចក្តីលម្អិតដទៃទៀត[1] _____

(ឃ). ប្រាក់បម្រុងដើមទុន

(១) ប្រាក់បម្រុងបុព្វលាភរបស់សន្លឹកហ៊ុន _____

(២) ប្រាក់បម្រុងវាយតម្លៃ _____

(៣) ប្រាក់បម្រុងដើមទុនដទៃទៀត _____

(ង). ប្រាក់បម្រុងចំណូល[2]

(១) ប្រាក់បម្រុងកាតព្វកិច្ច _____

(២) ប្រាក់បម្រុងចំណូលដទៃទៀត _____

(៣) ចំណេញ ឬខាតដែលមិនសមស្រប _____

(ច). សំវិធានធនដទៃទៀត និងការបម្រុងទុកសម្រាប់ការបាត់បង់ ឬយថាភាព ផ្តល់សេចក្តីលម្អិតនៃការធ្វើសំវិធានធន និងប្រាក់បម្រុងដទៃទៀត "ដោយ បញ្ជាក់ពីគោលបំណងនៃការបម្រុងទុកនោះ" ដែលបានបែងចែកទៅតាម ខ្នង់ (បំណុលដទៃទៀតដែលបានរួមបញ្ចូលសំវិធានធននិងការបម្រុងទុក ដទៃទៀត) នៅក្នុងតុល្យការ។ _____

(ឆ). ផ្តល់ព័ត៌មានលម្អិតដែលបានបញ្ចូលនៅក្នុងគណនីដទៃទៀត _____

(ជ). (១) ប្រាក់បញ្ញើសរុបរបស់អតិថិជនដែលមិនមែនធនាគារ _____

(២) ប្រាក់បញ្ញើ និងសមតុល្យរបស់ធនាគារ និងភ្នាក់ងារ _____

(ឈ). ប្រសិនបើអាចធ្វើបាន គួរតែភ្ជាប់មកជាមួយនូវខ្នង់ដូចខាងក្រោម

---

[1] លុបចោលនៅពេលចាំបាច់

[2] - ប្រាក់បម្រុងកាតព្វកិច្ចដែលបានកំណត់នៅក្នុងប្រកាសលេខ ធ៧-០២០-២៣០ ប្រ.ក
- ប្រាក់បម្រុងចំណូលដទៃទៀតគឺចំនួនដែលលើសពីប្រាក់បម្រុងកាតព្វកិច្ច

(១) រាយឈ្មោះប្រភេទឥណទានប្រើប្រាស់ដោយក្រុមហ៊ុនដែលធនាគារកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោល។

(២) រាយឈ្មោះឥណទាន និងប្រភេទឥណទានដទៃទៀតដែលបានផ្តល់ទៅឱ្យសម្ព័ន្ធញាតិដូចមានចែងក្នុងមាត្រា ៤៨-៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

(៣) រាយឈ្មោះទ្រព្យសម្បត្តិរបស់ធនាគារ ដែលបានដាក់បញ្ចាំ ឬផ្ទើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត។ល។ ដូចជាវត្ថុធានាសម្រាប់មូលនិធិដែលបានផ្តល់ឱ្យធនាគារ ឬភាគីណាមួយ ដោយប្រើមធ្យោបាយជាប្រាក់បញ្ញើ ឥណទាន បុរេប្រទាន ឬមធ្យោបាយដទៃទៀត។

(II). របាយការណ៍ចំណេញ-ខាត

(១) របាយការណ៍ចំណេញ-ខាតដែលបានធ្វើសវនកម្មរួចមួយច្បាប់ ដែលបង្ហាញសេចក្តីលម្អិតអំពីចំណូល និងចំណាយរបស់ធនាគារ និង

(២) ភ្ជាប់មកជាមួយនូវរបាយការណ៍ចំណេញ-ខាត មួយច្បាប់

នាយកប្រតិបត្តិ

នាយកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ

យើងសូមអះអាងថា ព័ត៌មានហិរញ្ញវត្ថុដែលបានបញ្ជាក់ខាងលើអនុលោមទៅតាមបញ្ជី និងកំណត់ត្រាហិរញ្ញវត្ថុរបស់ធនាគារ ដែលបានរៀបចំឡើងផ្អែកលើមូលដ្ឋានសវនកម្មរបស់ធនាគារ។

ស្នងការគណនីឯករាជ្យ

ឧបសម្ព័ន្ធទី៣

ប្រកាសលេខ ធ៧-០៤-២០៤ ប្រ.ក

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

កំណត់សម្គាល់

២	ដើមទុនថ្នាក់ទី ១ = ដើមទុនបានបង់ជម្រះ (ភាគហ៊ុនធម្មតា) + ទុនបម្រុង
៣, ៤ និង ៦	ទ្រព្យសម្បត្តិដែលបានថ្លឹងហានិភ័យរួច សំដៅលើភាគយករបស់អនុបាតសាធនភាព។ សម្រាប់ព័ត៌មានលម្អិត សូមមើលប្រកាសស្តីពី អនុបាតសាធនភាពរបស់ធនាគារ
៤	ដើមទុនថ្នាក់ ១ + ថ្នាក់២ = ដើមទុនបានបង់ជម្រះ (ភាគហ៊ុនធម្មតា) + ទុនបម្រុង + ទុនបម្រុងទូទៅ + បំណុលបំពេញដើមទុន + ដើមទុនកូនកាត់ (ភាគហ៊ុនអាទិភាព)
៩	ភាគលាភ សំដៅលើភាគលាភដែលបានបង់ក្នុងឆ្នាំ
១១	ទុនបម្រុងសម្រាប់ហានិភ័យធនាគារ សំដៅលើគណនីលេខ ៤០៥០០០ នៅក្នុងប្លង់គណនី
១៤, ១៦	ទ្រព្យសម្បត្តិដែលបានចាត់ថ្នាក់សំដៅឥណទានមិនដំណើរការនិងទ្រព្យសម្បត្តិទាំងឡាយណាដែលចាំបាច់ត្រូវធ្វើសំវិធានធន
១៨	សម្រាប់និយមន័យនៃពាក្យ "ហានិភ័យធំៗ" សូមយោងទៅតាមប្រកាសលេខ ធ៧-០០-៥២ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៦-២២៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)*
២៤	សំវិធានធន = សំវិធានធនសម្រាប់ការខាតបង់ឥណទាននិងភតិសន្យា (គណនីលេខ ១៧០០០០) + សំវិធានធនសម្រាប់ការខាតបង់ឥណទានលើការវិនិយោគនិងមូលបត្រ (គណនីលេខ ២១៤០០០)។
៣១	សំវិធានធនកំណត់ដោយគណនីលេខ ៦៦១០០០ រួមមាន សំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យលើប្រាក់ដើមនិងបង្គរការប្រាក់ សំវិធានធនសម្រាប់ការខាតបង់លើខ្នង់ក្រៅតារាងតុល្យការ សំវិធានធនលើការខាតបង់ប្រាក់ដើមរបស់មូលបត្រ និងសំវិធានធនទូទៅ។
៣៤	ពន្ធ = ពន្ធប៉ាតង់ (៦៥៧១០០) + ពន្ធលើដីដែលមិនបានប្រើប្រាស់ (៦៥៧៤០០) + ពន្ធលើមធ្យោបាយដឹកជញ្ជូន (៦៥៨០០០) + ពន្ធលើប្រាក់ចំណេញ (៦៥៩១០០)។
៣៩	ទ្រព្យសម្បត្តិងាយក្លាយជាសាច់ប្រាក់ សូមយោងទៅខ្នង់ឥណពន្ធដែលបានកំណត់នៅក្នុងប្រកាសលេខ ធ៧-០០-៣៨ ស្តីអំពី អនុបាតសាច់ប្រាក់ងាយស្រួល។ *(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១៥-៣៥៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព។)*
៥២	Quick Assets = សាច់ប្រាក់ + មាស + ប្រាក់បញ្ញើនៅធនាគារជាតិ (មិនរាប់បញ្ចូលប្រាក់ធានាលើដើមទុននិងប្រាក់បម្រុងកាតព្វកិច្ច) + ប្រាក់បញ្ញើនៅធនាគារដទៃទៀត

Appendix 3 attached to
Prakas Nº B7-04-204 Prokor
date December 29, 2004

FINANCIAL SOUNDNESS INDICATORS

CAPITAL

1- Equity to Total Asset (A/B)
- A- Equity
- B- Total assets

2- Capital Tier I to Total Asset (A/B)
- A- Capital Tier I
- B- Total assets

3- Capital Tier I to Risk Weighted Asset (A/B)
- A- Capital Tier I
- B- Risk Weighted assets

4- Capital Tier 1 +Tier 2 to Risk Weighted Asset (A/B)
- A- Capital Tier 1 +Tier 2
- B- Risk Weighted assets

5- Net Worth to Total Assets (A/B)
- A- Net Worth
- B- Total assets

6- Solvency Ratio (A/B)
- A- Net Worth
- B- Risk Weighted assets

7- Debt to Total Asset (A/B)
- A- Total liabilities
- B- Total assets

8- Debt to Equity (A/B)
- A- Total liabilities
- B- Equity

9- Dividend to Net Profit (A/B)
- A- Dividend
- B- Net Profit

ASSET QUALITY

10- Banking Reserve to Total Loans (A/B)
- A- Banking Reserves
- B- Total Loans (gross)

11- Banking Reserve to Total Assets (A/B)
- A- Banking Reserves
- B- Total assets

12- NPL to Total Loan (A/B)
- A- NPL
- B- Total loan (gross)

13- NPL to Total Asset (A/B)
- A- NPL
- B- Total Asset

14- Classified Asset to Total Loan (A/B)
- A- Classified Asset
- B- Total loans (gross)

15- Classified Asset to Total Asset (A/B)
- A- Classified assets
- B- Total assets

16- Classified Asset to Equity (A/B)
- A- Classified assets
- B- Equity

17- Loan to Related Parties to Total Loan (A/B)
- A- Loan to Related Parties
- B- Total loans (gross)

18- Large Exposure to Total Loan (A/B)
- A- Large exposure
- B- Total loans (gross)

19- Loan to Related Party to Net Worth (A/B)
- A- Loan to related Parties
- B- Net Worth

20- Large Exposure to Net Worth (A/B)
- A- Large exposure
- B- Net Worth

21- General Provision to Total Loan (A/B)
- A- General Provision
- B- Total loans (gross)

22- Specific Provision to Total Loan (A/B)
- A- Specific Provision
- B- Total loans (gross)

23- Specific Provision to NPL (A/B)
- A- Specific provision
- B-NPL

24- All Allowances to Total Assets (A/B)
- A- Total all allowances
- B- Total assets

25- Loans to Deposits (A/B)
- A- Total loans to non-bank customers (gross)
- B- Customer's deposits

EARNINGS

26- ROA (A/B)
- A- Net profit
- B- Total assets

27- ROE (A/B)
- A- Net profit
- B- Equity

28- Gross Yield (A/B)
- A- Interest income
- B- Total assets

29- Net Interest margin (NIM) to Total Asset (A-B)/C)
- A- Interest income
- B- Interest expense
- C- Total assets

30- Other Income (OTINC) = (A/B)
- A- Other incomes
- B- Total assets

31- Provision to Total Assets (A/B)
- A- Provision
- B- Total assets

32- Overhead (OHEAD) = (A/B)
- A- Non-interest expenses
- B- Total assets

33- Net Income Before Tax (NIBT) = (A/B)
- A- Net income before tax
- B- Total assets

34- Tax to Total Assets (A/B)
- A-Tax
- B- Total assets

35- Interest Margin to Gross Income ((A-B)/C)
- A- Interest income
- B- Interest expense
- C- Gross income

36- Non-interest Income to Gross Income (A/B)
- A- Non-interest income
- B- Gross Income

37- Non-Interest Expense to Gross Income (A/B)
- A- Non-Interest expense
- B- Gross income

38- Times Interest earned ((A+B)/C)
- A- Income before tax
- B- Interest expense
- C- Interest expense

LIQUIDITY

39- Liquid Asset (A/B)
- A- Liquid asset
- B- Total assets

40- Short-term Liabilities (A/B)
- A- Short-term liabilities (less than one year)
- B- Total assets

41- Net Liquid Assets (A-B)/C
- A- Liquid assets
- B- Short-term liabilities
- C- Total liabilities

42- Quick ratio (A/B)
- A- Quick assets
- B- Current liabilities

43- Deposits to Total Loans (A/B)
- A- Total customers' deposits
- B- Total loans to non-bank customers (gross)

គោលការណ៍ណែនាំ

ប្រកាសលេខ ធ៧-០៤-២០៤ ប្រ.ក

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

គោលការណ៍សម្រាប់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុស្តីពីដំឡូកដែលត្រូវបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ

ធនាគារត្រូវបង្ហាញព័ត៌មានដូចខាងក្រោម៖

១. របាយការណ៍របស់នាយកក្រុមប្រឹក្សាភិបាល

- បរិស្ថានអាជីវកម្មទូទៅ
- របាយការណ៍សង្ខេបនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ
- បង្ហាញដោយសង្ខេបពីផលិតផលថ្មីដែលធ្វើការឧទ្ទេសនាម ប្រសិនបើមាន
- សមត្ថភាពក្នុងការគោរពទៅតាមបទប្បញ្ញត្តិធនាគារជាតិ និងសកម្មភាពផ្សេងៗ
- ជំហានដែលបានអនុវត្តដើម្បីពង្រឹងប្រត្តិបត្តិការ និងជំហររបស់ធនាគារ
- គោលដៅនិងកិច្ចសន្យារបស់ក្រុមប្រឹក្សាភិបាល

២. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល

- ការបែងចែកភារកិច្ច និងការទទួលខុសត្រូវនៅក្នុងធនាគារ
- ការរាយការណ៍ និងការគ្រប់គ្រង

៣. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

- របាយការណ៍គណនីគ្រប់គ្រង
- សកម្មភាពចម្បងៗនៅក្នុងឆ្នាំ

៤. គោលនយោបាយ និងរបាយការណ៍សម្រាប់អភិបាលកិច្ចសាជីវកម្ម

- ការជ្រើសរើសគណៈគ្រប់គ្រង
- ក្រុមប្រឹក្សាភិបាល
  - ✓ សមាសភាពក្រុមប្រឹក្សាភិបាល
  - ✓ ប្រវត្តិសង្ខេបរបស់ក្រុមប្រឹក្សាភិបាល
  - ✓ ការប្រជុំក្រុមប្រឹក្សាភិបាល
- ការត្រួតពិនិត្យផ្ទៃក្នុង
- ការគ្រប់គ្រងហានិភ័យ
- ក្រមសីលធម៌
- ឯករាជ្យភាព និងតម្លាភាព

៥. ការពិពណ៌នាពីអាជីវកម្ម

- សកម្មភាពចម្បងៗរបស់ធនាគារ
- បេសកម្មនិងទស្សនវិស័យ
- ទស្សនវិទ្យារបស់ធនាគារ
  - ✓ អតិថិជន
  - ✓ និយោជិត
  - ✓ បរិស្ថាន សង្គម និង សហគមន៍
  - ✓ ភាគទុនិក

៦. សន្ទស្សន៍ហិរញ្ញវត្ថុ (សូចនាករសំខាន់ៗ)

- លទ្ធភាពរកចំណូល
- សង្វៀបតារាងតុល្យការ
- អនុបាតហិរញ្ញវត្ថុ
- ជំពូកផ្សេងៗ (ភាគលាភ ការគ្រប់គ្រងដើមទុន)

៧. ការវិភាគលទ្ធផល (សូចនាករសំខាន់ៗ)

- ការវិភាគលម្អិតជំពូកនីមួយៗនៃប្រតិបត្តិការសំខាន់ៗ

៨. គោលដៅប្រតិបត្តិការអាជីវកម្ម

- ទស្សនវិស័យហិរញ្ញវត្ថុ
- ទស្សនវិស័យអតិថិជន
- ទស្សនវិស័យនៃដំណើរការត្រួតពិនិត្យផ្ទៃក្នុង
- ការអភិវឌ្ឍធនធានមនុស្ស
- ផែនការអាជីវកម្មសំខាន់ៗសម្រាប់ឆ្នាំក្រោយ

៩. គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

- ហានិភ័យប្រតិបត្តិការ
- ហានិភ័យឥណទាន
  - ✓ ឥណទានមិនដំណើរការ
  - ✓ បំណុលកែលម្អឡើងវិញ
  - ✓ ហានិភ័យពីការប្រមូលផ្តុំឥណទាន (ហានិភ័យឥណទានធំៗ)
  - ✓ ហានិភ័យពីការថយចុះតម្លៃនៃវត្ថុបញ្ចាំ
- ហានិភ័យទីផ្សារ
  - ✓ ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេស

- ✓ ហានិភ័យអត្រាការប្រាក់
- ✓ ហានិភ័យសាច់ប្រាក់ងាយស្រួល

១០. ការអះអាងរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ

១១. របាយការណ៍របស់ស្នងការគណនីឯករាជ្យ

១២. ព័ត៌មានស្តីពីការកាន់កាប់សន្លឹកហ៊ុន (បរិមាណ)

១៣. របាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សម្គាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

១៤. ភាគីតំណាងរបស់ធនាគារ (សាខាតំណាងនិងភាគីតំណាងអន្តរជាតិ)

- សាខាតំណាងនិងភាគីតំណាងអន្តរជាតិ

១៥. ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងឆ្នាំ

១៦. របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេលបីឆ្នាំ

- ការពិនិត្យមើលជារួម

ធ៧-០៦-២១១ ប្រ.ក

ប្រកាស
ស្តីពី
កាលបរិច្ឆេទផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស

ប្រការ ១.-

ធនាគារពាណិជ្ជនិងធនាគារឯកទេសត្រូវផ្ញើរាល់របាយការណ៍ប្រចាំគ្រា មកធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទ ដូចបានកំណត់ខាងក្រោម៖

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមករៀងរាល់ពេលព្រឹក នៅថ្ងៃធ្វើការបន្ទាប់
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវផ្ញើមករៀងរាល់ថ្ងៃអង្គារ នៃសប្តាហ៍បន្ទាប់
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់
- របាយការណ៍ប្រចាំឆ្នាំ (របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យដោយស្នងការគណនីឯករាជ្យ) ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់
- របាយការណ៍ប្រាក់បម្រុងកាតព្វកិច្ចត្រូវផ្ញើមកតាមកាលបរិច្ឆេទនៃប្រតិទិន ដែលធនាគារជាតិនៃកម្ពុជាបានកំណត់និងចែកជូនតាមឆ្នាំនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវផ្សព្វផ្សាយជាសាធារណៈត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំបន្ទាប់។

ប្រការ ២.-

ធនាគារពាណិជ្ជនិងធនាគារឯកទេសត្រូវឆ្លើយតបរាល់លិខិតបទដ្ឋាន តាមកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាកំណត់ឱ្យឆ្លើយនិងអនុវត្ត។

ប្រការ ៣.-

ធនាគារពាណិជ្ជ និងធនាគារឯកទេសត្រូវបានអនុញ្ញាតឱ្យរាយការណ៍នៅថ្ងៃធ្វើការបន្ទាប់ក្នុងករណីកាលបរិច្ឆេទដែលបានកំណត់ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើត្រូវចំថ្ងៃឈប់សម្រាកឬថ្ងៃបុណ្យជាតិ។

ប្រការ ៤.-

ធនាគារពាណិជ្ជនិងធនាគារឯកទេស ដែលមិនបានអនុវត្តតាមប្រការ ១ និងប្រការ ២ ខាងលើត្រូវរងការពិន័យតាមការកំណត់ ដូចខាងក្រោម៖

ក- ចំពោះរបាយការណ៍៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់និងរូបភាពពិន័យ
▪ ចាប់ពី ១ ដល់ ៥ថ្ងៃ	១.០០០.០០០ រៀល ក្នុង១ថ្ងៃ
▪ ចាប់ពី ៦ ដល់ ១០ថ្ងៃ	៧.៥០០.០០០ រៀល ក្នុង១ថ្ងៃ
▪ ចាប់ពី ១១ ដល់ ១៥ថ្ងៃ	១៥.០០០.០០០ រៀល ក្នុង១ថ្ងៃ

ចាប់ពី១៦ថ្ងៃឡើងទៅ ធនាគារពាណិជ្ជ និងធនាគារឯកទេសត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ។

ខ- ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់និងរូបភាពពិន័យ
▪ ចាប់ពី ១ ដល់ ៥ថ្ងៃ	៥០០.០០០ រៀល ក្នុង១ថ្ងៃ
▪ ចាប់ពី ៦ ដល់ ១០ថ្ងៃ	១.០០០.០០០ រៀល ក្នុង១ថ្ងៃ

ចាប់ពី១១ថ្ងៃឡើងទៅ ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ។

ប្រការ ៥.-

បទបញ្ជាលេខ ធ៧-៩៥-០២ បបជ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី ការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជនិងសារាចរណែនាំលេខ ធ៧-៩៥-០២ សរណន ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី កាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជមកធនាគារជាតិនៃកម្ពុជាត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១២-០០៤ ស.ក.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២

សេចក្តីណែនាំ
ស្តីពី
កាលបរិច្ឆេទ និងរយៈពេល សម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានធនាគារ

យោងតាមខ្លឹមសារនៃប្រកាសលេខ ធ៧-០៦-២១១ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍របស់គ្រឹះស្ថានធនាគារពាណិជ្ជ និងធនាគារឯកទេស ដើម្បីឱ្យមានការឯកភាពគ្នា និងមានមូលដ្ឋានច្បាស់លាស់ក្នុងការកំណត់កាលបរិច្ឆេទ និងរយៈពេលនៃការបញ្ជូនរបាយការណ៍តាមរយៈ Online ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារទាំងអស់ត្រូវបញ្ជូនរបាយការណ៍ប្រចាំគ្រា មានដូចខាងក្រោមនេះ៖

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមកជារៀងរាល់ព្រឹកនៃថ្ងៃធ្វើការបន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ១១ ព្រឹក
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវផ្ញើមកជារៀងរាល់ថ្ងៃអង្គារ៍នៃសប្តាហ៍បន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ១១ ព្រឹក
- របាយការណ៍ប្រចាំពីរសប្តាហ៍សម្រាប់ថ្ងៃទី១ ដល់ថ្ងៃទី១៥ ត្រូវផ្ញើមកនៅថ្ងៃទី១៦ ដល់ថ្ងៃទី១៧ នៅក្នុងខែ និងរបាយការណ៍សម្រាប់ថ្ងៃទី១៦ ដល់ថ្ងៃទី៣០ ឬ៣១ ត្រូវផ្ញើមកនៅថ្ងៃទី១ ដល់ ថ្ងៃទី២ នៃខែបន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៥ រសៀលនៃថ្ងៃធ្វើការបន្ទាប់
- របាយការណ៍ទុនបម្រុងកាតព្វកិច្ច ត្រូវផ្ញើមកតាមកាលបរិច្ឆេទនៃប្រតិទិនដែលធនាគារជាតិនៃកម្ពុជាបានកំណត់និងចែកជូនតាមឆ្នាំនីមួយៗ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៥ រសៀល
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៥ រសៀលនៃថ្ងៃធ្វើការ
- របាយការណ៍ត្រីមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៥ រសៀល
- របាយការណ៍ប្រចាំឆ្នាំ ផែនការអាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលផ្សព្វផ្សាយជាសាធារណៈ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៥ រសៀល។

ករណីមិនគោរពតាមសេចក្តីណែនាំខាងលើ គ្រឹះស្ថានធនាគារ នឹងទទួលរងការដាកពិន័យជាធរមាន ដូចមានចែងនៅក្នុងខ្លឹមសារនៃប្រកាសលេខ ធ៧-០៦-២១១ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ជ. អគ្គនាយករង្គតពិនិត្យ
ហត្ថលេខានិងត្រា៖ **ជា សិរី**

ធ៦-០២១-១៨៤ ប្រ.ក

ប្រកាស
ស្តីពី
ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ

ប្រការ ១.-

កំណត់នីតិវិធីសម្រាប់ការអនុវត្តប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System - ITRS) សម្រាប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រតិស្រុតិ ដែលតទៅនេះហៅកាត់ថា "គ្រឹះស្ថានហិរញ្ញវត្ថុ"។

នីតិវិធីនិងបែបបទបំពេញរបាយការណ៍មានរៀបរាប់ក្នុងសៀវភៅ "វិធីសាស្ត្រណែនាំអំពីការធ្វើចំណាត់ថ្នាក់ និងនីតិវិធីចងក្រងប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (Internatioanl Transactions Reporting System: Classification & Procedures Manual)"។

ប្រការ ២.-

គោលបំណងនៃការអនុវត្តប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) គឺដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការអន្តរជាតិ ដែលធ្វើឡើងតាមរយៈគណនីរបស់អតិថិជននៅធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុ សម្រាប់តម្លើងស្ថិតិវិស័យក្រៅប្រទេស និងប្រើជាធាតុចូលក្នុងការវិភាគ និងរៀបចំគោលនយោបាយយុទ្ធសាស្ត្រនានាលើវិស័យសេដ្ឋកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា។

ប្រការ ៣.-

នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវរាយការណ៍រាល់ប្រតិបត្តិការអន្តរជាតិទាំងអស់ ដោយពុំមានកំណត់ទឹកប្រាក់នៃប្រតិបត្តិការឡើយ។

ប្រការ ៤.-

នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្ញើរបាយការណ៍ប្រចាំខែឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាមកនាយកដ្ឋានស្ថិតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។

ក្នុងករណីនាយកដ្ឋានស្ថិតិមានការសង្ស័យលើប្រតិបត្តិការអន្តរជាតិណាមួយ នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវចូលរួមសហការផ្តល់នូវឯកសារទាំងឡាយណាដែលពាក់ព័ន្ធមកកាន់នាយកដ្ឋានស្ថិតិ។

ប្រការ ៥.-

ក្នុងករណីខកខានមិនបានផ្ញើរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) គ្រឹះស្ថានហិរញ្ញវត្ថុនឹងត្រូវទទួលនូវការពិន័យពីធនាគារជាតិនៃកម្ពុជា ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

នាយកដ្ឋានស្ថិតិត្រូវធានារក្សាការសម្ងាត់ចំពោះព័ត៌មានដែលទទួលបានពីនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុ។ នាយកដ្ឋានស្ថិតិប្រើប្រាស់ព័ត៌មានទាំងនេះ សម្រាប់តែការតម្លើងស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាប្រចាំគ្រា និងចេញផ្សាយក្នុងរូបភាពជារបាយការណ៍ និងស្ថិតិសរុបរួមប៉ុណ្ណោះ។

ប្រការ ៧.-

រាល់ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជាត្រូវបានប្រើប្រាស់សម្រាប់តែក្នុងការតម្លើងស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាប៉ុណ្ណោះ ហើយគឺជាកម្មសិទ្ធផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជាដែលមិនអាចត្រូវថតចម្លង ឬបញ្ជូនដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជាបានឡើយ។

ប្រការ ៨.-

ប្រកាសលេខ ធ៦-០៣-០១២ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣ ស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

គ.៣. បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ធ៧-០១-១៨៧ ប្រ.ក

ប្រកាស
ស្តីពី
ការផ្ទេរភាគហ៊ុនរបស់ធនាគារ

ប្រការ ១.-

ការផ្ទេរភាគហ៊ុនរបស់ធនាគារ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

ប្រការ ២.-

ធនាគារត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុនដែលអាចឱ្យភាគទុនិក ឬក្រុមភាគទុនិកណាមួយទទួលបាន ឬបាត់បង់ទៅវិញនូវចំនួនមួយភាគពីរ មួយភាគបី មួយភាគប្រាំ មួយភាគដប់ នៃសិទ្ធិបោះឆ្នោតរបស់គេនៅក្នុងធនាគារ។

ប្រការ ៣.-

ធនាគារត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុនដែលនាំឱ្យមានការផ្លាស់ប្តូរអំណាចក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងរបស់ធនាគារ។

ប្រការ ៤.-

ធនាគារត្រូវធ្វើប្រតិវេទន៍ជាមុនមកធនាគារជាតិនៃកម្ពុជាចំពោះរាល់ការផ្ទេរភាគហ៊ុនដែលនាំឱ្យមានកំណើន ឬការថយចុះភាគហ៊ុន ស្មើ ឬលើសពីប្រាំភាគរយ និងទាបជាងដប់ភាគរយនៃសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយភាគទុនិកណាម្នាក់របស់ធនាគារ។

ប្រការ ៥.-

ធនាគារត្រូវបំពេញឱ្យបានតាមរាល់ការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជាចំពោះព័ត៌មានជាក់លាក់ស្តីពីភាគទុនិកដែលមានបច្ចុប្បន្ននិងទៅអនាគត។

ប្រការ ៦.-

ការខកខានមិនបានធ្វើប្រតិវេទន៍ ឬមិនបានស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាតាមបញ្ញត្តិនៃប្រកាសនេះនឹងបណ្តាលឱ្យមានការដកហូតភាគហ៊ុនតាមសិទ្ធិបោះឆ្នោតដែលបានផ្ទេរនៅក្នុងការប្រជុំមហាសន្និបាត។

ប្រការ ៧.-

សាខារបស់ធនាគារបរទេសដែលបានទទួលអាជ្ញាបណ្ណនៅក្នុងប្រទេសកម្ពុជា ត្រូវជូនព័ត៌មានជាប្រចាំមកធនាគារជាតិនៃកម្ពុជា នូវរាល់ការផ្លាស់ប្តូរមានចំនួនច្រើននៃសមាសភាគរបស់ភាគទុនិកនៃក្រុមហ៊ុនមេរបស់ពួកគេ។ ការផ្លាស់ប្តូរត្រូវបានចាត់ទុកថាមានចំនួនច្រើននៅពេលដែលសាខារបស់ធនាគារបរទេសស្នើសុំការអនុញ្ញាតពីអាជ្ញាធរអាណាព្យាបាលរបស់ប្រទេសដើម។

ប្រការ ៨.-

រាល់ការផ្ទេរភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជីក្នុងស្រុកត្រូវបង់សោហ៊ុយចំនួនសូន្យ កណ្តាក់សញ្ញាប្រាំភាគរយ (0,៥%) នៃតម្លៃចារិកភាគហ៊ុនដែលបានផ្ទេរ។ សោហ៊ុយនេះត្រូវបង់ជូនធនាគារជាតិនៃកម្ពុជា មិនយឺតជាងថ្ងៃដែលបានផ្ទេរទេ។

ប្រការ ៩.-

ការខកខានមិនបានអនុវត្តតាមបញ្ញត្តិណាមួយដែលមាននៅក្នុងប្រកាសនេះ ត្រូវទទួលរងនូវការពិន័យនិងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ១០.-

ការធ្វើប្រតិវេទន៍ ឬសំណើសុំការអនុញ្ញាត ត្រូវអនុវត្តតាមគំរូមួយនៅក្នុងសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ១១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០១-២០១ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់អត្រាការប្រាក់ជាគោលសម្រាប់បុនហិរញ្ញប្បទាន

ប្រការ ១.-

កំណត់អត្រាការប្រាក់ជាគោល ០,៥០% ក្នុងមួយខែ ឬ ៦% ក្នុងមួយឆ្នាំ សម្រាប់អនុវត្តចំពោះការផ្តល់បុនហិរញ្ញប្បទាន ជាប្រាក់រៀលដល់ធនាគារពាណិជ្ជ ដើម្បីឱ្យធនាគារពាណិជ្ជទាំងឡាយអនុវត្តបានល្អនូវការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់របស់ខ្លួន។

ប្រការ ២.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៤.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ នេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៣-០០២ ស.រ.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣

សារាចរណែនាំ
ស្តីពី
ការផ្តល់និងការថតចម្លងឯកសារនៅពេលត្រួតពិនិត្យដល់ទីកន្លែង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ជាពិសេសត្រង់មាត្រាទី ៧, ១៦, ៣០, ៣៩ និង ៦៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេស ត្រង់មាត្រាទី ៤០ និង ៤៧

១- ធនាគារត្រូវផ្តល់រាល់ព័ត៌មាននិងទិន្នន័យទាំងអស់តាមសំណើ ដល់អ្នកត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ក្នុងពេលត្រួតពិនិត្យដល់ទីកន្លែង។

២- កាតព្វកិច្ចនៃការសម្ងាត់វិជ្ជាជីវៈមិនអាចយកមកប្រើជាមូលដ្ឋាន សម្រាប់ការមិនបង្ហាញព័ត៌មានដល់អ្នកត្រួតពិនិត្យឡើយ។ ជាងនេះទៀត អ្នកត្រួតពិនិត្យដែលជាបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ត្រូវមានកាតព្វកិច្ចក្នុងការរក្សាការសង្ងាត់វិជ្ជាជីវៈ និងមិនអាចផ្តល់ព័ត៌មានសម្ងាត់ទាំងឡាយដែលទទួលបានពីធនាគារពាណិជ្ជទៅបុគ្គលណាមួយឡើយ។

៣- ហេតុនេះ ធនាគារពាណិជ្ជទាំងអស់មិនអាចបដិសេធមិនផ្តល់ឯកសារ ឬព័ត៌មានតាមសំណើរបស់អ្នកត្រួតពិនិត្យឡើយ។

៤- ជាពិសេស ធនាគារត្រូវផ្តល់អ្នកត្រួតពិនិត្យនូវរាល់ព័ត៌មានគណនេយ្យ រាល់ឯកសារឥណទាននិងរាល់ព័ត៌មានទាំងអស់សម្រាប់ការវាយតម្លៃហានិភ័យ ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពចំណេញរបស់ធនាគារយ៉ាងត្រឹមត្រូវ។ ជាក់ស្តែង ព័ត៌មានទាំងនេះមិនត្រូវឱ្យមានខ្វះទេ។

៥- អ្នកត្រួតពិនិត្យអាចស្នើសុំថតចម្លងឯកសារ ឬព័ត៌មានទទួលបានពីធនាគារដែលត្រូវត្រួតពិនិត្យសម្រាប់ទុកជាឯកសារ។ អ្នកត្រួតពិនិត្យទទួលបានការអនុញ្ញាតឱ្យថតចម្លងឯកសារ ឬពីកុំព្យូទ័រ។

៦- រាល់ចំណាយដែលទាក់ទងនឹងការថតចម្លងព័ត៌មាន ឬឯកសារណាមួយជាចំណាយរបស់ធនាគារដែលត្រូវត្រួតពិនិត្យ។

៧- រាល់ការជំទាស់មិនផ្តល់ព័ត៌មាន ឬការថតចម្លងឯកសារណាមួយនឹងត្រូវរងការដាក់ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ៦៩ នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា។

៨- សារាចរនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អគ្គនាយក

ហត្ថលេខានិងត្រា៖ **តាល់ ណៃអ៊ីម**

ធ៧-០៤-០៣៧ ប្រ.ក

ប្រកាស
ស្តីពី
ការទូទាត់សងជាមុនទូទាប្រាក់ថ្លៃជួលនិងភតិសន្យា

ប្រការ ១.-

ធនាគារត្រូវបានអនុញ្ញាតឱ្យទូទាត់សងប្រាក់ថ្លៃជួល ឬភតិសន្យាលើទ្រព្យសម្បត្តិដោយត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោម។

ប្រការ ២.-

ទ្រព្យសម្បត្តិដែលបានជួលឬភតិសន្យាត្រូវបម្រើឱ្យប្រតិបត្តិការផ្ទាល់របស់ធនាគារ។ ធនាគារមិនត្រូវបានអនុញ្ញាតឱ្យជួល ប្រសិនបើទ្រព្យសម្បត្តិនោះមិនត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពចាំបាច់របស់ធនាគារទេ។

ប្រការ ៣.-

យោងតាមគោលការណ៍នៃខ្លឹមសារមានទម្ងន់លើទម្រង់ ការជួលឬភតិសន្យាដែលបានទូទាត់មុនមិនអាចត្រូវបានប្រើសម្រាប់ដកប្រាក់ពីធនាគារទេហើយជាពិសេសមិនអាចត្រូវបានប្រើសម្រាប់ដកដើមទុនផ្ទាល់របស់ភាគទុនិកឡើយ។

ប្រការ ៤.-

ការជួលឬភតិសន្យាដែលបានទូទាត់មុនមិនត្រូវឱ្យលើសពីរយៈពេលមួយឆ្នាំនៃថ្លៃជួលទ្រព្យសម្បត្តិឡើយ។

ប្រការ ៥.-

ប្រសិនបើធនាគារត្រូវតម្កល់ប្រាក់ធានា ឬត្រូវផ្តល់ឥណទានក្នុងចំនួនណាមួយឱ្យម្ចាស់ទ្រព្យសម្បត្តិនោះគឺជាចំនួនប្រាក់ដែលបានទូទាត់រួចកត់ត្រានៅក្នុងតារាងតុល្យការ ហើយចំនួនប្រាក់នោះមិនត្រូវលើសពីមួយឆ្នាំនៃថ្លៃជួលទ្រព្យសម្បត្តិទេ។

ប្រការ ៦.-

ចំនួនប្រាក់ដែលបានទូទាត់រួចទាំងអស់ លើសពីប្រាក់ថ្លៃជួលទ្រព្យសម្បត្តិមួយឆ្នាំនឹងត្រូវកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ប្រការ ៧.-

ក្នុងករណីប្រាក់ថ្លៃជួលដែលបានទូទាត់ជាមុនលើការជួល ឬភតិសន្យាមានរយៈពេលតិចជាងមួយឆ្នាំ ក៏ប៉ុន្តែមានតម្លៃខ្ពស់ជាងថ្លៃទីផ្សារ គំលាតរវាងប្រាក់ថ្លៃជួលដែលបានទូទាត់មុនលើការជួលឬភតិសន្យាជាមួយថ្លៃទីផ្សារនឹងត្រូវបានដកចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ប្រការ ៨.-

ការជួលឬភតិសន្យាជាមួយសម្ព័ន្ធញាតិត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសស្តីពីការផ្តល់ឥណទានទៅឱ្យសម្ព័ន្ធញាតិ។ ថ្លៃជួលទ្រព្យសម្បត្តិ ដែលបានទូទាត់ឱ្យសម្ព័ន្ធញាតិដែលនៅសល់ និងប្រាក់ជួល ឬភតិសន្យាដែលទូទាត់មុននឹងត្រូវបានបញ្ចូលទៅក្នុងប្រតិវេទន៍ប្រចាំត្រីមាស ស្តីពីឥណទានដែលបានផ្តល់ឱ្យសម្ព័ន្ធញាតិ។

ប្រការ ៩.-

ធនាគារដែលមានប្រាក់ថ្លៃជួលឬភតិសន្យាដែលបានទូទាត់មុនលើសពីមួយឆ្នាំ នឹងត្រូវបានទុកពេលឱ្យអនុវត្តតាមប្រកាសនេះក្នុងរយៈពេលប្រាំមួយខែ។ ផុតរយៈពេលនេះប្រាក់ថ្លៃជួល ឬភតិសន្យាដែលបានទូទាត់មុនលើសពីមួយឆ្នាំ នឹងត្រូវបានកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ប្រការ ១០.-

ទោះបីជាមានប្រការទី ៦ និងប្រការទី ៨ ក៏ដោយ ធនាគារដែលមិនអនុវត្តបានតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវទទួលរងការដាកពិន័យតាមមាត្រាទី៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ១១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៤-០០៦ ប្រ.ក

ប្រកាស
ស្តីពី
ការទូទាត់ភាគលាភជាមុន

ប្រការ ១.-

ធនាគារពាណិជ្ជ និងធនាគារឯកទេសត្រូវបានអនុញ្ញាតឱ្យទូទាត់ភាគលាភបាន លុះត្រាតែប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាក់លាក់។

ប្រការ ២.-

ប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់ជាក់លាក់ នៅពេលដែលស្នងការគណនីឯករាជ្យបានអនុម័តបញ្ជីគណនេយ្យប្រចាំឆ្នាំ។

ធនាគារមិនអាចទូទាត់ភាគលាភនៅមុនពេលអនុម័តនេះទេ។

ប្រការ ៣.-

ប្រសិនបើភាគលាភត្រូវបានទូទាត់ជាមុន ធនាគារជាតិនៃកម្ពុជាអាចបង្ខំឱ្យភាគទុនិកសងភាគលាភដែលបានទូទាត់ជាមុនមកវិញយ៉ាងឆាប់ ដោយបូកបន្ថែមជាមួយការប្រាក់ដែលបានគណនាដូចឥណទានលើសសមតុល្យចំពោះឯកត្តជន។

ប្រការ ៤.-

ថ្វីបើមានប្រការ ៣ ក៏ដោយ ការខកខានមិនបានគោរពតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្ម ស្របតាមមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឃ. បទប្បញ្ញត្តិអនុវត្តចំពោះ
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឃ.១. បទប្បញ្ញត្តិប្រឌប្រយ័ត្ន

ធ៧-០១-១១៥ ប្រ.ក

ប្រកាស
ស្តីពី
ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជី និងបានទទួលអាជ្ញាបណ្ណ ពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគមចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួនឱ្យបានស្របតាមខ្លឹមសារនៃប្រកាសនេះ។

ប្រការ ២.-

ការប្រាក់ចំពោះឥណទានដែលបានផ្តល់ឱ្យតាមខ្លឹមសារនៃប្រកាសនេះ ត្រូវគណនាដោយផ្អែកលើមូលដ្ឋាន នៃចំនួនប្រាក់ឥណទានដែលបានផ្តល់ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយបានន័យថា ការប្រាក់លើឥណទានសម្រាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ។

ប្រការ ៣.-

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជនត្រូវមានបង្ហាញតារាងពីការសងរំលស់ឥណទាន។

ប្រការ ៤.-

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៥.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថាន ធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២-៤៥ ប្រ.ក

ប្រកាស
ស្តីពី
ការរក្សាប្រាក់បម្រុងកាតព្វកិច្ចចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន ៥ ភាគរយ (៥%) នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

ប្រការ ២.-

ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់បញ្ញើដែលមាននៅក្នុងតារាងតុល្យការរបស់គ្រឹះស្ថាន និងក្នុងរបាយការណ៍បែងចែកប្រភេទប្រាក់បញ្ញើដែលគ្រឹះស្ថានប្រមូលបាននៅចុងខែនីមួយៗ។ ការគណនាប្រាក់បម្រុងកាតព្វកិច្ចត្រូវដកចេញប្រាក់សន្សំកាតព្វកិច្ចដែលជាលក្ខខណ្ឌក្នុងការផ្តល់ឥណទាន។

ប្រការ ៣.-

ប្រាក់បម្រុងកាតព្វកិច្ចដូចក្នុងប្រការ ២ ដែលបានគណនានៅខែណាមួយ ត្រូវរក្សាទុកក្នុងគណនីរបស់គ្រឹះស្ថាននៅធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី១៥ នៃខែបន្ទាប់រហូតដល់ថ្ងៃទី១៤ នៃខែបន្ទាប់ទៀតហើយការគណនានិងរក្សាទុកប្រាក់បម្រុងកាតព្វកិច្ចត្រូវអនុវត្តដូចគ្នានេះជាបន្តបន្ទាប់តាមគ្រានីមួយៗ។

ប្រការ ៤.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានឱនភាពប្រាក់បម្រុងកាតព្វកិច្ចត្រូវបំពេញជាបន្ទាន់នៅពេលណាដែលគ្រឹះស្ថានទាំងនេះទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២-៥៨ ប្រ.ក

ប្រកាស
ស្តីពី
អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ត្រូវរក្សាសាច់ប្រាក់ងាយស្រួលឱ្យបានគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ យ៉ាងហោចណាស់ស្មើនឹងមួយរយភាគរយ (១០០%)។

ប្រការ ២.-

អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចខាងក្រោម៖

- ភាគយក ៖ សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ឥណទានដែលឥណប្រតិទានៅសល់តិចជាងមួយខែ។
- ភាគបែង ៖ ម្ភៃប្រាំភាគរយ (២៥%) នៃប្រាក់សន្សំដោយស្ម័គ្រចិត្តមិនរួមបញ្ចូលប្រាក់សន្សំកាតព្វកិច្ច។

ប្រការ ៣.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្តល់ឯកសារពីការគណនាអនុបាតសាច់ប្រាក់ងាយស្រួលប្រចាំខែរបស់ខ្លួនតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៥.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៧-១៣២ ប្រ.ក

ប្រកាស
ស្តីពី
ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគណនាដូចតទៅ ៖

I- **សរុប A ៖** ខ្នង់ត្រូវបូក

- ដើមទុន ឬទាយជ្ជទានដើមទុន
- ទុនបម្រុងក្រៅពីទុនបម្រុងពីការវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ចំណេញរក្សាទុកសម្រាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយសម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ[1]
- ខ្នង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា[2]។

II- **សរុប B ៖** ខ្នង់ត្រូវដក

- ចំពោះភាគទុនិក៖ នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាន ឥណទាន មូលបត្រ និងកិច្ចសន្យារបស់ជនពាក់ព័ន្ធខាងលើ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់តាមតម្លៃចុះបញ្ជី
- ការខាតបង្គរ

---

[1] ក្រោយពីដកភាគលាភដែលត្រូវបែងចែក

[2] ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំក្នុងលក្ខខណ្ឌដែល៖

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណាដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ ព្រមទាំងសំវិធានធន និងតម្លៃគណនីកែតម្រូវ
- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវបានផ្ទៀងផ្ទាត់ដោយស្នងការគណនី

- ចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ (រួមបញ្ចូលទាំងសំវិធានធនសម្រាប់បំណុលនិងមូលបត្រសង្ស័យ)។

III- **សរុប C ៖ មូលនិធិផ្នាល់សុទ្ធមូលដ្ឋាន** = A - B

IV - **សរុប D ៖** ខ្នង់ត្រូវបូក

- ទុនបម្រុងពីការវាយតម្លៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- អនុបំណុល (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូល ១០០% នៃចំនួនមូលនិធិផ្នាល់សុទ្ធមូលដ្ឋាន
- ខ្នង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូលក្នុងការគណនាមូលនិធិផ្នាល់សុទ្ធមិនឱ្យលើសពីចំនួននៃមូលនិធិផ្នាល់សុទ្ធមូលដ្ឋាន[៣]។

V- **សរុប E ៖** ខ្នង់ត្រូវដក

- ភាគកម្មមូលនិធិផ្នាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា
- ខ្នង់ផ្សេងៗ[៤]។

VI- **សរុប F ៖** សរុបមូលនិធិផ្នាល់សុទ្ធ = C + D - E

ប្រការ ២.-

មូលនិធិផ្នាល់សុទ្ធដែលបានគណនាមកនេះ ត្រូវបានយកមកគិតគូរសម្រាប់ការគណនាអនុបាតប្រុងប្រយ័ត្ន និងអនុបាតផ្សេងទៀត។

ប្រការ ៣.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

---

[៣] ខ្នង់ផ្សេងៗអាចរួមមានខ្នង់ទាំងឡាយដូចខាងក្រោមនេះ៖

- មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ
- មូលនិធិសាធារណៈដែលបែងចែកសម្រាប់ធានាប្រភេទប្រតិបត្តិការឥណទាន
- ឧបត្ថម្ភធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ

[៤] ឧទាហរណ៍៖ ចំណាយដែលត្រូវបែងចែកសម្រាប់ច្រើនការិយបរិច្ឆេទ

ប្រការ ៤.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវ អនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

ឧេសានិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៧-១៣៣ ប្រ.ក

ប្រកាស
ស្តីពី
អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលតទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវពិនិត្យជាអចិន្ត្រៃយ៍នូវអនុបាតសាធនភាព របស់ខ្លួនឱ្យបានស្របតាមបញ្ញត្តិនៃប្រកាសនេះ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យទ្រព្យសកម្មសរុបដែលបានថ្លឹងមិនត្រូវតិចជាងដប់ប្រាំភាគរយ (១៥%) ឡើយ។

ប្រការ ២.-

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ប្រការ ៣.-

ក- ភាគបែងនៃអនុបាត គឺជាតម្លៃទ្រព្យសកម្មសរុប (តម្លៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធន និងការរំលស់តម្លៃ) និងខ្វង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកម្រិតហានិភ័យ។ ភាគបែងនេះ មិនរាប់បញ្ចូលនូវខ្វង់ដែលបានដកចេញនៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ខ- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម៖

ខ.១- ការថ្លឹងសូន្យភាគរយ (Zero Weighting) ចំពោះ៖

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលមានវត្ថុបញ្ចាំជាប្រាក់បញ្ញើនៅធនាគារ
- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ (Claim on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

ខ.២- ការថ្លឹង ២០% ចំពោះ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ ដោយធនាគារជាតិនៃកម្ពុជា។

ខ.៣- ការថ្លឹង ៥០% ចំពោះ៖

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ ដោយធនាគារជាតិនៃកម្ពុជា។
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយ ធនាគារជាតិនៃកម្ពុជា។

ខ.៤- ការថ្លឹង ១០០% ចំពោះ៖

- ទ្រព្យសកម្មដទៃទៀតទាំងអស់
- ខ្នង់ក្រៅតារាងតុល្យការទាំងអស់។

ប្រការ ៤.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៥.-

ប្រការ ១៥ នៃប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឃ.២. ទិដ្ឋានគណនេយ្យ និង វោយការណ៍

ធ៧-០២-៥៧ ប្រ.ក

ប្រកាស
ស្តីពី
តម្រូវការរបាយការណ៍សម្រាប់ប្រតិបត្តិករគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ

ប្រការ ១.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់ ស្តីអំពី លទ្ធផលហិរញ្ញវត្ថុ សំវៀតឥណទាន ប្រាក់បញ្ញើដែលប្រមូលបានព្រមទាំងបណ្តាញសាខា។

ប្រការ ២.-

រាល់ត្រីមាស ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា នៅក្នុងខែចុងក្រោយនៃត្រីមាសនីមួយៗនូវរបាយការណ៍ដូចខាងក្រោម ៖

- របាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណេញ-ខាត
- របាយការណ៍លម្អិតតាមប្រភេទប្រាក់បញ្ញើ
- របាយការណ៍លម្អិតប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍លម្អិតតាមប្រភេទឥណទាន
- របាយការណ៍លម្អិតឥណទានតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ស្តីពីចំណាត់ថ្នាក់ឥណទាន និងអនុបាតបំណុល
- របាយការណ៍ស្តីពីបណ្តាញសាខា

ប្រការ ៣.-

រៀងរាល់ខែ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា រួមទាំងការគោរពតាមបទប្បញ្ញត្តិក្នុងរយៈពេល ១៥ ថ្ងៃ នៃចុងខែនីមួយៗនូវរបាយការណ៍ដូចខាងក្រោម៖

- របាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណេញ-ខាត
- របាយការណ៍ក្រៅតារាងតុល្យការ
- របាយការណ៍លម្អិតតាមប្រភេទប្រាក់បញ្ញើ
- របាយការណ៍លម្អិតប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍លម្អិតតាមប្រភេទឥណទាន
- របាយការណ៍លម្អិតឥណទានតាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ស្តីពីចំណាត់ថ្នាក់ឥណទាន សំវិធានធន និងអនុបាតបំណុល

- តារាងឥណទានចំពោះសម្ព័ន្ធញាតិ
- តារាងហានិភ័យធំៗ
- ការគណនាអនុបាតគ្រប់គ្រាន់នៃដើមទុន
- ការគណនាអនុបាតសាច់ប្រាក់ងាយស្រួល។

ប្រការ ៤.-

នៅចុងត្រីមាសនីមួយៗគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ត្រូវធ្វើរបាយការណ៍ស្តីពីការវិវត្តន៍នៃបណ្តាញសាខារបស់ខ្លួន។

ប្រការ ៥.-

រៀងរាល់ឆ្នាំ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណត្រូវរៀបចំរបាយការណ៍ផ្ញើមកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី៣០ ខែមេសា នៃឆ្នាំបន្ទាប់ ដូចខាងក្រោម៖

- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈគ្រប់គ្រង
- ស្ថិតិបុគ្គលិក និងបៀវត្ស
- អង្គការលេខចុងក្រោយ ដោយមាននាម គោត្តនាម និងឋានៈរបស់និយោជិតកំពុងបម្រើការ។

ប្រការ ៦.-

របាយការណ៍ទាំងអស់ ត្រូវរៀបចំស្របតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៧.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឬគ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៨.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជានិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៦-២១២ ប្រ.ក

ប្រកាស
ស្តីពី
កាលបរិច្ឆេទផ្ញើរបាយការណ៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រការ ១.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្ញើរាល់របាយការណ៍ប្រចាំគ្រាមកធនាគារជាតិនៃកម្ពុជាតាមកាលបរិច្ឆេទដូចបានកំណត់ខាងក្រោម៖

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមករៀងរាល់ពេលព្រឹក នៅថ្ងៃធ្វើការបន្ទាប់
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវផ្ញើមករៀងរាល់ថ្ងៃអង្គារ នៃសប្តាហ៍បន្ទាប់
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់
- របាយការណ៍ប្រចាំឆ្នាំ (របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យដោយស្នងការគណនីឯករាជ្យ) ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមេសា នៃឆ្នាំបន្ទាប់
- របាយការណ៍ប្រាក់បម្រុងកាតព្វកិច្ច ត្រូវផ្ញើមកតាមកាលបរិច្ឆេទនៃប្រតិទិនដែលធនាគារជាតិនៃកម្ពុជា បានកំណត់និងចែកជូនតាមឆ្នាំនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំបន្ទាប់។

ប្រការ ២.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវឆ្លើយតបរាល់លិខិតបទដ្ឋានតាមកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជា កំណត់ឱ្យឆ្លើយនិងអនុវត្ត។

ប្រការ ៣.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យរាយការណ៍នៅថ្ងៃធ្វើការបន្ទាប់ក្នុងករណីកាលបរិច្ឆេទដែលបានកំណត់ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើត្រូវចំថ្ងៃឈប់សម្រាក ឬថ្ងៃបុណ្យជាតិ។

ប្រការ ៤.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនបានអនុវត្តតាមប្រការ ១ និងប្រការ ២ ខាងលើត្រូវរងពិន័យតាមការកំណត់ដូចខាងក្រោម៖

ក- ចំពោះរបាយការណ៍៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់និងរូបភាពពិន័យ
- ចាប់ពី ១ ដល់ ៥ ថ្ងៃ	៥០.០០០ រៀល ក្នុង ១ ថ្ងៃ
- ចាប់ពី ៦ ដល់ ១០ ថ្ងៃ	៣០០.០០០ រៀល ក្នុង ១ ថ្ងៃ
- ចាប់ពី ១១ ដល់ ១៥ ថ្ងៃ	៧០០.០០០ រៀល ក្នុង ១ ថ្ងៃ

ចាប់ពី ១៦ ថ្ងៃឡើងទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ។

ខ-ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេង៖

ចំនួនថ្ងៃដែលយឺតយ៉ាវ	ចំនួនទឹកប្រាក់និងរូបភាពពិន័យ
- ចាប់ពី ១ ដល់ ៥ ថ្ងៃ	៥០.០០០ រៀល ក្នុង ១ ថ្ងៃ
- ចាប់ពី ៦ ដល់ ១០ ថ្ងៃ	៣០០.០០០ រៀល ក្នុង ១ ថ្ងៃ

ចាប់ពី ១១ ថ្ងៃឡើងទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ។

ប្រការ ៥.-

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

១. បទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

១.១. បទប្បញ្ញត្តិប្រឌប្រយ័ត្ន

ធ៧-០២-២០៣ ប្រ.ក

ប្រកាស
ស្តីពី
នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់
ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

កំណត់នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថាគ្រឹះស្ថានហិរញ្ញវត្ថុ ដោយបង្កើតជាមុននូវបទដ្ឋានសម្រាប់ការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងដើម្បីអនុវត្តការត្រួតពិនិត្យប្រកបដោយការឯកភាព និងភាពត្រឹមត្រូវ។

ប្រការ ២.-

១. "សកម្មភាពកែតម្រូវបន្ទាន់" គឺជាទណ្ឌកម្មខាងវិន័យ និងការដាក់កំហិតជាផ្លូវការ សម្រាប់អនុវត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

២. "អនុបាតសាធនភាព" គឺជាអនុបាតដែលត្រូវបានគណនាតាមប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

៣. "ផែនការស្តារដើមទុន" គឺជាផែនការផ្លូវការចុះហត្ថលេខាដោយក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានហិរញ្ញវត្ថុ ហើយត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា។ ផែនការនេះត្រូវចែងលម្អិតពីសកម្មភាពយុទ្ធសាស្ត្រ និងការសន្យាដែលក្រុមប្រឹក្សាភិបាលត្រូវអនុវត្ត ដើម្បីសម្រេចឱ្យបានដើមទុនគ្រប់គ្រាន់តាមអនុបាតសាធនភាព។ ផែនការនេះត្រូវមានចែងផងដែរនូវគោលដៅហិរញ្ញវត្ថុជាតួលេខ និងកាលវិភាគដើម្បីសម្រេចឱ្យបាននូវគោលដៅនោះ។

៤. "អភិបាលបណ្តោះអាសន្ន" គឺជាបុគ្គលដែលបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ស្របតាមមាត្រា ៥៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងដឹកនាំ និងជាតំណាងឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ។ បុគ្គលដែលបានតែងតាំងមានកាតព្វកិច្ចត្រូវវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងគ្រប់គ្រងសកម្មភាពបច្ចុប្បន្ន ដើម្បីការពារឱ្យបាននូវសាធនភាពរបស់អង្គភាពចំណុះច្បាប់ និងរក្សាសិទ្ធិអ្នកផ្ញើប្រាក់ និងឥណទាយក។

៥. "ការប្រជុំអំពីដើមទុន" គឺជាការប្រជុំផ្លូវការរៀបចំដោយធនាគារជាតិនៃកម្ពុជា ដើម្បីជូនដំណឹងដល់នាយកនៃគ្រឹះស្ថានហិរញ្ញវត្ថុ អំពីកង្វះខាតដើមទុនធ្ងន់ធ្ងរនៅគ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន និងអំពីកាលវិភាគជាក់លាក់សម្រាប់បង្កើនដើមទុន។

ប្រការ ៣.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៥-២១២ ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពី វិសោធនកម្មលើប្រកាសស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។)

ប្រការ ៣ ថ្មី ចែងដូចខាងក្រោម៖

តាមនីតិវិធីសកម្មភាពកែតម្រូវបន្ទាន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបែងចែកជាប្រភេទដោយផ្អែកលើអនុបាតសាធនភាពរបស់ខ្លួនដូចបានកំណត់ក្នុងប្រកាសវិសោធនកម្មស្តីពីអនុបាតសាធនភាព។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ថា៖

ក. មានដើមទុនល្អប្រសើរ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ២០ ភាគរយ

ខ. មានដើមទុនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ១៥ ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ២០ ភាគរយ

គ. មានដើមទុនមិនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ១០ ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ១៥ ភាគរយ

ឃ. ខ្វះដើមទុនច្រើននៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ៥ ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ១០ ភាគរយ

ង. ខ្វះដើមទុនធ្ងន់ធ្ងរ នៅពេលអនុបាតសាធនភាពរបស់ខ្លួននៅក្រោម ៥ ភាគរយ។

ប្រការ ៤.-

នៅពេលចាប់ផ្តើមមានដើមទុនមិនគ្រប់គ្រាន់ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានកាតព្វកិច្ចរៀបចំ និងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជាឱ្យបានក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលដើមទុនមានមិនគ្រប់គ្រាន់។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងដល់គ្រឹះស្ថានហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ពីការយល់ព្រមទទួលយកបានផែនការស្តារដើមទុន ក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃទទួល ឬពីការយឺតយ៉ាវ និងមូលហេតុនៃការយឺតយ៉ាវ។

ប្រការ ៥.-

ផែនការស្តារដើមទុនដែលអាចទទួលយកបាន ត្រូវបង្ហាញឱ្យឃើញពីលទ្ធភាពអនុវត្តបានការស្តារដើមទុន និងត្រូវមាន៖

ក. តារាងតុល្យការនិងថវិកាបច្ចុប្បន្ន គម្រោងថវិការយៈកាលវែង ផែនការជាយុទ្ធសាស្ត្រការវិភាគស្ថានភាពទីផ្សារដោយផ្អែកលើការសន្មតប្រាកដនិយម និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

ខ. មធ្យោបាយសម្រាប់អនុវត្តការស្តារដើមទុន ត្រូវរៀបរាប់ផងដែរអំពី៖

- ជំហានដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវអនុវត្តសំដៅបង្កើនដើមទុនឱ្យបានគ្រប់គ្រាន់ឡើងវិញ

- កម្រិតនៃដើមទុនដែលត្រូវសម្រេចឱ្យបានរៀងរាល់ត្រីមាសនៃឆ្នាំផែនការនីមួយៗ
- ប្រភេទនិងកម្រិតនៃសកម្មភាពដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវប្រតិបត្តិ
- ព័ត៌មានដទៃទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

ក្រៅពីការរៀបចំនិងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជា ភាគទុនិកមានឥទ្ធិពលត្រូវធានាជាលាយលក្ខណ៍អក្សរថា គ្រឹះស្ថានហិរញ្ញវត្ថុនោះនឹងបំពេញកាតព្វកិច្ចក្នុងការអនុវត្តផែនការស្តារដើមទុន។ ការធានានេះត្រូវមានរៀបរាប់អំពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគទុនិកមានឥទ្ធិពលក្នុងការអនុវត្តផែនការស្តារដើមទុន។ ក្រៅពីនេះ ការធានាក៏ត្រូវមានការសន្យាថាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនឹង៖

ក. ចាត់វិធានការណ៍ដែលតម្រូវដោយផែនការស្តារដើមទុន

ខ. ធានាជ្រើសរើសអ្នកគ្រប់គ្រងថ្មីមានសមត្ថភាព

គ. រឹតត្បិតប្រតិបត្តិការរវាងគ្រឹះស្ថានហិរញ្ញវត្ថុជាមួយបុគ្គលដែលជាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនោះ

ឃ. បញ្ឈប់សកម្មភាពណាដែលមានហានិភ័យ ឬពុំមានលក្ខណៈសមស្រប។

អាស្រ័យទៅលើក្រុមហ៊ុនដែលពាក់ព័ន្ធ ការធានាត្រូវមានប័ណ្ណសងតាមបញ្ជា ការដាក់បញ្ចាំទ្រព្យសម្បត្តិ ការអះអាងដ៏សមស្របពីស្មាក្តីក្រុមហ៊ុន សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងសកម្មភាពត្រួតពិនិត្យ ផ្សេងទៀតដែលធានាការអនុវត្ត។

ប្រការ ៧.-

គ្រឹះស្ថានហិរញ្ញវត្ថុមានដើមទុនមិនគ្រប់គ្រាន់ដែលមិនបានដាក់ជូន ឬមិនបានអនុវត្តផែនការស្តារដើមទុនដែលអាចទទួលយកបាន និងគ្រឹះស្ថានហិរញ្ញវត្ថុដែលខ្វះដើមទុនច្រើន ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចខាងក្រោមនេះ៖

ក. ត្រូវមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា មុនពេលបើកប្រាក់រង្វាន់ ឬមុនពេលបង្កើនប្រាក់កម្រៃជូនដល់អ្នកគ្រប់គ្រងជាន់ខ្ពស់

ខ. ត្រូវបញ្ជាឱ្យបំពេញដើមទុនឡើងវិញ

គ. ត្រូវមានការដាក់កំហិតលើប្រតិបត្តិការជាមួយបុត្តសម្ព័ន្ធ

ឃ. ត្រូវមានការដាក់កំហិតលើអត្រាការប្រាក់ចំពោះប្រាក់បញ្ញើ។

វិធានការប្រកបដោយឆន្ទានុសិទ្ធិផ្សេងទៀត ក៏អាចសម្រេចដោយឯកច្ឆន្ទពីធនាគារជាតិនៃកម្ពុជា៖

ក. តម្រូវឱ្យរឹតត្បិតមិនឱ្យមានកំណើនទ្រព្យសកម្ម ឬតម្រូវឱ្យកាត់បន្ថយទ្រព្យសកម្មសរុប

ខ. តម្រូវឱ្យរឹតត្បិតសកម្មភាពអាជីវកម្ម

គ. តម្រូវឱ្យលាលែងពីតំណែងនាយកប្រតិបត្តិមួយ ឬច្រើន

ឃ. បញ្ឈោឱ្យជួលអ្នកគ្រប់គ្រងជាន់ខ្ពស់ថ្មីដែលមានគុណវុឌ្ឍិគ្រប់គ្រាន់

ង. បញ្ឈោឱ្យបញ្ឈប់ការទទួលប្រាក់បញ្ញើពីធនាគារទំនាក់ទំនង

ច. បញ្ឈោឱ្យដកខ្លួនចេញពីបុគ្គលសម្ព័ន្ធ ដែលបណ្តាលឱ្យមានហានិភ័យខ្ពស់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ

ឆ. តែងតាំងអភិបាលបណ្តោះអាសន្ន។

ប្រការ ៨.-

នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានដឹងថាខ្វះដើមទុនធ្ងន់ធ្ងរ ត្រូវកោះប្រជុំអំពីដើមទុន។

គ្រឹះស្ថានហិរញ្ញវត្ថុដែលខ្វះដើមទុនធ្ងន់ធ្ងរមិនអាចធ្វើសកម្មភាពដូចខាងក្រោមបានឡើយ៖

ក. លក់ទ្រព្យសកម្មយ៉ាងច្រើន ឬបដិសេធការធានារបស់អតិថិជន

ខ. ផ្តល់ឥណទានថ្មីចំពោះអតិថិជន

គ. កែប្រែវិធីគណនេយ្យ លើកលែងតែវិធីនេះមិនស្របតាមច្បាប់

ឃ. បើកប្រាក់កម្រៃ ឬ ប្រាក់រង្វាន់

ង. ផ្តល់ការប្រាក់លើទ្រព្យអកម្មខ្ពស់ជាងអត្រាទីផ្សារ។

អភិបាលបណ្តោះអាសន្នត្រូវបានតែងតាំងក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីបានជូនដំណឹងពីការប្រជុំអំពីដើមទុន។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៧-១៣៥ ប្រ.ក

ប្រកាស
ស្តីពី
ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណង ដើម្បីបង្ការហានិភ័យនៃការប្តូរប្រាក់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ប្រការ ២.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- "ហានិភ័យនៃការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ខាងហិរញ្ញវត្ថុដែលកើតឡើងពីចលនាឡើងចុះនៃអត្រាប្តូរប្រាក់។
- "ហានិភ័យនៃការទូទាត់ការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយទូទាត់សងនូវរូបិយវត្ថុដែលខ្លួនបានលក់តែអាចមិនទទួលមកវិញនូវរូបិយវត្ថុដែលខ្លួនបានទិញពីប្រតិបត្តិការប្តូរប្រាក់។
- "ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណណាមួយ" ជាសមតុល្យសុទ្ធនៃរាល់ទ្រព្យសកម្ម ទ្រព្យអកម្ម និងខ្ទង់ក្រៅតារាងតុល្យការនៃរូបិយប័ណ្ណនោះ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណយិកគឺជាស្ថានភាពវែង។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណទាយី គឺជាស្ថានភាពខ្លី។

ប្រការ ៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពមួយដើម្បីកំណត់ វាស់វែង តាមដាន និងត្រួតពិនិត្យនូវទំហំនិងប្រភពហានិភ័យនៃការប្តូរប្រាក់ និងហានិភ័យនៃការទូទាត់ការប្តូរប្រាក់ក្នុងអំឡុងពេលនៃថ្ងៃជួញដូរនិងនៅពេលបិទបញ្ជីប្រចាំថ្ងៃ។ លក្ខណៈនិងទំហំរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ ត្រូវស្របតាមទំហំនៃប្រតិបត្តិការប្តូរប្រាក់ និងស្ថានភាពប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាគ្រប់ពេល នូវស្ថានភាពចំហសុទ្ធជារូបិយប័ណ្ណណាមួយ ឬសរុបជារូបិយប័ណ្ណទាំងអស់ ទោះក្នុងស្ថានភាពវែង ឬខ្លីក៏ដោយមិនឱ្យលើសពី ២០ ភាគរយនៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះឡើយ។

ប្រការ ៥.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ប្រចាំខែ ទាំងហាដកូពី (Hard copy) និងសូហ្វកូពី (Soft copy) ស្តីពីស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណឱ្យបានទៀងទាត់តាមគំរូក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវធានាផងដែរថា ស្ថានភាពរូបិយប័ណ្ណត្រូវបានរាយការណ៍ត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជា។

(ឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវបានជំនួសដោយឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខ ធ៧-០២០-៨៦៨ ធ.ត ចុះថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ករណីលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធចំពោះរូបិយវត្ថុជាតិ។)

ប្រការ ៦.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

បទបញ្ជាលេខ ធ៧-៩៥-០១ បបជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ធនាគារពាណិជ្ជ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២០-៨៦៨ ឆ.ត

ថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

ជម្រាបមក
លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្មវត្ថុ ៖ ករណីលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធចំពោះរូបិយវត្ថុជាតិ។
យោង ៖ ប្រកាសលេខ ធ៧-០៧-១៣៥ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានជ្រាបថា ដើម្បីរួមចំណែកអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានសម្រេចលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធចំពោះរូបិយវត្ថុជាតិ។ កម្រិតកំណត់នេះត្រូវបានដកចេញពីឧបសម្ព័ន្ធស្តីពី ការគណនាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ ដូចមានចែងក្នុងប្រកាសលេខ ធ៧-០៧-១៣៥ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងត្រូវបានដាក់ជំនួសដោយឧបសម្ព័ន្ធថ្មី ដូចមានភ្ជាប់មកជាមួយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អាន អំពីខ្ញុំ។

ត.ប. ទេសាភិបាល
អគ្គនាយកត្រួតពិនិត្យ
ហត្ថលេខានិងត្រា៖ **រ័ត្ន សុវណ្ណនរៈ**

របាយការណ៍ប្រចាំខែស្តីពី ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ

MONTHLY REPORT ON NET OPEN POSITION

កាលបរិច្ឆេទ:

As of:

ឈ្មោះធនាគារ :

Name of Bank:

ទ ម្រ ង់ Form: P-NOP-M

មូលនិធិផ្ទាល់សុទ្ធ		អត្រាប្តូរប្រាក់ :	៤០០០ រៀល/ដុល្លារអាមេរិក (ឯកតាគិតជាលានរៀល)
Total Net worth (NW) :	2,000.00	Exchange Rate:	4000 KHR/USD (In Millions of KHR)

ល.រ No	រូបិយប័ណ្ណ Currency	ខ្វង់ផ្សេងៗបន្ទាប់ពីដកចេញសំវិធានធន Elements after deduction of affected provision				ស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណ Net open position វែង ឬ ខ្លី Long or short	រូបិយប័ណ្ណចំហសុទ្ធ / មូលនិធិផ្ទាល់សុទ្ធ (%) Net open position / Net worth (%)	កម្រិតកំណត់ (%) Limit (%)	ភាពលើស (១) Excess (1)
		ទ្រព្យសកម្ម Assets	ទ្រព្យអកម្ម និងមូលធន Liabilities & Capital	រូបិយប័ណ្ណត្រូវទទួល Currency receivables	រូបិយប័ណ្ណត្រូវចំណាយ Currency Payables				
				ខ្វង់ក្រៅតុល្យការ Off-balance sheet	ខ្វង់ក្រៅតុល្យការ Off-balance sheet				
		1	2	3	4	5 = 1 - 2 + 3 - 4			
1	KHR			0.00	0.00	0.00	0.00%	N/A	N/A
2	USD			0.00	0.00	0.00	0.00%	N/A	N/A
3	EUR			0.00	0.00	0.00	0.00%	20%	
4	SGD			0.00	0.00	0.00	0.00%	20%	
5	HKD			0.00	0.00	0.00	0.00%	20%	
6	THB			0.00	0.00	0.00	0.00%	20%	
7	JPY			0.00	0.00	0.00	0.00%	20%	
8	PHP			0.00	0.00	0.00	0.00%	20%	
9	AUD			0.00	0.00	0.00	0.00%	20%	
10	CAD			0.00	0.00	0.00	0.00%	20%	
11	GBP			0.00	0.00	0.00	0.00%	20%	
12	CNY			0.00	0.00	0.00	0.00%	20%	
13	KRW			0.00	0.00	0.00	0.00%	20%	
14	VND			0.00	0.00	0.00	0.00%	20%	
15	OTHERS			0.00	0.00	0.00	0.00%	20%	
សរុប (Total)		0.00	0.00	0.00	0.00	0.00			
		(២) (2)	(៣) (3)			(៤) (4)			

កំណត់សំគាល់ (Note):

(១) នៅពេលដែលមានភាពលើស ត្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវពន្យល់ជាលាយលក្ខណ៍អក្សរពីមូលហេតុនិងវិធានការកែតម្រូវ

(1) Where there is an excess, the bank shall submit a written explaination of the origin of each excess, and the measures taken to remedy the situation

(២) ចំនួនទ្រព្យសកម្មសរុបក្នុងតារាងតុល្យការ

(2) Total assets on the balance sheet

(៣) ចំនួនទ្រព្យអកម្មសរុប និងមូលធនក្នុងតារាងតុល្យការ

(3) Total liabilities and capital on the balance sheet

(៤) ចំនួនសរុប = សូន្យ

ថ្ងៃទី ខែ ឆ្នាំ ២០២០

Reporting date: day/month/year

នាយកធនាគារ	អ្នកពិនិត្យ	អ្នករៀបចំតារាង
CEO/Director	Verified by	Prepared by

Contact NBC IT departement for adding new Rows and Cells Tel: 023- 63 09 431 (Help Desk)

ធ៧-០១១-២៤៣ ប្រ.ក

ប្រកាស
ស្តីពី
តម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ។

ប្រការ ២.-

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឱ្យភាន់ច្រឡំ និងត្រូវធានាថាអតិថិជនបានទទួលព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ។

ប្រការ ៣.-

អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ នៅមុនពេល ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌ អត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៤.-

អតិថិជនត្រូវទទួលបានព័ត៌មានជាមុន អំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

ប្រការ ៥.-

ព័ត៌មានអតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់ ហើយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនអតិថិជននូវប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ការរក្សាព័ត៌មានអតិថិជនជាសម្ងាត់មិនត្រូវអនុវត្តចំពោះការផ្តល់ព័ត៌មានអតិថិជនដល់ប្រព័ន្ធព័ត៌មានឥណទាននោះទេ។

ប្រការ ៦.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

តារាងព័ត៌មានសម្រាប់អតិថិជន

តារាងនេះសម្រាប់ផ្តល់ព័តមានតែប៉ុណ្ណោះ។ តារាងនេះកំណត់ចេញនូវថ្លៃដើមពេលបច្ចុប្បន្ន និងកម្រៃផ្សេងៗសម្រាប់ឥណទានដែលទទួលបាន ហើយធនាគារអាចកែប្រែថ្លៃដើម និងកម្រៃទាំងនេះ ក្នុងករណីចាំបាច់។ សូមមេត្តាកត់សម្គាល់ថា ការផ្តល់នូវតារាងនេះមិនត្រូវចាត់ទុកថាជាការផ្តល់ឥណទានដល់អតិថិជនដោយធនាគារនោះទេ។

ឈ្មោះធនាគារ/និមិត្តសញ្ញា ឈ្មោះអ្នកសួរព័តមាន _____

១. សាខា _____ ប្រភេទនៃខ្ទង់ឥណទាន _____

ចំនួនឥណទាន និងការប្រាក់/កម្រៃផ្សេងៗរបស់ធនាគារ

(គិតជាប្រាក់រៀល)

២. ចំនួនស្នើសុំ (ចំនួនប្រាក់ដើម)	_____
៣. (ដក: ចំនួនត្រូវទូទាត់ក្នុងគ្រាទី១/ការប្រាក់បានបង់មុន)	_____
៤. ចំនួនសុទ្ធដែលអតិថិជនបានទទួល	_____
៥. អត្រាដែលស្នើសុំ	_____ % ក្នុង១ឆ្នាំ
៦. អត្រាការប្រាក់មានប្រសិទ្ធភាព	_____ % ក្នុង១ឆ្នាំ
៧. ការទូទាត់ប្រចាំខែ	_____
៨. ចំនួនដងដែលត្រូវទូទាត់សង	_____
៩. ការប្រាក់សរុប	_____
១០.កម្រៃធ្វើប្រតិបត្តិការ	_____
១១.កម្រៃផ្សេងៗរបស់ធនាគារ (សូមបញ្ជាក់ ប្រសិនបើមាន)	
_____	_____
១២. កម្រៃផ្សេងៗសរុប (ជួរទី១០ + ជួរទី១១)	_____
១៣. ការប្រាក់សរុបបូកកម្រៃផ្សេងៗសរុប (ជួរទី៩ + ជួរទី១២)	_____
១៤. សរុបចំនួននៅជំពាក់ (ជួរទី២ + (៣) ឬជួរទី៤ + ជួរទី១៣)	_____
១៥. កាលបរិច្ឆេទនៃការចាប់ផ្តើមទូទាត់សង	_____

<u>កម្រៃបន្ថែម</u>

ធនាគារនឹងគិតកម្រៃសម្រាប់

(ក) ការទូទាត់សងឥណទានមុនពេលកំណត់	ការទូទាត់សងដោយផ្នែក	ការទូទាត់សងពេញលេញ
១៦. ប្រសិនបើសងក្នុងអំឡុងពេល	_____ឆ្នាំ	_____ឆ្នាំ
១៧. ចំនួននៃការទូទាត់សងអប្បបរមាគឺ	_____	_____
១៨. កម្រៃលើការទូទាត់សងមុនពេលកំណត់	_____	_____
១៩. កម្រៃធ្វើប្រតិបត្តិការ	_____	_____
២០. អំឡុងពេលជូនដំណឹងដែលតម្រូវ	_____	_____

(ខ) ការទូទាត់យឺតយ៉ាវតាមគ្រានីមួយៗ

២១. ការប្រាក់ដែលត្រូវគិតគឺ	_____%ក្នុង១ឆ្នាំ (សម្រាប់ចំនួនដែលជំពាក់)
២២. កម្រៃធ្វើប្រតិបត្តិការ	_____
២៣. កម្រៃផ្សេងៗ	_____

<u>កម្រៃសម្រាប់តតិយជន</u>

២៤. ព័ត៌មានខាងលើ មិនរាប់បញ្ចូលកម្រៃសម្រាប់តតិយជន មានដូចជាតែមប្រ៊ី កម្រៃផ្នែកច្បាប់ កម្រៃលើការវាយតម្លៃ បុព្វលាភធានារ៉ាប់រង។ល។ សូមមេត្តាត្រួតពិនិត្យជាមួយគ្នាភាគីខាងលើស្តីពីកម្រៃទាំងឡាយ។

គោលនយោបាយធានារ៉ាប់រងដែលទាមទារឱ្យមាន

មន្ត្រីដែលមានវត្តមាន _____ ហត្ថលេខា _____

កាលបរិច្ឆេទ _____

ធ៧-០១២-១៨៤ ប្រ.ក

ប្រកាស
ស្តីពី
កម្រិតកំណត់នៃការកាន់កាប់ និងជួញដូរមូលបត្រ
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់កម្រិតកំណត់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការកាន់កាប់ និងជួញដូរមូលបត្រ ដែលបានចុះបញ្ជីក្នុងក្រុមហ៊ុនទីផ្សារមូលបត្រ។

ប្រការ ២.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចកាន់កាប់ និងជួញដូរមូលបត្របានក្រោមលក្ខខណ្ឌ និងវិធានការប្រុងប្រយ័ត្នដូចមានចែងក្នុងប្រកាសនេះ។

ប្រការ ៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តដូចខាងក្រោម៖

១. មុនពេលជួញដូរ ឬកាន់កាប់មូលបត្រ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវវិភាគឱ្យបានហ្មត់ចត់អំពីហានិភ័យ ប្រភពនិងស្ថិរភាពនៃមូលនិធិ ផលប៉ះពាល់ដែលបណ្តាលមកពីការជួញដូរមូលបត្រលើមូលនិធិផ្គាល់សុទ្ធនិងស្ថានភាពសន្ទនីយភាព ធនធានសម្រាប់គ្រប់គ្រងហានិភ័យ ព្រមទាំងប្រព័ន្ធព័ត៌មានវិទ្យា។ គ្រឹះស្ថានត្រូវកំណត់កម្រិតហានិភ័យដែលទទួលយក (Risk tolerance) ឬស្របតាមការកំណត់ផ្ទៃក្នុង ដើម្បីទប់ទល់នឹងស្ថានភាពមិនអំណោយផលរបស់ទីផ្សារ។

២. ផ្អែកលើការវាយតម្លៃខាងលើ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្រុមប្រឹក្សាភិបាល) ត្រូវពិចារណាលើហានិភ័យដែលពាក់ព័ន្ធ និងធ្វើសេចក្តីសម្រេចក្នុងការកាន់កាប់និងជួញដូរមូលបត្រ។

៣. ក្រុមប្រឹក្សាភិបាលត្រូវកំណត់ឱ្យច្បាស់លាស់នូវកម្រិតហានិភ័យដែលទទួលយកសម្រាប់សកម្មភាពជួញដូរ ជាពិសេសដាក់ចេញនូវកម្រិតកំណត់សមស្រប កាតព្វកិច្ចរាយការណ៍ជូនសមាជិកក្រុមប្រឹក្សាភិបាល កំណត់គណនេយ្យភាពនិងការទទួលខុសត្រូវរបស់គ្រឹះស្ថានស្របតាមការកំណត់ផ្ទៃក្នុង លក្ខខណ្ឌនានាដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងវិធានប្រុងប្រយ័ត្ន ដែលកំណត់ដោយប្រកាសនេះ។

៤. ចំពោះក្រុមសម្ព័ន្ធធនាគារ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចអំពី ក្របខ័ណ្ឌហានិភ័យរួម (Aggregated risk exposure) ធនធានសម្រាប់ការគ្រប់គ្រងហានិភ័យរួម ប្រព័ន្ធព័ត៌មានវិទ្យាកំណត់ហានិភ័យដែលទទួលយក និងកំណត់កម្រិតគួបសរុប ជាពិសេសត្រូវយកចិត្តទុកដាក់ដល់បញ្ហាសន្ទនីយភាព។

៥. សេចក្តីសម្រេច ការកំណត់ និងលក្ខខណ្ឌនានារបស់ក្រុមប្រឹក្សាភិបាលដែលទាក់ទងនឹងសកម្មភាពជួញដូរមូលបត្រ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងភ្ជាប់ជាមួយកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តដូចខាងក្រោម៖

១. ប៉ូស៊ីសិន (Position) មូលបត្រដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគិតតាមម៉ាកធ្វម៉ាខេត (Mark-to-market) តាមតម្លៃពេលបិទទីផ្សារប្រចាំថ្ងៃ ដែលបង្ហាញដោយក្រុមហ៊ុនទីផ្សារមូលបត្រ។

២. ផ្អែកលើប៉ូស៊ីសិនមូលបត្រ គិតតាមម៉ាកធ្វម៉ាខេតតាមតម្លៃពេលបិទទីផ្សារប្រចាំថ្ងៃនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនត្រូវកាន់កាប់មូលបត្រសរុបលើសពី ២០% (ម្ភៃភាគរយ) នៃមូលនិធិផ្ទាល់សុទ្ធឡើយ។

៣. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវការទទួលខុសត្រូវ និងតាមដាន ដើម្បីសម្រេចបាននូវការគោរពតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់ ២០% (ម្ភៃភាគរយ) នេះ។

៤. ក្នុងករណីល្មើសកម្រិតកំណត់ខាងលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាត់វិធានការកែតម្រូវ និងត្រូវរាយការណ៍ពីមូលហេតុនៃការល្មើស វិធានការ និងពេលវេលាចាំបាច់សម្រាប់ការកែតម្រូវជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

ដោយសារពុំទាន់មានក្របខ័ណ្ឌសាធនភាពពេញលេញក្នុងការកំណត់បន្ទុកដើមទុន (Capital charges) សម្រាប់ហានិភ័យទីផ្សារ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលកាន់កាប់ និងជួញដូរមូលបត្រត្រូវគោរពតាមការតម្រូវដូចខាងក្រោម៖

១. សតសែលលីង (Short Selling) ត្រូវបានហាមឃាត់។

២. ឡងប៉ូស៊ីសិន (Long position) សម្រាប់មូលបត្រនីមួយៗ ត្រូវគិតតាមម៉ាកធ្វម៉ាខេតតាមតម្លៃពេលបិទទីផ្សារប្រចាំថ្ងៃ ដែលបង្ហាញដោយក្រុមហ៊ុនទីផ្សារមូលបត្រ នាការិយបរិច្ឆេទនៃរបាយការណ៍ និងប៉ូស៊ីសិនសរុបទាំងអស់ គិតតាមម៉ាកធ្វម៉ាខេតតាមតម្លៃពេលបិទទីផ្សារប្រចាំថ្ងៃ។

៣. ក្នុងការគណនាអនុបាតសាធនភាព ការថ្លឹងហានិភ័យត្រូវអនុវត្ត ១២0% (មួយរយម្ភៃភាគរយ) ចំពោះប៉ូស៊ីសិនសរុបគិតតាមម៉ាកធ្វម៉ាខេតតាមតម្លៃពេលបិទទីផ្សារប្រចាំថ្ងៃ។

ប្រការ ៦.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមិនអាចកាន់កាប់ និងជួញដូរមូលបត្រទេ។

ប្រការ ៧.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាដែលមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ មាត្រា ៥៣ និងមាត្រា ៥៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៨.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១២-១៨៥ ប្រ.ក

ប្រកាស
ស្តីពី
វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ តទៅនេះហៅថា "ធនាគារភ្នាក់ងារ" ដែលទទួលប្រតិស្រុតពីគណៈកម្មការមូលបត្រកម្ពុជា ឱ្យធ្វើសកម្មភាពជាត់ទាត់ ឬទូទាត់សាច់ប្រាក់សម្រាប់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ ដែលមានគណនីទូទាត់សាច់ប្រាក់ជាមួយធនាគារភ្នាក់ងារ។

ប្រការ ២.-

ធនាគារភ្នាក់ងារត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដូចខាងក្រោមនេះ៖

១. ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី គោលនយោបាយ នីតិវិធី និងដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាម ហើយតែងតាំងបុគ្គលិកមានចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវឱ្យទទួលបន្ទុកការងារនេះ។ ការត្រួតពិនិត្យនេះត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ហើយត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រាអំពីប្រសិទ្ធភាព ភាពគ្រប់គ្រាន់ និងតម្រូវការក្នុងការកែលម្អ។

២. ត្រូវធានាឱ្យមាន៖

ក. ការញែកឱ្យដាច់ពីគ្នារវាងដំណើរការទូទាត់សម្រាប់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រ និងដំណើរការទូទាត់សម្រាប់សកម្មភាពប្រតិបត្តិការធម្មតា ដែលចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ. ការញែកឱ្យដាច់ពីគ្នារវាងគណនីអតិថិជនរបស់ក្រុមហ៊ុនមូលបត្រសម្រាប់ទូទាត់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រកម្ពុជា និងគណនីប្រាក់បញ្ញើអតិថិជនធម្មតា។ គណនីទូទាត់របស់ក្រុមហ៊ុនមូលបត្រដែលមានឬគ្មានសិទ្ធិអំណាចជាអ្នកធានាទិញ ឬជួញដូរមូលបត្រ ក៏ត្រូវញែកឱ្យដាច់ពីគ្នា ដើម្បីចៀសវាងការលាយឡំគ្នារវាងសាច់ប្រាក់របស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ និងប្រាក់បញ្ញើរបស់អតិថិជនធម្មតា។

គ. ដំណើរការទាំងអស់ដែលពាក់ព័ន្ធសម្រាប់ចាត់ចែង និងទូទាត់ប្រតិបត្តិការទិញ-លក់មូលបត្រត្រូវមានឯកសារយោងតាមលំនាំសវនកម្ម (Audit trail process) ដែលសមស្រប និងមានប្រសិទ្ធភាព។ ប្រសិទ្ធភាពនៃលំនាំសវនកម្មត្រូវបានធ្វើតេស្ត និង

វាយតម្លៃឡើងវិញជាប្រចាំ។ ឯកសារនៃដំណើរការនិងនីតិវិធីទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងរក្សាទុក។ ឯកសារយោងតាមលំនាំសវនកម្មត្រូវបានការពារ និងរក្សាទុកសម្រាប់រយៈពេលយ៉ាងតិច ៥ ឆ្នាំ (ប្រាំឆ្នាំ) និងត្រូវផ្តល់ឱ្យស្នងការគណនីឯករាជ្យ គណៈកម្មការមូលបត្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា តាមសំណើ។

ប្រការ ៣.-

១. ធនាគារភ្នាក់ងារមិនត្រូវផ្តល់ឥណទានវិបារូបន៍ ឬឥណទានផ្សេងទៀតដល់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រក្នុងការប្រើប្រាស់សម្រាប់គោលបំណងទូទាត់ប្រតិបត្តិការទិញ-លក់ក្នុងទីផ្សារមូលបត្រកម្ពុជា។

២. ដើម្បីធានានូវការញែកឱ្យដាច់ពីគ្នារវាងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជន ធនាគារភ្នាក់ងារមិនត្រូវប្រើប្រាស់សមតុល្យទឹកប្រាក់របស់អតិថិជននៃក្រុមហ៊ុនមូលបត្រ ជាប្រភពទុនសម្រាប់សកម្មភាពប្រតិបត្តិការធម្មតារបស់ធនាគារភ្នាក់ងារទេ។

៣. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ (ទ្រព្យអកម្ម) ត្រូវដកចេញពីភាគយក និងថ្លឹង ១០០% (មួយរយភាគរយ) ក្នុងខ្នង់ភាគបែង។

៤. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

ប្រការ ៤.-

១. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

២. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារ ត្រូវដកចេញពីភាគយក និងថ្លឹង ១០០% (មួយរយភាគរយ) ក្នុងខ្នង់ភាគបែង។

ប្រការ ៥.-

១. ដោយពិនិត្យលើហានិភ័យនៃការបង្ហាក់ដល់ដំណើរការទូទាត់និងជាត់ទាត់ជាទូទៅ ដែលបណ្តាលមកពីធនាគារភ្នាក់ងារខកខានក្នុងការទូទាត់ ឬជាត់ទាត់សាច់ប្រាក់ ធនាគារភ្នាក់ងារត្រូវបង្កើតផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មសមស្រប ដោយមានដំណោះស្រាយបែកអាប់ (Back-up) គ្រប់គ្រាន់។

២. ការធ្វើផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មនោះ ត្រូវពិចារណាទាំងលើការខកខានឬការបង្ហាក់ដែលផ្តើមចេញពីធនាគារភ្នាក់ងារ និងពីកត្តាខាងក្រៅ។

៣. ត្រូវរៀបចំចងក្រងជាឯកសារ និងធ្វើតេស្តជាប្រចាំ ដើម្បីវាយតម្លៃឡើងវិញពីប្រសិទ្ធភាព នៃការធ្វើផែនការ នីតិវិធីនិងដំណើរការយថាភាពនិងនិរន្តរភាពអាជីវកម្ម។ ឯកសារទាំងនេះត្រូវបានរក្សាទុកជាកាលប្បវត្តិនិងធ្វើបច្ចុប្បន្នកម្ម។

៤. សវនកម្មផ្ទៃក្នុងរបស់ធនាគារភ្នាក់ងារ ត្រូវធ្វើការវាយតម្លៃដោយឯករាជ្យនិងជាប្រចាំលើផែនការ នីតិវិធីនិងដំណើរការបែកអាប់ (Back-up) ហើយគណៈគ្រប់គ្រងធនាគារភ្នាក់ងារត្រូវពិចារណានិងដោះស្រាយជាបន្ទាន់តាមអនុសាសន៍របស់សវនករផ្ទៃក្នុង។

ប្រការ ៦.-

ធនាគារភ្នាក់ងារដែលមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ មាត្រា ៥៣ និងមាត្រា ៥៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៥-៣៤៩ ប្រ.ក

ប្រកាស
ស្តីពី
អនុបាតក្របខ័ណ្ឌសន្ទនីយភាព

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យក្នុងការគណនា និងកំណត់កម្រិតអប្បបរមានៃអនុបាតក្របខ័ណ្ឌសន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើពីសាធារណជន ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះមានគោលដៅ៖

- បង្កើនភាពធន់រយៈពេលខ្លី (Short-Term Resilience) ចំពោះហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន
- ធានាថាគ្រឹះស្ថានមានបរិមាណទ្រព្យសកម្មសន្ទនីយគ្រប់គ្រាន់មិនជាប់កាតព្វកិច្ច ដែលអាចបំលែងជាសាច់ប្រាក់ដោយមិនខាតបង់ ឬខាតបង់តិចតួចពីតម្លៃនៅលើទីផ្សារ ដើម្បីបំពេញតម្រូវការសន្ទនីយភាពក្នុងស្ត្រេសសេណារីយ៉ូ (Stress Scenario) សម្រាប់រយៈពេល ៣០ ថ្ងៃ និង
- ធានាថា នៅពេលដែលអនុបាតក្របខ័ណ្ឌសន្ទនីយភាពនេះធ្លាក់ចុះក្រោមកម្រិតកំណត់អប្បបរមា គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវចាត់វិធានការកែតម្រូវបន្ទាន់។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានត្រូវរក្សាអនុបាតក្របខ័ណ្ឌសន្ទនីយភាពយ៉ាងតិច ១០០% (មួយរយភាគរយ) គ្រប់ពេលវេលាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។

អនុបាតក្របខ័ណ្ឌសន្ទនីយភាព មានសមាសធាតុពីរគឺ៖

- ភាគយក៖ តម្លៃទីផ្សារនៃបរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន ដូចមានកំណត់ក្នុងប្រការ ៧
- ភាគបែង៖ លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុកគណនាស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ។

$$\text{អនុបាតក្របខ័ណ្ឌសន្ទនីយភាព} = \frac{\text{បរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន}}{\text{លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុករយៈពេល ៣០ ថ្ងៃ}} \geq ១០០\%$$

គ្រឹះស្ថានដែលបង្កើតឡើងនៅកម្ពុជា ត្រូវគណនាទាំងកម្រិតគ្រឹះស្ថាននិងកម្រិតគួបសរុប ចំណែកគ្រឹះស្ថានដែលជាសាខារបស់ធនាគារបរទេស ត្រូវគណនាត្រឹមកម្រិតគ្រឹះស្ថាន។

ប្រការ ៥.-

គ្រឹះស្ថានត្រូវអនុវត្តការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព ស្របតាមគំរូរបាយការណ៍ថ្មី ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ជាដំណាក់កាលរហូតបំពេញបានទាំងស្រុងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។ គ្រឹះស្ថានត្រូវរក្សាជាប្រចាំនូវបរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន គ្រប់គ្រាន់ ដើម្បីឱ្យកម្រិតអនុបាតដែលបានកំណត់ស្របទៅតាមពេលវេលា ដូចខាងក្រោម៖

ចាប់អនុវត្ត	០១ កញ្ញា ២០១៦	០១ កញ្ញា ២០១៧	០១ កញ្ញា ២០១៨	០១ មិថុនា ២០១៩	០១ មករា ២០២០
អនុបាតអប្បបរមា	៦០%	៧០%	៨០%	៩០%	១០០%

ប្រការ ៦.-

គ្រឹះស្ថានត្រូវមានទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានបន្ថែមទៀត លើសពីកម្រិតកំណត់នៃអនុបាតនេះស្របតាមគោលនយោបាយនិងការទទួលយកបាននៃកម្រិតហានិភ័យសន្ទនីយភាពរបស់ខ្លួន។

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ធនាគារជាតិនៃកម្ពុជា នៅពេលមិនគោរពបានតាមកម្រិតកំណត់នៃអនុបាតនេះ ឬនៅពេលព្យាករណ៍ដឹងថាមិនអាចបំពេញតាមកម្រិតកំណត់។

គ្រឹះស្ថានត្រូវគណនាអនុបាតនេះដោយឡែកពីគ្នាសម្រាប់ទ្រព្យសកម្មនិងទ្រព្យអកម្ម ដែលចារឹកជាប្រាក់រៀល ដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗទៀតរួមគ្នា ព្រមទាំងសរុបរូបិយប័ណ្ណទាំងអស់បញ្ចូលគ្នា។ ប្រកាសនេះអនុវត្តចំពោះអនុបាតក្របខ័ណ្ឌសន្ទនីយភាព ដែលត្រូវបានគណនាជាសរុបរូបិយប័ណ្ណទាំងអស់បញ្ចូលគ្នា គិតជា ប្រាក់រៀល។

ប្រការ ៧.-

ទ្រព្យសកម្មសន្ទនីយអាចទទួលយកបាន គឺជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ (High Quality Liquid Assets) និងទ្រព្យសកម្មសន្ទនីយផ្សេងទៀត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ។ ទ្រព្យសកម្មដែលត្រូវបញ្ចូលនៅក្នុងប្រភេទនីមួយៗ គឺជាទ្រព្យសកម្មដែលគ្រឹះស្ថានកាន់កាប់រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃរាយការណ៍នីមួយៗ ដោយមិនគិតពីឥណប្រតិទាន។

ទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ត្រូវគិតតម្លៃពេញតាមទីផ្សារ ១០០% (មួយរយភាគរយ) ចំណែក ទ្រព្យសកម្មសន្ទនីយផ្សេងទៀត ត្រូវកាត់បន្ថយតម្លៃទាបជាងទីផ្សារ (Haircut) ១៥% (ដប់ប្រាំភាគរយ) ទៅ ២៥% (ម្ភៃប្រាំភាគរយ)។

ទំហំទ្រព្យសកម្មសន្ទនីយផ្សេងទៀត ត្រូវកម្រិតអតិបរមា ៥0% (សែសិបភាគរយ) នៃទំហំទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន។

សំពៀតនៃទ្រព្យសកម្មសន្ទនីយផ្សេងទៀតត្រូវតែធ្វើពិពិធកម្មតាមប្រភេទនៃទ្រព្យសកម្ម និងអ្នកបោះផ្សាយ។

ប្រការ ៨.-

លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុក = លំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក - លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុក (ក្នុងរយៈពេល ៣0 ថ្ងៃ បន្ទាប់ពីថ្ងៃរាយការណ៍នីមួយៗ)។

លំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក = សមតុល្យដក់សល់នៃខ្នង់ទ្រព្យអកម្មនិងខ្នង់ក្រៅតារាងតុល្យការ x អត្រារំពឹងទុកនៃលំហូរចេញ។

លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុក = សមតុល្យដក់សល់នៃខ្នង់ត្រូវទទួលតាមការសន្យា x អត្រារំពឹងទុកនៃលំហូរចូល។

ពេលគណនាលំហូរចូលនៃសាច់ប្រាក់ គ្រឹះស្ថានត្រូវគិតតែលំហូរចូលទ្រព្យសកម្មស្តង់ដារដក់សល់ និងមិនរំពឹងថាខកខានទូទាត់សងក្នុងរយៈពេល ៣0 ថ្ងៃ។

លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុកត្រូវបានកំណត់ត្រឹម ៧៥% (ចិតសិបប្រាំភាគរយ) នៃលំហូរចេញសាច់ប្រាក់ដែលរំពឹងទុក ដែលមានន័យថា លំហូរចេញសុទ្ធនៃសាច់ប្រាក់អប្បបរមាគឺ ២៥% (ម្ភៃប្រាំភាគរយ) នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកសរុប។

នៅក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព គ្រឹះស្ថានមិនត្រូវយកទ្រព្យសកម្មណាមួយមកគណនាពីរដងទេ (Double Count Items)។ ប្រសិនបើទ្រព្យសកម្មណាមួយត្រូវបានគិតបញ្ចូលទៅក្នុងបរិមាណនៃទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានរួចហើយ ដូចមានក្នុងប្រការ ៧ នៃប្រកាសនេះ ទ្រព្យសកម្មនេះ មិនត្រូវបានបញ្ចូលសម្រាប់គណនាលំហូរចេញសុទ្ធនៃសាច់ប្រាក់ទៀតឡើយ។

ប្រការ ៩.-

លំហូរចេញនៃសាច់ប្រាក់ ដែលពាក់ព័ន្ធប្រាក់បញ្ញើមានកាលកំណត់ មិនត្រូវរាប់បញ្ចូលក្នុងការគណនាលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកទេ ក្នុងករណីៈ

- មានឥណប្រតិទានលើសពី ៣0 ថ្ងៃ ឬ
- មានការជូនដំណឹងអំពីការដកប្រាក់ លើសពី ៣0 ថ្ងៃ

ប៉ុន្តែ ប្រសិនបើគ្រឹះស្ថានអនុញ្ញាតឱ្យម្ចាស់ប្រាក់បញ្ញើដកប្រាក់នោះមុនឥណប្រតិទានទោះបីមានពិន័យការប្រាក់ក៏ដោយ ប្រាក់បញ្ញើទាំងនេះ ត្រូវចាត់ទុកដូចជាប្រភេទប្រាក់បញ្ញើដកបានតាមតម្រូវការ និងត្រូវបញ្ចូលក្នុងការគណនាលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក។

លំហូរចូលនៃសាច់ប្រាក់ពីការបោះផ្សាយប័ណ្ណបំណុលថ្មីណាមួយក្នុងរយៈពេល ៣0 ថ្ងៃខាងមុខ មិនត្រូវគិតបញ្ចូលក្នុងការគណនាលំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុកទេ។

លំហូរដែលកើតចេញពីប៉ូស៊ីសិននៃប្រតិបត្តិការឧបករណ៍និស្សន្ទ អាចត្រូវបានកាត់កងដោយសមភាគី ប្រសិនបើមានកិច្ចសន្យារវាងភាគីទាំងពីរ។ ចំពោះប៉ូស៊ីសិន និងលំហូរផ្សេងទៀតដែលចែងក្នុងប្រកាសនេះ គ្រឹះស្ថានត្រូវផ្តល់ការវិភាគនិងភស្តុតាងច្បាស់លាស់ ដើម្បីបញ្ជាក់ពីលំហូរចេញ និងលំហូរចូលនៃឧបករណ៍និស្សន្ទ ដែលគ្រឹះស្ថានបានយកមកគិត។

ប្រការ ១០.-

ចំពោះគ្រឹះស្ថានជាបុគ្គលសម្ព័ន្ធ ឬជាសាខារបស់ធនាគារបរទេស ធនាគារជាតិនៃកម្ពុជាអាចអនុញ្ញាតឱ្យគ្រឹះស្ថានទាំងនោះទទួលទុនពីទីស្នាក់ការកណ្តាលតាមរយៈកិច្ចសន្យាផ្តល់ទុន។ ក្នុងករណីនេះ កិច្ចសន្យាផ្តល់ទុនទាំងនោះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ដែលមិនអាចបដិសេធបានពីទីស្នាក់ការកណ្តាល
- ដែលអនុញ្ញាតឱ្យទទួលទុនសរុបក្នុងរយៈពេលតិចជាង ៣០ ថ្ងៃ
- ដែលត្រូវរៀបចំជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ
- ដែលមានបញ្ជាក់ពីទំហំទឹកប្រាក់ច្បាស់លាស់ និង
- ត្រូវមានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម។

ទំហំទឹកប្រាក់ក្នុងកិច្ចសន្យានេះដែលអាចឱ្យលំហូរចូលនៃសាច់ប្រាក់កើនឡើង ត្រូវបានកំណត់ត្រឹមតែ ៤០% (សែសិបភាគរយ) នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកសរុប។

ប្រការ ១១.-

គ្រឹះស្ថានត្រូវមានរចនាសម្ព័ន្ធផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្នុងសមស្របដែលអាចធានាអនុវត្តបានតាមប្រកាសនេះ។

ប្រការ ១២.-

អនុបាតក្របខ័ណ្ឌសន្ទនីយភាព ត្រូវបានប្រើប្រាស់ជាប្រចាំក្នុងការតាមដាន និងត្រួតពិនិត្យហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន។ គ្រឹះស្ថានត្រូវគោរពឱ្យបានតាមកម្រិតកំណត់នៃអនុបាតនេះជាបន្តបន្ទាប់។

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍ស្តីពីអនុបាតនេះ មកធនាគារជាតិនៃកម្ពុជាជារៀងរាល់ខែ។ ករណីមានស្ថានភាពតានតឹង (Stress Situation) ធនាគារជាតិនៃកម្ពុជាមានសិទ្ធិតម្រូវឱ្យគ្រឹះស្ថានរាយការណ៍ប្រចាំសប្តាហ៍ ឬប្រចាំថ្ងៃ បន្ថែមទៀត។

ប្រការ ១៣.-

ត្រូវបានចាត់ទុកជានិរាករណ៍៖

- ប្រកាសលេខ ធ៧-០០-៣៨ ប្រ.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី សាច់ប្រាក់ងាយស្រួលរបស់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ

- ប្រកាសលេខ ធ៧-០២-១៨៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី វិសោធនកម្ម លើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ធ៧-០៤-២០៧ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង
- ប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំណុចទី៤ នៃប្រការ ៣។

ប្រការ ១៤.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព។

ប្រការ ១៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ ១
Annex 1

របាយការណ៍ប្រចាំខែ ស្តីពី អនុបាតគ្រប់គ្រាន់ណ្តាសន្ទនីយភាព
Monthly Report on Liquidity Coverage Ratio

ឈ្មោះគ្រឹះស្ថាន ៖ Name of the Institution :	
កាលបរិច្ឆេទ ៖ Reporting Date :	

អត្រាប្តូរក្នុង ១ ដុល្លារអាមេរិក (Exchange rate 1 USD) = KHR

កិតជាលានរៀល (In million riels)				ចំនួនទឹកប្រាក់មិនទាន់ថ្លឹង Non weighted amounts			ចំនួនទឹកប្រាក់ក្រោយថ្លឹង Weighted amounts			សរុប Total
ប្រព្យសកម្ម ASSETS				KHR	USD	Other currencies	KHR	USD	Other currencies	
ប្រព្យសកម្មសន្ទនីយាំងាយបានគុណភាពខ្ពស់ HQLA	1.11	1	សាច់ប្រាក់ និងកាសក្នុងដៃ Notes and coins				0.00	0.00	0.00	0.00
	1.12	1	អតិជនប្រាក់បម្រុងតាមកិច្ចនៅធនាគារជាតិនៃកម្ពុជា Reserves requirement with the NBC > minimum reserve requirement				0.00	0.00	0.00	0.00
	1.13	1	ប្រាក់បម្រុងតាមកិច្ចជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា Reserves requirement with the NBC in KHR				0.00	0.00	0.00	0.00
	1.14	0.7	ប្រាក់បម្រុងតាមកិច្ចជាប្រាក់ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា Reserves requirement with the NBC in USD				0.00	0.00	0.00	0.00
	1.15	1	សមតុល្យប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា លើកលែងគណនីទូទាត់ និងគណនីប្រាក់ចាត់ទុកលើដើមទុន Amounts deposited at the NBC excluding settlement account and capital guarantee account				0.00	0.00	0.00	0.00
	1.16	1	មូលបត្រអាចផ្តល់ផ្តាំបាន (និង ប្រភេទមូលបត្រផ្សេងទៀត) ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា NCDs (and any other securities) issued by the NBC				0.00	0.00	0.00	0.00
	1.17	1	តម្លៃទីផ្សារនៃមូលបត្រប្រាក់ណ្តាលអាចផ្តល់ផ្តាំបានមិនជាប់ភាពកិច្ចរបស់ ឬធានាដោយ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាលដែលមានចំណាត់ថ្នាក់ AAA ទៅ AA- និង ធនាគារសម្រាប់ការទូទាត់អន្តរជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃសហគមន៍អឺរ៉ុប សហគមន៍អឺរ៉ុប និងធនាគារអភិវឌ្ឍន៍ ដែលមានចំណាត់ថ្នាក់ AAA Market value of unencumbered marketable debt securities on or guaranteed by sovereigns and central banks, with rating comprised between AAA and AA- included BIS, IMF, ECB, EU, and MDBs when rated AAA				0.00	0.00	0.00	0.00
			សរុប ១ = ផលបូក (1.11 ដល់ 1.17) **Total 1 = Σ (1.11 ; 1.17)**	**0.00**	**0.00**	**0.00**	0.00	0.00	0.00	0.00
ប្រព្យសកម្មសន្ទនីយផ្សេងទៀត OLA	1.21	0.85	តម្លៃទីផ្សារនៃមូលបត្រប្រាក់ណ្តាលអាចផ្តល់ផ្តាំបានមិនជាប់ភាពកិច្ចរបស់ ឬធានាដោយ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាលដែលមានចំណាត់ថ្នាក់ A+ ទៅ A- Market value of unencumbered marketable debt securities on or guaranteed by sovereigns and central banks, with rating between A+ and A-				0.00	0.00	0.00	0.00
	1.22	0.85	តម្លៃទីផ្សារនៃមូលបត្រប្រាក់ណ្តាលអាចផ្តល់ផ្តាំបានមិនជាប់ភាពកិច្ចរបស់ ឬធានាដោយ សហគ្រាសសង្គមភាពសាធារណៈ ធនាគារអភិវឌ្ឍន៍ ដែលពុំបានបញ្ចូលនៅក្នុង ១ ១៧ ដែលមានចំណាត់ថ្នាក់ខ្ពស់ជាង ឬ ស្មើ A- Market value of unencumbered marketable debt securities on or guaranteed by Public Sector Entities (PSEs) and MDBs not included in 1.17 with rating higher or equal to A-				0.00	0.00	0.00	0.00
	1.23	0.85	មូលបត្រប្រាក់ណ្តាលអាចផ្តល់ផ្តាំបានមិនជាប់ភាពកិច្ចដែលអាចទទួលយកបាន (រួមទាំងផលបត្រពាណិជ្ជកម្ម) និង Covered Bonds ដែលមានចំណាត់ថ្នាក់ខ្ពស់ជាង ឬ ស្មើ AA- Unencumbered eligible debt securities (including commercial paper) and covered bonds, with rating higher or equal to AA-				0.00	0.00	0.00	0.00
	1.24	0.75	មាស Gold for own account				0.00	0.00	0.00	0.00
			សរុប ២ = អប្បបរមា នៃ [OLA ; 40% (HQLA+OLA)] **Total 2 = Minimum [OLA ; 40% (HQLA+OLA)]**	0.00	0.00	0.00	**0.00**	**0.00**	**0.00**	**0.00**
ប្រព្យសកម្មសរុប Total ASSETS			**សរុប ៣ = សរុប ១ + សរុប ២** **Total 3 = Total 1 + Total 2**	**0.00**	**0.00**	**0.00**	0.00	0.00	0.00	0.00

ច្បាប់ចម្លងឯកសារនេះ ត្រូវបានធ្វើឡើងសម្រាប់ប្រើប្រាស់ក្នុងការងារ

ចំណូលបញ្ចូលសុទ្ធនៃសាច់ប្រាក់ដែលចេញ - ចំណូលបញ្ចូលសាច់ប្រាក់ដែលចេញ - ចំណូលបញ្ចូលសាច់ប្រាក់ដែលចេញសុទ្ធ NET CASH OUTFLOWS - expected cash outflows - expected cash inflows														
	ចំណូលចេញ OUTFLOWS													
			ចំណូលចេញសាច់ប្រាក់ (ទឹកប្រាក់ដែលត្រូវបានបង់) និងប្រាក់ចំណូលសាច់ប្រាក់ពីសកម្មភាពសន្សាក្នុងទីផ្សារ (ទាំងទាក់ ឬ មិនទាក់) ***ចន្លោះ 100.000 ដុល្លារអាមេរិក ឬ សមមូល*** ***Retail cash outflows (regardless of amount) and qualifying SME deposits (less than or equal to USD 100,000 or equivalent)***										
	2.11	0.05	ប្រាក់បញ្ញើគ្មានកំណត់ Stable deposits					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.12	0.15	ប្រាក់បញ្ញើមិនស្ថិតក្នុងកំណត់ Less stable deposits					0.00	0.00	0.00	0.00	0.00	0.00	0.00
			ប្រាក់បម្រុងមិនទាក់ទងការលក់ ***Unsecured wholesale funding***											
	2.21	0.25	ប្រាក់បញ្ញើប្រតិបត្តិការ (ប្រាក់ដុល្លារមិនទាក់ទងការលក់ដែលបានបង្កើតឡើងដោយសេវាកម្មបង្កាន់ដៃ រក្សាទុក និងប្រាក់បម្រុងសាច់ប្រាក់) operational deposits (unsecured funding generated by clearing, custody and cash management activities)					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.22	0.4	ប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ពីប្រភពមិនមែនហិរញ្ញវត្ថុ (មិនបានបញ្ជាក់ក្នុង ២.១១ និង ២.១៥) non operational deposits from non-financial corp not qualifying for reporting in 2.11 to 2.12					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.23	0.4	ប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ពីស្ថាប័នអធិបតេយ្យ ធនាគារកណ្តាល និងសាជីវកម្មសាធារណៈ: non operational deposits from sovereigns, central banks, and PSEs					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.24	1	ប្រាក់បញ្ញើមិនមែនប្រតិបត្តិការពីស្ថាប័នហិរញ្ញវត្ថុ (ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ២) non operational deposits from banks and financial institutions (as defined in Annex 2)					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.25	1	ប្រាក់បញ្ញើមិនមែនប្រតិបត្តិការពីអង្គភាពផ្លូវច្បាប់ផ្សេងទៀត non operational deposits from all other legal entities					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.26	1	ប្រភពមូលនិធិមិនទាក់ទងការលក់ផ្សេងទៀត រួមទាំងមូលប្បទានប័ណ្ណបំណុល any other unsecured wholesale funding including debt securities					0.00	0.00	0.00	0.00	0.00	0.00	0.00
			ប្រាក់បម្រុងទាក់ទងការលក់ ***Secured funding***											
	2.31	0	ប្រតិបត្តិការប្រភពមូលនិធិទាក់ទងការលក់ដែលធានាដោយ HQLA secured funding transactions backed by HQLA					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.32	0.15	ប្រតិបត្តិការប្រភពមូលនិធិទាក់ទងការលក់ដែលធានាដោយមាសផ្សេងទៀតក្រៅពីមាស secured funding transactions backed by OLA other than Gold					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.33	0.25	ប្រតិបត្តិការប្រភពមូលនិធិទាក់ទងការលក់ដែលធានាដោយមាសសម្រាប់គណនីផ្ទាល់ secured funding transactions backed by Gold for own account					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.34	1	ប្រតិបត្តិការប្រភពមូលនិធិទាក់ទងការលក់ផ្សេងទៀត all other secured funding transactions					0.00	0.00	0.00	0.00	0.00	0.00	0.00
			កម្ចីប្រភេទមូលនិធិសមាហរណកម្មទាក់ទងនឹងការប្តូរមុខមាត់ និងប្រភពកម្ចីប្រភេទផ្សេងទៀត ***Increased liquidity needs related to derivatives and other transactions***											
	2.41	1	ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ derivative payables					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.42	1	លំហូរចេញដែលបង្កើតឡើងដោយការផ្លាស់ប្តូរនៃតម្លៃទីផ្សារ នៃប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុ outflows from market valuation changes of collateral for derivative transactions					0.00	0.00	0.00	0.00	0.00	0.00	0.00
	2.43	1	លំហូរចេញសាច់ប្រាក់ដែលបង្កើតឡើងដោយឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវផ្សេងទៀត other derivative cash outflows					0.00	0.00	0.00	0.00	0.00	0.00	0.00
			កិច្ចសន្យា Committed facilities											
ចំណូលចេញនៃសាច់ប្រាក់ CASH OUTFLOWS			***សក្តានុពលទាក់ទងនឹងប្រាក់ដែលត្រូវដកពីកិច្ចសន្យាឥណទាន និងការផ្តល់ជូនសាច់ប្រាក់*** *for the undrawn portion of committed credit and liquidity facilities*											
			ចំណាកចំពីឥណទាន និងសហគ្រាសខ្នាតតូច និងមធ្យម *to retails and SMEs*											
	2.51	0.05	កិច្ចសន្យាឥណទាន Credit facilities					0.00	0.00	0.00	0.00	0.00	0.00	0.00

	2.52	0.05	កិច្ចសម្រួលឥណទាន liquidity facilities							0.00	0.00	0.00	0.00	0.00	0.00
			ចំពោះប្រាក់កម្ចីនិងឥណទានពាណិជ្ជកម្ម ស្ថាប័នរដ្ឋាភិបាលជាតិ និង ធនាគារកណ្តាល *to non financial corporates, sovereigns and central banks*												
	2.53	0.1	កិច្ចសម្រួលឥណទាន credit facilities							0.00	0.00	0.00	0.00	0.00	0.00
	2.54	0.3	កិច្ចសម្រួលនៃរយៈពេល liquidity facilities							0.00	0.00	0.00	0.00	0.00	0.00
			ចំពោះស្ថាប័នធនាគារនិងហិរញ្ញវត្ថុ (ស្ថាប័នដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២) *to banks and financial institutions (as defined in Annex 2)*												
	2.55	0.4	កិច្ចសម្រួលឥណទាន credit facilities							0.00	0.00	0.00	0.00	0.00	0.00
	2.56	0.4	កិច្ចសម្រួលនៃរយៈពេល liquidity facilities							0.00	0.00	0.00	0.00	0.00	0.00
			ទៅស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត *to other financial institutions*												
	2.57	0.4	កិច្ចសម្រួលឥណទាន credit facilities							0.00	0.00	0.00	0.00	0.00	0.00
	2.58	1	កិច្ចសម្រួលនៃរយៈពេល liquidity facilities							0.00	0.00	0.00	0.00	0.00	0.00
			និតិបុគ្គលផ្សេងទៀត *to other legal entities*												
	2.59	1	កិច្ចសម្រួលឥណទាន credit facilities							0.00	0.00	0.00	0.00	0.00	0.00
	2.60	1	កិច្ចសម្រួលនៃរយៈពេល liquidity facilities							0.00	0.00	0.00	0.00	0.00	0.00
			កាតព្វកិច្ចផ្សេងទៀតក្នុងការផ្តល់ជូន (ថាតើកិច្ចសន្យាត្រូវបានកំណត់ឬអត់) ***Other contingent funding obligations (whether contractual or not)***												
	2.71	0.1	កិច្ចសម្រួលឥណទានដែលអាចដកវិញបានដោយមិនមានលក្ខខណ្ឌ unconditional revocable credit and liquidity facilities' agreements							0.00	0.00	0.00	0.00	0.00	0.00
	2.72	1	កាតព្វកិច្ចទាក់ទងនឹងហិរញ្ញប្បទានពាណិជ្ជកម្ម (តាមការប៉ាន់ស្មានចរន្តចេញជាមធ្យមប្រចាំខែសម្រាប់រយៈពេល ១២ ខែចុងក្រោយ) trade finance related obligations (report average of monthly net outflows in last 12 month period)							0.00	0.00	0.00	0.00	0.00	0.00
	2.73	0.5	ការធានាប័ណ្ណកម្ចីនិងលិខិតឥណទាន ផ្សេងទៀតដែលទាក់ទងនឹងកាតព្វកិច្ចហិរញ្ញប្បទាន (តាមការប៉ាន់ស្មានចរន្តចេញជាមធ្យមសុទ្ធប្រចាំខែ) Guarantees and letters of credit other than trade finance related obligations (report average of monthly net outflows in last 12 month period)							0.00	0.00	0.00	0.00	0.00	0.00
	2.81	1	***ចំណាយកម្ចីដែលទាក់ទងនឹងការអនុវត្តផ្សេងទៀត*** ***Other contractual outflows***							0.00	0.00	0.00	0.00	0.00	0.00
			សរុប ផ - ផលបូក (២.១១ ដល់ ២.៨១) **Total 4 – Σ (2.11 ; 2.81)**			0.00	0.00	0.00		0.00	0.00	0.00	0.00	0.00	0.00
ចំណូលចូល INFLOWS															
			សារពើភ័ណ្ឌសន្យាទិញត្រឡប់ (Reverse Repo) និងកម្ចីដែលធានាដោយមធ្យោបាយទូទាត់ក្នុងរយៈពេលតិចជាង ៣០ ថ្ងៃ ***Outstanding Reverse repos and securities borrowing with remaining maturities within 30 days***												
			ប្រសិនបើធានាដោយទ្រព្យធានាដែលមិនត្រូវបានប្រើប្រាស់ឡើងវិញ *where the collateral received is not re-hypothecated*												
	3.11	0	ធានាដោយប្រាក់សាច់ឬមូលប្បទានបត្រសុវត្ថិភាពរដ្ឋាភិបាល covered by HQLA							0.00	0.00	0.00	0.00	0.00	0.00
	3.12	0.25	ធានាដោយប្រាក់សាច់ឬមូលប្បទានបត្រសុវត្ថិភាព covered by CLA							0.00	0.00	0.00	0.00	0.00	0.00
	3.13	1	ធានាដោយប្រាក់សាច់ឬមូលប្បទានបត្រសុវត្ថិភាព covered by other assets							0.00	0.00	0.00	0.00	0.00	0.00

			ប្រតិបត្តិការដែលបានទទួលនូវវត្ថុបញ្ចាំដែលត្រូវបានដាក់បញ្ចាំបន្ត *where the collateral received is re-hypothecated*												
	3.14	0	ការធានាប្រតិបត្តិការមូលនិធិរដ្ឋាភិបាលកណ្តាលទូទាំង covered by HQLA								0.00	0.00	0.00	0.00	0.00
	3.15	0	ការធានាប្រតិបត្តិការមូលនិធិរដ្ឋាភិបាលក្នុង covered by OLA								0.00	0.00	0.00	0.00	0.00
	3.16	0	ការធានាប្រតិបត្តិការផ្សេងទៀត covered by other assets								0.00	0.00	0.00	0.00	0.00
			ការផ្តល់ជូនមិនទាន់ដកហូតវិញ ពីស្ថាប័នធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២ *Undrawn committed facilities from banks and financial institutions as defined in Annex 2*												
	3.21	0	ការផ្តល់ជូនពីស្ថាប័នធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ដែលមិនមានចែងក្នុងចំណុច ៣.២២ Committed facilities from banks and financial institutions other than those reported in 3.22								0.00	0.00	0.00	0.00	0.00
	3.22	1	ការផ្តល់ជូនពីធនាគារមេ Committed fund facilities with parent bank								0.00	0.00	0.00	0.00	0.00
			ចំណូលចរន្តពីប្រតិបត្តិការផ្សេងទៀត ដែលមានលក្ខណៈដូចខាងក្រោម ក្នុងរយៈពេល ៣០ ថ្ងៃ:សរុប ខាងក្រោម ***Other contractual inflows , either secured or unsecured , within 30 days***												
ចំណូលចូលនៃសាច់ប្រាក់ **CASH INFLOWS**	3.31	0.5	ពីអតិថិជនរាយ from retail customers								0.00	0.00	0.00	0.00	0.00
	3.32	0.5	ពីសហគ្រាសមូលនិធិតូចនិងមធ្យម from SMEs								0.00	0.00	0.00	0.00	0.00
	3.33	0.5	ពីក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ from non financial corporates								0.00	0.00	0.00	0.00	0.00
	3.34	1	ពីធនាគារកណ្តាល from central banks								0.00	0.00	0.00	0.00	0.00
	3.35	1	ពីស្ថាប័នធនាគារនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២ from banks and financial institutions as defined in Annex 2								0.00	0.00	0.00	0.00	0.00
	3.36	0.5	ពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២ from other financial institutions as defined in Annex 2								0.00	0.00	0.00	0.00	0.00
	3.37	0.5	ពីនីតិបុគ្គលផ្សេងទៀត from other legal entities								0.00	0.00	0.00	0.00	0.00
	3.38	0.5	ពីស្ថាប័នរដ្ឋាភិបាល from sovereigns								0.00	0.00	0.00	0.00	0.00
	3.39	1	ប្រាក់បញ្ញើពីស្ថាប័នធនាគារនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២ deposits with banks and financial institutions as defined in Annex 2								0.00	0.00	0.00	0.00	0.00
			ចំណូលចរន្តពីប្រតិបត្តិការហិរញ្ញវត្ថុ ***derivative cash inflows***												
	3.50	1	ចំណូលចរន្តសុទ្ធដែលទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុ net contractual derivative cash inflows within 30 days								0.00	0.00	0.00	0.00	0.00
	3.60	1	***ចំណូលចរន្តពីប្រតិបត្តិការផ្សេងទៀត ដែលមានលក្ខណៈដូចខាងក្រោម ក្នុងរយៈពេល ៣០ ថ្ងៃ:សរុប*** ***Contractual inflows from other securities maturing within 30 days***								0.00	0.00	0.00	0.00	0.00
	3.70	0	***ចំណូលចរន្តពីប្រតិបត្តិការផ្សេងទៀត ដែលមានលក្ខណៈដូចខាងក្រោម ក្នុងរយៈពេល ៣០ ថ្ងៃ:សរុប*** ***Any other contractual inflows due in the next 30 days***								0.00	0.00	0.00	0.00	0.00
			សរុប ឆ – ជួរឈរ (ក.១១ ដល់ ក.៣០) **Total 5 – Σ (3.11 : 3.70)**					0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
ចំណូលចរន្តសុទ្ធនៃសាច់ប្រាក់ **TOTAL NET CASH OUTFLOWS**			**សរុប ជ – សរុបទាបបំផុត (សរុប ឈ ឬ ឆ៧% នៃ សរុប ឯ)** **Total 6 – Total 4 - Min (Total 5 ; 75% Total 4)**					0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
អត្រាគម្របទំហំសាច់ប្រាក់ **LIQUIDITY COVERAGE RATIO**			**អត្រាគម្របទំហំសាច់ប្រាក់ – សរុប ញ / សរុប ជ** **LCR– Total 3/Total 6**								#DIV/0!	#DIV/0!	#DIV/0!	#DIV/0!	

ភ្នំពេញ ថ្ងៃ ខែ ឆ្នាំ

អ្នកធ្វើការ
Prepared By

អ្នកត្រួតពិនិត្យ
Verified By

អគ្គនាយក
General Manager/CEO

សេចក្តីពន្យល់ក្នុងការបំពេញតំរូវបាយការណ៍អនុបាតក្របខ័ណ្ឌសន្ទនីយភាព

ភាពខ្វះចន្លោះនៃការគ្រប់គ្រងហានិភ័យសន្ទនីយភាព គឺជាផ្នែកមួយនៃវិបត្តិហិរញ្ញវត្ថុដែលបានកើតឡើងក្នុងឆ្នាំ២០០៨។ ហេតុនេះ គណៈកម្មាធិការទីក្រុងបាសែលស្តីពីការត្រួតពិនិត្យធនាគារបានរៀបចំបទដ្ឋានសន្ទនីយភាពថ្មី ក្នុងនោះរួមមានទាំងអនុបាតក្របខ័ណ្ឌសន្ទនីយភាពផងដែរ។ បទដ្ឋានសន្ទនីយភាពថ្មីនេះ ត្រូវបានបង្កើតឡើងដើម្បីពង្រឹងក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ ជាពិសេសបង្កើនភាពធន់ទៅនឹងហានិភ័យសន្ទនីយភាពក្នុងអំឡុងពេលមានវិបត្តិ។ ផ្អែកលើបទដ្ឋានខាងលើនេះ អនុបាតក្របខ័ណ្ឌសន្ទនីយភាព គឺជាផលធៀបរវាងទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានរបស់គ្រឹះស្ថាននីមួយៗ នឹងលំហូរចេញសុទ្ធដែលរំពឹងទុកក្នុងស្ថានភាពតានតឹងរយៈពេល ៣០ថ្ងៃ។ គ្រឹះស្ថានត្រូវរក្សាទុកជានិច្ចកាលនូវទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ សម្រាប់ទូទាត់លំហូរចេញសុទ្ធដែលរំពឹងទុក ទោះបីស្ថិតនៅក្នុងអំឡុងពេលដែលមានវិបត្តិក៏ដោយ។ ក្នុងបរិបទនេះ៖

- ទ្រព្យសកម្មដែលមាននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងជំពូកទី១ មិនត្រូវបានចាត់ទុកជាទ្រព្យសកម្មសន្ទនីយទេក្នុងអំឡុងពេលមានវិបត្តិ ដោយសារគ្រឹះស្ថានទាំងនោះអាចជួបបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ និងមិនមានលទ្ធភាពទូទាត់សងវិញបាន
- លំហូរចេញដែលកើតឡើងពីខ្នង់ទ្រព្យអកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀតត្រូវចាត់ទុកជាលំហូរចេញ ១០០% ដោយសារបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ និងតម្រូវការសន្ទនីយភាពជាបន្តបន្ទាប់របស់ពួកគេ
- លំហូរចេញផ្សេងៗទៀតត្រូវគណនា ដោយថ្លឹងតាមស្ថានភាពតានតឹងនៃខ្នង់នីមួយៗ ផ្អែកលើប្រភេទនៃសមភាគី
- លំហូរចូលអាចកាត់បន្ថយលំហូរចេញសុទ្ធបានមួយចំនួន ក្នុងករណីដែល (១) ជាលំហូរចូលដែលអាចជឿជាក់បាន មិនគ្រាន់តែជាលំហូរចូលដែលអាចមាននោះទេ និង (២) លំហូរចូលនេះត្រូវបានកំណត់ត្រឹម ៧៥% នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក។

ជំពូកទី ១
និយមន័យ

ក្នុងការអនុវត្តប្រកាសនេះ និយមន័យមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖ សំដៅដល់គ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រចុះបញ្ជីពីធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានស្រដៀងគ្នាដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីអាជ្ញាធរបញ្ញត្តិកម្ម ឬដោយអាជ្ញាធរត្រួតពិនិត្យធនាគារនៅបរទេស។

គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត៖ សំដៅដល់គ្រឹះស្ថាន ក្រៅពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមានក្រុមហ៊ុនធានារ៉ាប់រង មូលនិធិសោធននិវត្តន៍ និងក្រុមហ៊ុនមូលបត្រ ជាដើម។

ទ្រព្យសកម្មមិនជាប់កាតព្វកិច្ច៖ សំដៅដល់ទ្រព្យសកម្មមិនជាប់កាតព្វកិច្ចផ្លូវច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា ឬកាតព្វកិច្ចផ្សេងទៀត ដែលអាចឱ្យគ្រឹះស្ថានមានលទ្ធភាពជម្រះបញ្ជី លក់ ផ្ទេរ ឬចាត់ចែងបាន។

ចំណាត់ថ្នាក់ឥណទាន (Credit Rating)៖ សំដៅដល់ចំណាត់ថ្នាក់វាយតម្លៃដោយភ្នាក់ងារផ្តល់ចំណាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

សហគ្រាសខ្នាតតូចនិងមធ្យម៖ សំដៅដល់សហគ្រាសដែលកំណត់ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

ប្រភពទុនដុំ៖ សំដៅដល់ទ្រព្យអកម្ម និងកាតព្វកិច្ចទូទៅចំពោះនីតិបុគ្គល ដែលមានឥណប្រតិទានតិចជាង ឬ ស្មើ ៣០ ថ្ងៃ ឬមូលនិធិទាំងឡាយណាដែលអាចនឹងត្រូវទូទាត់ក្នុងអំឡុងពេល ៣០ ថ្ងៃ។

ប្រភពទុនដុំដែលមិនមានការធានា៖ សំដៅដល់ទ្រព្យអកម្ម ឬ កាតព្វកិច្ចទូទៅដែលមិនមានការធានាដោយទ្រព្យសកម្មជាក់លាក់។

ប្រភពទុនដែលមានការធានា៖ សំដៅដល់ទ្រព្យអកម្ម ឬ កាតព្វកិច្ចទូទៅដែលមានការធានា ដោយទ្រព្យសកម្មជាក់លាក់។

កិច្ចសន្យាឥណទាននិងសន្នីយភាព៖ សំដៅដល់កាតព្វកិច្ចផ្តល់ទុនទៅអនាគតតាមការសន្យា ទៅឱ្យសមភាគីខ្ចីដុំ ឬ រាយ។ ក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្នីយភាព កិច្ចសន្យានេះគិតបញ្ចូលតែកាតព្វកិច្ចដែលមិនអាចបដិសេធបាន ឬអាចបដិសេធបានដោយមានលក្ខខណ្ឌ។

កិច្ចសន្យាសន្នីយភាព (Liquidity facility)៖ សំដៅដល់កាតព្វកិច្ចផ្តល់ទុនទៅអនាគតតាមការសន្យាដែលអាចប្រើប្រាស់ជាបុនហិរញ្ញប្បទានដល់អតិថិជនណាមួយ ក្នុងស្ថានភាពដែលអតិថិជននោះមិនអាច roll-over បំណុល នៅលើទីផ្សារហិរញ្ញវត្ថុបាន (ឧទាហរណ៍៖ ផលបត្រពាណិជ្ជកម្ម)។ កិច្ចសន្យាឥណទានទុនបង្វិលសម្រាប់ក្រុមហ៊ុនសាជីវកម្មមិនត្រូវបានចាត់ទុកជាកិច្ចសន្យាសន្នីយភាពទេ ប៉ុន្តែជាកិច្ចសន្យាឥណទាន។

កាតព្វកិច្ចផ្តល់ទុនយថាភាព៖ សំដៅដល់ការផ្តល់ទុនដោយមានកិច្ចសន្យា ឬមិនមានកិច្ចសន្យា។ ការផ្តល់ទុនមិនមានកិច្ចសន្យា គឺជាការផ្តល់ទុនក្នុងស្ថានភាពតានតឹងនាពេលអនាគត ពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្ម ឬការគាំទ្រផលិតផល ឬសេវាកម្មនោះ ដែលធ្វើឱ្យតារាងតុល្យការមានការកើនឡើងដោយមិនមានការគ្រោងទុក។ ការខកខានក្នុងការផ្តល់ទុនទាំងនោះទៅតាមការរំពឹងទុករបស់អតិថិជន អាចធ្វើឱ្យគ្រឹះស្ថានប្រឈមនឹងហានិភ័យកេរ្តិ៍ឈ្មោះធ្ងន់ធ្ងរ។

ហិរញ្ញប្បទានពាណិជ្ជកម្ម៖ សំដៅដល់កាតព្វកិច្ចពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម ដែលកើតចេញពីការដឹកជញ្ជូនទំនិញ ឬការផ្តល់សេវាកម្ម ដូចជា លិខិតឥណទាន Documentary and Clean Collection បណ្ណនាំចូល (Import Bills) បណ្ណនាំចេញ (Export Bills) និងការធានាពាក់ព័ន្ធដោយផ្ទាល់នឹងកាតព្វកិច្ចហិរញ្ញប្បទានពាណិជ្ជកម្ម។

លំហូរចូលតាមកិច្ចសន្យាផ្សេងទៀត ទាំងមានការធានា ឬមិនមានការធានាក្នុងរយៈពេល៣០ថ្ងៃ៖ នៅពេលគិតអំពីការទូទាត់ឥណទាន គ្រឹះស្ថានត្រូវបញ្ចូលតែលំហូរចូលពីឥណទានស្តង់ដារ។ សម្រាប់ឧបករណ៍ឥណទានអាចប្រើប្រាស់ឡើងវិញ (Revolving Credit Facilities) គ្រឹះស្ថានត្រូវសន្មតថា

ផ្នែកខ្លះនៃឥណទាននោះ នឹងត្រូវប្រើប្រាស់បន្ត មានន័យថាសមតុល្យដក់សល់នឹងត្រូវថ្លឹង។ លំហូរចូលនៃឥណទាន ដែលមិនមានឥណប្រតិទានច្បាស់លាស់មិនត្រូវគិតបញ្ចូលទេ មានន័យថាត្រូវយកមកគិតបញ្ចូលតែលំហូរចូលតាមការសន្យាក្នុងអំឡុងពេល ៣០ ថ្ងៃប៉ុណ្ណោះ។

ជំពូកទី ២
ការបំពេញគំរូរបាយការណ៍អនុបាតក្របខ័ណ្ឌសន្ធនីយភាព

ឯកតាត្រូវរាយការណ៍ គិតជា "លានរៀល"។

១- ទ្រព្យសកម្មសន្ធនីយដែលអាចទទួលយកបាន

ប្រាក់បញ្ញើនៅ ឬការឱ្យខ្ចីទៅ "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ដូចមានកំណត់ក្នុងជំពូកទី១ ខាងលើ មិនត្រូវបានចាត់ទុកជាទ្រព្យសកម្មសន្ធនីយដែលអាចទទួលយកបានទេ។ ប្រការនេះ គឺដើម្បីកាត់បន្ថយហានិភ័យសន្ធនីយភាព បណ្តាលមកពីកង្វះសន្ធនីយភាពនៅគ្រឹះស្ថានមួយ ដែលអាចរាលដាលដល់គ្រឹះស្ថានផ្សេងទៀត និងដើម្បីឆ្លុះបញ្ចាំងពីហានិភ័យដែលគ្រឹះស្ថានផ្សេងទៀតមិនអាចទូទាត់សងបំណុលបានក្នុងស្ថានភាពតានតឹង។

ក. ទ្រព្យសកម្មសន្ធនីយដែលមានគុណភាពខ្ពស់

ខ្នង់ ១.១១៖ សាច់ប្រាក់ និងកាសក្នុងដៃ

ខ្នង់ ១.១២៖ អតិរេកប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា

ខ្នង់ ១.១៣៖ ប្រាក់បម្រុងកាតព្វកិច្ច១00% នៅធនាគារជាតិនៃកម្ពុជា ជាប្រាក់រៀល និងត្រូវថ្លឹង ១00%។

ខ្នង់ ១.១៤៖ ប្រាក់បម្រុងកាតព្វកិច្ច១00% នៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក និងត្រូវថ្លឹង ៧0% ដោយសារធនាគារជាតិនៃកម្ពុជាមិនមែនជាស្ថាប័នបោះផ្សាយក្រដាសប្រាក់ដុល្លារអាមេរិក។

ខ្នង់ ១.១៥៖ ទឹកប្រាក់នៃគណនីចរន្ត និងគណនីប្រាក់បញ្ញើមានកាលកំណត់នៅ ធនាគារជាតិនៃកម្ពុជាដោយមិនគិតពីឥណប្រតិទាន។ ខ្នង់នេះមិនរាប់បញ្ចូលទឹកប្រាក់ក្នុងគណនីទូទាត់ និងគណនីប្រាក់ធានាលើដើមទុនទេ។

ខ្នង់ ១.១៦៖ មូលបត្រអាចជួញដូរបានមិនជាប់កាតព្វកិច្ច និងមូលបត្រផ្សេងទៀតមិនជាប់កាតព្វកិច្ចដែលបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា និងឥណទានទៅធនាគារជាតិនៃកម្ពុជាដែលអាចប្រើប្រាស់បានភ្លាមក្នុងស្ថានភាពតានតឹង។

ខ្នង់ ១.១៧៖ តម្លៃទីផ្សារនៃមូលបត្របំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ដែលមានចំណាត់ថ្នាក់ AAA ទៅ AA- និងធនាគារសម្រាប់ការទូទាត់អន្តរជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃសហគមន៍អឺរ៉ុប សហភាពអឺរ៉ុប និងធនាគារអភិវឌ្ឍន៍ ដែលមានចំណាត់ថ្នាក់ AAA។

ខ. ទ្រព្យសកម្មសន្ទនីយផ្សេងទៀត

ខ្នង់ ១.២១៖ តម្លៃទីផ្សារនៃមូលបត្របំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ដែលមានចំណាត់ថ្នាក់ A+ ទៅ A-។

ខ្នង់ ១.២២៖ តម្លៃទីផ្សារនៃមូលបត្របំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយសហគ្រាស/អង្គភាពសាធារណៈ (PSEs) ធនាគារអភិវឌ្ឍន៍ដែលមិនរាប់បញ្ចូលក្នុងខ្នង់ ១.១៧ ដែលមានចំណាត់ថ្នាក់ខ្ពស់ជាង ឬ ស្មើ A-។

ខ្នង់ ១.២៣៖ តម្លៃទីផ្សារនៃមូលបត្របំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចដែលអាចទទួលយកបាន និង Covered Bonds ។ ទ្រព្យសកម្មនេះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មិនមែនជាមូលបត្របំណុលសាជីវកម្ម ដែលបោះផ្សាយដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនសម្ព័ន្ធញាតិ និងជាទ្រព្យសកម្ម plain vanilla ដែលមានការវាយតម្លៃជាស្រេចផ្អែកលើវិធីសាស្ត្រស្តង់ដារ (standard methods) និងមិនផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន (private knowledge)
- មិនមែនជា covered bonds ដែលបោះផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនសម្ព័ន្ធញាតិ
- ទ្រព្យសកម្មដែលមានចំណាត់ថ្នាក់ឥណទានយ៉ាងតិច AA-
- ត្រូវបានជួញដូរក្នុងទីផ្សារ repo និងទីផ្សារសាច់ប្រាក់ (cash market) ទូលាយនិងសកម្ម ដែលមានលក្ខណៈប្រមូលផ្តុំទាប (low concentration) និង
- ត្រូវមានកំណត់ត្រាបញ្ជាក់ថាជាប្រភពសន្ទនីយភាពដែលអាចជឿជាក់បាននៅក្នុងទីផ្សារ ទោះបីស្ថិតក្នុងស្ថានភាពតានតឹងក៏ដោយ។

ខ្នង់ ១.២៤៖ មាសដុំ (Metal gold) និងវិញ្ញាបនបត្រកាន់កាប់មាស នៅក្នុងគណនីរបស់គ្រឹះស្ថាន។ ខ្នង់នេះត្រូវថ្លឹងត្រឹមតែ ៧៥% ដោយសារតែបម្រែបម្រួលថ្លៃនៃទ្រព្យសកម្មនេះ។

២- លំហូរចេញនៃសាច់ប្រាក់

ក. លំហូរចេញនៃប្រាក់បញ្ញើរាយ

ប្រាក់បញ្ញើរាយសំដៅដល់ប្រាក់បញ្ញើរបស់រូបវន្តបុគ្គល។ ប្រាក់បញ្ញើរាយដែលប្រើសម្រាប់គណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាពរួមមាន ប្រាក់បញ្ញើសន្សំ ប្រាក់បញ្ញើអាចដកបានតាមតម្រូវការ និងប្រាក់បញ្ញើមានកាលកំណត់ដែលមានឥណប្រតិទានឬសេចក្តីជូនដំណឹងពីការដកប្រាក់ក្នុងអំឡុងពេល ៣០ ថ្ងៃ។ ប្រភពទុនមិនមានការធានាពីសហគ្រាសខ្នាតតូចនិងមធ្យម ដូចដែលបានកំណត់និយមន័យក្នុងជំពូកទី១ខាងលើ អាចចាត់ទុកជាប្រភេទប្រាក់បញ្ញើរាយ ប្រសិនបើប្រភពទុនរួមសរុបដែលទទួលបានពីសហគ្រាសខ្នាតតូចនិងមធ្យម មានចំនួនតិចជាង ឬ ស្មើ ១០០.០០០ ដុល្លារអាមេរិក ឬសមមូល។ ចំណែកប្រភពទុនផ្សេងទៀត ដែលមិនបំពេញតាមលក្ខខណ្ឌខាងលើនេះ ត្រូវចាត់ទុកជាប្រភពទុនដុំមិនមានការធានា (ខ្នង់ ២.២១ ឬ ២.២២)។

ប្រាក់បញ្ញើរាយត្រូវបានបែងចែកជា "ប្រាក់បញ្ញើមានស្ថិរភាព" និង "ប្រាក់បញ្ញើមិនសូវមានស្ថិរភាព" ដែលមានអត្រាលំហូរចេញខុសៗគ្នា។

ខ្នង់ ២.១១៖ **"ប្រាក់បញ្ញើមានស្ថិរភាព"** គឺជាប្រាក់បញ្ញើទាំងឡាយណាដែលធានាទាំងស្រុងដោយគម្រោងធានារ៉ាប់រងលើប្រាក់បញ្ញើដែលក្នុងនោះរួមមាន ប្រាក់បញ្ញើដកតាមតម្រូវការ ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ដែលមានឥណប្រតិទានៅសល់ក្នុងអំឡុងពេល ៣០ ថ្ងៃ ប៉ុណ្ណោះ។ ខ្នង់នេះត្រូវថ្លឹង ៥%។

"ការធានាទាំងស្រុង" មានន័យថាទំហំប្រាក់បញ្ញើ ដែលនឹងត្រូវទូទាត់សងត្រឹមកម្រិតអតិបរមា ដោយប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើ។ សម្រាប់ទំហំទឹកប្រាក់ដែលលើសពីកម្រិតទូទាត់សងអតិបរមា ដោយប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើ ត្រូវចាត់ទុកជា "ប្រាក់បញ្ញើមិនសូវមានស្ថិរភាព"។

ខ្នង់ ២.១២៖ ប្រាក់បញ្ញើរាយទាំងអស់ដែលមិនបំពេញលក្ខខណ្ឌក្នុងខ្នង់ ២.១១ ខាងលើ ត្រូវចាត់ទុកជា "ប្រាក់បញ្ញើមិនសូវមានស្ថិរភាព" នៅក្នុងខ្នង់នេះ។ ប្រាក់បញ្ញើនេះជាប្រាក់បញ្ញើរាយរួមមាន ប្រាក់បញ្ញើដកតាមតម្រូវការ ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ (មិនគិតពីឥណប្រតិទាន)។ ខ្នង់នេះត្រូវថ្លឹង ១៥%។

ខ. ប្រភពទុនដុំមិនមានការធានា

សម្រាប់ការគណនាអនុបាតនេះ ប្រភពទុនដុំមិនមានការធានា គឺជាទ្រព្យអកម្ម និងកាតព្វកិច្ចទូទៅរបស់នីតិបុគ្គល និងមិនមានការធានា។ ប្រភពទុនដុំដែលគិតបញ្ចូលក្នុងការគណនា ជាប្រភពទុនដែលអាចត្រូវបានដកចេញក្នុងរយៈពេល ៣០ ថ្ងៃ។ ប្រភពទុនដុំផ្សេងទៀតដែលអាចត្រូវបានដកចេញក្នុងរយៈពេលលើសពី ៣០ ថ្ងៃ មិនត្រូវរាប់បញ្ចូលក្នុងការគណនាទេ មានន័យថាអ្នកផ្តល់ទុននឹងមិនដកទុននោះត្រឡប់ទៅវិញ មុនកាលកំណត់នៃកិច្ចសន្យា។ ប្រភពទុនដុំមិនមានការធានា គឺប្រាក់បញ្ញើ រួមទាំងប្រភពទុនដុំផ្សេងទៀត ដូចជា បណ្ណបំណុល សញ្ញាបណ្ណ និងមូលបត្របំណុលជាដើម។

ការបង់ភាគលាភ និងការប្រាក់តាមកិច្ចសន្យា ត្រូវរាយការណ៍ ក្នុងខ្នង់ ២.៨១។

ខ្នង់ ២.២១៖ គ្រឹះស្ថានមួយចំនួនតម្រូវឱ្យអតិថិជនជានីតិបុគ្គល (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) ដាក់ប្រាក់បញ្ញើដើម្បីសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធទូទាត់ និងជាត់ទាត់។ ប្រាក់បញ្ញើដែលអាចរាយការណ៍ក្នុងខ្នង់ ២.២១ ជាប្រាក់បញ្ញើដែលប្រើប្រាស់សម្រាប់រាល់តម្រូវការប្រតិបត្តិការ ដូចខាងក្រោម៖

- ប្រតិបត្តិការទាំងនោះប្រើប្រាស់សម្រាប់ ការទូទាត់ គណនីរក្សាទុក (Custody) និង/ឬ ការគ្រប់គ្រងសាច់ប្រាក់សម្រាប់អតិថិជន។ ប្រាក់បញ្ញើដែលកើតចេញពីប្រតិបត្តិការធនាគារទំនាក់ទំនង និងកើតឡើងពីក្រុមហ៊ុនមូលបត្រ មិនតម្រូវឱ្យរាយការណ៍ក្នុងខ្នង់ ២.២១ ប៉ុន្តែ ត្រូវរាយការណ៍ក្នុង ខ្នង់ ២.២២ ដល់ ខ្នង់ ២.២៦។

- គ្រឹះស្ថានត្រូវផ្តល់សេវាខាងលើក្នុងនាមជាតតិយភាគីឯករាជ្យតាមការតម្រូវរបស់អតិថិជន
- សេវាកម្មនេះត្រូវបានផ្តល់ដោយគ្រឹះស្ថានស្របតាមកិច្ចសន្យា
- ការបញ្ចប់កិច្ចសន្យាត្រូវជូនដំណឹងជាមុនយ៉ាងតិច ៣០ ថ្ងៃ ឬការបញ្ចប់កិច្ចសន្យានេះអាចប្រឈមនឹងសោហ៊ុយចំណាយ និងខាតបង់ច្រើន
- ប្រាក់បញ្ញើត្រូវដាក់ចូលក្នុងគណនីដែលមានគោលដៅច្បាស់លាស់
- ប្រាក់បញ្ញើត្រូវបែងចែកតាមផលិតផលនៃសេវាខាងលើដែលផ្តល់ឱ្យដោយគ្រឹះស្ថាន។ សមតុល្យប្រាក់បញ្ញើដែលលើសពីតម្រូវការនៃការប្រើប្រាស់សេវាខាងលើ ត្រូវរាយការណ៍ក្នុងខ្ទង់ ២.២២ ដល់ ២.២៦។ គ្រឹះស្ថានត្រូវមានវិធីសាស្ត្រច្បាស់លាស់ក្នុងការកំណត់សមតុល្យប្រាក់បញ្ញើដែលលើស ហើយសមតុល្យដែលលើសនោះ ត្រូវដកចេញពីខ្ទង់ ២.២១។

ធនាគារជាតិនៃកម្ពុជា អាចបដិសេធប្រាក់បញ្ញើដែលត្រូវរាយការណ៍ក្នុងខ្ទង់ ២.២១ ក្នុងករណីពិនិត្យឃើញថាខ្ទង់នេះមានសមតុល្យធំ ប៉ុន្តែប្រមូលផ្តុំដោយចំនួនអតិថិជនតិច (Concentration Risk)។

ខ្ទង់ ២.២២៖ រាយការណ៍ទំហំទឹកប្រាក់នៃប្រាក់បញ្ញើដុំមិនមែនប្រតិបត្តិការ និងមិនមានការធានាពីគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ។

ខ្ទង់ ២.២៣៖ រាយការណ៍ទំហំទឹកប្រាក់នៃប្រាក់បញ្ញើដុំមិនមែនប្រតិបត្តិការ និងមិនមានការធានាពីស្ថាប័នអធិបតេយ្យ ធនាគារកណ្តាល និងសហគ្រាស/អង្គភាពសាធារណៈ។

ខ្ទង់ ២.២៤៖ រាយការណ៍ទំហំទឹកប្រាក់នៃប្រាក់បញ្ញើដុំមិនមែនប្រតិបត្តិការ និងមិនមានការធានាពី "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ដូចកំណត់នៅក្នុងជំពូកទី១ ខាងលើ។

ខ្ទង់ ២.២៥៖ រាយការណ៍ទំហំទឹកប្រាក់នៃប្រាក់បញ្ញើដុំមិនមែនប្រតិបត្តិការ និងមិនមានការធានាពីនីតិបុគ្គលផ្សេងៗរួមទាំង "គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត" ដូចកំណត់នៅក្នុងជំពូកទី១ ខាងលើ។

ខ្ទង់ ២.២៦៖ រាយការណ៍ទំហំលំហូរចេញនៃសាច់ប្រាក់ពីប្រភពទុនដុំមិនមានការធានាផ្សេងៗទៀត ដូចជា បណ្ណបំណុល សញ្ញាបណ្ណ និងមូលបត្របំណុលផ្សេងទៀតដែលបោះផ្សាយដោយមិនគិតពីប្រភេទនៃអ្នកកាន់កាប់។

គ. ប្រភពទុនមានការធានា

សម្រាប់ការគណនាអនុបាតនេះ ប្រភពទុនមានការធានា គឺជាទ្រព្យអកម្ម និងកាតព្វកិច្ចទូទៅដែលមានទ្រព្យបញ្ចាំ។ គ្រឹះស្ថានត្រូវគណនាទំហំទឹកប្រាក់នៃលំហូរចេញតាមរយៈប្រតិបត្តិការ Repo, Collateral Swap និង Forward ជាដើម ។

ខ្នង់ ២.៣១៖ រាយការណ៍សមតុល្យទុនមានការធានា ដែលដល់ឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ និងធានាដោយទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ (ខ្នង់ ១.១១ ដល់ ១.១៧)។

ខ្នង់ ២.៣២៖ រាយការណ៍សមតុល្យទុនមានការធានា ដែលដល់ឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ និងធានាដោយទ្រព្យសកម្មសន្ទនីយផ្សេងទៀត (ខ្នង់ ១.២១ ដល់ ១.២៣)។

ខ្នង់ ២.៣៣៖ រាយការណ៍សមតុល្យទុនមានការធានា ដែលដល់ឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ និងធានាដោយមាស (ខ្នង់ ១.២៤)។

ខ្នង់ ២.៣៤៖ រាយការណ៍សមតុល្យទុនមានការធានា ដែលដល់ឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ និងធានាដោយទ្រព្យសកម្មផ្សេងទៀតក្រៅពីខ្នង់ ១.១១ ដល់ ១.២៤។

ឃ. តម្រូវការសន្ទនីយភាពពាក់ព័ន្ធនឹងប្រតិបត្តិការឧបករណ៍និស្សន្ទ និងប្រតិបត្តិការផ្សេងទៀត

ខ្នង់ ២.៤១៖ គ្រឹះស្ថានត្រូវគណនាលំហូរចេញ និងលំហូរចូលនៃប្រតិបត្តិការឧបករណ៍និស្សន្ទតាមកិច្ចសន្យាតាមវិធីសាស្ត្រ Mark-to-Market ឬការវាយតម្លៃទូទៅ។ លំហូរចេញ និងលំហូរចូលនៃប្រតិបត្តិការឧបករណ៍និស្សន្ទ ដែលត្រូវរាយការណ៍នៅក្នុងខ្នង់ ២.៤១ រួមមានបុព្វលាភ (Premium) និង margin call ឬប្រតិបត្តិការប្រហាក់ប្រហែល ការទូទាត់សំណងជាប្រាក់ (Possible monetary compensations) ការទូទាត់ការប្រាក់ និងប្រាក់ដើម។ លំហូរសាច់ប្រាក់អាចគណនាផ្អែកលើមូលដ្ឋានកាត់កង (net basis) ដោយសមភាគីនៅពេលដែលមានចែងក្នុងកិច្ចសន្យា។ កិច្ចសន្យា Option ត្រូវសន្មតថានឹងអនុវត្តនៅពេលដែលមានចំណេញ (in the money)។

គ្រឹះស្ថានអាចកាត់កងរវាងលំហូរចេញ និងលំហូរចូលនៃសាច់ប្រាក់ ដែលកើតឡើងពីឧបករណ៍និស្សន្ទនៃការប្តូររូបិយប័ណ្ណបរទេស (Foreign exchange derivative) ទោះបីមិនមានចែងក្នុងកិច្ចសន្យាក៏ដោយ ប្រសិនបើប្រតិបត្តិការនោះពាក់ព័ន្ធនឹងការកាត់កងប្រាក់ដើមទាំងស្រុងក្នុងថ្ងៃតែមួយ។

គ្រឹះស្ថានមិនត្រូវរាប់បញ្ចូលតម្រូវការសន្ទនីយភាពទាំងឡាយណាដែលកើតចេញពីការកើនឡើងនៃតម្រូវការការធានាបន្ថែមដោយសារបម្រែបម្រួលថ្លៃលើទីផ្សារ ឬដោយសារទ្រព្យធានាធ្លាក់ថ្លៃ។ តម្រូវការសន្ទនីយភាពទាំងនេះ នឹងត្រូវរាយការណ៍ក្នុងខ្នង់ ២.៤២។

នៅពេលទូទាត់ប្រតិបត្តិការឧបករណ៍និស្សន្ទដែលធានាដោយទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ និងទ្រព្យសកម្មសន្ទនីយផ្សេងទៀត គ្រឹះស្ថានត្រូវគណនាលំហូរចេញនៃសាច់ប្រាក់ ដោយកាត់កងនូវលំហូរចូលទ្រព្យធានា ឬសាច់ប្រាក់ផ្សេងៗ ដែលកើតចេញពីកាតព្វកិច្ចតាមការសន្យា សម្រាប់សាច់ប្រាក់ ឬទ្រព្យធានាដែលផ្តល់ឱ្យដោយសមភាគី ប្រសិនបើគ្រឹះស្ថានមានសិទ្ធិប្រើប្រាស់វត្ថុធានានោះឡើងវិញ។ ខ្នង់នេះត្រូវថ្លឹង ១០០%។

ខ្នង់ ២.៤២៖ ខ្នង់នេះសម្រាប់ "លំហូរចេញនៃទ្រព្យធានាលើឧបករណ៍និស្សន្ទ" ដោយសារទីផ្សារទាមទារឱ្យមានទ្រព្យធានាសម្រាប់បម្រែបម្រួលតម្លៃទីផ្សារ (Mark-to-market) នៃ

ឧបករណ៍និស្សន្ទ និងប្រតិបត្តិការផ្សេងទៀត។ គ្រឹះស្ថានអាចប្រឈមនឹងហានិភ័យសន្ទនីយភាព នៅពេលមានបម្រែបម្រួលតម្លៃទ្រព្យធានាទាំងនេះ នៅពេលគ្រឹះស្ថានចុះកិច្ចសន្យាបញ្ចាំ ដើម្បីការពារខ្លួនឯងទៅនឹងបម្រែបម្រួលនៃតម្លៃឧបករណ៍និស្សន្ទលើទីផ្សារ និងប្រតិបត្តិការផ្សេងទៀត គ្រឹះស្ថានត្រូវរាយការណ៍ខ្ទង់នេះនូវលំហូរចេញនៃសាច់ប្រាក់ដែលបណ្តាលមកពីបម្រែបម្រួលតម្លៃទីផ្សារទាក់ទងទៅនឹងទ្រព្យធានា។ ការគណនាត្រូវធ្វើឡើង តាមវិធីសាស្ត្រមើលលើប្រវត្តិនៃប្រតិបត្តិការ (Look Back Approach)។ ទំហំទឹកប្រាក់ដែលត្រូវរាយការណ៍ គឺជាលំហូរសុទ្ធនៃតម្លៃវត្ថុធានាប្រចាំខែធំជាងគេ (តម្លៃដាច់ខាត) ក្នុងរយៈពេល ២៤ ខែ ចុងក្រោយ។ លំហូរសុទ្ធនៃតម្លៃវត្ថុធានា (តម្លៃដាច់ខាត) គឺជាតម្លៃកាត់កងរវាងលំហូរចេញនិងលំហូរចូល ទោះបីជាលំហូរចេញនិងលំហូរចូលទាំងនោះមានចែងនៅក្នុងកិច្ចសន្យាដែលអាចកាត់កងបានរួចហើយក៏ដោយ។

ខ្ទង់ ២.៤៣៖ រាយការណ៍ពីតម្រូវការសន្ទនីយភាពពាក់ព័ន្ធបម្រែបម្រួលតម្លៃទីផ្សារនៃទ្រព្យធានារបស់ឧបករណ៍និស្សន្ទ ឬប្រតិបត្តិការផ្សេងទៀត ក្នុងករណីមានចែងក្នុងកិច្ចសន្យា។ ការខាតបង់លើតម្លៃនៃទ្រព្យធានាទាំងនេះ ត្រូវថ្លឹង ០% ប្រសិនបើទ្រព្យធានាទាំងនេះជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ និងត្រូវថ្លឹង ២០% ចំពោះទ្រព្យសកម្មផ្សេងទៀត។ តម្លៃទ្រព្យធានាដែលលើស ដែលសមភាគីអាចទាមទារទៅវិញត្រូវរាយការណ៍បន្ថែមក្នុងខ្ទង់នេះ ១០០%។

ង. កិច្ចសន្យា (Committed Facilities)

កិច្ចសន្យាឥណទាន និងកិច្ចសន្យាសន្ទនីយភាព សំដៅដល់កិច្ចសន្យា ឬកាតព្វកិច្ចក្នុងការផ្តល់ទុនក្នុងពេលអនាគតដល់សមភាគី (ដុំ ឬវាយ)។ សម្រាប់ការគណនាអនុបាតនេះ កិច្ចសន្យាទាំងនេះអាចបញ្ចូលបានតែក្នុងករណីជាកិច្ចសន្យាដែលមិនអាចបដិសេធបាន ឬអាចបដិសេធបានដោយមានលក្ខខណ្ឌ។ ចំណែកកិច្ចសន្យាដែលអាចបដិសេធបានដោយគ្មានលក្ខខណ្ឌ ត្រូវរាយការណ៍ក្នុងខ្ទង់ ២.៧១។ កិច្ចសន្យាសន្ទនីយភាពសំដៅដល់កិច្ចសន្យាដែលមិនអាចបដិសេធបានលើទឹកប្រាក់ដែលមិនទាន់ប្រើប្រាស់ សម្រាប់បំពេញតម្រូវការសន្ទនីយភាពដែលកើតមាន ដូចកំណត់ក្នុងជំពូកទី១។

ខ្ទង់ ២.៥១៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាឥណទានមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់អតិថិជនជារូបវន្តបុគ្គល និងអតិថិជនជាសហគ្រាសខ្នាតតូចនិងមធ្យម។

ខ្ទង់ ២.៥២៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់អតិថិជនជារូបវន្តបុគ្គល និងអតិថិជនជាសហគ្រាសខ្នាតតូចនិងមធ្យម។

ខ្ទង់ ២.៥៣៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាឥណទានមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់ក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ធនាគារអភិវឌ្ឍ និងសហគ្រាស/អង្គភាពសាធារណៈ។

ខ្នង់ ២.៥៤៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់ក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ធនាគារអភិវឌ្ឍន៍ និងសហគ្រាស/អង្គភាពសាធារណៈ។

ខ្នង់ ២.៥៥៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាឥណទានមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចកំណត់ក្នុងជំពូកទី១។

ខ្នង់ ២.៥៦៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចកំណត់ក្នុងជំពូកទី១។

ខ្នង់ ២.៥៧៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាឥណទានមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដូចកំណត់ក្នុងជំពូកទី១។

ខ្នង់ ២.៥៨៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដូចកំណត់ក្នុងជំពូកទី១។

ខ្នង់ ២.៥៩៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាឥណទានមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់នីតិបុគ្គលផ្សេងទៀត និងរាយការណ៍ទំហំទឹកប្រាក់នៃកាតព្វកិច្ចផ្តល់ទុនផ្សេងទៀតក្នុងរយៈពេល ៣០ ថ្ងៃ ដែលមិនបានរាយការណ៍នៅក្នុងខ្នង់ផ្សេងទៀត។

ខ្នង់ ២.៦០៖ រាយការណ៍ទំហំទឹកប្រាក់ក្នុងកិច្ចសន្យាសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់នីតិបុគ្គលផ្សេងទៀត។

ច. បំណុលយថាភាពផ្សេងៗ

បំណុលយថាភាពផ្សេងៗ អាចជាបំណុលជាប់កិច្ចសន្យា ឬមិនជាប់កិច្ចសន្យា។ នៅពេលដែលគិតពីទំហំទឹកប្រាក់នៃលំហូរចេញដែលអាចកើតមាន គ្រឹះស្ថានត្រូវពិចារណាទៅលើផលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះក្នុងករណីមិនបានបំពេញតម្រូវការអតិថិជនរបស់ខ្លួន។

ខ្នង់ ២.៧១៖ រាយការណ៍ទំហំទឹកប្រាក់នៃកិច្ចសន្យាអាចបដិសេធបានដោយគ្មានលក្ខខណ្ឌ ដែលគ្រឹះស្ថានមានសិទ្ធិបដិសេធការដកសមតុល្យដែលមិនទាន់ប្រើប្រាស់របស់អតិថិជន។ ខ្នង់នេះក៏រាប់បញ្ចូលកិច្ចសន្យា និងកាតព្វកិច្ចដែលមានលក្ខខណ្ឌក្នុងការផ្តល់ទុនដែលមិនបានរាយការណ៍ក្នុងខ្នង់ ២.៧២ និង ២.៧៣។

ខ្នង់ ២.៧២៖ សម្រាប់កាតព្វកិច្ចទុនយថាភាពដែលជាកាតព្វកិច្ចទាក់ទងនឹងហិរញ្ញប្បទានពាណិជ្ជកម្ម ខ្នង់នេះត្រូវរាយការណ៍ទឹកប្រាក់លំហូរចេញសុទ្ធប្រចាំខែជាមធ្យមក្នុងអំឡុងពេល ១២ ខែ ចុងក្រោយ ប្រសិនបើលំហូរចេញនៃសាច់ប្រាក់ធំជាងលំហូរចូលនៃសាច់ប្រាក់។ ផ្ទុយទៅវិញ ត្រូវរាយការណ៍ "សូន្យ" ប្រសិនបើលំហូរចូលនៃសាច់ប្រាក់ធំជាងលំហូរចេញនៃសាច់ប្រាក់។ ហិរញ្ញប្បទានពាណិជ្ជកម្ម រួមមានកាតព្វកិច្ចទាក់ទងផ្នាល់នឹងពាណិជ្ជកម្ម ដូចជា Trade Discount និង Trade Debt Assignment, Documentary និង Clean Collection, បណ្ណនាំចូល (Import Bills) បណ្ណនាំចេញ (Export Bills) និងការធានាពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញប្បទានពាណិជ្ជកម្ម ដូចជាការធានាលើការដឹកជញ្ជូន។

ខ្នង់ ២.៧៣៖ សម្រាប់កាតព្វកិច្ចទុនយថាភាពដែលកើតពីការធានា និងលិខិតឥណទានក្រៅពីកាតព្វកិច្ចហិរញ្ញប្បទានពាណិជ្ជកម្ម ខ្នង់នេះត្រូវរាយការណ៍ទឹកប្រាក់លំហូរចេញសុទ្ធប្រចាំខែជាមធ្យមក្នុងអំឡុងពេល ១២ ខែ ចុងក្រោយ ប្រសិនបើលំហូរចេញនៃសាច់ប្រាក់ធំជាងលំហូរចូលនៃសាច់ប្រាក់។ ផ្ទុយទៅវិញ ត្រូវរាយការណ៍ "សូន្យ" ប្រសិនបើលំហូរចូលនៃសាច់ប្រាក់ធំជាងលំហូរចេញនៃសាច់ប្រាក់។

ឆ. លំហូរចេញនៃសាច់ប្រាក់តាមកិច្ចសន្យាផ្សេងទៀត

ខ្នង់ ២.៨១៖ រាយការណ៍លំហូរចេញនៃសាច់ប្រាក់តាមកិច្ចសន្យា ក្នុងអំឡុងពេល ៣០ ថ្ងៃ ដូចជាលំហូរចេញនៃសាច់ប្រាក់ដើម្បីទូទាត់ Unsecured Collateral Borrowings បំណុលផ្សេងៗ (Unsecured Debt Borrowing), Uncovered Short Position, ភាគលាភ (Dividends) និងការទូទាត់សងការប្រាក់ (Contractual Interest Payments)។ លំហូរចេញដែលទាក់ទងនឹងចំណាយប្រតិបត្តិការរបស់គ្រឹះស្ថាន មិនត្រូវបានរាប់បញ្ចូលនៅក្នុងការគណនាអនុបាតនេះទេ។

៣. លំហូរចូលនៃសាច់ប្រាក់

នៅពេលគណនាលំហូរចូលនៃសាច់ប្រាក់ គ្រឹះស្ថានត្រូវគិតតែលំហូរចូលទ្រព្យសកម្មស្តង់ដារដក់សល់ រួមទាំង ការប្រាក់បង្គរដែលត្រូវទូទាត់ ដោយមិនរំពឹងថាមានការខកខានទូទាត់សងក្នុងរយៈពេល ៣០ ថ្ងៃ។ ជាគោលការណ៍ លំហូរចូលយថាភាពមិនត្រូវបានរាប់បញ្ចូលក្នុងលំហូរចូលនៃសាច់ប្រាក់សរុបទេ។ ការថ្លឹងលំហូរចូលនៃសាច់ប្រាក់ ត្រូវយោងលើការសន្មត ឬការរំពឹងទុកនៃការផ្តល់ឥណទានរបស់គ្រឹះស្ថាន ផ្អែកលើប្រភេទសមភាគី។

កម្រិតកំណត់លើលំហូរចូលសរុបនៃសាច់ប្រាក់៖

លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុកត្រូវបានកំណត់ត្រឹម ៧៥% (ចិតសិបប្រាំភាគរយ) នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក ដើម្បីចៀសវាងការពឹងផ្អែកទាំងស្រុងលើលំហូរចូលនៃសាច់ប្រាក់ ក្នុងការបំពេញតម្រូវការសន្ទនីយភាព និងដើម្បីធានាបាននូវកម្រិតអប្បបរមានៃទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន។ នេះមានន័យថា គ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានស្មើនឹង ២៥% (ម្ភៃប្រាំភាគរយ) នៃលំហូរចេញសរុបនៃសាច់ប្រាក់ដែលរំពឹងទុក។

កម្រិតកំណត់បន្ថែម៖

លំហូរចូលនៃសាច់ប្រាក់ដែលកើតចេញពីកិច្ចសន្យាផ្តល់ទុនផ្លូវការនិងមិនអាចបដិសេធបាន (formalized and irrevocable committed fund facilities) ជាមួយទីស្នាក់ការកណ្តាលរបស់សាខា ឬក្រុមហ៊ុនមេរបស់បុត្តសម្ព័ន្ធធនាគារបរទេស ត្រូវបានកំណត់ត្រឹម ៤០% (សែសិបភាគរយ) នៃលំហូរចេញសរុបនៃសាច់ប្រាក់ដែលរំពឹងទុក ដើម្បីចៀសវាងការពឹងផ្អែកខ្លាំងទៅលើលំហូរចូលពីសមភាគីតែមួយ (សូមមើលខ្នង់ ៣.២២) ។

កិច្ចសន្យាឥណទាននិងសន្ទនីយភាព ជាមួយគ្រឹះស្ថានដទៃទៀត៖

កិច្ចសន្យាឥណទាននិងសន្ទនីយភាពមិនទាន់ប្រើប្រាស់ជាមួយគ្រឹះស្ថានដទៃទៀត ត្រូវបានថ្លឹង ០% (សូន្យភាគរយ) នៃលំហូរចូល លើកលែងតែកិច្ចសន្យាចំពោះសាខានិងបុត្តសម្ព័ន្ធរបស់ធនាគារបរទេស ដែលបានអនុញ្ញាតស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ព្រោះថាក្នុងស្ថានភាពតានតឹង គ្រឹះស្ថានអាចនឹងមិនមានលទ្ធភាពប្រើប្រាស់កិច្ចសន្យាទាំងនោះទេ។

ក- កិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ (Securities Borrowing)

ខ្នង់ ៣.១១៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ និងមិនត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ (not re-hypothecated)។ គ្រឹះស្ថានត្រូវសន្មតថា កិច្ចសន្យានេះនឹងត្រូវបន្ត (Rolled over) ឡើងវិញ ហេតុនេះនឹងគ្មានលំហូរចូលនៃសាច់ប្រាក់ទេ (ថ្លឹង ០%)។

ខ្នង់ ៣.១២៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយផ្សេងទៀត និងមិនត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ។ ដោយយោងលើគុណភាពនៃទ្រព្យសកម្មទាំងនោះ គ្រឹះស្ថានត្រូវសន្មតថាកិច្ចសន្យានេះ មិនអាចបន្តឡើងវិញទេ (ថ្លឹង ២៥%)។

ខ្នង់ ៣.១៣៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយមិនមែនជា ទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ឬទ្រព្យសកម្មសន្ទនីយផ្សេងទៀត និងមិនត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ។ ដោយយោងលើគុណភាពនៃទ្រព្យសកម្មទាំងនោះ គ្រឹះស្ថានត្រូវសន្មតថាកិច្ចសន្យានេះមិនអាចបន្តឡើងវិញទេ (ថ្លឹង ១០០%)។

ខ្នង់ ៣.១៤៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ និងត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ។ គ្រឹះស្ថានត្រូវសន្មតថា កិច្ចសន្យានេះអាចបន្តឡើងវិញ ដើម្បីទូទាត់ short position (ថ្លឹង ០%)។

ខ្នង់ ៣.១៥៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយផ្សេងទៀត និងត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ។ គ្រឹះស្ថានត្រូវសន្មតថា កិច្ចសន្យានេះអាចបន្តឡើងវិញ ដើម្បីទូទាត់ short position (ថ្លឹង ០%)។

ខ្នង់ ៣.១៦៖ រាយការណ៍សមតុល្យនៃកិច្ចសន្យា Reverse-repo និងកម្ចីមូលបត្រ ដែលមានឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ ក្នុងករណីវត្ថុធានាជាទ្រព្យសកម្មសន្ទនីយមិន

មែនជា ទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ឬទ្រព្យសកម្មសន្ទនីយផ្សេងទៀត និងត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ។ គ្រឹះស្ថានត្រូវសន្មតថា កិច្ចសន្យានេះអាចបន្តឡើងវិញ ដើម្បីទូទាត់ short position (ថ្លឹង 0%)។

ខ- កិច្ចសន្យាមិនទាន់ប្រើប្រាស់ ពីគ្រឹះស្ថានផ្សេងទៀត

ខ្នង់ ៣.២១៖ រាយការណ៍ទំហំទឹកប្រាក់នៃកិច្ចសន្យាឥណទាននិងសន្ទនីយភាពដែលមិនទាន់ប្រើប្រាស់ ដែលគ្រឹះស្ថានមានជាមួយគ្រឹះស្ថានផ្សេងទៀត។ គួរកត់សម្គាល់ថា ទម្រង់របាយការណ៍មានបំណងឆ្លុះបញ្ចាំងពីស្ថានភាពតានតឹង ដូច្នេះកិច្ចសន្យាបែបនេះត្រូវសន្មតថាមិនអាចប្រើប្រាស់បាន និងមានអត្រាថ្លឹងលំហូរចូល 0%។ ការសន្មតនេះគឺដើម្បី (១) កាត់បន្ថយការរាលដាលនៃហានិភ័យសន្ទនីយភាព ពីគ្រឹះស្ថានមួយ ទៅគ្រឹះស្ថានផ្សេងទៀត និង (២) ឆ្លុះបញ្ចាំងពីហានិភ័យដែលគ្រឹះស្ថានផ្សេងទៀតមិនមានលទ្ធភាពអនុវត្តតាមកិច្ចសន្យាឥណទាននិងសន្ទនីយភាព ឬគ្រឹះស្ថាននោះសម្រេចចិត្តមិនអនុវត្តកិច្ចសន្យា ដោយទទួលយកហានិភ័យគតិយុត្តិ និងហានិភ័យកេរ្តិ៍ឈ្មោះ ដើម្បីរក្សាសន្ទនីយភាពរបស់ខ្លួន។

ខ្នង់ ៣.២២៖ ខ្នង់នេះគឺប្រើសម្រាប់តែសាខា និងបុត្តសម្ព័ន្ធរបស់ធនាគារបរទេសដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។ ខ្នង់នេះត្រូវរាយការណ៍ទំហំទឹកប្រាក់ទាំងស្រុងនៃកិច្ចសន្យាផ្តល់ទុនផ្លូវការនិងមិនអាចបដិសេធបាន (formalized and irrevocable committed fund facilities) ជាមួយទីស្នាក់ការកណ្តាលរបស់ សាខា ឬធនាគារមេរបស់បុត្តសម្ព័ន្ធធនាគារបរទេស ដែលបានអនុញ្ញាតស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។ ទំហំទឹកប្រាក់ដែលត្រូវចាត់ទុកជាលំហូរចូល ត្រូវកំណត់ត្រឹម ៥0% (សែសិបភាគរយ) នៃលំហូរចេញសរុបនៃសាច់ប្រាក់ដែលរំពឹងទុក។

គ. លំហូរចូលពីកិច្ចសន្យាផ្សេងៗ ដែលមានការធានា ឬមិនមានការធានា

អត្រានៃលំហូរចូលត្រូវបានកំណត់ទៅតាមប្រភេទនៃសមភាគី។ ឥណទាយីត្រូវបានចាត់ទុកថាបំពេញបានពេញលេញតាមកិច្ចសន្យាជាមួយគ្រឹះស្ថាននៅពេលដែល ឥណទាយីនោះមិនមានការយឺតយ៉ាវក្នុងការទូទាត់សងទាំងប្រាក់ដើម និងការប្រាក់។

ខ្នង់ ៣.៣១ ដល់ ៣.៣២៖ រាយការណ៍ទំហំទឹកប្រាក់នៃលំហូរចូលតាមការសន្យាពីអតិថិជនជារូបវន្តបុគ្គល និងអតិថិជនជាសហគ្រាសខ្នាតតូចនិងមធ្យម ដូចបានកំណត់ក្នុងជំពូកទី១ ខាងលើ។ ទំហំទឹកប្រាក់នេះគិតតែទៅលើការទូទាត់ទាំងឡាយណា (រាប់បញ្ចូលទាំងការប្រាក់បង្គរដែលត្រូវទូទាត់) ដែលទទួលបានពីអតិថិជនជារូបវន្តបុគ្គល និងអតិថិជនសហគ្រាសខ្នាតតូចនិងមធ្យមដែលស្ថិតក្នុងកម្រិតស្តង់ដារ (មិនមានការយឺតយ៉ាវក្នុងការទូទាត់សង) ក្នុងរយៈពេល ៣0 ថ្ងៃ។ ប៉ុន្តែគ្រឹះស្ថានរំពឹងថានឹងបន្តផ្តល់ឥណទានទៅអតិថិជនដដែលនៅក្នុងអត្រា ៥0% នោះមានន័យថាខ្នង់ទាំងពីរនេះ ត្រូវថ្លឹងត្រឹមតែ ៥0% ប៉ុណ្ណោះ។

ខ្នង់ ៣.៣៣ ដល់ ៣.៣៨៖ រាយការណ៍ទំហំទឹកប្រាក់នៃលំហូរចូលតាមការសន្យា ទៅតាមប្រភេទស្ថាប័ន។ ទំហំទឹកប្រាក់នេះគិតតែទៅលើការទូទាត់ទាំងឡាយណា (រាប់បញ្ចូលទាំងការប្រាក់បង្គរ

ដែលត្រូវទូទាត់) ដែលទទួលបានពីអតិថិជនដុំ និងអតិថិជនជាស្ថាប័ននីតិបុគ្គលផ្សេងទៀតដែលស្ថិតក្នុងកម្រិតស្តង់ដារ (មិនមានការយឺតយ៉ាវក្នុងការទូទាត់សង) ក្នុងរយៈពេល ៣០ ថ្ងៃ។ លើសពីនេះ គ្រឹះស្ថានមិនរំពឹងថានឹងបន្តផ្តល់ឥណទានទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមទាំងធនាគារកណ្តាល និងបន្តផ្តល់ឥណទានក្នុងអត្រា ៥០% ទៅអតិថិជនផ្សេងទៀតដូចជា ក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ស្ថាប័នអធិបតេយ្យ ធនាគារអភិវឌ្ឍ សហគ្រាស/អង្គភាពសាធារណៈ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដូចបានកំណត់ក្នុងជំពូកទី១។ នោះមានន័យថា ខ្ទង់ ៣.៣៣ ៣.៣៦ ៣.៣៧ និង៣.៣៨ ត្រូវថ្លឹង ៥០% និងខ្ទង់ ៣.៣៤ និង៣.៣៥ ត្រូវថ្លឹង ១០០%។

<u>ចំណាំ៖</u>

- **ខ្ទង់ ៣.៣៥៖** រាយការណ៍នូវលំហូរចូលនៃសាច់ប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ដូចមានកំណត់ក្នុងជំពូកទី១) ទាំងក្នុងស្រុក និងបរទេស។ ខ្ទង់នេះរាប់បញ្ចូលទាំងលំហូរចូលដែលដល់ឥណប្រតិទានក្នុងរយៈពេល ៣០ ថ្ងៃ ខាងមុខ ពីប្រភពទុនដែលជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ និងទ្រព្យសកម្មសន្ទនីយផ្សេងទៀត តែក្នុងករណីដែលទ្រព្យសកម្មសន្ទនីយទាំងនោះមិនបានរាយការណ៍ក្នុងភាគយក។ ចំណែកលំហូរចូលពីទ្រព្យសកម្មផ្សេងទៀតមិនត្រូវរាយការណ៍ក្នុងខ្ទង់នេះទេ។
- **ខ្ទង់ ៣.៣៦៖** រាយការណ៍លំហូរចូលនៃសាច់ប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត (ដូចមានកំណត់ក្នុងជំពូកទី១) ទាំងក្នុងស្រុក និងបរទេស។
- **ខ្ទង់ ៣.៣៧ ដល់ ៣.៣៨៖** រាយការណ៍លំហូរចូលនៃសាច់ប្រាក់ពីនីតិបុគ្គលទាំងក្នុងស្រុក និងបរទេស រួមទាំង ធនាគារអភិវឌ្ឍន៍ និងសហគ្រាស/អង្គភាពសាធារណៈ និងពីស្ថាប័នអធិបតេយ្យ។

ខ្ទង់ ៣.៣៩៖ រាយការណ៍ទំហំនៃសាច់ប្រាក់ក្នុងគណនីចរន្ត និងគណនីមានកាលកំណត់ ដែលមាននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ដូចមានកំណត់ក្នុងជំពូកទី១)។ គួរកត់សម្គាល់ថា៖

(១) ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់គោលបំណងប្រតិបត្តិការ ដូចជាជាត់ទាត់ រក្សាទុក និងគ្រប់គ្រងសាច់ប្រាក់ ត្រូវបានសន្មតថានឹងស្ថិតនៅក្នុងគណនី និងមិនត្រូវបានរាយការណ៍ជាលំហូរចូលនៃសាច់ប្រាក់ទេ។ ការកំណត់និយមន័យនៃប្រាក់បញ្ញើប្រតិបត្តិការ ដូចគ្នាទៅនឹងនិយមន័យដែលអនុវត្តនៅក្នុងខ្ទង់ ២.២១។

(២) ចំពោះប្រាក់បញ្ញើមានកាលកំណត់៖ (ក) រាយការណ៍តែទំហំទឹកប្រាក់ទាំងឡាយណាដែលដល់ឥណប្រតិទានក្នុងអំឡុងពេល ៣០ ថ្ងៃ និង/ឬ (ខ) រាយការណ៍តែទំហំទឹកប្រាក់ទាំងឡាយណាដែលមានឥណប្រតិទាននៅសល់លើសពី ៣០ ថ្ងៃ ក្នុងករណីមានចែងក្នុងកិច្ចសន្យាថាអតិថិជនអាចដកប្រាក់បញ្ញើទាំងនោះមុនកាលកំណត់។

ឃ. លំហូរចូលនៃសាច់ប្រាក់ពីឧបករណ៍និស្សន្ទ

ខ្ទង់ ៣.៥០៖ រាយការណ៍លំហូរចូលសរុបនៃសាច់ប្រាក់ពីឧបករណ៍និស្សន្ទ ប្រសិនបើមាន។ ទឹកប្រាក់ត្រូវគណនាស្របតាមវិធីសាស្ត្រដូចមានក្នុងខ្ទង់ ២.៤១ ២.៤២ និង ២.៤៣។

ង. លំហូរចូលនៃសាច់ប្រាក់កើតចេញពីកិច្ចសន្យាមូលបត្រ និងកិច្ចសន្យាផ្សេងទៀត

ខ្ទង់ ៣.៦០៖ រាយការណ៍លំហូរចូលនៃសាច់ប្រាក់តាមការសន្យាពីមូលបត្រផ្សេងៗដែលមិនបានរាយការណ៍ក្នុងខ្ទង់ផ្សេងទៀត និងមានកាលកំណត់ ៣០ ថ្ងៃ ក្នុងករណីដែលមូលបត្រទាំងនោះបំពេញបានពេញលេញតាមកិច្ចសន្យា (មានន័យថា មូលបត្រទាំងនោះ គ្មានការខកខាន ឬសញ្ញាខកខានក្នុងការទូទាត់)។ ខ្ទង់នេះ ក៏អាចបញ្ចូលលំហូរចូលពីវិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចជួញដូរបាន ប៉ុន្តែលំហូរចូលពីទ្រព្យសកម្មសន្ធនីយដែលមានគុណភាពខ្ពស់ និងទ្រព្យសកម្មសន្ធនីយផ្សេងទៀត ដែលរាយការណ៍ក្នុងខ្ទង់ ១.១១ ដល់ ១.២៥ មិនត្រូវរាយការណ៍ម្តងទៀតក្នុងខ្ទង់នេះទេ។

ខ្ទង់ ៣.៧០៖ រាយការណ៍លំហូរចូលនៃសាច់ប្រាក់តាមការសន្យាផ្សេងៗទៀតដែលមានកាលកំណត់ ៣០ ថ្ងៃ និងមិនបានរាយការណ៍ក្នុងខ្ទង់ផ្សេងទៀត។

ធ៧-០២០-០០៣ ស.រ.ណ.ន

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

សារាចរណែនាំ
ស្តីពី
សេចក្តីពន្យល់បន្ថែមទៅលើឧបសម្ព័ន្ធ ២
នៃប្រកាសស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងតាមប្រកាសលេខ ធ៧-០១៥-៣៥៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព ធនាគារជាតិនៃកម្ពុជាសូមណែនាំអំពីការអនុវត្តខ្លឹមសារនៃប្រកាសនេះ ដូចខាងក្រោម៖

១. ប្រាក់បញ្ញើប្រតិបត្តិការ

ក. និយមន័យប្រាក់បញ្ញើប្រតិបត្តិការ

សម្រាប់គោលបំណងនៃប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព "ប្រាក់បញ្ញើប្រតិបត្តិការ" សំដៅដល់ប្រាក់បញ្ញើរបស់អតិថិជនហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដែលដាក់ឬរក្សាទុកនៅធនាគារសម្រាប់ទូទាត់និងជាត់ទាត់[1]។ ប្រាក់បញ្ញើនេះមានអត្រាលំហូរចេញនិងលំហូរចូលជាក់លាក់នៅក្នុងរបាយការណ៍អនុបាតក្របខ័ណ្ឌសន្ទនីយភាព។

- អត្រាលំហូរចេញ៖ ២៥%
  - ប្រាក់បញ្ញើប្រតិបត្តិការដែលទទួលបានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអតិថិជនដុំត្រូវរាយការណ៍នៅក្នុងខ្ទង់ ២.២១។
- អត្រាលំហូរចូល៖ ០%
  - ប្រាក់បញ្ញើប្រតិបត្តិការរបស់គ្រឹះស្ថានដែលបានដាក់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដទៃទៀតមិនត្រូវបានអនុញ្ញាតឱ្យរាយការណ៍ក្នុងខ្ទង់ ៣.៣៩ ឬ ក្នុងខ្ទង់ណាមួយនៃរបាយការណ៍អនុបាតក្របខ័ណ្ឌសន្ទនីយភាពឡើយ។

[1] តាមក្របខ័ណ្ឌបាសែល III (អនុបាតក្របខ័ណ្ឌសន្ទនីយភាព ចេញផ្សាយនៅខែមករា ឆ្នាំ២០១៣)

ខ. លក្ខខណ្ឌរបស់ប្រាក់បញ្ញើដែលត្រូវចាត់ជាប្រាក់បញ្ញើប្រតិបត្តិការ

- ប្រាក់បញ្ញើដែលត្រូវចាត់ជាប្រាក់បញ្ញើប្រតិបត្តិការត្រូវទាក់ទងនឹងសកម្មភាពមួយចំនួន រួមមាន ការជាត់ទាត់ គណនីរក្សាទុក (Custody) និងការគ្រប់គ្រងសាច់ប្រាក់សម្រាប់អតិថិជន[២] និងត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖
  - អតិថិជនមានការពឹងផ្អែកយ៉ាងខ្លាំងលើគ្រឹះស្ថានដើម្បីផ្តល់សេវាខាងលើក្នុងនាមជាអន្តរការិយកម្មធនាគារតតិយភាគីឯករាជ្យ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់
  - សេវានេះត្រូវបានផ្តល់ដោយគ្រឹះស្ថានក្រោមកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ និង
  - ការបញ្ចប់កិច្ចព្រមព្រៀងត្រូវជូនដំណឹងជាមុន យ៉ាងតិច ៣០ថ្ងៃ ឬរងការពិន័យធ្ងន់ធ្ងរក្នុងករណីប្រាក់បញ្ញើប្រតិបត្តិការត្រូវបានដកយកទៅប្រើប្រាស់ទាំងស្រុង ឬផ្នែកខ្លះមុនពេលជូនដំណឹង ៣០ថ្ងៃ។
- ប្រាក់បញ្ញើប្រតិបត្តិការដែលអាចទទួលយកបានត្រូវស្ថិតក្រោមលក្ខខណ្ឌបន្ថែម ដូចខាងក្រោម៖
  - ប្រាក់បញ្ញើនេះ គឺជាផ្នែកមួយនៃសេវាខាងលើ (by-product)
  - ប្រាក់បញ្ញើនេះត្រូវបានរក្សាទុកក្នុងគណនីជាក់លាក់ (មិនមានឬមានការប្រាក់ទាបខ្លាំង) ដែលមិនលើកទឹកចិត្តឱ្យអតិថិជនរក្សាទុកមូលនិធិអតិរេកនៅក្នុងគណនីទាំងនោះឡើយ
  - ផ្នែកនៃប្រាក់បញ្ញើដែលប្រើប្រាស់សម្រាប់គោលបំណងប្រតិបត្តិការរបស់អតិថិជនអាចចាត់ទុកជាប្រាក់បញ្ញើប្រតិបត្តិការ ប៉ុន្តែសមតុល្យលើស (Excess Balance) នឹងត្រូវដកចេញពីប្រាក់បញ្ញើប្រតិបត្តិការ ហើយត្រូវរាយការណ៍តាមប្រភេទលំហូរចេញសមស្របសម្រាប់ប្រាក់បញ្ញើមិនមែនប្រតិបត្តិការ (ខ្ទង់ ២.២២ ដល់ ខ្ទង់ ២.២៥) និង
  - គ្រឹះស្ថានត្រូវមានវិធីសាស្ត្រច្បាស់លាស់ និងត្រឹមត្រូវក្នុងការកំណត់សមតុល្យប្រាក់បញ្ញើលើស ដែលត្រូវដកចេញពីខ្ទង់ ២.២១។ ចំពោះគ្រឹះស្ថានដែលមិនមាន

[២] ទំនាក់ទំនងសេវាប្រាក់បញ្ញើប្រតិបត្តិការរវាងគ្រឹះស្ថាន និងអតិថិជន មានដូចខាងក្រោម៖

- ការជាត់ទាត់ សំដៅដល់សេវាដែលអនុញ្ញាតឱ្យអតិថិជនផ្ទេរមូលនិធិដោយប្រយោល តាមរយៈគ្រឹះស្ថានដែលចូលរួមដោយផ្ទាល់នៅក្នុងប្រព័ន្ធទូទាត់ទៅដល់អ្នកទទួលចុងក្រោយ។ ការផ្តល់សេវាបែបនេះត្រូវបានកម្រិតត្រឹមតែការផ្ទេរ ការផ្សៀងផ្ទាត់ (Reconcile) និងការបញ្ជាក់អំពីបញ្ជាទូទាត់ ឬសកម្មភាពពាក់ព័ន្ធ។
- គណនីរក្សាទុក សំដៅដល់សេវារក្សាសុវត្ថិភាព និងដំណើរការទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងសកម្មភាពពាក់ព័ន្ធផ្សេងទៀត (ដូចជា គណនី Escrow)។
- ការគ្រប់គ្រងសាច់ប្រាក់ សំដៅដល់សេវាគ្រប់គ្រងសាច់ប្រាក់ និងសេវាពាក់ព័ន្ធនឹងការផ្ទេរប្រាក់ ការប្រមូលមូលនិធិ និងការគ្រប់គ្រងរៀវត្សរ៍ ដែលបានផ្តល់ឱ្យអតិថិជន។

វិធីសាស្ត្រច្បាស់លាស់ ប្រាក់បញ្ញើទាំងមូលនឹងត្រូវចាត់ទុកថាជាប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ហើយត្រូវរាយការណ៍ក្នុងខ្ទង់ ២.២២ ដល់ខ្ទង់ ២.២៥។

ធនាគារជាតិនៃកម្ពុជាមិនអនុញ្ញាតឱ្យគ្រឹះស្ថានរាយការណ៍ប្រាក់បញ្ញើក្នុងខ្ទង់ ២.២១ នៃរបាយការណ៍អនុបាតក្របខ័ណ្ឌសន្ទនីយភាព ក្នុងករណីដែល៖

- គ្រឹះស្ថានប្រើប្រាស់មិនសមស្របតាមគោលបំណងប្រាក់បញ្ញើប្រតិបត្តិការ ឬ
- គ្រឹះស្ថានមានសមតុល្យប្រាក់បញ្ញើប្រតិបត្តិការធំ ដែលប្រមូលផ្តុំដោយចំនួនអតិថិជនតិច (ដើម្បីចៀសវាងហានិភ័យប្រមូលផ្តុំ)។

២. ប្រព្រឹត្តកម្មនៃប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការជាមួយធនាគារទំនាក់ទំនង

ក. និយមន័យប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការជាមួយធនាគារទំនាក់ទំនង

ប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការជាមួយធនាគារទំនាក់ទំនង សំដៅដល់ប្រាក់បញ្ញើដែលធនាគារមួយ (ធនាគារដាក់ប្រាក់បញ្ញើ - Respondent Bank) ដាក់ឬរក្សាទុកនៅធនាគារផ្សេងទៀត (ធនាគារទំនាក់ទំនង - Correspondent Bank) សម្រាប់ការទូទាត់និងជាត់ទាត់ជារូបិយប័ណ្ណ[៣]។

ខ. ប្រព្រឹត្តកម្ម

ទោះបីប្រាក់បញ្ញើដែលប្រើប្រាស់សម្រាប់ធនាគារទំនាក់ទំនង ត្រូវបានប្រើប្រាស់ដូចគោលបំណងប្រាក់បញ្ញើប្រតិបត្តិការ ការរាយការណ៍ត្រូវបានកំណត់ដូចខាងក្រោម ដោយសារភាពងាយប្រែប្រួលនៃប្រាក់បញ្ញើនេះ៖

- ប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការធនាគារទំនាក់ទំនងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាត់ទុកថាជាប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ដែលមានអត្រាលំហូរចេញ ១០០% និងត្រូវរាយការណ៍ក្នុងខ្ទង់ ២.២៤។
- ប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការធនាគារទំនាក់ទំនង ដែលគ្រឹះស្ថានដាក់នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងមានអត្រាលំហូរចូល ០% និងមិនត្រូវរាយការណ៍ក្នុងខ្ទង់ ៣.៣៩ ឬខ្ទង់ផ្សេងទៀតនៃរបាយការណ៍នេះទេ។

ក្នុងករណីគ្រឹះស្ថានអាចកំណត់សមតុល្យដែលលើសពីតម្រូវការប្រើប្រាស់សម្រាប់ប្រតិបត្តិការធនាគារទំនាក់ទំនង ហើយអាចដកបានក្នុងរយៈពេល ៣០ថ្ងៃ សមតុល្យលើសអាចមានអត្រាលំហូរចូល ១០០% ហើយរាយការណ៍ក្នុងខ្ទង់ ៣.៣៩។

[៣] តាមក្របខ័ណ្ឌបាសែល III (អនុបាតក្របខ័ណ្ឌសន្ទនីយភាព ចេញផ្សាយនៅខែមករា ឆ្នាំ២០១៣)

៣. ប្រាក់បញ្ញើដុំមិនមានការធានាផ្សេងទៀត

ប្រាក់បញ្ញើដុំមិនមានការធានាផ្សេងទៀត ដែលមិនមែនជាប្រាក់បញ្ញើប្រតិបត្តិការត្រូវរាយការណ៍ក្នុងខ្នង់ ២.២២ ដល់ ២.២៥ ដោយផ្អែកលើប្រភេទអតិថិជន។

៤. លំហូរចូល - ខ្នង់ ៣.៣៩ (ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

ប្រាក់បញ្ញើមិនមែនប្រតិបត្តិការនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងៗ ត្រូវរាយការណ៍ក្នុងខ្នង់ ៣.៣៩ និងមានអត្រាលំហូរចូល ១០០% ក្នុងករណីគ្រឹះស្ថានអាចដកប្រាក់បញ្ញើនេះបានក្នុងអំឡុងពេល ៣០ថ្ងៃ ខាងមុខ។

ដូចបានបញ្ជាក់ខាងលើ ប្រាក់បញ្ញើប្រតិបត្តិការរបស់គ្រឹះស្ថានដែលបានដាក់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដទៃទៀត មានអត្រាលំហូរចូល ០% និងមិនត្រូវអនុញ្ញាតឱ្យរាយការណ៍ក្នុងខ្នង់ណាមួយឡើយ។

គ្រឹះស្ថានអាចចាត់ទុកសមតុល្យលើសនៃប្រាក់បញ្ញើប្រតិបត្តិការជាប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ហើយអាចរាយការណ៍នៅក្នុងខ្នង់ ៣.៣៩ លុះត្រាតែ៖

- គ្រឹះស្ថានត្រូវមានវិធីសាស្ត្រសមស្របនិងច្បាស់លាស់ក្នុងការកំណត់សមតុល្យលើសដែលអាចដកចេញពីប្រាក់បញ្ញើប្រតិបត្តិការដោយមិនប៉ះពាល់ដល់និរន្តរភាពប្រតិបត្តិការរបស់គ្រឹះស្ថាន
- គ្រឹះស្ថានអាចដកសមតុល្យប្រាក់បញ្ញើលើសនេះបានក្នុងអំឡុងពេល ៣០ថ្ងៃ ខាងមុខ និង
- ប្រសិនបើគ្រឹះស្ថានមិនអាចកំណត់សមតុល្យលើសបានទេ ប្រាក់បញ្ញើទាំងមូលត្រូវចាត់ទុកថាជាប្រាក់បញ្ញើប្រតិបត្តិការ និងមានអត្រាលំហូរចូល ០%។

៥. ឧទាហរណ៍អំពីប្រព្រឹត្តកម្មនៃប្រាក់បញ្ញើប្រតិបត្តិការអន្តរធនាគារ

ឧទាហរណ៍ខាងក្រោមបង្ហាញពីប្រព្រឹត្តកម្មនៃប្រាក់បញ្ញើប្រតិបត្តិការអន្តរធនាគារក្នុងរបាយការណ៍អនុបាតក្របខ័ណ្ឌសន្ទនីយភាព៖

ក. ប្រតិបត្តិការធនាគារទូទៅ

ធនាគារ "ក" ដាក់ប្រាក់បញ្ញើនៅធនាគារ "ខ" ចំនួន ២០០ លានរៀល ក្នុងគោលបំណងសម្រាប់ប្រតិបត្តិការ ដោយមានកិច្ចព្រមព្រៀងតាមផ្លូវច្បាប់។ ប្រការមួយនៃកិច្ចព្រមព្រៀងបានចែងថា ប្រសិនបើប្រាក់បញ្ញើប្រតិបត្តិការនេះត្រូវបានដកយកទៅប្រើប្រាស់មុនពេលជូនដំណឹង ៣០ថ្ងៃ ធនាគារ "ក" ត្រូវរងការពិន័យចំនួន ១% នៃសមតុល្យដែលបានដក។ ធនាគារ "ក" ត្រូវរក្សាសមតុល្យប្រាក់បញ្ញើប្រតិបត្តិការនេះ ចំនួន ២០០ លានរៀល នៅធនាគារ "ខ" សម្រាប់ប្រតិបត្តិការជាប់ទាត់ក្នុងអំឡុងពេល ៣០ថ្ងៃ ខាងមុខ។ ធនាគារ "ក" អាចដកសមតុល្យដែលលើសបានគ្រប់ពេល។

ក្នុងករណីនេះ គ្រឹះស្ថានទាំងពីរត្រូវចាត់ទុកប្រាក់បញ្ញើចំនួន ២០០ លានរៀល នេះ ជាប្រាក់បញ្ញើប្រតិបត្តិការដោយសារប្រាក់បញ្ញើនេះបំពេញបានតាមលក្ខខណ្ឌប្រាក់បញ្ញើប្រតិបត្តិការ។ ធនាគារ "ខ" ត្រូវរាយការណ៍ប្រាក់បញ្ញើនេះក្នុងគណនីប្រាក់បញ្ញើប្រតិបត្តិការជាក់លាក់មួយ ដោយមិនមានការប្រាក់ ឬមានការប្រាក់ក្នុងកម្រិតទាបខ្លាំង។

<u>ករណីទី១</u>

ប្រសិនបើនៅថ្ងៃរាយការណ៍ គណនីប្រាក់បញ្ញើប្រតិបត្តិការមានសមតុល្យ ២០០ លានរៀល ធនាគារ "ខ" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ២០០ លានរៀល នៅក្នុងខ្ទង់ ២.២១ ចំណែកធនាគារ "ក" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ០ រៀល នៅក្នុងខ្ទង់ ៣.៣៩។

<u>ករណីទី២</u>

ប្រសិនបើនៅថ្ងៃរាយការណ៍ គណនីប្រាក់បញ្ញើប្រតិបត្តិការមានសមតុល្យ ២២៥ លានរៀល ធនាគារ "ខ" ត្រូវរាយការណ៍សាច់ប្រាក់តែចំនួន ២០០ លានរៀល នៅក្នុងខ្ទង់ ២.២១ និងកត់ត្រាចំនួន ២៥ លានរៀល នៅក្នុងខ្ទង់ ២.២៤ ចំណែកធនាគារ "ក" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ២៥ លានរៀល នៅក្នុងខ្ទង់ ៣.៣៩។

<u>ករណីទី៣</u>

ប្រសិនបើនៅថ្ងៃរាយការណ៍ គណនីប្រាក់បញ្ញើប្រតិបត្តិការមានសមតុល្យ ១៨០ លានរៀល មានន័យថា ធនាគារ "ក" មានឱនភាព ២០ លានរៀល។ ករណីនេះធនាគារ "ខ" ត្រូវរាយការណ៍សាច់ប្រាក់តែចំនួន ១៨០ លានរៀល នៅក្នុងខ្ទង់ ២.២១។ ចំណែកធនាគារ "ក" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ០ រៀល នៅក្នុងខ្ទង់ ៣.៣៩។ ធនាគារ "ក" ដែលមានសមតុល្យ ១៨០ លានរៀល ត្រូវរងពិន័យចំនួន ១% លើចំនួនសាច់ប្រាក់ឱនភាព ២០ លានរៀល។

ខ. ប្រតិបត្តិការធនាគារទំនាក់ទំនង

<u>ករណីទី៤</u>៖ ធនាគារដាក់ប្រាក់បញ្ញើស្ថិតនៅប្រទេសកម្ពុជា

<u>៤.១. ករណីកិច្ចសន្យាមានកំណត់សមតុល្យអប្បបរមាដែលត្រូវរក្សាទុកក្នុងគណនី៖</u>

ធនាគារ "ក" (ធនាគារដាក់ប្រាក់បញ្ញើ) មានស្នាក់ការកណ្តាលនៅប្រទេសកម្ពុជា មានកិច្ចព្រមព្រៀងដាក់ប្រាក់បញ្ញើនៅធនាគារ "ABC" (ធនាគារទំនាក់ទំនង) នៅប្រទេសបារាំង យ៉ាងតិចចំនួន ១០០ លានអឺរ៉ូ ក្នុងគោលបំណងសម្រាប់ប្រតិបត្តិការធនាគារទំនាក់ទំនង។

- ករណីនេះ ប្រសិនបើនៅថ្ងៃរាយការណ៍ សមតុល្យគណនីនេះ (ហៅថាគណនី Nostro របស់ធនាគារ "ក") មានចំនួន ១០០ លានអឺរ៉ូ ឬតិចជាង ធនាគារ "ក" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ០ អឺរ៉ូ នៅក្នុងខ្ទង់ ៣.៣៩ ដោយសារប្រាក់បញ្ញើនេះត្រូវបានចាត់ទុកថាជាប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការហើយមានអត្រាលំហូរចូល ០%។

- ផ្ទុយទៅវិញ ប្រសិនបើនៅថ្ងៃរាយការណ៍ សមតុល្យគណនីមានចំនួនលើសពី ១០០ លានអឺរ៉ូ ឧបមាថា គណនីនេះមានសមតុល្យ ១២០ លានអឺរ៉ូ ហើយធនាគារ "ក" មានសិទ្ធិដកប្រើប្រាស់បានចំនួន ២០ លានអឺរ៉ូ គ្រប់ពេល ដូច្នេះ ធនាគារអាចរាយការណ៍សមតុល្យដែលលើសចំនួន ២០ លានអឺរ៉ូ នេះនៅក្នុងខ្ទង់ ៣.៣៩។

<u>៤.២. ករណីកិច្ចសន្យាមិនមានកំណត់សមតុល្យអប្បបរមាដែលត្រូវរក្សាទុកក្នុងគណនី៖</u>

ធនាគារ "ក" (ធនាគារដាក់ប្រាក់បញ្ញើ) មានស្នាក់ការកណ្តាលនៅប្រទេសកម្ពុជា មានកិច្ចព្រមព្រៀងដាក់ប្រាក់បញ្ញើនៅធនាគារ "ABC" (ធនាគារទំនាក់ទំនង) នៅប្រទេសបារាំង សម្រាប់គោលបំណងប្រតិបត្តិការធនាគារទំនាក់ទំនង។

១). ករណីធនាគារ "ក" មិនមានវិធីសាស្ត្រក្នុងការគណនាសមតុល្យដែលត្រូវរក្សាទុកសម្រាប់ប្រតិបត្តិការទូទាត់

- ករណីនេះ នៅថ្ងៃរាយការណ៍ សមតុល្យគណនីនេះ (ហៅថាគណនី Nostro របស់ធនាគារ "ក") មានចំនួន ១០០ លានអឺរ៉ូ ធនាគារ "ក" ត្រូវរាយការណ៍សាច់ប្រាក់ចំនួន ០ អឺរ៉ូ នៅក្នុងខ្ទង់ ៣.៣៩ ដោយសារប្រាក់បញ្ញើនេះត្រូវបានចាត់ទុកថាជាប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការហើយមានអត្រាលំហូរចូល ០%។

២). ករណីធនាគារ "ក" មានវិធីសាស្ត្រក្នុងការគណនាសមតុល្យដែលត្រូវរក្សាទុកសម្រាប់ប្រតិបត្តិការទូទាត់

- ផ្ទុយទៅវិញ ប្រសិនបើនៅថ្ងៃរាយការណ៍ សមតុល្យគណនីមានចំនួន ១០០ លានអឺរ៉ូ ប៉ុន្តែធនាគារ "ក" មានវិធីសាស្ត្រសមស្របក្នុងការគណនាសមតុល្យដែលត្រូវរក្សាទុកសម្រាប់ប្រតិបត្តិការទូទាត់ (ដូចជា វិធីសាស្ត្រគណនាលំហូរសាច់ប្រាក់ចេញសុទ្ធជាមធ្យមនៃលំហូរសាច់ប្រាក់ចេញសុទ្ធក្នុងខែនីមួយៗ រយៈពេល ១២ខែ កន្លងមក គិតត្រឹមខែរាយការណ៍) ដោយឧបមាថា ធនាគារ "ក" គណនាសមតុល្យដែលត្រូវរក្សាទុកសម្រាប់ប្រតិបត្តិការទូទាត់ជាមធ្យមមានចំនួន ៧០ លានអឺរ៉ូ ហើយ ធនាគារ "ក" អាចប្រើប្រាស់បានចំនួន ៣០ លានអឺរ៉ូ (លើសពីតម្រូវការប្រើប្រាស់) ក្នុងអំឡុង ៣០ថ្ងៃ ដូច្នេះសមតុល្យដែលលើសពីការប្រើប្រាស់ចំនួន ៣០ លានអឺរ៉ូ (ឬតិចជាងនេះ) នេះអាចមានអត្រាលំហូរចូល ១០០% ចុះនៅក្នុងខ្ទង់ ៣.៣៩។

<u>ករណីទី៥៖</u> ធនាគារដាក់ប្រាក់បញ្ញើស្ថិតនៅប្រទេសបារាំង

ធនាគារ "XYZ" (ធនាគារដាក់ប្រាក់បញ្ញើ) មានស្នាក់ការកណ្តាលនៅប្រទេសបារាំង មានកិច្ចព្រមព្រៀងដាក់ប្រាក់បញ្ញើនៅធនាគារ "ក" (ធនាគារទំនាក់ទំនង) នៅប្រទេសកម្ពុជា យ៉ាងតិចចំនួន ៥០ លានដុល្លារអាមេរិក ក្នុងគោលបំណងសម្រាប់ប្រតិបត្តិការធនាគារទំនាក់ទំនងជាមួយប្រទេសកម្ពុជា។

ករណីនេះ ទោះបីនៅថ្ងៃរាយការណ៍ គណនីនេះ (ហៅថាគណនី Vostro របស់ធនាគារ "ក") មានសមតុល្យចំនួនប៉ុន្មានក៏ដោយ ធនាគារ "ក" (ធនាគារទំនាក់ទំនងនៅកម្ពុជា) ត្រូវរាយការណ៍សមតុល្យសាច់ប្រាក់ដែលមានក្នុងគណនីនេះទាំងអស់នៅក្នុងខ្នង ២.២៤។

៦. ប្រាក់បញ្ញើរាយ

ប្រាក់បញ្ញើរាយរួមមាន ប្រាក់បញ្ញើដកតាមតម្រូវការ ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ (ដោយមិនគិតពីឥណប្រតិទាន)។ ប្រាក់បញ្ញើរាយត្រូវបានបែងចែងជាប្រាក់បញ្ញើមានស្ថិរភាព និងប្រាក់បញ្ញើមិនសូវមានស្ថិរភាព៖

- **ខ្នង ២.១១ (ប្រាក់បញ្ញើមានស្ថិរភាព)**

ប្រាក់បញ្ញើរាយដែលត្រូវបានចាត់ទុកថាជាប្រាក់បញ្ញើមានស្ថិរភាព ត្រូវគោរពតាមលក្ខខណ្ឌពីរដូចខាងក្រោម៖

១). ប្រាក់បញ្ញើរាយដែលត្រូវបានធានាដោយប្រព័ន្ធការពារប្រាក់បញ្ញើ និង

២). ទំនាក់ទំនងរវាងអ្នកដាក់ប្រាក់បញ្ញើនិងគ្រឹះស្ថានតាមលក្ខខណ្ឌយ៉ាងតិចមួយដូចខាងក្រោម៖

- មានគណនីធនាគារដែលមានសុពលភាព យ៉ាងតិច ១២ខែ ជាមួយគ្រឹះស្ថាន
- មានកិច្ចសន្យាឥណទានលំនៅដ្ឋាន ឬឥណទានដែលមានឥណប្រតិទានលើសពី ១២ខែ ជាមួយគ្រឹះស្ថាន ឬ
- ប្រើប្រាស់យ៉ាងសកម្មនូវផលិតផលហិរញ្ញវត្ថុមួយយ៉ាងតិចជាមួយគ្រឹះស្ថានក្រៅពីឥណទាន។

- **ខ្នង ២.១២ (ប្រាក់បញ្ញើមិនសូវមានស្ថិរភាព)**

ប្រាក់បញ្ញើរាយដែលមិនបំពេញលក្ខខណ្ឌដូចមានចែងក្នុងខ្នង ២.១១ ខាងលើត្រូវចាត់ទុកជា "ប្រាក់បញ្ញើមិនសូវមានស្ថិរភាព"។

៧. កិច្ចសន្យា

ក. និយមន័យ

កិច្ចសន្យាឥណទាននិងសន្ទនីយភាព សំដៅដល់កាតព្វកិច្ចផ្តល់ទុនទៅអនាគតតាមការសន្យាទៅឱ្យសមភាគីខ្ចីដុំ ឬរាយ។ ក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព កិច្ចសន្យានេះគិតបញ្ចូលតែកាតព្វកិច្ចដែលមិនអាចបដិសេធបាន ឬអាចបដិសេធបានដោយមានលក្ខខណ្ឌ។

កិច្ចសន្យាឥណទាន សំដៅដល់កាតព្វកិច្ចរបស់គ្រឹះស្ថានក្នុងការផ្តល់ហ្វាស៊ីលីធីប្រើប្រាស់ជាទុនបង្វិលទូទៅ និងឥណទានវិបារូបន៍ដល់អតិថិជន (ទាំងនីតិបុគ្គល និងរូបវន្តបុគ្គល)។ ឧទាហរណ៍៖ ចំណែកឥណទានមិនទាន់ប្រើប្រាស់នៃ ឥណទានពាណិជ្ជកម្ម (Trade Loan) ឥណទានបង្វិលទុន (Revolving Loan) បណ្ណឥណទាន (Credit Card) និងឥណទានវិបារូបន៍ (Overdraft) ជាដើម។

កិច្ចសន្យាសន្ទនីយភាព សំដៅដល់កាតព្វកិច្ចដែលគ្រឹះស្ថានសន្យាផ្តល់ហ្វាស៊ីលីធី ដើម្បីគាំទ្រសន្ទនីយភាពរបស់អតិថិជន ក្នុងស្ថានភាពដែលអតិថិជននោះមានបញ្ហាសន្ទនីយភាព។ ឧទាហរណ៍៖ អតិថិជនមិនអាចទទួលបានប្រភពទុន តាមរយៈការបោះផ្សាយលក់ផលបត្រពាណិជ្ជកម្មនៅលើទីផ្សារហិរញ្ញវត្ថុ ដោយសារកត្តាណាមួយ (ការទម្លាក់ចំណាត់ថ្នាក់ឬលក្ខខណ្ឌទីផ្សារមិនអំណោយផល)។

ខ. ការអនុវត្តចំពោះលំហូរចេញនៃសាច់ប្រាក់រំពឹងទុកទាក់ទងនឹងកិច្ចសន្យា

- **ខ្ទង់ ២.៥១ និង ២.៥២** រាយការណ៍ទំហំសាច់ប្រាក់ក្នុងកិច្ចសន្យាឥណទាន និងសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់អតិថិជនជារូបវន្តបុគ្គល និងអតិថិជនជាសហគ្រាសខ្នាតតូច និងមធ្យម។ អត្រាលំហូរចេញត្រូវបានកំណត់ ៥% ដូចក្នុងតារាងឧបសម្ព័ន្ធ ១។
- **ខ្ទង់ ២.៥៣ និង ២.៥៤** រាយការណ៍ទំហំសាច់ប្រាក់ក្នុងកិច្ចសន្យាឥណទាន និងសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់ក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ស្ថាប័នអធិបតេយ្យនិងធនាគារកណ្តាល (Sovereigns and Central Banks) ធនាគារអភិវឌ្ឍន៍និងសហគ្រាសឬអង្គភាពសាធារណៈ។ អត្រាលំហូរចេញត្រូវបានកំណត់ ១០% និង ៣០% ដូចក្នុងតារាងឧបសម្ព័ន្ធ១។
- **ខ្ទង់ ២.៥៥ និង ២.៥៦** រាយការណ៍ទំហំសាច់ប្រាក់ក្នុងកិច្ចសន្យាឥណទាន និងសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ អត្រាលំហូរចេញត្រូវបានកំណត់ ៤០% ដូចក្នុងតារាងឧបសម្ព័ន្ធ១។
- **ខ្ទង់ ២.៥៧ និង ២.៥៨** រាយការណ៍ទំហំសាច់ប្រាក់ក្នុងកិច្ចសន្យាឥណទាន និងសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ អត្រាលំហូរចេញត្រូវបានកំណត់ ៤០% និង ១០០% ដូចក្នុងតារាងឧបសម្ព័ន្ធ១។
- **ខ្ទង់ ២.៥៩ និង ២.៦០** រាយការណ៍ទំហំសាច់ប្រាក់ក្នុងកិច្ចសន្យាឥណទាន និងសន្ទនីយភាពមិនទាន់ប្រើប្រាស់ ដែលផ្តល់ដល់នីតិបុគ្គលផ្សេងទៀត និងរាយការណ៍ទំហំសាច់ប្រាក់នៃកាតព្វកិច្ចផ្តល់ទុនផ្សេងទៀត ក្នុងរយៈពេល ៣០ថ្ងៃ ដែលមិនបានរាយការណ៍នៅក្នុងខ្ទង់ផ្សេងទៀត។ អត្រាលំហូរចេញត្រូវបានកំណត់ ១០០% ដូចក្នុងតារាងឧបសម្ព័ន្ធ១។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៧-៣០១ ប្រ.ក

ប្រកាស
ស្តីពី
ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ធនីយភាព
របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងបង្កើតក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ធនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅកាត់បន្ថយបញ្ហាសន្ធនីយភាពធ្ងន់ធ្ងរ កាត់បន្ថយផលប៉ះពាល់លើប្រព័ន្ធធនាគារ និងការពារអ្នកដាក់ប្រាក់បញ្ញើ និងឥណទាយក។

ប្រការ ៣.-

ប្រកាសនេះ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

សម្រាប់គោលបំណងនៃប្រកាសនេះ និយមន័យមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

សន្ធនីយភាព សំដៅដល់សមត្ថភាពក្នុងការផ្តល់ទុនដើម្បីបង្កើនទ្រព្យសកម្ម បំពេញកាតព្វកិច្ចទូទាត់បំណុលដែលបានឬមិនបានរំពឹងទុក និងលទ្ធភាពទូទាត់ឬកាត់កងប៉ូស៊ីសិន (position) ដោយមិនបង្កឱ្យមានការខាតបង់ធ្ងន់ធ្ងរ។ សន្ធនីយភាពអាចរងផលប៉ះពាល់ពីឧបករណ៍ហិរញ្ញវត្ថុទាំងក្នុងនិងក្រៅតារាងតុល្យការ។

ហានិភ័យសន្ធនីយភាព សំដៅដល់ហានិភ័យដែលគ្រឹះស្ថានមិនអាចបំពេញកាតព្វកិច្ច ឬមិនអាចទូទាត់បំណុលឬកាត់កងប៉ូស៊ីសិន (position) នៅក្នុងបរិបទសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថានភាពទីផ្សារជាក់លាក់ណាមួយ។ ហានិភ័យសន្ធនីយភាពនេះអាចធ្វើឱ្យគ្រឹះស្ថានរងការខាតបង់ដែលអាចបណ្តាលមកពី៖ ១). គ្រឹះស្ថានគ្មានសាច់ប្រាក់ ឬគ្មានសមមូលសាច់ប្រាក់គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការរបស់អ្នកដាក់ប្រាក់បញ្ញើ អ្នកខ្ចីប្រាក់ និងការទូទាត់បំណុលយថាភាព ២). ការលក់ទ្រព្យសកម្មអសន្ធនីយទាបជាងតម្លៃទីផ្សារ និង៣). ទ្រព្យសកម្មអសន្ធនីយមិនអាចលក់ទាន់ពេលវេលាដោយសារគ្មានអ្នកទិញ។

រីសអាប់កែថាយ (Risk Appetite) សំដៅដល់ប្រភេទនិងកម្រិតហានិភ័យដែលអាចទទួលយកបានក្នុងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។

រីសថលើរែន (Risk Tolerance) សំដៅដល់បម្រែបម្រួលបរិមាណនៃកម្រិតហានិភ័យអតិបរមាដែលអាចទទួលយកបាន ដោយគិតគូរដល់វិធានការសមស្របដើម្បីកាត់បន្ថយហានិភ័យ។

ទ្រព្យសកម្មជាប់កាតព្វកិច្ច (Encumbered Assets) សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា ឬកាតព្វកិច្ចផ្សេងទៀត ដែលរារាំងគ្រឹះស្ថានក្នុងការជម្រះបញ្ជី លក់ ផ្ទេរ ឬចាត់ចែង ទ្រព្យសកម្មទាំងនេះ។

ទ្រព្យសកម្មមិនជាប់កាតព្វកិច្ច (Unencumbered Assets) សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលមិនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា ឬកាតព្វកិច្ចផ្សេងទៀត ដែលអាចឱ្យគ្រឹះស្ថានមានលទ្ធភាពជម្រះបញ្ជី លក់ ផ្ទេរ ឬចាត់ចែង ទ្រព្យសកម្មទាំងនេះ។

ទ្រព្យសកម្មសន្ធនីយ សំដៅដល់សាច់ប្រាក់ ឬសមមូលសាច់ប្រាក់ ដែលជាទ្រព្យសកម្មអាចបំលែងជាសាច់ប្រាក់បានភ្លាមៗ ដោយមិនមាន ឬមានការខាតបង់តិចតួច។

ទ្រព្យសកម្មសន្ធនីយអាចទទួលយកបាន សំដៅដល់ទ្រព្យសកម្មដែលកំណត់នៅក្នុងប្រកាសលេខ ធ៧-០១៥-៣៥៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ធនីយភាព។

ជំពូកទី ២
អភិបាលកិច្ច

ប្រការ ៥.-

គ្រឹះស្ថានត្រូវរៀបចំក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ធនីយភាពឱ្យបានច្បាស់លាស់ដើម្បីរក្សាសន្ធនីយភាពឱ្យបានគ្រប់គ្រាន់ជាប្រចាំ រួមទាំងការកាន់កាប់ទ្រព្យសកម្មមិនជាប់កាតព្វកិច្ចដើម្បីទប់ទល់នឹងស្ថានភាពតានតឹងណាមួយពាក់ព័ន្ធនឹងការបាត់បង់ប្រភពទុនដូចជា ប្រាក់បញ្ញើ ប្រាក់កម្ចី ការកៀរគរដើមទុនបន្ថែម និងបញ្ហាផ្សេងៗទៀត។

គ្រឹះស្ថានត្រូវធានាថាប្រភពទុនរបស់ខ្លួនមានស្ថិរភាពជាប្រចាំសម្រាប់គាំទ្រសកម្មភាពប្រតិបត្តិការ។

គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាឱ្យបានឆាប់ នូវរាល់បញ្ហាសន្ធនីយភាពនាពេលបច្ចុប្បន្ននិងទៅអនាគត និងផែនការដោះស្រាយបញ្ហាទាំងនោះ។ ក្នុងករណីគ្រឹះស្ថានជួបស្ថានភាពសន្ធនីយភាពតានតឹងធ្ងន់ធ្ងរ គ្រឹះស្ថានត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជាភ្លាមដោយបញ្ជាក់ពីវិធានការដោះស្រាយ។

ប្រការ ៦.-

គ្រឹះស្ថានត្រូវកំណត់ឱ្យបានច្បាស់អំពីរីសថលើរែន (Risk Tolerance) សម្រាប់សន្ធនីយភាពស្របនឹងយុទ្ធសាស្ត្រអាជីវកម្ម និងតួនាទីរបស់គ្រឹះស្ថាននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថា រីសថលើរែន (Risk Tolerance) នេះមានភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដែលអាចជួយគ្រឹះស្ថានក្នុងការគ្រប់គ្រងសន្ទនីយភាពប្រកបដោយប្រសិទ្ធភាពដើម្បីទប់ទល់នឹងស្ថានភាពតានតឹងដែលអូសបន្លាយ។ រីសថលើរែន (Risk Tolerance) នេះ ត្រូវរៀបចំដោយគិតពីភាពងាយរងគ្រោះជាក់លាក់របស់គ្រឹះស្ថាន និងត្រូវពិនិត្យឡើងវិញយ៉ាងតិចម្តងក្នុងមួយឆ្នាំដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពហិរញ្ញវត្ថុនិងសមត្ថភាពប្រមូលទុន។

ប្រការ ៧.-

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព តម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន។

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីអនុវត្តដើម្បីគ្រប់គ្រងហានិភ័យសន្ទនីយភាពស្របតាមរីសថលើរែន (Risk Tolerance) និងដើម្បីធានាថា គ្រឹះស្ថានរក្សាទុកសន្ទនីយភាពបានគ្រប់គ្រាន់។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវពិនិត្យឡើងវិញជាបន្តបន្ទាប់នូវព័ត៌មានអំពីការប្រែប្រួលសន្ទនីយភាពរបស់គ្រឹះស្ថានហើយរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជាប្រចាំ។ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យឡើងវិញ និងអនុម័តយុទ្ធសាស្ត្រ គោលនយោបាយ និងការអនុវត្តទាក់ទងទៅនឹងការគ្រប់គ្រងសន្ទនីយភាពយ៉ាងតិចម្តងក្នុងមួយឆ្នាំ ហើយត្រូវធានាថាគណៈគ្រប់គ្រងជាន់ខ្ពស់គ្រប់គ្រងហានិភ័យសន្ទនីយភាពប្រកបដោយប្រសិទ្ធភាព។

ក្នុងការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងសន្ទនីយភាពនេះ គ្រឹះស្ថានត្រូវពិចារណាលើទម្រង់គតិយុត្ត សកម្មភាពអាជីវកម្មសំខាន់ៗ វិសាលភាពនិងភាពសម្បូរបែបនៃផលិតផល ទីផ្សារនិងយុត្តាធិការដែលកំពុងធ្វើប្រតិបត្តិការ និងលក្ខខណ្ឌតម្រូវផ្នែកបទប្បញ្ញត្តិរបស់អាជ្ញាធរត្រួតពិនិត្យរួមទាំងបញ្ញត្តិការក្នុងនិងក្រៅប្រទេស (ប្រសិនបើមាន)។

គ្រឹះស្ថានត្រូវមានគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យគ្រប់គ្រាន់ ដើម្បីធានាថាក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់ទទួលបានរបាយការណ៍ទាន់ពេលវេលាអំពីបញ្ហាដែលអាចប៉ះពាល់ដល់សន្ទនីយភាព ដូចជា កំណើននៃថ្លៃដើម ឬការប្រមូលផ្តុំនៃប្រភពទុន ការកើនឡើងលក្ខខណ្ឌតម្រូវនៃប្រភពទុន កង្វះជម្រើសនៃប្រភពសន្ទនីយភាព ការបំពានលើកម្រិតកំណត់ធ្ងន់ធ្ងរឬជាប្រចាំ ការធ្លាក់ចុះទ្រព្យសកម្មសន្ទនីយមិនជាប់កាតព្វកិច្ច និងការប្រែប្រួលស្ថានភាពទីផ្សារ ដែលអាចជាសញ្ញានៃបញ្ហាសន្ទនីយភាពទៅអនាគត។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា ព័ត៌មាននៅក្នុងរបាយការណ៍ខាងលើមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការធ្វើសេចក្តីសម្រេចច្បាស់លាស់ដើម្បីចាត់វិធានការដោះស្រាយបញ្ហាដែលអាចប៉ះពាល់ដល់សន្ទនីយភាពរបស់គ្រឹះស្ថាន។

ប្រការ ៨.-

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវ៖

១. បង្កើតយុទ្ធសាស្ត្រ គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងសន្ទនីយភាព

២. ធានាថា គ្រឹះស្ថានមានសន្ទនីយភាពគ្រប់គ្រាន់គ្រប់ពេលវេលា រួមទាំងទ្រព្យសកម្មសន្ទនីយមិនជាប់កាតព្វកិច្ច ដើម្បីទប់ទល់នឹងស្ថានភាពតានតឹង

៣. កំណត់រចនាសម្ព័ន្ធ ការទទួលខុសត្រូវ និងការត្រួតពិនិត្យសម្រាប់គ្រប់គ្រងហានិភ័យសន្ធនីយភាពនិងត្រួតពិនិត្យស្ថានភាពសន្ធនីយភាពរបស់នីតិបុគ្គល សាខា និងបុត្តសម្ព័ន្ធទាំងអស់របស់គ្រឹះស្ថានដែលស្ថិតក្នុងយុត្តាធិការទាំងឡាយណាដែលគ្រឹះស្ថានកំពុងធ្វើប្រតិបត្តិការ ហើយការកំណត់ទាំងនេះត្រូវមានចែងច្បាស់នៅក្នុងគោលនយោបាយសន្ធនីយភាពរបស់គ្រឹះស្ថាន

៤. ធានាថាគ្រឹះស្ថានមានការត្រួតពិនិត្យផ្ទៃក្នុងគ្រប់គ្រាន់ ដើម្បីរក្សាសុចរិតភាពនៃដំណើរការគ្រប់គ្រងហានិភ័យសន្ធនីយភាព

៥. ធានាថា ការធ្វើស្ត្រេសតេស្ត ការរៀបចំផែនការទុនយថាភាព និងការកាន់កាប់ទ្រព្យសកម្មសន្ធនីយមានប្រសិទ្ធភាពនិងសមស្របសម្រាប់សកម្មភាពរបស់គ្រឹះស្ថាន

៦. កំណត់ខ្លឹមសារនៅក្នុងរបាយការណ៍ដោយមានបញ្ជាក់ច្បាស់អំពីវិសាលភាព ភាពញឹកញាប់នៃការរាយការណ៍និងអ្នកទទួលខុសត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងគណៈកម្មការទ្រព្យសកម្ម/ទ្រព្យអកម្មជាដើម។ ព័ត៌មានស្តីពីការវិវត្តនៃស្ថានភាពសន្ធនីយភាពត្រូវមានការពិនិត្យឡើងវិញនិងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជាប្រចាំ

៧. តាមដានយ៉ាងដិតដល់អំពីនិន្នាការបច្ចុប្បន្ននិងការវិវត្តនៃទីផ្សារ ដែលអាចនាំឱ្យមានការប្រឈមធ្ងន់ធ្ងរ មិនអាចព្យាករណ៍បាន និងស្មុគស្មាញសម្រាប់ការគ្រប់គ្រងហានិភ័យសន្ធនីយភាពដែលឈានដល់ការផ្លាស់ប្តូរយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យឱ្យបានសមស្រប និងទាន់ពេលវេលាបានតាមការចាំបាច់

៨. បង្កើតនីតិវិធីជាក់លាក់ និងការអនុមតិចាំបាច់ចំពោះការលើកលែងការអនុវត្តតាមគោលនយោបាយនិងកម្រិតកំណត់នានា រួមទាំងនីតិវិធីនិងវិធានការតាមដានការអនុវត្តទាំងនេះ

៩. ផ្សព្វផ្សាយផ្ទៃក្នុងអំពីយុទ្ធសាស្ត្រគ្រប់គ្រងសន្ធនីយភាពគោលនយោបាយគន្លឹះសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យសន្ធនីយភាព និង

១០. ធានាថា ផ្នែកអាជីវកម្មនីមួយៗដែលសកម្មភាពរបស់ខ្លួនមានផលប៉ះពាល់ដល់សន្ធនីយភាពត្រូវយល់ឱ្យបានច្បាស់អំពីយុទ្ធសាស្ត្រគ្រប់គ្រងសន្ធនីយភាព និងត្រូវធ្វើសកម្មភាពប្រតិបត្តិការស្របតាមគោលនយោបាយ នីតិវិធី កម្រិតកំណត់ និងការត្រួតពិនិត្យដែលបានអនុម័ត។

ប្រការ ៩.-

គ្រឹះស្ថានត្រូវគិតអំពីកត្តាចំណេញ-ខាត និងហានិភ័យសន្ធនីយភាពក្នុងការកំណត់ថ្លៃការវាស់វែងលទ្ធផលប្រតិបត្តិការ និងដំណើរការអនុម័តផលិតផលថ្មី ចំពោះគ្រប់សកម្មភាពអាជីវកម្មសំខាន់ៗ (ទាំងក្នុងនិងក្រៅតារាងតុល្យការ) ដើម្បីឱ្យស្របនឹងអត្ថប្រយោជន៍ដែលទទួលបានពីការទទួលយកហានិភ័យនៃផ្នែកអាជីវកម្មនីមួយៗ និងហានិភ័យសន្ធនីយភាពដែលប៉ះពាល់ដល់សកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានទាំងមូល។

ប្រការ ១០.-

ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពត្រូវតែបានពិនិត្យឡើងវិញជាប្រចាំដោយឯករាជ្យ ប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។ មុខងារត្រួតពិនិត្យឡើងវិញនេះត្រូវតែដំណើរការដោយឯករាជ្យ និងមានបុគ្គលិកដែលមានជំនាញ និងមានសិទ្ធិអំណាចក្នុងការពិភាក្សាដេញដោលជាមួយផ្នែករតនាគាររបស់គ្រឹះស្ថាន និងផ្នែកគ្រប់គ្រងហានិភ័យសន្ទនីយភាព។

សវនកម្មផ្ទៃក្នុង ត្រូវពិនិត្យឡើងវិញដោយឯករាជ្យនូវក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព ជាទៀងទាត់យ៉ាងតិចម្តងក្នុងមួយឆ្នាំ និងត្រូវរាយការណ៍អំពីលទ្ធផលនៃការពិនិត្យឡើងវិញនោះជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់។ គ្រឹះស្ថានត្រូវដោះស្រាយជាបន្ទាន់នូវចំណុចខ្វះខាតដែលបានពិនិត្យឃើញដោយបុគ្គលិកដែលទទួលបន្ទុកគ្រប់គ្រងសន្ទនីយភាព ឬសវនករផ្ទៃក្នុង។

ជំពូកទី៣
ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ប្រការ ១១.-

ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវមានធាតុសំខាន់ៗយ៉ាងតិច ដូចខាងក្រោម៖

១. របាយការណ៍ស្តីពី រីសអាប់តៃថាយ (Risk Appetite) និងរីសថលើរែន (Risk Tolerance) របស់គ្រឹះស្ថាន

២. យុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងហានិភ័យសន្ទនីយភាព

៣. ស្តង់ដារប្រតិបត្តិការរបស់គ្រឹះស្ថានដើម្បីកំណត់ វាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យសន្ទនីយភាពស្របតាមរីសថលើរែន (Risk Tolerance)

៤. នីតិវិធី និងវិធីសាស្ត្រសម្រាប់ប្រើប្រាស់ធ្វើស្ត្រេសតេស្តនិងការវិភាគសេណារីយ៉ូ ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ

៥. យុទ្ធសាស្ត្រប្រភពទុន និងផែនការទុនយថាភាពដូចមានចែងក្នុងប្រការ ២១ នៃប្រកាសនេះ។

ការគ្រប់គ្រងហានិភ័យសន្ទនីយភាពត្រូវរាប់បញ្ចូលទាំងហានិភ័យដែលពាក់ព័ន្ធនឹងសន្ទនីយភាពក្នុងថ្ងៃ ព្រមទាំងហានិភ័យសន្ទនីយភាពរយៈពេលខ្លី មធ្យម និងវែង។

គ្រឹះស្ថានក៏ត្រូវបញ្ចូលក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព ទៅក្នុងដំណើរការគ្រប់គ្រងហានិភ័យរួម ផងដែរ។

ប្រការ ១២.-

របាយការណ៍អំពីរីសអាប់តៃថាយ (Risk Appetite) របស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ឱ្យច្បាស់អំពីរីសអាប់តៃថាយនៃសន្ទនីយភាព (Liquidity Risk Appetite) និងរីសថលើរែននៃសន្ទនីយភាព (Liquidity Risk Tolerance) របស់គ្រឹះស្ថាន។

គ្រឹះស្ថានត្រូវរៀបចំចងក្រងរបាយការណ៍រឹសថលើវែន (Risk Tolerance) ឱ្យបានត្រឹមត្រូវ និងស្របតាមចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម។ របាយការណ៍រឹសថលើវែន (Risk Tolerance) នេះត្រូវគិតអំពី៖

១. តម្រូវការសន្ទនីយភាពនៅក្នុងនិងក្រៅតារាងតុល្យការ

២. ចរិតលក្ខណៈនៃទំនាក់ទំនងរបស់គ្រឹះស្ថានជាមួយភាគទុនិក និងសម្ព័ន្ធញាតិផ្សេងទៀត និង

៣. ចរិតលក្ខណៈនៃប្រព័ន្ធធនាគារនៅកម្ពុជា។

ប្រការ ១៣.-

យុទ្ធសាស្ត្រគ្រប់គ្រងសន្ទនីយភាព ត្រូវរួមបញ្ចូលគោលនយោបាយជាក់លាក់អំពីការគ្រប់គ្រងហានិភ័យសន្ទនីយភាពដោយត្រូវមានចំណុចសំខាន់ៗយ៉ាងតិចដូចខាងក្រោម៖

១. សមាសធាតុ និងឥណប្រតិទាននៃទ្រព្យសកម្មនិងទ្រព្យអកម្ម និងខ្នង់ក្រៅតារាងតុល្យការ

២. ពិពិធកម្មនិងស្ថិរភាពនៃប្រភពទុន

៣. វិធីសាស្ត្រគ្រប់គ្រងសន្ទនីយភាពតាមប្រភេទរូបិយប័ណ្ណ ប្រតិបត្តិការឆ្លងប្រទេស និងទូទាំងផ្នែកអាជីវកម្ម និងនីតិបុគ្គលផ្សេងៗ ដែលជាក្រុមហ៊ុនបុត្តសម្ព័ន្ធ ឬសាខារបស់គ្រឹះស្ថាន

៤. វិធីសាស្ត្រគ្រប់គ្រងសន្ទនីយភាពក្នុងថ្ងៃ

៥. តម្រូវការសន្ទនីយភាពក្នុងស្ថានភាពធម្មតានិងស្ថានភាពតានតឹងដោយរួមបញ្ចូលគោលដៅទាំងបរិមាណនិងគុណភាព។

វិធីសាស្ត្រវាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យសន្ទនីយភាពអាចជួយឱ្យគ្រឹះស្ថានបំពេញតម្រូវការសន្ទនីយភាពប្រសិនបើមានលំហូរចេញនៃសាច់ប្រាក់ក្នុងពេលណាមួយ ដោយកំណត់បរិមាណទុនបន្ថែម (Buffer) លើសពីកម្រិតកំណត់នៃបទប្បញ្ញត្តិស្របតាមរឹសថលើវែន (Risk Tolerance) របស់គ្រឹះស្ថាន។

គ្រឹះស្ថានត្រូវដាក់ចេញកម្រិតកំណត់ជាក់លាក់ ដើម្បីគ្រប់គ្រងហានិភ័យសន្ទនីយភាព និងស្ថានភាពងាយរងគ្រោះ។ គ្រឹះស្ថានត្រូវចាត់វិធានការដោះស្រាយភ្លាមក្នុងករណីមិនអាចគោរពតាមកម្រិតកំណត់។ កម្រិតកំណត់ និងនីតិវិធីដោះស្រាយហានិភ័យសន្ទនីយភាព ត្រូវមានការពិនិត្យឡើងវិញជាប្រចាំ។

គ្រឹះស្ថានត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ននូវស្ថានភាពសន្ទនីយភាព និងហានិភ័យសន្ទនីយភាពក្នុងថ្ងៃ ដើម្បីបំពេញកាតព្វកិច្ចទូទាត់ឱ្យបានទាន់ពេលវេលា ទាំងក្នុងស្ថានភាពធម្មតានិងតានតឹងដែលនឹងរួមចំណែកដល់ប្រក្រតីភាពនៃដំណើរការប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់។

ប្រការ ១៤.-

គ្រឹះស្ថានត្រូវមានប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចជឿជាក់បាន ដែលអាចផ្តល់ព័ត៌មានស្តីពីស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានបានទាន់ពេលវេលានិងផ្អែកលើទស្សន:អនាគតជូនក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកពាក់ព័ន្ធ។ ប្រព័ន្ធនេះត្រូវរួមបញ្ចូលការព្យាករណ៍សន្ទនីយភាពដែលបង្ហាញពីការរិភាគ "ភាពមិនស៊ីគ្នានៃលំហូរសាច់ប្រាក់" ឬ "គម្លាតសន្ទនីយភាព" ដោយផ្អែកលើសម្មតិកម្មនៃលក្ខណៈទ្រព្យសកម្មទ្រព្យអកម្ម និងខ្វង់ក្រៅតារាងតុល្យការ នាពេលខាងមុខ។ ការរិភាគនេះត្រូវបានប្រើប្រាស់សម្រាប់គណនាលំហូរសាច់ប្រាក់សុទ្ធបង្គរក្នុងរយៈពេលជាក់លាក់ណាមួយ។

ប្រការ ១៥.-

ចំពោះដំណើរការគ្រប់គ្រងហានិភ័យសន្ទនីយភាព គ្រឹះស្ថានត្រូវបញ្ចូលការព្យាករណ៍លំហូរសាច់ប្រាក់លម្អិត ដែលអាចបង្ហាញពីប្រភពហានិភ័យសន្ទនីយភាពសំខាន់ៗ។ លើសពីនេះ សម្មតិកម្មអំពីតម្រូវការសន្ទនីយភាពរយៈពេលខ្លីនិងវែងត្រូវឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃអាជីវកម្មនិងផលិតផលរបស់គ្រឹះស្ថាន។

នៅពេលព្យាករណ៍លំហូរសាច់ប្រាក់ គ្រឹះស្ថានត្រូវគិតដល់៖

១. កត្តាដែលមានឥទ្ធិពលដល់ភាពមិនងាយហូរចេញនៃប្រាក់បញ្ញើរាយដូចជា ទំហំ វេទយិតភាពអត្រាការប្រាក់ និងមធ្យោបាយនៃលំហូរប្រាក់បញ្ញើ (ការដាក់ប្រាក់បញ្ញើដោយផ្ទាល់ តាមប្រព័ន្ធអ៊ីនធឺណែត ឬតាមរយៈជើងសាករ ជាដើម)

២. ការព្យាករណ៍ផលប៉ះពាល់នៃកិច្ចសន្យាមិនទាន់ប្រើប្រាស់ ដែលនឹងត្រូវអនុវត្តដោយគិតពីប្រភេទនៃកិច្ចសន្យា និងលទ្ធភាពសងរបស់សមភាគី ព្រមទាំងការប្រឈមនឹងហានិភ័យទៅតាមវិស័យនិងតំបន់ធ្វើធុរកិច្ច

៣. ការកំណត់ និងការគ្រប់គ្រងទ្រព្យធានាដោយបែងចែកច្បាស់លាស់រវាងទ្រព្យសកម្មជាប់កាតព្វកិច្ចនិងទ្រព្យសកម្មមិនជាប់កាតព្វកិច្ច។

ប្រការ ១៦.-

គ្រឹះស្ថានត្រូវបង្កើតយុទ្ធសាស្ត្រប្រមូលទុនប្រចាំឆ្នាំដែលប្រភពទុននេះមានលក្ខណៈពិពិធកម្មសមស្រប។ យុទ្ធសាស្ត្រនេះត្រូវមានចំណុចសំខាន់ៗយ៉ាងតិចដូចខាងក្រោម៖

១. លទ្ធភាពទទួលបានប្រភពទុនពីទីផ្សារនិងទំនាក់ទំនងល្អជាមួយអ្នកផ្តល់ទុន

២. ការវាយតម្លៃជាប្រចាំលើសមត្ថភាពក្នុងការស្វែងរកទុនទាន់ពេលវេលា។ គ្រឹះស្ថានត្រូវកំណត់កត្តាសំខាន់ៗដែលប៉ះពាល់ដល់លទ្ធភាពស្វែងរកទុន និងតាមដានកត្តាទាំងនោះឱ្យបានដិតដល់ដើម្បីធានាថា ការព្យាករណ៍អំពីសមត្ថភាពស្វែងរកទុននៅតែមានសុពលភាព

៣. សម្មតិកម្មច្បាស់លាស់ស្របតាមយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យសន្ទនីយភាព

៤. សមាសធាតុទាំងផ្នែកគុណភាព និងបរិមាណនៃសន្ទនីយភាពដែលមាននៅក្នុងតារាងតុល្យការនិងលទ្ធផលសំខាន់ៗ។

គ្រឹះស្ថានត្រូវពិនិត្យយុទ្ធសាស្ត្រប្រមូលទុននិងរាយការណ៍ទៅក្រុមប្រឹក្សាភិបាលជាប្រចាំ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ស្របតាមបម្រែបម្រួលនៃលក្ខខណ្ឌប្រភពទុន និង/ឬ ការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។

ប្រការ ១៧.-

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានណាមួយ ឬក្រុមគ្រឹះស្ថាន បង្កើនកាតព្វកិច្ចសន្ទនីយភាពដែលត្រូវបានកំណត់ថាចាំបាច់ទៅតាមកម្រិតហានិភ័យរបស់គ្រឹះស្ថាននីមួយៗ ឬរបស់ប្រព័ន្ធធនាគារទាំងមូល ឬតម្រូវឱ្យមានវិធានការកាត់បន្ថយផ្សេងៗ ដើម្បីរក្សាបានជានិច្ចនូវសន្ទនីយភាពគ្រប់គ្រាន់ស្របតាមកាតព្វកិច្ចនៃបទប្បញ្ញត្តិ។

ជំពូកទី៤
សូចនាករផ្តល់សញ្ញាជាមុន

ប្រការ ១៨.-

គ្រឹះស្ថានត្រូវបង្កើតសូចនាករផ្តល់សញ្ញាជាមុន ជាជំនួយក្នុងដំណើរការគ្រប់គ្រងហានិភ័យសន្ទនីយភាពប្រចាំថ្ងៃ ដើម្បីកំណត់សញ្ញានៃការកើនឡើងហានិភ័យ ឬភាពងាយរងគ្រោះនៃស្ថានភាពហានិភ័យសន្ទនីយភាព ឬតម្រូវការទុនចាំបាច់របស់គ្រឹះស្ថាន។ សូចនាករផ្តល់សញ្ញាជាមុននេះ ត្រូវបានរៀបចំឡើងដើម្បីជួយកំណត់និន្នាការអវិជ្ជមាននៃស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថាន និងឈានទៅវាយតម្លៃជាបន្តបន្ទាប់និងចាត់វិធានការឆ្លើយតបចាំបាច់ដើម្បីកាត់បន្ថយហានិភ័យ។

សូចនាករផ្តល់សញ្ញាជាមុនអាចមានលក្ខណៈជាគុណភាព ឬបរិមាណ ដែលត្រូវមានចំណុចសំខាន់ៗយ៉ាងតិចដូចខាងក្រោម៖

១. កំណើនការប្រមូលផ្តុំនៃទ្រព្យសកម្មឬទ្រព្យអកម្ម
២. កំណើននៃភាពមិនស៊ីគ្នានៃរូបិយប័ណ្ណ
៣. កំណើននៃភាពមិនស៊ីគ្នានៃឥណប្រតិទាន
៤. ការថយចុះនៃឥណប្រតិទានជាមធ្យមនៃទ្រព្យអកម្មដែលបានថ្លឹង
៥. ការខិតជិតឬការល្មើសដដែលៗទៅលើកម្រិតកំណត់ផ្ទៃក្នុង ឬកម្រិតកំណត់ដោយបទប្បញ្ញត្តិ
៦. ការធ្លាក់ចុះយ៉ាងគំហុកនៃប្រាក់ចំណេញ គុណភាពទ្រព្យសកម្ម និងស្ថានភាពហិរញ្ញវត្ថុ
៧. ការផ្សព្វផ្សាយជាអវិជ្ជមាន
៨. ការធ្លាក់ចុះនៃចំណាត់ថ្នាក់ឥណទាន
៩. ការធ្លាក់ចុះនៃតម្លៃភាគហ៊ុន
១០. ការកើនឡើងថ្លៃដើមនៃបំណុលនិងប្រាក់បញ្ញើ

១១. សមភាគីដែលចាប់ផ្តើមទារទ្រព្យធានាបន្ថែមសម្រាប់ឥណទានដែលមានស្រាប់ ឬដែលបដិសេធមិនធ្វើប្រតិបត្តិការថ្មី

១២. ធនាគារទំនាក់ទំនងដែលកាត់បន្ថយឬលុបចោលកម្រិតបន្ទាត់ឥណទាន

១៣. ការកើនឡើងនៃលំហូរចេញប្រាក់បញ្ញើរាយ

១៤. ការកើនឡើងនៃការដកប្រាក់បញ្ញើមានកាលកំណត់មុនឥណប្រតិទាន

១៥. ការលំបាកក្នុងការស្វែងរកទុនរយៈពេលវែង

១៦. ការលំបាកក្នុងការស្វែងរកទ្រព្យអកម្មរយៈពេលខ្លី (ផលបត្រពាណិជ្ជកម្ម ជាដើម)

១៧. ការកើនឡើងទ្រព្យអកម្មយថាភាពរយៈពេលខ្លី

១៨. ការលំបាកក្នុងការស្វែងរកទុនពីបរទេស។

ជំពូកទី៥
ស្ត្រេសតេស្តនិងការវិភាគសេណារីយ៉ូ

ប្រការ ១៩.-

គ្រឹះស្ថានត្រូវធ្វើស្ត្រេសតេស្តសន្ទនីយភាពឱ្យបានទៀងទាត់ យ៉ាងហោចណាស់មួយឆ្នាំម្តង ឬច្រើនដងតាមការចាំបាច់ ដោយប្រើប្រាស់សេណារីយ៉ូផ្សេងៗគ្នា ដូចជា សេណារីយ៉ូរយៈពេលខ្លីមធ្យម និងវែង សេណារីយ៉ូកម្រិតគ្រឹះស្ថាននិងកម្រិតទីផ្សារ និងត្រូវមានហេតុផលសមស្របក្នុងការកំណត់យកសម្មតិកម្មសម្រាប់ធ្វើស្ត្រេសតេស្ត។ ការធ្វើស្ត្រេសតេស្តចាំបាច់ត្រូវរាប់បញ្ចូលឧបករណ៍ហិរញ្ញវត្ថុទាំងក្នុងនិងក្រៅតារាងតុល្យការ។

គ្រឹះស្ថានត្រូវរៀបចំចងក្រងសេណារីយ៉ូស្ត្រេសតេស្តនិងសម្មតិកម្មពាក់ព័ន្ធផ្សេងទៀត និងរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ ព្រមទាំងពិនិត្យឡើងវិញជាមួយនឹងលទ្ធផលស្ត្រេសតេស្តដែលទទួលបាន។

គ្រឹះស្ថានត្រូវរាយការណ៍អំពីលទ្ធផលស្ត្រេសតេស្តនិងភាពងាយរងគ្រោះ ដោយលើកជាផែនការសកម្មភាព ដើម្បីចាត់វិធានការជូនក្រុមប្រឹក្សាភិបាល។ លទ្ធផលនៃស្ត្រេសតេស្តត្រូវដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យសន្ទនីយភាព និងនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ក៏ដូចជាក្នុងការរៀបចំផែនការទុនយថាភាពរបស់គ្រឹះស្ថានផងដែរ។ លទ្ធផលនេះ ត្រូវចាត់ទុកជាមូលដ្ឋានយ៉ាងសំខាន់ក្នុងការដាក់ចេញកម្រិតកំណត់សន្ទនីយភាពផ្ទៃក្នុងរបស់គ្រឹះស្ថាន។

កម្មវិធីស្ត្រេសតេស្ត ជាទូទៅ ត្រូវគិតអំពីសេណារីយ៉ូទស្សនៈអនាគត ដោយរាប់បញ្ចូលពីបម្រែបម្រួលនៃសមាសធាតុក្នុងសំវៀតនៃឧបករណ៍ហិរញ្ញវត្ថុទាំងក្នុងនិងក្រៅតារាងតុល្យការ រួមទាំងព័ត៌មាន និងហានិភ័យដែលអាចកើតឡើងថ្មីៗ ដែលមិនធ្លាប់បានដាក់បញ្ចូលក្នុងការធ្វើស្ត្រេសតេស្តពីមុន។ ការពិភាក្សានិងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងជាន់ខ្ពស់នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានចាំបាច់ក្នុងការវិភាគសេណារីយ៉ូ។ ការធ្វើស្ត្រេសតេស្ត និងការវិភាគសេណារីយ៉ូត្រូវរាប់បញ្ចូលសម្មតិកម្មអវិជ្ជមានសំខាន់ៗយ៉ាងតិចដូចខាងក្រោម៖

១. ទ្រព្យសកម្មដែលគ្មានទីផ្សារ និងការធ្លាក់ចុះនៃតម្លៃរបស់ទ្រព្យសកម្មសន្ធនីយ
២. ការដកប្រាក់បញ្ញើរាយ
៣. លទ្ធភាពរបស់គ្រឹះស្ថានក្នុងការបំប្លែងទ្រព្យសកម្មទៅជាសាច់ប្រាក់
៤. ទំនាក់ទំនងរវាងទីផ្សារផ្តល់ទុនឬប្រសិទ្ធភាពនៃពិធកម្មប្រភពទុន
៥. តម្រូវការបន្ថែមលើម៉ាជីនខល (Margin Calls) និងតម្រូវការទ្រព្យធានា
៦. អ្នកផ្តល់ទុន
៧. ការប៉ាន់ស្មានទៅលើកំណើននៃតារាងតុល្យការ
៨. ឥណទេយ្យយថាភាព ជាពិសេស លទ្ធភាពនៃការប្រើប្រាស់បន្ទាត់ឥណទានរបស់តតិយភាគីឬបុគ្គសម្ព័ន្ធ សាខា ឬស្មាក់ការកណ្តាលរបស់គ្រឹះស្ថាន
៩. សន្ធនីយភាពដែលប្រើប្រាស់សម្រាប់ខ្ចង់ក្រៅតារាងតុល្យការ និងសកម្មភាពផ្សេងៗ
១០. ការអាចរកបានប្រភពទុនដុំដែលមាននិងគ្មានការធានា
១១. បន្ទាត់ឥណទានយថាភាពដែលគ្រឹះស្ថានអាចរកបាន។

ប្រការ ២០.-

គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា អំពីសេណារីយ៉ូ និងលទ្ធផលស្ត្រេសតេស្ត ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ធនីយភាពយ៉ាងហោចណាស់ជាប្រចាំឆ្នាំ ឬតាមការចាំបាច់។

ជំពូកទី ៦
ផែនការទុនយថាភាព

ប្រការ ២១.-

គ្រឹះស្ថានត្រូវត្រៀមឆ្លើយតបភ្លាមៗនិងមានការសម្រេចចិត្តច្បាស់លាស់ក្នុងពេលមានសន្ធនីយភាពតានតឹង។ គ្រឹះស្ថានត្រូវបង្កើតផែនការទុនយថាភាពដែលរួមមានគោលនយោបាយ នីតិវិធី និងផែនការសកម្មភាពសម្រាប់ទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរដល់សមត្ថភាពរបស់គ្រឹះស្ថានក្នុងការផ្តល់ទុនដល់ប្រតិបត្តិការរបស់ខ្លួនទាន់ពេលវេលានិងតាមតម្លៃសមស្រប។

ផែនការទុនយថាភាពនេះ ត្រូវមានវិសាលភាព និងនីតិវិធី ស្របតាមការវិភាគហានិភ័យសន្ធនីយភាពជាប្រចាំ សម្មតិកម្មនិងលទ្ធផលនៃស្ត្រេសតេស្ត។ ផែនការនេះក៏ត្រូវកំណត់អំពីដំណោះស្រាយចំពោះបញ្ហាដែលកើតមាននៅតាមគ្រាខុសៗគ្នា រួមទាំងក្នុងថ្ងៃផងដែរ។

គ្រឹះស្ថានត្រូវរៀបចំផែនការនេះឱ្យស្របនឹងចរិតលក្ខណៈភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម។ ផែនការនេះត្រូវបញ្ជាក់ច្បាស់លាស់នូវប្រភពទុនយថាភាព ទំហំទុនដែលគ្រឹះស្ថានអាចរកបាន នីតិវិធីអាទិភាពសម្រាប់ស្វែងរកទុនដោយរៀបរាប់លម្អិតអំពីពេលវេលានិងវិធីសាស្ត្រក្នុងការអនុវត្តនីតិវិធីនីមួយៗ និងរយៈពេលដែលគ្រឹះស្ថានត្រូវការដើម្បីស្វែងរកទុនបន្ថែមពីប្រភពទុនយថាភាពទាំងនោះ។ ផែនការនេះត្រូវមានក្របខ័ណ្ឌសមស្របនិងមានភាពងាយបត់បែនដើម្បីឱ្យគ្រឹះស្ថានអាចឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រប់ស្ថានភាព។

ផែនការទុនយថាភាពត្រូវ ១). បញ្ជាក់អំពីវិធីដោះស្រាយទប់ទល់នឹងស្ថានភាពតានតឹងនានា ២). ចែងឱ្យច្បាស់លាស់អំពីកម្រិតនៃការទទួលខុសត្រូវ និង៣). ធ្វើតេស្តសាកល្បងនិងធ្វើបច្ចុប្បន្នកម្ម ជាប្រចាំដើម្បីធានាថាផែនការនេះនៅតែមានប្រសិទ្ធភាពអនុវត្ត។ គ្រឹះស្ថានត្រូវពិនិត្យឡើងវិញនិង ធ្វើបច្ចុប្បន្នកម្មផែនការនេះឱ្យបានយ៉ាងហោចណាស់មួយឆ្នាំម្តងឬច្រើនដងទៅតាមបម្រែបម្រួល ស្ថានភាពទីផ្សារនិងអាជីវកម្មជាក់ស្តែង និងស្នើសុំការអនុមតិពីក្រុមប្រឹក្សាភិបាល។

ចំពោះគ្រឹះស្ថានដែលពឹងផ្អែកខ្លាំងលើប្រាក់បញ្ញើរាយ ផែនការនេះត្រូវបង្ហាញពីការដកប្រាក់ បញ្ញើរាយយ៉ាងគំហុកនិងវិធីទូទាត់សងអ្នកដាក់ប្រាក់បញ្ញើរាយបានឆាប់រហ័ស។ ផែនការទុនយថាភាព សម្រាប់ការដកប្រាក់បញ្ញើរាយយ៉ាងគំហុកមិនត្រូវពឹងផ្អែកទៅលើការបិទមធ្យោបាយដកប្រាក់នានា របស់អតិថិជននោះទេ។ ក្នុងករណីដែលមានការបាត់បង់ជំនឿទុកចិត្តក្នុងទីផ្សារ ផែនការទុនយថាភាព សម្រាប់ការដកប្រាក់បញ្ញើរាយត្រូវធានាថា អ្នកដាក់ប្រាក់បញ្ញើរាយនឹងដកប្រាក់បញ្ញើរបស់ពួកគេ ភ្លាមៗ តាមលក្ខខណ្ឌកិច្ចសន្យានៃផលិតផលប្រាក់បញ្ញើទាំងនោះ។

គ្រឹះស្ថានត្រូវធានាថាព័ត៌មានទំនាក់ទំនងក្នុងផែនការនេះមានលក្ខណៈបច្ចុប្បន្នភាព និងមាន នីតិវិធីចាំបាច់ផ្អែកគតិយុត្តនិងប្រតិបត្តិការដើម្បីអនុវត្តផែនការទុនយថាភាពបានទាន់ពេលវេលា។

គ្រឹះស្ថានត្រូវរៀបចំចងក្រងផែនការទុនយថាភាពនេះនិងរក្សាទុកជាឯកសារ ហើយត្រូវ ផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

ប្រការ ២២.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាន នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៣.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៧-៣៤៤ ប្រ.ក

ប្រកាស
ស្តីពី
ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ុមតែរមិន

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់កាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ក្នុងការអនុវត្តផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ន។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅបញ្ជាក់ពីភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធី (Facilities) ដែលមានអ៊ុមតែរមិនរបស់គ្រឹះស្ថាន។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ហ្វាស៊ីលីធី (Facilities)** សំដៅដល់ប្រាក់កម្ចី និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទាំងនៅក្នុងឬក្រៅតារាងតុល្យការ ដែលគ្រឹះស្ថានបានផ្តល់ទៅឱ្យសមភាគី ហើយហ្វាស៊ីលីធីនេះអាចបង្កហានិភ័យឥណទានដល់គ្រឹះស្ថាន។ បណ្តុំនៃហ្វាស៊ីលីធីទាំងអស់ដែលមានចែងក្នុងប្រកាសនេះ ហៅថា "សំពៀតឥណទាន"។
- **សមភាគី** សំដៅដល់ អតិថិជន អ្នកខ្ចីប្រាក់ ឬបុគ្គលផ្សេងទៀត រួមមាន រូបវន្តបុគ្គល ឬនីតិបុគ្គល មានទំនាក់ទំនងជាមួយគ្រឹះស្ថាន។ សមភាគីនេះ ក៏អាចជាគ្រឹះស្ថានផ្សេងទៀតដែលមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយគ្នាផងដែរ។
- **ហានិភ័យឥណទាន** សំដៅដល់ហានិភ័យដែលសមភាគីមិនអាចអនុវត្តបានតាមកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យា។ ក្រៅពីកម្ចីដែលជាប្រភពចម្បងនៃហានិភ័យឥណទាន ប្រតិបត្តិការផ្សេងៗដែលមាននៅក្នុងបញ្ជីកាធនាគារ (Banking Book) និងបញ្ជីកាសម្រាប់ជួញដូរ (Trading Book) ទាំងក្នុងនិងក្រៅតារាងតុល្យការ ក៏ជាប្រភពនៃហានិភ័យ

ឥណទានដែរ។ គ្រឹះស្ថានអាចប្រឈមនឹងហានិភ័យឥណទាន ដែលអាចកើតមកពីឧបករណ៍ហិរញ្ញវត្ថុនានាក្រៅពីប្រាក់កម្ចី ដូចជា ការធ្វើស្វីការ (Acceptances) ហិរញ្ញប្បទានពាណិជ្ជកម្ម ការសន្យាផ្តល់ឥណទាននិងការធានា ប្រតិបត្តិការអន្តរធនាគារ ប្រតិបត្តិការទូទាត់ ប្រតិបត្តិការប្តូរប្រាក់ សញ្ញាបណ្ណ មូលបត្រកម្មសិទ្ធិ និងឧបករណ៍និស្សន្ទ ជាដើម។

- **ទ្រព្យធានា** សំដៅដល់ ការធានា ទ្រព្យ ឬទ្រព្យសកម្ម ដែលសមភាគីបានដាក់ធានាចំពោះហានិភ័យឥណទានរបស់គ្រឹះស្ថាន។
- **មូលធនកម្មការប្រាក់ (Interest Capitalization)** សំដៅដល់រាល់ការបង្គរការប្រាក់ និងការប្រាក់មិនអាចប្រមូលបានដែលត្រូវបូកបញ្ចូលក្នុងប្រាក់ដើមនៃឥណទាននៅថ្ងៃទូទាត់សងប្រាក់ ឬថ្ងៃឥណប្រតិទាន។ មូលធនកម្មការប្រាក់ក៏ត្រូវរួមបញ្ចូលផងដែរនូវការប្រាក់មិនបានទូទាត់ ហើយការប្រាក់នេះ ត្រូវបានប្រែក្លាយទៅជាប្រាក់កម្ចីថ្មី តាមរយៈការធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី។
- **ការខកខានទូទាត់សង (Default)** សំដៅដល់ការខកខានក្នុងការទូទាត់សងតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។
- **តម្លៃជាក់ស្តែង (Fair Value)** សំដៅដល់តម្លៃដែលទទួលបានពីប្រតិបត្តិការលក់ទ្រព្យសកម្ម ឬតម្លៃដែលត្រូវចំណាយលើប្រតិបត្តិការផ្ទេរទ្រព្យអកម្មរវាងអ្នកចូលរួមនៅក្នុងទីផ្សារនៅកាលបរិច្ឆេទទទួលស្គាល់តម្លៃនៃការទិញលក់។
- **អ៊ីមភែរមិន (Impairment)** សំដៅដល់ស្ថានភាពហ្វាស៊ីលីធីដែលស្ថិតក្នុងការសង្ស័យចំពោះលទ្ធភាពទូទាត់សងគ្រប់ចំនួននិងទាន់ពេលវេលារបស់សមភាគីតាមកិច្ចសន្យា។
- **ហួសកាលកំណត់សង (Past due)** សំដៅដល់ការខកខានរបស់សមភាគី ក្នុងការទូទាត់សងហ្វាស៊ីលីធីនៅថ្ងៃកំណត់តាមកិច្ចសន្យា។

ប្រការ ៥.-

ការចាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គឺជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូទៅដែលគ្រឹះស្ថានត្រូវអនុវត្ត។ ដើម្បីគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានត្រូវមាន៖

១. ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដែលមានលក្ខណៈសមស្របទៅនឹង ចរិតលក្ខណៈភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម

២. ការពិនិត្យឡើងវិញជាប្រចាំ ទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សកម្មភាព អតិថិជន និងហានិភ័យនានា

៣. ប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់ជាមុន ការតាមដាននិងការវាស់វែងហានិភ័យឥណទានឱ្យបានត្រឹមត្រូវ រួមទាំងការកំណត់ឱ្យបានពេញលេញនិងការរាយការណ៍អំពីហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការព្យាករណ៍ការខាតបង់នៃសំវៀតឥណទាន

៤. សំវិធានធនគ្រប់គ្រាន់សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា និង

៥. គោលនយោបាយ នីតិវិធី និងដំណើរការអនុវត្ត អនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់នៃប្រកាសនេះ។

ជំពូកទី ២
ការតាមដានហានិភ័យឥណទាន

ប្រការ ៦.-

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ត្រូវទទួលខុសត្រូវក្នុងការធានាថាការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធានធន ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឱ្យមានសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនក្នុងកម្រិតមួយសមស្របនិងគ្រប់គ្រាន់។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធានាលើការអនុវត្តចំពោះ ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងដំណើរការឱ្យស្របតាម ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពរបស់គ្រឹះស្ថាន។

ប្រការ ៧.-

ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តក្របខ័ណ្ឌ និងគោលនយោបាយសម្រាប់ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធានធន ព្រមទាំងគោលនយោបាយនៃការលុបចោលហ្វាស៊ីលីធី។ គោលនយោបាយនេះ ក៏ត្រូវកំណត់យន្តការតាមដាននិងរាយការណ៍ អំពីវិធានការប្រមូលមកវិញដែលគ្រឹះស្ថានត្រូវអនុវត្ត។

ប្រការ ៨.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា៖

១. នីតិវិធីនិងដំណើរការ អាចឱ្យគ្រឹះស្ថានកំណត់ឱ្យបានជាមុននូវការធ្វើចំណាត់ថ្នាក់ ការវាយតម្លៃ និងការដោះស្រាយបញ្ហាគុណភាពឥណទាន

២. ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីគុណភាពឥណទាន និងសំវិធានធនដែលពាក់ព័ន្ធទៅនឹងឥណទានឱ្យបានទៀងទាត់និងតាមពេលកំណត់

៣. ការវិនិច្ឆ័យលើមុខងារត្រួតពិនិត្យឡើងវិញនិងគ្រប់គ្រង ធ្វើឡើងស្របតាមគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន និង

៤. ការត្រួតពិនិត្យផ្ទៃក្នុងលើការវាយតម្លៃហានិភ័យឥណទាន និងដំណើរការធ្វើសំវិធានធន ធ្វើឡើងឱ្យបានត្រឹមត្រូវនិងទៀងទាត់ ដោយបុគ្គលដែលមានឯករាជ្យភាពពីប្រតិបត្តិការឥណទានរបស់គ្រឹះស្ថាន។

ប្រការ ៩.-

ក្រុមប្រឹក្សាភិបាល ត្រូវពិនិត្យឡើងវិញលើគោលនយោបាយនិងនីតិវិធី យ៉ាងតិចមួយឆ្នាំម្តង ដើម្បីធានាថា គោលនយោបាយនិងនីតិវិធីទាំងនេះនៅតែមានសង្គតិភាពជាមួយនឹងសកម្មភាព ស្ថានភាពសេដ្ឋកិច្ច អតិថិជន និងហានិភ័យឥណទានរបស់គ្រឹះស្ថាន។

ប្រការ ១០.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយនិងនីតិវិធីសម្រាប់កំណត់សំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ចំពោះហ្វាស៊ីលីធីទោល និងហ្វាស៊ីលីធីក្រុម ព្រមទាំងគោលនយោបាយនៃការលុបចោលហ្វាស៊ីលីធី ត្រូវតែបានអនុវត្តតាមឱ្យបានទាន់ពេលវេលា និងសមស្របទៅនឹងសកម្មភាព និងទម្រង់ហានិភ័យឥណទានរបស់គ្រឹះស្ថាន។

ប្រការ ១១.-

គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវទទួលខុសត្រូវក្នុងការរៀបចំ និងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលនយោបាយនិងនីតិវិធីនានាដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ទាក់ទងនឹងការវាយតម្លៃឥណទាន ការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការលុបចោលហ្វាស៊ីលីធី។ គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវធានាថា៖

១. បុគ្គលិកពាក់ព័ន្ធ ត្រូវយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តដោយសង្គតិភាពនូវគោលនយោបាយផ្ទៃក្នុង នីតិវិធី និងដំណើរការត្រួតពិនិត្យឥណទានឡើងវិញនិងការធ្វើសំវិធានធន

២. ដំណើរការធ្វើសំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវអនុវត្តឱ្យបានសមស្របមានលក្ខណៈជាប្រព័ន្ធនិងមានសង្គតិភាព ដើម្បីជួយសម្រួលដល់ការប្រមូលឱ្យបានទាន់ពេលវេលា នូវព័ត៌មានបន្ថែម ឬថ្មីៗ ទាក់ទងទៅនឹងលទ្ធភាពប្រមូលមកវិញនៃហ្វាស៊ីលីធីក្នុងគោលបំណងកំណត់សំវិធានធនទៅលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិននោះ។ យ៉ាងហោចណាស់ ដំណើរការនេះត្រូវផ្តល់ព័ត៌មានសមស្រប និងទាន់ពេលវេលាអំពី៖

   ក. ហ្វាស៊ីលីធីដែលហួសកាលកំណត់សង

   ខ. ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

   គ. តម្លៃជាក់ស្តែងរបស់ទ្រព្យធានាលើហ្វាស៊ីលីធី

   ឃ. ប្រភពផ្សេងទៀតនៃលំហូរសាច់ប្រាក់ ដែលគ្រឹះស្ថានអាចប្រើជាមូលដ្ឋានក្នុងការកំណត់កម្រិតនៃអ៊ីមភែរមិន និងទំហំនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និង

   ង. ទំហំសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនដែលត្រូវកត់ត្រា។

៣. ការតាមដាននិងការត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ននិងត្រឹមត្រូវ ត្រូវបានអនុវត្តចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ការធ្វើសំវិធានធន និងការប្រមូលមកវិញចំពោះហ្វាស៊ីលីធីដែលបានលុបចោល។

ជំពូកទី ៣
ការចាត់ថ្នាក់ហានិភ័យឥណទាន

ប្រការ ១២.-

ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទានដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ត្រូវរួមបញ្ចូលប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានដែលបានកំណត់ច្បាស់លាស់ ដោយត្រូវកំណត់ការទទួលខុសត្រូវលម្អិតរបស់បុគ្គលពាក់ព័ន្ធនៅក្នុងគ្រឹះស្ថាន។

ប្រការ ១៣.-

គ្រឹះស្ថានត្រូវរៀបចំដំណើរការចាត់ថ្នាក់ហ្វាស៊ីលីធីឱ្យមានលក្ខណៈជាប្រព័ន្ធ និងមានសង្គតិភាព ដោយផ្អែកលើមូលដ្ឋានហានិភ័យឥណទាន។ ក្នុងគោលបំណងនេះ គ្រឹះស្ថានត្រូវមានប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទាន ដែលសមស្របទៅនឹងកម្រិតហានិភ័យពាក់ព័ន្ធនឹង ចរិតលក្ខណៈភាពស្មុគស្មាញ និងទំហំនៃហ្វាស៊ីលីធីរបស់គ្រឹះស្ថាន។ ហ្វាស៊ីលីធីធំៗនឹងត្រូវធ្វើចំណាត់ថ្នាក់ដោយផ្អែកតាមវិធីសាស្ត្រវាយតម្លៃហានិភ័យឥណទានដែលមានលក្ខណៈពិស្តារ ចំណែកឯហ្វាស៊ីលីធីតូចៗដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នានិងស្ថិតក្រោមការគ្រប់គ្រងសំពៀតតែមួយ អាចត្រូវបានចាត់ថ្នាក់ដោយផ្អែកតាមវិធីសាស្ត្រចាត់ថ្នាក់ឥណទាននេះ ឬអាចចាត់ថ្នាក់តាមប្រវត្តិហ្វាស៊ីលីធីខាតបង់។ ការចាត់ថ្នាក់ហានិភ័យឥណទានប្រកបដោយភាពជឿជាក់បាន នឹងជួយក្នុងការវាយតម្លៃហ្វាស៊ីលីធីដោយប្រុងប្រយ័ត្ន និងកំណត់ការធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៥៨ ដល់ ប្រការ ៥២ នៃប្រកាសនេះ។

ប្រការ ១៤.-

គ្រឹះស្ថានត្រូវរក្សាទុកសំណុំឯកសារឥណទានរបស់សមភាគីទាំងអស់ជារូបវន្ត និង/ឬអេឡិកត្រូនិក ដែលត្រូវមានព័ត៌មានគ្រប់គ្រាន់និងទាន់ពេលវេលាអំពីលទ្ធភាពសងបំណុលរបស់សមភាគីដើម្បី៖

១. សម្រួលដល់ការតាមដាន និងការត្រួតពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីទាំងអស់របស់គ្រឹះស្ថានឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព និង

២. សម្រួលដល់សវនករផ្ទៃក្នុងនិងក្រុមហ៊ុនសវនកម្មឱ្យទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ការផ្តល់មតិយោបល់ច្បាស់លាស់និងដោយសត្យានុម័ត ទៅលើគុណភាពហ្វាស៊ីលីធីទាំងអស់ក្នុងសំពៀតឥណទាន។

ប្រការ ១៥.-

គ្រឹះស្ថានត្រូវអនុវត្តការពិនិត្យឡើងវិញឱ្យមានលក្ខណៈជាប្រព័ន្ធនិងទៀងទាត់ចំពោះហ្វាស៊ីលីធីទាំងអស់ ទោះបីជាមាន ឬមិនមានអ៊ីមភែរមិន រួមបញ្ចូលទាំងខ្នង់ក្រៅតារាងតុល្យការដើម្បីឱ្យការចាត់ថ្នាក់ហ្វាស៊ីលីធីអាចធ្វើទៅបានទាន់ពេលវេលា។ គ្រឹះស្ថានត្រូវកំណត់វដ្តនៃការពិនិត្យឡើងវិញទៅតាមប្រភេទផ្សេងៗគ្នានៃហ្វាស៊ីលីធី។ ការពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីជាលក្ខណៈទោល និងហ្វាស៊ីលីធីដែលមានហានិភ័យខ្ពស់ ត្រូវមានវដ្តនៃការពិនិត្យឡើងវិញញឹកញាប់។ វដ្តនៃការពិនិត្យឡើងវិញនេះមិនត្រូវមានរយៈពេលលើសពីមួយឆ្នាំទេ។

ប្រការ ១៦.-

ការចាត់ថ្នាក់ហានិភ័យឥណទាន ត្រូវបានធ្វើឡើងឱ្យបានលម្អិត ច្បាស់លាស់ និងគ្រប់គ្រាន់ទៅតាមកម្រិតនៃហានិភ័យឥណទានរបស់គ្រឹះស្ថាន។ គ្រឹះស្ថានត្រូវបែងចែកហ្វាស៊ីលីធីតាមប្រភេទ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើសមត្ថភាពទូទាត់សងរបស់សមភាគីតាមរយៈប្រភពចំណូលជាក់ស្តែង។

លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃសមត្ថភាពទូទាត់សងរបស់សមភាគី ត្រូវមានចំណុចយ៉ាងតិច ដូចខាងក្រោម៖

១. ប្រវត្តិទូទាត់សង

២. ស្ថានភាពហិរញ្ញវត្ថុរបស់សមភាគីនាពេលបច្ចុប្បន្ន និងការព្យាករណ៍

៣. ចក្ខុវិស័យអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់ ដោយផ្អែកលើការសន្មតដែលមានលក្ខណៈជាក់ស្តែងនិងប្រុងប្រយ័ត្ន

៤. លទ្ធភាពនិងឆន្ទៈទូទាត់សង

៥. ស្ថានភាពសេដ្ឋកិច្ច និង

៦. គុណភាពនៃសំណុំឯកសារ។

ដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ហ្វាស៊ីលីធីដែលមានចរិតលក្ខណៈហានិភ័យប្រហាក់ប្រហែលគ្នា និងស្ថិតក្រោមកម្រិតកំណត់ជាសារវន្ត (Materiality Threshold) អាចត្រូវចាត់ថ្នាក់ក្នុងសំពៀតឥណទានតែមួយ។

ហេតុការណ៍ណាមួយដែលនាំឱ្យប៉ះពាល់ដល់ប្រភពចំណូលចម្បងក្នុងការទូទាត់សង អាចនាំឱ្យមានការចាត់ថ្នាក់ឥណទានទាបជាងមុន ទោះបីជាហ្វាស៊ីលីធីនោះស្ថិតក្នុងចំណាត់ថ្នាក់ល្អ ឬត្រូវបានការពារដោយទ្រព្យធានាក៏ដោយ។ ការចាត់ថ្នាក់ឡើងវិញក៏អាចត្រូវបានធ្វើឡើង ប្រសិនបើសមភាគីមិនអាចបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា និងបានកែប្រែលក្ខខណ្ឌនៃកិច្ចសន្យា ធ្វើបុនហិរញ្ញប្បទាន ឬទទួលបុរេប្រទានបន្ថែម។

ក្នុងករណីដែលអាចមានការចាត់ថ្នាក់ខុសគ្នាដោយផ្អែកលើកត្តាអត្តនោម័តិ គ្រឹះស្ថានត្រូវជ្រើសយកការចាត់ថ្នាក់ទាបជាងគេ។ ជាងនេះទៅទៀត រាល់លក្ខខណ្ឌដែលមានចែងអំពីការចាត់ថ្នាក់ឥណទានក្នុងបញ្ញត្តិនៃប្រការ ១៧ និងប្រការ ១៨ នៃប្រកាសនេះ មិនអាចរារាំងពីការចាត់ថ្នាក់ទាបជាងមុននោះទេ នៅពេលដែលការវិភាគទៅលើស្ថានភាពហិរញ្ញវត្ថុ លទ្ធភាពសង និងឆន្ទៈក្នុងការសងរបស់សមភាគី អាចបង្ហាញថាឥណទាននោះអាចត្រូវបានចាត់ថ្នាក់ទាបជាងមុន។

ប្រការ ១៧.-

ស្តង់ដារនៃការចាត់ថ្នាក់ហ្វាស៊ីលីធីអាចមានរូបភាពផ្សេងៗគ្នានៅក្នុងគ្រឹះស្ថាន ប៉ុន្តែយន្តការនៃការចាត់ថ្នាក់របស់គ្រឹះស្ថាននីមួយៗត្រូវមានលក្ខណៈលម្អិតគ្រប់គ្រាន់ក្នុងការតាមដានការវិវត្តនៃហានិភ័យ។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីយ៉ាងហោចប្រាំប្រភេទ។ លើកលែងតែមានការចែងផ្សេងទៀតក្នុង ប្រការ ១៨ នៃប្រកាសនេះ ការចាត់ថ្នាក់ទាំងប្រាំប្រភេទនេះ មានដូចខាងក្រោម៖

១. ចំពោះហ្វាស៊ីលីធីដែលមានកាលកំណត់ដំបូងលើសពីមួយឆ្នាំ៖

ក. ធម្មតា៖ ហ្វាស៊ីលីធីមានការទូទាត់សងតាមកាលកំណត់ និងមិនមានការសង្ស័យលើការទូទាត់សងនាពេលអនាគត។ ការទូទាត់សងត្រូវបានធ្វើឡើងទៀងទាត់ស្របតាមកិច្ចសន្យា ហើយហ្វាស៊ីលីធីមិនមានបង្ហាញពីសញ្ញាចុះខ្សោយទាក់ទងនឹងសមត្ថភាពទូទាត់សង អាជីវកម្ម លំហូរសាច់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី។

ខ. ឃ្លាំមើល៖ ហ្វាស៊ីលីធីប្រភេទនេះកំពុងស្ថិតនៅក្រោមកិច្ចគាំពារ និងមិនទាន់ហួសកាលកំណត់ទូទាត់សង ប៉ុន្តែបង្ហាញពីសញ្ញាចុះខ្សោយដែលអាចជះឥទ្ធិពលដល់ការទូទាត់សងរបស់សមភាគីនាពេលអនាគត ប្រសិនបើមិនមានវិធានការកែតម្រូវទាន់ពេលវេលា និងការយកចិត្តទុកដាក់ឱ្យបានដិតដល់ពីគ្រឹះស្ថាន។ សញ្ញាចុះខ្សោយនេះ មានដូចជា ស្ថានភាពធ្លាក់ចុះជាបណ្តើរៗនៃអាជីវកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី និងការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ចនិងទីផ្សារ ដែលអាចប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញ និងសមត្ថភាពទូទាត់សងនាពេលអនាគត ឬការធ្លាក់ចុះតម្លៃទ្រព្យធានា។ ចំណាត់ថ្នាក់នេះត្រូវធ្វើឡើងដោយមានហេតុផលច្បាស់លាស់ និងមិនគួរប្រើប្រាស់ជាការសម្របសម្រួលនៅពេលចាត់ថ្នាក់រវាងហ្វាស៊ីលីធីធម្មតា និងហ្វាស៊ីលីធីក្រោមស្តង់ដារទេ។

ហ្វាស៊ីលីធីណាដែលហួសកាលកំណត់សងរយៈពេល ៣០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ឃ្លាំមើល"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៣០ ថ្ងៃ ទៅ ៨៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ឃ្លាំមើល" ឬអន់ជាងនេះ។

គ. ក្រោមស្តង់ដារ៖ ហ្វាស៊ីលីធីប្រភេទនេះ បង្ហាញភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ និងមិនត្រូវបានគាំពារគ្រប់គ្រាន់ដោយស្ថានភាពអាជីវកម្ម ឬហិរញ្ញវត្ថុបច្ចុប្បន្ន និងសមត្ថភាពទូទាត់សងរបស់សមភាគី។ ជាពិសេស ប្រភពចំណូលចម្បងមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងបំណុល ដោយមិនគិតពីប្រភពចំណូលបន្ទាប់បន្សំផ្សេងៗទៀត ដូចជាការលក់ទ្រព្យធានាជាដើម។ កត្តានាំឱ្យមានការចាត់ថ្នាក់ក្រោមស្តង់ដារ មានដូចជា៖

- សមភាគីគ្មានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចសងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផល ដែលនឹងជះឥទ្ធិពលមិនល្អដល់អាជីវកម្ម និងលទ្ធភាពរកប្រាក់ចំណេញរបស់សមភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុធ្លាក់ចុះ និង/ឬ សមភាគីគ្មានលទ្ធភាពក្នុងការស្វែងរកចំណូលគ្រប់គ្រាន់ដើម្បីទូទាត់សងបំណុល

- សមភាគីជួបប្រទះការលំបាកក្នុងការទូទាត់ហ្វាស៊ីលីធីផ្សេងៗទៀតរបស់គ្រឹះស្ថានផ្ទាល់ ឬរបស់គ្រឹះស្ថានផ្សេងទៀត ប្រសិនបើមានព័ត៌មានគ្រប់គ្រាន់ និង
- សមភាគីល្មើសលើលក្ខខណ្ឌនៃកិច្ចសន្យាហិរញ្ញវត្ថុ។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ៩០ ថ្ងៃ ឬ លើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៩០ ថ្ងៃ ទៅ ១៧៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ឬអន់ជាងនេះ។

ឃ. សង្ស័យ៖ ហ្វាស៊ីលីធីប្រភេទនេះ បង្ហាញភាពទន់ខ្សោយធ្ងន់ធ្ងរ ជាងចំណាត់ថ្នាក់ "ក្រោមស្តង់ដារ" ដោយសារមានភាពសង្ស័យខ្លាំង ឬមិនមានភាពច្បាស់លាស់ ចំពោះការប្រមូលមកវិញនូវហ្វាស៊ីលីធីទាំងអស់ ផ្អែកលើតថភាពជាក់ស្តែង លក្ខខណ្ឌ ឬតម្លៃទ្រព្យធានា។ ការខាតបង់នាពេលអនាគតមានកម្រិតខ្ពស់ ទោះបីចំនួនជាក់លាក់នៃការបាត់បង់មិនទាន់អាចកំណត់បានក៏ដោយ។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ១៨០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "សង្ស័យ"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ១៨០ ថ្ងៃ ទៅ ៣៥៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "សង្ស័យ" ឬអន់ជាងនេះ។

ង. បាត់បង់៖ ហ្វាស៊ីលីធីប្រភេទនេះ ត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់" នៅពេលគ្រឹះស្ថានមិនអាចប្រមូលមកវិញបាន ហើយគ្រឹះស្ថានក៏គ្មាន ឬមានមធ្យោបាយតិចតួចក្នុងការប្រមូលមកវិញនូវសមតុល្យហ្វាស៊ីលីធីដក់សល់ ពីសមភាគី។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ៣៦០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៣៦០ ថ្ងៃ ឬច្រើនជាង ត្រូវបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់"។

២. ចំពោះហ្វាស៊ីលីធីដែលមានកាលកំណត់ដំបូងតិចជាង ឬស្មើមួយឆ្នាំ៖

ចំពោះហ្វាស៊ីលីធី ដែលមានកាលកំណត់ដំបូងរយៈពេលតិចជាង ឬស្មើមួយឆ្នាំ គឺជាហ្វាស៊ីលីធីរយៈពេលខ្លី។ ការកំណត់ចំនួនថ្ងៃអតិបរមានៅក្នុងចំណាត់ថ្នាក់នីមួយៗខាងលើត្រូវបានបន្តយដូចខាងក្រោម៖

ក. "ធម្មតា" មានការទូទាត់សងតាមកាលកំណត់

ខ. "ឃ្លាំមើល" បើហួសកាលកំណត់សងអតិបរមារយៈពេល ៣០ ថ្ងៃ

គ. "ក្រោមស្តង់ដារ" បើហួសកាលកំណត់សងអតិបរមារយៈពេល ៦០ ថ្ងៃ

ឃ. "សង្ស័យ" បើហួសកាលកំណត់សងអតិបរមារយៈពេល ៩០ ថ្ងៃ

ង. "បាត់បង់" បើហួសកាលកំណត់សងអតិបរមារយៈពេល ១៨០ ថ្ងៃ។

ឥណទានវិបារូបន៍ដោយមិនគិតពីឥណប្រតិទាន ត្រូវចាត់ជាឥណទានរយៈពេលខ្លី និងត្រូវបានប្រើប្រាស់សម្រាប់តែហិរញ្ញប្បទានរយៈពេលខ្លីប៉ុណ្ណោះ។ ឥណទានវិបារូបន៍នឹងត្រូវចាត់ថ្នាក់ផ្សេងៗគ្នាតាមលំដាប់ដូចការកំណត់ក្នុងចំណុចទី២ នៃប្រការនេះ អាស្រ័យលើ ១). ឥណទានវិបារូបន៍ត្រូវបានប្រើលើសកម្រិតអនុម័ត ២). គណនីឥណទានវិបារូបន៍មិនមានចលនាសាច់ប្រាក់ចេញចូល ឬ ៣). លំហូរចូលសាច់ប្រាក់សុទ្ធក្នុងគណនីនោះមិនមានភាពគ្រប់គ្រាន់ដើម្បីទូទាត់ការប្រាក់។ គ្រឹះស្ថានត្រូវកែប្រែលក្ខណៈដើមនៃឥណទានវិបារូបន៍ ដែលមិនមានលំហូរចូលសាច់ប្រាក់សុទ្ធសម្រាប់ក្នុងអំឡុងពេល ៦០ ថ្ងៃ ឱ្យទៅជាឥណទានមានកាលកំណត់។

ចំនួនថ្ងៃដែលហួសកាលកំណត់ខាងលើនៃប្រការនេះ ត្រូវចាត់ជាចំនួនថ្ងៃអតិបរមាប៉ុណ្ណោះ។ ការកំណត់ខាងលើនេះនឹងមិនហាមឃាត់គ្រឹះស្ថានក្នុងការចាត់ថ្នាក់អន់ជាងមុន នៅពេលដែលគ្រឹះស្ថានគិតថាសមស្រប។

ប្រការ ១៨.-

ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំត្រីមាស ឆមាស ឬរយៈពេលវែងជាងនេះ ហើយសមភាគីខកខានក្នុងការទូទាត់សង គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីនោះ "ក្រោមស្តង់ដារ" ឬចាត់ថ្នាក់អន់ជាងនេះ ផ្អែកលើស្ថានភាពរបស់សមភាគី លើកលែងតែគ្រឹះស្ថានអាចបញ្ជាក់ថាហ្វាស៊ីលីធីមិនមានសញ្ញាទន់ខ្សោយ។ សម្រាប់គោលបំណងនៃប្រការ ១៨ នៃប្រកាសនេះ ការខកខានទូទាត់សងត្រូវគិតចាប់ពី ០៥ ថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទូទាត់សង។ គ្រឹះស្ថានអាចចាត់ថ្នាក់ហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ក្នុងករណីតែសមភាគីអាចបង្ហាញច្បាស់ថា ការខកខានសងនេះគ្រាន់តែជាការយឺតយ៉ាវបណ្តោះអាសន្ន។

ប្រការ ១៩.-

ហ្វាស៊ីលីធីដែលត្រូវបានចាត់ថ្នាក់ "ក្រោមស្តង់ដារ" "សង្ស័យ" និង "បាត់បង់" នឹងត្រូវចាត់ថ្នាក់ជា "ហ្វាស៊ីលីធីមិនដំណើរការ" (Non-performing Facilities)។ ចំណែកឯហ្វាស៊ីលីធី "ធម្មតា" និង "ឃ្លាំមើល" នឹងត្រូវចាត់ថ្នាក់ជា "ហ្វាស៊ីលីធីដំណើរការ" (Performing Facilities)។

ប្រការ ២០.-

កម្រិតលម្អិតនៃការចាត់ថ្នាក់ហានិភ័យឥណទាន នឹងសម្រួលដល់ការកំណត់ឱ្យបានត្រឹមត្រូវចំពោះ ចរិតលក្ខណៈនៃសំពៀតឥណទាន ការរាយការណ៍ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន។

ប្រការ ២១.-

ហ្វាស៊ីលីធីហួសកាលកំណត់សង ត្រូវបានចាត់ទុកថាមានហានិភ័យខកខានសងខ្ពស់ជាងហ្វាស៊ីលីធីដែលបានទូទាត់សងទៅតាមកិច្ចសន្យា។ គ្រឹះស្ថានត្រូវមានប្រព័ន្ធតាមដានសមស្របក្នុងការគ្រប់គ្រងហ្វាស៊ីលីធីហួសកាលកំណត់សងឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកាត់បន្ថយជាអប្បបរមានូវការប្រែក្លាយជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ គ្រឹះស្ថានត្រូវមាននីតិវិធីនិងដំណើរការដើម្បីកំណត់ តាមដាន និងរាយការណ៍ដល់ក្រុមប្រឹក្សាភិបាល នូវស្ថានភាពរបស់ហ្វាស៊ីលីធីហួសកាលកំណត់សង រួមទាំងហ្វាស៊ីលីធីដែលមិនទាន់បានចាត់ថ្នាក់ថាមានអ៊ីមភែរមិន។

ប្រការ ២២.-

គ្រឹះស្ថានត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មការចាត់ថ្នាក់ហានិភ័យឥណទានចំពោះហ្វាស៊ីលីធី នៅពេលដែលគ្រឹះស្ថានទទួលបានព័ត៌មានថ្មីដែលពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះ។ លើសពីនេះ គ្រឹះស្ថានត្រូវពិនិត្យឡើងវិញប្រចាំគ្រា និងមានឯកសារបញ្ជាក់ច្បាស់លាស់ចំពោះហ្វាស៊ីលីធីទាំងអស់ ដើម្បីធ្វើបច្ចុប្បន្នកម្មចំណាត់ថ្នាក់។ រាល់ចំណាត់ថ្នាក់ហានិភ័យឥណទានត្រូវវាយតម្លៃឡើងវិញយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ គ្រឹះស្ថានត្រូវពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីធំ ឬមានហានិភ័យខ្ពស់ ឬ "ក្រោមស្តង់ដារ" ឬអន់ជាងនេះឱ្យបានញឹកញាប់ យ៉ាងតិចម្តងក្នុងមួយឆមាស ឬកាន់តែញឹកញាប់ជាងនេះសម្រាប់ហ្វាស៊ីលីធីដែលជួបនឹងការធ្លាក់ចុះលទ្ធភាពសងប្រាក់វិញ។

ជំពូកទី ៤
ហ្វាស៊ីលីធីរៀបចំឡើងវិញ

ប្រការ ២៣.-

"ហ្វាស៊ីលីធីរៀបចំឡើងវិញ" (Restructured Facilities) ជាហ្វាស៊ីលីធីដែលមានលក្ខខណ្ឌនៃកិច្ចសន្យាដើមត្រូវបានកែប្រែដើម្បីផ្តល់ការអនុគ្រោះដល់សមភាគី ដែលមានស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន។ ការអនុគ្រោះដែលត្រូវចាត់ទុកថាជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" មានដូចខាងក្រោម៖

១. ការកាត់បន្ថយចំនួនប្រាក់ដើមហ្វាស៊ីលីធី ឬចំនួនដែលត្រូវសងនៅឥណប្រតិទាន
២. ការបន្ថយអត្រាការប្រាក់ទាបជាងលក្ខខណ្ឌនៃកិច្ចសន្យាដើម
៣. ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់ ឬការធ្វើមូលធនកម្មការប្រាក់
៤. ការពន្យារឥណប្រតិទាន ឬ
៥. ការបន្ថែម និង/ឬការផ្លាស់ប្តូរអ្នករួមខ្ចី និង/ឬអ្នកធានា ប្រសិនបើមាន។

ប្រការ ២៤.-

ចំពោះហ្វាស៊ីលីធីដែលត្រូវបានចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" គ្រឹះស្ថាននិងសមភាគីត្រូវយល់ព្រមជាផ្លូវការលើលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។ ក្នុងករណីដែលលក្ខខណ្ឌថ្មីនៃកិច្ចសន្យាមិនបានធ្វើឡើងជាផ្លូវការ ហ្វាស៊ីលីធីនោះមិនមែនជាហ្វាស៊ីលីធីរៀបចំឡើងវិញទេ និងត្រូវបានចាត់ទុកថាជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

ប្រការ ២៥.-

ប្រសិនបើគ្រឹះស្ថានមិនមានព័ត៌មានគ្រប់គ្រាន់អំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់សមភាគី ហ្វាស៊ីលីធីដែលអាចទទួលបានការអនុគ្រោះណាមួយដូចមានចែងក្នុងប្រការ ២៣ ខាងលើ ត្រូវបានចាត់ទុកថាជា ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

ប្រការ ២៦.-

គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរដែលអនុម័តដោយក្រុមប្រឹក្សាភិបាលសម្រាប់កំណត់អំពីស្ថានភាព និងលក្ខខណ្ឌនៃហ្វាស៊ីលីធីដែលត្រូវបានចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" និងសម្រាប់តាមដាននិងគ្រប់គ្រងហ្វាស៊ីលីធីរៀបចំឡើងវិញ។ រាល់ការរៀបចំហ្វាស៊ីលីធីឡើងវិញត្រូវមានឯកសារវាយតម្លៃឥណទានត្រឹមត្រូវគ្រប់គ្រាន់ និងមានសម្មតិកម្មជាក់លាក់អំពីការទូទាត់សងទាំងស្រុង ស្របតាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។

ប្រការ ២៧.-

ហ្វាស៊ីលីធីរៀបចំឡើងវិញ អាចធ្វើបានតែចំពោះសមភាគីណាដែលស្ថានភាពអាជីវកម្ម និង/ឬ ស្ថានភាពហិរញ្ញវត្ថុនៅតែមានចីរភាព ហើយគ្រឹះស្ថានរំពឹងថាសមភាគីជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ និងការទូទាត់សងតែក្នុងរយៈពេលបណ្តោះអាសន្នប៉ុណ្ណោះ។ គ្រឹះស្ថានត្រូវពន្យល់អំពីការសម្រេចក្នុងការរៀបចំហ្វាស៊ីលីធីឡើងវិញផ្អែកតាមប្រការ ២៨ នៃប្រកាសនេះ នូវមូលហេតុដែលគ្រឹះស្ថានចាត់ទុកសមភាគីនោះស្ថិតក្នុងស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុនិងការទូទាត់សងក្នុងរយៈពេលបណ្តោះអាសន្ន។ ការរៀបចំហ្វាស៊ីលីធីឡើងវិញមិនត្រូវប្រើប្រាស់ដើម្បីរួចផុតពី៖

១. ការទទួលស្គាល់ជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៥៨ ដល់ ប្រការ ៥២ នៃប្រកាសនេះ
២. ការបង្កើនសំវិធានធនចំពោះការខាតបង់ឥណទានដែលរំពឹងទុក និង
៣. ការបញ្ឈប់ពីការទទួលស្គាល់ចំណូលការប្រាក់ផ្អែកលើមូលដ្ឋានបង្គរ។

ប្រការ ២៨.-

គ្រឹះស្ថានត្រូវកំណត់លក្ខខណ្ឌថ្មីនៃហ្វាស៊ីលីធីរៀបចំឡើងវិញ ដោយផ្អែកលើសមត្ថភាពទូទាត់សងរបស់សមភាគីតាមរយៈការព្យាករណ៍លំហូរសាច់ប្រាក់ថ្មីដោយមានសម្មតិកម្មត្រឹមត្រូវ និងប្រុងប្រយ័ត្នចំពោះស្ថានភាពហិរញ្ញវត្ថុ និង/ឬ អាជីវកម្មរបស់សមភាគី។ រាល់ការសម្រេចរៀបចំហ្វាស៊ីលីធីឡើងវិញ គ្រឹះស្ថានត្រូវមានហេតុផលត្រឹមត្រូវ ដោយមានការពន្យល់ឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ និងរក្សាទុកជាឯកសារ។

ប្រការ ២៩.-

ហ្វាស៊ីលីធីនីមួយៗ មិនអាចធ្វើការរៀបចំឡើងវិញលើសពីមួយដងឡើយ។ ប្រសិនបើមានការរៀបចំឡើងវិញលើសពីមួយដង ហ្វាស៊ីលីធីនោះត្រូវចាត់ថ្នាក់យ៉ាងហោចណាស់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ។

ប្រការ ៣០.-

ក្នុងដំណើរការរៀបចំហ្វាស៊ីលីធីឡើងវិញ គ្រឹះស្ថានអាចអនុញ្ញាតឱ្យពន្យារពេលសងដោយមិនត្រូវលើសពីរយៈពេល ០៦ ខែឡើយ។ ការអនុញ្ញាតនេះត្រូវមានការវាយតម្លៃហានិភ័យឥណទានឱ្យបានហ្មត់ចត់និងត្រឹមត្រូវ។

ប្រការ ៣១.-

ការរៀបចំហ្វាស៊ីលីធីឡើងវិញ ត្រូវធ្វើឡើងដោយបុគ្គល ឬផ្នែកផ្សេងដែលមិនទទួលបន្ទុកក្នុងដំណើរការផ្តល់ឥណទាន។ ការអនុញ្ញាតឱ្យមានការរៀបចំហ្វាស៊ីលីធីឡើងវិញត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងដែលមានសិទ្ធិសម្រេចសមស្រប និងយ៉ាងហោចណាស់ ត្រូវមានការចូលរួមចាប់ពីគណៈគ្រប់គ្រងជាន់ខ្ពស់ឡើងទៅ។

ប្រការ ៣២.-

របាយការណ៍ស្តីពីស្ថានភាពនៃហ្វាស៊ីលីធីរៀបចំឡើងវិញ ត្រូវផ្តល់ជូនគណៈគ្រប់គ្រងជាន់ខ្ពស់ យ៉ាងតិចម្តងក្នុងមួយត្រីមាស ដើម្បីផ្សៀងផ្ទាត់ការអនុវត្តស្របតាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរួមរបស់គ្រឹះស្ថាន ព្រមទាំងចាត់វិធានការកែតម្រូវសមស្រប ក្នុងករណីមានចំណុចខ្វះចន្លោះ។

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញមានចំណុចខ្វះចន្លោះ របាយការណ៍ស្តីពីស្ថានភាពហ្វាស៊ីលីធីរៀបចំឡើងវិញនេះ ត្រូវបានផ្តល់ភ្លាមៗជូនគណៈគ្រប់គ្រងជាន់ខ្ពស់។

ប្រការ ៣៣.-

ក្រោយពីបញ្ចប់ដំណើរការរៀបចំហ្វាស៊ីលីធីឡើងវិញ ហ្វាស៊ីលីធីត្រូវបានរក្សាការចាត់ថ្នាក់ដដែលរហូតដល់ហ្វាស៊ីលីធីនោះអាចចាត់ថ្នាក់ល្អជាងមុន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៨១ និងប្រការ ៨២ នៃប្រកាសនេះ។

ជំពូកទី ៥
បុនហិរញ្ញប្បទាន

ប្រការ ៣៤.-

"បុនហិរញ្ញប្បទាន" សំដៅដល់ការអនុវត្ត ឬយន្តការទាំងឡាយណារបស់គ្រឹះស្ថាន ដែលអនុញ្ញាតឱ្យមានការជំនួសកាតព្វកិច្ចសងបំណុលដែលមានស្រាប់ ជាមួយនឹងកាតព្វកិច្ចសងបំណុលថ្មីក្នុងលក្ខខណ្ឌនៃកិច្ចសន្យាថ្មី។

ប្រការ ៣៥.-

"បុនហិរញ្ញប្បទាន" មិនត្រូវបានអនុវត្តដើម្បីប្រែក្លាយហ្វាស៊ីលីធីដែលមិនល្អ ទៅជា "ហ្វាស៊ីលីធីល្អជានិច្ច" ក្នុងគោលបំណងគេចវេសពីការធ្វើសំវិធានធន ឬលុបចោលហ្វាស៊ីលីធីនោះទេ។ គ្រឹះស្ថានត្រូវបកស្រាយជូនធនាគារជាតិនៃកម្ពុជា អំពីមូលហេតុនៃការធ្វើបុនហិរញ្ញប្បទានច្រើនដង ដែលជាប្រយោជន៍ដល់សមភាគីរបស់គ្រឹះស្ថាន។ ក្នុងពេលធ្វើបុនហិរញ្ញប្បទាន គ្រឹះស្ថានត្រូវរក្សាទុករាល់

ប្រវត្តិទិន្នន័យទាក់ទងនឹងហ្វាស៊ីលីធីដែលបានធ្វើបុនហិរញ្ញប្បទាន និងការទូទាត់សងតាមគ្រានិងការទូទាត់សងចុងក្រោយ។ គ្រឹះស្ថានត្រូវបង្ហាញថា ហ្វាស៊ីលីធីដែលបានធ្វើបុនហិរញ្ញប្បទានជាបន្តបន្ទាប់នេះ ស្ថិតនៅក្រោមដំណើរការផ្តល់ឥណទានដែលច្បាស់លាស់និងរឹងមាំ និងត្រូវបានទទួលការអនុមតិពីគណៈគ្រប់គ្រងដែលមានសិទ្ធិសម្រេច។

កត្តាដែលត្រូវយកចិត្តទុកដាក់ និងរក្សាទុកជាឯកសារក្នុងការធ្វើបុនហិរញ្ញប្បទាន ត្រូវមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្តល់ហ្វាស៊ីលីធីដំបូងដែរ រួមមាន ១). គោលបំណងនៃការប្រើប្រាស់ឥណទាន និងប្រភពនៃការទូទាត់សងហ្វាស៊ីលីធី ២). ទម្រង់ហានិភ័យបច្ចុប្បន្នរបស់សមភាគីរាប់បញ្ចូលទាំងប្រវត្តិនិងសមត្ថភាពបច្ចុប្បន្នក្នុងការទូទាត់សង និង ៣). ភាពគ្រប់គ្រាន់និងលទ្ធភាពអនុវត្តបានចំពោះទ្រព្យធានាឬការធានា។

ប្រការ ៣៦.-

"ហ្វាស៊ីលីធីរៀបចំឡើងវិញ" ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ២៣ ដល់ប្រការ ៣៣ នៃប្រកាសនេះ គឺជាផ្នែកមួយនៃ "បុនហិរញ្ញប្បទាន" ដែលផ្តល់ឱ្យតែក្នុងករណីសមភាគីជួបបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុរយៈពេលបណ្តោះអាសន្ន។ នៅពេលធ្វើបុនហិរញ្ញប្បទានហ្វាស៊ីលីធី គ្រឹះស្ថានត្រូវពិនិត្យមើលថាតើបុនហិរញ្ញប្បទានធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងប្រការ ២៣ ខាងលើឬទេ។ ប្រសិនបើសមស្រប ហ្វាស៊ីលីធីថ្មីនោះត្រូវចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" និងត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ២៣ ដល់ប្រការ ៣៣ នៃប្រកាសនេះ។

ប្រការ ៣៧.-

នៅពេលដែល "បុនហិរញ្ញប្បទាន" មិនមានលក្ខណៈគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌនៃ "ហ្វាស៊ីលីធីរៀបចំឡើងវិញ" "បុនហិរញ្ញប្បទាន" នោះអាចត្រូវបានធ្វើឡើងដើម្បីឱ្យសមភាគីដែលពុំមានស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុ អាចទទួលបានផលប្រយោជន៍អំពីលក្ខខណ្ឌនៃកិច្ចសន្យាឥណទានប្រសើរជាងមុន ដូចជាអត្រាការប្រាក់ល្អជាងមុន ការផ្លាស់ប្តូររវាងអត្រាការប្រាក់ថេរនិងអត្រាការប្រាក់ប្រែប្រួល ការកាត់បន្ថយចំនួនប្រាក់សងប្រចាំខែ ការកែប្រែរយៈពេលនៃកិច្ចសន្យា ការកើនឡើងទំហំប្រាក់កម្ចី ឬការគូបសរុបបំណុល។ បុនហិរញ្ញប្បទានមិនត្រូវធ្វើឡើងដើម្បីជំនួសពីការចាត់ថ្នាក់ហ្វាស៊ីលីធីដែលត្រូវបានកំណត់ថាមានអ៊ីមែរមិន។

គ្រឹះស្ថានមិនអាចធ្វើបុនហិរញ្ញប្បទានជាមួយអតិថិជន នៅពេលដែលគ្រឹះស្ថានមានការសង្ស័យថាការទូទាត់សងហ្វាស៊ីលីធីជាបុនហិរញ្ញប្បទាន ត្រូវបានធ្វើឡើងដោយកម្ចីដែលបានមកពីអ្នកផ្តល់ផ្សេងទៀតដែលជាគ្រឹះស្ថាន ឬក៏បុគ្គលមិននៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៣៨.-

គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីរឹងមាំជាលាយលក្ខណ៍អក្សរ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីកំណត់ស្ថានភាពនិងលក្ខខណ្ឌនៃហ្វាស៊ីលីធីដែលកំណត់ថាជា "បុនហិរញ្ញប្បទាន"។ គោលនយោបាយនិងនីតិវិធីនេះ ជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ

ឥណទានដែលមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ក្នុងគោលដៅកំណត់អត្តសញ្ញាណ វាស់វែង តាមដាននិងត្រួតពិនិត្យហានិភ័យឥណទានរបស់គ្រឹះស្ថាន។

ទោះស្ថិតក្នុងបរិបទសេដ្ឋកិច្ចនិងស្ថានភាពហិរញ្ញវត្ថុណាក៏ដោយ គ្រឹះស្ថានមិនត្រូវធ្វើបុនហិរញ្ញប្បទានច្រើនដងលើហ្វាស៊ីលីធីរបស់សមភាគីតែមួយក្នុងរយៈពេលខ្លី ដើម្បីធ្វើឱ្យហ្វាស៊ីលីធីនេះជា "ហ្វាស៊ីលីធីល្អជានិច្ច" ដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ ឬដើម្បីគេចវេសពីការរៀបចំហ្វាស៊ីលីធីនេះឡើងវិញ ឬចាត់ថ្នាក់ជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន លើកលែងតែមានហេតុផលច្បាស់លាស់ និងត្រូវកត់ត្រាដោយហ្មត់ចត់។ គ្រឹះស្ថានអាចត្រូវបានតម្រូវឱ្យពិនិត្យនិងកែតម្រូវឡើងវិញ ចំពោះការធ្វើបុនហិរញ្ញប្បទានតាមរបៀបនេះ។

ជំពូកទី ៦
ទ្រព្យធានា

ប្រការ ៣៩.-

បញ្ញត្តិនៃប្រការ ៤០ ដល់ ប្រការ ៤៧ នៃប្រកាសនេះ គឺដើម្បីផ្តល់ការណែនាំអំពីទ្រព្យធានាដែលប្រើប្រាស់សម្រាប់ធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ប្រការ ៤០.-

ទ្រព្យធានាត្រូវបានរក្សាទុកដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ទ្រព្យធានាអាចជាទម្រង់នៃការធានា ទ្រព្យ ឬប្រភេទផ្សេងៗនៃទ្រព្យសកម្ម ជាពិសេសទ្រព្យសកម្មហិរញ្ញវត្ថុជួញដូរបាន ដូចជា មូលបត្រកម្មសិទ្ធិ និងសញ្ញាបណ្ណជាដើម ដែលអាចជួញដូរបានយ៉ាងឆាប់រហ័សនៅក្នុងទីផ្សារតាមតម្លៃសមស្រប។

ប្រការ ៤១.-

ការវាយតម្លៃប្រកបដោយវិជ្ជាជីវៈមានសារៈសំខាន់ណាស់ក្នុងការប៉ាន់ស្មានតម្លៃជាក់ស្តែងនៃទ្រព្យធានា។ គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរច្បាស់លាស់ក្នុងការកំណត់ និងពិនិត្យលើតម្លៃទ្រព្យធានាណាមួយដែលដាក់ធានាចំពោះហ្វាស៊ីលីធី។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវមានយ៉ាងតិច ដូចខាងក្រោម៖

១. សេចក្តីបញ្ជាក់អំពីទម្រង់ផ្សេងៗគ្នានៃទ្រព្យធានា និងលក្ខខណ្ឌដែលទ្រព្យធានានោះអាចទទួលយកបានដោយគ្រឹះស្ថាន

២. វិធីសាស្ត្រ និងមធ្យោបាយដែលរៀបចំដោយគ្រឹះស្ថាន ដើម្បីវិភាគយ៉ាងហ្មត់ចត់ទៅលើគុណភាព និងតម្លៃទ្រព្យធានានោះ មុនពេលចុះកិច្ចសន្យាហ្វាស៊ីលីធីមានទ្រព្យធានា។ រាល់ទ្រព្យធានាត្រូវកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ និងចងក្រងជាសំណុំឯកសារហ្វាស៊ីលីធីឱ្យបានត្រឹមត្រូវ។ គ្រឹះស្ថានត្រូវធានាថា រាល់កាតព្វកិច្ចផ្លូវច្បាប់ដែលពាក់ព័ន្ធត្រូវបានបំពេញ ដើម្បីរក្សាសិទ្ធិស្របច្បាប់លើទ្រព្យធានា និងអនុញ្ញាតឱ្យគ្រឹះស្ថានអាចអនុវត្តសិទ្ធិទាំងនោះបាន

៣. វិធីសាស្ត្រ និងមធ្យោបាយដែលរៀបចំឡើងដោយគ្រឹះស្ថាន ដើម្បីធ្វើបច្ចុប្បន្នកម្មការវាយតម្លៃទ្រព្យធានាឱ្យបានហ្មត់ចត់សម្រាប់អាយុកាលនៃហ្វាស៊ីលីធី។ ការធ្វើបច្ចុប្បន្នកម្មមានសារៈសំខាន់ជាពិសេសចំពោះ ១). តម្លៃទ្រព្យធានាងាយរងការប្រែប្រួលខ្លាំងទៅតាមពេលវេលា ២). ទ្រព្យធានាហ្វាស៊ីលីធីមានអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យធានាកម្រិតខ្ពស់ និង ៣). ហ្វាស៊ីលីធីដែលមានអាយុកាលមធ្យមឬវែង។ ការវាយតម្លៃ និងការពិនិត្យឡើងវិញលើការវាយតម្លៃទ្រព្យធានាសម្រាប់អាយុកាលនៃហ្វាស៊ីលីធី ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និងពិនិត្យលើពេលវេលា បន្ទុកចំណាយ និងការលំបាកផ្សេងៗពាក់ព័ន្ធនឹងការលក់ទ្រព្យធានានោះ និង

៤. ការពិនិត្យឡើងវិញជាទៀងទាត់នូវលទ្ធភាពទទួលបានការទូទាត់សងពីការលក់ទ្រព្យធានាក្នុងអាយុកាលនៃហ្វាស៊ីលីធី។

ប្រការ ៤២.-

ទ្រព្យសកម្មដែលទទួលយកជាទ្រព្យធានាត្រូវបានវាយតម្លៃតាមតម្លៃជាក់ស្តែង ដោយប្រើប្រាស់វិធីសាស្ត្រស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ប្រការ ៤៣.-

មុនពេលចុះកិច្ចសន្យាហ្វាស៊ីលីធីមានទ្រព្យធានាថ្មី គ្រឹះស្ថានត្រូវរិភាគគុណភាព និងតម្លៃទ្រព្យធានាឱ្យបានហ្មត់ចត់ ព្រមទាំងសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិលើទ្រព្យធានា ដើម្បីទូទាត់សងគ្រប់ចំនួនតាមកិច្ចសន្យា ក្នុងករណីសមភាគីខកខានមិនបានបំពេញតាមកិច្ចសន្យា។

ប្រការ ៤៤.-

ក្នុងការកំណត់តម្លៃជាក់ស្តែងនៃទ្រព្យធានា គ្រឹះស្ថានត្រូវផ្អែកលើអ្នកវាយតម្លៃទ្រព្យធានាផ្ទៃក្នុង និង/ឬ ខាងក្រៅ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ គោលនយោបាយនិងនីតិវិធីដែលមានចែងក្នុងប្រការ ៤១ នៃប្រកាសនេះ ត្រូវបញ្ជាក់ឱ្យច្បាស់អំពីលក្ខខណ្ឌនៃការវាយតម្លៃទ្រព្យធានានោះ។

ប្រការ ៤៥.-

អ្នកវាយតម្លៃផ្ទៃក្នុងនិងខាងក្រៅរបស់គ្រឹះស្ថានត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់និងបទពិសោធន៍វិជ្ជាជីវៈក្នុងការវាយតម្លៃទ្រព្យធានា។ គ្រឹះស្ថានត្រូវជ្រើសរើសអ្នកវាយតម្លៃខាងក្រៅ ពីបញ្ជីឈ្មោះក្រុមហ៊ុនវាយតម្លៃដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៤៦.-

រយៈពេលសម្រាប់លក់ទ្រព្យធានាគឺជាកត្តាសំខាន់នៅពេលវាយតម្លៃទ្រព្យធានាលើហ្វាស៊ីលីធី។ ជាទូទៅ រយៈពេល ១២ ខែ ជារយៈពេលសមស្រប លើកលែងតែកាលៈទេសៈពិសេស ដែលទាមទាររយៈពេលវែងជាងនេះ។ ក្នុងករណីរយៈពេលវែងជាង ១២ ខែ គ្រឹះស្ថានត្រូវជ្រើសរើសយករយៈពេលវែងបំផុតសម្រាប់កំណត់តម្លៃជាក់ស្តែង។

ប្រការ ៤៧.-

ក្នុងករណី "តម្លៃជាក់ស្តែង" នៃទ្រព្យធានាត្រូវបានកំណត់ដោយផ្អែកលើតម្លៃទីផ្សារអាចជឿជាក់បាន គ្រឹះស្ថានត្រូវពិនិត្យលើការកំណត់យកទីផ្សារសមស្រប សន្ទនីយភាពនៃទ្រព្យធានាក្នុងទីផ្សារនោះ រយៈពេលលក់ ចំណាយផ្សេងៗពាក់ព័ន្ធនឹងការលក់ និងផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតឡើងពីការលក់ទៅលើតម្លៃទីផ្សារ។

ជំពូកទី ៧
ការទទួលស្គាល់ និងការវាស់វែងសមស្របចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

ប្រការ ៤៨.-

ការទទួលស្គាល់ និងការវាស់វែងសមស្របចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ជាធាតុដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយធ្វើសំវិធានធនរបស់គ្រឹះស្ថាន ហើយជាពិសេសសម្រាប់វាយតម្លៃលើភាពគ្រប់គ្រាន់នៃដើមទុន។

បញ្ញត្តិនៃប្រការ ៤៩ ដល់ ប្រការ ៧១ នៃប្រកាសនេះ គឺជាការណែនាំអប្បបរមាសម្រាប់ការទទួលស្គាល់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការវាស់វែងសំវិធានធនតាមស្តង់ដារគណនេយ្យជាធរមាន។

ប្រការ ៤៩.-

វិសាលភាពនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវគិតបញ្ចូលទ្រព្យសកម្មទាំងអស់ដែលមានទាំងនៅក្នុងនិងក្រៅតារាងតុល្យការ។ ក្នុងការទទួលស្គាល់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គ្រឹះស្ថានមិនត្រឹមតែកំណត់ចំពោះការផ្តល់កម្ចីប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតបញ្ចូលហ្វាស៊ីលីធីផ្សេងទៀតដែលនាំឱ្យមានហានិភ័យឥណទានជាមួយសមភាគីផងដែរ។ គ្រឹះស្ថានត្រូវទទួលស្គាល់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ហ្វាស៊ីលីធីដែលត្រូវទទួលស្គាល់ថាមានអ៊ីមភែរមិន នៅពេលដែលមានការសង្ស័យថាទឹកប្រាក់ជំពាក់សរុប រួមទាំងការប្រាក់ និងទឹកប្រាក់ផ្សេងៗទៀត មិនត្រូវបានទូទាត់សងទាន់ពេលវេលា ដោយមិនគិតពីរយៈពេលហួសកាលកំណត់ ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ឬច្រើនជាង។ ហ្វាស៊ីលីធីក៏ត្រូវទទួលស្គាល់ថាមានអ៊ីមភែរមិនដែរ ទោះបីជាទំហំនៃការបាត់បង់ទាំងអស់មិនអាចកំណត់បានច្បាស់លាស់ក៏ដោយ។

កត្តាមួយចំនួនដែលនាំឱ្យមានការសង្ស័យ និងតម្រូវឱ្យចាត់ថ្នាក់សមតុល្យហ្វាស៊ីលីធីដក់សល់ថាមានអ៊ីមភែរមិន មានដូចខាងក្រោម៖

១. ហ្វាស៊ីលីធីដែលមានការទូទាត់សងប្រចាំខែ ឬតិចជាង និងហួសកាលកំណត់ ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ដោយមិនមានការធានាត្រឹមត្រូវនិងគ្រប់គ្រាន់
២. សមភាគីដែលទទួលបានហ្វាស៊ីលីធី ប្រឈមនឹងការបរាជ័យ ឬនីតិវិធីក្ស័យធន លើកលែងតែហ្វាស៊ីលីធីមានការធានាត្រឹមត្រូវនិងគ្រប់គ្រាន់ ឬ
៣. ការលុបចោលផ្នែកខ្លះនៃហ្វាស៊ីលីធី ទោះបីក្នុងហេតុផលណាក៏ដោយ។

កត្តាដទៃទៀតដែលអាចបញ្ជាក់ពីអ៊ីមភែរមិននៃហ្វាស៊ីលីធី មានដូចខាងក្រោម៖

១. ការលំបាកធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុរបស់សមភាគី

២. ការអនុគ្រោះដែលគ្រឹះស្ថានផ្តល់ទៅឱ្យសមភាគីនៅពេលសមភាគីជួបការលំបាកផ្នែកហិរញ្ញវត្ថុ ឬ

៣. ព័ត៌មានឬទិន្នន័យណាមួយបញ្ជាក់ថាមានការថយចុះនៃលំហូរសាច់ប្រាក់រំពឹងទុកដែលនឹងប្រមូលបានពីសមភាគី និងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក និងសកលដែលជះឥទ្ធិពលដល់លំហូរសាច់ប្រាក់រំពឹងទុកនោះ។

ការទូទាត់សងតាមគ្រានីមួយៗត្រូវធ្វើឡើងឱ្យបានគ្រប់ចំនួន។ សម្រាប់ការគណនាហ្វាស៊ីលីធីសងយឺត ការទូទាត់សងតែមួយចំណែកនៃការសងតាមគ្រា ត្រូវចាត់ទុកថាជាការសងយឺត។

នៅពេលដែលការទូទាត់សងត្រូវបានកំណត់ក្នុងរយៈពេល ៩០ ថ្ងៃ ឬវែងជាងនេះ ហ្វាស៊ីលីធីត្រូវបានចាត់ថាមានអ៊ីមភែរមិនភ្លាម ក្នុងករណីដែលមានការខកខានទូទាត់សង លើកលែងតែគ្រឹះស្ថានអាចបង្ហាញថាហ្វាស៊ីលីធីមិនមានភាពទន់ខ្សោយណាមួយដែលនាំឱ្យមានការចាត់ថ្នាក់ក្រោមស្តង់ដារឬអន់ជាងនេះ។ ការខកខានទូទាត់សងត្រូវគិតចាប់ពី ០៥ ថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទទូទាត់សង។

ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ (Revolving Facilities) ផ្សេងៗទៀត ដែលបន្តមានសមតុល្យលើសកម្រិតអនុម័ត ក្នុងរយៈពេល ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ឬលើសពីនេះបន្តបន្ទាប់គ្នា ត្រូវចាត់ទុកជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវគិតលើសមតុល្យសរុបដក់សល់នៃហ្វាស៊ីលីធីនោះ។

ការសន្យាផ្តល់ឥណទាន (Loan commitment facilities) ដែលមិនអាចកែប្រែបាន (Irrevocable) ត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន នៅពេលដែលសមត្ថភាពទូទាត់សង (Creditworthiness) របស់សមភាគីថយចុះ ដែលនាំឱ្យមានការសង្ស័យអំពីលទ្ធភាពទូទាត់សងប្រាក់គ្រប់ចំនួន និងទាន់ពេលវេលាចំពោះការប្រើប្រាស់ឥណទាន និង/ឬ ការទូទាត់ការប្រាក់ ឬសោហ៊ុយផ្សេងៗ។

ហ្វាស៊ីលីធីផ្សេងទៀតនៃខ្ទង់ក្រៅតារាងតុល្យការ ក៏ត្រូវអនុវត្តតាមប្រកាសនេះដែរ។ ហ្វាស៊ីលីធីដែលមានលក្ខណៈជំនួសឥណទាន (Direct credit substitutes) ដូចជា ការធានា និងលិខិតឥណទានដែលជាទូទៅនឹងក្លាយជាខ្ទង់ក្នុងតារាងតុល្យការនៅពេលប្រើប្រាស់។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីថាមានអ៊ីមភែរមិនក្នុងករណីគ្រឹះស្ថានមានហេតុផលច្បាស់លាស់ថា ឧបករណ៍ខាងលើនេះ នឹងត្រូវប្រើប្រាស់ដោយសមភាគី នាពេលអនាគតក្នុងកាលៈទេសៈ ដែលគ្រឹះស្ថានជឿជាក់ថាមិនអាចប្រមូលមកវិញគ្រប់ចំនួនបានទាន់ពេលវេលា ចំពោះទឹកប្រាក់ដែលគ្រឹះស្ថាននឹងត្រូវទូទាត់សងជំនួស។

ហានិភ័យនៃការខាតបង់ ក៏អាចកើតឡើងពីហ្វាស៊ីលីធីផ្សេងៗទៀតក្នុងខ្ទង់ក្រៅតារាងតុល្យការដែរ ដូចជា ប្រតិបត្តិការនិស្សន្ទ ជាពិសេសនៅពេលដែលចំណាត់ថ្នាក់ឥណទានរបស់សមភាគីធ្លាក់ចុះ។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីនេះថាមានអ៊ីមភែរមិន នៅពេលមានការសង្ស័យថា មិនអាចទទួលបានលំហូរសាច់ប្រាក់ដែលដល់ ឬនឹងដល់ពេលទូទាត់សងគ្រប់ចំនួន និងទាន់ពេលវេលាពីសមភាគី។

ប្រការ ៥០.-

គ្រឹះស្ថានត្រូវធានាថា ការទទួលស្គាល់ និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គោរពតាមគោលការណ៍និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដែលអនុវត្តតាមវិធីសាស្ត្ររំលស់ថ្លៃដើម ត្រូវធ្វើឡើងជាលើកដំបូងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" លើកលែងតែចំពោះហ្វាស៊ីលីធីដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នា និងស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្ត ត្រូវវាយតម្លៃជាក្រុម។ ហ្វាស៊ីលីធីដែលត្រូវបានវាយតម្លៃជាក្រុម និងស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្ត មានដូចជា ប័ណ្ណឥណទាន ឥណទានសម្រាប់អ្នកប្រើប្រាស់តូចៗ រួមទាំងឥណទានយានយន្ត ជាដើម។

ក្នុងការវាយតម្លៃលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបែងចែកសំពៀតហ្វាស៊ីលីធីជាក្រុមៗតាមការចាំបាច់ ដើម្បីប្រមូលផ្តុំហ្វាស៊ីលីធីដែលមានចរិតលក្ខណៈ និងមានហានិភ័យឥណទានប្រហាក់ប្រហែលគ្នា ដូចជា ប្រភេទហ្វាស៊ីលីធី ប្រភេទសមភាគី ស្ថានភាពហួសកាលកំណត់ ចំណាត់ថ្នាក់ហានិភ័យឥណទាន ប្រភេទទ្រព្យធានា និងស្ថានភាពភូមិសាស្ត្រ។ ការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា ទៅតាមប្រភេទក្រុមនីមួយៗ។

នៅពេលដែលសមភាគីមួយមានហ្វាស៊ីលីធីច្រើន ដោយក្នុងនោះ ហ្វាស៊ីលីធីមួយមានទំហំលើសពីកម្រិតកំណត់ជាសារវន្ត និងត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន ឬផលបូកសរុបនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន លើសកម្រិតកំណត់ជាសារវន្ត ការវាស់វែងលើហ្វាស៊ីលីធីទាំងនោះត្រូវធ្វើឡើងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ទោះបីជាហ្វាស៊ីលីធីផ្សេងទៀតដែលផ្តល់ទៅឱ្យសមភាគីនោះស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្តក៏ដោយ។

ប្រការ ៥១.-

ហ្វាស៊ីលីធីទាំងឡាយណាដែលត្រូវបានវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ដូចមានចែងក្នុងប្រការ ៥០ នៃប្រកាសនេះ បានបង្ហាញថាមិនមានអ៊ីមភែរមិន និងមិនត្រូវបានធ្វើសំវិធានធនលើហ្វាស៊ីលីធីទោល នឹងត្រូវដាក់បញ្ចូលគ្នាទៅក្នុងក្រុមហ្វាស៊ីលីធីដែលមានចរិតលក្ខណៈហានិភ័យស្រដៀងគ្នា ដើម្បីវាយតម្លៃជាលើកទីពីរ តាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដោយអនុវត្តវិធីសាស្ត្រដូចទៅនឹងក្រុមហ្វាស៊ីលីធីដែលស្ថិតក្រោមកម្រិតកំណត់។ ការដាក់បញ្ចូលជាក្រុមនេះ ត្រូវតែកែសម្រួលឱ្យសមស្របតាមទំហំ និងប្រភេទនៃហ្វាស៊ីលីធីដែលត្រូវបានវាយតម្លៃ។ ហ្វាស៊ីលីធីដែលមានទឹកប្រាក់ខ្ពស់លើសលប់ និងពិសេសជាងគេ អាចត្រូវលើកលែងពីការវាយតម្លៃក្នុងដំណាក់កាលទីពីរ ប៉ុន្តែការលើកលែងនេះ អនុវត្តចំពោះតែហ្វាស៊ីលីធីពិសេសដែលមានចំនួនតិចតួចប៉ុណ្ណោះ។

ប្រការ ៥២.-

អ៊ីមភែរមិននៃហ្វាស៊ីលីធីទោល ឬហ្វាស៊ីលីធីក្រុមស្រដៀងគ្នា ដែលអនុវត្តតាមវិធីសាស្ត្ររំលស់ថ្លៃដើម ត្រូវបានគណនាតាមវិធីសាស្ត្រ "ការខាតបង់ឥណទានរំពឹងទុក" (Expected Credit Losses - ECL) ដែលជាការប៉ាន់ស្មានការខាតបង់ឥណទានថ្លឹងតាមប្រូបាប៊ីលីតេ (កង្វះសាច់ប្រាក់

គិតក្នុងតម្លៃបច្ចុប្បន្ន - Present value of all cash shortfalls) សម្រាប់រយៈពេលទាំងស្រុងនៃកិច្ចសន្យាហ្វាស៊ីលីធី។ កង្វះសាច់ប្រាក់ត្រូវបានគណនាដោយយកលំហូរសាច់ប្រាក់ដែលត្រូវទទួលបានដោយគ្រឹះស្ថានទៅតាមកិច្ចសន្យា ដក លំហូរសាច់ប្រាក់ដែលគ្រឹះស្ថានរំពឹងថានឹងទទួលបាន។ ប្រសិនបើនៅកាលបរិច្ឆេទរាយការណ៍ ហានិភ័យឥណទាននៃហ្វាស៊ីលីធីមិនមានការកើនឡើងខ្លាំងធៀបនឹងកាលបរិច្ឆេទទទួលស្គាល់ដំបូង គ្រឹះស្ថានត្រូវធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីក្នុងចំនួនស្មើនឹងការខាតបង់ឥណទានរំពឹងទុករយៈពេល ១២ ខែ ប៉ុណ្ណោះ។ លក្ខខណ្ឌលម្អិតនៃការគណនាការខាតបង់ឥណទានរំពឹងទុកត្រូវផ្អែកលើគោលការណ៍ និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ប្រការ ៥៣.-

ចំពោះ ឥណទានស៊ីនឌីខេត (Syndicated loans) គ្រឹះស្ថាននីមួយៗដែលចូលរួមផ្តល់ឥណទានត្រូវទទួលខុសត្រូវរក្សាព័ត៌មានឥណទានរបស់សមភាគីឱ្យបានគ្រប់គ្រាន់ ដើម្បីវាយតម្លៃ និងធ្វើសំវិធានធនទៅលើចំណែកនៃឥណទានស៊ីនឌីខេតរបស់ខ្លួន។ គ្រឹះស្ថានដឹកនាំត្រូវចែករំលែកព័ត៌មានឥណទានរបស់សមភាគី ដែលធ្វើបច្ចុប្បន្នកម្មចុងក្រោយដល់គ្រប់គ្រឹះស្ថានចូលរួមទាំងអស់។ នៅពេលដែលមានព័ត៌មានគួរឱ្យយកចិត្តទុកដាក់ថា គ្រឹះស្ថានចូលរួមដែលជាគ្រឹះស្ថានដឹកនាំ ឬគ្រឹះស្ថានចូលរួមណាមួយបានបន្តយចំណាត់ថ្នាក់ឥណទានស៊ីនឌីខេត គ្រឹះស្ថានត្រូវបន្តយចំណាត់ថ្នាក់ឥណទានស៊ីនឌីខេតនោះ តាមចំណែករបស់ខ្លួន។

ប្រការ ៥៤.-

គ្រឹះស្ថានមិនត្រូវរំលាយកិច្ចសន្យាមុនឥណប្រតិទាន ចំពោះហ្វាស៊ីលីធីណាមួយ នៅពេលដែលគ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីថ្មីមួយទៀត ទៅឱ្យសមភាគីតែមួយ ឬសម្ព័ន្ធបុគ្គលដែលទាក់ទងនឹងសមភាគី ដើម្បីចៀសវាងពីការចាត់ថ្នាក់ឥណទានដំបូងថាមានអ៊ីមភែរមិន។ ក្នុងករណី គ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះ ត្រូវចាត់ថ្នាក់ថាមានអ៊ីមភែរមិនភ្លាមនៅពេលអនុម័ត។

ប្រការ ៥៥.-

គ្រឹះស្ថានត្រូវមាន គោលនយោបាយ នីតិវិធី ប្រព័ន្ធព័ត៌មានវិទ្យា និងដំណើរការ ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាការទទួលស្គាល់និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនធ្វើឡើងបានទាន់ពេលវេលា និងអាចជឿជាក់បាន។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវមានចែងអំពីក្របខ័ណ្ឌវិភាគសម្រាប់វាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ គោលនយោបាយនិងនីតិវិធី ត្រូវមានចែងជាអប្បបរមា ដូចតទៅ៖

១. កំណត់តួនាទីនិងការទទួលខុសត្រូវរបស់ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវចូលរួមរៀបចំក្របខ័ណ្ឌវិភាគសម្រាប់វាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

២. កំណត់អត្តសញ្ញាណចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

៣. កំណត់ហ្វាស៊ីលីធីណា ដែលត្រូវវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" និងហ្វាស៊ីលីធីណា ដែលត្រូវវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម"។ គ្រឹះស្ថានត្រូវមានលទ្ធភាព

ពន្យល់បង្ហាញដល់ធនាគារជាតិនៃកម្ពុជាថា គោលនយោបាយរបស់ខ្លួនក្នុងការកំណត់ហ្វាស៊ីលីធី ដែលត្រូវបានវាយតម្លៃនិងគ្រប់គ្រង តាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" ត្រូវផ្តល់ការវិភាគដោយប្រុងប្រយ័ត្នទៅលើហានិភ័យឥណទាន ដែលអាចកើតមានចំពោះហ្វាស៊ីលីធីទោល

៤. កំណត់ពីវិធីសាស្ត្រវាស់វែងទំហំហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និង

៥. ពិនិត្យឡើងវិញជាទៀងទាត់លើ ទំហំ និងវិធីសាស្ត្រវាស់វែងទំហំហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

គោលនយោបាយនិងនីតិវិធីទាំងនោះត្រូវមានចែងអំពី ការប្រមូលនិងរក្សាទិន្នន័យទាំងអស់ រួមទាំងព័ត៌មានផ្សេងទៀតដើម្បីជួយដល់ការធ្វើសំវិធានធនឱ្យបានគ្រប់គ្រាន់។ គោលនយោបាយនិងនីតិវិធីនេះ រួមបញ្ចូលទាំងការរក្សាទុកគ្រប់ទិន្នន័យមានគុណភាពខ្ពស់ទាំងប្រភេទនិងទំហំ ដែលចាំបាច់សម្រាប់ប្រើប្រាស់ក្នុងម៉ូដែលហានិភ័យឥណទាន (Credit risk models) បច្ចេកទេសស្ថិតិ (Statistical techniques) និងវិធីសាស្ត្រដទៃទៀត ដែលប្រើប្រាស់ដោយគ្រឹះស្ថានក្នុងការវាយតម្លៃហានិភ័យឥណទាន។ គ្រឹះស្ថានត្រូវធានាភាពត្រឹមត្រូវនៃទិន្នន័យនិងព័ត៌មាន។

ប្រការ ៥៦.-

គ្រឹះស្ថានត្រូវបង្កើតនិងរក្សាប្រព័ន្ធពិនិត្យឥណទានឡើងវិញ ប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់ តាមដាន និងគ្រប់គ្រងគុណភាពទ្រព្យសកម្មឱ្យបានត្រឹមត្រូវ មានលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលា ស្របតាមគោលការណ៍ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៥ ដល់ ប្រការ ១០ នៃប្រកាសនេះ។ ជាផ្នែកមួយនៃដំណើរការពិនិត្យឥណទានឡើងវិញ គ្រឹះស្ថានត្រូវបង្កើតយន្តការនិងវាយតម្លៃជាប្រចាំនូវភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន សម្រាប់ទប់ទល់នឹងការខាតបង់រំពឹងទុក ដែលអាចកើតចេញពីសំពៀតឥណទាន ដោយគិតបញ្ចូលកត្តាទាំងអស់ដែលបង្ហាញពីភាពថមថយសមត្ថភាពរបស់គ្រឹះស្ថាន ក្នុងការប្រមូលប្រាក់ដែលដល់កាលកំណត់សងពីសមភាគី។

ក្នុងការទទួលស្គាល់និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវពិនិត្យឥណទានឡើងវិញទៅលើហ្វាស៊ីលីធីទាំងអស់ រួមទាំងហ្វាស៊ីលីធីដែលត្រូវបានចាត់ថ្នាក់ជា "ធម្មតា" និង "ឃ្លាំមើល"។

ប្រការ ៥៧.-

ផ្នែកទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយនិងនីតិវិធីនៃការចាត់ថ្នាក់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនរបស់គ្រឹះស្ថាន ត្រូវមានបុគ្គលិកដែលមានសមត្ថភាពនិងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវបានពិនិត្យឡើងវិញតាមគ្រាជាប្រចាំដោយសវនកម្មផ្ទៃក្នុង និងក្រុមហ៊ុនសវនកម្ម ហើយលទ្ធផលនៃការធ្វើសវនកម្ម ត្រូវរាយការណ៍ទៅក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់។ គ្រឹះស្ថានត្រូវកែតម្រូវភ្លាមៗនូវរាល់ចំណុចខ្វះខាតដែលបានរកឃើញ ដោយបុគ្គលិកទទួលបន្ទុកផ្នែកឥណទាន ឬដោយបុគ្គលិកទទួលបន្ទុកអនុវត្តគោលនយោបាយ និងនីតិវិធីនេះ ឬដោយសវនករផ្ទៃក្នុង ឬក្រុមហ៊ុនសវនកម្ម។

ប្រការ ៥៨.-

ការទទួលស្គាល់ និងការវាស់វែងអ៊ីមភែរមិននៃហ្វាស៊ីលីធី មិនពឹងផ្អែកតែលើរូបមន្ត និងវិធាននានាទេ តែតម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យផ្អែកលើបទពិសោធន៍ផ្អែកឥណទាន។ វិសាលភាពនៃការសម្រេចជាឆន្ទានុសិទ្ធិរបស់គណៈគ្រប់គ្រងក្នុងការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវមានកំណត់ដោយប្រុងប្រយ័ត្ន ហើយដំណើរការវិនិច្ឆ័យត្រូវកត់ត្រា និងមានឯកសារគ្រប់គ្រាន់ដែលមានលក្ខណៈងាយយល់។ គ្រឹះស្ថានត្រូវបង្ហាញថាការវិនិច្ឆ័យនេះនឹងមិននាំឱ្យមានការរាយការណ៍ខុសជាប្រព័ន្ធចំពោះការប៉ាន់ស្មានអ៊ីមភែរមិននៃហ្វាស៊ីលីធីនិងការធ្វើសំវិធានធន។ ការវិនិច្ឆ័យត្រូវផ្អែកលើសម្មតិកម្មគ្រប់គ្រាន់នៅគ្រប់កាលៈទេសៈពាក់ព័ន្ធ និងធ្វើឡើងដោយប្រុងប្រយ័ត្ន។ ការវិនិច្ឆ័យនេះអាចមានសារៈសំខាន់ៈ

១. សម្រាប់កំណត់រយៈពេលសមស្របដែលអាចអនុញ្ញាតឱ្យគណនាទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់។ ដើម្បីកំណត់ពីទិន្នន័យជាមធ្យមនៃហ្វាស៊ីលីធីបាត់បង់ដែលធ្លាប់កើតមានសម្រាប់ក្រុមហ្វាស៊ីលីធីណាមួយ គ្រឹះស្ថានមិនត្រូវកំណត់យកតែរយៈពេលថេរឡើយ។ ក្នុងអំឡុងពេលសេដ្ឋកិច្ចមានស្ថិរភាព គ្រឹះស្ថានអាចប្រើប្រាស់ទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់រយៈពេលវែង (លើសពី ០៥ ឆ្នាំ) ចំណែកឯក្នុងអំឡុងពេលសេដ្ឋកិច្ចមានការប្រែប្រួលខ្លាំង គ្រឹះស្ថានអាចប្រើប្រាស់ទិន្នន័យរយៈពេលខ្លីជាងនេះ ឬ

២. សម្រាប់ករណីដែលគ្រឹះស្ថានមិនមានទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់គ្រប់គ្រាន់ឬទិន្នន័យទាំងនោះមិនអាចឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្នបាន។

ប្រការ ៥៩.-

ការកែសម្រួលទៅលើទិន្នន័យនិងបទពិសោធន៍នៃប្រវត្តិហ្វាស៊ីលីធីខាតបង់ ត្រូវមានចំណុចយ៉ាងតិចដូចខាងក្រោមៈ

១. ការប្រែប្រួលទៅលើកម្រិតនិងនិន្នាការនៃអត្រាសងឃឺតនិងទំហំនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

២. ការប្រែប្រួលទៅលើការបែងចែក និងការប្រមូលផ្តុំឥណទាន

៣. ការកែប្រែគោលនយោបាយនិងនីតិវិធីឥណទានរបស់គ្រឹះស្ថាន

៤. ការប្រែប្រួលការរៀបចំហ្វាស៊ីលីធីឡើងវិញ

៥. ការប្រែប្រួលបទពិសោធន៍ និងសមត្ថភាពរបស់គណៈគ្រប់គ្រងរបស់គ្រឹះស្ថានក្នុងការគ្រប់គ្រងហានិភ័យឥណទាន និងក្នុងការប្រមូលត្រឡប់មកវិញនូវចំនួនទឹកប្រាក់ដែលហួសកាលកំណត់សង និង

៦. ការប្រែប្រួលស្ថានភាព និងនិន្នាការសេដ្ឋកិច្ចក្នុងស្រុកនិងសកល ទាំងបច្ចុប្បន្ន និងអំពីងទុក។

ប្រការ ៦០.-

នៅពេលគ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីច្រើនទៅឱ្យសមភាគីតែមួយ ឬក្រុមសម្ព័ន្ធសមភាគី គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធី ដើម្បីធានាថា ប្រសិនបើហ្វាស៊ីលីធីណាមួយត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីដទៃទៀតជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនដូចគ្នា លើកលែងតែក្នុងករណី ដូចខាងក្រោម៖

១. ហ្វាស៊ីលីធីផ្សេងៗ មិនត្រូវបានធានាដោយទ្រព្យធានារួម និងមិនមានការធានាទៅវិញទៅមក រវាងសមភាគីសម្ព័ន្ធញាតិ ឬ

២. ហ្វាស៊ីលីធីដែលមានទ្រព្យធានារួម និង/ឬ ការធានាទៅវិញទៅមក ប៉ុន្តែ សមភាគី ឬសមភាគីសម្ព័ន្ធញាតិមានការធានាគ្រប់គ្រាន់ ក្នុងការប្រមូលគ្រប់ចំនួននូវការទូទាត់សងដែលដល់កាលកំណត់ រួមមាន ប្រាក់ដើម ការប្រាក់ និងបំណុលផ្សេងៗ ទាំងចំពោះហ្វាស៊ីលីធីមាន និងមិនមានអ៊ីមភែរមិន។

ប្រការ ៦១.-

ជាផ្នែកមួយនៃការវាស់វែងកម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី គ្រឹះស្ថានត្រូវមានគោលនយោបាយ និងនីតិវិធីដើម្បីធានាបាននូវភាពជឿទុកចិត្តបាន សង្គតិភាព និងភាពប្រុងប្រយ័ត្ន ចំពោះការប៉ាន់ស្មានការទូទាត់នាពេលអនាគតលើប្រាក់ដើមនិងការប្រាក់ ដែលបានប្រើប្រាស់ក្នុងការកំណត់កម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី។

ប្រការ ៦២.-

គ្រឹះស្ថានមិនត្រូវប្រើទ្រព្យធានាធ្វើជាហេតុផលជំនួសកង្វះព័ត៌មានរបស់សមភាគី ឬកង្វះការវិភាគរបស់គ្រឹះស្ថាន ក្នុងការតាមដានជាប្រចាំអំពីការបំពេញកាតព្វកិច្ចស្របតាមកិច្ចសន្យារបស់សមភាគី។ លើសពីនេះ គ្រឹះស្ថានក៏មិនត្រូវប្រើទ្រព្យធានាធ្វើជាហេតុផលជំនួសការវិភាគរបស់គ្រឹះស្ថាន ក្នុងការវាយតម្លៃជាប្រចាំនូវកម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី និងតម្រូវការធ្វើសំវិធានធនលើអ៊ីមភែរមិន។

ប្រការ ៦៣.-

ក្នុងការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី គ្រឹះស្ថានត្រូវពិនិត្យទាំងកត្តាខាងក្នុង និងខាងក្រៅដែលអាចបង្ហាញពីការថយចុះលទ្ធភាព ឬគ្មានលទ្ធភាពប្រមូលការទូទាត់សង ដែលដល់កាលកំណត់តាមកិច្ចសន្យារបស់សមភាគី។ កត្តាទាំងនេះ រួមមាន៖

១. ការថយចុះលទ្ធភាពទូទាត់សងរបស់សមភាគី ដែលត្រូវធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ របស់ក្រុមសមភាគីដែលត្រូវធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម"

២. ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពសងរបស់សមភាគី

៣. ព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងបម្រែបម្រួលសំខាន់ៗក្នុងស្រុក និងអន្តរជាតិដែលមានឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពក្នុងស្រុក និងលទ្ធភាពសងរបស់សមភាគី។

បម្រែបម្រួលទាំងនេះរួមមាន ការផ្លាស់ប្តូរនៃបរិស្ថានបច្ចេកវិទ្យា សេដ្ឋកិច្ច ទីផ្សារ ច្បាប់ និងសង្គម

៥. សូចនាករហានិភ័យប្រទេសដែលអាចមានឥទ្ធិពលអវិជ្ជមានលើស្ថានភាពរបស់សមភាគី។

ប្រការ ៦៤.-

ការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវអនុវត្តឱ្យមានសង្គតិភាពតាមគ្រានីមួយៗ។ រាល់ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធី ត្រូវកែសម្រួល និងអនុម័តដោយគណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

ប្រការ ៦៥.-

គ្រឹះស្ថានត្រូវកំណត់កម្រិតនៃការធ្វើសំវិធានធនដោយប្រុងប្រយ័ត្នដើម្បីរ៉ាប់រងការខាតបង់ដែលអាចបណ្តាលមកពីហានិភ័យឥណទាន។ ការខាតបង់នេះ រាប់បញ្ចូលទាំងការខាតបង់ដែលមានរួចហើយ ប៉ុន្តែមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណ ឬចាត់ថ្នាក់ក្នុងហ្វាស៊ីលីធីទោល ឬហ្វាស៊ីលីធីក្រុម។ ការអនុវត្តនេះមានសារៈសំខាន់នៅពេលមានស្ថានភាពឥណទានមិនល្អកើតឡើង ប៉ុន្តែមិនបានរាយការណ៍នៅពេលធ្វើការវាយតម្លៃ ឬនៅកាលបរិច្ឆេទនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ជំពូកទី ៨
ការធ្វើសំវិធានធនតាមស្តង់ដារគណនេយ្យ

ប្រការ ៦៦.-

នៅពេលហ្វាស៊ីលីធីត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន ទោះជាតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបង្កើនសំវិធានធនជាក់លាក់ ដើម្បីរ៉ាប់រងកង្វះលំហូរសាច់ប្រាក់ដែលអាចកើតមាននៅពេលដល់កាលកំណត់សងតាមកិច្ចសន្យា។ ការបង្កើនសំវិធានធននេះត្រូវរួមបញ្ចូលសោហ៊ុយ និងចំណាយផ្សេងៗដែលកើតមាន ដើម្បីទទួលបានលំហូរសាច់ប្រាក់មកវិញ។ ការធ្វើសំវិធានធនជាក់លាក់ត្រូវបានរាយការណ៍តាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" ប្រសិនបើការវាស់វែងអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវបានវាយតម្លៃដោយផ្អែកតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" រៀងគ្នា។

ប្រការ ៦៧.-

នៅពេលគណនាសំវិធានធនជាក់លាក់សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវវាយតម្លៃដោយផ្អែកលើលក្ខណៈ "ហ្វាស៊ីលីធីទោល"។ ហ្វាស៊ីលីធីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា និងស្ថិតក្រោមកម្រិតកំណត់ជាសារវន្ត ត្រូវបានបញ្ចូលគ្នានិងវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដូចមានចែងក្នុងប្រការ ៥០ នៃប្រកាសនេះ។

ជាផ្នែកមួយនៃការពិនិត្យឥណទានឡើងវិញ គ្រឹះស្ថានត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីទំហំហ្វាស៊ីលីធីដែលត្រូវយកមកវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ដើម្បីចែកឱ្យដាច់ថាហ្វាស៊ីលីធីដែលមានតម្លៃក្រោមកម្រិតកំណត់ អាចត្រូវបានចាត់ក្នុងក្រុមដែលមានលក្ខណៈប្រហាក់ប្រហែល

ក្នុងគោលបំណងវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី។ គ្រឹះស្ថានត្រូវធានាថា រាល់ហ្វាស៊ីលីធីទាំងអស់ក្នុងសំពៀតឥណទានត្រូវបានពិនិត្យឡើងវិញតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម"។

ការធ្វើសំវិធានធនជាក់លាក់បន្ថែមត្រូវធ្វើឡើងដោយផ្អែកលើការវាយតម្លៃបន្ថែមតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដូចមានចែងក្នុងប្រការ ៥១ នៃប្រកាសនេះ។

ប្រការ ៦៨.-

ការធ្វើសំវិធានធន ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដែលធ្វើឡើងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ត្រូវផ្អែកលើការប៉ាន់ស្មានសមហេតុផលនិងមានឯកសារគ្រប់គ្រាន់ អំពីតម្លៃបច្ចុប្បន្ននៃហ្វាស៊ីលីធី និងការទូទាត់នាពេលអនាគតនៃប្រាក់ដើម ការប្រាក់ និងលំហូរសាច់ប្រាក់ផ្សេងៗទៀត ដែលគ្រឹះស្ថានរំពឹងថានឹងទទួលបានពីហ្វាស៊ីលីធីនោះ។ ហ្វាស៊ីលីធីធំៗ ត្រូវបានវាយតម្លៃតាមវិធីសាស្ត្រដែលមានលក្ខណៈជឿនលឿន ដូចជាការប្រើប្រាស់ម៉ូដែល និងបច្ចេកទេសស្ថិតិផ្សេងៗទៀត។

ប្រការ ៦៩.-

ការធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ត្រូវផ្អែកលើបទពិសោធន៍នៃប្រវត្តិខាតបង់ហ្វាស៊ីលីធីរបស់គ្រឹះស្ថាន ដែលត្រូវកែសម្រួលដូចមានចែងក្នុងប្រការ ៥៩ នៃប្រកាសនេះ ឱ្យបានសមស្របតាមស្ថានភាព លក្ខខណ្ឌនានាពេលបច្ចុប្បន្ន និងកត្តាផ្សេងទៀត ដែលអាចមានឥទ្ធិពលលើការទូទាត់សងហ្វាស៊ីលីធីក្នុងសំពៀតឥណទាន។ ការធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ត្រូវប្រើប្រាស់បច្ចេកទេសជឿនលឿន ដែលអាចជួយដល់ការប៉ាន់ស្មានអ៊ីមភែរមិននៃហ្វាស៊ីលីធីកាន់តែច្បាស់លាស់។

គ្រឹះស្ថានត្រូវរក្សាឱ្យបានគ្រប់គ្រាន់នូវទិន្នន័យនៃប្រវត្តិខាតបង់ហ្វាស៊ីលីធីសម្រាប់រយៈពេលមួយវដ្តឥណទាន ដើម្បីប៉ាន់ស្មានទំហំអ៊ីមភែរមិននៃហ្វាស៊ីលីធីឱ្យបានត្រឹមត្រូវនិងអាចទុកចិត្តបានក្នុងការកំណត់ទំហំសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" សម្រាប់ក្រុមនីមួយៗនៃហ្វាស៊ីលីធីដែលមានលក្ខណៈស្រដៀងគ្នា។

ប្រការ ៧០.-

ការធ្វើសំវិធានធន ក៏ត្រូវផ្អែកលើការវិនិច្ឆ័យប្រកបដោយបទពិសោធន៍ផ្នែកឥណទាន ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥៨ នៃប្រកាសនេះ។

ប្រការ ៧១.-

ដើម្បីកំណត់កម្រិតសមស្របនៃការធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបែងចែកសំពៀតហ្វាស៊ីលីធីទៅជាក្រុមតូចៗតាមការចាំបាច់ ទៅតាមចរិតលក្ខណៈស្រដៀងគ្នា ដូចជា ប្រភេទហ្វាស៊ីលីធី ចំណាត់ថ្នាក់ហានិភ័យ ឥណប្រតិទាន ស្ថានភាពហួសកាលកំណត់សង ប្រភេទអតិថិជន និងប្រភេទទ្រព្យធានា ជាដើម។

ជំពូកទី ៩
ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ

ប្រការ ៧២.-

ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ ដល់ប្រការ ៧៣ នៃប្រកាសនេះ ត្រូវចាត់ទុកជាកម្រិតគោលនៃសំវិធានធន ដែលគ្រឹះស្ថានបានគណនាត្រឹមត្រូវនិងសមស្របសម្រាប់តាមដានផ្នែកបទប្បញ្ញត្តិនូវកម្រិតសំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៥៩ ដល់ប្រការ ៧១ នៃប្រកាសនេះ។

ការគណនាកម្រិតសំវិធានធនសរុបតាមបទប្បញ្ញត្តិ ស្មើនឹងខ្នង់ ១ + ២ ដែលក្នុងនោះ៖

១. សំវិធានធនទូទៅ ស្មើនឹង ១% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ "ធម្មតា"

២. សំវិធានធនជាក់លាក់ ស្មើនឹង ក + ខ + គ + ឃ

ក = ៣% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "ឃ្លាំមើល"

ខ = ២០% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "ក្រោមស្តង់ដារ"

គ = ៥០% នៃហ្វាស៊ីលីធីដុលសម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "សង្ស័យ"

ឃ = ១០០% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "បាត់បង់"

គ្រឹះស្ថានត្រូវធ្វើចំណាត់ថ្នាក់ហានិភ័យឥណទានចំពោះសំពៀតហ្វាស៊ីលីធីទាំងអស់ស្របតាមបញ្ញត្តិនៃប្រការ ១២ ដល់ ប្រការ ២២ នៃប្រកាសនេះ ដើម្បីឱ្យគ្រឹះស្ថានអាចកំណត់កម្រិតសំវិធានធនតាមបទប្បញ្ញត្តិ តាមស្ថានភាពជាក់ស្តែងនៃសំពៀតហ្វាស៊ីលីធី។ សំវិធានធនតាមបទប្បញ្ញត្តិ ត្រូវចាត់ទុកជាចំនួនអប្បបរមានៃសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៧២ ដល់ប្រការ ៧៣ នៃប្រកាសនេះ ត្រូវធ្វើឡើងទន្ទឹមនឹងការគណនាកម្រិតសំវិធានធនលើហ្វាស៊ីលីធី ដែលមានអ៊ីមភែរមិនដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៥៩ ដល់ប្រការ ៧១ ខាងលើ ដែលជាកាតព្វកិច្ចសម្រាប់គ្រប់គ្រឹះស្ថានទាំងអស់។

ប្រការ ៧៣.-

គ្រឹះស្ថានត្រូវប្រៀបធៀបកម្រិតសំវិធានធនគណនាតាមបញ្ញត្តិនៃប្រការ ៥៩ ដល់ប្រការ ៧១ និងកម្រិតសំវិធានធនតាមបទប្បញ្ញត្តិដែលគណនាតាមប្រការ ៧២ ហើយត្រូវកត់ត្រាចំនួនសំវិធានធនដូចខាងក្រោម៖

១. ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ **<u>ទាបជាង</u>** កម្រិតសំវិធានធនដែលគណនាតាមបញ្ញត្តិនៃប្រការ ៥៩ ដល់ប្រការ ៧១ គ្រឹះស្ថានត្រូវកត់ត្រាសំវិធានធនដែលគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា។

២. ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ **<u>ខ្ពស់ជាង</u>** កម្រិតសំវិធានធនដែលគណនាតាមបញ្ញត្តិនៃប្រការ ៥៩ ដល់ប្រការ ៧១ គ្រឹះស្ថានត្រូវ

កត់ត្រាសំវិធានធនដែលគណនាតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ហើយត្រូវផ្ទេរចំនួនខុសគ្នា (the difference) ពីគណនីប្រាក់ចំណេញរក្សាទុកឬខាតបង្គរទៅក្នុងគណនី "ទុនបម្រុងតាមបទប្បញ្ញត្តិ" (Regulatory Reserve) ក្នុងខ្នង់មូលនិធិភាគទុនិកនៃតារាងតុល្យការ។

ទុនបម្រុងតាមបទប្បញ្ញត្តិនេះមិនត្រូវអនុញ្ញាតឱ្យបូកបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានទេ។

ប្រការ ៧៤.-

ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ត្រូវចាត់វិធានការសមស្របដើម្បីធានាបានការអនុវត្តពេញលេញតាមលក្ខខណ្ឌនានានៃប្រកាសនេះ។

ជំពូកទី ១០
ការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី

ប្រការ ៧៥.-

ក្នុងការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី គ្រឹះស្ថានត្រូវផ្អែកលើការវាយតម្លៃយ៉ាងហ្មត់ចត់អំពីលទ្ធភាពសងរបស់សមភាគី និងការវិភាគលើស្ថានភាពអាជីវកម្មនិងហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ពីសកម្មភាពអាជីវកម្មនោះ ស្របតាមក្របខ័ណ្ឌនៃការចាត់ថ្នាក់ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ១២ ដល់ ប្រការ ២២ នៃប្រកាសនេះ។

ប្រការ ៧៦.-

គ្រឹះស្ថានអាចស្តារចំណាត់ថ្នាក់ហ្វាស៊ីលីធីពីហ្វាស៊ីលីធីមិនដំណើរការ ទៅជា ហ្វាស៊ីលីធីដំណើរការ និងត្រូវបំពេញតាមលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម៖

១. ហ្វាស៊ីលីធីវិវដ្តទៅរកស្ថានភាពដែលបានអនុវត្តគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាដើម រួមទាំងការទទួលបានការទូទាត់សងប្រាក់ដើម ការប្រាក់ និងសោហ៊ុយផ្សេងៗដែលហួសកាលកំណត់សង

២. គ្រឹះស្ថានមានហេតុផលសមស្របក្នុងការជឿជាក់ថាសមភាគីនឹងបំពេញតាមកាតព្វកិច្ចទូទាត់សងនាពេលអនាគត

៣. ហ្វាស៊ីលីធីដែលខកខានសងហួសរយៈពេល ៩០ ថ្ងៃ ឬលើសពីនេះ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ត្រូវបានទូទាត់សងវិញទាំងអស់ ហើយការទូទាត់សងនេះត្រូវធ្វើឡើងដោយមិនប្រើប្រាស់ការធ្វើបុរេប្រទានបន្ថែមពីគ្រឹះស្ថាន។ ចំពោះហ្វាស៊ីលីធីដែលបង់រំលស់ប្រចាំខែ សមភាគីបានអនុវត្តតាមកាតព្វកិច្ចទូទាត់សងបន្តបន្ទាប់គ្នាក្នុងរយៈពេលយ៉ាងតិច ០៦ ខែ (០៣ ខែសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី)។ គ្រឹះស្ថានមិនត្រូវស្តារចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះទេ ប្រសិនបើគ្រឹះស្ថានសង្ស័យថា ការទូទាត់សងរបស់សមភាគីបានមកពីបុរេប្រទានពីគ្រឹះស្ថានផ្សេងៗ ឬបុគ្គលណាមួយ។ ក្នុងករណី

ណាក៏ដោយ គ្រឹះស្ថានត្រូវធានាថា សមភាគីមានលទ្ធភាពទូទាត់សងបន្ថែមទៀតលើសពីការតម្រូវ (Margin of comfort) ដែលអាចការពារមិនឱ្យហ្វាស៊ីលីធីរីរដ្ឋទៅស្ថានភាពមិនដំណើរការវិញនាពេលអនាគត បើមិនដូច្នោះទេ ហ្វាស៊ីលីធីនេះនៅតែត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីមិនដំណើរការដដែល

៤. ហ្វាស៊ីលីធីដែលត្រូវបានលុបចោលមួយផ្នែក ត្រូវបានទូទាត់សងវិញជាបន្តបន្ទាប់ក្នុងរយៈពេលយ៉ាងតិច ០៦ ខែ ឬយ៉ាងតិច ០៣ គ្រា

៥. ចំពោះហ្វាស៊ីលីធីដែលតម្រូវឱ្យធ្វើសំវិធានធនដោយសារហេតុផលសមស្របណាមួយ សំវិធានធននោះមិនតម្រូវទៀតទេ និង

៦. ចំពោះហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ (Revolving Facilities) ដោយមិនមានការធានាគ្រប់គ្រាន់ និងត្រូវបានប្រើប្រាស់លើសកម្រិតកំណត់ ហ្វាស៊ីលីធីត្រូវរីរដ្ឋមកត្រឹមកម្រិតអនុម័តវិញ ក្នុងរយៈពេលបន្តបន្ទាប់យ៉ាងតិច ០៣ ខែ។

ប្រការ ៧៧.-

គ្រឹះស្ថានត្រូវអនុវត្តដោយប្រុងប្រយ័ត្នក្នុងការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីពីមួយថ្នាក់ទៅមួយថ្នាក់ និងត្រូវធានាថា ហ្វាស៊ីលីធីដែលគ្រឹះស្ថានមានបំណងតម្លើងចំណាត់ថ្នាក់ បង្ហាញនិន្នាការវិវត្តទៅរកភាពល្អប្រសើរជាលំដាប់ និងគោរពតាមរាល់លក្ខខណ្ឌនៃការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី។

ប្រការ ៧៨.-

រាល់ការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី គ្រឹះស្ថានត្រូវមានឯកសារភស្តុតាងច្បាស់លាស់ជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តក្នុងការតម្លើងចំណាត់ថ្នាក់នោះ។ គ្រឹះស្ថានត្រូវរាយការណ៍ពីការតម្លើងចំណាត់ថ្នាក់តាមគ្រាជូនក្រុមប្រឹក្សាភិបាល ហើយរបាយការណ៍នោះអាចប្រើប្រាស់បានដោយ សវនករផ្ទៃក្នុង ក្រុមហ៊ុនសវនកម្ម និងធនាគារជាតិនៃកម្ពុជាតាមការចាំបាច់។

ប្រការ ៧៩.-

នៅពេលហ្វាស៊ីលីធីមិនដំណើរការត្រូវបានតម្លើងចំណាត់ថ្នាក់ជាហ្វាស៊ីលីធីដំណើរការ ហើយបន្ទាប់មកក្លាយជាហ្វាស៊ីលីធីមិនដំណើរការម្តងទៀត គ្រឹះស្ថានមិនអាចតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះ ជាលើកទីពីរបានទេ។ គ្រឹះស្ថានត្រូវរក្សាហ្វាស៊ីលីធីនោះជាហ្វាស៊ីលីធីមិនដំណើរការដដែល។

ប្រការ ៨០.-

បន្ថែមទៅលើបញ្ញត្តិនៃប្រការ ៦០ នៃប្រកាសនេះ គ្រឹះស្ថានមិនអាចបំបែកហ្វាស៊ីលីធីតែមួយទៅជាផ្នែកដែលមិនដំណើរការផង និងផ្នែកដំណើរការផងបានទេ។

ប្រការ ៨១.-

ហ្វាស៊ីលីធីដែលត្រូវបានរៀបចំឡើងវិញរួចហើយ មិនត្រូវបានចាត់ថ្នាក់ឱ្យល្អជាងមុនទេ លុះត្រាតែសមភាគីបានគោរពពេញលេញតាមលក្ខខណ្ឌនៃកិច្ចសន្យាហ្វាស៊ីលីធីរៀបចំឡើងវិញ និងបានអនុវត្តដូចខាងក្រោម៖

១. បានទូទាត់សងគ្រប់ចំនួន ទាំងប្រាក់ដើមនិងការប្រាក់ យ៉ាងតិចក្នុងរយៈពេល ០៦ ខែ ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំខែ ឬ

២. បានទូទាត់សងគ្រប់ចំនួន ទាំងប្រាក់ដើមនិងការប្រាក់ យ៉ាងតិចក្នុងរយៈពេល ០១ ឆ្នាំ ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំត្រីមាស ឬឆមាស។

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញដែលមានការទូទាត់សងប្រាក់ដើមនិងការប្រាក់ប្រចាំឆ្នាំ ឬរយៈពេលវែងជាង គ្រឹះស្ថានអាចតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីបាន លុះត្រាតែសមភាគីបានគោរពពេញលេញតាមលក្ខខណ្ឌកិច្ចសន្យានៃហ្វាស៊ីលីធីរៀបចំឡើងវិញ ហើយបានបង្ហាញពីលទ្ធភាពទូទាត់សង បន្ទាប់ពីបញ្ចប់ការទូទាត់សងលើកទីមួយ។ គ្រឹះស្ថានមិនត្រូវតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី មុនពេលសមភាគីធ្វើការសងរំលស់លើកទីមួយទាន់ពេលនិងគ្រប់ចំនួន។

ក្នុងករណីដែលហ្វាស៊ីលីធីរៀបចំឡើងវិញត្រូវបានផ្តល់រយៈពេលអនុគ្រោះ (Moratorium) គ្រឹះស្ថានមិនត្រូវតម្លើងចំណាត់ថ្នាក់ក្នុងអំឡុងពេលអនុគ្រោះនោះទេ។ ការតម្លើងចំណាត់ថ្នាក់នេះអាចធ្វើបាន លុះត្រាតែសមភាគីគោរពទៅតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការនេះ ដោយថ្ងៃចាប់ផ្តើមត្រូវគិតចាប់ពីថ្ងៃបញ្ចប់រយៈពេលអនុគ្រោះ។

ប្រការ ៨២.-

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញចំពោះហ្វាស៊ីលីធីដើមដែលត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីមិនដំណើរការ ដូចជា "ក្រោមស្តង់ដារ" "សង្ស័យ" ឬ "បាត់បង់" រួចហើយ គ្រឹះស្ថានមិនត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីទាំងនោះឱ្យល្អជាង "ក្រោមស្តង់ដារ" ទេ។ ក្នុងករណីណាក៏ដោយ ហ្វាស៊ីលីធីដែលត្រូវបានរៀបចំឡើងវិញលើសពីមួយដង មិនអាចតម្លើងចំណាត់ថ្នាក់បានទេ។

ជំពូកទី ១១
ការលុបចោលហ្វាស៊ីលីធី

ប្រការ ៨៣.-

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តលើគោលនយោបាយលុបចោលហ្វាស៊ីលីធី ហើយគោលនយោបាយនេះត្រូវមានចែងអំពី កាលៈទេសៈ លក្ខខណ្ឌ និងសិទ្ធិអនុម័ត ក្នុងការលុបចោលហ្វាស៊ីលីធីទាំងនោះ។ គោលនយោបាយនេះ ត្រូវកំណត់អំពីចរិតលក្ខណៈ និងគ្រោងការណ៍អំពីការលុបចោលហ្វាស៊ីលីធី ជូនក្រុមប្រឹក្សាភិបាល។ ការរាយការណ៍នេះត្រូវមានព័ត៌មានត្រឹមត្រូវអំពីការខិតខំប្រឹងប្រែងប្រមូលហ្វាស៊ីលីធីមកវិញ មុនពេលសម្រេចលុបចោលហ្វាស៊ីលីធីនោះ។

ប្រការ ៨៤.-

ជាគោលការណ៍ គ្រឹះស្ថានត្រូវដកចេញហ្វាស៊ីលីធីផ្នែកខ្លះឬទាំងស្រុងចេញពីតារាងតុល្យការ នៅពេលគ្រឹះស្ថានបាត់បង់ការគ្រប់គ្រងលើសិទ្ធិ ដូចមានចែងក្នុងកិច្ចសន្យានៃហ្វាស៊ីលីធីនោះ ឬនៅពេលហ្វាស៊ីលីធីនោះ ផ្នែកខ្លះឬទាំងស្រុង មិនរំពឹងថាអាចប្រមូលមកវិញបាន ជាពិសេស ក្នុងករណីដែលហ្វាស៊ីលីធីនោះមិនប្រាកដថានឹងអាចប្រមូលមកវិញបាន ឬនៅពេលគ្រឹះស្ថានបាត់បង់ការគ្រប់គ្រងលើសិទ្ធិដូចមានចែងក្នុងកិច្ចសន្យានៃហ្វាស៊ីលីធី ដោយសារសេចក្តីសម្រេចរបស់តុលាការ។ ហ្វាស៊ីលីធីអាចត្រូវបានលុបចោលក្នុងករណីណាមួយយ៉ាងតិចដូចខាងក្រោម៖

១. ការធានា ឬទ្រព្យធានាគ្រប់ប្រភេទ ត្រូវបានបញ្ចប់ និងបានលក់ចេញ ប៉ុន្តែទឹកប្រាក់ដែលលក់បាន មិនអាចទូទាត់សងគ្រប់សមតុល្យដក់សល់របស់ហ្វាស៊ីលីធី

២. គ្រឹះស្ថានមិនអាចប្រមូល ឬមិនមានមូលហេតុសមស្របក្នុងការធានាថានឹងប្រមូលបានគ្រប់ចំនួនដែលដល់កាលកំណត់សង ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាហ្វាស៊ីលីធី

៣. សមភាគីបានក្ស័យធន ឬស្ថិតក្នុងដំណាក់កាលរៀបចំឡើងវិញផ្នែកហិរញ្ញវត្ថុ ដែលលទ្ធផលនៃការរៀបចំឡើងវិញនេះ មិនអាចទូទាត់សងហ្វាស៊ីលីធីបាន ឬ

៤. ហ្វាស៊ីលីធីត្រូវបានចាត់ថ្នាក់ថា "បាត់បង់"។

ជំពូកទី ១២
ការត្រួតពិនិត្យ

ប្រការ ៨៥.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ កែសម្រួលគោលការណ៍និងនីតិវិធី និងលទ្ធផលនៃការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធី ការវាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវចាត់វិធានការកែតម្រូវភ្លាមៗឱ្យបានសមស្រប។

ជំពូកទី ១៣
អន្តរប្បញ្ញត្តិ

ប្រការ ៨៦.-

គ្រឹះស្ថានត្រូវត្រៀមខ្លួនអនុវត្តការទទួលស្គាល់ ការវាស់វែង និងការធ្វើសំវិធានធនរបស់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

ប្រការ ៨៧.-

ក្នុងរយៈពេលអន្តរកាលមុនឈានទៅការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា គ្រឹះស្ថានត្រូវធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមប្រការ ៧២ នៃប្រកាសនេះ។

បន្ទាប់ពីអនុវត្តបានពេញលេញតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់កម្ពុជា គ្រឹះស្ថានត្រូវអនុវត្តតាមប្រការ ៧៣ នៃប្រកាសនេះ ចំពោះការធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្នុងករណីគ្រឹះស្ថានមានបំណងអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់កម្ពុជា មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ គ្រឹះស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជា។

ជំពូកទី ១៤
អវសានប្បញ្ញត្តិ

ប្រការ ៨៨.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៨៩.-

ប្រកាសលេខ ធ៧-០៩-០៧៤ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការធ្វើចំណាត់ថ្នាក់និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើឥណទានអនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩០.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩១.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ គ.ស ២០១៧
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៨-០០១ ស.រ.ច.ណ

ថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨

សារាចរណែនាំ
ស្តីពី
ការអនុវត្តប្រកាសស្តីពី
ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន

យោងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឱ្យចូលជាធរមានដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខ ធ៧-០១៧-៣៥៤ ប្រ.ក ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាសូមណែនាំបន្ថែមអំពីការអនុវត្តខ្លឹមសារនៃប្រកាសនេះ ដូចខាងក្រោម៖

១- ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិទាំងអស់នៃប្រកាសលេខ ធ៧-០១៧-៣៥៤ ប្រ.ក រួមបញ្ចូលទាំងការគណនាសំវិធានធនលើអ៊ីមតែរមិន ក្នុងរបាយការណ៍សវនកម្មប្រចាំឆ្នាំ២០១៧។ ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបញ្ជាក់ថាមានការលំបាកក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសថ្មីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចបន្តអនុវត្តតាមកាតព្វកិច្ចដូចការអនុវត្តកន្លងមក ចំពោះតែការបិទបញ្ជិកាគណនេយ្យសម្រាប់ឆ្នាំ២០១៧ ប៉ុណ្ណោះ។

២- ការរៀបចំការពិនិត្យឡើងវិញនិងការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធី

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការពិនិត្យឡើងវិញជាផ្លូវការ និងគ្រប់ជ្រុងជ្រោយលើការចាត់ថ្នាក់ហ្វាស៊ីលីធីទាំងអស់របស់ខ្លួនស្របតាមវិធាននានា ដូចបានកំណត់ក្នុងប្រកាសលេខ ធ៧-០១៧-៣៥៤ ប្រ.ក ឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១៨។ លទ្ធផលនៃការពិនិត្យឡើងវិញនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមរាយការណ៍លម្អិតអំពីចំនួនហ្វាស៊ីលីធី និងទំហំទឹកប្រាក់ដក់សល់ក្នុងចំណាត់ថ្នាក់ទាំងប្រាំនៃហ្វាស៊ីលីធីដូចមានចែងក្នុងប្រកាសលេខ ធ៧-០១៧-៣៥៤ ប្រ.ក មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៣- ការវាយតម្លៃសាកល្បងអំពីសំវិធានធនលើអ៊ីមតែរមិនសម្រាប់ឆ្នាំ២០១៨

ផ្អែកលើប្រកាសលេខ ធ៧-០១៧-៣៥៤ ប្រ.ក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃឱ្យបានពេញលេញអំពីតម្រូវការសំវិធានធនលើអ៊ីមតែរមិន ស្របតាមបញ្ញត្តិនានាចាប់ពីប្រការ ៥៩ ដល់ប្រការ ៧១ ដូចខាងក្រោម៖

- លើកទី ១៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្វាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។ ការរាយតម្លៃនេះនឹងជួយគ្រឹះស្ថានក្នុងការរៀបចំគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងគ្រប់គ្រាន់ដើម្បីគណនាតម្រូវការសំវិធានធនលើអ៊ីមភែរមិនដោយយោងតាមវិធានថ្មីនានា។
- លើកទី ២៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគណនាសំវិធានធនលើអ៊ីមភែរមិន ដោយយកទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងត្រូវរាយការណ៍លទ្ធផលនៃការគណនាសំវិធានធនលើអ៊ីមភែរមិន ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗនៃហ្វាស៊ីលីធីមកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

របាយការណ៍លទ្ធផលនេះ ត្រូវបង្ហាញឱ្យច្បាស់អំពីចំនួនសំវិធានធនលើអ៊ីមភែរមិនទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាននីមួយៗ (Credit Risk Grading) នៃហ្វាស៊ីលីធី ដោយត្រូវឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងការធ្វើសំវិធានធនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំការវាយតម្លៃសំវិធានធនខាងលើនេះ ដោយការយកចិត្តទុកដាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

៤- គោលនយោបាយនិងនីតិវិធីឥណទាន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ញើគោលនយោបាយនិងនីតិវិធីឥណទានស្របតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក មកធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ក្នុងករណី មានការធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយនិងនីតិវិធីឥណទានដែលបានរៀបចំរួចហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើគោលនយោបាយនិងនីតិវិធីឥណទាននោះមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃក្រោយពីក្រុមប្រឹក្សាភិបាលបានអនុម័ត។

ដោយផ្អែកលើរបាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ព័ត៌មានបន្ថែម និងត្រូវកែប្រែគោលនយោបាយនិងនីតិវិធី ព្រមទាំងការអនុវត្តគោលនយោបាយនិងនីតិវិធីទាំងនោះ។

៥- ការកត់ត្រាសំវិធានធនជាក់លាក់ និងការប្រាក់បន្តរ

ក្នុងការអនុវត្តតម្រូវការសំវិធានធនតាមបទប្បញ្ញត្តិ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនជាក់លាក់ (Specific provision) ឱ្យបានគ្រប់គ្រាន់ និងកត់ត្រានៅក្នុងគណនីរបស់គ្រឹះស្ថានឱ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់សមភាគី ហើយទទួលស្គាល់ជាចំណាយនៅក្នុង

របាយការណ៍ចំណេញ-ខាតតាមគ្រា មកធនាគារជាតិនៃកម្ពុជា។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះមិនត្រូវយកមកគិតសម្រាប់គណនាសំវិធានធនទេ។

ផ្អែកលើគោលការណ៍គណនេយ្យបង្គរ (Accrual Accounting Principle) ការប្រាក់បង្គរលើហ្វាស៊ីលីធីដំណើរការ ត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត ចំណែកការប្រាក់បង្គរលើហ្វាស៊ីលីធីទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីក្រោមស្តង់ដារ ហ្វាស៊ីលីធីសង្ស័យ ឬហ្វាស៊ីលីធីបាត់បង់ ត្រូវកត់ត្រាក្នុងខ្លង់ទ្រព្យអកម្មនៃតារាងតុល្យការក្នុងគណនីការប្រាក់ព្យួរទុក។

៦- ការអនុវត្តប្លង់គណនី

ដើម្បីសម្រួលដល់ការចុះកិច្ចបញ្ជិកាគណនេយ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវអនុវត្តប្លង់គណនីឯកភាព (Uniform Chart of Accounts) ដូចគ្រឹះស្ថានធនាគារ។ ចំណែកឯគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តប្លង់គណនីឯកភាពដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

៧- ចំណាត់ថ្នាក់ និងសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី

ចំណាត់ថ្នាក់និងសំវិធានធនសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លីត្រូវបានកំណត់ដូចខាងក្រោម៖

ប្រភេទហ្វាស៊ីលីធី (រយៈពេលខ្លី)	ចំនួនថ្ងៃហួសកាលកំណត់សង	សំវិធានធនតាមបទប្បញ្ញត្តិ
ធម្មតា	តិចជាង ឬស្មើ ១៤ ថ្ងៃ	១%
ឃ្លាំមើល	១៥ ដល់ ៣០ ថ្ងៃ	៣%
ក្រោមស្តង់ដារ	៣១ ដល់ ៦០ ថ្ងៃ	២០%
សង្ស័យ	៦១ ដល់ ៩០ ថ្ងៃ	៥០%
បាត់បង់	ចាប់ពី ៩១ ថ្ងៃឡើងទៅ	១០០%

៨- ការធ្វើសំវិធានធនសម្រាប់ខ្លង់ក្រៅតារាងតុល្យការ

ក. ឥណទានវិបារូបន៍

ទំហំសំវិធានធនចំពោះឥណទានវិបារូបន៍នឹងត្រូវគណនាដោយផ្អែកលើ សមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់ ឬកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើសកម្រិតអនុម័ត អាស្រ័យលើគោលនយោបាយឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។ ឧទាហរណ៍ ក្នុងករណីគោលនយោបាយ ឬកិច្ចសន្យារបស់គ្រឹះស្ថានចែងថានៅពេលឥណទានវិបារូបន៍ត្រូវបានចាត់ថ្នាក់ចាប់ពីចំណាត់ថ្នាក់ឃ្លាំមើល ជាស្វ័យប្រវត្តិ អ្នកខ្ចីគ្មានសិទ្ធិ

ឬមិនអាចដកយកចំណែកឥណទានដែលនៅសល់ទៅប្រើប្រាស់បាន នោះការធ្វើសំវិធានធនត្រូវផ្អែកលើសមតុល្យនៃឥណទានវិបារូបន៍ដែលបានប្រើប្រាស់។ ផ្ទុយទៅវិញ ក្នុងករណីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុគ្មានគោលនយោបាយដែលហាមឃាត់អតិថិជនដកឥណទានវិបារូបន៍យកទៅប្រើប្រាស់ដូចខាងលើទេ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនដោយផ្អែកលើកម្រិតអនុម័តឥណទានវិបារូបន៍ ឬសមតុល្យដែលបានប្រើប្រាស់លើសកម្រិតអនុម័ត។

ខ. ខ្ចប់ផ្សេងៗទៀតនៃក្រៅតារាងតុល្យការ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវធ្វើសំវិធានធនលើកម្រិតអនុម័តនៃកិច្ចសន្យាឥណទាន ឬកិច្ចសន្យាផ្សេងទៀតដែលបានចុះកិច្ចសន្យារួចហើយ ដែលគ្រឹះស្ថានមិនអាចបដិសេធបានដោយសារតែកិច្ចសន្យាទាំងនេះនឹងអាចក្លាយទៅជាកាតព្វកិច្ចទូទាត់របស់គ្រឹះស្ថាន។

ចំពោះផលិតផលហិរញ្ញប្បទានពាណិជ្ជកម្ម ដូចជាលិខិតឥណទាន ឬការធានាឥណទានដែលធានាដោយប្រាក់បញ្ញើ (Margin Deposit) សំវិធានធនត្រូវគណនាដោយផ្អែកលើកម្រិតអនុម័តដកចេញប្រាក់បញ្ញើធានាដែលមានឥណប្រតិទានលើសពីឥណប្រតិទានរបស់ផលិតផលនោះ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២០-១៣៤ ឆ.ត

ថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ជម្រាបមក
លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា
គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្មវត្ថុ ៖ សេចក្តីបញ្ជាក់បន្ថែមលើការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលរក្សានៅធនាគារជាតិនៃកម្ពុជា។

យោង ៖ ប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យបានជ្រាបថា ដើម្បីឱ្យមានសង្គតិភាពក្នុងការអនុវត្តប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ធនាគារជាតិនៃកម្ពុជាសូមបញ្ជាក់បន្ថែមថា រាល់ហ្វាស៊ីលីធីទាំងអស់ដែលរក្សានៅធនាគារជាតិនៃកម្ពុជា ត្រូវបានចាត់ទុកថាមិនមានហានិភ័យឥណទាន និងមិនរងការធ្វើសំវិធានធនទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

ឧ.ម. ទេសាភិបាល
អគ្គនាយកត្រួតពិនិត្យ
ហត្ថលេខានិងត្រា៖ **វ័ត្ត សុវណ្ណនរៈ**

ធ៧-០១៨-០៦៨ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់ទ្រនាប់ដើមទុន ដែលរួមមានដើមទុនខនស៊ើវេសិន (Capital Conservation) និងដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital) ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅ៖

- ពង្រឹងមូលដ្ឋានដើមទុនសម្រាប់បំពេញការខាតបង់នានាដែលអាចកើតឡើងពីហានិភ័យរបស់គ្រឹះស្ថាន
- បង្ការការធ្លាក់ចុះដើមទុនមិនឱ្យទាបជាងកម្រិតដើមទុនអប្បបរមា និង
- កាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុ និងវដ្តសេដ្ឋកិច្ច (Pro-cyclicality)។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប ប្រសិនបើមាន។ គ្រឹះស្ថានដែលមានកម្រិតគួបសរុបត្រូវអនុវត្តដូចគ្នានឹងការគណនាគួបសរុបក្នុងរបាយការណ៍ស្តីពី អនុបាតសាធនភាព។

ប្រការ ៤.-

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

ដើមទុនថ្នាក់ទី ១ សំដៅដល់ដើមទុនថ្នាក់ទី១ ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

ដើមទុនថ្នាក់ទី ២ សំដៅដល់ដើមទុនថ្នាក់ទី២ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

ដើមទុនសរុប សំដៅដល់ "មូលនិធិផ្ទាល់សុទ្ធ" ដូចមានចែងក្នុងប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ដើមទុនសរុបរបស់គ្រឹះស្ថានគឺជាផលបូកវាងដើមទុនថ្នាក់ទី១ និងដើមទុនថ្នាក់ទី២។

ទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ សំដៅដល់ផលបូកនៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

អនុបាតសាធនភាព សំដៅដល់ការគណនាដូចមានចែងក្នុងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

អនុបាតដើមទុនថ្នាក់ទី១ សំដៅដល់ផលធៀបរវាងដើមទុនថ្នាក់ទី១ និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

អនុបាតដើមទុនសរុប សំដៅដល់ផលធៀបរវាងដើមទុនសរុប និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

កម្រិតដើមទុនអប្បបរមា (MCR) សំដៅដល់ការតម្រូវឱ្យគ្រឹះស្ថានត្រូវរក្សាកម្រិតដើមទុនអប្បបរមាជាអចិន្ត្រៃយ៍ដូចខាងក្រោម ប្រសិនបើមិនមានការកំណត់ជាក់លាក់ដូចមានចែងក្នុងប្រការ ២០ នៃប្រកាសនេះ៖

- អនុបាតដើមទុនថ្នាក់ទី១ អប្បបរមា (MCR1) ស្មើ ៧,៥% មានន័យថា ដើមទុនថ្នាក់ទី១ ត្រូវស្មើ ឬច្រើនជាង ៧,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ
- ដើមទុនថ្នាក់ទី១ ត្រូវស្មើ ឬច្រើនជាង ៥0% នៃដើមទុនសរុប និង
- អនុបាតដើមទុនសរុបអប្បបរមា (MCRt) ស្មើ ១៥% មានន័យថាដើមទុនសរុប ត្រូវស្មើ ឬច្រើនជាង ១៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

ប្រាក់ចំណេញ សំដៅដល់ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុដែលអាចបែងចែកបានដោយត្រូវបានគណនាមុនពេលដកចេញនូវធាតុដែលមិនអាចបែងចែកផ្សេងៗ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។ ប្រាក់ចំណេញត្រូវបានគណនាក្រោយការបង់ពន្ធ ដែលត្រូវបានរាយការណ៍មុនពេលដកចេញនូវធាតុដែលអាចបែងចែកបាន។ ដូច្នេះ ផលប៉ះពាល់លើកាតព្វកិច្ចបង់ពន្ធ ត្រូវគណនាសារឡើងវិញ នៅពេលដែលមានការបែងចែកប្រាក់ចំណេញ។

ចំពូកទី ២
ទ្រនាប់ដើមទុនខនស៊ើវេសិន (Capital Conservation Buffer)

ប្រការ ៥.-

ក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា គ្រឹះស្ថានត្រូវមានទ្រនាប់ដើមទុនខនស៊ើវេសិន ដើម្បីធានាថាគ្រឹះស្ថានអាចទប់ទល់នឹងការធ្លាក់ចុះនៃដើមទុននៅពេលមានការខាតបង់។ នៅពេលទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ចុះមួយចំណែក ឬទាំងស្រុង គ្រឹះស្ថានត្រូវបំពេញឡើងវិញឱ្យបានឆាប់រហ័សតាម

តែអាចធ្វើទៅបាន។ ក្នុងករណីមិនអាចបំពេញបានភ្លាម គ្រឹះស្ថានត្រូវធ្វើជូនធនាគារជាតិនៃកម្ពុជានូវ "ផែនការគ្រប់គ្រងដើមទុន" ដោយត្រូវពន្យល់អំពីវិធីសាស្ត្រ និងកំណត់កាលបរិច្ឆេទដែលគ្រឹះស្ថានត្រូវបំពេញឡើងវិញនូវទ្រនាប់ដើមទុនខនស៊ើវេសិនដែលខ្វះនោះ។

ប្រការ ៦.-

ទ្រនាប់ដើមទុនខនស៊ើវេសិន ត្រូវបង្កើនទៅក្នុងដើមទុនថ្នាក់ទី១ ដែលមានគុណភាពខ្ពស់ ពោលគឺ ដើមទុនចុះបញ្ជី និង/ឬ ទុនបម្រុងដែលមិនអាចបែងចែកបាន។

ប្រការ ៧.-

គ្រឹះស្ថានត្រូវរក្សាកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិនបន្ថែមលើកម្រិតដើមទុនថ្នាក់ទី១ អប្បបរមា (MCR1)។ កម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន ត្រូវស្មើ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យលើកលែងតែមានការកំណត់ផ្សេងដោយធនាគារជាតិនៃកម្ពុជា។ ដូច្នេះ ផលបូកសរុបនៃអនុបាតដើមទុនថ្នាក់ទី១ (៧,៥%) និងកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន (២,៥%) មិនត្រូវតិចជាង ១០% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

ប្រការ ៨.-

ក្នុងករណីដែលគ្រឹះស្ថានមានកម្រិតអនុបាតដើមទុនថ្នាក់ទី១លើសកម្រិតកំណត់អប្បបរមា (MCR1 = ៧,៥%) គ្រឹះស្ថានអាចប្រើប្រាស់ចំនួនទឹកប្រាក់ដើមទុនថ្នាក់ទី១ដែលលើស សម្រាប់បំពេញអនុបាតដើមទុនសរុបអប្បបរមា (MCRt = ១៥%) ប៉ុន្តែមិនអាចយកមករាប់បញ្ចូលក្នុងការគណនាទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានបានទេ យោងតាមកម្រិតដើមទុនអប្បបរមា (MCR) ដែលមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។ ទម្រង់របាយការណ៍ និងការពន្យល់សម្រាប់ការគណនាកម្រិតទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ រៀងគ្នា។

ប្រការ ៩.-

ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានហាមឃាត់ នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ (MCR1 = ៧,៥%) របស់គ្រឹះស្ថាន ស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិនដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសនេះ។ ការហាមឃាត់នេះ អនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានឡើយ។

ប្រការ ១០.-

ការបែងចែកដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១ត្រូវបានហាមឃាត់មានដូចជា ការបែងចែកភាគលាភ ការទិញភាគហ៊ុនត្រឡប់មកវិញ និងការទូទាត់លើប្រាក់រង្វាន់បុគ្គលិក ជាដើម។

ប្រការ ១១.-

គ្រឹះស្ថានមានកាតព្វកិច្ចរក្សាដើមទុនបម្រុងអប្បបរមាដូចបានកំណត់ក្នុងតារាង ១។

តារាង ១ បង្ហាញអំពីអនុបាតដើមទុនបម្រុងអប្បបរមាដែលគ្រឹះស្ថានត្រូវរក្សា ដើម្បីឱ្យស្របតាមអនុបាតដើមទុនថ្នាក់ទី១ តាមចតុភាគនីមួយៗ ដូចខាងក្រោម៖

- ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ០,៦២៥%
- ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ១,២៥%
- ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ១,៨៧៥%
- ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ២,៥%

តារាង ១

អនុបាតដើមទុនថ្នាក់ទី១ Tier 1 Capital ratio	**អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)** Minimum Capital Conservation ratio (expressed as percentage of earnings)
ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ≥ MCR1 (៧,៥%) ដល់ (MCR1 + ០,៦២៥%)	១០០
ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន > (MCR1 + ០,៦២៥%) ដល់ (MCR1 + ១,២៥%)	៨០
ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន > (MCR1 + ១,២៥%) ដល់ (MCR1 + ១,៨៧៥%)	៦០
ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន > (MCR1 + ១,៨៧៥%) ដល់ (MCR1 + ២,៥%)	៤០
ក្នុងកម្រិតខ្ពស់ជាងទ្រនាប់ដើមទុនខនស៊ើវេសិន > (MCR1 + ២,៥%)	០

អនុបាតដើមទុនបម្រុងអប្បបរមានៅក្នុងតារាង ១ បង្ហាញពីភាគរយនៃប្រាក់ចំណេញដែលគ្រឹះស្ថានមិនអាចបែងចែក នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ របស់គ្រឹះស្ថានស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិន។

គ្រឹះស្ថានដែលមានការខាតបង់ និងមានអនុបាតដើមទុនថ្នាក់ទី១ តិចជាង ១០% មិនអាចបែងចែកប្រាក់ចំណេញឡើយ។

សម្រាប់គោលបំណងនៃប្រកាសនេះ ការបែងចែកទាំងឡាយណា ដែលមិនធ្វើឱ្យដើមទុនថ្នាក់ទី១ អប្បបរមាថយចុះ មិនត្រូវបានហាមឃាត់ឡើយ។

ទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធ ១ បង្ហាញពីការគណនាអនុបាតដើមទុនបម្រុងអប្បបរមាដោយផ្អែកលើស្ថានភាពរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងការបន្ថែមទ្រនាប់ដើមទុន។ គ្រឹះស្ថានត្រូវរក្សាអនុបាតដើមទុនបម្រុងអប្បបរមានៅក្នុងរយៈពេលពេញមួយឆ្នាំ។ ទិន្នន័យអនុបាតដើមទុនបម្រុង

អប្បបរមានៅចុងឆ្នាំហិរញ្ញវត្ថុជាមូលដ្ឋានសម្រាប់គណនាចំណែកនៃប្រាក់ចំណេញដែលត្រូវរក្សាទុកនៅក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់។

ប្រការ ១២.-

ធនាគារជាតិនៃកម្ពុជា អាចកំណត់កាលបរិច្ឆេទឱ្យបំពេញឡើងវិញនូវទ្រនាប់ដើមទុនតាមករណីនីមួយៗ ចំពោះគ្រឹះស្ថានណាដែលមានប្រតិបត្តិការស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុន។

ប្រការ ១៣.-

ក្នុងករណីដែលគ្រឹះស្ថានមានបំណងធ្វើការបែងចែកប្រាក់ចំណេញលើសពីការកំណត់ដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ គ្រឹះស្ថានត្រូវបង្កើនដើមទុនជាមុន ឬស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដែលការអនុញ្ញាតនេះអាចធ្វើទៅបានលុះត្រាតែគ្រឹះស្ថានបានអនុវត្តវិធានការចាំបាច់នានាក្នុងការបង្កើនដើមទុនឱ្យស្មើ ឬលើសពីកម្រិតជាភាគរយនៃប្រាក់ចំណេញដែលបានហាមឃាត់ដូចមានចែងក្នុងតារាង ១។

ជំពូកទី ៣
ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer)

ប្រការ ១៤.-

ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលត្រូវបានរៀបចំឡើងដើម្បីធានាថា គ្រឹះស្ថានមានដើមទុនគ្រប់គ្រាន់សម្រាប់បំពេញការខាតបង់នានានៅពេលធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ឥណទានមានកំណើនលើសលុបដែលអាចបណ្តាលឱ្យមានហានិភ័យជាប្រព័ន្ធ។ ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ចាប់ពីកម្រិត ០% ទៅ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

ប្រការ ១៥.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានរក្សាកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលខុសៗគ្នា ដោយសារការវាយតម្លៃកំណើនឥណទានលើសលុបមានលក្ខណៈមិនដូចគ្នារវាងគ្រឹះស្ថាននីមួយៗ។

ប្រការ ១៦.-

ធនាគារជាតិនៃកម្ពុជា នឹងចេញសារាចរណែនាំដោយឡែក ដើម្បីកំណត់ ឬកែសម្រួលកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល។

ប្រការ ១៧.-

ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលត្រូវបានកំណត់ដើម្បីដាក់បន្ថែមលើទ្រនាប់ដើមទុនខនសើវេសិន។ សមាសធាតុនិងវិធីសាស្ត្រក្នុងការបំពេញ ឬបំពេញឡើងវិញនូវទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ត្រូវអនុវត្តដូចគ្នានឹងប្រការ ៥ និងប្រការ ៦ ខាងលើ។

ការហាមឃាត់ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានអនុវត្តដូចក្នុងប្រការ ៩ និងប្រការ ១០ ខាងលើនៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ របស់គ្រឹះស្ថានស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនសរុបដូចមានកំណត់ក្នុងតារាង ២ ខាងក្រោម។

តារាង ២ បង្ហាញអំពីអនុបាតដើមទុនបម្រុងអប្បបរមាដែលគ្រឹះស្ថានត្រូវរក្សា ដើម្បីឱ្យស្របតាមអនុបាតដើមទុនថ្នាក់ទី១ តាមចតុភាគនីមួយៗ។

អញ្ញត្តិ **y** គឺជាកម្រិតទ្រនាប់ដើមទុនបន្ថែមទៅលើអនុបាតដើមទុនថ្នាក់ទី១ ដែល y = (២,៥% + x)/៤ ក្នុងនោះ ២,៥% ជាទ្រនាប់ដើមទុនខនស៊ើវេសិន និងអញ្ញត្តិ **X** ជាទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលដែលនឹងត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជាស្របតាមប្រការ ១៦ ខាងលើ។

តារាង ២

អនុបាតដើមទុនថ្នាក់ទី ១ Tier 1 Capital ratio	**អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)** Minimum Capital Conservation ratio (expressed as percentage of earnings)
ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុន ≥ MCR1 (៧,៥%) ដល់ (MCR1 + y)	១០០
ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុន > (MCR1 + y) ដល់ (MCR1 + 2y)	៨០
ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុន > (MCR1 + 2y) ដល់ (MCR1 + 3y)	៦០
ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុន > (MCR1 + 3y) ដល់ (MCR1 + 4y)	៤០
ក្នុងកម្រិតខ្ពស់ជាងទ្រនាប់ដើមទុន > (MCR1 + 4y)	០

ការពន្យល់អំពីការគណនាកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣។

ជំពូកទី ៤
អន្តរប្បញ្ញត្តិ

ប្រការ ១៨.-

ប្រកាសនេះ បំពេញបន្ថែមប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

ប្រការ ១៩.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវអនុវត្តឱ្យបានពេញលេញតាម ប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្នាល់សុទ្ធរបស់ធនាគារ និងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

ប្រការ ២០.-

ដោយឡែក គ្រឹះស្ថានដែលធនាគារជាតិនៃកម្ពុជាតម្រូវឱ្យរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមា ត្រូវអនុវត្តបញ្ញត្តិដូចខាងក្រោម៖

- គ្រឹះស្ថានដែលមានកាតព្វកិច្ចបង្កើនអនុបាតសាធនភាព កម្រិតដើមទុនអប្បបរមាសម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ជាកម្រិតដើមទុនអប្បបរមា ១៥% ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បូកនឹងកាតព្វកិច្ចដើមទុនដែលបានតម្រូវឱ្យបង្កើនបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត។
- ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលផ្សេងៗគ្នាចំពោះគ្រឹះស្ថាន ដែលទ្រនាប់ដើមទុនទាំងពីរនេះសរុបមិនលើសពីកម្រិត ២,៥% លើកម្រិតដើមទុនអប្បបរមាដែលបានបន្ថែមរួចហើយ និងមិនតិចជាងកម្រិតដើមទុនអប្បបរមាដែលបានចែងក្នុងប្រការ ៧ និងប្រការ ១៤ នៃប្រកាសនេះ។
- គ្រឹះស្ថានដែលត្រូវរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមានឹងត្រូវអនុវត្តតាមការកំណត់ដោយឡែករបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ២១.-

គ្រឹះស្ថានត្រូវរាយការណ៍ជាប្រចាំខែអំពីស្ថានភាពនៃទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ទៅតាមទម្រង់របាយការណ៍ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១។

គ្រឹះស្ថានត្រូវបំពេញរបាយការណ៍ក្នុងឧបសម្ព័ន្ធ ១ រួមមាន ដើមទុនថ្នាក់ទី១ ដើមទុនថ្នាក់ទី២ និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ដែលមានតួលេខដូចគ្នាទៅនឹងតួលេខក្នុងរបាយការណ៍ស្តីពី អនុបាតសាធនភាព និងការគណនាមូលនិធិផ្នាល់សុទ្ធ។

ប្រការ ២២.-

គ្រឹះស្ថានត្រូវអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធនឹងទ្រនាប់ដើមទុនខនស៊ើវេសិនយ៉ាងតិចឱ្យបាន ៥០% នៃទ្រនាប់ដើមទុនដែលត្រូវបន្ថែម ឱ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ និងត្រូវបំពេញឱ្យបានពេញលេញមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ ២។

ចំពោះការអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធនឹងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល គ្រឹះស្ថានត្រូវអនុវត្តតាមការកំណត់ដែលមានចែងក្នុងសារាចរណែនាំដោយឡែក។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

ប្រការ ២៣.-

គ្រឹះស្ថានណាដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២៤-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បត៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ ១

របាយការណ៍ស្តីពី តម្រូវការទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល
និងអនុបាតដើមទុនបម្រុងអប្បបរមារបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

Report on the need in capital conservation buffer and Countercyclical buffer
and minimum capital conservation ratio
in Banks and Microfinance Deposit Taking Institutions

ឈ្មោះគ្រឹះស្ថាន ***Name of the institutions:***	
កាលបរិច្ឆេទរបាយការណ៍ ***Reporting date:***	

បញ្ញត្តិជាក់លាក់សម្រាប់អនុវត្តចំពោះគ្រឹះស្ថាន ***Specific rules applicable to the institution:***	*%*
អនុបាតសាធនភាពអប្បបរមា *Minimum solvency ratio =*	15
អនុបាតដើមទុនថ្នាក់ទី១ អប្បបរមា *Minimum Tier1 solvency ratio =*	7.5
ទ្រនាប់ដើមទុនខនស៊ើវេសិន *Capital conservation buffer (%) =*	2.5
ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល *countercyclical buffer (%) =*	0

សូមបំពេញតួរលេខនៅក្នុងប្រអប់ពណ៌សគិតជាលានរៀល
Please enter figures in white cells in MKHR

ទ្រនាប់ដើមទុនដែលត្រូវបំពេញ Buffer to be built	ចំនួន Amount	គិតជា % នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ as % of RWA
ទ្រនាប់ដើមទុនខនស៊ើវេសិន Capital conservation buffer *(B1)*		2.50
ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល Countercyclical capital buffer *(B2)*		0.00
ទ្រនាប់ដើមទុនសរុប Total capital buffer *(B3)*	0.00	2.50
ដើមទុនថ្នាក់ទី១ Tier 1 Capital *(A1)*		#DIV/0!
ដើមទុនថ្នាក់ទី២ Tier 2 Capital *(A2)*		#DIV/0!
ដើមទុនសរុប(មូលនិធិផ្គាល់សុទ្ធ) Total Capital (Net Worth) *(A3)*	0.00	**#DIV/0!**
ទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ Risk Weighted Assets - RWA *(A4)*		
ដើមទុនថ្នាក់ទី១ ដែលត្រូវការសម្រាប់អនុបាតសាធនភាព ១៥% Tier 1 capital needed for Minimum Solvency ratio *(A5)*	**#DIV/0!**	**#DIV/0!**
ដើមទុនថ្នាក់ទី១ ដែលនៅសល់សម្រាប់ទ្រនាប់ដើមទុន Available Tier 1 Capital for Capital buffers *(A6)*	#DIV/0!	#DIV/0!
តម្រូវការដើមទុនថ្នាក់ទី១ ដែលត្រូវបំពេញបន្ថែម **Additional Tier 1 Capital buffer to be built up** *(A7)*	**#DIV/0!**	**#DIV/0!**

អនុបាតដើមទុនថ្នាក់ទី១អប្បបរមា + ដើមទុនថ្នាក់ទី១នៅសល់ សម្រាប់បំពេញទ្រនាប់ដើមទុនMinimum Tier 1 capital ratio + available Tier 1 capital for capital buffer	**#DIV/0!**
អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ) **Minimum Capital Conservation ratio (expressed as percentage of earnings)**	**#DIV/0!**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

អគ្គនាយក General Manager/CEO	អ្នកត្រួតពិនិត្យ Verified By	អ្នករៀបចំ Prepared by

ឧបសម្ព័ន្ធ ២

ឧបសម្ព័ន្ធ ២ បង្ហាញពីសេចក្តីពន្យល់ខ្លឹមសារប្រការ ៧ ប្រការ ៨ ប្រការ ៩ ប្រការ ១១ និង ប្រការ ១៩។

តារាង ១ នឹងបង្ហាញពីការតម្រូវឱ្យគ្រឹះស្ថានរក្សាទុកប្រាក់ចំណេញនៅពេលទ្រនាប់ដើមទុន ធ្លាក់ក្នុងចតុភាគណាមួយ ទៅតាមឆ្នាំដូចបានកំណត់ក្នុងប្រការ ១៩ ដូចខាងក្រោម៖

តារាង ១.១ ៖ អនុបាតដើមទុនបម្រុងអប្បបរមា អនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩

អនុបាតដើមទុនថ្នាក់ទី ១ Tier 1 Capital ratio	**អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)** Minimum Capital Conservation ratio (expressed as percentage of earnings)
≥ ៧,៥% ដល់ ៧,៨១៣%	១០០
> ៧,៨១៣% ដល់ ៨,១២៥%	៨០
> ៨,១២៥% ដល់ ៨,៤៣៨%	៦០
> ៨,៤៣៨% ដល់ ៨,៧៥០%	៤០
> ៨,៧៥០%	០

តារាង ១.២ ៖ អនុបាតដើមទុនបម្រុងអប្បបរមា អនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០

អនុបាតដើមទុនថ្នាក់ទី ១ Tier 1 Capital ratio	**អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)** Minimum Capital Conservation ratio (expressed as percentage of earnings)
≥ ៧,៥% ដល់ ៨,១២៥%	១០០
> ៨,១២៥% ដល់ ៨,៧៥%	៨០
> ៨,៧៥% ដល់ ៩,៣៧៥%	៦០
> ៩,៣៧៥% ដល់ ១០%	៤០
> ១០%	០

ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ គ្រឹះស្ថានត្រូវមានកាតព្វកិច្ចរក្សាអនុបាតដើមទុនថ្នាក់ទី១ យ៉ាងហោចណាស់ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។ អនុបាតដើមទុនថ្នាក់ទី១ ដែលលើស ប៉ុន្តែត្រូវប្រើប្រាស់សម្រាប់បំពេញអនុបាតដើមទុនសរុបអប្បបរមា (១៥%) មិនអាចប្រើប្រាស់សម្រាប់ការគណនាទ្រនាប់ដើមទុនខនស៊ើវេសិននោះទេ។ ឧទាហរណ៍៖

ករណីទី១

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ និងអនុបាតដើមទុនថ្នាក់ទី២ មាន ៨% ស្មើគ្នា។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៨% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ០,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ០,៥% = ៨%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១០០%។

ករណីទី២

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៧% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ៩,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៧,៥%។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៩,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ២% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ០,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៤ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ២% = ៩,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៥០%។

ករណីទី៣

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦,៥% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១១,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៥%។ គ្រឹះស្ថានបានប្រើប្រាស់ ១០% ក្នុងចំណោម ១១,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ១,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ១% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៣ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ១,៥% = ៩%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៦០%។

ករណីទី៤

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៥% ដែលសុទ្ធតែជាអនុបាតដើមទុនថ្នាក់ទី១។ គ្រឹះស្ថានត្រូវបានចាត់ទុកថា ពុំមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ០% = ៧,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១០០%។

ករណីទី៥

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៨% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១២% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៦%។ គ្រឹះស្ថានបានប្រើប្រាស់ ៩% ក្នុងចំណោម ១២% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ ចំនួន ៣% នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានមិនត្រូវការអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានអាចបែងចែកប្រាក់ចំណេញបានទាំងស្រុង។

ឧបសម្ព័ន្ធ ៣

ឧបសម្ព័ន្ធ ៣ ពន្យល់ពីខ្លឹមសារប្រការ ១៧។ ឧទាហរណ៍ នៅពេលធនាគារជាតិនៃកម្ពុជាចេញសារាចរណែនាំដោយឡែកក្នុងការកំណត់ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ២% កម្រិតកំណត់ទ្រនាប់ដើមទុនមានចំនួន ៤,៥% (២,៥% សម្រាប់ទ្រនាប់ដើមទុនខនស៊ើវេសិន + ២% សម្រាប់ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល) ដូច្នេះ y = (២,៥% + ២%)/៤ = ១,១២៥%។ តារាង ២ នឹងបង្ហាញដូចខាងក្រោម៖

អនុបាតដើមទុនថ្នាក់ទី ១ Tier 1 Capital ratio	**អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)** Minimum Capital Conservation ratio (expressed as percentage of earnings)
≥ ៧,៥% ដល់ ៨,៦២៥%	១០០
> ៨,៦២៥% ដល់ ៩,៧៥%	៨០
> ៩,៧៥% ដល់ ១០,៨៧៥%	៦០
> ១០,៨៧៥% ដល់ ១២%	៤០
> ១២%	០

ធ៧-០១៨-០០១ ស.ក.ណ

ថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨

សារាចរណែនាំ
ស្តីពី
ការអនុវត្តប្រកាសស្តីពី
ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ប្រកាសលេខ ធ៧-០១៨-០៦៨ ប្រ.ក ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ និងដោយពិនិត្យឃើញថាប្រព័ន្ធធនាគារកម្ពុជានាពេលបច្ចុប្បន្ននេះមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងកំណើនឥណទានសមស្របទៅតាមបរិបទនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាកំណត់អនុបាតនៃទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital buffer) ចំនួន ០% រហូតដល់មានការជូនដំណឹងជាថ្មី។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០២០-០០២ ស.រ.ណ.ន

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

សារាចរណែនាំបន្ថែម
ស្តីពី
ការអនុវត្តប្រកាសស្តីពី
ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងតាមប្រកាសលេខ ធ៧-០១៨-០៦៨ ប្រ.ក ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាសូមណែនាំអំពីការអនុវត្តខ្លឹមសារនៃប្រកាសនេះ ដូចខាងក្រោម៖

១. ការពន្យល់បន្ថែមអំពីនិយមន័យនៃប្រាក់ចំណេញ

ប្រការ ៤.-

*[...] **ប្រាក់ចំណេញ** សំដៅដល់ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុដែលអាចបែងចែកបានដោយត្រូវបានគណនាមុនពេលដកចេញនូវធាតុដែលមិនអាចបែងចែកផ្សេងៗ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។ ប្រាក់ចំណេញត្រូវបានគណនាក្រោយការបង់ពន្ធ ដែលត្រូវបានរាយការណ៍មុនពេលដកចេញនូវធាតុដែលអាចបែងចែកបាន។ ដូច្នេះ ផលប៉ះពាល់លើកាតព្វកិច្ចបង់ពន្ធ ត្រូវគណនាសារឡើងវិញ នៅពេលដែលមានការបែងចែកប្រាក់ចំណេញ។*

ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ សំដៅដល់ប្រាក់ចំណេញសុទ្ធដែលរាយការណ៍ក្នុងរបាយការណ៍ប្រចាំខែស្តីពី ចំណូល និងចំណាយនៅក្នុងខែធ្នូ (ខ្លង "ចំណេញ/ខាត សុទ្ធក្នុងគ្រា") ប៉ុន្តែនៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានធ្វើសវនកម្មរួច គ្រឹះស្ថានត្រូវប្រើប្រាស់តួលេខប្រាក់ចំណេញសុទ្ធក្នុងរបាយការណ៍នោះវិញ។ ប្រាក់ចំណេញដែលអាចបែងចែកបានត្រូវគណនាបន្ទាប់ពីបង់ពន្ធរួច ដោយមិនគិតពីផលប៉ះពាល់នៃពន្ធទៅលើខ្លង់ដែលអាចបែងចែកបាន។

២. ការពន្យល់បន្ថែមលើប្រការ ៥

ប្រការ ៥.-

ក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា គ្រឹះស្ថានត្រូវមានទ្រនាប់ដើមទុនខនស៊ើវេសិន ដើម្បីធានាថាគ្រឹះស្ថានអាចទប់ទល់នឹងការធ្លាក់ចុះនៃដើមទុននៅពេលមានការខាតបង់។ នៅពេលទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ចុះមួយចំណែក ឬទាំងស្រុង គ្រឹះស្ថានត្រូវបំពេញឡើងវិញឱ្យបានឆាប់

រហ័សតាមតែអាចធ្វើទៅបាន។ ក្នុងករណីមិនអាចបំពេញបានភ្លាម គ្រឹះស្ថានត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវ "ផែនការគ្រប់គ្រងដើមទុន" ដោយត្រូវពន្យល់អំពីវិធីសាស្ត្រ និងកំណត់កាលបរិច្ឆេទដែលគ្រឹះស្ថានត្រូវបំពេញឡើងវិញនូវទ្រនាប់ដើមទុនខនស៊ើវេសិនដែលខ្វះនោះ។

ដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសស្តីពី ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អនុបាតដើមទុនខនស៊ើវេសិនអប្បបរមានៅចុងឆ្នាំហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការហាមឃាត់ការបែងចែកប្រាក់ចំណេញនៅឆ្នាំបន្ទាប់។ ក្នុងករណីដែលគ្រឹះស្ថានមិនអាចបំពេញទ្រនាប់ដើមទុនខនស៊ើវេសិនភ្លាមៗដោយប្រើប្រាស់ប្រាក់ចំណេញ គ្រឹះស្ថាននោះត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវផែនការគ្រប់គ្រងដើមទុន ដើម្បីឱ្យអនុបាតនោះគ្រប់គ្រាន់វិញឱ្យបានឆាប់រហ័ស។ ក្នុងស្ថានភាពធម្មតា គ្រឹះស្ថានមិនត្រូវកម្រិតទ្រនាប់ដើមទុននេះតែក្នុងចន្លោះណាមួយដើម្បីប្រកួតប្រជែងជាមួយគ្រឹះស្ថានផ្សេងទៀត និងដើម្បីទទួលបានចំណែកទីផ្សារធំនោះទេ។

ឧទាហរណ៍ នៅក្នុងខែមករា ឆ្នាំ២០១៩ គ្រឹះស្ថានមួយមានដើមទុនថ្នាក់ទី១ សរុប ៨% (ដើមទុនថ្នាក់ទី១ ស្មើ ៧,៥% និងទ្រនាប់ដើមទុន ០,៥%)។ ក្នុងករណីនេះ បើយោងតាមតារាង ១.១ ក្នុងឧបសម្ព័ន្ធ២ គ្រឹះស្ថានត្រូវរក្សា ៨០% នៃប្រាក់ចំណេញក្នុងឆ្នាំ២០១៨ ដើម្បីឱ្យស្របតាមការតម្រូវនៃទ្រនាប់ដើមទុន។ គ្រឹះស្ថានត្រូវតែរក្សាទុក ៨០% នៃប្រាក់ចំណេញឆ្នាំ២០១៨ ជាចំណេញរក្សាទុក និង ២០% អាចបែងចែកភាគលាភ ឬប្រាក់រង្វាន់បុគ្គលិកជាដើម។

នៅពេលដែលគ្រឹះស្ថានត្រូវអនុវត្តតាមកម្រិតអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% ក្នុងករណីគ្រឹះស្ថានមិនអាចបំពេញបាន គ្រឹះស្ថានត្រូវផ្ញើផែនការគ្រប់គ្រងដើមទុនដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ទៅធនាគារជាតិនៃកម្ពុជាភ្លាម ស្របតាមប្រការ ៥ នៃប្រកាស។

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវក្នុងការកំណត់អាទិភាព និងវាយតម្លៃជាបរិមាណច្បាស់លាស់ដែលប៉ះពាល់ដល់ដើមទុន ដែលធ្វើឱ្យគ្រឹះស្ថានមិនអាចបំពេញដើមទុនរបស់ខ្លួនបានទាន់ពេល ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍ដែលអាចនឹងកើតឡើងដោយមិនបានគិតទុកជាមុន។ ការរៀបចំផែនការគ្រប់គ្រងដើមទុន ក៏ត្រូវពិចារណាផងដែរនូវការកាត់បន្ថយ ឬការផ្អាកការបែងចែកភាគលាភ ការដាក់ដើមទុនថ្មីបន្ថែម ឬការបន្ថយទំហំតារាងតុល្យការជាដើម។ ធនាគារជាតិនៃកម្ពុជានឹងវាយតម្លៃអំពីភាពសមស្របនៃផែនការគ្រប់គ្រងដើមទុន។

៣. ការពន្យល់បន្ថែមលើប្រការ ៨

ប្រការ ៨.-

ក្នុងករណីដែលគ្រឹះស្ថានមានកម្រិតអនុបាតដើមទុនថ្នាក់ទី១ លើសកម្រិតកំណត់អប្បបរមា (MCR1 = ៧,៥%) គ្រឹះស្ថានអាចប្រើប្រាស់ចំនួនទឹកប្រាក់ដើមទុនថ្នាក់ទី១ដែលលើស សម្រាប់បំពេញអនុបាតដើមទុនសរុបអប្បបរមា (MCRt = ១៥%) ប៉ុន្តែមិនអាចយកមករាប់បញ្ចូលក្នុងការគណនាទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានបានទេ យោងតាមកម្រិតដើមទុនអប្បបរមា (MCR) ដែលមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។ ទម្រង់របាយការណ៍ និងការពន្យល់សម្រាប់ការគណនាកម្រិតទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ រៀងគ្នា។

អនុបាតដើមទុនថ្នាក់ទី១ ដែលលើស ៧,៥% ត្រូវយកទៅបំពេញតាមការតម្រូវនៃអនុបាតដើមទុនសរុបអប្បបរមា (អនុបាតសាធនភាព) ជាមុន ទើបយកផ្នែកដែលនៅសល់ពីការបំពេញទៅធ្វើជាទ្រនាប់ដើមទុនខនស៊ើវេសិន។

ករណីទី១

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ និងអនុបាតដើមទុនថ្នាក់ទី២ មាន ៨% ស្មើគ្នា។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៨% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ 0,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២% បន្ថែមទៀត ដើម្បីបំពេញតម្រូវការ ១0% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + 0,៥% = ៨%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១00%។

ករណីទី២

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៧% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ៩,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៧,៥%។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៩,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ២% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន 0,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១0% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៤ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ២% = ៩,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៤0%។

ករណីទី៣

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦,៥% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១១,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៥%។ គ្រឹះស្ថានបានប្រើប្រាស់ ១0% ក្នុងចំណោម ១១,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១នៅសល់ ១,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ១% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១0% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៣ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ១,៥% = ៩%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៦០%។

ក្នុងករណីនេះ ដើមទុនថ្នាក់ទី១ដែលលើសគឺ ៤% (១១,៥% - ៧,៥%) ប៉ុន្តែចំណែកដែលលើសនោះ មិនអាចយកទៅប្រើជាទ្រនាប់ដើមទុនខនស៊ើវេសិនទេ ព្រោះវិធាននៃកម្រិតដើមទុនអប្បបរមាគឺ ១៥%។ គ្រឹះស្ថានត្រូវប្រើ ១០% នៃ ១១,៥% ទៅបំពេញដើមទុនអប្បបរមាសិន (ដើមទុនថ្នាក់ទី១ ១០% + ដើមទុនថ្នាក់ទី២ ៥%)។ ដូច្នេះ គ្រឹះស្ថានទៅសល់តែដើមទុន ១,៥% ប៉ុណ្ណោះ ដែលអាចយកទៅប្រើជាផ្នែកមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិន។ គ្រឹះស្ថានត្រូវបន្ថែមដើមទុនថ្នាក់ទី១ ១% ទៀតដើម្បីបង្គ្រប់កម្រិតអប្បបរមា ១០% (៧,៥% + ២,៥%)។

ករណីទី៤

គ្រឹះស្ថានមួយមានអនុបាតសាធនភាព ១៥% ដែលសុទ្ធតែជាអនុបាតដើមទុនថ្នាក់ទី១។ គ្រឹះស្ថានត្រូវបានចាត់ទុកថា ពុំមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ០% = ៧,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១០០%។

ករណីទី៥

គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៨% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១២% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៦%។ គ្រឹះស្ថានបានប្រើប្រាស់ ៩% ក្នុងចំណោម ១២% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ ចំនួន ៣% នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានមិនត្រូវការអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

យោងតាមតារាង១.២ គ្រឹះស្ថានអាចបែងចែកប្រាក់ចំណេញបានទាំងស្រុង។

ករណីទី៦

គ្រឹះស្ថានមានអនុបាតសាធនភាពចំនួន ១៦% ដែលជាដើមទុនថ្នាក់ទី១ ទាំងអស់ គ្រឹះស្ថានអាចប្រើ១៥% ជាដើមទុនអប្បបរមា ដូច្នេះ មានន័យថា គ្រឹះស្ថានកំពុងអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិន ១% រួចហើយ ប៉ុន្តែ គ្រឹះស្ថានត្រូវការបន្ថែមទ្រនាប់ដើមទុននេះ ១,៥% ទៀត។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី២ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ១% = ៨,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៨០%។

៤. ការពន្យល់បន្ថែមលើប្រការ ៩

ប្រការ ៩.-

ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានហាមឃាត់ នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ (MCR1=៧,៥%) របស់គ្រឹះស្ថាន ស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិនដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសនេះ។ ការហាមឃាត់នេះ អនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានឡើយ។

គ្រឹះស្ថានត្រូវរក្សាអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនលើសពីកម្រិតដើមទុនថ្នាក់ទី១អប្បបរមា (៧,៥%)។ ក្នុងអំឡុងពេលធម្មតា គ្រឹះស្ថានត្រូវរក្សាកម្រិតដើមទុនថ្នាក់ទី១អប្បបរមា ១០%។ ក្នុងករណីអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ក្នុងចន្លោះពី ០% ទៅ ២,៥% នោះការបែងចែកភាគលាភនឹងត្រូវបានហាមឃាត់។ ការហាមឃាត់នេះគឺអនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ ដូចជា ភាគលាភ តែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានទេ។

ទោះបីជាទ្រនាប់ដើមទុនមានគោលដៅកាត់បន្ថយភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុដើម្បីចៀសវាងការមិនគោរពតាមកម្រិតកំណត់ដើមទុនអប្បបរមា ទ្រនាប់ដើមទុនមិនត្រូវបានចាត់ទុកថាជាដើមទុនអប្បបរមាថ្មីទេ។ ប្រាក់ចំណេញរក្សាទុក ត្រូវប្រើប្រាស់ជាជម្រើសទីមួយក្នុងការបំពេញទ្រនាប់ដើមទុនឡើងវិញ។

៥. ការពន្យល់បន្ថែមលើប្រការ ១០

ប្រការ ១០.-

ការបែងចែកដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១ ត្រូវបានហាមឃាត់មានដូចជា ការបែងចែកភាគលាភ ការទិញភាគហ៊ុនត្រឡប់មកវិញ និងការទូទាត់លើប្រាក់រង្វាន់បុគ្គលិក ជាដើម។

គ្រឹះស្ថានត្រូវមានគោលនយោបាយអភិបាលកិច្ចច្បាស់លាស់ពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ដល់គណៈគ្រប់គ្រងនិងបុគ្គលិក និងត្រូវមានផែនការដើមទុន មុនពេលបែងចែកប្រាក់ចំណេញដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១។

ផែនការដើមទុនត្រូវធានាថា ការបែងចែកប្រាក់រង្វាន់បុគ្គលិកមិនត្រូវធ្វើឡើង មុនការគណនាអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនទេ។ រាល់គម្រោងផ្តល់ប្រាក់រង្វាន់បុគ្គលិកត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ ដោយចៀសវាងការបែងចែកប្រាក់ចំណេញរក្សាទុកដែលត្រូវទុកសម្រាប់បំពេញបង្គ្រប់ ឬបង្កើនទ្រនាប់ដើមទុន។

អនុបាតដើមទុនថ្នាក់ទី១នៅចុងឆ្នាំហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់គណនាការបែងចែកប្រាក់ចំណេញនៅឆ្នាំហិរញ្ញវត្ថុបន្ទាប់។ ជាធម្មតា ប្រាក់រង្វាន់បុគ្គលិក ត្រូវបានកំណត់ទុកនៅឆ្នាំហិរញ្ញវត្ថុមុន (t-1) ហើយត្រូវបានបែងចែកនៅក្នុងត្រីមាសទី១ នៃឆ្នាំហិរញ្ញវត្ថុ

បច្ចុប្បន្ន (t)។ ដើម្បីគណនាការបែងចែកប្រាក់ចំណេញឱ្យបានត្រឹមត្រូវ ប្រាក់រង្វាន់បុគ្គលិកដែលត្រូវបានកំណត់ទុកមុនត្រូវបូកបញ្ចូលទៅក្នុងប្រាក់ចំណេញសុទ្ធ ដើម្បីរក្សាកម្រិតអនុបាតដើមទុនថ្នាក់ទី១ និងអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនអប្បបរមា។

៦. ការពន្យល់បន្ថែមលើប្រការ ២០

ប្រការ ២០.-

ដោយឡែក គ្រឹះស្ថានដែលធនាគារជាតិនៃកម្ពុជាតម្រូវឱ្យរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមា ត្រូវអនុវត្តបញ្ញត្តិដូចខាងក្រោម៖

- *គ្រឹះស្ថានដែលមានកាតព្វកិច្ចបង្កើនអនុបាតសាធនភាព កម្រិតដើមទុនអប្បបរមាសម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ជាកម្រិតដើមទុនអប្បបរមា ១៥% ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បូកនឹងកាតព្វកិច្ចដើមទុនដែលបានតម្រូវឱ្យបង្កើនបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត។*
- *ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលផ្សេងៗគ្នាចំពោះគ្រឹះស្ថាន ដែលទ្រនាប់ដើមទុនទាំងពីរនេះសរុបមិនលើសពីកម្រិត ២,៥% លើកម្រិតដើមទុនអប្បបរមាដែលបានបន្ថែមរួចហើយ និងមិនតិចជាងកម្រិតដើមទុនអប្បបរមាដែលបានចែងក្នុងប្រការ ៧ និងប្រការ ១៤ នៃប្រកាសនេះ។*
- *គ្រឹះស្ថានដែលត្រូវរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមានឹងត្រូវអនុវត្តតាមការកំណត់ដោយឡែករបស់ធនាគារជាតិនៃកម្ពុជា។*

គ្រឹះស្ថានដែលតម្រូវឱ្យបង្កើនអនុបាតសាធនភាពបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម៖

- <u>គោលការណ៍ទី១៖</u> គ្រឹះស្ថាននីមួយៗត្រូវអនុវត្តស្របតាមកម្រិតនៃទ្រនាប់ដើមទុន ពោលគឺទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល មិនលើសពី ២,៥%។ សម្រាប់ការគណនាអនុបាតខនស៊ើវេសិន គ្រឹះស្ថានត្រូវអនុវត្តតាមប្រការ ៤ ប៉ុន្តែ កម្រិតដើមទុនអប្បបរមា (MCR) និងអនុបាតដើមទុនថ្នាក់ទី១ អប្បបរមា (MCR1) ត្រូវស្របតាមប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក។
- <u>គោលការណ៍ទី២៖</u> យោងតាមប្រការ ២០ និងប្រការ ១៥ ប្រសិនបើអនុបាតទ្រនាប់ដើមទុននិងអនុបាតដើមទុនបន្ថែមមានលក្ខណៈតឹងពេក ធនាគារជាតិនៃកម្ពុជាអាចផ្លាស់ប្តូរកម្រិតអនុបាតខោនធើស៊ីឃ្លីខលដោយផ្អែកលើកម្រិតហានិភ័យជាប្រព័ន្ធរបស់គ្រឹះស្ថាន។

ឧទាហរណ៍៖ ទ្រនាប់ដើមទុនខនស៊ើវេសិនស្មើ ២,៥% ហើយទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលស្មើ ២%។ សម្រាប់ការគណនាអនុបាតខនស៊ើវេសិនអប្បបរមា សូមមើលតារាងក្នុងឧបសម្ព័ន្ធ ៣ និងឧទាហរណ៍ ដូចខាងក្រោម៖

<u>ឧទាហរណ៍ទី១</u>៖ ប្រសិនបើគ្រឹះស្ថាន XYZ ត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនអនុបាតសាធនភាព ៣% បន្ថែមលើដើមទុនអប្បបរមា (១៥%) គ្រឹះស្ថានត្រូវអនុវត្តតាមការកំណត់អនុបាតទ្រនាប់ដើមទុនទាំងពីរជាមួយនឹងដើមទុនអប្បបរមាថ្មី។ ក្នុងករណីនេះ ដើមទុនអប្បបរមាស្មើ ១៨% (១៥% + ៣%) ហើយដើមទុនថ្នាក់ទី១ ត្រូវធំជាងឬស្មើ ៥០% នៃដើមទុនសរុប មានន័យថាដើមទុនថ្នាក់ទី១ ថ្មីធំជាងឬស្មើ ៩%។ ដូច្នេះ គ្រឹះស្ថានមិនមានដើមទុននៅសល់សម្រាប់ទ្រនាប់ដើមទុនទេ (ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល) ក្នុងករណីដែលអនុបាតសាធនភាពរបស់គ្រឹះស្ថាន XYZ ស្មើ ១៨% និងដើមទុនថ្នាក់ទី១ ស្មើ ៩%។

<u>ឧទាហរណ៍ទី២</u>៖ ធនាគារជាតិនៃកម្ពុជាបានកំណត់ឱ្យគ្រឹះស្ថាន XYZ មានកម្រិតដើមទុនអប្បបរមា ១៦% ផ្អែកលើការវាយតម្លៃហានិភ័យ។ ដូច្នេះ គ្រឹះស្ថានត្រូវមានដើមទុនសរុប ២០,៥% ក្នុងនោះ កម្រិតដើមទុនអប្បបរមា ១៦% ទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ២% (យោងឧបសម្ព័ន្ធ៣ នៃប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)។

ជាក់ស្តែង គ្រឹះស្ថានមានអនុបាតសាធនភាព ១៨% ក្នុងនោះដើមទុនថ្នាក់ទី១ ចំនួន ១០%។ ដូច្នេះ គ្រឹះស្ថាន XYZ មានទ្រនាប់ដើមទុនខនស៊ើវេសិន ២% រួចជាស្រេច។ ដូច្នេះ គ្រឹះស្ថាន XYZ ត្រូវបង្កើតទ្រនាប់ដើមទុនខនស៊ើវេសិនបន្ថែម ០,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ២% ដើម្បីមានដើមទុនសរុប ២០,៥% ។

សារាចរណែនាំបន្ថែមនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

១.២. អតិបាលកិច្ច

ធ៧-០៨-២១១ ប្រ.ក

ប្រកាស
ស្តីពី
អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងពង្រឹងអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅហៅថា "គ្រឹះស្ថាន" ដោយរៀបចំឱ្យមានរចនាសម្ព័ន្ធគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ រួមមានក្រុមប្រឹក្សាភិបាលឯករាជ្យនិងសកម្ម គណៈប្រតិបត្តិនិងគណៈកម្មការជំនាញ ដែលចាំបាច់ប្រកបដោយគុណវុឌ្ឍិ សមត្ថភាព សុចរិតភាព ដើម្បីដឹកនាំ គ្រប់គ្រងគ្រឹះស្ថានឱ្យមានប្រសិទ្ធភាព។

ប្រការ ២.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចតទៅ៖

- ក្រុមប្រឹក្សាភិបាល ជាគណៈគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការគ្រប់គ្រង និងស្ថានភាពរបស់គ្រឹះស្ថាន ក្នុងនាមភាគទុនិក ដូចជាក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលគ្រប់គ្រងដោយច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឬក្រុមប្រឹក្សាត្រួតពិនិត្យដែលមានភារកិច្ចសមមូលនៃក្រុមហ៊ុនដែលមានទម្រង់គតិយុត្តិផ្សេងគ្នា។
- គណៈប្រតិបត្តិ ជាក្រុមបុគ្គលដែលទទួលខុសត្រូវលើការគ្រប់គ្រងដោយប្រសិទ្ធភាពលើគ្រឹះស្ថាន ស្របតាមប្រការ ៦ នៃប្រកាសលេខ ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៥ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេសឥណទានជនបទ ឬ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- គណៈកម្មការសវនកម្ម ជាគណៈកម្មការជំនាញដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាព ភារកិច្ច នីតិវិធីប្រតិបត្តិ និងលក្ខខណ្ឌដែលក្នុងនោះសវនករ និងបុគ្គលដទៃទៀតរបស់គ្រឹះស្ថានត្រូវជាប់ពាក់ព័ន្ធក្នុងការងាររបស់ខ្លួន។

- គណៈកម្មការគ្រប់គ្រងហានិភ័យ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាព ភារកិច្ច និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ។
- គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាព ភារកិច្ច និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ។
- អ្នកគ្រប់គ្រងជាន់ខ្ពស់ ជាក្រុមប្រតិបត្តិគន្លឹះ ដែលមានភារកិច្ចមើលការខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃរបស់គ្រឹះស្ថាន។

ជំពូក ២
ក្រុមប្រឹក្សាភិបាលឯករាជ្យ សកម្ម និងមានគុណភាពខ្ពស់

ប្រការ ៣.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវ៖

- ឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របមួយដោយធនាគារជាតិនៃកម្ពុជា ដែលជាផ្នែកមួយនៃការផ្តល់អាជ្ញាបណ្ណ
- យល់ពីតួនាទីរបស់ខ្លួន រួមទាំងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន
- បើចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដើម្បីរក្សាបានជំនាញរួមគ្នា
- យល់ពីភារកិច្ចរបស់ខ្លួនចំពោះភាគទុនិក ចំពោះគ្រឹះស្ថាន និងចំពោះអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ
- យល់ដឹងអំពីបរិស្ថានច្បាប់និងបទប្បញ្ញត្តិទាំងមូល ដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើង
- តាមដានស្ថានភាពទីផ្សារបច្ចុប្បន្ន និងយល់ដឹងអំពីបរិស្ថានប្រកួតប្រជែងនៃអាជីវកម្មរបស់គ្រឹះស្ថាន
- មានពេលវេលា និងថាមពលដែលអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព។

ប្រការ ៤.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវសកម្មការងារ។ យ៉ាងហោចណាស់ សមាជិកក្រុមប្រឹក្សាភិបាលត្រូវ៖

- អនុម័តយុទ្ធសាស្ត្រ គោលនយោបាយហានិភ័យ និងនីតិវិធីគ្រប់គ្រងហានិភ័យទាំងនោះ
- រៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឱ្យការពិភាក្សាមានប្រសិទ្ធភាព
- ជ្រើសរើស ត្រួតពិនិត្យ ផ្លាស់ប្តូរនាយកប្រតិបត្តិសំខាន់ៗ
- សាកសួរអ្នកគ្រប់គ្រងជាន់ខ្ពស់
- រៀបចំប្រព័ន្ធរាយការណ៍មួយដែលអាចជួយឱ្យការអនុវត្តកាតព្វកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលមានលក្ខណៈយល់ដឹងបាន និងទាន់ពេល

- ជួបជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ និងសវនករផ្ទៃក្នុងឱ្យបានទៀងទាត់
- វាយតម្លៃការប្រតិបត្តិរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ឱ្យបានទៀងទាត់
- វាយតម្លៃគោលនយោបាយរបស់គ្រឹះស្ថានឱ្យបានទៀងទាត់ទៅលើការអនុវត្ត និងបញ្ហាជាសក្តានុពលដែលអាចសម្គាល់បាន
- អនុវត្តនូវការវិនិច្ឆ័យសម្រាប់ពេលអនាគត ដើម្បីសម្គាល់នូវបញ្ហាជាសក្តានុពលដែលគ្រឹះស្ថានត្រូវប្រឈម និងធានាថាសកម្មភាពកែតម្រូវសមស្របត្រូវបានអនុវត្តជាបន្ទាន់បើចាំបាច់

សមាជិកក្រុមប្រឹក្សាភិបាលនឹងត្រូវប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ សមាជិកនោះត្រូវបានដកចេញពីតំណែង ក្នុងករណីបុគ្គលនោះមិនបានចូលរួមអង្គប្រជុំក្រុមប្រឹក្សាភិបាលបីដងជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ។

ក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជាជាបន្ទាន់រាល់ការផ្លាស់ប្តូរកម្មសិទ្ធិភាគហ៊ុន និង/ឬ សិទ្ធិបោះឆ្នោតនៅក្នុងគ្រឹះស្ថាន។ កាតព្វកិច្ចជូនដំណឹងនេះមិនត្រូវធ្វើឡើងចំពោះតែការផ្លាស់ប្តូរការកាន់កាប់ដើមទុនឈានដល់ ៥% ឬ ២០% ឬ នៃសិទ្ធិបោះឆ្នោត ប៉ុន្តែការជូនដំណឹងក៏ត្រូវធ្វើឡើងចំពោះការផ្លាស់ប្តូរដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គ្រឹះស្ថាន តាមរយៈការកាន់កាប់សមាមាត្រភាគហ៊ុន ឬនៃសិទ្ធិបោះឆ្នោត។ ការជូនដំណឹងនេះជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដោយមិនគិតដល់កាតព្វកិច្ចដែលតម្រូវដោយបទប្បញ្ញត្តិផ្សេងទៀតពាក់ព័ន្ធទៅនឹងភាគហ៊ុនថ្មី ឬភាគហ៊ុនដែលបានផ្ទេរ និង/ឬ នៃសិទ្ធិបោះឆ្នោត។

ប្រការ ៥.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចេះវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ហើយត្រូវ៖

- ចៀសវាងទំនាស់ផលប្រយោជន៍
- មិនត្រូវចូលរួមធ្វើសេចក្តីសម្រេចនៅពេលមានទំនាស់ផលប្រយោជន៍
- ជំរុញសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថាន។

ប្រការ ៦.-

១- សម្រាប់ធនាគារពាណិជ្ជ លើកលែងតែសាខាធនាគារបរទេស ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកឯករាជ្យយ៉ាងតិចពីររូប។ សមាជិកឯករាជ្យត្រូវមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅ ដែលមិនសមស្រប។

២- សម្រាប់ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិច ៣ រូប ដែលក្នុងនោះមួយរូបត្រូវតែជាសមាជិកឯករាជ្យដូចបានចែងក្នុងចំណុច ១ ខាងលើ។ ប្រសិនបើគ្រឹះស្ថាននោះមានសមាជិកលើសពី ៣ រូប គ្រឹះស្ថានត្រូវធានាថាយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកត្រូវតែជាសមាជិកឯករាជ្យ។

៣- សាខាធនាគារបរទេស ត្រូវអនុវត្តគោលនយោបាយអភិបាលកិច្ចត្រឹមត្រូវ និងនីតិវិធីអនុលោមតាមគោលការណ៍ដែលបានកំណត់នៅក្នុងប្រកាសនេះ។ ភាពរឹងមាំនៃអភិបាលកិច្ចរបស់សាខាធនាគារបរទេសត្រូវសមស្របនឹងកម្រិតស្មុគស្មាញភាពនៃការគ្រប់គ្រង ដែលស្នាក់ការកណ្តាលបរទេសបានផ្តល់ឱ្យនាយកប្រតិបត្តិក្នុងស្រុក។

ប្រការ ៧.-

គ្រឹះស្ថានត្រូវបង្កើតគណៈកម្មការសវនកម្ម និងគណៈកម្មការហានិភ័យ ហើយអាចបង្កើតគណៈកម្មការជំនាញផ្សេងទៀតតាមការចាំបាច់ ឬតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៨.-

គណៈកម្មការសវនកម្មរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ និងបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកច្បាប់ និងធនាគារ។

គណៈកម្មការសវនកម្ម ត្រូវទទួលខុសត្រូវជាអប្បបរមាដោយ៖

- ធានាថាព័ត៌មានដែលបានផ្តល់ជូនសាធារណជន និងធនាគារជាតិនៃកម្ពុជា ត្រឹមត្រូវនិងអាចជឿជាក់បាន
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ ដែលបានប្រើដើម្បីរៀបចំគណនីដោយឡែក និងគណនីរួមបញ្ចូលគ្នា ប្រសិនបើមាន
- វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃថាតើប្រព័ន្ធសម្រាប់វាស់វែង តាមដាន និងត្រួតពិនិត្យហានិភ័យមានសង្គតិភាព និងផ្តល់អនុសាសន៍លើសកម្មភាពអនុវត្តបន្តនៅពេលណាដែលសមស្រប។

ប្រការ ៩.-

គណៈកម្មការហានិភ័យរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយបុគ្គលដែលមានជំនាញខាងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ។ បុគ្គលនោះត្រូវមានឯករាជ្យពីការងារគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ។

គណៈកម្មការហានិភ័យត្រូវទទួលខុសត្រូវជាអប្បបរមា លើការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

ប្រការ ១០.-

ប្រសិនបើគ្រឹះស្ថានមានគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ គណៈកម្មការនេះត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យដែលមានជំនាញផ្នែកច្បាប់ និងធនាគារ។

គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវទទួលខុសត្រូវជាអប្បបរមាដោយ៖

- ធានាថាគោលនយោបាយផ្តល់តម្លៃការ មានសង្គតិភាពទៅនឹងគោលដៅរយៈពេលវែង និងតម្លៃរួម (Corporate Value) របស់គ្រឹះស្ថាន

- ផ្តល់អនុសាសន៍លើនីតិវិធីដើម្បីជ្រើសរើស និងផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល
- ផ្តល់អនុសាសន៍ចំពោះបុគ្គលឯករាជ្យដែលនឹងក្លាយជាសមាជិកគណៈកម្មការ ដូចមានយោងក្នុងប្រកាសនេះ
- អនុម័តការតែងតាំងអ្នកគ្រប់គ្រងជាន់ខ្ពស់។

ជំពូក ៣
គោលដៅជាយុទ្ធសាស្ត្រ និងតម្លៃរួមរបស់គ្រឹះស្ថាន

ប្រការ ១១.-

ក្រុមប្រឹក្សាភិបាលត្រូវកំណត់តម្លៃរួម និងធានាថា តម្លៃរួមទាំងនោះត្រូវបានផ្សព្វផ្សាយយល់ដឹង និងទទួលយកទូទាំងគ្រឹះស្ថាន។ តម្លៃទាំងនេះត្រូវគិតពីផលប្រយោជន៍របស់ភាគទុនិក និងអ្នកផ្ញើប្រាក់ផងដែរ។

ប្រការ ១២.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយនិងនីតិវិធី ត្រូវបានបង្កើតឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រតិបត្តិតាមទាំងស្រុង ជាពិសេសទាក់ទងទៅនឹងចំណុចដូចខាងក្រោម៖

- ទំនាស់ផលប្រយោជន៍
- ការផ្តល់ឥណទានដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិត
- ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងបុត្តសម្ព័ន្ធ។

ប្រការ ១៣.-

ទំនាស់ផលប្រយោជន៍ដែលមានសក្តានុពលត្រូវតែមានការយកចិត្តទុកដាក់ជាពិសេសពីក្រុមប្រឹក្សាភិបាល៖

- នៅពេលដែលគ្រឹះស្ថានជាផ្នែកមួយនៃចង្កោមក្រុមហ៊ុន
- ទំនាស់ផលប្រយោជន៍ត្រូវតែទប់ស្កាត់ គ្រប់គ្រង និងបើកចំហ
- ត្រូវកំណត់របាំងព័ត៌មាន ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍
- ព័ត៌មានរបស់អតិថិជនត្រូវតែច្បាស់លាស់ និងត្រឹមត្រូវអំពីទំនាស់ផលប្រយោជន៍
- អ្នកត្រួតពិនិត្យត្រូវតែបានជូនដំណឹងយ៉ាងជិតដល់អំពីទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល។

ជំពូក ៤
តាពច្បាស់លាស់ស្តីពីការទទួលខុសត្រូវ

ប្រការ ១៤.-

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ និងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតវិធានច្បាស់លាស់ ដើម្បីផ្ទេរភារកិច្ចរបស់ខ្លួនទៅបុគ្គលិក។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតផងដែរនូវកាតព្វកិច្ចរាយការណ៍ច្បាស់លាស់ ក្នុងគោលបំណងគាំទ្រដល់ការតាមដានការប្រតិបត្តិតាមវិធានដែលត្រូវបានបង្កើតឡើងខាងលើប្រកបដោយប្រសិទ្ធភាព។

អ្នកគ្រប់គ្រងជាន់ខ្ពស់ដែលជាផ្នែកមួយនៃគណៈប្រតិបត្តិ ដូចដែលបានកំណត់និយមន័យក្នុងប្រការ ២ នៃ ប្រកាសនេះ ត្រូវឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របមួយដោយធនាគារជាតិនៃកម្ពុជា មុននឹងទទួលភារកិច្ចជាអ្នកប្រតិបត្តិជាន់ខ្ពស់នៅក្នុងគ្រឹះស្ថាន។

ប្រការ ១៥.-

នៅក្នុងក្រុមសម្ព័ន្ធធនាគារ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុមសម្ព័ន្ធ និងនៅថ្នាក់ក្រុមហ៊ុននីមួយៗដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម។ ក្រុមប្រឹក្សាភិបាលរបស់បុគ្គលសម្ព័ន្ធណាមួយ ត្រូវរក្សាឱ្យបានពេញលេញនូវការទទួលខុសត្រូវលើអភិបាលកិច្ចរបស់ខ្លួន។ ដូចគ្នានេះដែរ ការផ្តល់សេវាសំខាន់ៗពីប្រភពខាងក្រៅគ្រឹះស្ថាន មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការពិនិត្យមើលសកម្មភាព និងការគ្រប់គ្រងហានិភ័យបានឡើយ។

ប្រការ ១៦.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា មានការត្រួតពិនិត្យសមស្រប ត្រឹមត្រូវពីអ្នកគ្រប់គ្រងជាន់ខ្ពស់ស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវមានជំនាញជាចាំបាច់។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវលើសេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលយក និងអនុវត្តតាមទាំងស្រុងនូវគោលនយោបាយដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង និងត្រូវរាយការណ៍ឱ្យបានទៀងទាត់ទៅក្រុមប្រឹក្សាភិបាលអំពីទម្រង់ហានិភ័យ លទ្ធផលនៃការអនុវត្ត បញ្ហាផ្សេងៗវិវាទចម្បងរបស់គ្រឹះស្ថាន និងបញ្ហាចំពោះមុខ និងជាសក្តានុពលនៃបទប្បញ្ញត្តិ។

ជំពូក ៥
ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសវនកម្ម

ប្រការ ១៧.-

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រូវប្រើប្រាស់ការងាររបស់សវនករ និងមុខងារត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានប្រសិទ្ធភាព៖

- អ្នកគ្រប់គ្រងត្រូវផ្សព្វផ្សាយឱ្យមានការទទួលស្គាល់ពីសារៈសំខាន់នៃការងាររបស់សវនករខាងក្នុង និងខាងក្រៅ ទូទាំងគ្រឹះស្ថាន
- លទ្ធផលរកឃើញរបស់សវនកម្មផ្ទៃក្នុងត្រូវតែប្រើប្រាស់សម្រាប់សកម្មភាពកែតម្រូវដោយប្រសិទ្ធភាពគ្រប់កាលៈទេសៈដែលតម្រូវ
- ការអនុវត្តទាន់ពេលវេលានូវសកម្មភាពកែតម្រូវដែលចាំបាច់ និងប្រកបដោយប្រសិទ្ធភាព ត្រូវតែពិចារណាយោងតាមភាពធ្ងន់ធ្ងរនៃការរកឃើញ និងហានិភ័យដែលនាំឱ្យមានការធ្លាក់ដុនដាបជាបន្តបន្ទាប់នៃទម្រង់ហានិភ័យរួម និងស្ថានភាពប្រតិបត្តិតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថាន។

ជំពូក ៦
គោលនយោបាយលាភការ

ប្រការ ១៨.-

តាមការចាំបាច់ ក្រុមប្រឹក្សាភិបាល និងគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវធានាថាការអនុវត្តនិងគោលនយោបាយលាភការមានសង្គតិភាពជាមួយនឹងវប្បធម៌សាជីវកម្ម (Corporate Culture) យុទ្ធសាស្ត្រនិងគោលដៅរយៈពេលវែង និងបរិយាកាសត្រួតពិនិត្យរបស់គ្រឹះស្ថាន។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ ឬអនុម័តលាភការដល់សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់។

តម្លៃការជូនទៅនាយកមិនប្រតិបត្តិ ត្រូវសមាមាត្រទៅនឹងការចូលរួមរបស់អ្នកទាំងនោះ ប៉ុន្តែការផ្តល់តម្លៃការនោះ មិនទាក់ទងនឹងលទ្ធផលរយៈពេលខ្លីរបស់គ្រឹះស្ថានទេ។

រង្វាន់លើកទឹកចិត្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រូវមានគោលដៅបង្កើនតម្លៃរួម (Corporate Value) រយៈពេលវែង។

ជំពូក ៧
តម្លាភាព

ប្រការ ១៩.-

គ្រឹះស្ថានត្រូវតែដឹកនាំគ្រប់គ្រងប្រកបដោយមានតម្លាភាព។ ការបើកចំហដល់សាធារណជនត្រូវតែសមាមាត្រទៅនឹងទំហំ សកម្មភាព ភាពស្មុគស្មាញ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន។ ការបើកចំហយ៉ាងហោចណាស់ត្រូវមានដូចខាងក្រោម៖

- រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថាន
- រចនាសម្ព័ន្ធភាគទុនិក
- រចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម បើអាចធ្វើបានត្រូវឱ្យសមស្របទៅនឹងកម្មសិទ្ធិភាគហ៊ុន ដែលត្រូវបានកាន់កាប់
- រចនាសម្ព័ន្ធចាត់តាំង
- រង្វាន់លើកទឹកចិត្ត
- ក្រមប្រតិបត្តិ ឬ ក្រមសីលធម៌
- គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍
- គោលនយោបាយឥណទាន និងកម្រិតកំណត់ដែលត្រូវអនុវត្តចំពោះសម្ព័ន្ធញាតិនិងបុគ្គលសម្ព័ន្ធ។

ជំពូក ៨
ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន

ប្រការ ២០.-

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់៖

- ត្រូវយល់ដឹងអំពីរចនាសម្ព័ន្ធប្រតិបត្តិការរបស់គ្រឹះស្ថាន រួមទាំងនៅពេលដែលគ្រឹះស្ថានធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការ ឬតាមរយៈរចនាសម្ព័ន្ធណាមួយដែលរារាំងដល់តម្លាភាព
- ត្រូវធានាថា អ្នកគ្រប់គ្រងជាន់ខ្ពស់អនុវត្តតាមគោលនយោបាយច្បាស់លាស់ចំពោះប្រតិបត្តិការដែលត្រូវបានធ្វើតាមរយៈរចនាសម្ព័ន្ធ ឬ យុត្តាធិការ ដែលគ្មានតម្លាភាព
- ត្រូវមានគោលនយោបាយសមស្របសម្រាប់ការអនុមតិ និងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ ហិរញ្ញវត្ថុ ឧបករណ៍ ឬ ផលិតផល ដែលមានភាពស្មុគស្មាញ
- ត្រូវធានាថា សវនកម្មផ្ទៃក្នុងមិនត្រូវទុកឱ្យរចនាសម្ព័ន្ធ ឬសកម្មភាពទាំងនេះស្ថិតនៅក្រៅការត្រួតពិនិត្យឡើងវិញជាប្រចាំរបស់ខ្លួនឡើយ
- ត្រូវធានាថាការផ្តល់សេវាពីខាងក្រៅ ចំពោះសកម្មភាពសំខាន់ៗ នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យគ្រប់គ្រាន់ និងធានាថាហានិភ័យដែលផ្សារភ្ជាប់និងការផ្តល់សេវាពីខាងក្រៅនេះ ត្រូវបានសម្គាល់ និងតាមដានពេញលេញ។

ជំពូក ៩
អន្តរប្បញ្ញត្តិ

ប្រការ ២១.-

១- បន្ទាប់ពីប្រកាសនេះចូលជាធរមាន ធនាគារពាណិជ្ជ និងធនាគារឯកទេសលើកលែងតែសាខាធនាគារបរទេស ត្រូវអនុវត្តឱ្យបានពេញលេញនូវបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយនៃអភិបាលកិច្ច ជាពិសេសប្រការ ៦ នៃប្រកាសនេះ ដោយមិនឱ្យលើសពី៖

- ១២ ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកលើសពី ៣០០ នាក់ ឬ ទ្រព្យសកម្មសរុបច្រើនជាង ៥០០ ពាន់លានរៀល
- ១៨ ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកពី ១៥០ នាក់ ដល់ ៣០០ នាក់ ឬ ទ្រព្យសកម្ម សរុបពី ២០០ ពាន់លានរៀល ដល់ ៥០០ ពាន់លានរៀល និង
- ២៤ ខែ សម្រាប់គ្រប់គ្រឹះស្ថានដទៃទៀតដែលមានចំនួនបុគ្គលិកតិចជាង ១៥០ នាក់ ឬ ទ្រព្យសកម្មសរុបតិចជាង ២០០ ពាន់លានរៀល។

២- ក្នុងអំឡុងពេល៩ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជា ដោយរៀបរាប់លម្អិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពី៖

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការសម្រាប់បំពេញមុខតំណែងក្នុងអង្គការលេខដែលបានគ្រោងទុក
- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយគណៈកម្មការដែលត្រូវបង្កើតឡើង។

៣- ផែនការសកម្មភាព អង្គការលេខដែលបានគ្រោងទុក និងការទទួលខុសត្រូវដែលបានរៀបរាប់ខាងលើឱ្យបានច្បាស់លាស់ត្រូវរាយការណ៍ទាន់ពេលវេលាមកធនាគារជាតិនៃកម្ពុជា។

ប្រការ ២២.-

ក្នុងអំឡុងពេល៩ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន សាខាធនាគារបរទេសត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា ស្តីពី គោលនយោបាយនិងនីតិវិធីនៃអភិបាលកិច្ច ដោយត្រូវរៀបរាប់ពីៈ

- ស្ថិយភាពនៃសិទ្ធិសម្រេចដែលផ្តល់ដោយទីស្នាក់ការកណ្តាល
- គោលនយោបាយ និងនីតិវិធីនៃអភិបាលកិច្ច និងការគ្រប់គ្រងដោយទីស្នាក់ការកណ្តាលដែលសាខាត្រូវអនុវត្តតាម
- បណ្តាញនៃការរាយការណ៍របស់គណៈប្រតិបត្តិសាខា ទៅសមាជិកក្រុមប្រឹក្សាភិបាលនិងការទទួលខុសត្រូវក្នុងគ្រឹះស្ថាន ដែលកំណត់ដោយទីស្នាក់ការកណ្តាល
- ការផ្តល់សិទ្ធិអំណាចដោយទីស្នាក់ការកណ្តាលចំពោះគណៈប្រតិបត្តិសាខាក្នុងស្រុក និង
- នីតិវិធី និងគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងសិទ្ធិអំណាចដែលតម្រូវដោយទីស្នាក់ការកណ្តាលដើម្បីឱ្យសាខាមានសិទ្ធិធ្វើប្រតិបត្តិការ។

ច្បាប់ចម្លងនៃរាល់ឯកសារខាងលើ ត្រូវភ្ជាប់ជាមួយរបាយការណ៍ផ្តល់មកធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធ្វើបច្ចុប្បន្នកម្មតាមគ្រានូវរបាយការណ៍ទាំងនោះសំដៅវាយតម្លៃភាពខ្លាំងនិងភាពខ្សោយនៃការត្រួតពិនិត្យ និងអភិបាលកិច្ចរបស់សាខាធនាគារបរទេស។

ប្រការ ២៣.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យបានពេញលេញមិនឱ្យលើសពី ២៤ ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន។ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជាដោយរៀបរាប់លម្អិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពីៈ

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការសម្រាប់បំពេញមុខតំណែង ក្នុងអង្គការលេខដែលបានគ្រោងទុក

- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយគណៈកម្មការដែលត្រូវបង្កើតឡើង។

ក្នុងករណីចាំបាច់ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពខាងលើមកធនាគារជាតិនៃកម្ពុជាក្នុងអំឡុងពេល ៩ ខែ។

ជំពូក ១០
អវសានប្បញ្ញត្តិ

ប្រការ ២៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថាននៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ប្រកាស
ស្តីពី
លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះកំណត់នូវតម្រូវការអប្បបរមាចំពោះបុគ្គលដែលមានមុខងារសំខាន់នៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ឬបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវទទួលរងការវាយតម្លៃថាមាន "លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប" ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។

គោលបំណងនៃប្រកាសនេះរួមមាន៖

១- ការពារផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើ និងបុគ្គលដែលពាក់ព័ន្ធដោយធានាថាគ្រឹះស្ថានត្រូវបានគ្រប់គ្រងនិងដឹកនាំយ៉ាងត្រឹមត្រូវនិងប្រុងប្រយ័ត្ន

២- ដាក់ចេញនូវក្របខ័ណ្ឌអប្បបរមាស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដែលគ្រឹះស្ថានអាចយកទៅប្រើប្រាស់ដើម្បីកំណត់ចំពោះបុគ្គលដែលនឹងទទួលតំណែងសំខាន់ៗ

៣- ដោះស្រាយហានិភ័យដែលបណ្តាលមកពីការគ្រប់គ្រងមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងររបស់គ្រឹះស្ថាន និងទប់ស្កាត់ការគំរាមកំហែងជាសក្តានុពលដល់ប្រព័ន្ធធនាគារទាំងមូល និងការពារផលប្រយោជន៍របស់អ្នកដាក់ប្រាក់បញ្ញើ។

ប្រការ ២.-

គ្រឹះស្ថានទាំងអស់ ត្រូវមានគោលនយោបាយផ្ទៃក្នុងគ្រប់គ្រាន់ ដែលហ្មត់ចត់និងច្បាស់លាស់តាមស្តង់ដារ សម្រាប់ជ្រើសរើសនាយកប្រតិបត្តិ និងអ្នកគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ទោះបីជាការទទួលខុសត្រូវសំខាន់ក្នុងការកំណត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវពឹងផ្អែកជាចម្បងលើភាគទុនិក។ អាជ្ញាធរត្រូវពិនិត្យក៏ទទួលខុសត្រូវផងដែរក្នុងការវាយតម្លៃពីភាពស្មោះត្រង់ សុចរិត កិត្តិនាម ចំណេះដឹង និងសមត្ថភាពរបស់បុគ្គលសំខាន់ៗក្នុងពេលបច្ចុប្បន្ននិងអនាគតក្នុងលក្ខខណ្ឌនៃការដឹកនាំគ្រឹះស្ថានប្រកបដោយប្រសិទ្ធភាព។

បុគ្គលទាំងនេះ ត្រូវអនុវត្តឱ្យពេញលេញស្របតាមប្រកាសលេខ ធ៧-០៨-២១១ ប្រ.ក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៣.-

ក្នុងការអនុវត្តន៍រលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ធនាគារជាតិនៃកម្ពុជា កំណត់ផងដែរ សម្រាប់បុគ្គលដែលមានតំណែងសំខាន់ៗនៅក្នុងគ្រឹះស្ថាន ត្រូវមានកម្រិតសមត្ថភាព និងបទពិសោធន៍ សមស្របទៅនឹងការទទួលខុសត្រូវរបស់ខ្លួន។ ការវាយតម្លៃសមត្ថភាពនិងបទពិសោធន៍ដោយផ្អែក លើទំហំនិងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន ក៏ដូចជាទំហំនិងភាពស្មុគស្មាញនៃអាជីវកម្ម និងភាព ជឿនលឿនហួសហេតុនៃប្រតិបត្តិការ។

ជំពូក ២
បុគ្គលសំខាន់ៗ ត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របដោយធនាគារជាតិនៃកម្ពុជា

ប្រការ ៤.-

បុគ្គលសំខាន់ៗត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដោយធនាគារជាតិនៃ កម្ពុជារួមមាន៖

១- ក្រុមប្រឹក្សាភិបាល

២- អ្នកគ្រប់គ្រងជាន់ខ្ពស់ ដូចមានចែងនៅក្នុងប្រការ ២ នៃប្រកាសលេខ ធ៧-០៨-២១១ ប្រ.ក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣- នាយកសាខាធនាគារបរទេស និង

៤- បុគ្គលដែលមានតួនាទីជំនួសដោយការកំណត់ ឬបុគ្គលដែលទទួលបានសិទ្ធិប្រទានពី បុគ្គលដូចមានចែងខាងលើ។

ប្រការ ៥.-

ការឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដែលមានចែងនៅ ក្នុងប្រការ ៤ ត្រូវអនុវត្តគ្រប់កាល:ទេស:នៃការស្នើសុំដូចខាងក្រោម៖

១- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រតិបត្តិការធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា

២- ការដាក់ពាក្យសុំបើកបុត្តសម្ព័ន្ធរបស់ធនាគារបរទេសនៅកម្ពុជា

៣- ការដាក់ពាក្យសុំបើកសាខាធនាគារបរទេសនៅកម្ពុជា

៤- រាល់ការសម្រេចរបស់កិច្ចប្រជុំភាគទុនិក ឬក្រុមប្រឹក្សាភិបាលដែលបណ្តាលឱ្យមាន ការកើនឡើងចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៥- រាល់ការសម្រេចរបស់ធនាគារបរទេសដែលបង្កើតបុត្តសម្ព័ន្ធនៅកម្ពុជា ដែលបណ្តាល ឱ្យមានការកែប្រែ ឬផ្លាស់ប្តូរចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៦- រាល់ការសម្រេចទាំងឡាយណាដែលនាំទៅដល់ការតែងតាំងបុគ្គលជំនួស ឬបុគ្គលដែល ទទួលសិទ្ធិប្រទានដូចមានចែងក្នុងប្រការ ៤ ចំនុច ១, ២ និង ៣ និង

៧- រាល់ការផ្លាស់ប្តូរដែលកើតមានបន្ទាប់ពីការបញ្ឈប់ ឬការលាឈប់របស់បុគ្គលទាំងនោះ។

ជំពូក ៣
តម្រូវការព័ត៌មាន

ប្រការ ៦.-

នៅក្នុងដំណើរការដាក់ពាក្យសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានថ្មី គ្រឹះស្ថានត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា នូវព័ត៌មានដែលទាក់ទងនឹងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របនៃបុគ្គលសំខាន់ៗ សម្រាប់ជាឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ និងផ្តល់បន្ថែមនូវរចនាសម្ព័ន្ធចាត់តាំងដែលមានបញ្ជាក់ពីមុខងារ និងការទទួលខុសត្រូវនៃបុគ្គលទាំងនោះ។

ប្រការ ៧.-

ចំពោះគ្រឹះស្ថានដែលបានទទួលអាជ្ញាបណ្ណរួចហើយ រាល់ការផ្លាស់ប្តូរបុគ្គលសំខាន់ៗត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាមិនឱ្យលើសពី ៣០ ថ្ងៃ បន្ទាប់ពីការលាលែង ការចូលនិវត្តន៍ ឬការបញ្ឈប់បុគ្គលសំខាន់ៗនោះ។

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិនិត្យឡើងវិញនូវលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របនៃបុគ្គលដែលត្រូវបានស្នើសម្រាប់តំណែងទំនេរ ឬតំណែងទើបបង្កើតថ្មី មុនពេលសម្រេចតែងតាំង។ ធនាគារជាតិនៃកម្ពុជា មិនអាចបញ្ជាក់អំពីការទទួលយល់ព្រមការតែងតាំងទាំងនោះបានទេ មុនពេលបានទទួលនិងសិក្សាឡើងវិញនូវព័ត៌មានដែលតម្រូវឱ្យមាន។

ធនាគារជាតិនៃកម្ពុជា អាចនឹងសំភាសន៍ជាមួយបុគ្គលដែលបានស្នើ ដើម្បីឱ្យប្រាកដអំពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របនៃបុគ្គលក្នុងហានៈដែលត្រូវបានផ្តល់ឱ្យ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថានទាំងមូល។

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងនូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថានក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលឯកសារគ្រប់គ្រាន់និងអាចទទួលយកបាន។

ជំពូក ៤
ការវាយតម្លៃ និងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

ប្រការ ៩.-

បុគ្គលសម្រាប់តំណែងសំខាន់ៗនឹងត្រូវបានវាយតម្លៃ ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យច្រើនប្រភេទ ដើម្បីកំណត់ថាបុគ្គលទាំងនោះមានលក្ខខណ្ឌត្រឹមត្រូវនិងសមស្របគ្រប់គ្រាន់ ដើម្បីបំពេញនូវការទទួលខុសត្រូវ ដូចខាងក្រោម៖

១- ភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ

២- ការសិក្សា ចំណេះដឹង និងសមត្ថភាព

៣- ស្ថានភាពហិរញ្ញវត្ថុរឹងមាំ

ប្រការ ១០.-

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិចារណាលើកត្តាសមស្របជាច្រើន ដើម្បីវាយតម្លៃពីភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ យ៉ាងតិចបំផុតមានដូចខាងក្រោម៖

១- បុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម និងបទឧក្រិដ្ឋ ឬកំហុសខាងវិន័យ

២- បុគ្គលដែលមានកំហុសដោយសារការក្លែង ឬផ្តល់នូវភស្តុតាងក្លែងបន្លំ

៣- ចំពោះភាគទុនិកដែលមានឥទ្ធិពល ឬបុគ្គលដែលមានសិទ្ធិត្រួតពិនិត្យ ត្រូវបានទទួលទណ្ឌកម្មខាងវិន័យ ឬព្យួរការងារដោយអាជ្ញាធរត្រួតពិនិត្យ ឬគ្រឹះស្ថានវិជ្ជាជីវៈ ឬតុលាការជាសាធារណៈ ឬជាឯកជន

៤- បុគ្គលដែលមានតួនាទីទទួលខុសត្រូវ ឬជាម្ចាស់ក្រុមហ៊ុន ឬស្ថាប័នដែលធ្លាប់ត្រូវបានបដិសេធពេលចុះបញ្ជីពាណិជ្ជកម្ម ឬបញ្ឈប់អាជីវកម្ម ឬត្រូវបានដកហូតអាជ្ញាបណ្ណ

៥- បុគ្គលដែលត្រូវបញ្ឈប់ពីការងារ ឬបង្ខំឱ្យលាលែងពីតំណែងដោយសារតែពាក់ព័ន្ធលើបញ្ហាភាពសុចរិត ឬភាពស្មោះត្រង់

៦- បុគ្គលដែលត្រូវបានដកហូតពីតំណែងជានាយក ឬជាអ្នកគ្រប់គ្រងដោយសារតែបានប្រព្រឹត្តខុស

៧- បុគ្គលដែលគ្មានសីលធម៌និងសច្ចៈធម៌ ក្នុងការទំនាក់ទំនងជាមួយអតិថិជន ថ្នាក់ដឹកនាំ សវនករ និងអាជ្ញាធរផ្សេងទៀត

៨- បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពដូចជា ការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ការក្លែងបន្លំ ឬអំពើពុករលួយ ទោះបីជាការប្រព្រឹត្តនោះមិនឈានដល់ការផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងប្រទេសខ្លះក្តី

៩- បុគ្គលដែលគ្មានការវិនិច្ឆ័យនិងការសម្រេចចិត្តដោយឯករាជ្យ ដើម្បីប្រតិបត្តិតួនាទីរបស់ខ្លួន

១០- បុគ្គលដែលមិនបានត្រៀមជាស្រេច និងមិនមានបំណងប្រតិបត្តិតាមកាតព្វកិច្ច បទប្បញ្ញត្តិ និងការអនុវត្តដ៏ល្អ សំដៅទ្រទ្រង់សុវត្ថិភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារ។

ប្រការ ១១.-

បុគ្គលត្រូវមានការសិក្សា ចំណេះដឹង បទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីស្វែងយល់នូវតម្រូវការបច្ចេកទេសអាជីវកម្ម ហានិភ័យដែលពាក់ព័ន្ធ និងដំណើរការគ្រប់គ្រងទាំងឡាយដោយមានការទទួលខុសត្រូវ ដើម្បីអនុវត្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពរឹងមាំ ដោយគិតដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់។

ធនាគារជាតិនៃកម្ពុជា នឹងពិចារណារាល់កត្តាពាក់ព័ន្ធទាំងឡាយក្នុងការវាយតម្លៃកម្រិតយល់ដឹងនិងសមត្ថភាពវិជ្ជាជីវៈនៃបុគ្គល យ៉ាងតិចបំផុតមានដូចខាងក្រោម៖

១- បុគ្គលដែលមានប្រវត្តិសិក្សាសមស្រប នាំឱ្យមានការយល់ដឹងត្រឹមត្រូវនិងគ្រប់គ្រាន់អំពីអាជីវកម្ម និងហានិភ័យដែលពាក់ព័ន្ធ។

២- បុគ្គលដែលបានបង្ហាញថាមានសមត្ថភាពក្នុងការអនុវត្តតួនាទីប្រកបដោយជោគជ័យតាមរយៈគុណវុឌ្ឍិ បទពិសោធន៍ និងការប្រតិបត្តិមុខតំណែងពីមុនមក។

៣- បុគ្គលដែលមានចំណេះដឹងផ្នែកអាជីវកម្ម និងការទទួលខុសត្រូវចំពោះមុខតំណែង ហើយការយល់ដឹងនេះមានភាពសមស្របទៅនឹងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន ព្រមទាំងទំហំ ភាពស្មុគស្មាញនៃអាជីវកម្ម និងភាពជឿនលឿនហួសហេតុនៃប្រតិបត្តិការ។

៤- បុគ្គលធ្លាប់ទទួលទណ្ឌកម្មខាងវិន័យដោយអាជ្ញាធរត្រួតពិនិត្យ និងសមាគមវិជ្ជាជីវៈ និងពាណិជ្ជកម្ម ត្រូវបានបណ្តេញចេញ ឬតម្រូវឱ្យលាឈប់ពីមុខតំណែង ឬពីគ្រឹះស្ថានដោយសារការធ្វេសប្រហែស អសមត្ថភាព ការក្លែងបន្លំ ឬការគ្រប់គ្រងមិនត្រឹមត្រូវ និង

៥- បុគ្គលដែលបាត់បង់សមត្ថភាពក្នុងការបំពេញការងារ ដែលអាចជះឥទ្ធិពលលើសមត្ថភាពនិងសុភវិនិច្ឆ័យឯករាជ្យរបស់ខ្លួន។

ប្រការ ១២.-

ធនាគារជាតិនៃកម្ពុជានឹងពិចារណាផងដែរលើភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំក្នុងការវាយតម្លៃពីភាពត្រឹមត្រូវនិងសមស្រប។

ការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងត្រឹមត្រូវនៃការងារហិរញ្ញវត្ថុរបស់បុគ្គល ជាការបង្ហាញនូវសមត្ថភាពរបស់បុគ្គលនោះក្នុងការរួមចំណែកដើម្បីធានាសុវត្ថិភាព ភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត។ លើសពីនេះ ស្ថានភាពហិរញ្ញវត្ថុផ្ទាល់របស់បុគ្គលដូចបានលើកឡើងខាងលើ មិនរឹងមាំ អាចប៉ះពាល់ផងដែរលើសុភវិនិច្ឆ័យឯករាជ្យរបស់បុគ្គលនោះ។

ធនាគារជាតិនៃកម្ពុជា នឹងពិចារណារាល់កត្តាពាក់ព័ន្ធទាំងអស់យ៉ាងគិចបំផុតមានដូចខាងក្រោម៖

១- បុគ្គលនោះ ជាកម្មវត្ថុក្នុងការវិនិច្ឆ័យការងារណាមួយដោយតុលាការ ឬជាកម្មវត្ថុក្នុងការដាក់ទណ្ឌកម្មខាងវិន័យនៅចំពោះមុខសមាគមវិជ្ជាជីវៈ ជាពិសេស ប្រសិនបើនៅតែមានបណ្តឹងដែលទាក់ទងនឹងសកម្មភាពនោះ មិនទាន់បានដោះស្រាយ

២- បុគ្គលនោះ មានសមតុល្យឥណទានហួសកាលកំណត់នៅធនាគារផ្សេង និងមិនទាន់បានជម្រះស្ថានភាពនេះនៅឡើយ

៣- បុគ្គលនោះ បានធ្វើការសម្រុះសម្រួលជាមួយម្ចាស់បំណុល បានដាក់ពាក្យសុំក្ស័យធន ត្រូវបានវិនិច្ឆ័យថាក្ស័យធន ទ្រព្យសម្បត្តិត្រូវបានរឹបអូស ឬជាប់ពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់ទាក់ទងនឹងចំណុចណាមួយដែលបានលើកឡើងខាងលើ។

ជំពូក ៥
ការត្រួតពិនិត្យលើលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់បុគ្គលសំខាន់

ប្រការ ១៣.-

គ្រឹះស្ថានត្រូវបង្កើតគោលនយោបាយ និងនីតិវិធីក្នុងគោលបំណងធានាថា បុគ្គលសំខាន់ ឬបុគ្គលដែលត្រូវបានតែងតាំងរួចហើយ ឬបុគ្គលដាក់ពាក្យសុំកាន់តំណែងដែលនៅទំនេរ ត្រូវអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របជាអប្បបរមា។

ប្រការ ១៤.-

ប្រសិនបើបុគ្គលសំខាន់លែងអនុវត្តតាមតម្រូវការអប្បបរមានៃលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របទៀតហើយ គ្រឹះស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាអំពីស្ថានភាពនេះមិនឱ្យលើសពី ៣០ ថ្ងៃ បន្ទាប់ពីការពិតត្រូវបានរកឃើញ។ ទោះបីជាកាល:ទេស:ដែលនាំឱ្យចាត់ទុកថាភាពមិនត្រឹមត្រូវនិងមិនសមស្រប មិនទាន់ច្បាស់លាស់ក៏ដោយ ការរាយការណ៍បែបនេះមកធនាគារជាតិនៃកម្ពុជា ត្រូវតែបាននិងគាំទ្រដោយការពិពណ៌នាលម្អិតអំពីហេតុការណ៍ពិត និងកាល:ទេស:នោះ។ ធនាគារជាតិនៃកម្ពុជា នឹងឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបាននូវសំណុំឯកសារពេញលេញ ដើម្បីសម្រេចថាបដិសេធ ឬមិនបដិសេធលើការរក្សាទុកនូវបុគ្គលសំខាន់ៗក្នុងមុខតំណែង។

ប្រការ ១៥.-

គ្មានបុគ្គលសំខាន់ណាម្នាក់ត្រូវបានតែងតាំងនៅក្នុងគ្រឹះស្ថាន មុនពេលទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជាឡើយ។

គ្មានបុគ្គលសំខាន់ណាម្នាក់ដែលលែងបំពេញបានតាមតម្រូវការអប្បបរមា ដែលមានចែងនៅក្នុងប្រកាសនេះ នៅរក្សាតួនាទីរបស់ខ្លួនដដែលឡើយ។

ប្រការ ១៦.-

ចំពោះបេក្ខជនថ្មីដែលត្រូវទទួលខុសត្រូវមុខងារសំខាន់ៗ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ដែលមិនបានបំពេញតាមតម្រូវការទាំងស្រុង ដោយមូលហេតុណាមួយដូចជា កង្វះខាតការសិក្សា ការបំពាក់បំប៉ន ឬបទពិសោធន៍ ធនាគារជាតិនៃកម្ពុជាអាចសម្រេចចិត្ត "មិនបដិសេធ" ប្រសិនបើដឹងជាមុននូវស្ថានភាពផ្សេងៗដូចជា ការចូលរួមវគ្គសិក្សាបន្ថែម ឬត្រូវបានតែងតាំងដំបូងក្នុងមុខតំណែងរង ឬជាអ្នកទទួលសិទ្ធិប្រទានសម្រាប់បំពេញការងារសាកល្បង ក្នុងរយៈពេលដែលត្រូវបំពេញការសិក្សានោះ ដែលមិនត្រូវលើសពី ១៨ ខែ។

ធនាគារជាតិនៃកម្ពុជា នឹងវាយតម្លៃការបំពេញតាមលក្ខខណ្ឌដែលបានដាក់ចេញក្នុងរយៈពេលសាកល្បងការងារនៅចុងបញ្ចប់រយៈពេលដែលបានកំណត់ខាងលើ។ រាល់ព័ត៌មាន ឯកសារ និងកំណត់ត្រាលទ្ធផលការងារ ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់នៃរយៈពេលសាកល្បងការងារនោះ។ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ ៧ ធនាគារជាតិនៃកម្ពុជា អាចតម្រូវនិងធ្វើការសម្ភាសបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ ដើម្បីផ្តល់ជាទស្សនៈលើ

លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់បុគ្គលនោះ នៅក្នុងការបំពេញលក្ខខណ្ឌសុកវិនិច្ឆ័យ និងសមត្ថភាពគ្រប់គ្រង និងលទ្ធផលដែលសម្រេចបានក្នុងរយៈពេលសាកល្បងការងារដោយប្រសិទ្ធភាព។

ជំពូក ៦
ទណ្ឌកម្ម

ប្រការ ១៧.-

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការផ្សៀងផ្ទាត់ព័ត៌មាន និងទិន្នន័យជាភស្តុតាងដែលបានភ្ជាប់ជាមួយនឹងឯកសារស្នើសុំតែងតាំងតំណែងបុគ្គលសំខាន់នៅក្នុងគ្រឹះស្ថាន។ ប្រសិនបើការរាយការណ៍លិខិតថ្កោលទោស និងរបាយការណ៍ដែលចេញផ្សាយដោយសមាគមវិជ្ជាជីវៈ ឬអាជ្ញាធរត្រួតពិនិត្យដែលបានបញ្ជូនមកមានភាពមិនត្រឹមត្រូវ ឬក្លែងបន្លំ ធនាគារជាតិនៃកម្ពុជា ត្រូវដាក់នូវទណ្ឌកម្មខាងវិន័យ និងការជាកពិន័យដល់គ្រឹះស្ថាន ក៏ដូចជាបុគ្គលដែលបានបញ្ជូនព័ត៌មានទាំងនោះដោយចេតនា។ ការប្រព្រឹត្តបែបនេះ អាចនាំឱ្យឈានដល់ការបដិសេធចំពោះការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ១៨.-

ប្រសិនបើក្នុងរយៈពេលនៃដំណើរការត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថាន មន្ត្រីទទួលបន្ទុករបស់ធនាគារជាតិនៃកម្ពុជា បានរកឃើញថា៖

ក. បុគ្គលសំខាន់មិនបានឆ្លងកាត់ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របដូចមានចែងក្នុងប្រកាសនេះ

ខ. បុគ្គលសំខាន់មិនបានបំពេញតាមតម្រូវការអប្បបរមា ដើម្បីក្លាយជាបុគ្គលដែលមានលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

គ. ទោះបីមិនត្រូវបានកំណត់ជា "បុគ្គលសំខាន់" ក៏ដោយ តែបុគ្គលនោះអនុវត្តការងារទទួលខុសត្រូវ និងដឹកនាំគ្រឹះស្ថានទាំងស្រុង

ឃ. បុគ្គលដែលរងនូវការបដិសេធពីធនាគារជាតិនៃកម្ពុជា នៅតែបំពេញការងារសំខាន់ក្នុងគ្រឹះស្ថាន

ង. បន្ទាប់ពីការសាកល្បងការងារក្នុងរយៈពេលកំណត់ ១៨ ខែ បុគ្គលសំខាន់មិនបានអនុវត្តតាមការតម្រូវ ដូចមានចែងនៅក្នុងប្រការ ១៦ នៃប្រកាសនេះ ឬ

ច. បុគ្គលសំខាន់លែងអនុវត្តតាមការតម្រូវអប្បបរមាទៀតហើយ ទោះបីជាធនាគារជាតិនៃកម្ពុជា បានយល់ព្រមថាបុគ្គលនោះបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របចាប់ពីដំបូងក៏ដោយ។

គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូក ៧
អវសានប្បញ្ញត្តិ

ប្រការ ១៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថាននៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២០.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ប្រកាស
ស្តីពី
ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.- គោលការណ៍

១.១. ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏ពេញលេញមួយនៅតែជាមធ្យោបាយប្រកបដោយប្រសិទ្ធភាព ទោះបីគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ជាអ្នកទទួលខុសត្រូវលើសុវត្ថិភាព និងភាពរឹងមាំនៃប្រតិបត្តិការ ព្រមទាំងការគោរពតាមច្បាប់និងបទបញ្ជាផ្សេងៗក៏ដោយ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាមធ្យោបាយសម្រាប់៖

ក. ជួយដល់គណៈគ្រប់គ្រងក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន

ខ. ជួយដល់ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និង

គ. គាំទ្រការយល់ដឹងអំពីហានិភ័យ និងការឆ្លើយតបចំពោះការអនុវត្តវិធានការកែតម្រូវផ្សេងៗ។

១.២. គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដោយផ្អែកលើទំហំ និងភាពស្មុគស្មាញនៃសកម្មភាព រចនាសម្ព័ន្ធក្រុមសាជីវកម្ម និងប្រភេទគ្រឹះស្ថានដែលបានបង្កើតក្នុងនិងក្រៅប្រទេសព្រមទាំងប្រភេទហានិភ័យដែលគ្រឹះស្ថានត្រូវប្រឈម។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានលក្ខណៈសមស្របនឹងភាពស្មុគស្មាញនៃប្រតិបត្តិការនិងសកម្មភាព មានបុគ្គលិកគ្រប់គ្រាន់ព្រមទាំងមានធនធានសមស្របផ្សេងទៀតសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មាន ផែនការយថាភាព (Contingency Planning) និងការសាកល្បងជាដើម។

១.៣. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងក៏សំដៅជំរុញស្មារតីទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗផងដែរ ដោយផ្អែកលើវិធាននៃការទទួលខុសត្រូវលើភារកិច្ចច្បាស់លាស់ ដែលងាយយល់សម្រាប់គ្រឹះស្ថានទាំងមូល។ វិធានទាំងនេះត្រូវមានចែងអំពីបែបបទរាយការណ៍ច្បាស់លាស់ទៅគណៈគ្រប់គ្រង គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ឬគណៈប្រតិបត្តិដែលមានហានៈស្មើ។ វិធានទាំងនេះត្រូវមានចែងអំពីបែបបទនៃការផ្ទេរសិទ្ធិអំណាច ដើម្បីធានាថាអ្នកទទួលសិទ្ធិអំណាចបានយល់ដឹងច្បាស់លាស់អំពីការផ្ទៀងផ្ទាត់និងការត្រួតពិនិត្យពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិអំណាចទាំងនោះទៅតាមហានានុក្រមនៃការគ្រប់គ្រង។

១.៤. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានយ៉ាងតិចនូវ៖

ក. ប្រព័ន្ធត្រួតពិនិត្យសម្រាប់នីតិវិធីប្រតិបត្តិការ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង

ខ. រចនាសម្ព័ន្ធនៃប្រព័ន្ធគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា

គ. ប្រព័ន្ធវាស់វែងលទ្ធផលនិងហានិភ័យ

ឃ. ប្រព័ន្ធកំណត់អត្តសញ្ញាណ វាស់វែង និងតាមដានហានិភ័យ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យហានិភ័យ តាមរយៈការដាក់ចេញនូវវិធានការកែតម្រូវ

ង. ការបែងចែកភារកិច្ច ការទប់ស្កាត់ទំនាស់ផលប្រយោជន៍ ព្រមទាំងគោលនយោបាយ និងនីតិវិធីដោះស្រាយទំនាស់

ច. គោលនយោបាយ នីតិវិធី និងដំណើរការប្រតិបត្តិតាម (Compliance)

ឆ. ប្រព័ន្ធព័ត៌មាននិងរក្សាទុកឯកសារ និង

ជ. ប្រព័ន្ធសម្រាប់តាមដានស្ថានភាព និងលំហូរសាច់ប្រាក់និងមូលបត្រ។

១.៥. បើចាំបាច់ គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅកម្រិតគួបសរុបមួយដែលមានប្រសិទ្ធភាពក្នុងការកំណត់ វាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យនៅកម្រិតគួបសរុបនេះ។ ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅកម្រិតគួបសរុបនេះ គ្រឹះស្ថានចាំបាច់ត្រូវកំណត់ច្បាស់លាស់នូវមុខងារភារកិច្ច បែបបទរាយការណ៍ និងគណនេយ្យភាព។

ប្រការ ២.- គោលបំណង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានគោលបំណងផ្តល់លក្ខខណ្ឌប្រសើរបំផុត ដើម្បីធានាសុវត្ថិភាព ជំនឿទុកចិត្ត និងភាពគ្រប់ជ្រុងជ្រោយ ដើម្បី៖

២.១. ធានាថាប្រតិបត្តិការ រចនាសម្ព័ន្ធ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានអនុលោមតាមច្បាប់និងបទបញ្ជាពាក់ព័ន្ធក្រមសីលធម៌ ទម្លាប់នៃការអនុវត្តប្រតិបត្តិការ និងយុទ្ធសាស្ត្រអាជីវកម្ម ដែលត្រូវបានកំណត់ដោយគណៈប្រតិបត្តិ។

២.២. ធានាឱ្យមានការប្រតិបត្តិតាមម៉ឺងម៉ាត់តាមនីតិវិធីនៃការសម្រេចចិត្ត និងគោលនយោបាយ និងនីតិវិធីនៃការទទួលយកហានិភ័យ ទោះជាហានិភ័យពាក់ព័ន្ធប្រភេទណាក៏ដោយ និងតាមបទដ្ឋាននៃការគ្រប់គ្រង ដូចបានកំណត់ ឬអនុម័តដោយគណៈប្រតិបត្តិ។ ជាពិសេស គោលនយោបាយនិងនីតិវិធីទាំងនេះត្រូវមានទម្រង់ជាសកម្មភាពនិងប្រតិបត្តិការដែលត្រូវបានអនុញ្ញាត និងហាមឃាត់ ព្រមទាំងកម្រិតកំណត់ដែលត្រូវអនុវត្តចំពោះប្រភេទហានិភ័យនីមួយៗជាដើម។

២.៣. ធានាគុណភាពនៃព័ត៌មានគណនេយ្យនិងហិរញ្ញវត្ថុ ទោះបីជាសម្រាប់គណៈប្រតិបត្តិ ឬអ្នកសម្រេចចិត្ត ឬអាជ្ញាធរត្រួតពិនិត្យ ឬការផ្សព្វផ្សាយជាសាធារណៈក្តី។

២.៤. ពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងឡាយក្នុងការវាយតម្លៃ កត់ត្រា រក្សាទុក និងផ្សព្វផ្សាយព័ត៌មានជាពិសេសដោយធានាថានីតិវិធីនិងប្រព័ន្ធលំនាំសវនកម្ម (Audit Trail System) មានប្រសិទ្ធភាព និងអាចទាញយករាល់ឯកសារគតិយុត្ត ឬឯកសារគាំទ្រគណនេយ្យនៅគ្រាដំបូងនៃការចុះបញ្ជិកាទៅក្នុងប្រព័ន្ធគណនេយ្យ ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានវិទ្យា។

២.៥. ធានាគុណភាពនិងភាពសមស្របនៃប្រព័ន្ធព័ត៌មាន និងទំនាក់ទំនងនៅក្នុងគ្រឹះស្ថាន ទាំងនៅកម្រិតដាច់ដោយឡែកនិងកម្រិតគួបសរុប និងបើចាំបាច់ ចំពោះអាជ្ញាធរនិងសវនករឯករាជ្យ តាមរយៈការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃប្រចាំគ្រា។

ប្រការ ៣.- និយមន័យ

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

- **"គណៈកម្មការសវនកម្ម"** ៖ ជាគណៈកម្មការដែលត្រូវបានបង្កើតឡើងដោយគណៈប្រតិបត្តិ ដើម្បីជួយក្នុងការបំពេញភារកិច្ច។ គណៈប្រតិបត្តិត្រូវកំណត់សមាជិកភាព ភារកិច្ច និង នីតិវិធី និងលក្ខខណ្ឌប្រតិបត្តិការសម្រាប់សវនករឯករាជ្យ សវនករផ្ទៃក្នុង និងបុគ្គលដទៃ ទៀតដែលពាក់ព័ន្ធនៅក្នុងការងាររបស់គណៈកម្មការសវនកម្ម។ គណៈកម្មការសវនកម្ម ត្រូវដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ឬសមាជិកគណៈប្រតិបត្តិម្នាក់ ដែលមិនទទួលបន្ទុកផ្នាល់ក្នុងសកម្មភាពកំណត់ការទទួលយកហានិភ័យ ឬការអភិវឌ្ឍ អាជីវកម្មរបស់គ្រឹះស្ថាន។

  គណៈកម្មការសវនកម្ម ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈសម្រេច ដែលមានហាន:ស្មើ ហើយត្រូវមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

  ក. ធានាថាព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធនឹងហានិភ័យមានភាពច្បាស់លាស់ និងវាយតម្លៃលើភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ និងវិធីវាយតម្លៃដែលត្រូវ បានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុដាច់ដោយឡែក និងគួបសរុប (Consolidated) បើចាំបាច់។

  ខ. វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសចំពោះសង្គតិភាពនៃប្រព័ន្ធ វាស់វែង តាមដាន និងត្រួតពិនិត្យហានិភ័យ ព្រមទាំងលើកវិធានការជាអនុសាសន៍ បន្ថែម បើចាំបាច់។

  គ. តាមដានប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវ ជាពិសេស ឃ្លាំមើលអនុសាសន៍ របស់សវនកម្មផ្ទៃក្នុងដែលមិនទាន់បានអនុវត្ត ឬអនុវត្តមិនទាន់សម្រេច និងបន្តជួយ គាំទ្រដល់ការងាររបស់សវនកម្មផ្ទៃក្នុង។

- **"ផលិតផលថ្មី/សកម្មភាពថ្មី"** ៖ សំដៅដល់ប្រតិបត្តិការថ្មី សេវាកម្មថ្មី ការចូលភាគកម្មថ្មី ការប្រើសេវាតតិយភាគីថ្មី ឬអ្វីផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរ/ការលើកកម្ពស់/ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ទិដ្ឋភាពគតិយុត្ត ការប្រតិបត្តិតាមនិងការវាយតម្លៃ ហានិភ័យ កិច្ចការពារអតិថិជន ការកែប្រែសំខាន់ៗលើគោលនយោបាយ នីតិវិធី/ដំណើរការ និងរចនាសម្ព័ន្ធ ការកែប្រែនិងការលើកកម្ពស់កិច្ចបញ្ជិកា និងប្លង់គណនីជាដើម ដែល ប្រសិនបើមិនអនុវត្តឱ្យបានត្រឹមត្រូវទេ នឹងអាចបង្កជាហានិភ័យប្រតិបត្តិការ ការប្រតិបត្តិ តាមច្បាប់ឬប្រភេទហានិភ័យផ្សេងទៀតរបស់គ្រឹះស្ថានដែលមិនអាចកំណត់អត្តសញ្ញាណ

បាន។ មុននឹងដាក់ឱ្យប្រើប្រាស់ផលិតផលថ្មី ឬអនុវត្តសកម្មភាពថ្មី ហានិភ័យទាំងនេះត្រូវតែបានវាយតម្លៃជាមុនដោយពិនិត្យទៅលើមុខងារពាក់ព័ន្ធ ដូចជាប្រតិបត្តិការ ការទ្រទ្រង់និងការត្រួតពិនិត្យ និងបើចាំបាច់ ចាត់វិធានការសមស្របដើម្បីដំណើរការត្រួតពិនិត្យ តាមដាន គ្រប់គ្រង និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងសកម្មភាពនិងផលិតផលថ្មីនោះ។

- **"គណៈប្រតិបត្តិ"** ៖ សំដៅដល់ក្រុមប្រឹក្សាភិបាលចំពោះក្រុមហ៊ុនសាជីវកម្ម ដែលការទទួលខុសត្រូវប្រតិបត្តិ ផ្អែកតែលើក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាប្រតិបត្តិចំពោះក្រុមហ៊ុនសាជីវកម្មដែលមានក្រុមប្រឹក្សាត្រួតពិនិត្យ។

- **"ការវាយតម្លៃទម្រង់ហានិភ័យ"** (Supervisory risk-profile assessment) ៖ ការវិភាគគ្រប់ជ្រុងជ្រោយលើស្ថានភាពរបស់គ្រឹះស្ថាន ដោយផ្អែកលើរាល់ទិន្នន័យ និងព័ត៌មានដែលបានផ្តល់ឱ្យអាជ្ញាធរត្រួតពិនិត្យ។ ការវាយតម្លៃនេះមានគោលបំណងវាយតម្លៃរាល់ហានិភ័យរបស់គ្រឹះស្ថាន (ជាពិសេស សាធនភាព សាច់ប្រាក់ងាយស្រួល ឥណទាន/សមភាគី (Counterparty) ទីផ្សារ និងអត្រាការប្រាក់) រួមទាំងកត្តាផ្សេងៗទៀតដូចជា គុណភាពសវនកម្មផ្ទៃក្នុង ហានិភ័យប្រមូលផ្តុំ អាជីវកម្មប្រមូលផ្តុំ ការផ្តល់មូលនិធិប្រមូលផ្តុំ សមត្ថភាពក្នុងការទប់ទល់នឹងការវិវត្តជាអវិជ្ជមាននៃទីផ្សារនិងអាជីវកម្ម រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យនិងប្រសិទ្ធភាព ធនធានមនុស្សគ្រប់គ្រាន់ ការបែងចែកមុខងារភារកិច្ច សក្តានុពលនៃទំនាស់ផលប្រយោជន៍ ឯករាជ្យភាពនៃមុខងារ "គន្លឹះ" ប្រសិទ្ធភាពនៃបែបបទរាយការណ៍ ដំណើរការនិងហេដ្ឋារចនាសម្ព័ន្ធ ព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន អភិបាលកិច្ចសាជីវកម្ម ការគាំទ្ររបស់ភាគទុនិក ផែនការយថាភាព នីតិវិធី និងប្រសិទ្ធភាពនៃដំណោះស្រាយបែកអាប់ (back up) តាមរយៈការសាកល្បងប្រចាំគ្រា។

- **"ការវាយតម្លៃទម្រង់ហានិភ័យគួបសរុប"** ៖ ជាការវាយតម្លៃទម្រង់ហានិភ័យដែលធនាគារជាតិនៃកម្ពុជាអនុវត្តនៅកម្រិតគួបសរុប ក្នុងនាមខ្លួនជាអ្នកត្រួតពិនិត្យគួបសរុប។ ក្នុងករណីចាំបាច់ ការវាយតម្លៃនេះក៏ត្រូវអនុវត្តចំពោះកម្រិតនៃកុងគ្លូមេរ៉ាហិរញ្ញវត្ថុ (Financial Conglomerate) ផងដែរ។

- **"ហានិភ័យឥណទាន/ហានិភ័យសមភាគី"** ៖ ហានិភ័យទាំងនេះកើតឡើងដោយសារតែការខកខានមិនគោរពតាមកិច្ចសន្យានៃសមភាគីណាមួយ ឬនៃសមភាគីច្រើនដែលរួមគ្នាជា "អត្តគាហក:" តែមួយ ដូចដែលបានចែងនៅក្នុងប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ហានិភ័យបែបនេះត្រូវតែបានពិចារណាជារួម ទាំងចំពោះស្ថានភាពក្នុងតារាងតុល្យការ និងទាំងការសន្យានិងយថាភាពផ្សេងៗនៅក្រៅតារាងតុល្យការ។ *(សូមមើលនិយមន័យនៃហានិភ័យឥណទានក្នុងប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។)*

- **"ហានិភ័យទីផ្សារ"** ៖ ជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុកើតឡើងពីបម្រែបម្រួលថ្លៃទ្រព្យសកម្មនៅលើទីផ្សារ្ងបិយវត្ថុ ទីផ្សារទុននិងហិរញ្ញវត្ថុ។ ហានិភ័យទីផ្សាររួមបញ្ចូលទាំងហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យដើមទុន និងហានិភ័យពាក់ព័ន្ធនឹងទំនិញ។
- **"ហានិភ័យអត្រាការប្រាក់"** ៖ ជាហានិភ័យនៃប្រតិបត្តិការដែលមាននៅក្នុងបញ្ជិកាធនាគារ (Banking book transactions) ទាំងក្នុងនិងក្រៅតារាងតុល្យការ នៅពេលមានបម្រែបម្រួលអត្រាការប្រាក់ដែលកើតឡើងពីអតុល្យភាពរវាងលក្ខខណ្ឌនៃការទទួលទុន និងការឱ្យខ្ចី។ ហានិភ័យនេះប៉ះពាល់ដោយផ្ទាល់ទៅលើគម្លាតការប្រាក់សុទ្ធរបស់គ្រឹះស្ថាន ដែលគណៈកម្មការជាក់លាក់មួយ ដូចជា គណៈកម្មការគ្រប់គ្រងទ្រព្យសកម្មនិងទ្រព្យអកម្មជាដើមត្រូវតាមដាននិងគ្រប់គ្រងឱ្យបានត្រឹមត្រូវ រួមជាមួយនឹងស្ថានភាពសាច់ប្រាក់ងាយស្រួលជារួម។ បញ្ជិកាធនាគារសំដៅដល់ខ្នង់ចំណូល និងចំណាយការប្រាក់នៅលើមូលដ្ឋានបង្គរ។ ហានិភ័យអត្រាការប្រាក់ដែលពាក់ព័ន្ធនឹងបម្រែបម្រួលថ្លៃឧបករណ៍អាចជួញដូរបានដែលកើតឡើងពីការចុះបញ្ជិកាតាមថ្លៃទីផ្សារ ឬថ្លៃសមស្រប ត្រូវតែបានចាត់ទុកជាហានិភ័យទីផ្សារ។
- **"ហានិភ័យសាច់ប្រាក់ងាយស្រួល"** ៖ ជាហានិភ័យក្នុងលក្ខខណ្ឌទីផ្សារមួយ ដែលគ្រឹះស្ថានអាចពុំមានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួន ឬគ្មានលទ្ធភាពដោះស្រាយ (to unwind) ឬកាត់កងស្ថានភាពបំណុលមួយ ដែលជាលទ្ធផលគ្រឹះស្ថាននោះត្រូវបានចាត់ទុកថាខកខានមិនគោរពកិច្ចសន្យា ដោយអ្នកចូលរួមទីផ្សារដទៃទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួលត្រូវគិតទាំងសាច់ប្រាក់ជារូបិយវត្ថុនិងរូបិយប័ណ្ណ និងទាំងទ្រព្យសកម្មចុះបញ្ជីឬជួញដូរផ្សេងៗ ដែលគ្រឹះស្ថានកំពុងមានប្រតិបត្តិការ។
- **"ហានិភ័យទូទាត់" / "ហានិភ័យប្រគល់"** ៖ ជាហានិភ័យដែលការទូទាត់នៅក្នុងប្រព័ន្ធទូទាត់មិនបានកើតឡើងដូចបានរំពឹងទុក។ ហានិភ័យនេះកើតឡើងក្នុងអំឡុងពេលដែលបញ្ហាទូទាត់សងប្រាក់ឬបញ្ហាប្រគល់ឧបករណ៍ហិរញ្ញវត្ថុមួយដែលបានទិញ/លក់ ហើយដែលមិនអាចត្រូវបានលុបចោលវិញជាឯកតោភាគី និងក្នុងអំឡុងពេលនៃការទទួលសាច់ប្រាក់ឬឧបករណ៍ហិរញ្ញវត្ថុជាបញ្ចប់។
- **"ហានិភ័យប្រតិបត្តិការ"** ៖ ជាហានិភ័យកើតឡើងពីភាពមិនគ្រប់គ្រាន់ ឬកំហុសឆ្គងពីនីតិវិធីផ្ទៃក្នុង បុគ្គលិក (Personnel) ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឬកត្តាខាងក្រៅផ្សេងទៀត។
- **"ហានិភ័យគតិយុត្ត"** ៖ ជាហានិភ័យកើតឡើងពីវិវាទរវាងសមភាគីណាមួយ ដែលបណ្តាលមកពីភាពមិនច្បាស់លាស់ ភាពមិនត្រឹមត្រូវ ឬភាពទន់ខ្សោយ ឬអ្វីផ្សេងទៀត ដែលអាចកើតឡើងចំពោះគ្រឹះស្ថាននៅក្នុងពេលធ្វើប្រតិបត្តិការ។ ហានិភ័យគតិយុត្តជាប្រភេទហានិភ័យមួយស្ថិតនៅក្រោមហានិភ័យប្រតិបត្តិការ។
- **"ហានិភ័យអន្តរការិយកម្ម"** ៖ ជាហានិភ័យដែលសមភាគីដើម (Principal) ឬសមភាគីខកខានមិនគោរពតាមកិច្ចសន្យាពាក់ព័ន្ធនឹងប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុដែលគ្រឹះស្ថានបានធានាការប្រគល់ ឬការទូទាត់បញ្ចប់នូវឧបករណ៍ហិរញ្ញវត្ថុនោះ។

- **"ផែនការនិរន្តភាពអាជីវកម្ម"** ៖ គឺជាសំណុំវិធានការ និងនីតិវិធីសម្រាប់ធានានិរន្តភាពអាជីវកម្មសំខាន់ៗ របស់គ្រឹះស្ថានដោយផ្អែកលើសេណារីយ៉ូនៃវិបត្តិផ្សេងៗ រួមមានការប៉ះទង្គិចធ្ងន់ធ្ងរ ឬស្ថានភាពមិនអំណោយផល តាមការសមស្របនិងជាបណ្តោះអាសន្នទៅតាមករណី ប៉ុន្តែវិធានការទាំងនោះត្រូវមានគោលដៅបន្តអនុវត្តប្រតិបត្តិការជាធម្មតាឡើងវិញឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។ ផែនការនិរន្តភាពអាជីវកម្មនេះអាចត្រូវបានបំបែកជា "ផែនការយថាភាព" ជាច្រើនដូចជា "ផែនការយថាភាពនៃសាច់ប្រាក់ងាយស្រួល" "ផែនការយថាភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបើកអាប់" ឬ "ផែនការគ្រប់គ្រងវិបត្តិ" ជាដើម។

- **"ហានិភ័យនៃការមិនប្រតិបត្តិតាម"** ៖ ជាហានិភ័យនៃការទទួលរងវិធានការខាងវិន័យ វិធានការរដ្ឋបាល ឬទណ្ឌកម្មតាមផ្លូវតុលាការ ឬជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរ ឬការបាត់បង់កិត្តិសព្ទ ដែលកើតឡើងពីការមិនគោរពតាមច្បាប់ និងបទបញ្ជាជាធរមាន បទដ្ឋានវិជ្ជាជីវៈ និងក្រមសីលធម៌ បទបញ្ជារបស់អាជ្ញាធរទីផ្សារ ពាក់ព័ន្ធនឹងសកម្មភាពធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយនិងសេចក្តីណែនាំផ្សេងៗដែលចេញដោយគ្រឹះស្ថាន។

- **"សកម្មភាពរបស់តតិយភាគី"** (Outsourced activities) ៖ ជាសកម្មភាពដែលគ្រឹះស្ថានបានទុកចិត្តផ្តល់សេវាកម្មសំខាន់ៗមួយចំនួនឱ្យតតិយភាគីជាអ្នកប្រតិបត្តិជំនួស តាមរយៈការចុះកិច្ចសន្យាបន្តផ្តល់នូវសេវាកម្ម និងធ្វើសកម្មភាពទាំងនោះជាអចិន្ត្រៃយ៍ និងជាប្រក្រតី។ សេវាកម្ម និងសកម្មភាពសំខាន់ៗទាំងនោះសំដៅលើសេវាកម្ម ឬសកម្មភាពដែលការអនុវត្តមិនបានទាន់ពេលវេលាដោយភាគីនៃកិច្ចសន្យាបន្ត នាំឱ្យមានការបង្អាក់ដល់ប្រតិបត្តិការប្រក្រតីរបស់គ្រឹះស្ថាន និងអាចនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពបំពេញកាតព្វកិច្ចឬកិត្តិសព្ទរបស់គ្រឹះស្ថាន។

- **"ហានិភ័យប្រមូលផ្តុំ"** ៖ ជាហានិភ័យដោយផ្ទាល់ឬដោយប្រយោល ដែលបណ្តាលពីហានិភ័យចំពោះសមភាគី/ក្រុម ឬសមភាគីពាក់ព័ន្ធផ្សេងទៀតតែមួយ ចំពោះអ្នកចេញផ្សាយតែមួយនៃមូលបត្រ ចំពោះវិស័យសេដ្ឋកិច្ច/តំបន់ភូមិសាស្ត្រនិងប្រទេសតែមួយ និងចំពោះប្រភេទទ្រព្យសកម្ម ឬវត្ថុបញ្ចាំណាមួយ ឬជាហានិភ័យដែលកើតឡើងពីហានិភ័យធំៗ ចំពោះសមភាគីមួយ ដែលគ្រឹះស្ថានមានប្រតិបត្តិការជាមួយដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗ។

- **"នីតិវិធី វីស្សុលប្លូវីង"** (Whistle blowing procedure) ៖ ជានីតិវិធីសម្រាប់ដោះស្រាយស្ថានភាពទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬជាសក្តានុពល ឬការមិនប្រតិបត្តិតាមដែលកើតមានក្នុងដំណើរការប្រតិបត្តិការជាប្រក្រតី តាមរយៈការដាក់ចេញនូវបែបបទរាយការណ៍ឯករាជ្យនិងសមស្រប និងការបង្កើតវិធានការពារចំពោះមន្ត្រីបុគ្គលិក ដែលបំពេញភារកិច្ចដោយសុចរិតនិងដើម្បីផលប្រយោជន៍របស់គ្រឹះស្ថានទាំងមូល។

ជំពូក ២
រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
ប្រការ ៤.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់

៤.១. ក្រុមប្រឹក្សាភិបាលមានភារកិច្ចបង្កើតក្របខ័ណ្ឌទូទៅសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសមស្រប អនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ។ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ក្នុងគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព ហើយត្រូវរាយតម្លៃប្រចាំគ្រា និងកែលម្អ បើចាំបាច់។

៤.២. ក្រុមប្រឹក្សាភិបាលត្រូវបង្កើតគណៈកម្មការជាន់ខ្ពស់ ដែលស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន តែងតាំងសមាជិកភាព កំណត់ច្បាស់លាស់នូវមុខងារភារកិច្ចរបស់គណៈកម្មការទាំងនោះ និងលក្ខខណ្ឌផ្សេងៗដែលប្រធានគណៈកម្មការត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។ ក្រៅពីគណៈកម្មការដែលបានកំណត់នៅក្នុងប្រកាសស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលត្រូវពិចារណាបង្កើតគណៈកម្មការផ្សេងទៀត បើចាំបាច់ ឱ្យស្របតាមភាពស្មុគស្មាញ ទំហំប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ក្នុងគោលដៅទទួលយកនិងគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន។

៤.៣. គោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ត្រូវមានចែងផងដែរអំពីលក្ខខណ្ឌសម្រាប់ការអនុវត្តសកម្មភាពថ្មី ការផ្តល់សេវាកម្មថ្មី ឬការចូលរួមភាគកម្មផ្នែកហិរញ្ញវត្ថុថ្មីរបស់គ្រឹះស្ថាន។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវលើដំណើរការរាយតម្លៃហានិភ័យជាដំបូងនេះ និងក្នុងករណីចាំបាច់ត្រូវពិភាក្សាក្នុងគណៈកម្មការផលិតផលថ្មី និងសកម្មភាពថ្មី (New Activities and Products Committee) ផងដែរ ក្នុងគោលដៅធានាភាពសមស្រប និងសមត្ថភាពរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដំណើរការគ្រប់គ្រងហានិភ័យ មុខងារគណនេយ្យ និងការរាយការណ៍ ព្រមទាំងនីតិវិធីប្រតិបត្តិតាមមុននឹងអនុវត្តសកម្មភាពថ្មី និងការចូលរួមភាគកម្មថ្មីទាំងនេះ។

រាល់ការវាយតម្លៃនិងអនុសាសន៍ពាក់ព័ន្ធ ត្រូវបានធ្វើឡើងជាផ្លូវការ និងដាក់ជូនក្រុមប្រឹក្សាភិបាល។ កំណត់ហេតុប្រជុំរបស់គណៈកម្មការទាំងឡាយត្រូវតែបានរក្សាទុកជាឯកសារ និងផ្ញើជូនអាជ្ញាធរត្រួតពិនិត្យ សវនករផ្ទៃក្នុង និងសវនករឯករាជ្យ តាមការស្នើសុំ។

ប្រសិនបើអនុសាសន៍នោះលើកឡើងអំពីលក្ខខណ្ឌដំបូងដែលត្រូវបំពេញ ឬអំពីដំណាក់កាលសាកល្បង គោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងត្រូវតែមានចែងនូវនីតិវិធីផ្សេងៗ សម្រាប់វាយតម្លៃលើប្រសិទ្ធភាព មុននឹងអនុវត្តសកម្មភាពថ្មីនិងផ្តល់សេវាកម្មថ្មី ព្រមទាំងមុននឹងអនុវត្តផែនការវិនិយោគតាមរយៈការចូលរួមភាគកម្មហិរញ្ញវត្ថុ ឬបង្កើតបុត្តសម្ព័ន្ធ។ ដំណើការគ្រប់គ្រងហានិភ័យនិងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងត្រូវធ្វើឡើងនៅកម្រិតគួបសរុប ក្នុងករណីបុត្តសម្ព័ន្ធ និងការចូលរួមភាគកម្ម។ ជាពិសេសទៅទៀត ផលប៉ះពាល់ជាសក្តានុពលលើស្ថានភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងសាធនភាពនិងសាច់ប្រាក់ងាយស្រួល ត្រូវតែបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន និងទាមទារការយកចិត្តទុកដាក់ខ្ពស់ពីក្រុមប្រឹក្សាភិបាល។

៥.៤. ជាគោលការណ៍ទូទៅ ប្រធានគណៈកម្មការជាន់ខ្ពស់ដែលទទួលបន្ទុកការងារត្រួតពិនិត្យផ្ទៃក្នុង សវនកម្មផ្ទៃក្នុង ការបង្កើតផលិតផលថ្មីនិងសកម្មភាពថ្មី ការគ្រប់គ្រងហានិភ័យ និងគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ដែលមិនពាក់ព័ន្ធនឹងការគ្រប់គ្រងឬការអភិវឌ្ឍអាជីវកម្ម ឬប្រតិបត្តិការប្រចាំថ្ងៃរបស់គ្រឹះស្ថាន។ រចនាសម្ព័ន្ធ និងការជ្រើសរើសប្រធានគណៈកម្មការនីមួយៗ ត្រូវតែបានធ្វើឡើងដោយពិចារណាជានិច្ចដល់ទំនាស់ផលប្រយោជន៍ជាសក្តានុពល និងត្រូវបម្រើគោលបំណងផ្តល់ព័ត៌មានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពជូនក្រុមប្រឹក្សាភិបាល និងជួយទ្រទ្រង់ដល់ការសម្រេចចិត្តដ៏ត្រឹមត្រូវ។

៥.៥. ក្រុមប្រឹក្សាភិបាលត្រូវរៀបចំផងដែរនូវគោលនយោបាយទទួលយកហានិភ័យ ដែលត្រូវតែបានពិនិត្យឡើងវិញដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និងលើចាំបាច់ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមគ្រឹះស្ថាន ឬគ្រឹះស្ថានកុងគ្លូមេរ៉ាហិរញ្ញវត្ថុ និងការអភិវឌ្ឍទីផ្សារ។ ជាពិសេស គោលនយោបាយទាំងនេះត្រូវកំណត់អំពីសកម្មភាពហាមឃាត់ គោលការណ៍ទទួលយក និងបញ្ចៀសហានិភ័យ (risk tolerance and aversion principles) ជាបឋមក្រោមរូបភាពជាខែលហានិភ័យសាច់ប្រាក់ងាយស្រួល និងសាធនភាពអប្បបរមា (solvency buffers) កម្រិតកំណត់លើហានិភ័យប្រមូលផ្តុំ និងគោលនយោបាយដោះស្រាយស្ថានភាពវិបត្តិ (ផែនការយថាភាព)។ គោលនយោបាយទាំងនេះត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រា ហើយមន្ត្រីមុខងារប្រតិបត្តិតាម (compliance functions) ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវការវាយតម្លៃ ដែលមានគោលដៅដើម្បីធានានូវការយល់ច្បាស់លាស់ និងការអនុវត្តបានពេញលេញនូវគោលនយោបាយនោះ។

៥.៦. ក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវក្នុងការផ្តល់ធនធានមនុស្សគ្រប់គ្រាន់ និងមានគុណវុឌ្ឍិដើម្បីបំពេញតួនាទីត្រួតពិនិត្យផ្ទៃក្នុងនេះជាអចិន្ត្រៃយ៍និងប្រចាំគ្រា។ ក្នុងគោលដៅទទួលយក និងគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន ធនធានទាំងនេះត្រូវឱ្យស្របតាមភាពស្មុគស្មាញ ទំហំប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធានាដែរថា សវនកម្មផ្ទៃក្នុងអាចប្រព្រឹត្តិទៅដោយឯករាជ្យតាមរយៈ ១) ការមានបុគ្គលិកគ្រប់គ្រាន់ ២) ការមានលទ្ធភាពពេញលេញក្នុងការទទួលបានព័ត៌មាននិងទិន្នន័យចាំបាច់សម្រាប់បំពេញបេសកកម្មរបស់ខ្លួនក្នុងគ្រឹះស្ថានទាំងមូល និង ៣) ការបំពាក់នូវបច្ចេកវិទ្យាព័ត៌មានសមស្រប លទ្ធភាពប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ការបណ្តុះបណ្តាល ធនធានសម្រាប់រៀបចំវិធីសាស្ត្រនិងផែនការសវនកម្ម។

ប្រការ ៥.- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង៖ ការត្រួតពិនិត្យអចិន្ត្រៃយ៍ និងប្រចាំគ្រា

៥.១. ក្រុមប្រឹក្សាភិបាល ឬគណៈដែលមានឋានៈស្មើ ត្រូវអនុម័តគោលនយោបាយ និងរចនាសម្ព័ន្ធជារួម ពាក់ព័ន្ធនឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន។ ប្រព័ន្ធនេះត្រូវមានបញ្ជូលទាំងមុខងារត្រួតពិនិត្យជាអចិន្ត្រៃយ៍ និងប្រចាំគ្រា។

៥.២. ការត្រួតពិនិត្យអចិន្ត្រៃយ៍ត្រូវបានបង្កើតនិងរៀបចំឡើង ដើម្បីត្រួតពិនិត្យជាប្រចាំនូវ៖

ក. ការប្រតិបត្តិតាមច្បាប់និងបទបញ្ជាជាធរមាន បទដ្ឋានវិជ្ជាជីវៈនិងក្រមសីលធម៌និងបទបញ្ជាដោយឡែកផ្សេងទៀតចេញដោយអាជ្ញាធរទីផ្សារ ដែលទាក់ទងនឹង

សកម្មភាពធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយ និងការណែនាំផ្សេងៗរបស់គណៈមានសិទ្ធិសម្រេច (decision-making body)។

ខ. អត្ថិភាពនិងប្រសិទ្ធភាពនៃនីតិវិធីនិងដំណើរការ ដើម្បីចៀសវាង ឬដោះស្រាយស្ថានភាពទំនាស់ផលប្រយោជន៍ បើចាំបាច់។

គ. ការអនុមតិ សុវត្ថិភាព និងការធ្វើសុពលភាពនៃប្រតិបត្តិការដែលបានបញ្ចប់ស្របតាមគោលនយោបាយ នីតិវិធី និងដំណើរការដែលមានស្រាប់ ពាក់ព័ន្ធនឹងសិទ្ធិអំណាច ការបែងចែកភារកិច្ច និងឯករាជ្យភាពនៃការសម្រេចចិត្ត និងការពិនិត្យឡើងវិញ។

ឃ. ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនិងនីតិវិធីផ្ទៃក្នុងជាក់លាក់ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ ការវាស់វែង កម្រិតកំណត់ និងការតាមដាន នូវរាល់ប្រភេទហានិភ័យដែលពាក់ព័ន្ធនឹងសកម្មភាពនិងប្រតិបត្តិការរបស់គ្រឹះស្ថាន។

៥.៣. គ្រឹះស្ថានត្រូវមានធនធានមនុស្សសមរម្យទាំ ងបរិមាណនិងគុណភាព រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផងដែរ សម្រាប់ការត្រួតពិនិត្យអចិន្ត្រៃយ៍ ដែលត្រូវតែបានអនុវត្តតាមរយៈការចាត់តាំង ដូចតទៅ៖

ក. មន្ត្រីបុគ្គលិកដែលមានឋានានុក្រមសមស្របនឹងរចនាសម្ព័ន្ធចាត់តាំង ដោយមានការទទួលខុសត្រូវត្រួតពិនិត្យច្បាស់លាស់ និងមិនមានទំនាស់ផលប្រយោជន៍ជាមួយការទទួលខុសត្រូវផ្នែកប្រតិបត្តិការផ្សេងទៀតរបស់គ្រឹះស្ថាន ឬ

ខ. មន្ត្រីបុគ្គលិកដែលមានភារកិច្ចអនុវត្តតែការត្រួតពិនិត្យអចិន្ត្រៃយ៍ប៉ុណ្ណោះ ហើយដែលត្រូវការរាយការណ៍ដោយផ្ទាល់ ឬដោយប្រយោល តែដោយឯករាជ្យភាពជូនសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យម្នាក់ ឬគណៈមានហាន:ស្មើ ឬ

គ. មន្ត្រីបុគ្គលិកដែលមានភារកិច្ចផ្នែកប្រតិបត្តិការ ដែលភារកិច្ចនោះពុំមានទំនាស់ផលប្រយោជន៍ជាមួយមុខងារត្រួតពិនិត្យ និងដែលបានចែកដាច់ដោយឡែក និងច្បាស់លាស់ពីមុខងារប្រតិបត្តិការ ឬ

ឃ. បន្សំណាមួយនៃវិធីទាំងបីខាងលើដែលសមស្របតាមប្រភេទ ភាពស្មុគស្មាញ និងទំហំហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃ និងដោយអាស្រ័យលើរចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន។

៥.៤. សវនកម្មផ្ទៃក្នុងត្រូវអនុវត្តការត្រួតពិនិត្យប្រចាំគ្រា ដែលត្រូវមានឯករាជ្យភាពពីមុខងារត្រួតពិនិត្យអចិន្ត្រៃយ៍ និងពីផ្នែកប្រតិបត្តិការ។ លើសពីនេះ សវនកម្មផ្ទៃក្នុងមិនត្រូវទទួលខុសត្រូវលើការងារណាដែលមានទំនាស់ផលប្រយោជន៍ និងអាចរំខានដល់ឯករាជ្យភាពនៃការរាយតម្លៃឡើយ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ទៅប្រធានគណៈកម្មការសវនកម្ម។

៥.៥. គ្រឹះស្ថានត្រូវស្នើសុំការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា មុននឹងធ្វើការតែងតាំងជាផ្លូវការនូវប្រធានសវនកម្មផ្ទៃក្នុង និងប្រធានមុខងារប្រតិបត្តិតាម ដោយត្រូវភ្ជាប់មកជាមួយ

នូវប្រវត្តិរូប ការពិពណ៌នាលម្អិតអំពីសាវតា វិជ្ជាជីវៈ និងបទពិសោធន៍ វិញ្ញាបនបត្របញ្ជាក់ការសិក្សា ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត។ ធនាគារជាតិនៃកម្ពុជា អាចជូនដំណឹងអំពីការបដិសេធរបស់ខ្លួន ចំពោះការតែងតាំងនោះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលឯកសារត្រឹមត្រូវពេញលេញស្តីពីការតែងតាំង។ ធនាគារជាតិនៃកម្ពុជា មានសិទ្ធិធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយ ឬលើកសំណើផ្សេងៗទៅកាន់ប្រធានសវនកម្មផ្ទៃក្នុងនិងប្រធានមុខងារប្រតិបត្តិតាម។ រាល់ការផ្លាស់ប្តូរ បញ្ឈប់ ឬបណ្តេញចេញ នូវប្រធានសវនកម្មផ្ទៃក្នុង និងប្រធានមុខងារប្រតិបត្តិតាម ត្រូវតែបានជូនដំណឹងជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ហើយសេចក្តីសម្រេចនេះត្រូវតែបានធ្វើឡើងដោយមានហេតុផលសមរម្យ (duly motivated) និងត្រូវរាយការណ៍ច្បាស់លាស់ជូនធនាគារជាតិនៃកម្ពុជា។

៥.៦. ចំពោះក្រុមហិរញ្ញវត្ថុនិងកុងគ្លូមេរ៉ាហិរញ្ញវត្ថុ មន្ត្រីបុគ្គលិកទទួលបន្ទុកសវនកម្មផ្ទៃក្នុងនិងមុខងារប្រតិបត្តិតាមនៅកម្រិតគួបសរុបត្រូវមានកាតព្វកិច្ចរាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌ ៥.៥ ខាងលើ។ របាយការណ៍ទាំងនេះត្រូវតែមានភ្ជាប់ជាមួយនូវរចនាសម្ព័ន្ធចាត់តាំង គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ដែលអាចងាយយល់អំពីបែបបទរាយការណ៍ និងអំពីទំនាក់ទំនងជាមួយមន្ត្រីបុគ្គលិកទទួលបន្ទុកដទៃទៀតរបស់ស្ថាប័នផ្សេងៗ ដែលស្ថិតនៅក្នុងក្រុមគ្រឹះស្ថាន ឬកុងគ្លូមេរ៉ាហិរញ្ញវត្ថុជាមួយគ្នា។

ជំពូក ៣
សេវាកម្មផ្តល់ដោយតតិយភាគី

ប្រការ ៦.- សេវាកម្មផ្តល់ដោយតតិយភាគី ដែលមិនមែនជាសវនកម្មផ្ទៃក្នុង

៦.១. សេវាកម្មដែលផ្តល់ដោយតតិយភាគី (Outsourced activities and services) ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ត្រូវ៖

ក. ស្ថិតក្រោមការត្រួតពិនិត្យលើការប្រតិបត្តិតាម ដើម្បីធានាថាសកម្មភាពទាំងនេះមិនត្រូវបានហាមឃាត់ដោយច្បាប់ឬបទបញ្ជាណាមួយឬដោយគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។

ខ. មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរវាងតតិយភាគីនិងគ្រឹះស្ថាន។

គ. បានអនុវត្តក្នុងក្របខ័ណ្ឌគោលនយោបាយផ្លូវការមួយ ស្តីពី ការត្រួតពិនិត្យអ្នកផ្តល់សេវាកម្មជាតតិយភាគីរបស់គ្រឹះស្ថាន។

៦.២. ក្នុងទំនាក់ទំនងជាមួយអ្នកផ្តល់សេវាកម្មជាតតិយភាគី គ្រឹះស្ថានត្រូវធានាថា តតិយភាគីនោះ

ក. ធានាកម្រិតគុណភាពដែលឆ្លើយតបនឹងប្រតិបត្តិការធម្មតានៃសេវាកម្ម ហើយក្នុងករណីមានហេតុការណ៍កើតឡើង តតិយភាគីត្រូវប្រើប្រាស់នីតិវិធី និងយន្តការយថាភាព (Contingency procedures and mechanisms) សំដៅផ្តល់សេវាកម្មឡើងវិញក្នុងរយៈពេលមួយដែលគ្រឹះស្ថានអាចទទួលយកបាន។

ខ. អនុវត្តយន្តការបន្ទាន់ (emergency mechanisms) ក្នុងករណីមានការលំបាកធ្ងន់ធ្ងរ ប៉ះពាល់ដល់និរន្តភាពនៃសេវាកម្ម ឬគ្រឹះស្ថានត្រូវធានាថាផែនការនិរន្តភាពរបស់ខ្លួនបានគិតគូរទៅដល់សេណារីយ៉ូ ដែលក្នុងនោះតតិយភាគីគ្មានលទ្ធភាពផ្តល់សេវាដល់គ្រឹះស្ថានឡើងវិញបាន។

គ. មិនត្រូវកែប្រែធំដុំលើសេវាកម្មរបស់ខ្លួន ដោយគ្មានការយល់ព្រមជាមុនពីគ្រឹះស្ថានឡើយ និងក្នុងរយៈពេលសមស្របមួយដែលចាំបាច់សម្រាប់ចាត់វិធានការជំនួស។

ឃ. ប្រតិបត្តិតាមនីតិវិធីរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងការអនុវត្តការត្រួតពិនិត្យសេវាកម្មដែលផ្តល់ដោយតតិយភាគី។

ង. ផ្តល់ដល់គ្រឹះស្ថាននូវរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់អំពីសេវាកម្មរបស់ខ្លួន បើចាំបាច់ ហើយគ្រឹះស្ថានអាចចុះពិនិត្យដល់ទីកន្លែង ស្របតាមកាតព្វកិច្ចបើកចំហព័ត៌មានដែលបានកំណត់។

ច. ត្រូវរាយការណ៍ទៅគ្រឹះស្ថានជាប្រចាំអំពីដំណើរការផ្តល់សេវាកម្ម និងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

ឆ. ផ្តល់ដល់ធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មានចាំបាច់ ទាក់ទិននឹងការអនុវត្តភារកិច្ចរបស់ខ្លួន ហើយក្នុងករណីចាំបាច់ធនាគារជាតិនៃកម្ពុជាអាចធ្វើការត្រួតពិនិត្យ និងសម្ភាសន៍ផ្ទាល់នៅទីស្នាក់ការរបស់តតិយភាគី។

៦.៣. ផ្អែកលើការវាយតម្លៃហានិភ័យរបស់ខ្លួន សវនកម្មផ្ទៃក្នុងត្រូវធ្វើសវនកម្មឡើងវិញតាមគ្រា ដោយផ្តោតជាសំខាន់លើសេវាកម្មរបស់តតិយភាគី។ ភាពញឹកញាប់នៃសវនកម្មនេះត្រូវអាស្រ័យទៅនឹងហានិភ័យពាក់ព័ន្ធផ្សេងៗរបស់គ្រឹះស្ថាន។ ជាពិសេស ការប្រតិបត្តិតាមបទប្បញ្ញត្តិដូចបានកំណត់ខាងលើ ត្រូវតែបានវាយតម្លៃជាក់លាក់ រួមទាំងអត្ថិភាព សង្គតិភាព និងប្រសិទ្ធភាពនៃយន្តការបន្ទាន់ និងផែនការយថាភាពផងដែរ។

ប្រការ ៧.- សេវាកម្មតតិយភាគីចំពោះការធ្វើសវនកម្មផ្ទៃក្នុង

៧.១. ចំពោះគ្រឹះស្ថានខ្នាតតូចដែលស្ថិតនៅក្នុងក្រុមធនាគារ ឬក្រុមហិរញ្ញវត្ថុមួយ ក្រុមប្រឹក្សាភិបាលក្រោមការទទួលខុសត្រូវរបស់ខ្លួន អាចពិចារណាជ្រើសរើសតតិយភាគីសម្រាប់ការងារសវនកម្មផ្ទៃក្នុង។ ប៉ុន្តែតតិយភាគីនេះមិនត្រូវជាក្រុមហ៊ុនសវនកម្មឯករាជ្យដែលទទួលបន្ទុកធ្វើសវនកម្មលើគ្រឹះស្ថាននោះ ឬជាសម្ព័ន្ធរបស់ក្រុមហ៊ុននោះឡើយ។ មុននឹងជ្រើសរើសក្រុមហ៊ុនឯកទេសឬនាយកដ្ឋានសវនកម្មនៃក្រុមហ៊ុនមេរបស់ខ្លួនសម្រាប់ដំណើរការសវនកម្ម គ្រឹះស្ថានត្រូវតែសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវទិន្នន័យ និងព័ត៌មានចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្ត។

៧.២. នៅពេលសម្រេចជ្រើសរើសតតិយភាគីសម្រាប់ធ្វើសវនកម្មផ្ទៃក្នុង សមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលបន្ទុកត្រូវធានាថា៖

ក. សេវាកម្មដែលតតិយភាគីផ្តល់ឱ្យគ្រឹះស្ថានសមស្របនឹងសកម្មភាព រចនាសម្ព័ន្ធ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់គ្រឹះស្ថាន។

ខ. សវនកម្មត្រូវអនុវត្តស្របតាមបទដ្ឋានល្អបំផុតនៃទីផ្សារ និងដោយអ្នកមានវិជ្ជាជីវៈដែលមានការសិក្សា ជំនាញ និងបទពិសោធន៍ក្នុងការធ្វើសវនកម្ម។

គ. ថវិកាគ្រប់គ្រាន់ សម្រាប់ធ្វើសវនកម្មផ្ទៃក្នុង ដើម្បីធានាការគោរពតាមរាល់គោលការណ៍ ដូចដែលបានកំណត់ក្នុងប្រកាសនេះ ជាពិសេស ដើម្បីធានាឯករាជ្យភាពពេញលេញនៃសវនកម្ម ការវាយតម្លៃ និងអនុសាសន៍ និង

ឃ. តតិយភាគីមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើសវនកម្មលើគ្រប់ផ្នែកទាំងអស់នៃមុខងារ និងប្រតិបត្តិការ ស្របតាមផែនការសវនកម្មគ្រប់ជ្រុងជ្រោយ ដែលគ្របដណ្តប់លើរាល់ហានិភ័យ និងដែលតម្រូវដោយបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងប្រកាសនេះ ស្តីពីវដ្តនិងវិសាលភាពនៃសវនកម្ម។

៧.៣. លើសពីនេះ រាល់កាតព្វកិច្ចដូចមានចែងក្នុងប្រការ ៦ ពាក់ព័ន្ធនឹងសកម្មភាពរបស់តតិយភាគីត្រូវតែបានគោរពតាមយ៉ាងម៉ឺងម៉ាត់ ពីព្រោះសវនកម្មផ្ទៃក្នុងត្រូវបានចាត់ទុកថាជាសកម្មភាពសំខាន់ដូចមានចែងក្នុងប្រការ ៣។ ជាពិសេស ផែនការយថាភាពសមស្របត្រូវមានចែងអំពីដំណោះស្រាយដទៃទៀត ដើម្បីចៀសវាងការបង្ខាក់ ឬការពន្យារណាមួយ ក្នុងការបំពេញផែនការសវនកម្ម ក្រោមការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលទទួលបន្ទុក។

ជំពូក ៤
ការប្រតិបត្តិតាម

ប្រការ ៨.- ការតែងតាំង និងការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាម

៨.១ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តរចនាសម្ព័ន្ធនៃមុខងារប្រតិបត្តិតាម (Compliance Function) ឱ្យបានសមស្រប ដើម្បីគាំទ្រដល់ការបំពេញភារកិច្ច និងការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព ស្របតាមទំហំ ភាពស្មុគស្មាញ បណ្តាញ ការចូលភាគកម្ម និងហានិភ័យពាក់ព័ន្ធនឹងអាជីវកម្មរបស់គ្រឹះស្ថាន។ មុខងារប្រតិបត្តិតាមត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាមម្នាក់ដែលមិនពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ជាសក្តានុពល។ មន្ត្រីមុខងារប្រតិបត្តិតាមត្រូវរាយការណ៍ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក។

៨.២. ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ឈប់ ការបណ្តេញចេញ ឬការលាលែងរបស់មន្ត្រីមុខងារប្រតិបត្តិតាម ត្រូវតែបានជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងចំណុច ៥.៥ និង ៥.៦ នៃប្រការ ៥។

៨.៣. មន្ត្រីបុគ្គលិកទទួលបន្ទុកត្រួតពិនិត្យអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងគោលនយោបាយ "ស្គាល់អតិថិជនរបស់ខ្លួន" ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ត្រីមុខងារប្រតិបត្តិតាម។ អាស្រ័យលើរចនាសម្ព័ន្ធនៃមុខងារប្រតិបត្តិតាមគោលនយោបាយនិងនីតិវិធី ត្រូវតែអាចជួយគាំទ្រយ៉ាងពេញលេញចំពោះកិច្ចសហការរវាងមន្ត្រី

មុខងារប្រតិបត្តិតាមនិងមន្ត្រីបុគ្គលិក ព្រមទាំងផ្នែកដទៃទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យការប្រតិបត្តិតាម ដូចជានាយកដ្ឋានហិរញ្ញវត្ថុ និងការរាយការណ៍គណនេយ្យ និងគតិយុត្ត ជាដើម។ មន្ត្រីមុខងារប្រតិបត្តិតាមត្រូវតែចូលរួមជាប្រព័ន្ធក្នុងការអនុវត្តនីតិវិធី វីស្សលប្លុីង (whistle blowing) ដូចមានចែងក្នុងប្រការ ១១។

ប្រការ ៩.- ប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាម

៩.១. ប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាមត្រូវតែបានបង្កើត និងរៀបចំឱ្យស្របតាមគោលនយោបាយ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវតែមានដំណើរការ និងនីតិវិធីសមស្របប្រកបដោយប្រសិទ្ធភាពក្រោមការទទួលខុសត្រូវរបស់មន្ត្រីមុខងារប្រតិបត្តិតាម ដូចមានចែងក្នុងប្រការ ៨។

៩.២. គ្រឹះស្ថានត្រូវផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់មន្ត្រីបុគ្គលិកដែលពាក់ព័ន្ធស្តីពីនីតិវិធីត្រួតពិនិត្យការប្រតិបត្តិតាមឱ្យស្របតាមប្រតិបត្តិការ និងការត្រួតពិនិត្យដែលមន្ត្រីទាំងនោះអនុវត្ត។

៩.៣. ប្រព័ន្ធនិងនីតិវិធីត្រួតពិនិត្យការប្រតិបត្តិតាមទាំងឡាយ ត្រូវតែបានរៀបចំឡើងដើម្បីទប់ស្កាត់ហានិភ័យនៃការមិនប្រតិបត្តិតាម ដូចមានចែងក្នុងប្រការ ៣ និងដើម្បីដោះស្រាយឱ្យបានឆាប់បំផុតនូវបញ្ហា ឬការបារម្ភអំពីការមិនប្រតិបត្តិតាមជាសក្តានុពលណាមួយ។ ក្នុងគោលបំណងនេះ គ្រឹះស្ថានត្រូវបង្កើតនីតិវិធីនិងដំណើរការសម្រាប់វាយតម្លៃការប្រតិបត្តិតាមដែលរួមមាន៖

- នីតិវិធីសម្រាប់ការផ្តល់ការអនុមតិជាមុននិងជាប្រព័ន្ធ រួមទាំងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីមន្ត្រីមុខងារប្រតិបត្តិតាម ឬពីបុគ្គលទទួលសិទ្ធិពីមន្ត្រីមុខងារប្រតិបត្តិតាមក្នុងគោលបំណងនេះ ចំពោះផលិតផលថ្មីនិងសកម្មភាពថ្មី ការអនុវត្ត ឬការកែប្រែសំខាន់ៗទៅលើផលិតផលនិងសេវាកម្មដែលមានស្រាប់ និង
- នីតិវិធីសម្រាប់ត្រួតពិនិត្យប្រតិបត្តិការ ដែលបានបញ្ចប់រួចហើយ។

៩.៤. ជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិតាម គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធតាមដានមួយអំពីការកែប្រែបទបញ្ជា ឬវិធានទាំងឡាយដែលត្រូវអនុវត្តទៅលើប្រតិបត្តិការរបស់គ្រឹះស្ថានដែលមានដំណើរការជាប្រក្រតី និងជាញឹកញាប់តាមដែលអាចអនុវត្តបាន ហើយក្នុងបរិការណ៍នេះជូនដំណឹងភ្លាមដល់មន្ត្រីបុគ្គលិកពាក់ព័ន្ធស្តីពីការកែប្រែទាំងនោះ។

ជំពូក ៥
ទំនាស់ផលប្រយោជន៍៖ ការទប់ស្កាត់ និងដំណោះស្រាយ

ប្រការ ១០.- នីតិវិធី និងយន្តការទប់ស្កាត់ទំនាស់ផលប្រយោជន៍

១០.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធីនិងយន្តការដើម្បីទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍។ នីតិវិធីនិងយន្តការទាំងនេះត្រូវពឹងផ្អែកជាពិសេសលើវិធាន និងគោលការណ៍ដ៏ច្បាស់លាស់ដែលត្រូវបានបង្កើតឡើង ដូចជាឯករាជ្យភាពនៃការត្រួតពិនិត្យ ការបែងចែកមុខងារភារកិច្ច ការប្រគល់សិទ្ធិ

និងគណនេយ្យភាពសមស្រប ឯករាជ្យភាពនៃដំណើរការផ្ទៀងផ្ទាត់គណនី ឬការចៀសវាងការលើកទឹកចិត្តជាអវិជ្ជមានក្រោមរូបភាពជាការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដែលអាចធ្វើឱ្យមានឥទ្ធិពលមិនល្អដល់ការគ្រប់គ្រងនិងការជ្រើសរើសហានិភ័យដោយប្រុងប្រយ័ត្ន ការកាន់កាប់មូលបត្រ ការត្រួតពិនិត្យលើគុណភាពទ្រព្យសកម្ម/ស្ថានភាពសាច់ប្រាក់ងាយស្រួលនិងអសាធនភាព ជាដើម។

១០.២. ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍ជាសក្តានុពល និងត្រូវវាយតម្លៃគោលនយោបាយនោះឡើងវិញប្រចាំគ្រា។ បើចាំបាច់គោលនយោបាយនេះត្រូវបានពិនិត្យឡើងវិញ និងកែលម្អស្របតាមការវាយតម្លៃប្រចាំគ្រានោះ។

១០.៣. មុខងារប្រតិបត្តិតាមត្រូវធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ និងនីតិវិធីទាំងនោះ និងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក នូវរាល់កំហុសឬបញ្ហាដែលបានរកឃើញ។ ហេតុការណ៍កើតឡើង ត្រូវមានកំណត់ត្រាជាឯកសារ ហើយត្រូវមានការផ្តល់អនុសាសន៍សម្រាប់ជាវិធានការកែតម្រូវផងដែរ។ រាល់វិធានការកែតម្រូវដែលបានដាក់ចេញត្រូវតែបានអនុវត្តតាមភ្លាមដោយគ្មានបង្អង់។

ប្រការ ១១.- នីតិវិធីវីស្សលប្លុងីង

១១.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធីវីស្សលប្លុងីង "Whistle Blowing Procedures" ដូចមានចែងក្នុងប្រការ ៣ ដែលត្រូវក្រសោបនូវតួនាទីរបស់មន្ត្រីមុខងារប្រតិបត្តិតាមផងដែរ ដែលត្រូវតែរក្សារបាយការណ៍ជាការសម្ងាត់ ជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក និងចាត់វិធានការដោះស្រាយសមស្រប។

១១.២. មន្ត្រីបុគ្គលិករបស់គ្រឹះស្ថានត្រូវយល់ដឹងច្បាស់លាស់អំពីដំណើរការ និងនីតិវិធីវីស្សលប្លុងីង និងត្រូវដឹងថា នីតិវិធីនោះផ្តល់ការការពារចំពោះខ្លួន ប៉ុន្តែ ក៏ទាមទារនូវការបំពេញភារកិច្ចដោយសុចរិតផងដែរ។

ជំពូក ៦
សវនកម្មផ្ទៃក្នុង

ប្រការ ១២.- រចនាសម្ព័ន្ធនៃសវនកម្មផ្ទៃក្នុង

១២.១. សវនកម្មផ្ទៃក្នុងត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង ដែលត្រូវបានចាត់តាំងស្របតាមបទប្បញ្ញត្តិនិងកាតព្វកិច្ចដូចមានចែងក្នុងចំណុច ៥.៥ និង ៥.៦ នៃប្រការ ៥ នៃប្រកាសនេះ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានឯករាជ្យភាពពេញលេញ រាយការណ៍ផ្ទាល់ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក និងមិនត្រូវមានភារកិច្ចត្រួតពិនិត្យអចិន្ត្រៃយ៍ ឬការងារប្រតិបត្តិការឡើយ។ ជាពិសេស ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវទទួលបន្ទុកលើមុខងារប្រតិបត្តិតាមទេ ហើយដូចនេះគឺពុំអាចមានតួនាទីពីរទន្ទឹមគ្នាជាមន្ត្រីមុខងារប្រតិបត្តិតាមរបស់គ្រឹះស្ថានឡើយ។

១២.២. ប្រសិនបើសវនកម្មផ្ទៃក្នុងត្រូវបានធ្វើឡើងដោយតតិយភាគី រាល់លក្ខខណ្ឌនៃការប្រើប្រាស់តតិយភាគីនោះ ត្រូវតែគោរពតាមកាតព្វកិច្ចដូចមានចែងក្នុងប្រការ ៧ និងគោលការណ៍ដូចមានចែងក្នុងជំពូកនេះ។

១២.៣. មុខងារសវនកម្មផ្ទៃក្នុងត្រូវតែមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់ទាំងបរិមាណនិងគុណភាព ស្របតាមទំហំ ភាពស្មុគស្មាញនៃអាជីវកម្ម និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ តាមករណីចាំបាច់ បែបបទវាយការណ៍ ការវាយតម្លៃការអនុវត្ត ការចាត់ចែងមន្ត្រីបុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងវិធីសាស្ត្រ និងនីតិវិធីសវនកម្ម ត្រូវធ្វើឡើងក្នុងកម្រិតជាក្រុម។

ប្រការ ១៣.- គោលបំណងនៃមុខងារសវនកម្មផ្ទៃក្នុង

១៣.១. សវនកម្មផ្ទៃក្នុង មានភារកិច្ចអនុវត្តការងារសវនកម្ម និងធ្វើការអង្កេតប្រចាំគ្រា និងគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងផ្តល់ដល់ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងនូវការវាយតម្លៃ និងអនុសាសន៍ ដោយមានឯកសារគាំទ្រលើចំណុចដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការកំណត់អត្តសញ្ញាណ វាស់វែង តាមដាន គ្រប់គ្រង ដាក់កម្រិតកំណត់ និងបើចាំបាច់ នីតិវិធីនិងដំណើរការកាត់បន្ថយហានិភ័យ។
- ប្រសិទ្ធភាពនៃនីតិវិធីនិងដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងភាពសមស្របនៃដំណើរការដែលបានបង្កើតឡើងដើម្បីទប់ស្កាត់ស្ថានភាពទំនាស់ផលប្រយោជន៍ ឬបើចាំបាច់ ដើម្បីដោះស្រាយស្ថានភាពនោះដោយប្រុងប្រយ័ត្ន និង
- ភាពសមស្របនិងប្រសិទ្ធភាពនៃការត្រួតពិនិត្យការប្រតិបត្តិតាម និងការគោរពពេញលេញ នូវគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។

១៣.២. ការងារសវនកម្ម ត្រូវមានផែនការប្រចាំឆ្នាំ និងត្រូវកំណត់អាទិភាពស្របតាមការវាយតម្លៃហានិភ័យរបស់សវនកម្មផ្ទៃក្នុង។ ផ្នែកហានិភ័យនិងអាទិភាពដែលបានកំណត់ ត្រូវកត់ត្រាទុកជាឯកសារ និងគាំទ្រដោយវិធីសាស្ត្រវាយតម្លៃហានិភ័យដ៏សមស្រប ដែលត្រូវដាក់ជូននិងអនុម័តដោយក្រុមប្រឹក្សាភិបាល ឬគណៈកម្មការសវនកម្ម។ ការងារសវនកម្ម ត្រូវប្រព្រឹត្តិទៅក្នុងអំឡុងវដ្តសវនកម្មមួយដែលមានរយៈពេលខ្លីតាមដែលអាចធ្វើបាន និងត្រូវគ្របដណ្តប់រាល់ផ្នែកហានិភ័យទាំងអស់របស់គ្រឹះស្ថាន។ ក្នុងអំឡុងវដ្តសវនកម្ម រាល់ផ្នែកហានិភ័យទាំងអស់ត្រូវតែបានធ្វើសវនកម្ម។ លើសពីនេះ ផ្នែកដែលមានហានិភ័យខ្ពស់ត្រូវរងសវនកម្មច្រើនដងនៅក្នុងវដ្តសវនកម្មទាំងមូល។

១៣.៣. រាល់បញ្ហា និងកង្វល់សំខាន់ៗពាក់ព័ន្ធនឹងសវនកម្ម ត្រូវមានកត់ត្រាជាឯកសារច្បាស់លាស់ ដោយមានភ្ជាប់ជាមួយនូវអនុសាសន៍ចំពោះក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសំដៅដោះស្រាយបញ្ហានោះប្រកបដោយប្រសិទ្ធភាព និងដោយគ្មានការពន្យារមិនសមហេតុផល។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃវិធានការកែតម្រូវតាមអនុសាសន៍ត្រូវស្ថិតនៅក្រោមយន្តការតាមដានមួយ និងតាមករណីចាំបាច់ត្រូវអនុវត្តជាបន្តដើម្បីវាយតម្លៃប្រសិទ្ធភាពនៃវិធានការណ៍កែតម្រូវទាំងនេះ។ អនុសាសន៍ដែលមិនទាន់បានអនុវត្ត ចាំបាច់ត្រូវរាយការណ៍ប្រចាំគ្រា និងយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុកដែលជាប្រធានសវនករផ្ទៃក្នុង និងទៅសមាជិកគណៈកម្មការសវនកម្មឯទៀតតាមការស្នើសុំរបស់ប្រធានគណៈកម្មការសវនកម្ម។

ប្រការ ១៤.- ធនធាន យុទ្ធសាស្ត្រ និងនីតិវិធីសវនកម្ម

១៤.១. សវនកម្មផ្ទៃក្នុងត្រូវមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់សម្រាប់អនុវត្តវដ្តសវនកម្មប្រកបដោយប្រសិទ្ធភាព។ សវនករផ្ទៃក្នុងត្រូវមានឋវិកាស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ចំណាយទាំងអស់ទាក់ទិននឹងការបណ្តុះបណ្តាលផ្នែកសវនកម្ម ដំណើរបេសកកម្ម និងចំណាយប្រើប្រាស់តតិយភាគីសម្រាប់បំពេញភារកិច្ចរបស់ខ្លួន។

១៤.២. ភាពគ្រប់គ្រាន់នៃមន្ត្រីបុគ្គលិកនិងទម្រង់សវនកម្មជាក់លាក់ ត្រូវបានវាយតម្លៃប្រចាំគ្រាស្របតាមកំណើនអាជីវកម្ម ភាពស្មុគស្មាញនិងទំហំនៃប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំងសាជីវកម្ម បច្ចេកវិទ្យាដែលបានអនុវត្តនិងហានិភ័យពាក់ព័ន្ធផ្សេងៗ។ ការវាយតម្លៃនេះត្រូវធ្វើឡើងជាផ្លូវការ និងត្រូវរាយការណ៍ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក។

១៤.៣. ការវាយតម្លៃហានិភ័យនិងសវនកម្ម ត្រូវធ្វើឡើងស្របតាមបទដ្ឋានវិជ្ជាជីវៈ និងតាមករណីចាំបាច់ ត្រូវពិនិត្យឡើងវិញស្របតាមការអនុវត្តដ៏ល្អបំផុត និងត្រូវបានទ្រទ្រង់ដោយវិធីសាស្ត្រ នីតិវិធី និងក្បួនណែនាំផ្សេងៗជាលាយលក្ខណ៍អក្សរ។ ឯកសារ និងវិធីសាស្ត្រទាំងនេះអាចត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មការសវនកម្ម សវនករឯករាជ្យ និងអាជ្ញាធរត្រួតពិនិត្យ តាមការស្នើសុំ។

ជំពូក ៧
គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ

ប្រការ ១៥.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

១៥.១. ក្រុមប្រឹក្សាភិបាលត្រូវបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យ សម្រាប់ទប់ទល់ប្រភេទហានិភ័យសំខាន់ៗកើតឡើងពីសកម្មភាព ភាពស្មុគស្មាញ និងទំហំរបស់គ្រឹះស្ថាន។ ការគោរពតាមគោលនយោបាយគ្រប់គ្រងហានិភ័យនេះជាប្រចាំ ត្រូវតែជាផ្នែកមួយនៃការត្រួតពិនិត្យរបស់មុខងារប្រតិបត្តិតាម ហើយគោលនយោបាយនេះក៏ជាផ្នែកមួយនៅក្នុងប្រព័ន្ធរក្សាទុកឯកសាររបស់គ្រឹះស្ថាន ដូចមានចែងក្នុងជំពូក ១០ ផងដែរ។

១៥.២. គណៈគ្រប់គ្រងត្រូវទទួលខុសត្រូវបង្កើតនីតិវិធី និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃដំណើរការសមស្រប សំដៅកំណត់អត្តសញ្ញាណ វាស់វែង តាមដាន ដាក់កម្រិតកំណត់ គ្រប់គ្រង និងតាមករណីចាំបាច់ កាត់បន្ថយហានិភ័យផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការ និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ នីតិវិធីនិងដំណើរការទាំងនេះត្រូវបានវាយតម្លៃ និងពិនិត្យឡើងវិញប្រចាំគ្រា ស្របតាមការអនុវត្តដ៏ល្អបំផុត ការអភិវឌ្ឍន៍ទីផ្សារ និងអាជីវកម្មថ្មី។ ភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការជាក់លាក់ដែលបានអនុវត្តត្រូវ បានវាយតម្លៃឡើងវិញជាប្រព័ន្ធ មុននឹងអនុវត្តសកម្មភាពថ្មី ចូលរួមភាគកម្មថ្មី ព្រមទាំងមុននឹងផ្តល់ផលិតផលនិងសេវាកម្មថ្មីដល់អតិថិជន និងសមភាគីទីផ្សាររបស់គ្រឹះស្ថាន។

ប្រការ ១៦.- ប្រសិទ្ធភាពនៃនីតិវិធី ដំណើរការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន

១៦.១. នីតិវិធី ដំណើរការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ត្រូវបានរៀបចំនិងបង្កើតឡើង ស្របតាមគោលការណ៍របស់ក្រុមប្រឹក្សាភិបាល នៅក្នុងគោលនយោបាយពាក់ព័ន្ធផ្សេងៗ និងត្រូវស្ថិតក្រោមការវាយតម្លៃការប្រតិបត្តិតាម និងក្នុងករណីចាំបាច់ ត្រូវបានពិនិត្យឡើងវិញផងដែរ។

១៦.២. ដើម្បីធានាប្រសិទ្ធភាព នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មាន ត្រូវ

ក. អាចកំណត់អត្តសញ្ញាណ វាស់វែង ឬវាយតម្លៃហានិភ័យបានត្រឹមត្រូវ។

ខ. ទ្រទ្រង់សេចក្តីសម្រេច ស្របតាមវេទយិតភាពនៃហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសចំពោះការវិវត្តជាអវិជ្ជមាននៃទីផ្សារ ស្ថានភាពហិរញ្ញវត្ថុមិនល្អរបស់កូនបំណុល ឬរបស់សមភាគី និងជាទូទៅចំពោះការយកចិត្តទុកដាក់ ដែលត្រូវមានក្នុងគោលបំណងគ្រប់គ្រងដ៏ប្រុងប្រយ័ត្ន ជាដើម។

គ. គូបសរុបហានិភ័យទាំងនោះ (Consolidation of such risks) ដើម្បីកំណត់អត្តសញ្ញាណតាមដាន និងគ្រប់គ្រងបញ្ហាហានិភ័យប្រមូលផ្តុំប្រកបដោយប្រសិទ្ធភាព។

ឃ. បានរៀបចំនិងអនុវត្តតាមដែលអាចទ្រទ្រង់ពេញលេញនូវការទទួលខុសត្រូវ និងគណនេយ្យភាព ស្របតាមសិទ្ធអំណាច ការប្រគល់សិទ្ធ និងកម្រិតកំណត់ដែលអនុវត្តបាន និង

ង. ផ្តល់សញ្ញាអាសន្នតាមហានានុក្រម និងជូនក្រុមប្រឹក្សាភិបាល អំពីការមិនអនុវត្តកម្រិតកំណត់ ឬការប្រើប្រាស់សិទ្ធិអំណាច និងការប្រគល់សិទ្ធលើសដែនកំណត់សំដៅចាត់វិធានការកែតម្រូវបន្ទាន់ តាមករណីចាំបាច់។

១៦.៣. ប្រសិទ្ធភាព និងភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មានត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រាជាឯករាជ្យដោយសវនករផ្ទៃក្នុង ក្រោមការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងជាន់ខ្ពស់។ តាមករណីចាំបាច់ នីតិវិធីនិងដំណើរការ និងប្រព័ន្ធព័ត៌មានទាំងនេះត្រូវជួយដល់ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពនៅកម្រិតគូបសរុបផងដែរ។

១៦.៤. ភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មាន ត្រូវបានវាយតម្លៃឡើងវិញជាប្រព័ន្ធ មុននឹងអនុវត្តសកម្មភាពថ្មី ចូលរួមភាគកម្មថ្មី ព្រមទាំងមុននឹងផ្តល់ផលិតផលនិងសេវាកម្មថ្មីដល់អតិថិជននិងសមភាគីទីផ្សាររបស់គ្រឹះស្ថាន។

១៦.៥. ឯកសារស្តីពីនីតិវិធីនិងដំណើរការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធព័ត៌មាន ត្រូវតែបានធ្វើបច្ចុប្បន្នកម្ម និងជាផ្នែកមួយនៃប្រព័ន្ធរក្សាទុកឯកសារ ដូចមានចែងក្នុងជំពូក ១០ ខាងក្រោម។

ជំពូក ៨
ប្រព័ន្ធគណនេយ្យនិងព័ត៌មាន

ប្រការ ១៧.- ការប្រតិបត្តិតាមបទដ្ឋានច្បាប់និងបទប្បញ្ញត្តិ និងការរក្សាទុកឯកសារ

១៧.១. គ្រឹះស្ថានត្រូវប្រតិបត្តិតាមបទដ្ឋានច្បាប់និងបទប្បញ្ញត្តិដែលអនុវត្ត ចំពោះកិច្ចបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងការបើកចំហរព័ត៌មានហិរញ្ញវត្ថុ ព្រមទាំងត្រូវមានការត្រួតពិនិត្យសមស្រប ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការប្រតិបត្តិតាមបទដ្ឋានទាំងនេះ។ គណៈកម្មការសវនកម្មត្រូវពិភាក្សា និងអនុម័តដោយប្រុងប្រយ័ត្ននូវជម្រើសផ្សេងៗ ប្រសិនបើមាន ហើយជម្រើសនោះត្រូវបានទុកដាក់ជាឯកសារត្រឹមត្រូវ និងត្រូវគោរពតាមយ៉ាងហ្មត់ចត់។

១៧.២. គ្រឹះស្ថានត្រូវបង្កើតនិងរក្សាទុកឱ្យបានគ្រប់គ្រាន់ នូវឯកសារអំពីប្លង់គណនីដែលបានអនុវត្ត កិច្ចបញ្ជិកាគណនេយ្យសម្រាប់កត់ត្រាប្រតិបត្តិការ និងហេតុការណ៍ដែលនាំឱ្យមានកិច្ចបញ្ជិកាគណនេយ្យ ព្រមទាំងប្រព័ន្ធព័ត៌មានគណនេយ្យដែលបានអនុវត្ត។

ប្រការ ១៨.- ដំណើរការនិងនីតិវិធីនៃលំនាំសវនកម្ម ប្រកបដោយប្រសិទ្ធភាព

១៨.១. ចំពោះព័ត៌មានដែលបានបង្ហាញក្នុងតារាងតុល្យការ ក្រៅតារាងតុល្យការ របាយការណ៍ចំណូល-ចំណាយ និងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ការរៀបចំដំណើរការគណនេយ្យត្រូវបង្កើតនូវសំណុំនីតិវិធីនិងដំណើរការ ហៅថាលំនាំសវនកម្ម (audit trail) ដើម្បីអាច៖

ក. បង្កើតឡើងវិញនូវរាល់ប្រតិបត្តិការតាមលំដាប់លំដោយនៃពេលវេលា។

ខ. គាំទ្ររាល់ព័ត៌មានដោយឯកសារច្បាប់ដើម ដែលអនុញ្ញាតដល់ការរកដានប្រតិបត្តិការដោយផ្ទាល់ តាំងពីឯកសារដើមរហូតដល់ឯកសារសង្ខេប និងផ្ទុយមកវិញ។

គ. គិតគូរអំពីបម្រែបម្រួលនៃសមតុល្យ ពីកាលបរិច្ឆេទបិទបញ្ជីទៅថ្ងៃបន្ទាប់ដោយរក្សាទុកពេញលេញនូវកំណត់ត្រានៃប្រតិបត្តិការ ដែលនាំឱ្យមានបម្រែបម្រួលលើសមតុល្យគណនីទាំងនោះ។

១៨.២. ប្រសិទ្ធភាពនៃលំនាំសវនកម្ម ត្រូវតែបានសាកល្បង និងវាយតម្លៃប្រចាំគ្រា។

ប្រការ ១៩.- សន្និធិទ្រព្យសកម្មដែលគ្រឹះស្ថានកាន់កាប់ក្នុងនាមអតិថិជន និងតតិយភាគី

១៩.១. គ្រឹះស្ថានត្រូវបង្កើតនីតិវិធី និងរក្សាកំណត់ត្រាត្រឹមត្រូវ បង្ហាញអំពីសន្និធិ លំហូរចេញនិងលំហូរចូលនៃទ្រព្យសកម្ម ដែលគ្រឹះស្ថានបានកាន់កាប់ក្នុងនាមអតិថិជននិងតតិយភាគី ដូច្នេះទ្រព្យសម្បត្តិទាំងនោះមិនត្រូវបានកត់ត្រា ឬរាយការណ៍ជាទ្រព្យសម្បត្តិផ្ទាល់របស់គ្រឹះស្ថានទេ។

១៩.២. គ្រឹះស្ថានត្រូវញែកទ្រព្យសកម្មខាងលើ រវាងទ្រព្យសកម្មជាប្រាក់បញ្ញើ និងទ្រព្យសកម្មជាវត្ថុបញ្ចាំសម្រាប់ធានាការសន្យាដែលបានធ្វើឡើងក្នុងគោលបំណងជាក់លាក់ណាមួយ ឬសម្រាប់កិច្ចព្រមព្រៀងដែលជាប្រយោជន៍ដល់ម្ចាស់ប្រាក់បញ្ញើ។

ប្រការ ២០.- ការត្រួតពិនិត្យឯករាជ្យ ការបែងចែកមុខងារតួនាទីកិច្ច និងការផ្ទៀងផ្ទាត់ប្រចាំគ្រា

២០.១. គ្រឹះស្ថានត្រូវអនុវត្តនីតិវិធី និងដំណើរការ ដែលទ្រទ្រង់ដល់ការបែងចែកប្រកបដោយប្រសិទ្ធភាពនូវភារកិច្ច ការត្រួតពិនិត្យឯករាជ្យ និងការផ្ទៀងផ្ទាត់ប្រចាំគ្រា សំដៅការពារទ្រព្យសកម្មរបស់គ្រឹះស្ថាន និងដើម្បីកំណត់អត្តសញ្ញាណបានឆាប់រហ័សនូវរាល់ភាពខុសគ្នាសំខាន់ៗ។

២០.២. នីតិវិធីនិងដំណើរការទាំងនោះត្រូវបញ្ជាក់ជាពិសេស អំពីការបែងចែកច្បាស់លាស់នូវភារកិច្ចពាក់ព័ន្ធនឹងការសន្យា ការចំណាយមូលនិធិ និងកិច្ចបញ្ជិកាទ្រព្យសកម្មនិងទ្រព្យអកម្មរបស់គ្រឹះស្ថាន។ ដំណើរការនេះត្រូវតែបានផ្ទៀងផ្ទាត់ និងវាយតម្លៃឡើងវិញប្រចាំគ្រា។

២០.៣. នីតិវិធីនិងដំណើរការទាំងនេះត្រូវក្រសោបនូវតារាងត្រួតពិនិត្យ ការផ្ទៀងផ្ទាត់គណនី ការពិនិត្យនិងថ្លឹងថ្លែង (ការត្រួតពិនិត្យទ្វេដង ការធ្វើសុពលភាពដោយឯករាជ្យនៃការចុះបញ្ជិកាគណនេយ្យ ការចុះហត្ថលេខាពីរូមគ្នា ឬដំណើរការប្រហាក់ប្រហែលផ្សេងទៀតនៅក្នុងប្រព័ន្ធគណនេយ្យ) ការត្រួតពិនិត្យឡើងវិញដោយល្អិតល្អន់លើទ្រព្យសកម្មជាសន្និធិ ព្រមទាំងព័ត៌មានអំពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនោះ ដែលត្រូវផ្តល់ជូនគណៈគ្រប់គ្រង។ រាល់ភាពខុសគ្នាត្រូវតែបានអង្កេតស្លាម កត់ត្រាទុកជាឯកសារ និងដោះស្រាយដោយប្រុងប្រយ័ត្ន។ បើចាំបាច់ គ្រឹះស្ថានត្រូវពិចារណាស្លាមអំពីផលប៉ះពាល់នៃភាពខុសគ្នានេះ ទៅលើចំណូលដែលបានរាយការណ៍ និងមូលនិធិផ្ទាល់សុទ្ធដែលត្រូវតែកែតម្រូវជាបន្ទាន់។

ជំពូក ៩
ប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ

ប្រការ ២១.- ប្រសិទ្ធភាពនៃប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ

២១.១. គ្រឹះស្ថានត្រូវបង្កើតប្រព័ន្ធវាស់វែងនិងវិភាគហានិភ័យ ស្របតាមប្រភេទនិងទំហំប្រតិបត្តិការ និងភាពស្មុគស្មាញនៃសកម្មភាពរបស់គ្រឹះស្ថាន។ ប្រព័ន្ធនេះត្រូវតែអាចវាយតម្លៃឱ្យបានទាន់ពេលវេលានិងជឿទុកចិត្តបាន ចំពោះរាល់ប្រភេទហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ និងបើចាំបាច់ ហានិភ័យទីផ្សារ ហានិភ័យអន្តរការិយកម្ម ហានិភ័យប្រគល់ និងហានិភ័យទូទាត់។

២១.២. បើចាំបាច់ ប្រព័ន្ធនេះត្រូវបានរៀបចំ និងបង្កើតឡើងដើម្បីជួយដល់ការវាយតម្លៃ និងការវិភាគហានិភ័យនៅកម្រិតគួបសរុប ហើយជាពិសេស អាចកំណត់អត្តសញ្ញាណ និងតាមដានបានសមស្របនូវហានិភ័យប្រមូលផ្តុំ និងអាចគាំទ្រដល់សេចក្តីសម្រេចទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពអំពីការគ្រប់គ្រងហានិភ័យ។

២១.៣. ប្រព័ន្ធទាំងនេះ និងនីតិវិធីទ្រទ្រង់ផ្សេងៗ ត្រូវស្ថិតក្រោមការពិនិត្យផ្ទៃក្នុងឡើងវិញដោយទៀងទាត់ ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយ និងភាពសមស្របទៅនឹងប្រភេទ ទំហំ ភាពស្មុគស្មាញនៃសកម្មភាព និងរចនាសម្ព័ន្ធសាជីវកម្មរបស់គ្រឹះស្ថាន។

ប្រការ ២២.- ដំណើរការត្រួតពិនិត្យអចិន្ត្រៃយ៍ ដើម្បីធានាការប្រតិបត្តិតាមភាពឆ្កិច្ច និងកម្រិតកំណត់

ប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យរបស់គ្រឹះស្ថាន ត្រូវមានលទ្ធភាពតាមដានជាអចិន្ត្រៃយ៍នូវរាល់កាតព្វកិច្ច ឬកម្រិតកំណត់ផ្សេងៗ។ រាល់កំហុសដែលបានរកឃើញត្រូវតែបានដោះស្រាយ និងរាយការណ៍ភ្លាមទៅប្រធានមុខងារប្រតិបត្តិតាម។ របាយការណ៍នោះត្រូវមានបញ្ជាក់អំពីដើមហេតុនៃកំហុស ព្រមទាំងវិធានការកែតម្រូវទាំងឡាយដើម្បីដោះស្រាយហានិភ័យនៃការមិនប្រតិបត្តិតាម។ វិធានការកែតម្រូវនេះក៏ត្រូវមានគោលបំណងចៀសវាងនូវកំហុសដដែលៗផងដែរ និងសំដៅពិនិត្យឡើងវិញនូវរាល់ការត្រួតពិនិត្យកន្លងមក បើមានការវាយតម្លៃថា ការត្រួតពិនិត្យកន្លងមកនោះមិនសមស្របនិងគ្មានប្រសិទ្ធភាព។

ជំពូក ១០
ប្រព័ន្ធរក្សាទុកឯកសារ

ប្រការ ២៣.- គោលនយោបាយ នីតិវិធី សមត្ថកិច្ច ការប្រគល់សិទ្ធិ និងបាយការណ៍

២៣.១. គ្រឹះស្ថានត្រូវអនុម័ត វាយតម្លៃឡើងវិញ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវគោលនយោបាយ នីតិវិធី ការកំណត់សិទ្ធិអំណាចនិងការប្រគល់សិទ្ធិ រចនាសម្ព័ន្ធចាត់តាំង ប្រព័ន្ធព័ត៌មាន សកម្មភាព អភិបាលកិច្ច និងរចនាសម្ព័ន្ធសាជីវកម្ម ប្រសិនបើជាគ្រឹះស្ថានដែលរងការគួបសរុប (Consolidated Entity) ឬគ្រឹះស្ថានដែលត្រូវធ្វើការគួបសរុប (Consolidated Entity) ។

២៣.២. ការកំណត់សិទ្ធិអំណាចនិងការប្រគល់សិទ្ធិ ត្រូវមានរៀបចំជាឯកសារច្បាស់លាស់ សម្រាប់ឱ្យភាគីពាក់ព័ន្ធទាំងអស់ រួមមាន អត្តគាហក: មុខងារគ្រប់គ្រងហានិភ័យនិងត្រួតពិនិត្យ រួមទាំងមុខងារប្រតិបត្តិតាមផងដែរ។ ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថាន និងបើចាំបាច់របស់ក្រុមគ្រឹះស្ថាន ត្រូវតែអាចធានាថា ភាគីពាក់ព័ន្ធទាំងអស់ទទួលបានព័ត៌មានច្បាស់លាស់អំពីវិធាននៃការសម្រេចផ្ទៃក្នុងនេះ។ គ្រឹះស្ថានក៏ត្រូវមានដំណើរការត្រួតពិនិត្យគ្រប់គ្រាន់ផងដែរ ដើម្បីធានាថា សមត្ថកិច្ច និងការប្រគល់សិទ្ធិ មិនត្រូវបានប្រើប្រាស់លើសដែនកំណត់ ឬខុសគោលដៅ។

២៣.៣. គោលនយោបាយនិងនីតិវិធីត្រូវតែបានផ្តល់ទៅគណៈគ្រប់គ្រងនិងមន្ត្រីបុគ្គលិកជាលាយលក្ខណ៍អក្សរ បើចាំបាច់ ការអនុវត្តគោលនយោបាយ និងនីតិវិធីទាំងនោះត្រូវតែបានទ្រទ្រង់ដោយការបណ្តុះបណ្តាលសមស្របផងដែរ។ គោលនយោបាយនិងនីតិវិធីទាំងនោះ ត្រូវតែមានការត្រួតពិនិត្យការប្រតិបត្តិតាមមុននឹងដាក់ឱ្យអនុវត្ត។ គោលនយោបាយនិងនីតិវិធីទាំងនោះ ត្រូវមានបញ្ជាក់ច្បាស់លាស់អំពីដំណើរការដែលត្រូវបានអនុវត្ត សំដៅធានាការបែងចែកភារកិច្ច ឯករាជ្យភាពនៃការត្រួតពិនិត្យ និងការទប់ស្កាត់ ឬដំណោះស្រាយទំនាស់ផលប្រយោជន៍ជាសក្តានុពល។

២៣.៤. ក្រោមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ២៣.១ ដល់កថាខណ្ឌ ២៣.៣ ខាងលើជាពិសេស គ្រឹះស្ថានត្រូវបង្កើត វាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំ នូវរាល់ឯកសារផ្សេងៗ សំដៅទ្រទ្រង់ដល់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងមូល ស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។ ឯកសារទាំងនោះ អាចផ្តល់ជូនភាគីពាក់ព័ន្ធទាំងអស់សម្រាប់ប្រើប្រាស់ ដែលរួមមាន៖

ក. ការពិពណ៌នាអំពីការទទួលខុសត្រូវនៅគ្រប់កម្រិតទាំងអស់

ខ. ការកំណត់មុខងារ តួនាទី និងធនធានដែលបានបែងចែក សម្រាប់ការបំពេញមុខងារ និងតួនាទីទាំងនោះ

គ. ការពិពណ៌នាអំពីបែបបទ និងយន្តការនៃបែបបទរាយការណ៍ សំដៅធានាឯករាជ្យភាព ប្រសិទ្ធភាព និងភាពគ្មានទំនាស់ផលប្រយោជន៍

ឃ. ការពិពណ៌នាអំពីប្រព័ន្ធនិងដំណើរការវាស់វែងហានិភ័យ។ បើចាំបាច់ វិធីសាស្ត្រវាស់វែងហានិភ័យជាក់លាក់ ដូចជារង្វាស់ស្ថិតិលើហានិភ័យ ចំណាយសម្រាប់ផ្លាស់ប្តូរ ការចុះបញ្ជិកាតាមថ្លៃទីផ្សារ ជាដើម ត្រូវមានកត់ត្រាទុកជាឯកសារ និងត្រូវអនុម័តដោយឯករាជ្យពីប្រតិបត្តិការអាជីវកម្ម

ង. ការពិពណ៌នាអំពីប្រព័ន្ធតាមដានហានិភ័យដែលបានអនុវត្តសម្រាប់ការតាមដានហានិភ័យ ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ការពិពណ៌នាអំពីប្រព័ន្ធត្រួតពិនិត្យ វិធានការកែតម្រូវចាំបាច់បើមាន និងការពិពណ៌នាអំពីសញ្ញាអាសន្ន ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាភិបាល។

ប្រការ ២៤.- ការរៀបចំប្រព័ន្ធព័ត៌មាន និងរក្សាទុកឯកសារ

២៤.១. ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថានត្រូវតែធានាការរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវនូវរាល់សេចក្តីសម្រេច ឬហេតុការណ៍សំខាន់ៗពាក់ព័ន្ធនឹងអាជីវកម្ម ប្រតិបត្តិការ និងរចនាសម្ព័ន្ធ ដើម្បីងាយស្រួលរក និងប្រើប្រាស់ព័ត៌មានទាំងនោះ។

២៤.២. ប្រព័ន្ធព័ត៌មានរបស់គ្រឹះស្ថានក៏ត្រូវទ្រទ្រង់ដល់ការបែងចែកព័ត៌មានបានសមស្របនៅក្នុងគ្រឹះស្ថានទាំងមូលផងដែរ ហើយការបែងចែកនេះត្រូវផ្តោតជាចម្បងលើព័ត៌មានពាក់ព័ន្ធនឹងបញ្ហាត្រួតពិនិត្យផ្ទៃក្នុង និងជាពិសេស កាតព្វកិច្ចនិងបទប្បញ្ញត្តិស្តីពីការប្រតិបត្តិតាម។

២៤.៣. ផែនការយថាភាព និងនីតិវិធីពាក់ព័ន្ធផ្សេងៗ ត្រូវតែជាផ្នែកមួយនៃប្រព័ន្ធរក្សាទុកឯកសាររបស់គ្រឹះស្ថាន ហើយបើចាំបាច់ ត្រូវតែមានចែងច្បាស់លាស់ស្របតាមផែនការយថាភាព និងនីតិវិធីសម្រាប់កម្រិតក្រុមគ្រឹះស្ថាន និងនីតិវិធីដូចមានចែងក្នុងកថាខណ្ឌ ៦.៣ នៃប្រការ ៦ ស្តីពីសេវាកម្មផ្តល់ដោយតតិយភាគី។

២៤.៤. រាល់គោលនយោបាយ នីតិវិធី ការកំណត់សិទ្ធអំណាច ការប្រគល់សិទ្ធិ របាយការណ៍ និងកំណត់ហេតុ ត្រូវតែផ្តល់ឱ្យសវនករផ្ទៃក្នុង មន្ត្រីមុខងារប្រតិបត្តិតាម អាជ្ញាធរត្រួតពិនិត្យ ព្រមទាំងសវនករឯករាជ្យ ដើម្បីប្រើប្រាស់តាមការស្នើសុំ ។

ប្រការ ២៥.- របាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

២៥.១. គ្រឹះស្ថានត្រូវតែរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលពិពណ៌នាអំពីរចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងគោលនយោបាយ នីតិវិធី និងយន្តការពាក់ព័ន្ធផ្សេងៗ។ របាយការណ៍នេះក៏ត្រូវវាយតម្លៃផងដែរទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមកំណើននិងពិពិធកម្មនៃអាជីវកម្ម និងការកែប្រែផ្សេងៗ នៅក្នុងគ្រឹះស្ថាន។

២៥.២. បើចាំបាច់ របាយការណ៍នេះក៏ត្រូវមានចែងច្បាស់លាស់អំពីការត្រួតពិនិត្យផ្ទៃក្នុងនោះដោយមានគោលនយោបាយនិងរចនាសម្ព័ន្ធ ដែលបានបង្កើតឡើងនៅកម្រិតគួបសរុបផងដែរ។

២៥.៣. សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក ត្រូវទទួលខុសត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលនឹងត្រូវបានពិភាក្សានៅក្នុងគណៈកម្មការសវនកម្ម។ បើសមស្រប ឬចាំបាច់ អនុសាសន៍អំពីវិធានការកែតម្រូវ ឬកែលម្អ ត្រូវបានលើកឡើងជូនក្រុមប្រឹក្សាភិបាល។

២៥.៤. គ្រឹះស្ថានត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំនេះជូនធនាគារជាតិនៃកម្ពុជា ដោយមានហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុក យ៉ាងយូរបំផុតនៅថ្ងៃទី៣១ ខែមីនានៃឆ្នាំបន្ទាប់។

ជំពូក ១១
ផែនការយថាភាព និងការសាកល្បង

ប្រការ ២៦.- កាតព្វកិច្ចចំពោះផែនការយថាភាព

២៦.១. គ្រឹះស្ថានមានកាតព្វកិច្ចវាយតម្លៃហានិភ័យប្រចាំគ្រា ក្នុងគោលបំណងកំណត់អត្តសញ្ញាណហានិភ័យ ហានិភ័យប្រមូលផ្តុំ វេទយិតភាពសំខាន់ៗ ចំពោះព្រឹត្តិការណ៍និងការវិវត្តជាអវិជ្ជមានដែលអាចបណ្តាលឱ្យមានការរអាក់រអួលធ្ងន់ធ្ងរ ដូចជាការខកខានមិនបានសង ឬមិនបានប្រគល់ឱ្យទាន់ពេលវេលា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ការមិនប្រតិបត្តិតាមចម្បងៗ ឬការឈប់ដំណើរការនៃប្រព័ន្ធ។

២៦.២. ការវាយតម្លៃប្រចាំគ្រាខាងលើ នាំឱ្យកើតមានដំណើរការគ្រប់គ្រងគ្រាអាសន្ន និងដំណើរការចេញសេចក្តីសម្រេច សម្រាប់ដោះស្រាយស្ថានភាពវិបត្តិ ជាពិសេស តាមរយៈការដោះស្រាយសេណារីយ៉ូអវិជ្ជមានដែលសមស្រប និងដែលត្រូវដោះស្រាយឱ្យបានក្នុងពេលវេលាដ៏ខ្លី។ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគោលនយោបាយសម្រាប់ដោះស្រាយស្ថានភាពវិបត្តិ ផែនការយថាភាពនិងការសាកល្បង និងទំនាក់ទំនងជាមួយអាជ្ញាធរ និងសាធារណជន ដែលនឹងត្រូវអនុវត្តក្រោមការទទួលខុសត្រូវរបស់មាជិកក្រុមប្រឹក្សាភិបាលម្នាក់ឬច្រើននាក់ ដែលមានការចាត់តាំងច្បាស់លាស់។

២៦.៣. គ្រឹះស្ថានមានកាតព្វកិច្ចបង្កើតផែនការនិរន្តភាពអាជីវកម្ម ដូចមានចែងក្នុងប្រការ ៣ ស្របតាមហានិភ័យដែលបានកំណត់អត្តសញ្ញាណ ដោយការវាយតម្លៃប្រចាំគ្រា ដូចមានចែងក្នុងចំណុច ២៦.២ ខាងលើ។ យ៉ាងហោចណាស់ ផែនការនិរន្តភាពអាជីវកម្មនេះនិងនីតិវិធីនានា ត្រូវមានចែងអំពីការផ្តល់មូលនិធិយថាភាព (contingency funding) និងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលគ្រាអាសន្ន ក៏ដូចជាដំណោះស្រាយ និងដំណើរការបែកអាប់ (Back up) ដើម្បីដោះស្រាយការខូចខាតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

២៦.៤. ផែនការយថាភាពនិងដំណើរការ ត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រា ស្របតាមការវិវត្តទីផ្សារនិងអាជីវកម្ម ភាពស្មុគស្មាញនៃរចនាសម្ព័ន្ធនិងបច្ចេកវិទ្យាពាក់ព័ន្ធ ភាពគ្រប់គ្រាន់នៃនីតិវិធីនិងដំណើរការជំនួសដែលមានកម្រិតទាបជាងកាតព្វកិច្ចអប្បបរមា ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព និងជាទូទៅ ដោយពិចារណាអំពីផលប៉ះពាល់នៃយថាភាពដែលអាចមើលឃើញជាមុនថាជាសក្តានុពលចំពោះការប្រតិបត្តិតាម និងហានិភ័យកិត្តិសព្ទ។

ជំពូក ១២
ពិន័យ និងកាតព្វកិច្ចបង្កើនសាធនភាព

ប្រការ ២៧.- ពិន័យក្នុងករណីមិនប្រតិបត្តិតាម ឬអប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចដាក់ពិន័យចំពោះគ្រឹះស្ថានណាដែលមិនប្រតិបត្តិតាមឬល្មើសនឹងបទប្បញ្ញត្តិផ្សេងៗនៃប្រកាសនេះ យោងតាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏ត្រូវយកចិត្តទុកដាក់ដល់ការរំលោភ និងកង្វះខាត ព្រមទាំងផលប៉ះពាល់ជាសក្តានុពលទៅលើការវាយតម្លៃទម្រង់ហានិភ័យជារួមរបស់គ្រឹះស្ថាន ទាំងនៅកម្រិតដាច់ដោយឡែក និងនៅកម្រិតគួបសរុបផងដែរ។

ប្រការ ២៨.- កាតព្វកិច្ចបង្កើនសាធនភាព

២៨.១. ក្នុងករណីមានកង្វះខាតធ្ងន់ធ្ងរនៅក្នុងដំណើរការគ្រប់គ្រងហានិភ័យ ឬជាទូទៅនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានដែលមានទម្រង់ហានិភ័យខ្ពស់ដោយសារតែកង្វះខាតនោះ ដើម្បីបង្កើនកាតព្វកិច្ចសាធនភាពថែមទៀត។

២៨.២. កាតព្វកិច្ចបង្កើនសាធនភាពនេះ តម្រូវជាពិសេសចំពោះគ្រឹះស្ថានណាដែលមិនអនុវត្តតាមវិធានការកែតម្រូវចាំបាច់ បន្ទាប់ពីមានអធិបញ្ជាពីធនាគារជាតិនៃកម្ពុជា។

២៨.៣.កាតព្វកិច្ចបង្កើនសាធនភាពមិនត្រូវលើសពីសាមសិប (៣០) ភាគរយនៃអនុបាតសាធនភាពអប្បបរមាឡើយ និងមិនត្រូវបានលើកលែងពីកាតព្វកិច្ចនេះវិញ ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនពេញចិត្តទាំងស្រុងចំពោះប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវដែលបានអនុវត្តនោះឡើយ។ ផ្អែកលើកម្រិតកាតព្វកិច្ចសាធនភាពអប្បបរមានាបច្ចុប្បន្នចំនួនដប់ប្រាំ (១៥) ភាគរយ កាតព្វកិច្ចបង្កើនសាធនភាពអតិបរមាត្រូវមានកម្រិតដប់ប្រាំបួនក្បៀសប្រាំ (១៩,៥) ភាគរយ។

២៨.៤. កាតព្វកិច្ចបង្កើនសាធនភាព និងការលើកលែងពីការអនុវត្តវិធានការត្រួតពិនិត្យប្រុងប្រយ័ត្ននេះ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថាន។

ជំពូក ១៣
អន្តរប្បញ្ញត្តិ

ប្រការ ២៩.- ការអនុវត្តប្រកាសនេះ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែអនុវត្តឱ្យបានពេញលេញតាមបទប្បញ្ញត្តិនៃប្រកាសនេះយ៉ាងយូរបំផុតនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ តទៅ។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពត្រូវមានការវាយតម្លៃជារួមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលមានស្រាប់របស់គ្រឹះស្ថាន និងលើការកំណត់ជំហានដែលត្រូវអនុវត្តដើម្បីសម្រេចតាមប្រកាសនេះ។

ប្រការ ៣០.- ការវាយតម្លៃ និងផែនការសកម្មភាព

៣០.១. ផ្អែកលើការវាយតម្លៃចាំបាច់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកំណត់អត្តសញ្ញាណនូវផ្នែកទាំងឡាយ ដូចជាគោលនយោបាយ នីតិវិធី ដំណើរការវាយតម្លៃ ក្របខ័ណ្ឌរចនាសម្ព័ន្ធប្រព័ន្ធព័ត៌មានគ្រប់គ្រង ជាដើម ដែលទាមទារនូវសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងបង្កើតផែនការសកម្មភាពលម្អិតអំពីជំហានដែលត្រូវប្រកាន់យក និងមធ្យោបាយបន្ថែមសម្រាប់ធ្វើសកម្មភាពនោះ។

៣០.២. បើចាំបាច់ ផែនការសកម្មភាពនេះត្រូវមានចែងអំពីសកម្មភាពដែលត្រូវអនុវត្តដើម្បីប្រតិបត្តិតាមនៅកម្រិតគួបសរុប។

៣០.៣. ផែនការសកម្មភាពនេះត្រូវចែងលម្អិតអំពីលំហូរការងារ (flow charts) រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន ការពិពណ៌នាអំពីមុខងារ លក្ខខណ្ឌការងាររបស់គណៈកម្មការនានា គោលនយោបាយនិងនីតិវិធីក៏ដូចជាសមាសធាតុថវិកា ដើម្បីទ្រទ្រង់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពទាំងនោះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។

៣០.៤. ច្បាប់ថតចម្លងនៃផែនការសកម្មភាព និងឯកសារភស្តុតាងផ្សេងៗ ដូចមានចែងក្នុងចំណុច ៣០.៣ ខាងលើ ឬឯកសារចាំបាច់បន្ថែមទៀត ត្រូវបញ្ជូនមកធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។ គ្រឹះស្ថានដែលមានការយឺតយ៉ាវក្នុងការផ្តល់ផែនការសកម្មភាពនេះមកធនាគារជាតិនៃកម្ពុជា នឹងត្រូវទទួលរងពិន័យ។

ជំពូក ១៤
អវសានប្បញ្ញត្តិ

ប្រការ ៣១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៣២.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

១.៣. ព័ត៌មានផ្សាយពាណិជ្ជកម្ម គណនេយ្យ និង របាយការណ៍

ធ៧-០០-៥០ ប្រ.ក

ប្រកាស
ស្តីពី
ដំណើរការគណនេយ្យកម្មសម្រាប់ប្រតិបត្តិការរូបិយប័ណ្ណ

ប្រការ ១.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **រូបិយវត្ថុរាយការណ៍** មានន័យថា រូបិយវត្ថុដែលបានប្រើសម្រាប់កត់ត្រាគណនី និងសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ ស្ថិតនៅក្នុងរយៈពេលបណ្តោះអាសន្ននៃការងារគណនេយ្យ ប្រាក់ដុល្លារអាមេរិកត្រូវបានប្រើជារូបិយវត្ថុរាយការណ៍ រហូតដល់ពេលណាដែលដំណើរការបដិដុល្លារូបនីយកម្មសេដ្ឋកិច្ចកម្ពុជាបានជឿនលឿនសមស្រប។

២- **រូបិយប័ណ្ណ** មានន័យថា រូបិយប័ណ្ណក្រៅពីរូបិយវត្ថុរាយការណ៍របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

៣- **អត្រាប្តូរប្រាក់** មានន័យថា អនុបាតរវាងមួយឯកតានៃរូបិយវត្ថុមួយ និងចំនួនទឹកប្រាក់ជារូបិយវត្ថុមួយទៀត ដែលក្នុងនោះ ឯកតានេះអាចត្រូវបានប្តូរពីមួយទៅមួយក្នុងពេលកំណត់មួយ។

៤- **អត្រាប្តូរប្រាក់ដល់ដៃ (spot rate)** មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់សម្រាប់ប្រតិបត្តិការប្តូរដោយប្រគល់ប្រាក់ដល់ដៃភ្លាម។

៥- **អត្រាប្តូរប្រាក់មានកាលកំណត់ (forward rate)** មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាប្តូរប្រាក់នាកាលបរិច្ឆេទច្បាស់លាស់មួយទៅអនាគត។

៦- **អត្រាប្តូរប្រាក់នៅពេលបិទ (closing rate)** មានន័យថា អត្រាប្តូរប្រាក់ដល់ដៃនាកាលបរិច្ឆេទនៃការធ្វើតារាងតុល្យការ។

៧- **ប្រតិបត្តិការជារូបិយប័ណ្ណ** មានន័យថា ប្រតិបត្តិការមួយដែលត្រូវចារឹកឬទាមទារឱ្យទូទាត់ជារូបិយប័ណ្ណ រួមបញ្ចូលទាំងប្រតិបត្តិការប្តូរប្រាក់ដែលបង្កើតឱ្យមានស្ថានភាពប្តូរប្រាក់ (foreign exchange position)។

ប្រការ ២.-

ប្រតិបត្តិការជារូបិយប័ណ្ណត្រូវបានកត់ត្រាស្របតាមបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ។ ដូច្នេះ ប្រព័ន្ធគណនេយ្យប្រើប្រាស់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែបានរៀបចំយ៉ាងណាដើម្បីអាចផ្តល់ព័ត៌មានដែលតម្រូវដោយប្រកាសនេះ។

លោហៈធាតុមានតម្លៃដូចជា មាស និងប្រាក់ ដែលត្រូវបានរក្សាទុកតាមទម្រង់ដែលអាចជួញដូរបាន ត្រូវអនុវត្តតាមវិធាននៃការវាយតម្លៃ ដែលមានចែងនៅក្នុងប្រការ ៦ នៃប្រកាសនេះ។

ប្រការ ៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកត់ត្រាប្រតិបត្តិការប្តូរប្រាក់ដល់ដៃ ឬមានកាលកំណត់ក្នុងគណនីដែលបានបើក និងចារិកតាមប្រភេទរូបិយប័ណ្ណនីមួយៗដែលបានប្រើ។

សម្រាប់គោលបំណងនៃប្រកាសនេះ រាល់ការទិញឬការលក់រូបិយប័ណ្ណដែលភាគីទាំងអស់មិនបានពន្យារពេល ឬបានពន្យារតែក្នុងរយៈពេលជាទម្លាប់ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាប្តូរប្រាក់ដល់ដៃ។ ដូច្នេះ កិច្ចសន្យាប្តូរប្រាក់ដល់ដៃ (Spot Contract) ត្រូវបានឱ្យនិយមន័យថាជាកិច្ចសន្យាប្តូរប្រាក់ណាមួយ ក្នុងរយៈ ពេល ២ ថ្ងៃធ្វើការ (2 business days) នៃកាលវិសាន (maturity) លើកលែងតែរយៈពេលខ្លីជាងរយៈពេលជាទម្លាប់ ឬទាមទារដោយទីផ្សារក្នុងស្រុក។

សម្រាប់គោលបំណងនៃប្រកាសនេះ រាល់ការទិញ ឬការលក់រូបិយប័ណ្ណដែលភាគីទាំងអស់សម្រេចពន្យាររយៈពេលជាទម្លាប់វែងជាង២ថ្ងៃធ្វើការ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាប្តូរប្រាក់មានកាលកំណត់ (forward contracts)។

ប្រការ ៤.-

បដិភាគនៃការកត់ត្រាគណនេយ្យរូបិយប័ណ្ណទាក់ទងទៅនឹងប្រតិបត្តិការប្តូរប្រាក់ ដូចជាប្រតិបត្តិការដែលជាប់ទាក់ទងដល់ស្ថានភាពរូបិយប័ណ្ណ (foreign currency position) ត្រូវបានកត់ត្រាក្នុងគណនីស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ និងចារិកទៅតាមប្រភេទរូបិយប័ណ្ណដែលបានប្រើ។

ការកត់ត្រាគណនេយ្យជារូបិយវត្ថុរាយការណ៍ដែលទាក់ទងជាមួយប្រតិបត្តិការប្តូរប្រាក់ ត្រូវបានចុះបញ្ជិកាក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ។

ជាលទ្ធផល ប្រតិបត្តិការជារូបិយប័ណ្ណនិងជារូបិយវត្ថុរាយការណ៍ត្រូវបានកត់ត្រាចូលក្នុងសៀវភៅធំ (Ledger) សមស្រប ហើយសៀវភៅធំនីមួយៗត្រូវមានតុល្យភាពដោយប្រើគណនីឆ្លុះបញ្ចាំង (mirror accounts) ដូចខាងក្រោម៖

* ស្ថានភាពប្តូរប្រាក់ជារូបិយប័ណ្ណចែកជា៖
  - ស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ
  - ស្ថានភាពប្តូរប្រាក់នៅក្រៅតារាងតុល្យការ

* ស្ថានភាពប្តូរប្រាក់ជារូបិយវត្ថុរាយការណ៍សមមូល (ឬតម្លៃបដិភាគ) ចែកជា៖
  - ស្ថានភាពប្តូរប្រាក់សមមូលនៅក្នុងតារាងតុល្យការ
  - ស្ថានភាពប្តូរប្រាក់សមមូលនៅក្រៅតារាងតុល្យការ ។

ប្រការ ៥.-

ដើមទុនដែលបានមកពីការទិញ ឬលក់ក្នុងប្រតិបត្តិការប្តូរប្រាក់ដល់ដៃ (foreign exchange transactions) ដែលមានកាលវិសាន (maturity) ជាទម្លាប់ ២ ថ្ងៃធ្វើការ និងក្នុងប្រតិបត្តិការប្តូរប្រាក់

មានកាលកំណត់ ត្រូវតែកត់ត្រាក្នុងគណនីក្រៅតារាងតុល្យការសមស្រប នាកាលបរិច្ឆេទដែលប្រតិបត្តិការកើតឡើង។ នៅពេលប្រគល់រូបិយប័ណ្ណ ប្រតិបត្តិការត្រូវបានកត់ត្រាចូលក្នុងតារាងតុល្យការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

នាកាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យនីមួយៗ ទ្រព្យសកម្ម ទ្រព្យអកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ត្រូវបានឱ្យតម្លៃតាមថ្លៃទីផ្សារ។ អត្រាទីផ្សារដែលអនុវត្តចំពោះខ្ទង់ទ្រព្យសកម្ម និងខ្ទង់ទ្រព្យអកម្ម និងចំពោះការសន្យាប្តូរប្រាក់ដល់ដៃ គឺជាអត្រាប្តូរប្រាក់នៅពេលបិទនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ។

អត្រាប្តូរប្រាក់ទីផ្សារដែលអនុវត្តចំពោះការសន្យាប្តូរប្រាក់មានកាលកំណត់ គឺជាអត្រាប្តូរប្រាក់មានកាលកំណត់នៃរូបិយប័ណ្ណពាក់ព័ន្ធសម្រាប់រយៈកាលដែលនៅសល់ ដូចជាអត្រាប្តូរប្រាក់មានកាលកំណត់នៅទីផ្សារត្រូវស្របទៅនឹងកាលវិសាននៃការសន្យា។

ប្រការ ៧.-

នាកាលបរិច្ឆេទរបាយការណ៍គណនេយ្យនីមួយៗ វិសមភាពនៃចំនួនប្រាក់ជារូបិយវត្ថុរាយការណ៍ដែលបានមកពីការវាយតម្លៃគណនីស្ថានភាពប្តូរប្រាក់ ស្របតាមបញ្ញត្តិនៃប្រការ ៥ ម៉្យាង និងម៉្យាងទៀតចំនួនប្រាក់ដែលបានបង្ហាញក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ ត្រូវបានកត់ត្រាចូលក្នុងគណនីចំណេញ-ខាត។ បដិភាគនៃការកត់ត្រានេះ ត្រូវបានកត់ត្រាចូលក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ចារិកជារូបិយវត្ថុរាយការណ៍។

នៅពេលដែលមិនទាន់អាចកត់ត្រាឥណពន្ធលើគណនីក្នុងតារាងតុល្យការបាន ដោយកត់ត្រាឥណទាននៃគណនីក្រៅតារាងតុល្យការ និងផ្ទុយមកវិញ ប្រាក់ចំណេញនិងខាតដែលបានកត់ត្រាក្នុងគណនីចំណេញ-ខាត និងដែលកើតចេញពីស្ថានភាពប្តូរប្រាក់ក្រៅតារាងតុល្យការ ត្រូវតែមានតុល្យភាព ដោយប្រើគណនីមួយដែលធ្វើឱ្យមានតុល្យភាពនៃតារាងតុល្យការ។

វិសមភាពទាំងឡាយដែលទាក់ទងដល់ប្រតិបត្តិការ ដែលក្នុងនោះហានិភ័យនៃការប្តូរប្រាក់វ៉ាប់រងដោយរដ្ឋ ត្រូវតែកត់ត្រាចូលក្នុងគណនីកែតម្រូវ។

ប្រការ ៨.-

ចំណូលនិងចំណាយបង្គរជារូបិយប័ណ្ណដែលទាក់ទងដល់ឥណទាននិងកម្ចី មូលបត្រ ឬប្រតិបត្តិការក្រៅតារាងតុល្យការ ត្រូវបានឱ្យតម្លៃតាមអត្រាប្តូរប្រាក់ដល់ដៃនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ ហើយត្រូវកត់ត្រាចូលក្នុងគណនីចំណេញ-ខាតតាមគ្រាដែលកំណត់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងយ៉ាងយឺតបំផុតដល់កាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យ។

ចំណូលដែលត្រូវទទួល និងចំណាយដែលត្រូវសងជារូបិយប័ណ្ណមិនបង្គរ ទាក់ទងដល់ប្រតិបត្តិការក្នុងតារាងតុល្យការឬក្រៅតារាងតុល្យការ ត្រូវតែបង្ហាញនៅក្នុងគណនីដោយឡែក នៅពេលណាដែលចំណូលនិងចំណាយទាំងនេះ ត្រូវបានការពារការខាតបង់ (hedged)។

ប្រការ ៩.-

ដើម្បីធានាឱ្យការធ្វើរបាយការណ៍ពីហានិភ័យប្តូរប្រាក់ស៊ីសង្វាក់គ្នាទូទាំងប្រព័ន្ធធនាគារយ៉ាងហោចណាស់ ការវាយតម្លៃឡើងវិញត្រូវតែអនុវត្តនាកាលបរិច្ឆេទបិទបញ្ជីនៅខែនីមួយៗ។ ប្រសិនបើកាលបរិច្ឆេទនេះមិនមែនជាថ្ងៃធ្វើការ ការវាយតម្លៃបិទបញ្ជីត្រូវធ្វើនៅថ្ងៃធ្វើការមុននោះ។

ប្រការ ១០.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

សារាចរណែនាំ
ស្តីពី
ការអនុវត្តគណនេយ្យរូបិយវត្ថុចម្រុះតាមប្លង់គណនីឯកតាព

សេចក្តីណែនាំនេះ ជាការណែនាំគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អំពីរបៀបធ្វើគណនេយ្យកម្ម រូបិយវត្ថុច្រើនប្រភេទសម្រាប់ប្រតិបត្តិការរូបិយប័ណ្ណផ្សេងៗ ដែលរួមមាននីតិវិធីនៃការវាយតម្លៃឡើងវិញ និងគណនេយ្យកម្មប្រចាំថ្ងៃ សម្រាប់ចំណេញឬខាតពីការវាយតម្លៃឡើងវិញ ក៏ដូចជាការទទួលស្គាល់ស្ថានភាពប្តូរប្រាក់ពីការផ្តល់ឥណទានជារូបិយប័ណ្ណ និងការប្រាក់បង្គរជារូបិយប័ណ្ណ។

សេចក្តីណែនាំត្រូវអនុលោមតាមប្រកាសលេខ ធ៧-០០-៥០ ស្តីពី ដំណើរការគណនេយ្យកម្ម សម្រាប់ប្រតិបត្តិការរូបិយប័ណ្ណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០។

គណនេយ្យកម្មរូបិយប័ណ្ណច្រើនប្រភេទ

ប្លង់គណនីឯកភាព ដែលបានអនុវត្តជាប្លង់គណនីឯកភាពមានរូបិយប័ណ្ណច្រើនប្រភេទ។ គណនីសៀវភៅធំ (General Ledger) នីមួយៗមានលេខកូដរូបិយប័ណ្ណមួយនៅខ្ទង់ចុងក្រោយ។ ប្រព័ន្ធលេខកូដនេះអនុវត្តចំពោះទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូលនិងចំណាយ និងខ្ទង់ក្រៅតារាងតុល្យការ។ ដូច្នេះ ការចុះបញ្ជីកាប្រតិបត្តិការណាមួយ សុទ្ធតែបានចុះឥណពន្ធ និងឥណទានក្នុងគណនីសៀវភៅធំទៅតាមប្រភេទរូបិយប័ណ្ណនីមួយៗ។ ឧទាហរណ៍ ការផ្ទេរប្រាក់ចេញជាអឺរ៉ូ ដោយចុះឥណពន្ធគណនីរបស់អតិថិជនមួយ អាចចុះបញ្ជីសាមញ្ញដូចខាងក្រោម ប្រសិនអតិថិជនមានគណនីចរន្តជាអឺរ៉ូ៖

ឥណពន្ធ គណនីអតិថិជន ជាអឺរ៉ូ

ឥណទាន គណនី Nostro ជាអឺរ៉ូ

(មិនគិតកម្រៃជើងសា)

ករណីស្រដៀងគ្នា ឥណទានមានកាលកំណត់មួយ ជាថៃបាត អាចកត់ត្រា៖

ឥណពន្ធ ឥណទានមានកាលកំណត់ ជាបាតថៃ

ឥណទាន គណនីអតិថិជន ជាបាតថៃ

ដូចគ្នានេះដែរ ឥណទានមានកាលកំណត់មួយជាបាតថៃ អាចកត់ត្រាក្នុងទិន្នានុប្បវត្តិ "Journalized"៖

ឥណពន្ធ ឥណទានមានកាលកំណត់ ជាបាតថៃ

ឥណទាន គណនីអតិថិជន ជាបាតថៃ

ឧទាហរណ៍ខាងលើនេះ មិនមានជាប់ទាក់ទងនឹងការប្តូររូបិយប័ណ្ណទេ។ រាល់ហានិភ័យប្តូរប្រាក់ជាប្រាក់អឺរ៉ូ ឬជាបាតថៃ ខាងផ្នែកទ្រព្យសកម្មនិងទ្រព្យអកម្ម លែងកើតមានដោយសារបានចុះបញ្ជីទាំងខាងឥណពន្ធនិងខាងឥណទាននៃទ្រព្យសកម្មផងនិងទ្រព្យអកម្មផង។

ប៉ុន្តែ ប្រសិនបើអតិថិជនមានគណនីចរន្តជាប្រាក់ដុល្លារអាមេរិក ហើយចង់ឱ្យធនាគារផ្ទេរប្រាក់ជាអឺរ៉ូ ធនាគារនឹងប្តូរប្រាក់អឺរ៉ូ ទៅជាប្រាក់ដុល្លារអាមេរិក ហើយត្រូវចុះខាងឥណពន្ធនៃគណនីអតិថិជន។ ប្រតិបត្តិការនេះបង្កើតជាស្ថានភាពប្តូរប្រាក់ជាអឺរ៉ូធៀបជាមួយរូបិយប័ណ្ណគោលជាប្រាក់ដុល្លារអាមេរិក។ ការចុះបញ្ជីគណនេយ្យ គឺ៖

ឥណពន្ធ គណនីអតិថិជន ជាដុល្លារអាមេរិក

ឥណទាន គណនីប្តូរប្រាក់សមមូលជាដុល្លារអាមេរិក

ឥណពន្ធ ស្ថានភាពប្តូរប្រាក់ ជាអឺរ៉ូ

ឥណទាន គណនី Nostro ជាអឺរ៉ូ

(រូបិយប័ណ្ណគោលជាដុល្លារអាមេរិក)

នៅក្នុងតារាងតុល្យភាពរូបិយប័ណ្ណច្រើនប្រភេទមួយ ប្រាក់ដុល្លារអាមេរិក និងប្រាក់អឺរ៉ូ នឹងមានសមតុល្យ ទាំងខ្ទង់ឥណពន្ធ និងឥណទាន។ ក្នុងការបង្ហាញនិងរាយការណ៍ការប្តូរប្រាក់ដុល្លារអាមេរិកនិងប្រាក់អឺរ៉ូជាប្រាក់រៀល ពុំបាននាំឱ្យមានចំណេញ ឬខាតក្នុងប្រតិបត្តិការប្តូរប្រាក់ ឬចំណេញ ឬខាតពីការប្តូរប្រាក់ទេ។

ក្នុងឧទាហរណ៍ខាងលើ ធនាគារមានស្ថានភាពប្តូរប្រាក់ជាប្រាក់អឺរ៉ូធៀបនឹងប្រាក់ដុល្លារអាមេរិក។ គណៈគ្រប់គ្រងធនាគារត្រូវកំណត់គោលនយោបាយផ្ទៃក្នុងអំពីដែនកំណត់នៃហានិភ័យប្តូរប្រាក់។ ស្ថានភាពប្តូរប្រាក់ត្រូវតែបានវាយតម្លៃឡើងវិញជាប្រចាំថ្ងៃ ឬគំលាតផ្សេងៗទៀតដោយប្រើអត្រាប្តូរប្រាក់ទីផ្សារ និងចំណេញ ឬខាតណាដែលចុះក្នុងរបាយការណ៍ចំណូល-ចំណាយ។ ចំណេញនិងខាតបានពីការវាយតម្លៃឡើងវិញនៃរូបិយប័ណ្ណរបស់ធនាគារ មិនត្រូវចុះក្នុងគណនីប្រាក់បម្រុងក្នុងតារាងតុល្យការទេ។

គណនេយ្យរូបិយប័ណ្ណទ្វេភាគ

ថ្មីៗនេះ ធនាគារជាច្រើនប្រើប្រាស់គណនេយ្យកម្ម្យរូបិយប័ណ្ណទ្វេភាគ ទោះបីបានយកប្លង់គណនីឯកភាពមកប្រើហើយក៏ដោយ ប្រការនេះមានរូបភាពពីរគឺ៖ ការអនុវត្តមានរូបភាពពីរគឺ៖ ទី១ ធនាគារពុំមានគណនីទំនាក់ទំនងនៅក្រៅប្រទេសសម្រាប់ផ្ទេររូបិយប័ណ្ណ។ ឧបមាថា អតិថិជនធនាគារម្នាក់មានគណនីចរន្តជាប្រាក់ដុល្លារអាមេរិក ហើយគាត់បញ្ជាធនាគារិករបស់គាត់ឱ្យផ្ទេរប្រាក់ជាអឺរ៉ូ។ ក្នុងករណីនេះ ធនាគារិកបញ្ជូនស្ថានភាពប្តូរប្រាក់ទាំងស្រុងទៅធនាគារទំនាក់ទំនងរបស់ខ្លួននៅសហរដ្ឋអាមេរិក ហើយបញ្ជាធនាគារិក (នៅអាមេរិក) ឱ្យផ្ទេរប្រាក់អឺរ៉ូ និងកាត់ចេញពីគណនីរបស់គាត់ជាប្រាក់ដុល្លារអាមេរិក។ ធនាគារក្នុងស្រុកទទួលយកអត្រាប្តូរប្រាក់ដែលកាត់ចេញដោយធនាគារអាមេរិក ហើយធនាគារក្នុងស្រុកមិនមានស្ថានភាពប្តូរប្រាក់ទេ។ គុណវិបត្តិនៃរបៀបនេះគឺថា វាមានចំណាយខ្ពស់ចំពោះធនាគារក្នុងស្រុក និងអតិថិជនរបស់ខ្លួន។

រូបភាពទី២ ថាអតិថិជនមានគណនីចរន្តជាប្រាក់រៀល ប៉ុន្តែចង់ផ្ទេរប្រាក់ជាដុល្លារអាមេរិក។ ក្នុងករណីនេះ កិច្ចបញ្ជិកាគណនេយ្យក្នុងគណនីរូបិយប័ណ្ណទ្វេភាគត្រូវកត់ត្រា ដូចខាងក្រោម៖

ឥណពន្ធ គណនីអតិថិជន ជារៀល

ឥណទាន គណនី Nostro ជាអឺរ៉ូ និងជារៀល (រូបិយប័ណ្ណទ្វេភាគ)

(មិនគិតកម្រៃជើងសា និងសន្មតថារូបិយវត្ថុគោលជារៀល)

ប្រាក់អឺរ៉ូនៅក្នុងគណនី Nostro និងប្រាក់សមមូលជារៀល នឹងប្រែប្រួលតាមតម្លៃទីផ្សារនៃប្រាក់អឺរ៉ូ ធៀបនឹងប្រាក់រៀល។ គ្រប់គ្រឹះស្ថានធនាគារគួរតែវាយតម្លៃរូបិយប័ណ្ណឡើងវិញធៀបនឹងរូបិយវត្ថុគោលយ៉ាងតិចបំផុតម្តងក្នុងមួយខែ ហើយយកចំណេញ ឬខាតទៅចុះក្នុងរបាយការណ៍ចំណូល-ចំណាយ។

ខ្លឹមចំណូល និងចំណាយពីរូបិយប័ណ្ណបរទេស

មាត្រា ៨ នៃប្រកាសខាងលើចែងថា ចំណូលនិងចំណាយបង្គរជារូបិយប័ណ្ណ ដែលទាក់ទងដល់ការឱ្យខ្ចី និងឥណទានជារូបិយប័ណ្ណ មូលបត្រ ឬប្រតិបត្តិការក្រៅតារាងតុល្យការ ត្រូវបានវាយតម្លៃឡើងវិញតាមអត្រាប្តូរប្រាក់ដល់ដៃ (Spot rate) ហើយត្រូវកត់ត្រាចូលក្នុងគណនីចំណេញ-ខាត។

ក្នុងប្រព័ន្ធគណនេយ្យកម្ម្យរូបិយប័ណ្ណច្រើនប្រភេទខាងលើ ការងារនេះមានភាពងាយស្រួល។ នៅខែនីមួយៗ របាយការណ៍ចំណេញនិងខាតនឹងមានច្រើននៅពេលមានរូបិយវត្ថុផ្សេងៗនៅក្នុងធនាគារ។ ដើម្បីឱ្យមាត្រា ៨ មានប្រសិទ្ធភាព ធនាគារចាំបាច់គ្រាន់តែទទួលយកស្ថានភាពប្តូរប្រាក់រវាងចំណូលសុទ្ធ ដកចំណាយតាមរូបិយប័ណ្ណនីមួយៗ ហើយចុះបញ្ជីគណនី៖

សន្មតថា មានចំណូលសុទ្ធជាបាតថៃ

ឥណពន្ធ ចំណូលជាបាតថៃ

ឥណទាន ស្ថានភាពប្តូរប្រាក់ជាបាតថៃ

ឥណពន្ធ សមមូលជាដុល្លារអាមេរិក (សន្មតរូបិយប័ណ្ណគោលជាដុល្លារអាមេរិក)

ឥណទាន ចំណូលជាដុល្លារអាមេរិក

(អាស្រ័យដោយប្រតិបត្តិការនេះ ស្ថានភាពធនាគារនឹងវាយតម្លៃឡើងវិញនូវចំណូលពីការប្តូររូបិយប័ណ្ណទទួលបានពីការឱ្យខ្ចីជារូបិយប័ណ្ណរបស់ខ្លួន)

នៅក្នុងប្រព័ន្ធគណនេយ្យកម្ម្យរូបិយប័ណ្ណទ្វេភាគ ការប្រាក់បង្គរមិនអាចធ្វើការវាយតម្លៃឡើងវិញដោយងាយស្រួលឡើយ នៅពេលណាការប្រាក់បង្គរត្រូវទទួលជារូបិយប័ណ្ណ និងចំណូលការប្រាក់ត្រូវបានចុះបញ្ជីតាមអត្រាចុះបញ្ជីដូចគ្នា។ ការវាយតម្លៃឡើងវិញណាក៏មិនមានផលប៉ះពាល់ដល់ចំនួនប្រាក់ចំណូលដែរ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥

នាយកដ្ឋានត្រួតពិនិត្យ

ជាន់ ហូរ គិម ខ៉ាជា

ធ៧-០៧-១៦៤ ប្រ.ក

ប្រកាស
ស្តីពី
ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជិកា គណនេយ្យ និងរាយការណ៍

ប្រការ ១.-

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចុះកិច្ចបញ្ជិកាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់មធ្យមផ្លូវការដែលប្រកាសដោយធនាគារជាតិនៃកម្ពុជាតាមគ្រានីមួយៗ។

ប្រការ ២.-

រាល់លិខិតបទដ្ឋាននានាដែលធ្វើឡើងសម្រាប់ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជាត្រូវតែប្រើជាភាសាខ្មែរ។

ប្រការ ៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាដែលមិនគោរពតាមប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៤.-

ប្រកាសលេខ ធ៥-៩៣-២០៨ ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការប្រើប្រាស់ភាសា និងឯកត្តារូបិយវត្ថុសម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៩-១២២ ស.ជ.ណ

ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

ជម្រាបមក
លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា
គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្មវត្ថុ ៖ កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

យោង ៖ - ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និង
- សារាចរណែនាំលេខ ០០៤ ក.ជ.គ ចុះថ្ងៃព្រហស្បតិ៍ ១២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ ស្តីពី ការអនុវត្តសេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំ សូមជម្រាបមក លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យបានជ្រាបថា ដើម្បីសម្រួលដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការចុះកិច្ចបញ្ជិកាគណនេយ្យ ស្របតាមស្តង់ដារគណនេយ្យដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមណែនាំដល់គ្រឹះស្ថានទាំងអស់ដូចខាងក្រោម៖

១. <u>ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ</u>៖

- ត្រូវអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)
- ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែតាមទម្រង់របាយការណ៍ និងប្លង់គណនីឯកភាពបច្ចុប្បន្ន សម្រាប់របាយការណ៍ចាប់ពីខែមករា ឆ្នាំ២០១៩ រហូតដល់មានការជូនដំណឹងជាថ្មី និង
- ត្រូវចាប់ផ្តើមអនុវត្តតាមប្លង់គណនីឯកភាព និងរាយការណ៍តាមទម្រង់របាយការណ៍ថ្មី ចាប់ពីខែមិថុនា ឆ្នាំ២០១៩ តទៅ ទន្ទឹមគ្នានឹងប្លង់គណនីឯកភាព និងទម្រង់របាយការណ៍បច្ចុប្បន្ន។

២. <u>គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ</u>៖

- អាចមានជម្រើសក្នុងការអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ឬ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ

នៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs)។ ប៉ុន្តែ ចំពោះ
កាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានត្រូវអនុវត្តតាមស្តង់ដារ
របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច
និងមធ្យម និង

- ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រាតាមទម្រង់របាយការណ៍ និងប្លង់គណនី
ឯកភាពបច្ចុប្បន្ន សម្រាប់របាយការណ៍ចាប់ពីខែមករា ឆ្នាំ២០១៩។ ទន្ទឹមនេះ
គ្រឹះស្ថានត្រូវរៀបចំរបាយការណ៍ប្រចាំគ្រាតាមទម្រង់របាយការណ៍បច្ចុប្បន្ន ដោយ
ប្រើប្រាស់ទិន្នន័យអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
អន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ចាប់ពីខែមិថុនា ឆ្នាំ២០១៩
រហូតដល់មានការជូនដំណឹងជាថ្មីអំពីការអនុវត្តប្លង់គណនីឯកភាព និងទម្រង់
របាយការណ៍ថ្មី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា
នាយក នាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អាន
អំពីខ្ញុំ។

ចេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ cifrs@nbc.org.kh

ធ៧-០២០-៣៥២ ប្រ.ក

ប្រកាស
ស្តីពី
ការចែករំលែកព័ត៌មានឥណទាន

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងបង្កើតក្របខ័ណ្ឌនិងកិច្ចសហប្រតិបត្តិការសម្រាប់ការចែករំលែកព័ត៌មានឥណទាន ដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ និងការប្រកួតប្រជែងស្មើភាព សំដៅកាត់បន្ថយហានិភ័យឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។

ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ និងគ្រឹះស្ថាន/ក្រុមហ៊ុនផ្សេងទៀត ដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៣.- និយមន័យ

- **ការយល់ព្រម** សំដៅដល់ការព្រមព្រៀងជាលាយលក្ខណ៍អក្សរ និង/ឬ ទម្រង់ដទៃផ្សេងទៀតដែលបញ្ជាក់ពីការយល់ព្រម ដើម្បីផ្តល់សិទ្ធិដល់អ្នកផ្តល់ទិន្នន័យក្នុងការបញ្ចូលព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងចែករំលែកព័ត៌មានទាំងនេះជាមួយអ្នកប្រើប្រាស់ប្រតិស្រុតិសម្រាប់គោលបំណងប្រើប្រាស់ ដូចមានចែងក្នុងប្រកាសនេះ។
- **កាលបរិច្ឆេទចាប់ផ្តើម** សំដៅដល់ថ្ងៃដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានចាប់ផ្តើមធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទានដល់អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិរបស់ខ្លួន។
- **ក្រមប្រតិបត្តិ** សំដៅដល់វិធាននិងបទបញ្ជាសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានតាមការព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងអ្នកប្រើប្រាស់ប្រតិស្រុតិ។

- **ក្រុមប្រឹក្សាភិបាល** សំដៅដល់ក្រុមបុគ្គលដែលទទួលបន្ទុកត្រួតពិនិត្យលើគណៈគ្រប់គ្រង និងទទួលខុសត្រូវរួមលើក្រុមហ៊ុនផ្តល់សេវាចែករំលែកព័ត៌មានឥណទាន។
- **ក្រុមប្រឹក្សាផ្តល់យោបល់** សំដៅដល់គណៈកម្មការផ្តល់យោបល់ដែលត្រូវបានបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់យោបល់ពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។
- **គ្រឹះស្ថានចំណុះច្បាប់** សំដៅដល់គ្រឹះស្ថាន ដូចមានចែងនៅក្នុងច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- **គ្រឹះស្ថានមិនចំណុះច្បាប់** សំដៅដល់គ្រឹះស្ថានដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- **បហារក** សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានបត្រ ឬរូបិយាណត្តិ។
- **ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់គ្រឹះស្ថាន បទបញ្ជានិងស្តង់ដារ បច្ចេកវិទ្យា និងទិន្នន័យ ដែលផ្តល់លទ្ធភាពឱ្យមានការផ្លាស់ប្តូរព័ត៌មានឥណទាន។
- **ព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី** សំដៅដល់ព័ត៌មានទាក់ទងនឹងការចេញមូលប្បទានបត្រដែលមិនមានសមតុល្យ ឬមានសមតុល្យមិនគ្រប់គ្រាន់នៅក្នុងគណនី សម្រាប់ការទូទាត់។
- **ព័ត៌មានឥណទាន** សំដៅដល់ព័ត៌មានទាក់ទងនឹងកាតព្វកិច្ចខាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់អតិថិជន រួមទាំងសារតារទូទាត់សងប្រាក់ ការធានា ព័ត៌មានដែលអាចប្រើប្រាស់បានជាសាធារណៈ និងទិន្នន័យពាក់ព័ន្ធផ្សេងទៀតដែលអាចប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចផ្តល់ឥណទាន។
- **ព័ត៌មានឥណទានវិជ្ជមាន** សំដៅដល់ព័ត៌មានឬទិន្នន័យរបស់អតិថិជន ពាក់ព័ន្ធនឹងពាក្យស្នើសុំឥណទាននិងគុណភាពឥណទាន ដូចជា ទំហំប្រាក់កម្ចី កាលវិសាន លក្ខខណ្ឌនៃការសងប្រាក់ និងវត្ថុបញ្ចាំ ជាដើម។
- **ព័ត៌មានឥណទានអវិជ្ជមាន** សំដៅដល់ព័ត៌មានទាក់ទងនឹងការហួសពេលកំណត់សង ឬការមិនបានសងប្រាក់កម្ចីរយៈពេល ៩០ (កៅសិប) ថ្ងៃ ឬការលុបចោលប្រាក់កម្ចី។
- **វិធានបដិការ** សំដៅដល់សំណុំវិធានដែលកំណត់កម្រិតនៃការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកនិងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់ទិន្នន័យ។
- **សកម្មភាពចែករំលែកព័ត៌មានឥណទាន** សំដៅដល់សកម្មភាពទាំងឡាយណាដែលស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះ រួមមានការផ្តល់របាយការណ៍ឥណទាន និងការផ្តល់សេវាពាក់ព័ន្ធផ្សេងៗទៀត។

- **សកម្មភាពមិនអំណោយផល** សំដៅដល់ការបដិសេធឥណទាន ឬការកែប្រែក្នុខណ្ឌឥណទានដោយផ្អែកលើព័ត៌មាននៅក្នុងរបាយការណ៍ឥណទាន។
- **អតិថិជន** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលមួយឬច្រើនដែលទិន្នន័យ/ព័ត៌មានរបស់ខ្លួនត្រូវបានឬអាចត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទោះក្នុងទំនាក់ទំនងជាកិច្ចសន្យាជាមួយនឹងអ្នកឱ្យខ្ចី ឬពាក្យសុំខ្ចីប្រាក់ដែលចុះហត្ថលេខាដោយអតិថិជន ឬក្នុងគោលបំណងស្របច្បាប់ណាមួយផ្សេងទៀត។
- **អ្នកធានា** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលទាំងឡាយណាដែលធានា ឬប្រើមធ្យោបាយណាមួយ ដើម្បីធានាការសងបំណុល ឬបំពេញកាតព្វកិច្ចណាមួយដល់ម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលមិនបានសងបំណុល ឬបំពេញកាតព្វកិច្ចណាមួយតាមកិច្ចសន្យា។
- **អ្នកប្រើប្រាស់ប្រតិស្រុតិ (Authorized user)** សំដៅដល់បុគ្គលទាំងឡាយណាដែលទទួលបានការអនុញ្ញាតឱ្យមានសិទ្ធិបញ្ចូលនិងទាញយកទិន្នន័យពីដាតាបេស្ស (Database)។ អ្នកប្រើប្រាស់ប្រតិស្រុតិ រួមមាន និយោជិតដែលចាត់តាំងដោយអ្នកផ្តល់ទិន្នន័យ និយោជិតរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មន្ត្រី-បុគ្គលិកដែលបានចាត់តាំងដោយធនាគារជាតិនៃកម្ពុជានិងនីតិបុគ្គលដទៃផ្សេងៗទៀត ដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។
- **អ្នកផ្តល់ទិន្នន័យ** សំដៅដល់គ្រឹះស្ថានចំណុះច្បាប់ និងគ្រឹះស្ថាន/ក្រុមហ៊ុនដទៃទៀតដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់ព័ត៌មានចូលក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។
- **អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់អង្គភាពដែលធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទានហើយទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

ជំពូកទី ២
ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងការផ្តល់អាជ្ញាបណ្ណ

ប្រការ ៤.- ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលនឹងបង្កើតឡើងត្រូវមានប្រសិទ្ធភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាន ដើម្បីធានាប្រព្រឹត្តកម្មស្មើភាពនិងត្រឹមត្រូវ សម្រាប់អ្នកផ្តល់ទិន្នន័យ និងអ្នកចូលរួមក្នុងទីផ្សារឥណទានផ្សេងទៀត។

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.- ការហាមឃាត់

ក. គ្មានបុគ្គលណាអាចធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ឬបង្ហាញដល់សាធារណជនថាខ្លួនធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទានដោយពុំមានអាជ្ញាបណ្ណាពីធនាគារជាតិនៃកម្ពុជាឡើយ។

ខ. គ្មានបុគ្គលណា ត្រូវបានផ្តល់អាជ្ញាបណ្ណឱ្យអនុវត្តសកម្មភាពចែករំលែកព័ត៌មានឥណទានបានឡើយ លើកលែងតែនីតិបុគ្គលដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម។

គ. ប្រការនេះពុំអនុវត្តចំពោះធនាគារជាតិនៃកម្ពុជា ដែលធ្វើប្រតិបត្តិការចែករំលែកព័ត៌មានឥណទានឡើយ។

ប្រការ ៦.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

នីតិបុគ្គលណាដែលមានបំណងចង់ប្រកបអាជីវកម្មលើសកម្មភាពចែករំលែកព័ត៌មានឥណទានត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា តាមគំរូពាក្យស្នើសុំអាជ្ញាបណ្ណដែលបានកំណត់។

ប្រការ ៧.- ឯកសារសម្រាប់ជាដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

រាល់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវភ្ជាប់មកជាមួយនូវព័ត៌មាន និងឯកសារពាក់ព័ន្ធ ដូចខាងក្រោម៖

ក. ឯកសារពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងនឹងស្ថានភាពស្របច្បាប់របស់ក្រុមហ៊ុន

ខ. របាយការណ៍ទាក់ទងនឹងបទពិសោធន៍ពីមុនៗរបស់ស្ថាបនិកក្រុមហ៊ុន នៅក្នុងវិស័យធនាគារនិងឥណទាន រួមទាំងបញ្ជីឈ្មោះរបស់ភាគទុនិក ចំនួនប្រាក់ដែលបានដាក់វិនិយោគ និងការវិនិយោគនៅក្រុមហ៊ុនផ្សេងទៀត

គ. សមាសភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់

ឃ. ក្រុមអ្នកគ្រប់គ្រងត្រូវមានសញ្ញាបត្រសាកលវិទ្យាល័យ និងមានបទពិសោធន៍គ្រប់គ្រាន់ពាក់ព័ន្ធក្នុងទីផ្សារឥណទាន វិស័យធនាគារឬហិរញ្ញវត្ថុ

ង. រចនាសម្ព័ន្ធអង្គភាព ផែនការអាជីវកម្ម ៣ (បី) ឆ្នាំសម្រាប់ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រព័ន្ធព័ត៌មានវិទ្យា នីតិវិធីផ្ទៃក្នុង និងសៀវភៅណែនាំប្រតិបត្តិការ

ច. ការសិក្សាពីភាពអាចធ្វើបានតាមផែនការអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់អាជីវកម្ម ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនានាជាមួយអ្នកផ្តល់ទិន្នន័យផ្សេងទៀត

ឆ. រចនាសម្ព័ន្ធកម្មសិទ្ធិ និងអភិបាលកិច្ច រួមទាំងសមាសភាពនៃក្រុមប្រឹក្សាភិបាល និងលក្ខណៈវិនិច្ឆ័យ

ជ. ផែនការនិរន្តរភាព

ឈ.សំណើគោលនយោបាយកំណត់ថ្លៃ

ញ. ក្រមប្រតិបត្តិនិងវិធានពាក់ព័ន្ធផ្សេងទៀតសម្រាប់ដំណើរការប្រព័ន្ធ និង

ដ. សេចក្តីប្រកាសរបស់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តតាមក្រមប្រតិបត្តិនេះ។

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យផ្តល់ឯកសារចាំបាច់ផ្សេងទៀតសម្រាប់ការវាយតម្លៃលើពាក្យស្នើសុំនេះ។

ប្រការ ៨.- នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យស្នើសុំទាំងអស់ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ រួមជាមួយឯកសារពាក់ព័ន្ធដទៃទៀតមកធនាគារជាតិនៃកម្ពុជា។

នៅក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំគ្រប់គ្រាន់រួមទាំងឯកសារពាក់ព័ន្ធនឹងការបង់សោហ៊ុយសិក្សាសំណុំលិខិត ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីការឯកភាព ឬការបដិសេធលើពាក្យស្នើសុំនោះ។

ជំពូកទី ៣
គោលការណ៍នៃការប្រើប្រាស់ព័ត៌មាន

ប្រការ ៩.- ទិសដៅនៃសេវាចែករំលែកព័ត៌មាន

ការផ្តល់សេវាចែករំលែកព័តិមានឥណទានមានទិសដៅ ដូចខាងក្រោម៖

ក. វាយតម្លៃអំពីលទ្ធភាពសងនិងការជំពាក់បំណុលរបស់អតិថិជន ឬអ្នកធានា នៅពេលដាក់ពាក្យស្នើសុំខ្ចីឥណទាន

ខ. គាំទ្រធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីត្រួតពិនិត្យ ដើម្បីតាមដានលំហូរឥណទានក្នុងប្រព័ន្ធហិរញ្ញវត្ថុ វិភាគទិន្នន័យសម្រាប់ធ្វើរបាយការណ៍អំពីស្ថិរភាពហិរញ្ញវត្ថុ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ. វាយតម្លៃហានិភ័យឥណទាន និង/ឬ ពិនិត្យឥណទានឡើងវិញ

ឃ. វាយតម្លៃហានិភ័យនៃប្រតិបត្តិការដែលមានការខកខានទូទាត់សងប្រាក់ ឬតាមរយៈការចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

ង. ផ្តល់សិទ្ធិឱ្យអតិថិជន ឬអ្នកធានា មានលទ្ធភាពផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័តិមានរបស់ខ្លួនផ្ទាល់ ដែលមានក្នុងរបាយការណ៍ឥណទាន

ច. វាយតម្លៃ ឬធ្វើសវនកម្មអំពីប្រសិទ្ធភាពនិងភាពអាចទុកចិត្តបាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាននិងការប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមាន

ឆ. ជួយគាំទ្រការស្គាល់អតិថិជនឱ្យកាន់តែច្បាស់ រួមទាំងកំណត់អត្តសញ្ញាណបុគ្គលដែលអាចពាក់ព័ន្ធនឹងសកម្មភាព ក្លែងបន្លំអត្តសញ្ញាណ ចោរកម្ម និងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង

ជ. ជួយសម្រួលឱ្យអតិថិជនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុទាំងនៅក្នុងនិងក្រៅប្រទេស។

ព័ត៌មានដែលមាននៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្រៅពីទិសដៅដូចមានចែងក្នុងប្រការនេះឡើយ លើកលែងតែទទួលបានការយល់ព្រមជាក់លាក់ជាមុនពីអតិថិជន។

ប្រការ ១០.- កាតព្វកិច្ចរបស់តាគីពាក់ព័ន្ធក្នុងការធានាគុណភាពទិន្នន័យ

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យ ត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីឱ្យប្រាកដថា ព័ត៌មានអតិថិជនដែលបានប្រមូល ប្រើប្រាស់ និងបើកចំហ គឺជាព័ត៌មានដែលត្រឹមត្រូវពេញលេញនិងដែលបានធ្វើបច្ចុប្បន្នកម្ម។ ទិន្នន័យនឹងត្រូវប្រមូលដោយប្រើប្រាស់មធ្យោបាយត្រឹមត្រូវនិងស្របច្បាប់ ហើយត្រូវបញ្ចូលតែព័ត៌មានចាំបាច់ ដូចជា អត្តសញ្ញាណដែលមានសុពលភាព សារតារសងឥណទានរបស់អតិថិជន និងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យមានកាតព្វកិច្ច ដូចខាងក្រោម៖

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន៖

១. ត្រូវបង្កើតនីតិវិធីសមស្រប ដើម្បីធានាឱ្យបាននូវភាពពេញលេញ និងភាពត្រឹមត្រូវនៃព័ត៌មាន

២. ត្រូវធានាថាទិន្នន័យនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ ស្របតាមក្រមប្រតិបត្តិ

៣. ត្រូវបង្កើតយន្តការសមស្របសម្រាប់កែតម្រូវ និងលុបទិន្នន័យដើម្បីធានាថា រាល់អ្នកប្រើប្រាស់ទាំងអស់ ដែលបានចូលយកទិន្នន័យមិនត្រឹមត្រូវក្នុងរយៈពេល ៣ (បី) ខែកន្លងមក ត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីកំហុសនិងកែតម្រូវទិន្នន័យ ដោយស្របទៅតាមពេលកំណត់ជាក់លាក់ដូចមានចែងនៅក្នុងក្រមប្រតិបត្តិ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថាអ្នកប្រើប្រាស់ទាំងអស់ ដែលមានសិទ្ធិប្រើប្រាស់ទិន្នន័យក្នុងរយៈពេល ៣ (បី) ខែចុងក្រោយនេះ បានដឹងពីកំហុសនិងទទួលបានព័ត៌មានត្រឹមត្រូវវិញ ហើយច្បាប់ចម្លងនៃទិន្នន័យនោះក៏នឹងត្រូវផ្ញើទៅឱ្យអតិថិជនផងដែរ

៤. ត្រូវទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ និងអតិថិជន នូវកំហុសទិន្នន័យនានា ដែលបានកើតឡើងក្នុងពេលដំណើរការ ឬចែកចាយទិន្នន័យឥណទាន ដែលបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវ៖

- កែតម្រូវទិន្នន័យភ្លាមៗ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថា អ្នកប្រើប្រាស់ទាំងអស់ដែលបានប្រើប្រាស់ទិន្នន័យក្នុងរយៈពេល ៣ (បី) ខែចុងក្រោយបានដឹងពីកំហុសនេះនិងទទួលបានព័ត៌មានត្រឹមត្រូវវិញបន្ទាប់ពីបានធ្វើបច្ចុប្បន្នកម្ម
- ទទួលរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នកម្មនោះ ហើយត្រូវប្រគល់ទៅឱ្យអតិថិជន
- ទទួលខុសត្រូវចំពោះការប្តឹងទាមទាររបស់អតិថិជនពីកំហុស ដែលអាចបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិសព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់
- ប្រឹងប្រែងតាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយការខូចខាតនានាដែលទទួលរងដោយអតិថិជនដោយសារតែទិន្នន័យមិនត្រឹមត្រូវនេះ។

៥. ត្រូវទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ ធនាគារជាតិនៃកម្ពុជា ឬតតិយជនណាមួយ សម្រាប់រាល់ការទាមទារពាក់ព័ន្ធនឹងការពន្យារពេលការរំខាន ឬការខកខានមិនបានផ្តល់ព័ត៌មានឥណទាន ឬរបាយការណ៍ស្តិតិ លើកលែងតែហេតុការណ៍ទាំងនោះបណ្តាលមកពីការបង្គាប់បញ្ជារបស់រាជរដ្ឋាភិបាល ការធ្វើវិទ្ធង្សនា កុបកម្ម ការបំផ្លាញទ្រព្យសម្បត្តិជាសាធារណៈ ការបដិសេធសេវាពីអ្នកផ្តល់សេវាអ៊ីនធឺណិត ឬរាល់មូលហេតុដទៃទៀត ដែលហួសពីសមត្ថកិច្ចរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

៦. មិនត្រូវផ្ទេរ លក់ ឬជួលរាល់ព័ត៌មានឥណទានដែលត្រូវបានបញ្ចូលក្នុងប្រព័ន្ធដោយអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិ លើកលែងការអនុញ្ញាតទាំងឡាយដែលស្ថិតក្រោមប្រកាសនេះ និង

៧. អាចចែករំលែកព័ត៌មានឥណទានឆ្លងប្រទេសក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងការផ្តល់ព័ត៌មានឥណទាន ដោយត្រូវមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា និងត្រូវយកចិត្តទុកដាក់ជាពិសេសលើ៖

- ការការពារសិទ្ធិឯកជនរបស់អតិថិជន
- ការបញ្ជាក់អំពីដំណោះស្រាយលើវិវាទ និងការកែប្រែទិន្នន័យ

- ការរក្សាសុវត្ថិភាពទិន្នន័យ និង
- ការទទួលបានការយល់ព្រមជាមុនពីអតិថិជន។

ខ. អ្នកផ្តល់ទិន្នន័យត្រូវទទួលខុសត្រូវចំពោះ៖

១. ព័ត៌មានមិនត្រឹមត្រូវណាដែលខ្លួនបានផ្តល់ឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

២. ការប្តឹងទាមទាររបស់អតិថិជនអំពីកំហុសនានា ដែលអាចបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិសព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់ ស្របតាមការសម្រេចដែលធ្វើឡើងក្រោមយន្តការដោះស្រាយវិវាទ ដូចមានចែងក្នុងប្រការ ២៨ នៃប្រកាសនេះ និង

៣. ការខិតខំកាត់បន្ថយការខូតខាតរបស់អតិថិជនដែលបណ្តាលមកពីទិន្នន័យមិនត្រឹមត្រូវតាមរយៈការបង្កើតឱ្យមាននូវគោលនយោបាយ និងតម្រូវការនីតិវិធីចាំបាច់នានា។

ព័ត៌មានឥណទាននិងសេវាដទៃទៀតដែលផ្តល់ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់ទុកជាឧបករណ៍មួយសម្រាប់ដំណើរការនៃការសម្រេចលើហានិភ័យឥណទាន ប៉ុន្តែការសម្រេចក្នុងការផ្តល់ឥណទានមិនត្រូវធ្វើឡើងដោយគ្រាន់តែផ្អែកទៅលើមូលដ្ឋានព័ត៌មានឥណទាន ដែលបានទទួលពីអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមួយប៉ុណ្ណោះទេ។ អ្នកផ្តល់ទិន្នន័យនីមួយៗត្រូវមានវិធានក្នុងការសម្រេចផ្តល់ឥណទានរបស់ខ្លួន។

ប្រការ ១១.- សុវត្ថិភាពទិន្នន័យ

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាននិងអ្នកផ្តល់ទិន្នន័យ ត្រូវធានាសុវត្ថិភាពនិងភាពត្រឹមត្រូវនៃដាតាបេស្ស (Database) ឱ្យបានគ្រប់ពេលវេលា។ ដើម្បីបង្ការការប្រើប្រាស់មិនត្រឹមត្រូវ ឬការចូលយកព័ត៌មានទិន្នន័យប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតទិន្នន័យ រាល់ដំណើរការចាំបាច់នានាត្រូវមានវិធានការ ដូចខាងក្រោម៖

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមានប្រព័ន្ធ កិច្ចដំណើរការ និងនីតិវិធីក្នុងការទាញយកទិន្នន័យមកវិញ និងត្រូវមានផែនការស្តារគ្រោះមហន្តរាយ ដើម្បីទប់ស្កាត់ការបាត់បង់ ឬការខូចខាតទិន្នន័យដូចជា៖

១. ត្រូវអនុញ្ញាតឱ្យចូលទៅក្នុងដាតាបេស្ស (Database) ចំពោះតែអ្នកប្រើប្រាស់ប្រតិស្រុតិប៉ុណ្ណោះ

២. ត្រូវមានយន្តការសមស្របដើម្បីធានាថា ទិន្នន័យត្រូវបានឱ្យប្រើប្រាស់សម្រាប់តែទិសដៅដែលបានអនុញ្ញាតប៉ុណ្ណោះ ឬសម្រាប់ទិសដៅស្របច្បាប់ផ្សេងទៀត ដោយមានការយល់ព្រមពីអតិថិជន ស្របតាមប្រការ ៩ នៃប្រកាសនេះ។

ខ. អ្នកផ្តល់ទិន្នន័យត្រូវធានាឱ្យមានជាស្រេចនូវនីតិវិធី គោលនយោបាយ និងវិធានការសុវត្ថិភាពគ្រប់គ្រាន់។ គោលនយោបាយ និងវិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានត្រូវតែអនុម័តដោយក្រុមប្រឹក្សាភិបាលនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ វិធានការដែលបានអនុម័តត្រូវឆ្លុះបញ្ចាំងពីលក្ខណៈបច្ចេកទេស រចនាសម្ព័ន្ធចាត់តាំង និងបច្ចេកវិទ្យា។

គ. ក្នុងករណីមានការបាត់បង់ ឬបែកធ្លាយទិន្នន័យ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ឬអ្នកផ្តល់ទិន្នន័យ មានកាតព្វកិច្ចចាំបាច់ក្នុងការចាត់វិធានការទប់ស្កាត់ជាបន្ទាន់ និងត្រូវជូនដំណឹងភ្លាមៗមកធនាគារជាតិនៃកម្ពុជា។

ប្រការ ១២.- រយៈពេលរក្សាទុកនិងបញ្ចាញទិន្នន័យ

ក. ព័ត៌មានប្រមូលដោយប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានរក្សាទុកនិងបែងចែកក្នុងចំណោមអ្នកផ្តល់ទិន្នន័យសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃឥណទានត្រូវបានទូទាត់សងគ្រប់ចំនួនក្នុងករណីព័ត៌មានវិជ្ជមាន។

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបង្ហាញទិន្នន័យ ដូចខាងក្រោម៖

១. ព័ត៌មានឥណទានវិជ្ជមានត្រូវបង្ហាញក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន

២. ព័ត៌មានឥណទានអវិជ្ជមានត្រូវបង្ហាញក្នុងរយៈពេល ៣ (បី) ឆ្នាំគិតពីថ្ងៃឥណប្រតិទាន

៣. ព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីត្រូវបង្ហាញក្នុងរយៈពេល ២ (ពីរ) ឆ្នាំ គិតពីថ្ងៃដែលមូលប្បទានបត្រនោះត្រូវបានប្រគល់ត្រឡប់ទៅគ្រឹះស្ថានវិញ

៤. ទិន្នន័យអំពីការក្ស័យធននិងការជម្រះបញ្ជីរបស់អង្គភាពតាមផ្លូវច្បាប់ត្រូវបង្ហាញក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ដោយគិតពីកាលបរិច្ឆេទនៃសេចក្តីប្រកាសអំពីការក្ស័យធន ឬការជម្រះបញ្ជី។

គ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវរក្សាទុកទិន្នន័យទាំងអស់ជាកាលប្បវត្តិយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ។

ប្រការ ១៣.- សិទ្ធិអតិថិជន

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងភាគីពាក់ព័ន្ធ ត្រូវធានាថា៖

ក. សិទ្ធិរបស់អតិថិជន អ្នកធានា និងបហារ័កចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ត្រូវបានគោរពចំពោះការប្រើប្រាស់ ការចែករំលែក ការបាត់បង់ និងការបែកធ្លាយទិន្នន័យ។ ក្នុងករណីមានការបាត់បង់ ឬបែកធ្លាយទិន្នន័យ អតិថិជន អ្នកធានា និងបហារ័កចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីមានសិទ្ធិទទួលបានព័ត៌មានទាំងនោះ។

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតឱ្យមានផ្នែកមួយដែលមាននីតិវិធី និងវិធានច្បាស់លាស់ដើម្បីដោះស្រាយការតវ៉ា និងសំណើរបស់បុគ្គលដែលពាក់ព័ន្ធនឹងទិន្នន័យរបស់ខ្លួន។

គ. ទិន្នន័យពាក់ព័ន្ធនឹងនិន្នាការនយោបាយ ជំនឿសាសនា ពណ៌សម្បុរ ពូជសាសន៍ និងព័ត៌មានឯកជនរបស់បុគ្គល មិនត្រូវបានប្រមូល ឬរក្សាទុកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ។

ឃ. ទិន្នន័យត្រូវបានប្រមូលសម្រាប់តែប្រើប្រាស់ក្នុងគោលបំណងដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។ ទិន្នន័យដែលបានប្រមូល ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីមានចែងក្នុងប្រការ ៩ នេះ ត្រូវមានការយល់ព្រមច្បាស់លាស់ពីអតិថិជន អ្នកធានា និងបហារ័កចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី។

ជំពូកទី ៤
អ្នកផ្តល់ទិន្នន័យ

ប្រការ ១៤.- គ្រឹះស្ថានចំណុះច្បាប់

ក. គ្រឹះស្ថានចំណុះច្បាប់ត្រូវចូលរួមផ្តល់រាល់ព័ត៌មានឥណទានទាំងវិជ្ជមាននិងអវិជ្ជមាន ព្រមទាំងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានយ៉ាងតិច ១ (មួយ) ដង ក្នុង ១ (មួយ) ខែ។

ខ. ការយល់ព្រមរបស់អតិថិជន អ្នកធានា និងបហារ័កចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី គឺជាការចាំបាច់សម្រាប់ការផ្តល់និងប្រើប្រាស់ទិន្នន័យ ហើយការយល់ព្រមនោះនៅតែមានសុពលភាពសម្រាប់ការបន្តឥណទាន ឬការពិនិត្យឥណទានឡើងវិញ ឬការស្នើសុំឥណទានបន្ថែមរហូតដល់ការបញ្ចប់នៃឥណទាននោះ។ ធនាគារជាតិនៃកម្ពុជានឹងបង្កើតទម្រង់ស្តង់ដារយល់ព្រមជាគំរូ ដើម្បីឱ្យគ្រឹះស្ថានចំណុះច្បាប់ទាំងអស់ប្រើប្រាស់។ គ្រឹះស្ថានចំណុះច្បាប់អាចប្រើប្រាស់ស្តង់ដារផ្សេងៗទៀតបាន ឱ្យតែអត្ថន័យនិងអត្ថបទមានភាពច្បាស់លាស់ហើយមានសង្គតិភាពទៅនឹងទម្រង់ស្តង់ដាររបស់ធនាគារជាតិនៃកម្ពុជា។

គ. អ្នកផ្តល់ទិន្នន័យដែលទើបទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាត្រូវរៀបចំនីតិវិធី ដំណើរការ និងប្រព័ន្ធរបស់ខ្លួនឱ្យស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីថ្ងៃទទួលបានការអនុញ្ញាត។

ឃ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវផ្តល់សេវាស្មើភាពចំពោះអ្នកចូលរួមទាំងអស់ ដោយគ្មានការរើសអើងចំពោះអ្នកផ្តល់ទិន្នន័យឡើយ។

ប្រការ ១៥.- អ្នកប្រើប្រាស់និងអ្នកផ្តល់ទិន្នន័យផ្សេងទៀត

ក. គ្រឹះស្ថានក្រៅពីគ្រឹះស្ថានចំណុះច្បាប់ អាចចូលរួមផ្តល់និងចូលប្រើប្រាស់ទិន្នន័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នៅពេលដែលទទួលបានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជានិងមានការយល់ព្រមជាមុនពីអតិថិជន។

ខ. អ្នកប្រើប្រាស់ប្រតិស្រុតិ និងអ្នកផ្តល់ទិន្នន័យទាំងអស់ ទោះបីស្ថិត ឬមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ត្រូវស្ថិតនៅក្រោមវិធាន កាតព្វកិច្ច និងទណ្ឌកម្ម ដូចមានចែងនៅក្នុងប្រកាសនេះ។

គ. យោងតាមវិធានបដិការ គ្រឹះស្ថានដែលមិនបានរាយការណ៍រាល់ព័ត៌មានដែលតម្រូវ មិនត្រូវបានអនុញ្ញាតឱ្យទទួលព័ត៌មានទាំងឡាយណាដែលបានបញ្ចូលក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយអ្នកផ្តល់ទិន្នន័យផ្សេងទៀតឡើយ។

ឃ. ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យមានការចូលរួមរបស់អ្នកផ្តល់ទិន្នន័យថ្មី នៅពេលដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាសកម្មភាពរបស់គេមានភាពចាំបាច់នៅក្នុងទីផ្សារឥណទានកម្ពុជា។

ជំពូកទី ៥
ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ប្រការ ១៦.- អភិបាលកិច្ចសាជីវកម្ម

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាជិកយ៉ាងតិចចំនួន ៧ (ប្រាំពីរ) រូប ដែលក្នុងនោះសមាជិក ១ (មួយ) រូប ជាតំណាងមកពីធនាគារជាតិនៃកម្ពុជា និង ១ (មួយ) រូបទៀត ជាអភិបាលឯករាជ្យ។

ខ. សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់អំពីប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ។ គ្មានជនណាម្នាក់ ត្រូវតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ ប្រសិនបើជននោះត្រូវបានផ្តន្ទាទោសពី៖

១. បទឧក្រិដ្ឋណាមួយ

២. បទលួច បទក្លែងបន្លំ ឬបទរំលោភលើសេចក្តីទុកចិត្ត

៣. បទគៃបំបាត់

៤. ព្រឺទ្ធិកម្ម

៥. ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៦. ការចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

៧. ការក្ស័យធនផ្ទាល់ខ្លួន ការដាក់ទ្រព្យសម្បត្តិក្រោមអភិបាលបណ្តោះអាសន្ន ឬការជម្រះបញ្ជីទ្រព្យសម្បត្តិ។

គ. នាយកប្រតិបត្តិត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល។ គ្មានជនណាម្នាក់ត្រូវបានតែងតាំងជានាយកប្រតិបត្តិទេ ប្រសិនបើជននោះជា៖

១. ជនដែលទទួលទោសពីបទឧក្រិដ្ឋណាមួយ

២. អនីតិជន ឬអសមត្ថជនតាមផ្លូវច្បាប់

៣. ជនដែលទទួលទោសពីបទលួច ឬក្លែងបន្លំដែលបណ្តាលឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ

៤. ជនដែលត្រូវបានបណ្តេញចេញពីមុខតំណែង ដោយសារតែបានយកមុខតំណែងទៅប្រើប្រាស់ក្នុងគោលបំណងមិនត្រឹមត្រូវ ឬបានប្រព្រឹត្តអំពើពុករលួយក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំចុងក្រោយនេះ

៥. ជនដែលត្រូវបានផ្តន្ទាទោសពីបទរំលោភលើសេចក្តីទុកចិត្ត និង

៦. នាយកប្រតិបត្តិ ឬសមាជិកក្រុមប្រឹក្សាភិបាលរបស់អ្នកប្រើប្រាស់ប្រតិស្រុតិ និងអ្នកផ្តល់ទិន្នន័យ។

ឃ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតផ្នែកមួយដើម្បីអនុវត្តការគោរពសិទ្ធិអតិថិជន ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងវិធានការសុវត្ថិភាព។

ង. ក្រុមប្រឹក្សាភិបាលត្រូវធានាថា ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ននិងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី ៦

ដំណើរការនៃប្រព័ន្ធ

ប្រការ ១៧.- ប្រភពទិន្នន័យ

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវប្រមូល បញ្ចូល និងចែករំលែកព័ត៌មានឥណទាន ព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី និងទិន្នន័យពាក់ព័ន្ធនឹងអតិថិជនពីប្រភពដូចខាងក្រោម៖

១. គ្រឹះស្ថានចំណុះច្បាប់ អ្នកប្រើប្រាស់ប្រតិស្រុតិ និងអ្នកផ្តល់ទិន្នន័យផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

២. ព័ត៌មានពីប្រភពផ្សេងទៀតដែលមានជាសាធារណៈតាមមធ្យោបាយស្របច្បាប់។

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចមានលទ្ធភាពបញ្ចូលនិងប្រើប្រាស់ព័ត៌មានដែលអាចរកបានជាសាធារណៈពីប្រភពផ្សេងទៀត ដូចខាងក្រោម៖

   ១. ស្ថាប័ន ឬអង្គភាពទទួលបន្ទុកលើការចុះបញ្ជីពាណិជ្ជកម្ម ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

   ២. ស្ថាប័ន ឬអង្គភាពទទួលបន្ទុករក្សាទុកឯកសារសម្គាល់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ លិខិតឆ្លងដែន និងព័ត៌មានពន្ធដារ ជាដើម

   ៣. ទិន្នន័យសេចក្តីសម្រេចរបស់តុលាការនិងដំណើរការក្ស័យធនប្រសិនបើមាន និងអាចប្រមូលបានតាមធ្យោបាយស្របច្បាប់។

គ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចប្រមូលទិន្នន័យពីបណ្តាស្ថាប័ន ឬអង្គភាពផ្សេងៗទៀត ដែលផ្តល់សេវា អគ្គិសនី ផ្គត់ផ្គង់ទឹក ទូរស័ព្ទ អ៊ីនធឺណិត និងសេវាផ្សេងទៀតដែលមានទម្រង់ជាឥណទាន ឱ្យតែមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

ប្រការ ១៨.- ការប្រមូលនិងការចែករំលែក

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវប្រមូល រៀបចំ និងរក្សាទុកព័ត៌មានឥណទាននិងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ដែលទទួលបានពីអ្នកផ្តល់ទិន្នន័យ និងពីប្រភពផ្សេងៗទៀតតាមដែលអាចធ្វើទៅបាន រាប់បញ្ចូលទាំងសេចក្តីណែនាំអំពីប្រតិបត្តិការក្នុងការការពារទិន្នន័យពីការប្រើប្រាស់មិនត្រឹមត្រូវ ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតនៃប្រព័ន្ធ។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមាននីតិវិធីត្រួតពិនិត្យគុណភាពដើម្បីធានាឱ្យបាននូវនិរន្តរភាពសេវាកម្ម។

ខ. អ្នកផ្តល់ទិន្នន័យត្រូវផ្តល់សំពៀតឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីទាំងអស់ ដោយអនុលោមតាមទម្រង់និងគំរូដែលកំណត់ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយមានការព្រមព្រៀងជាមួយក្រុមប្រឹក្សាផ្តល់យោបល់។ ទម្រង់ដំបូងនឹងត្រូវយកតាមទម្រង់ដែលមានក្នុងឧបសម្ព័ន្ធ ១ (ទម្រង់ឯកសារ)។ ទម្រង់ឯកសារនេះចែកចេញជាពីរផ្នែក៖ ផ្នែកទី១ ចែងពីព័ត៌មានស្តីពីអត្តសញ្ញាណរបស់អតិថិជន អ្នកធានា និងបហារ័កចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី និងផ្នែកទី២ ចែងពីទិន្នន័យនៃប្រតិបត្តិការឥណទាន និងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី។

គ. អ្នកផ្តល់ទិន្នន័យត្រូវផ្តល់ឯកសារដំបូងក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីកាលបរិច្ឆេទចាប់ផ្តើម។

១. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបញ្ចូលទិន្នន័យពាក់ព័ន្ធស្របតាមទម្រង់ឯកសារដែលបានទទួលពីអ្នកផ្តល់ទិន្នន័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃធ្វើការបន្ទាប់ពីបានទទួលទិន្នន័យនោះ

២. អ្នកផ្តល់ទិន្នន័យទាំងអស់ ត្រូវផ្តល់ព័ត៌មានឥណទាននិងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ដែលបានធ្វើបច្ចុប្បន្នកម្មរបស់ខ្លួនជារៀងរាល់ខែ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ នៃខែបន្ទាប់

៣. សំណុំឯកសារដែលផ្តល់ដោយអ្នកប្រើប្រាស់ប្រតិស្រុតិត្រូវផ្តល់ជូនតាមទម្រង់ដែលបង្កើតដោយក្រុមប្រឹក្សាភិបាល និងឯកភាពដោយក្រុមប្រឹក្សាផ្តល់យោបល់។

ឃ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវទទួលខុសត្រូវចំពោះដាតាបេស្ស (Database) របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងត្រូវផ្តល់សេវាព័ត៌មានឥណទានដល់គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ផ្សេងទៀត អនុលោមតាមប្រកាសនេះ ក្រមប្រតិបត្តិ ឬបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

ង. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវទទួលខុសត្រូវចំពោះការលេចធ្លាយទិន្នន័យដោយសារការខូចខាតនៃប្រព័ន្ធ ឬការប្រើប្រាស់ទិន្នន័យមិនសមស្របពីសំណាក់និយោជិតរបស់ខ្លួន។

ច. គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត មិនត្រូវលក់ ឬលាតត្រដាងព័ត៌មានឥណទាននិងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីដល់តតិយជនឡើយ។ គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត មិនត្រូវប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីផ្តល់សេវាកម្មឱ្យតតិយជន ឬធ្វើយុទ្ធនាការស្វែងរកទីផ្សារក្រៅពីអតិថិជនរបស់ខ្លួនឡើយ។

ឆ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចកែប្រែលក្ខខណ្ឌសេវាកម្ម ដើម្បីធានា ឬលើកកម្ពស់គុណភាពសេវាកម្ម។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវផ្ញើសេចក្តីជូនដំណឹងដល់អ្នកផ្តល់ទិន្នន័យក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ មុនលក្ខខណ្ឌថ្មីចូលជាធរមាន។

ប្រការ ១៩.- ការចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ក. គ្រឹះស្ថានចំណុះច្បាប់ទាំងអស់ត្រូវប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីវិភាគលើឥរិយាបទនៃការសងប្រាក់របស់អតិថិជន និងអ្នកធានា នៅពេលដែលគ្រឹះស្ថាន

ចំណុះច្បាប់នេះទទួលបានពាក្យសុំខ្ចីប្រាក់ថ្មី ឬពាក្យសុំបន្ត ឬពន្យារឥណទានចាស់ដោយមិនគិតពីទំហំនៃឥណទានឡើយ។

១. សិទ្ធិចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានផ្តល់ឱ្យតែអ្នកផ្តល់ទិន្នន័យឬអ្នកប្រើប្រាស់ប្រតិស្រុតិដែលស្ថិតក្រោមលក្ខខណ្ឌដូចមានចែងនៅក្នុងក្រមប្រតិបត្តិ ឬលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា

២. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវរៀបចំ ដំណើរការ នីតិវិធី និងវិធានដើម្បីកំណត់អ្នកប្រើប្រាស់ប្រតិស្រុតិដែលនឹងត្រូវបានអនុញ្ញាត។

ខ. អ្នកផ្តល់ទិន្នន័យផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាត្រូវផ្តល់ព័ត៌មានឥណទាន និងចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយឈរលើមូលដ្ឋានស្មគ្រចិត្ត និងអនុលោមតាមវិធានបដិការ និងក្រមប្រតិបត្តិ។

គ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវធានាថា សេវាកម្មមានសុវត្ថិភាព ស្ថិរភាព និងអាចប្រើប្រាស់បាន ហើយត្រូវធានាថា ប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានសមត្ថភាពពេញលេញក្នុងការផ្តល់សេវាកម្មដល់អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិ។

ឃ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមិនទទួលខុសត្រូវចំពោះការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ដោយសារតែអ្នកផ្តល់ទិន្នន័យឬអ្នកប្រើប្រាស់ប្រតិស្រុតិបានចែករំលែក ឬបានបើកចំហលេខកូដ ឬពាក្យសម្ងាត់របស់ខ្លួនឱ្យតតិយជនចូលប្រើប្រាស់។

ង. អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិទាំងអស់ត្រូវគោរពតាមនីតិវិធី និងវិធានការពារសុវត្ថិភាពដែលបានអនុម័ត និងមានចែងនៅក្នុងក្រមប្រតិបត្តិ។

ប្រការ ២០.- សេវាកម្មផ្សេងទៀត

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្នើសុំការណែនាំពីក្រុមប្រឹក្សាផ្តល់យោបល់មុនពេលដាក់ឱ្យប្រើប្រាស់សេវាកម្ម ឬផលិតផលថ្មី។ ក្រុមប្រឹក្សានេះ ត្រូវធ្វើរបាយការណ៍ដែលមានសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើភាពត្រឹមត្រូវនៃផលិតផលចំពោះឥណទាយកទាំងអស់ និងផលប៉ះពាល់ចំពោះអតិថិជន។ ក្រុមប្រឹក្សា ត្រូវប្រគល់របាយការណ៍នេះឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃស្នើសុំ។

ប្រការ ២១.- គោលនយោបាយកំណត់ថ្លៃ

ក. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចយក សោហ៊ុយ កម្រៃ ឬពិន័យចំពោះការប្រើប្រាស់សេវាកម្មរបស់ខ្លួន ដោយផ្អែកលើគោលនយោបាយមួយប្រកបដោយតម្លាភាព និងសមស្របតាមសេវាកម្មដែលបានផ្តល់។

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្នើសុំការយល់ព្រមពីធនាគារជាតិនៃកម្ពុជាចំពោះការកែប្រែគោលនយោបាយកំណត់ថ្លៃ មុនពេលដាក់ឱ្យអនុវត្ត។ ធនាគារជាតិនៃកម្ពុជានឹងពិនិត្យពិចារណាពាក្យស្នើសុំនិងសំណុំលិខិតពាក់ព័ន្ធ ដោយអនុម័តយល់ព្រម ឬបដិសេធក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការ។

ជំពូកទី ៧
សិទ្ធិអតិថិជន

ប្រការ ២២.- សេចក្តីជូនដំណឹងអំពីសិទ្ធិឯកជន

ក. ផ្អែកលើលក្ខខណ្ឌយល់ព្រមរបស់អតិថិជន អ្នកផ្តល់ទិន្នន័យត្រូវជូនដំណឹងដល់អតិថិជន អ្នកធានា និងបហារ័ក នូវរាល់ការបញ្ចូលព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទាំងនៅពេលដាក់ពាក្យសុំខ្ចី សុំបន្ត ឬសុំពន្យារពេលឥណទាន ឬសុំទិញសៀវភៅមូលប្បទានបត្រ។ លក្ខខណ្ឌនេះត្រូវមានព័ត៌មានយ៉ាងតិច ដូចខាងក្រោម៖

   ១. ឈ្មោះអ្នកផ្តល់ទិន្នន័យ

   ២. គោលបំណងនៃការប្រមូលព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

   ៣. ឈ្មោះ និងអាសយដ្ឋាននៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និង

   ៤. មធ្យោបាយដើម្បីទទួលបានព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ប្រសិនបើមានតម្រូវការកែប្រែឬកែសម្រួល។

ខ. គ្រឹះស្ថានចំណុះច្បាប់ និងគ្រឹះស្ថានមិនចំណុះច្បាប់ នៅពេលបានក្លាយជាអ្នកផ្តល់ទិន្នន័យ ត្រូវបញ្ចូលកំណត់សម្គាល់អំពីសិទ្ធិឯកជនក្នុងពាក្យសុំខ្ចីឥណទាន ពាក្យស្នើសុំបើកគណនីមូលប្បទានបត្រ និងពាក្យស្នើសុំប្រើសេវាផ្សេងៗ។

គ. ប្រសិនបើមានសកម្មភាពមិនអំណោយផល ប៉ះពាល់ដល់អតិថិជននិងអ្នកធានា ដោយសារលទ្ធផលនៃការវិភាគព័ត៌មានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកផ្តល់ទិន្នន័យត្រូវជូនដំណឹងដល់អតិថិជននិងអ្នកធានាក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃធ្វើការ។

ប្រការ ២៣.- ការផ្អាកការចែករំលែកព័ត៌មាន

ក. អតិថិជន អ្នកធានា ឬបហារ័ក អាចស្នើសុំអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានផ្អាកការចែករំលែកព័ត៌មានរបស់ខ្លួន ក្នុងករណីមានការក្លែងបន្លំ ឬលួចប្រើអត្តសញ្ញាណរបស់អតិថិជន អ្នកធានា ឬបហារ័ក។

ខ. អតិថិជន អ្នកធានា ឬបហារ័ក ត្រូវផ្តល់ភស្តុតាងគ្រប់គ្រាន់សម្រាប់ការស្នើសុំផ្អាកការចែករំលែកព័ត៌មានដល់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃស្នើសុំ។

គ. ក្នុងករណីការស្នើសុំផ្អាកការចែករំលែកព័ត៌មានមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវជូនដំណឹងដល់អតិថិជន អ្នកធានា ឬបហារ័ក អំពី៖

១. ការផ្អាកការចែករំលែកព័ត៌មានរបស់អ្នកស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

២. ប្រសិនបើផុតកំណត់នៃរយៈពេលផ្អាកនេះ អតិថិជន អ្នកធានា ឬបហារ័ក អាចស្នើសុំពន្យារពេលបន្ថែមទៀតយ៉ាងយូរត្រឹម ៣០ (សាមសិប) ថ្ងៃ។ ការពន្យារពេលនេះអាចធ្វើបានតែ ១ (មួយ) ដងគត់។

៣. ក្នុងករណីមិនមានការស្នើសុំពន្យារពេលមុនថ្ងៃផុតកំណត់ ឬការស្នើសុំពន្យារពេលត្រូវបានបដិសេធ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចដំណើរការចែករំលែកព័ត៌មានឡើងវិញ គិតចាប់ពីថ្ងៃផុតកំណត់នៃការផ្អាកនោះ។

ឃ. ក្នុងករណីអតិថិជន អ្នកធានា ឬបហារ័ក មិនមានភស្តុតាង ឬមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់តាមពេលកំណត់ក្នុងការស្នើសុំការផ្អាកការចែករំលែកព័ត៌មាន អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចដំណើរការការចែករំលែកព័ត៌មានជាធម្មតា។

ង. ប្រសិនបើអតិថិជនមានបំណងស្នើសុំឥណទានពីគ្រឹះស្ថានចំណុះច្បាប់ នៅពេលដែលព័ត៌មានរបស់ខ្លួនត្រូវបានផ្អាក អតិថិជនអាចធ្វើសំណើជាលាយលក្ខណ៍អក្សរស្នើសុំរបាយការណ៍ព័ត៌មានឥណទានពីអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីបង្ហាញព័ត៌មាននោះដល់គ្រឹះស្ថានចំណុះច្បាប់។

ប្រការ ២៤.- ការសម្ងាត់វិជ្ជាជីវៈ

ក. ព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីជាព័ត៌មានសម្ងាត់ដែលត្រូវបានប្រើប្រាស់សម្រាប់តែទិសដៅដូចបានអនុញ្ញាតក្នុងប្រការ ៩ នៃប្រកាសនេះ។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិ ត្រូវរក្សាការសម្ងាត់នេះឱ្យបានម៉ឺងម៉ាត់ ហើយមិនត្រូវលក់ ឬផ្តល់ព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីដល់តតិយជនណាម្នាក់បានឡើយ។

ខ. ធនាគារជាតិនៃកម្ពុជា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកប្រើប្រាស់ប្រតិស្រុតិ អាចចូលប្រើប្រាស់ព័ត៌មាន សម្រាប់តែការបំពេញតួនាទីរបស់ខ្លួនប៉ុណ្ណោះ។

គ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវអនុវត្តរាល់វិធានការចាំបាច់នានាដើម្បីធានាថា អភិបាល គណៈគ្រប់គ្រង និងនិយោជិតរបស់ខ្លួនរក្សាបានជាប្រចាំនូវការសម្ងាត់នៃព័ត៌មាននិងត្រូវមានវិធានការសមស្របដើម្បីបង្ការការចូលទៅយកព័ត៌មានដោយគ្មានការអនុញ្ញាត ហើយត្រូវរៀបចំនិងអនុវត្តគោលនយោបាយ និងនីតិវិធីរក្សាសុវត្ថិភាពសម្រាប់ការគ្រប់គ្រងការចូលទៅយកព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី។

ឃ. ធនាគារជាតិនៃកម្ពុជា មានសិទ្ធិចូលយកព័ត៌មានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយពុំមានបង់សោហ៊ុយនិងកម្រៃ ដើម្បីបំពេញមុខងាររបស់ខ្លួនជាអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានចំណុះច្បាប់និងមានសិទ្ធិចូលយកព័ត៌មានដទៃទៀតដែលទាក់ទងទៅនឹងគ្រឹះស្ថានមិនចំណុះច្បាប់ ដើម្បីតាមដានស្ថិរភាពជាទូទៅនៃវិស័យហិរញ្ញវត្ថុ។

ង. ធនាគារជាតិនៃកម្ពុជា មានសិទ្ធិត្រួតពិនិត្យប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីបំពេញមុខងារត្រួតពិនិត្យរបស់ខ្លួនក្នុងការរក្សាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព ភាពត្រឹមត្រូវនិងស្របច្បាប់នៃប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ច. អភិបាលនិងនិយោជិតនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកប្រើប្រាស់ប្រតិស្រុតិនិងនិយោជិតនៃអ្នកផ្តល់ទិន្នន័យ ត្រូវចុះហត្ថលេខាជាមុនលើកិច្ចព្រមព្រៀងស្តីពីការរក្សាការសម្ងាត់ មុនមានសិទ្ធិចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ប្រការ ២៥.- សិទ្ធិក្នុងការឧទ្ធរណ៍បានព័ត៌មាន

ក. អតិថិជនមានសិទ្ធិស្នើសុំរបាយការណ៍ព័ត៌មានរបស់ខ្លួន ១ (មួយ) ច្បាប់ ១ (មួយ) ដងក្នុង ១ (មួយ) ឆ្នាំ ដោយត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យបានច្បាស់លាស់។

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវផ្តល់របាយការណ៍ជូនអតិថិជនដោយឥតគិតថ្លៃ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើ។ របាយការណ៍នេះត្រូវមាន ព័ត៌មានរបស់អតិថិជន ឈ្មោះរបស់អ្នកផ្តល់ទិន្នន័យ និងបញ្ជីអ្នកផ្តល់ទិន្នន័យទាំងអស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងក្រោយ។

គ. អតិថិជនអាចស្នើសុំរបាយការណ៍លើសពី ១ (មួយ) ដង ក្នុង ១ (មួយ) ឆ្នាំ ប៉ុន្តែត្រូវបង់កម្រៃតាមអត្រាកំណត់ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ឃ. អតិថិជនមានសិទ្ធិស្នើសុំកែប្រែព័ត៌មាន ដែលមិនត្រឹមត្រូវឬមិនគ្រប់ជ្រុងជ្រោយនៅពេលណាក៏បាន។

ង. នីតិវិធីលម្អិតអំពីសិទ្ធិអតិថិជនអាចរកបានពីអ្នកផ្តល់ទិន្នន័យនិងអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានទាំងអស់ដោយផ្ទាល់ឬតាមគេហទំព័ររបស់អ្នកទាំងនោះ។

ជំពូកទី ៨
ការត្រួតពិនិត្យ

ប្រការ ២៦.- តួនាទីរបស់ធនាគារជាតិនៃកម្ពុជា

ក. ធនាគារជាតិនៃកម្ពុជា មានតួនាទីរៀបចំបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យរាល់សកម្មភាពចែករំលែកព័ត៌មានឥណទាន រួមទាំងការទំនាក់ទំនងជាមួយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានឬអ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិពាក់ព័ន្ធនឹងប្រសិទ្ធភាពនិងដំណើរការត្រឹមត្រូវនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ខ. ធនាគារជាតិនៃកម្ពុជា មានសិទ្ធិ៖

១. ផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

២. តាមដានការប្រតិបត្តិតាមវិធាន បទប្បញ្ញត្តិ ក្រមប្រតិបត្តិ លក្ខខណ្ឌ នីតិវិធី និងប្រព័ន្ធប្រតិបត្តិការនានា

៣. ត្រួតពិនិត្យភាពសមស្របនៃយន្តការ ក្នុងការធានានិរន្តរភាពនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានរាប់ទាំងលក្ខខណ្ឌនៃការបើកដំណើរការនិងការបញ្ឈប់អាជីវកម្មនិងលក្ខខណ្ឌផ្សេងៗទៀត

៤. តាមដានការអនុវត្តរាល់សេចក្តីសម្រេចដែលបានអនុម័តដោយក្រុមប្រឹក្សាផ្តល់យោបល់

៥. តម្រូវឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តវិធានការចាំបាច់ដើម្បីឱ្យមានការចូលរួមចែករំលែកព័ត៌មានជាកាតព្វកិច្ចពីគ្រឹះស្ថានចំណុះច្បាប់ និងអ្នកប្រើប្រាស់ប្រតិស្រុតិនិងការចូលរួមដោយស្ម័គ្រចិត្តពីគ្រឹះស្ថានមិនចំណុះច្បាប់ដែលធ្វើប្រតិបត្តិការនៅក្នុងទីផ្សារឥណទាន

៦. ដាក់ពិន័យ និងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងជំពូកទី ៩ នៃប្រកាសនេះ ទៅលើភាគីទាំងអស់ដែលចូលរួមក្នុងសកម្មភាពប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយមិនកម្រិតត្រឹមអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ និងអតិថិជននោះទេ និង

៧. តម្រូវឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានរាយការណ៍តាមគ្រា និងតាមយថាហេតុ។

ប្រការ ២៧.- ក្រុមប្រឹក្សាផ្តល់យោបល់

ក. ក្រុមប្រឹក្សាផ្តល់យោបល់ត្រូវមានសមាជិកពី ៥ (ប្រាំ) រូប ដល់ ១១ (ដប់មួយ) រូប។ សមាសភាពនៃក្រុមប្រឹក្សានេះត្រូវមានសមាជិកតំណាងឱ្យ ធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាភិបាលនិងអគ្គនាយករបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អ្នកផ្តល់ទិន្នន័យ អ្នកជំនាញឯករាជ្យ និងអាជ្ញាធរដែលពាក់ព័ន្ធដទៃទៀត។

ខ. ក្រុមប្រឹក្សាផ្តល់យោបល់ត្រូវស្ថិតក្រោមការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវកោះប្រជុំយ៉ាងតិច ២ (ពីរ) ដង ក្នុង ១ (មួយ) ឆ្នាំ ឬច្រើនជាងនេះ តាមការចាំបាច់។

គ. ដើម្បីធានាបាននូវប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន និងសុវត្ថិភាពនៃប្រព័ន្ធ ក្រុមប្រឹក្សាផ្តល់យោបល់ត្រូវកោះប្រជុំឱ្យបានទៀងទាត់ដើម្បីអនុម័តចំណុចដូចខាងក្រោម៖

១. ចក្ខុវិស័យជាយុទ្ធសាស្ត្រនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា

២. ទម្រង់និងខ្លឹមសារនៃសំណុំឯកសារព័ត៌មានឥណទាន និងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

៣. វិធានប្រតិបត្តិការសម្រាប់ការគ្រប់គ្រង សេវាចែករំលែកព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

៤. បច្ចុប្បន្នកម្មរយៈពេលបញ្ចូលនិងបើកចំហទិន្នន័យ ព័ត៌មានឥណទាននិងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

៥. ផលិតផលនិងសេវាទាំងអស់របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងវិធីសាស្ត្របញ្ជូនដទៃទៀត រាប់បញ្ចូលទាំងបច្ចេកវិទ្យានិងវិធានការសុវត្ថិភាពផង

៦. ការចូលរួមរបស់សមាជិកថ្មី

៧. ភាពគ្រប់គ្រាន់នៃបច្ចេកវិទ្យានិងភាពស៊ីសង្វាក់គ្នា (Homogenization) នៃសេវាព័ត៌មានវិទ្យាក្នុងការផ្តល់ទិន្នន័យ

៨. ខ្លឹមសារនៃសៀវភៅណែនាំពីប្រតិបត្តិការ និងបច្ចេកទេសទាក់ទងនឹងសុវត្ថិភាពប្រតិបត្តិការ សិទ្ធិអតិថិជន ការដោះស្រាយវិវាទ និងរាល់ការកែប្រែខ្លឹមសារនេះ

៩. ខ្លឹមសារនៃក្រមប្រតិបត្តិ

១០. ភាពសមស្របនៃសេវានិងផលិតផលដែលបានផ្តល់ និងគោលនយោបាយកំណត់ថ្លៃ

១១. កម្មវិធីអប់រំសម្រាប់មន្ត្រីឥណទាន ដើម្បីប្រើប្រាស់ទិន្នន័យឱ្យបានត្រឹមត្រូវ និង

១២. ផ្តល់អនុសាសន៍ដល់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទាក់ទងនឹងការផ្តល់សេវា ឬការប្រព្រឹត្តទៅរបស់អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត។

ប្រការ ២៨.- យន្តការដោះស្រាយវិវាទ

ក. គ្រឹះស្ថានចំណុះច្បាប់ គ្រឹះស្ថានមិនចំណុះច្បាប់ អតិថិជន អ្នកធានា និងបហារ័ក ត្រូវបញ្ជូនរាល់ការដាក់ពាក្យតវ៉ាពាក់ព័ន្ធនឹងសុក្រឹតភាពព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ទៅអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីពិនិត្យដោះស្រាយ។

ខ. នៅពេលទទួលបានពាក្យតវ៉ា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវពិនិត្យដោះស្រាយចំពោះវិវាទនោះ និងត្រូវឆ្លើយតបទៅអ្នកដាក់ពាក្យតវ៉ាក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យតវ៉ាដោយ៖

១. ប្រសិនបើពាក់ព័ន្ធនឹងសំណើកែតម្រូវព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីដែលមិនត្រឹមត្រូវ ឬមិនគ្រប់ជ្រុងជ្រោយ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវជូនដំណឹងទៅឱ្យអ្នកផ្តល់ទិន្នន័យយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃធ្វើការ។ អ្នកផ្តល់ទិន្នន័យត្រូវពិនិត្យនិងកែតម្រូវព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង។

២. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវជូនដំណឹងទៅអ្នកតវ៉ា ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការឆ្លើយតបពេញលេញពីអ្នកផ្តល់ទិន្នន័យអំពីលទ្ធផលនៃការតវ៉ា។

គ. អ្នកតវ៉ាដែលមិនពេញចិត្តចំពោះការសម្រេចនេះ អាចបន្តតវ៉ាទៅធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១០ (ដប់) ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីសម្រេច។

ឃ. ប្រសិនបើអ្នកតវ៉ាមិនពេញចិត្តចំពោះការសម្រេចរបស់ធនាគារជាតិនៃកម្ពុជា អ្នកតវ៉ាអាចប្តឹងទៅតុលាការ។

ជំពូកទី ៩
នីតិវិធីរដ្ឋបាល

ប្រការ ២៩.- ការប្រព្រឹត្តល្មើស

អ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ ឬគ្រឹះស្ថានមិនចំណុះច្បាប់ដែលប្រើប្រាស់ព័ត៌មានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ក្នុងគោលបំណងផ្សេងក្រៅពីគោលបំណងនៃប្រកាសនេះ ត្រូវទទួលខុសត្រូវចំពោះការរំលោភលើបញ្ញត្តិនៃការសម្ងាត់វិជ្ជាជីវៈ និងទទួលទោសដូចមានចែងក្នុងច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៣០.- ការពិន័យអន្តរការណ៍

បុគ្គលណាដែលបានប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះត្រូវរងការពិន័យអន្តរការណ៍ដូចខាងក្រោម៖

ក. ជនណាដែលប្រតិបត្តិសម្រាប់ខ្លួនឯង ឬប្រតិបត្តិជំនួសឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងសកម្មភាពចែករំលែកព័ត៌មានឥណទានដោយមិនមានអាជ្ញាបណ្ណ ត្រូវរងការពិន័យអន្តរការណ៍ជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ដល់ ២៥0.000.000 (ពីររយហាសិបលាន) រៀល ដោយមិនគិតដល់ការបិទគ្រឹះស្ថាននោះឡើយ។

ខ. បុគ្គល ឬអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិណាដែលប្រើប្រាស់ព័ត៌មានទទួលបានមកពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងគោលបំណងក្រៅពីទិសដៅដែលមានចែងនៅក្នុងប្រកាសនេះ ត្រូវរងការពិន័យអន្តរការណ៍ជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀលដល់ ២៥0.000.000 (ពីររយហាសិបលាន) រៀល។

គ. គ្រឹះស្ថានចំណុះច្បាប់ និងគ្រឹះស្ថានមិនចំណុះច្បាប់ត្រូវរងការពិន័យអន្តរការណ៍ជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ដល់ ៥0.000.000 (ហាសិបលាន) រៀល ក្នុងករណី៖

១. ប្រព្រឹត្តល្មើសនឹងក្រមប្រតិបត្តិ

២. មិនបានបញ្ចូលព័ត៌មានឥណទាន ឬព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីឱ្យបានគ្រប់ជ្រុងជ្រោយនិងត្រឹមត្រូវ

៣. មិនបានចូលប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានសម្រាប់ការងារវាយតម្លៃឥណទាន

៤. មិនបានឆ្លើយតបតាមការស្នើសុំព័ត៌មាន របស់ធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ

៥. មានចេតនាផ្តល់ព័ត៌មានមិនពិត ឬមិនគ្រប់ជ្រុងជ្រោយទាក់ទងនឹងការតវ៉ាមកឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីពិនិត្យដោះស្រាយ

៦. មិនបានអនុវត្តតាមពេលកំណត់ស្របតាមសិទ្ធិអតិថិជន អ្នកធានា និងបហារ័ក

៧. មិនបានស្នើសុំការយល់ព្រមជាមុនពី អតិថិជន អ្នកធានា និងបហារ័ក

៨. បញ្ចូលព័ត៌មានមិនត្រឹមត្រូវ ឬធ្វេសប្រហែស ដែលបង្កឱ្យប៉ះពាល់ដល់កិត្តិសព្ទ ហិរញ្ញវត្ថុរបស់អតិថិជន អ្នកធានា និងបហារ័ក។

ឃ. ក្នុងករណីអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមិនអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងការពិន័យអន្តរការណ៍ជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀលដល់ ២៥0.000.000 (ពីរយហាសិបលាន) រៀល។

ង. ក្រៅពីការពិន័យអន្តរការណ៍ខាងលើ បុគ្គលដែលប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ឬក្នុងក្រមប្រតិបត្តិ អាចរងទណ្ឌកម្មខាងវិន័យ និងទណ្ឌកម្មខាងព្រហ្មទណ្ឌ តាមច្បាប់ជាធរមាន។

ជំពូកទី ១០
អវសានប្បញ្ញត្តិ

ប្រការ ៣១.- និរាករណ៍

ប្រកាសលេខ ធ៧-0១១-១៤៥ ប្រ.ក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២0១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣២.- ការអនុវត្ត

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៣៣.- ការចូលជាធរមាន

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២0២0

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចែករំលែកព័ត៌មានឥណទាន

ឧបសម្ព័ន្ធ ១

ក) ទិន្នន័យសម្គាល់អត្តសញ្ញាណអតិថិជន អ្នកធានា និងបុគ្គលពាក់ព័ន្ធ

<u>រូបវន្តបុគ្គល</u>

(១) នាមត្រកូល និងនាមខ្លួន
(២) ភេទ
(៣) ថ្ងៃ ខែ ឆ្នាំកំណើត
(៤) អាសយដ្ឋានស្នាក់នៅ
(៥) ឯកសារសម្គាល់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬបណ្ណស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតឆ្លងដែន) និង
(៦) លេខសម្គាល់អត្តសញ្ញាណកម្មបង់ពន្ធ

<u>នីតិបុគ្គល</u>

(១) ឈ្មោះអង្គភាព
(២) រចនាសម្ព័ន្ធចាត់តាំងនិងរូបភាពគតិយុត្ត
(៣) ទីតាំង
(៤) លេខនិងកាលបរិច្ឆេទចុះបញ្ជីជានីតិបុគ្គល
(៥) លេខអត្តសញ្ញាណកម្មបង់ពន្ធ
(៦) នាមត្រកូល និងនាមខ្លួនរបស់នាយកប្រតិបត្តិ អភិបាល និងម្ចាស់ភាគហ៊ុន និង
(៧) លេខអត្តសញ្ញាណកម្មបង់ពន្ធ នៃនាយកប្រតិបត្តិ អភិបាល និងម្ចាស់ភាគហ៊ុន

ខ) ទិន្នន័យឥណទាន

(១) កាលបរិច្ឆេទផ្តល់ឥណទាន និងទូទាត់សងប្រាក់ដើមនិងការប្រាក់ តាមការព្រមព្រៀង
(២) ឥណទានសរុប ឬឥណទានដទៃទៀតដែលបានផ្តល់ឱ្យអតិថិជន
(៣) រូបិយវត្ថុ
(៤) សមតុល្យដក់សល់បច្ចុប្បន្ន
(៥) ចំណាត់ថ្នាក់ឥណទានតាមប្រភេទហានិភ័យ
(៦) កាលបរិច្ឆេទនៃសកម្មភាពទូទាត់សងប្រាក់ចុងក្រោយ
(៧) ប្រភេទវត្ថុបញ្ចាំ សម្រាប់ធានាឥណទាន ប្រសិនបើមាន

(៨) ប្រភេទឥណទាន (និក្ខេប កម្ចីអតិថិជន និងឥណទានវិបារូបន៍។ល។)

(៩) ឈ្មោះឥណទាយក/ឬលេខពិសេស (Unique) របស់ឥណទាយក

(១០) មូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី

(១១) ឥណទានគ្មានលទ្ធភាពសង សមតុល្យនៅជំពាក់

(១២) សេចក្តីសម្រេចតុលាការពាក់ព័ន្ធនឹងកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ និង

(១៣) ព័ត៌មានដទៃទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា សម្រាប់ការត្រួតពិនិត្យ។

ក្នុងករណី អ្នកផ្តល់ឥណទានដែលលក់ទំនិញ ឬផ្តល់សេវាក្រោមរូបភាពជាឥណទាន ឬដោយមានលក្ខខណ្ឌពន្យារការទូទាត់សងប្រាក់៖

(១) បរិមាណទំនិញ និងសេវាដែលផ្តល់ក្រោមរូបភាពជាឥណទាន និងកាតព្វកិច្ចចាំបាច់មួយចំនួន

(២) កាលបរិច្ឆេទនៃការផ្តល់សេវា

(៣) កាលវិភាគនៃការទូទាត់សងប្រាក់ ដែលបានព្រមព្រៀង និង

(៤) ព័ត៌មានស្តីពីសមាសភាព និងប្រភេទវត្ថុបញ្ចាំដែលធានា កាតព្វកិច្ចទូទាត់សងប្រាក់។

ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចែករំលែកព័ត៌មានឥណទាន

ឧបសម្ព័ន្ធ ២
កំណត់សម្គាល់អំពីសិទ្ធិឯកជន

(កំណត់សម្គាល់អំពីសិទ្ធិឯកជនត្រូវមាននៅក្នុងពាក្យសុំឥណទានរបស់អ្នកផ្តល់ទិន្នន័យ។)

កំណត់សម្គាល់អំពីសិទ្ធិឯកជន

គ្រឹះស្ថាន (ឈ្មោះគ្រឹះស្ថាន) នឹងប្រមូលព័ត៌មានរបស់ (អតិថិជន អ្នកធានា និងបហារ័ក) ដើម្បីបញ្ចូលនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាប្រព័ន្ធដែលស្ថិតក្រោមការត្រួតពិនិត្យ របស់ធនាគារជាតិនៃកម្ពុជា។ ព័ត៌មានដែលប្រមូលបាននឹងត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃក្នុងការផ្តល់ឥណទាន ហើយព័ត៌មាននេះនឹងត្រូវបានចែករំលែកដល់គ្រឹះស្ថានដទៃទៀតដែលចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អនុលោមតាមប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និងក្រមប្រតិបត្តិ។ ប្រសិនបើលោកអ្នក (អតិថិជន អ្នកធានា និងបហារ័ក) ចង់បាន ឬចង់កែតម្រូវព័ត៌មានរបស់ខ្លួន លោកអ្នក (អតិថិជន អ្នកធានា និងបហារ័ក) អាចស្នើសុំជាលាយលក្ខណ៍អក្សរទៅអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយភ្ជាប់ជាមួយឯកសារសម្គាល់អត្តសញ្ញាណ ហើយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងឆ្លើយតបជូនលោកអ្នក (អតិថិជន អ្នកធានា និងបហារ័ក) វិញ។

ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចែករំលែកព័ត៌មានឥណទាន

ឧបសម្ព័ន្ធ ៣
លក្ខខណ្ឌនៃការយល់ព្រមសម្រាប់រូបវន្តបុគ្គល

(លក្ខខណ្ឌនៃការយល់ព្រមនេះត្រូវមាននៅក្នុងពាក្យសុំឥណទានរបស់អ្នកផ្តល់ទិន្នន័យ។)

ការយល់ព្រម

ខ្ញុំបាទ/នាងខ្ញុំ.....*(ឈ្មោះអតិថិជន)*.....ដែលមានអាសយដ្ឋាន.....*(អាសយដ្ឋានរបស់អតិថិជន)*.....និងមានអត្តសញ្ញាណ.....*(អត្តសញ្ញាណប័ណ្ណ បណ្ណស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន)*.....យល់ព្រមឱ្យគ្រឹះស្ថាន.....*(ឈ្មោះគ្រឹះស្ថាន)*.....ប្រមូលព័ត៌មានដែលមាននៅក្នុងពាក្យសុំនិងព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងពាក្យសុំនេះ ព្រមទាំងចែករំលែកព័ត៌មានទាំងនេះ ទៅឱ្យតតិយជនសម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំបាទ/នាងខ្ញុំយល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន.....(ឈ្មោះអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន).....និងគ្រឹះស្ថាន.....(ឈ្មោះគ្រឹះស្ថាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់គ្រឹះស្ថាន).....ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការចែករំលែកទិន្នន័យ។ ខ្ញុំបាទ/នាងខ្ញុំមានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និង/ឬ ក្រមប្រតិបត្តិ។

លក្ខខណ្ឌនៃការយល់ព្រមសម្រាប់អ្នកធានា

ខ្ញុំបាទ/នាងខ្ញុំ.....*(ឈ្មោះអ្នកធានា)*.....ដែលមានអាសយដ្ឋាន.....*(អាសយដ្ឋានរបស់អ្នកធានា)*.....និងមានអត្តសញ្ញាណ.....*(អត្តសញ្ញាណប័ណ្ណ បណ្ណស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន)*.....ជាអ្នកធានាចំពោះឥណទាន ដែលបានស្នើសុំដោយ.....*(ឈ្មោះអតិថិជន)*.....ដែលមានអាសយដ្ឋាន.....*(អាសយដ្ឋានរបស់អតិថិជន)*.....និងមានអត្តសញ្ញាណ.....*(អត្តសញ្ញាណប័ណ្ណ បណ្ណស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន)*.....សូមផ្តល់សិទ្ធិឱ្យគ្រឹះស្ថាន.....*(ឈ្មោះគ្រឹះស្ថាន)*..... ប្រមូលព័ត៌មានដែលមាននៅក្នុងពាក្យស្នើសុំ និងព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងពាក្យស្នើសុំនេះ ព្រមទាំងចែករំលែកព័ត៌មានទាំងនេះទៅឱ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំបាទ/នាងខ្ញុំយល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន.....(ឈ្មោះអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន).....និងគ្រឹះស្ថាន.....(ឈ្មោះគ្រឹះស្ថាន) .....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់គ្រឹះស្ថាន).....ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការចែករំលែកទិន្នន័យ។ ខ្ញុំបាទ/នាងខ្ញុំមានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និង/ឬ ក្រមប្រតិបត្តិ។

លក្ខខណ្ឌនៃការយល់ព្រមសម្រាប់នីតិបុគ្គល

ខ្ញុំបាទ/នាងខ្ញុំ.....*(ឈ្មោះ)*.....មានអាសយដ្ឋាន.....មានអត្តសញ្ញាណ.....*(អត្តសញ្ញាណប័ណ្ណ បណ្ណស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន)*..... ដែលមានតួនាទីជា *ភាគទុនិក អភិបាល ឬអ្នកតំណាងរបស់.....(ឈ្មោះក្រុមហ៊ុនដែលជាអតិថិជន)* .....ដែលមានអាសយដ្ឋាន.....*(អាសយដ្ឋានរបស់ក្រុមហ៊ុន)*.....ហើយមានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ.....*(លេខចុះបញ្ជីរបស់ក្រុមហ៊ុន)*.....សូមផ្តល់សិទ្ធិឱ្យគ្រឹះស្ថាន.....*(ឈ្មោះគ្រឹះស្ថាន)*.....ប្រមូលព័ត៌មានដែលមាននៅក្នុងពាក្យស្នើសុំដោយ.....*(ឈ្មោះរបស់ក្រុមហ៊ុនដែលជាអតិថិជន)*.....រួមទាំងព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំនិងព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងពាក្យស្នើសុំនេះ ព្រមទាំងចែករំលែកព័ត៌មានទាំងនេះទៅឱ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំបាទ/នាងខ្ញុំយល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន.....(ឈ្មោះអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន).....និងគ្រឹះស្ថាន.....(ឈ្មោះគ្រឹះស្ថាន) .....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់គ្រឹះស្ថាន).....ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការចែករំលែកទិន្នន័យ។ ខ្ញុំបាទ/នាងខ្ញុំមានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និង/ឬ ក្រមប្រតិបត្តិ។

លក្ខខណ្ឌនៃការយល់ព្រមសម្រាប់បហារ័ក

ខ្ញុំបាទ/នាងខ្ញុំ.....*(ឈ្មោះបហារ័ក)*.....ដែលមានអាសយដ្ឋាន.....*(អាសយដ្ឋានរបស់បហារ័ក)*.....និងមានអត្តសញ្ញាណ.....*(អត្តសញ្ញាណប័ណ្ណ បណ្ណស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន)*.....ជាអ្នកចេញមូលប្បទានបត្រ សូមផ្តល់សិទ្ធិឱ្យគ្រឹះស្ថាន.....*(ឈ្មោះគ្រឹះស្ថាន)*.....បញ្ចូលព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី និងចែករំលែកព័ត៌មានទាំងនេះទៅឱ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំបាទ/នាងខ្ញុំយល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន.....(ឈ្មោះអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន).....និងគ្រឹះស្ថាន.....(ឈ្មោះគ្រឹះស្ថាន).....ដែលមានអាសយដ្ឋាននៅ.....(អាសយដ្ឋានរបស់គ្រឹះស្ថាន).....ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការចែករំលែកទិន្នន័យ។ ខ្ញុំបាទ/នាងខ្ញុំមានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និង/ឬ ក្រមប្រតិបត្តិ។

១.៤. អត្រាការប្រាក់

ធ៥-០៣-០០៧ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់

ប្រការ ១.-

កំណត់អត្រាការប្រាក់បញ្ញើមានរយៈពេលកំណត់ជារៀល និងជាដុល្លារអាមេរិកសម្រាប់ផ្តល់ជូនអតិថិជនដែលបានធ្វើប្រាក់នៅធនាគារជាតិនៃកម្ពុជាក្រៅពីអតិថិជនជាស្ថាប័នរដ្ឋដែលពាក់ព័ន្ធជាមួយថវិកាដូចតទៅ៖

ក- អត្រាការប្រាក់បញ្ញើជារៀល

- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៣ ខែ ១.០០% ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៦ ខែ ១.២០% ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ១ ឆ្នាំ ២.០០% ក្នុងមួយឆ្នាំ

ខ- *(ត្រូវបានជំនួសដោយប្រការ ១ នៃប្រកាសលេខ ធ៥-០៩-០១១ ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានារលើដើមទុនជាវបិយប័ណ្ណដុល្លារអាមេរិក។)*

ប្រការ ២.-

អត្រាការប្រាក់ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣ តទៅរហូតដល់មានការកែប្រែជាថ្មី។

ប្រការ ៣.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០៩-០១១ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក

ប្រការ ១.-

អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ១ខែ ៣ខែ ៦ខែ ១ឆ្នាំ ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនតាមអត្រា ១/២ នៃ SIBOR (Singapore Inter-Bank Offered Rate)។

(SIBOR ត្រូវជំនួសដោយ LIBOR ដោយយោងតាមប្រកាសលេខ ធ៥-០១៤-០០២ ប្រ.ក ស្តីពី ការប្រើប្រាស់អត្រា LIBOR ជំនួស SIBOR។)

ប្រការ ២.-

អត្រាការប្រាក់លើប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច (Reserve Requirement) ដែលត្រូវទទួលការប្រាក់ ត្រូវបានផ្តល់ជូនតាមមាត្រា ១/២ នៃ SIBOR គិតលើមូលដ្ឋានមួយខែ។

(SIBOR ត្រូវជំនួសដោយ LIBOR ដោយយោងតាមប្រកាសលេខ ធ៥-០១៤-០០២ ប្រ.ក ស្តីពី ការប្រើប្រាស់អត្រា LIBOR ជំនួស SIBOR។)

ប្រការ ៣.-

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ខែ។

(SIBOR ត្រូវជំនួសដោយ LIBOR ដោយយោងតាមប្រកាសលេខ ធ៥-០១៤-០០២ ប្រ.ក ស្តីពី ការប្រើប្រាស់អត្រា LIBOR ជំនួស SIBOR។)

ប្រការ ៤.-

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០១៤-០០២ ប្រ.ក

ប្រកាស
ស្តីពី
ការប្រើប្រាស់អត្រា LIBOR ជំនួសអត្រា SIBOR

ប្រការ ១.-

ប្រើប្រាស់អត្រា LIBOR ជាប្រាក់ដុល្លារអាមេរិកជំនួសអត្រា SIBOR ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការទាំងឡាយដែលទាក់ទងនឹងអត្រា SIBOR នៅធនាគារជាតិនៃកម្ពុជា។

ប្រការ ២.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុតិ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៤.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៩-២១៣ ប្រ.ក

ប្រកាស
ស្តីពី
ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

ប្រការ ១ .-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។

ប្រការ ២ .-

រាល់ដំណាច់ខែនីមួយៗ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីអត្រាការប្រាក់ជាមធ្យមដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា។

ប្រការ ៣ .-

ប្រកាសលេខ ធ៥-៩៥-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤ .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥ .-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៧-១០៩ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់ពិដានអត្រាការប្រាក់ឥណទាន

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ពិដានអត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ហើយធ្វើប្រតិបត្តិការឥណទានជនបទ តទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះមានគោលដៅការពារអតិថិជនពីការគិតអត្រាការប្រាក់ខ្ពស់ពេកពីគ្រឹះស្ថាន និងជំរុញការប្រើប្រាស់ឥណទានឱ្យមានប្រសិទ្ធភាព។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានត្រូវកំណត់អត្រាការប្រាក់ឥណទាន មិនឱ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

ប្រការ ៥.-

ការកំណត់អត្រាការប្រាក់ឥណទានដូចមានចែងក្នុងប្រការ ៤ ខាងលើនេះ មានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំង ឥណទានរៀបចំឡើងវិញ (Restructured Loan) និងបុនហិរញ្ញប្បទាន (Refinancing) ដោយមានចុះហត្ថលេខា និង/ឬ ស្នាមផ្តិតមេដៃ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

ប្រការ ៦.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

១.៥. បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ធ៧-០២-២២០ ប្រ.ក

ប្រកាស
ស្តីពី
ប្រតិបត្តិការលើមូលបត្ររបស់ធនាគារ
ដែលមានអាជ្ញាបណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រការ ១.-

ធនាគារជាតិនៃកម្ពុជាគាំទ្រ និងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់ និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសម្របសម្រួលនីតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងសម្រួលការផ្តល់ឥណទាន និងការជួញដូរមូលបត្រជាអន្តរធនាគារ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តនូវស្តង់ដារពិសេសសម្រាប់ធ្វើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារការី ឬជាប្រតិបត្តិករមូលបត្រ។

ប្រការ ២.-

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារការីឬជាប្រតិបត្តិករមូលបត្រ បើធនាគារនោះផ្តល់ការធានា ឬជួញដូរ ឬធ្វើប្រព្រឹត្តិកម្មមូលបត្រ។ ប្រសិនបើការទិញនិងលក់មូលបត្ររយៈពេលខ្លីតាមរូបភាពដដែលៗបង្ហាញឱ្យប្រតិបត្តិករមូលបត្រ ឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលបត្រ ធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលបត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ។

ប្រការ ៣.-

ការសម្របសម្រួលនីតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតឱ្យធនាគារផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជា តាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជាដោយមានការសួរបញ្ជាក់តបវិញ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់ និងធនាគារទទួលប្រាក់ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោលដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយបង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលរបស់សាមីធនាគារវៀងៗខ្លួនផងដែរ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសម្រាប់មូលបត្ររបស់រដ្ឋាភិបាល នៅពេលណាដែលមូលបត្រនេះត្រូវបានចេញផ្សាយ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសម្រាប់ការជួញដូរមូលបត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារ នឹងត្រូវបង្កើតឡើងនៅពេលនោះ។

ប្រការ ៤.-

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារ ដែលធ្វើសកម្មភាពជួញដូរមូលបត្រ។ នីតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាលនិងការគ្រប់គ្រង ការត្រួតពិនិត្យលើគោលនយោបាយនិងកម្រិតហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការជួញដូរនិងការបែងចែកភារកិច្ច ការងារបណ្តុះបណ្តាលនិងកម្មវិធីផ្តល់កម្រៃដល់ប្រតិបត្តិកររនិងបុគ្គលិក ការកាន់កាប់មូលបត្រនិងការកត់ត្រាការជួញដូរនិងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ។ ការត្រួតពិនិត្យបែបនេះអាចជាផ្នែកមួយនៃការត្រួតពិនិត្យជារួមទៅលើធនាគារ ឬអាចមានលក្ខណៈដោយឡែកពីការត្រួតពិនិត្យដទៃទៀត។

ប្រការ ៥.-

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចម្លង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយ លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត។

ប្រការ ៦.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលនៃធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៤-០៣៨ ប្រ.ក

ប្រកាស
ស្តីពី
ភាតព្វកិច្ចអនុវត្តតាមខ្លឹមសារនិងការពិត

ប្រការ ១.-

គណនេយ្យកម្មរបស់ធនាគារត្រូវបង្ហាញពីទស្សន:ពិតនិងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ និងកាតព្វកិច្ចបើកចំហព័ត៌មាន ស្របទៅតាមគោលការណ៍គណនេយ្យនៃស្តង់ដារគណនេយ្យអន្តរជាតិនិងស្តង់ដារគណនេយ្យកម្ពុជា។ វិធានទូទៅនេះត្រូវតែបានអនុវត្តជាពិសេសលើពីរចំណុចគឺ គោលការណ៍នៃខ្លឹមសារមានទម្ងន់លើទម្រង់ និងការទទួលស្គាល់កម្រៃការប្រាក់លើមូលដ្ឋានបង្គរ។

ប្រការ ២.-

ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍និងប្រតិបត្តិការ ដោយមិនគ្រាន់តែបំពេញឱ្យត្រឹមត្រូវតាមគោលការណ៍នៃទម្រង់ប៉ុណ្ណោះទេ មានន័យថាការកត់ត្រាគណនេយ្យត្រូវផ្តល់សារសំខាន់លើខ្លឹមសារជាជាងលើទម្រង់។

ប្រការ ៣.-

ជាទូទៅ ធនាគារមិនត្រូវប្រើប្រាស់គណនេយ្យសម្រាប់លាក់បាំងប្រតិបត្តិការខ្លះ ដោយគ្រាន់តែប្រើប្រាស់ទម្រង់ឱ្យស្របតាមច្បាប់និងប្រកាសប៉ុណ្ណោះទេ ចំណែកឯខ្លឹមសារនៃប្រតិបត្តិការបែរជាអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់និងប្រកាសទៅវិញ។

ជាក់ស្តែង ប្រតិបត្តិការដែលប៉ះពាល់ដល់គោលការណ៍ខ្លឹមសារមានទម្ងន់លើទម្រង់ត្រូវបានអនុវត្តតាមរូបភាពជាកិច្ចសន្យាជួលឬទិញអចលនទ្រព្យ ដោយទូទាត់មុនរយៈពេលវែង ប៉ុន្តែតាមខ្លឹមសារ មានន័យថា ម្ចាស់ធនាគារបានដកដើមទុនរបស់ខ្លួនចេញទៅវិញ។

ប្រការ ៤.-

ក្នុងករណីដែលធនាគារជាតិនៃកម្ពុជារកឃើញប្រតិបត្តិការណាមួយដែលបញ្ជិកាគណនេយ្យមិនបានឆ្លុះបញ្ចាំងពីគោលការណ៍ខ្លឹមសារសេដ្ឋកិច្ច ក៏ប៉ុន្តែដោយគ្រាន់តែតម្រូវតាមគោលការណ៍ទម្រង់ឬកាតព្វកិច្ចនោះ ប្រតិបត្តិការនេះនឹងត្រូវបានតម្រូវឱ្យរៀបចំចុះបញ្ជិកាគណនេយ្យឡើងវិញតាមខ្លឹមសារពិត។

ប្រការ ៥.-

ក្នុងករណីភាគទុនិកដកដើមទុនដោយផ្អែកលើគោលការណ៍ទម្រង់ដើម្បីបង្កើនប្រាក់ចំណេញឬទ្រព្យសកម្ម ឬកាត់បន្ថយការខាតបង់ ឬទ្រព្យអកម្ម ចំនួនប្រាក់នៃប្រតិបត្តិការទាំងនោះនឹងត្រូវបានដកចេញពីដើមទុនផ្ទាល់និងមូលនិធិផ្ទាល់សុទ្ធ ហើយបើចាំបាច់ ធនាគារត្រូវតែបង់បំពេញដើមទុនឡើងវិញ។

ប្រការ ៦.-

ដោយមិនគិតដល់ប្រការ ៥ ធនាគារជាតិនៃកម្ពុជាអាចដាក់ទណ្ឌកម្មតាមមាត្រាទី ៣៣ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា និងមាត្រាទី ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

គណនេយ្យកម្មចំណាយនិងចំណូលរបស់ធនាគារត្រូវតែអនុវត្តស្របតាមស្តង់ដារគណនេយ្យកម្ពុជាដែលដូចគ្នាទៅនឹងស្តង់ដារគណនេយ្យអន្តរជាតិ។

គណនេយ្យកម្មការប្រាក់ត្រូវបានកំណត់ដូចតទៅ៖

- ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលផលប្រយោជន៍សេដ្ឋកិច្ចទៅអនាគតរំពឹងថាអាចហូរចូលទៅក្នុងសហគ្រាស ហើយការរំពឹងទុកពីផលប្រយោជន៍ទាំងនេះត្រូវបានវាស់ស្ទង់ថាអាចជឿទុកចិត្តបាន។
- ការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានសមាមាត្រពេលវេលាដែលត្រូវយកមកគិតគូរពីប្រសិទ្ធភាពនៃផលចំណូលពីទ្រព្យសកម្ម។
- ការទទួលស្គាល់ចំណូលនិងចំណាយការប្រាក់មានសារសំខាន់ក្នុងការកំណត់លទ្ធភាពចំណេញរបស់ធនាគារ។
- ចំណូលការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានបង្គរ លើកលែងតែក្នុងករណីឥណទានមិនដំណើរការ និងឥណទានមិនបានរៀបចំឡើងវិញ។

ប្រការ ៨.-

ដើម្បីផ្តល់នូវព័ត៌មានប្រកបដោយគុណភាពកម្រិតខ្ពស់ ធនាគារត្រូវកត់ត្រាជាប្រចាំថ្ងៃនូវ៖

- ការប្រាក់ដែលបានសងនិងបានទទួលពីអតិថិជន ធនាគារ អ្នកជំពាក់បំណុល និងឥណទាយកដទៃទៀត។
- ការរំលស់អចលនទ្រព្យនិងទ្រព្យសកម្មផ្សេងៗទៀត ប្រសិនបើចាំបាច់។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០៥-០២ ស.រ.ណ.ន

សារាចរណែនាំ
ស្តីពី
ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាពនៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

សារាចរណែនាំនេះ ជាការណែនាំពីការចាំបាច់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានប្រព័ន្ធត្រួតពិនិត្យតម្លាភាពនៅក្នុងប្រព័ន្ធគណនេយ្យ ដើម្បីអាចលើកកម្ពស់ភាពត្រឹមត្រូវនៃការកត់ត្រាបញ្ជីគណនេយ្យ ហើយអាចរំលេចនិងកែតម្រូវកំហុសឆ្គងទាំងឡាយបានឆាប់រហ័ស។ ប្រព័ន្ធត្រួតពិនិត្យតម្លាភាពជាចំណែកមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងមូលរបស់ធនាគារ និងកាត់បន្ថយហានិភ័យប្រតិបត្តិការជាអប្បបរមានៅក្នុងប្រតិបត្តិការធនាគារ។ ជាស្តង់ដារអប្បបរមា ធនាគារនីមួយៗត្រូវធានាថាចំណុចដូចខាងក្រោមនេះ មានចំណែកក្នុងប្រព័ន្ធត្រួតពិនិត្យតម្លាភាព៖

ការបែងចែកភារកិច្ចរបស់បុគ្គលិក

គ្រប់ធនាគារ មិនត្រូវអនុញ្ញាតឱ្យបុគ្គលិកតែម្នាក់អនុវត្តគ្រប់ផ្នែកទាំងអស់នៃប្រតិបត្តិការធនាគារទេ។ ឧទាហរណ៍ បុគ្គលិកតែម្នាក់មិនត្រូវផ្តល់អនុសាសន៍ អនុម័ត វិភាគ ចំណាយប្រាក់ កត់ត្រាបញ្ជី និងត្រួតពិនិត្យវត្ថុធានានៅក្នុងប្រតិបត្តិការឥណទានទេ។ បុគ្គលិកទទួលខុសត្រូវប្រតិបត្តិការកំព្យូទ័រមិនត្រូវឱ្យបង្កើតកម្មវិធីផង ឬកែប្រែកម្មវិធីផងទេ។ បេឡាធិការដែលជាអ្នកទទួលប្រាក់បញ្ញើសម្រាប់បញ្ចូលក្នុងគណនីអតិថិជនមិនត្រូវឱ្យទទួលខុសត្រូវចំពោះសៀវភៅធំទេ។ ជាទូទៅ មុខងារកត់ត្រា រក្សាទុក និងអនុញ្ញាតត្រូវកំណត់ដោយឡែកពីគ្នាសម្រាប់ប្រតិបត្តិការធនាគារនីមួយៗ។

ធនាគារត្រូវចៀសវាងស្ថានភាពទំនាស់ផលប្រយោជន៍ នៅពេលចាត់តាំងភារកិច្ចឱ្យបុគ្គលិក ដើម្បីធានាឱ្យមានប្រព័ន្ធតម្លាភាពដ៏ត្រឹមត្រូវ។

ការកត់ត្រានិងកិច្ចបញ្ជិកាគណនេយ្យ

ក្នុងករណីមានការចុះបញ្ជីទិន្នានុប្បវត្តិដោយដៃ ការចុះបញ្ជីទាំងនោះត្រូវតែមានការអនុញ្ញាតត្រឹមត្រូវពីមន្ត្រីធនាគារ។ មន្ត្រីធនាគារនេះត្រូវចុះហត្ថលេខាលើសក្តីបត្រគណនេយ្យទុកជាភស្តុតាងនៃការអនុញ្ញាតមុនពេលប្រតិបត្តិការអាចចុះបញ្ជីនៅក្នុងសៀវភៅធំ។ ក្នុងការចុះបញ្ជីកុំព្យូទ័រ ការអនុញ្ញាតជានិច្চកាលធ្វើឡើងនៅលើអេក្រង់កុំព្យូទ័រដោយផ្ទាល់។ ទោះយ៉ាងណាក៏ដោយ សិទ្ធិប្រើប្រាស់និងអនុញ្ញាតរបស់បុគ្គលិកត្រូវរក្សាទុកនៅក្នុងសំនុំឯកសារកុំព្យូទ័រ ហើយត្រូវតែមានការពិនិត្យឡើងវិញយ៉ាងត្រឹមត្រូវពីសំណាក់គណៈគ្រប់គ្រងក្នុងការបញ្ចូលការអនុញ្ញាតនិងការកែប្រែទិន្នន័យ។

គណនីនៅស្ងៀម ឬ គ្មានសកម្មភាព

ធនាគារត្រូវបែងចែកគណនីនៅស្ងៀមនិងគ្មានសកម្មភាពពីគណនីមានសកម្មភាព ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យគណនីទាំងនោះ។ គណនីមួយត្រូវបានចាត់ទុកថានៅស្ងៀម ប្រសិនបើ

គណនីនេះគ្មានសកម្មភាពលើសពី ១២ ខែ។ ធនាគារត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះគណនីចរន្តនិងគណនីសន្សំរបស់អតិថិជនដែលគ្មានសកម្មភាព។ ប្រព័ន្ធត្រួតពិនិត្យតម្លាភាពតម្រូវឱ្យមានការអនុញ្ញាតជាក់លាក់ពីមន្ត្រីជាន់ខ្ពស់ធនាគារ ក្នុងករណីដែលគណនីមិនមានសកម្មភាពពីមុនមកស្រាប់តែមានសកម្មភាពឡើងវិញ។

គ្រប់ធនាគារត្រូវផ្ទេរសមតុល្យឥណទានរបស់គណនីអតិថិជន ដែលមិនមានសកម្មភាពរយៈពេល ១០ ឆ្នាំ ជាប់គ្នាទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអភិបាលកិច្ចដោយអនុលោមទៅតាមមាត្រា ៧១ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

សមតុល្យប្រចាំខែនៃគណនីសាខា

រាល់គ្រាកំណត់ណាមួយធនាគារត្រូវផ្សៀងផ្ទាត់ថាសមតុល្យគណនីសាខា និងការកត់ត្រានៅក្នុងគណនីសាខាស៊ីគ្នាទៅនឹងគណនីមេនិងសៀវភៅធំ។ ការផ្សៀងផ្ទាត់នេះត្រូវធ្វើឡើងយ៉ាងហោចណាស់មួយដងក្នុងមួយខែ។

ការរាប់ទ្រព្យសកម្មជាក់ស្តែង

ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរ ដើម្បីរាប់ទ្រព្យសកម្មជាក់ស្តែងរាល់គ្រាកំណត់ណាមួយ ឱ្យវាស៊ីទៅនឹងគណនីមេនិងសៀវភៅធំ។ ចំណុចដូចខាងក្រោមបង្ហាញភាពញឹកញាប់អប្បបរមានៃការរាប់៖

ទ្រព្យសកម្មជាក់ស្តែង	ភាពញឹកញាប់
សាច់ប្រាក់នៅក្នុងដៃ	ប្រចាំខែ
មូលបត្រ	ប្រចាំខែ
វិញ្ញាបនបត្រប្រាក់បញ្ញើ	ប្រចាំខែ
វត្ថុធានា	ប្រចាំឆមាស
ប័ណ្ណឥណទេយ្យ	ប្រចាំត្រីមាស
ប័ណ្ណទូទាត់មានកាលកំណត់	ប្រចាំត្រីមាស
លិខិតឥណទានមិនទាន់ទូទាត់	ប្រចាំឆមាស
ការធានា	ប្រចាំឆមាស
ទ្រព្យសម្បត្តិ	ប្រចាំឆមាស
អចលនទ្រព្យ	ប្រចាំឆមាស

ការផ្សៀងផ្ទាត់សាច់ប្រាក់ជាមួយធនាគារ

ធនាគារត្រូវធានាថា ការផ្សៀងផ្ទាត់សាច់ប្រាក់ត្រូវអនុវត្តចំពោះគ្រប់គណនីប្រាក់បញ្ញើនៅបរទេស (គណនី Nostro) យ៉ាងតិចមួយខែម្តង។ ប្រតិបត្តិការដែលមិនអាចផ្សៀងផ្ទាត់បាន ត្រូវធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងឈានទៅសន្និដ្ឋានឱ្យបានត្រឹមត្រូវ។ ការផ្សៀងផ្ទាត់សាច់ប្រាក់ជាមួយធនាគារត្រូវមានការត្រួតពិនិត្យដោយមន្ត្រីធនាគារដែលត្រូវអនុម័តផង។

គណនីព្យួរទុក

ប្រតិបត្តិការដែលបានកត់ត្រានៅក្នុងគណនីព្យួរទុកត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ហើយផ្ទេរយ៉ាងត្រឹមត្រូវទៅកាន់លេខគណនីនៃប្លង់គណនីឯកភាព។ ខ្នង់ព្យួរទុកមិនត្រូវរក្សាទុកឱ្យលើសពី ២-៣ថ្ងៃទេ។ គណៈគ្រប់គ្រងធនាគារត្រូវលុបចោលខ្នង់នៃគណនីព្យួរទុកប្រសិនបើមិនអាចរកលេខគណនីណាមួយក្នុងប្លង់គណនីឯកភាពមកដាក់បានទេ។ គណនីនេះ មិនត្រូវយកមកប្រើប្រាស់នៅពេលប្លង់គណនីឯកភាពមានលេខគណនីសម្រាប់កត់ត្រាប្រតិបត្តិការ។

នីតិវិធីក្នុងការផ្ទុកទិន្នន័យ និងនីតិវិធីប្រមូលទិន្នន័យមកវិញក្នុងករណីមានអន្តរាយ

ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងការផ្ទុកទិន្នន័យនៃកំណត់ត្រាគណនេយ្យ កំណត់ត្រាអតិថិជន ឋាសនិងខ្សែអាត់កុំព្យូទ័រ បញ្ជីវត្ថុធានា និងឯកសារដទៃទៀតដែលមានតម្លៃ។ ក្នុងចំណោមខ្នង់មានបញ្ហាដែលត្រូវពិចារណាផ្សេងទៀតដូចជា ភាពញឹកញាប់នៃការផ្ទុកទិន្នន័យ ទីតាំងរក្សាទុកឯកសារ ឧបករណ៍ផ្ទុកឯកសារនិងនីតិវិធី។ ធនាគារត្រូវមាននីតិវិធីជាលាយលក្ខណ៍អក្សរស្តីពីការប្រមូលទិន្នន័យមកវិញ ក្នុងករណីមានអន្តរាយ និងផែនការបន្តអាជីវកម្មឡើងវិញ។

នីតិវិធីក្នុងការផ្ទុកទិន្នន័យនិងនីតិវិធីប្រមូលទិន្នន័យមកវិញក្នុងករណីមានអន្តរាយ ត្រូវមានការសាកល្បង យ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ។ ឯកសារត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ។

សវនកម្មផ្ទៃក្នុង

គ្រប់ធនាគារត្រូវបង្កើតឱ្យមានផ្នែកសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ទៅកាន់គណៈគ្រប់គ្រងខ្ពស់បំផុត ដែលមានឯករាជ្យភាពពីមុខងារប្រតិបត្តិដើម្បីរក្សាឯករាជ្យភាពនិងប្រសិទ្ធភាព។

គ្រប់ធនាគារត្រូវចងចាំពីប្រកាសលេខ ធ៧-០០-០៤ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារ ត្រង់មាត្រាទី ១ ស្តីពី សវនកម្មផ្ទៃក្នុង។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥

នាយកជ្ជានត្រួតពិនិត្យ

ហត្ថលេខា៖ **ជាន់ ហូរ តឹម ង៉ាងហ**

ធ៧-០៥-០៥៤ ប្រ.ក

ប្រកាស
ស្តីពី
គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន

ប្រការ ១.-

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានស្របតាមគោលនយោបាយឥណទានត្រឹមត្រូវនិងប្រុងប្រយ័ត្ន ការប្រតិបត្តិជាទូទៅនិងនីតិវិធីក្នុងការផ្តល់ឥណទានដែលត្រូវតែបានអនុម័តនិងពិនិត្យឡើងវិញដោយត្រឹមត្រូវពីគណៈគ្រប់គ្រង និង/ឬ ក្រុមប្រឹក្សាភិបាល។

ប្រការ ២.-

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើត៖

១. គោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរសម្រាប់ដាក់ចេញនូវគោលនយោបាយឥណទាន នីតិវិធីនិងកំណត់សិទ្ធិអំណាចឱ្យខ្ចីរបស់មន្ត្រីឥណទាន និង/ឬ គណៈកម្មការឥណទាន និងក្រុមប្រឹក្សាភិបាល ហើយគោលនយោបាយនិងនីតិវិធីទាំងនោះត្រូវតែបានបញ្ជូនទៅបុគ្គលិកដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ឥណទាន។

២. សំណុំឯកសារឥណទានរបស់អ្នកសុំខ្ចីទាំងអស់ត្រូវតែមានព័ត៌មានថ្មីៗគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។

ប្រការ ៣.-

គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចឱ្យខ្ចីត្រូវមានការវិភាគឥណទាន ដំណើរការអនុម័តឥណទាន នីតិវិធីពិនិត្យឥណទានឡើងវិញតាមគ្រា កម្រិតកំណត់អនុម័តឥណទានរបស់មន្ត្រីនិង/ឬ គណៈកម្មការឥណទាន វត្ថុធានា និងព័ត៌មានចាំបាច់ផ្សេងៗទៀត។

ប្រការ ៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៧-០៥-០៥៤ ប្រ.ក

ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥

ព័ត៌មានដែលត្រូវរក្សាទុកក្នុងសំណុំឯកសារឥណទាន

I- ព័ត៌មានអំពីអ្នកសុំខ្ចី

ក- រូបវន្តបុគ្គល៖ អាសយដ្ឋាន អាសយដ្ឋានទំនាក់ទំនង មុខរបរ និយោជិក បៀវត្ស និង/ឬ ចំណូល ស្ថានភាពហិរញ្ញវត្ថុ និង/ឬ មូលនិធិផ្គាល់សុទ្ធ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

ខ- នីតិបុគ្គល៖ លក្ខន្តិក:ក្រុមហ៊ុនឯកកម្មសិទ្ធ ឬសហកម្មសិទ្ធ ប្រវត្តិនិងសាវតារអាជីវកម្ម រចនាសម្ព័ន្ធចាត់តាំងក្រុមហ៊ុន គណៈគ្រប់គ្រង នាយក ភាគទុនិក ម្ចាស់កម្មសិទ្ធ សហកម្មសិទ្ធ ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

II- ព័ត៌មានអំពីការផ្តល់ឥណទាន

ក- ពិពណ៌នាពីប្រភេទឥណទាន (ឥណទានវិបារូបន៍ ឥណទានបង្វិលជុំ ឥណទានសងរំលស់ ចំនួនប្រាក់ ប្រភេទរូបិយប័ណ្ណ)

ខ- គោលបំណងឥណទាន

គ- លក្ខខណ្ឌឥណទាន៖ កម្រិតកំណត់ អត្រាការប្រាក់ តារាងពេលវេលាសងប្រាក់ រយៈពេលកាលកំណត់ និងកាលបរិច្ឆេទផុតកំណត់

ឃ- វត្ថុធានា៖ លេខប័ណ្ណកម្មសិទ្ធវត្ថុធានា ទីតាំង ប្រភេទ ចំនួនប្រាក់ដែលបានវាយតម្លៃ កាលបរិច្ឆេទ និងទីកន្លែងវាយតម្លៃ ឈ្មោះអ្នកវាយតម្លៃ

ង- អ្នកធានា៖ ឈ្មោះ ស្ថានភាពហិរញ្ញវត្ថុ និងមូលនិធិផ្គាល់សុទ្ធ

III- ព័ត៌មានសម្រាប់ទាយតម្លៃពាក្យស្នើសុំឥណទាន

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតម្លៃនិងអនុសាសន៍របស់មន្ត្រីគ្រប់គ្រងគណនីឥណទាន និងនាយកចាត់ការ

ខ- ការអនុមតិ និងមូលដ្ឋាននៃការអនុមតិដោយគណៈគ្រប់គ្រង ឬគណៈកម្មការឥណទាន

គ- ការវិភាគគុណភាពឆ្អែកលើ៖

i- ព័ត៌មានរបស់អ្នកសុំខ្ចី

ii- សាវតារស្តីពីទំនាក់ទំនងជាមួយអតិថិជន

iii- សាវតារស្តីពីទំនាក់ទំនងប្រតិបត្តិការនៃក្រុមពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំខ្ចីជាមួយធនាគារ

iv- ព័ត៌មានអំពីអ្នកសុំខ្ចីដែលទទួលបានពីគ្រឹះស្ថាននិងប្រភពផ្សេងៗ រួមមានការិយាល័យទំនាក់ទំនងរបស់ធនាគារ

v- ការវិភាគហានិភ័យក្នុងវិស័យ និងអាជីវកម្មនៃការផ្តល់ឥណទាន

vi- ការប្រមូលផ្តុំឥណទានទៅលើអតិថិជនតែមួយ (បើសមស្រប)

ឃ- ការវិភាគបរិមាណផ្អែកលើ៖

i- ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្ត (គ្រាមុន គ្រាបច្ចុប្បន្ន និងតាមគម្រោង)

ii- ផែនការអាជីវកម្ម ប្រភព និងការព្យាករណ៍លំហូរសាច់ប្រាក់សម្រាប់បំពេញតម្រូវការសងប្រាក់

iii- ប្រភពដើមទុន

iv- កិច្ចសន្យាផ្សេងៗ

v- ការវាយតម្លៃនិងតម្លៃវត្ថុធានា

IV- ព័ត៌មានសម្រាប់ពិនិត្យឥណទានឡើងវិញតាមគ្រា

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតម្លៃនិងអនុសាសន៍របស់មន្ត្រីពិនិត្យឥណទានឡើងវិញរួមមាន៖

i- ចំណាត់ថ្នាក់និងកម្រិតឥណទានដែលបានយល់ព្រម

ii- សំវិធានធនសម្រាប់ការខាតបង់

iii- ការប្រាក់ដែលព្យួរទុក

ខ- ការអនុមតិនិងមូលដ្ឋាននៃការអនុមតិសម្រាប់ការផ្តល់ឥណទានជាថ្មី ការកែតម្រូវខ្លឹមសារនិងលក្ខខណ្ឌ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន

គ- ព័ត៌មានដែលអាចទទួលបានចុងក្រោយស្តីពី៖

i- ឥណទានកំពុងប្រើប្រាស់រួមមាន ទ្រព្យអកម្មយថាហេតុ កិច្ចសន្យា និងប្រតិបត្តិការក្រៅតារាងតុល្យការដទៃទៀត

ii- ដំណើរការនិងការផ្តល់សេវាកម្មគណនី

iii- ឯកសារទំនាក់ទំនងនិងរបាយការណ៍លទ្ធផលនៃការប្រជុំ (call report) ជាមួយអ្នកសុំខ្ចីនិងការពិនិត្យដល់ទីកន្លែង

iv- ការវិភាគជាប្រចាំតាមគុណភាពផ្អែកលើព័ត៌មានថ្មីៗបំផុត រួមមានការផ្តល់យោបល់ពីសវនករផ្ទៃក្នុង និងពីខាងក្រៅដែលអាចទទួលបានអំពីអ្នកសុំខ្ចី

ឃ- ការវិភាគតាមបែបបរិមាណផ្អែកលើព័ត៌មានហិរញ្ញវត្ថុ ការវាយតម្លៃ និងការកម្រិតតម្លៃថ្មីៗបំផុត

ង- ព័ត៌មានស្តីពីដំណើរការគណនីរបស់ក្រុមដទៃទៀតដែលពាក់ព័ន្ធជាមួយអ្នកសុំខ្ចី

ច- វិភាគហានិភ័យក្នុងវិស័យនិងអាជីវកម្មនៃការផ្តល់ឥណទាន

ធ៧-០១១-០៨២ ប្រ.ក

ប្រកាស
ស្តីពី
ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត

ប្រការ ១.-

គ្រប់គ្រឹះស្ថានធនាគារតទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវរាល់កាតព្វកិច្ចដែលកំណត់ដោយបទបញ្ជាជាធរមាន។ ការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នេះអាចនឹងសម្រេចបានតាមរយៈគោលនយោបាយច្បាស់លាស់ នីតិវិធីនិងដំណើរការសមស្រប និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងត្រួតពិនិត្យហានិភ័យ។ ការគួបផ្សំគ្នានៃចំណុចខ្សោយចម្បង។ រួមជាមួយការទទួលយកហានិភ័យហិរញ្ញវត្ថុ អាចនាំឱ្យមានទម្រង់ហានិភ័យពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មដែលជាបំណុល និងកំណើនខ្លាំងនៃភាពងាយរងគ្រោះ ព្រមទាំងធ្វើឱ្យអន្តរាយដល់សមត្ថភាពទប់ទល់នឹងការវិវត្តអវិជ្ជមានដែលអាចប៉ាន់ប្រមាណជាមុន។ ដើម្បីវាយតម្លៃទម្រង់ហានិភ័យបានពេញលេញនៅកម្រិតគ្រឹះស្ថានធនាគារ និងបើចាំបាច់នៅកម្រិតគួបសរុប ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ក្នុងគោលបំណងប៉ាន់ប្រមាណជាមុននូវការវិវត្តអវិជ្ជមានជាសក្តានុពល និងដោះស្រាយទាន់ពេលវេលា ដោយដាក់ចេញអធិបញ្ញាសមស្របដើម្បីអនុវត្តសកម្មភាពកែតម្រូវចាំបាច់ ប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាព។

ប្រការ ២.-

ការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត សំដៅដល់ដំណើរការតាមដានត្រួតពិនិត្យអចិន្ត្រៃយ៍លើមូលដ្ឋាននៃការវាយតម្លៃទម្រង់ហានិភ័យ ការប៉ាន់ប្រមាណនិងស្ត្រេសតេស្ត (Stress-testing) ផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីកំណត់អត្តសញ្ញាណកត្តានៃភាពងាយរងគ្រោះនិងភាពចុះខ្សោយរបស់គ្រឹះស្ថានឬក្រុមគ្រឹះស្ថានដែលរងការត្រួតពិនិត្យ និងប៉ាន់ប្រមាណអំពីបញ្ហានិងកង្វល់នៃការត្រួតពិនិត្យឱ្យបានទាន់ពេលវេលា សំដៅដោះស្រាយជាបន្ទាន់ ទប់ស្កាត់ស្ថានភាពហិរញ្ញវត្ថុចុះខ្សោយជាលំដាប់និងពង្រឹងសមត្ថភាពទប់ទល់ស្ថានភាពអវិជ្ជមានរបស់ទីផ្សារតាមរយៈសកម្មភាពត្រួតពិនិត្យសមស្រប។

ប្រការ ៣.-

ការអនុវត្តនិងសកម្មភាពត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគតពឹងផ្អែកលើលទ្ធផលនៃការវាយតម្លៃទម្រង់ហានិភ័យប្រចាំគ្រា និងគ្រប់ជ្រុងជ្រោយនៅកម្រិតគ្រឹះស្ថាននិងកម្រិតគួបសរុប បើចាំបាច់។

ការវាយតម្លៃទម្រង់ហានិភ័យ សំដៅដល់ការវិភាគគ្រប់ជ្រុងជ្រោយ អំពីស្ថានភាពរបស់គ្រឹះស្ថានដោយផ្អែកលើរាល់ទិន្នន័យនិងព័ត៌មាន ដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា។

ការវាយតម្លៃនេះ មានគោលបំណងវាយតម្លៃរាល់ហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសហានិភ័យសាធនភាព សាច់ប្រាក់ងាយស្រួល ឥណទាន/សមភាគី ទីផ្សារនិងអត្រាការប្រាក់ និងប្រសិទ្ធភាព និងឯករាជ្យភាពនៃសវនកម្មនិងការត្រួតពិនិត្យផ្ទៃក្នុង បញ្ហាហានិភ័យ/អាជីវកម្ម/និងការផ្តល់មូលនិធិប្រមូលផ្តុំ ពិពិធកម្មសំពៀតឥណទាន ការកំណត់អត្តសញ្ញាណនៃភាពទន់ខ្សោយចំពោះសមត្ថភាពរបស់គ្រឹះស្ថានក្នុងការទប់ទល់នឹងការវិវត្តអវិជ្ជមាននៃទីផ្សារឬអាជីវកម្ម ការរៀបចំនិងប្រសិទ្ធភាពគ្រប់គ្រងហានិភ័យ ការចាត់ចែងបុគ្គលិក ការបែងចែកភារកិច្ច និងទំនាស់ផលប្រយោជន៍ជាសក្តានុពល ឯករាជ្យភាពនៃមុខងារ "គន្លឹះ" ដូចជាការត្រួតពិនិត្យផ្ទៃក្នុងឬការប្រតិបត្តិតាម ប្រសិទ្ធភាពនៃបែបបទរាយការណ៍ នីតិវិធីនិងដំណើរការប្រគល់សិទ្ធិ/គណនេយ្យភាព ហេដ្ឋារចនាសម្ព័ន្ធនិងដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធគ្រប់គ្រងព័ត៌មាន អភិបាលកិច្ចសាជីវកម្ម និងប្រសិទ្ធភាពរបស់គណៈកម្មការដែលបានបង្កើត ការគាំទ្ររបស់ភាគទុនិក ផែនការយថាភាពសម្រាប់ដោះស្រាយហានិភ័យធំៗ នីតិវិធីនិងប្រសិទ្ធភាពនៃដំណោះស្រាយប៊ែកអាប់ (Back up) ដែលគាំទ្រដោយការធ្វើតេស្តទៀងទាត់ប្រចាំគ្រា។

ជាពិសេស ការវាយតម្លៃនេះអាចអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណបានទាន់ពេលវេលានូវចំណុចខ្សោយចម្បងៗ និងបញ្ហាជាសក្តានុពល ដែលកើតឡើងដោយសារការគូបបញ្ចូលគ្នានូវហានិភ័យដែលអាចនាំឱ្យមានកត្តាងាយរងគ្រោះពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុល។

ប្រការ ៥.-

ធនាគារជាតិនៃកម្ពុជានឹងប្រើប្រាស់សេណារីយ៉ូ (Scenarios) និងរង្វាស់នៃការធ្វើស្ត្រេសតេស្ត (Stress-testing measures) ក៏ដូចជាការប៉ាន់ប្រមាណផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវាយតម្លៃផ្អែកលើរង្វាស់ស្ត្រេសមេទ្រិក (Stress Metrics)។ ការធ្វើស្ត្រេសតេស្ត (Stress-testing) និងការប៉ាន់ប្រមាណនេះក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនៃផែនការយថាភាព ជាពិសេស ដូចជា ផែនការផ្តល់មូលនិធិយថាភាព និងផែនការស្តារសាធនភាពនៅក្រោមស្ថានភាពឬការវិវត្តទីផ្សារជាអវិជ្ជមាន ជាដើម។

ក្នុងការអនុវត្តការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងពិចារណាផងដែរអំពីការប្តេជ្ញារបស់ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ក្នុងការវាយតម្លៃឡើងវិញប្រចាំគ្រាលើប្រសិទ្ធភាពនៃគោលនយោបាយទទួលយកហានិភ័យ រចនាសម្ព័ន្ធចាត់តាំង ការរៀបចំ និងឯករាជ្យភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។ ការវាយតម្លៃឡើងវិញនេះ ត្រូវបានអនុវត្តជាពិសេស ក្នុងករណីៈ

ក. មានការប្រែប្រួលចម្បងចំពោះសកម្មភាពរបស់គ្រឹះស្ថាន ដូចជា សកម្មភាពថ្មី ហានិភ័យថ្មី និងប្រតិបត្តិការថ្មី

ខ. មានការប្រែប្រួលចម្បងនៅក្នុងរចនាសម្ព័ន្ធសាជីវកម្ម ដូចជា ការចូលភាគកម្ម ឬការបង្កើតបុគ្គលសម្ព័ន្ធឯកទេសថ្មី និង

គ. មានការវិវត្តអវិជ្ជមាននៃទីផ្សារ និងការប្រែប្រួលបរិស្ថានប្រកួតប្រជែង ដែលនាំឱ្យមានការដោះស្រាយនូវចំណុចខ្សោយជាសក្តានុពលនៅក្នុងផែនការយថាភាព។

ប្រការ ៥.-

ផ្អែកលើការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងធ្វើការវិនិច្ឆ័យផ្អែកលើទស្សនៈអនាគតនិងដោះស្រាយជាបន្ទាន់នូវបញ្ហាជាសក្តានុពលនៅក្នុងកម្រិតគ្រឹះស្ថាន និងក្នុងកម្រិតគួបសរុប បើចាំបាច់។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញវិធានការកែតម្រូវជាបន្ទាន់ចំពោះគ្រឹះស្ថានបើចាំបាច់។ ការបង្គាប់ឱ្យអនុវត្តអធិបញ្ញាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការកែតម្រូវសមស្រប ចាំបាច់ត្រូវពិចារណាស្របតាមផលប៉ះពាល់ជាសក្តានុពលចំពោះស្ថិរភាពហិរញ្ញវត្ថុ។

ប្រការ ៦.-

ធនាគារជាតិនៃកម្ពុជា នឹងពិចារណាដាក់ឱ្យអនុវត្តកាតព្វកិច្ចបង្កើនអនុបាតសាធនភាពចំពោះគ្រឹះស្ថាន ឬក្រុមគ្រឹះស្ថានដែលមានទម្រង់ហានិភ័យក្នុងការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុលដែលមានកត្តាងាយរងគ្រោះធ្ងន់ធ្ងរ និង/ឬ ដែលអាចមានការគំរាមកំហែងធ្ងន់ធ្ងរចំពោះម្ចាស់ប្រាក់បញ្ញើ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនេះជាការសម្រេចរបស់ធនាគារជាតិនៃកម្ពុជា ប៉ុន្តែមិនត្រូវលើសពី ៣០ (សាបសិប) ភាគរយ នៃកាតព្វកិច្ចអនុបាតសាធនភាពអប្បបរមា ដែលអនុវត្តចំពោះគ្រឹះស្ថានឡើយ។

ប្រការ ៧.-

ធនាគារជាតិនៃកម្ពុជាអាចលើកលែងកាតព្វកិច្ចបង្កើនអនុបាតសាធនភាព លុះត្រាតែទម្រង់ហានិភ័យដែលបានវាយតម្លៃឡើងវិញនោះលែងជាកង្វល់នៃការត្រួតពិនិត្យក្រោយពីបានពិចារណាលើប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវ។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនៅកម្រិតគួបសរុបត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរចំពោះគ្រឹះស្ថាន និងមិនត្រូវជាផ្នែកមួយនៃកាតព្វកិច្ចបើកចំហព័ត៌មាននោះទេ។

ប្រការ ៨.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គបេឡាអគ្គាធិការដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៣-១២២ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់ សោហ៊ុយអាជ្ញាបណ្ណ សោហ៊ុយលិខិតអនុញ្ញាត សោហ៊ុយសាកសួរព័ត៌មាន សោហ៊ុយសិក្សាសំណុំលិខិត សោហ៊ុយកែប្រែលក្ខន្តិក: សោហ៊ុយផ្ទេរភាគហ៊ុន សោហ៊ុយបង្កើនដើមទុន និងសោហ៊ុយបន្ថយដើមទុន សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ពាក្យបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចតទៅ៖

- ទីស្នាក់ការកណ្តាល និងសាខាធនាគារបរទេស សំដៅដល់មជ្ឈមណ្ឌលគ្រប់គ្រងរូមរបស់គ្រឹះស្ថានដែលបានចុះបញ្ជីពាណិជ្ជកម្ម និងបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា
- សាខារាជធានី-ខេត្ត-ក្រុង សំដៅដល់ការិយាល័យដែលធ្វើប្រតិបត្តិការក្នុងរាជធានី ខេត្ត ឬក្រុង ហើយដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា
- សាខាស្រុក សំដៅដល់ការិយាល័យដែលធ្វើប្រតិបត្តិការក្នុងស្រុក ហើយដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា
- សាខារងរាជធានី-ខេត្ត-ក្រុង សំដៅដល់ការិយាល័យរបស់គ្រឹះស្ថានបរទេសដែលធ្វើប្រតិបត្តិការតាមរាជធានី ខេត្ត ក្រុង ហើយស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលគ្រប់គ្រងរូមក្នុងព្រះរាជាណាចក្រកម្ពុជា និងបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា
- ប៉ុស្តិ៍សេវា សំដៅដល់ការិយាល័យដែលមានសកម្មភាពព័ត៌មាន សម្ព័ន្ធការ ឬជាតំណាងរបស់គ្រឹះស្ថាននៅតាមក្រុង ស្រុក ឃុំ ភូមិ ហើយបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។ ប៉ុស្តិ៍សេវា មិនត្រូវអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនាគារបានទេ។

ប្រការ ៣.-

សាខាធនាគារបរទេស ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ដូចខាងក្រោម៖

១- សាខាធនាគារពាណិជ្ជបរទេស

ក- សាខា ១៥០.០០០.០០០ រៀល

ខ- សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧
ក្នុង ១ សាខារង ១០០.០០០.០០០ រៀល

គ- សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨
ឡើងទៅ ក្នុង ១ សាខារង ៤០.០០០.០០០ រៀល

២- សាខាធនាគារឯកទេសបរទេស

ក- សាខា ៧០.០០០.០០០ រៀល

ខ- សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧
ក្នុង ១ សាខារង ៤០.០០០.០០០ រៀល

គ- សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨
ឡើងទៅ ក្នុង ១ សាខារង ២០.០០០.០០០ រៀល

សាខាធនាគារបរទេស មិនត្រូវបានអនុញ្ញាតឱ្យបើកសាខាស្រុក និងប៉ុស្តិ៍សេវាបានទេ។

ប្រការ ៤.-

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ដូចខាងក្រោម៖

១- ធនាគារពាណិជ្ជ

ក- ទីស្នាក់ការកណ្តាល ១៥០.០០០.០០០ រៀល

ខ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧ ក្នុង ១ សាខា ១០០.០០០.០០០ រៀល

គ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ
ក្នុង ១ សាខា ៤០.០០០.០០០ រៀល

ឃ- សាខាស្រុក ក្នុង ១ សាខា ១០.០០០.០០០ រៀល

ង- ប៉ុស្តិ៍សេវា ១.០០០.០០០ រៀល

២- ការិយាល័យតំណាងធនាគារបរទេស ១០០.០០០.០០០ រៀល

៣- ធនាគារឯកទេស

ក- ទីស្នាក់ការកណ្តាល ៧០.០០០.០០០ រៀល

ខ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧ ក្នុង ១ សាខា ៤០.០០០.០០០ រៀល

គ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ
ក្នុង ១ សាខា ២០.០០០.០០០ រៀល

ឃ- សាខាស្រុក ក្នុង ១ សាខា ៥.០០០.០០០ រៀល

ង- ប៉ុស្តិ៍សេវា ៥០០.០០០ រៀល

៤- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ក- ទីស្នាក់ការកណ្តាល ៧០.០០០.០០០ រៀល

ខ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧ ក្នុង ១ សាខា ៤០.០០០.០០០ រៀល

គ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ
ក្នុង ១ សាខា ២០.០០០.០០០ រៀល

ឃ- សាខាស្រុក ក្នុង ១ សាខា ៥.000.000 រៀល

ង- ប៉ុស្តិ៍សេវា ៥00.000 រៀល

៥- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ក- ទីស្នាក់ការកណ្តាល ២0.000.000 រៀល

ខ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី ១ ដល់ ៧ ក្នុង ១ សាខា ៥.000.000 រៀល

គ- សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ
ក្នុង ១ សាខា ១.000.000 រៀល

ឃ- សាខាស្រុក ក្នុង ១ សាខា ៥00.000 រៀល

ង- ប៉ុស្តិ៍សេវា ២00.000 រៀល

៦- ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

ក- ទីស្នាក់ការកណ្តាល ២0.000.000 រៀល

ខ- សាខាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ក្នុង ១ សាខា ៥.000.000 រៀល

៧- ការិយាល័យចែករំលែកព័ត៌មានឥណទាន ៤0.000.000 រៀល

៨- អាជ្ញាបណ្ណប្តូរប្រាក់

ក- ទីស្នាក់ការកណ្តាល ១0.000.000 រៀល

ខ- សាខា ១.000.000 រៀល

៩- លិខិតអនុញ្ញាតប្តូរប្រាក់ ២00.000 រៀល

១0- ស្នងការគណនីឯករាជ្យ ២0.000.000 រៀល

១១- អ្នកដំណើរការតតិយភាគី ២0.000.000 រៀល

ប្រការ ៥.-

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យបានមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

គ្រឹះស្ថានដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតក្នុងឆ្នាំ ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី២ ៖ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី៣ ៖ ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី៤ ៖ ត្រូវបង់មួយត្រីមាស

ប្រការ ៦.-

រាល់ការសាកសួរព័ត៌មាន និងសិក្សាសំណុំលិខិតទាក់ទងនឹងនីតិវិធីនៃការសុំអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតត្រូវបង់សោហ៊ុយជាមុន ដូចខាងក្រោម៖

១- ធនាគារពាណិជ្ជ សាខាធនាគារបរទេស ការិយាល័យតំណាងធនាគារបរទេស និង ធនាគារឯកទេស

ក- សាកសួរព័ត៌មាន ១.០០០.០០០ រៀល

ខ- សិក្សាសំណុំលិខិត ៥.០០០.០០០ រៀល

២- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

ក- សាកសួរព័ត៌មាន ៥០០.០០០ រៀល

ខ- សិក្សាសំណុំលិខិត ២.៥០០.០០០ រៀល

៣- អាជីវកម្មប្តូរប្រាក់

ក- សិក្សាសំណុំលិខិតសុំអាជ្ញាបណ្ណ ២០០.០០០ រៀល

ខ- សិក្សាសំណុំលិខិតសុំលិខិតអនុញ្ញាត ១០០.០០០ រៀល

៤- ស្នងការគណនីឯករាជ្យ

ក- សាកសួរព័ត៌មាន ៥០០.០០០ រៀល

ខ- សិក្សាសំណុំលិខិត ៤.០០០.០០០ រៀល

៥- អ្នកដំណើរការតតិយភាគី

ក- សាកសួរព័ត៌មាន ៥០០.០០០ រៀល

ខ- សិក្សាសំណុំលិខិត ២.០០០.០០០ រៀល

ប្រការ ៧.-

គ្រឹះស្ថានត្រូវបង់សោហ៊ុយជាមុនចំពោះការសិក្សាសំណុំលិខិតបើកសាខា សាខារង រាជធានី ខេត្ត ក្រុង និងស្រុក ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ។

ប្រការ ៨.-

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយកែប្រែលក្ខន្តិក: ដូចខាងក្រោម៖

ក- ធនាគារពាណិជ្ជ

- សម្រាប់ ១ ទំព័រ ២.០០០.០០០ រៀល

ខ- ធនាគារឯកទេស

- សម្រាប់ ១ ទំព័រ ១.៥០០.០០០ រៀល

គ- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

- សម្រាប់ ១ ទំព័រ ១.០០០.០០០ រៀល

ឃ- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

- សម្រាប់ ១ ទំព័រ ៥០០.០០០ រៀល

ង- ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

- សម្រាប់ ១ ទំព័រ ៥០០.០០០ រៀល

ប្រការ ៩.-

រាល់ការស្នើសុំប្តូរអាជ្ញាបណ្ណ គ្រឹះស្ថានត្រូវបង់សោហ៊ុយចំនួន ២.០០០.០០០ រៀល ក្នុងមួយលើក។

ប្រការ ១០.-

រាល់ការស្នើសុំលិខិតបញ្ជាក់ អាជ្ញាបណ្ណ ដើមទុន និងភាគទុនិក ត្រូវបង់សោហ៊ុយចំនួន ១.០០០.០០០ រៀល ក្នុងមួយលើក លើកលែងតែចំពោះអាជ្ញាធរពាក់ព័ន្ធតាមការចាំបាច់។

ប្រការ ១១.-

រាល់ការផ្ទេរភាគហ៊ុនរបស់គ្រឹះស្ថាន ភាគីផ្ទេរភាគហ៊ុន ត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសប្រាំភាគរយ (0,៥%) នៃតម្លៃចារិកភាគហ៊ុនដែលបានផ្ទេរ។

ប្រការ ១២.-

រាល់ការបង្កើនដើមទុនរបស់គ្រឹះស្ថាន ភាគីបង្កើនដើមទុន ត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសសូន្យបីភាគរយ (0,0៣%) លើចំនួនទឹកប្រាក់ដែលសុំបង្កើន។

ប្រការ ១៣.-

រាល់ការបន្ថយដើមទុនរបស់គ្រឹះស្ថាន ភាគីបន្ថយដើមទុន ត្រូវបង់សោហ៊ុយមួយភាគរយ (១%) លើចំនួនទឹកប្រាក់ដែលសុំបន្ថយ។

ប្រការ ១៤.-

គ្រឹះស្ថានដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មតាមច្បាប់ជាធរមាន។

ប្រការ ១៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៦.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុតិនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៧.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៣-០០១ ស.រ.ច.ណ

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣

សារាចរណែនាំ
ស្តីពី
ការអនុវត្តប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានធនាគារជាតិនៃកម្ពុជាដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។ ដើម្បីឱ្យការអនុវត្តប្រកាសនេះមានដំណើរការប្រកបដោយប្រសិទ្ធភាពនិងសម្រេចបានគោលដៅ ធនាគារជាតិនៃកម្ពុជាសូមធ្វើការណែនាំអំពីការអនុវត្តខ្លឹមសារនៃប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

១- ធនាគារពាណិជ្ជ សាខាធនាគារបរទេស និង ធនាគារឯកទេស

- ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលមានអាជ្ញាបណ្ណ

ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលមានអាជ្ញាបណ្ណរួចហើយត្រូវបង់សាហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាប់ពីខែមករា ឆ្នាំ២០១៤ តទៅ។

- សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ដែលមានលិខិតអនុញ្ញាត

សាខាក្រុង សាខាស្រុក ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណ ឬសោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាប់ពីខែមករា ឆ្នាំ២០១៤ តទៅ។

- ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលនឹងបង្កើតថ្មី

គ្រឹះស្ថានធនាគារ ដែលមានបំណងបើកទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

- សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ដែលនឹងបង្កើតថ្មី

គ្រឹះស្ថានធនាគារ ដែលមានបំណងបើកសាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបើកដំណើរការអាជីវកម្មជាសាខារាជធានី សាខាខេត្ត សាខាក្រុង និងសាខាស្រុក ឬប៉ុស្តិ៍សេវា ដោយពុំទាន់មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៣- គ្រឹះស្ថានផ្សៀងទៀត

គ្រឹះស្ថានផ្សេងទៀត ត្រូវអនុវត្តការបង់សោហ៊ុយផ្សេងៗស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃហត្ថលេខានេះតទៅ។

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៤-០០១ ស.រ.ច

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤

សារាចរណែនាំ
ស្តីពី
ការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
នៃធនាគារជាតិនៃកម្ពុជា

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពីការកំណត់សោហ៊ុយ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សារាចរនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាជូនសាធារណជន។ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យអនុវត្តនូវតារាងបញ្ជាក់លម្អិតអំពីតំម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាពទៅតាមសេវាសាធារណៈនីមួយៗ ដូចចែងនៅក្នុងឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។

ធនាគារជាតិនៃកម្ពុជា រៀបចំឱ្យមានកន្លែងជាក់លាក់ដែលជាលក្ខណៈច្រកចេញចូលតែមួយក្នុងការផ្តល់សេវា និងទីកន្លែងទទួលពាក្យបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយកកម្រៃលើសកំណត់ ឬមានការយឺតយ៉ាវជាដើម។ រាល់ការបង់កម្រៃសេវាសាធារណៈរបស់អគ្គយកដ្ឋានត្រួតពិនិត្យត្រូវបានប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

តារាងឧបសម្ព័ន្ធនៃការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា

ល.រ	បរិយាយ	តម្លៃសេវា	រយៈពេលផ្តល់សេវា (គិតពីថ្ងៃទទួលបានពាក្យស្នើសុំដែលមានឯកសារគ្រប់គ្រាន់)	សុពលភាព
អាជ្ញាបណ្ណ				
០១	សាខាធនាគារពាណិជ្ជបរទេស			
	សាខា	150,000,000.00 រៀល/ឆ្នាំ	6 ខែ	អចិន្ត្រៃយ៍
	សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពី១ ដល់ ៧ ក្នុង ១ សាខារង	100,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅក្នុង ១ សាខារង	40,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
០២	សាខាធនាគារឯកទេសបរទេស			
	សាខា	70,000,000.00 រៀល/ឆ្នាំ	6 ខែ	អចិន្ត្រៃយ៍
	សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពី១ ដល់ ៧ ក្នុង ១ សាខារង	40,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខារងរាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ ក្នុង ១ សាខារង	20,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
០៣	ការិយាល័យតំណាងសាខាធនាគារបរទេស	100,000,000.00 រៀល/ឆ្នាំ	6 ខែ	2 ឆ្នាំ
០៤	ធនាគារពាណិជ្ជ			
	ទីស្នាក់ការកណ្តាល	150,000,000.00 រៀល/ឆ្នាំ	6 ខែ	អចិន្ត្រៃយ៍

	សាខារាជធានី-ខេត្ត-ក្រុងចាប់ពី១ ដល់ ៧ ក្នុង ១ សាខា	100,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ ក្នុង ១ សាខា	40,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខាស្រុកក្នុង ១ សាខា	10,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	ប៉ុស្តិ៍សេវា	1,000,000.00 រៀល/ឆ្នាំ	20-45 នៃថ្ងៃធ្វើការ	2 ឆ្នាំ
០៥	ធនាគារឯកទេស			
	ទីស្នាក់ការកណ្តាល	70,000,000.00 រៀល/ឆ្នាំ	6 ខែ	អចិន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី១ ដល់ ៧ ក្នុង ១ សាខា	40,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ ក្នុង ១ សាខា	20,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខាស្រុកក្នុង ១ សាខា	5,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	ប៉ុស្តិ៍សេវា	500,000.00 រៀល/ឆ្នាំ	20-45 នៃថ្ងៃធ្វើការ	2 ឆ្នាំ
០៦	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ			
	ទីស្នាក់ការកណ្តាល	70,000,000.00 រៀល/ឆ្នាំ	6 ខែ	អចិន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី១ ដល់ ៧ ក្នុង ១ សាខា	40,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ឡើងទៅ ក្នុង ១ សាខា	20,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	សាខាស្រុកក្នុង ១ សាខា	5,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អចិន្ត្រៃយ៍
	ប៉ុស្តិ៍សេវា	500,000.00 រៀល/ឆ្នាំ	20-45 នៃថ្ងៃធ្វើការ	2 ឆ្នាំ

០៧	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ			
	ទីស្នាក់ការកណ្តាល	20,000,000.00 រៀល/ឆ្នាំ	6 ខែ	អាចបន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពី១ ដល់ ៧ ក្នុង ១ សាខា	5,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
	សាខារាជធានី-ខេត្ត-ក្រុង ចាប់ពីសាខាទី៨ ទៅរៀងទៅ ក្នុង ១ សាខា	1,000,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
	សាខាស្រុក/ក្នុង ១ សាខា	500,000.00 រៀល/ឆ្នាំ	45-60 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
	ប៉ុស្តិ៍សេវា	200,000.00 រៀល/ឆ្នាំ	20-45 នៃថ្ងៃធ្វើការ	2 ឆ្នាំ
០៨	ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ			
	ទីស្នាក់ការកណ្តាល	20,000,000.00 រៀល/ឆ្នាំ	3 ខែ	5 ឆ្នាំ
	សាខាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្នុង ១ សាខា	5,000,000.00 រៀល/ឆ្នាំ	20-45 នៃថ្ងៃធ្វើការ	5 ឆ្នាំ
០៩	ការិយាល័យចែករំលែកព័ត៌មានឥណទាន	40,000,000.00 រៀល/ឆ្នាំ	3 ខែ	អាចបន្ត្រៃយ៍
១០	អាជ្ញាបណ្ណប្រាក់			
	ទីស្នាក់ការកណ្តាល	10,000,000.00 រៀល/ឆ្នាំ	10-20 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
	សាខា	1,000,000.00 រៀល/ឆ្នាំ	10-20 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
១១	លិខិតអនុញ្ញាតប្រាក់	200,000.00 រៀល/ឆ្នាំ	10-20 នៃថ្ងៃធ្វើការ	អាចបន្ត្រៃយ៍
១២	សួរឯកសណ្ឋានឯកជ្ញ	20,000,000.00 រៀល/ឆ្នាំ	3 ខែ	អាចបន្ត្រៃយ៍
១៣	អ្នកដំណើរការតំណាងតំ	20,000,000.00 រៀល/ឆ្នាំ	3 ខែ	3 ឆ្នាំ
១៤	ប្រតិបត្តិការឥណទានជនបទ (គ្រឹះស្ថានចុះបញ្ជី)	0.00 រៀល	20-45 នៃថ្ងៃធ្វើការ	3 ឆ្នាំ

សាកសួរព័ត៌មានសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបើកថ្មី				
០១	ធនាគារពាណិជ្ជ	1,000,000.00 រៀល	ថ្ងៃធ្វើការ	
០២	សាខាធនាគារបរទេស	1,000,000.00 រៀល	ថ្ងៃធ្វើការ	
០៣	ការិយាល័យតំណាងធនាគារបរទេស	1,000,000.00 រៀល	ថ្ងៃធ្វើការ	
០៤	ធនាគារឯកទេស	1,000,000.00 រៀល	ថ្ងៃធ្វើការ	
០៥	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ	500,000.00 រៀល	ថ្ងៃធ្វើការ	
០៦	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ	500,000.00 រៀល	ថ្ងៃធ្វើការ	
០៧	ប្រតិបត្តិករឥណទានជនបទ (គ្រឹះស្ថានចុះបញ្ជី)	0.00 រៀល	ថ្ងៃធ្វើការ	
០៨	ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ	500,000.00 រៀល	ថ្ងៃធ្វើការ	
០៩	ស្នងការគណនីឯករាជ្យ	500,000.00 រៀល	ថ្ងៃធ្វើការ	
១០	អ្នកដំណើរការតតិយភាគី	500,000.00 រៀល	ថ្ងៃធ្វើការ	
សិក្សាសំណុំលិខិតសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបើកថ្មី				
០១	ធនាគារពាណិជ្ជ	5,000,000.00 រៀល		
០២	សាខាធនាគារបរទេស	5,000,000.00 រៀល		
០៣	ការិយាល័យតំណាងធនាគារបរទេស	5,000,000.00 រៀល		
០៤	ធនាគារឯកទេស	5,000,000.00 រៀល		
០៥	សាខាធនាគារ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (សម្រាប់ ១ សាខា)	5,000,000.00 រៀល		

០៦	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ	2,500,000.00 រៀល		
០៧	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ	2,500,000.00 រៀល		
០៨	សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (សម្រាប់ ១ សាខា)	2,500,000.00 រៀល		
០៩	ប្រតិបត្តិករឥណទានជនបទ (គ្រឹះស្ថានចុះបញ្ជី)	0.00 រៀល		
១០	ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ	2,500,000.00 រៀល		
១១	អាជីវកម្មប្តូរប្រាក់			
	អាជ្ញាបណ្ណប្តូរប្រាក់ (សម្រាប់ ១ លើក)	200,000.00 រៀល		
	អាជ្ញាបណ្ណប្តូរប្រាក់ ១សាខា (សម្រាប់ ១ លើក)	200,000.00 រៀល		
	លិខិតអនុញ្ញាត (សម្រាប់ ១ លើក)	100,000.00 រៀល		
១២	ស្នងការគណនីឯករាជ្យ	4,000,000.00 រៀល		
១៣	អ្នកដំណើរការតតិយភាគី (សម្រាប់ ១ លើក)	2,000,000.00 រៀល		
១៤	ប៉ុស្តិ៍សេវា (ធនាគារ)	0.00 រៀល		
១៥	ប៉ុស្តិ៍សេវា (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)	0.00 រៀល		
កែប្រែលក្ខន្តិក:		**ក្នុងមួយទំព័រ**		
០១	ធនាគារពាណិជ្ជ	2,000,000.00 រៀល	45-60 នៃថ្ងៃធ្វើការ	
០២	ធនាគារឯកទេស	1,500,000.00 រៀល	45-60 នៃថ្ងៃធ្វើការ	
០៣	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ	1,000,000.00 រៀល	45-60 នៃថ្ងៃធ្វើការ	

០៤	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ	500,000.00 រៀល	45-60 នៃថ្ងៃធ្វើការ	
០៥	ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ	500,000.00 រៀល	45-60 នៃថ្ងៃធ្វើការ	
សេវាផ្សេងៗ				
០១	ការបង្កើនដើមទុន	0.03% លើទឹកប្រាក់សុំបង្កើន	45-60 នៃថ្ងៃធ្វើការ	
០២	ការបន្តយដើមទុន	1% លើទឹកប្រាក់សុំបន្តយ	45-60 នៃថ្ងៃធ្វើការ	
០៣	ការផ្ទេរភាគហ៊ុន	0.5% នៃតម្លៃចារិកភាគហ៊ុន	45-60 នៃថ្ងៃធ្វើការ	
០៤	ការស្នើសុំប្តូរអាជ្ញាបណ្ណ (សម្រាប់អាជ្ញាបណ្ណ ១ ក្នុង ១ លើក)	2,000,000.00 រៀល	20-45 នៃថ្ងៃធ្វើការ	
០៥	ការស្នើសុំលិខិតបញ្ជាក់ អាជ្ញាបណ្ណ លិខិតអនុញ្ញាត ដើមទុន និង ភាគទុនិក (សម្រាប់ ១ លើក)	1,000,000.00 រៀល	10-20 នៃថ្ងៃធ្វើការ	
០៦	ការផ្លាស់ប្តូរសមាសភាពភាគទុនិក	0.00 រៀល	45-60 នៃថ្ងៃធ្វើការ	
០៧	ការបន្ថែមសមាសភាពភាគទុនិកថ្មី	0.00 រៀល	45-60 នៃថ្ងៃធ្វើការ	
០៨	ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល	0.00 រៀល	15-25 នៃថ្ងៃធ្វើការ	
០៩	ការបន្ថែមសមាសភាពក្រុមប្រឹក្សាភិបាលថ្មី	0.00 រៀល	15-25 នៃថ្ងៃធ្វើការ	
១០	ការផ្លាស់ប្តូរអ្នកគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងថ្នាក់ដឹកនាំលំដាប់សាខា)	0.00 រៀល	15-25 នៃថ្ងៃធ្វើការ	
១១	ការតែងតាំងអ្នកគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងថ្នាក់ដឹកនាំលំដាប់សាខា)	0.00 រៀល	15-25 នៃថ្ងៃធ្វើការ	
១២	ការស្នើសុំធ្វើប្រតិបត្តិការផលិតផលថ្មី	0.00 រៀល	45-60 នៃថ្ងៃធ្វើការ	

ធ៧-០១៤-២២៦ ប្រ.ក

ប្រកាស
ស្តីពី
កិច្ចការពារផ្នែកគតិយុត្តសម្រាប់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងការពារផ្នែកគតិយុត្តសម្រាប់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបំពេញមុខងារ-ភារកិច្ចត្រួតពិនិត្យ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅបង្កើនទំនុកចិត្ត និងពង្រឹងប្រសិទ្ធភាពការងាររបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវខ្ពស់។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីទទួលបន្ទុកត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតែប៉ុណ្ណោះ។

ប្រការ ៤.-

មន្ត្រីទទួលបន្ទុកត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមាន៖

- ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា
- មន្ត្រី-បុគ្គលិកនៃអគ្គនាយកដ្ឋានត្រួតពិនិត្យ
- បុគ្គលដែលត្រូវបានតែងតាំងឱ្យបំពេញការងារត្រួតពិនិត្យ
- ជំនាញការ ឬទីប្រឹក្សាដែលពាក់ព័ន្ធនឹងការងារត្រួតពិនិត្យ
- បុគ្គលដែលបំពេញមុខងារជាអភិបាលបណ្តោះអាសន្ន។

ប្រការ ៥.-

មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ ដែលត្រូវបានការពារផ្នែកគតិយុត្ត ក្នុងការបំពេញមុខងារ-ភារកិច្ចត្រួតពិនិត្យ ជាឯកត្តជន ឬជាក្រុម ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- បំពេញមុខងារ-ភារកិច្ចដោយសុចរិត
- បំពេញមុខងារ-ភារកិច្ចប្រកបដោយវិជ្ជាជីវៈដូចមានចែងក្នុងក្រមប្រតិបត្តិរបស់ធនាគារជាតិនៃកម្ពុជា
- គោរពតាមក្រមសីលធម៌សម្រាប់មន្ត្រីត្រួតពិនិត្យ

- គោរពគោលការណ៍រក្សាការសម្ងាត់វិជ្ជាជីវៈ
- បំពេញមុខងារ-ភារកិច្ចតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា
- ចៀសវាងទំនាស់ផលប្រយោជន៍
- ចៀសវាងការធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អាជ្ញាធរត្រួតពិនិត្យ
- ចៀសវាងការធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងផលប្រយោជន៍របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ប្រការ ៦.-

ក្នុងករណីមន្ត្រីទទួលបន្ទុកត្រួតពិនិត្យ រងការប្តឹងតវ៉ាតាមផ្លូវតុលាការ ក្នុងការបំពេញមុខងារ-ភារកិច្ចត្រួតពិនិត្យ ជាឯកត្តជន ឬជាក្រុម ធនាគារជាតិនៃកម្ពុជា ត្រូវ៖

- ទទួលបន្ទុករាល់ការចំណាយទាំងអស់ ដែលទាក់ទងនឹងនីតិវិធីដំណើរការនៃបណ្តឹង
- ជ្រើសរើស និងទទួលបន្ទុកចំណាយលើសេវាមេធាវី
- ផ្តល់កិច្ចការពារសុវត្ថិភាពដល់មន្ត្រីដែលទទួលរងការចោទប្រកាន់
- សហការក្នុងការផ្តល់ភស្តុតាង និងព័ត៌មាននានា តាមការតម្រូវរបស់តុលាការ។

ប្រការ ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៥-១៥៤ ប្រ.ក

ប្រកាស
ស្តីពី
ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស

ប្រការ ១.-

ប្រកាសនេះមានគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស។

ប្រការ ២.-

ប្រកាសនេះមានគោលដៅ៖

- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យក្រុមនិងសម្ព័ន្ធគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង
- បង្កើតយន្តការការពារនិងដោះស្រាយវិបត្តិ។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តក្របខ័ណ្ឌចែករំលែកព័ត៌មានត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស។

ប្រការ ៤.-

ក្របខ័ណ្ឌចែករំលែកព័ត៌មានអាចត្រូវបានរៀបចំឡើងតាមទម្រង់ដូចខាងក្រោម៖

(១) កិច្ចប្រជុំទ្វេភាគីរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(២) អនុស្សារណៈយល់គ្នារវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(៣) កិច្ចប្រជុំរវាងមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស និង

(៤) កិច្ចទំនាក់ទំនងផ្សេងទៀត តាមការចាំបាច់។

ប្រការ ៥.-

ការចែករំលែកព័ត៌មានត្រួតពិនិត្យត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការ គោរពតាមគោលការណ៍នៃការរក្សាការសម្ងាត់វិជ្ជាជីវៈ និងច្បាប់ជាធរមាន។

អាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស ដែលទទួលបានព័ត៌មានត្រូវរក្សាការសម្ងាត់ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរដែលបានផ្តល់ព័ត៌មាន។

ប្រការ ៦.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៦-២១០ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦

សេចក្តីជូនដំណឹង
ស្តីពី
ការហាមឃាត់ទទួលយកអត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្តល់ឥណទាន

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ មេត្តាជ្រាបថា កន្លងមក ធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួន ជាពិសេស ប្រតិបត្តិករឥណទានជនបទ បាននិងកំពុងផ្តល់ឥណទានដល់អតិថិជនរបស់ខ្លួនដោយទទួលយកនូវ អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជាវត្ថុធានាក្នុងការផ្តល់ឥណទាន ដែលជាការអនុវត្តមិនត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិធរមាន។ ធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ជាប្រភេទលិខិតយថាភូត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់បញ្ជាក់អត្តសញ្ញាណបុគ្គល និងសម្រង់ស្ថិតិប្រជា-ពលរដ្ឋតែប៉ុណ្ណោះ។ លិខិតយថាភូតមិនមែនជាទ្រព្យសម្រាប់ការដាក់បញ្ចាំ ឬជាទ្រព្យធានាក្នុង ប្រតិបត្តិការផ្តល់ឥណទានឡើយ ពីព្រោះថា លិខិតទាំងនោះមិនមានតម្លៃសេដ្ឋកិច្ចសម្រាប់សកម្មភាព ពាណិជ្ជកម្ម។ ដូច្នេះ គ្រប់គ្រឹះស្ថានធនាគារហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ត្រូវ បញ្ឈប់ជាបន្ទាន់ ចំពោះការទទួលយកនូវ អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជាវត្ថុធានាលើការផ្តល់ឥណទាន។ ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករ ឥណទានជនបទណាមិនអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន គ្រឹះស្ថាននឹងត្រូវរងការពិន័យ តាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ត.ប. ទេសាភិបាល
អគ្គនាយកត្រួតពិនិត្យ
ហត្ថលេខានិងត្រា៖ **គិម ខ៉ាជា**

ធ៧-០១៦-៣៣៥ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់ឥណទានជារូបិយវត្ថុជាតិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងជំរុញការផ្តល់ឥណទានជារូបិយវត្ថុជាតិដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះមានគោលដៅបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ចសម្រាប់ជាយន្តការក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានទាំងអស់ត្រូវមានឥណទានជារូបិយវត្ថុជាតិ យ៉ាងតិច ១០% (ដប់ភាគរយ) នៃសំពៀតឥណទានសរុប ដោយត្រូវអនុវត្តចាប់ពីថ្ងៃប្រកាសនេះចូលជាធរមាន និងឱ្យបានពេញលេញយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

ប្រការ ៥.-

ការផ្តល់ឥណទានជារូបិយវត្ថុជាតិត្រូវមានចែងនៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយរបស់គ្រឹះស្ថាន។

ប្រការ ៦.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានបង្កើនការផ្តល់ឥណទានជារូបិយវត្ថុជាតិបន្ថែមទៀត ស្របតាមការចាំបាច់។

ប្រការ ៧.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៧-២៩៩ ប្រ.ក

ប្រកាស
ស្តីពី
ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់យន្តការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅលើកកម្ពស់កិច្ចការពារអតិថិជនដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់អតិថិជនចំពោះការប្រើប្រាស់ផលិតផលនិងសេវារបស់គ្រឹះស្ថាន តាមរយៈការដោះស្រាយបណ្តឹងឱ្យបានសមស្រប និងមានប្រសិទ្ធភាព។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

សម្រាប់គោលបំណងនៃប្រកាសនេះ និយមន័យមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

អតិថិជន សំដៅដល់រូបវន្តបុគ្គល ដែលកំពុងស្វែងរកផលិតផលនិងសេវាពីគ្រឹះស្ថាន ឬដែលកំពុងមានទំនាក់ទំនងជាមួយគ្រឹះស្ថាន។

បណ្តឹង សំដៅដល់ការបញ្ចេញមតិរបស់អតិថិជនដែលបង្ហាញពីការមិនពេញចិត្តលើផលិតផលឬសេវា ដែលបានផ្តល់ដោយគ្រឹះស្ថាន។

មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន សំដៅដល់គណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានដែលតែងតាំងដោយក្រុមប្រឹក្សាភិបាលដើម្បីទទួលខុសត្រូវក្នុងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន។

ប្រការ ៥.-

គ្រឹះស្ថានត្រូវទទួល និងដោះស្រាយបណ្តឹងដែលទទួលបានផ្ទាល់ពីអតិថិជន និង/ឬ បុគ្គលតំណាងអតិថិជន រួមទាំងបណ្តឹងអតិថិជនដែលធនាគារជាតិនៃកម្ពុជាទទួលបាន រួចបញ្ជូនបន្តទៅគ្រឹះស្ថាន។

អតិថិជនត្រូវដាក់ពាក្យបណ្តឹងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបានដឹងអំពីបញ្ហាដែលចង់តវ៉ា។ បណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់ និង/ឬ សរសេរជាលាយលក្ខណ៍អក្សរ។

គ្រឹះស្ថានមិនត្រូវរារាំង ឬរឹតត្បិតសិទ្ធិរបស់អតិថិជនក្នុងការដាក់ពាក្យបណ្តឹង រួមទាំងការយកសោហ៊ុយលើការដាក់ពាក្យ ការដំណើរការ និងការបញ្ចប់បណ្តឹង។

ជំពូកទី ២
ក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន

ប្រការ ៦.-

គ្រឹះស្ថានត្រូវបង្កើតក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជនដោយរួមមានចំណុចមួយចំនួនយ៉ាងតិចដូចខាងក្រោម៖

១. តួនាទីរបស់មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន ទទួលបន្ទុកអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន

២. គោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរច្បាស់លាស់ ពេញលេញ និងមានការផ្សព្វផ្សាយទូលំទូលាយដល់បុគ្គលិករបស់គ្រឹះស្ថាន

៣. គោលនយោបាយនិងនីតិវិធីសម្រាប់៖

ក. កំណត់ដំណើរការបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន

ខ. រក្សាការសម្ងាត់ព័ត៌មានទាក់ទងនឹងបណ្តឹងអតិថិជន

គ. រក្សាទុកឯកសារបណ្តឹងអតិថិជនដោយសុវត្ថិភាពយ៉ាងតិចរយៈពេល ៣ (បី) ឆ្នាំ

ឃ. បណ្តុះបណ្តាលគណៈគ្រប់គ្រង និងបុគ្គលិកដែលពាក់ព័ន្ធនឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន។

៤. ធ្វើមជ្ឈការក្នុងការតាមដាននិងត្រួតពិនិត្យក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន

៥. របៀបរាយការណ៍ជាប្រចាំដល់គណៈគ្រប់គ្រងជាន់ខ្ពស់អំពី ការគ្រប់គ្រង និងដោះស្រាយបណ្តឹង

៦. ក្រមប្រតិបត្តិនៃការរាយការណ៍ ការចៀសវាង និងការគ្រប់គ្រងការដោះស្រាយបណ្តឹងដែលពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍

៧. ការកំណត់ច្បាស់លាស់អំពី តួនាទី ការទទួលខុសត្រូវ និងការផ្តល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន និង

៨. នីតិវិធីសម្រាប់ធ្វើការពិនិត្យ និងរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន រួមទាំង រយៈពេលនៃដំណើរការដោះស្រាយ កម្រិតនៃការពេញចិត្តរបស់អតិថិជន និងលទ្ធផលនៃបណ្តឹងអតិថិជនដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនទៅ។

ប្រការ ៧.-

ក្រុមប្រឹក្សាភិបាលត្រូវធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជនដូចមានចែងក្នុងប្រការ ៦។ សម្រាប់គោលបំណងនៃប្រកាសនេះ ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវយ៉ាងតិចដូចខាងក្រោម៖

១. អនុម័ត និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន

២. កំណត់តួនាទី ការទទួលខុសត្រូវ និងផ្តល់សិទ្ធិអំណាចដល់មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន

៣. ផ្តល់ការបណ្តុះបណ្តាលសមស្របជាប្រចាំ និងទៀងទាត់ដល់ថ្នាក់គ្រប់គ្រងនិងបុគ្គលិកដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន និង

៤. ធ្វើការពិនិត្យឡើងវិញប្រចាំឆ្នាំអំពីប្រសិទ្ធភាពនិងលទ្ធផលនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន។

ប្រការ ៨.-

គ្រឹះស្ថានត្រូវបង្កើតផ្នែកគ្រប់គ្រងបណ្តឹង ដែលទទួលបន្ទុកដោយមន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជនដើម្បីទទួល និងដោះស្រាយបណ្តឹងរបស់អតិថិជន។ ផ្នែកគ្រប់គ្រងបណ្តឹង ត្រូវទទួលខុសត្រូវយ៉ាងតិចដូចខាងក្រោម៖

១. ទទួលនិងដោះស្រាយបណ្តឹងស្របតាមគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន

២. តាមដាន និងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន

៣. ប្រតិបត្តិតាមប្រកាសនេះ និងមានកាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា និង

៤. រាយការណ៍ជាប្រចាំអំពីបណ្តឹងទៅគណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល។

មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន និងបុគ្គលិកដែលទទួលបន្ទុកដោះស្រាយបណ្តឹងត្រូវបង្ហាញអំពីបញ្ហាទាក់ទងនឹងទំនាស់ផលប្រយោជន៍រវាងគ្រឹះស្ថានជាមួយអ្នកប្តឹង ឬកម្មវត្ថុនៃបណ្តឹងទៅគណៈគ្រប់គ្រងជាន់ខ្ពស់។

គ្រឹះស្ថានត្រូវបញ្ជូនឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន មកធនាគារជាតិនៃកម្ពុជា។ ក្នុងករណីមានការផ្លាស់ប្តូរមន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន គ្រឹះស្ថានត្រូវជូនដំណឹងភ្លាមដល់ធនាគារជាតិនៃកម្ពុជា។

ជំពូកទី ៣
ការដោះស្រាយបណ្តឹង

ប្រការ ៩.-

បណ្តឹងផ្ទាល់មាត់ត្រូវដោះស្រាយក្នុងអំឡុងពេល ២ (ពីរ) ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីបណ្តឹងផ្ទាល់មាត់មិនអាចដោះស្រាយបានតាមពេលកំណត់ គ្រឹះស្ថានត្រូវណែនាំដល់អតិថិជន និង/ឬ បុគ្គលតំណាងអតិថិជនឱ្យដាក់បណ្តឹងជាលាយលក្ខណ៍អក្សរ។

ក្នុងករណី អតិថិជនមិនមានបំណងចង់បន្តបណ្តឹងជាលាយលក្ខណ៍អក្សរ គ្រឹះស្ថានត្រូវធ្វើកំណត់ត្រានូវការមិនពេញចិត្តរបស់អតិថិជននិងរក្សាទុកនៅគ្រឹះស្ថាន។ កំណត់ត្រាត្រូវមានបញ្ជាក់អំពី កាលបរិច្ឆេទ បញ្ហា និងលទ្ធផលនៃដំណោះស្រាយ។ ធនាគារជាតិនៃកម្ពុជា អាចស្នើសុំកំណត់ត្រានេះបានតាមការចាំបាច់។

ក្នុងករណីអតិថិជនចង់ដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ប៉ុន្តែមិនអាចធ្វើបានដោយហេតុផលណាមួយ គ្រឹះស្ថានត្រូវរៀបចំពាក្យបណ្តឹងក្នុងនាមអតិថិជន និងដាក់ពាក្យបណ្តឹងនេះស្របតាមដំណើរការគ្រប់គ្រងបណ្តឹងរបស់គ្រឹះស្ថាន។ គ្រឹះស្ថានត្រូវផ្តល់ច្បាប់ចម្លងនៃពាក្យបណ្តឹងមួយច្បាប់ដល់អតិថិជន។

ចំពោះបណ្តឹងជាលាយលក្ខណ៍អក្សរ គ្រឹះស្ថានត្រូវប្រតិបត្តិតាមពេលកំណត់សម្រាប់បញ្ចប់ដំណាក់កាលនីមួយៗ ក្នុងដំណើរការដោះស្រាយបណ្តឹង ដូចខាងក្រោម៖

<u>ដំណាក់កាលទី១៖</u>

គ្រឹះស្ថានត្រូវចេញលិខិតទទួលស្គាល់បណ្តឹងជាលាយលក្ខណ៍អក្សរទៅអតិថិជន និង/ឬ បុគ្គលតំណាងអតិថិជនបន្ទាប់ពីបានទទួលបណ្តឹងពីអតិថិជន។ លិខិតទទួលស្គាល់បណ្តឹងត្រូវមានបញ្ជាក់ យ៉ាងតិចនូវចំណុចដូចខាងក្រោម៖

- លេខចុះបញ្ជី
- កាលបរិច្ឆេទទទួលបណ្តឹង
- ឈ្មោះអតិថិជន និង/ឬ បុគ្គលតំណាងអតិថិជន
- ឈ្មោះ និងលេខទូរស័ព្ទបុគ្គលិករបស់គ្រឹះស្ថានដែលទទួលបណ្តឹង និង
- សេចក្តីសង្ខេបនៃបណ្តឹង។

លិខិតទទួលស្គាល់បណ្តឹងត្រូវចុះហត្ថលេខាដោយបុគ្គលិករបស់គ្រឹះស្ថានដែលទទួលបណ្តឹង។

<u>ដំណាក់កាលទី២៖</u>

គ្រឹះស្ថានត្រូវស្វែងរកអង្គហេតុ និងដោះស្រាយបណ្តឹងមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យបណ្តឹង។ គ្រឹះស្ថានត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃដំណោះស្រាយបណ្តឹងដោយមានបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

<u>ដំណាក់កាលទី៣៖</u>

ក្នុងករណីបណ្តឹងពាក់ព័ន្ធនឹងបញ្ហាធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ បញ្ហាជាប្រព័ន្ធ ឬបញ្ហាផ្នែកច្បាប់ គ្រឹះស្ថានត្រូវបញ្ជូនបន្តទៅអ្នកជំនាញដើម្បីផ្តល់យោបល់ដល់គណៈគ្រប់គ្រងជាន់ខ្ពស់ឬក្រុមប្រឹក្សាភិបាលធ្វើសេចក្តីសម្រេចចុងក្រោយ។

គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា ក្នុងរបាយការណ៍ត្រីមាសបន្ទាប់នូវរាល់ការសម្រេចនិងមូលហេតុនៃបណ្តឹងដែលមិនអាចដោះស្រាយបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ។ របាយការណ៍នេះត្រូវពន្យល់អំពីមូលហេតុនៃការពន្យារពេលនិងកំណត់កាលបរិច្ឆេទដែលត្រូវដោះស្រាយបញ្ចប់បណ្តឹង។ ក្នុងករណីនេះ គ្រឹះស្ថានត្រូវជូនដំណឹងទៅអតិថិជនអំពីការពន្យារពេលនៃដំណើរការដោះស្រាយបណ្តឹងដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

ជំពូកទី ៤
ភាតព្វកិច្ចរាយការណ៍

ប្រការ ១០.-

គ្រឹះស្ថានត្រូវធ្វើរបាយការណ៍គ្រប់គ្រងនិងដោះស្រាយបណ្តឹងមកធនាគារជាតិនៃកម្ពុជារៀងរាល់ត្រីមាសយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ (ដប់ប្រាំ) នៃខែទី១ (មួយ) នៃត្រីមាសបន្ទាប់។ របាយការណ៍នេះត្រូវបង្ហាញនូវព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

- ចំនួនបណ្តឹងដែលទទួលបានក្នុងគ្រារាយការណ៍
- បណ្តឹងដែលបានដោះស្រាយចប់ក្នុងគ្រារាយការណ៍
- ផលិតផល និងសេវាពាក់ព័ន្ធនឹងបណ្តឹង
- បញ្ហាជាប្រព័ន្ធក្នុងគ្រឹះស្ថាន
- រយៈពេលជាមធ្យមសម្រាប់ការដោះស្រាយបណ្តឹង
- វិធានការកែតម្រូវ ដើម្បីកាត់បន្ថយចំនួនបណ្តឹងដែលកើតឡើងញឹកញាប់ និងមានសារៈសំខាន់ជាប្រព័ន្ធ និង
- បណ្តឹងកំពុងដំណើរការដោះស្រាយក្នុងគ្រារាយការណ៍។

ប្រការ ១១.-

គ្រឹះស្ថានត្រូវរក្សាកំណត់ត្រានៃបណ្តឹងនីមួយៗក្នុងឃ្លាំងទិន្នន័យ (Database) រយៈពេល ៣ (បី) ឆ្នាំចាប់ពីពេលដែលបណ្តឹងត្រូវបានបញ្ចប់ដូចមានចែងនៅក្នុងប្រការ ១៣ និង ១៤ នៃប្រកាសនេះ។ ទិន្នន័យបណ្តឹងនីមួយៗត្រូវបញ្ចូលព័ត៌មានយ៉ាងតិចដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី ៥
ឯកសារផ្តល់ព័ត៌មាន

ប្រការ ១២.-

គ្រឹះស្ថានត្រូវដាក់បង្ហាញជាសាធារណៈនូវឯកសារផ្តល់ព័ត៌មានដល់អតិថិជនអំពី៖

- ដំណើរការគ្រប់គ្រង និងដោះស្រាយបណ្តឹងដែលមានលក្ខណៈងាយយល់ ដោយមានបញ្ជាក់អំពីពេលវេលាដោះស្រាយច្បាស់លាស់ ទាំងជាភាសាខ្មែរ និងអង់គ្លេស នៅគ្រប់ទីតាំងផ្តល់ផលិតផលនិងសេវា

- ដំណើរការគ្រប់គ្រង និងដោះស្រាយបណ្តឹងនៅក្នុងគេហទំព័រដែលបង្ហាញឱ្យឃើញច្បាស់នូវ ICON/LINK សម្រាប់អតិថិជនទាញយកបាន និង
- ប័ណ្ណព័ត៌មានសម្រាប់ទំនាក់ទំនង ដែលត្រូវបង្ហាញឱ្យច្បាស់លាស់អំពី Hotline ដោយមានលេខទូរស័ព្ទ អ៊ីម៉ែល និងអាសយដ្ឋានសម្រាប់ទទួលបណ្តឹង។

ជំពូកទី ៦
ការបញ្ចប់បណ្តឹង និងការតវ៉ាមកធនាគារជាតិនៃកម្ពុជា

ប្រការ ១៣.-

នៅពេលដែលអតិថិជនសម្រេចដកបណ្តឹង គ្រឹះស្ថានត្រូវចងក្រងឯកសារដកបណ្តឹងក្នុងរបាយការណ៍ប្រចាំត្រីមាសដែលផ្ញើមកធនាគារជាតិនៃកម្ពុជាដោយបញ្ជាក់ពីមូលហេតុនៃការដកបណ្តឹង។

ក្នុងករណីដែលអតិថិជនទទួលយកសេចក្តីសម្រេចលើបណ្តឹងរបស់គ្រឹះស្ថានដែលមានការផ្តល់សំណង និង/ឬ ការសងប្រាក់ត្រឡប់វិញ គ្រឹះស្ថានត្រូវបំពេញកាតព្វកិច្ចនោះ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីដែលសេចក្តីសម្រេចរបស់គ្រឹះស្ថានមានបញ្ជាក់អំពីសកម្មភាពកែតម្រូវ គ្រឹះស្ថានត្រូវធ្វើការកែតម្រូវឱ្យបានចប់ត្រឹមកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចនោះ។

នៅពេលបណ្តឹងត្រូវបានដោះស្រាយរួច គ្រឹះស្ថានត្រូវអនុវត្តសកម្មភាពកែតម្រូវចំពោះបញ្ហាដែលជាមូលហេតុនៃបណ្តឹងជាទូទៅ។

ប្រការ ១៤.-

ក្នុងករណីអតិថិជនមិនយល់ស្របតាមសេចក្តីសម្រេចរបស់គ្រឹះស្ថាន អតិថិជន និង/ឬ គ្រឹះស្ថានអាចស្នើមកធនាគារជាតិនៃកម្ពុជាដើម្បីពិនិត្យឡើងវិញលើដំណើរការ និងសេចក្តីសម្រេចនៃបណ្តឹង ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានសេចក្តីសម្រេចរបស់គ្រឹះស្ថាន។

អតិថិជន និង/ឬ គ្រឹះស្ថាន ត្រូវធ្វើសំណើតវ៉ាជាលាយលក្ខណ៍អក្សរមកផ្នែកទទួលបណ្តឹងអតិថិជនរបស់ធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់ជាមួយនូវច្បាប់ថតចម្លងនៃបណ្តឹង និងសេចក្តីសម្រេចរបស់គ្រឹះស្ថាន។ សំណើតវ៉ារបស់អតិថិជនត្រូវបញ្ជាក់ពីមូលហេតុនៃការតវ៉ា និងមូលហេតុដែលអតិថិជនមិនព្រមទទួលយកសេចក្តីសម្រេចរបស់គ្រឹះស្ថាន។

បន្ទាប់ពីទទួលបានសំណើតវ៉ារបស់អតិថិជន និង/ឬ គ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យ និងដោះស្រាយលើសំណើតវ៉ានោះ តាមរយៈការពិនិត្យឡើងវិញនូវបណ្តឹងរបស់អតិថិជន និងដំណោះស្រាយរបស់គ្រឹះស្ថាន។ ធនាគារជាតិនៃកម្ពុជាអាចផ្តល់អនុសាសន៍សម្រាប់ការដោះស្រាយបណ្តឹងនោះ។ ក្នុងករណីមិនអាចដោះស្រាយបាន ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសិទ្ធិរបស់ភាគីនៃបណ្តឹងក្នុងការប្តឹងបន្តទៅតុលាការ ឬមជ្ឈត្តកម្ម។

ជំពូកទី ៧
ការពិន័យ

ប្រការ ១៥.-

គ្រឹះស្ថានណាដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ១៦.-

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ ដូចខាងក្រោម៖

១. គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ១.000.000 (មួយលាន) រៀល ក្នុងមួយថ្ងៃ។

២. គ្រឹះស្ថានណាដែលល្មើសនឹងបញ្ញត្តិជាធរមាននៃប្រកាសនេះ ត្រូវពិន័យជាទឹកប្រាក់ចំនួន ៣.000.000 (បីលាន) រៀល ក្នុងមួយថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាកំណត់ឱ្យកែតម្រូវ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

ប្រការ ១៧.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

កំណត់ត្រានៃបណ្តឹង	
ព័ត៌មាននៃបណ្តឹង	<u>**ការប្រមូលព័ត៌មានបណ្តឹង៖**</u> ១. លេខចុះបញ្ជី ២. ឈ្មោះអ្នកប្តឹង ៣. ព័ត៌មានទំនាក់ទំនង ៤. តើបុគ្គលិករបស់គ្រឹះស្ថានបានផ្តល់ព័ត៌មានអំពីដំណើរការនៃបណ្តឹងជូនអតិថិជនដែរឬទេ? (មាន/គ្មាន) ៥. កាលបរិច្ឆេទសំខាន់ៗនៃដំណើរការបណ្តឹង៖ ក. កាលបរិច្ឆេទនៃការទទួលបណ្តឹង ខ. កាលបរិច្ឆេទនៃការចេញលិខិតទទួលស្គាល់បណ្តឹង គ. កាលបរិច្ឆេទបញ្ចប់ការស្វែងរកអង្គហេតុ ឃ. កាលបរិច្ឆេទដែលគ្រឹះស្ថានបានជូនដំណឹងដល់អតិថិជនអំពីសេចក្តីសម្រេចលើបណ្តឹង ៦. សេចក្តីសង្ខេបនៃបណ្តឹង ៧. ឈ្មោះ និងតួនាទីមន្ត្រីទទួលបន្ទុកចាត់ចែងបណ្តឹង ៨. តើគ្រឹះស្ថានយល់ស្របលើមូលដ្ឋាននៃបណ្តឹងដែរឬទេ? (យល់ស្រប / មិនយល់ស្រប) ៩. ការបញ្ចប់បណ្តឹង៖ ក. បណ្តឹងត្រូវបានដកនិងដោះស្រាយរួច ខ. បណ្តឹងត្រូវបានដក ប៉ុន្តែមិនអាចដោះស្រាយ គ. បណ្តឹងត្រូវបានដោះស្រាយ និងទទួលយកដោយអតិថិជន ឃ. បណ្តឹងបានដោះស្រាយ ប៉ុន្តែមិនទទួលយកដោយអតិថិជន ១០. តើបណ្តឹងត្រូវបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំត្រីមាស ជូនធនាគារជាតិនៃកម្ពុជាដែរឬទេ ? (បាន / មិនបាន)

កំណត់ត្រានៃបណ្តឹង	
វិធីនៃការរៀបចំបណ្តឹង	<u>**តើបណ្តឹងត្រូវដាក់នៅកន្លែងណា? ដោយរបៀបណា?**</u> ១. ទីតាំងសាខា ឬកន្លែងផ្សេងៗទៀតដែលអតិថិជនបានប្តឹង ២. វិធីប្តឹង៖ ក. ទំនាក់ទំនងផ្ទាល់ជាមួយបុគ្គលិករបស់គ្រឹះស្ថាន - ទូរស័ព្ទ - ជួបផ្ទាល់ ខ. ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច - អ៊ីម៉ែល - គេហទំព័រ - ផ្ញើសារ - ទូរសារ គ. ផ្ញើលិខិត
កម្មវត្ថុនៃបណ្តឹង	<u>**កំណត់ពីបញ្ហាដែលត្រូវប្តឹង៖**</u> ១. កំហុសផ្នែកគណនេយ្យ (ពិព័ណ៌នាអំពីកំហុស) ២. ពន្យារពេលក្នុងការបញ្ចប់ប្រតិបត្តិការ៖ ក. ដំណើរការឥណទាន ខ. ចេញមូលប្បទានបត្រ គ. ប្រាក់បញ្ញើ ឃ. កែតម្រូវគណនី ង. ផ្ទេរប្រាក់ ច. ចេញវិក្កយបត្រ / របាយការណ៍ប្រចាំខែ ៣. ពេលបង្ហាញព័ត៌មាន-មិនបានផ្តល់មុនពេលធ្វើប្រតិបត្តិការ ៤. ការបង្ហាញព័ត៌មានមិនគ្រប់គ្រាន់អំពី៖ ក. សោហ៊ុយ ខ. លក្ខខណ្ឌនៃកិច្ចសន្យា គ. អត្រាការប្រាក់ / វិធីសាស្ត្រគណនា ៥. ព័ត៌មាននាំឱ្យមានការភាន់ច្រឡំ

កំណត់ត្រានៃបណ្តឹង	
	៦. សកម្មភាពប្រមូលឥណទានដោយការរំលោភបំពាន ៧. ការគណនាអត្រាការប្រាក់ (សន្សំ និងឥណទាន) ៨. ការគៃបន្លំ ៩. គុណភាពនៃសេវាកម្មផ្តល់ដោយបុគ្គលិករបស់គ្រឹះស្ថាន ១០. ការរំលោភបំពាន ១១. ល្មើសនឹងការសម្ងាត់អតិថិជន ១២. សកម្មភាពលក់ផលិតផលនិងសេវា ដោយ៖ ក. គំរាមកំហែង ខ. មិនមានការអនុញ្ញាត គ. ផ្តល់ព័ត៌មាននាំឱ្យមានការភាន់ច្រឡំ ១៣. មិនបានជូនដំណឹងត្រឹមត្រូវពីគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន ១៤. ផ្សេងៗ (បញ្ជាក់)
ប្រភេទផលិតផល ឬសេវាដែលរងការប្តឹង	**<u>ប្រភេទផលិតផល/សេវា៖</u>** ១. ឥណទានឯកត្តជន ២. ឥណទានអាជីវកម្មខ្នាតតូច ៣. ភតិសន្យាហិរញ្ញវត្ថុ ៤. ប័ណ្ណទូទាត់ប្រាក់ ៥. ប័ណ្ណឥណទាន ៦. គណនីសន្សំ ៧. គណនីចរន្ត ៨. ការផ្ទេរប្រាក់ ៩. ការវិនិយោគ ១០. ប្រតិបត្តិការធនាគារចល័ត ១១. ផ្សេងៗ (បញ្ជាក់)

ធ៧-០១៧-៣០០ ប្រ.ក

ប្រកាស
ស្តីពី
លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
ដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន" សម្រាប់ការដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅផ្តល់លទ្ធភាពដល់គ្រឹះស្ថានក្នុងការកៀរគរ និងបង្កើនមូលនិធិសម្រាប់ពង្រីកអាជីវកម្ម ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានដែលមានបំណងចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា
- ត្រូវមានមូលនិធិផ្ទាល់សុទ្ធយ៉ាងតិច ៦០.០០០.០០០.០០០ រៀល (ហុកសិបប៊ីលានរៀល)
- ត្រូវមានស្ថានភាពហិរញ្ញវត្ថុល្អ និងអភិបាលកិច្ចរឹងមាំ តាមរយៈការធ្វើចំណាត់ថ្នាក់ដោយធនាគារជាតិនៃកម្ពុជា ត្រឹមកម្រិតសុវត្ថិភាព ចាប់ពី ២ (ពីរ) ឆ្នាំ ឡើងទៅ និង
- ត្រូវអនុវត្តពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

បន្ទាប់ពីទទួលបានការអនុញ្ញាតចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា គ្រឹះស្ថានត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- អាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិក្នុងផ្សារមូលបត្រកម្ពុជា មិនលើសពី ២០% (ម្ភៃភាគរយ) នៃសិទ្ធិបោះឆ្នោតនៅក្នុងគ្រឹះស្ថាន និង/ឬ

- អាចបោះផ្សាយសញ្ញាបណ្ណសាជីវកម្មលក់ក្នុងផ្សារមូលបត្រកម្ពុជា មិនលើសពី ២០% (ម្ភៃភាគរយ) នៃទ្រព្យសកម្មសរុប។

ប្រការ ៦.-

ការចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជាមិនត្រូវបានប្រើប្រាស់ជាមូលហេតុគេចវេសពីកាតព្វកិច្ចបំពេញដើមទុនចុះបញ្ជីអប្បបរមាដែលបានកំណត់ចំពោះភាគទុនិកឡើយ។

គ្រឹះស្ថាននៅតែមានកាតព្វកិច្ចអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៧.-

គ្រឹះស្ថានណាមួយដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុង មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៨.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៧-០១៧-៣៣៥ ប្រ.ក

ប្រកាស
ស្តីពី
សវនកម្ម ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ដើម្បីទទួលស្គាល់ក្រុមហ៊ុនសវនកម្មដែលធ្វើសវនកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងកំណត់កាតព្វកិច្ចរបស់ក្រុមហ៊ុនសវនកម្មដែលត្រូវបានទទួលស្គាល់ តទៅនេះ ហៅថា "ក្រុមហ៊ុន" និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្ម តទៅនេះហៅថា "សវនដ្ឋាន"។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅ ដើម្បី៖

- ធានានូវភាពត្រឹមត្រូវនិងសុចរិតនៃព័ត៌មាននិងទិន្នន័យហិរញ្ញវត្ថុ ដែលសវនដ្ឋានផ្តល់ជូនធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធ
- លើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យ ដោយអនុលោមតាមបទដ្ឋាននិងឧត្តមានុវត្តជាតិនិងអន្តរជាតិ និង
- ពង្រឹងគុណភាពការងារសវនកម្មរបស់ក្រុមហ៊ុន។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុន ដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា និងសវនដ្ឋាន ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

សមត្ថភាពវិជ្ជាជីវៈ (Competence) សំដៅដល់សមត្ថភាពរបស់សវនករ ក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងអនុវត្តការងារសវនកម្មសំខាន់ៗដូចជា ការកំណត់និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត ការរៀបចំ និងអនុវត្តយន្តការសមស្របដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។

ភាពមិនលំអៀង (Objectivity) សំដៅដល់ការវិនិច្ឆ័យរបស់សវនករ ដោយមិនមានទំនាស់ផលប្រយោជន៍។ សវនករត្រូវមានឯករាជ្យភាពទាំងស្រុងក្នុងការបំពេញមុខងារ-ភារកិច្ចសវនកម្ម។

ឯករាជ្យភាព (Independence) សំដៅដល់ការមិនរាវាំងពីស្ថានភាព និងពីទំនាក់ទំនងទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ការវិនិច្ឆ័យដោយឯករាជ្យ និងមិនលំអៀងរបស់សវនករ។ ឯករាជ្យភាពនេះត្រូវមានគ្រប់ពេលក្នុងការទំនាក់ទំនងជាមួយសវនដ្ឋាន និងជាមួយស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងសវនដ្ឋាន។

ក្រមសីលធម៌ (Code of Ethics) សំដៅដល់ក្រមសីលធម៌វិជ្ជាជីវៈ ដែលប្រកាសឱ្យប្រើដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដៃគូសវនកម្ម (Engagement Partner) សំដៅដល់រូបវន្តបុគ្គលក្នុងក្រុមហ៊ុនសវនកម្ម ដែលជាអ្នកទទួលខុសត្រូវចំពោះរាល់កិច្ចការពាក់ព័ន្ធការធ្វើសវនកម្ម និងចំពោះការចេញផ្សាយរបាយការណ៍សវនកម្មក្នុងនាមក្រុមហ៊ុន។

សមាជិកគ្រួសារផ្ទាល់ (Immediate Family Member) សំដៅដល់ទំនាក់ទំនងជា ប្តី ប្រពន្ធ កូន ឪពុក ម្តាយ បងប្អូនបង្កើត ឬបុគ្គលនៅក្រោមអាណាព្យាបាលរបស់បុគ្គលណាម្នាក់។

ជំពូកទី ២
លក្ខខណ្ឌនៃការទទួលស្គាល់

ប្រការ ៥.-

ក្រុមហ៊ុន ដែលមានបំណងធ្វើសវនកម្មលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុន ដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

១. បានចុះបញ្ជីពាណិជ្ជកម្ម
២. ជាសមាជិកវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (វ.គ.ស.ក.)
៣. មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៤. មានដៃគូសវនកម្ម និងសវនករ ជាសមាជិកសកម្ម នៅ វ.គ.ស.ក. យ៉ាងតិច ០២ (ពីរ)រូប ដែលមានគុណវុឌ្ឍិដូចមានចែងក្នុងប្រការ ៧
៥. មានសកម្មភាពធុរកិច្ចសវនកម្ម និងមានកេរ្តិ៍ឈ្មោះល្អ យ៉ាងតិច ០៣ (បី) ឆ្នាំ គិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំ
៦. មានការពិនិត្យគុណភាពការងារសវនកម្មជាប្រចាំ និង
៧. បំពេញលក្ខខណ្ឌផ្សេងទៀត ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

ក្រុមហ៊ុន ដែលដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

១. សារតារក្រុមហ៊ុន

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

៣. វិញ្ញាបនបត្រចុះបញ្ជីជាសមាជិករបស់ វ.គ.ស.ក.

៤. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៥. បញ្ជីឈ្មោះដៃគូសវនកម្ម និងសវនករដែលជាសមាជិកសកម្មនៅ វ.គ.ស.ក. ដោយភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រចុះឈ្មោះជាសមាជិកសកម្ម លិខិតថ្កោលទោស និងប្រវត្តិរូបដែលមានបញ្ជាក់អំពី គុណវុឌ្ឍិ បទពិសោធន៍ និងរយៈពេលបំពេញការងារ

៦. នីតិវិធីនៃការធ្វើសវនកម្ម

៧. ព័ត៌មានស្តីពីការផ្តល់សេវាសវនកម្ម ក្នុងអំឡុងពេល ០៣ (បី) ឆ្នាំ ចុងក្រោយ

៨. របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាមីដែលត្រូវបានធ្វើសវនកម្ម ក្នុងរយៈពេល ០៣ (បី) ឆ្នាំ ចុងក្រោយ និង

៩. ឯកសារផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៧.-

ដៃគូសវនកម្ម និងសវនករ ដែលជាសមាជិកសកម្មរបស់ វ.គ.ស.ក. ត្រូវមានគុណវុឌ្ឍិបន្ថែមដូចខាងក្រោម៖

១. ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

២. បំពេញលក្ខខណ្ឌនៃភាពមិនលំអៀងនិងឯករាជ្យភាព ស្របតាមក្រមសីលធម៌ដែលប្រកាសឱ្យប្រើដោយស្តាប់ឆ្នាមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣. មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងការងារសវនកម្មនៅក្នុងវិស័យធនាគារ និង

៤. មានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ពាក់ព័ន្ធនឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារ។

ប្រការ ៨.-

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការទទួលស្គាល់ ឬមិនទទួលស្គាល់ក្រុមហ៊ុន ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់។

ជំពូកទី ៣
កាតព្វកិច្ចរបស់ក្រុមហ៊ុន និងសវនដ្ឋាន

ប្រការ ៩.-

ក្រុមហ៊ុន ត្រូវមានកាតព្វកិច្ច ដូចខាងក្រោម៖

១. ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សវនដ្ឋាន

២. វាយតម្លៃលើរបាយការណ៍ផ្សេងទៀតរបស់សវនដ្ឋាន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា

៣. រាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជាអំពីភាពមិនប្រក្រតី ដែលទាក់ទងទៅនឹងអសាធនភាព ឬហានិភ័យធ្ងន់ធ្ងរដែលអាចនាំឱ្យសវនដ្ឋានឈានទៅរកអសាធនភាព ការមិនអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងសកម្មភាពបច្ចុប្បន្ន ឬផែនការអនាគតដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់កិច្ចការពារផលប្រយោជន៍របស់អ្នកដាក់ប្រាក់បញ្ញើ និងភាគីពាក់ព័ន្ធ

៤. មិនត្រូវផ្តល់ដល់សវនដ្ឋាននូវ ព័ត៌មាន និងឯកសារ ដូចមានចែងក្នុងចំណុច ៣ ខាងលើ

៥. រាយការណ៍មកធនាគារជាតិនៃកម្ពុជា អំពីការផ្លាស់ប្តូរបុគ្គលិកដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់សវនដ្ឋានដោយមិនបានគ្រោងទុក ក្នុងអំឡុងពេលធ្វើសវនកម្ម

៦. ផ្តល់ឯកសារលទ្ធផលនៃការពិនិត្យគុណភាពការងារសវនកម្ម ជូនមកធនាគារជាតិនៃកម្ពុជា តាមការតម្រូវ

៧. ជូនដំណឹងមកធនាគារជាតិនៃកម្ពុជានូវព័ត៌មាន ដែលបានធ្វើបច្ចុប្បន្នកម្មទាក់ទងទៅនឹងការផ្លាស់ប្តូរសំខាន់ៗ រួមមាន ការផ្លាស់ប្តូរដៃគូសវនកម្ម សមាជិកសកម្ម និងគណៈគ្រប់គ្រងជាន់ខ្ពស់ និង

៨. ផ្តល់ឯកសារ ឬព័ត៌មានផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុន ត្រូវបំពេញពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ស្របតាមឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ១០.-

ក្នុងករណីមានការធ្វើសវនកម្មពិសេស ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍សវនកម្មពិសេសនេះជូនធនាគារជាតិនៃកម្ពុជា និងក្រុមប្រឹក្សាភិបាលរបស់សវនដ្ឋាន។

បើគ្មានការកំណត់ផ្សេងពីធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនត្រូវផ្តល់ការធានាសមស្រប (Reasonable Assurance) លើរបាយការណ៍សវនកម្មពិសេស និងជូនដំណឹងទៅសវនដ្ឋានជាលាយលក្ខណ៍អក្សរ។

ប្រការ ១១.-

ក្នុងគោលបំណងពង្រឹងគុណភាពសវនកម្ម និងតាមដានពីភាពរឹងមាំនៃប្រតិបត្តិការនិងការអនុវត្តតាមបទប្បញ្ញត្តិរបស់សវនដ្ឋាន ធនាគារជាតិនៃកម្ពុជាអាចរៀបចំកិច្ចប្រជុំរួមជាមួយសវនដ្ឋាន

និងក្រុមហ៊ុន ដើម្បីពិភាក្សាលើរបាយការណ៍សវនកម្ម ការរកឃើញពីភាពមិនប្រក្រតី និងបញ្ហាផ្សេងទៀត។ ក្រៅពីកិច្ចប្រជុំនេះ កិច្ចប្រជុំរវាងធនាគារជាតិនៃកម្ពុជា ជាមួយក្រុមហ៊ុន អាចធ្វើឡើងតាមការចាំបាច់។

ប្រការ ១២.-

ក្រុមហ៊ុន ត្រូវគោរពតាមបទប្បញ្ញត្តិ ដូចខាងក្រោម៖

១. ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

២. ស្តង់ដារសវនកម្មដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

៣. ក្រមសីលធម៌ និង

៤. ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។

ប្រការ ១៣.-

ក្រុមហ៊ុនដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា មិនត្រូវធ្វើសវនកម្មចំពោះសវនដ្ឋានប្រសិនបើក្រុមហ៊ុន៖

១. មានទំនាក់ទំនងសំខាន់ផ្នែកហិរញ្ញវត្ថុ និង/ឬ សេដ្ឋកិច្ច ដោយផ្ទាល់និងដោយប្រយោលជាមួយសវនដ្ឋាន

២. មានសមាជិកគ្រួសារផ្ទាល់ជា ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង ប្រធានសវនកម្មផ្ទៃក្នុង ប្រធានមុខងារប្រតិបត្តិតាម ប្រធានហិរញ្ញវត្ថុ និងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធផ្សេងទៀតរបស់សវនដ្ឋាន ឬ

៣. ទទួលអត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលពីសវនដ្ឋាន និង/ឬ មានទំនាក់ទំនងផ្សេងទៀតដែលធនាគារជាតិនៃកម្ពុជាយល់ថា អាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

ប្រការ ១៤.-

ក្រុមហ៊ុន មិនត្រូវផ្តល់ដល់សវនដ្ឋាននូវសេវា ដូចខាងក្រោម៖

១. ការចុះកិច្ចបញ្ជិកា ឬសេវាផ្សេងទៀតទាក់ទងនឹងការកត់ត្រាគណនេយ្យ ឬរបាយការណ៍ហិរញ្ញវត្ថុ

២. ការបង្កើតនិងការដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាផ្នែកហិរញ្ញវត្ថុ

៣. សេវាសវនកម្មផ្ទៃក្នុង

៤. សេវាប្រឹក្សាផ្នែកពន្ធ និង

៥. សេវាផ្សេងៗដែលធនាគារជាតិនៃកម្ពុជាយល់ថាអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

ក្នុងករណី ក្រុមហ៊ុនបានផ្តល់សេវាណាមួយដូចរៀបរាប់ខាងលើដល់សវនដ្ឋាន ក្រុមហ៊ុនមិនត្រូវចុះកិច្ចសន្យាសវនកម្មជាមួយសវនដ្ឋាននោះឡើយ លើកលែងតែការផ្តល់សេវាខាងលើត្រូវបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ សម្រាប់ចំណុច ១ និង ០១ (មួយ) ឆ្នាំ សម្រាប់ចំណុចផ្សេងទៀតនៃប្រការនេះ។

ប្រការ ១៥.-

ក្រុមហ៊ុន មិនត្រូវបានអនុញ្ញាតឱ្យធ្វើសវនកម្មជាបន្តបន្ទាប់លើសវនដ្ឋានតែមួយ លើសពីរយៈពេល ០៣ (បី) ឆ្នាំឡើយ។ ប៉ុន្តែសវនដ្ឋានទាំងឡាយណាដែលជាសាខា ឬជាបុគ្គលសម្ព័ន្ធរបស់ធនាគារបរទេសអាចជ្រើសរើសក្រុមហ៊ុនដូចទីស្នាក់ការកណ្តាលរបស់ខ្លួនបាន ដោយគ្រាន់តែផ្លាស់ប្តូរដៃគូសវនកម្មរៀងរាល់ ០៣ (បី) ឆ្នាំម្តង។ ក្រុមហ៊ុន ដែលត្រូវបានប្តូរចេញពីការធ្វើសវនកម្មនៅសវនដ្ឋានណាមួយ អាចត្រឡប់ទៅបំពេញសវនកម្មលើសវនដ្ឋានដដែលនោះវិញ បន្ទាប់ពីរយៈពេល ០២ (ពីរ) ឆ្នាំ ក្រោយបញ្ចប់ការបំពេញសវនកម្មលើកចុងក្រោយ។

ប្រការ ១៦.-

១. សវនដ្ឋាន ត្រូវមានកាតព្វកិច្ច ដូចខាងក្រោម៖

ក. រងការធ្វើសវនកម្មប្រចាំឆ្នាំ ដោយក្រុមហ៊ុន

ខ. ជ្រើសរើសក្រុមហ៊ុន និងស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវឈ្មោះដៃគូសវនកម្មឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិននីមួយៗ

គ. ផ្តល់កិច្ចសន្យាសវនកម្មជូនធនាគារជាតិនៃកម្ពុជាឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនពេលចាប់ផ្តើមធ្វើសវនកម្ម

ឃ. ផ្តល់ឱ្យក្រុមហ៊ុននូវទិន្នន័យនិងព័ត៌មានទាំងអស់របស់សវនដ្ឋានទៅតាមវិសាលភាពនៃការធ្វើសវនកម្មនិងកាតព្វកិច្ចផ្នែកបទប្បញ្ញត្តិ ព្រមទាំងការណែនាំទាក់ទងនឹងការធ្វើសវនកម្មពីធនាគារជាតិនៃកម្ពុជា។ សវនដ្ឋានមិនត្រូវផ្តល់របាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជាដល់ក្រុមហ៊ុន លើកលែងតែមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា

ង. អនុញ្ញាតឱ្យក្រុមហ៊ុនសាកសួរព័ត៌មានពី ក្រុមប្រឹក្សាភិបាល គណៈកម្មការ សវនកម្មផ្ទៃក្នុង បុគ្គលិកពាក់ព័ន្ធតាមការចាំបាច់ និងអាចទទួលព័ត៌មានសំខាន់ៗផ្សេងទៀតដើម្បីបំពេញការងាររបស់ខ្លួន ស្របតាមប្រកាសនេះ

ច. ធានាថាគណៈកម្មការសវនកម្មរបស់ខ្លួន ត្រូវពិនិត្យឡើងវិញលើកិច្ចសន្យាសវនកម្មរៀងរាល់ឆ្នាំ រួមទាំងការវាយតម្លៃពីឯករាជ្យភាពរបស់ក្រុមហ៊ុន

ឆ. ធានាថាប្រធានសវនកម្មផ្ទៃក្នុងរបស់ខ្លួន ត្រូវចូលរួមកិច្ចប្រជុំរួមរវាង ធនាគារជាតិនៃកម្ពុជា សវនដ្ឋាន និងក្រុមហ៊ុន លើកលែងតែមានការកំណត់ផ្សេងទៀតពីធនាគារជាតិនៃកម្ពុជា និង

ជ. ផ្តល់ជូនក្រុមប្រឹក្សាភិបាលនិងគណៈកម្មការសវនកម្មរបស់សវនដ្ឋាន និងធនាគារជាតិនៃកម្ពុជានូវរបាយការណ៍សវនកម្ម ព្រមទាំងឯកសារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

២. ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជា អាចស្នើសវនដ្ឋានឱ្យតែងតាំងក្រុមហ៊ុន ដែលអាចជាក្រុមហ៊ុនកំពុងធ្វើសវនកម្ម ឬជាក្រុមហ៊ុនផ្សេងទៀត ឱ្យធ្វើសវនកម្មពិសេសលើផ្នែកណាមួយនៃប្រតិបត្តិការ របាយការណ៍តម្រូវដោយបទប្បញ្ញត្តិ របាយការណ៍ប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬស្ថានភាពហិរញ្ញវត្ថុរបស់សវនដ្ឋាន ជាដើម។

៣. ការចំណាយលើរាល់ការធ្វើសវនកម្មនិងចំណាយពាក់ព័ន្ធផ្សេងទៀត ជាបន្ទុករបស់សវនដ្ឋាន។

ជំពូកទី ៤
កម្រៃ និងសោហ៊ុយ

ប្រការ ១៧.-

ក្រុមហ៊ុនសវនកម្មដែលកំពុងដាក់ពាក្យស្នើសុំការទទួលស្គាល់ ត្រូវបង់សោហ៊ុយសាកសួរព័ត៌មាន និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំ ដូចខាងក្រោម៖

១. សោហ៊ុយសាកសួរព័ត៌មាន ៖ ៥០០.០០០ រៀល (ប្រាំរយពាន់រៀល)

២. សោហ៊ុយសិក្សាសំណុំលិខិត ៖ ៤.០០០.០០០ រៀល (បួនលានរៀល)

ក្រុមហ៊ុន ដែលត្រូវបានទទួលស្គាល់ ត្រូវបង់សោហ៊ុយ ប្រចាំឆ្នាំចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ឱ្យបានមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

ក្រុមហ៊ុន ដែលត្រូវបានទទួលស្គាល់ក្នុងឆ្នាំ ត្រូវបង់សោហ៊ុយ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី២ ៖ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី៣ ៖ ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី៤ ៖ ត្រូវបង់មួយត្រីមាស

ជំពូកទី ៥
អន្តរប្បញ្ញត្តិ

ប្រការ ១៨.-

ក្រុមហ៊ុន ដែលបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជារួចហើយ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ជាថ្មីស្របតាមខ្លឹមសារនៃប្រកាសនេះ មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែគិតចាប់ពីថ្ងៃដែលប្រកាសនេះ ចូលជាធរមាន។

ជំពូកទី ៦
ទោសប្បញ្ញត្តិ

ប្រការ ១៩.-

ក្រុមហ៊ុន ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញតិនៃប្រកាសនេះ នឹងត្រូវរងវិធានការរដ្ឋបាល ដូចជាការព្រមានការណែនាំឱ្យកែតម្រូវកំហុស និងការដកហូតការទទួលស្គាល់ ជាដើម។

ប្រការ ២០.-

ធនាគារជាតិនៃកម្ពុជា អាចដកហូតការទទួលស្គាល់ក្រុមហ៊ុន ក្នុងករណីក្រុមហ៊ុន៖

១. ត្រូវបានដកហូតវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម វិញ្ញាបនបត្រចុះបញ្ជីជាសមាជិក វ.គ.ស.ក. និង/ឬ អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២. ប្រព្រឹត្តខុសធ្ងន់ធ្ងរពីគោលការណ៍គណនេយ្យ និង/ឬ សវនកម្ម ដូចមានចែងក្នុងច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ឬច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត និង/ឬ

៣. មិនបានអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងប្រកាសនេះ និងការតម្រូវផ្សេងទៀតពីធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនណាមួយដែលត្រូវបានដកហូតការទទួលស្គាល់ ត្រូវបញ្ចប់សកម្មភាពសវនកម្មរបស់ខ្លួនទាំងស្រុង គិតចាប់ពីថ្ងៃទទួលបានលិខិតដកហូតជាលាយលក្ខណ៍អក្សរ ពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជាអាចពិចារណាការដាក់ពាក្យស្នើសុំការទទួលស្គាល់ជាថ្មី បន្ទាប់ពីការទទួលស្គាល់ក្រុមហ៊ុនត្រូវបានដកហូត ក្នុងរយៈពេល ០៣ (បី) ឆ្នាំ។

ប្រការ ២១.-

ក្រុមហ៊ុន ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលពិន័យអន្តរការណ៍ជាទឹកប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ទៅ ២០.០០០.០០០ រៀល (ម្ភៃលានរៀល)។

ប្រការ ២២.-

សវនដ្ឋានណា ដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

ប្រការ ២៣.-

សារាចរណែនាំលេខ ធ៧-០១០-០០២ ស.រ.ណ ស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ និងរាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៤.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនសវនកម្មដែលត្រូវបានទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

Appendix

ពាក្យស្នើសុំ
ការទទួលស្គាល់ក្រុមហ៊ុនសវនកម្ម
ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

Application for Accreditation of
External Audit Firm for Banking and Financial Institutions

ផ្នែកទី ១: ព័ត៌មានក្រុមហ៊ុនសវនកម្ម

SECTION 1: Information of Audit Firm

១-ឈ្មោះបុគ្គលតំណាងក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំ:.....

1- Name of Authorized Person for the Applying Firm: .....

២-តួនាទីបុគ្គលតំណាងក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំ: .....

2- Position of the Authorized Person for the Applying Firm: .....

៣-ឈ្មោះក្រុមហ៊ុនសវនកម្ម:.....

3- Name of Audit Firm:.....

៤-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ:.....

4- Company Registration N°: .....

៥-វិញ្ញាបនបត្រចុះបញ្ជីជាសមាជិករបស់ វ.គ.ស.ក លេខ:.....

5- Certificate of Active Membership with KICPAA N°: .....

៦-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី ក.ជ.គ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ:.....

6- License for Audit Firm from the NAC of the MEF N°: .....

៧-អាសយដ្ឋានទីស្នាក់ការកណ្តាលក្រុមហ៊ុន:.....

7- Company Address: .....

៨-ទូរស័ព្ទ/ទូរសារ:.....អ៊ីម៉ែល:.....

8- Phone/Fax: .....E-mail:.....

ផ្នែកទី ២: ការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនសវនកម្ម

SECTION 2: Services of the Audit Firm

៩- ការផ្តល់សេវាសវនកម្មនិងសេវាផ្សេងទៀតលើវិស័យធនាគារក្នុងរយៈពេល ០៣ ឆ្នាំចុងក្រោយ:

9- Audit and other services conducted for banking sector for the last 3 years

កាលបរិច្ឆេទ Date	ប្រភេទនៃការផ្តល់សេវាកម្ម Type of Services	ឈ្មោះនិងប្រភេទស្ថាប័នទទួលសេវាកម្ម Name and type of audited institutions
……	……	……
……	……	……
……	……	……
……	……	……
……	……	……

ផ្នែកទី ៣: ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

SECTION 3: Enclosed Documents

- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម / Copy of Company Registration
- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីជាសមាជិកសកម្ម វ.គ.ស.ក / Copy of Certificate of Active Membership with KICPAA
- ☐ ច្បាប់ចម្លងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី ក.ជ.គ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ / Copy of License for Audit Firm from the NAC of the MEF
- ☐ ព័ត៌មានរបស់ក្រុមហ៊ុននិងផែនការអាជីវកម្ម / Company Profile and Business Plan
- ☐ បញ្ជីឈ្មោះដៃគូសវនកម្មដែលជាសមាជិកសកម្ម វ.គ.ស.ក / List of Audit Partners as Active Members with KICPAA
- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីជាសមាជិកសកម្ម វ.គ.ស.ក របស់ដៃគូសវនកម្ម និងនាយក / អ្នកគ្រប់គ្រង / Copy of certificate of active membership with KICPAA of Audit Partners and Directors / Managers
- ☐ ប្រវត្តិរូបរបស់ដៃគូសវនកម្ម និងនាយក/អ្នកគ្រប់គ្រង ដែលមានបញ្ជាក់អំពីគុណវុឌ្ឍិ និងបទពិសោធន៍ការងារ / Curriculum Vitae of Audit Partners and Directors / Managers specifying qualifications and work experiences

- ☐ លិខិតថ្កោលទោសរបស់ដៃគូសវនកម្ម និងនាយក / អ្នកគ្រប់គ្រង / Criminal record of Audit Partners and Directors / Managers
- ☐ នីតិវិធីសវនកម្ម / Audit Manual
- ☐ របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យសម្រាប់រយៈពេល ០៣ ឆ្នាំចុងក្រោយ / Audited Financial Statements for the last 3 years
- ☐ បញ្ជីការងារសវនកម្មនិងសេវាផ្សេងទៀត ដែលបានធ្វើក្នុងរយៈពេល ០៣ ឆ្នាំចុងក្រោយ / List of audit and other services that have been performed for the last 3 years
- ☐ របាយការណ៍នៃការប្រែប្រួលជាសារវន្តរយៈពេល ០៣ ឆ្នាំ ចុងក្រោយ ដែលបានឬអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុនសវនកម្ម / Statement of material changes during the last 3 years that have affected or may affect the operation and business result of the audit firm
- ☐ ឯកសារភ្ជាប់ផ្សេងៗ (ប្រសិនបើមាន) / Other documents (If applicable)

ផ្នែកទី ៤: សេចក្តីបញ្ជាក់

SECTION 4: Declarations

ក្នុងនាមក្រុមហ៊ុនសវនកម្ម ខ្ញុំបាទ/នាងខ្ញុំ សូមធ្វើការបញ្ជាក់ថា៖

On behalf of the Audit Firm, I would like to declare that:

- ក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីព័ត៌មានដែលបានផ្តល់ក្នុងពាក្យស្នើសុំនេះខុសពីការពិត។
- The Audit firm will take full responsibility under Cambodian Law in case there is any misleading information provided in this application.
- ក្រុមហ៊ុននឹងផ្តល់ព័ត៌មានជូនធនាគារជាតិនៃកម្ពុជា នូវរាល់ហេតុការណ៍ផ្លាស់ប្តូរណាមួយដែលកើតមានក្នុងអំឡុងពេលសិក្សាសំណុំលិខិត។
- The Audit firm will undertake to inform the NBC of any change material to this application which arises during the application being considered.

រាជធានីភ្នំពេញថ្ងៃទី_____/_____/_____

Phnom Penh, Date: ថ្ងៃ/dd ខែ/mm ឆ្នាំ/yyyy

ហត្ថលេខា និងត្រា

Signature and Seal

ធ៧-០២០-១៥៤៩ ឆ.ត

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

ជម្រាបមក
លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កម្មវត្ថុ ៖ សេចក្តីជូនដំណឹងអំពីបញ្ជីរាយនាមឯកសារ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវភ្ជាប់ឯកសារជូនជាមួយសំណើសុំផ្សេងៗ មកធនាគារជាតិនៃកម្ពុជា។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា ឱ្យបានជ្រាបថា ដើម្បីផ្តល់ភាពងាយស្រួល និងជាមូលដ្ឋានសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឯកសារឱ្យបានពេញលេញ និងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់សំណើសុំផ្សេងៗ មុននឹងដាក់ពាក្យស្នើសុំធនាគារជាតិនៃកម្ពុជា សូមផ្តល់ជូន លោក លោកស្រី អគ្គនាយក អគ្គនាយិកា នូវបញ្ជីរាយនាមឯកសារ ដូចមានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធ។ ធនាគារជាតិនៃកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី អគ្គនាយក អគ្គនាយិកា នឹងផ្សព្វផ្សាយនូវបញ្ជីរាយនាមឯកសារនេះ ឱ្យបានទូលំទូលាយដល់បុគ្គលិកពាក់ព័ន្ធទាំងអស់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

ត.ប.ទេសាភិបាល
អគ្គនាយកត្រួតពិនិត្យ
ហត្ថលេខានិងត្រា៖ **វ័ន្ត សុវណ្ណនរៈ**

តារាងឧបសម្ព័ន្ធនៃលិខិតលេខ ធ៧-០២០-១៥៤៩ ឆ.ត

បញ្ជីរាយនាមឯកសារ

សំណើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវភ្ជាប់ជាមួយនូវរាល់ឯកសារពាក់ព័ន្ធនឹងការស្នើសុំឱ្យបានពេញលេញនិងគ្រប់គ្រាន់តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

I. សំណើសុំបើកសាខាក្នុងប្រទេស និងក្រៅប្រទេស និងប្រតិបត្តិការប៉ុស្តិ៍សេវា

១. សំណើសុំការអនុញ្ញាតបើកសាខារាជធានី-ខេត្ត-ក្រុង-ស្រុក ត្រូវបែងចែកជាពីរដំណាក់កាល និងត្រូវផ្តល់ឯកសារដូចខាងក្រោម៖

ដំណាក់កាលទី១៖ លិខិតអនុញ្ញាតជាគោលការណ៍

- ពាក្យស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ផែនការអាជីវកម្មរយៈពេលបីឆ្នាំនៃសាខាថ្មី
- របាយការណ៍សិក្សាពីសក្តានុពលនៃសាខាថ្មី
- រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាខាថ្មី
- កិច្ចសន្យាជួលទីតាំង (ប្រសិនបើជួលទីតាំង)
- សក្ខីបត្រនៃការបង់សោហ៊ុយសិក្សាសំណុំលិខិតស្នើសុំបើកសាខា និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ដំណាក់កាលទី២៖ អាជ្ញាបណ្ណ

- ពាក្យស្នើសុំ
- រូបថតនៃទីតាំងសាខាថ្មី
- បញ្ជីឈ្មោះបុគ្គលិកសាខាថ្មី
- កិច្ចសន្យាជួលទីតាំង (ប្រសិនបើមិនទាន់ផ្តល់ ពេលសុំគោលការណ៍)
- លិខិតតែងតាំងនាយក/ប្រធានសាខាថ្មី និងត្រូវបំពេញឯកសារគាំទ្រដូចក្នុងចំណុចទី I.៤
- លិខិតគោលការណ៍ (ច្បាប់ចម្លង) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំការអនុញ្ញាតជាគោលការណ៍បើកសាខានៅក្រៅប្រទេសត្រូវផ្តល់ឯកសារដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)

- លិខិតតែងតាំងនិងឯកសារពាក់ព័ន្ធនឹងនាយកសាខា (ប្រវត្តិរូបតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក លិខិតថ្កោលទោសដែលមានសុពលភាព សញ្ញាបត្រជំនាញ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ ជាដើម)
- ផែនការស្តីពីការបង្កើតសាខា (របាយការណ៍សិក្សាពីទីផ្សារ ផែនការអាជីវកម្មសម្រាប់ ០៣ ឆ្នាំខាងមុខ ការសិក្សាពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ការសិក្សាពីហានិភ័យ និងការគ្រប់គ្រងហានិភ័យ) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៣. សំណើសុំធ្វើប្រតិបត្តិការប៉ុស្តិ៍សេវាត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- រចនាសម្ព័ន្ធប៉ុស្តិ៍សេវា
- លិខិតតែងតាំង និងឯកសារពាក់ព័ន្ធនឹងប្រធានប៉ុស្តិ៍សេវា
- ឯកសារថតចម្លងកិច្ចសន្យាជួលទីតាំងដែលមានការបញ្ជាក់ត្រឹមត្រូវនិងរូបថតទីតាំង និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៤. សំណើសុំតែងតាំងប្រធានសាខារាជធានី/ខេត្ត/ក្រុង/ស្រុក ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- លិខិតតែងតាំង ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) និង
- លិខិតថ្កោលទោសដែលនៅមានសុពលភាព(ច្បាប់ដើម)។

II. សំណើសុំបន្តសុពលភាព បញ្ចប់សុពលភាព ផ្លាស់ប្តូរអាជ្ញាបណ្ណ អាជ្ញាបណ្ណអ្នកដំណើរការតតិយភាគី និងវិញ្ញាបនបត្ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

១. សំណើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ

ក. ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវផ្តល់ឯកសារដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ផែនការអាជីវកម្មសម្រាប់ ០៣ ឆ្នាំខាងមុខ
- ឯកសារថតចម្លងកិច្ចសន្យាជួលទីតាំងនិងរូបថតទីតាំង
- សក្ខីបត្រនៃការបង់សោហ៊ុយសិក្សាសំណុំលិខិតនៃការបន្តសុពលភាពអាជ្ញាបណ្ណ
- អាជ្ញាបណ្ណចាស់ (យកមកផ្លាស់ប្តូរ)
- របាយការណ៍ចុះត្រួតពិនិត្យដល់ទីកន្លែង (ប្រសិនបើចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ខ. ចំពោះគ្រឹះស្ថានឥណទានជនបទត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ផែនការអាជីវកម្មសម្រាប់ ០៣ ឆ្នាំខាងមុខ
- តារាងបញ្ជីឥណទាន (Loan Listing)
- ឯកសារថតចម្លងកិច្ចសន្យាជួលទីតាំងនិងរូបថតទីតាំង
- សក្ខីបត្រនៃការបង់សោហ៊ុយសិក្សាសំណុំលិខិត
- វិញ្ញាបនបត្រចាស់ (យកមកផ្លាស់ប្តូរ)
- របាយការណ៍ចុះត្រួតពិនិត្យដល់ទីកន្លែង (ប្រសិនបើចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

គ. ចំពោះអ្នកដំណើរការតតិយភាគីត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សក្ខីបត្រនៃការបង់សោហ៊ុយសិក្សាសំណុំលិខិត
- របាយការណ៍សវនកម្មគ្រាចុងក្រោយរបស់អ្នកដំណើរការតតិយភាគី
- បញ្ជីទីតាំងដែលអ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការ
- កិច្ចសន្យារវាងធនាគារនិងអ្នកដំណើរការតតិយភាគី
- វិញ្ញាបនបត្រចាស់ (យកមកផ្លាស់ប្តូរ)
- ការកែប្រែព័ត៌មានសំខាន់ៗ និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំផ្លាស់ប្តូរអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ តាមរយៈការផ្លាស់ប្តូរទីតាំង ឬនាមករណ៍ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម ៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ភាគទុនិក ឬសេចក្តីសម្រេចរបស់ធនាគារមេ និង/ឬ សេចក្តីសម្រេចរបស់អគ្គនាយក (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារថតចម្លងកិច្ចសន្យាជួលទីតាំងដែលមានការបញ្ជាក់ត្រឹមត្រូវ និងរូបថតទីតាំង (សម្រាប់សំណើផ្លាស់ប្តូរទីតាំង)
- លិខិតបម្រុងទុកនាមករណ៍នៅក្រសួងពាណិជ្ជកម្មដែលនៅមានសុពលភាព (សម្រាប់សំណើប្តូរនាមករណ៍)
- អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រចាស់ (យកមកផ្លាស់ប្តូរ) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៣. សំណើសុំការបញ្ចប់សុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនិងភាគទុនិក ឬសេចក្តីសម្រេចរបស់ធនាគារមេ និង/ឬ សេចក្តីសម្រេចរបស់អគ្គនាយក (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រចាស់ (ប្រគល់ត្រឡប់មកវិញ) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

III. សំណើសុំផ្លាស់ប្តូររូបភាពគតិយុត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ម្ចាស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ឬធនាគារមេ (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- លិខិតអនុញ្ញាត ឬលិខិតមិនជំទាស់ពីអាជ្ញាធរត្រួតពិនិត្យប្រទេសដើម (សម្រាប់ធនាគារបុត្តសម្ព័ន្ធបរទេស និងសាខាធនាគារបរទេស) (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ផែនការអាជីវកម្ម ០៣ ឆ្នាំខាងមុខ
- លក្ខន្តិក:ថ្មីដែលចុះហត្ថលេខាដោយម្ចាស់ភាគទុនិក ឬតំណាងម្ចាស់ភាគទុនិក (លើកលែងសាខាធនាគារបរទេស)
- រចនាសម្ព័ន្ធគ្រប់គ្រងថ្មី និងឯកសារពាក់ព័ន្ធ (ដើម្បីឆ្លងកាត់ការវិភាគលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

IV. សំណើសុំពាក់ព័ន្ធដើមទុន

១. សំណើសុំបង្កើន ឬបន្តយដើមទុនត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិកនិងក្រុមប្រឹក្សាភិបាល ឬធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារបញ្ជាក់អំពីសមតុល្យទឹកប្រាក់ក្នុងធនាគារដើម្បីយកមកបង្កើនដើមទុន
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំផ្ទេរភាគហ៊ុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ក. សំណើសុំផ្ទេរភាគហ៊ុន ១០០% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើជាពីរដំណាក់កាលគឺ ១. ស្នើសុំការអនុញ្ញាតជាគោលការណ៍ និង ២. ស្នើសុំការអនុញ្ញាតជាផ្លូវការ (លើកលែងគ្រឹះស្ថានឥណទានជនបទ)

ក.១. សំណើសុំការអនុញ្ញាតជាគោលការណ៍ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- លិខិតចំណាប់អារម្មណ៍របស់វិនិយោគិនថ្មី
- ឯកសារពាក់ព័ន្ធនឹងវិនិយោគិនថ្មីជារូបវន្តបុគ្គល៖
  - ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
  - លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារពាក់ព័ន្ធនឹងវិនិយោគិនថ្មីជានីតិបុគ្គល (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)៖
  - លក្ខន្តិក:ក្រុមហ៊ុន
  - របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍សវនកម្មគ្រាចុងក្រោយ
  - ឯកសារចុះបញ្ជីអាជីវកម្ម
- ការធ្វើបទបង្ហាញ (ក្នុងករណីចាំបាច់)
- ឯកសារបញ្ជាក់អំពីសមតុល្យទឹកប្រាក់ក្នុងធនាគារដើម្បីយកមកបង្កើនដើមទុន និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ក.២. សំណើសុំការអនុញ្ញាតជាផ្លូវការត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ច្បាប់ចម្លងលិខិតយល់ព្រមជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជា
- ឯកសារបន្ថែមពាក់ព័ន្ធនឹងវិនិយោគិនថ្មីជារូបវន្តបុគ្គល៖
  - លិខិតថ្កោលទោសដែលមានសុពលភាព (ច្បាប់ដើម)
  - សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារបន្ថែមពាក់ព័ន្ធនឹងវិនិយោគិនថ្មីជានីតិបុគ្គល៖
  - លិខិតអនុញ្ញាត ឬលិខិតមិនជំទាស់ពីអាជ្ញាធរត្រួតពិនិត្យប្រទេសដើម (សម្រាប់ធនាគារបុត្តសម្ព័ន្ធបរទេស និងសាខាធនាគារបរទេស) (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
  - រចនាសម្ព័ន្ធរបស់គ្រុប
  - លិខិតតែងតាំង និងឯកសារពាក់ព័ន្ធនឹងអ្នកតំណាងភាគទុនិក (ប្រវត្តិរូបតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក លិខិតថ្កោលទោសដែលមានសុពលភាព សញ្ញាបត្រជំនាញ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ ជាដើម)
- កិច្ចសន្យាផ្សេរ ឬទិញ-លក់ភាគហ៊ុន (ដោយមានត្រារបស់សាការី ឬមេធាវី)
- ផែនការអាជីវកម្មសម្រាប់ ០៣ ឆ្នាំខាងមុខ និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ខ. សំណើសុំផ្ទេរភាគហ៊ុនមួយផ្នែក សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (លើកលែងគ្រឹះស្ថានឥណទានជនបទ) ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- លិខិតអនុញ្ញាត ឬលិខិតមិនជំទាស់ពីអាជ្ញាធរត្រួតពិនិត្យប្រទេសដើម (សម្រាប់ធនាគារបុត្តសម្ព័ន្ធបរទេស និងសាខាធនាគារបរទេស) (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារពាក់ព័ន្ធនឹងវិនិយោគិនថ្មីជារូបវន្តបុគ្គល៖
  - ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
  - លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)

- លិខិតថ្កោលទោសដែលមានសុពលភាព (ច្បាប់ដើម)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)

- ឯកសារពាក់ព័ន្ធនឹងវិនិយោគិនថ្មីជានីតិបុគ្គល៖
  - លក្ខន្តិក:ក្រុមហ៊ុន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
  - របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍សវនកម្មគ្រាចុងក្រោយ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
  - ឯកសារចុះបញ្ជីអាជីវកម្ម (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
  - លិខិតអនុញ្ញាត ឬលិខិតមិនជំទាស់ពីអាជ្ញាធរត្រួតពិនិត្យប្រទេសដើម (សម្រាប់ធនាគារបុត្តសម្ព័ន្ធបរទេស និងសាខាធនាគារបរទេស) (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
  - រចនាសម្ព័ន្ធរបស់គ្រុប
  - លិខិតតែងតាំង និងឯកសារពាក់ព័ន្ធនឹងអ្នកតំណាងភាគទុនិក (ប្រវត្តិរូបតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក លិខិតថ្កោលទោស សញ្ញាបត្រជំនាញ លិខិតឆ្លងដែនឬអត្តសញ្ញាណបណ្ណ ជាដើម)
- កិច្ចសន្យាផ្ទេរ ឬទិញ-លក់ភាគហ៊ុន (ដោយមានត្រារបស់សាការីឬមេធាវី)
- ឯកសារបញ្ជាក់អំពីសមតុល្យទឹកប្រាក់ក្នុងធនាគារដើម្បីយកមកបង្កើនដើមទុន និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

គ. សំណើសុំផ្ទេរភាគហ៊ុនរបស់គ្រឹះស្ថានឥណទានជនបទត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬក្រុមប្រឹក្សាភិបាល (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ឯកសារពាក់ព័ន្ធនឹងម្ចាស់ភាគទុនិកថ្មី ឬអ្នកតំណាង (ប្រវត្តិរូបតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក លិខិតថ្កោលទោស សញ្ញាបត្រជំនាញ លិខិតឆ្លងដែនឬអត្តសញ្ញាណបណ្ណ លក្ខន្តិក:ក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុគ្រាចុងក្រោយ ជាដើម)
- កិច្ចសន្យាផ្ទេរ ឬទិញ-លក់ភាគហ៊ុន (ដោយមានត្រារបស់សាការី ឬមេធាវី)
- ឯកសារបញ្ជាក់អំពីសមតុល្យទឹកប្រាក់ក្នុងធនាគារដើម្បីយកមកបង្កើនដើមទុន និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

***ចំណាំ ៖** នៅពេលទទួលបានការអនុម័តយល់ព្រមលើការស្នើសុំផ្ទេរភាគហ៊ុនពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ បន្ទាប់មកត្រូវប្រគល់ឯកសារអំពីកាតព្វកិច្ចពន្ធដារជូនរដ្ឋនោះមកធនាគារជាតិនៃកម្ពុជា។

៣. សំណើសុំចូលភាគកម្មត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេរបស់ភាគីទាំងពីរ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- កិច្ចសន្យា ឬលក្ខន្តិក:ចូលភាគកម្ម (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព
- ផែនការអាជីវកម្មរបស់ក្រុមហ៊ុនដែលនឹងត្រូវចូលរួមភាគកម្ម
- ឯកសារពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ភាគទុនិក ដែលត្រូវចូលភាគកម្មជាមួយ រួមមាន លក្ខន្តិក: អាជ្ញាបណ្ណ លិខិតអនុញ្ញាតអាជីវកម្ម និងរបាយការណ៍សវនកម្មគ្រាចុងក្រោយ ប្រសិនបើមាន (ចំពោះភាគទុនិកជានីតិបុគ្គល) និងប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក លិខិតថ្កោលទោស (នៅមានសុពលភាព) សញ្ញាបត្រជំនាញ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ (ចំពោះភាគទុនិកជារូបវន្តបុគ្គល)
- លិខិតអនុញ្ញាត ឬលិខិតមិនជំទាស់ពីអាជ្ញាធរត្រួតពិនិត្យប្រទេសដើម (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៤. សំណើសុំបញ្ចូល និងទូទាត់បំណុលបន្ទាប់បន្សំនៅក្នុងដើមទុនថ្នាក់ទី២

ក. សំណើសុំបញ្ចូលបំណុលបន្ទាប់បន្សំត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ សេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព
- កិច្ចសន្យាបំណុលបន្ទាប់បន្សំដែលត្រូវមានបញ្ជាក់ច្បាស់ពីលំដាប់នៃម្ចាស់បំណុលដែលនៅខ្ពស់បន្ទាប់ពីភាគទុនិកធម្មតា កាលវិសាន និងលក្ខខណ្ឌផ្សេងទៀត និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ខ. សំណើសុំទូទាត់បំណុលបន្ទាប់បន្សំត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៥. សំណើសុំផ្ទេរប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុងដែលមិនត្រូវបែងចែក ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៦. សំណើសុំបែងចែកភាគលាភ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចភាគទុនិកនិងក្រុមប្រឹក្សាភិបាល ឬធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការធ្វើតេស្តសាកល្បង (Simulation) ពីផលប៉ះពាល់ដល់ប្រកាសនានារបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងអនុបាតសាធនភាព និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

V. សំណើសុំតែងតាំង និង/ឬ ផ្លាស់ប្តូរ សមាសភាពក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ មន្ត្រីប្រតិបត្តិតាម និងសវនករផ្ទៃក្នុង របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

១. អ្នកតំណាងភាគទុនិកត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬក្រុមប្រឹក្សាភិបាល ស្តីពីការតែងតាំង (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)

- ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) និង
- លិខិតថ្កោលទោសដែលនៅមានសុពលភាព(ច្បាប់ដើម) ។

២. ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ស្តីពីការតែងតាំង (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលធនាគារមេ សម្រាប់ករណីបុគ្គលសម្ព័ន្ធធនាគារបរទេស (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) និង
- លិខិតថ្កោលទោសដែលនៅមានសុពលភាព (ច្បាប់ដើម) ។

៣. នាយកប្រតិបត្តិ និងនាយករងប្រតិបត្តិត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ម្ចាស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាល ស្តីពីការតែងតាំង (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- លិខិតថ្កោលទោសដែលនៅមានសុពលភាព (ច្បាប់ដើម) និង
- ការសម្ភាសន៍ (ប្រសិនបើចាំបាច់)។

៤. ប្រធានមុខងារប្រតិបត្តិតាម និងប្រធានសវនកម្មផ្ទៃក្នុងត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង/ឬ លិខិតតែងតាំង
- ប្រវត្តិរូប (តាមគំរូរបស់ធនាគារជាតិនៃកម្ពុជា) ភ្ជាប់រូបថតបច្ចុប្បន្នភាពទំហំ ៤×៦ ចំនួន ១ សន្លឹក

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សញ្ញាបត្រជំនាញ (ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- លិខិតថ្កោលទោសដែលនៅមានសុពលភាព(ច្បាប់ដើម) និង
- ការសម្ភាសន៍ (ប្រសិនបើចាំបាច់)។

VI. សំណើសុំសហការជាមួយក្រុមហ៊ុនផ្តល់សេវាទូទាត់សងប្រាក់ ប្រតិបត្តិការធនាគារចល័ត សេវាធនាគារតាមរយៈអ៊ិនធើណែត និង E-Wallet

១. សំណើសុំសហការជាមួយក្រុមហ៊ុនផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់ឯកសារដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការពាក់ព័ន្ធ និង/ឬ បុគ្គលដែលមានសិទ្ធិ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- កិច្ចសន្យារវាងគ្រឹះស្ថានិងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់
- នីតិវិធីក្នុងការការពារហានិភ័យ និងកិច្ចការពារអតិថិជន
- ការធ្វើបទបង្ហាញអំពីប្រតិបត្តិការនេះ (ក្នុងករណីចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំធ្វើប្រតិបត្តិការធនាគារចល័ត សេវាធនាគារតាមរយៈអ៊ិនធើណែត ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការពាក់ព័ន្ធ និង/ឬ បុគ្គលដែលមានសិទ្ធិ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- នីតិវិធីនៃការការពារអតិថិជន
- គោលការណ៍និងនីតិវិធីស្តីពីការគ្រប់គ្រង និងការអនុវត្តប្រតិបត្តិការនេះ
- ផែនការអាជីវកម្មដែលពាក់ព័ន្ធនឹងប្រតិបត្តិការនេះ
- នីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- គោលនយោបាយគ្រប់គ្រងហានិភ័យ/ស្តង់ដារសុវត្ថិភាពប្រព័ន្ធ
- ការសិក្សាលើហានិភ័យប្រតិបត្តិការ និងព័ត៌មានវិទ្យា
- ការធ្វើបទបង្ហាញអំពីប្រតិបត្តិការនេះ (ក្នុងករណីចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៣. សំណើសុំធ្វើប្រតិបត្តិការធនាគារ E-Wallet ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការពាក់ព័ន្ធ និង/ឬ បុគ្គល ដែលមានសិទ្ធិ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- នីតិវិធីនៃការការពារអតិថិជន
- គោលការណ៍ និងនីតិវិធីស្តីពីការគ្រប់គ្រង និងការអនុវត្តប្រតិបត្តិការនេះ
- ផែនការអាជីវកម្ម E-Wallet
- នីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- គោលនយោបាយគ្រប់គ្រងហានិភ័យ/ស្តង់ដារសុវត្ថិភាពប្រព័ន្ធ
- ការសិក្សាលើហានិភ័យប្រតិបត្តិការ និងព័ត៌មានវិទ្យា
- ការធ្វើបទបង្ហាញអំពីប្រតិបត្តិការនេះ (ក្នុងករណីចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

VII. សំណើសុំបោះផ្សាយមូលបត្រ និងប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្រ

១. សំណើសុំបោះផ្សាយមូលបត្រ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- កិច្ចព្រមព្រៀងរវាងគ្រឹះស្ថាន និងក្រុមហ៊ុនមូលបត្រ
- នីតិវិធីពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រ
- នីតិវិធីពាក់ព័ន្ធនឹងការកំណត់អត្រា Coupon
- ការធ្វើបទបង្ហាញស្តីពីការបោះផ្សាយមូលបត្រ
- លិខិតបញ្ជាក់ពីសុពលភាពរបស់ក្រុមហ៊ុនមូលបត្រដែលចេញដោយអាជ្ញាធរសាមី និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent, Security Registrar, Underwriter...) ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការពាក់ព័ន្ធ និង/ឬ បុគ្គលដែលមានសិទ្ធិ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- វិភាគស្ថានភាពរបស់គ្រឹះស្ថានដែលប្រឈម

- នីតិវិធីក្នុងការការពារហានិភ័យ និងកិច្ចការពារអតិថិជន និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

VIII. សំណើសុំផ្សេងៗ

១, សំណើសុំទូទាត់រូបិយប័ណ្ណបរទេសត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- ឯកសារស្តីពីយន្តការ និងនីតិវិធីទូទាត់រូបិយប័ណ្ណបរទេសដែលដាក់ស្នើ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- យុទ្ធសាស្ត្រនិងគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារទាក់ទងនឹងប្រតិបត្តិការស្នើសុំ
- ការធ្វើបទបង្ហាញពីការធ្វើប្រតិបត្តិការនេះ និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

២. សំណើសុំធ្វើជាភ្នាក់ងារណែនាំសេវាធានារ៉ាប់រង ឬភ្នាក់ងារណែនាំសេវាធានារ៉ាប់រងខ្នាតតូចត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង/ឬ គណៈកម្មការពាក់ព័ន្ធ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- កិច្ចសន្យារវាងគ្រឹះស្ថាននិងក្រុមហ៊ុនធានារ៉ាប់រង
- នីតិវិធីនៃការដោះស្រាយបណ្តឹងអតិថិជន
- គោលការណ៍និងនីតិវិធីស្តីពីការគ្រប់គ្រង និងការអនុវត្តប្រតិបត្តិការនេះ
- ព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ក្រុមហ៊ុនធានារ៉ាប់រង ដូចជា លក្ខន្តិក: អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងពីក្រសួងសាមី ជាដើម
- នីតិវិធីគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងប្រតិបត្តិការនេះ និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៣. សំណើសុំដកប្រាក់ពីគណនីចរន្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជាមុនពេលទទួលបានការអនុញ្ញាតឱ្យបង្កើនដើមទុនជាផ្លូវការត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- ឯកសារបញ្ជាក់អំពីសមតុល្យទឹកប្រាក់ក្នុងគណនីចរន្ត និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៤. សំណើសុំកែប្រែលក្ខន្តិក:ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក ឬអ្នកតំណាងភាគទុនិក (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) ឬ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលធនាគារមេ សម្រាប់ករណីបុត្តសម្ព័ន្ធធនាគារបរទេស (ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ) និង
- ទំព័រដែលត្រូវកែប្រែ ឬលក្ខន្តិក:ថ្មី។

៥. សំណើសុំជ្រើសរើសក្រុមហ៊ុនសវនកម្មត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង/ឬ ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ សេចក្តីសម្រេចរបស់ធនាគារមេ និង/ឬ គណៈកម្មការសវនកម្ម និង/ឬ បុគ្គលមានសិទ្ធិសម្រេចចំពោះសាខាធនាគារបរទេស (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សេចក្តីព្រាង ឬកិច្ចសន្យារវាងគ្រឹះស្ថាននិងក្រុមហ៊ុនសវនកម្ម និង
- ឈ្មោះដៃគូសវនកម្មថ្មី បញ្ជីឈ្មោះក្រុមការងារសវនកម្ម ព្រមទាំងលេខទូរស័ព្ទ ទំនាក់ទំនង និងអ៊ីម៉ែល។

៦. សំណើសុំបន្តជ្រើសរើសក្រុមហ៊ុនសវនកម្មដដែលក្រោយរយៈពេល ០៣ ឆ្នាំ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ភាគទុនិក និង ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន និង/ឬ សេចក្តីសម្រេចរបស់ធនាគារមេ និង/ឬគណៈកម្មការសវនកម្ម និង/ឬ បុគ្គលមានសិទ្ធិសម្រេចចំពោះសាខាធនាគារបរទេស (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- សេចក្តីព្រាង ឬកិច្ចសន្យារវាងគ្រឹះស្ថាននិងក្រុមហ៊ុនសវនកម្ម និង
- ឈ្មោះដៃគូសវនកម្មថ្មី បញ្ជីឈ្មោះក្រុមការងារសវនកម្ម ព្រមទាំងលេខទូរស័ព្ទ ទំនាក់ទំនង និងអ៊ីម៉ែល។

៧. សំណើសុំធ្វើប្រតិបត្តិការកតិសន្យាហិរញ្ញវត្ថុ ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង/ឬ គណៈកម្មការពាក់ព័ន្ធ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ផែនការអាជីវកម្មរយៈពេល ០៣ឆ្នាំខាងមុខ

- គោលនយោបាយ និងនីតិវិធីសម្រាប់ប្រតិបត្តិការនេះ
- ការធ្វើបទបង្ហាញអំពីប្រតិបត្តិការនេះ (ក្នុងករណីចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៨. សំណើសុំចែករំលែកទិន្នន័យអតិថិជន និងអនុវត្តទម្រង់របាយការណ៍រួមជាមួយធនាគារមេ (អនុវត្តចំពោះធនាគារបុត្តសម្ព័ន្ធបរទេស និងសាខាធនាគារបរទេសតែប៉ុណ្ណោះ) ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចរបស់ធនាគារមេ (ច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ)
- ការវិភាគហានិភ័យក្នុងការអនុវត្តទម្រង់របាយការណ៍រួម ដោយមានការចូលរួមពីគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធ
- សៀវភៅណែនាំការប្រើប្រាស់ទម្រង់
- កិច្ចព្រមព្រៀងរវាងគ្រឹះស្ថាន និងធនាគារមេ ពាក់ព័ន្ធនឹងការរក្សាការសម្ងាត់របស់អតិថិជន
- ការអនុមតិ ឬការទទួលស្គាល់ពីអាជ្ញាធរត្រួតពិនិត្យធនាគារមេ
- ឈ្មោះ តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកធនាគារមេនិងគ្រឹះស្ថាន ដែលមានសិទ្ធិចូលមើលទិន្នន័យ និង/ឬ គ្រប់គ្រងទិន្នន័យ ដោយមានហត្ថលេខាទទួលខុសត្រូវ
- ឯកសារបញ្ជាក់ពីការធ្វើតេស្តសាកល្បងក្នុងការអនុវត្ត
- ការបញ្ជាក់ពីដំណើរការផ្ទៀទិន្នន័យ និងដំណើរការទាញយករបាយការណ៍
- ការធ្វើបទបង្ហាញ (ក្នុងករណីចាំបាច់) និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

៩. សំណើសុំផ្ទេរប្រាក់ដែលបានបង់ខុសគណនីឬបង់លើស ចេញពីគណនីនៅធនាគារជាតិនៃកម្ពុជាត្រូវផ្តល់ឯកសារ ដូចខាងក្រោម ៖

- លិខិតស្នើសុំ និង
- ច្បាប់ចម្លងប្រកាសឥណទានដែលបង្ហាញពីការបង់ប្រាក់នៅនាយកដ្ឋានប្រតិបត្តិការនៃធនាគារជាតិនៃកម្ពុជា។

១០. សំណើសុំឈប់សម្រាករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្រៅពីការអនុញ្ញាតឈប់សម្រាករបស់ក្រសួងការងារ) ត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- លិខិតស្នើសុំ និង
- ឯកសារផ្សេងៗពាក់ព័ន្ធនឹងសំណើសុំ។

ធ៧-០២១-១០៥ ប្រ.ក

ប្រកាស
ស្តីពី
លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការធ្វើអាជីវកម្មបើងកាសួរេន

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ក្របខ័ណ្ឌបទប្បញ្ញត្តិ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកបអាជីវកម្មបើងកាសួរេន (Bancassurance) ក្នុងគោលដៅចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការបង្កើនលទ្ធភាពឱ្យសាធារណជនទទួលបានសេវាធានារ៉ាប់រង និងពង្រឹងកិច្ចការពារអតិថិជន។

ប្រការ ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ៣.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **បើងកាសួរេន** សំដៅដល់កិច្ចសហការរវាងគ្រឹះស្ថាន និងក្រុមហ៊ុនធានារ៉ាប់រងក្នុងការចែកចាយ និងផ្សព្វផ្សាយផលិតផលធានារ៉ាប់រងតាមរយៈការប្រើប្រាស់បណ្តាញរបស់គ្រឹះស្ថាន។
- **អាជីវកម្មបើងកាសួរេន** សំដៅដល់ការផ្តល់ផលិតផលធានារ៉ាប់រងដោយគ្រឹះស្ថានក្នុងនាមក្រុមហ៊ុនធានារ៉ាប់រង ប៉ុន្តែមិនចូលរួមបង្កើតផលិតផលធានារ៉ាប់រងទេ។ គ្រឹះស្ថានអាចជ្រើសរើសយកម៉ូឌែលណែនាំអតិថិជន (Referral) ឬម៉ូឌែលភ្នាក់ងារ (Corporate agent) ដែលគ្រឹះស្ថានទទួលបានប្រាក់កម្រៃជើងសា ប៉ុន្តែមិនទទួលហានិភ័យពីផលិតផលធានារ៉ាប់រងទេ។
- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ដែលទទួលអាជ្ញាបណ្ណពីអាជ្ញាធរមានសមត្ថកិច្ច។

- **កិច្ចព្រមព្រៀងបើងកាសូរេន** សំដៅដល់កិច្ចសន្យារវាងគ្រឹះស្ថាន និងក្រុមហ៊ុនធានារ៉ាប់រង។
- **ម៉ូឌែលណែនាំអតិថិជន** សំដៅដល់ការណែនាំដល់អតិថិជនដោយគ្រឹះស្ថានទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងជាដៃគូ ប៉ុន្តែគ្រឹះស្ថានមិនពាក់ព័ន្ធនឹងការលក់ផលិតផលធានារ៉ាប់រងដោយផ្ទាល់ទេ។
- **ម៉ូឌែលភ្នាក់ងារ** សំដៅដល់ការប្រើប្រាស់បុគ្គលិករបស់គ្រឹះស្ថានដើម្បីផ្សព្វផ្សាយ និងលក់ផលិតផលធានារ៉ាប់រងដោយផ្ទាល់ដល់អតិថិជន។

ជំពូកទី ២
លក្ខណៈទិនិច្ឆ័យ

ប្រការ ៤.-

គ្រឹះស្ថានដែលមានបំណងធ្វើអាជីវកម្មបើងកាសូរេន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក. ស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា

ខ. ត្រូវបានវាយតម្លៃដោយធនាគារជាតិនៃកម្ពុជាថាមានស្ថានភាពហិរញ្ញវត្ថុល្អ និងអភិបាលកិច្ចរឹងមាំក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំចុងក្រោយ និង

គ. អនុវត្តពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

ដើម្បីទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំដោយភ្ជាប់មកជាមួយឯកសារ ដូចខាងក្រោម៖

ក. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការប្រកបអាជីវកម្មបើងកាសូរេន ដោយបញ្ជាក់ពីការជ្រើសរើសយកម៉ូឌែលណែនាំអតិថិជន ឬម៉ូឌែលភ្នាក់ងារ

ខ. ការសិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) និងការវាយតម្លៃហានិភ័យលើអាជីវកម្មបើងកាសូរេន រួមទាំងវិធីកាត់បន្ថយហានិភ័យ និងការប្រកបអាជីវកម្មដោយប្រុងប្រយ័ត្ន

គ. ផែនការអាជីវកម្មបើងកាសូរេន

ឃ. កិច្ចព្រមព្រៀងបើងកាសូរេន រវាងគ្រឹះស្ថាន និងក្រុមហ៊ុនធានារ៉ាប់រង

ង. គោលនយោបាយនិងនីតិវិធីគ្រប់គ្រងអាជីវកម្មបើងកាសូរេន រួមទាំងនីតិវិធីដោះស្រាយបណ្តឹងអតិថិជន និងគោលការណ៍ណែនាំប្រតិបត្តិការ

ច. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្ម របាយការណ៍ស្ថានភាពសាធនភាព និងរបាយការណ៍សន្ទនីយភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង និង

ឆ. ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

គ្រឹះស្ថានអាចចុះកិច្ចព្រមព្រៀងបើងកាសូរេន ជាមួយក្រុមហ៊ុនធានារ៉ាប់រងយ៉ាងច្រើនចំនួន ៣ (បី)។ កិច្ចព្រមព្រៀងត្រូវមានចែងជាអប្បបរមា ដូចខាងក្រោម៖

ក. កាតព្វកិច្ចរបស់គ្រឹះស្ថាននិងក្រុមហ៊ុនធានារ៉ាប់រង ជាពិសេសកាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការបណ្តុះបណ្តាលបុគ្គលិកគ្រឹះស្ថាន

ខ. ការផ្តល់ព័ត៌មានអតិថិជន និងការចាត់ចែងប្រមូលនិងទូទាត់បុព្វលាភធានារ៉ាប់រង

គ. កម្រៃជើងសារបស់គ្រឹះស្ថាន រួមទាំងអត្រានិងរបៀបគណនាកម្រៃជើងសា

ឃ. ដំណើរការទាមទារសំណង និងកិច្ចការពារអតិថិជន និង

ង. ការបញ្ជាក់ពីភាពមិនពាក់ព័ន្ធគ្នារវាងសេវាធនាគារនិងផលិតផលធានារ៉ាប់រង ដើម្បីចៀសវាងផលប៉ះពាល់មកលើអាជីវកម្មធនាគារ ដែលបណ្តាលមកពីហានិភ័យរបស់ក្រុមហ៊ុនធានារ៉ាប់រង។

ប្រការ ៧.-

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចផ្តល់ ឬមិនផ្តល់ការអនុញ្ញាតជូនគ្រឹះស្ថាន ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។ ការអនុញ្ញាតរបស់ធនាគារជាតិនៃកម្ពុជា មានសុពលភាព ៣ (បី) ឆ្នាំ និងអាចស្នើសុំបន្តជាថ្មីទៀតបាន។ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពការអនុញ្ញាត ក្នុងរយៈពេល ៣ (បី) ខែ មុនការអនុញ្ញាតផុតសុពលភាព។

ប្រការ ៨.-

គ្រឹះស្ថាន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មបើងកាសូរេនតាមម៉ូឌែលភ្នាក់ងារ ត្រូវបង់សោហ៊ុយប្រចាំឆ្នាំ មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំដូចខាងក្រោម៖

- សម្រាប់ទីស្នាក់ការកណ្តាល ៖ ៥.០០០.០០០ រៀល (ប្អូនលានរៀល)
- សម្រាប់មួយសាខា ៖ ២.០០០.០០០ រៀល (ពីរលានរៀល)

គ្រឹះស្ថានដែលទទួលបានការអនុញ្ញាតក្នុងឆ្នាំ ត្រូវបង់សោហ៊ុយ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី២ ៖ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី៣ ៖ ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី៤ ៖ ត្រូវបង់មួយត្រីមាស។

ជំពូកទី ៣
ភាតព្វកិច្ចផ្នែកប្រតិបត្តិការ និងកិច្ចការពារអតិថិជន

ប្រការ ៩.-

គ្រឹះស្ថានត្រូវមានគោលការណ៍ណែនាំប្រតិបត្តិការដើម្បីប្រកបអាជីវកម្មបើងកាសូរេន និងត្រូវធានាថា៖

ក. បុគ្គលិកទទួលបានការបណ្តុះបណ្តាល និងមានសមត្ថភាពក្នុងការពន្យល់ឱ្យបានច្បាស់លាស់អំពីផលិតផលធានារ៉ាប់រងដល់អតិថិជន

ខ. មិនត្រូវបង្ខិតបង្ខំឬបញ្ចុះបញ្ចូលអតិថិជនឱ្យទិញផលិតផលធានារ៉ាប់រងឡើយ

គ. បុព្វលាភមិនត្រូវបានដកចេញដោយផ្ទាល់ពីគណនីធនាគាររបស់អតិថិជន ដោយគ្មានការអនុញ្ញាត ឬយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជនឡើយ

ឃ. គ្រឹះស្ថានត្រូវផ្សព្វផ្សាយជូនអតិថិជនឱ្យយល់ច្បាស់ថា គ្រឹះស្ថានមិនមែនជាក្រុមហ៊ុនធានារ៉ាប់រង និងមិនទទួលខុសត្រូវលើហានិភ័យផលិតផលធានារ៉ាប់រងឡើយ។ ផលិតផលធានារ៉ាប់រងនិងការទូទាត់សំណង គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនធានារ៉ាប់រង និង

ង. យន្តការកិច្ចការពារអតិថិជន និងដោះស្រាយបណ្តឹងសមស្របពាក់ព័ន្ធនឹងធានារ៉ាប់រងដាច់ដោយឡែក ត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព។

ក្នុងករណីគ្រឹះស្ថានជ្រើសរើសយកម៉ូឌែលភ្នាក់ងារ គ្រឹះស្ថានត្រូវ៖

ក. តែងតាំងបុគ្គលិកបង្គោលដែលមានគុណវុឌ្ឍិ ១ (មួយ) រូប និងមានបុគ្គលិកគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវប្រតិបត្តិការនិងដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងបើងកាសូរេន

ខ. មានផ្នែកទទួលបន្ទុក និងប្រព័ន្ធដាច់ដោយឡែកដែលត្រូវមានរបាំងព័ត៌មាន (Chinese wall) សមស្រប រវាងអាជីវកម្មបើងកាសូរេន និងគ្រឹះស្ថាន និង

គ. បង្ហាញជូនអតិថិជនពីបុព្វលាភរបស់ផលិតផលធានារ៉ាប់រង ដែលកំណត់ដោយក្រុមហ៊ុនធានារ៉ាប់រង។

ប្រការ ១០.-

សម្រាប់គោលបំណងនៃកិច្ចការពារអតិថិជន គ្រឹះស្ថានត្រូវធានាថា៖

ក. មានការគោរពសិទ្ធិរបស់អតិថិជន ក្នុងការជ្រើសរើសភ្នាក់ងារបើងកាសូរេនផ្សេងទៀតឬទាក់ទងទៅក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់

ខ. មិនមានការផ្តល់ព័ត៌មានខុស ឬការពន្យល់មិនត្រឹមត្រូវដល់អតិថិជន ដោយបុគ្គលិកលក់ផលិតផលធានារ៉ាប់រងអំពីអត្ថប្រយោជន៍នៃផលិតផលនេះឡើយ

គ. រាល់ទិន្នន័យនិងព័ត៌មានរបស់អតិថិជនត្រូវបានរក្សាជាការសម្ងាត់

ឃ. មិនត្រូវយកសោហ៊ុយ និង/ឬ ដាក់លក្ខខណ្ឌបន្ថែមក្រៅពីលក្ខខណ្ឌដែលកំណត់ដោយក្រុមហ៊ុនធានារ៉ាប់រង និង

ង. គ្រឹះស្ថាន និងក្រុមហ៊ុនធានារ៉ាប់រង មិនត្រូវប្រើប្រាស់នាមករណ៍ យីហោ ពាណិជ្ជសញ្ញា ការផ្សាយដំណឹងពាណិជ្ជកម្ម ឬពាក្យពេចន៍ដទៃទៀត ដែលនាំឱ្យមានការយល់ច្រឡំថា គ្រឹះស្ថាននិងក្រុមហ៊ុនធានារ៉ាប់រងគឺជាក្រុមហ៊ុនតែមួយ។

ប្រការ ១១.-

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍ប្រចាំត្រីមាសយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ (ដប់ប្រាំ) នៃខែទី១ (មួយ) នៃត្រីមាសបន្ទាប់ មកធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

- របាយការណ៍សកម្មភាពបើងកាសូរេន (ចំនួនប្រតិបត្តិការ ចំនួនប្រាក់បុព្វលាភ កម្រៃជើងសា ជាដើម) និង
- របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សាធនភាព និងរបាយការណ៍សន្ទនីយភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង។

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រង យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ (ដប់) ខែមេសា មកធនាគារជាតិនៃកម្ពុជា។

ប្រការ ១២.-

គ្រឹះស្ថានត្រូវរក្សាទុកកំណត់ត្រា និងទិន្នន័យឱ្យបានគ្រប់គ្រាន់អំពីអាជីវកម្មបើងកាសូរេន ដែលអាចផ្តល់មកធនាគារជាតិនៃកម្ពុជាតាមការស្នើសុំ។

គ្រឹះស្ថានត្រូវជូនដំណឹងជាបន្ទាន់មកធនាគារជាតិនៃកម្ពុជាបន្ទាប់ពីមានការកែប្រែ ការបន្ត ឬការបញ្ចប់កិច្ចព្រមព្រៀងបើងកាសូរេន។

គ្រឹះស្ថានត្រូវជូនដំណឹងជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា នូវបញ្ហាពាក់ព័ន្ធនឹងអាជីវកម្មបើងកាសូរេន ដែលអាចបង្កឱ្យមានប៉ះពាល់ទៅលើគ្រឹះស្ថានជាយថាហេតុ។

ជំពូកទី ៤
ការពិន័យ

ប្រការ ១៣.-

គ្រឹះស្ថានដែលមិនគោរពតាមប្រកាសនេះ ត្រូវទទួលទណ្ឌកម្មយោងតាមមាត្រា ៥២ និង ៥៥ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ១៤.-

បន្ថែមលើទណ្ឌកម្មខាងលើ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ ដូចខាងក្រោម៖

ក. គ្រឹះស្ថានដែលមិនគោរពតាមបញ្ញត្តិដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ

ខ. គ្រឹះស្ថានដែលល្មើសនឹងបញ្ញត្តិជាធរមាននៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាកំណត់ឱ្យកែតម្រូវ។

ជំពូកទី ៥
អនុសាសនប្បញ្ញត្តិ

ប្រការ ១៥.-

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៦.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ច. ហ្វាស៊ីលីធីរបស់
ធនាគារជាតិនៃកម្ពុជា

ធ៥-០៩-២២៩ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សារបិយវត្ថុ

ប្រការ ១.-

ដាក់ឱ្យប្រើប្រាស់កិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីផ្តល់ដល់អ្នកចូលរួមក្នុងទីផ្សារនូវក្របខ័ណ្ឌកិច្ចសន្យាដែលមានការធានា ក្នុងគោលបំណងជំរុញប្រតិបត្តិការកម្ចីអន្តរធនាគារដោយមានវត្ថុបញ្ចាំដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។ នៅក្នុងន័យនៃប្រកាសនេះ ពាក្យថាទទួលទិញវិញ (Repos) សំដៅដល់ពាក្យប៉ង់ស្យុង ដូចមានចែងនៅក្នុងមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

នៅពេលដែលចុះហត្ថលេខាលើកិច្ចសន្យាមេ ភាគីទាំងពីរព្រមព្រៀងថា ប្រតិបត្តិការទទួលទិញវិញទាំងអស់ដែលត្រូវបានធ្វើរវាងភាគីទាំងពីរ ត្រូវតែអនុលោមតាមគោលការណ៍ដែលមានចែងក្នុងកិច្ចសន្យាមេនេះលើកលែងតែភាគីទាំងពីរបានព្រមព្រៀងជាក់លាក់ផ្សេងពីនេះ។ លើសពីនេះ ប្រតិបត្តិការទទួលទិញវិញនីមួយៗដែល ធ្វើរវាងភាគីទាំងពីរ ត្រូវតែបានបញ្ជាក់ដោយមធ្យោបាយសមស្រប និងជាលាយលក្ខណ៍អក្សរ។

តាមកាល:ទេស:តម្រូវ កិច្ចសន្យាមេបង្កើនភាពទន់ភ្លន់ក្នុងការគ្រប់គ្រងហានិភ័យនៃសមតុល្យឥណទានតាមរយៈការគណនាចំនួនសុទ្ធនៃឥណទានដែលនៅសល់ដោយរួមបញ្ចូលនូវរាល់ស្ថានភាពហានិភ័យនៃប្រតិបត្តិការទទួលទិញវិញទាំងអស់ ដែលស្ថិតក្រោមវិធាននៃកិច្ចសន្យាមេ។

ប្រការ ២.-

ក្រោមកាល:ទេស:ធម្មតា កិច្ចសន្យាមេនៃប្រតិបត្តិការទទួលទិញវិញ ត្រូវចាត់ទុកជាសំខាន់ថាជាមធ្យោបាយដើម្បីគ្រប់គ្រងហានិភ័យគូភាគី ដោយប្រមើលទុកជាមុននូវកម្រិតកំណត់ដែលបើសិនជាថ្លៃទីផ្សារឡើង ឬចុះដល់ ឬហួសកម្រិតកំណត់នោះ នឹងអាចនាំឱ្យភាគីដែលទទួលរងហានិភ័យទាមទារវត្ថុបញ្ចាំបន្ថែម ឬមួយក្នុងទម្រង់ជា Margin Calls ជាមូលបត្រ ឬ Margin Calls ជាសាច់ប្រាក់។ នៅពេលសមស្របនិងនៅពេលដែលភាគីទាំងពីរព្រមព្រៀងគ្នាលើបែបបទខាងលើការកាត់បន្ថយហានិភ័យគូភាគី អាចនឹងបានមកដោយសារការផ្ទេរបន្តនូវការបន្ថែម Margin Calls ជាមូលបត្រនិង Margin Calls ជាសាច់ប្រាក់។

បើគ្មានហេតុការណ៍ខកខានទេភាគីទាំងពីរនឹងបំពេញរាល់កាតព្វកិច្ចទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនីមួយៗក្រោមកិច្ចសន្យាមេ ដោយអនុលោមតាមលក្ខខណ្ឌជាក់លាក់នៃការបញ្ជាក់ទៅវិញទៅមកដែលចេញ ដោយភាគីទាំងពីរ។

ដូច្នេះ ប្រតិបត្តិការទទួលទិញវិញនីមួយៗដែលស្ថិតក្រោមកិច្ចសន្យាមេគឺជាការផ្គូបគ្នានូវប្រតិបត្តិការពីរ ដែលត្រូវតែបានធ្វើឡើងព្រមគ្នាក្នុងពេលតែមួយ។ ប្រតិបត្តិការម្ខាង គឺភាគីឱ្យខ្ចីប្រាក់ផ្តល់ឥណទានដល់ភាគីខ្ចីប្រាក់ និងប្រតិបត្តិការម្ខាងទៀត ភាគីខ្ចីប្រាក់លក់កម្មសិទ្ធិពេញលេញនៃមូលបត្រទៅឱ្យភាគីឱ្យខ្ចីប្រាក់ដោយប្តេជ្ញាទទួលទិញមូលបត្រវិញនាកាលវិសានតាមថ្លៃព្រមព្រៀងគ្នាដែលបានបញ្ជាក់ជាមុនក្នុងកិច្ចសន្យា។ ផ្នែកម្ខាងៗនៃប្រតិបត្តិការទទួលទិញវិញត្រូវបានចាត់ទុកថាជាការផ្តល់ការធានាដល់ភាគីនីមួយៗនៃកិច្ចសន្យា។

ប្រការ ៣.-

ភាគីទាំងពីរនៃកិច្ចសន្យាមេ ត្រូវតែព្រមព្រៀងគ្នាលើមូលបត្រសម្រាប់ប្រតិបត្តិការទទួលទិញវិញ។ យោងទៅលើការវិវត្តរបស់ទីផ្សារ ភាគីទាំងពីរត្រូវតែធ្វើបញ្ជីមូលបត្រ ហើយបញ្ជីនោះត្រូវចាត់ទុកជាកិច្ចសន្យាបន្ថែមទៅលើកិច្ចសន្យាមេ។

មូលបត្រទាំងនោះអាចក្លាយជាកម្មវត្ថុនៃហានិភ័យថ្លៃ ដូច្នេះវាត្រូវតែឆ្លើយតប និងអនុលោមទៅនឹងការរារាំងនិងការហាមឃាត់ដែលបានកំណត់នៅក្នុងកិច្ចសន្យាមេ ជាពិសេសចំពោះការផ្លាស់ប្តូរអត្រាការប្រាក់នៅក្នុងទីផ្សារ។ ដូច្នេះ ភាគីទាំងពីរត្រូវតែព្រមព្រៀងគ្នាលើគ្រាដែលត្រូវធ្វើការវាយតម្លៃត្រូបញ្ចាំតាមតម្លៃទីផ្សារនិងប្រភពព័ត៌មានថ្លៃ ដែលត្រូវប្រើសម្រាប់វាយតម្លៃនោះ។ លើសពីនេះ ស្ថានភាពហានិភ័យគួភាគីត្រូវតែបានព្រមព្រៀងគ្នា ហើយមូលបត្រដែលពាក់ព័ន្ធ និង/ឬ Margin Calls ជាសាច់ប្រាក់ត្រូវតែបានបញ្ជាក់។

ចំពោះស្ថានភាពហានិភ័យឥណទានដែលនៅសល់ដែលគ្មានការធានា អ្នកចូលរួមទីផ្សារត្រូវបង្កើតគោលនយោបាយ និងនីតិវិធីសមស្របក៏ដូចជាដំណើរការឱ្យបានគ្រប់គ្រាន់ ដើម្បីពិនិត្យនិងគ្រប់គ្រងស្ថានភាពហានិភ័យ និងដំណើរការបញ្ជាក់របស់ភាគីទាំងសងខាង។

ប្រការ ៤.-

អ្នកចូលរួមទីផ្សារត្រូវតែបង្កើតនីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងឱ្យបានគ្រប់គ្រាន់ដើម្បីការពារការខកខានមិនបានអនុវត្តកាតព្វកិច្ចទាន់ពេលវេលានៅពេលធ្វើប្រតិបត្តិការ។ ក៏ប៉ុន្តែ ប្រសិនបើភាគីណាមួយខកខានមិនបានទូទាត់ឬប្រគល់មូលបត្រដោយសារតែបញ្ហាប្រតិបត្តិការ ភាគីនោះត្រូវតែជូនដំណឹងភ្លាមទៅភាគីម្ខាងទៀតអំពីបញ្ហាដែលបានកើតឡើង ហើយទទួលខុសត្រូវចំពោះការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតឡើងដោយសារតែការខកខានមិនបានទូទាត់ឬប្រគល់ឱ្យទាន់ពេលវេលានោះ តាមលក្ខខណ្ឌនិងខចែងនៃកិច្ចសន្យា។

ក្នុងករណីបានដឹងមុននូវហេតុការណ៍ខកខានអនុវត្តកិច្ចសន្យាមេ ភាគីម្ខាងទៀតត្រូវតែជូនដំណឹងទៅភាគីខកខានអំពីការបញ្ចប់មុនពេលកំណត់ នូវប្រតិបត្តិការទាំងអស់ក្រោមកិច្ចសន្យាមេ និងគណនាចំនួនបំណុលសុទ្ធតាមតម្លៃទីផ្សារនៃគ្រប់កាតព្វកិច្ចពាក់ព័ន្ធទាំងអស់របស់ប្រតិបត្តិការដែលកំពុងអនុវត្តនៅថ្ងៃខកខាន។ បំណុលសុទ្ធដែលនៅសល់នេះ ត្រូវតែប្រគល់ទៅឱ្យអភិបាលបណ្តោះអាសន្ន ឬអ្នកជម្រះបញ្ជីនិងតុលាការដើម្បីដោះស្រាយដោយយោងទៅលើកាល:ទេស:នៃការខកខាននោះ។ ប្រសិនបើភាគីម្ខាងទៀតត្រូវសងបំណុលសុទ្ធចុងក្រោយទៅឱ្យភាគីខកខាន ការទូទាត់សងត្រូវតែធ្វើទៅឱ្យកាតព្វកិច្ចសុទ្ធទៅវិញទៅមក ដោយសារការបញ្ចប់មុនពេលកំណត់បណ្តាលមកពីការខកខាន។

ប្រការ ៥.-

ដើម្បីធានាកុំឱ្យមានការជំទាស់លើការគណនាសមតុល្យសុទ្ធចុងក្រោយ និងយន្តការនៃការជំនួសមូលបត្រក្នុងប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេ អ្នកចូលរួមក្នុងទីផ្សារត្រូវតែប្រើប្រាស់គំរូកិច្ចសន្យាមេ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះទាំងស្រុង។

ប្រការ ៦.-

ដើម្បីអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជានឹងតម្រូវឱ្យអ្នកចូលរួមក្នុងទីផ្សារចុះហត្ថលេខាជាមុនលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការទីផ្សារចំហ ឬប្រតិបត្តិការអប្បហារ។

ប្រការ ៧.-

មុនពេលចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ អ្នកចូលរួមក្នុងទីផ្សារត្រូវតែធានាថា ពួកគេបានបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងគ្រប់គ្រាន់ក្នុងការវាយតម្លៃទីផ្សារ ពិនិត្យនិងគ្រប់គ្រងហានិភ័យគួរភាគីរបស់ខ្លួន ដែលពាក់ព័ន្ធនឹងកិច្ចសន្យាមេឱ្យបានគ្រប់ជ្រុងជ្រោយ។

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយផងដែរ នូវសេចក្តីណែនាំលើបទប្បញ្ញត្តិស្តីអំពីការចុះកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ចាំបាច់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ និងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់លើទម្រង់របាយការណ៍តាមបទប្បញ្ញត្តិ។

ធនាគារជាតិនៃកម្ពុជា នឹងចេញផ្សាយសេចក្តីណែនាំបន្ថែមស្តីពីការគណនាស្ថានភាពថ្លឹងហានិភ័យ ដែលពាក់ព័ន្ធដោយស្ថានភាពហានិភ័យនៃឥណទាននៅសល់ដែលមានធានា ពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ។

ប្រការ ៨.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៩.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ នៃប្រកាសលេខ ធ៥-០៩-២២៩ ប្រ.ក ស្តីពី
ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ
ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ

កិច្ចសន្យាមេ
សម្រាប់ប្រតិបត្តិការទទួលទិញវិញ
របស់ធនាគារជាតិ នៃ កម្ពុជា

ភាគី ក ៖ .....

តំណាងពេញសិទ្ធិដោយលោក ..... មានឋានៈជា ..... និង

ភាគី ខ ៖ .....

តំណាងពេញសិទ្ធិដោយលោក ..... មានឋានៈជា .....

ភាគី ក និង ភាគី ខ បានយល់ព្រមចុះហត្ថលេខានៅលើកិច្ចសន្យាមេក្នុងគោលបំណងដើម្បីធានាថា គ្រប់ប្រតិបត្តិការឱ្យខ្ចី/សុំខ្ចីត្រូវមានវត្ថុធានា។ វត្ថុធានាទាំងនេះត្រូវមានទម្រង់ជាឧបករណ៍បំណុលអាចជួញដូរបាន មានកំណត់កាលវសាន ដូចជា ប័ណ្ណ មូលបត្រ និងសញ្ញាប័ណ្ណ ដោយមិនរាប់បញ្ចូលនូវភាគហ៊ុននិងឧបករណ៍កូនកាត់ (Hybrid) អាចជួញដូរបាន ព្រមទាំងឧបករណ៍បំណុលអាចជួញដូរបានមិនមានកំណត់កាលវសាន ឬមូលបត្រដែលបានដកការប្រាក់មួយចំណែករួចហើយ (Stripped or perpetual debt instrument) ។

កិច្ចសន្យាមេនេះនឹងអនុវត្តដោយស្វ័យប្រវត្តិចំពោះរាល់ប្រតិបត្តិការទទួលទិញវិញ ដែលនឹងត្រូវធ្វើដោយភាគីនៃកិច្ចសន្យា លើកលែងតែភាគីទាំងពីរយល់ព្រមដកចេញនូវប្រតិបត្តិការជាក់លាក់ណាមួយក្នុងពេលអនាគត ឬក៏លុបចោលនូវសុពលភាពនៃកិច្ចសន្យាមេ។ កិច្ចសន្យាមេមិនត្រូវបានលុបចោលដោយឯកតោភាគីទេ លើសពីនេះទៀត កិច្ចសន្យាមេនឹងនៅតែមានសុពលភាពពេញលេញ ដរាបណាប្រតិបត្តិការទាំងឡាយនៅក្រោមកិច្ចសន្យានេះនៅតែមានបន្ត។

ប្រការ ១.- កម្មវត្ថុ និង គោលការណ៍ទូទៅ

១-១ ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាមេនៃប្រតិបត្តិការទទួលទិញវិញនេះ ភាគីទាំងពីរយល់ព្រមអនុវត្តតាមកម្មវត្ថុច្បាស់លាស់ទាំងឡាយ ដូចខាងក្រោម៖

- ក្នុងករណីដែលកិច្ចសន្យាមេត្រូវបានបញ្ចប់មុនកាលកំណត់ គ្រប់ប្រតិបត្តិការទទួលទិញវិញនីមួយៗ ដែលត្រូវបានធ្វើរវាងភាគីទាំងពីរនៅក្រោមកិច្ចសន្យានេះ ត្រូវបានចាត់ទុកថាជាធាតុមួយនៃសំណុំប្រតិបត្តិការទាំងមូល និងដើម្បីគណនាចំនួនទូទាត់សុទ្ធនៃសមតុល្យ ដែលភាគីមួយជំពាក់ភាគីមួយទៀត។

- នៅពេលដែលភាគីណាមួយគ្មានលទ្ធភាពសង ភាគីម្ខាងទៀតមានសិទ្ធិពេញលេញក្នុងការបញ្ចប់រាល់ប្រតិបត្តិការក្រោមកិច្ចសន្យាមេ និងជាត់ទាត់រកចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយ គិតត្រឹមថ្ងៃដែលគ្មានលទ្ធភាពសងនោះ។

- ចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយខាងលើនេះ នឹងត្រូវកំណត់ដោយតម្លៃសេដ្ឋកិច្ច ផ្អែកលើមូលដ្ឋាននៃតម្លៃទីផ្សាររបស់មូលបត្រ លើរាល់ផ្នែកទិញ ឬលក់នៃប្រតិបត្តិការ រួមទាំងម៉ាជីនខល (Margin Call) ដែលបានបង់ដោយភាគីទាំងពីរនៅពេលចាប់ផ្តើមអនុវត្តកិច្ចសន្យា។

- នៅពេលភាគីណាមួយក្ស័យធន ភាគីទាំងពីរយល់ព្រមថា ចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយ គឺជាបំណុលតែមួយគត់ដែលត្រូវយកទៅទាមទារនៅតុលាការ ឬជាបំណុលតែមួយគត់ដែលត្រូវទាមទារពីភាគីម្ខាងទៀត ដោយអភិបាលបណ្តោះអាសន្នរបស់ភាគីដែលក្ស័យធន ឬដោយតុលាការ។ សមតុល្យបញ្ចប់ចុងក្រោយគឺជាបំណុលតែមួយគត់ដែលត្រូវទាមទារដោយភាគីណាមួយ។ រាល់បំណុលនៃប្រតិបត្តិការនីមួយៗក្រោមកិច្ចសន្យាមេ ត្រូវបានផុតរលត់នៅពេលដែលបានទូទាត់ឬដែលរកឃើញចំនួនប្រាក់បំណុលសុទ្ធនោះ។

១-២ ភាគីទាំងពីរព្រមព្រៀងថា ការកែប្រែលក្ខខណ្ឌនិងខចែងនៃកិច្ចសន្យាមេ អាចនឹងធ្វើទៅបាន ក៏ប៉ុន្តែការកែប្រែនេះត្រូវតែអនុលោមតាមគោលការណ៍ និងកម្មវត្ថុដែលបានចែងក្នុងប្រការ ១ នៃកិច្ចសន្យាមេនេះ ។

១-៣ នៅពេលដែលមានការព្រមព្រៀងគ្នាកែប្រែ ភាគីទាំងពីរត្រូវចុះហត្ថលេខាលើកិច្ចសន្យាបន្ថែមភ្ជាប់ជាមួយកិច្ចសន្យាមេ។ ក្នុងករណីនេះ លក្ខខណ្ឌនិងខចែងដែលមាននៅក្នុងកិច្ចសន្យាបន្ថែមនេះត្រូវចាត់ទុកជាអាទិភាពទៅលើលក្ខខណ្ឌនិងខចែងនៅក្នុងកិច្ចសន្យាមេ។

១-៤ នៅពេលចុះកិច្ចសន្យាមេ ភាគីទាំងពីរដែលសុទ្ធតែអ្នកមានវិជ្ជាជីវៈ បានយល់ដឹងអំពីផលវិបាកទាំងឡាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញដែលគ្រប់គ្រងដោយកិច្ចសន្យាមេ និងប្រកាសថាត្រូវតែធ្វើសកម្មភាពដោយសុចរិតទៀងត្រង់។ លើសពីនេះទៀត តំណាងទាំងអស់ដែលបានចុះហត្ថលេខាលើកិច្ចសន្យាមេត្រូវតែទទួលបានការផ្ទេរសិទ្ធិអំណាចចាំបាច់ ដើម្បីបំពេញតួនាទីជូនមុខភាគីណាមួយដែលខ្លួនតំណាងឱ្យ។ ក្នុងន័យនេះ ភាគីទាំងពីរមិនអាចប្តឹងទៅតុលាការ ឬតាមមធ្យោបាយផ្សេងទៀតដើម្បីជំទាស់សុពលភាព ឬលុបចោលកិច្ចសន្យាមេបានឡើយ លើកលែងតែមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

ប្រការ ២.- និយមន័យ

ពាក្យមួយចំនួននៃកិច្ចសន្យាមេនេះ ត្រូវមាននិយមន័យដូចខាងក្រោម៖

- **ប្រតិបត្តិការទទួលទិញវិញ** ៖ ជាប្រតិបត្តិការណាមួយដែលត្រូវបានព្រមព្រៀងដោយទ្វេភាគី ដែលក្នុងនោះ ភាគីអ្នកលក់យល់ព្រមលក់មូលបត្រដែលអាចទទួលយកបានឱ្យភាគីអ្នកទិញ ហើយយល់ព្រមផ្ទេរកម្មសិទ្ធិពេញលេញលើមូលបត្រនោះឱ្យអ្នកទិញដើម្បីធានាប្រាក់ដែលខ្លួនបានខ្ចី ដោយមានការសន្យាយ៉ាងមុឺងម៉ាត់ថា នឹងទិញយកវិញនូវមូលបត្រនោះនាកាលវសានៃកិច្ចសន្យា (កាលបរិច្ឆេទទទួលទិញវិញ) ទៅតាមថ្លៃដែលបានព្រមព្រៀងគ្នា (ថ្លៃទទួលទិញវិញ) នៅពេលចាប់ផ្តើមប្រតិបត្តិការទទួលទិញវិញ។ ប្រតិបត្តិការទិញនិងលក់នេះមិនអាចផ្តាច់ចេញពីគ្នាបានឡើយ ដោយសារតែប្រតិបត្តិការទាំងពីរនេះ ជាការធានាឱ្យគ្នាទៅវិញទៅមក ក្នុងគោលបំណងកាត់បន្ថយជាអតិបរមា ឬលុបបំបាត់ចោលនូវហានិភ័យនៃគូភាគី ដែលកើតឡើងពីភាគីណាមួយក្នុងចំណោមភាគីទាំងពីរ។

- ហេតុការណ៍ខកខានក្នុងការបំពេញកាតព្វកិច្ច (Event of Default)៖ ត្រូវបានចាត់ទុកថា ហេតុការណ៍ខកខានក្នុងការអនុវត្តកិច្ចសន្យាមេ នៅពេលដែលមានករណីដូចខាងក្រោម៖

  - តុលាការបានសម្រេចដាក់ភាគីណាមួយឱ្យស្ថិតនៅក្រោមនីតិវិធីក្ស័យធន
  - អាជ្ញាធរត្រួតពិនិត្យសម្រេចដកហូតអាជ្ញាបណ្ណរបស់ភាគីណាមួយ
  - ការមិនអាចសងបំណុលបានរបស់អ្នកបោះផ្សាយមូលបត្រដែលបានលក់ចេញ
  - ការទូទាត់សងប្រាក់ ឬការប្រគល់មូលបត្រ មិនទាន់ពេលវេលា ដែលកើតមកពីទំនាក់ទំនងធុរៈកិច្ចរវាងភាគីទាំងពីរ ទោះជាស្ថិតក្រោមកិច្ចសន្យាមេនេះ ឬក្រោមប្រតិបត្តិការដទៃទៀតក៏ដោយ លើកលែងតែការខកខាននេះកើតចេញពីកំហុសផ្នែកបច្ចេកទេសដែលត្រូវបានដោះស្រាយលឿនបំផុត និងភាគីទាំងពីរមិនមានបញ្ហាខាងផ្លូវច្បាប់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន
  - ការព្យួរ ឬការដកភាគីណាមួយពីសភាជាត់ទាត់ ឬពីប្រព័ន្ធទូទាត់សងប្រាក់
  - ការខកខានមិនទូទាត់សងប្រាក់ដែលកើតចេញពីទំនាក់ទំនងធុរៈកិច្ចរវាងភាគីណាមួយនៃភាគីទាំងពីរជាមួយនឹងតតិយភាគីលើកលែងតែការមិនបានទូទាត់សងប្រាក់នោះកើតចេញពីកំហុសផ្នែកបច្ចេកទេស ភាគីទាំងពីរមិនមានបញ្ហាខាងផ្លូវច្បាប់ក្នុងការទូទាត់សងប្រាក់ និងការមិនទូទាត់សងប្រាក់នេះជាសញ្ញានៃការចុះថយនៃស្ថានភាពសាធនភាព និង
  - ករណីប្រធានសក្តិដទៃទៀតកំណត់ដោយភាគីទាំងពីរ ដែលភាពធ្ងន់ធ្ងរនៃករណីប្រធានសក្តិនោះ នាំឱ្យមានបញ្ចប់មុនកាលកំណត់នូវប្រតិបត្តិការទទួលទិញវិញទាំងអស់ក្រោមកិច្ចសន្យាមេ ព្រមទាំងកិច្ចសន្យាមេខ្លួនឯងផងដែរ និងជាត់ទាត់បញ្ចប់នូវរាល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគីទាំងពីរ។

- **ការបញ្ជាក់ (Confirmation)** ៖ ជាឯកសារលាយលក្ខណ៍អក្សរចេញដោយភាគីណាមួយ ដើម្បីទទួលស្គាល់ការសន្យារបស់ខ្លួនទៅឱ្យភាគីមួយទៀត និងប្តេជ្ញាបំពេញរាល់កាតព្វកិច្ចដែលកើតចេញពីប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេ។ ការបញ្ជាក់ត្រូវតែបានឡើង ដោយភាគីនីមួយៗដើម្បីបញ្ជាក់អំពីការព្រមព្រៀងគ្នា ជាពិសេស នៅពេលដែលមានប្រតិបត្តិការទទួលទិញវិញថ្មី ការកែប្រែចរិតលក្ខណៈធំៗណាមួយ ការជំនួសនូវមូលបត្រដែលបានលក់ ឬការព្រមព្រៀងណាមួយ ដើម្បីកែតម្រូវតម្លៃសេដ្ឋកិច្ចនៃប្រតិបត្តិការទទួលទិញវិញ និងបន្ទាប់មកម៉ាជីនដែលបានបង់ឬត្រូវទទួល ឬហ៊ែរខាត់ (Haircut)។ ចរិតលក្ខណៈធំៗត្រូវមានជាពិសេសនូវកាលវិសោនកាលបរិច្ឆេទប្រតិបត្តិការ ថ្ងៃប្រសិទ្ធភាព អត្រាការប្រាក់ រូបិយប័ណ្ណ រូបិយប័ណ្ណគោល អត្តសញ្ញាណនៃមូលបត្រ មូលបត្រដែលតម្រូវឱ្យបន្ថែមហ៊ែរខាត់ (Haircut) កម្រិតកំណត់នៃម៉ាជីនខល (Margin Calls) និងម៉ាជីនខលដែលត្រូវបង់ ឬត្រូវទទួលក្រោមកិច្ចសន្យាមេ និងថ្លៃទទួលទិញវិញ។ ភាគីនីមួយៗ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីប្រតិបត្តិការថ្មី និងយោងកិច្ចសន្យាមេ ឬការកែប្រែណាមួយដែលបានព្រមព្រៀងជាមួយភាគីម្ខាង ទៀតដោយយកចិត្តទុកដាក់។ កិច្ចសន្យាមេអាចចាត់ទុកថាមានលក្ខណៈពេញលេញសម្រាប់ភាគីទាំងពីរ លុះត្រាតែលក្ខខណ្ឌនៃការបញ្ជាក់ដែលត្រូវបានចេញឆ្លើយតបពេញលេញទៅនឹងលក្ខខណ្ឌនៃការបញ្ជាក់ ដែលបានទទួល។

- **កិច្ចសន្យាបំពេញបន្ថែម** ៖ ជាការកែប្រែណាមួយទៅលើកិច្ចសន្យាមេ ដែលបានព្រមព្រៀងរវាងភាគីទាំងពីរ។ ការកែប្រែនេះត្រូវតែអនុលោមតាមគោលការណ៍ទូទៅ និងកម្មវត្ថុនានាដែលបានចែងក្នុងប្រការ ១ នៃកិច្ចសន្យាមេនេះ។ ការកែប្រែដែលត្រូវបានធ្វើឡើងជាផ្លូវការ ដោយមានហត្ថលេខារបស់ភាគីទាំងពីរលើកិច្ចសន្យាបំពេញបន្ថែមនោះត្រូវតែបានអនុវត្តជាអាទិភាព ដោយសារថាកិច្ចសន្យាបំពេញបន្ថែមនោះមានអានុភាពលើ ឬនាំឱ្យមានការលើកលែងបញ្ញត្តិទូទៅនៃកិច្ចសន្យាមេ។

- **ហ៊ែរខាត់ (Haircut)** ៖ គឺជាការតម្រូវឱ្យដាក់មូលបត្របន្ថែមសម្រាប់ធានាប្រតិបត្តិការទទួលទិញវិញ ហើយការដាក់បន្ថែមនេះត្រូវបានគិតជាភាគរយ។ ហ៊ែរខាត មានគោលបំណងធានាដល់ការប្រែប្រួលថ្លៃនៃមូលបត្រដែលបានលក់ក្នុងរយៈពេលនៃប្រតិបត្តិការទទួលទិញវិញ និងដើម្បីចៀសវាងការកែតម្រូវខាសម៉ាជីនញឹកញាប់។ ដូច្នេះ ហ៊ែរខាត់ គឺជាការដាក់វត្ថុធានាលើសពីពេលចាប់ផ្តើមនៃប្រតិបត្តិការទទួលទិញវិញ និងនាំទៅកែតម្រូវថ្លៃមូលបត្រ។

- **ការកែតម្រូវថ្លៃមូលបត្រ (Adjusted Securities' Price)** ៖ ថ្លៃមូលបត្រ គឺជាថ្លៃគោលដែលយោងតាមនោះ មូលបត្រអាចទទួលយកបាននៃប្រតិបត្តិការទទួលទិញវិញ ត្រូវបានជួញដូរនៅក្នុងទីផ្សារ។ សម្រាប់គោលបំណងនៃកិច្ចសន្យានេះ ភាគីទាំងពីរព្រមព្រៀងគ្នាប្រើប្រាស់ថ្លៃមធ្យមទីផ្សារ (មធ្យមភាគនៃថ្លៃទិញ-លក់)។ ការកែតម្រូវថ្លៃមូលបត្រឆ្លុះបញ្ចាំងអំពីហ៊ែរខាត់ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាមានគោលបំណងធានាដល់ការប្រែប្រួលនៃថ្លៃមូលបត្រដែលបានលក់ ក្នុងរយៈពេលនៃប្រតិបត្តិការទទួលទិញវិញ និងដើម្បីចៀសវាងការកែតម្រូវខាសម៉ាជីនញឹកញាប់។

- **ម៉ាជីន (Margin)** ៖ គឺជាផលបូកនៃប្រាក់តម្កល់ជាមូលបត្រ (Securities Margin) និងខាសម៉ាជីន (Cash Margin) ក្នុងចំណុចណាមួយនៃរយៈពេលប្រតិបត្តិការ។ ប្រាក់តម្កល់ជាមូលបត្រ (Securities Margin) សមមូលទៅនឹងតម្លៃសេដ្ឋកិច្ច ឬតម្លៃទីផ្សារ នៃហ៊ែរខាត់ (Haircut) នាពេលផ្តើមប្រតិបត្តិការ។

- **ខាសម៉ាជីន (Cash Margin)** ៖ ជាចំនួនប្រាក់ដែលទូទាត់សងដោយភាគីមួយឱ្យភាគីមួយទៀតដើម្បីបង្កើតឡើងវិញនូវសមតុល្យនៃស្ថានភាពហានិភ័យឥណទាន ឬហានិភ័យគូភាគី បន្ទាប់ពីមានចំណេញឬខាត ដោយសារតែការវាយតម្លៃឡើងវិញនៃមូលបត្រដែលបានលក់ក្រោមប្រតិបត្តិការទទួលទិញវិញ។

- **ម៉ាជីនខល (Margin Calls)** ៖ ជាប្រាក់តម្កល់ជាសាច់ប្រាក់ដែលបានទាមទារដោយភាគីណាមួយ ដើម្បីកែតម្រូវឡើងវិញនូវម៉ាជីន។ អាស្រ័យទៅលើការព្រមព្រៀងរវាងភាគីទាំងពីរ ម៉ាជីនខលអាចជាសាច់ប្រាក់ឬជាការលក់បន្ថែមនូវមូលបត្រដែលមានលក្ខណៈដូចគ្នា។ ជាទូទៅ ម៉ាជីនខលត្រូវមានកម្រិតកំណត់ដែលបាន ព្រមព្រៀងដោយភាគីទាំងពីរ។

- **កាលបរិច្ឆេទជួញដូរ** ៖ ជាកាលបរិច្ឆេទដែលភាគីទាំងពីរ ព្រមព្រៀងធ្វើប្រតិបត្តិការទទួលទិញវិញថ្មី ហើយក៏ជាកាលបរិច្ឆេទដែលភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ផងដែរ។

- **កាលបរិច្ឆេទទិញ** ៖ ជាកាលបរិច្ឆេទនៃកិច្ចសន្យាដែលមូលបត្រត្រូវបានលក់ទៅឱ្យភាគីអ្នកឱ្យខ្ចីប្រាក់ ហើយក៏ជាពេលចាប់ផ្តើមគិតការប្រាក់បង្គរសម្រាប់ប្រតិបត្តិការទទួលទិញវិញផងដែរ។

- **កាលបរិច្ឆេទទទួលទិញវិញ ឬកាលវសានៃប្រតិបត្តិការទទួលទិញវិញ** ៖ ជាកាលវសាននៃកិច្ចសន្យាដែលប្រតិបត្តិការទទួលទិញវិញត្រូវបានបញ្ចប់ ការប្រាក់បង្គរត្រូវបានបញ្ឈប់ ភាគីខ្ចីប្រាក់សន្យាទិញយកវិញនូវមូលបត្រដែលបានលក់ ដោយទូទាត់សងវិញនូវប្រាក់ដែលបានខ្ចី (ប្រាក់ដើម) និងការប្រាក់បង្គរតាមអត្រាទទួលទិញវិញ។

- **កាលបរិច្ឆេទវាយតម្លៃ** ៖ ជាកាលបរិច្ឆេទដែលភាគីទាំងពីរសម្រេច៖

  ១) ធ្វើការវាយតម្លៃសេដ្ឋកិច្ចទៅលើប្រតិបត្តិការទទួលទិញវិញ ដើម្បីកំណត់នូវតម្លៃនៃម៉ាជីន និងដើម្បីកែតម្រូវតម្លៃនេះតាមរយៈម៉ាជីនខល និងការទូទាត់ ឬ

  ២) ដើម្បីគណនាតម្លៃសុទ្ធនូវរាល់ឥណទេយ្យ និងបំណុល ដែលស្ថិតក្រោមកិច្ចសន្យាមេនេះ ក្នុងគោលបំណងបញ្ចប់មុនកាលវសាន ឬដោយសារតែការខកខានមិនបានសងបំណុលដោយភាគីណាមួយ។

- **រូបិយប័ណ្ណ** ៖ ជារូបិយប័ណ្ណដែលអាចផ្ទេរប្តូរ និងជួញដូរបានដោយសេរី រួមទាំងរូបិយវត្ថុក្នុងស្រុកផង។ ក្នុងករណីដែលមូលបត្រត្រូវបានចេញផ្សាយជារូបិយប័ណ្ណផ្សេងខុសពីរូបិយប័ណ្ណដែលបានខ្ចី ភាគីទាំងពីរត្រូវតែប្រើរូបិយប័ណ្ណគោលមួយដើម្បីវាយតម្លៃឡើងវិញនូវមូលបត្រ និងការទូទាត់ម៉ាជីនខល។ ការគណនា និងដំណើរការទូទាត់នេះត្រូវតែធ្វើឡើងដោយប្រើអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

- **រូបិយប័ណ្ណគោល** ៖ ជារូបិយប័ណ្ណដែលភាគីទាំងពីរបានព្រមព្រៀងប្រើប្រាស់សម្រាប់ដំណើរការវាយតម្លៃ ការទូទាត់សងនូវប្រាក់តម្កល់ជាសាច់ប្រាក់ និងការកំណត់នូវការជាត់ទាត់សមតុល្យសុទ្ធ ក្នុងករណីដែលមានការខកខានមិនបានទូទាត់ ឬការបញ្ចប់ដោយភាគីទាំងពីរនូវរាល់ប្រតិបត្តិការទទួលទិញវិញ ដែលស្ថិតនៅក្រោមកិច្ចសន្យាមេ ឬការបញ្ចប់នូវកិច្ចសន្យាមេខ្លួនឯង។

- **អត្រាការប្រាក់ប្រតិបត្តិការទទួលទិញវិញ** ៖ ជាអត្រាការប្រាក់ដែលត្រូវបង់ដោយភាគីខ្ចីប្រាក់ "អ្នកលក់មូលបត្រ" ឱ្យទៅភាគីឱ្យខ្ចី "អ្នកទិញមូលបត្រ" គិតលើប្រាក់ដើមដែលបានឱ្យខ្ចី ចាប់ពីថ្ងៃផ្តើមប្រតិបត្តិការរហូតដល់កាលវសាន។

- **អត្រាការប្រាក់គោល** ៖ ជាអត្រាការប្រាក់ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ហើយដែលត្រូវបានអនុវត្តតាមសមាមាត្រលើរាល់ការទូទាត់សងខាសម៉ាជីន ដោយភាគីណាមួយទៅភាគីមួយទៀត។ ប្រសិនបើគ្មានការកំណត់អត្រាការប្រាក់គោលនេះនៅក្នុងកិច្ចសន្យាទទួលទិញវិញ ក្រោមកិច្ចសន្យាមេនេះទេ ខាសម៉ាជីនបានចាត់ទុកថាគ្មានការប្រាក់។

- **មូលបត្រ** ៖ ជារាល់ឧបករណ៍បំណុលអាចជួញដូរបាន ដែលភាគីទាំងពីរបានព្រមព្រៀងប្រើសម្រាប់ប្រតិបត្តិការទទួលទិញវិញ។ យោងតាមលក្ខខណ្ឌដែលបានព្រមព្រៀង ភាគីទាំងពីរអាចព្រមព្រៀងផងដែរថា មូលបត្រមួយអាចត្រូវបានជំនួសដោយមូលបត្រផ្សេងទៀត ក្នុងកំឡុងពេលប្រតិបត្តិការទទួលទិញវិញ។ ក៏ប៉ុន្តែ ការជំនួសត្រូវតែមានការបញ្ជាក់ពីភាគីទាំងពីរ ហើយសិទ្ធិនៃការជំនួសមិនត្រូវកំណត់ដោយភាគីដែលផ្តួចផ្តើម ការជំនួសនោះឡើយ។

- **ការជំនួសមូលបត្រ** ៖ ក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ដែលស្ថិតក្រោមកិច្ចសន្យាមេ ភាគីទាំងពីរអាចព្រមព្រៀងថា មូលបត្រដែលត្រូវប្រគល់អាចជាមូលបត្រផ្សេងក្រៅពី

មូលបត្រដែលបានលក់ដំបូង។ ការជំនួសនេះ មិនត្រូវធ្វើឡើងដោយអ្នកលក់មូលបត្រជាឯកតោភាគីឡើយ។ ភាគីទាំងពីរ ត្រូវយល់ព្រម និងបញ្ជាក់ថាមូលបត្រដែលត្រូវជំនួសនោះអាចទទួលយកបាន។ តាមវិធានជាទូទៅ ការជំនួសបែបនេះនឹងធ្វើឱ្យមានការវាយតម្លៃឡើងវិញនូវប្រតិបត្តិការ និងកែតម្រូវឡើងវិញនូវម៉ាជីន។

- **ការប្រគល់មូលបត្រ** ៖ ប្រតិបត្តិការទទួលទិញវិញដែលស្ថិតក្រោមកិច្ចសន្យាមេ នាំឱ្យមានការផ្ទេរកម្មសិទ្ធិពេញលេញដោយគ្មានការរារាំងលើមូលបត្រទៅឱ្យភាគីឱ្យខ្ចី ចាប់ពីកាលបរិច្ឆេទទិញរហូតដល់កាលវសានៃប្រតិបត្តិការ។ ការផ្ទេរកម្មសិទ្ធិនេះ ត្រូវតែកត់ត្រាក្នុងបញ្ជីភាគីលក់មូលបត្រ។ ជាទូទៅ ការផ្ទេរកម្មសិទ្ធិនេះ នាំឱ្យមានការផ្ទេរមូលបត្រទៅក្នុងគណនីរក្សាមូលបត្ររបស់អ្នកឱ្យខ្ចីដែលចង្អុលបង្ហាញដោយភាគីទិញមូលបត្រ។ ក៏ប៉ុន្តែ ដោយសារប្រតិបត្តិការទិញយកវិញមានរយៈពេលខ្លី ហើយការផ្ទេរមូលបត្រពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ ភាគីទាំងពីរអាចព្រមព្រៀងថាភាគីខ្ចីប្រាក់អាចរក្សាទុកមូលបត្រ ក្នុងនាមភាគីឱ្យខ្ចីដែលទិញមូលបត្រនោះ។ ក្នុងករណីនេះ ភាគីខ្ចីប្រាក់ដើរតួនាទីជាអ្នកថែរក្សាមូលបត្ររបស់ភាគីទិញ។ ភាគីខ្ចីប្រាក់ត្រូវបានហាមឃាត់មិនឱ្យលក់នូវមូលបត្រនោះម្តងទៀត ភាគីខ្ចីប្រាក់ត្រូវចុះកិច្ចបញ្ជិកានៅក្នុងខ្នង់ក្រៅតារាងតុល្យការ និងកត់ត្រាជាទ្រព្យសម្បត្តិពេញលេញរបស់ភាគីឱ្យខ្ចី។ ក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ភាគីឱ្យខ្ចីអាចតម្រូវឱ្យភាគីខ្ចីប្រាក់ប្រគល់មូលបត្រតាមសំណើរបស់ខ្លួន។ បើអ្នកខ្ចីប្រាក់មិនអាចប្រគល់មូលបត្រទៅឱ្យភាគីឱ្យខ្ចីនោះទេ ករណីនេះត្រូវបានចាត់ទុកថាជាហេតុការណ៍ខកខាន។ ត្រូវបានចាត់ទុកថាជាហេតុការណ៍ខកខានមិនបានអនុវត្តតាមកិច្ចសន្យាផងដែរ ប្រសិនបើភាគីឱ្យខ្ចីរកឃើញថាគ្មានមូលបត្រ ដែលបានលក់ ហើយការអះអាងរបស់ភាគីខ្ចីប្រាក់ជាចេតនាមិនស្មោះត្រង់ ក្នុងគោលបំណងឆបោកភាគីឱ្យខ្ចីប្រាក់ និងចេតនាបំភាន់អំពីចរិតលក្ខណៈតម្លៃ ឬអត្ថិភាពរបស់មូលបត្រដែលបានលក់។

- **ហានិភ័យនៃការទូទាត់** ៖ ជាហានិភ័យដែលកើតឡើងចំពោះភាគីលក់មូលបត្រ ដោយមិនបានទទួលការទូទាត់សងប្រាក់ នៅពេលដែលខ្លួនបានធ្វើការផ្ទេរដោយមិនអាចលុបចោលបាននូវមូលបត្រជាស្តាពរ ទៅឱ្យភាគីទិញមូលបត្ររួចហើយ។

- **ហានិភ័យនៃការប្រគល់** ៖ ជាហានិភ័យដែលកើតឡើងចំពោះភាគីទិញមូលបត្រ ដោយមិនបានទទួលមូលបត្រនៅពេលដែលខ្លួនបានចេញបញ្ជាទូទាត់ដែលមិនអាចលប់ចោលបាន ដើម្បីសងប្រាក់ជាស្តាពរទៅឱ្យភាគីលក់មូលបត្ររួចហើយ។

- **ការទូទាត់ទល់នឹងការប្រគល់** ៖ ជាការតម្រូវរបស់ភាគីទាំងពីរ ដែលបានព្រមព្រៀងដើម្បីដាក់លក្ខខណ្ឌលើការទូទាត់ទល់នឹងការប្រគល់ដោយប្រសិទ្ធភាព ដើម្បីលប់បំបាត់នូវហានិភ័យនៃការទូទាត់ និងហានិភ័យនៃការប្រគល់ពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ។

- **អ្នកថែរក្សា** ៖ ជាអន្តរការីហិរញ្ញវត្ថុ ឬស្ថាប័នហិរញ្ញវត្ថុ ដែលផ្តល់សេវាថែរក្សាសុវត្ថិភាពឧបករណ៍អាចជួញដូរបាន។ អ្នកថែរក្សាបំពេញតួនាទីក្នុងនាម និងអនុវត្តតាមបញ្ជារបស់ម្ចាស់ឧបករណ៍។ អ្នកថែរក្សាមិនត្រូវលក់ឧបករណ៍អាចជួញដូរបានដែលបានដាក់ធ្វើ ដោយគ្មានបញ្ជាជាផ្លូវការពីម្ចាស់គណនីឡើយ ។

ប្រការ ៣.- មូលបត្រអាចទទួលយកបាន / ការជំនួសមូលបត្រ

៣-១ មូលបត្រអាចទទួលបាន (Eligible Security)

ដើម្បីអាចធ្វើប្រតិបត្តិការទទួលទិញវិញក្រោមវិធានកិច្ចសន្យាមេបាន មូលបត្រដែលត្រូវលក់ឬទិញត្រឡប់វិញត្រូវតែស្ថិតក្នុងទម្រង់ជាឧបករណ៍បំណុលអាចជួញដូរបាន ដោយមានកំណត់នូវកាលវិសានដូចជា លិខិតដែលចេញដោយធនាគារជាតិនៃកម្ពុជា ប័ណ្ណបំណុលរយៈពេលមធ្យមមូលបត្រ និងសញ្ញាប័ណ្ណ តែមិនរាប់បញ្ចូលនូវភាគហ៊ុន និងឧបករណ៍ជួញដូរមានលក្ខណៈជាកូនកាត់ (Hybrid) ព្រមទាំងឧបករណ៍បំណុលអាចជួញដូរបានមិនមានកំណត់កាលវិសាន ឬមូលបត្រដែលបានដកការប្រាក់មួយចំណែក (Stripped or perpetual debt instrument)។

មូលបត្រអាចជួញដូរបាននោះ ត្រូវតែបានជួញដូរនៅក្នុងទីផ្សារសាច់ប្រាក់ងាយស្រួលអាចជាទីផ្សារដែលបានរៀបចំ ឬទីផ្សាររំលងបញ្ជរ (OTC) ដោយមានការកំណត់ថ្លៃ (Price quotation) ប្រចាំថ្ងៃដែលធ្វើឱ្យងាយស្រួលទទួលបានដោយភាគីទាំងពីរ។ ភាគីទាំងពីរ អាចបង្កើតបញ្ជីសង្ខេបនៃមូលបត្រអាចជួញដូរបានដែលត្រូវភ្ជាប់ជាមួយកិច្ចសន្យាមេ និងត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ។

៣-២ ការជំនួសមូលបត្រ

នៅអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ភាគីទាំងពីរអាចព្រមព្រៀងជំនួសមូលបត្រមួយដោយមូលបត្រមួយទៀតបាន។ ការព្រមព្រៀងនេះត្រូវតែបានបញ្ជាក់ជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ ហើយដាច់ខាតមិនត្រូវសន្មតដោយភាគីតែម្ខាងឡើយ។

ក៏ប៉ុន្តែ ការជំនួសនេះគឺជាការផ្លាស់ប្តូរមូលបត្រដែលបានលក់ពីដំបូង ដោយមូលបត្រដែលមានលក្ខណៈនិងតម្លៃសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា យ៉ាងហោចណាស់ក៏សមមូលទៅនឹងមូលបត្រដែលត្រូវបានផ្លាស់ប្តូរនោះដែរ។

ការជំនួសត្រូវបានធ្វើឡើងដោយការប្រគល់មូលបត្រថ្មីទៅឱ្យភាគីឱ្យខ្ចីដែលត្រូវប្រគល់វិញនូវមូលបត្រដែលបានលក់លើកដំបូងទៅភាគីខ្ចីប្រាក់។ ការជំនួសមូលបត្រមិនមានការប៉ះពាល់ខាងផ្លូវច្បាប់ ឬខាងកិច្ចសន្យាទៅលើកាតព្វកិច្ចរបស់ភាគីទាំងពីរឡើយ។ ក៏ប៉ុន្តែ ការជំនួសនេះអាចនាំឱ្យភាគីទាំងពីរវាយតម្លៃឡើងវិញនូវប្រតិបត្តិការទទួលទិញវិញ និងកែតម្រូវម៉ាជីនទៅតាមនោះ។

ប្រការ ៤.- ហេតុការណ៍ដែលមានឥទ្ធិពលលើមូលបត្រ ក្នុងពេលធ្វើប្រតិបត្តិការទទួលទិញវិញ

ជាវិធានការទូទៅ ភាគីទាំងពីរព្រមព្រៀងនិងសន្យាថាមិនលក់ ឬមិនទិញវិញនូវមូលបត្រដែលអាចត្រូវបានសងរំលស់ ឬសងជាគូប៉ុងនៅក្នុងរយៈកាលនៃប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេនេះឡើយ។

ក៏ប៉ុន្តែ បើមូលបត្រត្រូវបានសងជាគូប៉ុងនៅក្នុងអំឡុងពេលនៃប្រតិបត្តិការទទួលទិញវិញគូប៉ុងនោះត្រូវតែបានសងទៅឱ្យភាគីខ្ចីប្រាក់វិញ លើកលែងតែមានខចែងផ្សេងពីនេះ។

បើមូលបត្រត្រូវបានសងរំលស់មុនកាលវសានៃប្រតិបត្តិការទទួលទិញវិញ ភាគីខ្ចីប្រាក់ត្រូវជំនួសមូលបត្រអាចជួញដូរបានសម្រាប់ការបង់រំលស់នោះ។ បន្ថែមលើនេះ ប្រសិនបើភាគីឱ្យខ្ចីប្រាក់ត្រូវតែសងមូលបត្រវិញ ភាគីឱ្យខ្ចីប្រាក់នោះត្រូវផ្ទេរចំនួនប្រាក់រំលស់ដែលទទួលបាននោះទៅឱ្យភាគីខ្ចីប្រាក់នៅពេលដែលការជំនួសមូលបត្រត្រូវបានព្រមព្រៀងគ្នា។

ប្រការ ៥.- ការសម្រេចពេញលេញ / ការបញ្ចាក់នៃប្រតិបត្តិការទទួលទិញវិញ

ប្រតិបត្តិការទទួលទិញវិញ ត្រូវបានចាត់ទុកថាសម្រេចពេញលេញនៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នាលើរាល់ចរិតលក្ខណៈនៃប្រតិបត្តិការនេះ។ ក៏ប៉ុន្តែ ប្រតិបត្តិការនេះត្រូវតែបានបញ្ចាក់ជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ។ កាលបរិច្ឆេទដែលក្នុងនោះប្រតិបត្តិការទទួលទិញវិញត្រូវបានចរចានិងសម្រេច គឺជាកាលបរិច្ឆេទនៃប្រតិបត្តិការ (Transaction Date)។

ភាគីទាំងពីរត្រូវត្រួតពិនិត្យឱ្យបានលឿនបំផុតលើការបញ្ជាក់ ដែលចេញដោយភាគីម្ខាងទៀតដើម្បីរកឱ្យឃើញនូវភាពខុសគ្នា និងកំហុសជាសក្តានុពល។ ភាគីទាំងពីរប្តេជ្ញាដោះស្រាយភាពខុសគ្នានិងកំហុសទាំងនោះជាបន្ទាន់ ដោយសុចរិតនិងមិត្តភាព។ ភាគីដែលចេញការបញ្ជាក់ខុសត្រូវតែចេញការបញ្ជាក់ថ្មីឡើងវិញភ្លាម ក្នុងករណីដែលបញ្ហាអាចត្រូវបានដោះស្រាយដោយភាគីទាំងពីរ។ ដើម្បីសម្រួលដល់ការដោះស្រាយទំនាស់ ភាគីទាំងពីរប្តេជ្ញានឹងផ្តល់និងផ្លាស់ប្តូរគ្រប់មធ្យោបាយជាភស្តុតាងទាំងអស់ដូចជា សក្ខីបត្រជួញដូរ កំណត់ត្រា ការថតសម្លេង បញ្ជារបស់ការិយាល័យជួរមុខចេញឱ្យទៅការិយាល័យជួរក្រោយ និងឯកសារផ្សេងៗទៀតដែលយល់ថាចាំបាច់។

ភាគីទាំងពីរចាត់ទុកថា រាល់ប្រតិបត្តិការទទួលទិញវិញត្រូវតែស្ថិតនៅក្រោមកិច្ចសន្យាមេលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ រាល់ប្រតិបត្តិការទទួលទិញវិញរវាងភាគីទាំងពីរត្រូវចាត់ទុកថាជាសមាសធាតុនៃសំណុំប្រតិបត្តិការដែលត្រូវតែបានទូទាត់សរុប នៅក្នុងករណីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ និងដើម្បីគណនាចំនួនបំណុលសុទ្ធសរុប ក្នុងគោលបំណងកំណត់នូវសមតុល្យចុងក្រោយដែលភាគីមួយជំពាក់ភាគីមួយទៀត។

ប្រការ ៦.- ការប្រគល់និងការផ្ទេរ មូលបត្រ

ចាប់ពីថ្ងៃទិញរហូតដល់កាលវសាន ភាគីឱ្យខ្ចីប្រាក់ត្រូវបានចាត់ទុកថាជាម្ចាស់កម្មសិទ្ធិតែមួយគត់នៃមូលបត្រដែលត្រូវបានលក់ឱ្យខ្លួន ដែលជាកម្មសិទ្ធិគ្មានការរារាំងលើមូលបត្រដែលបានទិញ។ ជាវិធានទូទៅ ភាគីខ្ចីប្រាក់ត្រូវផ្ទេរមូលបត្រទៅក្នុងគណនីថែរក្សាមូលបត្ររបស់ភាគីឱ្យខ្ចីប្រាក់ ឬទៅក្នុងគណនីផ្សេងទៀតដែលកំណត់ដោយភាគីឱ្យខ្ចីប្រាក់។

នៅកាលវសាន ភាគីឱ្យខ្ចីប្រាក់ត្រូវប្រគល់មូលបត្រទៅឱ្យភាគីខ្ចីប្រាក់វិញ រីឯភាគីខ្ចីប្រាក់ត្រូវទូទាត់សងនូវចំនួនប្រាក់ថ្លៃទិញវិញដូចដែលបានព្រមព្រៀង រួមទាំងការប្រាក់បង្គរក្នុងអំឡុងពេលធ្វើប្រតិបត្តិការទៅភាគីឱ្យខ្ចីប្រាក់។

ភាគីទាំងពីរអាចព្រមព្រៀងថា មូលបត្រមិនចាំបាច់ផ្ទេរទៅឱ្យភាគីឱ្យខ្ចីក៏បាន។ ក្នុងកាលៈទេសៈនេះ ភាគីខ្ចីប្រាក់អាចដើរតួជាអ្នកថែរក្សាមូលបត្រជំនួសភាគីឱ្យខ្ចីប្រាក់ ឬភាគីទិញមូលបត្រ។ ប៉ុន្តែ ការផ្ទេរកម្មសិទ្ធិត្រូវតែកត់ត្រានៅក្នុងបញ្ជីរបស់ភាគីខ្ចីប្រាក់ឬភាគីលក់មូលបត្រ និងកត់ត្រា

ផងដែរនៅក្នុងបញ្ជីរបស់ភាគីឱ្យខ្ចីឬភាគីទិញមូលបត្រ។ លើសពីនេះ ការសន្យាថាទិញមកវិញឬលក់ទៅវិញ នូវមូលបត្រត្រូវតែកត់ត្រាក្នុងខ្នង់ក្រៅតារាងតុល្យការ តាមថ្លៃទិញនិងលក់វិញដែលបានព្រមព្រៀង។

ក្នុងនាមជាអ្នកថែរក្សាមូលបត្រឱ្យភាគីឱ្យខ្ចីប្រាក់ ភាគីខ្ចីប្រាក់ត្រូវបានហាមឃាត់មិនឱ្យលក់មូលបត្រនោះម្តងទៀត ដោយគ្មានការព្រមព្រៀងជាមុនជាមួយភាគីឱ្យខ្ចីប្រាក់ ក្នុងការជំនួសមូលបត្រនោះឡើយ។ ក្នុងអំឡុងពេលនៃប្រតិបត្តិការទទួលទិញវិញ ភាគីឱ្យខ្ចីប្រាក់អាចទាមទារឱ្យប្រគល់មូលបត្រនៅពេលណាក៏បាន ដោយជូនដំណឹងអំពីការទាមទារនោះ និងផ្តល់បញ្ជាច្បាស់លាស់អំពីគណនីដែលមូលបត្រនោះត្រូវផ្ទេរចូល។

ប្រការ ៧.- ការមិនទូទាត់ ការមិនប្រគល់ ការប្រគល់ទល់នឹងការទូទាត់ ការពិន័យតាមកិច្ចសន្យា

ភាគីទាំងពីរអាចព្រមព្រៀងគ្នាប្រើប្រាស់សេវាប្រគល់ទល់នឹងការទូទាត់នៅទីកន្លែង និងនៅពេលណាដែលមានសេវានោះ ដើម្បីការពារហានិភ័យនៃការប្រគល់ឬការទូទាត់។

រាល់ការមិនទូទាត់ ឬមិនប្រគល់មូលបត្រឱ្យទាន់ពេល និងអនុលោមតាមលក្ខខណ្ឌដែលបានព្រមព្រៀងពីមុន ឬសេចក្តីជូនដំណឹងសុំឱ្យប្រគល់ ត្រូវបានចាត់ទុកថាជាហេតុការណ៍នៃការខកខាន។ ហេតុការណ៍នៃការខកខានណាមួយនឹងនាំទៅដល់ការបញ្ចប់មុនកាលកំណត់នូវរាល់ប្រតិបត្តិការទទួលទិញវិញដែលស្ថិតក្រោមកិច្ចសន្យាមេ ហើយនឹងនាំដល់ការវាយតម្លៃឡើងវិញនូវប្រតិបត្តិការទាំងអស់នៅថ្ងៃដែលខកខាន ដើម្បីកំណត់ចំនួនសមតុល្យសុទ្ធចុងក្រោយ ដែលត្រូវទូទាត់មធ្យោបាយសមស្របណាមួយដែលអាចធ្វើទៅបាន រួមទាំងមធ្យោបាយទាមទារបំណុលមុនពេលដំណើរការក្ស័យធននៅតុលាការ។

ក៏ប៉ុន្តែ បើការមិនទូទាត់ ឬការមិនប្រគល់មូលបត្រកើតឡើងពីកំហុស ឬការភាន់ច្រឡំណាមួយ ភាគីទាំងពីរត្រូវធ្វើការស្រាវជ្រាវជាបន្ទាន់ ដើម្បីរកមូលហេតុនៃការខកខាននោះ និងដោះស្រាយបញ្ចប់បញ្ហាដោយធ្វើការទូទាត់ ឬការប្រគល់ភ្លាម។ ភាគីដើមហេតុ នៃការខកខាន ត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីម្ខាងទៀត បញ្ជាក់អំពីមូលហេតុនៃការខកខាន និងផ្តល់ព័ត៌មានអំពីថ្ងៃប្រសិទ្ធភាពនៃការទូទាត់ ឬការប្រគល់មូលបត្រ។

នៅពេលដែលការខកខានដែលបណ្តាលមកពីបញ្ហាប្រតិបត្តិការបង្កឱ្យមានការយឺតយ៉ាវ និងការខាតបង់ខាងហិរញ្ញវត្ថុជាបន្តបន្ទាប់ ឬថ្លៃឱកាស ភាគីទាំងពីរត្រូវប្រឹងប្រែងដោះស្រាយបញ្ហា និងព្រមព្រៀងគ្នាលើការពិន័យសមស្រប សំដៅទូទាត់សងការខូចខាតដែលកើតឡើងចំពោះភាគីណាមួយ។

ភាគីទាំងពីរអាចគិតទុកមុននូវការពិន័យដែលត្រូវសងគ្នាទៅវិញទៅមកនៅក្នុងកិច្ចសន្យាបំពេញបន្ថែម ក្នុងករណីការខកខានបណ្តាលមកពីបញ្ហាប្រតិបត្តិការដោយមិនគិតដល់បញ្ហាអសាធនភាព ឬសាច់ប្រាក់ងាយស្រួល ដែលភាគីណាមួយជួបប្រទះ។

ប្រការ ៨.- ការគោរពជាន់ហានិភ័យឥណទាន ឬ ហានិភ័យគូភាគី ម៉ាជីន (Margins) ហ៊ែរខាត់ (Haircuts) ខាសម៉ាជីន (Cash Margins) ម៉ាជីនខល (Margin Calls)

ដោយមូលបត្រជាកម្មវត្ថុនៃហានិភ័យថ្លៃ តម្លៃនៃមូលបត្រដែលបានលក់អាចនឹងប្រែប្រួលក្នុងអំឡុងពេលធ្វើប្រតិបត្តិការទទួលទិញវិញ ដែលបណ្តាលឱ្យមានការប្រែប្រួលនូវស្ថានភាពហានិភ័យឥណទានឬហានិភ័យគូភាគី។

ដើម្បីកាត់បន្ថយជាអតិបរមានូវហានិភ័យនៃការខាតបង់ខាងសេដ្ឋកិច្ចលើប្រាក់ដើម ក្នុងករណីដែលមានហេតុការណ៍នៃការខកខាន ភាគីទាំងពីរព្រមព្រៀងគ្នាប្រើប្រាស់នូវដំណើរការកាត់បន្ថយហានិភ័យដោយផ្ទេរម៉ាជីន ហ៊ែរខាត់ ខាសម៉ាជីន ម៉ាយជីនខល និងធ្វើសំវិធានធនមូលបត្របន្ថែមដែលតម្រូវដោយការកែតម្រូវហ៊ែរខាត់ ដូចមានចែងក្នុងប្រការ ១ នៃកិច្ចសន្យាមេនេះ។

មុននឹងធ្វើប្រតិបត្តិការទទួលទិញវិញ ភាគីទាំងពីរត្រូវព្រមព្រៀងគ្នាលើលក្ខខណ្ឌ វិធីសាស្ត្រកំណត់ថ្លៃ ថ្លៃគោល ឬការកំណត់តម្លៃ (Quotation) ភាពញឹកញាប់ (Frequency) កម្រិតកំណត់ (Threshold) ជំរុញប្រសិទ្ធភាពទូទាត់នៃម៉ាជីនខល និងធាតុសំខាន់ៗដទៃទៀត ក្នុងគោលបំណងគ្រប់គ្រងប្រតិបត្តិការការព្រមព្រៀង និងការបញ្ជាក់ចាំបាច់ក្នុងការអនុវត្តគោលដៅកាត់បន្ថយហានិភ័យប្រកបដោយប្រសិទ្ធភាព។

តម្លៃសេដ្ឋកិច្ចរបស់ប្រតិបត្តិការទទួលទិញវិញដែលស្ថិតក្រោមកិច្ចសន្យាមេ ត្រូវតែបានកំណត់មួយៗដោយឡែកពីគ្នា និងត្រូវតែបានព្រមព្រៀងដោយភាគីទាំងពីរ។ ចំនួននៃម៉ាជីនចុងក្រោយ ត្រូវបានកំណត់ដោយបូកសរុបនូវតម្លៃអវិជ្ជមាន និងតម្លៃសេដ្ឋកិច្ចរបស់ប្រតិបត្តិការនីមួយៗ ដើម្បីទទួលបាននូវចំនួនតែមួយចុងក្រោយ ដែលត្រូវទូទាត់តាមរយៈម៉ាជីនបន្ថែមក្នុងទម្រង់ជាការលក់មូលបត្របន្ថែម ឬការទូទាត់ជាខាសម៉ាជីន។

ភាគីទាំងពីរអាចព្រមព្រៀងគ្នាលើកម្រិតកំណត់នៅក្នុងកិច្ចសន្យា បើហួសកម្រិតកំណត់នេះ ភាគីទាំងពីរនឹងជំរុញការទូទាត់ប្រកបដោយប្រសិទ្ធភាពនូវម៉ាជីនខល។

ការខកខានមិនបានទូទាត់ខាសម៉ាជីន ឬការប្រគល់មូលបត្របន្ថែម ដោយយោងទៅលើការកែតម្រូវនៃខាសម៉ាជីន និង/ឬ ម៉ាជីនមូលបត្រឱ្យទាន់ពេល ដោយអនុលោមតាមលក្ខខណ្ឌ ដែលបានព្រមព្រៀងពីមុន ឬសេចក្តីជូនដំណឹងសុំឱ្យប្រគល់ ត្រូវបានចាត់ទុកថាជាហេតុការណ៍ខកខាន។

ក៏ប៉ុន្តែ បើការមិនទូទាត់ ឬការមិនប្រគល់មូលបត្រកើតឡើងពីកំហុស ឬការភាន់ច្រឡំណាមួយ ភាគីទាំងពីរត្រូវធ្វើការស្រាវជ្រាវជាបន្ទាន់ ដើម្បីរកមូលហេតុនៃការខកខាននោះ និងដោះស្រាយបញ្ចប់បញ្ហាដោយធ្វើការទូទាត់ ឬការប្រគល់ភ្លាម។ ភាគីដើមហេតុនៃការខកខានត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីម្ខាងទៀត បញ្ជាក់អំពីមូលហេតុនៃការខកខាន និងផ្តល់ព័ត៌មានអំពីថ្ងៃប្រសិទ្ធភាពនៃការទូទាត់ ឬការប្រគល់មូលបត្រ។

ភាគីទាំងពីរអាចគិតទុកមុននូវការពិន័យដែលត្រូវសងគ្នាទៅវិញទៅមកនៅក្នុងកិច្ចសន្យាបំពេញបន្ថែម ក្នុងករណីការខកខានបណ្តាលមកពីបញ្ហាប្រតិបត្តិការ ដោយមិនគិតដល់បញ្ហាអសាធនភាព ឬសាច់ប្រាក់ងាយស្រួល ដែលភាគីណាមួយជួបប្រទះ។

ប្រការ ៩.- អត្រាការប្រាក់តាមកិច្ចសន្យា / រូបិយប័ណ្ណគោល

ចំពោះប្រតិបត្តិការទទួលទិញវិញនីមួយៗដែលស្ថិតនៅក្រោមវិធានកិច្ចសន្យាមេ ភាគីទាំងពីរត្រូវកំណត់អត្រាការប្រាក់ដែលត្រូវអនុវត្តក្នុងប្រតិបត្តិការនោះ ដោយផ្អែកទៅលើកាលវិសាន ចរិតលក្ខណៈ និងគុណភាពរបស់មូលបត្រដែលបានលក់ ដើម្បីធានាដល់ប្រតិបត្តិការ និងលក្ខខណ្ឌទូទៅនៃទីផ្សារ។

លើសពីនេះ ភាគីទាំងពីរត្រូវកំណត់អត្រាគោល ដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តសងវិញចំពោះសាច់ប្រាក់ងាយស្រួលដែលមានតាមរយៈការទូទាត់សងខាសម៉ាជីន។

ក្នុងករណីដែលភាគីទាំងពីរមានបំណងធ្វើប្រតិបត្តិការដោយប្រើប្រាស់រូបិយប័ណ្ណច្រើនប្រភេទ និងសម្រេចធ្វើប្រតិបត្តិការទទួលទិញវិញ ទោះបីមានរូបិយប័ណ្ណដែលបានព្រមព្រៀងពីមុនមកក្តី ភាគីទាំងពីរត្រូវកំណត់រូបិយប័ណ្ណគោល ដូចមានចែងក្នុងប្រការ ១ នៃកិច្ចសន្យាមេ។ រូបិយប័ណ្ណគោលនោះត្រូវយកទៅប្រើដើម្បីកំណត់សមតុល្យជាត់ទាត់សុទ្ធចុងក្រោយ ក្នុងករណីដែលមានការបញ្ចប់ប្រតិបត្តិការមុនកាលកំណត់ដែលបង្កឡើងដោយហេតុការណ៍ខកខាន។

ប្រការ ១០.- សុពលភាពនៃកិច្ចសន្យាមេ / កិច្ចសន្យាបំពេញបន្ថែម

កិច្ចសន្យាមេត្រូវតែគ្រប់គ្រងលើប្រតិបត្តិការទទួលទិញវិញទាំងអស់ ដែលត្រូវបានធ្វើឡើងរវាងភាគីទាំងពីរ។ កិច្ចសន្យាមេត្រូវតែមានប្រសិទ្ធភាពរហូតដល់ភាគីទាំងពីរសម្រេចបញ្ចប់។ ប៉ុន្តែការបញ្ចប់កិច្ចសន្យាមេនោះត្រូវចូលជាធរមាន ក្រោយពីមានការពន្យារពេលសមស្របយ៉ាងតិចបំផុត ៥ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីមានហេតុការណ៍ខកខានកើតឡើងក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាមេ កិច្ចសន្យានេះនឹងនៅតែមានសុពលភាពលើប្រតិបត្តិការទទួលទិញវិញដែលបានចាប់ផ្តើមអនុវត្តរួចហើយ ក៏ប៉ុន្តែមិនអនុវត្តលើប្រតិបត្តិការទទួលទិញវិញដែលកើតឡើងក្រោយពីថ្ងៃនៃហេតុការណ៍ខកខានជាពិសេស ក្នុងអំឡុងពេលនៃការអភិបាលបណ្តោះអាសន្ននៃភាគីណាមួយ។

ប្រការ ១១.- ការសន្យា

ភាគីទាំងពីរអាចបន្ថែម ឬបញ្ជាក់ឱ្យច្បាស់នូវកិច្ចសន្យាមេ ដោយការចុះហត្ថលេខាលើកិច្ចសន្យាបំពេញបន្ថែម។ ខចែងក្នុងកិច្ចសន្យាបំពេញបន្ថែមត្រូវតែបានអនុវត្តជាអាទិភាព ដោយសារតែខចែងក្នុងកិច្ចសន្យានេះ គ្របដណ្តប់លើបញ្ហាតិទូទៅនៃកិច្ចសន្យាមេ។ ក៏ប៉ុន្តែកិច្ចសន្យាបំពេញបន្ថែមនេះត្រូវតែអនុលោមតាមគោលការណ៍ទូទៅ ដែលចែងក្នុងកិច្ចសន្យាមេ។

- ☐ ភាគីទាំងពីរព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាបំពេញបន្ថែមភ្ជាប់ជាមួយកិច្ចសន្យាមេ។
  .....
  .....
- ☐ ភាគីទាំងពីរព្រមព្រៀងថា មិនបំពេញបន្ថែមកិច្ចសន្យាមេដោយការសន្យា ហើយសម្រេចដោះស្រាយរាល់បញ្ហាសក្តានុពលដែលកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា។

នៅពេលដែលការអនុវត្តកិច្ចសន្យាបំពេញបន្ថែមដែលបានចុះហត្ថលេខា បង្កើតឱ្យមានការបកស្រាយផ្សេងៗគ្នា ឬវិវាទ ភាគីទាំងពីរយល់ព្រមថា ការបកស្រាយទាំងនេះត្រូវតែធ្វើតាមគោលការណ៍នៃកិច្ចសន្យាមេ ហើយអនុលោមយ៉ាងពេញលេញតាមគោលការណ៍ទូទៅដែលបានចែង ជាពិសេសគោលការណ៍ដែលបានលើកឡើងក្នុងប្រការ ១។

ប្រការ ១២.- ការជាក់ឱ្យអនុវត្ត និងប្រសិទ្ធភាព

កិច្ចសន្យាមេ ត្រូវមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ។ រាល់ប្រតិបត្តិការទទួលទិញវិញដែលធ្វើឡើងរវាងភាគីទាំងពីរ ត្រូវស្ថិតនៅក្រោមកិច្ចសន្យាមេ ចាប់ពីថ្ងៃចុះហត្ថលេខាលើកលែងតែប្រតិបត្តិការទទួលទិញវិញណា ដែលមិនត្រូវបានរាប់បញ្ចូលយ៉ាងជាក់លាក់នៅក្រោមកិច្ចសន្យាមេ ដែលចាំបាច់ត្រូវមានការបញ្ជាក់ពីភាគីទាំងពីរ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

ភាគី ខ	ភាគី ក
តំណាងដោយ	តំណាងដោយ

ប្រកាស
ស្តីពី
ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

ប្រការ ១.- គោលបំណង

ធនាគារជាតិនៃកម្ពុជាចេញផ្សាយមូលបត្រអាចជួញដូរបានក្នុងគោលបំណងដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងការផ្តល់ឥណទានអន្តរធនាគារ ផ្អែកលើមូលដ្ឋានសុវត្ថិភាព ដោយមូលបត្រដែលត្រូវបានចេញផ្សាយអាចយកមកប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់ប្រតិបត្តិការ ទទួលទិញវិញ (Repo)។
- ផ្តល់ឱ្យអ្នកចូលរួមក្នុងទីផ្សារនូវជម្រើសទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលមួយទៀតបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា និង
- បង្កើតឧបករណ៍បន្ថែមក្នុងគោលដៅជួយគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

នៅពេលមានការស្នើសុំពីអ្នកកាន់មូលបត្រនឹងអាចត្រូវផ្ទេរទៅឱ្យអ្នកចូលរួមក្នុងទីផ្សារណាមួយផ្សេងទៀតបាន លុះត្រាតែអ្នកទទួលមូលបត្របានបើកគណនីបញ្ញើសាច់ប្រាក់ និងគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃកម្ពុជាដែលមានតួនាទីជាអ្នកថែរក្សាមូលបត្រដែលខ្លួនបានចេញផ្សាយ។

ប្រការ ២.- លក្ខណៈនិងប្រភេទមូលបត្រដែលបានចេញផ្សាយ

១- មូលបត្រនឹងត្រូវបានចេញផ្សាយតាមសំណើរបស់អ្នកទិញ ដូចជាប្រាក់បញ្ញើមានកាលកំណត់ដែលដាក់ធ្វើនៅធនាគារជាតិនៃកម្ពុជាដែរ។ មូលបត្រដែលបានចេញផ្សាយនឹងទទួលបានអត្រាការប្រាក់ថេរដែល កំណត់ដោយធនាគារជាតិនៃកម្ពុជានៅពេលមានការបញ្ជាទិញ។ ការប្រាក់នឹងត្រូវបានបង្គរតាមមូលដ្ឋានចំនួនថ្ងៃ ជាក់ស្តែងនៃឆ្នាំនីមួយៗ។ គូប៉ុង (Coupon) ដែលត្រូវបានគិតបង្គរតាមអាយុកាលនៃមូលបត្រនឹងត្រូវបានទូទាត់ សងរួមគ្នាជាមួយតម្លៃចារឹករបស់មូលបត្រនៅកាលវសានទៅឱ្យអ្នកកាន់មូលបត្រ ដូចបានកំណត់ក្នុងប្រការ ៦.២ នៃប្រកាសនេះ។

២- មូលបត្រត្រូវបានចេញផ្សាយជាអរូបិយ (Dematerialize) ដូច្នេះត្រូវតែបានដាក់ធ្វើក្នុងគណនីបញ្ញើមូលបត្រដែលបើកដោយអ្នកទិញនៅធនាគារជាតិនៃកម្ពុជាមុនពេលបញ្ជាទិញ។ គំរូហត្ថលេខាអ្នកមានសិទ្ធិសម្រាប់ការទិញ និងការផ្ទេរមូលបត្រត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា។

៣- ការទិញនឹងត្រូវបានបញ្ជាក់ដោយធនាគារជាតិនៃកម្ពុជា។ ការកាន់កាប់មូលបត្រនេះត្រូវបានបង្ហាញដោយទៀងទាត់ផងដែរនៅក្នុងរបាយការណ៍គណនីមូលបត្រ។

៤- មូលបត្ររបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវបានចេញផ្សាយជារូបិយវត្ថុជាតិ និងជារូបិយប័ណ្ណ។ មូលបត្រទាំងនេះ នឹងត្រូវបានសម្គាល់ដោយលេខមាលាមូលបត្រ និងលេខសម្គាល់អត្តសញ្ញាណនៅក្នុងលេខមាលានេះមានដូចជា តម្លៃចារឹករូបិយប័ណ្ណ អត្រាការប្រាក់ និងកាលវសាន។

៥- (ត្រូវបានជំនួសដោយប្រកាសលេខ ធ៥-០១៧-១៤៨ ប្រ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ស្តីពី ការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា។)

ចំណុច ៥ ថ្មី ចែងដូចខាងក្រោម៖

មូលបត្រអាចជួញដូរបានមានឥណប្រតិទានគិតជាថ្ងៃលើមូលដ្ឋានសប្តាហ៍ ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ។ ឥណប្រតិទានអាចនឹងត្រូវបានកែតម្រូវដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃបញ្ជាទិញ ក្នុងករណីដែលឥណប្រតិទាននេះត្រូវចំថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

ប្រការ ៣.- ការថែរក្សា និងការចុះបញ្ជីមូលបត្រ

១- ដូចបានចែងក្នុងប្រការ ២ កថាខណ្ឌ ២ ខាងលើ មូលបត្រត្រូវចេញផ្សាយជាអរូបិយ (Dematerialize)។ មូលបត្រទាំងនេះ ចាំបាច់ត្រូវដាក់ធ្វើក្នុងគណនីបញ្ជីមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

២- បែបបទនៃការចុះបញ្ជី និងការផ្ទេរកម្មសិទ្ធិមូលបត្រត្រូវធ្វើដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.- ម្ចាស់កម្មសិទ្ធិលើមូលបត្រ

១- កម្មសិទ្ធិលើមូលបត្រអរូបិយ (Dematerialize) ត្រូវបានបញ្ជាក់ជាភស្តុតាងដោយការធ្វើលេខាចារឹកដោយទៀងទាត់នៅក្នុងគណនីបញ្ជីមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកចេញផ្សាយ និងជាអ្នកថែរក្សាមូលបត្រ។

ដូច្នេះ រាល់ការផ្លាស់ប្តូរកម្មសិទ្ធិចាំបាច់ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីបញ្ជាក់លើការផ្ទេរកម្មសិទ្ធិនេះឱ្យទៅអ្នកលក់និងអ្នកទិញមូលបត្រ។

២- ការបញ្ជាក់របស់ធនាគារជាតិនៃកម្ពុជា ទៅឱ្យអ្នកទិញតែម្ខាងមិនមែននិងមិនអាចចាត់ទុកជាប័ណ្ណសម្គាល់កម្មសិទ្ធិអាចជួញដូរបាននោះទេ និងដូចនេះអ្នកចូលរួមក្នុងទីផ្សារ មិនអាចធ្វើបិដ្ឋិលេខដើម្បីផ្ទេរកម្មសិទ្ធិមូលបត្រទាំងនោះបានឡើយ។

ការផ្ទេរកម្មសិទ្ធិនេះ អាចធ្វើឡើងស្របច្បាប់បានលុះត្រាតែធនាគារជាតិនៃកម្ពុជា ទទួលបានបញ្ជាពីភាគីទាំងពីរ ក្នុងការធ្វើប្រតិបត្តិការទិញ-លក់ផ្តាច់ ឬប្រតិបត្តិការដាក់វត្ថុធានា ជាពិសេសក្នុងទម្រង់ជាប្រតិបត្តិការទទួលទិញវិញ ឬដាក់បញ្ចាំជាវត្ថុធានាតែប៉ុណ្ណោះ។

ប្រការ ៥.- ប្រតិបត្តិការទទួលទិញវិញ (Repo)

១- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានទទួលយកសម្រាប់ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ។ ក៏ប៉ុន្តែ ដើម្បីធានាសុវត្ថិភាពតាមកិច្ចសន្យា និងតាមផ្លូវច្បាប់សម្រាប់ប្រតិបត្តិការទាំងនោះ អ្នកចូលរួមក្នុងទីផ្សារទាំងឡាយត្រូវតែចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា។

២- ជាគោលការណ៍ ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ ត្រូវរួមបញ្ចូលនូវដំណាក់កាលពេញលេញដែលអនុវត្តដោយភាគីទាំងពីរ ក្នុងការបញ្ជូនមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិនៃមូលបត្រដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញ។

៣- ចំពោះប្រតិបត្តិការដែលមានរយៈពេលខ្លី ភាគីនៃកិច្ចសន្យាអាចមិនចាំបាច់បញ្ជូនមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិមូលបត្រដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញនោះឡើយ។ ក្នុងករណីនេះ អ្នកលក់មូលបត្រ (ភាគីខ្វីប្រាក់) ត្រូវតែដើរតួជាអ្នកថែរក្សាមូលបត្របន្ទាប់ឱ្យអ្នកទិញមូលបត្រ (ភាគីឱ្យខ្វីប្រាក់) និងចុះបញ្ជិកាគណនេយ្យជាបន្តបន្ទាប់ដើម្បីជាភស្តុតាងនៃការផ្ទេរកម្មសិទ្ធិ។

៤- ប្រតិបត្តិការទទួលទិញវិញអាចធ្វើបានដោយប្រើរូបិយប័ណ្ណខុសៗគ្នា យោងតាមកិច្ចសន្យាទ្វេភាគីរបស់ភាគីទាំងពីរ។ ក្នុងករណីនេះ ភាគីខ្វីប្រាក់ជាអ្នកទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់ (អ្នកលក់មូលបត្រសន្យាថានឹងទិញមូលបត្រវិញតាមតម្លៃដែលបានព្រមព្រៀងទុកជាមុន)។ លើសពីនេះ ភាគីដែលទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញ និងទទួលបន្ថែមម៉ាជីនខសសាច់ប្រាក់ (Cash Margin Calls) ប្រសិនបើចាំបាច់។

ប្រការ ៦ .- ការបញ្ជាក់ និងការបញ្ជាផ្ទេរ

១- ការបញ្ជាក់លើការទិញ ដោយធនាគារជាតិនៃកម្ពុជា មិនរួមបញ្ចូលកម្មសិទ្ធិភាពលើមូលបត្រ ដែលបានទិញនោះទេ។ ដូច្នេះការបញ្ជាក់នេះ មិនអាចចាត់ទុកជាវិញ្ញាបនបត្រ ដែលអាចធ្វើបិដ្ឋិលេខដោយអ្នកចូលរួមទីផ្សារ ព្រោះថាការធ្វើបិដ្ឋិលេខនោះនឹងមិនរួមបញ្ចូលសិទ្ធិកាន់កាប់លើមូលបត្រនោះឡើយ។

២- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ជាមូលបត្រអរូបិយ (Dematerialize) ភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ គឺជាលទ្ធផលនៃការធ្វើលេខាចារឹកដោយទៀងទាត់លើមូលបត្រទាំងនោះនៅក្នុង គណនីបញ្ជើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ នៅកាលវសានតម្លៃចារឹកនៃមូលបត្រ និងគូប៉ុងដែលបានបង្គរ ត្រូវបានផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធជាមួយគណនីបញ្ជើមូលបត្រនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកចូលរួមទីផ្សារមានបំណងវិនិយោគឡើងវិញនូវចំនួនប្រាក់ទាំងអស់ ឬមួយផ្នែកនៃចំនួនប្រាក់ដែលបានទទួលអ្នកចូលរួមនោះត្រូវផ្តល់បញ្ជាទៅធនាគារជាតិនៃកម្ពុជាឱ្យបានមុនកាលវសានចំនួនពីរថ្ងៃនៃថ្ងៃធ្វើការ។

៣- នៅពេលចេញផ្សាយមូលបត្រ ក្រោយពីទទួលបានបញ្ជាទិញជាលាយលក្ខណ៍អក្សរដែលចុះហត្ថលេខាដោយអ្នកទទួលសិទ្ធិ ធនាគារជាតិនៃកម្ពុជានឹងចុះឥណពន្ធក្នុងគណនីចរន្តដោយស្វ័យប្រវត្តិនិងចុះឥណទានគណនីបញ្ជើមូលបត្រដែលពាក់ព័ន្ធរបស់អ្នកកាន់កាប់មូលបត្រនៅថ្ងៃប្រសិទ្ធភាពដែលកំណត់នៅលើបញ្ជាទិញ។ អ្នកទិញ និងអ្នកចូលរួមដេញថ្លៃត្រូវធានាថាមានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនីដើម្បីទូទាត់សងថ្លៃមូលបត្រដែលបានទិញ ឬដេញថ្លៃបាន។

៤- ដើម្បីអនុវត្តការផ្ទេរកម្មសិទ្ធិមូលបត្រដែលត្រូវបានលក់និងទិញយកវិញ តាមរយៈប្រតិបត្តិការទទួលទិញវិញ ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យភាគីទាំងពីរបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរដោយឡែកពីគ្នាទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនោះ។ ដើម្បីចៀសវាងការយឺតយ៉ាវ ភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ឱ្យគ្នាទៅវិញទៅមកនូវបញ្ជារបស់ខ្លួន ហើយត្រូវធានាថាការបញ្ជាក់ទាំងនោះមានខ្លឹមសារស្របគ្នាទាំងស្រុង។

៥- ក្នុងដំណើរការនៃប្រតិបត្តិការទទួលទិញវិញ ទោះបីភាគីទាំងពីរយល់ព្រមទូទាត់ម៉ាជីនជាសាច់ប្រាក់ ឬដាក់បន្ថែមម៉ាជីនជាមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរ ដែលមានខ្លឹមសារស្របគ្នាទៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលបានចែងក្នុងកថាខណ្ឌទី ៤ ខាងលើ។

៦- ទោះបីជាភាគីទាំងពីរសម្រេចចិត្តទិញលក់ផ្តាច់ជាមួយគ្នានូវមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាទៅធនាគារជាតិនៃកម្ពុជា ទាំងការផ្ទេរមូលបត្រដែលបានទិញ ឬលក់នោះផង និងការទូទាត់សាច់ប្រាក់ ដោយបញ្ជាក់អំពីថ្ងៃប្រសិទ្ធភាព និងចំនួនប្រាក់ដែលត្រូវបានទូទាត់សងផងដែរ។ ចរិតលក្ខណៈនៃមូលបត្រដែលត្រូវបានទិញ ឬលក់ ត្រូវតែបានបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់ដោយភាគីទាំងពីរនៅលើប្រតិបត្តិការដែលបានធ្វើ។

ប្រការ ៧.- ឥណទានអូវើណាយដែលមានការធានា និងឌីសខោនទិនដូ
(Overnight Secured Facilities and Discount Window)

១- ក្រោមលក្ខខណ្ឌដែលនឹងត្រូវមានចែងក្នុងប្រកាសដោយឡែករបស់ធនាគារជាតិនៃកម្ពុជា មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានប្រើប្រាស់ជាវត្ថុធានាសម្រាប់ការផ្តល់ឥណទានអូវើណាយ (Overnight) ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ឱ្យអ្នកចូលរួមទីផ្សារក្នុងការបំពេញសមតុល្យជាត់ទាត់អវិជ្ជមានរបស់ខ្លួនរយៈពេលមួយថ្ងៃ។ ឥណទាននេះ មិនត្រូវបានចាត់ទុកជាប្រភពទុនអចិន្ត្រៃយ៍របស់សមាជិកសភាជាត់ទាត់ឡើយ ហើយធនាគារជាតិនៃកម្ពុជានឹងផ្តល់ឥណទាននេះតាមអត្រាការប្រាក់ជាកពិន័យ។

២- ឥណទានអូវើណាយ (Overnight) ត្រូវបានធានាដោយមូលបត្រកាន់កាប់ដោយសមាជិកសភាជាត់ទាត់តាមតម្លៃចារឹកសមមូល ឬខ្ពស់ជាងកម្រិតឥណទាន។ ធនាគារជាតិនៃកម្ពុជា នឹងផ្ទេរកម្មសិទ្ធិនៃវត្ថុធានា ក្រោយពីបញ្ជាក់អំពីការផ្តល់ឥណទានអូវើណាយ (Overnight) នោះដល់អត្តគាហក។ ធនាគារជាតិនៃកម្ពុជានឹងសងមូលបត្រត្រឡប់វិញនៅថ្ងៃបន្ទាប់ក្រោយពីគណនីជាត់ទាត់មានសមតុល្យវិជ្ជមានឡើងវិញ។

៣- មូលបត្រដែលកាន់កាប់ដោយអ្នកចូលរួមទីផ្សារអាចប្រើប្រាស់សម្រាប់បំពេញតម្រូវការសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ននិងរយៈពេលខ្លី។ ប្រតិបត្តិការនេះត្រូវតែមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា និងត្រូវបានផ្តល់សម្រាប់ចន្លោះពេលពី ២ថ្ងៃរហូតដល់ ២សប្តាហ៍នៃថ្ងៃធ្វើការ។ ការចូលទៅប្រើឥណទានអប្បហារ នឹងមិនត្រូវបានជំនួសដោយឥណទានវិបារូបន៍ឡើយ ដោយឥណទានទាំងពីរនេះមានលក្ខណៈខុសគ្នា។ ការធ្វើប្រតិបត្តិការអប្បហារ ជាមួយធនាគារជាតិនៃកម្ពុជានឹងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ដែលថាមូលបត្រនោះមានតម្លៃអាចទទួលយកបាន

(អាចជួញដូរបាន)។ បញ្ជីមូលបត្រដែលអាចទទួលយកបានសម្រាប់ធ្វើប្រតិបត្តិការអប្បហារ និង អត្រាអប្បហារ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

៤- ប្រតិបត្តិការដែលដំណើរការក្នុងឱសខោនវីនដូ នឹងត្រូវគាំទ្រដោយកិច្ចសន្យាមេ សម្រាប់ប្រតិបត្តិការទទួលទិញវិញ ដែលចុះហត្ថលេខាដោយធនាគារជាតិនៃកម្ពុជា និងអត្តគាហកមូលបត្រ។ ធនាគារជាតិនៃកម្ពុជានឹងផ្ទេរមូលបត្រ ដែលត្រូវបានជ្រើសរើស និងព្រមទទួលយក នៅថ្ងៃចាប់ផ្តើម និងនៅកាលវសានៃប្រតិបត្តិការ។

ប្រការ ៨.- ប្រតិបត្តិការទីផ្សារចំហ និងការដេញថ្លៃ

១- ទន្ទឹមនឹងការបញ្ជាទិញជាធម្មតានៃមូលបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា តាមអត្រាដែលបានកំណត់ ធនាគារជាតិនៃកម្ពុជា ក៏អាចរៀបចំដាក់ឱ្យដេញថ្លៃមូលបត្រ ដោយការជូនដំណឹងជាមុនតាមចំនួនដែលបានកំណត់ទៅឱ្យអ្នកចូលរួមដេញថ្លៃ។

២- ការដេញថ្លៃនេះ នឹងត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រតិបត្តិការទីផ្សារចំហនិងធ្វើឱ្យសម្រេចគោលដៅនៃគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៩.- អ្នកចូលរួមក្នុងការដេញថ្លៃ និងការអនុវត្តប្រតិបត្តិការទីផ្សារចំហ

១- ការរៀបចំ និងលក្ខខណ្ឌផ្សេងៗសម្រាប់ការចូលរួមដេញថ្លៃ នឹងត្រូវបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងដោយឡែកៗពីគ្នា រៀងរាល់ការដេញថ្លៃនីមួយៗ ដែលនឹងប្រព្រឹត្តទៅតាមការផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីអញ្ជើញអ្នកចូលរួមដូចមានចែងក្នុងកថាខណ្ឌ ២ ខាងក្រោមឱ្យចូលរួមដេញថ្លៃ។

២- ការដេញថ្លៃ នឹងត្រូវអនុញ្ញាតចំពោះអ្នកចូលរួមក្នុងទីផ្សាររូបិយវត្ថុជាប្រក្រតី។ ក៏ប៉ុន្តែធនាគារជាតិនៃកម្ពុជាអាចអនុញ្ញាតឱ្យអ្នកផ្សេងទៀតចូលរួមដេញថ្លៃ ដូចជាអាជីវករប្តូរប្រាក់ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀតជាដើម។ អ្នកដែលត្រូវបានអញ្ជើញឱ្យចូលរួមដេញថ្លៃ ត្រូវមានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃនីមួយៗ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជារួមជាមួយនឹងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ឬសមស្របសម្រាប់ការរៀបចំខ្លួន និងការដាក់ពាក្យសុំចូលដេញថ្លៃ។

ប្រការ ១០.- ការប្រើប្រាស់មូលបត្ររបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ជាវត្ថុធានាក្នុងប្រតិបត្តិការអារេទូទាត់ដុលតាមពេលវេលាពិត (RTGS)

មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា នឹងត្រូវបានទទួលយកជាវត្ថុធានាដើម្បីធានាដំណើរការនៃប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត។ បែបបទបង្កើតឱ្យមានជាប្រក្រតីនូវវត្ថុធានានោះ នឹងត្រូវបានចែងនៅក្នុងបទបញ្ជាស្តីពី ប្រតិបត្តិការប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត។

ប្រការ ១១.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

ទេសាភិបាល

ហត្ថលេខានិងត្រោះ **ជា ចាន់តូ**

ធ៥-០១៤-២៣០ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាជាត់ទាត់ជាតិ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងផ្តល់សន្ទនីយភាពក្នុងរូបភាពឥណទានវិបារូបន៍ ដល់សមាជិកសភាជាត់ទាត់ជាតិ តទៅនេះហៅថា "សមាជិក" ដើម្បីសម្រួលដល់កង្វះសន្ទនីយភាពចាំបាច់សម្រាប់បំពេញកាតព្វកិច្ចទូទាត់ក្នុងថ្ងៃ។

ប្រការ ២.-

ការផ្តល់ឥណទានវិបារូបន៍ មានគោលដៅធានាការទូទាត់នៅក្នុងថ្ងៃឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពខ្ពស់។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសមាជិកដែលមានសាធនភាព។ សមាជិកត្រូវស្នើសុំឥណទានវិបារូបន៍ជាលាយលក្ខណ៍អក្សរទុកជាមុនពីធនាគារជាតិនៃកម្ពុជា ដោយត្រូវបំពេញនូវឯកសារចាំបាច់ដូចខាងក្រោម៖

- លិខិតស្នើសុំឥណទានវិបារូបន៍សម្រាប់រយៈពេលមួយឆ្នាំ
- កិច្ចសន្យាឥណទានវិបារូបន៍ចំពោះសមាជិក
- កិច្ចសន្យាដាក់ធានាលើឥណទានវិបារូបន៍របស់សមាជិក

ប្រការ ៤.-

សមាជិកត្រូវស្នើសុំឥណទានវិបារូបន៍សម្រាប់មួយឆ្នាំម្តង ដោយបង់សោហ៊ុយទម្រង់ការចំនួន ១.០០០.០០០ រៀល (មួយលានរៀល)។

កិច្ចសន្យាឥណទានវិបារូបន៍ និងកិច្ចសន្យាដាក់ធានាឥណទានវិបារូបន៍ មានសុពលភាពបីខែ និងត្រូវស្នើសុំបន្តឡើងវិញរៀងរាល់បីខែម្តង។

ប្រការ ៥.-

សមាជិកអាចស្នើសុំឥណទានវិបារូបន៍យ៉ាងតិចស្មើនឹង ៣០% (សាមសិបភាគរយ) នៃការទូទាត់ដែលខ្ពស់ជាងគេនៅថ្ងៃណាមួយក្នុងរយៈពេលបីខែចុងក្រោយមុនពេលស្នើសុំ។ ទំហំឥណទានវិបារូបន៍ស្មើនឹង ១០០% (មួយរយភាគរយ) នៃតម្លៃដើមនៃវត្ថុធានា។ ការផ្តល់ឥណទានវិបារូបន៍នេះនឹងត្រូវអនុវត្តនៅពេលដែលគណនីទូទាត់មានសមតុល្យមិនគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់ក្នុងថ្ងៃប៉ុណ្ណោះ ដោយសមាជិកត្រូវស្នើសុំផ្ទេរប្រាក់ពីគណនីចរន្តទៅគណនីទូទាត់។

ប្រការ ៦.-

វត្ថុធានាសម្រាប់ឥណទានវិបារូបន៍របស់ធនាគារជាតិនៃកម្ពុជាដែលអាចទទួលបាន រួមមាន វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ និងមូលបត្រអាចជួញដូរបាន (NCD) ចេញផ្សាយដោយ ធនាគារជាតិនៃកម្ពុជា។

វត្ថុធានាត្រូវមានឥណប្រតិទានរែងជាងឥណប្រតិទានរបស់ឥណទានវិបារូបន៍យ៉ាងតិចចំនួន ពីរថ្ងៃនៃថ្ងៃធ្វើការ។

ប្រការ ៧.-

ឥណទានវិបារូបន៍អាចផ្តល់ជូនជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។ ការប្រាក់ត្រូវបានគិត លើចំនួនប្រាក់ដែលបានប្រើប្រាស់ គិតចាប់ពីពេលបានទទួលឥណទាន ក្នុងអត្រាដែលកំណត់ដោយ ធនាគារជាតិនៃកម្ពុជា។

ប្រការ ៨.-

ឥណប្រតិទាននៃការប្រើប្រាស់ឥណទានវិបារូបន៍មានរយៈពេលមួយថ្ងៃ ដោយត្រូវសងវិញ នៅថ្ងៃបន្ទាប់ជាកំហិត។ ករណីថ្ងៃសងវិញត្រូវចំថ្ងៃសៅរ៍ ឬថ្ងៃឈប់សម្រាកបុណ្យជាតិ កម្រៃការប្រាក់ នឹងត្រូវបានគណនាតាមចំនួនថ្ងៃជាក់ស្តែង។

ប្រការ ៩.-

សមាជិកដែលទទួលបានឥណទានវិបារូបន៍ហើយខកខានមិនបានសងនៅថ្ងៃឥណប្រតិទាន នឹងត្រូវរងពិន័យទ្វេដងនៃអត្រាការប្រាក់ដែលបានកំណត់ តាមចំនួនថ្ងៃប្រើប្រាស់ជាក់ស្តែង។

ប្រការ ១០.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១១.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុត នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ច រៀងៗខ្លួន។

ប្រការ ១២.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០១៤-00៤ ស.ក.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤

សេចក្តីណែនាំ

អនុវត្តប្រកាស

ស្តីពី

ការផ្តល់សន្ធនីយភាពចំពោះសមាជិកសភាជាត់ទាត់ជាតិ

ដើម្បីឱ្យការអនុវត្តប្រកាសលេខ ធ៥-០១៤-២៣០ ប្រ.ក ស្តីពី "ការផ្តល់សន្ធនីយភាពចំពោះសមាជិកសភាជាត់ទាត់ជាតិ" ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងបញ្ចៀសបាននូវហានិភ័យជាប្រព័ន្ធ ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់សមាជិកសភាជាត់ទាត់ជាតិទាំងអស់ដូចតទៅ៖

- ត្រូវដាក់ពាក្យស្នើសុំឥណទានវិបារូបន៍ជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជា សម្រាប់រយៈពេលមួយឆ្នាំ ដោយត្រូវបង់សោហ៊ុយទម្រង់ការចំនួន ១.០០០.០០០ រៀល (មួយលានរៀល) សម្រាប់ការស្នើសុំនេះ។
- ការស្នើសុំឥណទានវិបារូបន៍នេះ ត្រូវភ្ជាប់ជាមួយនូវកិច្ចសន្យាតាមគំរូដែលមានស្រាប់ចំនួន ២ (ពីរ) គឺ (១) កិច្ចសន្យាឥណទានវិបារូបន៍ និង (២) កិច្ចសន្យាដាក់ធានាលើឥណទានវិបារូបន៍។ កិច្ចសន្យាទាំងពីរប្រភេទនេះមានសុពលភាពបីខែ នឹងត្រូវធ្វើឡើងវិញរៀងរាល់បីខែ។
- សមាជិកអាចប្រើប្រាស់មូលបត្រអាចជួញដូរបាន (NCD) ឬ/និង វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ចេញដោយធនាគារជាតិនៃកម្ពុជា សម្រាប់ធានាលើឥណទានវិបារូបន៍។ វត្ថុធានាត្រូវមានកាលវសានវែងជាងកាលវសានរបស់ឥណទានវិបារូបន៍យ៉ាងតិចបំផុតពីរថ្ងៃនៃថ្ងៃធ្វើការ។ តម្លៃវត្ថុធានាត្រូវស្មើនឹងទំហំឥណទានវិបារូបន៍។ ក្នុងករណី វត្ថុធានាមានតម្លៃចាំរកជារូបិយប័ណ្ណផ្សេងគ្នាពីរូបិយប័ណ្ណឥណទានវិបារូបន៍ នឹងត្រូវបានគណនាតាមអត្រាប្តូរប្រាក់កំណត់ដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃចុះកិច្ចសន្យាឥណទានវិបារូបន៍។
- អត្រាការប្រាក់ឥណទានវិបារូបន៍នឹងត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយនិងមានចែងលម្អិតក្នុងកិច្ចសន្យាឥណទានវិបារូបន៍។ ការប្រាក់ឥណទានវិបារូបន៍នឹងត្រូវបានគណនាផ្អែកលើទំហំឥណទាន និងចំនួនថ្ងៃដែលប្រើប្រាស់។

សមាជិកដែលមិនអាចអនុវត្តតាមលក្ខខណ្ឌចែងនៃប្រកាសស្តីពី "ការផ្តល់សន្ធនីយភាពចំពោះសមាជិកសភាជាត់ទាត់ជាតិ" នេះ នឹងត្រូវស្នើឱ្យដកខ្លួនចេញពីសមាជិកផ្ទាល់ (Direct member) មកជាសមាជិកមិនផ្ទាល់វិញ (Indirect member) ដោយអនុលោមតាមវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។

សមាជិកទាំងអស់ត្រូវអនុវត្តតាមខ្លឹមសារណែនាំខាងលើនេះជាកំហិត យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ នេះជាដាច់ខាត។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

អគ្គនាយកបច្ចេកទេស

ហត្ថលេខានិងត្រា៖ **ជា សិរី**

ធ៧-០១៥-១៥៣ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់សន្ធនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងបង្កើតយន្តការដោះស្រាយតម្រូវការសន្ធនីយភាពចាំបាច់ ដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅបន្តដំណើរការជាប្រក្រតី។

ប្រការ ២.-

ប្រកាសនេះមានគោលដៅទប់ស្កាត់ហានិភ័យជាប្រព័ន្ធកើតឡើងដោយសារការផ្លាស់ប្តូរស្ថានភាព ឬនិន្នាការទីផ្សារដែលមិនអាចព្យាករណ៍ទុកមុនបាន ដែលនាំឱ្យមានកង្វះសន្ធនីយភាពជាយថាហេតុ។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើពីសាធារណជន និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

គ្រឹះស្ថានត្រូវមានស្ថានភាពដូចខាងក្រោម៖

- មានសាធនភាព មានចំណេញ និងអនុវត្តបានពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន
- មានវត្ថុធានាដែលអាចទទួលយកបានដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវបង្កើតគោលនយោបាយប្រុងប្រយ័ត្ន ដោយកំណត់ឱ្យបានច្បាស់លាស់ពីកម្រិតហានិភ័យសន្ធនីយភាពដែលអាចទទួលយកបាន រៀបចំផែនការបំពេញសន្ធនីយភាព (Contingency Liquidity Plan) ស្របតាមកម្រិតហានិភ័យនោះ និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយ និងផែនការជាប្រចាំដែលឆ្លុះបញ្ចាំងពីស្ថានភាពផ្លាស់ប្តូររបស់ទីផ្សារ។

ការស្នើសុំសន្ធនីយភាពពីធនាគារជាតិនៃកម្ពុជាត្រូវចាត់ទុកថាជាជម្រើសចុងក្រោយរបស់គ្រឹះស្ថាន បន្ទាប់ពីបានប្រើប្រាស់អស់លទ្ធភាពនូវជម្រើសផ្សេងៗទៀត។

ប្រការ ៥.-

សន្ធនីយភាពត្រូវបានផ្តល់ក្នុងកាលៈទេសៈពិសេស ដែលគ្រឹះស្ថានមិនត្រូវចាត់ទុកសន្ធនីយភាពនេះជាការផ្តល់ឥណទានជាលក្ខណៈប្រព័ន្ធឡើយ ហើយមិនត្រូវពឹងផ្អែកទាំងស្រុងទៅលើឥណទានទាំងនេះ ដើម្បីជាមធ្យោបាយគ្រប់គ្រងកង្វះសន្ធនីយភាពឡើយ។ ការផ្តល់សន្ធនីយភាព ត្រូវបានកំណត់ដូចខាងក្រោម៖

(១) សន្ទនីយភាពត្រូវបានផ្តល់ដោយផ្អែកលើវត្ថុធានា

(២) ឥណប្រតិទានរបស់វត្ថុធានាត្រូវតែមានរយៈពេលវែងជាងឥណប្រតិទានរបស់សន្ទនីយភាព

(៣) ធនាគារជាតិនៃកម្ពុជាផ្តល់សន្ទនីយភាពដែលមានឥណប្រតិទានយ៉ាងយូរ៣០ថ្ងៃ។ ក្នុងករណីចាំបាច់ គ្រឹះស្ថានអាចស្នើសុំពន្យារពេលបាន។ ធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យពន្យារពេលត្រឹម ២ លើកប៉ុណ្ណោះ ដែលក្នុង ១ លើកអាចមានរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ

(៤) ធនាគារជាតិនៃកម្ពុជាអាចផ្តល់សន្ទនីយភាពត្រឹមហុកសិបភាគរយ (៦០%) នៃតម្លៃវត្ថុធានា និងអាចបង្កើនឬបន្ថយទៅតាមទំហំហានិភ័យជាក់ស្តែងនៃវត្ថុធានា

(៥) សន្ទនីយភាពមានទំហំខ្ពស់បំផុតត្រឹមហាសិបភាគរយ (៥០%) នៃប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាន

(៦) អត្រាការប្រាក់ត្រូវតែខ្ពស់ជាងអត្រាការប្រាក់នៃសន្ទនីយភាពចំពោះសមាជិកសភាជាត់ទាត់ជាតិ (Standing Liquidity Facilities)។ ការប្រាក់ត្រូវគិតលើមូលដ្ឋានបង្គរប្រចាំថ្ងៃនៃសមតុល្យដក់សល់ ចាប់ពីថ្ងៃទទួលបានសន្ទនីយភាពរហូតដល់ឥណប្រតិទាន។ គ្រឹះស្ថានអាចទូទាត់សងផ្នែកខ្លះ ឬទាំងស្រុងនៃសន្ទនីយភាពមុនឥណប្រតិទាន។ ក្នុងករណីគ្រឹះស្ថានមិនបានទូទាត់សងសន្ទនីយភាពតាមកាលកំណត់ ធនាគារជាតិនៃកម្ពុជានឹងអនុវត្តអត្រាការប្រាក់ពិន័យទៅលើប្រាក់ដើមបូកនឹងមូលធនកម្មការប្រាក់ (Capitalized Interest) រហូតដល់មានការទូទាត់សងទាំងស្រុងនិង/ឬចាត់វិធានការដទៃទៀតតាមច្បាប់ជាធរមាន។

ប្រការ ៦.-

គ្រឹះស្ថានដែលមានតម្រូវការសន្ទនីយភាពត្រូវដាក់ពាក្យស្នើសុំជាមុន ដោយភ្ជាប់មកជាមួយនូវ៖

(១) កិច្ចសន្យាស្នើសុំសន្ទនីយភាព និងកិច្ចសន្យាដាក់វត្ថុធានា

(២) ការវាយតម្លៃស្ថានភាពរួមរបស់គ្រឹះស្ថានដើម្បីបង្ហាញថាគ្រឹះស្ថានកំពុងមានសាធនភាពនិងមានចំណេញ

(៣) ការព្យាករណ៍សន្ទនីយភាពដោយមានសម្មតិកម្មច្បាស់លាស់ និងប៉ាន់ស្មានកាលបរិច្ឆេទកង្វះសន្ទនីយភាពរួមទាំងការសាកល្បងសេណារីយ៉ូ (Stress Test Scenario) ផងដែរ

(៤) ការវិភាគអំពីការផ្លាស់ប្តូរនិន្នាការ និង/ឬស្ថានភាពទីផ្សារដែលអាចប៉ាន់ស្មានបាននូវកង្វះសន្ទនីយភាព

(៥) ផែនការសកម្មភាពដែលអាចទុកចិត្តបានក្នុងការដោះស្រាយកង្វះសន្ទនីយភាពដោយមានការប៉ាន់ស្មាន និងដោយប្រុងប្រយ័ត្ននូវពេលវេលាចាំបាច់សម្រាប់អនុវត្តផែនការសកម្មភាពនោះ និងទូទាត់សងមកវិញនូវសន្ទនីយភាព

(៦) ការព្យាករណ៍អំពីផលប៉ះពាល់និងបច្ច័យដែលអាចកើតមានឡើងក្នុងការអនុវត្តផែនការសកម្មភាពលើលទ្ធភាពចំណេញ (តម្លៃនៃមូលនិធិ ប្រភពផ្សេងទៀតនៃមូលនិធិ ការជម្រះទ្រព្យសកម្ម) និងសាធនភាព។

ធនាគារជាតិនៃកម្ពុជាអាចស្នើសុំព័ត៌មាន ឬទិន្នន័យបន្ថែមទៀតពីគ្រឹះស្ថាន ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ សវនករផ្ទៃក្នុង សវនករឯករាជ្យ បុគ្គល ឬ អង្គភាពផ្សេងទៀត តាមការចាំបាច់។

ប្រការ ៧ .-

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយទម្រង់ការ សូន្យក្បៀសប្រាំភាគរយ (0,៥%) នៃទំហំសន្ទនីយភាព ដែលបានអនុម័ត។

ប្រការ ៨.-

បន្ទាប់ពីទទួលបានសន្ទនីយភាព គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាដូចតទៅ៖

(១) រាល់ព្រឹត្តិការណ៍ដែលកើតមាន និងការផ្លាស់ប្តូរចំណាត់ថ្នាក់ចំពោះវត្ថុធានាដោយមិន កំណត់ត្រឹមតែការមិនសងប្រាក់ ឬការទូទាត់សងមុនកាលកំណត់។ ក្នុងករណីមានការផ្លាស់ប្តូរ គ្រឹះស្ថានត្រូវដាក់សំណើពាក់ព័ន្ធនឹងការដាក់វត្ថុធានាថ្មីជំនួសវត្ថុធានាចាស់

(២) ការវិវត្តនៃការអនុវត្តផែនការសកម្មភាព និងផលប៉ះពាល់លើស្ថានភាពសន្ទនីយភាព របស់គ្រឹះស្ថាន

(៣) ការលំបាកនិងបញ្ហាប្រឈមផ្សេងៗទៀត ដែលអាចកើតមានក្នុងការអនុវត្តផែនការ សកម្មភាព។

ក្នុងករណីមានកង្វះសន្ទនីយភាពកាន់តែធ្ងន់ធ្ងរ គ្រឹះស្ថានត្រូវផ្តល់របាយការណ៍ប្រចាំថ្ងៃស្តីពី លំហូរសាច់ប្រាក់ចេញ-ចូល របាយការណ៍ស្តីពីការព្យាករណ៍គម្លាតសន្ទនីយភាពនៅថ្ងៃបន្ទាប់ និង/ឬ អាចត្រូវបានត្រួតពិនិត្យដល់ទីកន្លែង។

ប្រការ ៩.-

ប្រកាសលេខ ធ៧-០៩-០១៣ ប្រក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីពី ការផ្តល់ឥណទាន វិបារូបន៍ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ត្រូវ ចាត់ទុកជានិរាករណ៍។

ប្រការ ១០.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១១.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ១-០១៦-០៥៤ ពិសេស

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា
របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានក្តីសោមនស្សរីករាយសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ផ្អែកលើប្រកាសស្តីពីការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារក្នុងទីផ្សាររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-Providing Collateralized Operation - LPCO)។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងលើកកម្ពស់ការគ្រប់គ្រងសន្ទនីយភាព តាមរយៈការធ្វើទំនើបកម្មការតាមដាននិងព្យាករណ៍សន្ទនីយភាព និងការបន្តអភិវឌ្ឍមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit - NCD)។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ឱ្យដំណើរការនូវប្រតិបត្តិការថ្មីមួយគឺការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមការចាំបាច់ដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដែលជាភាគីពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ។

លក្ខខណ្ឌចាំបាច់នៃប្រតិបត្តិការថ្មីនេះរួមមាន៖

- ប្រតិបត្តិការនឹងត្រូវធ្វើឡើងដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀល ហើយត្រូវធានាពេញលេញដោយការដាក់បញ្ចាំមូលបត្រអាចជួញដូរបានជាប្រាក់រៀលឬប្រាក់ដុល្លារអាមេរិក។ វិធានការគ្រប់គ្រងហានិភ័យសមស្របនឹងត្រូវអនុវត្តចំពោះមូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិកដើម្បីកាត់បន្ថយហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (haircut ១០% លើមូលបត្រអាចជួញដូរបានចារឹកជាប្រាក់ដុល្លារអាមេរិក)
- ប្រតិបត្តិការនឹងត្រូវអនុវត្តប្រចាំខែ
- ប្រតិបត្តិការនីមួយៗត្រូវមានកាលវិសាន ៣ខែ និងអាចបន្តបានអាស្រ័យលើប្រសិទ្ធភាពនៃការប្រើប្រាស់សន្ទនីយភាពដែលបានទទួល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមាសមស្របនិងបរិមាណទឹកប្រាក់ដែលគ្រោងផ្តល់ នឹងត្រូវប្រកាសនៅពេលចាប់ផ្តើមប្រតិបត្តិការ LPCO នីមួយៗ ដោយធនាគារជាតិនៃកម្ពុជានឹងកំណត់បរិមាណផ្តល់សមស្របទៅតាមស្ថានភាពតម្រូវការជាក់ស្តែង ជាពិសេសទៅតាមការទទួលសំណើដេញថ្លៃនៅប្រតិបត្តិការនីមួយៗ និង

- គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនីមួយៗដែលចូលរួមក្នុងប្រតិបត្តិការ LPCO នឹងតម្រូវឱ្យមានការបង្ហាញពីចំនួនទឹកប្រាក់ដែលមានបំណងចង់ដេញថ្លៃជាមួយនឹងអត្រាការប្រាក់មួយ។

ធនាគារជាតិនៃកម្ពុជាគ្រោងនឹងធ្វើប្រតិបត្តិការ LPCO ជាលើកទី១ នៅថ្ងៃអង្គារ ទី១៨ ខែតុលា ឆ្នាំ២០១៦។ ធនាគារជាតិនៃកម្ពុជានឹងធ្វើការវិភាគដោយប្រុងប្រយ័ត្នពីលទ្ធផលនិងឥទ្ធិពលនៃប្រតិបត្តិការនីមួយៗ និងកែសម្រួលលក្ខខណ្ឌនានាតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃប្រតិបត្តិការថ្មីនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានបំណងចង់ចូលរួមក្នុងប្រតិបត្តិការ LPCO នេះ មកទទួលយកព័ត៌មានលម្អិតពីនាយកដ្ឋានប្រតិបត្តិការនៃធនាគារជាតិនៃកម្ពុជារៀងរាល់ម៉ោងធ្វើការ។

ត្រា

សូមទំនាក់ទំនងមកធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិការ
ទូរស័ព្ទ៖ ០១២ ៩៦ ៩៦ ៥៥ / ០១១ ៦១ ៥៨ ៣៥
អ៊ីម៉ែល៖ sveatiny@nbc.org.kh / veatiny@gmail.com

ធ៥-០១៧-៤១៥ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
ការបង្កើនឥណទានប្រតិទានប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានា (LPCO)

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនជាដំណឹងដល់ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ឥណទានប្រតិបត្តិការ LPCO នឹងមានការបង្កើន ពី ៣ខែ ទៅ ១ឆ្នាំ (៣៦៤ថ្ងៃ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការសន្ធនីយភាពរយៈពេលវែង របស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ។ LPCO ដែលមានឥណទានរយៈពេល១ឆ្នាំនេះ នឹងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដែលមានបំណងចូលរួមក្នុងប្រតិបត្តិការ LPCO សូមត្រៀមលក្ខណៈចូលរួមដេញថ្លៃនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧
អគ្គនាយកបច្ចេកទេស
ហត្ថលេខានិងត្រា៖ **ជា សិរី**

សូមទំនាក់ទំនងមកធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិការ
អ៊ីមែល៖ lpco_info@nbc.org.kh

ធ៥-០១៨-២៣០ ស.ជ.ណ

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

សេចក្តីជូនដំណឹង
ស្តីពី
ការបន្ថែមឥណទានប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានា (LPCO)

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូ-ហិរញ្ញវត្ថុទាំងអស់ជ្រាបថា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់សន្ធនីយភាពរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានឹងបង្កើតឱ្យមានឥណទាន ៣ខែ (៩១ថ្ងៃ) និង ៦ខែ (១៨២ថ្ងៃ) បន្ថែមលើឥណទាន ១ឆ្នាំ (៣៦៤ថ្ងៃ) ដែលកំពុងមាន។ ឥណទានបន្ថែមទាំងពីរប្រភេទខាងលើនេះ នឹងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃប្រតិបត្តិការ LPCO តាមឥណទានដែលចង់បានតាមការគួរ។

ក្រា

សូមទំនាក់ទំនង៖
- អគ្គនាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានប្រតិបត្តិការ
- ទូរសព្ទលេខ ៖ (៨៥៥-២៣) ៧២៤ ៩៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
- សារអេឡិចត្រូនិក ៖ lpco_info@nbc.org.kh

ធ៥-០១៨-០០២ ស.ក.ណ.ន

ថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨

សេចក្តីណែនាំ
លើការអនុវត្តប្រតិបត្តិការ
ផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

យោងសេចក្តីជូនដំណឹងលេខ ធ១-០១៦-០៥៤ ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់អំពីលក្ខខណ្ឌចាំបាច់ និងនីតិវិធីមួយចំនួនក្នុងការចូលរួមដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

ក- លក្ខខណ្ឌចាំបាច់មុនពេលដេញថ្លៃ

- ត្រូវចុះកិច្ចសន្យាជាមួយធនាគារជាតិនៃកម្ពុជា លើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា។
- ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP)។
- ត្រៀមបម្រុងមូលបត្រអាចជួញដូរបាន (NCD) សម្រាប់ធានាប្រតិបត្តិការ LPCO ដែលទទួលបានជោគជ័យក្នុងការដេញថ្លៃ។ ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយ NCD នៅរៀងរាល់ថ្ងៃព្រហស្បតិ៍បន្ទាប់ពីទទួលបានពាក្យសុំជារៀងរាល់ថ្ងៃពុធ។
- តណប្រតិទានរបស់ NCD ត្រូវតែធំជាង ឬស្មើនឹងតណប្រតិទានរបស់ប្រតិបត្តិការ LPCO។ NCD ជាប្រាក់ដុល្លារអាមេរិកដែលបានដាក់ធានា នឹងត្រូវអនុវត្ត Haircut លើតម្លៃចារឹក ក្នុងកម្រិតមួយដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ខ- នីតិវិធីក្នុងការដាក់ដេញថ្លៃ

- ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃមួយលើកៗ នឹងត្រូវបានជូនដំណឹងមួយសប្តាហ៍មុនថ្ងៃដេញថ្លៃ
- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា/អប្បរមាក្នុងមួយគ្រឹះស្ថាន កម្រិត Haircut លើ NCD ជាប្រាក់ដុល្លារអាមេរិកដែលដាក់ធានា អត្រាការប្រាក់សម្រាប់តណប្រតិទាននីមួយៗ ព្រមទាំងនីតិវិធីដទៃទៀតពាក់ព័ន្ធនឹងការដាក់ដេញថ្លៃ នឹងត្រូវបានជូនដំណឹងនៅវេលាម៉ោង ៨:០០ នាទីព្រឹក នៃថ្ងៃដេញថ្លៃ។

- ការដាក់ដេញថ្លៃត្រូវធ្វើឡើងតាមប្រព័ន្ធ NBCP ចាប់ពីម៉ោង ៨:០០ នាទីព្រឹក រហូតដល់ម៉ោង ១២:០០ ថ្ងៃត្រង់។ ក្នុងករណីប្រព័ន្ធ NBCP មិនអាចអនុវត្តបាន ការដាក់ដេញថ្លៃត្រូវធ្វើតាមសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើទៅនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា។
- លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ នាទីរសៀល នាថ្ងៃដេញថ្លៃ។
- គ្រឹះស្ថានដែលដាក់ដេញថ្លៃតាមប្រព័ន្ធ NBCP ហើយទទួលជោគជ័យ នឹងត្រូវទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការដេញថ្លៃព្រមទាំងព័ត៌មានពាក់ព័ន្ធពីប្រព័ន្ធ NBCP ចំណែកគ្រឹះស្ថានដែលដាក់ដេញថ្លៃតាមសារអេឡិចត្រូនិក ឬតាមស្រោមសំបុត្រ ត្រូវចុះកិច្ចសន្យាបំពេញបន្ថែមជាមួយធនាគារជាតិនៃកម្ពុជា។
- នៅថ្ងៃទូទាត់ (២ថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃ) គ្រឹះស្ថានដែលទទួលជោគជ័យក្នុងការដេញថ្លៃនឹងទទួលបានសន្ធនីយភាព បន្ទាប់ពីបានចុះកិច្ចសន្យាប្រគល់សិទ្ធិកាន់កាប់ NCD ជូនធនាគារជាតិនៃកម្ពុជា។ ក្នុងករណីមិនបានប្រគល់ NCD តាមកាលកំណត់ លទ្ធផលដេញថ្លៃដែលទទួលជោគជ័យនឹងត្រូវទុកជាមោឃៈ។
- នៅឥណប្រតិទានៃប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជានឹងផ្ទេរសិទ្ធិកាន់កាប់ NCD ជូនភាគីខ្ចីប្រាក់វិញ បន្ទាប់ពីភាគីនេះបានទូទាត់ចប់សព្វគ្រប់នូវទឹកប្រាក់បានខ្ចី និងការប្រាក់ រួមទាំងកាតព្វកិច្ចផ្សេងៗទៀត ប្រសិនបើមាន។
- ការប្រាក់បង្គរនឹងត្រូវបានគណនាអាស្រ័យលើទំហំប្រាក់ រយៈពេលខ្ចីប្រាក់ អត្រាការប្រាក់ និងលើមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងក្នុងឆ្នាំនីមួយៗ។

សេចក្តីណែនាំការអនុវត្តប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានាលេខ ធ៥-០១៦-០០៥ ស.ក.ណ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ត្រូវចាត់ទុកជាមោឃៈចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុជ្រាប និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ត្រា

សូមទំនាក់ទំនងៈ
-ធនាគារជាតិនៃកម្ពុជា
-អគ្គនាយកដ្ឋានបច្ចេកទេស
-នាយកដ្ឋានប្រតិបត្តិការ
-លេខទូរសព្ទ ៖ (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
-សារអេឡិចត្រូនិក ៖ lpco_info@nbc.org.kh

ធ៥-០១៧-៧០០ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ផ្លែតហ្វូមរបស់ធនាគារជាតិនៃកម្ពុជា (NBCP)

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្ស សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ក្នុងគោលបំណងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យប្រើប្រាស់ផ្លែតហ្វូមរបស់ធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ តទៅ។ ផ្លែតហ្វូមរបស់ធនាគារជាតិនៃកម្ពុជានេះ មានលទ្ធភាពអាចឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (អ្នកទទួលសេវា) ធ្វើប្រតិបត្តិការជួញដូរអន្តរាញជាមួយអ្នកទទួលសេវាដទៃទៀត ឬជាមួយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបំណងប្រើប្រាស់ផ្លែតហ្វូមរបស់ធនាគារជាតិនៃកម្ពុជានេះ សូមទាក់ទងចុះឈ្មោះតាមអាសយដ្ឋានដូចខាងក្រោម ព្រមទាំងចុះហត្ថលេខាលើលក្ខខណ្ឌ និងខចែងទូទៅរបស់ផ្លែតហ្វូមនេះ។

ត្រា

<u>អាសយដ្ឋានទំនាក់ទំនង៖</u>
ធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានប្រតិបត្តិការ)
អគារលេខ ២២-២៤ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ ០២៣ ៧២៤ ៩៦៣ (Ext: ១០៤៨)
អ៊ីម៉ែល៖ banking@nbc.org.kh

ឆ. ប្រព័ន្ធទូទាត់ ជាត់ទាត់ និង ផ្ទេរប្រាក់ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ឆ.១. ប្រព័ន្ធចូរនាត់ ជាត់នាត់ និង ផ្ទេរប្រាក់

ប្រកាស
ស្តីពី
ប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់

ប្រការ ១.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពី ឧបករណ៍អាចផ្ទេរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួនដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេងពីនេះ៖

១. **ប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង** សំដៅដល់ប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនៅក្រោមប្រកាសនេះ។

២. **សេចក្តីណែនាំ** សំដៅដល់ខ្លឹមសារនៃបញ្ជាទូទាត់។

៣. **អ្នកចាត់ការ** រួមមានសមាជិកនៃក្រុមប្រឹក្សាភិបាល និងសំដៅដល់បុគ្គលមួយចំនួនដែលធនាគារជាតិនៃកម្ពុជាយល់ថាស្ថិតក្នុងហាន:ជាអ្នកត្រួតពិនិត្យហើយដែលទទួលខុសត្រូវលើការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់អ្នកផ្តល់សេវា។ សេចក្តីជូនដំណឹងនៅក្រោមប្រការនេះត្រូវបានផ្តល់ឱ្យអ្នកចាត់ការ ដូចដែលអ្នកផ្តល់សេវាបានជូនដំណឹងចំពោះធនាគារជាតិនៃកម្ពុជា លើកលែងតែធនាគារជាតិនៃកម្ពុជាបានចាត់តាំងជាក់លាក់នូវបុគ្គលមួយផ្សេងទៀតថាជាអ្នកចាត់ការ។

៤. **តម្លៃរូបិយវត្ថុ** សំដៅដល់មធ្យោបាយដោះដូរ ទោះបីជាអាចប្តូរជាប្រាក់ឬមិនអាចក្តី រួមទាំងក្រោមរូបភាពជាតម្លៃសន្សំ ជាឧបករណ៍ទូទាត់សងប្រាក់ ឬជាការចុះឥណទានចូលក្នុងគណនីផងដែរ។

៥. **រូបិយវត្ថុ** សំដៅដល់ឯកតារូបិយវត្ថុ ឬមធ្យោបាយដោះដូរដែលត្រូវបានចេញផ្សាយបង្កើតឡើង អនុញ្ញាត ឬអនុម័តដោយប្រទេសកម្ពុជា ឬរដ្ឋាភិបាលបរទេស។ ពាក្យនេះរួមបញ្ចូលទាំងឯកតារូបិយវត្ថុ ឬមធ្យោបាយដោះដូរដែលបានចេញផ្សាយ បង្កើតឡើង អនុញ្ញាត ឬអនុម័ត ដោយអង្គការអន្តររដ្ឋាភិបាល ឬដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលពីរ ឬច្រើនផងដែរ។

៦. **ការបញ្ជូនប្រាក់** សំដៅដល់ការលក់ ឬចេញផ្សាយតម្លៃរូបិយវត្ថុ ឬការទទួលប្រាក់ ឬតម្លៃរូបិយវត្ថុពាក់ព័ន្ធនឹងការបញ្ជូនប្រាក់ ឬតម្លៃរូបិយវត្ថុ ទោះបីពីអ្នកបញ្ជូន ឬសម្រាប់អត្ថគាហកក្តី ហើយរួមទាំងការផ្តល់សេវាកម្មសម្រាប់ការដកប្រាក់ ការផ្ទេរតម្លៃរូបិយវត្ថុរវាងគណនី ឬសម្រាប់ការទូទាត់សងតម្លៃរូបិយវត្ថុភាគីទីបីផងដែរ។ ពាក្យនេះរួមបញ្ចូលទាំងការចូលរួមក្នុងប្រតិបត្តិការ ឬកិច្ចសម្របសម្រួលពាក់ពន្ធ័នឹងការអនុវត្ត ការបញ្ជូនប្រាក់ពីអ្នកបញ្ជូនទៅអត្ថគាហក ទោះបីជាអ្នកបញ្ជូន ឬអត្ថគាហកនោះពុំមែនជាភាគី ឬ

អ្នកចូលរួមផ្ទាល់ នៅក្នុងប្រតិបត្តិការនោះក្តី។ ការបញ្ជូនប្រាក់អាចធ្វើឡើងពីកន្លែងមួយទៅកន្លែងមួយនៅក្នុង ទៅកាន់ ឬចេញពីប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត។

៧. **អ្នកចូលរួម** សំដៅដល់ភាគីមួយនៃកិច្ចសម្របសម្រួលពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់។ បុគ្គលនោះអាចជាធនាគារ ជាអ្នកផ្តល់សេវាបញ្ជូលប្រាក់ ឬបុគ្គលដទៃផ្សេងទៀត តែមិនរួមបញ្ចូលអ្នកប្រើប្រាស់ ឬអតិថិជនរបស់អ្នកចូលរួម ដែលជាអ្នកចេញបញ្ជា ឬទទួលការទូទាត់សងប្រាក់តាមរយៈប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ឡើយ។

៨. **បណ្ណទូទាត់សងប្រាក់** សំដៅដល់បណ្ណ សន្លឹកបណ្ណ សៀវភៅគូប៉ុង ឬឧបករណ៍ផ្សេងទៀតដែលរួមមានទាំងលេខកូដ ឬមធ្យោបាយផ្សេងទៀតសម្រាប់ចូលរួមទៅប្រើប្រាស់គណនី ឬតម្លៃសន្សំដែលអាចត្រូវបានប្រើប្រាស់ពីពេលមួយទៅពេលមួយ ដើម្បីទទួលបានប្រាក់ ឬធ្វើការទូទាត់សងប្រាក់ហើយរួមបញ្ចូលទាំងបណ្ណឥណពន្ធ កម្រៃ បណ្ណឥណទាន និងបណ្ណនៃតម្លៃសន្សំផងដែរ។

៩. **ប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់** សំដៅដល់ប្រព័ន្ធ ឬកិច្ចសម្របសម្រួលសម្រាប់ទំនាក់ទំនង ដំណើរការ ការប្តូរ ការជាត់ទាត់ឬទូទាត់ នូវបញ្ជាទូទាត់និងសារផ្សេងៗដែលជះឥទ្ធិពលបញ្ជា បង្កលក្ខណៈ ឬសម្រួលដល់ការទូទាត់សងប្រាក់ ការបញ្ជូនប្រាក់ ការដកប្រាក់ ឬការផ្ទេរតម្លៃរូបិយវត្ថុ។

១០. **វិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់** សំដៅដល់វិធាន ដែលទោះជាមានឈ្មោះដូចម្តេចក្តីក្រៅពីវិធានចេញដោយធនាគារជាតិនៃកម្ពុជា គឺជាវិធានដែលគ្រប់គ្រងលើប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់រួមទាំងលើប្រតិបត្តិការ ការជាត់ទាត់ និងការទូទាត់នៃប្រព័ន្ធនោះផងដែរ។ វិធាននោះរួមបញ្ចូលទាំងវិសោធនកម្ម ឬការលុបចោលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ផងដែរ។

១១. **ឧបករណ៍ទូទាត់សងប្រាក់** សំដៅដល់មូលប្បទានបត្រ រូបិយាណត្តិ អាណត្តិផ្ទេរប្រាក់ មូលប្បទានបត្រទេសចរណ៍ បណ្ណទូទាត់សងប្រាក់ ឬឧបករណ៍ផ្សេងទៀត សម្រាប់ការបញ្ជូន ឬការទូទាត់សងប្រាក់ ឬតម្លៃរូបិយវត្ថុ ដែលអាចជួញដូរបាន ឬមិនបានក្តី។ ពាក្យនេះមិនរួមបញ្ចូល វិក្កយបត្រ បណ្ណឥណទាន លិខិតឥណទាន ឬឧបករណ៍ដែលអាចសងវិញ ដោយអ្នកចេញផ្សាយជាទំនិញ ឬសេវាទេ។

១២. **បុគ្គល** សំដៅដល់ឯកត្តជន សាជីវកម្ម ឯកាធិកម្មអាជីវកម្ម ក្រុមហ៊ុនអចលនទ្រព្យ មូលនិធិរួមភាពជាដៃគូ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត សមាគម សម្ព័ន្ធសាជីវកម្ម រដ្ឋាភិបាល អង្គភាពណាមួយនៃរដ្ឋាភិបាល ទីភ្នាក់ងារ ឬអង្គភាពសាជីវកម្មសាធារណៈ ឬស្ថាប័នសាធារណៈណាមួយ ក្រុមហ៊ុនឯកជន ឬអង្គភាពពាណិជ្ជកម្ម ការិយាល័យ ឬអង្គភាពដែលមាន ឬគ្មានភាពជានីតិបុគ្គលដោយឡែក។

១៣. **កំណត់ត្រា** សំដៅដល់ព័ត៌មាន ដែលបានកត់ត្រាលើមធ្យោបាយរូបិយ ឬដែលត្រូវបានរក្សាទុកក្នុងមធ្យោបាយអេឡិកត្រូនិក ឬមធ្យោបាយផ្សេងទៀត ហើយដែលអាចយកមកប្រើបានក្នុងទម្រង់ជាក់ស្តែង។

១៤. **អ្នកផ្តល់សេវា** សំដៅដល់បុគ្គលដែលដំណើរការ ឬចូលរួមនៅក្នុងប្រតិបត្តិការប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់។

១៥. **តម្លៃសន្សំ** សំដៅដល់តម្លៃរូបិយវត្ថុដែលបង្ហាញភស្តុតាងតាមកំណត់ត្រាអេឡិកត្រូនិក។

ប្រការ ២.-

១. ធនាគារជាតិនៃកម្ពុជាអាចចេញវិធានដើម្បី៖

ក. កំណត់លក្ខខណ្ឌ កាតព្វកិច្ច និងស្តង់ដារដែលនៅក្រោមនោះប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់អាចនឹងត្រូវបានដំណើរការ និងបានចាត់តាំង

ខ. តម្រូវឱ្យមានការចុះបញ្ជី ឬការសុំអាជ្ញាបណ្ណចំពោះអ្នកផ្តល់សេវា កំណត់លក្ខខណ្ឌ និងកាតព្វកិច្ចសម្រាប់ការចុះបញ្ជី ឬការផ្តល់អាជ្ញាបណ្ណ និងចែងអំពីកាល:ទេស:ដែលអាជ្ញាបណ្ណ ឬការចុះបញ្ជីនេះអាចត្រូវបានបដិសេធដោយធនាគារជាតិនៃកម្ពុជា

គ. កំណត់កម្រៃ និងសោហ៊ុយសម្រាប់ការចុះបញ្ជី ឬការផ្តល់អាជ្ញាបណ្ណចំពោះអ្នកផ្តល់សេវា

ឃ. ត្រួតពិនិត្យ ដាក់បញ្ញត្តិកម្ម និងមើលការខុសត្រូវលើការអនុវត្តរបស់អ្នកផ្តល់សេវា

ង. កំណត់លក្ខខណ្ឌ និងកាតព្វកិច្ច ដែលនៅក្រោមនោះ បុគ្គលទាំងឡាយ រួមទាំងអ្នកផ្តល់សេវាបញ្ជូនប្រាក់ អាចជាអ្នកចូលរួមនៅក្នុងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ឬមានគណនីនិងរក្សាប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា

ច. ដាក់អ្នកផ្តល់សេវាឱ្យស្ថិតនៅក្រោមកាតព្វកិច្ចប្រុងប្រយ័ត្ន រួមទាំងកាតព្វកិច្ចរាយការណ៍និងគណនេយ្យ

ឆ. កំណត់កាតព្វកិច្ច ស្តង់ដារ និងសេចក្តីណែនាំស្តីពីបញ្ហាសាជីវកម្មរបស់អ្នកផ្តល់សេវា ដូចជា បញ្ហាទាក់ទងនឹងទម្រង់នៃការបង្កើតឡើង ឬការរៀបចំ ការគ្រប់គ្រង ការចាត់ចែង អភិបាលកិច្ច ការត្រួតពិនិត្យ ភាពគ្រប់គ្រាន់នៃដើមទុន និងកាតព្វកិច្ចដើមទុនផ្សេងៗទៀត រចនាសម្ព័ន្ធកម្មសិទ្ធិ គុណវុឌ្ឍិរបស់ភាគទុនិកនិងអភិបាល ព្រមទាំងអំណាចអាជីវកម្មនិងការវិនិយោគ

ជ. តម្រូវចំពោះអ្នកផ្តល់សេវានូវកាតព្វកិច្ច ស្តង់ដារនិងសេចក្តីណែនាំ ដែលបានរៀបចំឡើង ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា រួមទាំងកាតព្វកិច្ចស្តង់ដារ និងសេចក្តីណែនាំពាក់ព័ន្ធនឹងការប្រមូល ការរក្សាកំណត់ត្រា និងការផ្តល់របាយការណ៍ ទៅធនាគារជាតិនៃកម្ពុជា នូវព័ត៌មានលើបញ្ហាជាក់លាក់ និងព័ត៌មានអំពីអ្នកចូលរួមរបស់ខ្លួន និងអ្នកទំនាក់ទំនងជាមួយប្រតិបត្តិការ ឬប្រភេទណាមួយនៃអ្នកទាំងនោះ ក្នុងទម្រង់ និងភាពលម្អិត តាមការកំណត់នៅក្នុងវិធាន និង

ឈ. កំណត់ឱ្យអ្នកផ្តល់សេវាស្ថិតនៅក្រោមបទប្បញ្ញត្តិទីផ្សារក្នុងគោលបំណងការពារអតិថិជន និងអ្នកចូលរួម ឬប្រភេទណាមួយនៃអ្នកទាំងនោះ និងជាពិសេសកំណត់នូវ

កាតព្វកិច្ចបើកចំហព័ត៌មាន និងធ្វើបញ្ញត្តិកម្មចំពោះលក្ខខណ្ឌកិច្ចសន្យានៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់និងអ្នកចូលរួមក្នុងប្រព័ន្ធនោះ។

២. វិធានក្នុងប្រការនេះ ព្រមទាំងលក្ខខណ្ឌ កាតព្វកិច្ច និងស្តង់ដារ ដែលចែងខាងក្រោមនេះ អំពីបញ្ហាណាមួយរួមទាំងការផ្តល់អាជ្ញាបណ្ណ ការចុះបញ្ជី ឬការចាត់តាំង និងស្តីពីកម្រៃ និងសោហ៊ុយ អាចប្រែប្រួលពីប្រភេទមួយទៅប្រភេទមួយទៀត ក៏ដូចជាពីប្រភេទរង ឬបែបផែននៃអ្នកផ្តល់សេវាដូចដែលបានចាត់ថ្នាក់ និងកំណត់ដោយប្រុងប្រយ័ត្នដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៣.-

១. ប្រសិនបើមានការយល់ថាជាផលប្រយោជន៍សាធារណៈក្នុងការធ្វើដូច្នេះ ធនាគារជាតិនៃកម្ពុជាអាចចាត់តាំងឱ្យមានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់មួយឱ្យនៅក្រោមបទប្បញ្ញត្តិ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តនៅក្រោមប្រកាសនេះ។

២. ដើម្បីកំណត់ថា តើការចាត់តាំងឱ្យមានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ជាផលប្រយោជន៍ សាធារណៈ ឬយ៉ាងណា គប្បីត្រូវពិចារណាលើកត្តាមួយចំនួនដូចខាងក្រោម៖

ក. កម្រិតសុវត្ថិភាពហិរញ្ញវត្ថុដែលប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ផ្តល់ចំពោះអ្នកចូលរួម និងអ្នកប្រើប្រាស់

ខ. ប្រសិទ្ធភាពនិងការប្រកួតប្រជែងនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ក្នុងប្រទេសកម្ពុជា និង

គ. ផលប្រយោជន៍ខ្ពស់បំផុតរបស់អ្នកចូលរួម និងអតិថិជននៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ឬនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។

៣. មុននឹងធ្វើការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាត្រូវពិភាក្សាជាមួយអ្នកចាត់ការ និងអ្នកចូលរួមក្នុងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ក៏ដូចជាអាចពិភាក្សាជាមួយភាគីមានចំណាប់អារម្មណ៍ដទៃទៀតអំពីផលប៉ះពាល់នៃការចាត់តាំងនោះ។

៤. ធនាគារជាតិនៃកម្ពុជាត្រូវផ្តល់ដំណឹងដល់អ្នកចាត់ការ និងអ្នកចូលរួមអំពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ដែលបានចាត់តាំងតាមវិធីណាក្តីដែលខ្លួនគិតថាសមស្រប។

៥. ការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

ប្រការ ៤.-

១. ច្បាប់ចម្លងនៃរាល់វិធានប្រព័ន្ធជាត់ទាត់នៃការសងប្រាក់ ដែលគ្រប់គ្រងលើប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង នឹងត្រូវបានផ្តល់ដោយអ្នកចាត់ការប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់នោះ ឬបើគ្មានអ្នកចាត់ការទេ ច្បាប់ចម្លងនេះនឹងត្រូវបានផ្តល់ដោយអ្នកចូលរួមទៅឱ្យធនាគារជាតិនៃកម្ពុជា៖

ក. ក្នុងករណីដែលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវបានធ្វើឡើងមុនការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ វិធាននេះត្រូវផ្តល់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការចាត់តាំង និង

ខ. ក្នុងករណីដែលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ត្រូវបានធ្វើឡើងក្រោយការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយការបង្កើតវិធាននោះ។

២. វិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ក្រៅពីវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ដែលមានចែងក្នុងកថាខណ្ឌទី ១ ក មិនចូលជាធរមានមុនរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានផ្តល់ច្បាប់ចម្លងវិធាននេះជូនធនាគារជាតិនៃកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ទេ ប៉ុន្តែធនាគារជាតិនៃកម្ពុជាអាចប្រកាសឱ្យប្រធាននោះចូលជាធរមាននៅពេលណាក៏បានមុនពេលផុតរយៈពេលកំណត់។

៣. បើធនាគារជាតិនៃកម្ពុជាយល់ថាការពន្យាររយៈពេលកំណត់ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី២ ជាការចាំបាច់ដើម្បីអាចពិនិត្យឡើងវិញឱ្យបានសមស្របនូវវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ក្នុងរវាង ១០ ថ្ងៃ បន្ទាប់ពីបានទទួលវិធាននោះ តាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់អ្នកផ្ញើវិធាននោះ ធនាគារជាតិនៃកម្ពុជាអាចពន្យារពេលកំណត់រហូតដល់ ៣០ ថ្ងៃ។

៤. ធនាគារជាតិនៃកម្ពុជា អាចមិនអនុញ្ញាតទាំងស្រុង ឬលើផ្នែកណាមួយនៃវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលគ្រប់គ្រងលើប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនៅមុន ឬនៅពេលណាមួយ ក្រោយវិធាននេះចូលជាធរមាន ឬកំពុងនៅជាធរមាន។ វិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលកំពុងមានសុពលភាពតែមិនត្រូវបានអនុញ្ញាតវិញ នឹងត្រូវបាត់បង់សុពលភាពចាប់ពីពេលដែលសេចក្តីសម្រេចពីការមិនអនុញ្ញាតនោះត្រូវបានជូនដំណឹងទៅអ្នកចាត់ការប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ ដែលបានចាត់តាំងនោះ ឬនៅពេលណាមួយក្រោយមកទៀត ដូចដែលធនាគារជាតិនៃកម្ពុជាបានណែនាំនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីការមិនអនុញ្ញាតនូវវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់នោះ។

៥. នៅពេលណាដែលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលកំពុងមានសុពលភាពមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តទាំងស្រុង ឬមួយផ្នែកពីធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌទី៤ ដែលនាំឱ្យមានការចាំបាច់ត្រូវធ្វើវិសោធនកម្ម ឬធ្វើការជំនួសឡើងវិញនូវប្រធានជាត់ទាត់នៃការទូទាត់សងប្រាក់ ដើម្បីសម្រួលដល់ប្រតិបត្តិការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងឱ្យមានភាពរលូនបន្តទៀត សេចក្តីសម្រេចរបស់ធនាគារជាតិនៃកម្ពុជាអំពីការមិនអនុញ្ញាតឱ្យអនុវត្តវិធាននេះ ចាំបាច់ត្រូវដាក់បញ្ចូលក្នុងសេចក្តីណែនាំដែលចេញផ្សាយអនុលោមតាមប្រការ ៥ ដែលណែនាំចំពោះអ្នកចាត់ការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនោះអំពី

វិសោធនកម្ម ឬការជំនួសដ៏ចាំបាច់នោះ និងថែមទាំងផ្តល់នូវអត្ថបទវិធានសម្រាប់ប្រព័ន្ធនៃការទូទាត់សងប្រាក់បណ្តោះអាសន្ន ដែលត្រូវអនុវត្តរហូតដល់វិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវធ្វើវិសោធនកម្ម ឬជំនួសត្រូវបានអនុម័តដោយប្រព័ន្ធនោះ។ វិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់បណ្តោះអាសន្ន ត្រូវចូលជាធរមានភ្លាមនៅពេលដែលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលត្រូវធ្វើវិសោធនកម្ម ឬត្រូវបានជំនួសអស់សុពលភាព។

៦. ធនាគារជាតិនៃកម្ពុជាអាចធ្វើការលើកលែងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងនោះអនុលោមតាមកថាខណ្ឌទី២។

ប្រការ ៥.-

១. ធនាគារជាតិនៃកម្ពុជាអាចចេញផ្សាយសេចក្តីណែនាំទៅកាន់អ្នកចាត់ការ ឬអ្នកចូលរួមនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំងដូចខាងក្រោម៖

ក. លក្ខខណ្ឌទាំងឡាយដែលបុគ្គលម្នាក់ចាំបាច់ត្រូវបំពេញដើម្បីប្រើប្រាស់ ឬក្លាយជាអ្នកចូលរួមក្នុងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ដែលបានចាត់តាំង។

ខ. ប្រតិបត្តិការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់រួមមានការជាត់ទាត់ និងការទូទាត់នៃប្រព័ន្ធនោះ។

គ. អន្តរកម្មនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់នោះជាមួយប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ផ្សេងទៀត។

ឃ. ទំនាក់ទំនងនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ជាមួយអ្នកចូលរួមរបស់ខ្លួន។

២. មុននឹងផ្តល់សេចក្តីណែនាំ ធនាគារជាតិនៃកម្ពុជាត្រូវពិគ្រោះជាមួយបុគ្គលដែលត្រូវទទួលសេចក្តីណែនាំនោះ ហើយក៏អាចពិគ្រោះជាមួយភាគីមានចំណាប់អារម្មណ៍ផ្សេងទៀតដែរ អំពីខ្លឹមសារ និងផលប៉ះពាល់នៃសេចក្តីណែនាំនោះ។

៣. ធនាគារជាតិនៃកម្ពុជាអាចបញ្ជាក់ក្នុងសេចក្តីណែនាំថា ក្នុងអំឡុងពេលដែលធនាគារជាតិនៃកម្ពុជាយល់ថាចាំបាច់ អ្នកចាត់ការ និងអ្នកចូលរួមប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់នោះត្រូវ

ក. បញ្ឈប់ ឬផ្អាកសកម្មភាព ឬការប្រព្រឹត្ត

ខ. ធ្វើសកម្មភាពទាំងនោះដែលធនាគារជាតិនៃកម្ពុជាយល់ថាជាការចាំបាច់សម្រាប់បម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ

គ. បង្កើត ធ្វើវិសោធនកម្ម ឬលុបចោលវិធានប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់។

៤. ក្នុងពេលយ៉ាងឆាប់តាមតែអាចទៅបាន ក្រោយពីការអនុវត្តសេចក្តីណែនាំ និងបំពេញរាល់សកម្មភាពដែលបានតម្រូវក្នុងទំនាក់ទំនងជាមួយសេចក្តីណែនាំនោះ បុគ្គលដែល

បានទទួលការណែនាំត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជាថា បញ្ហាណែនាំត្រូវបានអនុវត្តនិងបានបំពេញសកម្មភាពរួចរាល់ហើយ។

៥. សេចក្តីណែនាំត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

៦. សេចក្តីណែនាំគឺជាចំណងកាតព្វកិច្ចចំពោះបុគ្គលដែលស្ថិតនៅក្រោមសេចក្តីណែនាំនោះ។

ប្រការ ៦.-

១. ធនាគារជាតិនៃកម្ពុជាអាចធ្វើសវនកម្ម អធិការកិច្ច និងតម្រូវឱ្យបង្ហាញនូវគណនី កំណត់ត្រា បញ្ជី និងឯកសារនានា ធ្វើការពិនិត្យតាមការិយាល័យ និងស្នើសុំព័ត៌មានពីបុគ្គលណាដែលធនាគារជាតិនៃកម្ពុជាមានបំណងកំណត់ ទោះជាបុគ្គលនោះធ្វើប្រតិបត្តិការឬពាក់ព័ន្ធក្នុងប្រព័ន្ធជាត់ទាត់សងប្រាក់ដែលត្រូវលើកយកមកពិចារណាសម្រាប់ការចាត់តាំងដែលមានចែងក្នុងប្រការនេះ។

២. បុគ្គល និងនិយោជិត ភ្នាក់ងារ ឬអ្នកចាត់ការរបស់បុគ្គលដែលទទួលសំណើសុំនៅក្រោមកថាខណ្ឌទី១ ត្រូវតែគោរពតាមសំណើនោះ។

៣. ធនាគារជាតិនៃកម្ពុជាអាចប្រគល់ឱ្យសវនករឯករាជ្យខាងក្រៅធ្វើសវនកម្ម និងអធិការកិច្ចទាំងស្រុង ឬមួយផ្នែក ក្នុងនាមរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ ហើយត្រូវរាយការណ៍ជូនធនាគារជាតិនៃកម្ពុជា។

៤. ក្នុងគោលបំណងទទួលបានភស្តុតាងត្រឹមត្រូវក្រោមការសច្ចាប្រណិធានពាក់ព័ន្ធនឹងការធ្វើសវនកម្ម ឬ អធិការកិច្ចក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ធនាគារជាតិនៃកម្ពុជា។

៥. អ្នកចូលរួមត្រូវគោរពតាមរាល់កាតព្វកិច្ចដែលបានតម្រូវចំពោះអ្នកចាត់ការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់នៅក្រោមប្រការ ៦ នេះ។

៦. បើអ្នកចាត់ការនៃប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមប្រការនេះ អ្នកចូលរួមទាំងអស់ត្រូវរួមគ្នាអនុវត្តកាតព្វកិច្ចទាំងនោះ និងត្រូវទទួលខុសត្រូវចំពោះការបំពានលើកាតព្វកិច្ចទាំងនោះក្នុងលក្ខណៈ និងកម្រិតដូចគ្នាដូចអ្នកចាត់ការដែរ។

ប្រការ ៧.-

ការស្នើសុំការពិនិត្យដោយឫត្ថចត់លើការចាត់តាំងប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ណាមួយ ឬសេចក្តីណែនាំដែលចេញផ្សាយក្រោមប្រការនេះ មិនត្រូវមានការពន្យារពេលចាត់តាំង ឬផ្តល់ការណែនាំដើម្បីរង់ចាំសេចក្តីសម្រេចចុងក្រោយលើការស្នើសុំនោះឡើយ។

ប្រការ ៨.-

១. ព័ត៌មាន និងឯកសារដែលទទួលបាននៅក្រោមប្រកាសនេះ ត្រូវរក្សាជាការសម្ងាត់ និងត្រូវទុកដាក់ឱ្យបានត្រឹមត្រូវ។

២. គ្មានចំណុចណានៅក្នុងកថាខណ្ឌទី១ ហាមឃាត់ធនាគារជាតិនៃកម្ពុជាមិនឱ្យផ្សព្វផ្សាយព័ត៌មាន ឬឯកសារណាមួយទៅអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នបញ្ញត្តិកម្មដែលទទួលបន្ទុកគ្រប់គ្រងលើគ្រឹះស្ថានហិរញ្ញវត្ថុឡើយ នៅក្នុងលក្ខខណ្ឌដែលថាធនាគារជាតិនៃកម្ពុជាមានទំនុកចិត្តថាព័ត៌មាន ឬឯកសារទាំងនោះត្រូវបានរក្សាទុកជាការសម្ងាត់ដោយស្ថាប័ន អង្គភាព ឬបុគ្គលទាំងនោះ។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានអង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៩-០៦-២៣៥ ប្រ.ក

ប្រកាស
ស្តីពី
ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់

ប្រការ ១.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួន ដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេងពីនេះ៖

១- **ភាគីបដិភាគចម្បង** សំដៅដល់សាជីវកម្ម សមាគម ភាពជាដៃគូ ភ្នាក់ងារ ឬអ្នកផ្តល់សេវាកម្មដទៃទៀត ឬបុគ្គលក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលជាមួយភាគីទាំងឡាយនោះ សិទ្ធិ និងកាតព្វកិច្ចទូទាត់សងប្រាក់របស់អ្នកចូលរួមក្នុងប្រព័ន្ធត្រូវបានជាត់ទាត់សុទ្ធដើម្បីគណនាប្រាក់ជំពាក់សុទ្ធតែមួយ រវាងអ្នកចូលរួមនីមួយៗនិងភាគីបដិភាគចម្បង។

២- **ប្រព័ន្ធជាត់ទាត់និងទូទាត់** សំដៅដល់ប្រព័ន្ធមួយ ឬកិច្ចសម្របសម្រួលសម្រាប់ការជាត់ទាត់ឬទូទាត់បំណុលក្នុងប្រព័ន្ធហិរញ្ញវត្ថុជារូបិយប័ណ្ណណាមួយ និងដែលក្នុងនោះយ៉ាងហោចណាស់ក៏មានអ្នកចូលរួមចំនួនបី ហើយយ៉ាងតិចបំផុតមួយគឺគ្រឹះស្ថានហិរញ្ញវត្ថុ។ ដើម្បីឱ្យមានការច្រាកដជាងនេះ ប្រព័ន្ធនេះមានរាប់បញ្ចូលផងដែរនូវប្រព័ន្ធ ឬកិច្ចសម្របសម្រួលសម្រាប់ការជាត់ទាត់និងទូទាត់ជារូបិយវត្ថុជាតិរបស់ប្រទេសកម្ពុជា ឬកិច្ចសម្របសម្រួលសម្រាប់ប្រតិបត្តិការមូលបត្រ ប្រតិបត្តិការរូបិយប័ណ្ណបរទេស ឬប្រតិបត្តិការដទៃទៀត ឬកិច្ចសន្យាហិរញ្ញវត្ថុ នៅពេលណាដែលប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះធ្វើការជាត់ទាត់ឬទូទាត់កាតព្វកិច្ចសងប្រាក់ដែលកើតចេញពីប្រតិបត្តិការនិងកិច្ចសន្យាទាំងនោះ។

៣- **សភាជាត់ទាត់** សំដៅដល់សាជីវកម្ម សមាគម ភាពជាដៃគូ ភ្នាក់ងារ ឬអង្គភាពដទៃទៀត អង្គការ ឬ បុគ្គលដែលផ្តល់សេវាជាត់ទាត់ ឬទូទាត់សម្រាប់ប្រព័ន្ធជាត់ទាត់និងទូទាត់ ប៉ុន្តែមិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជាឡើយ។

៤- **ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង** សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងក្រោមប្រការ ២ កថាខណ្ឌទី១។

៥- **គ្រឹះស្ថានហិរញ្ញវត្ថុ** សំដៅដល់៖

ក- ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណ

ខ- បុគ្គលដទៃទៀត អង្គភាព ឬបុគ្គល ឬអង្គភាពក្នុងក្រុមបុគ្គល ឬអ្នកផ្តល់សេវាកម្មដែលប្រកបរបរជាចម្បងក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលអាចត្រូវបានចាត់តាំងដោយធនាគារជាតិនៃកម្ពុជា ថាជាគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីបម្រើឱ្យគោលបំណងក្នុងប្រកាសនេះ។

៦- **ប្រព័ន្ធហិរញ្ញវត្ថុ** សំដៅដល់ប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

៧- **សេចក្តីណែនាំ** សំដៅដល់ខ្លឹមសារនៃបញ្ហាទូទាត់។

៨- **អ្នកចូលរួម** សំដៅដល់សមាជិកនៃសភាជាត់ទាត់ ឬភាគីនៃកិច្ចសម្របសម្រួលដែលបង្កើតប្រព័ន្ធជាត់ទាត់និងទូទាត់។

៩- **ហានិភ័យជាប្រព័ន្ធ** សំដៅដល់ហានិភ័យដែលអសមត្ថភាពរបស់អ្នកចូលរួមម្នាក់ក្នុងការបំពេញកាតព្វកិច្ចបំណុលក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ នៅពេលដែលបំណុលនោះដល់កាលកំណត់ ឬរាំងស្ទះណាមួយក្នុងប្រព័ន្ធជាត់ទាត់ និងទូទាត់តាមរយៈការបញ្ជូនបញ្ហាហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធដែលអាចបណ្តាលឱ្យ៖

ក- អ្នកចូលរួមដទៃទៀតក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅពេលដល់កាលកំណត់

ខ- គ្រឹះស្ថានហិរញ្ញវត្ថុក្នុងផ្នែកដទៃទៀតនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួនបាននៅពេលដល់កាលកំណត់ ឬ

១០- សភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ ឬសភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ផ្សេងទៀតក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា គ្មានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅពេលដល់កាលកំណត់។

ប្រការ ២.-

១- នៅពេលដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា ប្រព័ន្ធជាត់ទាត់និងទូទាត់មួយធ្វើសកម្មភាពក្នុងលក្ខណៈ ដែលអាចបង្កឱ្យមានហានិភ័យជាប្រព័ន្ធនោះ ធនាគារជាតិនៃកម្ពុជាអាចចាត់ថ្នាក់ប្រព័ន្ធជាត់ទាត់និងទូទាត់នេះជាប្រព័ន្ធជាត់ទាត់និងទូទាត់មានសារៈសំខាន់ជាប្រព័ន្ធដែលត្រូវស្ថិតនៅក្រោមប្រកាសនេះ។

២- ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងដល់សភាជាត់ទាត់នៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងអំពីការចាត់ថ្នាក់នេះ ហើយត្រូវផ្សព្វផ្សាយព័ត៌មាននេះក្នុងរាជកិច្ច។

៣- ការចាត់តាំងប្រព័ន្ធជាត់ទាត់និងទូទាត់មួយថា មានសារៈសំខាន់ជាប្រព័ន្ធនៅក្រោមប្រកាសនេះអាចនឹងត្រូវបានផ្តល់ជាបន្ថែមទៅលើការចាត់តាំងនៃប្រព័ន្ធដូចគ្នានេះក្រោមប្រកាសស្តីពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់។ បុគ្គលដែលស្ថិតក្រោមប្រកាសស្តីពីការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ និងប្រកាសស្តីពីប្រព័ន្ធជាត់ទាត់នៃការទូទាត់សងប្រាក់ត្រូវតែអនុវត្តតាមរាល់កាតព្វកិច្ចដែលត្រូវបានតម្រូវក្រោមប្រកាសទាំងពីរនេះ។

ប្រការ ៣.-

ធនាគារជាតិនៃកម្ពុជាអាចធ្វើកិច្ចព្រមព្រៀងជាមួយ ឬចេញសេចក្តីណែនាំដល់សភាជាត់ទាត់ឬអ្នកចូលរួមក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬប្រព័ន្ធទាំងពីរចំពោះ៖

ក- កិច្ចសម្របសម្រួលជាត់ទាត់និងទូទាត់សុទ្ធ

ខ- យន្តការបែងចែកហានិភ័យនិងគ្រប់គ្រងហានិភ័យ

គ- ភាពប្រាកដប្រជានៃការទូទាត់ និងការបញ្ចប់ជាស្ថាពរនៃការទូទាត់សងប្រាក់

ឃ- លក្ខណៈនៃកិច្ចសម្របសម្រួលហិរញ្ញវត្ថុក្នុងចំណោមអ្នកចូលរួម

ង- ប្រព័ន្ធប្រតិបត្តិការនិងភាពរឹងមាំខាងហិរញ្ញវត្ថុនៃសភាជាត់ទាត់

ច- ការងារផ្សេងទៀតដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា អាចពាក់ព័ន្ធនឹងហានិភ័យជាប្រព័ន្ធ។

ប្រការ ៤.-

១- នៅពេលណាដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា៖

ក- សភាជាត់ទាត់សម្រាប់ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងកំពុងធ្វើ ឬរៀបនឹងធ្វើសកម្មភាព ធ្វើការភ្លេចភ្លាំង ឬការប្រព្រឹត្តណាមួយ

ខ- អ្នកចូលរួមកំពុងធ្វើ ឬរៀបនឹងធ្វើសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តណាមួយពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួនក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

គ- ប្រព័ន្ធជាត់ទាត់ និងទូទាត់ដែលចាត់តាំង កំពុងអនុវត្ត ឬរៀបនឹងអនុវត្តតាមរបៀបមួយដែលបណ្តាលឱ្យ ឬទំនងជាបណ្តាលឱ្យមានហានិភ័យជាប្រព័ន្ធ ដោយសារមិនត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ ធនាគារជាតិនៃកម្ពុជាអាចចេញសេចក្តីណែនាំដល់សភាជាត់ទាត់ ដោយតម្រូវឱ្យភាគីទាំងឡាយនោះ ក្នុងរយៈពេលមួយដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់៖

- បញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្ត ឬឱ្យអ្នកចូលរួមបញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្ត និង
- ធ្វើសកម្មភាព ឬឱ្យអ្នកចូលរួមធ្វើសកម្មភាព ដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់ ដើម្បីដោះស្រាយបញ្ហា។

២- នៅពេលណាដែលធនាគារជាតិនៃកម្ពុជាមានការយល់ឃើញនៅក្រោមកថាខណ្ឌទី១ ថាហានិភ័យជាប្រព័ន្ធមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវទេនោះ ហើយ៖

ក- សភាជាត់ទាត់មិនបានអនុវត្តតាមសេចក្តីណែនាំដែលត្រូវបានដាក់ចេញចំពោះខ្លួននៅក្រោមកថាខណ្ឌទី១

ខ- ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងពុំមានសភាជាត់ទាត់ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជា ឬ

គ- តាមយោបល់របស់ធនាគារជាតិនៃកម្ពុជា

- ហានិភ័យជាប្រព័ន្ធនោះមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវដោយសារតែសកម្មភាពណាមួយ ការភ្លេចភ្លាំង ឬការប្រព្រឹត្តរបស់អ្នកចូលរួមពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកទាំងនោះនៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង និង
- សកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តនោះមិនស្ថិតនៅក្រោមច្បាប់ កិច្ចសម្របសម្រួល វិធាន នីតិវិធី សេចក្តីណែនាំ ឬបទបញ្ជាដទៃទៀតដែលគ្រប់គ្រងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង។

ធនាគារជាតិនៃកម្ពុជា អាចចេញសេចក្តីណែនាំដល់អ្នកចូលរួម ក្នុងរយៈពេលមួយដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់ ហើយអាចបញ្ជាក់នៅក្នុងសេចក្តីណែនាំនោះថាអ្នកចូលរួម៖

- បញ្ឈប់ ឬផ្អាកសកម្មភាព ការភ្លេចភ្លាំង ឬការប្រព្រឹត្តជាក់លាក់ណាមួយពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួននៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង និង
- ធ្វើសកម្មភាពពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួន ដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់ ដើម្បីដោះស្រាយបញ្ហា។

៣- សេចក្តីណែនាំស្ថិតក្រោមប្រការនេះ អាចត្រូវបានធ្វើឡើងចំពោះបញ្ហាណាមួយដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការចូលរួមក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង។ ដើម្បីឱ្យមានការច្បាស់ដជាងនេះ សេចក្តីណែនាំក្រោមប្រការនេះអាចមិនត្រូវបានធ្វើឡើងចំពោះបញ្ហាដូចខាងក្រោមទេ៖

ក- ភាពគ្រប់គ្រាន់នៃដើមទុនរបស់អ្នកចូលរួម

ខ- ការគ្រប់គ្រងលើវិនិយោគរបស់អ្នកចូលរួម

គ- អភិបាលកិច្ចសាជីវកម្មរបស់អ្នកចូលរួម

ឃ- ទំនាក់ទំនងរបស់អ្នកចូលរួមជាមួយអតិថិជនដែលមិនមែនជាអ្នកចូលរួមដោយផ្ទាល់ក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

ង- រចនាសម្ព័ន្ធកម្មសិទ្ធិរបស់អ្នកចូលរួម។

៤- សេចក្តីណែនាំអាចតម្រូវថា កាតព្វកិច្ចទូទាត់សងប្រាក់ដែលកើតចេញពីការជាត់ទាត់នៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវតែបានទូទាត់តាមរយៈការកែតម្រូវចំពោះគណនីមួយ ឬ ច្រើនរបស់អ្នកចូលរួមមួយ ឬច្រើននៅធនាគារជាតិនៃកម្ពុជា។

៥- សេចក្តីណែនាំ ប្រសិនបើមានចែងដូច្នេះ នឹងអនុវត្តចំពោះប្រព័ន្ធជាត់ទាត់ និងទូទាត់ដែលបានចាត់តាំងដែលត្រូវបានបង្កើតឡើងដោយ ឬក្រោមច្បាប់ណាមួយ។

៦- សេចក្តីណែនាំត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច។

៧- សេចក្តីណែនាំគឺជាចំណែងកាតព្វកិច្ចចំពោះបុគ្គលដែលស្ថិតក្រោមសេចក្តីណែនាំនោះ។

ប្រការ ៥.-

១- ធនាគារជាតិនៃកម្ពុជាអាចធ្វើអ្វីៗទាំងអស់ ឬអ្វីមួយដូចខាងក្រោម ក្នុងទំនាក់ទំនងជាមួយប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង និងសភាជាត់ទាត់នៃប្រព័ន្ធនោះ៖

ក- ផ្តល់ការធានាដោយមាន ឬគ្មានវត្ថុបញ្ចាំចំពោះការទូទាត់សងប្រាក់ពីអ្នកចូលរួម

ខ- ផ្តល់ឥណទានសាច់ប្រាក់ងាយស្រួលដល់សភាជាត់ទាត់ និងភាគីបដិភាគចម្បង និង

គ- ដើរតួជាភាគីបដិភាគចម្បងចំពោះអ្នកចូលរួម។

២- ប្រសិនបើធនាគារជាតិនៃកម្ពុជាយល់ឃើញថា ការចូលរួមនៅក្នុងប្រព័ន្ធជាត់ទាត់ និងទូទាត់ ដែលបានចាត់តាំងដោយអ្នកចូលរួមធ្វើឱ្យ ឬទំនងជាធ្វើឱ្យមានហានិភ័យជាប្រព័ន្ធដែលមិនអាចទទួលយកបាន ឬហានិភ័យដែលមិនអាចទទួលយកបានចំពោះធនាគារជាតិនៃកម្ពុជាក្នុងការធានាការទូទាត់សងបំណុលរបស់អ្នកចូលរួមនោះ ធនាគារជាតិនៃកម្ពុជាអាចពន្យារការចូលរួមរបស់អ្នកចូលរួមនោះ ហាមឃាត់មិនឱ្យចូលរួម ឬអាចទាមទារឱ្យអ្នកចូលរួមបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធនឹងការចូលរួមរបស់ខ្លួនតាមដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាជាការចាំបាច់។

ប្រការ ៦.-

១- ក្នុងប្រការ ៦ និងប្រការ ៧ បណ្តឹងអំពីអសាធនភាព សំដៅដល់វិធានការរួមដែលកំណត់ដោយច្បាប់ ដើម្បីបញ្ចប់សកម្មភាពរបស់អ្នកចូលរួម ឬដើម្បីរៀបចំអ្នកចូលរួមនោះឡើងវិញ ទោះដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តក្តី ដែលវិធានការទាំងនោះ រួមមានការព្យួរ ឬការដាក់កំហិតលើបញ្ជាទូទាត់ និងការទូទាត់សងប្រាក់។

២- បញ្ជាទូទាត់ដែលចូលទៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង និងក្នុងការទូទាត់សុទ្ធនៃប្រព័ន្ធនោះ ត្រូវតែអនុវត្តបានដោយស្របច្បាប់ ទោះបីជាក្នុងករណីមានបណ្តឹងអំពីអសាធនភាពទល់នឹងអ្នកចូលរួមក្តី និងត្រូវតែជាចំណងនីត្យានុកូលលើភាគីទីបីនៅក្នុងលក្ខខណ្ឌថាបញ្ជាទូទាត់ត្រូវបានចូលទៅក្នុងប្រព័ន្ធមុនពេលមានបើកបណ្តឹងអំពីអសាធនភាពនោះ។

៣- នៅពេលណាដែលបញ្ជាទូទាត់ត្រូវបានចូលទៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងក្រោយពេលបើកបណ្តឹងអំពីអសាធនភាព និងត្រូវបានអនុវត្តនៅថ្ងៃបើកបណ្តឹងបែបនេះ បញ្ជាទូទាត់ទាំងនោះត្រូវតែអាចអនុវត្តដោយស្របច្បាប់ និងត្រូវតែជាចំណងនីត្យានុកូលលើភាគីទីបីតែប៉ុណ្ណោះ ប្រសិនបើក្រោយពេលទូទាត់ ភាគីបដិភាគចម្បង ឬសភាជាត់ទាត់អាចបញ្ជាក់អះអាងថា ពួកគេមិនបានដឹង ឬមិនត្រូវបានឱ្យដឹងអំពីការបើកបណ្តឹងបែបនេះ។

៤- ពេលវេលាដែលបញ្ជាទូទាត់ចូលមកក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងត្រូវតែបានកំណត់ដោយវិធាននៃប្រព័ន្ធនេះ។

៥- ចំពោះគោលបំណងនៃប្រការនេះ ពេលវេលានៃការបើកបណ្តឹងអំពីអសាធនភាពត្រូវតែជាពេលវេលា ដែលអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការបានធ្វើសេចក្តីសម្រេច។

៦- នៅពេលណាដែលសេចក្តីសម្រេចត្រូវបានធ្វើឡើងអនុលោមតាមកថាខណ្ឌទី៥ អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះជាបន្ទាន់ដល់ធនាគារជាតិនៃកម្ពុជា។

៧- បណ្តឹងអំពីអសាធនភាព មិនត្រូវមានឥទ្ធិពលប្រតិសកម្មទៅលើសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកចូលរួមដែលកើតឡើងពីការផាត់ទាត់និងទូទាត់បំណុលតាមប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងនៅគ្រាមុនពេលបើកបណ្តឹងនេះឡើយ។

ប្រការ ៧.-

១- ក្នុងប្រការនេះ វិធានទូទាត់ សំដៅដល់វិធានដែលត្រូវបានបង្កើតឡើងតាមវិធីណាមួយដែលផ្តល់ជាមូលដ្ឋានសម្រាប់គណនាកាតព្វកិច្ចទូទាត់សងប្រាក់ចំនួនសុទ្ធ ឬត្រូវបានទូទាត់ និងដែលរួមបញ្ចូលផងដែរនូវវិធានច្បាប់ដើម្បីចាត់វិធានការក្នុងព្រឹត្តិការណ៍ដែលអ្នកចូលរួមគ្មានលទ្ធភាព ឬទំនងជាគ្មានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សងរបស់ខ្លួនចំពោះសភាផាត់ទាត់ ភាគីបដិភាគចម្បង ឬអ្នកចូលរួមដទៃទៀត។

២- ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតចែងផ្ទុយពីនេះ៖

ក- វិធានទូទាត់នៃប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងមានសុពលភាព និងជាចំណងកាតព្វកិច្ចចំពោះសភាផាត់ទាត់ អ្នកចូលរួម ភាគីបដិភាគចម្បង និងធនាគារជាតិនៃកម្ពុជា។ សកម្មភាពណាមួយ ឬការទូទាត់សងប្រាក់ណាមួយអាចនឹងត្រូវបានធ្វើឡើងដោយអនុលោមតាមវិធានទូទាត់នេះ។

ខ- កាតព្វកិច្ចរបស់អ្នកចូលរួម សភាផាត់ទាត់ ឬភាគីបដិភាគចម្បងក្នុងការទូទាត់សងប្រាក់ឱ្យអ្នកចូលរួមម្នាក់ និងសិទ្ធិរបស់អ្នកចូលរួមសភាផាត់ទាត់ ឬភាគីបដិភាគចម្បងដើម្បីទទួលបានការទូទាត់សងប្រាក់ពីអ្នកចូលរួម សភាផាត់ទាត់ ឬភាគីបដិភាគចម្បងត្រូវតែបានគណនាជាចំនួនសុទ្ធ ហើយចំនួនប្រាក់ទូទាត់សុទ្ធ ឬចំនួនប្រាក់បិទបញ្ជីត្រូវតែបានកំណត់ស្របតាមវិធានទូទាត់នៃប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងប្រសិនបើមានចែងបែបនេះ និង

គ- នៅពេលដែលវិធានទូទាត់នៃប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងបានចែងថាការទូទាត់កាតព្វកិច្ចទូទាត់សងប្រាក់តាមរយៈការទូទាត់ចូល ឬការទូទាត់ចេញពីគណនីរបស់អ្នកចូលរួមសភាផាត់ទាត់ ឬភាគីបដិភាគចម្បងនៅធនាគារជាតិនៃកម្ពុជាត្រូវបានបញ្ចប់ជាស្ថាពរ និងមិនអាចបដិសេធបាន ការទូទាត់សងប្រាក់ចូលឬចេញនោះនឹងមិនត្រូវបានចុះបញ្ច្រាសទូទាត់សងត្រឡប់វិញ ឬទុកដោយឡែកសិនបានឡើយ។

៣- ការទូទាត់សងប្រាក់ចូល ឬចេញពីគណនីរបស់អ្នកចូលរួម សភាផាត់ទាត់ ឬភាគីបដិភាគចម្បងនៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចបំណុលក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់ដែលបានចាត់តាំងមិនត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ ឬបញ្ហាណាមួយដែលមានលក្ខណៈជាការពន្យារពេលនៃសកម្មភាពនោះទេ។

៤- សិទ្ធិនិងដំណោះស្រាយរបស់អ្នកចូលរួម សភាជាត់ទាត់ ភាគីបដិភាគចម្បង ឬធនាគារជាតិនៃកម្ពុជា ចំពោះប្រាតិភោគដែលផ្តល់ការធានាចំពោះការទូទាត់សងប្រាក់ ឬការអនុវត្តកាតព្វកិច្ចដែលកើតមាននៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង អាចមិនត្រូវបានទទួលរងឥទ្ធិពលពីបណ្តឹងអសាធនភាពឡើយ។ ជាពិសេស សិទ្ធិនិងដំណោះស្រាយទាំងនេះ អាចមិនត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិពន្យារពេល ឬ បញ្ឈាណាមួយ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់ឥណទាយកក្នុងការអនុវត្តសិទ្ធិនិងដំណោះស្រាយរបស់ខ្លួនពាក់ព័ន្ធដល់ប្រាតិភោគនោះឡើយ។

៥- ទោះបីជាការគ្រប់គ្រង ឬប្រតិបត្តិការទាំងអស់ ឬមួយផ្នែកនៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវបានធ្វើឡើងនៅក្រៅប្រទេសកម្ពុជា ឬវិធានទូទាត់នៃប្រព័ន្ធនោះត្រូវបានគ្រប់គ្រងដោយច្បាប់នៃយុត្តាធិការបរទេសក្តី នៅពេលដែលក្នុងបណ្តឹងណាមួយក្នុងប្រទេសកម្ពុជា តុលាការកំណត់ថា សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលណាមួយដែលកើតចេញ ឬមានពាក់ព័ន្ធជាមួយប្រតិបត្តិការរបស់ប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងត្រូវបានគ្រប់គ្រងទាំងមូល ឬមួយផ្នែកដោយច្បាប់របស់កម្ពុជា បទប្បញ្ញត្តិនៃប្រការនេះត្រូវតែអនុវត្តក្នុងកម្រិតមួយដែលច្បាប់កម្ពុជាបានអនុវត្តក្នុងការកំណត់សិទ្ធិ និងកាតព្វកិច្ចទាំងនោះ។

ប្រការ ៨.-

១- ពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង សភាជាត់ទាត់នីមួយៗត្រូវផ្តល់ដំណឹងជាមុនដល់ធនាគារជាតិនៃកម្ពុជា អំពីការកែប្រែទាំងឡាយណាដែលធ្វើឡើងដោយសភាជាត់ទាត់ដែលមានលក្ខណៈសំខាន់ចំពោះប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងនោះ និងដោយពុំមានកំណត់តែចំពោះការកែប្រែជាទូទៅទេ សេចក្តីជូនដំណឹងត្រូវតែបានធ្វើឡើង ចំពោះរាល់ការកែប្រែទាំងឡាយណាដែលមានផលប៉ះពាល់ទៅលើ៖

ក- ឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងការកសាង បង្កើត រៀបចំ អភិបាលកិច្ច និងប្រតិបត្តិការរបស់សភាជាត់ទាត់ រួមទាំងផ្នែកទាំងឡាយនៃឯកសារនោះ ឬអនុស្សារណៈសមាគម ប្រកាស និងសេចក្តីសម្រេចសំខាន់ៗ និងកិច្ចសម្របសម្រួលវិធាន និងនីតិវិធីផងដែរ

ខ- ប្រតិបត្តិការនៃប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ឬ

គ- ប្រកាស កិច្ចសម្របសម្រួល វិធាន នីតិវិធី សេចក្តីណែនាំ ឬឯកសារផ្សេងៗទៀតដែលគ្រប់គ្រងលើប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង។

២- បន្ទាប់ពីបានធ្វើការកែប្រែពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំងនោះ សភាជាត់ទាត់នីមួយៗត្រូវតែផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃកម្ពុជាអំពីការកែប្រែនេះ និងដោយពុំមានកំណត់តែចំពោះការកែប្រែជាទូទៅទេ សេចក្តីជូនដំណឹងត្រូវតែបានធ្វើឡើងចំពោះរាល់ការកែប្រែទាំងឡាយណាដែលមានផលប៉ះពាល់ទៅលើ៖

ក- សមាសភាពរបស់សមាជិកក្រុមប្រឹក្សាភិបាលសភាជាត់ទាត់ ដោយសារការលាឈប់ពីដំណែង ឬពីមូលហេតុផ្សេងទៀត ឬ

ខ- សវនករសភាជាត់ទាត់ដែលត្រូវបានតែងតាំង។

៣- ពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង សភាជាត់ទាត់នីមួយៗត្រូវផ្តល់ដំណឹងដល់ធនាគារជាតិនៃកម្ពុជានូវព័ត៌មានទាំងនោះ តាមពេលវេលានិងទម្រង់បែបបទដែលធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ។

ប្រការ ៥.-

១- ក្នុងគោលបំណងអនុវត្តភារកិច្ចដូចដែលមានចែងក្នុងប្រការនេះ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិធ្វើសវនកម្ម និងអធិការកិច្ចលើសភាជាត់ទាត់ ហើយសភាជាត់ទាត់នីមួយៗប្រសិនបើមានការស្នើសុំ ត្រូវតែជួយដល់ធនាគារជាតិនៃកម្ពុជាតាមការចាំបាច់ ដើម្បីបង្កលក្ខណៈឱ្យធនាគារជាតិនៃកម្ពុជាអាចធ្វើសវនកម្ម និងអធិការកិច្ចបាន។

២- ធនាគារជាតិនៃកម្ពុជាអាចប្រគល់ឱ្យសវនករឯករាជ្យខាងក្រៅធ្វើសវនកម្មនិងអធិការកិច្ចទាំងស្រុង ឬមួយផ្នែកក្នុងនាមរបស់ខ្លួន ដូចដែលមានចែងក្នុងកថាខណ្ឌទី១ ហើយត្រូវរាយការណ៍ជូនធនាគារជាតិនៃកម្ពុជា។

៣- ក្នុងគោលបំណងទទួលបានភស្តុតាងត្រឹមត្រូវពាក់ព័ន្ធនឹងការធ្វើសវនកម្ម ឬអធិការកិច្ចក្រោមកថាខណ្ឌទី១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចជាបុគ្គលដែលត្រូវបានតែងតាំងជាស្នងការគណនីក្រោមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

៤- ធនាគារជាតិនៃកម្ពុជាអាចអនុវត្តនូវមុខងារទាំងអស់ ឬមុខងារមួយដែលពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ និងសភាជាត់ទាត់ដូចខាងក្រោម៖

ក- ជាអ្នកចូលរួម ចូលរួមនិងធ្វើសកម្មភាពជាភាគីបដិភាគចម្បង រួមទាំងនៅក្នុងយន្តការបែងចែកការខាតបង់

ខ- ធ្វើសកម្មភាពជាអ្នករក្សាទុកទ្រព្យសកម្មហិរញ្ញវត្ថុ ឬជាភ្នាក់ងារទូទាត់ ឬធ្វើទាំងពីរ និង

គ- ទទួលប្រាក់បញ្ញើពីសភាជាត់ទាត់ អ្នកចូលរួម ឬភាគីបដិភាគចម្បង ឬទូទាត់សងការប្រាក់។

៥- នៅពេលណាដែលធនាគារជាតិនៃកម្ពុជាមានមូលហេតុសមស្របនឹងជឿជាក់ថាប្រព័ន្ធមួយ ឬកិច្ចសម្របសម្រួលមួយត្រូវបានបង្កើតឡើងសម្រាប់ការជាត់ទាត់និងទូទាត់កាតព្វកិច្ច ឬសារសម្រាប់ទូទាត់សងប្រាក់ ប៉ុន្តែធនាគារជាតិនៃកម្ពុជាត្រូវការព័ត៌មានបន្ថែមទៀតដើម្បីកំណត់ថាប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះជាប្រព័ន្ធជាត់ទាត់និងទូទាត់ ធនាគារជាតិនៃកម្ពុជាអាចស្នើទៅបុគ្គលណាម្នាក់ដែលជាភាគីនៃប្រព័ន្ធ ឬកិច្ចសម្របសម្រួលនោះឱ្យផ្តល់ព័ត៌មាន និងឯកសារផ្សេងៗដែលទាក់ទងនឹងប្រព័ន្ធ ឬ

កិច្ចសម្របសម្រួលនោះ តាមដែលធនាគារជាតិនៃកម្ពុជាត្រូវការដើម្បីធ្វើការកំណត់។ រាល់បុគ្គលទាំងឡាយណាដែលទទួលបានសំណើក្រោមកថាខណ្ឌនេះត្រូវតែគោរពតាមសំណើនោះ។

៦- ពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់របស់ខ្លួន សភាជាត់ទាត់នីមួយៗ ត្រូវផ្តល់ព័ត៌មាននិងឯកសារទាំងឡាយដល់ធនាគារជាតិនៃកម្ពុជា តាមដែលធនាគារជាតិនៃកម្ពុជាអាចតម្រូវជាក់ស្តែង ដើម្បីផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាឱ្យអាចកំណត់បានថាតើប្រព័ន្ធជាត់ទាត់និងទូទាត់នោះបង្កឱ្យមានហានិភ័យជាប្រព័ន្ធដែរឬទេ ដោយពុំមានការកំណត់ ចំពោះតែព័ត៌មានជាទូទៅពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ សភាជាត់ទាត់ចាំបាច់ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវព័ត៌មានដូចខាងក្រោម៖

ក- ឈ្មោះអ្នកចូលរួមរបស់ខ្លួន

ខ- ច្បាប់ចម្លងនៃឯកសារទាំងឡាយណាពាក់ព័ន្ធនឹងការកសាង បង្កើត រៀបចំ អភិបាលកិច្ច និងប្រតិបត្តិការរបស់សភាជាត់ទាត់រួមទាំងផ្នែកទាំងឡាយនៃឯកសារនោះ ឬ អនុស្សារណៈសមាគម ប្រកាស និងសេចក្តីសម្រេចសំខាន់ៗរបស់សភាជាត់ទាត់ កិច្ចសម្របសម្រួល វិធាន និងនីតិវិធីផងដែរ

គ- ឈ្មោះរបស់នាយកចាត់ចែង សមាជិកគណៈកម្មការ និងសវនករ

ឃ- ច្បាប់ចម្លងនៃរបាយការណ៍ សេចក្តីថ្លែងការណ៍ ឬឯកសារដទៃទៀតរបស់ខ្លួនដែលត្រូវបានទាមទារឱ្យរក្សាទុកនៅនឹងស្ថាប័នរដ្ឋាភិបាលឬអង្គភាពបញ្ញត្តិកម្មនិង

ង- ច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុ។

៧- នៅក្នុងប្រការនេះ ធនាគារជាតិនៃកម្ពុជាមិនតម្រូវឱ្យអ្នកចូលរួមណាមួយផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអ្នកចូលរួមដទៃមួយទៀតនៃប្រព័ន្ធជាត់ទាត់ណាមួយទេ ប្រសិនបើព័ត៌មាននោះមិនមានសម្រាប់ការប្រើប្រាស់របស់អ្នកចូលរួមទាំងអស់គ្នា។

ប្រការ ១០.-

១- នៅក្នុងប្រការនេះ៖

ក- តម្លៃបញ្ចប់សុទ្ធ សំដៅដល់ចំនួនប្រាក់សុទ្ធដែលទទួលបានពីការកាត់កង ឬការជាត់ទាត់កាតព្វកិច្ចសុទ្ធរវាងភាគីនានានៃកិច្ចព្រមព្រៀងជាត់ទាត់សុទ្ធ អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនោះ។

ខ- កិច្ចព្រមព្រៀងជាត់ទាត់សុទ្ធ សំដៅដល់កិច្ចព្រមព្រៀងរវាងគ្រឹះស្ថានហិរញ្ញវត្ថុពីរ ឬច្រើន ឬរវាងធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើនដែលផ្តល់នូវការជាត់ទាត់ ឬកាត់កងកាតព្វកិច្ចទូទាត់សងប្រាក់បច្ចុប្បន្ន ឬអនាគតទល់នឹងសិទ្ធិបច្ចុប្បន្ន ឬអនាគតក្នុងការទទួលការទូទាត់សងប្រាក់។

២- ទោះបីជាមានបទប្បញ្ញត្តិក្នុងច្បាប់ណាមួយដែលពាក់ព័ន្ធ ឬមិនពាក់ព័ន្ធក្តីទៅនឹងច្បាប់ក្ស័យធន ឬក៏ដីការរបស់តុលាការដែលធ្វើឡើងដោយអនុលោមទៅតាមការគ្រប់គ្រងនៃការរៀបចំឡើងវិញ កិច្ចព្រមព្រៀង ឬភាពជាអ្នកទទួលសំណងពាក់ព័ន្ធនឹងអសាធនភាពដែលនៅក្នុងនោះគ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារជាតិនៃកម្ពុជាជាភាគីមួយនៃកិច្ចព្រមព្រៀងជាត់ទាត់សុទ្ធ គ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារជាតិនៃកម្ពុជាអាចបញ្ចប់កិច្ចព្រមព្រៀង ឬកំណត់តម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធ អនុលោមតាមបទប្បញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀង។ ភាគីដែលមានសិទ្ធិទទួលបានតម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធ ត្រូវតែជាឥណទាយកនៃភាគីដែលជំពាក់តម្លៃបញ្ចប់សុទ្ធ ឬចំនួនប្រាក់ទូទាត់សុទ្ធក្នុងតម្លៃ ឬចំនួនប្រាក់នោះ។

ប្រការ ១១.-

១- នៅពេលណាសភាជាត់ទាត់ខកខានមិនបានអនុវត្តកាតព្វកិច្ចដែលតម្រូវដោយប្រកាសនេះពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់របស់ខ្លួន ឬមិនគោរពតាមប្រកាសនេះ អ្នកចូលរួមទាំងអស់ត្រូវរួមគ្នាអនុវត្តកាតព្វកិច្ចទាំងនោះ ហើយអ្នកចូលរួមទាំងនោះត្រូវទទួលខុសត្រូវចំពោះការមិនគោរពកាតព្វកិច្ចទាំងនោះក្នុងលក្ខណៈ និងកម្រិតដូចជាសភាជាត់ទាត់ដែរ។

២- នៅពេលណាប្រព័ន្ធជាត់ទាត់និងទូទាត់មួយមិនមានសភាជាត់ទាត់ ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាទេនោះ អ្នកចូលរួមដែលមានទីតាំងនៅប្រទេសកម្ពុជា

ក- ត្រូវគោរពតាមកាតព្វកិច្ចទាំងឡាយដែលបានដាក់ចេញនៅក្រោមប្រការនេះអំពីសភាជាត់ទាត់ចំពោះការងារពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់ និង

ខ- មានសិទ្ធិគ្រប់យ៉ាងដែលត្រូវបានផ្តល់ឱ្យនៅក្នុងប្រការនេះស្តីពីសភាជាត់ទាត់ ចំពោះការងារពាក់ព័ន្ធនឹងប្រព័ន្ធជាត់ទាត់និងទូទាត់

ក្នុងលក្ខណៈនិងកម្រិតដូចគ្នា ដូចជាអ្នកចូលរួមដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាជាសភាជាត់ទាត់ដែលក្នុងនេះកាតព្វកិច្ច និងសិទ្ធិទាំងនោះត្រូវបានតម្រូវ និងក្នុងគោលបំណងនេះ វិធានការនានាដែលធនាគារជាតិនៃកម្ពុជាអាចដាក់ចុះពាក់ព័ន្ធនឹងសភាជាត់ទាត់អាចនឹងត្រូវបានអនុវត្តតែចំពោះអ្នកចូលរួមដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ដើម្បីគោលបំណងនៃកថាខណ្ឌនេះ អ្នកចូលរួមត្រូវបានចាត់ទុកថាមានទីតាំងនៅកម្ពុជានៅពេលណា ពួកគេត្រូវបានបង្កើតឡើងនៅក្រោមច្បាប់នៃប្រទេសកម្ពុជា។

៣- ធនាគារបរទេសដែលជាអ្នកចូលរួម ឬមានបំណងធ្វើជាអ្នកចូលរួមនៅក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់ដែលបានចាត់តាំង ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវព័ត៌មានដែលទាក់ទងទៅនឹងការអនុវត្តច្បាប់បរទេសចំពោះធនាគារបរទេសដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាចាំបាច់។

ប្រការ ១២.-

១- ការគោរពតាមបទប្បញ្ញត្តិនៃប្រកាសនេះ ឬសេចក្តីណែនាំចេញដោយធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងបញ្ហាណាមួយនៅក្រោមបទប្បញ្ញត្តិខាងលើ ឬការស្នើសុំព័ត៌មានដោយស្របច្បាប់នៅក្រោមប្រកាសនេះ អាចនឹងត្រូវបានអនុវត្តតាមរយៈការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជាទៅកាន់តុលាការមានសមត្ថកិច្ចឱ្យចេញដីកាបង្គាប់ឱ្យគោរពតាមបទប្បញ្ញត្តិ វិធាន សេចក្តីណែនាំ ឬសំណើនោះ។ ដោយផ្អែកលើការស្នើសុំនេះ តុលាការអាចចេញដីកាតាមនោះ ឬដីកាបន្ថែមទៀត ប្រសិនបើយល់ថាចាំបាច់។

២- ចំពោះការស្នើសុំការត្រួតពិនិត្យដោយតុលាការលើការចាត់តាំងណាមួយក្រោមប្រកាសនេះ ឬសេចក្តីណែនាំពាក់ព័ន្ធដែលត្រូវបានចេញផ្សាយ មិនត្រូវមានការផ្តល់ឱ្យនូវការពន្យារពេលការចាត់តាំង ឬសេចក្តីណែនាំដើម្បីរង់ចាំសេចក្តីសម្រេចចុងក្រោយលើការស្នើសុំសេចក្តីណែនាំឡើយ។

ប្រការ ១៣.-

១- ព័ត៌មាននិងឯកសារដែលទទួលបាននៅក្រោមប្រកាសនេះត្រូវរក្សាជាការសម្ងាត់ និងត្រូវចាត់ចែងជាការសម្ងាត់ដូចគ្នា។

២- ខ្លឹមសារក្នុងកថាខណ្ឌទី១ មិនហាមឃាត់ធនាគារជាតិនៃកម្ពុជាក្នុងការផ្សព្វផ្សាយព័ត៌មាន ឬឯកសារណាមួយទៅអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នបញ្ញត្តិកម្មដែលទទួលបន្ទុកគ្រប់គ្រងលើគ្រឹះស្ថានហិរញ្ញវត្ថុឡើយ នៅក្នុងលក្ខខណ្ឌដែលធនាគារជាតិនៃកម្ពុជាមានទំនុកចិត្តថា ព័ត៌មាន ឬឯកសារ ទាំងនោះត្រូវបានរក្សាទុកជាការសម្ងាត់ដោយស្ថាប័ន អង្គភាព និងបុគ្គលទាំងនោះ។

ប្រការ ១៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៥.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៩-០៦-២៤០ ប្រ.ក

ប្រកាស
ស្តីពី
ប្រតិបត្តិការនៃគណនីទូទាត់

ប្រការ ១.-

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សង់ប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួនដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេង៖

១. **ធនាគារ** សំដៅដល់ធនាគារ ដូចមានចែងក្នុងមាត្រា ២ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា។

២. **ការទូទាត់សងប្រាក់ធនាគារទ្វេភាគី** សំដៅដល់ការទូទាត់ពីធនាគារមួយទៅធនាគារមួយផ្សេងទៀត។

៣. **ការទូទាត់** សំដៅដល់ការទូទាត់ចេញពី ឬចូលក្នុងគណនីទូទាត់។

៤. **ការទូទាត់សងប្រាក់ធនាគារតែមួយ** សំដៅដល់ការទូទាត់ប្រាក់រវាងធនាគារ និងធនាគារជាតិនៃកម្ពុជា។

៥. **អ្នកដំណើរការតតិយភាគី** សំដៅដល់អ្នកផ្តល់មធ្យោបាយសម្រាប់ដំណើរការបញ្ជាទូទាត់ក្នុងនាមធនាគារ។

ប្រការ ២.-

១. ការជាត់ទាត់និងការទូទាត់នឹងធ្វើរាល់ថ្ងៃធ្វើការ របស់ធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះដូរបញ្ជាទូទាត់ដែលពាក់ព័ន្ធនឹងការទូទាត់សងប្រាក់ធនាគារតែមួយ និងទ្វេភាគី។

២. ដើម្បីចូលរួមក្នុងការជាត់ទាត់និងការទូទាត់ បញ្ជាទូទាត់អន្តរធនាគារមួយនឹងឆ្លុះបញ្ចាំងពីប្រតិបត្តិការទូទាត់ក្នុងនាមអតិថិជនម្នាក់ ឬធនាគារចូលរួមមួយ។ បញ្ជាទូទាត់ដែលបានប្រគល់ដោយផ្ទាល់ពីអតិថិជនទៅអ្នកដំណើរការតតិយភាគីតាមការបញ្ជារបស់ធនាគារខ្លួន ត្រូវបានចាត់ទុកជាបញ្ជាទូទាត់ផ្ទាល់របស់ធនាគារដែលអនុវត្តតាមបញ្ជារបស់អតិថិជន។

៣. អ្នកចូលរួមក្នុងការជាត់ទាត់និងការទូទាត់គឺជាធនាគារ។ ការទូទាត់អន្តរធនាគារនៃការជាត់ទាត់ធ្វើឡើងនៅលើគណនីទូទាត់របស់ធនាគារដែលរក្សានៅធនាគារជាតិនៃកម្ពុជា។

៤. ធនាគារត្រូវគោរពតាមប្រកាសនេះ និងនីតិវិធីប្រតិបត្តិការនានាក៏ដូចជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងប្រការជាបន្តបន្ទាប់ទៅនេះ។

៥. ប្រកាសនេះអនុវត្តតែចំពោះការផ្ទេរឥណទាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងគណនីទូទាត់ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ។

ប្រការ ៣.-

១. ដើម្បីអាចបញ្ចូលទៅក្នុងការទូទាត់បាន បញ្ជាទូទាត់នីមួយៗត្រូវតែសម្រាប់ការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគី និង/ឬ ចូលក្នុងគណនីទូទាត់។ បញ្ជាទូទាត់ត្រូវមានចែងសេចក្តីណែនាំដោយគ្មានលក្ខខណ្ឌនិងមិនអាចបដិសេធបានចំពោះការទូទាត់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ហើយមិនត្រូវស្ថិតនៅក្រោមការរឹតត្បិត ឬការដាក់កម្រិតណាឡើយ លើកលែងតែបញ្ជាទូទាត់នេះមានកំណត់ថ្ងៃប្រសិទ្ធភាព ដូចបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ។ បញ្ជាទូទាត់ត្រូវគោរពតាមលក្ខណៈជាក់លាក់ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ និងត្រូវបញ្ជូនទៅធនាគារណាមួយ ឬធនាគារជាតិនៃកម្ពុជា។

២. ក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ បញ្ជាទូទាត់ដែលគោរពតាមកថាខណ្ឌទី១ នៃប្រការនេះនឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជា តាមការចុះឥណពន្ធនិង/ឬឥណទានក្នុងគណនីទូទាត់។ បញ្ជាទូទាត់ដែលមិនគោរពតាមកថាខណ្ឌទី១ នៃប្រការនេះ ឬមិនអាចបញ្ជូនបានដោយសារទិន្នន័យមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ មិនអាចបញ្ជាក់យថាភូតបាន ឬហេតុផលផ្សេងទៀត ព្រមទាំងបញ្ជាទូទាត់នីមួយៗ ដែលបានផ្ញើខុសអាសយដ្ឋាន ត្រូវបញ្ជូនត្រឡប់ទៅធនាគារផ្ញើវិញដោយអនុលោមតាមលេខកូដតែមួយដែលបានជ្រើសយកសម្រាប់ផ្ញើត្រឡប់វិញនេះ ដែលផ្តល់ដោយធនាគារចូលរួមនីមួយៗ។

ប្រការ ៤.-

រាល់ធនាគារកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជាដែលមានបំណងចូលរួមការទូទាត់បញ្ជាទូទាត់ក្នុងស្រុក ត្រូវបើកនិងរក្សាគណនីទូទាត់ក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជា ហើយត្រូវបើកនិងដាក់ឱ្យដំណើរការនូវគណនីនោះតាមលក្ខខណ្ឌ និងការកំណត់ដូចដែលបានសម្រេចដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

១. ចំពោះរាល់ធនាគារ ការទូទាត់សងប្រាក់នីមួយៗដូចខាងក្រោមដែលផ្តើមឡើងដោយបញ្ជាទូទាត់អាចត្រូវបានធ្វើឡើងដោយបញ្ចូលទៅក្នុង និងដកចេញពីគណនីទូទាត់៖

   ក. ការទូទាត់សងប្រាក់ធនាគារតែមួយ

   ខ. ការទូទាត់សងប្រាក់ធនាគារទ្វេភាគី

២. ធនាគារជាតិនៃកម្ពុជានឹងមិនចុះឥណពន្ធទូទាត់ ឬអនុញ្ញាតឱ្យដកសាច់ប្រាក់ចេញពីគណនីនេះទេ លុះត្រាតែមានសមតុល្យគ្រប់គ្រាន់ដើម្បីធានាចំនួនឥណពន្ធ ឬការដកប្រាក់។

៣. ការទូទាត់សងប្រាក់ធនាគារតែមួយ ដូចជាការដកសាច់ប្រាក់ ឬការដាក់ប្រាក់បញ្ញើនឹងត្រូវបានចុះកិច្ចបញ្ជិកាដោយធនាគារជាតិនៃកម្ពុជាទៅក្នុងគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ចេញពីគណនីទូទាត់របស់នៅធនាគារជាតិនៃកម្ពុជា ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធចំពោះគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ដោយធនាគារជាតិនៃកម្ពុជាចូលក្នុងគណនីទូទាត់ត្រូវធ្វើឡើងតាមរយៈការចុះឥណទានចំពោះគណនីទូទាត់

របស់ធនាគារ។ ការទូទាត់សងប្រាក់ក្នុងធនាគារតែមួយនឹងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន នៅពេលណាបានចុះកិច្ចបញ្ជិកាខ្វង់ឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៤. ការទូទាត់សងប្រាក់ធនាគារទ្វេភាគីអាចផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់ទៅកាន់ធនាគារជាតិនៃកម្ពុជា ដើម្បីចុះឥណពន្ធគណនីទូទាត់សងប្រាក់ និងចុះឥណទានគណនីទូទាត់របស់ធនាគារមួយទៀត។ ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ និងចុះឥណទានព្រមគ្នាលើគណនីទូទាត់របស់ធនាគារមួយផ្សេងទៀត។ ការទូទាត់សងប្រាក់ធនាគារទ្វេភាគីនិងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន នៅពេលណាបានចុះបញ្ជិកាខ្វង់ឥណពន្ធ និងឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៥. លិខិតបញ្ជាក់តាមរយៈការជូនដំណឹងការចុះកិច្ចបញ្ជិកាខ្វង់ឥណពន្ធ ឬឥណទានទៅក្នុងគណនីទូទាត់នៅក្រោមកថាខណ្ឌនេះ ត្រូវផ្ញើដោយធនាគារជាតិនៃកម្ពុជាទៅកាន់ធនាគារដែលចូលរួមនៅក្នុងការទូទាត់សង់ប្រាក់ធនាគារតែមួយ ឬទ្វេភាគីនោះ។ ការជូនដំណឹងត្រូវធ្វើឡើងភ្លាមបន្ទាប់ពីការបញ្ចប់ការជាត់ទាត់ប្រចាំថ្ងៃដូចដែលបានកំណត់ក្នុងនីតិវិធីប្រតិបត្តិការ។

៦. ខ្វង់ឥណពន្ធចំពោះការដកសាច់ប្រាក់ដោយធនាគារ ត្រូវតែបានចុះកិច្ចបញ្ជិកាជាបន្ទាន់ដោយធនាគារជាតិនៃកម្ពុជា ទៅក្នុងគណនីទូទាត់របស់ធនាគារនោះភ្លាមបន្ទាប់ពីការដកសាច់ប្រាក់។

៧. ចំពោះរាល់ប្រតិបត្តិការទូទាត់សងប្រាក់ ការទូទាត់ត្រូវបានបញ្ចប់នៅពេលណាដែលលទ្ធផលនៃខ្វង់ឥណពន្ធ ឬខ្វង់ឥណទាននៃការទូទាត់នោះត្រូវបានចុះកិច្ចបញ្ជិកាគណនីទូទាត់របស់ធនាគារជាភាគីនៃការទូទាត់សងប្រាក់បានក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន។

ប្រការ ៦.-

១. បញ្ជាទូទាត់ដែលបញ្ជាឱ្យធនាគារជាតិនៃកម្ពុជាអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគីអាចត្រូវបានប្រគល់ដោយធនាគារទៅឱ្យធនាគារជាតិនៃកម្ពុជា ជាបញ្ជាទូទាត់មួយៗដោយឡែក ឬជាផ្នែកនៃសំណុំមួយ។

២. ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តការទូទាត់ចំពោះបញ្ជាទូទាត់នីមួយៗ ដែលបានបញ្ជូនមក៖

- តែនៅពេលណាដែលគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់ប៉ុណ្ណោះ និង
- នៅពេលណាមួយមុនពេលបញ្ចប់ការជាត់ទាត់ប្រចាំថ្ងៃ ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ។

ចំពោះបញ្ជាទូទាត់មានថ្ងៃប្រសិទ្ធភាពដូចដែលបានចែងក្នុងនីតិវិធីប្រតិបត្តិការ ពេលវេលានៃការអនុវត្តបញ្ជាទូទាត់នោះត្រូវតែនៅថ្ងៃប្រសិទ្ធភាព។

៣. នៅពេលណាដែលមូលនិធិនៃគណនីធនាគារទូទាត់សងប្រាក់ពុំមានគ្រប់គ្រាន់សម្រាប់ទូទាត់ធនាគារជាតិនៃកម្ពុជាអាចបដិសេធ ឬដាក់បញ្ជាទូទាត់ឱ្យស្ថិតក្នុងការរង់ចាំ ហើយផ្តល់ដំណឹងដល់ធនាគារបញ្ជានោះ។ បញ្ជាទូទាត់ដែលបានដាក់ឱ្យស្ថិតក្នុងការរង់ចាំនឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជា ទៅតាមលំដាប់នៃការរង់ចាំ និងដោយគ្មានការជូនដំណឹងជាមុន លុះត្រាតែគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់។ ធនាគារជាតិនៃកម្ពុជាអាចបដិសេធបញ្ជាទូទាត់ដែលមិនទាន់ត្រូវបានអនុវត្តនៅពេលណាក៏បាន មុនពេលបញ្ជាទូទាត់នេះត្រូវបានអនុវត្ត ហើយនឹងផ្តល់ដំណឹងដល់ធនាគារបញ្ជានោះ។ បញ្ជាទូទាត់របស់ធនាគារដែលមិនត្រូវបានអនុវត្តនឹងបដិសេធក្នុងអំឡុងពេលជាត់ទាត់ប្រចាំថ្ងៃ និងត្រូវបានលុបចោលតាមការកំណត់ដោយច្បាប់នៅចុងបញ្ចប់នៃការជាត់ទាត់ប្រចាំថ្ងៃដូចមានចែងក្នុងនីតិវិធីប្រតិបត្តិការ។

៤. ចំពោះគោលបំណងនៃកថាខណ្ឌខាងលើនៅពេលណាមានមូលនិធិមិនគ្រប់គ្រាន់សម្រាប់សំណុំបញ្ជាទូទាត់ ធនាគារជាតិនៃកម្ពុជាអាចចាត់ទុកបញ្ជាទូទាត់នីមួយៗក្នុងសំណុំនោះជាបញ្ជាទូទាត់ដែលបញ្ជូនមកដាច់ដោយឡែកៗពីគ្នា។ ធនាគារជាតិនៃកម្ពុជាត្រូវចាត់ចែងបញ្ជាទូទាត់នីមួយៗ នោះសម្រាប់អនុវត្តទៅតាមមូលនិធិដែលមានដោយការដាក់បន្តគ្នា ឬបដិសេធទៅតាមលំដាប់សមស្រប។

៥. លើកលែងតែមានការបដិសេធ ឬការដាក់ឱ្យស្ថិតក្នុងការរង់ចាំបន្តគ្នាដោយធនាគារជាតិនៃកម្ពុជា ដូចបានចែងក្នុងកថាខណ្ឌទី៣ ខាងលើ បញ្ជាទូទាត់របស់ធនាគារដែលបានប្រគល់ឱ្យធនាគារជាតិនៃកម្ពុជានឹងមិនអាចបដិសេធបាន និងលុបចោលបានដោយធនាគារនោះឡើយ។ ចំពោះបញ្ជាទូទាត់ដែលស្ថិតក្នុងការរង់ចាំ ការលុបចោលដោយធនាគារបញ្ជានឹងមានប្រសិទ្ធភាព លុះត្រាតែបានជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជាតាមរបៀប ពេលវេលា និងអនុលោមតាមវិធីដែលបានចែង និងអនុម័តដោយធនាគារជាតិនៃកម្ពុជាតែប៉ុណ្ណោះ ដែលបង្កលក្ខណៈឱ្យធនាគារជាតិនៃកម្ពុជាអាចចាត់វិធានការមុនមានការចុះឥណពន្ធគណនីទូទាត់របស់ធនាគារ។

៦. ធនាគារជាតិនៃកម្ពុជា ត្រូវបដិសេធចំពោះបញ្ជាទូទាត់ណាដែលគ្មានយថាភាពត្រឹមត្រូវ មិនមានព័ត៌មានលម្អិតអំពីធនាគារឬអត្តគាហកគ្រប់គ្រាន់ ឬល្មើសនឹងប្រកាសនេះ ឬប្រកាសស្តីពីនីតិវិធីប្រតិបត្តិការ ឬបញ្ជាណាផ្សេងៗទៀត។

៧. បញ្ជាទូទាត់របស់ធនាគារដែលត្រូវបានលុបចោលឬបដិសេធមិនអាចយកមកអនុវត្តបានឡើយ លើកលែងតែមានការបញ្ជូនមកវិញជាបញ្ជាទូទាត់ថ្មីពីសំណាក់ធនាគារបញ្ជា។

ប្រការ ៧.-

នីតិវិធីប្រតិបត្តិការអាចអនុញ្ញាតឱ្យធនាគារធ្វើ ចាត់ថ្នាក់បញ្ជាទូទាត់មួយនៅក្រោមវិធាននេះជាការទូទាត់សងប្រាក់អាទិភាព។ ជាកម្មវត្ថុនៃការមានមូលនិធិក្នុងគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជានឹងព្យាយាមដំណើរការ ការទូទាត់សងប្រាក់អាទិភាពនេះនៅពេលបានទទួលបញ្ជាទូទាត់ដែលត្រូវបានចាត់ថ្នាក់នេះ។

ប្រការ ៨.-

១. ចំពោះការទូទាត់ប្រាក់ជំពាក់រវាងធនាគារនៅទីបញ្ចប់នៃវដ្តជាត់ទាត់ពហុភាគីអន្តរធនាគារ បញ្ជីអំពីស្ថានភាពឥណពន្ធនិងឥណទានរបស់ធនាគារនីមួយៗ ត្រូវប្រគល់ទៅឱ្យធនាគារជាតិនៃកម្ពុជាក្នុងនាមធនាគារចូលរួមទាំងអស់។ ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តការទូទាត់ដោយ៖

- ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយ ពីធនាគារដែលមានស្ថានភាពឥណទាននូវចំនួនប្រាក់ឥណពន្ធរបស់ធនាគារ និងបន្ទាប់មក
- ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយទៅឱ្យធនាគារដែលមានស្ថានភាពឥណទាននូវចំនួនទឹកប្រាក់ឥណទានរបស់ធនាគារ។

គ្មានខ្វង់ឥណពន្ធ ឬឥណទានចំពោះគណនីទូទាត់នៅក្រោមប្រការនេះនឹងក្លាយជាស្ថាពរមិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាននៅមុនពេលដែលរាល់ខ្វង់ឥណពន្ធសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់ របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថានភាពឥណពន្ធ និងរាល់ខ្វង់ឥណទានសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថានភាពឥណទានឡើយ។ ការទូទាត់សងប្រាក់ធនាគារតែមួយនៅក្រោមកថាខណ្ឌនោះអាចត្រូវបានធ្វើឡើង ដើម្បីបញ្ចូល ឬទូទាត់ចេញពីគណនីហាមឃាត់ដែលបានរក្សានៅធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជា មិនត្រូវអនុវត្តការទូទាត់ក្រោមកថាខណ្ឌទី១ទេ និងត្រូវស្វះស្វែងរកការបញ្ជាក់បន្ថែមដើម្បីបញ្ចប់ការទូទាត់ក្រោមកថាខណ្ឌទី១ លើកលែងតែ៖

ក. ធនាគារជាតិនៃកម្ពុជាបានធ្វើការបញ្ជាក់ដំបូងថា ចំនួនប្រាក់សរុបជំពាក់ដោយធនាគារទាំងអស់ក្នុងស្ថានភាពឥណពន្ធ ស្មើនឹងចំនួនប្រាក់សរុបជំពាក់ចំពោះធនាគារទាំងអស់ក្នុងស្ថានភាពឥណទាន និង

ខ. ចំពោះធនាគារដែលស្ថិតក្នុងស្ថានភាពឥណពន្ធ មូលនិធិមានចំនួនគ្រប់គ្រាន់សម្រាប់ទូទាត់ចេញពីគណនីទូទាត់ដើម្បីអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយក្នុងចំនួនប្រាក់ឥណពន្ធ។

៣. វិធានគ្រប់គ្រងការជាត់ទាត់ពហុភាគីអន្តរធនាគារដែលត្រូវបានទូទាត់នៅក្រោមប្រការនេះ រួមទាំងនីតិវិធីសម្រាប់ប្រើនៅពេលដែលមានការមិនគោរពតាមលក្ខខណ្ឌនានាក្រោមកថាខណ្ឌទី២ ខ ត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយការសម្របសម្រួលរវាងធនាគារចូលរួមដែលមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៩.-

១. ធនាគារជាតិនៃកម្ពុជាអាចអនុម័តនីតិវិធីប្រតិបត្តិការ រួមទាំងការកំណត់លក្ខណៈជាក់លាក់សម្រាប់បញ្ជាទូទាត់ តារាងពេលវេលា និងនីតិវិធីសម្រាប់គ្រប់គ្រងលើការជាត់ទាត់ និងការទូទាត់។

២. ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយជាបន្តបន្ទាប់ នូវតារាងកម្រៃនិងសោហ៊ុយសេវានៅក្រោមប្រកាសនេះ។

ប្រការ ១០.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន នាយកដ្ឋានអង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១១.-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦

ទេសាភិបាល

ហត្ថលេខានិងត្រោះ **ជា ចាន់តូ**

ធ៩-០១០-១៥០ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន

ប្រការ ១.-

ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់ សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរ ឬអេឡិកត្រូនិក ដែលមានទម្រង់ជាការផ្ទេរឥណទាន។

បញ្ជាទូទាត់នេះនឹងត្រូវបានប្រើ ដើម្បីផ្ទេរប្រាក់ពីគណនីរបស់អ្នកសងប្រាក់ទៅគណនីរបស់អ្នកទទួលប្រាក់ដែលគណនីទាំងនេះអាចមាន ឬមិនមាននៅក្នុងធនាគារ ឬសាខាធនាគារជាមួយគ្នា។

ប្រការ ២.-

បញ្ជាទូទាត់ត្រូវបានប្រើជាឧបករណ៍ស្របច្បាប់ អនុលោមតាមមាត្រា ១៩៩, ២០០, ២០១ និង ២០២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។ បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានត្រូវបានរៀបចំឱ្យមានលក្ខណៈស្តង់ដារច្បាស់លាស់ និងគ្រប់គ្រាន់ អំពីទម្រង់ទិន្នន័យ និងព័ត៌មានដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៣.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៤.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០១០-១៥០ ប្រ.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

លក្ខណៈស្តង់ដារនៃបញ្ជាទូទាត់

ទម្រង់ ទិន្នន័យ និងព័ត៌មានដែលត្រូវបំពេញនៅក្នុងបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ជាលាយលក្ខណ៍អក្សរ និងអេឡិកត្រូនិក ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានបី ដូចខាងក្រោម៖

- SWIFT
- សារប័ណ្ណ (Card Message)
- មូលប្បទានបត្រស្តង់ដារ ដូចមានចែងនៅក្នុងប្រកាសលេខ ធ៩-០៨-១៨៦ និងឧបសម្ព័ន្ធ នៃប្រកាសនេះ។

១- តារាងទិន្នន័យ និងព័ត៌មាននៃការផ្ទេរឥណទាន

<u>ឈ្មោះខ្លឹមសារ</u>	<u>ទម្រង់ខ្លឹមសារ</u>	<u>ការពន្យល់</u>
លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់	៦ ខ្ទង់	លេខកូដតំណាងឱ្យ "ការផ្ទេរឥណទាន" (ជាកាតព្វកិច្ច)
កាលបរិច្ឆេទ	៨ ខ្ទង់	ថ្ងៃ-ខែ-ឆ្នាំ (00-00-0000) (ជាកាតព្វកិច្ច)
លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់	៦ ខ្ទង់	៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច)
លេខកូដផ្ទៀងផ្ទាត់	១ ខ្ទង់	សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ (ជាកាតព្វកិច្ច)
លេខគណនីអ្នកសងប្រាក់	៣៤ ខ្ទង់	អតិបរមា៣៤ខ្ទង់ (ជាកាតព្វកិច្ច) *(ត្រូវបានជំនួសដោយប្រកាសលេខ ធ១៤-០១៦-១៣៥ ប្រ.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។)*
ឈ្មោះអ្នកសងប្រាក់	៣៥ អក្សរ និង/ឬ លេខ	(ជាកាតព្វកិច្ច)

អត្ថន័យយោងរបស់អ្នកសងប្រាក់	៣០ អក្សរ និង/ឬ លេខ	(ជាជម្រើស)
ចំនួនប្រាក់	១៥ ខ្ទង់	១៥ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច)
លេខកូដរូបិយប័ណ្ណ	៣ ខ្ទង់	៣ខ្ទង់តំណាងឱ្យរូបិយប័ណ្ណ ឧទាហរណ៍ KHR ឬ USD (ជាកាតព្វកិច្ច)
លេខកូដសុវត្ថិភាព	១៨ ខ្ទង់	តំណាងឱ្យលេខកូដសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ (ម៉ាស៊ីនគណនាដោយស្វ័យប្រវត្តិ)
លេខសម្គាល់អត្តសញ្ញាណធនាគារទទួលការប្រាក់	៦ ខ្ទង់	៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច)
លេខកូដផ្ទៀងផ្ទាត់	១ ខ្ទង់	សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណ ធនាគារទទួលប្រាក់ (ជាកាតព្វកិច្ច)
លេខគណនីរបស់អ្នកទទួលប្រាក់	៣៤ ខ្ទង់	អតិបរមា៣៤ខ្ទង់ (ជាកាតព្វកិច្ច) *(ត្រូវបានជំនួសដោយប្រកាសលេខ ធ១៤-០១៦-១៣៥ ប្រ.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។)*
ឈ្មោះអ្នកទទួលប្រាក់	៣៥ អក្សរ និង/ឬ លេខ	(ជាកាតព្វកិច្ច)
អត្ថន័យយោងរបស់អ្នកទទួលប្រាក់	៣០ អក្សរ និង/ឬ លេខ	(ជាជម្រើស)

២- ទម្រង់និទ្ទេសភាព នៃបញ្ជាទូទាត់

ឡូហ្គូ ធនាគារ	**ការផ្ទេរឥណទាន**

កាលបរិច្ឆេទ: □□□□□□□□

ប្រភពនៃប្រាក់ផ្ទេរ: សាច់ប្រាក់ □ ផ្ទេរពីគណនី: □

លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់: □□□□□□

ឈ្មោះអ្នកសងប្រាក់: □□□

លេខអត្តសញ្ញាណធនាគារសងប្រាក់: □□□□□□

លេខគណនីអ្នកសងប្រាក់: □□□□□□□□□□□□□□

អត្ថន័យយោងរបស់អ្នកសងប្រាក់: □□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□

ចំនួនប្រាក់: □□□□□□□□□□□□□□□□□□

លេខកូដរូបិយប័ណ្ណ: □□□

ឈ្មោះអ្នកទទួលប្រាក់: □□

លេខអត្តសញ្ញាណធនាគារទទួលប្រាក់: □□□□□□

លេខគណនីអ្នកទទួលប្រាក់: □□□□□□□□□□□□□□

អត្ថន័យយោងរបស់អ្នកទទួលប្រាក់: □□□□□□□□□□□□□□□□□□□□

ធ៥-០១៤-០៦៨ ប្រ.ក

ប្រកាស
ស្តីពី
ការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
តាមរយៈធនាគារជាតិនៃកម្ពុជា

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធី និងកម្រៃសេវានៃការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈធនាគារនៃកម្ពុជា។

ប្រការ ២.-

ប្រកាសនេះអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៣.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចផ្ទេរប្រាក់ជារូបិយប័ណ្ណតាមរយៈធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

ធនាគារជាតិនៃកម្ពុជានឹងចាត់ចែងធ្វើប្រតិបត្តិការផ្ទេរប្រាក់ទៅតាមពេលវេលាដូចខាងក្រោម៖

- មុនម៉ោង ១១ ព្រឹក៖ ឯកសារផ្ទេរប្រាក់នឹងត្រូវចាត់ចែងធ្វើប្រតិបត្តិការក្នុងថ្ងៃ
- ក្រោយម៉ោង ១១ ព្រឹក៖ ឯកសារផ្ទេរប្រាក់នឹងត្រូវរក្សាទុកសម្រាប់ធ្វើប្រតិបត្តិការនាថ្ងៃធ្វើការបន្ទាប់។

ប្រការ ៥.-

ការផ្ទេរប្រាក់ទៅធនាគារទទួលផលតែមួយ ត្រូវអនុលោមទៅតាមបរិមាណប្រាក់នៃប្រតិបត្តិការជាក់ស្តែងនិងមានថ្ងៃប្រសិទ្ធភាព ដូចខាងក្រោម៖

- ទំហំប្រាក់ផ្ទេរតូចជាង ៨០ ពាន់លានរៀល ឬ សមមូល ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺមួយថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+1)
- ទំហំប្រាក់ផ្ទេរចាប់ពី ៨០ ពាន់លានរៀល ឬ សមមូល ថ្ងៃប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទេរប្រាក់ គឺពីរថ្ងៃបន្ទាប់ពីបានចុះឥណពន្ធគណនីចរន្ត (t+2) ។

ប្រការ ៦.-

ឯកសារផ្ទេរប្រាក់ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រគល់ជូនធនាគារជាតិនៃកម្ពុជាមានដូចខាងក្រោម៖

- បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស (Oversea Transfer Order) (ទម្រង់គំរូ ឧបសម្ព័ន្ធ ១)
- តារាងប្រភពនិងការប្រើប្រាស់ទុនក្នុងស្រុក (Local Sources and Uses of Fund) (ទម្រង់គំរូឧបសម្ព័ន្ធ ២) និង
- ឯកសារពាក់ព័ន្ធ តាមការចាំបាច់។

ប្រការ ៧.-

កម្រៃសេវាផ្ទេរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគិតលើចំនួនប្រាក់ដែលត្រូវផ្ទេរដោយកាត់ចេញពីគណនីចរន្ត នៅធនាគារជាតិនៃកម្ពុជា តាមការកំណត់ដូចខាងក្រោម៖

ក- ប្រាក់ផ្ទេរពីបរទេស

- ០,១២% នៃប្រាក់ផ្ទេរចូល
- អប្បបរមា ៣០.០០០ រៀល ឬសមមូល
- អតិបរមា ៩.០០០.០០០ រៀល ឬសមមូល

ខ- ប្រាក់ផ្ទេរទៅបរទេស

- ០,១២% នៃប្រាក់ផ្ទេរចេញ
- អប្បបរមា ៣០.០០០ រៀល ឬសមមូល និង
- ថ្លៃ SWIFT ១២០.០០០រៀល ក្នុងមួយប្រតិបត្តិការ

ប្រការ ៨.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យនាំចេញសាច់ប្រាក់ជាដុល្លារអាមេរិកទៅក្រៅប្រទេសដោយខ្លួនឯងឡើយ។

ប្រការ ៩.-

ត្រូវចាត់ទុកជានិរាករណ៍នូវ៖

- ប្រកាសលេខ ធ៩-៩៨-៥១១ ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជតាមរយៈធនាគារជាតិនៃកម្ពុជា
- សេចក្តីជូនដំណឹងលេខ ធ៥-០៧-១៨៦ សជណ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពី បែបបទផ្ទេរប្រាក់ទៅក្រៅប្រទេស
- សេចក្តីជូនដំណឹងលេខ ធ៥-០៨-៥៦១ សជណ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ស្តីពី កម្រៃសេវាផ្ទេរប្រាក់ជារូបិយប័ណ្ណតាមរយៈធនាគារជាតិនៃកម្ពុជា
- សេចក្តីជូនដំណឹងបន្ថែមលេខ ធ៥-១១-០២៨៩ សជណ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ព្រមទាំងរាល់ខ្លឹមសារទាំងឡាយណាដែលផ្ទុយពីស្មារតីនៃ ប្រកាសនេះ។

ប្រការ ១០.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គលេខ្លា គ្រប់នាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុតិនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១១.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

Bank
Logo

ឧបសម្ព័ន្ធ ១

បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស

Oversea Transfer Order

- ចំនួនប្រាក់ / Amount: .....
- អ្នកទទួលប្រាក់ / Beneficiary's Name: .....
- លេខគណនី / Account Number: .....
- ធនាគារអ្នកទទួលប្រាក់ / Beneficiary's Bank: .....
  អាសយដ្ឋាន / Address: .....
  Swift Code: .....
- ធនាគារអន្តរការី ឬធនាគារទំនាក់ទំនងរបស់ធនាគារអ្នកទទួលប្រាក់ / Intermediary Bank or Correspondent Bank: .....
  អាសយដ្ឋាន / Address: .....
  Swift Code: .....
- គោលបំណងនៃការទូទាត់ / Purpose of payment: .....
- សូមចុះឥណពន្ធកម្រៃសេវាធនាគារពី / Deduct Bank Charge from:
  - ☐ អ្នកផ្ទេរប្រាក់/ Debit from drawer's account
  - ☐ អ្នកទទួលផល/ Debit from beneficiary amount

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Phnom Penh, Date

ធនាគារ .....

Bank.....

Bank
Logo

ឧបសម្ព័ន្ធ ២

តារាងប្រភពនិងការប្រើប្រាស់ទុនក្នុងស្រុក

Local Source and Use of Fund

ថ្ងៃទី ខែ ឆ្នាំ

ការប្រើប្រាស់ទុនក្នុងស្រុក (Fund Used Locally)	**ចំនួនប្រាក់**
១. សាច់ប្រាក់ (Cash)	
២. ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (Deposits with NBC)	
ដក ប្រាក់តម្កល់ធានាលើដើមទុន (Minus capital guarantee)	
៣. ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក (Deposits with local banks)	
៤. ប្រាក់ឱ្យខ្ចីចងការនិងបុរេប្រទានសុទ្ធ (Net loans and advances)	
សរុបទុនដែលប្រើប្រាស់ I (Total I)	
ប្រភពទុនក្នុងស្រុក (Fund Collected Locally)	
១. ប្រាក់បញ្ញើទទួលពីអតិថិជនក្នុងស្រុក (Deposits from local customer)	
២. ប្រាក់បញ្ញើរបស់ធនាគារក្នុងស្រុក (Deposits from local bank)	
សរុបប្រភពទុន II (Total II)	
បម្រែបម្រួល (Change) = I - II	
អនុបាត (Ratio) = I / II	

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Phnom Penh, Date

ធនាគារ .....

Bank

ធ៥-០១៦-០១៥ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យប្រើប្រាស់សេវា Online Banking System របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានកិត្តិយស សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជ្រាបថា ក្នុងគោលបំណងជំរុញការទូទាត់ជាអេឡិចត្រូនិកឱ្យកាន់តែទូលំទូលាយនិងមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យប្រើប្រាស់សេវា Online Banking System សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ នេះតទៅ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបំណងចង់ប្រើប្រាស់សេវា Online Banking System នេះ សូមអញ្ជើញមកទំនាក់ទំនងចុះឈ្មោះបំពេញសំណុំបែបបទនៅធនាគារជាតិនៃកម្ពុជានៅរៀង រាល់ម៉ោងធ្វើការតាមអាសយដ្ឋានដូចខាងក្រោម៖

នាយកដ្ឋានប្រតិបត្តិការ
ធនាគារជាតិនៃកម្ពុជា
២២-២៤ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ ៖ ០២៣ ៧២២ ៥៦៣ (១០៨៦ ឬ ១០៥៨)
អ៊ីម៉ែល ៖ nbcobs@nbc.org.kh

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦
អគ្គនាយកបច្ចេកទេស
ហត្ថលេខានិងត្រា៖ **ជា សិរី**

ធ៥-០១៦-០០២ ស.រ.ច.ណ.ន

សារាចរណែនាំ
ស្តីពី
ការពន្រឹងការអនុវត្តច្បាប់
ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់

ដើម្បីអនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ឱ្យបានម៉ឺងម៉ាត់និងពេញលេញ ធានាបាននូវប្រសិទ្ធភាពនៃការទូទាត់ បង្កើនភាពជឿជាក់លើឧបករណ៍ទូទាត់ ការពារផលប្រយោជន៍អ្នកទទួលផល ព្រមទាំងដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវបរិមាណមូលប្បទានបត្របង្វិលវិញ ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ដូចតទៅ៖

- ផ្សព្វផ្សាយដល់បុគ្គលិកនូវច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ជាពិសេសមាត្រានានាដែលពាក់ព័ន្ធនឹងការចេញផ្សាយ ការប្រើប្រាស់ ការទូទាត់មូលប្បទានបត្រ និងក្រើនរំលឹកបុគ្គលិកដែលមានភារកិច្ចពាក់ព័ន្ធឱ្យយកចិត្តទុកដាក់ពិនិត្យដោយប្រុងប្រយ័ត្នអំពីភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃនិទ្ទេសលើមូលប្បទានបត្រ។
- ណែនាំអតិថិជនឱ្យបានយល់ច្បាស់អំពីលក្ខខណ្ឌ នីតិវិធីនៃនៃការចេញផ្សាយ និងការប្រើប្រាស់មូលប្បទានបត្រ។ មូលប្បទានបត្រត្រូវតែទូទាត់សងនៅពេលបង្ហាញ ទោះបីជាមូលប្បទានបត្រនោះបង្ហាញនៅមុនកាលបរិច្ឆេទចេញផ្សាយក៏ដោយ។
- ធនាគារបហារិតត្រូវកត់ត្រាហេតុការណ៍ និងរាយការណ៍អំពីមូលប្បទានបត្របង្វិលវិញដោយសារមូលនិធិមិនគ្រប់គ្រាន់មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល២ថ្ងៃបន្ទាប់ ដើម្បីធនាគារជាតិនៃកម្ពុជាអនុវត្តសិទ្ធិផ្តន្ទាទោសខាងវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

ករណីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់មិនបានអនុវត្តឱ្យបានម៉ឺងម៉ាត់នូវសារាចរណែនាំនេះ ព្រមទាំងវិធាននិងនីតិវិធីពាក់ព័ន្ធនឹងឧបករណ៍ទូទាត់ និងប្រតិបត្តិការទូទាត់សងប្រាក់ នឹងត្រូវទទួលរងនូវការពិន័យដូចមានចែងក្នុងច្បាប់ បទប្បញ្ញត្តិមួយចំនួនជាធរមាន។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ១៥-០១៦-១៣៥ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើវិធានន៍ងនីតិវិធីសភាជាត់ទាត់ជាតិ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ" ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះដើម្បីជាមូលដ្ឋាន នៃការអនុវត្តការជាត់ទាត់និងទូទាត់តាមរយៈប្រព័ន្ធជាត់ទាត់ជាតិ និងប្រព័ន្ធទូទាត់រាយភ្លាមៗ ដែលបម្រើដល់កិច្ចដំណើរការនិងការគ្រប់គ្រងរបស់សភាជាត់ទាត់ជាតិនៃធនាគារជាតិនៃកម្ពុជា។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅផ្តល់ព័ត៌មានលម្អិតអំពីប្រតិបត្តិការសភាជាត់ទាត់ជាតិ និងផ្តល់ការណែនាំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់សភាជាត់ទាត់ជាតិ និងសមាជិកនីមួយៗ។ "វិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ" នេះជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកសភាជាត់ទាត់ជាតិ។

ប្រការ ៣.-

ប្រកាសនេះអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលផ្តល់សកម្មភាពជាត់ទាត់ និងទូទាត់ទាំងសមាជិកផ្ទាល់ និងមិនផ្ទាល់របស់សភាជាត់ទាត់ជាតិ។

ប្រការ ៤.-

ត្រូវចាត់ទុកជានិរាករណ៍នូវ៖

- ប្រកាសលេខ ធ៩-០១៣-១២៥ ប្រ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ
- ប្រកាសលេខ ធ៩-០១៥-០០៦ ប្រ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពី ការកែសម្រួលវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ
- ឧបសម្ព័ន្ធនៃប្រកាសលេខ ធ៩-០១០-១៥០ ប្រ.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨ ស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ត្រង់ចំណុច លេខគណនីរបស់អ្នកសងប្រាក់ និងអ្នកទទួលប្រាក់។

ប្រការ ៥.-

អគ្គលេខាធិការ អគ្គបេឡា អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅ ក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ១៥-០១៦-១៥៧ ប្រ.ក

ប្រកាស
ស្តីពី
សមាជិកភាពប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមជាសមាជិកប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch ជាកាតព្វកិច្ច។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅជំរុញការទូទាត់រាយឱ្យកាន់តែងាយស្រួល រហ័ស ប្រសិទ្ធភាព សុវត្ថិភាព និងជឿទុកចិត្តបាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិ។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ តទៅនេះហៅថា "គ្រឹះស្ថាន"។

ប្រការ ៤.-

ប្រព័ន្ធ FAST (Fast And Secure Transfers) គឺជាប្រព័ន្ធទូទាត់សងប្រាក់រាយ ដែលដំណើរការប្រតិបត្តិការទូទាត់សងប្រាក់រវាងគ្រឹះស្ថានជាសមាជិក។ ប្រតិបត្តិការទូទាត់សងប្រាក់ តាមរយៈប្រព័ន្ធនេះធ្វើឡើងជាប្រាក់រៀល និងអនុញ្ញាតឱ្យអតិថិជនរបស់គ្រឹះស្ថានជាសមាជិកទទួលបាននូវមូលនិធិភ្លាមៗ។

ប្រព័ន្ធ Central Shared Switch គឺជាប្រព័ន្ធកណ្តាលសម្រាប់ ភ្ជាប់បណ្តាញម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM - Automated Teller Machine) និងម៉ាស៊ីនឆូតកាត (EFTPOS - Electronic Fund Transfer Point of Sale) របស់គ្រឹះស្ថានជាសមាជិក។

ប្រការ ៥.-

ប្រតិបត្តិការទាក់ទងប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch មានចែងក្នុងវិធាន និងនីតិវិធីដោយឡែក ។

ប្រការ ៦.-

គ្រឹះស្ថានជាសមាជិក មានកាតព្វកិច្ចរៀបចំប្រព័ន្ធធនាគារស្នូល និងហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់តភ្ជាប់ជាមួយប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch។

ប្រការ ៧.-

គ្រឹះស្ថាន មានកាតព្វកិច្ចចូលរួមជាសមាជិកនៅក្នុងប្រព័ន្ធ FAST ឱ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ និងជាសមាជិកនៅក្នុងប្រព័ន្ធ Central Shared Switch ឱ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ជាកំហិត។

ប្រការ ៨.-

ការខកខានមិនបានចូលរួមតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដូចមានចែងក្នុងមាត្រាទី៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៩.-

អគ្គលេខាធិការ អគ្គបេឡា អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ១៥-០១៧-៣០៧ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើ
វិធាននិងនីតិវិធី Cambodian Shared Switch

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធី Cambodian Shared Switch" ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះដើម្បីជាមូលដ្ឋាននៃការអនុវត្តការជាត់ទាត់និងទូទាត់តាមរយៈប្រព័ន្ធ Cambodian Shared Switch ដែលបម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងរបស់ប្រព័ន្ធ Cambodian Shared Switch នៃធនាគារជាតិនៃកម្ពុជា។

ប្រការ ២.-

ប្រកាសនេះមានគោលដៅផ្តល់ព័ត៌មានលម្អិតអំពីប្រតិបត្តិការប្រព័ន្ធ Cambodian Shared Switch ផ្តល់ការណែនាំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកនីមួយៗ និងដំណើរការដំណោះស្រាយបណ្តឹង។ "វិធាននិងនីតិវិធី Cambodian Shared Switch" នេះជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកប្រព័ន្ធ Cambodian Shared Switch។

ប្រការ ៣.-

ប្រកាសនេះអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ អគ្គបេឡា ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

កំណត់សម្គាល់៖ សូមទំនាក់ទំនងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់សម្រាប់ឧបសម្ព័ន្ធនៃប្រកាសនេះ។

ធ១៥-០១៨-១៩៥ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញា
សម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment)
និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ជាផ្លូវការសម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុដើម្បីជាសញ្ញាសម្គាល់ក្នុងការធ្វើប្រតិបត្តិការ និងអនុញ្ញាតឱ្យគ្រឹះស្ថានជាសមាជិកប្រព័ន្ធ ប្រើសម្រាប់អនុវត្តការងារពាក់ព័ន្ធ។

ប្រការ ២.-

ការកំណត់ស្លាកសញ្ញានេះក្នុងគោលដៅរក្សាសង្គតភាពក្នុងការប្រើប្រាស់ជាសាធារណៈ ធានាពីសិទ្ធិនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថានជាសមាជិកប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការនិងការប្រើប្រាស់ស្លាកសញ្ញាដែលពាក់ព័ន្ធនឹងប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ត្រូវរៀបចំ បោះពុម្ព និងប្រើប្រាស់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវនិងមានលក្ខណៈស្តង់ដារ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៥.-

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាទាំងនេះមិនបានត្រឹមត្រូវ និង/ឬដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៦.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តម៉ឺងម៉ាត់នូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ
លក្ខណៈសម្គាល់ស្លាកសញ្ញា
ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច
(Cambodian Shared Switch)

ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ដូចខាងក្រោម៖

១. ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment)

១.១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) មានរាងចតុកោណកែងផ្ទៃពណ៌ក្រហមក្រមៅ ដែលមានរូប “ធ្នូនិងព្រួញ” ពណ៌ស នៅចំកណ្តាលផ្នែកខាងលើ និងមានចារឹកអក្សរ “**សេវាទូទាត់រហ័ស**” នៅផ្នែកខាងក្រោមនៃនិមិត្តសញ្ញា។ ដងធ្នូត្រូវបានរចនាឡើងជាអក្សរ “ន” តំណាងឱ្យប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងរំលេចដោយក្បាច់បុរាណខ្មែរ។ ចំណែករូបសញ្ញា “ព្រួញ” មានអត្ថន័យសំដៅដល់ការបញ្ជូនមូលនិធិយ៉ាងឆាប់រហ័សពីភាគីផ្ញើទៅភាគីទទួល។

រូបភាពទី១ ៖ ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment)



១.២. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហមក្រមៅ ដែលមានពណ៌គោលដូចខាងក្រោម៖


- *ពណ៌ក្រហមក្រមៅ* C: 28 M: 99 Y: 89 K: 32

២. ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)

២.១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) មានរាងចតុកោណផ្ទៃពណ៌ស និងមានបន្ទាត់ជុំវិញពណ៌ខៀវ ដែលមានអក្សរ “CSS” នៅចំកណ្តាល លម្អដោយចម្លាក់ជារចនាបទអង្គរពណ៌ប្រផេះស្រាលនៅគែមខាងលើនិងខាងក្រោម។ អក្សរ “ C ” មានពណ៌ខៀវ អក្សរ “S” បន្ទាប់មានពណ៌ក្រហម និងអក្សរ “S” ចុងក្រោយមានពណ៌ខៀវ។

រូបភាពទី២ ៖ ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)



២.២. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ខៀវ ក្រហម និងប្រផេះដែលមានពណ៌គោលដូចខាងក្រោម៖

- *ពណ៌ខៀវ* C: 100 M: 90 Y: 00 K: 00

- *ពណ៌ក្រហម* C: 00 M: 100 Y: 100 K: 00

- *ពណ៌ប្រផេះ* C: 00 M: 00 Y: 00 K: 25

២.៣. ការប្រើប្រាស់ស្លាកសញ្ញា

២.៣.១. ការបោះពុម្ពលើប័ណ្ណឥណទានសងប្រាក់

ចំពោះការចេញផ្សាយប័ណ្ណ Proprietary Card គ្រឹះស្ថានជាសមាជិកត្រូវបោះពុម្ពស្លាកសញ្ញាប្រព័ន្ធ CSS នៅផ្ទៃខាងមុខផ្នែកខាងក្រោមជ្រុងខាងស្តាំនៃប័ណ្ណ។ ចំណែកឯប្រភេទប័ណ្ណ Co-badge ស្លាកសញ្ញាប្រព័ន្ធ CSS នឹងស្ថិតនៅផ្ទៃខាងក្រោយផ្នែកខាងក្រោមជ្រុងខាងស្តាំនៃប័ណ្ណ។

២.៣.២. ការបិទស្លាកសញ្ញានៅតាមម៉ាស៊ីន ATM និង/ឬ POS


គ្រឹះស្ថានជាសមាជិកត្រូវបិទស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ដូចបានកំណត់ខាងលើ តាមម៉ាស៊ីន ATM និង/ឬ POS នៅទីតាំងដែលងាយកត់សម្គាល់។

៣. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) នឹងត្រូវពង្រីកឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ខាងលើ។

៣.១. ស្លាកសញ្ញានៃប្រព័ន្ធ (Fast Payment)


ស្លាកសញ្ញាប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) ត្រូវបានកំណត់ទម្រង់ស្តង់ដារដូចខាងក្រោម៖



ទម្រង់សមាមាត្រស្តង់ដារនៃស្លាកសញ្ញានេះត្រូវបានបែងចែកដោយមានប្រវែងទទឹងស្មើនឹង 5X និងប្រវែងបណ្តោយស្មើ $(6+\frac{1}{2})$ X ចំណែកឯ អក្សរ “រ” មានប្រវែង $(4+\frac{3}{4})$ X ក្នុងនោះ X = 1។

៣.២. ស្លាកសញ្ញានៃប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)

ស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) ត្រូវបានកំណត់ទម្រង់ស្តង់ដារដូចខាងក្រោម៖



ទម្រង់សមាមាត្រស្តង់ដារនៃស្លាកសញ្ញានេះត្រូវបានបែងចែកដោយមានប្រវែងទទឹងស្មើនឹង $(4+\frac{2}{3})$ X និងប្រវែងបណ្តោយស្មើនឹង $(8+\frac{1}{3})$ X ចំណែកឯ X = 1។

ធ១៥-០១៩-៤២៥ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធី Retail Pay" ដែលរួមមាន ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ ប្រព័ន្ធទូទាត់ចល័ត ប្រព័ន្ធទូទាត់តាមរយៈ QR Code និងប្រព័ន្ធជាត់ទាត់អេឡិចត្រូនិក ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅផ្តល់ព័ត៌មានលម្អិតអំពីដំណើរការប្រព័ន្ធ ការទទួលខុសត្រូវរបស់សភាជាត់ទាត់ជាតិ Processors និងសមាជិកនីមួយៗ យន្តការជាត់ទាត់និងទូទាត់ ដំណើរការដោះស្រាយវិវាទ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត។ វិធាននិងនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកប្រព័ន្ធនីមួយៗនៃ Retail Pay ដូចមានចែងក្នុងប្រការ១ខាងលើ។

ប្រការ ៣.-

ប្រកាសនេះអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ អគ្គបេឡា ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

កំណត់សម្គាល់៖ សូមទំនាក់ទំនងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់សម្រាប់ឧបសម្ព័ន្ធនៃប្រកាសនេះ។

ធ១៤-០២០-០៤៦ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធ "Retail Pay" សម្រាប់ជាសញ្ញាសម្គាល់ផ្លូវការសម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅរក្សាសង្គតភាពក្នុងការប្រើប្រាស់ស្លាកសញ្ញា "Retail Pay" ជាសាធារណៈ ធានាពីសិទ្ធិនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថានជាសមាជិកប្រព័ន្ធ "Retail Pay" ។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការពាក់ព័ន្ធដែលចូលរួមក្នុងប្រព័ន្ធ "Retail Pay" ។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃប្រព័ន្ធ "Retail Pay" ត្រូវរៀបចំ បោះពុម្ពនិងប្រើប្រាស់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវនិងមានលក្ខណៈស្តង់ដារ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៥.-

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាមិនត្រឹមត្រូវ និង/ឬ ការប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តម៉ឺងម៉ាត់នូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ
លក្ខណៈសម្គាល់ស្លាកសញ្ញា
ប្រព័ន្ធ Retail Pay

ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ " Retail Pay " ដូចខាងក្រោម៖

១. ស្លាកសញ្ញាប្រព័ន្ធ (Retail Pay)

១.១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធ " Retail Pay " មានរាងចតុកោណកែងដែលមាន ២ ថ្នាក់ ហើយថ្នាក់ទី១ មានផ្ទៃពណ៌ខៀវនិងមានអក្សរ " RETAIL " ពណ៌ស នៅចំកណ្តាល ដែលមានអក្សរ " R " រចនាឡើងដោយនិមិត្តសញ្ញាលុយរៀល " ៛ "។ ចំណែកឯថ្នាក់ទី២ មានផ្ទៃពណ៌ស គឺជារចនាភ្ញីទេសស្រាលៗ ចំនួន ៣នៅលើផ្ទៃនិងអក្សរ " PAY " ដែលមានពណ៌ក្រហម និងហ៊ុំព័ទ្ធដោយបន្ទាត់ពណ៌ក្រហម។



១.២. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធ "Retail Pay" នឹងត្រូវពង្រីកឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង x និងប្រវែងបណ្តោយស្មើនឹង ២x។

១.៣. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហម ខៀវ និងពណ៌ស ដែលមានពណ៌គោលដូចខាងក្រោម៖

- **ពណ៌ក្រហម R: 229 G: 33 B: 52**

- **ពណ៌ខៀវ R: 7 G: 64 B: 249**

- **ពណ៌ស R: 251 G: 246 B: 24**

១.៤. ការប្រើប្រាស់ស្លាកសញ្ញា

គ្រឹះស្ថានជាសមាជិកត្រូវបិទស្លាកសញ្ញាប្រព័ន្ធ "Retail Pay" ដូចបានកំណត់ខាងលើនៅតាមទីតាំងដែលងាយកត់សម្គាល់។

ធ១៥-០២០-៣៥៩ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ វិធាននិងនីតិវិធី ប្រព័ន្ធបាគង

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ **វិធាននិងនីតិវិធីប្រព័ន្ធបាគង** ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជាឯកសារគតិយុត្តិសម្រាប់អនុវត្តក្នុងការធ្វើប្រតិបត្តិការប្រព័ន្ធបាគង។

ប្រការ ២.-

ប្រកាសនេះ មានគោលដៅដាក់ចេញនូវគោលការណ៍ណែនាំអំពីប្រតិបត្តិការប្រព័ន្ធបាគង ការកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធ ក៏ដូចជាវិធានការប្រុងប្រយ័ត្ននានា ដើម្បីធានានិរន្តរភាពនិងសុវត្ថិភាពប្រព័ន្ធបាគង។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថាន និងអង្គភាពទាំងឡាយណាដែលជាសមាជិកប្រព័ន្ធបាគង។

ប្រការ ៤.-

គ្រឹះស្ថាន និងអង្គភាពដែលជាសមាជិកប្រព័ន្ធបាគងត្រូវគោរពតាម **វិធាននិងនីតិវិធីប្រព័ន្ធបាគង** ឱ្យបានត្រឹមត្រូវ។

ប្រការ ៥.-

បុគ្គលណាដែលប្រើប្រាស់ប្រព័ន្ធបាគងសម្រាប់ធ្វើប្រតិបត្តិការណាមួយដោយពុំមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

កំណត់សម្គាល់៖ សូមទំនាក់ទំនងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់សម្រាប់ឧបសម្ព័ន្ធនៃប្រកាសនេះ។

ធ១៥-០២០-៣៥០ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធទូទាត់ "បាគង" តទៅនេះហៅថា ប្រព័ន្ធបាគង សម្រាប់ជាសញ្ញាសម្គាល់ដើម្បីប្រើប្រាស់នៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ និងក្នុងការធ្វើប្រតិបត្តិការប្រព័ន្ធបាគង ហើយអនុញ្ញាតឱ្យគ្រឹះស្ថានជាសមាជិកប្រព័ន្ធប្រើសម្រាប់អនុវត្តការងារពាក់ព័ន្ធ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅរក្សាសង្គតិភាពក្នុងការប្រើប្រាស់ស្លាកសញ្ញារបស់ប្រព័ន្ធបាគងជាសាធារណៈ ធានាពីសិទ្ធិ និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថាន និងអង្គភាពជាសមាជិកប្រព័ន្ធបាគង។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថាន និងអង្គភាពដែលជាសមាជិកនៃប្រព័ន្ធបាគង របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថាន និងអង្គភាពដែលជាសមាជិកនៃប្រព័ន្ធបាគង ត្រូវរៀបចំបោះពុម្ព និងប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគងឱ្យបានត្រឹមត្រូវតាមលក្ខណៈសម្គាល់ស្លាកសញ្ញាប្រព័ន្ធបាគង។

ប្រការ ៥.-

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគងមិនបានត្រឹមត្រូវ ឬគ្មានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ស្លាកសញ្ញាប្រព័ន្ធបាគង

ធនាគារជាតិនៃកម្ពុជាសូមណែនាំ អំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធបាគង ដូចខាងក្រោម៖

១. លក្ខណៈសម្គាល់ស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធបាគង ដែលមានរូបដូចប្លង់ប្រាសាទបាគងមើលពីលើ ឬស្លាកសញ្ញាប្រព័ន្ធបាគងមានផ្គុំពាក្យជាខេមរៈភាសា “បាគង” ជាមួយនិងអក្សរឡាតាំង “BAKONG”។

ស្លាកសញ្ញាប្រព័ន្ធ បាគង មាន ២ ទម្រង់ដូចខាងក្រោម៖


- **ស្លាកសញ្ញាទម្រង់ទី១ ៖** ស្លាកសញ្ញាពណ៌ក្រហម និងមានផ្ទៃខាងក្រោយថ្លា (Transparent)។



ឬ



- **ស្លាកសញ្ញាទម្រង់ទី២ ៖** ស្លាកសញ្ញាពណ៌ស និងមានផ្ទៃខាងក្រោយពណ៌ក្រហម។



ឬ



២. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធបាគង នឹងត្រូវពង្រីក ឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង X និងប្រវែងបណ្តោយស្មើនឹង X ឬ

ស្លាកសញ្ញាប្រព័ន្ធបាគងមានផ្គុំពាក្យជាខេមរៈភាសា “បាគង” ជាមួយនិងអក្សរឡាតាំង “BAKONG” នឹងត្រូវពង្រីក ឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង X និងប្រវែងបណ្តោយស្មើនឹង $\frac{៧}{៣}$X។

៣. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហម និងពណ៌ស ដែលមានពណ៌គោលដូចខាងក្រោម៖

- ពណ៌ក្រហម **R: 227** **G: 43** **B:45**

- ពណ៌ស **R: 255** **G: 255** **B: 255**

៤. ការប្រើប្រាស់ស្លាកសញ្ញា

គ្រឹះស្ថាននិងអង្គភាពជាសមាជិកត្រូវដាក់បង្ហាញស្លាកសញ្ញាប្រព័ន្ធបាគង ដូចបានកំណត់ខាងលើនៅតាមទីតាំងដែលងាយកត់សម្គាល់។

ធ១៥-0២0-៣៥១ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារស្តីពី គំរូបរិច្ឆិនភាពបច្ចេកទេស (Specification) ខ្មែរឃ្វីករ៉េសស៉្បុនកូត (KHMER QUICK RESPONSE CODE) ហៅកាត់ថា ខេអេចយ្យូអរកូត "KHQR Code" សម្រាប់ការទូទាត់សងប្រាក់នៅព្រះរាជាណាចក្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅ ផ្តល់ជាឯកសារមូលដ្ឋានក្នុងការរៀបចំគំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយ្យូអរកូត សម្រាប់ការទូទាត់ឱ្យមានសណ្តាប់ធ្នាប់ សុវត្ថិភាព និងទូទាត់ឆ្លងគ្រឹះស្ថានបានប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងឡាយណាដែលប្រើប្រាស់ឃ្យូអរកូតសម្រាប់ការទូទាត់សងប្រាក់នៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំ និងដាក់ឱ្យប្រើប្រាស់ខេអេចយ្យូអរកូតទៅតាមគំរូបរិច្ឆិនភាពបច្ចេកទេស ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ យ៉ាងយូរត្រឹមដំណាច់ឆ្នាំ២0២0។

ប្រការ ៥.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមិនអនុវត្តតាមគំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយ្យូអរកូតនេះនឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងនៅក្នុងច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់ភូ**

ឧបសម្ព័ន្ធនៃ

ប្រកាសលេខ ធ១៨-០២០-៣៨១ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយ៉ូអរកូត (KHQR Code)

សម្រាប់ការទូទាត់សងប្រាក់

KHQR Code Specification in Cambodia

Merchant-Presented Mode

Version 3.0

April/2020

Legal Notice

The KHQR specification is adapted from EMV® QR Code specification for Payment System – Merchant-Presented Mode (EMV QRCPS), QR Technical teams (QR Working Group-QRWG) from various Banks, MDIs and PSI had reviewed and changed follow Cambodia's requirement, after that submitted to Payment Committee in The Association of Banks in Cambodia (ABC) for endorsement. KHQR Code is created for Retail Payment in Cambodia and cross-border payment within ASEAN countries. The EMV® QR Code specifications are provided "AS IS" without warranties of any kind, and the QR Working Group and its Members neither assume nor accept any liability for any errors or omissions contained in these specifications. The QRWG and its Members DISCLAIMS ALL REPRESENTATIONS AND WARRANTIES, EXPRESS OR IMPLIED, INCLUDING WITHOUT LIMITATION IMPLIED WARRANTIES OF MERCHANTABILITY, FITNESS FOR A PARTICULAR PURPOSE, TITLE AND NON-INFRINGEMENT, AS TO THESE SPECIFICATIONS.

The QRWG and its Members make no representations or warranties with respect to intellectual property rights of any third parties in or in relation to this specification. The QRWG and its Members undertake no responsibility to determine whether any implementation of these specifications may violate, infringe, or otherwise exercise the patent, copyright, trademark, trade secret, know-how, or other intellectual property rights of third parties, and thus any person who implements any part of this specification should consult an intellectual property attorney before any such implementation.

Without limiting the foregoing, this specification may provide for the use of public key encryption and other technology, which may be the subject matter of patents in several countries. Any party seeking to implement this specification is solely responsible for determining whether its activities require a license to any such technology, including for patents on public key encryption technology. The WG and its Members shall not be liable under any theory for any party's infringement of any intellectual property rights in connection with this specification.

QR Code is a registered trademark of DENSO WAVE.

Table of Contents

1. Introduction
2. Overview of EMV® QR Code Specification for Payment Systems (EMV QRCPS)
    2.1 Notational Conventions
3. Common use cases
    3.1 Static QR Code
    3.2 Dynamic QR Code
4. QR Code Payload Data Objects
    4.1 QR Code Conventions
    4.2 Merchant Account Information
    4.3 Additional Merchant Information
    4.4 Transaction Value
    4.5 Additional Data Template

Annex A

1. Introduction

With guidance from the National Bank of Cambodia, the Association of Banks in Cambodia, established the Working Group (the "WG") on the Common QR Code Standard in Cambodia in September 2019, to develop national QR Code standard.

The WG aims to develop a common QR code specification in Cambodia, which will facilitate merchants, especially SMEs, in using a single QR code to accept payments via different payment service operators. Members of the WG include representatives from Banks, MDIs, Payment Service Providers, and International Card Schemes.

A full list of the WG Members is at Annex A.

The standardization of QR code specification will help promote wider use of mobile retail payments in Cambodia and provide consistent user experience for merchants and consumers. It can enable interoperability in the payment industry. By prescribing a QR code standard, it will enable the use of a single common QR code that can encompass QR code payment solutions from multiple payment service operators. A common QR code would facilitate payments among different payment schemes, e-wallets and banks and would encourage small merchants to adopt QR code as a payment method.

The WG agreed to focus the work on a common merchant-presented QR code. Having studied various options, the WG agreed to develop a common QR code specification by using the EMV® Merchant-Presented QR Code Specification for Payment Systems (EMV QRCPS) published by EMVCo[8] as a basis, as it offers an effective solution to ensure interoperability. This specification should be read in conjunction with the EMV QRCPS. The notational conventions used in this specification are the same as those used in EMV QRCPS.

2. Overview of EMV® QR Code Specification for Payment Systems (EMV QRCPS)

An EMV Merchant-Presented QR Code Payment transaction enables consumers to make purchases using a merchant generated and displayed QR Code based on the merchant's details. Following the design of the EMV QRCPS, the data within a QR code are organized in a tree-like structure of data objects. A data object may be a primitive data object or a template. A template may include other primitive data objects and templates.

Each data object is made up of three individual fields. The first field is an identifier (ID) by which the data object can be referenced. The second field is a length field that explicitly indicates the number of characters included in the third field, i.e. the value field. A data object therefore comprises the following:

- ID field, which is coded as a two-digit numeric value, with a value ranging from "00" to "99";
- Length field, which is coded as a two-digit numeric value, with a value ranging from "01" to "99"; and
- Value field, which has a minimum length of one character and maximum length of 99 characters.

A common QR code may support multiple payment operators, where individual payment operators may define their own structures of merchant account information and make use of the common data fields, such as transaction currency and amount, contained in the common QR code.

[8] EMVCo is the global technical body that facilitates the worldwide interoperability and acceptance of secure payment transactions by managing and evolving EMV® Specification and related testing processes.

Specifically, the EMV Merchant-Presented QR Code supports EMVCo and non-EMVCo payment operators through the use of IDs “02” to “25” for the EMVCo payment operators and IDs “26” to “51” for any payment operators. Individual payment operators may also include some proprietary data in the Additional Merchant Information data objects (See Section 4).

2.1 Notational Conventions

The abbreviations listed in Table 2.1, which is extracted from the EMV QRCPS, are used in this specification.

Table 2.1: Abbreviations

Abbreviation	Description
AID	Application Identifier
ans	Alphanumeric Special
API	Application Programming Interface
C	Conditional
CRC	Cyclic Redundancy Check
EMV	Europay, MasterCard, Visa
ID	Identifier of the data object
IEC	International Electrotechnical Commission
ISO	International Standards Organization
M	Mandatory
N	Numeric
O	Optional
QR Code	Quick Response Code
QR-CPS	Quick Response Code Specification for Payment Systems
RFU	Reserved for Future Use
S	String
UUID	Universally Unique Identifier
var.	Variable


3. Common use cases

Merchant-Presented QR code enables a merchant presenting a request for payment to a payer, who can then verify the associated information and make a payment to the payee, or reject the request for payment. It supports various payment types, including bill payments, online payments and point-of-sale payments. QR codes are classified into static and dynamic QR codes. The information encoded in a static QR code is fixed and used for multiple transactions while a dynamic QR code contains additional transaction details such as payment amount and is used for specific transactions.

3.1 Static QR Code

A typical use case of static QR code is payment to small merchants. A florist shop may display a static QR code with merchant account information. Consumers may then scan the QR code with a mobile application to initiate the payment. The merchant's information, such as the shop name, is displayed on the mobile device for verification. The consumer will be prompted to enter a payment amount. Figure 3.1 shows a typical transaction flow of using static QR code to make merchant payment.

Figure 3.1: Transaction flow of Static QR code merchant payment



[1] Merchant displays QR Code with merchant details.

[2] Consumer scans QR Code using a mobile application and inputs the amount to initiate the transaction.

[3] Mobile application sends the transaction initiation request to the payment service operator.

[4] The payment service operator processes the transaction and informs the merchant and the consumer of the transaction outcome.

3.2 Dynamic QR Code

Dynamic QR codes are commonly used in online payments, delivery payments, bill payments as well as payments at self-service kiosks. A typical use case of dynamic QR code is payment for online shopping. When a consumer checks out at an online shop, the merchant generates and presents the dynamic QR code, embedded with the essential transaction details, for the consumer to scan with a mobile application to initiate the payment. The merchant's information (such as Merchant Name) and variable invoice information (such as payment amount) are displayed on the mobile device for verification.

4. QR Code Payload Data Objects

As described in the EMV QRCPS, the content of the QR Code includes the following 5 groups of data objects:

- QR Code Conventions (Table 4.1)
- Merchant Account Information (Table 4.2)
- Additional Merchant Information (Table 4.3)
- Transaction Value (Table 4.4)
- Additional Data Template (Table 4.5)

4.1 QR Code Conventions

The QR Code Conventions (Table 4.1) specify conventions used for the QR Code content, such as Payload Format indicator, which defines the version of the QR Code template and hence the conventions on the identifiers, lengths and values.

Table 4.1: QR Code Conventions

ID	Name	Length	Presence	Remarks
“00”	Payload Format Indicator	“02”	M	A fixed value of “01”
“01”	Point of Initiation Method	“02”	O	“11” for static QR Codes; “12” for dynamic QR Codes
“63”	Cyclic Redundancy Check (CRC)	“04”	M	Checksum calculated over all the data objects included in the QR code

The Payload Format Indicator (ID “00”) shall contain a value of "01". All other values are RFU.

The Point of Initiation Method (ID “01”) shall contain a value of "11" or "12". All other values are RFU. The value of "11" should be used when the same QR Code is shown for more than one transaction and the value of “12” should be used when a new QR Code is shown for each transaction.

The CRC (ID “63”) shall be calculated according to [ISO/IEC 13239] using the polynomial '1021' (hex) and initial value 'FFFF' (hex). The data over which the checksum is calculated shall cover all data objects, including their ID, Length and Value, to be included in the QR Code, in their respective order, as well as the ID and Length of the CRC itself (but excluding its Value). Following the calculation of the checksum, the resulting 2-byte hexadecimal value shall be encoded as a 4-character Alphanumeric Special value by converting each nibble to an Alphanumeric Special character. For example, a CRC with a two-byte hexadecimal value of '007B' is included in the QR Code as "6304007B".

4.2 Merchant Account Information

The Merchant Account Information specifies the identity of a merchant. Each payment operator may define its own format of the Merchant Account Information IDs. Table 4.2A shows the allocation of Merchant Account Information IDs among various payment operators.

Table 4.2A: Merchant Account Information

ID	Name	Length	Presence	Remarks
“02” - “03”	Reserved for Visa	Var. up to “99”	M One or more data objects (IDs “02” to “51”) shall be included	
“04” - “05”	Reserved for Mastercard			
“06” - “08”	Reserved by EMVCo			
“09” - “10”	Reserved for Discover			
“11” - “12”	Reserved for Amex			
“13” - “14”	Reserved for JCB			
“15” - “16”	Reserved for UnionPay			
“17” - “25”	Reserved by EMVCo			
“26”	Reserved for Local Debit Card (CSS) for use in KH			
“27” - “28”	Reserved by the ABC for use in Cambodia			These IDs are reserved for future use
“29” - “30”	Reserved for National Payment (Bakong/ KHQR) for use in Cambodia			“29” Reserved For Remittance “30” Reserved For Payment
“31”	Reserved by the ABC for Payment Innovation (API)			These IDs are reserved for future use
“32” - “33”	Reserved by the Retail Pay			“32” Reserved For Remittance “33” Reserved For Payment
“34” - “38”	Reserved for additional payment network for use in Cambodia			These IDs are reserved for future use
“39” - “51”	Reserved for non-bank payment network for use in Cambodia			Dynamically used by non-bank payment operators for use in Cambodia

The IDs ”26” to “51” are Merchant Account Information templates, which may include primitive data objects and other templates that can be defined by individual payment operators.

The Merchant Account Information template shall contain a primitive Globally Unique Identifier data object with a data object ID "00" to identify the payment operator and the corresponding merchant account information specific to that payment operator (Table 4.2B).

Table 4.2B: Data Object ID Allocation in Merchant Account Information Template (IDs "26" to "51")

ID	Name	Format	Length	Presence	Remarks
"00"	Globally Unique Identifier	ans	Var. up to “32”	M	An identifier to identify the payment operator which uses this template to define the Merchant Account Information The value is one of the following: • an Application Identifier (AID); • a [UUID] without the hyphen (-) separators; or • a reverse domain name.
"01"-“99”	Payment network specific	S		O	Additional data objects to define the Merchant Account Information specific to the payment operator

The value of the Globally Unique Identifier field shall contain one of the following:

- An Application Identifier (AID) consisting of a RID registered with ISO and, optionally, a PIX, as defined by [ISO 7816-4]. For example, "D840000000".
- A [UUID] without the hyphen (-) separators. For example, “581b314e257f41bfbbdc6384daa31d16”.
- A reverse domain name. For example, “com.merchant.name”.

The value of the Globally Unique Identifier field sets the context for the remainder of the template and the meaning of the other data objects in the template are context specific and outside of the scope of this specification.

4.3 Additional Merchant Information

The Additional Merchant Information (Table 4.3A) specifies the information about a merchant such as merchant name and business location.

Table 4.3A: Additional Merchant Information

ID	Name	Format	Length	Presence	Remarks
"52"	Merchant Category Code	N	"04"	M	Put a dummy code of “0000” in this field if the payment operator does not use this information
"58"	Country Code	ans	"02"	M	For Cambodia is “KH”
"59"	Merchant Name	ans	var. up to "25"	M	

"60"	Merchant City	ans	var. up to "15"	M	
"61"	Postal Code	ans	var. up to "10"	O	
"64"	Merchant Information - Language Template	S	var. up to "99"	O	A template with other primitive data objects (See EMV QRCPS for details)

The Merchant Category Code (MCC) (ID “52”) shall contain an MCC as defined by [ISO 18245]. The MCC should indicate the Merchant Category Code of the merchant. Put a dummy code of “0000” in the MCC field if the payment operator does not use this information.

The Country Code (ID “58”) shall contain a value as defined by [ISO 3166-1 alpha 2]. The Country Code should indicate the country in which the merchant transacts. Put “KH” in the Country Code field if the merchant transacts in Cambodia.

The Merchant Name (ID “59”) shall be present. The Merchant Name should indicate the “doing business as” name for the merchant. If the QR code information supports only payment operators who supply merchant information via the payment operator’s centralized database, this field may be populated with a dummy code of “NA” in the Merchant Name field. In all other instances, the Merchant Name field must indicate the “doing business as” name for the merchant.

The Merchant City shall be present (ID “60”). The Merchant City should indicate the city of the merchant's physical location. Put the physical real name, “Phnom Penh” in the Merchant City Code field if the merchant is located in Phnom Penh, Cambodia.

The Merchant Information – Language Template (ID “64”) is a template, which contains other data fields, which may be used by a mobile application to present the merchant information in an alternate language (Table 4.3B).

Table 4.3B: Data Fields for Merchant Information – Language Template (ID “64”)

ID	Name	Format	Length	Presence	Remarks
"00"	Language Preference	ans	"02"	M	
"01"	Merchant Name— Alternate Language	S	Var. up to “25	M	
"02"	Merchant City— Alternate Language	S	var. up to "15"	O	
"03"- “99”	RFU for EMVCo	S	var. up to "99"		Data objects reserved for EMVCo

If the Merchant Information – Language Template (ID “64”) is present, the template shall contain the Language Preference field (ID "00") and Merchant Name — Alternate Language field (ID "01"). It may contain the Merchant City — Alternate Language field (ID "02"). All other IDs within the Merchant Information—Language Template are RFU for EMVCo.

The data fields with IDs "01" and "02" are used as an addition to the merchant information under the root. While the equivalent data objects under the root are defined with a format of Alphanumeric Special, and as such can only contain the Common Character Set, the data fields with IDs “01” and “02”, if present, are defined with a format of String, so therefore may contain a different character set.

The Language Preference field (ID “00”) shall contain 2 alphabetical characters coded to a value defined by [ISO 639]. The value should represent the single language used to encode the Merchant Name—Alternate Language field (ID “01”) and the optional Merchant City—Alternate Language field (ID “02”).

4.4 Transaction Value

The Transaction Value data objects (Table 4.4) specify the currency and amount of a transaction. They also include tip or convenience indicators, which allow merchants or customers to specify the convenience fee in fixed value or percentage.

Table 4.4: Transaction Value

ID	Name	Format	Length	Presence	Remarks
“53”	Transaction Currency	N	“03”	M	A numeric code based on [ISO 4217], e.g. put “116” for KHR.
“54”	Transaction Amount	ans	Var. up to “13”	C	
“55”	Tip or Convenience Indicator	N	“02”	O	
“56”	Value of Convenience Fee Fixed	ans	Var. up to “13”	C	
“57”	Value of Convenience Fee Percentage	ans	Var. up to “05”	C	

The Transaction Currency (ID “53”) shall conform to [ISO 4217] and shall contain the 3-digit numeric representation of the currency. For example, KHR is represented by the value "116". The value should indicate the transaction currency in which the merchant transacts.

The Transaction Amount (ID “54”), if present, shall be different from zero, shall only include (numeric) digits "0" to "9" and may contain a single "." character as the decimal mark. When the amount includes decimals, the "." character shall be used to separate the decimals from the integer value and the "." character may be present even if there are no decimals. The Transaction Amount shall not be included if the mobile application should prompt the consumer to enter the amount to be paid to the Merchant.

The payment system operators should follow the rules and format in accordance with the EMV QRCPS to process the Transaction Value IDs of the QR Code.

4.5 Additional Data Template

The ID “62” is a template which includes common additional data objects such as Bill Number and Reference Label. It also allows payment operators to define their own additional data objects.

Table 4.5: Additional Data

ID	Sub- ID	Name	Format	Length	Pre-sence	Remarks
“62”	“01”	Bill Number	ans	var. up to “25”	O	
	“02”	Mobile Number	ans	var. up to “25”	O	
	“03”	Store Label	ans	var. up to “25”	O	
	“04”	Loyalty Number	ans	var. up to “25”	O	
	“05”	Reference Label	ans	var. up to “25”	O	
	“06”	Customer Label	ans	var. up to “25”	O	
	“07”	Terminal Label	ans	var. up to “25”	O	
	“08”	Purpose of Transaction	ans	var. up to “25”	O	
	“09”	Additional Consumer Data Request	ans	var. up to “25”	O	
	“10” – “49”	Reserved for EMVCo	S		O	
	“50”	Reserved for FPS	S		O	
	“51” – “55”	Reserved for the WG	S		O	
	“56” – “99”	Reserved for Cambodia payment system operators	S		O	Dynamically used by payment operators for use in Cambodia

The payment operators should follow the rules and format in accordance with the EMV QRCPS to process the Data Objects for Additional Data Field Template of the QR Code. As the maximum data size of this Additional Data Field Template (ID “62”) is only 99 characters, it is highly recommended that the operators make use of the pre-defined additional data objects (Sub-IDs “01” – “09”) and avoid defining their own additional data objects in this template so as to prevent data overflow when QR codes of several payment system operators are combined into one common QR Code.

Annex A

Members of Working Group on KHQR Code Standard in Cambodia consist of representatives from the following institutions:

The Association of Banks in Cambodia:

ACLEDA Bank

CIMB Bank

Angkor Capital Specialized Bank

Foreign Trade Bank of Cambodia (FTB)

Phnom Penh Commercial Bank (PPCBank)

Wing (Cambodia) Limited Specialised Bank

The Cambodian Association of Finance and Technology (CAFT):

Bongloy

Microfinance deposit taking institutions (MDI):

AMK

Card schemes:

MasterCard

UnionPay

Visa

ឆ.២. មូលប្បទានបត្រ

ធ៥-០០-១៥០ ប្រ.ក

ប្រកាស
ស្តីពី
សភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

១. បង្កើតសភាជាត់ទាត់សម្រាប់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកតទៅនេះហៅថា "សភាជាត់ទាត់" ដើម្បីផ្តល់នូវសេវាចំពោះអតិថិជននៃប្រព័ន្ធធនាគារ ដែលមានសំណូមពរទូទាត់ប្រចាំថ្ងៃនូវមូលប្បទានបត្រក្នុងចំណោមសមាជិកសភាជាត់ទាត់បើកគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

២. ដាក់ចេញនូវបទបញ្ជានៃសភាជាត់ទាត់តទៅនេះហៅថា "បទបញ្ជា" ដែលកំណត់អំពីលក្ខខណ្ឌទាំងឡាយសម្រាប់អនុវត្តចំពោះសេវានេះក្នុងប្រការបន្តបន្ទាប់ដូចខាងក្រោម។

ប្រការ ២.- អំពីសមាជិកភាព

១. ធនាគារដែលមានគោលបំណងចូលជាសមាជិកសភាជាត់ទាត់ត្រូវដាក់ពាក្យស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ១។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាមីនឹងត្រូវបានធនាគារជាតិនៃកម្ពុជាបញ្ចូលជាសមាជិកនៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់។ សមាជិកសភាជាត់ទាត់ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាមដូចមានក្នុងឧបសម្ព័ន្ធ ២។

២. ធនាគារដែលមិនមែនជាសមាជិកត្រូវបានអនុញ្ញាតឱ្យមានតំណាងក្នុងសភាជាត់ទាត់ជំនួសខ្លួនដោយធនាគារជាសមាជិក ចំពោះសំណូមពរជាត់ទាត់និងទូទាត់មូលប្បទានបត្រ។ ការសុំឱ្យមានតំណាងនេះត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយធនាគារជាតិនៃកម្ពុជាជាមុន។

ប្រការ ៣.- លក្ខណៈសម្បត្តិជាសមាជិក

១. ធនាគារដែលធនាគារជាតិនៃកម្ពុជាចេញអាជ្ញាបណ្ណឱ្យប្រកបអាជីវកម្មអាចសុំចូលជាសមាជិក។ បែបបទនៃការស្នើសុំរួមមាន៖

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬអ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចម្លងនៃអាជ្ញាបណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាមនិងគំរូហត្ថលេខា។

លើសពីនេះទៀតធនាគារជាសមាជិកត្រូវ៖

- មានគណនីចរន្តនិងគណនីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា
- បង់សោហ៊ុយសេវាតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាសមាជិកត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ។

ប្រការ ៤.- ការបាត់បង់សមាជិកភាព

១. ធនាគារដែលត្រូវបានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាបណ្ណពុំអាចចូលរួមក្នុងសភាជាត់ទាត់បានទេ។

២. ធនាគារអាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាជាត់ទាត់ឱ្យតែធនាគារនោះបានធ្វើការសម្របសម្រួលត្រឹមត្រូវជាមួយនឹងធនាគារជាសមាជិកមួយទៀតឱ្យកាន់កាប់មូលប្បទានបត្រដើម្បីជាត់ទាត់ជំនួសខ្លួនដោយមានការយល់ព្រមជាមុនជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.- ធនាគារទូទាត់

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃអំពីទឹកប្រាក់សរុបនៃមូលប្បទានបត្រដែលសភាជាត់ទាត់បានបញ្ជូនទៅនិងទទួលយក និងគណនីទឹកប្រាក់សុទ្ធដែលត្រូវចុះឥណពន្ធ ឬចុះឥណទានគណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ។

ប្រការ ៦.- អំពីការគ្រប់គ្រង

១. ធនាគារជាតិនៃកម្ពុជាត្រូវជ្រើសរើសប្រធានសភាជាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាជាត់ទាត់។ ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និងតាមដានមុខងារប្រចាំថ្ងៃទៅឱ្យអ្នកដឹកនាំជាត់ទាត់។ ប្រធានសភាជាត់ទាត់ និងអ្នកដឹកនាំជាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា។

២. ករណីកើតមានវិវាទរវាងតំណាងរបស់ធនាគារសមាជិកក្នុងពេលប្រគល់ ឬទទួលការទូទាត់ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសម្រេចរបស់អ្នកដឹកនាំជាត់ទាត់ អាចត្រូវទទួលយកជាបណ្តោះអាសន្នដោយមានទិដ្ឋាការរបស់ប្រធានសភាជាត់ទាត់។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសម្រេចការដោះស្រាយត្រូវធ្វើដោយផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

ប្រការ ៧.- គណៈកម្មាធិការប្រតិបត្តិការ

១. ការងារសភាជាត់ទាត់អាចត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការដែលរួមមានតំណាងមួយរូបរបស់ធនាគារសមាជិកនីមួយៗ និងដឹកនាំដោយប្រធានមួយរូបជ្រើសរើសដោយសមាជិក។ ប្រធានត្រូវបម្រើការរយៈពេលមួយឆ្នាំ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំងនិងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាជាត់ទាត់។

២. គណៈកម្មាធិការប្រតិបត្តិការមានមុខងារដូចតទៅ៖

- ពិគ្រោះផ្តល់យោបល់ដើម្បីលើកកម្ពស់គុណភាពប្រតិបត្តិការជាត់ទាត់
- ពង្រឹងសណ្តាប់ធ្នាប់និងវិន័យរបស់តំណាងសមាជិក
- អនុវត្តឱ្យបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយគណៈកម្មាធិការ។

៣. គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់ ៤ ដង ក្នុងមួយឆ្នាំ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយលក្ខណ៍អក្សររបស់សមាជិកពីរូបយ៉ាងតិចដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា។

ប្រការ ៨.- ការកែប្រែបន្ថយញ្ញា

ខ្លឹមសារ និងលក្ខខណ្ឌនៃបទបញ្ជាជាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការជាត់ទាត់ទៅខេត្ត-ក្រុងដទៃទូទាំងប្រទេសបន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូទាត់។

ជំពូកទី ២
និយមន័យនៃពាក្យបច្ចេកទេស

ប្រការ ៩.-

ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ជាមាននិយមន័យដូចតទៅ៖

១. ថ្ងៃធ្វើការ (Business Day) គឺថ្ងៃចន្ទដល់ថ្ងៃសុក្រ ឬថ្ងៃបន្ថែមណាមួយដែលធនាគារជាតិនៃកម្ពុជាបានកំណត់បើកធ្វើការ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សម្រាកជាសាធារណៈទេ។

២. សភាជាត់ទាត់ (Clearing House) គឺជាមណ្ឌលសម្រួលការជាត់ទាត់ដែលធ្វើឡើងដោយធនាគារជាតិនៃកម្ពុជានៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ។

៣. ឧបករណ៍ទូទាត់ (Payment or item) គឺជាមូលប្បទានបត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ មូលប្បទានបត្រគឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយឱ្យទូទាត់ប្រាក់គណនីនោះទៅឱ្យអត្ថគាហក។

៤. ឧបករណ៍បង្វិលវិញឬមិនទូទាត់ (Returned or unpaid item) គឺជាមូលប្បទានបត្រដែលមិនអាចទូទាត់ដោយសមាជិកទទួលដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ៣។ មូលប្បទានប័ត្រត្រូវចាត់ទុកថាបានទូទាត់បញ្ចប់ជាមួយនឹងមូលនិធិដែលបានសងទៅអត្ថគាហក លុះត្រាតែគ្រាជាត់ទាត់នៃមូលប្បទានបត្របង្វិលវិញត្រូវបិទ។

៥. ឧបករណ៍ដែលអាចទទួលយកបាន (Eligible items) នៅសភាជាត់ទាត់រួមមាន៖

ក. មូលប្បទានបត្រ និងរូបិយាណត្តិជាដុល្លារអាមេរិករបស់ធនាគារដែលបានចេញផ្សាយដោយតតិយជនត្រូវសងឱ្យតតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតិនៅភ្នំពេញ

ខ. មូលប្បទានបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

គ. ឧបករណ៍ឥណពន្ធខ្លះទៀតដែលធនាគារជាតិនៃកម្ពុជាកំណត់ថាអាចទទួលយកបាន។ មូលប្បទានបត្របានចេញផ្សាយតាមទ្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយធនាគារមានលំនាំស្តង់ដារដូចដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ មូលប្បទានបត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬបារាំង។

៦. សមាជិក (Participant) គឺជាធនាគារដែលបានយល់ព្រមចូលរួមក្នុងសភាជាត់ទាត់ក្រោមខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជានេះ។

៧. ការចូលរួម (Participation) គឺជាវត្តមានក្នុងគ្រាជាត់ទាត់ប្រចាំថ្ងៃរបស់សភាជាត់ទាត់។ សមាជិកត្រូវចូលរួមរាល់គ្រាជាត់ទាត់ទោះបីមាន ឬគ្មានមូលប្បទានបត្រដើម្បីបញ្ជូនទៅសមាជិកដទៃក្តី។

៨. សមាជិកទទួល (Receiving Participant) គឺជាសមាជិកដែលទទួលការទូទាត់ជាមូលប្បទានបត្រតាមរយៈសភាជាត់ទាត់។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង (Paying Bank)។

៩. សមាជិកប្រគល់ (Sending Participant) គឺជាសមាជិកដែលប្រគល់មូលប្បទានបត្រសម្រាប់ការទូទាត់តាមរយៈសភាជាត់ទាត់។

១០. កិច្ចបញ្ជិកា (Books) គឺជាការកត់ត្រាគណនេយ្យលើគណនីអតិថិជន ដែលបើកនៅធនាគារ និងគណនីចរន្តរបស់ធនាគារដែលបើកនៅធនាគារជាតិនៃកម្ពុជា។

១១. ការកត់ត្រា (Posting) គឺជាការចុះឥណពន្ធគណនីអតិថិជនសម្រាប់មូលប្បទានបត្រដោយធនាគារទទួល។

១២. ការទូទាត់ (Settlement) គឺជាលេខនានៃឥណពន្ធសុទ្ធ ឬឥណទានសុទ្ធក្នុងគណនីជាត់ទាត់របស់ធនាគារជាសមាជិកសម្រាប់ការជាត់ទាត់ប្រចាំថ្ងៃ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ននិងអាចដកហូតមកវិញចំពោះការទូទាត់ណាដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ជា។

១៣. លេខអត្តសញ្ញាណ (Routing Number) គឺជាលេខសម្គាល់របស់សមាជិកដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយធនាគារជាតិនៃកម្ពុជា។ លេខអត្តសញ្ញាណត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាជាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសមស្របលើមូលប្បទានបត្រដោយអនុលោមតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា។

១៤. គ្រាជាត់ទាត់ (Session) គឺជាការប្រជុំរបស់សមាជិកសភាជាត់ទាត់ដើម្បីប្តូរមូលប្បទានបត្រទៅវិញទៅមក។ គ្រាជាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាជាត់ទាត់បន្ទាប់បន្សំសម្រាប់បង្វិលវិញនូវមូលប្បទានបត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល។ ប៉ុន្តែប្រធានអាចសម្រេចយកគ្រាជាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយប្រសិនបើយល់ថាចាំបាច់។

១៥. គណនីជាត់ទាត់ (Clearing Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជាសម្រាប់ការទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាជាត់ទាត់។ គណនីនេះត្រូវបានប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាជាត់ទាត់ដោយសមាជិក។

១៦. គណនីប្រាក់បម្រុងកាតព្វកិច្ច (Reserve Requirement Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជា ដើម្បីអនុវត្តតាមប្រកាសស្តីពីប្រាក់បម្រុងកាតព្វកិច្ចដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។ គណនីនេះមិនអាចប្រើសម្រាប់ការទូទាត់កាតព្វកិច្ចរបស់សភាជាត់ទាត់ដោយសមាជិកបានទេ។

១៧. គណនីប្រាក់តម្កល់ធានា (Deposit Guaranty Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗនៅធនាគារជាតិនៃកម្ពុជាដោយត្រូវតម្កល់ប្រាក់ចំនួនស្មើនឹងដប់ភាគរយ (១០%) នៃដើមទុនចុះក្នុងលក្ខន្តិក:។ គណនីនេះមិនអាចប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាជាត់ទាត់ដោយសមាជិកបានទេ។

ជំពូកទី ៣
ការទទួលខុសត្រូវរបស់ធនាគារប្រគល់

ប្រការ ១០.-

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាជាត់ទាត់ ដើម្បីប្រគល់មូលប្បទានបត្រទៅឱ្យសមាជិកដទៃ។ ការប្រគល់មូលប្បទានបត្រទ្វេភាគីក្រៅពីគ្រាប្រជុំនៃសភាជាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងពិសេសទៅវិញទៅមករវាងសមាជិកសភាជាត់ទាត់ផ្ទាល់។

ប្រការ ១១.-

សមាជិកប្រគល់ត្រូវ:

១. អនុញ្ញាតនិងកំណត់អត្តសញ្ញាណនៃការប្រគល់

មូលប្បទានបត្រទាំងអស់ត្រូវបោះត្រារបស់សមាជិក ប្រគល់និងកាលបរិច្ឆេទនៃការបញ្ជូននៅខាងខ្នងនៃមូលប្បទានបត្រនីមួយៗ។

២. រៀបចំការប្រគល់ឱ្យបានត្រឹមត្រូវ

សមាជិកប្រគល់ម្នាក់ៗត្រូវរៀបចំតារាងនៃមូលប្បទានបត្រជាពីរច្បាប់គំរូ PPC001 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានបត្រនីមួយៗ និងតម្លៃសរុបនៃមូលប្បទានបត្រដែលត្រូវដកប្រាក់ (Draw on) ពីសមាជិកដទៃ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ៤។ តារាងគំរូ PPC001 ត្រូវបានរៀបចំសម្រាប់សមាជិកនីមួយៗដោយបង្ហាញនូវ:

ក. ទឹកប្រាក់សរុប និងចំនួននៃមូលប្បទានបត្រចេញផ្សាយនៅបណ្តាទីស្នាក់ការភ្នំពេញ ដែលបានបង្ហាញដល់សមាជិកទាំងនោះនិង

ខ. មូលប្បទានបត្រមិនទូទាត់បង្វិលវិញនិងមិនអាចទទួលយកបាន។

សមាជិកប្រគល់ម្នាក់ៗត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPC001។

៣. ចូលរួមទៀងទាត់ក្នុងគ្រាជាត់ទាត់

មូលប្បទានបត្រត្រូវបានយកទៅសភាជាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗសមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាជាត់ទាត់លើសពី៥នាទី អាចត្រូវផ្អាកមិនឱ្យចូលរួមគ្រាជាត់ទាត់នោះដោយអ្នកដឹកនាំជាត់ទាត់។ សមាជិកដែលត្រូវផ្អាកមិនឱ្យចូលរួមក្នុងគ្រាជាត់ទាត់មិនអាចប្រគល់មូលប្បទានបត្រទៅសមាជិកដទៃឡើយ។ ប៉ុន្តែសមាជិកនោះត្រូវទទួលយកហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានបត្រដែលសមាជិកដទៃប្រគល់ឱ្យខ្លួន។

៤. អនុញ្ញាតឱ្យចុះឥណពន្ធគណនីចំពោះមូលប្បទានបត្របង្វិលវិញ

ក្នុងករណីមានកាលបង្វិលវិញនៃមូលប្បទានបត្រ ដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ។

៥. រក្សាទុកនូវការកត់ត្រា

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការធ្វើឬការទូទាត់ដាច់ពីគ្នាសម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទបង្ហាញដំបូង។ ប៉ុន្តែនេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការកែតម្រូវការទូទាត់យឺតជាងរយៈពេលនេះទេ។

ជំពូកទី ៥

ការទទួលខុសត្រូវរបស់ធនាគារកណ្តាល

ប្រការ ១២.-

ធនាគារទទួលត្រូវទទួលយកមូលប្បទានបត្រ ដែលបានប្រគល់ឱ្យខ្លួននៅសភាជាត់ទាត់រៀងរាល់ថ្ងៃដោយរួមបញ្ចូលទាំងមូលប្បទានបត្រមិនទូទាត់ដូចមានចែងក្នុងប្រការ ១១។ មូលប្បទានបត្រដែលត្រូវប្រគល់ឱ្យសមាជិកទទួលក៏ប៉ុន្តែមិនបានទទួលយក ដោយសារតែការមិនបានចូលរួមក្នុងគ្រាជាត់ទាត់ឬត្រូវបានផ្អាកមិនឱ្យចូលរួមដោយសារការមកដល់យឺតក្នុងថ្ងៃនោះត្រូវចាត់ទុកថាបានប្រគល់នៅថ្ងៃនោះដើម្បីសំណូមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានបត្រមិនទូទាត់។

ប្រការ ១៣.-

សមាជិកទទួលត្រូវ៖

១. បញ្ជាក់នូវការយល់ព្រមទទួល (Certify Acceptance)

សមាជិកទទួលត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC001 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានបត្រនៅសភាជាត់ទាត់។ សមាជិកទទួលនីមួយៗត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC002 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធឬឥណទានក្នុងគណនីជាត់ទាត់របស់ខ្លួនជាលទ្ធផលនៃគ្រាជាត់ទាត់។

២. ទូទាត់សងឬបង្វិលវិញនូវមូលប្បទានបត្រ (Settlement for or return payment)

មូលប្បទានបត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សងឬត្រូវបានបង្វិលវិញ។ សមាជិកទទួលកាន់កាប់មូលប្បទានបត្រជាការធ្វើទុក (In trust) រហូតដល់គេបានទទួលឥណទានពីបហារ័ក (Drawer) នៃមូលប្បទានបត្រដោយចុះចូលគណនីរបស់អតិថិជនខ្លួន។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីជាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ។

៣. បង្វិលវិញនូវមូលប្បទានបត្រមិនទូទាត់ (Return unpaid or dishonored payment)

ក. បទប្បញ្ញត្តិទូទៅ (General Provision)

មូលប្បទានបត្រមិនទូទាត់ ឬបដិសេធត្រូវបានបង្វិលមកវិញតាមរយៈសភាជាត់ទាត់។ សមាជិកទទួលត្រូវបញ្ជាក់ឱ្យច្បាស់លើមូលប្បទានបត្របង្វិលវិញនូវមូលហេតុ ដែលបានព្រមព្រៀងដូចមានរាយនាមក្នុងឧបសម្ព័ន្ធ៣ និងឈ្មោះរបស់សមាជិកទទួល។

ខ. បង្វិលវិញឱ្យទាន់ពេល (Timely Return)

មូលប្បទានបត្រដែលត្រូវបង្វិលវិញតាមរយៈសភាជាត់ទាត់ ត្រូវធ្វើការបង្វិលវិញឱ្យទាន់ពេលហើយសមាជិកទទួលមិនត្រូវបានបង្ខំឱ្យទទួលខុសត្រូវចំពោះមូលប្បទានបត្រនោះទេប្រសិនបើមូលប្បទានបត្រនោះត្រូវបានបង្វិលវិញមិនយឺតជាងម៉ោង ៣:០០ រសៀលនៃថ្ងៃជាត់ទាត់។ មូលប្បទានបត្រ មិនត្រូវបានចាត់ទុកថាទូទាត់បញ្ចប់ជាមួយនឹងការសងជម្រះជាសាច់ប្រាក់ទេរហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ។

គ. ការទូទាត់សម្រាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួលត្រូវបង្វិលវិញនូវមូលប្បទានបត្រមិនទូទាត់ ដែលបានបញ្ជាក់ច្បាស់ជាមូលប្បទានបត្របង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសម្រាប់សមាជិកទទួល (គំរូ PPC001)។

ឃ. ការផុតកំណត់នៃសិទ្ធិបង្វិលវិញ (Expiration of return privilege)

មូលប្បទានបត្រអាចមិនទូទាត់និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ។ មូលប្បទានបត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ (Dishonor) លើកទីពីរត្រូវតែដកចេញពីបណ្តាញនៃសភាជាត់ទាត់ដោយទុកឱ្យធ្វើបេឡានិច័យផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

៤. ការរក្សាទុកនូវការកត់ត្រា

សមាជិកទទួលត្រូវរក្សាទុកនូវថាសកុំព្យូទ័រ ឬក្រដាសតារាងនិងវត្ថុសំអាងជាក់ស្តែងផ្សេងៗទៀតដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសម្រាប់ប្រតិបត្តិការរបស់សភាជាត់ទាត់ សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទទទួល។ សមាជិកទទួលមិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតម្រូវការស្តីពីប្រតិបត្តិការ ដែលកើតមានឡើងបន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់។

៥. ការបង្វិលវិញនៃមូលប្បទានបត្រមិនបានកត់ត្រាក្នុងករណីមានកំហុស

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជាសម្រាប់ការទូទាត់ប្រចាំថ្ងៃនិងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថាមានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារឱ្យសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់នូវមូលប្បទានបត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួនទៅឱ្យធនាគារជាតិនៃកម្ពុជា។ បន្ទាប់មកធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានបត្រនោះទៅឱ្យសមាជិកដែលប្រគល់ពីដំបូងវិញ។

៦. ការធានានូវសិទ្ធិប្រទានរបស់អតិថិជន

សមាជិកទាំងឡាយត្រូវបានរំឭកថា៖

ក. ការចុះឥណពន្ធគណនីរបស់អតិថិជនទាមទារត្រូវមានសិទ្ធិប្រទានរបស់អតិថិជន។ មូលប្បទានប័ត្រដែលមានហត្ថលេខាក្លែងក្លាយ គឺគ្មានសិទ្ធិប្រទាននោះទេ ហើយជាធម្មតាមិនអាចត្រូវចុះឥណពន្ធគណនីរបស់អតិថិជនឡើយ។

ខ. អ្នកកាន់ឬអ្នកធ្វើបិដ្ឋិលេខ (ចារពីខ្នង) មូលប្បទានបត្រមិនអាចត្រូវចាត់ទុកជាមធ្យោបាយដែលគ្មានការក្លែងក្លាយឡើយ។ ដូច្នេះ សមាជិកអាចទទួលតែមូលប្បទានបត្រពីបុគ្គលណាដែលខ្លួនស្គាល់ ឬដែលត្រូវបានសម្គាល់អត្តសញ្ញាណត្រឹមត្រូវ។

ជំពូកទី ៥
ការទទួលខុសត្រូវរបស់ធនាគារជាតិនៃកម្ពុជា

ប្រការ ១៤.-

ធនាគារជាតិនៃកម្ពុជាគឺជាសមាជិកមួយនៃសភាជាត់ទាត់ដែលអាចទទួល និងប្រគល់មូលប្បទានបត្រដូចគ្នានឹងសមាជិកដទៃសម្រាប់សងឱ្យគេឬទារយកពីគេ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាសម្រួលដល់គ្រាជាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួនដែលបានបើកឱ្យសមាជិកទាំងអស់។

ប្រការ ១៥.- **ការរៀបចំគំរូ (Preparation of form)**

អ្នកដឹកនាំជាត់ទាត់ត្រូវរៀបចំនូវគំរូ PPC002 និង PPC003 ដោយឧបករណ៍អេឡិកត្រូនិកដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ៤ ដោយបញ្ចូលក្នុងតារាងកិច្ចការកុំព្យូទ័ររបស់សមាជិក (គំរូ PPC001) ពីថាសដែលបានយកមកក្នុងគ្រាជាត់ទាត់។

ប្រការ ១៦.- **ការទូទាត់** (Settlement)

១. ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗដោយការចុះឥណពន្ធ និងចុះឥណទាន គណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រប្រគល់លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រទទួលលើសចំនួនទឹកប្រាក់នៃមូលប្បទានបត្រប្រគល់ គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ។ នៅពេលដែលអ្នកដឹកនាំជាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាជាត់ទាត់មានតុល្យភាពហើយនោះអ្នកដឹកនាំជាត់ទាត់ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងឬតារាងបោះពុម្ពចេញនៃគំរូ PPC002 របស់សមាជិកនីមួយៗ ទុកជាប្រកាសឥណពន្ធ ឬឥណទានក្នុងគណនីចរន្តរបស់សមាជិកនោះ។ បន្ទាប់មកអ្នកដឹកនាំជាត់ទាត់ត្រូវប្រកាសថាគ្រាជាត់ទាត់ត្រូវបញ្ចប់។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាជាត់ទាត់បានឡើយ។

២. ក្នុងករណីដែលសមាជិកទទួលមានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់សមាជិកនោះមានរយៈពេល ២ម៉ោង ដើម្បីសម្របសម្រួលមូលនិធិពីធនាគារផ្សេងមួយទៀតដើម្បីដាក់បញ្ចូលក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា។ នេះគឺជាប្រភពចម្បង និងរំពឹងបាននៃមូលនិធិសម្រាប់ការទូទាត់។

ប្រការ ១៧.- **សមតុល្យដែលបានតម្កល់នៅធនាគារជាតិនៃកម្ពុជា** (Balance maintained at NBC)

សមាជិកទាំងអស់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចុះឥណពន្ធលើគណនីចរន្តរបស់ពួកគេ នូវចំនួនទឹកប្រាក់ដែលជាលទ្ធផលនៃការជាត់ទាត់មូលប្បទានបត្រ និងត្រូវតម្កល់មូលនិធិក្នុងគណនីចរន្តទាំងនោះឱ្យមានគ្រប់គ្រាន់ដើម្បីចុះឥណពន្ធ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធនាគារសមាជិកតម្កល់ឱ្យបានគ្រប់គ្រាន់នូវប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងគណនីផ្សេង ដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន។

ប្រការ ១៨.- **ការទូទាត់មិនបាន** (Failure to settle)

១. ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធសុទ្ធរបស់ខ្លួនក្នុងសភាជាត់ទាត់ក្នុងរយៈពេលអនុញ្ញាត ២ ម៉ោង នោះទេ អ្នកដឹកនាំជាត់ទាត់នឹងជូនដំណឹងចំពោះប្រធានសភាជាត់ទាត់ដែលនឹងកំណត់នូវវិធានការកែលម្អ។ ប្រសិនបើធនាគារជាតិនៃកម្ពុជាបានប្រកាសថា សមាជិកនោះ "មានកំហុស (In Default)" ប្រធានសភាជាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត។ គ្រាជាត់ទាត់មិនត្រូវបានប្រកាសបិទទេលើកលែងតែគណនីទាំងអស់ ត្រូវបានចុះឥណពន្ធជាស្តាពរនៅថ្ងៃជាត់ទាត់នោះ។

២. ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាជាត់ទាត់ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺចុះបញ្ច្រាសនូវឥណទាន ដែលបានផ្តល់ឱ្យធនាគារទទួលចំពោះមូលប្បទានបត្ររបស់ខ្លួនដែលយកទៅឱ្យសភាជាត់ទាត់ និងចុះបញ្ច្រាសនូវឥណពន្ធ ចំពោះមូលប្បទានបត្រ ដែលបានយកដោយធនាគារដទៃ ហើយគណនា

ជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាមនោះ។ អ្នកដឹកនាំជាត់ទាត់ត្រូវរៀបចំគំរូជាថ្មីដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់។ ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការជាត់ទាត់ឡើយ។

ប្រការ ១៩.- **ព្រំដែននៃការទទួលខុសត្រូវ** (Limited of Liability)

ធនាគារជាតិនៃកម្ពុជាមិនទទួលខុសត្រូវ និងមិនទទួលសងឡើយក្នុងករណីដែលសមាជិកមានការខាតបង់ក្នុងទំនាក់ទំនងជាមួយសមាជិកសភាជាត់ទាត់លើកលែងតែក្នុងករណីនៃការធ្វេសប្រហែស និងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់។ ការតវ៉ាទាំងអស់អំពីការបែងចែកមិនត្រឹមត្រូវ ការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានបត្រកំហុសរបស់សមាជិក។ល។ ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់ លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ជីរបស់ធនាគារជាតិនៃកម្ពុជាដើម្បីកត់ត្រាប្រតិបត្តិការ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជាសម្រាប់មូលប្បទានបត្ររបស់ខ្លួនផ្ទាល់ ដែលបានបញ្ចូលដើម្បីជាត់ទាត់និងទូទាត់តាមរបៀបដូចគ្នានឹងសមាជិកដទៃទៀត។

ជំពូកទី៦
បទប្បញ្ញត្តិផ្សេងៗ

ប្រការ ២០.- **អាសយដ្ឋានសម្រាប់ការជូនដំណឹង** (Address for notices)

១. ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសភាជាត់ទាត់ដូចដែលតម្រូវដោយបទបញ្ជាត្រូវតែបញ្ជាក់អាសយដ្ឋានដូចតទៅនេះ៖

ប្រធាន

សភាជាត់ទាត់នៃមូលប្បទានបត្រចារឹកជាដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជា

២២-២៤ មហាវិថីព្រះនរោត្តម

ប្រអប់សំបុត្រ២៥

ភ្នំពេញ កម្ពុជា

២. ការជូនដំណឹងជាលាយលក្ខណ៍អក្សររវាងសមាជិក ដែលតម្រូវដោយបទបញ្ជានេះត្រូវបញ្ជូនទៅអាសយដ្ឋានដែលសមាជិកបានចង្អុលបង្ហាញជារៀងរាល់ពេល។ ការបញ្ជាក់ពីអាសយដ្ឋានសមស្របនឹងត្រូវមានប្រសិទ្ធភាព ចាប់ពីពេលបានទទួលឬនៅពេលផុតកំណត់នៃពេលវេលាដែលបានកំណត់ពីមុនមក ក្នុងករណីនេះការជូនដំណឹងជាមុនគឺជាការចាំបាច់។

ប្រការ ២១.- **តំណាងទទួលសិទ្ធិ** (Authorized representatives)

សមាជិកត្រូវផ្តល់តារាងនៃតំណាងទទួលសិទ្ធិទាំងអស់ ដោយមានគំរូហត្ថលេខាគ្រប់គ្នាបញ្ជូនទៅអាសយដ្ឋានដូចមានចែងក្នុងប្រការ ២០ ខាងលើ។

ប្រការ ២២.- **ច្បាប់សម្រាប់គ្រប់គ្រង (Governing Law)**

ប្រតិបត្តិការដែលស្ថិតនៅក្រោមបទបញ្ជានេះត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងបទបញ្ជាផ្សេងទៀតរបស់ធនាគារជាតិនៃកម្ពុជាដែលបានផ្សព្វផ្សាយឱ្យអនុវត្តនូវគ្រប់ករណី។

ប្រការ ២៣.- **លក្ខខណ្ឌភាពអាសន្ន (Emergency Condition)**

ការដឹកនាំប្រតិបត្តិការជាត់ទាត់ប្រចាំថ្ងៃអាចត្រូវពន្យារពេលពេញមួយថ្ងៃធ្វើការ ឬអាចត្រូវលើកទៅថ្ងៃបន្ទាប់ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបានដោយសារតែមានភាពអាសន្នដូចជា អាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ ការចលាចលធំៗក្នុងទីក្រុង ឬក្នុងប្រទេស។ ក្នុងកាល:ទេស:នេះ ធនាគារជាតិនៃកម្ពុជា នឹងផ្តល់ការណែនាំជាក់លាក់ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសម្រាប់អនុវត្តក្នុងការជាត់ទាត់ ឬត្រូវបង្វិលវិញ។ ទោះយ៉ាងណាក្តី សមាជិកនីមួយៗគួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួនចំពោះការរំខាន និងត្រូវទទួលខុសត្រូវក្នុងការរក្សាគម្រោងការនិងទីកន្លែងដំណើរការដោយមានសម្ភារ:បរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសម្រាប់រយ:ពេលបន្ទាន់ៗ។

ប្រការ ២៤.- **អំពីស្ថិតិ (Statistics)**

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រង និងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានបត្រដែលបានជាត់ទាត់ប្រចាំថ្ងៃពេញមួយខែដោយបញ្ចូលព័ត៌មានស្តីពីមូលប្បទានបត្របង្វិលវិញ (មូលប្បទានបត្រមិនទូទាត់)។ លំដាប់លំដោយនៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសម្រាប់ឆ្នាំនេះ និងឆ្នាំមុន។ ព័ត៌មានស្តីពីការជាត់ទាត់របស់ធនាគារសមាជិកនីមួយៗមិនត្រូវបានផ្សព្វផ្សាយជាសាធារណ:ទេលើកលែងតែចំពោះធនាគារសាមី។

ប្រការ ២៥.-

រាល់លិខិតបទដ្ឋានទាំងឡាយដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៦.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទ ធនាគារជាតិនៃកម្ពុជា និងធនាគារជាសមាជិកសភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ ២៧.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ ១-ក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចូលជាសមាជិកសភាជាត់ទាត់

ឈ្មោះអ្នកសុំ:.....

ហាន:.....

អាសយដ្ឋាន:.....

អាសយដ្ឋានប្រៃសណីយ៍:.....

ទូរសព្ទ:.....

ជូនចំពោះលោកប្រធានសភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

ក្រោយពីបានស្វែងយល់ប្រកាសស្តីពីសភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....និងដើម្បីសម្រួលដល់ការប្រើប្រាស់មូលប្បទានបត្ររវាងធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ។

យើងខ្ញុំសុំស្នើលោកប្រធានសភាជាត់ទាត់មេត្តាពិនិត្យ និងសម្រេចឱ្យធនាគារយើងខ្ញុំបានចូលជាសមាជិកនៃសភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកដោយអនុគ្រោះ។

សូមជូនភ្ជាប់ជាមួយនូវ៖

- ច្បាប់ថតចម្លងនៃអាជ្ញាបណ្ណធ្វើអាជីវកម្មធនាគារ ១ ច្បាប់
- លិខិតឧទ្ទេសនាមនិងគំរូហត្ថលេខា ៣ ច្បាប់

យើងខ្ញុំសន្យាថានឹងគោរពអនុវត្តន៍នូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០០

ហត្ថលេខា

ឧបសម្ព័ន្ធ ១-ខ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារ.....

សូមឧទ្ទេសនាមនូវឈ្មោះនិងគំរូហត្ថលេខារបស់លោក-លោកស្រីក្នុងធនាគារយើងខ្ញុំដែលមានសិទ្ធិចុះហត្ថលេខាជាផ្លូវការលើលិខិតយុត្តិការ និងសំបុត្រស្នាមជាត់ទាត់របស់ធនាគារយើងខ្ញុំនៅធនាគារជាតិនៃកម្ពុជា ដើម្បីបម្រើការងារជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ។

ក/-<u>គណៈកម្មាធិការសភាជាត់ទាត់</u>៖

នាយកធនាគារ ឈ្មោះ.....		
តំណាងទទួលសិទ្ធិ ហាន:..... ឈ្មោះ.....		

ខ/-<u>តំណាងចូលរួមគ្រាជាត់ទាត់</u> (រត្តមានចាំបាច់ ១រូប)

តំណាង ហាន:..... ឈ្មោះ.....		
តំណាងទទួលសិទ្ធិ ហាន:..... ឈ្មោះ.....		

ពេលដែលលោក-លោកស្រីខាងលើមានការផ្លាស់ប្តូរភារកិច្ច យើងខ្ញុំនឹងឧទ្ទេសនាមនិងគំរូហត្ថលេខាជាថ្មីឡើងវិញ។

គំរូហត្ថលេខានេះមានប្រសិទ្ធភាពប្រើប្រាស់ចាប់

ពីថ្ងៃទី.....ដល់.....

ភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០០

ភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០០

ហត្ថលេខា

ប្រធានសភាជាត់ទាត់

ឧបសម្ព័ន្ធ ២ [9]

បញ្ជីរាយនាមសមាជិកសភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក

លេខរៀង	ឈ្មោះធនាគារ	អក្សរសម្គាល់	លេខអត្តសញ្ញាណ
១			
២			
៣			
៤			
៥			
៦			
៧			
៨			
៩			
១០			
១១			
១២			
១៣			
១៤			
១៥			
១៦			
១៧			
១៨			
១៩			
២០			

[9] បញ្ជីរាយនាមសមាជិកនេះនឹងត្រូវបានកត់ត្រាតែធនាគារដែលធនាគារជាតិនៃកម្ពុជាបានយល់ព្រមឱ្យចូលជាសមាជិកសភាជាត់ទាត់។

ឧបសម្ព័ន្ធ ៣

មូលហេតុដែលបានព្រមព្រៀងសម្រាប់ការបង្វិលវិញនូវមូលប្បទានបត្រ

១- សំវិធានវត្ថុគ្មានឬមិនគ្រប់គ្រាន់

២- សំវិធានវត្ថុមិនទាន់បានជម្រះ

៣- បញ្ឈប់ការទូទាត់

៤- បុរេបរិច្ឆេទនិងកាលបរិច្ឆេទមិនត្រឹមត្រូវ

៥- ហួសកាលបរិច្ឆេទ (លើសពី ៦ ខែ)

៦- ចំនួនជាអក្សរនិងជាលេខខុសគ្នា

៧- ខ្វះចំនួនទឹកប្រាក់ជាអក្សរ

៨- ហត្ថលេខារបស់បហារ័កខុសពីគំរូហត្ថលេខា

៩- ខ្វះហត្ថលេខារបស់បហារ័ក

១០- ខ្វះហត្ថលេខារបស់បហារ័កចំពោះការផ្លាស់ប្តូរ

១១- មិនចេញផ្សាយតាមគំរូធនាគារ

១២- មូលប្បទានបត្រខ្វេចខ្វី

១៣- គណនីត្រូវបានបិទ

១៤- គ្មានគណនី

១៥- បហារ័កទទួលមរណភាព

១៦- បហារ័កធនក្ស័យត្រូវជម្រះបញ្ជី

១៧- ខ្វះត្រារបស់បហារ័ក (ក្នុងករណីដែលមានចែងក្នុងគំរូហត្ថលេខា)

១៨- គណនីឃាត់ទុក

<u>ឧបសម្ព័ន្ធ ៥</u> គំរូ PPC001៖ កត់ត្រាមូលប្បទានបត្ររបស់ធនាគារនីមួយៗប្រគល់ឱ្យសភាជាត់ទាត់

សភាជាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

មូលប្បទានបត្រប្រគល់ដោយធនាគារ.....ចំពោះធនាគារ.....
ថ្ងៃទី.....

	មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជាដុល្លារ		មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជាដុល្លារ
1			35		
2			36		
3			37		
4			38		
5			39		
6			40		
7			41		
8			42		
9			43		
10			44		
11			45		
12			46		
13			47		
14			48		
15			49		
16			50		
17			51		
18			52		
19			53		
20			54		
21			បូកសរុបមូលប្បទានបត្រថ្មី		
22					
23			មូលប្បទានបត្របង្វិលវិញ		
24					
25				មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជាដុល្លារ
26					
27			1		
28			2		
29			3		
30			4		
31			5		
32			6		
33			7		
34			8		
	សរុប		សរុបមូលប្បទានបត្របង្វិលវិញ		
		សរុបមូលប្បទានបត្រថ្មី និងមូលប្បទានបត្របង្វិលវិញ			

សម្រាប់ប្រើប្រាស់ក្នុងសភាជាត់ទាត់

ហត្ថលេខា.....

សតាងាត់ធាត់មូលប្បធានបត្រចារឹកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

សម្រង់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកមិនអាចទូទាត់បាន

មូលប្បទានបត្រនៃគ្រាជាត់ទាត់ ថ្ងៃទី.....

ពីធនាគារ.....

ចំពោះធនាគារ.....

សម្រាប់គ្រាជាត់ទាត់ថ្ងៃទី.....

លេខរៀង	មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក
	សរុប៖	

មូលប្បទានបត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPC001នៃគ្រាជាត់ទាត់ថ្ងៃទី.....

សម្រាប់មូលប្បទានបត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ។

ហត្ថលេខា "ធនាគារប្រគល់".....

ហត្ថលេខា "ធនាគារទទួល".....

គំរូ PPC002៖ កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានបត្របានប្រគល់ឱ្យសភាជាត់ទាត់

សភាជាត់ទាត់មូលប្បទានបត្រថាវីកជាដុល្លារអាមេរិកទីក្រុងភ្នំពេញ

មូលប្បទានបត្រប្រគល់ដោយ..... "ឈ្មោះធនាគារ" ឥណពន្ធគណនី៖.....

នៅ..... "ម៉ោង" នាគ្រាជាត់ទាត់..... "កាលបរិច្ឆេទ" ឥណទានគណនី៖.....

ល.រ	លេខសម្គាល់ធនាគារ	ធនាគារ	មូលប្បទានបត្រប្រគល់ "សំរិធានវត្ថុត្រូវទទួល"	ចំនួន	មូលប្បទានបត្រទទួល "សំរិធានវត្ថុត្រូវសងធនាគារដទៃ"	ចំនួន
1						
2						
3						
4						
5						
6						
7						
8						
9						
10						
11						
12						
13						
14						
15						
16						
		សរុប៖				

ហត្ថលេខា..... "ធនាគារប្រគល់ឬទទួល"

ហត្ថលេខា....."ធនាគារជាតិនៃកម្ពុជា"

គំរូ PPC003៖ កត់ត្រានូវលទ្ធផលផាត់ទាត់សរុបតាមធនាគារនីមួយៗ

សតាផាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិកធីក្រុងភ្នំពេញ

នៅ..... "ម៉ោង" នាគ្រាផាត់ទាត់..... "កាលបរិច្ឆេទ"

ល.រ	លេខសម្គាល់ធនាគារ	ធនាគារ	"សំរិធានវត្ថុត្រូវសងធនាគារដទៃ"	ចំនួន	"សំរិធានវត្ថុត្រូវទទួលពីធនាគារដទៃ"	ចំនួន
1						
2						
3						
4						
5						
6						
7						
8						
9						
10						
11						
12						
13						
14						
15						
16						
		សរុប៖				

ហត្ថលេខា..... "ធនាគារជាតិនៃកម្ពុជា"

ធ៥-០០-១៧០ ប្រ.ក

ប្រកាស
ស្តីពី
សភាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ដាក់ចេញនូវបទបញ្ជាសភាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ដែលកំណត់អំពីលក្ខខណ្ឌទាំងឡាយ សម្រាប់អនុវត្តចំពោះការងារទូទាត់ប្រចាំថ្ងៃ នូវមូលប្បទានបត្រក្នុងចំណោមសមាជិកសភាជាត់ទាត់លើគណនីប្រាក់បញ្ញើរបស់ខ្លួន ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម។

ប្រការ ២.- **អំពីសមាជិកភាព**

១- ធនាគារដែលមានបំណងចូលជាសមាជិកសភាជាត់ទាត់ ត្រូវដាក់ពាក្យស្នើសុំតាមគំរូក្នុងឧបសម្ព័ន្ធ ១។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធនាគារសាមីនឹងត្រូវបានធនាគារជាតិនៃកម្ពុជា បញ្ចូលជាសមាជិកនៅថ្ងៃធ្វើការទីមួយនៃខែបន្ទាប់។ សមាជិកនៃសភាជាត់ទាត់ ត្រូវបានរាយឈ្មោះក្នុងបញ្ជីរាយនាម ដូចមានក្នុងឧបសម្ព័ន្ធ ២។

២- ធនាគារដែលមិនមែនជាសមាជិក ត្រូវបានអនុញ្ញាតឱ្យមានតំណាងក្នុងសភាជាត់ទាត់ជំនួសខ្លួនដោយធនាគារជាសមាជិក ចំពោះសំណូមពរជាត់ទាត់ និងទូទាត់មូលប្បទានបត្រ។ ការសុំឱ្យមានតំណាងនេះ ត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយធនាគារជាតិនៃកម្ពុជា ជាមុន។

ប្រការ ៣.- **លក្ខណៈសម្បត្តិជាសមាជិក**

១- ធនាគារដែលធនាគារជាតិនៃកម្ពុជាចេញអាជ្ញាបណ្ណឱ្យប្រកបអាជីវកម្មអាចសុំចូលជាសមាជិក។ បែបបទនៃការស្នើសុំរួមមាន៖

- ពាក្យសុំចូលជាសមាជិកដែលមានចុះហត្ថលេខានាយកធនាគារ ឬអ្នកដែលទទួលសិទ្ធិប្រទាន
- ច្បាប់ថតចម្លងនៃអាជ្ញាបណ្ណដែលចេញដោយធនាគារជាតិនៃកម្ពុជា
- លិខិតឧទ្ទេសនាម និង គំរូហត្ថលេខា។

លើសពីនេះទៀត ធនាគារជាសមាជិកត្រូវ៖

- មានគណនីចរន្តជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា
- បង់សោហ៊ុយសេវា តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

២- ធនាគារជាសមាជិក ត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញ។

ប្រការ ៤.- ការបាត់បង់សមាជិកភាព

១- ធនាគារដែលត្រូវបានធនាគារជាតិនៃកម្ពុជាដកហូតអាជ្ញាបណ្ណ ពុំអាចចូលរួមក្នុងសភាជាត់ទាត់បានទេ។

២- ធនាគារ អាចដកខ្លួនចេញដោយស្ម័គ្រចិត្តពីសភាជាត់ទាត់ ឱ្យតែធនាគារនោះបានធ្វើការសម្របសម្រួលត្រឹមត្រូវជាមួយនឹងធនាគារមួយទៀតជាសមាជិក ឱ្យកាន់កាប់មូលប្បទានបត្រដើម្បីជាត់ទាត់ជំនួសខ្លួន ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា ជាមុន។

ប្រការ ៥.- ធនាគារទូទាត់

ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំថ្ងៃ អំពីទឹកប្រាក់សរុបនៃមូលប្បទានបត្រ ដែលសភាជាត់ទាត់បានបញ្ជូនទៅ និងទទួលយក និងគណនាទឹកប្រាក់សុទ្ធ ដែលត្រូវចុះឥណពន្ធ ឬ ចុះឥណទាន គណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ។

ប្រការ ៦.- អំពីការគ្រប់គ្រង

១- ធនាគារជាតិនៃកម្ពុជា ត្រូវជ្រើសតាំងប្រធានសភាជាត់ទាត់ ដែលទទួលបន្ទុកប្រតិបត្តិការសភាជាត់ទាត់។ ប្រធានអាចប្រគល់ភារកិច្ចត្រួតពិនិត្យ និងតាមដានមុខងារប្រចាំថ្ងៃទៅឱ្យអ្នកដឹកនាំជាត់ទាត់។ ប្រធានសភាជាត់ទាត់ និងអ្នកដឹកនាំជាត់ទាត់ត្រូវតែជាមន្ត្រីធនាគារជាតិនៃកម្ពុជា។

២- ករណីកើតមានវិវាទរវាងតំណាងរបស់ធនាគារសមាជិក ក្នុងពេលប្រគល់ ឬទទួលការទទួលការទូទាត់ ឬពាក់ព័ន្ធជាមួយទឹកប្រាក់ត្រូវទូទាត់ ការសម្រេចរបស់អ្នកដឹកនាំជាត់ទាត់ អាចត្រូវទទួលយកជាបណ្តោះអាសន្នដោយមានទិដ្ឋាការរបស់ប្រធានសភាជាត់ទាត់។ ក្នុងករណីនៅបន្តមានការជំទាស់ក្រោយការសម្រេច ការដោះស្រាយត្រូវធ្វើដោយផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

ប្រការ ៧.- គណៈកម្មាធិការប្រតិបត្តិការ

១- ការងារសភាជាត់ទាត់អាចត្រូវបន្ថែមដោយគណៈកម្មាធិការប្រតិបត្តិការដែលរួមមានតំណាងមួយរូបរបស់ធនាគារសមាជិកនីមួយៗ និងដឹកនាំដោយប្រធានមួយរូបជ្រើសរើសដោយសមាជិក។ ប្រធានត្រូវបម្រើការរយៈពេលមួយឆ្នាំ។ អ្នកដឹកនាំបន្ទាប់នឹងត្រូវតែងតាំង និងបោះឆ្នោតជ្រើសរើសដោយសមាជិកសភាជាត់ទាត់។

២- គណៈកម្មាធិការប្រតិបត្តិការ មានមុខងារដូចតទៅ៖

- ពិគ្រោះផ្តល់យោបល់ដើម្បីលើកកម្ពស់គុណភាពប្រតិបត្តិការជាត់ទាត់
- ពង្រឹងសណ្តាប់ធ្នាប់ និងវិន័យរបស់តំណាងសមាជិក
- អនុវត្តឱ្យបានប្រសើរឡើងនូវភារកិច្ចដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយគណៈកម្មាធិការ។

៣- គណៈកម្មាធិការប្រតិបត្តិការត្រូវជួបប្រជុំយ៉ាងហោចណាស់៤ដងក្នុងមួយឆ្នាំ។ ការប្រជុំបន្ថែម អាចធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ឬនៅពេលមានសំណូមពរជាលាយលក្ខណ៍អក្សររបស់សមាជិកពីរូបយ៉ាងតិចដោយមានបញ្ជាក់ច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា។

ប្រការ ៨.- ការកែប្រែបទបញ្ជា

ខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជាជាត់ទាត់អាចនឹងត្រូវកែប្រែពីពេលមួយទៅពេលមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានការព្រមព្រៀងជាមួយគណៈកម្មាធិការប្រតិបត្តិការ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាអាចពង្រីកប្រតិបត្តិការជាត់ទាត់ទៅខេត្ត-ក្រុងដទៃទូទាំងប្រទេស បន្ថែមសេវាផ្សេងៗទៀតបើយល់ថាចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូទាត់។

ជំពូកទី ២
និយមន័យនៃពាក្យបច្ចេកទេស

ប្រការ ៩.-

ពាក្យបច្ចេកទេសដែលបានប្រើក្នុងបទបញ្ជាមាននិយមន័យដូចតទៅនេះ៖

១- ថ្ងៃធ្វើការ (Business day) គឺពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ឬ ថ្ងៃបន្ថែមណាមួយដែលធនាគារជាតិនៃកម្ពុជាបានកំណត់បើកធ្វើការ។ ថ្ងៃធ្វើការមិនរាប់បញ្ចូលថ្ងៃឈប់សម្រាកជាសាធារណៈទេ។

២- សភាជាត់ទាត់ (Clearing House) គឺជាមណ្ឌលសម្រួលការជាត់ទាត់ ដែលធ្វើឡើងដោយ ធនាគារជាតិនៃកម្ពុជា នៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅភ្នំពេញ។

៣- ឧបករណ៍ទូទាត់ (Payment or Item) គឺជាមូលប្បទានបត្រចេញផ្សាយលើគណនីចរន្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ មូលប្បទានបត្រគឺជាបញ្ជារបស់ម្ចាស់គណនីនៅធនាគារមួយឱ្យទូទាត់ប្រាក់ពីគណនីនោះទៅឱ្យអត្ថគាហក។

៤- ឧបករណ៍បង្វិលវិញ ឬ មិនទូទាត់ (Returned or unpaid item) គឺជាមូលប្បទានបត្រដែលមិនអាចទូទាត់ដោយសមាជិកទទួល ដោយមូលហេតុទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ ៣។

៥- ឧបករណ៍ដែលអាចទទួលយកបាន (Eligible items) នៅសភាជាត់ទាត់រួមមាន៖

ក- មូលប្បទានបត្ររបស់ធនាគារ ដែលបានចេញផ្សាយដោយតតិយជន ត្រូវសងទៅឱ្យតតិយជននៅទីស្នាក់ការធនាគារប្រតិស្រុតិនៅភ្នំពេញ

ខ- មូលប្បទានបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

គ- ឧបករណ៍ឥណពន្ធខ្លះទៀតដែលធនាគារជាតិនៃកម្ពុជា កំណត់ថាអាចទទួលយកបាន។ មូលប្បទានបត្រត្រូវបានចេញផ្សាយតាមទ្រង់ទ្រាយអនុញ្ញាត ដែលបានផ្តល់ដោយធនាគារ មានលំនាំស្តង់ដារដូចដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ មូលប្បទានបត្រអាចត្រូវចេញផ្សាយជាភាសាខ្មែរ អង់គ្លេស ឬ បារាំង។

៦- សមាជិក (Participant) គឺជាធនាគារដែលបានយល់ព្រមចូលរួមក្នុងសភាជាត់ទាត់ក្រោមខ្លឹមសារ និងលក្ខខណ្ឌនៃបទបញ្ជានេះ។

៧- ការចូលរួម (Participation) គឺជាវត្តមានក្នុងគ្រាជាត់ទាត់ប្រចាំថ្ងៃរបស់សភាជាត់ទាត់។ សមាជិកត្រូវចូលរួមរាល់គ្រាជាត់ទាត់ ទោះបីមាន ឬគ្មានមូលប្បទានបត្រដើម្បីបញ្ជូនទៅសមាជិកដទៃក្តី។

៨- សមាជិកទទួល (Receiving Participant) គឺជាសមាជិកដែលទទួលការទូទាត់ជាមូលប្បទានបត្រតាមរយៈសភាជាត់ទាត់។ សមាជិកនេះក៏អាចហៅផងដែរថាជាធនាគារចំណាយសង (Paying Bank)។

៩- សមាជិកប្រគល់ (Sending Participant) គឺជាសមាជិកដែលប្រគល់មូលប្បទានបត្រសម្រាប់ការទូទាត់តាមរយៈសភាជាត់ទាត់។

១០- កិច្ចបញ្ជិកា (Books) គឺជាការកត់ត្រាគណនេយ្យលើគណនីអតិថិជន ដែលបើកនៅធនាគារ និងគណនីចរន្តរបស់ធនាគារ ដែលបើកនៅធនាគារជាតិនៃកម្ពុជា។

១១- ការកត់ត្រា (Posting) គឺជាការចុះឥណពន្ធគណនីអតិថិជនសម្រាប់មូលប្បទានបត្រដោយធនាគារទទួល។

១២- ការទូទាត់ (Settlement) គឺជាលេខនានៃឥណពន្ធសុទ្ធ ឬឥណទានសុទ្ធក្នុងគណនីជាត់ទាត់ របស់ធនាគារជាសមាជិក សម្រាប់ការជាត់ទាត់ប្រចាំថ្ងៃ។ ការទូទាត់ទាំងអស់ត្រូវបានធ្វើជាបណ្តោះអាសន្ន និងអាចត្រូវដកហូតមកវិញចំពោះការទូទាត់ណាដែលត្រូវបដិសេធដោយសមាជិកទទួល ហើយបង្វិលវិញដូចដែលបានចែងក្នុងបទបញ្ជា។

១៣- លេខអត្តសញ្ញាណ (Routing number) គឺជាលេខសម្គាល់របស់សមាជិក ដូចដែលបានរាយក្នុងសៀវភៅរាយឈ្មោះរបស់ធនាគារដែលកាន់កាប់ដោយធនាគារជាតិនៃកម្ពុជា។ លេខអត្តសញ្ញាណត្រូវបានប្រើដើម្បីជ្រើសរើសនូវការទូទាត់ក្នុងចំណោមសមាជិកនៃសភាជាត់ទាត់ និងត្រូវបោះពុម្ពត្រង់កន្លែងសមស្របលើមូលប្បទានបត្រដោយអនុលោមតាមគំរូរបស់ធនាគារជាតិនៃកម្ពុជា។

១៤- គ្រាជាត់ទាត់ (Session) គឺជាការប្រជុំរបស់សមាជិកសភាជាត់ទាត់ដើម្បីប្តូរមូលប្បទានបត្រទៅវិញទៅមក។ គ្រាជាត់ទាត់សំខាន់នឹងប្រព្រឹត្តទៅនៅម៉ោង ១០:០០ ព្រឹក ហើយគ្រាជាត់ទាត់បន្ទាប់បន្សំសម្រាប់បង្វិលវិញនូវមូលប្បទានបត្រប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល។ ប៉ុន្តែ ប្រធានអាចសម្រេចយកគ្រាជាត់ទាត់បន្ថែមក្នុងថ្ងៃណាមួយ ប្រសិនបើយល់ថាចាំបាច់។

១៥- គណនីជាត់ទាត់ (Clearing Account) គឺជាគណនីដែលបើកដោយសមាជិកនីមួយៗ នៅធនាគារជាតិនៃកម្ពុជា សម្រាប់ទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាជាត់ទាត់។ គណនីនេះត្រូវបានប្រើសម្រាប់ទូទាត់កាតព្វកិច្ចរបស់សភាជាត់ទាត់។

ជំពូកទី ៣
ការទទួលខុសត្រូវរបស់ធនាគារប្រគល់

ប្រការ ១០.-

ធនាគារទាំងឡាយត្រូវប្រើប្រាស់សភាជាត់ទាត់ ដើម្បីប្រគល់មូលប្បទានបត្រទៅឱ្យសមាជិកដទៃ។ ការប្រគល់មូលប្បទានបត្រទ្វេភាគី ក្រៅពីគ្រាប្រជុំនៃសភាជាត់ទាត់ ត្រូវបានអនុញ្ញាតតែលើការព្រមព្រៀងទៅវិញទៅមក ពិសេសរវាងសមាជិកសភាជាត់ទាត់ផ្ទាល់។

ប្រការ ១១.-

សមាជិកប្រគល់ត្រូវ៖

១- អនុញ្ញាត និងកំណត់អត្តសញ្ញាណនៃការប្រគល់

មូលប្បទានបត្រទាំងអស់ត្រូវបោះត្រារបស់សមាជិកប្រគល់ និងកាលបរិច្ឆេទនៃការបញ្ជូននៅខាងខ្នងនៃមូលប្បទានបត្រនីមួយៗ។

២- រៀបចំការប្រគល់ឱ្យបានត្រឹមត្រូវ

សមាជិកប្រគល់ម្នាក់ៗ ត្រូវរៀបចំតារាងនៃមូលប្បទានបត្រជាពីរច្បាប់ គំរូ PPC001 បង្ហាញនូវទឹកប្រាក់នៃមូលប្បទានបត្រនីមួយៗ និងតម្លៃសរុបនៃមូលប្បទានបត្រដែលត្រូវដកប្រាក់ (Draw on) ពីសមាជិកដទៃ។ ឧទាហរណ៍នៃគំរូទាំងអស់បង្ហាញក្នុងឧបសម្ព័ន្ធ ៤។ តារាងគំរូ PPC001 ត្រូវបានរៀបចំសម្រាប់សមាជិកនីមួយៗ ដោយបង្ហាញនូវ៖

ក- ទឹកប្រាក់សុរប និងចំនួននៃមូលប្បទានបត្រចេញផ្សាយនៅបណ្តាទីស្នាក់ការភ្នំពេញ ដែលបានបង្ហាញដល់សមាជិកទាំងនោះ និង

ខ- មូលប្បទានបត្រមិនទូទាត់ បង្វិលវិញ និងមិនអាចទទួលយកបាន។

សមាជិកប្រគល់ម្នាក់ៗ ត្រូវប្រគល់ថាសកុំព្យូទ័រមួយដែលមានផ្ទុកនូវតារាងនៃគំរូ PPC001។

៣- ចូលរួមទៀងទាត់ក្នុងគ្រាជាត់ទាត់

មូលប្បទានបត្រត្រូវបានយកទៅសភាជាត់ទាត់នៅម៉ោងកំណត់ ឬមុនម៉ោងកំណត់នៃថ្ងៃធ្វើការនីមួយៗ សមាជិកដែលតំណាងរបស់ខ្លួនមកដល់យឺតក្រោយពេលកំណត់គ្រាជាត់ទាត់លើសពី៥នាទី អាចត្រូវផ្អាកមិនឱ្យចូលរួមគ្រាជាត់ទាត់នោះ ដោយអ្នកដឹកនាំជាត់ទាត់។ សមាជិក ដែលត្រូវផ្អាកមិនឱ្យចូលរួមក្នុងគ្រាជាត់ទាត់ មិនអាចប្រគល់មូលប្បទានបត្រទៅសមាជិកដទៃឡើយ។ ប៉ុន្តែ សមាជិកនោះត្រូវទទួលយក ហើយគណនីរបស់ខ្លួនត្រូវបានចុះឥណពន្ធនូវមូលប្បទានបត្រដែលសមាជិកដទៃប្រគល់ឱ្យខ្លួន។

៤- អនុញ្ញាតឱ្យចុះឥណពន្ធគណនីចំពោះមូលប្បទានបត្របង្វិលវិញ

ក្នុងករណីមានការបង្វិលវិញនៃមូលប្បទានបត្រដែលបានបដិសេធដោយសមាជិកទទួល សមាជិកប្រគល់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធគណនីចរន្តរបស់ខ្លួនវិញ។

៥- រក្សាទុកនូវការកត់ត្រា

សមាជិកប្រគល់ត្រូវរក្សាទុកនូវការកត់ត្រាពាក់ព័ន្ធទាំងអស់ដែលចាំបាច់ ដើម្បីបង្កើតឡើងវិញនូវការធ្វើ ឬការទូទាត់ដាច់ពីគ្នា សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទបង្ហាញដំបូង។ ប៉ុន្តែ នេះមិនបញ្ជាក់នូវកាតព្វកិច្ចដើម្បីស្រាវជ្រាវ ផ្តល់នូវការទាក់ទងអតិថិជន ឬដោះស្រាយនូវការទូទាត់យឺតជាងរយៈពេលនេះទេ។

ជំពូកទី ៤
ការទទួលខុសត្រូវរបស់ធនាគារទទួល

ប្រការ ១២.-

ធនាគារទទួល ត្រូវទទួលយកមូលប្បទានបត្រដែលបានប្រគល់ឱ្យខ្លួននៅសភាជាត់ទាត់រៀងរាល់ថ្ងៃដោយរួមបញ្ចូលទាំងមូលប្បទានបត្រមិនទូទាត់ដូចមានចែងក្នុងប្រការ ១១។ មូលប្បទានបត្រដែលត្រូវប្រគល់ឱ្យសមាជិកទទួល ក៏ប៉ុន្តែមិនបានទទួលយកដោយសារតែការមិនបានចូលរួមក្នុងគ្រាជាត់ទាត់ ឬត្រូវបានផ្អាកមិនឱ្យចូលរួម ដោយសារការមកដល់យឺតក្នុងថ្ងៃនោះ ត្រូវចាត់ទុកថាបានប្រគល់នៅថ្ងៃនោះ ដើម្បីសំណូមពរទូទាត់និងបង្វិលវិញទាន់ពេលនូវមូលប្បទានបត្រមិនទូទាត់។

ប្រការ ១៣.- សមាជិកទទួលត្រូវ៖

១- បញ្ជាក់នូវការយល់ព្រមទទួល (Certify Acceptance)

សមាជិកទទួល ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC001 ដើម្បីទទួលស្គាល់ការទទួលមូលប្បទានបត្រនៅសភាជាត់ទាត់។ សមាជិកទទួលនីមួយៗ ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងនៃតារាង PPC002 ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីទទួលស្គាល់នូវចំនួនទឹកប្រាក់ត្រូវចុះឥណពន្ធ ឬ ឥណទានក្នុងគណនីជាត់ទាត់របស់ខ្លួនជាលទ្ធផលនៃគ្រាជាត់ទាត់។

២- ទូទាត់សង ឬបង្វិលវិញនូវមូលប្បទានបត្រ (Settle for or return payment)

មូលប្បទានបត្រនៅតែជាកម្មសិទ្ធិរបស់សមាជិកប្រគល់រហូតដល់ត្រូវបានទូទាត់សង ឬត្រូវបានបង្វិលវិញ។ សមាជិកទទួលកាន់កាប់មូលប្បទានបត្រជាការផ្ញើទុក (In Trust) រហូតដល់គេបានទទួលឥណទានពីបហារ័ក (Drawer) នៃមូលប្បទានបត្រ ដោយចុះចូលគណនីរបស់អតិថិជនខ្លួន។ សមាជិកទទួលត្រូវមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីជាត់ទាត់របស់ខ្លួននៅធនាគារជាតិនៃកម្ពុជា ដើម្បីទូទាត់កាតព្វកិច្ចប្រចាំថ្ងៃ។

៣- បង្វិលវិញនូវមូលប្បទានបត្រមិនទូទាត់ (Return unpaid or dishonored payment)

ក- បទប្បញ្ញត្តិទូទៅ (General Provision)

មូលប្បទានបត្រមិនទូទាត់ ឬបដិសេធ ត្រូវបានបង្វិលមកវិញតាមរយៈសភាជាត់ទាត់។ សមាជិកទទួល ត្រូវបញ្ជាក់ឱ្យច្បាស់លើមូលប្បទានបត្របង្វិលវិញនូវមូលហេតុដែលបានព្រមព្រៀងដូចមានរាយក្នុងឧបសម្ព័ន្ធ ៣ និងឈ្មោះរបស់សមាជិកទទួល។

ខ- បង្វិលវិញឱ្យទាន់ពេល (Timely return)

មូលប្បទានបត្រដែលត្រូវបង្វិលវិញតាមរយៈសភាជាត់ទាត់ ត្រូវធ្វើការបង្វិលវិញឱ្យទាន់ពេល ហើយសមាជិកទទួលមិនត្រូវបានបង្ខំឱ្យទទួលខុសត្រូវចំពោះមូលប្បទានបត្រនោះទេ ប្រសិនបើមូលប្បទានបត្រនោះត្រូវបានបង្វិលវិញ មិនយឺតជាងម៉ោង ៣:០០ រសៀល នៃថ្ងៃជាត់ទាត់។ មូលប្បទានបត្រមិនត្រូវបានចាត់ទុកថា ទូទាត់បញ្ចប់ជាមួយនឹងការសងជម្រះ ជាសាច់ប្រាក់ទេរហូតដល់ក្រោយពេលបិទគ្រាបង្វិលវិញ ។

គ- ការទូទាត់សម្រាប់ការបង្វិលវិញ (Settlement for return)

សមាជិកទទួល ត្រូវបង្វិលវិញនូវមូលប្បទានបត្រមិនទូទាត់ដែលបានបញ្ជាក់ច្បាស់ថាមូលប្បទានបត្របង្វិលវិញ (Return item) តាមគំរូស្តង់ដារកំណត់។ ចំនួនទឹកប្រាក់ត្រូវបានដកចេញវិញពីក្នុងទឹកប្រាក់ទូទាត់សុទ្ធសម្រាប់សមាជិកទទួល (គំរូ PPC001) ។

ឃ- ការផុតកំណត់នៃសិទ្ធិបង្វិលវិញ (Expiration of return privilege)

មូលប្បទានបត្រអាចមិនទូទាត់ និងបង្វិលវិញបានតែពីរលើកប៉ុណ្ណោះ។ មូលប្បទានបត្រដែលនៅតែមិនទូទាត់បន្ទាប់ពីការបដិសេធ (Dishonor) លើកទីពីរ ត្រូវតែដកចេញពីបណ្តាញនៃសភាជាត់ទាត់ ដោយទុកឱ្យធ្វើបេឡានិច័យផ្ទាល់រវាងធនាគារដែលពាក់ព័ន្ធ។

៤- ការរក្សាទុកនូវការកត់ត្រា

សមាជិកទទួល ត្រូវរក្សានូវថាសកុំព្យូទ័រ ឬក្រដាសតារាង និងវត្ថុសំអាងជាក់ស្តែងផ្សេងទៀត ដែលចាំបាច់ដើម្បីបង្កើតឡើងវិញនូវការកត់ត្រាសម្រាប់ប្រតិបត្តិការរបស់សភាជាត់ទាត់ សម្រាប់រយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទទទួល។ សមាជិកទទួលមិនស្ថិតក្រោមកាតព្វកិច្ចទេ ប៉ុន្តែអាចជួយសមាជិកប្រគល់ក្នុងការដោះស្រាយតម្រូវការស្តីពីប្រតិបត្តិការ ដែលកើតមានឡើងបន្ទាប់ពីរយៈពេលរក្សាទុកនៃការកត់ត្រាចាំបាច់បានផុតកំណត់។

៥- ការបង្វិលវិញនៃមូលប្បទានបត្រមិនបានកត់ត្រាក្នុងករណីមានកំហុស

ក្នុងករណីសមាជិកមិនមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា សម្រាប់ការទូទាត់ប្រចាំថ្ងៃ និងត្រូវបាននាយកដ្ឋានត្រួតពិនិត្យធនាគារប្រកាសថាមានអសាធនភាព ធនាគារជាតិនៃកម្ពុជានឹងត្រូវជូនដំណឹងដល់សមាជិកដទៃ និងទាមទារឱ្យសមាជិកមិនបានទូទាត់នោះបង្វិលវិញជាបន្ទាន់នូវមូលប្បទានបត្រមិនបានកត់ត្រាក្នុងកម្មសិទ្ធិរបស់ខ្លួនទៅឱ្យធនាគារជាតិនៃកម្ពុជា។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជានឹងបង្វិលមូលប្បទានបត្រនោះទៅឱ្យសមាជិកដែលប្រគល់ពីដំបូងវិញ។

ជំពូកទី ៥
ការទទួលខុសត្រូវរបស់ធនាគារជាតិ នៃកម្ពុជា

ប្រការ ១៤.-

ធនាគារជាតិនៃកម្ពុជា គឺជាសមាជិកមួយនៃសភាជាត់ទាត់ ដែលអាចទទួល និងប្រគល់មូលប្បទានបត្រដូចគ្នានឹងសមាជិកដទៃសម្រាប់សងឱ្យគេឬទារយកពីគេ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាសម្រួលដល់គ្រាជាត់ទាត់ និងទូទាត់គណនីទាំងឡាយក្នុងបញ្ជីរបស់ខ្លួនដែលបានបើកឱ្យសមាជិកទាំងអស់។

ប្រការ ១៥.- ការរៀបចំគំរូ (Preparation of form)

អ្នកដឹកនាំជាត់ទាត់ត្រូវរៀបចំនូវគំរូ PPC002 និង PPC003 ដោយឧបករណ៍អេឡិកត្រូនិកដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ៤ ដោយបញ្ចូលក្នុងតារាងកិច្ចការកុំព្យូទ័ររបស់សមាជិក (គំរូ PPC001) ពីថាសដែលបានយកមកក្នុងគ្រាជាត់ទាត់។

ប្រការ ១៦.- ការទូទាត់ (Settlement)

១- ការទូទាត់នឹងត្រូវបានអនុវត្តចប់សព្វគ្រប់នៅថ្ងៃធ្វើការនីមួយៗ ដោយការចុះឥណពន្ធ និងចុះឥណទាន គណនីចរន្តរបស់សមាជិកដែលបើកនៅធនាគារជាតិនៃកម្ពុជា។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រប្រគល់ លើសចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រទទួល គណនីរបស់សមាជិកនឹងត្រូវចុះឥណទាន។ នៅពេលដែលចំនួនទឹកប្រាក់សរុបនៃមូលប្បទានបត្រទទួល លើសចំនួនទឹកប្រាក់នៃមូលប្បទានបត្រប្រគល់ គណនីរបស់សមាជិកនឹងត្រូវចុះឥណពន្ធ។ នៅពេលដែល

អ្នកដឹកនាំជាត់ទាត់ពិនិត្យឃើញថា គំរូទូទាត់របស់សភាជាត់ទាត់មានតុល្យភាព ហើយនោះ អ្នកដឹកនាំជាត់ទាត់ត្រូវចុះហត្ថលេខាលើច្បាប់ចម្លង ឬតារាងបោះពុម្ព ចេញនៃគំរូ PPC002 របស់សមាជិកនីមួយៗ ទុកជាប្រកាសឥណពន្ធ ឬឥណទាន ក្នុងគណនីចរន្តរបស់សមាជិកនោះ។ បន្ទាប់មកអ្នកដឹកនាំជាត់ទាត់ត្រូវប្រកាសថា គ្រាជាត់ទាត់ត្រូវបញ្ចប់។ សមាជិកណាក៏មិនអាចចាកចេញមុនពេលប្រកាសបញ្ចប់គ្រាជាត់ទាត់បានឡើយ។

២- ក្នុងករណីដែលសមាជិកទទួល មានមូលនិធិមិនគ្រប់គ្រាន់ក្នុងគណនីចរន្តដើម្បីទូទាត់ សមាជិកនោះមានរយៈពេល២ម៉ោងដើម្បីសម្របសម្រួលមូលនិធិពីធនាគារផ្សេងមួយទៀត ដើម្បីដាក់បញ្ចូលក្នុងគណនីចរន្តរបស់ខ្លួននៅធនាគារជាតិនៃកម្ពុជា។ នេះគឺជាប្រភពចម្បង និងរំពឹងបាននៃមូលនិធិសម្រាប់ការទូទាត់។

ប្រការ ១៧.- សមតុល្យដែលបានតម្កល់នៅធនាគារជាតិនៃកម្ពុជា (Balance maintained at NBC)

សមាជិកទាំងអស់ត្រូវអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា ចុះឥណពន្ធលើគណនីចរន្តរបស់ពួកគេ នូវចំនួនទឹកប្រាក់ដែលជាលទ្ធផលសុទ្ធនៃការជាត់ទាត់មូលប្បទានបត្រ និងត្រូវតម្កល់មូលនិធិក្នុងគណនីចរន្តទាំងនោះឱ្យមានគ្រប់គ្រាន់ដើម្បីចុះឥណពន្ធ។ ជាវិធានការប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធនាគារសមាជិកតម្កល់ឱ្យបានគ្រប់គ្រាន់នូវប្រាក់បញ្ញើជារូបិយបណ្ណក្នុងគណនីផ្សេងដើម្បីធានាក្នុងការចុះឥណពន្ធសុទ្ធធំបំផុតដែលកើតមានក្នុងត្រីមាសមុន។

ប្រការ ១៨.- ការទូទាត់មិនបាន (Failure to settle)

១- ប្រសិនបើសមាជិកមិនផ្តល់នូវការធានាចំពោះកាតព្វកិច្ចចុះឥណពន្ធរបស់ខ្លួនក្នុងសភាជាត់ទាត់ក្នុងរយៈពេលអនុញ្ញាត២ម៉ោងនោះទេ អ្នកដឹកនាំជាត់ទាត់នឹងជូនដំណឹងចំពោះប្រធានសភាជាត់ទាត់ដែលនឹងកំណត់នូវវិធានការកែលម្អ។ ប្រសិនបើធនាគារជាតិនៃកម្ពុជា បានប្រកាសថា សមាជិកនោះ "មានកំហុស (In Default)" ប្រធានសភាជាត់ទាត់នឹងជូនដំណឹងចំពោះសមាជិកដទៃទៀត។ គ្រាជាត់ទាត់មិនត្រូវបានប្រកាសបិទទេ លើកលែងតែគណនីទាំងអស់ត្រូវបានចុះឥណពន្ធជាស្តាពរនៅថ្ងៃជាត់ទាត់នោះ។

២- ក្នុងករណីកំហុសត្រូវបានប្រកាសក្នុងគ្រាជាត់ទាត់ ធនាគារជាតិនៃកម្ពុជាត្រូវធ្វើនិយ័តកម្ម (Unwind) នូវការទូទាត់ ពោលគឺចុះបញ្ច្រាសនូវឥណទានដែលបានផ្តល់ឱ្យធនាគារទទួល ចំពោះមូលប្បទានបត្ររបស់ខ្លួនដែលយកទៅឱ្យសភាជាត់ទាត់ និងចុះបញ្ច្រាសនូវឥណពន្ធចំពោះមូលប្បទានបត្រដែលបានយកដោយធនាគារដទៃ ហើយគណនាជាថ្មីនូវស្ថានភាពសុទ្ធរបស់សមាជិកទាំងអស់ស្របតាមនោះ។ អ្នកដឹកនាំជាត់ទាត់ត្រូវរៀបចំគំរូជាថ្មី ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពថ្មីរបស់សមាជិកទាំងអស់។ ធនាគារមានកំហុសនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការជាត់ទាត់ទៀតឡើយ។

ប្រការ ១៩.- ព្រំដែននៃការទទួលខុសត្រូវ (Limit of liability)

ធនាគារជាតិនៃកម្ពុជា មិនទទួលខុសត្រូវ និងមិនទទួលសងឡើយ ក្នុងករណីដែលសមាជិកមានការខាតបង់ក្នុងទំនាក់ទំនងជាមួយសមាជិកសភាផ្ទាត់ទាត់ លើកលែងក្នុងករណីនៃការធ្វេសប្រហែសនិងការដឹកនាំមិនត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាផ្ទាល់។ ការតវ៉ាទាំងអស់អំពីការបែងចែកមិនត្រឹមត្រូវ ការបង្វិលវិញមិនទាន់ពេល ការខកខានមិនបានបង្វិលវិញនូវមូលប្បទានបត្រ កំហុសរបស់សមាជិក។ល។ ត្រូវតែដោះស្រាយដោយផ្ទាល់រវាងអ្នកចូលរួមទាំងអស់ លើកលែងតែសមាជិកទាំងនោះយល់ព្រមប្រើប្រាស់បញ្ជីរបស់ធនាគារជាតិនៃកម្ពុជាដើម្បីកត់ត្រាប្រតិបត្តិការ។ ប៉ុន្តែធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវទៅនឹងខ្លឹមសារនិងលក្ខខណ្ឌនៃបទបញ្ជាសម្រាប់មូលប្បទានបត្ររបស់ខ្លួនផ្ទាល់ ដែលបានបញ្ចូលដើម្បីផ្ទាត់ទាត់ និងទូទាត់តាមរបៀបដូចគ្នានឹងសមាជិកដទៃទៀត។

ជំពូកទី ៦
បទប្បញ្ញត្តិផ្សេងៗ

ប្រការ ២០.- ច្បាប់សម្រាប់គ្រប់គ្រង (Governing Law)

ប្រតិបត្តិការដែលបិតនៅក្រោមបទបញ្ជានេះ ត្រូវតែអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ជាផ្សេងៗទៀតរបស់ធនាគារជាតិនៃកម្ពុជា ដែលបានផ្សព្វផ្សាយឱ្យអនុវត្តនូវគ្រប់ករណី។

ប្រការ ២១.- លក្ខខណ្ឌភាពអាសន្ន (Emergency Conditions)

ការដឹកនាំប្រតិបត្តិការផ្ទាត់ទាត់ប្រចាំថ្ងៃអាចត្រូវពន្យារពេលពេញមួយថ្ងៃធ្វើការ ឬអាចត្រូវលើកទៅថ្ងៃបន្ទាប់ ក្នុងករណីដែលសមាជិកមិនមានលទ្ធភាពអាចចូលរួមបានដោយសារតែមានភាពអាសន្ន ដូចជា អាកាសធាតុ ការដាច់ចរន្តអគ្គិសនី ទូរគមនាគមន៍ការចលាចលធំៗក្នុងទីក្រុង ឬក្នុងប្រទេស។ ក្នុងកាល:ទេស:នេះ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការណែនាំជាក់លាក់ ចំពោះសមាជិកទាំងអស់ទាក់ទងនឹងនីតិវិធីសម្រាប់អនុវត្តក្នុងការផ្ទាត់ទាត់ ឬត្រូវបង្វិលវិញ។ ទោះយ៉ាងណាក្តី សមាជិកនីមួយៗគួរដោះស្រាយតាមលទ្ធភាពរបស់ខ្លួនចំពោះការរំខាននោះ និងត្រូវទទួលខុសត្រូវក្នុងការរក្សាគម្រោងការ និងទីកន្លែងដំណើរការដោយមានសម្ភារ:បរិក្ខារចាំបាច់ដើម្បីបន្តប្រតិបត្តិការសម្រាប់រយ:ពេលបន្ទាប់ៗ។

ប្រការ ២២.- អំពីស្ថិតិ (Statistics)

ធនាគារជាតិនៃកម្ពុជាត្រូវចងក្រង និងផ្សព្វផ្សាយនូវស្ថិតិប្រចាំខែស្តីពីចំនួននិងទឹកប្រាក់នៃមូលប្បទានបត្រដែលបានផ្ទាត់ទាត់ប្រចាំថ្ងៃពេញមួយខែដោយបញ្ចូលព័ត៌មានស្តីពីមូលប្បទានបត្របង្វិលវិញ (មូលប្បទានបត្រមិនទូទាត់)។ លំដាប់លំដោយនៃស្ថិតិត្រូវប្រៀបធៀបមធ្យមប្រចាំខែសម្រាប់ឆ្នាំនេះ និងឆ្នាំមុន។ ព័ត៌មានស្តីពីការផ្ទាត់ទាត់របស់ធនាគារសមាជិកនីមួយៗ មិនត្រូវបានផ្សព្វផ្សាយជាសាធារណ:ទេ លើកលែងតែចំពោះធនាគារសាមី។

ប្រការ ២៣.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៤.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងធនាគារជាសមាជិកសភាជាត់ទាត់មូលប្បទានបត្រចារឹកជារៀល ត្រូវអនុវត្តន៍នូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ ២៥.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

<u>ឧបសម្ព័ន្ធ</u> ១-ក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចូលជាសមាជិកសភាជាត់ទាត់

ឈ្មោះអ្នកសុំ ៖ .....

ហាន: ៖ .....

អាសយដ្ឋាន ៖ .....

អាសយដ្ឋានប្រៃសណីយ៍ ៖.....

ទូរស័ព្ទ ៖.....

ជូនចំពោះ លោកប្រធានសភាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

ក្រោយពីបានស្វែងយល់ ប្រកាសស្តីពី សភាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....និងដើម្បីសម្រួលដល់ការប្រើប្រាស់មូលប្បទានបត្ររវាងធនាគារយើងខ្ញុំ និងធនាគារដទៃទៀតក្នុងទីក្រុងភ្នំពេញ

យើងខ្ញុំសុំស្នើលោកប្រធានសភាជាត់ទាត់ មេត្តាពិនិត្យនិងសម្រេចឱ្យធនាគារយើងខ្ញុំបានចូលជាសមាជិកនៃសភាជាត់ទាត់មូលប្បទានបត្រជាប្រាក់រៀល ដោយអនុគ្រោះ។

សូមជូនភ្ជាប់ជាមួយនូវ៖

- ច្បាប់ថតចម្លងនៃអាជ្ញាបណ្ណធ្វើអាជីវកម្មធនាគារ ១ច្បាប់
- លិខិតឧទ្ទេសនាម និងគំរូហត្ថលេខា ៣ច្បាប់

យើងខ្ញុំសន្យាថា នឹងគោរពអនុវត្តនូវខ្លឹមសារប្រកាសខាងលើដោយម៉ឺងម៉ាត់។

សូមលោកប្រធានទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ..... ខែ ..... ឆ្នាំ២០០

ហត្ថលេខា

<u>ឧបសម្ព័ន្ធ</u> ២

សញ្ញាតំណាងមូលប្បទានបត្រជារឹកជាប្រាក់រៀល

លេខរៀង	ឈ្មោះធនាគារ	អក្សរសម្គាល់	លេខអត្តសញ្ញាណ
១	ធនាគារជាតិនៃកម្ពុជា	NBC	
២	រតនាគារជាតិ	NTG	T001
៣	ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា	FTB	B001
៤	ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់	CCB	B003
៥	ធនាគារ កម្ពុជាសាធារណៈ ចំកាត់	CPB	B004
៦	ធនាគារ កាណាឌីយ៉ា	CNB	B005
៧	ធនាគារ ក្រុងថៃ	KTB	B009
៨	ធនាគារ កសិករថៃ	TFB	B012
៩	ធនាគារ ក្រេឌីតអាក្រ្តីកូលឥណ្ឌូស៊ុយអេស៍	CAI	B013
១០	ធនាគារ កម្ពុជាអាស៊ី	CAB	B016
១១	សាជីវកម្មធនាគារសឹង្ហបូរី	SBC	B018
១២	ធនាគារ មេយប៊ែង	MBB	B020
១៣	ធនាគារ សឹង្ហបូរីពាណិជ្ជ	SCB	B021
១៤	ធនាគារ ស្តាន់ដារឆាទើរ៉ែត	SCB1	B025
១៥	ធនាគារ សហាពាណិជ្ជ	UCB	B026
១៦	ធនាគារ ក្រៅប្រទេសទី១	FOB	B031

<u>ឧបសម្ព័ន្ធ ៣</u>

មូលហេតុដែលបានព្រមព្រៀងសម្រាប់ការបង្ខិលវិញ្ញត្តវមូលប្បទានបត្រ

១- សំរិធានវត្ថុគ្មាន ឬមិនគ្រប់គ្រាន់

២- សំរិធានវត្ថុមិនទាន់បានជម្រះ

៣- បញ្ឈប់ការទូទាត់

៤- បុរេបរិច្ឆេទ និងកាលបរិច្ឆេទមិនត្រឹមត្រូវ

៥- ហួសកាលបរិច្ឆេទ (លើសពី ៦ខែ)

៦- ចំនួនទឹកប្រាក់ជាអក្សរ និងជាលេខខុសគ្នា

៧- ខ្វះចំនួនទឹកប្រាក់ជាអក្សរ

៨- ហត្ថលេខារបស់បហារ័កខុសពីគំរូហត្ថលេខា

៩- ខ្វះហត្ថលេខារបស់បហារ័ក

១០- ខ្វះហត្ថលេខារបស់បហារ័កចំពោះការផ្លាស់ប្តូរ

១១- មិនចេញផ្សាយតាមគំរូធនាគារ

១២- មូលប្បទានបត្រខ្ទេចខ្ទី

១៣- គណនីត្រូវបានបិទ

១៤- គ្មានគណនី

១៥- បហារ័កទទួលមរណភាព

១៦- បហារ័កធនក្ស័យត្រូវជម្រះបញ្ជី

<u>ឧបសម្ព័ន្ធ ៤</u>

គំរូ PPC001 ៖ កត់ត្រាមូលប្បទានបត្ររបស់ធនាគារនីមួយៗប្រគល់ឱ្យសភាជាត់ទាត់

សភាជាត់ចាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

មូលប្បទានបត្រប្រគល់ដោយធនាគារ.....ចំពោះធនាគារ.....

ថ្ងៃទី .....

	មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជារៀល		មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជារៀល
1			35		
2			36		
3			37		
4			38		
5			39		
6			40		
7			41		
8			42		
9			43		
10			44		
11			45		
12			46		
13			47		
14			48		
15			49		
16			50		
17			51		
18			52		
19			53		
20			54		
21			បូកសរុបមូលប្បទានបត្រថ្មី		
22					
23			មូលប្បទានបត្របង្វិលវិញ		
24					
25				មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជារៀល
26					
27			1		
28			2		
29			3		
30			4		
31			5		
32			6		
33			7		
34			8		
	សរុប៖		សរុបមូលប្បទានបត្របង្វិលវិញ		
		សរុបមូលប្បទានបត្រថ្មីនិងមូលប្បទានបត្របង្វិលវិញ			

សម្រាប់ប្រើប្រាស់ក្នុងសភាជាត់ទាត់

ហត្ថលេខា.....

សតាងដាត់ចាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

សម្រង់មូលប្បទានបត្រចារឹកជារៀលមិនអាចទូទាត់បាន

មូលប្បទានបត្រនៃគ្រោងាត់ទាត់ ថ្ងៃទី.....

ពីធនាគារ .....

ចំពោះធនាគារ .....

សម្រាប់គ្រោងាត់ទាត់ថ្ងៃទី.....

លេខរៀង	មូលប្បទានបត្រលេខ	ចំនួនទឹកប្រាក់ជារៀល
សរុប៖		

មូលប្បទានបត្រទាំងនេះនឹងត្រូវបានរាយរាប់ក្នុងគំរូ PPC001 នៃគ្រោងាត់ទាត់ថ្ងៃទី.....
សម្រាប់មូលប្បទានបត្រមិនអាចទូទាត់ ត្រូវបង្វិលវិញ។

ហត្ថលេខា "ធនាគារប្រគល់" .....

ហត្ថលេខា "ធនាគារទទួល" .....

គំរូ PPC002 ៖ កត់ត្រាសង្ខេបតាមធនាគារនូវមូលប្បទានបត្របានប្រគល់ឱ្យសភាជាត់ទាត់

សភាជាត់ផាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

មូលប្បទានបត្រប្រគល់ដោយ ..... "ឈ្មោះធនាគារ" ឥណពន្ធគណនី៖ .....
នៅ ..... "ម៉ោង" នាគ្រាជាត់ទាត់..... "កាលបរិច្ឆេទ" ឥណទានគណនី៖.....

ល.រ	លេខសម្គាល់ធនាគារ	ធនាគារ	មូលប្បទានបត្រប្រគល់ "សំរិធានវត្ថុត្រូវទទួល"	ចំនួន	មូលប្បទានបត្រទទួល "សំរិធានវត្ថុត្រូវសងធនាគារដទៃ"	ចំនួន	ចំនួនទឹកប្រាក់	
							ត្រូវទទួល	ត្រូវសង
1								
2								
3								
4								
5								
6								
7								
8								
9								
10								
11								
12								
13								
14								
15								
16								
	សរុប៖							

ហត្ថលេខា ..... "ធនាគារប្រគល់ ឬទទួល"

ហត្ថលេខា ..... "ធនាគារជាតិនៃកម្ពុជា"

គំរូ PPC003 ៖ កត់ត្រានូវលទ្ធផលជាត់ទាត់សរុបតាមធនាគារនីមួយៗ

សតាជាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

នៅ ..... "ម៉ោង" នាគ្រាជាត់ទាត់ ..... "កាលបរិច្ឆេទ"

ល.រ	លេខសម្គាល់ធនាគារ	ធនាគារ	"សំរិធានវត្ថុត្រូវសងធនាគារដទៃ"	ចំនួន	"សំរិធានវត្ថុត្រូវទទួលពីធនាគារដទៃ"	ចំនួន	ចំនួនទឹកប្រាក់	
							ត្រូវទទួល	ត្រូវសង
1								
2								
3								
4								
5								
6								
7								
8								
9								
10								
11								
12								
13								
14								
15								
16								
	សរុប៖							

ហត្ថលេខា ..... "ធនាគារជាតិនៃកម្ពុជា"

ធ៩-០៨-១៨៦ ប្រ.ក

ប្រកាស
ស្តីពី
មូលប្បទានបត្រស្តង់ដារ

ប្រការ ១.-

កំណត់ឱ្យមានការឯកភាពជាលក្ខណៈស្តង់ដារនូវមូលប្បទានបត្រដែលប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ ដើម្បីឱ្យការទូទាត់និងជាត់ទាត់អន្តរធនាគារប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។

ប្រការ ២.-

គ្រឹះស្ថានធនាគារត្រូវរៀបចំ និងបោះពុម្ពមូលប្បទានបត្រសម្រាប់ប្រើប្រាស់ ឬផ្តល់ជូនអតិថិជនរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារមាត្រា ៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងឱ្យមានលក្ខណៈស្តង់ដារ ទាំងលេខកូដ ទំហំ និទ្ទេស ព្រមទាំងមានចារឹកតួលេខ និងសញ្ញាពិសេសដែលអាចអានបានដោយម៉ាស៊ីន ដូចមានចែងក្នុងសេចក្តីណែនាំស្តីពីលក្ខណៈស្តង់ដារនៃមូលប្បទានបត្រដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៣.-

ការប្រើប្រាស់មូលប្បទានបត្រស្តង់ដារនឹងចាប់ផ្តើមអនុវត្តក្រោយពីប្រកាសនេះចុះហត្ថលេខាហើយបានប្រាំមួយខែ (៦ខែ)។

ក្នុងរយៈពេល ៦ ខែបន្ទាប់ពីថ្ងៃចុះហត្ថលេខានៃប្រកាសនេះ គ្រឹះស្ថានធនាគារត្រូវរៀបចំបោះពុម្ពមូលប្បទានបត្រស្តង់ដារដូចមានចែងក្នុងប្រការ ២ ដើម្បីជំនួសមូលប្បទានបត្រដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។

ប្រការ ៤.-

ប្រកាសលេខ ធ៥-០១-៦៥ ប្រ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០១ ស្តីពី ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រថ្មី នឹងត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីថ្ងៃដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រស្តង់ដារតទៅ។

ប្រការ ៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ ដែលនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០៨-១៨៦ ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

សេចក្តីណែនាំ
ស្តីពី
លក្ខណៈស្តង់ដារនៃមូលប្បទានបត្រ

ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់គ្រឹះស្ថានធនាគារ អំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងព័ត៌មាន នៅលើមូលប្បទានបត្រឱ្យមានលក្ខណៈស្តង់ដារដូចខាងក្រោម៖

១- លក្ខណៈស្តង់ដារ

១.១. តម្រូវការខាងផ្នែកគតិយុត្ត

យោងតាមមាត្រាទី៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ មូលប្បទានបត្រ ដែលចេញផ្សាយអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬជាអក្សរបរទេស និងត្រូវមាន និទ្ទេសដូចខាងក្រោម៖

- ពាក្យថា **មូលប្បទានបត្រ** ដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ
- បញ្ជាដោយឥតលក្ខខណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ
- ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់
- កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់
- កាលបរិច្ឆេទ និងកន្លែងដែលមូលប្បទានបត្រត្រូវបានចេញ
- ហត្ថលេខារបស់បហារក ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានបត្រ

១.២. ទំហំមូលប្បទានបត្រ និងផ្នែសម្រាប់បន្ថែលេខកូដ

១.២.១. ទំហំមូលប្បទានបត្រ

ការតម្រូវឱ្យទំហំមូលប្បទានបត្រមានលក្ខណៈស្តង់ដារ គឺដើម្បីសម្រួលដល់ការចេញផ្សាយ ការប្រើប្រាស់ ការទទួល ដំណើរការទូទាត់ និងការរក្សាទុកមូលប្បទានបត្រជាលក្ខណៈរូបវន្ត។ ទំហំមូលប្បទានបត្រស្តង់ដារ (ដោយមិនគិតបញ្ចូលគល់សន្លឹក) ត្រូវបានកំណត់ឱ្យមានបណ្តោយប្រវែង ១៨០មម និងទទឹងប្រវែង ៩០មម។

១.២.២. សណ្ឋាននៃមូលប្បទានបត្រ

ផ្នែលាតសម្រាប់ធនាគារត្រូវស្ថិតនៅផ្នែកខាងក្រោមនៃមូលប្បទានបត្រ ដែលមានប្រវែង ១៦មមពីគែម ខាងក្រោម និងមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានបត្រ។ ផ្នែកខាងមុខ និងខាងក្រោយនៃផ្នែលាត ដែលត្រូវបានរក្សាទុកសម្រាប់ដាក់លេខកូដត្រូវមានសណ្ឋានដូចគ្នាបេះបិទ។ ផ្នែកខាងមុខនៃផ្នែលាតនេះត្រូវបានប្រើសម្រាប់ចុះព័ត៌មានលម្អិតរបស់មូលប្បទានបត្រ ដែលមានលក្ខណៈជាតួលេខ និងសញ្ញាពិសេសដោយប្រើពុម្ពអក្សរ E13B ដែលតម្រូវឱ្យចុះនៅលើ

បន្ទាត់លេខកូដ។ នៅលើផ្នែកខាងមុខ និងខាងក្រោយនៃផ្ទៃលាតមិនត្រូវមានសារធាតុគីមី ឬសញ្ញាអ្វីមួយដែលអាចធ្វើឱ្យរំខានដល់ការអានរបស់ម៉ាស៊ីនអានលេខកូដឡើយ។

រូបភាព១៖ ទីតាំងផ្ទៃលាតនៅលើផ្នែកខាងមុខនិងខាងក្រោយនៃមូលប្បទានបត្រ



១.៣. បន្ទាត់លេខកូដសម្រាប់ដំណើរការស្វ័យប្រវត្តិកម្ម

១.៣.១. ទីតាំងបោះពុម្ពបន្ទាត់លេខកូដ

បន្ទាត់លេខកូដត្រូវតែបោះពុម្ពតាមបណ្តោយផ្ទៃលាតលើផ្នែកខាងមុខនៃមូលប្បទានបត្រ។ ក្នុងករណី ដែលផ្នែកខាងមុខនេះមិនអាចប្រើដើម្បីបោះពុម្ពលេខកូដនេះបាន ដោយសារតែខូច ឬមានការសរសេរជាន់គ្នា ឬការជំនួសតួលេខ នោះបន្ទាត់លេខកូដត្រូវតែបោះពុម្ពនៅលើផ្ទៃលាតនៃផ្នែកខាងក្រោយរបស់មូលប្បទានបត្រ។

១.៣.២. ពុម្ពអក្សរលើបន្ទាត់លេខកូដ

បន្ទាត់លេខកូដនេះត្រូវតែបោះពុម្ពដោយប្រើពុម្ពអក្សរ E13B ដើម្បីសម្រួលឱ្យម៉ាស៊ីនអានលេខកូដ អាចអានតួលេខនិងសញ្ញាពិសេសបានលឿន និងត្រឹមត្រូវ។

១.៣.៣. ការការពារផ្ទៃលាតសម្រាប់ធនាគារ


នៅលើផ្នែកទាំងសងខាងនៃមូលប្បទានប្រ័តក្នុងផ្ទៃលាតសម្រាប់ធនាគារ មិនត្រូវមានការបោះពុម្ព ដោយទឹកខ្មៅផ្សេងៗ ឬការរំលេចពណ៌ណាមួយ ដែលអាចប៉ះពាល់ដល់ការអានដោយស្វ័យប្រវត្តិទៅលើតួលេខ និង សញ្ញាពិសេស ដូចជា ការបោះពុម្ពរូបបណ្តុះ ការបោះពុម្ពជុស ឬសញ្ញាណាផ្សេងៗទៀត ក្រៅពីពុម្ពអក្សរ E13B ឡើយ។

១.៣.៤. ទីតាំងសម្រាប់បន្ទាត់លេខកូដ

បន្ទាត់លេខកូដត្រូវមានកម្ពស់ ៣,១៧៥មម ហើយត្រូវស្ថិតនៅខាងក្នុងនិងចំកណ្តាលនៃផ្ទៃលាតសម្រាប់ធនាគារ ព្រមទាំងត្រូវបានខណ្ឌផ្នែកខាងលើ និងខាងក្រោមដោយចន្លោះលាតពីរដែលមានទទឹងស្មើនឹង ១,៥៨៧៥មម។ ផ្ទៃបន្ទាត់លេខកូដបូកនឹងចន្លោះលាតទាំងពីរដែលស្ថិតនៅខាងលើនិងខាងក្រោម គឺជាផ្ទៃសម្រាប់ម៉ាស៊ីនអាន (Read Band)។

ពុម្ពអក្សរ E13B ត្រូវតែបោះពុម្ពនៅក្នុងផ្ទៃបន្ទាត់លេខកូដតែប៉ុណ្ណោះ។

រូបភាពទី២៖ ផ្ទៃលាតសម្រាប់ធនាគារ: ផ្ទៃសម្រាប់ម៉ាស៊ីនអាន និងបន្ទាត់លេខកូដ




១.៤. ការកំណត់ទ្រង់ទ្រាយបន្ទាត់លេខកូដ

១.៤.១. ស្តង់ដារទូទៅ

បន្ទាត់លេខកូដស្តង់ដារនៃមូលប្បទានបត្ររបស់កម្ពុជា មានលក្ខណៈស្របតាមបន្ទាត់លេខកូដស្តង់ដារអន្តរជាតិ ដូចបានកំណត់ច្បាស់នៅក្នុងស្តង់ដារ ANSI X9[1] និង ISO[2]។ យោងតាមសេចក្តីកំណត់នៃស្តង់ដារទាំងនេះ ទីតាំងជាក់លាក់នៃតួលេខនិងសញ្ញាពិសេសនៅក្នុងបន្ទាត់លេខកូដត្រូវបានដាក់លេខរៀងពីខាងស្តាំបំផុតនៃបន្ទាត់លេខកូដដោយផ្តើមពីលេខ១។ បន្ទាត់លេខកូដមិនត្រូវមានកន្លែងចុះទិន្នន័យលើសពីប្រាំ (៥) ហើយកន្លែងនីមួយៗមិនត្រូវមានតួលេខនិងសញ្ញាពិសេសលើសពី១៥តួឡើយ។

រូបភាពទី៣៖ រចនាសម្ព័ន្ធបន្ទាត់លេខកូដនៃមូលប្បទានបត្រ



១.៤.២. ការបោះពុម្ពបន្ទាត់លេខកូដនិងការកំណត់លេខកូដ

ទិន្នន័យទាំងឡាយ ដូចជាលេខមូលប្បទានបត្រ លេខកូដធនាគារនិងសាខា និងលេខគណនីត្រូវតែបញ្ចូលដោយធនាគារដែលចេញផ្សាយមូលប្បទានបត្រ ដោយប្រើ Software សមស្រប និងត្រូវតែបោះពុម្ពជាស្រេចមុននឹងធ្វើការបែងចែកសៀវភៅមូលប្បទានបត្រទៅឱ្យអតិថិជន។

[1] ANSI X9: American National Standard ស្តង់ដារលេខកូដសម្រាប់ប្រើក្នុងវិស័យហិរញ្ញវត្ថុដូចជា មូលប្បទានបត្រ ការផ្ទេរតាមអេឡិកត្រូនិក និងលេខសម្គាល់អត្តសញ្ញាណ (PIN)។

[2] ISO: Internatioanl Standard Organization ស្តង់ដារទទួលស្គាល់អន្តរជាតិ។

សញ្ញាពិសេសនៃទិន្នន័យនៅក្នុងក្រុមនីមួយៗ ត្រូវតែបោះពុម្ពក្នុងពេលជាមួយគ្នានឹងទិន្នន័យដែលនៅក្នុងក្រុមនោះ។ ឧទាហរណ៍ សញ្ញាពិសេសនៃចំនួនប្រាក់ត្រូវតែបោះពុម្ពក្នុងពេលជាមួយគ្នានឹងចំនួនប្រាក់។

ពីខាងលើនិងខាងក្រោមនៃបន្ទាត់លេខកូដ ត្រូវមានបម្រុងទុកផ្ទៃទំនេរ ដើម្បីសម្រួលដល់ការពង្រីក ដំណើរការនៃការផាត់ទាត់ក្នុងពេលអនាគត ដូចជាលេខកូដរបស់សភាផាត់ទាត់ជាដើម។ ប្រសិនបើមានការតម្រូវឱ្យបញ្ចូលលេខកូដ លេខកូដនោះត្រូវតែបោះពុម្ពនៅក្នុងកន្លែងដែលបានបម្រុងទុកនេះ។

ចំពោះកន្លែងចុះទិន្នន័យដែលនៅជាប់គ្នាហើយគ្មានចន្លោះទំនេររវាងកន្លែងទាំងនោះ លេខកូដត្រូវតែបញ្ចូលក្នុងពេលជាមួយគ្នា ដើម្បីចៀសវាងកំហុសឆ្គងនានាដោយសារតែលំអៀងនៃតួលេខនិងចន្លោះបន្ទាត់ ដែលធ្វើឱ្យម៉ាស៊ីនអានលេខកូដមិនអាចអានពុម្ពអក្សរ E13B បានត្រឹមត្រូវ។

១.៤.៣. ទីតាំង និងកន្លែងចុះទិន្នន័យនៅក្នុងបន្ទាត់លេខកូដ

ទិន្នន័យនៅក្នុងបន្ទាត់លេខកូដត្រូវបានចែកចេញជាប្រាំផ្នែក ដោយរាប់ពីស្តាំទៅឆ្វេង។

ក. កន្លែងចុះចំនួនប្រាក់

កន្លែងចុះចំនួនប្រាក់មានតួលេខចំនួន ១៥ខ្ទង់ និងមានសញ្ញាពិសេសចំនួន២ដែលប្រាប់ពីចំណុចផ្តើមនិងចំណុចបញ្ចប់នៃកន្លែងចុះចំនួនប្រាក់។

- **ទីតាំងទី១៖** មានសញ្ញាពិសេសចំនួន១ខ្ទង់ ដែលតាងដោយនិមិត្តសញ្ញា (⑈) សម្គាល់ឃ្លៀបបើកនៃចំនួនប្រាក់។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានបត្រទៅគែមខាងស្តាំនៃសញ្ញាពិសេសមានប្រវែង៨មម។
- **ទីតាំងទី២ ដល់ ១៦៖** ចំនួនប្រាក់នៃមូលប្បទានបត្រជាដុល្លារ ឬជារៀល (ចំពោះមូលប្បទានបត្រជាដុល្លារ ខ្ទង់សេនមាន២ខ្ទង់ដែលស្ថិតនៅផ្នែកខាងស្តាំបំផុត ទោះបីជាមិនត្រូវចំណាយជាសេនក៏ដោយ)។
- **ទីតាំងទី១៧៖** សញ្ញាពិសេសតំណាងដោយនិមិត្តសញ្ញា (⑈) សម្គាល់ឃ្លៀបបិទនៃចំនួនប្រាក់។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានបត្រ ទៅគែមខាងឆ្វេងនៃកន្លែងចុះចំនួនប្រាក់ត្រូវមានប្រវែង ៦២មម។

ឧទាហរណ៍៖ ចំនួនប្រាក់ ៩៩.៩៨៨.៨០០,០០ រៀល នៅលើបន្ទាត់លេខកូដមានទម្រង់ ដូចខាងក្រោម៖

⑈០០០០០០៩៩៩៨៨៨០០⑈

<u>សម្គាល់</u> ៖ ការកែតួលេខត្រូវធ្វើឡើងដោយក្រដាសកែតម្រូវដែលមានកម្រាស់មិនលើសពី ០,២៣មម ដាក់បិទភ្ជាប់នៅខាងខ្នងមូលប្បទានបត្រ ហើយតួលេខត្រូវតែចុះនៅលើក្រដាសបិទភ្ជាប់នេះតាមចំនួនប្រាក់ដែលត្រូវទូទាត់សង។

ខ. កន្លែងចុះលេខកូដប្រតិបត្តិការ

កន្លែងចុះលេខកូដប្រតិបត្តិការមានលេខ ២ ខ្ទង់ ដែលស្ថិតនៅខ្ទង់ទី១៩ និងខ្ទង់ទី២០ សម្រាប់សម្គាល់ប្រភេទរូបិយប័ណ្ណ៖

- ០០ ៖ សម្រាប់មូលប្បទានបត្រជាប្រាក់រៀល
- ០១ ៖ សម្រាប់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិក

<u>សម្គាល់</u> ៖ គណៈកម្មាធិការទូទាត់នៃសមាគមធនាគារ អាចពិភាក្សាជាមួយសមាជិករបស់ខ្លួនលើការប្រើប្រាស់លេខកូដប្រតិបត្តិការទាំង ២ ខ្ទង់នេះសម្រាប់សម្គាល់ប្រភេទប្រតិបត្តិការទូទាត់ផ្សេងៗទៀតដូចជា ប្រភេទប្រតិបត្តិការឥណពន្ធ ឬឥណទានជាដើម។

- **ទីតាំងទី១៨ ៖** ជាចន្លោះទំនេរសម្រាប់ខណ្ឌកន្លែងចុះចំនួនប្រាក់ និងកន្លែងចុះលេខកូដប្រតិបត្តិការ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអានទិន្នន័យដោយស្វ័យប្រវត្តិឱ្យបានសុក្រឹត។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានបត្រ ទៅគែមខាងស្តាំនៃកន្លែងចុះលេខកូដនេះ ត្រូវមានប្រវែង ៧១,៥មម។

ឧទាហរណ៍៖ ចំនួនប្រាក់ ៩៩.៩៨៨.៨០០,០០ រៀល និងលេខកូដសម្គាល់ប្រភេទរូបិយប័ណ្ណដែលមូលប្បទានបត្រត្រូវទូទាត់សងមានបង្ហាញនៅលើបន្ទាត់លេខកូដ ដូចខាងក្រោម៖



គ. កន្លែងចុះលេខគណនី

កន្លែងចុះលេខគណនីមានលេខ ១២ ខ្ទង់ ដែលស្ថិតនៅខ្ទង់ទី២២ ដល់ខ្ទង់ទី៣៣។ កន្លែងចុះលេខគណនីនេះមានសញ្ញាពិសេស () ដែលស្ថិតនៅខ្ទង់ទី២១ សម្រាប់សម្គាល់លេខគណនី។

ឧទាហរណ៍៖ លេខគណនី ១១១២២២៣៣៣៤៤៤ ក្នុងបន្ទាត់លេខកូដមានបង្ហាញ ដូចខាងក្រោម៖



ឃ. កន្លែងចុះលេខកូដធនាគារ និងសាខាធនាគារ

លេខកូដធនាគារនិងលេខកូដសាខាធនាគារ ត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណធនាគារ ឬសាខាធនាគារ ដែលផ្តើមប្រតិបត្តិការ និងធនាគារឬសាខាធនាគារគោលដៅ។

កន្លែងចុះលេខនេះរួមមាន លេខកូដសម្គាល់ធនាគារចំនួន ៣ ខ្ទង់ លេខកូដសម្គាល់សាខាធនាគារចំនួន ៣ ខ្ទង់ ចន្លោះទំនេរចំនួន ១ ខ្ទង់ និងលេខកូដសម្រាប់ផ្ទៀងផ្ទាត់ចំនួន១ខ្ទង់ ព្រមទាំងមានសញ្ញាពិសេស ()។

- **ទីតាំងទី៣៤៖** ជាសញ្ញាពិសេស (:) ដែលជាឃ្លៀបបើកកន្លែងចុះលេខធនាគារ ឬសាខាធនាគារ
- **ទីតាំងទី៣៥៖** ជាលេខកូដផ្សៀងផ្ទាត់
- **ទីតាំងទី៣៦៖** ជាចន្លោះទំនេរ
- **ទីតាំងទី៣៧ ដល់ ៣៩៖** ជាលេខកូដសាខាធនាគារ
- **ទីតាំងទី៤០៖** ជាសញ្ញាពិសេស (▪▪▪)
- **ទីតាំងទី ៤១ ដល់ ៤៣៖** ជាលេខកូដធនាគារ

ឧទាហរណ៍៖ លេខកូដធនាគារនិងលេខកូដសាខាធនាគារ និងលេខកូដផ្សៀងផ្ទាត់ដែលត្រូវបានបញ្ចូលនៅក្នុងបន្ទាត់លេខកូដគឺ (១) លេខកូដធនាគារ = ១០០ (២) លេខកូដសាខាធនាគារ = ០០១ និង (៣) លេខកូដផ្សៀងផ្ទាត់ = ៧

⑈100⑇001⑈ ⑆:11122233445566⑈00 ⑇000000099888800⑇

ឯ. កន្លែងចុះលេខរៀងមូលប្បទានបត្រ

លេខមូលប្បទានបត្រមានចំនួន ៦ ខ្ទង់ ព្រមទាំងសញ្ញាឃ្លៀបបើកនិងបិទ (⑈) នៅអមសងខាង។ ចម្ងាយពីគែមខាងស្តាំនៃមូលប្បទានបត្រទៅចុងខាងឆ្វេងនៃកន្លែងចុះលេខរៀងមូលប្បទានបត្រមានប្រវែង១៧០មម។


ឧទាហរណ៍៖ លេខមូលប្បទានបត្រដែលដាក់នៅក្នុងបន្ទាត់លេខកូដគឺលេខ១។

⑈000001⑈ 100⑇001⑈ ⑆:11122233445566⑈00 ⑇000000099888800⑇

១.៤.៤. ទីតាំងជារូបវន្តនៃតួលេខនិងសញ្ញាពិសេស

ដើម្បីជាឯកសារយោងនិងដើម្បីសម្រួលដល់ការរៀបចំទីកន្លែង និងទីតាំងជារូបវន្តនៃតួលេខនិង សញ្ញាពិសេសរបស់លេខកូដដែលបោះពុម្ព និងកន្លែងចុះទិន្នន័យនានាត្រូវបានសង្ខេបក្នុងរូបភាព៤។

រូបភាព៤៖ ទីតាំងសម្រាប់ចុះទិន្នន័យនីមួយៗនៅក្នុងបន្ទាត់លេខកូដ



១.៤.៥. សេចក្តីលម្អិតអំពីលក្ខណៈស្តង់ដារនៃប្រភេទតួលេខនិងសញ្ញាពិសេស E13B

លក្ខណៈស្តង់ដារនៃរូបរាង ទំហំ និងចរិតលក្ខណៈរបស់ពុម្ពអក្សរ E13B (តួលេខនិងសញ្ញាពិសេស) រួមទាំងលក្ខណៈមើលស្គាល់ដោយស្វ័យប្រវត្តិនៃពុម្ពអក្សរ E13B ផង ត្រូវតែបោះពុម្ពដើម្បីឱ្យអាចមើលឃើញច្បាស់។

ក. គោលបំណងនិងការប្រើប្រាស់

ពុម្ពអក្សរនេះត្រូវបានប្រើជាអន្តរជាតិ ហើយត្រូវបានរៀបចំឡើងដើម្បីចៀសវាងនូវកំហុសឆ្គងក្នុងការបោះពុម្ព និងការអាន ព្រមទាំងដើម្បីសម្រួលដល់ដំណើរការស្វ័យប្រវត្តិកម្មនៃមូលប្បទានបត្រ ឬធ្វើជាឯកសារស្តង់ដារដទៃទៀត ជាពិសេសក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។

ខ. រូបរាងនៃតួលេខ និងសញ្ញាពិសេស

ពុម្ពអក្សរ E13B ដែលប្រើសម្រាប់បោះពុម្ពក្នុងបន្ទាត់លេខកូដនៅលើមូលប្បទានបត្រមានចំនួន ១០តួ ជាលេខ និង ៤តួ ជាសញ្ញាពិសេស ដូចមានបង្ហាញដូចខាងក្រោម៖

តួលេខ

1	មួយ	6	ប្រាំមួយ
2	ពីរ	7	ប្រាំពីរ
3	បី	8	ប្រាំបី
4	បួន	9	ប្រាំបួន
5	ប្រាំ	0	សូន្យ

សញ្ញាពិសេស

⑆	ធនាគារ / សាខា
⑇	ចំនួនប្រាក់
⑈	លេខគណនី
⑉	រញ្ជុសញ្ញា (Dash) ឬ សហសញ្ញា (Hyphen)

២- អនុសាសន៍អំពីមូលប្បទានបត្រស្តង់ដារ

២.១ ផ្នែខាងមុខនៃមូលប្បទានបត្រ

ផ្នែខាងមុខនៃមូលប្បទានបត្រត្រូវបានបែងចែកជាពីរផ្នែក៖ (១) ផ្នែលាតសម្រាប់ធនាគារ (២) សម្រាប់ធុរកិច្ច។ ព័ត៌មានដែលមាននៅក្នុងផ្នែកសម្រាប់ធុរកិច្ចត្រូវបានកំណត់ដោយតម្រូវការនៃផ្នែកគតិយុត្ត ដូចមានចែងដោយសង្ខេបក្នុងចំណុច ១.១ ខាងលើ។

ការបញ្ជាក់លម្អិតបន្ថែមចំពោះផ្ទៃដែលត្រូវប្រើប្រាស់ និងទីតាំងនៃព័ត៌មានផ្សេងៗមានជាអនុសាសន៍ ដូចតទៅ៖

២.១.១ ពណ៌ផ្ទៃខាងក្រោយ

ពណ៌ផ្ទៃខាងក្រោយនៅត្រង់កន្លែងសម្រាប់ធុរកិច្ច ត្រូវមានពណ៌ស ឬពណ៌ស្រាលដើម្បីឱ្យអាចមើលឃើញទិន្នន័យច្បាស់។ ពណ៌នៃផ្ទៃខាងក្រោយនិងការរំលេចពណ៌ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

(១) <u>សម្រាប់ការបោះពុម្ពអុបសិត (offset) ដែលដាក់ពណ៌ដោយការបោះពុម្ពអុបសិត</u>

សមាមាត្រជាភាគរយនៃការដាក់ពណ៌ក្នុងការបោះពុម្ពអុបសិតមិនត្រូវលើសពីចំនួនដូចខាងក្រោមនេះ៖

ពណ៌		ការដាក់ពណ៌ក្នុងការបោះពុម្ពអុបសិត
លឿង	(Yellow-Y)	100%
កំបោរ	(Magenta-M)	20%
ខៀវទឹកសមុទ្រ	(Cyan-C)	20%
ខ្មៅ	(Black-B)	0 %

(២) <u>សម្រាប់ការបោះពុម្ពអុបសិត ឬការបោះពុម្ពផ្សេងទៀតដែលមិនមានការដាក់ពណ៌ដោយការបោះពុម្ព</u>

ពណ៌នៃផ្ទៃខាងក្រោយនិងការរំលេចពណ៌ មិនត្រូវជិតជាងពណ៌លាយដែលអនុវត្តតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះពុម្ពដូចមានចែងក្នុងតារាងខាងលើចំណុច ២.២.១ (១)។

២.១.២ ទីតាំងចុះកាលបរិច្ឆេទ

កន្លែងចុះកាលបរិច្ឆេទត្រូវស្ថិតនៅខាងលើផ្នែកខាងស្តាំ សម្គាល់ដោយបន្ទាត់ចុចៗដែលមានប្រវែង ៥៥មម ហើយចុងខាងស្តាំនៃបន្ទាត់ចុចៗនេះមានចម្ងាយ៦មម ពីគែមខាងស្តាំនៃមូលប្បទានបត្រ និងចម្ងាយ ៧៧មម ពីគែមខាងក្រោមនៃមូលប្បទានបត្រ។ ពាក្យថា "កាលបរិច្ឆេទ" ត្រូវស្ថិតនៅខាងឆ្វេង និងនៅស្មើនឹងបន្ទាត់ចុចៗដែលបញ្ជាក់ថាជាទីតាំងសម្រាប់ចុះកាលបរិច្ឆេទ។

២.១.៣ ទីតាំងសម្រាប់ចុះចំនួនប្រាក់

ទីតាំងសម្រាប់ចុះចំនួនប្រាក់ត្រូវស្ថិតនៅខាងក្រោមកន្លែងចុះកាលបរិច្ឆេទ។ ទីតាំងសម្រាប់ចុះចំនួនប្រាក់នេះជាប្រអប់រាងចតុកោណកែងដែលមានទទឹងប្រវែង ១០មម និងបណ្តោយប្រវែង ៦៧មម។ ចុងខាងស្តាំនៃប្រអប់នេះមានចម្ងាយ ៦មម ពីគែមខាងស្តាំ និងចម្ងាយ ៥៧មម ពីគែមខាងក្រោមនៃមូលប្បទានបត្រ។ នៅក្នុងប្រអប់នេះ ត្រូវមានអក្សរកូដសម្គាល់រូបិយប័ណ្ណជា "KHR" សម្រាប់មូលប្បទានបត្រដែលទូទាត់សងជាប្រាក់រៀល ឬជា "USD" សម្រាប់មូលប្បទានបត្រដែល

ទូទាត់សងជាប្រាក់ដុល្លារអាមេរិក ហើយអក្សរកូដសម្គាល់រូបិយប័ណ្ណនេះ ត្រូវស្ថិតនៅចម្ងាយ ៦មម ពីគែមខាងឆ្វេងនៃប្រអប់។

២.១.៤ ទីតាំងសម្រាប់ចុះហត្ថលេខា

ទីតាំងសម្រាប់ចុះហត្ថលេខាត្រូវស្ថិតនៅខាងក្រោមផ្នែកខាងស្តាំនៃមូលប្បទានបត្រ ដែលមានចម្ងាយ ៦មម ពីគែមខាងស្តាំនៃមូលប្បទានបត្រ និងចម្ងាយ ១០មម ពីខាងលើផ្ទៃលាតសម្រាប់ធនាគារ។ ការកំណត់ទីតាំងនេះគឺដើម្បីសម្រួលដល់ប្រព័ន្ធផ្ទៀងផ្ទាត់ហត្ថលេខាដោយស្វ័យប្រវត្តិ និងម៉ាស៊ីនអានលេខកូដ E13B ផងដែរ។

២.១.៥ ឈ្មោះនិងអាសយដ្ឋានរបស់ធនាគារចេញផ្សាយមូលប្បទានបត្រ


កន្លែងសម្រាប់ឈ្មោះនិងអាសយដ្ឋានរបស់ធនាគារចេញផ្សាយមូលប្បទានបត្រ (ឡូហ្គោរបស់ធនាគារ និងសាខា) ត្រូវស្ថិតនៅផ្នែកខាងលើជ្រុងខាងឆ្វេង ដែលមានបណ្តោយប្រវែង ៥៨មម និងកម្ពស់ប្រវែង ១៨មម ហើយមានចម្ងាយ ៦មម ពីគែមខាងឆ្វេង និងចម្ងាយ ៧២មម ពីគែមខាងក្រោមនៃមូលប្បទានបត្រ។

២.១.៦ ឈ្មោះ (និងអាសយដ្ឋាន) របស់បហារ័ក

កន្លែងសម្រាប់ឈ្មោះ (និងអាសយដ្ឋាន) របស់បហារ័ក ត្រូវស្ថិតនៅពីក្រោមផ្នែកខាងឆ្វេងនៃពាក្យ "ចំនួនប្រាក់" នៃមូលប្បទានបត្រ។

គ្រឹះស្ថានធនាគារអាចដាក់ ឬមិនដាក់បញ្ចូលនូវអាសយដ្ឋានរបស់បហារ័កនៅលើមូលប្ប-ទានបត្រ។


រូបភាព៥៖ លក្ខណៈលម្អិតនៃមូលប្បទានបត្រគំរូ



២.២ ផ្នែកខាងខ្នងនៃមូលប្បទានបត្រ

ផ្នែកខាងខ្នងនៃមូលប្បទានបត្រត្រូវបានចែកចេញជាបីផ្នែកសំខាន់ៗ៖

រូបភាព៦៖ ផ្នែកខាងខ្នងនៃមូលប្បទានបត្រ



២.២.១ ផ្នែកទី១៖ ផ្ទៃលាតសម្រាប់ធនាគារ (Clear Band)

ផ្ទៃលាតនេះស្ថិតនៅផ្នែកខាងក្រោមបំផុតនៃមូលប្បទានបត្រ ដែលមានទទឹងប្រវែង ១៦មម ពីគែមខាងក្រោម និងមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានបត្រ។ ផ្ទៃលាតនេះមានទីតាំង និងទំហំស្មើនឹងផ្ទៃលាតសម្រាប់ធនាគារ ដែលស្ថិតនៅផ្ទៃខាងមុខមូលប្បទានបត្រដែរ។

២.២.២ ផ្នែកទី២៖ សម្រាប់ធនាគារនិងអតិថិជន

ផ្ទៃនៃផ្នែកនេះមានបណ្តោយស្មើនឹងប្រវែងបណ្តោយមូលប្បទានបត្រ និងមានទទឹងប្រវែង ៧៥មម ចាប់ពីខាងលើនៃផ្ទៃលាតសម្រាប់ធនាគារដល់គែមខាងលើនៃមូលប្បទានបត្រ ដោយដកចេញនូវផ្ទៃសម្រាប់សភាផាត់ទាត់ដូចមានចែងក្នុងចំណុច ២.២.៣ ខាងក្រោម។

២.២.៣ ផ្នែកទី៣៖ សម្រាប់សភាផាត់ទាត់

ផ្ទៃនៃផ្នែកនេះស្ថិតនៅខាងលើជ្រុងខាងស្តាំដែលមានទទឹងប្រវែង ៤២មម និងបណ្តោយប្រវែង ៨៥មម។

ផ្នែកខាងក្រោយនៃមូលប្បទានបត្រអាចមានបន្ទាត់ខណ្ឌចែកផ្នែកនីមួយៗដែលមានដាក់អក្សរសម្គាល់ ដោយពណ៌ស្រាលៗថា "សម្រាប់ធនាគារនិងអតិថិជន" និង "សម្រាប់សភាផាត់ទាត់"។

ការបោះពុម្ពត្រូវតែគោរពតាមការកំណត់ក្នុងចំណុច ២.២ នេះ ឬក៏អាចដាក់កំណត់សម្គាល់សម្រាប់បែងចែកផ្នែកនីមួយៗនៅលើក្របផ្នែកខាងក្នុងនៃសៀវភៅមូលប្បទានបត្រ។

៣- អនុសាសន៍លើការការពារការក្លែងបន្លំ

មូលប្បទានបត្រត្រូវមានលក្ខណៈពិសេសដែលអាចទប់ស្កាត់ការក្លែងបន្លំ និងការកែប្រែព័ត៌មានដូចខាងក្រោម៖

៣.១ ក្រដាសបោះពុម្ពមូលប្បទានបត្រ

ក្រដាសប្រើសម្រាប់បោះពុម្ពមូលប្បទានបត្រត្រូវមានលក្ខណៈពិសេស និងប្រកបដោយគុណភាព។

៣.២ ការការពារការកែប្រែព័ត៌មាន

កន្លែងសម្រាប់ចុះព័ត៌មានសំខាន់ៗក្នុងមូលប្បទានបត្រដែលអាចជាកម្មវត្ថុនៃការកែប្រែ ដូចជាឈ្មោះបហារិត ចំនួនប្រាក់ត្រូវទូទាត់សង (ជាលេខនិងជាអក្សរ) ត្រូវតែបោះពុម្ពនៅពីលើពណ៌នៃផ្ទៃខាងក្រោយ ឬនៅពីលើពណ៌រំលេចដោយទឹកខ្មៅដែលមិនងាយរលុបដើម្បីការពារការកែប្រែដូចជាការប្រើទឹកខ្មៅពិសេសដែល នឹងអាចមើលឃើញដោយកាំរស្មីពណ៌ស្វាយ (អ៊ុលត្រាវីយូឡេ) ឬទឹកខ្មៅដែលមិនងាយរលុបបាត់បន្ទាប់ពីត្រូវបានលុប ឬកែដោយទឹកលុប។ល។

៣.៣ ការការពារការថតចម្លងពណ៌ធម្មជាតិ

មូលប្បទានបត្រត្រូវបោះពុម្ពដោយប្រើបច្ចេកទេសពិសេស ដើម្បីការពារការក្លែងបន្លំដោយប្រើម៉ាស៊ីនថតចម្លងពណ៌ធម្មជាតិ។

គ្រឹះស្ថានធនាគារ ត្រូវកំណត់គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនចំពោះប្រតិបត្តិការមូលប្បទានបត្រ។

៤- ការប្រើមូលប្បទានបត្រ

សេចក្តីណែនាំក្នុងការប្រើប្រាស់មូលប្បទានបត្រ ត្រូវតែបោះពុម្ពនៅលើក្របផ្នែកខាងក្នុងនៃសៀវភៅមូលប្បទានបត្រ និងត្រូវមានគោលការណ៍ណែនាំដូចខាងក្រោម៖

ក- ទាំងផ្ទៃខាងមុខនិងផ្ទៃខាងក្រោយនៃផ្ទៃលាតសម្រាប់ធនាគារ មិនត្រូវមានសរសេរស្តាមកាត់ ឬ រហែក ស្តាមបិទឬកិប ឬប្រឡាក់ជាតិគីមីផ្សេងៗ ដែលនាំឱ្យរំខានដល់ការអានរបស់ម៉ាស៊ីនអានលេខកូដឡើយ។

ខ- ការឆ្លងបន្ទាត់ ហត្ថលេខារបស់បហារក ឬការបោះត្រាណាមួយ ឬចំណារ មិនត្រូវធ្វើឡើងនៅលើផ្នែកខាងក្រោមដែលជាផ្ទៃលាតសម្រាប់ធនាគារ ដែលប្រើសម្រាប់ចាប់កលេខកូដឡើយ។

គ- មិនត្រូវកោស ឬលុបតួលេខនិងសញ្ញាពិសេសនៅលើបន្ទាត់លេខកូដនៅក្នុងផ្ទៃលាតឡើយ។

ឃ- ដើម្បីកែប្រែព័ត៌មានណាមួយលើមូលប្បទានបត្រ អ្នកប្រើមូលប្បទានបត្រត្រូវគូសឆ្លងចោលព័ត៌មានទាំងមូល ហើយចុះហត្ថលេខារបស់ខ្លួននៅពីលើផ្នែកដែលត្រូវបានកែប្រែនោះចៀសវាងការប្រើទឹកលុប។

ង- ការប្រើប្រាស់ផ្នែកខាងខ្នងនៃមូលប្បទានបត្រ ត្រូវបានអនុញ្ញាតតែចំពោះផ្នែកសម្រាប់ធនាគារ និងអតិថិជនតែប៉ុណ្ណោះ។

ច- មិនត្រូវបត់ និងធ្វើឱ្យរហែកមូលប្បទានបត្រ ជាពិសេសនៅផ្នែកសម្រាប់បន្ទាត់លេខកូដ។

- ធនាគារត្រូវតែប្រាកដថាស្នាមចោះៗសម្រាប់ហែកសន្លឹកមូលប្បទានបត្រ ត្រូវបានធ្វើឡើងប្រកបដោយគុណភាពនិងគួរឱ្យទុកចិត្ត ដើម្បីសម្រួលឱ្យការហែកសន្លឹកមូលប្បទានបត្រចេញពីសៀវភៅមូលប្បទានបត្រធ្វើបានត្រឹមត្រូវ។
- ព័ត៌មានដែលសរសេរដោយដៃត្រូវតែច្បាស់និងអាចអានបានតាមដែលអាចធ្វើទៅបាន ព្រមទាំងត្រូវសរសេរដោយប្រើទឹកខ្មៅពណ៌ខ្មៅ ឬទឹកខ្មៅពណ៌ខៀវចាស់ដែលមិនរលុប។ ចៀសវាងការប្រើទឹកខ្មៅដែលមានលក្ខណៈចាំងពន្លឺ និងឧបករណ៍សរសេរដែលអាចលុបបានដូចជាខ្មៅដៃជាដើម។
- ព័ត៌មានដែលសរសេរដោយដៃត្រូវសរសេរបញ្ចូលឱ្យចំទីតាំងដែលបានកំណត់ដោយមិនទុកឱ្យមានសល់ចន្លោះទំនេរដែលធ្វើឱ្យអាចកែប្រែចំនួនប្រាក់ឡើយ ជាពិសេសចន្លោះពីសញ្ញាសម្គាល់រូបិយវត្ថុ និងចំនួនប្រាក់ជាតួលេខ។

ធ៩-០៨-១៨៧ ប្រ.ក

ប្រកាស
ស្តីពី
ការកំណត់លេខអត្តសញ្ញាណធនាគារ

ប្រការ ១.-


កំណត់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ ដើម្បីចារឹកលេខកូដធនាគារ នៅលើមូលប្បទានបត្រ ដែលអាចអានបានដោយម៉ាស៊ីន ស្របតាមមូលប្បទានបត្រស្តង់ដារ។

គ្រប់មូលប្បទានបត្រទាំងអស់ ត្រូវតែចារឹកនូវលេខអត្តសញ្ញាណសម្រាប់សម្គាល់ដូចតទៅ៖

ក- លេខកូដធនាគារដែលបោះផ្សាយមូលប្បទានបត្រ

ខ- លេខកូដសាខារបស់ធនាគារដែលចេញផ្សាយមូលប្បទានបត្រ និង

គ- លេខកូដផ្ទៀងផ្ទាត់ Check digit។



លេខកូដធនាគារ លេខកូដសាខា លេខកូដផ្ទៀងផ្ទាត់

ប្រការ ២.-

លេខកូដសម្រាប់សម្គាល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដូចតទៅ៖

ឈ្មោះគ្រឹះស្ថានធនាគារ	លេខកូដ
ធនាគារជាតិនៃកម្ពុជា	១០០
ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា	០០១
ធនាគារកម្ពុជាពាណិជ្ជចំកាត់	០០៣
ធនាគារកម្ពុជាសាធារណៈ ចំកាត់	០០៤
ធនាគារកាណាឌីយ៉ា ក្រុមហ៊ុនអនាមិក	០០៥
ធនាគារក្រុងថៃ មហាជន សាខាភ្នំពេញ	០០៩
ធនាគារកម្ពុជាអាស៊ីចំកាត់	០១៦
សាជីវកម្មធនាគារសឹង្ហបូរី ចំកាត់	០១៨

ធនាគារមេយប៊ែង សាខាភ្នំពេញ	០២០
ធនាគារសហពាណិជ្ជ ក្រុមហ៊ុនអនាមិក	០២៦
ធនាគារ មេគង្គកម្ពុជា មហាជនទទួលខុសត្រូវមានកម្រិត	០៣២
ធនាគារវឌ្ឍន:អាស៊ី ចំកាត់	០៣៦
ធនាគារអភិវឌ្ឍជនបទ	០៣៨
ធនាគារពាណិជ្ជទី១ សាខាភ្នំពេញ	០៤០
ធនាគារអេស៊ីលីដា ភីអិលស៊ី	០៤១
ធនាគារឯកទេស ប៉ែង ហោង អេស អឹម អ៊ី	០៤២
ធនាគារវឌ្ឍន:	០៤៣
ធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់កម្ពុជា	០៤៤
ធនាគារឯកទេស វិនិយោគទី១	០៤៧
ធនាគារ ខេមខូលីមីធីត	០៥២
ធនាគារ សុិនហានខ្មែរ	០៥៣
ធនាគារ វី. អាយ . ភី	០៥៤
ធនាគារ វិនិយោគរុងរឿង	០៥៥
ធនាគារជប៉ុន ម៉ារូហាន់	០៥៦
ធនាគារ ប៊ូយ៉ុង ខ្មែរ	០៦១
ធនាគារ ភ្នំពេញពាណិជ្ជ	០៥៨
ធនាគារ អូ. អេស. ខេ អិនដូឆាយណាលីមីធីត	០៥៧
ធនាគារ ខ្មែរឃ្លាំង	០៥៩
ធនាគារឯកទេស បេីស	០៦០
ធនាគារ អង្គរកាពីតាល់	០៦៣

ប្រការ ៣.-

ក- លេខកូដសម្រាប់សម្គាល់ទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជានៅតាមបណ្តាខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម៖

ឈ្មោះធនាគារ	លេខកូដ
ធនាគារជាតិនៃកម្ពុជា	០០១
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកណ្តាល	០០២
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម	០០៣
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបាត់ដំបង	០០៤
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រៃវែង	០០៥
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តសៀមរាប	០០៦
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ធំ	០០៧
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តតាកែវ	០០៨
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្វាយរៀង	០០៩
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តពោធិ៍សាត់	០១០
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ឆ្នាំង	០១១
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ស្ពឺ	០១២
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពត	០១៣
សាខា ធនាគារជាតិនៃកម្ពុជា ក្រុងព្រះសីហនុ	០១៤
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកោះកុង	០១៥
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រះវិហារ	០១៦
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តក្រចេះ	០១៧
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តរតនគីរី	០១៨
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តមណ្ឌលគីរី	០១៩
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្ទឹងត្រែង	០២០
សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបន្ទាយមានជ័យ	០២១
សាខា ធនាគារជាតិនៃកម្ពុជា ក្រុងភ្នំពេញ	០២៣

ខ- ចំពោះលេខកូដសម្គាល់សាខាគ្រឹះស្ថានធនាគារ នឹងត្រូវបានកំណត់ដោយសាមីគ្រឹះស្ថាននីមួយៗហើយសាមីគ្រឹះស្ថានត្រូវធ្វើបញ្ជីលេខកូដសម្គាល់សាខារបស់ខ្លួនដែលបានកំណត់ហើយនោះមកធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

ចំពោះលេខកូដសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ និងសម្គាល់សាខាធនាគារជាតិនៃកម្ពុជា ដែលត្រូវបង្កើតថ្មី នឹងត្រូវបានកំណត់ដោយសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា។

ប្រការ ៥.-

លេខកូដផ្ទៀងផ្ទាត់ (Check digit) ត្រូវបានប្រើសម្រាប់ផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃលេខកូដអត្តសញ្ញាណធនាគារដែលចែងក្នុងប្រការ ១។ វិធីសាស្ត្រដាក់លេខកូដផ្ទៀងផ្ទាត់នេះ នឹងត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ប្រការ ៦.-

ក្នុងករណីមានការផ្លាស់ប្តូរទីតាំងសាខាគ្រឹះស្ថានធនាគារ ឬបង្កើតសាខាគ្រឹះស្ថានធនាគារបន្ថែមទៀត សាមីគ្រឹះស្ថានធនាគារត្រូវផ្តល់ដំណឹងជាមុនមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១០ ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីដែលសាខាគ្រឹះស្ថានធនាគារណាមួយបិទទ្វារបញ្ឈប់សកម្មភាពអាជីវកម្ម លេខកូដសាខាគ្រឹះស្ថានធនាគារនោះ មិនអនុញ្ញាតឱ្យយកទៅប្រើសម្រាប់សម្គាល់សាខាគ្រឹះស្ថានធនាគារដែលបើកថ្មីឡើយ។ សាខាគ្រឹះស្ថានធនាគារថ្មីត្រូវកំណត់លេខកូដថ្មី។

ប្រការ ៧.-

ការប្រើប្រាស់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារដូចមានចែងខាងលើ នឹងចាប់ផ្តើមអនុវត្តនៅពេលដែលមូលប្បទានបត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់។

ប្រការ ៨.-

លិខិតបទដ្ឋានទាំងឡាយណាដែលពាក់ព័ន្ធនឹងការដាក់លេខអត្តសញ្ញាណធនាគារ ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃដែលមូលប្បទានបត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់។

ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០៩-២២៨ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់មូលបត្រស្តង់ដារ
របស់ធនាគារជាតិនៃកម្ពុជា

ប្រការ ១.-

ដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រស្តង់ដារថ្មី ចំនួន ២ (ពីរ) ប្រភេទ គឺមូលប្បទានបត្រចារឹកជាប្រាក់រៀល និងចារឹកជាប្រាក់ដុល្លារអាមេរិក ជំនួសមូលប្បទានបត្រដែលកំពុងប្រើបច្ចុប្បន្ននេះ។

ប្រការ ២.-

មូលប្បទានបត្រស្តង់ដារថ្មីនេះ មានលក្ខណៈសម្គាល់ដូចតទៅ៖

១. លក្ខណៈទូទៅ

ក. ទំហំមូលប្បទានបត្រមាន៖ បណ្តោយ ១៨០មម ទទឹង ៩០មម

ខ. ពណ៌នៃមូលប្បទានប័ត្រ៖

- មូលប្បទានបត្រចារឹកជាប្រាក់រៀល មានពណ៌មាសស្រាល
- មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារ មានពណ៌មរកតស្រាល

គ. មូលប្បទានបត្រស្តង់ដាររបស់ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្តាល និងសាខា មានលក្ខណៈដូចគ្នាទាំងស្រុង លើកលែងតែអាសយដ្ឋានប៉ុណ្ណោះ។

២. លក្ខណៈពិសេស

សន្លឹកមូលប្បទានបត្រ ត្រូវបានបោះពុម្ពដោយក្រដាសពិសេស និងមានលក្ខណៈពិសេសដូចខាងក្រោម៖

- មានរូបបណ្តុះ (Watermark) ជារូបផ្កាច័ន្ទត្របកមូល ពង្រាយពាសពេញផ្ទៃក្រដាស
- លើផ្ទៃក្រដាសទាំងសងខាង មានរាយបង្កប់កំណាត់សរសៃអំបោះពិសេស (Tissue) ចំនួនពីរប្រភេទ ក្នុងនោះមួយប្រភេទមើលឃើញមានពណ៌ទឹកក្រូច និងពណ៌បៃតង គ្មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយទេ និងមួយប្រភេទទៀតមើលមិនឃើញមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ទឹកក្រូច និងពណ៌បៃតង
- ផ្នែខាងឆ្វេងនៃមូលប្បទានបត្រ រួមទាំងសញ្ញាធនាគារផង (រូបធំព្រាលៗ) ត្រូវបានបោះពុម្ពដោយទឹកខ្មៅទិស្សមាន មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌មាសចំពោះមូលប្បទានបត្រចារឹកជាប្រាក់រៀល មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌មរកតចំពោះមូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក

- ផ្នែកកណ្តាលនៃផ្ទៃខាងស្តាំរបស់សន្លឹកមូលប្បទានបត្រ ត្រង់ប្រអប់រាងបួនជ្រុងទ្រវែងទាំងពីរត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេស មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ស៊ីជម្ពូ
- គំនូសបន្ទាត់ទាំង ៦ កំណាត់លើមូលប្បទានបត្រ សុទ្ធតែត្រូវបានផ្គុំឡើងដោយអក្សរតូចល្អិត "NATIONAL BANK OF CAMBODIA" និង
- លេខមូលប្បទានបត្រ នៅជ្រុងលើខាងស្តាំ ត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេសពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ។

ប្រការ ៣.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងគ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៤.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០១៨-៣០២ ប្រ.ក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មី
របស់ធនាគារជាតិនៃកម្ពុជា

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជាចំនួន ២ (ពីរ) ប្រភេទគឺមូលប្បទានបត្រចារឹកជាប្រាក់រៀល និងមូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក ដើម្បីបង្កើនគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃការទូទាត់តាមរយៈមូលប្បទានបត្រ។

ប្រការ ២.-

ប្រកាសនេះមានគោលដៅកំណត់លក្ខណៈសម្គាល់នៃមូលប្បទានប័ត្រគំរូថ្មីរបស់ ធនាគារជាតិនៃកម្ពុជាដែលនឹងត្រូវជំនួសមូលប្បទានប័ត្រដែលកំពុងប្រើបច្ចុប្បន្ន។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអតិថិជនដែលមានគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា។

ប្រការ ៤.-

មូលប្បទានបត្រគំរូថ្មីនេះ មានលក្ខណៈសម្គាល់ដូចតទៅ៖

ក- លក្ខណៈទូទៅ

១- ទំហំមូលប្បទានបត្រ៖ បណ្តោយ ១៨០មម ទទឹង ៩០មម

២- ពណ៌នៃមូលប្បទានបត្រ

២.១. ប្រភេទប្រាក់រៀល

- ផ្នែខាងឆ្វេង៖ ពណ៌ទង់ដែងស្រាល និងផ្នែខាងស្តាំ៖ ពណ៌មរកតស្រាល
- ទីតាំងសម្រាប់ចុះចំនួនប្រាក់៖ ពណ៌លឿង
- ទីតាំងសម្រាប់ចុះហត្ថលេខាបហារ័ក៖ ពណ៌លឿងស្រាល

២.២. ប្រភេទប្រាក់ដុល្លារអាមេរិក

- ផ្នែខាងឆ្វេង៖ ពណ៌មរកតស្រាល និងផ្នែខាងស្តាំ៖ ពណ៌ទង់ដែងស្រាល
- ទីតាំងសម្រាប់ចុះចំនួនប្រាក់៖ ពណ៌ផ្នែមេយ
- ទីតាំងសម្រាប់ចុះហត្ថលេខាបហារ័ក៖ ពណ៌ផ្នែមេយស្រាល

៣- មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជាស្នាក់ការកណ្តាល និងសាខា គឺមានលក្ខណៈដូចគ្នាទាំងស្រុង លើកលែងតែអាសយដ្ឋានប៉ុណ្ណោះ។

ខ- លក្ខណៈពិសេស

សន្លឹកមូលប្បទានបត្រ ត្រូវបានបោះពុម្ពដោយក្រដាសពិសេស និងមានលក្ខណៈ ពិសេសដូចខាងក្រោម៖

១. ផ្ទៃក្រដាសមានរូបបណ្តុះពង្រាយសព្វ និងមានបង្កប់ក្នុងក្រដាសនូវ កំណាត់ខ្សែសុវត្ថិភាពឆ្លាវៗ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពន្លឺពណ៌លឿងក្រហម និងពណ៌ផ្ទៃមេឃ។

២. ផ្នែកកន្ទុយសន្លឹកមានគំនូសបន្ទាត់ពិសេសមិនរៀបរយ និងមានកម្រាស់បន្ទាត់ប្រែប្រួលមិនស្មើគ្នា ។

៣. ផ្នែកកណ្តាលមានរូបឡូហ្គោធនាគារជាតិនៃកម្ពុជាព្រលឹងៗ ផ្តុំដោយគំនូសបន្ទាត់ពិសេសមិនរៀបរយ ដែលមានកម្រាស់ប្រែប្រួលមិនស្មើគ្នា។

៤. ផ្ទៃជុំវិញរូបឡូហ្គោមានរូបភាពផ្ទៃលម្អ បង្កើតដោយគំនូសបន្ទាត់ពិសេសមិនរៀបរយ។

៥. ផ្ទៃកណ្តាលមានពណ៌ឥន្ទធនូពីរពណ៌ ក្នុងនោះពណ៌មួយមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌លឿង។

៦. លេខមាលាពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ទឹកក្រូច។

៧. ចំណុចខាងលើទីតាំងសម្រាប់ចុះចំនួនប្រាក់ត្រូវបានបោះពុម្ពដោយទឹកខ្មៅអទិស្សមាន មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជារូបពណ៌លឿងនៃឡូហ្គោធនាគារជាតិនៃកម្ពុជា អក្សរ "CHECK NBC" និងផ្ទៃពិសេសប្រឆាំងការកោសលុប។

៨. ទីតាំងសម្រាប់ចុះកាលបរិច្ឆេទដែលមានអក្សរនិងស៊ុមព័ទ្ធជុំវិញ មើលឃើញព្រលឹងៗ បង្កើតឡើងដោយកំណាត់បន្ទាត់ខ្លីៗ។

៩. ទីតាំងសម្រាប់ចុះហត្ថលេខាបហារ៉កមានផ្ទៃបោះពុម្ពលម្អ បង្កើតឡើងដោយគំនូសបន្ទាត់ពិសេសមិនរៀបរយនិងមានកម្រាស់បន្ទាត់ផ្សេងៗគ្នា។

១០. នៅផ្នែកខាងឆ្វេងជ្រុងលើមានរូបឡូហ្គោធនាគារជាតិនៃកម្ពុជា បោះពុម្ពដោយទឹកខ្មៅមានធាតុលោហៈពណ៌ប្រាក់ និងពណ៌ទង់ដែង។

១១. អក្សរដ៏តូចល្អិត "NATIONAL BANK OF CAMBODIA" ផ្តុំបង្កើតជា បន្ទាត់ឆ្លាវៗ អាចមើលឃើញច្បាស់ដោយកែវពង្រីក។

១២. នៅផ្នែកខាងក្រោមមានរូបភាពក្បាច់លំអ បោះពុម្ពដោយគំនូសបន្ទាត់ពិសេសប្រណិត និងមានការប្តូរពីពណ៌មួយទៅពណ៌មួយទៀតដោយរលូន។

ប្រការ ៥.-

អតិថិជនរបស់ធនាគារជាតិនៃកម្ពុជា ត្រូវយកមូលប្បទានបត្រគំរូចាស់មកប្តូរយកមូលប្បទានបត្រគំរូថ្មីយ៉ាងយូរបំផុតត្រឹមរយៈពេល ១ខែ បន្ទាប់ពីថ្ងៃចុះហត្ថលេខានៃប្រកាសនេះ។

ប្រការ ៦.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងគ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទនិងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្ត យ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨
ទេសាភិបាល
ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

ធ៥-០១៨-៧៤២ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា

យោងប្រកាសលេខ ធ៥-០១៨-៣០២ ប្រ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ ស្តីពី ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងអតិថិជនទាំងអស់ដែលមានគណនីចរន្តនៅធនាគារជាតិនៃកម្ពុជាឱ្យបានជ្រាបថា មូលប្បទានបត្រគំរូថ្មីជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកនឹងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អតិថិជនរបស់ធនាគារជាតិនៃកម្ពុជា ត្រូវយកមូលប្បទានបត្រគំរូចាស់មកប្តូរយកមូលប្បទានបត្រគំរូថ្មី ចាប់ពីថ្ងៃនេះរហូតដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ជាកំហិត។ ធនាគារជាតិនៃកម្ពុជានឹងមិនគិតកម្រៃសេវាលើការផ្លាស់ប្តូរនេះទេ។ ការទូទាត់មូលប្បទានបត្រគំរូចាស់នឹងត្រូវអស់សុពលភាពនៅត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងអតិថិជនទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្តដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨
ជ. អគ្គនាយកបច្ចេកទេស
ហត្ថលេខានិងត្រា៖ **ឃូ ឆុណ្ឌី**

សូមទំនាក់ទំនង៖
លេខទូរសព្ទ៖ (៨៥៥-២៣) ៧២៤ ៩៦៣ EXT. ១០៥២
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៥២
សារអេឡិចត្រូនិក៖ banking@nbc.org.kh

ឆ.៣. កម្រៃសេវា

ធ៥-០៣-០១៦ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
ការផ្ទេរទៅ-មក ខេត្ត-ក្រុង និងការកំណត់កម្រៃសេវា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អតិថិជនដែលមានបើកគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា និងតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ជ្រាបថា ធនាគារជាតិនៃកម្ពុជាផ្តល់សេវាផ្ទេរប្រាក់ទៅ-មកខេត្តក្រុង តាមរយៈនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងចាប់ពីពេលជូនដំណឹងនេះតទៅ។

I. អតិថិជនដែលទទួលបានឧត្តមការផ្តល់សេវា

១- <u>ផ្ទេរប្រាក់ពីធនាគារជាតិនៃកម្ពុជាទៅសាខាធនាគារជាតិខេត្ត-ក្រុង៖</u>

- ក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបើកគណនីនៅនាយកដ្ឋានប្រតិបត្តិការ

២- <u>ផ្ទេរប្រាក់ពីសាខាធនាគារខេត្ត-ក្រុងមកធនាគារជាតិនៃកម្ពុជា</u>

- រតនាគារខេត្ត-ក្រុង
- មន្ទីរស្ថាប័នខេត្ត-ក្រុង កំពង់ផែ អគ្គិសនី រដ្ឋាករទឹក
- សាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គម
- អាជីវករប្តូរប្រាក់ និងលោហធាតុមានតម្លៃដែលមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

II. បែបបទផ្ទេរប្រាក់

អតិថិជនត្រូវបំពេញនូវបញ្ជាផ្ទេរប្រាក់តាមគំរូលេខ ១១ ចំពោះអតិថិជនជានីតិបុគ្គល ឬតាមគំរូលេខ ១២ ចំពោះ អតិថិជនជាឯកត្តជន ដោយភ្ជាប់ជាមួយនូវមូលប្បទានបត្រដកប្រាក់ពីគណនីរបស់ខ្លួន។ (សូមភ្ជាប់ជាមួយនេះនូវគំរូលេខ ១១ និងគំរូលេខ ១២)

III. កម្រៃសេវា

- កម្រៃសេវាត្រូវគិតលើចំនួនប្រាក់ផ្ទេរ ០.១០% (ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិក)
- កម្រិតអប្បបរមា ១២.០០០ រៀល ឬ ៣ ដុល្លារ ក្នុងប្រតិបត្តិការផ្ទេរប្រាក់១លើក ការផ្ទេរប្រាក់ ដែលជាថវិការដ្ឋមិនគិតកម្រៃសេវាទេ។

កម្រៃសេវាត្រូវបានគិតយកពីអតិថិជននៅធនាគារផ្តើមប្រតិបត្តិការ ហើយអតិថិជនមិនមានការចំណាយកម្រៃសេវានៅពេលទទួលប្រាក់ទៀតឡើយ។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៣

អគ្គនាយក

ហត្ថលេខានិងត្រា៖ **តាល់ ណៃអ៊ីម**

គំរូលេខ១១

ថ្ងៃទី ខែ ឆ្នាំ

.....Date.....

បញ្ជាផ្ទេរប្រាក់

Transfer Order

សូមជម្រាបជូន

ឯកឧត្តម / លោកជំទាវ សាខាធនាគារជាតិនៃកម្ពុជា

TO: Manager of the National Bank of Cambodia

ខេត្ត-ក្រុង

Branch.....

- អង្គភាព/ស្ថាប័ន/គ្រឹះស្ថាន៖

  Equity/Institution.....

- អ្នកដែលទទួលសិទ្ធិ៖

  Authorized Person.....

- យោងលិខិតផ្ទេរសិទ្ធិលេខ ចុះថ្ងៃទី

  Reference the Proxy No.....Date.....

- ចំនួនប្រាក់៖

  Amount.....

- អ្នកទទួលប្រាក់៖

  Beneficiary Name.....

- លេខគណនី៖

  Account Number.....

- ធនាគារអ្នកទទួលប្រាក់៖

  Beneficiary Bank.....

- អាសយដ្ឋាន៖

  Address of Beneficiary Bank.....

- **បញ្ជាពិសេស** ៖ សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក/លោកស្រី

  Special Instruction : please debit our account n.....
  opened with your bank.

ហត្ថលេខា

Signature

គំរូលេខ១២

ថ្ងៃទី ខែ ឆ្នាំ

.....Date.....

បញ្ជាផ្ទេរប្រាក់

Transfer Order

សូមជម្រាបជូន

ឯកឧត្តម / លោកជំទាវ សាខាធនាគារជាតិនៃកម្ពុជា

TO: Manager of the National Bank of Cambodia

ខេត្ត-ក្រុង

Branch.....

- អ្នកផ្ទេរប្រាក់៖

  Name of transferor.....
- អាសយដ្ឋាន៖

  Address.....
- អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន៖

  ID Card or Passport No.....
- ចំនួនប្រាក់៖

  Amount.....
- អ្នកទទួលប្រាក់៖

  Beneficiary Name.....
- លេខគណនី៖

  Account Number.....
- ធនាគារអ្នកទទួលប្រាក់៖

  Beneficiary Bank.....
- **បញ្ជាពិសេស** ៖ សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក / លោកស្រី
- **Special Instruction** : please debit our account n.....
  opened with your bank

ហត្ថលេខា

Signature

ធ៥-០៩-៦៣៨ ស.ជ.ណ

សេចក្តីជូនដំណឹង
អំពី
ការកំណត់កម្រៃសេវាផ្ទេរប្រាក់ទៅ-មកក្នុងប្រទេស
តាមរយៈធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយស សូមជូនដំណឹងដល់អតិថិជនដែលបើកគណនីនៅធនាគារជាតិនៃកម្ពុជា ដែលមានតម្រូវការផ្ទេរប្រាក់តាមគណនីទៅ-មក រវាងនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិនៃកម្ពុជា ដ្រាបដូចខាងក្រោម៖

- អតិថិជនត្រូវធ្វើបញ្ជាផ្ទេរប្រាក់ (ដូចគំរូជូនភ្ជាប់) ដោយភ្ជាប់ជាមួយនូវមូលប្បទានបត្រដកប្រាក់ពីគណនីរបស់ខ្លួន។
- កម្រៃសេវាត្រូវបានគិត ០.១០% លើទឹកប្រាក់ផ្ទេរ (មិនត្រូវបានគិតចំពោះការផ្ទេរថវិការដ្ឋ)
- កម្រិតអប្បបរមា ១២.០០០ រៀល ឬ ៣ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ
- កម្រិតអតិបរមា ៥.០០០.០០០ រៀល ឬ ១.០០០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ

កម្រៃសេវាត្រូវបានគិតដោយធនាគារផ្តើមធ្វើប្រតិបត្តិការ អតិថិជនមិនមានការចំណាយកម្រៃសេវានៅពេលទទួលប្រាក់ទៀតឡើយ។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩

ទេសាភិបាល

ជា ចាន់តូ

ធ៥-០៩-៨៦០ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

ជម្រាបមក
លោក លោកស្រី អគ្គនាយកគ្រប់ធនាគារ
ជាសមាជិកសភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា

កម្មវត្ថុ ៖ ការបង់កម្រៃសេវាសភាជាត់ទាត់ប្រចាំឆ្នាំ

យោង ៖ វិធាននិងនីតិវិធីសម្រាប់សភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោក-លោកស្រី អគ្គនាយកគ្រប់ធនាគារជាសមាជិកសភាជាត់ទាត់មូលប្បទានបត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកឱ្យបានជ្រាបថា ដើម្បីឱ្យស្របតាមវិធាន និងនីតិវិធីសម្រាប់សភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា ឧបសម្ព័ន្ធ ៧ ស្តីពីការយកកម្រៃសេវាសភាជាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំណត់កម្រៃសេវាការងារជាត់ទាត់មូលប្បទានបត្រជា ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ៣.២០០.០០០រៀល ក្នុង ១ ឆ្នាំ។

កម្រៃសេវាថ្មីនេះ នឹងត្រូវបានអនុវត្តពីឆ្នាំ២០១០ តទៅ រហូតដល់មានការជូនដំណឹងជាថ្មី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីអគ្គនាយក មេត្តាជ្រាប និងអនុវត្តតាមការគួរ។

សូម លោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

អគ្គនាយក
តាល់ ណៃអ៊ីម

ធ៥-០១០-៥៨៦ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០

ជម្រាបមក
លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាជាត់ទាត់

កម្មវត្ថុ៖ ការយកកម្រៃសេវាសភាជាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ជាកពិន័យមូលប្បទានបត្របញ្ជូនត្រឡប់នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត

យោង ៖ វិធាននិងនីតិវិធីសម្រាប់សភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន លោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាជាត់ទាត់ឱ្យបានជ្រាបថា ដើម្បីឱ្យស្របតាមវិធាន និងនីតិវិធីសម្រាប់សភាជាត់ទាត់ធនាគារជាតិនៃកម្ពុជា ឧបសម្ព័ន្ធ ៧ ស្តីពីការយកកម្រៃសេវាសភាជាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំណត់យកកម្រៃសេវាសភាជាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ជាកពិន័យមូលប្បទានបត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ៖

១- កម្រៃសេវាសភាជាត់ទាត់មូលប្បទានបត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ចំនួន ៣.២០០.០០០ រៀល ក្នុងមួយឆ្នាំ ដូចគ្នា។

២- ការជាកពិន័យមូលប្បទានបត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ៨.០០០ រៀល ក្នុងមួយសន្លឹក ដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំ និងប្រាក់ជាកពិន័យមូលប្បទានបត្របញ្ជូនត្រឡប់នេះ នឹងចាប់អនុវត្តពីឆ្នាំ២០១១ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាជាត់ទាត់ដើម្បីសហការអនុវត្ត។

សូម លោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

អគ្គនាយក
តាល់ ណៃអ៊ីម

ធ៥-០១១-១៣៦ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

ជម្រាបមក
លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត

កម្មវត្ថុ ៖ ការយកកម្រៃសេវាសភាជាត់ទាត់ប្រចាំឆ្នាំ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត
យោង ៖ ចំណារឯកភាពរបស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត ឱ្យបានជ្រាបថា ដើម្បីជំរុញនិងលើកទឹកចិត្តក្នុងការប្រើប្រាស់មូលប្បទានបត្រនៅតាមបណ្តាខេត្តឱ្យកាន់តែច្រើនថែមទៀតនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែសម្រួលការយកកម្រៃសេវាសភាជាត់ទាត់ប្រចាំឆ្នាំ លើមូលប្បទានបត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ២.០០០.០០០ រៀល ក្នុងមួយឆ្នាំដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំនេះ នឹងចាប់អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាជាត់ទាត់ដើម្បីសហការអនុវត្ត។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

អគ្គនាយកបច្ចេកទេស
ឌួន សុខា

ធ៥-០១៨-៧៥៩ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
កម្រៃសេវាគណនី និងសេវាសម្រាប់ការផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ
នៅធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់អតិថិជនដែលមានគណនីនៅធនាគារជាតិនៃកម្ពុជាឱ្យបានជ្រាបថា កម្រៃសេវាគណនី និងសេវាសម្រាប់ការផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ NBC Online Banking System (NBC OBS) និងប្រព័ន្ធ NBC Platform (NBCP) នៅធនាគារជាតិនៃកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម៖

១) កម្រៃសេវាគណនី

- បញ្ជាក់សមតុល្យគណនី	ម្តងចំនួន ៨០.០០០ រៀល
- ផលិតរបាយការណ៍គណនីបន្ថែម	ម្តងចំនួន ៤០.០០០ រៀល
- ប្តូរប័ណ្ណគំរូហត្ថលេខា	ម្តងចំនួន ៤០.០០០ រៀល

២) កម្រៃសេវាសម្រាប់ការផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ

- ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ NBC OBS	ម្តងចំនួន ៤០.០០០ រៀល
- ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ NBCP	ម្តងចំនួន ៤០.០០០ រៀល

កម្រៃសេវាខាងលើគឺត្រូវលើកលែងចំពោះអតិថិជនដែលជាស្ថាប័នរដ្ឋ។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨
អគ្គនាយកបច្ចេកទេស
ហត្ថលេខានិងត្រា៖ **ជា សិរី**

សូមទំនាក់ទំនង៖
លេខទូរសព្ទ ៖(៨៥៥-២៣) ៧២៤ ៩៦៣ EXT. ១០៥២
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៥២
សារអេឡិចត្រូនិក ៖ banking@nbc.org.kh

ធ៥-០១៩-១០៤៩ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
ការបង់កម្រៃពីការប្រើប្រាស់
សេវា NBC Online Banking System (OBS)

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានដែលជាសមាជិកនៃប្រព័ន្ធ OBS ទាំងអស់ជ្រាបថា ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង់កម្រៃពីការប្រើប្រាស់សេវា OBS ចាប់ពីឆ្នាំ២០២០ នេះតទៅ នីតិវិធីនៃការបង់កម្រៃនឹងត្រូវអនុវត្តដូចខាងក្រោម៖

១- ការបង់កម្រៃប្រចាំឆ្នាំ

- ធនាគារជាតិនៃកម្ពុជានឹងកាត់កម្រៃប្រចាំឆ្នាំ ដោយស្វ័យប្រវត្តិនៅក្នុងសប្តាហ៍ទី២ នៃខែមករានៃឆ្នាំនីមួយៗ។
- ចំពោះសមាជិកថ្មី កម្រៃប្រចាំឆ្នាំដំបូងនឹងត្រូវបានកាត់ដោយស្វ័យប្រវត្តិ នៅពេលទទួលបានការអនុញ្ញាតចូលជាសមាជិកប្រព័ន្ធ OBS។

២- ការជាវ E-Token

- ធនាគារជាតិនៃកម្ពុជានឹងកាត់កម្រៃជាវ E-Token ដែលត្រូវប្រើប្រាស់ជាមួយប្រព័ន្ធ OBS ដោយស្វ័យប្រវត្តិ តាមចំនួន Authorizer ដែលស្នើសុំបន្ថែមជាក់ស្តែង។
- ចំពោះសមាជិកថ្មី កម្រៃនេះនឹងត្រូវបានកាត់ដោយស្វ័យប្រវត្តិ តាមចំនួន Authorizer នៅពេលទទួលបានការអនុញ្ញាតចូលជាសមាជិក OBS។

លិខិតរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៥-០១៨-៣៤៩ ស.ជ.ណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៨ ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ តទៅ។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩
ជ.អគ្គនាយកបច្ចេកទេស
អគ្គនាយករងបច្ចេកទេស
ហត្ថលេខានិងត្រា៖ **តាន់ សុខាន់**

៩. ការគ្រប់គ្រងក្រដាសប្រាក់

ធ៣-៩៧-៥៧៦ ស.ជ.ណ

សេចក្តីជូនដំណឹង

ក្នុងពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា បានទទួលព័ត៌មានថា៖ មានបងប្អូនយើងខ្លះបានយកប្រាក់គំរូ (SPECIMEN) ដែលគេទុកមើល ឬទុកជាអនុស្សាវរីយ៍ ទៅចាយវាយទិញទំនិញផ្សេងៗធ្វើឱ្យមានការភាន់ច្រឡំក្នុងទីផ្សារ។

ដើម្បីចៀសវាងភាពមិនសមស្របនេះ ធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ជូនសាធារណជនឱ្យបានជ្រាបថា៖ បណ្តាប្រាក់គំរូគ្រប់ប្រភេទគឺគ្រាន់តែចែកជូនដល់វរៈជន និងអ្នកសារព័ត៌មានមួយចំនួនក្នុងពិធីប្រកាសចាយប្រាក់ថ្មីកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៥ សម្រាប់ផ្សព្វផ្សាយនិងពន្យល់ដល់ប្រជារាស្ត្រឱ្យស្គាល់ពីភិនភាគរបស់ប្រាក់រៀលថ្មីតែប៉ុណ្ណោះ គឺមិនបានអនុញ្ញាតឱ្យយកទៅចាយវាយឡើយ។ ប្រាក់គំរូចាប់ពីប្រភេទ ១.០០០ រៀល ដល់ ៥០.០០០ រៀល គឺមានបោះអក្សរឡាតាំង ពណ៌ក្រហម SPECIMEN លើផ្ទៃទាំងសងខាង។ ចំពោះប្រាក់គំរូប្រភេទ ១០០.០០០ រៀលវិញ គឺមានជាអក្សរឡាតាំង SPECIMEN ដែរ តែចោះរន្ធពីម្ខាងទៅម្ខាង អក្សរនេះមើលឃើញច្បាស់មិនអាចភាន់ច្រឡំបានឡើយ។ ម៉្យាងទៀត ប្រាក់គំរូគ្រប់ប្រភេទទាំងនេះ មានលេខស៊េរីសុទ្ធតែលេខសូន្យៗទាំង៧ខ្ទង់។

ធនគារជាតិ សូមរំឭកថា ប្រាក់គំរូដូចបានរៀបរាប់ខាងលើ ពុំមានតម្លៃអាចចាយវាយបានទេ។ ជនណាយកប្រាក់គំរូ (SPECIMEN) ទៅចាយវាយតាមទីផ្សារ គឺចាត់ទុកជាជនប្រព្រឹត្តអំពើតែបន្លំ ហើយជនជំពូកនោះ នឹងត្រូវជាប់ពិរុទ្ធយ៉ាងតឹងរឹងបំផុត។

ហេតុនេះ សូមសាធារណជន ពិនិត្យឱ្យបានច្បាស់លាស់មុននឹងចាយ ឬទទួលយកក្រដាសប្រាក់គ្រប់ប្រភេទ ចៀសវាងការភាន់ច្រឡំទទួលយកប្រាក់គំរូ ដូចបានរៀបរាប់ខាងលើ ព្រោះធនាគារជាតិត្រូវដកហូតទុកដោយគ្មានថ្នូរឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៧

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ចាង ម៉ៃឆលាត**

ធ១-០៩-៥៣៥ ស.ជ.ណ

សេចក្តីជូនដំណឹង

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ដោយសារប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះ ប្រាក់ដុល្លារអាមេរិកក្លែងក្លាយត្រូវបានយកមកចាយវាយនៅក្នុងប្រទេសកម្ពុជាជាច្រើន ដែលជាហេតុនាំឱ្យមានការខាតបង់ដល់អ្នកដែលបានទទួលយកប្រាក់ដុល្លារអាមេរិកក្លែងក្លាយទាំងនោះ។ ដើម្បីទប់ស្កាត់បញ្ហានេះ ធនាគារជាតិនៃកម្ពុជានឹងដកហូតយកប្រាក់ដុល្លារអាមេរិកក្លែងក្លាយទាំងឡាយណា ដែលត្រូវបានយកមកបង់ចូលបេឡាធនាគារជាតិនៃកម្ពុជា ដោយមិនប្រគល់ឱ្យអ្នកបង់ប្រាក់វិញឡើយ ព្រមទាំងបោះត្រាដែលមានពាក្យថា *"ប្រាក់ក្លែងក្លាយ"* លើប្រដាសប្រាក់នោះទៀតផង។

ទន្ទឹមនេះ ដើម្បីរួមចំណែកក្នុងការទប់ស្កាត់នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវសហការដកហូតប្រាក់ដុល្លារអាមេរិកក្លែងក្លាយពីអតិថិជនរបស់ខ្លួន ហើយយកមកប្រគល់ឱ្យធនាគារជាតិនៃកម្ពុជាផងដែរ។

អាស្រ័យហេតុនេះ ដើម្បីចៀសវាងការខាតបង់ ធនាគារជាតិនៃកម្ពុជាសុំឱ្យសាធារណជនពិនិត្យពិច័យឱ្យបានម៉ត់ចត់មុននឹងទទួលយកក្រដាសប្រាក់ដុល្លារអាមេរិក។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩

ទេសាភិបាល

ហត្ថលេខានិងត្រា៖ **ជា ចាន់តូ**

សេចក្តីជូនដំណឹង
ស្តីពី
ការទទួលរាប់ក្រដាសប្រាក់ជារូបិយវត្ថុជាតិនិងរូបិយប័ណ្ណ

ដើម្បីរៀបចំឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយល្អ ក្នុងការរាប់ក្រដាសប្រាក់ជា រូបិយវត្ថុជាតិ និងរូបិយប័ណ្ណ នៅបញ្ជរបេឡា និងការិយាល័យរាប់-ស្រាល់ជ្រើសនៃនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់អតិថិជនទាំងអស់ឱ្យបានជ្រាបថា៖

១- ធនាគារជាតិនៃកម្ពុជាទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចាប់ផ្តើមទទួលចំណូលពីអតិថិជនចាប់ពីម៉ោង ៧:៣០ នាទីព្រឹក ដល់ម៉ោង ២:០០ រសៀល ចំណែកប្រតិបត្តិការផ្សេងទៀត នៅដំណើរការរហូតដល់ម៉ោង ៣:០០ រសៀល រៀងរាល់ថ្ងៃធ្វើការ។ ដោយឡែក ការិយាល័យរាប់-ស្រាល់ជ្រើស ចាប់ផ្តើមទទួលចំណូលពីអតិថិជនចាប់ពីម៉ោង ៧:៣០ នាទីព្រឹក និងបញ្ចប់នៅម៉ោង ១២:០០ ថ្ងៃត្រង់

២- ក្រដាសប្រាក់គ្រប់ប្រភេទ ត្រូវតែរៀបចំទៅតាមក្រដាសប្រាក់នីមួយៗ ដោយរូបភាពត្រួតស៊ីគ្នា ត្រូវចងជាធ្នាប់ (១០០ សន្លឹក) និងចងជាដុំ (១០០០ សន្លឹក) ដោយរុំគ្រីបឱ្យបានត្រឹមត្រូវមុននឹងបង់ចូលបញ្ជរបេឡា

៣- ធនាគារជាតិនៃកម្ពុជា ទទួលយករូបិយប័ណ្ណពីអតិថិជនរបស់ខ្លួន (គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) ដែលមានគណនីនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលក្រដាសប្រាក់នោះ ជាក្រដាសប្រាក់ពិតប្រាកដ មិនក្លែងក្លាយ ហើយមានគុណភាពសមស្រប។ ធនាគារជាតិនៃកម្ពុជា មិនមានកាតព្វកិច្ចទទួលក្រដាសប្រាក់ជារូបិយប័ណ្ណបរទេសចាស់ ទក់ រហែក មានស្នាមប្រឡាក់ ឆេះរោលដោយប្រការណាមួយ ហើយប្តូរយកក្រដាសប្រាក់ថ្មីបានឡើយ

៤- ធនាគារជាតិនៃកម្ពុជា ធ្វើប័ណ្ណបង់ប្រាក់ជូនអតិថិជនក្នុងថ្ងៃ នូវចំនួនទឹកប្រាក់ដែលបានធ្វើការរាប់និងស្រាល់ជ្រើសរួច ចំណែកប្រាក់ដែលនៅសល់ មិនធ្វើប័ណ្ណបង់ប្រាក់ជូនឡើយ តែអាចបិទផ្តុំបេឡើទុកនៅធនាគារជាតិនៃកម្ពុជាដោយធ្វើជាលិខិតប្រគល់-ទទួលឱ្យបានច្បាស់លាស់ ដើម្បីធ្វើការរាប់-ស្រាល់ជ្រើសនៅថ្ងៃធ្វើការបន្ទាប់ លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិផ្សេងៗ

៥- ពេលបើកប្រាក់ អតិថិជនត្រូវរាប់ពិនិត្យសាច់ប្រាក់ឱ្យបានត្រឹមត្រូវ មុននឹងចាកចេញពីបញ្ជរបេឡា រាល់ករណីបាត់បង់ ធនាគារជាតិនៃកម្ពុជានឹងមិនទទួលខុសត្រូវឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦

អគ្គបេឡា

ហត្ថលេខា៖ **ថា យ៉ាវ**

ធ៥-០១៧-២៩២ ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី
នីតិវិធីនៃការបើកប្រាក់ពីធនាគារជាតិនៃកម្ពុជា

ដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពក្នុងប្រតិបត្តិការបើកប្រាក់ ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាម្ចាស់គណនីទាំងអស់មេត្តាជ្រាបថា រាល់ការបើកប្រាក់នៅធនាគារជាតិនៃកម្ពុជា គឺត្រូវប្រើ**មូលប្បទានបត្ររបស់ធនាគារជាតិនៃកម្ពុជា** ដោយភ្ជាប់មកជាមួយនូវឯកសារដែលមានសុពលភាពមួយចំនួន តាមករណីដូចខាងក្រោម៖

ក. ក្នុងករណីអ្នកបើកប្រាក់ជាអត្តគាហកលើមូលប្បទានបត្រ អ្នកបើកប្រាក់ត្រូវបង្ហាញប័ណ្ណសម្គាល់អត្តសញ្ញាណ (ច្បាប់ដើម) ដែលមានសុពលភាព ដូចជា៖
   - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
   - ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬ
   - លិខិតឆ្លងដែន (Passport) ឬ
   - លិខិតរដ្ឋបាលផ្លូវការរបស់ស្ថាប័នរដ្ឋ ឬអាជ្ញាធរមានសមត្ថកិច្ចដែលមានបិទរូបថត និងបញ្ជាក់អាសយដ្ឋានច្បាស់លាស់។

ខ. ក្នុងករណីអត្តគាហកផ្ទេរសិទ្ធិដោយធ្វើបិដ្ឋិលេខលើខ្នងមូលប្បទានបត្រ ឬផ្ទេរសិទ្ធិដោយអនុប័ត្រ អ្នកបើកប្រាក់ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណ ដូចក្នុងចំណុច (ក) ខាងលើ។

គ. ក្នុងករណីអត្តគាហកជាឈ្មោះអង្គភាពរដ្ឋ អ្នកបើកប្រាក់ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណដូចក្នុងចំណុច (ក) ខាងលើ ព្រមទាំងលិខិតឧទ្ទេសនាមអ្នកបើកប្រាក់ ឬលិខិតប្រគល់សិទ្ធិបើកប្រាក់។

ឃ.ក្នុងករណីអត្តគាហកជាឈ្មោះក្រុមហ៊ុន អ្នកបើកប្រាក់ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណដូចក្នុងចំណុច (ក) ខាងលើ និងលិខិតផ្ទេរសិទ្ធិបើកប្រាក់ (ករណីអ្នកបើកប្រាក់មិនមែនជាប្រធានក្រុមហ៊ុន) ព្រមទាំងប័ណ្ណប៉ាតង់ ឬលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម (បើជាច្បាប់ចម្លងត្រូវមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)។

សេចក្តីជូនដំណឹងលេខ ធ៥-០១១-៥៩២ សជណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧

អគ្គនាយកបច្ចេកទេស

ហត្ថលេខានិងត្រា៖ **ជា សីរី**

សេចក្តីជូនដំណឹង
ស្តីពី
ការបើកសាច់ប្រាក់ជារូបិយប័ណ្ណពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយស សូមជម្រាបជូនគ្រប់ក្រសួង-ស្ថាប័ន និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានគណនីនៅធនាគារជាតិនៃកម្ពុជាមេត្តាជ្រាបថា ដើម្បីឱ្យការសម្របសម្រួលសាច់ប្រាក់ជារូបិយប័ណ្ណ ទាំងនៅស្នាក់ការកណ្តាលនិងនៅសាខាធនាគារជាតិ នៃកម្ពុជារាជធានី-ខេត្ត ប្រព្រឹត្តទៅដោយរលូន ធនាគារជាតិនៃកម្ពុជា សូមកំណត់ការបើកសាច់ប្រាក់ដុល្លារអាមេរិក ដូចខាងក្រោម៖

ក. នៅស្នាក់ការកណ្តាល

- ការបើកសាច់ប្រាក់ដុល្លារអាមេរិក ខ្ពស់បំផុតត្រឹមចំនួនសរុប ២.000.000 ដុល្លារអាមេរិក (ពីរលានដុល្លារអាមេរិក) អាចដំណើរការបានក្នុងថ្ងៃ។

- ការបើកសាច់ប្រាក់ដុល្លារអាមេរិក លើសពីចំនួន ២.000.000 ដុល្លារអាមេរិក (ពីរលានដុល្លារអាមេរិក) ត្រូវជូនដំណឹងមកនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡាជាមុនយ៉ាងតិច២ថ្ងៃ នៃថ្ងៃធ្វើការ។

ខ. នៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត

ការបើកសាច់ប្រាក់ដុល្លារអាមេរិក ត្រូវអនុវត្តដោយផ្អែកលើទំហំប្រតិបត្តិការជាក់ស្តែងរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត នីមួយៗ។ ក្នុងករណី ការបើកសាច់ប្រាក់ដុល្លារអាមេរិកមានចំនួនច្រើន ត្រូវជូនដំណឹងមកនាយក-នាយិកា សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ជាមុនយ៉ាងតិច២ថ្ងៃ នៃថ្ងៃធ្វើការ។

សេចក្តីជូនដំណឹងទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ ត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០

អគ្គបេឡា

ហត្ថលេខានិងត្រា៖ **ថា យ៉ាវ**

សេចក្តីជូនដំណឹង

យោងតាមច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦។

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នៅក្នុងជំពូកទី៩ ស្តីពីរូបិយវត្ថុ ត្រង់មាត្រា ៥២ បានចែងថា៖ ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច។

អាស្រ័យហេតុនេះ សូមសាធារណជន ជាពិសេសគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្ត ហើយក្នុងករណីមានការសង្ស័យថា ក្រដាសប្រាក់ក្លែងក្លាយ សូមផ្ញើមកធនាគារជាតិនៃកម្ពុជា ដើម្បីស្នើសុំធ្វើកោសល្យវិច័យ។

សេចក្តីជូនដំណឹងលេខ ២០៧/៩៧ អ.ប ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៧ និងសេចក្តីជូនដំណឹងទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ ត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០

អគ្គបេឡា

ហត្ថលេខានិងត្រា៖ **ង៉ា យ៉ាង**

ឧបសម្ព័ន្ធ

តារាងបទប្បញ្ញត្តិពីឆ្នាំ២០១៧ ដល់ ពាក់កណ្តាលឆ្នាំ២០២១

១. ប្រកាសលេខ ធ៧-០១៧-១០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន។

២. សេចក្តីជូនដំណឹងលេខ ធ៥-០១៧-២៩២ ស.ជ.ណ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ស្តីពី នីតិវិធីនៃការបើកប្រាក់នៅធនាគារជាតិនៃកម្ពុជា។

៣. ប្រកាសលេខ ធ៥-០១៧-១៥៨ ប្រ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ស្តីពី ការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា។

៤. ប្រកាសលេខ ធ១៤-០១៧-១៦១ ប្រ.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

៥. សេចក្តីជូនដំណឹងលេខ ធ៥-០១៧-៧០០ ស.ជ.ណ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ស្តីពី ការដាក់ឱ្យប្រើប្រាស់ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP)។

៦. ប្រកាសលេខ ធ៧-០១៧-២៩៩ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៧. ប្រកាសលេខ ធ៧-០១៧-៣០០ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា។

៨. ប្រកាសលេខ ធ៧-០១៧-៣០១ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ធនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៩. ប្រកាសលេខ ធ១៤-០១៧-៣០៧ ប្រ.ក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Cambodian Shared Switch។

១០. ប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ។

១១. ប្រកាសលេខ ធ៧-០១៧-៣៣៥ ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី សវនកម្ម ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១២. ប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។

១៣. សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។

១៤. ប្រកាសលេខ ធ៧-០១៨-០៦៨ ប្រ.ក ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៥. សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.ក.ណ ចុះថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ស្តីពី ការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

១៦. សេចក្តីណែនាំលេខ ធ៥-០១៨-០០២ ស.ក.ណ.ន ចុះថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ លើការអនុវត្តប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានា (LPCO)។

១៧. ប្រកាសលេខ ធ១៥-០១៨-១៩៤ ប្រ.ក ចុះថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch)។

១៨. ប្រកាសលេខ ធ៧-០១៨-២៨២ ប្រ.ក ចុះថ្ងៃពុធ ៣រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។

១៩. ប្រកាសលេខ ធ៥-០១៨-៣០២ ប្រ.ក ចុះថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា។

២០. សេចក្តីជូនដំណឹងលេខ ធ៥-០១៨-៧៤២ ស.ជ.ណ ចុះថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី មូលប្បទានបត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា។

២១. សេចក្តីជូនដំណឹងលេខ ធ៥-០១៨-៧៥៩ ស.ជ.ណ ចុះថ្ងៃអង្គារ ៨រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពី កម្រៃសេវាគណនី និងសេវាសម្រាប់ការផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធនៅធនាគារជាតិនៃកម្ពុជា។

២២. សេចក្តីជូនដំណឹងលេខ ធ៧-០១៩-១២២ ស.ជ.ណ ចុះថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពី កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

២៣. ប្រកាសលេខ ធ៧-០១៩-៤២០ ប្រ.ក ចុះថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការកែសម្រួលប្រការ ២២ នៃប្រកាសស្តីពី អ្នកដំណើរការតតិយភាគី។

២៤. ប្រកាសលេខ ធ១៤-០១៩-៤២៥ ប្រ.ក ថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay។

២៥. សេចក្តីជូនដំណឹងលេខ ធ៥-០១៩-១០៤៩ ស.ជ.ណ ចុះថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការបង់កម្រៃពីការប្រើប្រាស់សេវា NBC Online Banking System (OBS)។

២៦. សេចក្តីជូនដំណឹងលេខ ធ៧-០២០-១៣៤ ឆ.ត ចុះថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ស្តីពី សេចក្តីបញ្ជាក់បន្ថែមលើការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលរក្សានៅធនាគារជាតិនៃកម្ពុជា។

២៧. ប្រកាសលេខ ធ១៤-០២០-០៤៦ ប្រ.ក ចុះថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay។

២៨. សេចក្តីណែនាំលេខ ធ៧-០២០-៤១៧ ឆ.ត ចុះថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការគណនាព័ត៌មានហិរញ្ញវត្ថុបន្ថែមនិងនិយមន័យ "សម្ព័ន្ធញាតិ"។

២៩. ប្រកាសលេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៣០. សេចក្តីជូនដំណឹងលេខ ធ៧-០២០-៨៦៨ ឆ.ត ចុះថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ករណីលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធចំពោះរូបិយវត្ថុជាតិ។

៣១. សារាចរណែនាំបន្ថែមលេខ ធ៧-០២០-០០២ ស.រ.ណ.ន ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៣២. សារាចរណែនាំលេខ ធ៧-០២០-០០៣ ស.រ.ណ.ន ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពី សេចក្តីពន្យល់បន្ថែមទៅលើឧបសម្ព័ន្ធ ២ នៃប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព។

៣៣. ប្រកាសលេខ ធ១៤-០២០-៣៤៩ ប្រ.ក ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការដាក់ឱ្យប្រើប្រាស់ វិធាននិងនីតិវិធីប្រព័ន្ធបាគង។

៣៤. ប្រកាសលេខ ធ១៤-០២០-៣៥០ ប្រ.ក ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង។

៣៥. ប្រកាសលេខ ធ១៤-០២០-៣៥១ ប្រ.ក ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់។

៣៦. ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចែករំលែកព័ត៌មានឥណទាន។

៣៧. សេចក្តីជូនដំណឹងលេខ ធ៧-០២០-១៥៤៩ ឆ.ត ចុះថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ ស្តីពី បញ្ជីរាយនាមឯកសារ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវភ្ជាប់ឯកសារជូនជាមួយសំណើសុំផ្សេងៗ មកធនាគារជាតិនៃកម្ពុជា។

៣៨. សេចក្តីជូនដំណឹងលេខ ០៩៩-២០ អ.ប ចុះថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពី ការបើកសាច់ប្រាក់ជារូបិយប័ណ្ណពីធនាគារជាតិនៃកម្ពុជា។

៣៩. សេចក្តីជូនដំណឹងលេខ ១០០-២០ អ.ប ចុះថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពី ការដកហូតយកក្រដាសប្រាក់រៀលក្លែងក្លាយ។

៤០. ប្រកាសលេខ ធ៩-០២១-០៥២ ប្រ.ក ចុះថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ។

៤១. ប្រកាសលេខ ធ៧-០២១-១០៥ ប្រ.ក ចុះថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការធ្វើអាជីវកម្មបេឹងកាសូរេន។

៤២. ប្រកាសលេខ ធ៦-០២១-១៨៤ ប្រ.ក ចុះថ្ងៃចន្ទ ១២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ។

តារាងបទប្បញ្ញត្តិដែលកែសម្រួលលើបទប្បញ្ញត្តិផ្សេងៗ

១. ប្រកាសលេខ ធ៧-០២-១៤៦ ប្រ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០១-១៣៧ ប្រ.ក ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។

២. ប្រកាសលេខ ធ៧-០៤-២០៦ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ។

៣. ប្រកាសលេខ ធ៧-០៥-២១២ ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីនីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៤. ប្រកាសលេខ ធ៧-០៦-២០៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ។

៥. ប្រកាសលេខ ធ៧-០៦-២០៨ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារឯកទេស។

៦. ប្រកាសលេខ ធ៧-០៦-២០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៧. ប្រកាសលេខ ធ៧-០៦-២១០ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាសស្តីពីសោហ៊ុយបង្កើនដើមទុនសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៨. ប្រកាសលេខ ធ៧-០៧-១៣៥ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ។

៩. ប្រកាសលេខ ធ៥-០១៧-១៤៨ ប្រ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ស្តីពី ការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា។

១០. ប្រកាសលេខ ធ៧-០១៩-៤២០ ប្រ.ក ចុះថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការកែសម្រួលប្រការ ២២ នៃប្រកាសស្តីពី អ្នកដំណើរការតតិយភាគី។

តារាងបទប្បញ្ញត្តិត្រូវបាននិរាករណ៍ និងបទប្បញ្ញត្តិមានប្រសិទ្ធភាពអនុវត្ត

បទប្បញ្ញត្តិត្រូវបាននិរាករណ៍	បទប្បញ្ញត្តិមានប្រសិទ្ធភាពអនុវត្ត
- បទប្បញ្ញត្តិលេខ ធ៧-៩៤-០០១ ប.ប៣ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៤ ស្តីពី លក្ខខណ្ឌសម្រាប់ធនាគារពាណិជ្ជ។	- ប្រកាសលេខ ធ៧-៩៧-១៤៧ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- បទប្បញ្ញត្តិលេខ ធ៥-៩៣-០១ ប.ប១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៣ ស្តីពី ការតម្កល់ប្រាក់បញ្ញើដើមទុនសម្រាប់ធានានៅធនាគារជាតិនៃកម្ពុជារបស់ធនាគារពាណិជ្ជដែលបានទទួលអាជ្ញាបណ្ណ។	- ប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ប្រាក់តម្កល់ធានាលើដើមទុន។ - ប្រកាសលេខ ធ៧-០៧-១៣៤ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហាសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-៩៦-១៥៣ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦ ស្តីពី អាជ្ញាបណ្ណរបស់ធនាគារដែលបង្កើតឡើងក្រោមទម្រង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក។	- ប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ។
- ធ៧-៩៥-០៣ ប.ប ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អនុបាតបង្គាហានិភ័យ។ - សារាចរណែនាំលេខ ធ៧-៩៥-០៣ ស.រ.ណ.ន ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អនុបាតបង្គាហានិភ័យ។	- ប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។
- ប្រកាសលេខ ធ៧-៩៥-៧៣ ប្រ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អត្រាជាគោលសម្រាប់បុនហិរញ្ញប្បទាន។	- ប្រកាសលេខ ធ៥-០១-២០១ ប្រ.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១ ស្តីពី ការកំណត់អត្រាការប្រាក់ជាគោលសម្រាប់បុនហិរញ្ញប្បទាន។

- បទបញ្ជាលេខ ធ៧-៩៥-០២ ប.ប.ជ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី ការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ។ - សារាចរណែនាំលេខ ធ៧-៩៥-០២ ស.រ.ណ.ន ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី កាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជមកធនាគារជាតិនៃកម្ពុជា។	- ប្រកាសលេខ ធ៧-០៦-២១១ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី កាលបរិច្ឆេទផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស។
- ប្រកាសលេខ ធ៧-០០-៥២ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។	- ប្រកាសលេខ ធ៧-០៦-២២៦ ប្រ.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- បទបញ្ជាលេខ ធ៧-៩៥-០១ ប.ប.ជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ធនាគារពាណិជ្ជ។ - សារាចរណែនាំលេខ ធ៧-៩៥-០០១ ស.រ.ណ.ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ធនាគារពាណិជ្ជ។	- ប្រកាសលេខ ធ៧-០៧-១៣៤ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៥-៩៣-២០៨ ប្រ.ក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការប្រើប្រាស់ភាសា និងឯកត្តារូបិយវត្ថុ សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍។	- ប្រកាសលេខ ធ៧-០៧-១៦៤ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជីកាគណនេយ្យ និងរាយការណ៍។
- ប្រកាសលេខ ធ៥-០១-៦៥ ប្រ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០១ ស្តីពី ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មី។	- ប្រកាសលេខ ធ៩-០៨-១៨៦ ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី មូលប្បទានបត្រស្តង់ដារ។
- សេចក្តីជូនដំណឹងលេខ ធ៥-០២-៥៩៣ សជណ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពី ការផ្លាស់ប្តូរអត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក។	- ប្រកាសលេខ ធ៥-០៩-០១១ ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក។

- បទប្បញ្ញត្តិលេខ ធ៧-៩៣-២៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗដោយស្ថាប័នរូបិយវត្ថុ។	- ប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ តារាងណែនាំ ស្តីពី រយៈពេលមូលដ្ឋានដែលត្រូវតម្កល់ និងថ្ងៃត្រូវរាយការណ៍ ត្រូវបានជំនួសដោយតារាងណែនាំថ្មីនៅរៀងរាល់ចុងឆ្នាំ។
- ប្រកាសលេខ ធ៥-៩៥-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៥ ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់។	- ប្រកាសលេខ ធ៧-០៩-២១៣ ប្រ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់។
- ប្រកាសលេខ ធ៩-៩៨-៣៩៣ ប្រ.ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវកម្មប្តូរប្រាក់។	- ប្រកាសលេខ ធ៩-០៩-២៣០ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពី ការផ្តល់អាជ្ញាបណ្ណឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់។
- ប្រកាសលេខ ធ៧-០០-៣៩ ប្រ.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៧-០០-៤៧ ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។	- ប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។
- ប្រកាសលេខ ធ៧-០៤-២០៥ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី សោហ៊ុយអាជ្ញាបណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ - ប្រកាសលេខ ធ៧-០៩-០១២ ប្រ.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីពី សោហ៊ុយអាជ្ញាបណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។	- ប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-៩៨-៣៦៦ ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពី កម្រិតកំណាត់នៃការយកកម្រៃសេវាផ្ទេរប្រាក់សម្រាប់ធនាគារពាណិជ្ជ។	- ប្រកាសលេខ ធ៥-០១៤-០៦៨ ប្រ.ក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពី ការផ្ទេរប្រាក់ក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈធនាគារជាតិនៃកម្ពុជា។

- ប្រកាសលេខ ធ៩-៩៨-៣៨៦ ប្រ.ក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី ការយកកម្រៃសេវាសម្រាប់ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៩-៩៨-៤១១ ប្រ.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ តាមរយៈធនាគារជាតិនៃកម្ពុជា។ - សេចក្តីជូនដំណឹងលេខ ធ៥-០៧-១៨៦ ស.ជ.ណ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពី បែបបទផ្ទេរប្រាក់ទៅក្រៅប្រទេស។ - សេចក្តីជូនដំណឹងលេខ ធ៥-០៨-៥៦១ ស.ជ.ណ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ស្តីពី កម្រៃសេវាផ្ទេរប្រាក់ជារូបិយប័ណ្ណតាមរយៈធនាគារជាតិនៃកម្ពុជា។ - សេចក្តីជូនដំណឹងបន្ថែមលេខ ធ៥-០១១-០២៨៩ ស.ជ.ណ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ស្តីពី ការស្នើសុំផ្ទេរប្រាក់ទៅក្រៅប្រទេសតាមរយៈធនាគារជាតិនៃកម្ពុជា។	
- ប្រកាសលេខ ធ៧-០៩-០១៣ ប្រ.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីពី ការផ្តល់ឥណទានវិបារូបន៍ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន។	- ប្រកាសលេខ ធ៧-០១៥-១៥៣ ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០០-៣៨ ប្រ.ក ចុះថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ២០០០ ស្តីពី សាច់ប្រាក់ងាយស្រួលរបស់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ។ - ប្រកាសលេខ ធ៧-០២-១៨៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។	- ប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព។

- ប្រកាសលេខ ធ៧-០៤-២០៧ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។	
- ប្រកាសលេខ ធ៩-០១៣-១២៥ ប្រ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។ - ប្រកាសលេខ ធ៩-០១៥-០០៦ ប្រ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពី ការកែសម្រួលវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។	- ប្រកាសលេខ ធ១៥-០១៦-១៣៥ ប្រ.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីសភាជាត់ទាត់ជាតិ។
- សារាចរណែនាំលេខ ធ៧-០១០-០០១ ស.រ.ណ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ ស្តីពី ការកំណត់ចំណាត់ថ្នាក់វិនិយោគ។	- សារាចរណែនាំលេខ ធ៧-០១៦-០០៣ ស.រ.ច.ណ.ន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពី ការអនុវត្តប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០២-៤៩ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពី កាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការស្នើសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។	- ប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ។
- សារាចរណែនាំលេខ ធ៧-០៥-០០១ ស.រ.ណ.ន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ - សារាចរណែនាំលេខ ធ៧-០១០-០០២ ស.រ.ណ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យសម្រាប់សវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។	- ប្រកាសលេខ ធ៧-០១៧-៣៣៥ ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី សវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-៩៤-៧៨ ប្រ.ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ចំណាត់ថ្នាក់និងនយោបាយក្នុងការធ្វើសំវិធានវត្ថុនៃបំណុលរបស់ធនាគារពាណិជ្ជ។	- ប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។

- សារាចរណែនាំលេខ ធ៧-៩៤-០០២ ស.រ.ណ.ន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ចំណាត់ថ្នាក់និងនយោបាយក្នុងការធ្វើសំវិធានវត្ថុនៃបំណុលនៃធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៧-០០-៥១ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ។ - ប្រកាសលេខ ធ៧-០២-១៥៥ ប្រ.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១ ប្រ.ក ស្តីពី ចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ។ - សារាចរណែនាំលេខ ធ៧-០៤-០១ ស.រ.ណ.ន ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពី ឥណទានមិនដំណើរការ សំវិធានធន និងកិច្ចបញ្ជីការគណនេយ្យការប្រាក់។ - សារាចរណែនាំលេខ ធ៧-០៥-០១ ស.រ.ណ.ន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពី ការធ្វើចំណាត់ថ្នាក់និងសំវិធានធនចំពោះឥណទានសងរំលស់។ - ប្រកាសលេខ ធ៧-០៩-០៧៤ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ - ប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើឥណទានអនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។	

- សេចក្តីណែនាំលេខ ធ៥-០១៦-០០៥ ស.ក.ណ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ស្តីពី ការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា។	- សេចក្តីណែនាំលេខ ធ៥-០១៨-០០២ ស.ក.ណ.ន ចុះថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ ស្តីពី ការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។
- បទប្បញ្ញត្តិលេខ ធ៧-៩៧-០២ ប.ប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី វិសោធនកម្មលើលក្ខខណ្ឌនៃការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗដោយស្ថាប័នរូបិយវត្ថុ។ - ប្រកាសលេខ ធ៧-០៨-០៦៣ ប្រ.ក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារ។ - ប្រកាសលេខ ធ៧-០៩-០២០ ប្រ.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៧-០១២-១៤០ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។ - ប្រកាសលេខ ធ៧-០១៨-២៨២ ប្រ.ក ចុះថ្ងៃពុធ ៣រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។	- ប្រកាសលេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។
- ប្រកាសលេខ ធ៧-០៦-០៧៣ ប្រ.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ការប្រើប្រាស់និងការការពារព័ត៌មានឥណទាន។ - ប្រកាសលេខ ធ៧-០៦-១០១ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។	- ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចែករំលែកព័ត៌មានឥណទាន។

- ប្រកាសលេខ ធ៧-០៦-១០២ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ - ប្រកាសលេខ ធ៧-០៦-១០៣ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ - ប្រកាសលេខ ធ៧-០៦-១០៤ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ស្តីពី ការបង្កើតក្រុមប្រតិបត្តិនិងលេខាធិការដ្ឋាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ - ប្រកាសលេខ ធ៧-០១១-១៤៥ ប្រ.ក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពី ការចែករំលែកព័ត៌មានឥណទាន។	
- ប្រកាសលេខ ធ៩-៩៤-០១ ប្រ.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពី ការនាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ និងការនាំចេញរូបិយប័ណ្ណ។ - ប្រកាសលេខ ធ៩-៩៩-១០០ ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងអាជីវកម្មត្បូងថ្ម និងលោហធាតុមានតម្លៃ។ - ប្រកាសលេខ ធ៩-០៩-២៦២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ។	- ប្រកាសលេខ ធ៩-០២១-០៥២ ប្រ.ក ចុះថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ។
- ប្រកាសប្រកាសលេខ ធ៦-០៣-០១២ ប្រ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣ ស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ។	- ប្រកាសលេខ ធ៦-០២១-១៨៤ ប្រ.ក ចុះថ្ងៃចន្ទ ១២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពី ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ។

រៀបចំបោះពុម្ពដោយ ធនាគារជាតិនៃកម្ពុជា